# ព្រះ
# ត្រៃបិដក

## ប្រែរួមនឹង
## ព្រះអដ្ឋកថា

## ភាគ៤២

បាលីប្រែ ៥៦ - ៥៧

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី២

# ព្រះ

# សុត្តន្តបិដក

## និង

## បរមត្ថទីបនី អដ្ឋកថា

### សេចក្តីប្រែជាភាសាខ្មែរ

## ខុទ្ទកនិកាយ ថេរគាថា

## បញ្ចមភាគ

## ៤២

## បាលីប្រែ ៥៦-៥៧



*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# ក្បាលទី ៤២

# សុត្តន្តបិដក

# ថេរគាថា តិកនិបាត

## អង្គណិកភារទ្វាជត្ថេរគាថា

[ ១៧១ ] កាលខ្ញុំស្វែងរកសេចក្តីបរិសុទ្ធ ដោយខុសទំនង បានបម្រើភ្លើងក្នុងព្រៃ មិនទាន់ដឹងនូវផ្លូវនៃសេចក្តីបរិសុទ្ធហើយក៏ធ្វើនូវតបៈដទៃ ( ដែលញុំាងខ្លួនឲ្យលំបាក ) ។ និព្វានសុខនោះ អាត្មាអញបានដោយស្រួលហើយ អ្នកចូរមើលនូវភាពនៃធម៌ដ៏ល្អចុះ វិជ្ជា ៣ អាត្មាអញបានដល់ហើយដោយលំដាប់ សាសនារបស់ព្រះពុទ្ធ អាត្មាអញបានធ្វើហើយ ។ ពីដើម អាត្មាអញជាផៅពង្សនៃព្រហ្ម ( ជាព្រាហ្មណ៍ដោយសម្មតិ ) ឥឡូវនេះ អាត្មាជាព្រាហ្មណ៍មែន ព្រោះអាត្មាអញជាអ្នកបានវិជ្ជា ៣ ផង មានមន្ទិល គឺកិលេសបានលាងហើយផង ជាអ្នកមានសួស្តីផង ដល់នូវវេទផង ។

*អង្គណិកភារទ្វាជត្ថេរ*

# អដ្ឋកថា
# ថេរគាថា តិកនិបាត

## អង្គណិកភារទ្វាជត្ថេរគាថា

[ ១៧១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងតិកនិបាតដូចតទៅនេះ គាថារបស់ព្រះអង្គណិកភារទ្វាជត្ថេរ មានពាក្យផ្តើមថា **អយោនិសុទ្ធិមន្វេសំ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកមកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃវិវដ្តក្នុងភពនោះៗ ។ ក្នុងកប្បទី ៣១ រាប់ថយអំពីកប្បនេះ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមសិខី កុលបុត្តនេះ កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្តីហើយ ។ ថ្ងៃមួយ ឃើញព្រះសាស្តាយាងបិណ្ឌបាត មានចិត្តជ្រះថ្លា ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ហើយផ្គងអញ្ជលី ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅមកក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងផ្ទះរបស់ព្រាហ្មណ៍ ជាអ្នកសម្បូរដោយសម្បត្តិ ក្នុងឧក្កដ្ឋនគរ ជិតព្រៃហេមពាន្ត មានឈ្មោះថាអង្គណិកភារទ្វាជៈ ចម្រើនវ័យហើយ សិក្សាសម្រេចក្នុងវិជ្ជា និងសិប្បៈទាំងឡាយហើយ ព្រោះមានអធ្យាស្រ័យក្នុងនេក្ខម្មៈ ទើបបួសជាបរិព្វាជក បំពេញតបៈ

ដើម្បីអមតៈ ។ គ្រាច់ទៅមកក្នុងទីនោះៗ បានឃើញព្រះសម្មាសម្ពុទ្ធ កំពុងចារិកទៅកាន់ជនបទ មានចិត្តជ្រះថ្លា ស្តាប់ព្រះធម្មទេសនាក្នុងសម្នាក់ព្រះសាស្តា លះនូវការប្រកាន់ខុស បួសក្នុងសាសនា ចម្រើនវិបស្សនា ក្នុងកាលមិនយូរ ក៏បានជាព្រះខីណាស្រព ជាអ្នកមានអភិញ្ញា ៦ សមដូចគាថាព័ន្ធដែលលោកពោលក្នុងអបទានថា

ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានថ្វាយបង្គំព្រះពុទ្ធដ៏ប្រសើរ ព្រះនាមវេស្សភូ ជាឧសភៈដ៏ប្រសើរ ទ្រង់មានព្យាយាម ទ្រង់ឈ្នះមារ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយបង្គំ ។ ក្នុងកប្បទី ២៤ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ១ អង្គ ព្រះនាមវិគតានន្ទៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា៤ វិមោក្ខ៨ និងអភិញ្ញា៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១] ។

ម្យ៉ាងទៀត ព្រះថេរៈកាលសម្រេចអភិញ្ញា ៦ សម្ងំដោយវិមុត្តិសុខ ដើម្បីអនុគ្រោះញាតិទាំងឡាយ ទើបត្រឡប់ទៅកាន់ជាតិភូមិរបស់ខ្លួន ឲ្យញាតិជាច្រើនប្រតិស្ឋាននៅក្នុងសរណៈ និងសីលទាំងឡាយ ហើយត្រឡប់ចាកជាតិភូមិនោះ មកនៅក្នុងព្រៃ មិនឆ្ងាយអំពីនិគម ឈ្មោះកុណ្ឌិយៈ ក្នុងដែនកុរុ

---

១- ក្នុងអបទាន ជាឯកវន្ទនិយត្ថេរ ។

ហើយទៅកាន់ឧគ្គារាម ដោយករណីយកិច្ចឯណានីមួយ បានជួបពួកព្រាហ្មណ៍ដែលធ្លាប់ស្គាល់មកអំពីឧត្តរាបថនិគម ត្រូវព្រាហ្មណ៍ទាំងនោះសួរថា បពិត្រលោកម្ចាស់ការទ្វាជៈ លោកម្ចាស់ឃើញប្រយោជន៍អ្វី ទើបលះនូវលទ្ធិព្រាហ្មណ៍ កាន់យកលទ្ធិនេះ ដើម្បីចង្អុលបង្ហាញដល់ព្រាហ្មណ៍ទាំងនោះថា សេចក្តីបរិសុទ្ធក្រៅអំពីព្រះពុទ្ធសាសនានេះមិនមាន ដូច្នេះ ទើបបានពោលគាថាទី ១ ថា

កាលខ្ញុំស្វែងរកសេចក្តីបរិសុទ្ធ ដោយខុសទំនង បានបម្រើភ្លើងក្នុងព្រៃ មិនទាន់ដឹងនូវផ្លូវនៃសេចក្តីបរិសុទ្ធហើយ ក៏ធ្វើនូវតបៈដទៃ ( ដែលញុំាងខ្លួនឲ្យលំបាក ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អយោនិ** សេចក្តីថា ដោយមិនជាឧបាយ គឺមិនមែនដោយឧបាយ ។ បទថា **សុទ្ធឹ** បានដល់ **សំសារសុទ្ធិ** គឺការស្រុះចេញទៅអំពីភព ។ បទថា **អន្វេសំ** បានដល់ កាលស្វែងរក គឺកំពុងស្វែងរក ។ បទថា **អគ្គឹ បរិចរឹ វនេ** សេចក្តីថា ខ្ញុំធ្វើផ្ទះភ្លើង ហើយសរសេរការបូជា បម្រើព្រះអគ្គិទេព គឺបូជាតាមវិធីដែលពោលហើយ ក្នុងគម្ពីរវេទត្រង់ទីលំនៅក្នុងព្រៃ គឺរោងបូជាភ្លើង ដោយបំណងថា នេះជាផ្លូវនៃសេចក្តីបរិសុទ្ធ ។

បទថា **សុទ្ធិមគ្គំ អជានន្តោ អកាសឹ អមរំ តបំ** សេចក្តីថា កាលខ្ញុំមិនស្គាល់ផ្លូវនៃសេចក្តីបរិសុទ្ធ គឺព្រះនិព្វាន បានបំពេញ គឺបានប្រព្រឹត្តបានដល់ បដិបត្តិអត្តកិលមថានុយោគ មានការទូន្មានខ្លួនដោយតបៈ ៥

យ៉ាងជាដើម ដូចជាការបូជាភ្លើង ដោយយល់ថា ជាផ្លូវនៃសេចក្តីបរិសុទ្ធ ។

ព្រះថេរៈកាលសម្តែងថា សេចក្តីបរិសុទ្ធខាងក្រៅមិនមាន ព្រោះបុគ្គលដែលមិនចេញអំពីកាលបូជាភ្លើងជាដើម តាមវិធីដែលបានពោលក្នុងវេទ នឹងដល់នូវសេចក្តីបរិសុទ្ធមិនបាន ឥឡូវនេះ កាលសម្តែងថា សេចក្តីបរិសុទ្ធ ខ្ញុំបានសម្រេចក្នុងសាសនានេះប៉ុណ្ណោះ ដូចចេញពីអាស្រមមួយ ទៅកាន់អាស្រមមួយ យ៉ាងនេះហើយ ទើបបានពោលគាថាទី ២ ថា

និព្វានសុខនោះ អាត្មាអញបានដោយស្រួលហើយ អ្នកចូរមើល
នូវភាពនៃធម៌ដ៏ល្អចុះ វិជ្ជា ៣ អាត្មាអញបានដល់ហើយដោយ
លំដាប់ សាសនារបស់ព្រះពុទ្ធ អាត្មាអញបានធ្វើហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តំ** ជាដើម សេចក្តីថា ខ្ញុំតាមស្វែងរកនូវសេចក្តីបរិសុទ្ធិ ដើម្បីប្រយោជន៍ដល់ព្រះនិព្វានណា កាលមិនដឹងផ្លូវនៃព្រះនិព្វាននោះ ទើបបានបម្រើភ្លើង ទើបបានប្រព្រឹត្តអមរតបៈ ( តបៈដែលមិនស្លាប់ ) សេចក្តីសុខ គឺព្រះនិព្វាននោះ ខ្ញុំបានមកហើយ គឺដល់ហើយ បានដល់ សម្រេចហើយដោយងាយ គឺដោយសមថវិបស្សនា ដែលជាបដិបទាងាយៗ មិនអាស្រ័យអត្តកិលមថានុយោគ ។

បទថា **បស្ស ធម្មសុធម្មតំ** សេចក្តីថា ព្រះថេរៈអាងដល់ធម៌ ឬអាងដល់ខ្លួនឯងថា ចូរអ្នកមើលចុះ គឺចូរដឹងចុះនូវសាសនធម៌របស់ព្រះសាស្តាថាជាធម៌ល្អ គឺមានសភាពជានិយ្យានិកធម៌ កាលសម្តែងថា លោកបានធម៌នោះហើយ ទើបពោលថា វិជ្ជា ៣ អាត្មាអញបានដល់ហើយ ដោយលំដាប់

សាសនារបស់ព្រះពុទ្ធ អាត្មាអញបានធ្វើហើយ ដូច្នេះ ។

ពាក្យនោះ មានអធិប្បាយដូចបានពោលមកហើយនោះឯង ។ ព្រះថេរៈកាលសម្តែងថា តាំងអំពីនេះទៅ ខ្ញុំជាព្រាហ្មណ៍ដោយបរមត្ថ ព្រោះសម្រេចសេចក្តីបរិសុទ្ធដោយប្រការយ៉ាងនេះ ទើបពោលគាថាទី ៣ ថា

ពីដើម អាត្មាអញជាផៅពង្សនៃព្រហ្ម ( ជាព្រាហ្មណ៍ដោយ
សម្មតិ ) ឥឡូវនេះ អាត្មាជាព្រាហ្មណ៍មែន ព្រោះអាត្មាអញជា
អ្នកបានវិជ្ជា ៣ ផង មានមន្ទិល គឺកិលេសបានលាងហើយផង
ជាអ្នកមានសួស្តីផង ដល់នូវវេទផង ដូច្នេះ ។

គាថានេះមានអត្ថថា កាលមុន ខ្ញុំបានឈ្មោះថា ជាផៅពង្សរបស់ព្រហ្មតាមសទ្ទតរបស់ពួកព្រាហ្មណ៍ ព្រោះជាព្រាហ្មណ៍ដោយកំណើត តែឥឡូវនេះខ្ញុំជាព្រាហ្មណ៍ដោយបរមត្ថ ព្រោះបានសម្រេចអរហត្តហើយ ព្រោះមានបាបបន្សាត់ហើយ អធិប្បាយថា មុននេះ ខ្ញុំឈ្មោះថា ជាអ្នកមានវិជ្ជា ៣ត្រឹមតែឈ្មោះ ព្រោះរៀនវិជ្ជា ៣ ពោល គឺវេទ ៣ ដែលធ្វើការសន្សំភពតែឥឡូវនេះ ខ្ញុំមានវិជ្ជា ៣ ដោយបរមត្ថ ព្រោះបានសម្រេចវិជ្ជា ៣ ដោយអំណាចនៃវិជ្ជា ដែលធ្វើឲ្យអស់ភព ។

ម្យ៉ាងទៀត មុននេះ ខ្ញុំឈ្មោះថា ជាអ្នកលាងបាបហើយត្រឹមតែឈ្មោះព្រោះសម្រេចដោយវត្តរបស់អ្នកងូតទឹក ដែលប្រកាន់ដោយការគាប់ចិត្តក្នុងភព តែឥឡូវនេះ បានឈ្មោះថា ជាអ្នកលាងបាបហើយដោយបរមត្ថ ព្រោះមន្ទិល គឺកិលេស ត្រូវលាងស្អាតហើយ ដោយផលដែលកើតអំពីអដ្ឋង្គិក-

មគ្គ ។

កាលមុន ខ្ញុំឈ្មោះថា ជាអ្នកមានសួស្តី ដោយហេតុត្រឹមតែការហៅ ព្រោះការរៀនមន្តដែលមានការពេញចិត្តក្នុងភព មិនទាន់រួចផុតទៅ តែឥឡូវនេះ បានឈ្មោះថា ជាអ្នកមានសួស្តីដោយបរមត្ថ ព្រោះការរៀនធម៌ ដែលធ្វើឲ្យផុតចាកការគាប់ចិត្តក្នុងភព ។

កាលមុន ខ្ញុំឈ្មោះថា ជាអ្នកចប់វេទ ដោយហេតុត្រឹមតែចប់វេទ ដែលរលាស់បាបធម៌ចេញមិនបាន តែឥឡូវនេះ ក្លាយជាអ្នកចប់វេទដោយបរមត្ថ ព្រោះទៅដល់ គឺដល់ បានដល់ ស្គាល់ត្រើយនៃអន្លង់ធំ គឺសង្សារ ដោយមគ្គញាណ ពោល គឺវេទ និងត្រើយនៃវេទ គឺសច្ចៈ ៤ ។

ព្រាហ្មណ៍ទាំងឡាយ កាលបានស្តាប់ពាក្យនោះហើយ នាំគ្នាប្រកាសការជ្រះថ្លាក្រៃលែង ក្នុងព្រះពុទ្ធសាសនា ។

**អដ្ឋកថា អង្គណិកភារទ្វាជត្ថេរគាថា ចប់**

# សុត្តន្តបិដក

## បច្ចយត្ថេរគាថា

[ ១៧២ ] ខ្ញុំបួសបាន ៥ ថ្ងៃ នៅជាសេក្ខបុគ្គល មិនទាន់សម្រេចព្រះអរហត្តនៅឡើយ កាលខ្ញុំចូលទៅក្នុងកុដិ មានចិត្តតាំងមាំថា អាត្មាអញនឹងមិនបរិភោគ នឹងមិនផឹក មិនចេញអំពីកុដិ កាលបើសរ គឺតណ្ហា អាត្មាអញមិនទាន់ដកចេញទេ អាត្មាអញនឹងមិនប្រែបន្ទៀងឡើយ ។ អ្នកចូរមើលសេចក្តីព្យាយាមប្រឹងប្រែងរបស់ខ្ញុំនោះ កាលនៅយ៉ាងនេះចុះ វិជ្ជា ៣ អាត្មាអញបានដល់ដោយលំដាប់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ អាត្មាអញក៏បានធ្វើហើយ ។

បច្ចយត្ថេរ

# អដ្ឋកថា

## បច្ចយត្ថេរគាថា

[ ១៧២ ] គាថារបស់ព្រះបច្ចយត្ថេរ មានពាក្យផ្តើមថា **បញ្ចាហាហំ បព្វជិតោ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្តុប្បត្តិហេតុដូចម្តេចបានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាម

វិបស្សី កុលបុត្តនេះកើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្តីហើយ ។ ថ្ងៃមួយ បានឃើញព្រះសាស្តាកំពុងយាងទៅកាន់ស្ទឹងឈ្មោះវិនតា មានចិត្តជ្រះថ្លា បានបេះផ្លែល្វាធំៗ មានរសឆ្ងាញ់ពិសា បង្អោនចូលទៅថ្វាយ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅមកក្នុងសុគតិប៉ុណ្ណោះ ក្នុងភទ្ទកប្បនេះ ព្រះសម្មាសម្ពុទ្ធព្រះនាមកស្សបៈ កើតឡើងក្នុងលោក ទ្រង់ប្រកាសធម្មចក្រ ទ្រង់អនុគ្រោះវេនេយ្យជន កុលបុត្តនោះបួសនៅក្នុងសាសនារបស់ព្រះអង្គ បំពេញវិបស្សនា ប្រកបភាវនារឿយៗ ។ ថ្ងៃមួយ គិតដល់ទុក្ខក្នុងសង្សារ កើតសេចក្តីសង្វេគក្រៃលែង អង្គុយក្នុងវិហារ អធិដ្ឋានថា បើអញមិនសម្រេចអរហត្ត នឹងមិនចេញអំពីទីនេះ កាលព្យាយាម ក៏មិនអាចឲ្យវិបស្សនាជាន់ខ្ពស់កើតឡើងបាន ព្រោះញាណមិនទាន់ចាស់ក្លា ធ្វើនូវមរណកាលហើយ អន្ទោលទៅមកក្នុងទេវតា និងមនុស្សទាំងឡាយ ។ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងខត្តិយត្រកូល នានគររោហិណី បានទទួលនាមថា បច្ចយៈ ទ្រង់ចម្រើនវ័យហើយ អស់វជ្ជកាលរបស់ព្រះជនក ក៏បានឡើងសោយរាជសម្បត្តិ ។ ថ្ងៃមួយ ទ្រង់ប្រារព្ធរាជពលីយ៉ាងធំ មហាជនបានមកប្រជុំគ្នាក្នុងទីនោះ ។ ដើម្បីឲ្យកើតសេចក្តីជ្រះថ្លាដល់មហាជន ក្នុងសមាគមនោះ ព្រះសាស្តាទ្រង់គង់លើរតនសីហាសនៈ ក្នុងរតនកូដាគារ ដែលព្រះបាទវេស្សវ័ណនិម្មិតថ្វាយលើអាកាស ទ្រង់បានសម្តែងធម៌ដល់មហាជនដែលកំពុងមើលនោះឯង ។ ការសម្រេចធម៌ មានដល់ប្រជុំមហាជនហើយ ។

ព្រះបាទបច្ចយរាជ កាលទ្រង់ស្តាប់ព្រះធម្មទេសនាហើយ ទ្រង់បានលះ

រាជសម្បត្តិ ត្រូវហេតុក្នុងកាលមុនដាស់តឿន ទើបទ្រង់សាងព្រះផ្នួស ។ ព្រះរាជាបានធ្វើប្ដេជ្ញា ( អធិដ្ឋាន ) ដូចដែលធ្លាប់បានធ្វើហើយ ក្នុងសាសនារបស់ព្រះមានព្រះភាគ ព្រះនាមកស្សបៈ ទ្រង់ចូលក្នុងព្រះវិហារ ចម្រើនវិបស្សនាហើយ បានសម្រេចអរហត្តក្នុងរំពេចនោះឯង ព្រោះព្រះញាណដល់នូវភាពចាស់ក្លា ។ សមដូចគាថាព័ន្ធដែលលោកពោលក្នុងអបទានថា

ព្រះពុទ្ធជាបុរសខ្ពង់ខ្ពស់ គង់នៅទៀបឆ្នេរស្ទឹងនិន្នគា ខ្ញុំបានឃើញព្រះពុទ្ធ ព្រះអង្គប្រាសចាកធូលី គឺរាគៈ មានព្រះហឫទ័យតម្កល់មាំ មានអារម្មណ៍តែមួយ ។ ខ្ញុំមានចិត្តជ្រះថ្លាចំពោះព្រះសម្ពុទ្ធនោះ ព្រះអង្គលាងមន្ទិល គឺកិលេស ខ្ញុំក៏បានយកផ្លែឧទុម្ពរ ថ្វាយដល់ព្រះសម្ពុទ្ធដ៏ប្រសើរ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ ឱ ដំណើរដែលខ្ញុំមក ក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយដោយលំដាប់ ពុទ្ធសាសនា ខ្ញុំក៏បានធ្វើហើយ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ(១) ។

ម្យ៉ាងទៀត កាលសម្រេចអរហត្តហើយ ដើម្បីព្យាករអរហត្តផលដោយបំណងប្រាប់បដិបទារបស់ខ្លួន ទើបបានភាសិត ៣ គាថាដូច្នេះថា

---

១- ក្នុងអបទានជា ឧទុម្ពរផលទាយកត្ថេរ ។

ខ្ញុំបួសបាន ៥ ថ្ងៃ នៅជាសេក្ខបុគ្គល មិនទាន់សម្រេចព្រះអរហត្តនៅឡើយ កាលខ្ញុំចូលទៅក្នុងកុដិ មានចិត្តតាំងមាំថា អាត្មាអញនឹងមិនបរិភោគ នឹងមិនផឹក មិនចេញអំពីកុដិ កាលបើសរ គឺតណ្ហា អាត្មាអញមិនទាន់ដកចេញទេ អាត្មាអញនឹងមិនប្រែបង្អៀងឡើយ ។ អ្នកចូរមើលសេចក្ដីព្យាយាម ប្រឹងប្រែងរបស់ខ្ញុំនោះ កាលនៅយ៉ាងនេះចុះ វិជ្ជា ៣ អាត្មាអញបានដល់ដោយលំដាប់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ អាត្មាអញក៏បានធ្វើហើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បញ្ចាហាហំ បព្វជិតោ** សេចក្ដីថា ខ្ញុំជាព្រះសេក្ខៈ ៥ ថ្ងៃ គឺបួសហើយ ៥ ថ្ងៃ អធិប្បាយថា ផុតថ្ងៃទី ៥ ទៅហើយ ។

បទថា **សេក្ខោ អប្បត្តមានសោ** សេចក្ដីថា ឈ្មោះថា **សេក្ខោ** ព្រោះសិក្សាអធិសីលសិក្ខាជាដើម ។ ធម៌ណាកាត់នូវមានះ គឺដកនូវមានះបានដោយមិនមានសេសសល់ ព្រោះហេតុនោះ ទើបធម៌នោះ ឈ្មោះថា **មានស** បានដល់ មគ្គដ៏កំពូល គឺអរហត្តមគ្គ ។ មួយវិញទៀត ធម៌ដែលមកអំពីមានសៈ ( អគ្គមគ្គ ) ដោយកើតអំពីមានសៈនោះ ឈ្មោះថា **មានស** បានដល់ អរហត្តផល ។ នូវអរហត្តផលនោះ ។ អគ្គមគ្គនោះដែលបុគ្គលនោះមិនទាន់បានសម្រេច ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះថា **អប្បត្តមានសោ** គឺមិនទាន់សម្រេចអរហត្តផល ។

បទថា **វិហារំ មេ បវិដ្ឋស្ស ចេតសោ បណិធី អហុ** សេចក្តីថា កាលខ្ញុំជាព្រះសេក្ខៈចូលទៅកាន់វិហារដែលជាលំនៅ គឺកុដិយ៉ាងនេះ មាន ការតាំងចិត្តដូចកំពុងពោលក្នុងឥឡូវនេះ អធិប្បាយថា ខ្ញុំតាំងចិត្តយ៉ាងនេះ ។

បទថា **នាសិស្សំ** ជាដើមនេះ លោកសម្តែងដល់ការតាំងចិត្ត ។ បណ្តា បទទាំងនោះ បទថា **នាសិស្សំ** សេចក្តីថា ខ្ញុំមិនឆាន់ គឺមិនបរិភោគភោជន ណាមួយ ក្នុងកាលខ្ញុំដកនូវព្រួញ គឺតណ្ហាដែលដោតក្នុងចិត្តមិនបាន គឺដក មិនទាន់បាន ។ អ្នកសិក្សាគួរប្រកបពាក្យដូចពោលមកនេះចូលក្នុងគ្រប់ៗ បទ ។ បទថា **ន បិវិស្សាមិ** សេចក្តីថា ខ្ញុំនឹងមិនផឹកទឹកណាមួយដែលគួរផឹក ។ បទថា **វិហារតោ ន និក្ខមេ** សេចក្តីថា ខ្ញុំនឹងមិនចេញអំពីទីនេះ គឺចាក បន្ទប់ដែលខ្ញុំអង្គុយហើយក្នុងខណៈនេះ ។

បទថា **នបិ បស្សំ និបាតេស្សំ** សេចក្តីថា បណ្តាឆ្អឹងជំនីរទាំងពីរនៃ សរីរៈរបស់ខ្ញុំ សូម្បីតែម្ខាងក៏មិនទម្រេត ដើម្បីបន្ទោបង់សេចក្តីចុកស្រពន់ នៃកាយ អធិប្បាយថា នឹងមិនដេកសូម្បីត្រឹមមួយចំហៀង ។ បទថា **តស្ស មេវំ វិហារតោ** សេចក្តីថា កាលខ្ញុំតាំងចិត្តយ៉ាងនេះហើយ នៅសម្ងំដោយ អំណាចនៃការតាំងវិរិយាធិដ្ឋានយ៉ាងមាំ ហើយបំពេញវិបស្សនា ។

បទថា **បស្ស វីរិយបរក្កមំ** សេចក្តីថា ចូរអ្នកមើល គឺដឹងនូវការ ព្យាយាមដែលឲ្យកើតឧស្សាហៈ ដែលបានឈ្មោះថា **វីរិយ** ព្រោះត្រូវប្រព្រឹត្ត ទៅឲ្យត្រូវវិធី និងដែលបានឈ្មោះថា **បរក្កម** ព្រោះឈានទៅខាងមុខ គឺ សេចក្តីព្យាយាមដែលមានអានុភាព ដូចខ្ញុំពោលហើយថា វិជ្ជា ៣ ខ្ញុំបាន ដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយនោះឯង ។ល។

# សុត្តន្តបិដក

## ពាកុលត្ថេរគាថា

[ ១៧៣ ] បុគ្គលណា ( មិនធ្វើ ) នូវអំពើដែលគួរធ្វើ ក្នុងកាលមុន ហើយចង់ធ្វើក្នុងកាលក្រោយវិញ បុគ្គលនោះ រមែងឃ្លាតចាកឋានៈជាសុខ ផង តែងក្តៅក្រហាយរឿយៗ ក្នុងកាលជាខាងក្រោយផង ។ បុគ្គលធ្វើអំពើណា ត្រូវនិយាយតែអំពើនោះ មិនធ្វើអំពើណា មិនត្រូវនិយាយអំពើនោះឡើយ បណ្ឌិតទាំងឡាយ តែងកំណត់ដឹងច្បាស់ នូវបុគ្គលកាលមិនធ្វើ បានតែនិយាយ ។ សេចក្តីទុក្ខរលត់ទៅក្នុងព្រះនិព្វានណា ព្រះនិព្វាននោះ ដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងហើយ ជាគុណជាតិមិនមានសេចក្តីសោក ប្រាសចាកធូលី ជាទីក្សេមក្សាន្ត នាំមកនូវសេចក្តីសុខ ដោយប្រពៃមែនពិត ។

ពាកុលត្ថេរ

---

# អដ្ឋកថា

## ពាកុលត្ថេរគាថា

[ ១៧៣ ] គាថារបស់ព្រះពាកុលត្ថេរ មានពាក្យផ្តើមថា **យោ បុព្វេ ករណីយានិ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះ ក្នុងអតីតកាល គឺក្នុងទីបំផុតមួយអសង្ខេយ្យ

និងមួយសែនកប្ប រាប់អំពីកប្បនេះ មុនព្រះមានព្រះភាគព្រះនាមអនោមទស្សី ទ្រង់កើតឡើងនោះឯង កើតក្នុងត្រកូលព្រាហ្មណ៍ ចម្រើនវ័យហើយ រៀនចប់ត្រៃវេទ មិនឃើញសារៈក្នុងត្រៃវេទនោះ ទើបបួសជាឥសី ដោយគិតថា អញនឹងស្វែងរកប្រយោជន៍ខាងមុខ ស្នាក់នៅត្រង់ជើងភ្នំ សម្រេចអភិញ្ញា ៥ និងសមាបត្តិ ៨ បានដឹងដំណឹងនៃការកើតឡើងរបស់ព្រះពុទ្ធ ទើបទៅគាល់ព្រះសាស្ដា ស្ដាប់ព្រះធម្មទេសនាហើយ តាំងនៅក្នុងសរណៈ កាលព្រះសាស្ដាប្រឈួនព្រះនាភី បាននាំថ្នាំអំពីព្រៃមកថ្វាយ ឲ្យព្រះរោគស្ងប់ហើយ បានបង្អោន ( អធិដ្ឋាន ) នូវបុណ្យក្នុងការថ្វាយថ្នាំនោះ ដើម្បីជាប្រយោជន៍ដល់ការមិនមានរោគ ចុតិអំពីអត្តភាពនោះ កើតក្នុងព្រហ្មលោក អន្ទោលទៅមកក្នុងទេវតា និងមនុស្សទាំងឡាយ អស់មួយអសង្ខេយ្យ ក្នុងសាសនាព្រះបទុមុត្តរៈ បានកាន់យកកំណើតក្នុងផ្ទះមានត្រកូល នាននគរហង្សវតី ឃើញព្រះសាស្ដាទ្រង់តែងតាំងភិក្ខុមួយរូប ឲ្យតាំងនៅក្នុងតំណែងឯតទគ្គៈជាងភិក្ខុទាំងឡាយ អ្នកមានអាពាធតិច ខ្លួនឯងត្រូវការតំណែងនោះ បានសន្សំបុណ្យជរាបដល់អស់ជីវិត ហើយតាំងបណិធាន អន្ទោលទៅមកក្នុងសុគតិតែម្យ៉ាង ។ មុនព្រះមានព្រះភាគព្រះនាមវិបស្សី ទ្រង់កើតឡើងក្នុងលោកនោះឯង កើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងនគរពន្ធុមតី បួសជាឥសីតាមន័យមុននោះឯង បានឈាន និងអភិញ្ញា នៅអាស្រ័យត្រង់ជើងភ្នំ បានដំណឹងថា ព្រះពុទ្ធកើតឡើងហើយក្នុងលោក បានទៅកាន់សម្នាក់ព្រះសាស្ដា ស្ដាប់ព្រះធម្មទេសនាហើយ តាំងនៅក្នុងសរណៈ កាលភិក្ខុទាំងឡាយកើតនូវ

អាពាធ ព្រោះស្មៅ និងផ្កាឈើ តាបសព្យាបាលរោគឲ្យស្ងប់ហើយ នៅទីនោះដរាបដល់អស់ជីវិត ចុតិអំពីជាតិនោះ ទៅកើតក្នុងព្រហ្មលោក អន្ទោលទៅមកក្នុងទេវតា និងមនុស្ស អស់ ៩១ កប្ប ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមកស្សបៈ បានកើតក្នុងផ្ទះមានត្រកូល ក្នុងនគរពារាណសី គ្រប់គ្រងផ្ទះ ឃើញវត្តចាស់ៗ ទើបសាងទីលំនៅគ្រប់យ៉ាង មានរោងឧបោសថជាដើម ផ្សំថ្នាំគ្រប់ប្រភេទថ្វាយសង្ឃក្នុងវត្តនោះ ។ សាងកុសលដរាបដល់អស់ជីវិត អន្ទោលទៅមកក្នុងទេវតា និងមនុស្ស ដរាបអស់មួយពុទ្ធន្តរ មុនព្រះមានព្រះភាគនៃយើងកើតឡើងនោះឯង កុលបុត្តនេះ កើតក្នុងផ្ទះរបស់សេដ្ឋី ក្នុងនគរកោសម្ពី ។

ពួកកីលៀងកំពុងងូតទឹកឲ្យក្នុងស្ទឹងធំ ឈ្មោះយមុនា ដើម្បីភាពមិនមានរោគ ត្រូវត្រីត្របាក់អំពីដៃរបស់កីលៀង កាលត្រីដល់ដៃរបស់អ្នកនេសាទ កិរិយារបស់សេដ្ឋីនគរពារាណសីទិញយក វះពោះត្រី ឃើញទារកមិនមានអន្តរាយ ព្រោះកម្លាំងបុណ្យ ទើបទទួលយកធ្វើជាកូន ហើយចិញ្ចឹមរក្សា កុលបុត្តនោះបានឈ្មោះថា **ពាក្កុលៈ** ព្រោះមានត្រកូល ២ ។ កាលមាតាបិតាបង្កើតជ្រាបដំណឹងនោះហើយ សួររឿយៗ ថា ក្មេងនេះ ជាកូនរបស់ខ្ញុំ សូមឲ្យកូនដល់ពួកខ្ញុំ ។ ព្រះរាជាទ្រង់វិនិច្ឆ័យឲ្យនៅក្នុងឋានៈជាទាយាទនៃត្រកូលទាំង ២ ថា ទារកនេះ ចូរជាសម្បត្តិនៃត្រកូលទាំង ២ ។ កុលបុត្តនោះចម្រើនវ័យហើយ បានបរិភោគសម្បត្តិសន្ទឹកសន្ទាប់ ដោយទ្រព្យ ៨០ កោដិ បានស្តាប់ធម្មទេសនាក្នុងសម្នាក់ព្រះសាស្តាហើយ បាននូវសទ្ធា បួស

ហើយ នៅជាបុថុជ្ជន ៧ ថ្ងៃប៉ុណ្ណោះ លុះអរុណថ្ងៃទី ៨ រះឡើង ក៏បាន សម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទា ។ សមដូចគាថាព័ន្ធដែលលោក ពោលក្នុងអបទានថា

ភ្នំឈ្មោះសោភិតៈ នៅក្នុងទីជិតនៃព្រៃហិមពាន្ត អាស្រមដ៏ល្អ របស់ខ្ញុំ គឺពួកសិស្សរបស់ខ្ញុំកសាងហើយ ។ មណ្ឌបទាំងឡាយ ជាច្រើន ដើមឈើភ្លើងមានផ្ការីក ក៏មានក្នុងទីនោះ ដើមខ្វិត ដើមច្បា ដើមខ្ទឹង ដើមរំចេក ក៏មានក្នុងទីនោះជាច្រើន ដើមចង្អេរ ទ្រាយ ដើមពុទ្រា ដើមកន្ទួតព្រៃ ដើមមាក់ប្រាង វល្លិឃ្លោក ដើមស្វាយសមានផ្ការីក ក៏មានក្នុងទីនោះជាច្រើន ដើមរាក់ស ដើមធ្នោ ដើមចេក ដើមក្រូចថ្លុង ក៏មានក្នុងទីនោះ ដើមជន្ទាត់ដៃ ដើមអង្គ្រង ដើមប្រយង្គុ ក៏មានច្រើនក្នុងទីនោះ ។ ដើមស្រូល ដើមស្រល់ ដើមកុម្ភ ដើមជ្រៃក្រឹម ដើមក្រសាំង ( ក៏មានក្នុង ទីនោះ ) អាស្រមរបស់ខ្ញុំប្រាកដយ៉ាងនេះ ខ្ញុំ ព្រមទាំងពួកសិស្ស ក៏នៅក្នុងអាស្រមនោះ ។ ព្រះមានព្រះភាគ ព្រះនាមអនោមទស្សី ជាសយម្ភូលោកនាយក ទ្រង់ស្វែងរកទីសម្រាប់ពួនសម្ងំ ស្តេច បានចូលមកកាន់អាស្រមរបស់ខ្ញុំ ។ លុះព្រះអនោមទស្សី ព្រះអង្គ មានព្យាយាមច្រើន មានយសធំ កំពុងស្តេចចូលមក អាពាធ បណ្តាលអំពីខ្យល់ ក៏បានតាំងឡើងដល់ព្រះលោកនាថ ក្នុងមួយ រំពេច ។ ខ្ញុំ កាលត្រាច់ទៅក្នុងព្រៃ បានឃើញព្រះលោកនាយក

ក៏ចូលមកជិតព្រះសម្ពុទ្ធ ទ្រង់មានចក្ខុ មានយសច្រើន ។ លុះខ្ញុំបានឃើញឥរិយាបថ ក៏កំណត់ទុកក្នុងកាលនោះថា ព្យាធិទាំងឡាយ ពិតជានឹងកើតដល់ព្រះពុទ្ធ ដោយឥតសង្ស័យ ។ ខ្ញុំបានត្រឡប់មកកាន់អាស្រម ដោយប្រញាប់ប្រញាល់ ខ្ញុំមានបំណងនឹងធ្វើថ្នាំ ក្នុងសម្នាក់ពួកសិស្សរបស់ខ្ញុំ ខ្ញុំបានហៅពួកសិស្សក្នុងកាលនោះ ។ ពួកសិស្សទាំងអស់ ជាអ្នកមានសេចក្តីគោរព បានទទួលស្តាប់ពាក្យរបស់ខ្ញុំ ហើយមកប្រជុំ ក្នុងទីជាមួយគ្នា ព្រោះពួកសិស្សទាំងនោះ ជាអ្នកមានសេចក្តីគោរពដល់ខ្ញុំជាគ្រូ ។ ខ្ញុំបានឡើងភ្នំជាប្រញាប់ ហើយបានធ្វើនូវឱសថទាំងអស់ ខ្ញុំធ្វើផ្សំនឹងទឹកសម្រាប់ផឹក បានថ្វាយដល់ព្រះពុទ្ធដ៏ប្រសើរ ។ កាលព្រះសព្វញ្ញូ លោកនាយក មានព្យាយាមធំ កាលទ្រង់សោយហើយ រោគខ្យល់នៃព្រះសុគត ទ្រង់ស្វែងរកគុណដ៏ធំ ក៏បានស្ងប់រម្ងាប់យ៉ាងឆាប់ ។ ព្រះអនោមទស្សី មានយសច្រើន ទ្រង់ឃើញសេចក្តីក្រវល់ក្រវាយស្ងប់រម្ងាប់ហើយ ទ្រង់គង់លើអាសនៈរបស់ព្រះអង្គ រួចទ្រង់ពោលនូវគាថាទាំងនេះថា បុរសណា បានប្រគេនភេសជ្ជៈដល់តថាគតផង បានរម្ងាប់ព្យាធិរបស់តថាគតផង តថាគតនឹងសរសើរបុរសនោះ អ្នកទាំងឡាយ ចូរស្តាប់ភាសិតដែលតថាគតនឹងសម្តែងចុះ ។ បុរសនេះ នឹងត្រេកអរក្នុងទេវលោក អស់មួយសែនកប្ប នឹងរីករាយក្នុងការប្រគំ តន្ត្រីក្នុង

ទេវលោកនោះ សព្វកាល ។ លុះត្រឡប់មកកាន់មនុស្សលោកវិញ ត្រូវកុសលមូលជាស់តឿន នឹងបានជាស្តេចចក្រពត្តិ អស់មួយពាន់ដង ។ ក្នុងកប្បទី ៥៥ បុរសនេះ នឹងបានកើតជាក្សត្រសោយ-រាជ្យ ព្រះនាមអនោមិ ជាធំក្នុងជម្ពូទ្វីប ជាធំលើផែនដី ឈ្មោះសង្គ្រាម មានសមុទ្រទាំង ៤ ជាទីបំផុត ។ នឹងបានជាស្តេចចក្រពត្តិ បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ញុំាងទេវតាក្នុងឋានតាវត្តិង្សឲ្យកម្រើក ហើយនឹងសោយនូវឥស្សរ-ភាព ។ បុរសនេះ ទោះនឹងកើតជាទេវតាក្តី ជាមនុស្សក្តី នឹងមិនមានអាពាធ នឹងវៀរបង់នូវព្យាធិ ជាគ្រឿងក្តៅក្រហាយ ក្នុងលោក ។ ក្នុងកប្បប្រមាណមិនបាន អំពីកប្បនេះ ព្រះសាស្តាព្រះនាមគោតម ទ្រង់នឹងសម្ភពក្នុងត្រកូលនៃស្តេចឱក្កាកៈ ទ្រង់ត្រាស់ឡើងក្នុងលោក ។ ឯបុរសនេះ នឹងបានជាអ្នកទទួលនូវមត៌កក្នុងធម៌របស់ព្រះសាស្តានោះ ជាឱរសដែលធម៌និម្មិតហើយ ហើយកំណត់ដឹងអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។ បុរសនេះ នឹងដុតនូវកិលេសទាំងឡាយ ហើយឆ្វងនូវខ្សែនៃតណ្ហា នឹងបានទីជាសាវកនៃព្រះសាស្តា ឈ្មោះពក្កុលៈ ។ ព្រះមានព្រះភាគ ព្រះនាមគោតម ជាសក្យៈប្រសើរ ទ្រង់បានជ្រាបនូវដំណើរទាំងអស់នេះ ទ្រង់គង់ក្នុងពួកភិក្ខុ នឹងតាំងពក្កុលភិក្ខុក្នុងទីជាឯតទគ្គៈ ។ ព្រះមានព្រះភាគព្រះនាមអនោមទស្សី ជាសយម្ភូ

លោកនាយក ទ្រង់ប្រមើលមើលសេចក្ដីស្ងប់ស្ងាត់ ក៏បានស្ដេចចូលមកអាស្រមរបស់ខ្ញុំ ។ លុះព្រះសព្វញ្ញូ ជាលោកនាយក ទ្រង់មានព្យាយាមធំ ស្ដេចចូលមកដល់ហើយ ខ្ញុំក៏ជ្រះថ្លា បានញុំាងព្រះអង្គឲ្យឆាន់ឆ្អែតស្កប់ស្កល់ ដោយឱសថទាំងពួង ដោយដៃរបស់ខ្លួន ។ ខ្ញុំនោះបានធ្វើអំពើល្អហើយ ចំពោះបុញ្ញក្ខេត្តដ៏ល្អ ខ្ញុំមិនអាចញុំាងអំពើដែលខ្ញុំធ្វើល្អហើយ ក្នុងកាលនោះ ឲ្យអស់ទៅបាន ព្រោះការដល់ព្រមដោយពូជ ។ ខ្ញុំឈ្មោះថា មានលាភ អត្តភាពជាមនុស្ស ឈ្មោះថា ខ្ញុំបានល្អហើយ ដ្បិតខ្ញុំបានឃើញព្រះនាយក ខ្ញុំក៏បានដល់នូវអចលបទ គឺព្រះនិព្វាន ដោយសំណល់នៃកម្មនោះឯង ។ ព្រះគោតមជាសក្យៈដ៏ប្រសើរ ទ្រង់បានជ្រាបដំណើរទាំងអស់នេះ ទ្រង់តាំងខ្ញុំក្នុងពួកភិក្ខុ ហើយតាំងខ្ញុំក្នុងទីជាឯតទគ្គៈ ។ ក្នុងកប្បប្រមាណមិនបាន អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃភេសជ្ជៈ ។ កិលេសទាំងឡាយ ខ្ញុំដុតបោលហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ម្យ៉ាងទៀត កាលបានសម្រេចអរហត្តហើយ ថ្ងៃមួយ ព្រះសាស្ដាទ្រង់បានតាំងព្រះថេរៈក្នុងតំណែងជាកំពូលលើសភិក្ខុទាំងឡាយ ខាងមានអាពាធ

---

១- ក្នុងអបទាន ជាពក្កុលត្ថេរ ។

តិច កាលនឹងព្យាករអរហត្តផល ដោយប្រាថ្នានឹងពោលទូន្មានភិក្ខុទាំងឡាយ ត្រង់កណ្តាលជំនុំសង្ឃ ក្នុងសម័យបរិនិព្វាន បានពោល ៣ គាថាថា

បុគ្គលណា ( មិនធ្វើ ) នូវអំពើដែលគួរធ្វើក្នុងកាលមុន ហើយចង់ធ្វើក្នុងកាលក្រោយវិញ បុគ្គលនោះ រមែងឃ្លាតចាកឋានៈជាសុខផង តែងក្តៅក្រហាយរឿយៗ ក្នុងកាលជាខាងក្រោយផង ។ បុគ្គលធ្វើអំពើណា ត្រូវនិយាយតែអំពើនោះ មិនធ្វើអំពើណា មិនត្រូវនិយាយអំពើនោះឡើយ បណ្ឌិតទាំងឡាយ តែងកំណត់ដឹងច្បាស់នូវបុគ្គលកាលមិនធ្វើ បានតែនិយាយ ។ សេចក្តីទុក្ខរលត់ទៅក្នុងព្រះនិព្វានណា ព្រះនិព្វាននោះ ដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងហើយ ជាគុណជាតិ មិនមានសេចក្តីសោក ប្រាសចាកធូលី ជាទីក្សេមក្សាន្ត នាំមកនូវសេចក្តីសុខ ដោយប្រពៃមែនពិត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យោ បុព្វេ ករណីយានិ បច្ឆា សោ កាតុមិច្ឆតិ** សេចក្តីថា បុគ្គលណាកាលមុន គឺមុនជរា និងរោគជាដើមគ្របសង្កត់ មិនធ្វើកិច្ចដែលគួរធ្វើ ដែលនាំប្រយោជន៍ និងសេចក្តីសុខមកឲ្យដល់ខ្លួន ដោយសេចក្តីប្រមាទ ខាងក្រោយ គឺហួសពេល ត្រូវធ្វើហើយទើបចង់ធ្វើ ។ បទថា **សោ** ត្រឹមតែជានិបាត ។ តែក្នុងកាលនោះ ខ្ញុំមិនអាចនឹងធ្វើបាន ព្រោះថា បុគ្គលត្រូវជរា និងរោគជាដើម គ្របសង្កត់ហើយ កាលមិនអាចធ្វើបាន បុគ្គលនោះ រមែងឃ្លាតចាកឋានៈជាសុខផង តែងក្តៅ

ក្រហាយរឿយៗ ក្នុងកាលជាខាងក្រោយផង អធិប្បាយថា បុគ្គលនោះ រមែងសាបសូន្យចាកឋានៈដែលជាសុខ គឺចាកស្ថានសួគ៌ និងព្រះនិព្វាន ព្រោះឧបាយដែលឲ្យដល់ទីនោះ ខ្លួនមិនទាន់បានឲ្យកើតឡើង ទាំងក្តៅក្រហាយ គឺដល់នូវការក្តៅក្រហាយក្នុងកាលជាខាងក្រោយ ដោយន័យជាដើមថា កម្មល្អអញមិនបានធ្វើហ្ន៎ ។

**ម** អក្ខរៈ ជាពាក្យសម្រាប់ភ្ជាប់បទ ព្រះថេរៈកាលសម្តែងថា ខ្ញុំធ្វើកិច្ចដែលគួរធ្វើស្រេចបាច់ហើយនោះឯង ទើបប្រាប់អ្នកទាំងឡាយយ៉ាងនេះ ដូច្នេះហើយ ទើបបានពោលគាថាទី ២ ថា **យញ្ហិ កយិរា** ជាដើម ។

បណ្តាបទទាំងនោះ បទថា **បរិជានន្តិ** សេចក្តីថា បណ្ឌិតទាំងឡាយដឹងថា បុគ្គលនេះក៏ប៉ុណ្ណោះ អធិប្បាយថា មិនដឹងក្រៃលែងជាងនេះ ព្រោះថា បុគ្គលពោលយ៉ាងណា ធ្វើយ៉ាងនោះប៉ុណ្ណោះ រមែងល្អ ដោយអំណាចសម្មាបដិបត្តិ មិនមែនល្អដទៃចាកសម្មាបដិបត្តិនោះឡើយ ។ ឥឡូវនេះ ដើម្បីសម្តែងអត្ថដែលលោកបានពោលមកហើយដោយមិនចំពោះ ទាក់ទងដោយកិច្ចដែលគួរធ្វើដោយសរុប ទើបព្រះថេរៈពោលគាថាទី ៣ ដោយន័យជាដើមថា **សុសុខំ វត** ដូច្នេះ ។

គាថាទី ៣ នេះ មានអធិប្បាយដូចតទៅនេះ ព្រះនិព្វាន ដែលព្រះមានព្រះភាគព្រះនាមថា **សម្មាសម្ពុទ្ធ** ព្រោះទ្រង់ត្រាស់ដឹងធម៌ទាំងអស់ដោយប្រពៃ ដោយព្រះអង្គឯង ទ្រង់សម្តែងហើយ ឈ្មោះថា **អសោកំ** ព្រោះមិនមានហេតុនៃសេចក្តីសោក ដោយប្រការទាំងពួង ឈ្មោះថា **វិរជំ** ព្រោះមិនមានកិលេសដូចធូលី មានរាគៈជាដើមទៅប្រាសហើយ ឈ្មោះថា **ខេមំ** ព្រោះមិនត្រូវឧបទ្រវៈ ៤ បៀតបៀន ជាសុខពិត ព្រោះហេតុអ្វី ព្រោះព្រះនិព្វានជាទីរម្ងត់មិនមានសេសសល់ គឺជាទីស្ងប់រម្ងាប់ដោយចំណែកមួយនៃវដ្តទុក្ខទាំងពួង ។ល។

**អដ្ឋកថាពាកុលត្ថេរគាថា ចប់**

# សុត្តន្តបិដក

## ធនិយត្ថេរគាថា

[ ១៧៤ ] បើបុគ្គលស្រឡាញ់ ក្នុងភាពជាសមណៈ ប្រាថ្នាដើម្បីរស់នៅស្រួល មិនគប្បីមើលងាយចីវរ ទឹក និងភោជនជារបស់សង្ឃទេ ។ បើបុគ្គលស្រឡាញ់ ក្នុងភាពជាសមណៈ ប្រាថ្នាដើម្បីរស់នៅស្រួល គប្បីសេពទីដេក និងទីអង្គុយ ដូចជាពស់សេពនូវរន្ធរបស់កណ្តុរ ។ បើបុគ្គលស្រឡាញ់ក្នុងភាពជាសមណៈ ប្រាថ្នាដើម្បីរស់នៅស្រួល គប្បីត្រេកអរដោយបច្ច័យតាមមានតាមបានផង គប្បីចម្រើនធម៌ឯកផង ។

ធនិយត្ថេរ

# អដ្ឋកថា

## ធនិយត្ថេរគាថា

[ ១៧៤ ] គាថារបស់ព្រះធនិយត្ថេរ មានពាក្យផ្តើមថា **សុខញ្ចេ ជីវិតុំ ឥច្ឆេ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំនូវបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ។ ក្នុងសាសនារបស់ព្រះមានព្រះភាគ ព្រះនាមសិខី កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្តីហើយ ថ្ងៃមួយ ឃើញព្រះសាស្តា មានចិត្ត

ជ្រះថ្លា បានធ្វើការបូជាដោយកម្រងផ្កាបបុស ។ ដោយបុញ្ញកម្មនោះ កុលបុត្ត នោះអន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ។ ក្នុងពុទ្ធុប្បាទនេះ កើត ក្នុងត្រកូលស្មូនឆ្នាំង នាក្រុងរាជគ្រឹះ មានឈ្មោះថា **ធនិយៈ** ចម្រើនវ័យ ហើយ ចិញ្ចឹមជីវិតជានាយស្មូនឆ្នាំង ។ សម័យនោះ ព្រះសាស្តាគង់ត្រង់ សាលារបស់ធនិយស្មូនឆ្នាំង ទ្រង់សម្តែងធាតុវិភង្គសូត្រដល់កុលបុត្តឈ្មោះ បុក្កុសាតិ ។ បុក្កុសាតិនោះ ស្តាប់សូត្រនោះហើយ បានសម្រេចកិច្ច ។ ឯ ធនិយៈបានជ្រាបថា បុក្កុសាតិនោះ រម្ងត់កិលេសអស់ហើយ បានទូវសទ្ធា គិតថា ព្រះពុទ្ធសាសនានេះ នាំសត្វចេញអំពីវដ្តៈពិតហ្ន៎ សូម្បីទទួលការ អប់រំត្រឹមមួយយប់ ក៏អាចផុតទុក្ខបាន ដូច្នេះ ទើបចេញបួស រវល់តែ រៀបចំកុដិ ត្រូវព្រះមានព្រះភាគតិះដៀល ព្រោះអាស្រ័យការធ្វើកុដិ ទើបនៅ ត្រង់កុដិរបស់សង្ឃ ចម្រើនវិបស្សនាហើយ សម្រេចអរហត្តផល ។ សម ដូចគាថាព័ន្ធដែលលោកពោលក្នុងអបទានថា

ខ្ញុំបានឃើញនូវព្រះសម្ពុទ្ធ មានវណ្ណៈដូចមាស ជាលោកនាយក ទ្រង់គួរទទួលនូវគ្រឿងបូជា ស្តេចទៅតាមជាយព្រៃធំ ។ ខ្ញុំកាន់ យកកម្រងផ្កាបបុស ហើយចេញទៅក្នុងខណៈនោះ បានឃើញ ព្រះសម្ពុទ្ធទ្រង់ឆ្លងឱឃៈ ព្រះអង្គមិនមានអាសវៈ គង់នៅក្នុងព្រៃ នោះ ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានបូជាកម្រងផ្កា បបុសចំពោះព្រះពុទ្ធជាទក្ខិណេយ្យបុគ្គល ព្រះអង្គមានព្យាយាម ច្រើន ទ្រង់អនុគ្រោះសព្វសត្វលោក ។ ក្នុងកប្បទី ៣១ អំពីកប្ប

នេះ ព្រោះហេតុដែលខ្ញុំបូជាផ្កា ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយដូច្នេះ[១] ។

១- ក្នុងអបទាន ជានទ្បមាលិយត្ថេរ ។

ម្យ៉ាងទៀត កាលបានសម្រេចអរហត្តផលហើយ ដើម្បីព្យាករអរហត្តផលដោយត្រង់ គឺការឲ្យឱវាទដល់ពួកភិក្ខុដែលលើកខ្លួនឡើងសង្កត់សង្កិនភិក្ខុដទៃ និងដែលត្រេកអរក្នុងសង្ឃភត្តជាដើម ដោយការសមាទានធុតង្គទើបពោល ៣ គាថាថា

បើបុគ្គលស្រឡាញ់ ក្នុងភាពជាសមណៈ ប្រាថ្នាដើម្បីរស់នៅស្រួល មិនគប្បីមើលងាយចីវរ ទឹក និងភោជន ជារបស់សង្ឃទេ ។ បើបុគ្គលស្រឡាញ់ ក្នុងភាពជាសមណៈ ប្រាថ្នាដើម្បីរស់នៅស្រួល គប្បីសេពទីដេក និងទីអង្គុយ ដូចជាពស់សេពនូវរន្ធរបស់កណ្តុរ ។ បើបុគ្គលស្រឡាញ់ ក្នុងភាពជាសមណៈ ប្រាថ្នាដើម្បីរស់នៅស្រួល គប្បីត្រេកអរដោយបច្ច័យតាមមានតាមបានផង គប្បីចម្រើនធម៌ឯកផង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សុខញ្ចេ ជីវិតុំ ឥច្ឆេ សាមញ្ញស្មឹ អបេក្ខវា** សេចក្តីថា ភិក្ខុប្រាថ្នាគុណជាសមណៈ គឺភាវៈជាសមណៈ ជាអ្នកមានការគោរពដ៏ខ្លាំងក្លាក្នុងសិក្ខា បើប្រាថ្នាធ្វើជីវិតឲ្យជាសុខ អធិប្បាយថា ប្រសិនបើ

ត្រូវការលះការស្វែងរកដែលមិនសមគួរ មានជីវិតរស់នៅជាសុខ តាមបែបសមណៈ ។

បទថា **សង្ឃិកំ នាតិមញ្ញេយ្យ ចីវរំ បានភោជនំ** សេចក្ដីថា មិនគួរមើលងាយចីវរ ទឹក និងភោជនដែលគេថ្វាយជារបស់សង្ឃ អធិប្បាយថា ធម្មតាលាភដែលកើតឡើងដល់សង្ឃ ជាលាភដែលកើតឡើងដោយបរិសុទ្ធ ព្រោះហេតុនោះ កាលបរិភោគលាភនោះ សេចក្ដីសុខតាមបែបសមណៈ ក៏ឈ្មោះថា នៅក្នុងកណ្ដាប់ដៃនោះឯង ព្រោះកើតអំពីអាជីវបារិសុទ្ធិសីល ។

បទថា **អហិ មូសិក សោព្ភំវ** សេចក្ដីថា គួរសេព គឺប្រើប្រាស់សេនាសនៈ ដូចពស់ដែលប្រើរន្ធកណ្ដុរ អធិប្បាយថា ឧបមាដូចពស់ មិនធ្វើទីលំនៅ អាស្រ័យឯងសម្រាប់ខ្លួន តែអាស្រ័យលំនៅកណ្ដុរ ឬសត្វដទៃធ្វើហើយ កាលត្រូវការ ( នឹងទៅ ) ក៏ចៀសចេញទៅ យ៉ាងណា ភិក្ខុក៏ដូច្នោះដូចគ្នា មិនគួរមានការជាប់ជំពាក់ ព្រោះត្រូវធ្វើសេនាសនៈឯង នៅក្នុងសេនាសនៈណាក៏បាន ហើយចៀសចេញទៅ ។

ឥឡូវនេះ ព្រះធនិយត្ថេរ កាលសម្ដែងថា សេចក្ដីរបស់សមណៈ រមែងមានដោយការពេញចិត្តក្នុងបច្ច័យតាមដែលបានមក ទាំងដែលបានពោល

មកហើយ និងមិនបានពោលដល់ប៉ុណ្ណោះ មិនមែនមានដោយប្រការដទៃឡើយ ទើបពោលថា **ឥតរីតរេន តុស្សេយ្យ** ជាដើម អធិប្បាយថា ភិក្ខុគួរដល់ការពេញចិត្ត គឺសន្តោសដោយបច្ច័យគ្រប់យ៉ាង តាមដែលបានមកទោះអាក្រក់ ឬប្រណីតក៏ដោយ ។

បទថា **ឯកធម្មំ** បានដល់ សេចក្តីមិនប្រមាទ ព្រោះថា ការមិនប្រមាទនោះ មិនមានទោសសម្រាប់បុគ្គលអ្នកប្រកបព្យាយាម លោកិយសុខក្តី លោកុត្តរសុខក្តី ឈ្មោះថា នៅក្នុងកណ្តាប់ដៃនោះឯង ។ ដោយហេតុនោះទើបព្រះមានព្រះភាគត្រាស់ថា ដ្បិតបុគ្គលអ្នកមិនប្រមាទ ខំសង្កេតពិនិត្យរមែងបានសេចក្តីសុខដ៏ទូលាយ ដូច្នេះ ៕៚

**អដ្ឋកថា ធនិយត្ថេរគាថា ចប់**

# សុត្តន្តបិដក

## មាតង្គបុត្តត្ថេរគាថា

[ ១៧៥ ] ខណៈរមែងប្រព្រឹត្តកន្លងនូវមាណពទាំងឡាយ ដែលមានការងាររលះបោល ( ដោយគិតអាងថា ) ត្រជាក់ពេក ក្តៅពេក ល្ងាចពេក ។ បុគ្គលណាមួយ កាលធ្វើនូវកិច្ចរបស់បុរស មិនអើពើចំពោះត្រជាក់ និងក្តៅ ឲ្យក្រៃលែងជាងស្មៅ បុគ្គលនោះ រមែងមិនសាបសូន្យចាកសេចក្តីសុខឡើយ ។ អាត្មាអញកាលចម្រើននូវវិវេក នឹងកម្ចាត់បង់បាននូវស្មៅចិញ្ចៀនស្បូវ គុម្ពឈើមានបន្លា ស្បូវរណ្តាស ស្មៅជំណេកទន្សាយ និងស្មៅយាប្លង ( កិលេសគ្រោតគ្រាត កណ្តាលល្អិត ) ដោយទ្រូង ( សេចក្តីព្យាយាម ) ។

មាតង្គបុត្តត្ថេរ

# អដ្ឋកថា

## មាតង្គបុត្តត្ថេរគាថា

[ ១៧៥ ] គាថារបស់ព្រះមាតង្គបុត្តត្ថេរ មានពាក្យផ្តើមថា **អតិសីតំ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះ ក្នុងសាសនារបស់ព្រះមានព្រះភាគ ព្រះនាមបទុមុត្តរៈ កើតជាស្តេចនាគ មានអានុភាពច្រើន ក្នុងនាគពិភព ខាងក្រោមជាតស្រះមួយ ជិតព្រៃហិមពាន្ត ថ្ងៃមួយ ចេញអំពីនាគពិភព ត្រាច់

ទៅ ឃើញព្រះសាស្តាយាងមកតាមអាកាស មានចិត្តជ្រះថ្លា បានធ្វើការបូជា ដោយកែវមណីដែលពាក់ត្រង់សិររបស់ខ្លួន ។ ដោយបុញ្ញកម្មនោះ កុលបុត្ត នោះ អន្ទោលទៅមកក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតជាកូនមាតង្គកុដុម្ពិកៈ ក្នុងកោសលរដ្ឋ មានឈ្មោះប្រាកដថា មាតង្គបុត្ត នោះឯង ។ កុលបុត្តនោះដឹងក្តីហើយ ជាអ្នកខ្ជិលច្រអូស មិនធ្វើការងារអ្វី ឡើយ ត្រូវញាតិ និងអ្នកដទៃតិះដៀល គិតថា សមណសក្យបុត្តទាំងនេះ រស់នៅដោយស្រួល បំណាចនឹងរស់នៅដោយស្រួល ជាបុគ្គលដែលភិក្ខុទាំង ឡាយ ធ្វើការអប់រំហើយ បានចូលទៅគាល់ព្រះសាស្តា ស្តាប់ព្រះធម្មទេសនា មានសទ្ធា ហើយបួស ឃើញភិក្ខុដទៃមានឫទ្ធិ ចង់បានឫទ្ធិ ទើបរៀនកម្មដ្ឋាន ក្នុងសម្នាក់របស់ព្រះសាស្តា ព្យាយាមប្រកបភាវនាហើយនូវអភិញ្ញា ៦ ។ សមដូចគាថាព័ន្ធដែលលោកពោលក្នុងអបទានថា

ព្រះជិនស្រីសម្ពុទ្ធ ព្រះនាមបទុមុត្តរៈ ទ្រង់ដល់នូវត្រើយនៃធម៌ ទាំងពួង ទ្រង់ប្រាថ្នានូវវិវេក កំពុងតែស្តេចទៅតាមអាកាស ។ មានជាតស្រះដ៏ធំមួយ នៅជិតព្រៃហិមពាន្ត ឯលំនៅរបស់ខ្ញុំដែល ប្រកបដោយបុញ្ញកម្ម នៅជិតស្រះនោះ ។ ខ្ញុំចេញអំពីលំនៅ បានឃើញព្រះលោកនាយក ទ្រង់ភ្លឺដូចផ្ការាជព្រឹក្ស រុងរឿងដូច ជាភ្លើង ខ្ញុំមិនឃើញផ្កាដែលគួរបេះថ្វាយ ទើបគិតថា អញនឹង បូជាអ្វីដល់ព្រះលោកនាយក ឲ្យចិត្តរបស់ខ្លួនជ្រះថ្លាហើយ ថ្វាយ បង្គំព្រះសាស្តាអេះ ។ ខ្ញុំយកកែវមណីប្រដាប់ក្បាលនៃខ្ញុំ បូជា

ព្រះលោកនាយក រួចប្រាថ្នាថា សូមឲ្យផលដ៏ចម្រើនសម្រេចដល់ខ្ញុំ ដោយសារបូជាកែវមណីនេះ ។ ព្រះសាស្ដាព្រះនាមបទុមុត្តរៈ ទ្រង់ជ្រាបច្បាស់ត្រៃលោក ព្រះអង្គគួរទទួលគ្រឿងបូជា ទ្រង់ឈរសម្ដែងក្នុងអាកាសនូវគាថានេះថា តម្រិះនោះ សូមឲ្យសម្រេចដល់អ្នក អ្នកចូរបាននូវសេចក្ដីសុខដ៏ធំទូលាយ អ្នកចូរបាននូវយសដ៏ធំ ដោយការបូជានូវកែវមណីនេះចុះ ។ ព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈ លុះពោលពាក្យនេះហើយ ទើបស្ដេចហួសទៅ ចិត្តដែលគេតម្កល់ទុកចំពោះបុគ្គលណា ( បុគ្គលនោះ ) គឺព្រះពុទ្ធដ៏ប្រសើរ ។ ខ្ញុំកើតជាព្រះឥន្ទ ជាស្ដេចទេវតា សោយទេវរាជ្យអស់ ៦០ កប្ប បានជាស្ដេចចក្រពត្តិច្រើនរយដង ។ ខ្ញុំកាលកើតជាទេវតា មានសតិ បានរឭកឃើញនូវបុញ្ញកម្ម ឯកែវមណី ជាវត្ថុជាតុ ធ្វើពន្លឺ ក៏កើតឡើងសម្រាប់ខ្ញុំ ។ ខ្ញុំគ្រប់គ្រងនារី ៨៦០០០ សឹងមានសំពត់ និងគ្រឿងអាភរណៈដ៏វិចិត្រ ពាក់នូវកែវមណី និងកណ្ឌល ។ នារីទាំងនោះ មានមុខទូលាយញញឹមស្រស់ មានត្របកល្អ មានចង្កេះរៀវ តែងចោមរោមខ្ញុំជានិច្ច នេះជាផលនៃការបូជាកែវមណី ។ ភណ្ឌៈទាំងឡាយរបស់ខ្ញុំ ជាវិការៈនៃមាស ជាវិការៈនៃកែវមណី ជាវិការៈនៃកែវក្រហម ដែលជាធរចនាល្អ ជាគ្រឿងប្រដាប់សម្រេចតាមសេចក្ដីប្រាថ្នា ។ ផ្ទះកំពូល គុហា គួររីករាយ ទីដេកមានថ្លៃច្រើនតែង

កើតឡើង សមតាមសេចក្តីប្រាថ្នា ព្រោះដឹងតម្រិះរបស់ខ្ញុំ ។ ឱ ជាលាភរបស់គេហើយ ឱ អត្តភាពជាមនុស្ស ឈ្មោះថា គេបានល្អហើយ ព្រោះហេតុដែលគេបាននូវការចូលទៅអែបស្តាប់ពុទ្ធោ-វាទ ជាបុញ្ញក្ខេត្តរបស់មនុស្ស ជាឱសថរបស់សត្វទាំងពួង ។ អំពើដែលខ្ញុំធ្វើល្អហើយ ព្រោះខ្ញុំបានឃើញព្រះពុទ្ធជានាយក ខ្ញុំរួចស្រឡះហើយចាកវិនិបាត ខ្ញុំបានដល់នូវអចលបទ គឺព្រះនិព្វាន ។ ខ្ញុំទៅកាន់កំណើតណាៗ ទោះជាទេវតា ឬជាមនុស្ស ពន្លឺតែងមានសម្រាប់ខ្ញុំ ទាំងថ្ងៃ ទាំងយប់ សព្វៗ កាល ។ ខ្ញុំសោយសម្បត្តិទាំងឡាយ ដោយសារការបូជានូវកែវមណីនោះឯង ពន្លឺគឺញាណ ខ្ញុំឃើញហើយ ខ្ញុំបានដល់នូវអចលបទ គឺព្រះនិព្វាន ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបូជាកែវមណីក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាកែវមណី ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈបានអភិញ្ញា ៦ ហើយ កាលតិះដៀលនូវការខ្ជិលច្រអូសសរសើរនូវការប្រារព្ធព្យាយាមរបស់ខ្លួន ដើម្បីជាបុគ្គលាធិដ្ឋាន ទើបពោល ៣ គាថាថា

ខណៈរមែងប្រព្រឹត្តកន្លងនូវមាណពទាំងឡាយ ដែលមានការងារ

---

១- ក្នុងអបទានជា មណិបូជកត្ថេរ ។

លះបោល ( ដោយគិតអាងថា ) ត្រជាក់ពេក ក្តៅពេក ល្ងាចពេក ។ បុគ្គលណាមួយ កាលធ្វើនូវកិច្ចរបស់បុរស មិនអើពើចំពោះត្រជាក់ និងក្តៅ ឲ្យក្រៃលែងជាងស្មៅ បុគ្គលនោះ រមែងមិនសាបសូន្យចាកសេចក្តីសុខឡើយ ។ អាត្មាអញ កាលចម្រើននូវវិវេក នឹងកម្ចាត់បង់បាននូវស្មៅចិញ្ចៀន ស្បូវ គុម្ពឈើមានបន្លា ស្បូវណ្ដាស ស្មៅជំណោកទន្សាយ និងស្មៅឃាប្លង ( កិលេសគ្រោតគ្រាត កណ្តាល ល្អិត ) ដោយទ្រូង ( សេចក្តីព្យាយាម ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អតិសីតំ** សេចក្តីថា រងាខ្លាំង ដោយសន្សើម និងភ្លៀងរលឹមជាដើម ។ គប្បីនាំបទនេះ មកភ្ជាប់នឹងបទថា **អហុ** ( អាងថា ) ។

បទថា **អតិឧណ្ហំ** សេចក្តីថា ក្តៅពេក ព្រោះកម្តៅថ្ងៃដុតរោលក្នុងរដូវក្តៅជាដើម ។ ដោយគាថាទាំង ២ នេះ ព្រះថេរៈបានពោលដល់ហេតុដែលជាទីតាំងនៃការខ្ជិលច្រអូស ដោយអំណាចនៃឧតុ ។

បទថា **អតិសាយំ** សេចក្តីថា ល្ងាចហើយ ព្រោះពេលថ្ងៃកន្លងផុតទៅ សូម្បីក្នុងពេលព្រឹកក៏សង្គ្រោះចូលក្នុងគាថានេះផងដែរ ពាក្យទាំង ២ នោះ ពាក្យថា ( **សាយំ** និង **ចាតោ** ) ព្រះថេរៈបានពោលដល់ហេតុជាទីតាំងនៃការខ្ជិលច្រអូស ដោយអំណាចកាលវេលា ។

បទថា **ឥតិ** សេចក្តីថា ដោយប្រការដូច្នេះ ។ ដោយ **ឥតិ** សព្ទនេះ

ព្រះថេរៈសង្គ្រោះយកហេតុជាទីតាំងនៃការខ្ជិលច្រអូស ដែលព្រះមានព្រះភាគត្រាស់ដោយន័យជាដើមថា ម្នាលភិក្ខុទាំងឡាយ អំពើ គឺការលៃលក វាស់កាត់ចីវរជាដើម ដែលភិក្ខុក្នុងសាសនានេះ គួរធ្វើក៏មាន ដូច្នេះ ។

បទថា **វិសដ្ឋកម្មន្តោ** បានដល់ ជាអ្នកលះបង់នូវការងារដែលធ្វើ ។ បទថា **ខណោ** បានដល់ ឱកាសនៃការនៅប្រព្រឹត្តព្រហ្មចរិយៈ មានឱកាសកើតឡើងរបស់ព្រះពុទ្ធជាដើម ។ បទថា **មាណវេ** បានដល់ សត្វលោកទាំងឡាយ ។ បទថា **តិណោ ភិយ្យោ ឆ មញ្ញតិ** សេចក្ដីថា មិនសម្គាល់ក្រៃលែងជាងស្មៅ គឺសម្គាល់ដូចស្មៅ បានដល់ សង្កត់នូវងារ និងក្ដៅ ធ្វើការងារដែលខ្លួនត្រូវធ្វើ ។ បទថា **ករំ** ស្មើគ្នានឹង **ករោន្តោ** ប្រែថា ធ្វើ ។ បទថា **បុរិសកិច្ចានិ** បានដល់ ប្រយោជន៍របស់ខ្លួន និងរបស់អ្នកដទៃដែលវីរបុរសត្រូវធ្វើ ។ បទថា **សុខា** បានដល់ ចាកសេចក្ដីសុខ អធិប្បាយថា ចាកនិព្វានសុខ ។ អត្ថនៃគាថាទី ៣ ខ្ញុំបានពោលហើយនោះឯង ( ក្នុងលោមសកង្គិយត្ថេរគាថា ឯកនិបាត ) ។៚

**អដ្ឋកថា មាតង្គបុត្តត្ថេរគាថា ចប់**

# សុត្តន្តបិដក

## ខុជ្ជសោភិតត្ថេរគាថា

[ ១៧៦ ] ពួកសមណៈណា ជាអ្នកមានសម្ដីដ៏វិចិត្រ ជាពហុស្សូត នៅក្នុងក្រុងបាតលិបុត្តជាប្រក្រតី បណ្ដាពួកសមណៈទាំងនោះ ខុជ្ជសោភិតត្ថេរ មានអាយុនេះ ជាសមណៈមួយរូបដែរ ឈរជិតទ្វារ ។

ពួកសមណៈណា ជាអ្នកមានសម្ដីដ៏វិចិត្រ ជាពហុស្សូត នៅក្នុងក្រុងបាតលិបុត្តជាប្រក្រតី បណ្ដាសមណៈទាំងនោះ ខុជ្ជសោភិតត្ថេរ មានអាយុនេះ ជាសមណៈមួយរូបដែរ ជាអ្នកមកដោយខ្យល់ គឺមកដោយកម្លាំងនៃឫទ្ធិ ហើយឈរជិតទ្វារ ។ ខុជ្ជសោភិតត្ថេរនេះ បានដល់នូវសេចក្ដីសុខ ដោយការច្បាំង ( នឹងពួកកិលេស ) ផង ដោយបូជាល្អផង ដោយការឈ្នះសង្គ្រាមផង ដោយការសន្សំនូវព្រហ្មចរិយធម៌ផង ។

ខុជ្ជសោភិតត្ថេរ

# អដ្ឋកថា

## ខុជ្ជសោភិតត្ថេរគាថា

[ ១៧៦ ] គាថារបស់ព្រះខុជ្ជសោភិតត្ថេរ មានពាក្យផ្តើមថា **យេ ចិត្តកថី ពហុស្សុតា** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្តីហើយ ថ្ងៃមួយ ឃើញព្រះមានព្រះភាគ យាងទៅជាមួយភិក្ខុសង្ឃជាច្រើន មានចិត្តជ្រះថ្លា បានពោលសរសើរ ១០[១] គាថា ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅមកក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងនគរបាដលិបុត្ត មាននាមថា សោភិតៈ ។ ទោះជាអ្នកគមបន្តិច ទើបប្រាកដឈ្មោះថា ខុជ្ជសោភិតៈនោះឯង ។ ចម្រើនវ័យហើយ កាលព្រះសាស្តាបរិនិព្វានហើយ បួសក្នុងសម្នាក់របស់ព្រះអានន្ទត្ថេរ បាននូវអភិញ្ញា ៦ ។ សមដូចគាថាព័ន្ធដែលលោកពោលនៅក្នុងអបទានថា

ខ្ញុំបានសរសើរថា ព្រះពុទ្ធជាទេវតាក្រៃលែងជាងទេវតា ព្រះអង្គប្រសើរជាងនរៈ មានព្រះដំណើរល្វាសល្វន់ បីដូចដើមថ្នាន់ត្រូវខ្យល់ ទ្រង់កំពុងស្តេចទៅតាមប្រេក បុគ្គលណាឃើញហើយ នឹងមិនជ្រះថ្លាម្តេចបាន ។ ព្រះពុទ្ធទ្រង់កម្ចាត់បង់នូវងងឹតអន្ធការ ទ្រង់

---

១- ១០ គាថានោះ មានក្នុងអបទានរបស់លោក ។

ចម្លងនូវជនច្រើន ទ្រង់រុងរឿងដោយពន្លឺ គឺញាណ បុគ្គលណា ឃើញហើយ នឹងមិនជ្រះថ្លាម្តេចបាន ។ ព្រះលោកនាយក ទ្រង់ស្តេចទៅជាមួយនឹងព្រះវិណាស្រពមួយសែន ដែលស្ងាត់ជំនាញ ទ្រង់ស្រង់នូវសត្វទាំងឡាយដ៏ច្រើន បុគ្គលណាឃើញហើយ នឹងមិនជ្រះថ្លាម្តេចបាន ។ ព្រះពុទ្ធនាំមកនូវធម្មភេរី ទ្រង់ញាំញីនូវពួកតិត្ថិយ បន្លឺឡើងនូវសីហនាទ បុគ្គលណាឃើញហើយ នឹងមិនជ្រះថ្លាម្តេចបាន ។ ពួកទេវតា ព្រមទាំងព្រហ្ម រហូតដល់ព្រហ្មលោក មកសួរនូវបញ្ហាដ៏ល្អិត អ្នកណាឃើញហើយ នឹងមិនជ្រះថ្លាម្តេចបាន ។ ពួកជន ព្រមទាំងទេវតា ធ្វើនូវអញ្ជលីបួងសួង ចំពោះព្រះពុទ្ធអង្គណា រមែងបានទទួលនូវបុណ្យដោយសារព្រះពុទ្ធអង្គនោះ បុគ្គលណាឃើញហើយ នឹងមិនជ្រះថ្លាម្តេចបាន ។ ជនទាំងពួងមកព្រមគ្នា ហើយបវារណាព្រះពុទ្ធមានចក្ខុ ព្រះអង្គដែលគេអារាធនាហើយ រមែងមិនញាប់ញ័រ បុគ្គលណាឃើញហើយ នឹងមិនជ្រះថ្លាម្តេចបាន ។ ស្គរជាច្រើន រមែងបន្លឺឡើងដ៏ទាំងឡាយដែលចុះប្រេង រមែងបន្លឺឡើងចំពោះព្រះសម្ពុទ្ធអង្គណា កាលដែលស្តេចចូលទៅក្នុងទីក្រុង បុគ្គលណាឃើញ ( ព្រះពុទ្ធអង្គនោះ ) ហើយ នឹងមិនជ្រះថ្លាម្តេចបាន ។ ឯពន្លឺនៃព្រះពុទ្ធអង្គណា ដែលកំពុងស្តេចទៅតាមថ្នល់ រមែងរុងរឿងស្មើៗ កាល រស្មីទាំងឡាយ ( របស់ព្រះពុទ្ធអង្គនោះ ) ខ្ពង់ខ្ពស់

ឡើងក្រែពេក បុគ្គលណាឃើញហើយ នឹងមិនជ្រះថ្លាម្តេចបាន ។ បុគ្គលឮ ( នូវសំឡេង ) នៃព្រះពុទ្ធកាលពោលក្នុងចក្រវាល ព្រះអង្គញ៉ាំងសត្វទាំងអស់ឲ្យដឹងច្បាស់ បុគ្គលណាឃើញហើយ នឹងមិនជ្រះថ្លាម្តេចបាន ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានសរសើរនូវព្រះពុទ្ធ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃសេចក្តីសរសើរ ។ កិលេសទាំងឡាយ ខ្ញុំដុត បំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បាន ប្រតិបត្តិហើយ ដូច្នេះ[១] ។

ម្យ៉ាងទៀត កាលលោកបានអភិញ្ញា ៦ ហើយ ក្នុងសម័យបឋមមហាសង្គាយនា លោកត្រូវសង្ឃដែលប្រជុំគ្នាត្រង់សត្តបណ្ណគុហា ក្រុងរាជគ្រឹះ មានបញ្ជាថា សូមលោកម្ចាស់ទៅនិមន្តព្រះអានន្ទត្ថេរមក ទើបមុជដី ផុសឡើងត្រង់មុខព្រះថេរៈ ប្រាប់ឲ្យជ្រាបហើយ ខ្លួនឯងត្រឡប់មកមុនតាមអាកាស ដល់មាត់ទ្វារសត្តបណ្ណគុហាហើយ ។ សម័យនោះ ទេវតាអង្គខ្លះដែលពួកទេវតា បញ្ជូនទៅដើម្បីការពារស្តេចមារ និងគ្នីគ្នា បានឈរត្រង់មាត់សត្តបណ្ណគុហា ព្រះខុជ្ជសោភិតត្ថេរ កាលប្រាប់ការមករបស់ខ្លួនដល់ទេវតានោះ បានពោលគាថាទី ១ ថា

ពួកសមណៈណា ជាអ្នកមានសម្តីដ៏វិចិត្រ ជាពហុស្សូត នៅក្នុងក្រុងបាតលិបុត្តជាប្រក្រតី បណ្តាពួកសមណៈទាំងនោះ ខុជ្ជ-

---

១- ក្នុងអបទាន ជាសយម្បដិភាណិយត្ថេរ ។

សោភិតត្ថេរ មានអាយុនេះ ជាសមណៈមួយរូបដែរ ឈរជិតទ្វារ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ចិត្តកថី** បានដល់ ជាអ្នកសម្ដែងធម៌ដ៏ពីរោះជាប្រក្រតី អធិប្បាយថា ជាអ្នកមានប្រក្រតីនិយាយធម៌ សមគួរដល់អធ្យាស្រ័យរបស់អ្នកដទៃ ដោយន័យផ្សេងៗ យ៉ាងនេះ គឺសង្ខេប ពិស្ដារ ធ្វើឲ្យជ្រៅ ធ្វើឲ្យរាក់ បន្ទោបង់សេចក្ដីសង្ស័យបាន ឲ្យអ្នកស្ដាប់តាំងនៅក្នុងធម៌បានជាដើម ។

បទថា **ពហុស្សុតា** សេចក្ដីថា ឈ្មោះថា ជាពហូសូត ព្រោះបរិបូណ៌ដោយភាពជាពហូសូត ទាំងផ្លូវបរិយត្តិ និងបដិវេធ ឈ្មោះថា ជាសមណៈ ព្រោះរម្ងាប់បាប ដោយប្រការទាំងពួង ។

បទថា **ចាដលិបុត្តវាសិនោ តេសញ្ញតរោ** សេចក្ដីថា ភិក្ខុទាំងឡាយ ឈ្មោះថា នៅប្រចាំក្នុងក្រុងបាដលីបុត្ត ព្រោះមានប្រក្រតីនៅត្រង់នគរបាដលីបុត្ត ។ បណ្ដាភិក្ខុទាំងនោះ អ្នកមានអាយុចាស់ ( ថេរៈ ) គឺអាវុសោរូបនេះមួយអង្គដែរ ក្នុងចំនួននោះ ។

បទថា **ទ្វារេ តិដ្ឋតិ** សេចក្ដីថា ឈរត្រង់ទ្វារសត្តបណ្ណគុហា អធិប្បាយថា ដើម្បីចូលទៅតាមអនុមតិរបស់សង្ឃ ។ ទេវតាកាលបានស្ដាប់ពាក្យនោះហើយ ទើបប្រកាសការមករបស់ព្រះថេរៈឲ្យសង្ឃជ្រាប បានពោលគាថាទី ២ ថា

ពួកសមណៈណា ជាអ្នកមានសម្ដីដ៏វិចិត្រ ជាពហុស្សុត នៅក្នុង

ក្រុងបាតលិបុត្តជាប្រក្រតី បណ្តាសមណៈទាំងនោះ ខុជ្ជសោភិ-
តត្ថេរ មានអាយុនេះ ជាសមណៈមួយរូបដែរ ជាអ្នកមកដោយ
ខ្យល់ គឺមកដោយកម្លាំងនៃឫទ្ធិ ហើយឈរជិតទ្វារ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មាលុតេរិតោ** សេចក្តីថា ជាអ្នកមក ហើយ ដោយខ្យល់ដែលកើតអំពីឫទ្ធិនៃចិត្ត អធិប្បាយថា មកហើយដោយ កម្លាំងឫទ្ធិ ។

ព្រះថេរៈដែលសង្ឃឲ្យឱកាសហើយ តាមដែលទេវតាអង្គនោះបាន ប្រកាសឲ្យដឹងយ៉ាងនេះហើយ កាលទៅកាន់សម្នាក់សង្ឃ បានព្យាករ អរហត្តផល ដោយគាថាទី ៣ ថា

ខុជ្ជសោភិតត្ថេរនេះ បានដល់នូវសេចក្តីសុខ ដោយការច្បាំង
( នឹងពួកកិលេស ) ផង ដោយបូជាល្អផង ដោយការឈ្នះ
សង្គ្រាមផង ដោយការសន្សំនូវព្រហ្មចរិយធម៌ផង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា <u>សុយុទ្ធេន</u> សេចក្តីថា ដោយការច្បាំង យ៉ាងល្អជាមួយកិលេសទាំងឡាយ ដោយអំណាចនៃតទង្គប្បហាន និង វិក្ខម្ភនប្បហាន ។

បទថា **សុយិដ្ឋេន** សេចក្តីថា ដោយធម្មទានជាទីសប្បាយ ដែលពួកកល្យាណមិត្តឲ្យហើយក្នុងចន្លោះៗ ។ បទថា **សង្គាមវិជយេន ច** សេចក្តីថា និងដោយជ័យជម្នះក្នុងសង្គ្រាម ដែលបានមកដោយអំណាចនៃសមុច្ឆេទប្បហាន និងដោយការញាំញីនូវអភិសង្ខារ គឺកិលេស ។ បទថា **ព្រហ្មចរិយានុចិណ្ណេន** សេចក្តីថា ដោយមគ្គព្រហ្មចរិយៈដ៏កំពូល ដែលប្រព្រឹត្តមកហើយជាប្រចាំ ។ បទថា **ឯវាយំ សុខមេធតិ** សេចក្តីថា ព្រះខុជ្ជសោភិតត្ថេរនេះ រមែងជួប អធិប្បាយថា សោយនូវសេចក្តីសុខ គឺព្រះនិព្វាន និងសេចក្តីសុខដែលកើតអំពីផលសមាបត្តិ ដោយប្រការយ៉ាងនេះ គឺដោយប្រការដូចពោលមកហើយ ៕

**អដ្ឋកថាខុជ្ជសោភិតត្ថេរគាថា ចប់**

# សុត្តន្តបិដក

## វារណត្ថេរគាថា

[ ១៧៧ ] បណ្តាពួកមនុស្ស ក្នុងលោកនេះ ជនណាមួយ បៀតបៀនសត្វដទៃ ជននោះរមែងសាបសូន្យចាកប្រយោជន៍ និងសេចក្តីសុខ ក្នុងលោកទាំង ២ គឺលោកនេះ និងលោកខាងមុខ ។ លុះតែជនណា អនុគ្រោះដល់សត្វទាំងពួង ដោយចិត្តប្រកបដោយមេត្តា ជនប្រាកដដូច្នោះនោះ ទើបទទួលបុណ្យដ៏ច្រើន ។ បុគ្គលគប្បីសិក្សាសុភាសិតផង នូវការចូលទៅរកសមណៈផង នូវការអង្គុយតែម្នាក់ឯងក្នុងទីស្ងាត់ផង នូវការញ៉ាំងចិត្តឲ្យស្ងប់រម្ងាប់ផង ។

វារណត្ថេរ

# អដ្ឋកថា

## វារណត្ថេរគាថា

[ ១៧៧ ] គាថារបស់ព្រះវារណត្ថេរ មានពាក្យផ្តើមថា **យោធ កោចិ មនុស្សេសុ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈ មានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះ មានបុញ្ញាធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ។ ក្នុងកប្បទី ៩២ រាប់អំពីកប្បនេះ មុនការកើតឡើងនៃព្រះមានព្រះភាគ ព្រះ

នាមតិស្សៈនោះឯង បានកើតក្នុងត្រកូលព្រាហ្មណ៍ ជាអ្នកដល់នូវត្រើយនៃវិជ្ជា និងសិប្បៈរបស់ព្រាហ្មណ៍ហើយ បួសជាឥសី បង្រៀនមន្តដល់អន្តេវាសិកប្រមាណ ៥៤០០០ នាក់ ។

សម័យនោះ មានការញាប់ញ័រនៃមហាប្រឹថពី ព្រោះព្រះមានព្រះភាគព្រះនាមតិស្សៈ ជាពោធិសត្វច្យុតអំពីទេវលោកជាន់តុសិត យាងចូលកាន់ព្រះគភ៌ទេររបស់ព្រះពុទ្ធមាតាក្នុងភពចុងក្រោយ ។ មហាជនឃើញហេតុការណ៍នោះហើយ ភិតភ័យ ទើបនាំគ្នាទៅរកឥសី សួរដល់ហេតុដែលធ្វើឲ្យផែនដីកម្រើក ឥសីប្រាប់ថា ជាបុព្វនិមិត្តនៃការកើតឡើងរបស់ព្រះពុទ្ធ លួងលោមជនទាំងនោះថា ព្រះពោធិសត្វឈានចុះកាន់គភ៌ទេររបស់ពុទ្ធមាតា ផែនដីញាប់ញ័រនេះ កើតឡើងដោយហេតុនោះ ព្រោះហេតុនោះ កុំខ្លាចឡើយ ហើយឲ្យជនទាំងនោះធូរស្បើយ និងឲ្យជនទាំងនោះបាននូវបីតិ មានព្រះពុទ្ធជាអារម្មណ៍ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅមកក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងដែនកោសលមានឈ្មោះថា **វារណៈ** ចម្រើនវ័យហើយ បានស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះថេរៈដែលនៅព្រៃមួយអង្គ បាននូវសេចក្តីជ្រះថ្លា ទើបចេញបួស បំពេញសមណធម៌ ថ្ងៃមួយ ខណៈចូលទៅគាល់ព្រះសម្ពុទ្ធ ក្នុងរវាងផ្លូវ ឃើញពស់វែក និងស្កាប្រយុទ្ធគ្នាស្លាប់ មានសេចក្តីសង្វេគថា សត្វទាំងនេះដល់នូវការអស់ជីវិត ព្រោះខឹងក្រោធដល់គ្នានិងគ្នា ដូច្នេះហើយ បានទៅកាន់

*សម្នាក់ព្រះមានព្រះភាគៗ កាលទ្រង់ជ្រាបអាចារដ៏ល្អរបស់ព្រះថេរៈហើយ កាលទ្រង់ប្រទានឱវាទឲ្យសមទីងអាចារនោះ ទើបភាសិត ៣ គាថាដូច្នេះថា*

*បណ្តាពួកមនុស្ស ក្នុងលោកនេះ ជនណាមួយ បៀតបៀនសត្វដទៃ ជននោះ រមែងសាបសូន្យចាកប្រយោជន៍ និងសេចក្តីសុខក្នុងលោកទាំង ២ គឺលោកនេះ និងលោកខាងមុខ ។ លុះតែជនណា អនុគ្រោះដល់សត្វទាំងពួង ដោយចិត្តប្រកបដោយមេត្តា ជនប្រាកដដូច្នោះនោះ ទើបទទួលបុណ្យដ៏ច្រើន ។ បុគ្គលគប្បីសិក្សាសុភាសិតផង នូវការចូលទៅរកសមណៈផង នូវការអង្គុយតែម្នាក់ឯងក្នុងទីស្ងាត់ផង នូវការញ៉ាំងចិត្តឲ្យ ស្ងប់រម្ងាប់ផង ដូច្នេះ ។*

*បណ្តាបទទាំងនោះ បទថា* **យោធ កោចិ មនុស្សេសុ** *សេចក្តីថា បណ្តាមនុស្សទាំងឡាយក្នុងលោកនេះ បុគ្គលណាមួយ ជាក្សត្រក្តី ជាព្រាហ្មណ៍ក្តី វេស្សៈក្តី សូទ្រៈក្តី គ្រហស្ថក្តី បព្វជិតក្តី ។ សព្ទថា* **មនុស្ស** *ក្នុងពាក្យថា* **យោធ កោជិ មនុស្សេសុ** *នេះ គប្បីជ្រាបថា ជាពាក្យប្រារព្ធដល់សត្វជាន់ខ្ពស់ ។*

*បទថា* **បរបាណានិ ហឹសតិ** *សេចក្តីថា សម្លាប់ និងបៀតបៀនសត្វដទៃ ។ បទថា* **អស្មា លោកា** *សេចក្តីថា ក្នុងលោកនេះ ។ បទថា* **បរម្ហា** *សេចក្តីថា ក្នុងលោកខាងមុខ ។*

*បទថា* **ឧភយា ធំសតេ** *សេចក្តីថា រមែងកម្ចាត់ហិតសុខក្នុងលោកទាំង ២ អធិប្បាយថា រមែងសាបសូន្យចាកប្រយោជន៍ និងសេចក្តីសុខ*

ដែលទាក់ទងក្នុងលោកទាំង ២ ។ បទថា **ឥតោ** បានដល់ សត្វ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងបាបធម៌ ដែលមានលក្ខណៈបៀតបៀនអ្នកដទៃយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្តែងកុសលធម៌ ដែលមានលក្ខណៈហាមនូវការបៀតបៀនអ្នកដទៃ ទើបបានត្រាស់គាថាទី ២ ដោយន័យជាដើមថា **យោ ច មេត្តេន** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មេត្តេន ចិត្តេន** សេចក្តីថា មានចិត្តប្រកបដោយមេត្តា ឬមានចិត្តក្រៅអំពីមេត្តា ដែលដល់អប្បនា ។

បទថា **សព្វបាណានុកម្បតិ** សេចក្តីថា មេត្តាសត្វទាំងអស់ ដូចកូនដែលកើតអំពីទ្រូងរបស់ខ្លួន ។

បទថា **ពហុំ ហិ សោ បសវតិ បុញ្ញំ តាទិសោ ឥតោ** សេចក្តីថា បុគ្គលនោះ គឺជាអ្នកនៅដោយមេត្តាបែបនេះ រមែងជួប គឺបានចំពោះ បានដល់ សម្រេចកុសលច្រើន គឺសន្ទឹកសន្ធាប់ បានដល់ មិនមែនតិច ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់ប្រកបព្រះថេរៈក្នុងធម៌ គឺសមថៈនិងវិបស្សនា មួយអន្លើដោយអង្គប្រកប ទើបត្រាស់គាថាទី ៣ ដោយន័យជាដើមថា **សុភាសិតស្ស** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **សុភាសិតស្ស សិក្ខេថ** សេចក្តីថា គប្បីសិក្សានូវព្រះបរិយត្តិធម៌ ដែលត្រាស់ល្អហើយ ចែកជាកថានៃអ្នកប្រាថ្នាតិចជាដើម ដោយអំណាចនៃការស្តាប់ ការទ្រទ្រង់ចាំ និងការសាកសួរជាដើម ។

បទថា **សមណូបាសនស្ស ច** សេចក្តីថា គប្បីសិក្សានៅការចូលទៅ

អន្ទុយជិតសមណៈដែលស្ងប់បាបហើយ និងឧបាសកដែលជាកល្យាណមិត្ត តាមកាលដ៏សមគួរ និងចរិយាដែលប្រហាក់ប្រហែលនឹងលោកទាំងនោះ ដោយបដិបទា ។

បទថា **ឯកាសនស្ស ច រហោ ចិត្តវូបសមស្ស ច** សេចក្តីថា គប្បីសិក្សាអាសនៈ គឺទីអន្ទុយរបស់បុគ្គលម្នាក់ឯង ដែលមិនមានសម្ងាញ់ ចម្រើននូវកាយវិវេក ដោយអំណាចព្យាយាមប្រកបកម្មដ្ឋានក្នុងទីស្ងាត់ ។ កាលព្យាយាមប្រកបកម្មដ្ឋានយ៉ាងនេះ នឹងញ៉ាំងការនាំឲ្យដល់ទីបំផុត ដើម្បីសិក្សានូវការស្ងប់នៃកិលេស និងការស្ងប់នៃចិត្ត ដោយអំណាចការកាត់ផ្តាច់ គឺសមុច្ឆេទប្បហាន ។ កិលេសទាំងឡាយដែលស្ងប់ទៅហើយ ដោយចំណែកមួយនោះឯង ឈ្មោះថា លោកលះបានហើយ ដោយសិក្ខាពួកណា មានអធិសីលសិក្ខាជាដើម កាលលោកសិក្សាសិក្ខាទាំងនោះ គឺសិក្ខាដែលទាក់ទងដោយមគ្គ និងផល ចិត្ត ក៏ឈ្មោះថា ស្ងប់ដោយចំណែកមួយ ។ ក្នុងទីបំផុតនៃគាថា លោកចម្រើនវិបស្សនាហើយ បានសម្រេចអរហត្តផល ។ សមដូចគាថាព័ន្ធដែលលោកពោលនៅក្នុងអបទានថា

កាលណោះ ខ្ញុំចូលទៅក្នុងព្រៃហិមពាន្ត បង្ហាញមន្តដល់ពួកសិស្ស

ឯសិស្សចំនួន ៥៤០០០ នាក់ បានបម្រើខ្ញុំ ។ សិស្សទាំងអស់នោះ ជាអ្នករៀនវេទ ដល់នូវបារមីក្នុងអង្គ ៦ រឹងប៉ឹងដោយវិជ្ជារបស់ខ្លួន នៅក្នុងព្រៃហិមពាន្ត ។ ទេវបុត្រមួយអង្គ មានយសច្រើន បានច្យុតចាកពួកទេវតា ក្នុងឋានតុសិត មកចាប់ផ្ទៃព្រះមាតា ជាអ្នកដឹងខ្លួន មានស្មារតី ។ កាលព្រះសម្ពុទ្ធបានត្រាស់លោកធាតុមួយម៉ឺនញាប់ញ័រ កាលព្រះនាយក ទ្រង់បានត្រាស់ពួកជនខ្វាក់ភ្នែកក៏បានភ្លឺភ្នែក ។ ផែនដីនេះទាំងមូល ញាប់ញ័រហើយដោយប្រការ ៦ មហាជនក៏តក់ស្លុត ព្រោះឮសំឡេងគឹកកង ។ ជនទាំងអស់ បានទៅប្រជុំគ្នាក្នុងសម្នាក់ខ្ញុំ សួរខ្ញុំថាផែនដីនេះញាប់ញ័រ តើនឹងមានផលដូចម្តេច ។ កាលណោះខ្ញុំប្រាប់ពួកជនទាំងនោះថា អ្នកទាំងឡាយកុំខ្លាចអ្វីឡើយ ភ័យនឹងមិនកើតដល់អ្នកទាំងឡាយទេ អ្នកទាំងអស់គ្នាកុំរង្កៀសឡើយការណ៍ដែលកើតឡើងនេះ ប្រកបដោយសេចក្តីសុខ និងសេចក្តីចម្រើនទេតើ ។ ផែនដីនេះ បើហេតុទាំង ៨ យ៉ាងប៉ះពាល់ហើយ

រមែងញ៉ាំង និមិត្តទាំងឡាយប្រាកដឡើង ពន្លឺដ៏ធំទូលាយប្រាកដឡើង ក៏ព្រោះហេតុនោះ ។ ព្រះពុទ្ធប្រសើរ ទ្រង់មានចក្ខុ នឹងត្រាស់ដោយឥតសង្ស័យ ខ្ញុំញ៉ាំងប្រជុំជនឲ្យដឹងច្បាស់ហើយ ទើបសម្តែងនូវសីល ៥ ពួកជនទាំងនោះ លុះបានស្តាប់នូវសីល ៥ ផង នូវការកើតឡើងនៃព្រះពុទ្ធ ដែលបុគ្គលរកបានដោយកម្រផង ក៏មានចិត្តអណ្តែតឡើង មានចិត្តរីករាយ ជាអ្នកត្រេកអរ ស្រស់ស្រាយ ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានព្យាករនូវនិមិត្តក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការព្យាករណ៍ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ៕ ✥

## អដ្ឋកថាវារណត្ថេរគាថា ចប់

---

១- ក្នុងអបទាន ជានិមិត្តព្យាករណិយត្ថេរ ។

# សុត្តន្តបិដក

## បសិ្សកត្ថេរគាថា

[ ១៧៨ ] បុគ្គលអ្នកមានសទ្ធា មានប្រាជ្ញា ឋិតនៅក្នុងធម៌ បរិបូណ៌ដោយសីល សូម្បីតែម្នាក់ឯង ក៏រមែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ដល់ពួកញាតិ និងផៅពង្ស ដែលជាអ្នកមិនមានសទ្ធា ។ ញាតិទាំងឡាយដែលខ្ញុំផ្ចញ់ផ្ចាល់រំឭក ដាស់តឿនដោយសេចក្តីអនុគ្រោះ ក៏បានធ្វើសក្ការៈចំពោះពួកភិក្ខុ ដោយសេចក្តីស្រឡាញ់ថាជាញាតិ ជាផៅពង្ស ។ ពួកញាតិទាំងនោះលុះធ្វើមរណកាល កន្លងលោកនេះទៅហើយ ក៏បានដល់នូវសេចក្តីសុខក្នុងទេវលោក ទាំងបងប្អូន និងមាតារបស់ខ្ញុំ ក៏ជាអ្នកបរិបូណ៌ដោយកាមគុណរមែងត្រេកអរដែរ ។

បសិ្សកត្ថេរ

# អដ្ឋកថា

## បស្សិកត្ថេរគាថា

[ ១៧៨ ] គាថារបស់ព្រះបស្សិកត្ថេរ មានពាក្យផ្តើមថា **ឯកោបិ សទ្ធោ មេធាវី** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ ធ្វើបុណ្យទាំងឡាយដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ។ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមអត្ថទស្សី កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្តីហើយ ។ ថ្ងៃមួយ បានឃើញព្រះសាស្តា មានចិត្តជ្រះថ្លា បានថ្វាយផ្លែដីប៉ី ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅមកក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងដែនកោសល មានឈ្មោះថា **បស្សិកៈ** ចម្រើនវ័យហើយ បានឃើញយមកប្បាដិហារ្យរបស់ព្រះសាស្តា បាននូវសទ្ធា បួសហើយ បំពេញសមណធម៌ បានជាអ្នកមានអាពាធ ។ កាលនោះ ញាតិទាំងឡាយនាំគ្នាឧបដ្ឋាកលោក ឲ្យជាសះស្បើយរោគ ដោយប្រើថ្នាំដែលគ្រូពេទ្យយល់សប្តិឃើញ ( ថ្នាំខ្មោចឲ្យ ) ព្រះថេរៈជាអាពាធហើយ មានសេចក្តីសង្វេគ បំពេញការនៃា រហូតបានសម្រេចអភិញ្ញា ៦ ។ សមដូចគាថាព័ន្ធដែលលោកពោលក្នុងអបទានថា

ខ្ញុំបានឃើញព្រះពុទ្ធ ព្រះអង្គយល់ឃើញនូវប្រយោជន៍ មាន
យសធំ ត្រង់ចន្លោះព្រៃ ក៏មានចិត្តជ្រះថ្លា មានចិត្តរីករាយ

បានថ្វាយផ្លែមិលក្ខុព្រឹក្ស ( ដីប៊ូ ) ។ ក្នុងកប្បទី ១៨០០
ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែ ខ្ញុំមិនដែល
ស្គាល់ទុគ្គតិ នេះជាផល នៃផលទាន ។ ឱ ដំណើរដែលខ្ញុំ
មកក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបាន
ដល់ហើយដោយលំដាប់ ពុទ្ធសាសនា ខ្ញុំក៏បានធ្វើហើយ ។
កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនា
របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ម្យ៉ាងទៀត លោកបានអភិញ្ញា ៦ ហើយ ទៅកាន់សម្នាក់របស់ពួកញាតិតាមអាកាស នៅលើអាកាសនោះឯង សម្តែងធម៌ឲ្យញាតិទាំងនោះតាំងនៅក្នុងសរណៈ និងសីល ញាតិទាំងនោះ ពួកខ្លះស្លាប់ហើយ កើតក្នុងស្ថានសួគ៌ ព្រោះបានតាំងនៅក្នុងសរណៈ និងសីល ។ កាលនោះ ព្រះសាស្ដាបានត្រាស់សួរព្រះបសុ្សិកត្ថេរដែលចូលមកបម្រើថា ម្នាលបសុ្សិកៈ ញាតិទាំងឡាយរបស់អ្នក មិនមានរោគទេឬ ព្រះថេរៈកាលទូលដល់ឧបការៈដែលខ្លួនបានធ្វើដល់ញាតិទាំងឡាយដល់ព្រះសាស្ដា ទើបពោល ៣ គាថាថា

បុគ្គលអ្នកមានសទ្ធា មានប្រាជ្ញា ឋិតនៅក្នុងធម៌ បរិបូណ៌ដោយ
សីល សូម្បីតែម្នាក់ឯង ក៏រមែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍
ដល់ពួកញាតិ និងផៅពង្ស ដែលជាអ្នកមិនមានសទ្ធា ។ ញាតិ
ទាំងឡាយដែលខ្ញុំផ្ចញ់ផ្ចាល់រំពុក ដាស់តឿនដោយសេចក្ដីអនុ-

---

១- ក្នុងអបទាន ជាមិលក្ខុផលទាយកត្ថេរ ។

គ្រោះ ក៏បានធ្វើសក្ការៈចំពោះពួកភិក្ខុ ដោយសេចក្តីស្រឡាញ់ ថាជាញាតិ ជាផៅពង្ស ។ ពួកញាតិទាំងនោះ លុះធ្វើមរណកាល កន្លងលោកនេះទៅហើយ ក៏បានដល់នូវសេចក្តីសុខក្នុងទេវលោក ទាំងបងប្អូន និងមាតារបស់ខ្ញុំ ក៏ជាអ្នកបរិបូណ៌ដោយកាមគុណ រមែងត្រេកអរដែរ ដូច្នេះ ។

បណ្តាបទទាំងនោះ គាថាទី ១ មានអត្ថដូចតទៅនេះថា បុគ្គលណា មានសទ្ធា ដោយអំណាចនៃការជឿក្នុងកម្ម និងផលនៃកម្ម និងការជឿក្នុងព្រះរតនត្រ័យ ឈ្មោះថា **មេធាវី** ព្រោះប្រកបដោយកម្មស្សកតាញាណជាដើមនោះឯង ឈ្មោះថា **ធម្មដ្ឋោ** ព្រោះតាំងនៅក្នុងព្រះធម៌ គឺពុទ្ធិវាទ និងនវលោកុត្តរធម៌ ឈ្មោះថា **សីលសម្បន្នោ** ដោយអំណាចសីលដែលទាក់ទងដោយអាចារ សីលដែលទាក់ទងដោយមគ្គ និងសីលដែលទាក់ទងដោយផល បុគ្គលនោះសូម្បីតែម្នាក់ក៏មានប្រយោជន៍ដល់ញាតិ ។ បុគ្គលបានឈ្មោះថា **ញាតីធំ** ព្រោះអត្ថថា ត្រូវស្គាល់គ្នាថា មនុស្សទាំងនេះ ជាមនុស្សរបស់អញ និងឈ្មោះថា **ពន្ធុ** ព្រោះអត្ថថា ពាក់ព័ន្ធ ដោយគ្រឿងចង គឺការស្រឡាញ់ ក្នុងទីនេះ គឺក្នុងលោកនេះ ដែលឈ្មោះថា **អស្សទ្ធានំ** ព្រោះមិនមានសទ្ធាដូចពោលមកហើយ ។

ដើម្បីសម្តែងអត្ថដែលលោកពោលដោយទូទៅ ឲ្យទាក់ទងជាមួយខ្លួន ទើបព្រះបស្សិកៈ ពោលគាថាដ៏សេសដោយន័យថា **និគ្គយ្ហ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **និគ្គយ្ហ អនុកម្បាយ ចោទិតា ញាតយោ**

**មយា** សេចក្តីថា ញាតិទាំងឡាយដែលខ្ញុំព្រះអង្គបានសង្កត់សង្កិនជាស់តឿនថា ក្នុងបច្ចុប្បន្ននេះ អ្នកទាំងឡាយជាអ្នកក្រីក្រ ព្រោះមិនបានធ្វើនូវកុសលតទៅ កុំបីសោយផលដែលសៅហ្មង ថោកទាបទៀតឡើយ ញាតិទាំងនោះកាលមិនអាចប្រព្រឹត្តកន្លងឱវាទរបស់ខ្ញុំព្រះអង្គបាន ព្រោះការស្រឡាញ់ខ្ញុំព្រះអង្គដែលជាញាតិ និងជាផៅពង្ស គឺព្រោះការស្រឡាញ់ដែលប្រព្រឹត្តទៅយ៉ាងនេះថា បុគ្គលនេះ ជាពូជពង្សរបស់ពួកខ្ញុំ ដូច្នេះ ទើបនាំគ្នាធ្វើសក្ការៈ ហើយជាអ្នកមានចិត្តជ្រះថ្លាក្នុងភិក្ខុទាំងឡាយ គឺនាំគ្នាធ្វើសក្ការៈ និងការរាប់អានក្នុងភិក្ខុទាំងឡាយ ដោយការប្រគេនបច្ច័យ មានចីវរជាដើម និងដោយការឧបដ្ឋាក ស្លាប់ហើយ គឺបានលះលោកនេះទៅហើយ ។ បទថា **តេ** មួយបទទៀត ត្រឹមតែជានិបាត ។

បទថា **តិទិវំ សុខំ** បានដល់ សេចក្តីសុខដែលទាក់ទងក្នុងទេវលោកម្យ៉ាងទៀត បានជួបសេចក្តីសុខដែលជាទិព្វ ដែលគួរប្រាថ្នា ។ ដើម្បីឆ្លើយនូវពាក្យសួរថា លោកទាំងនោះ គឺអ្នកណា ទើបព្រះថេរៈពោលថា ទាំងបងប្អូន និងមាតារបស់ខ្ញុំ ក៏ជាអ្នកបរិបូណ៌ដោយកាមគុណ រមែងត្រេកអរដែរ អធិប្បាយថា ជាអ្នកដល់ព្រមដោយវត្ថុកាម តាមដែលខ្លួនត្រូវការ នាំគ្នាត្រេកអរ ។៧៚

**អដ្ឋកថាបស្សិកាត្ថេរគាថា ចប់**

# សុត្តន្តបិដក

## យសោជត្ថេរគាថា

[ ១៧៩ ] ( ព្រះមានព្រះភាគទ្រង់ត្រាស់ថា ) នរៈ គឺយសោជត្ថេរនេះ មានអវយវៈប្រាកដស្មើដោយថ្នាំងនៃវល្លិ មានខ្លួនស្គម រឹមរវាមដោយសរសៃ ដឹងប្រមាណក្នុងបាយ និងទឹក ជាអ្នកមានចិត្តមិនរួញរា ។ យសោជត្ថេរពោលថា ភិក្ខុ ( នៅ ) ក្នុងព្រៃតូច ឬព្រៃធំ បើទុកជាសត្វរបោម និងមូសខាំហើយ ក៏គប្បីជាអ្នកមានស្មារតី អត់ទ្រាំចំពោះអន្តរាយមានរបោមជាដើម ក្នុងព្រៃនោះ ដូចដំរីដ៏ប្រសើរ អត់ទ្រាំក្នុងទីជាប្រធាននៃសង្គ្រាម ។ ភិក្ខុតែម្នាក់ឯង ( រមែងនៅជាសុខ ) ដូចគ្នានឹងព្រហ្ម ភិក្ខុនៅរួមគ្នា ២ រូប ( រមែងមានសេចក្តីខាំងខ្ទប់ ) ដូចគ្នានឹងទេវតា ភិក្ខុ ( នៅរួមគ្នា ) ៣ រូប ដូចគ្នានឹងជនអ្នកស្រុក ភិក្ខុមានចំនួនច្រើនរូបលើសពីនោះទៅ ជាហេតុនាំឲ្យជ្រួលជ្រើម ( ដូចគ្នានឹងពួកមហាជនដែលប្រជុំគ្នា ) ។

យសោជត្ថេរ

# អដ្ឋកថា

## យសោជត្ថេរគាថា

[ ១៧៩ ] *គាថារបស់ព្រះយសោជត្ថេរ មានពាក្យផ្តើមថា* **កាលាបព្វង្គសង្កាសោ** *ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។*

*បានឮថា កុលបុត្តនេះ មានបុញ្ញាធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ បានសន្សំបុណ្យទាំងឡាយក្នុងភពនោះៗ ។ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមវិបស្សី កើតក្នុងត្រកូលរបស់ឧទ្យានបាល ដល់នូវភាពជាអ្នកដឹងក្តីហើយ ថ្ងៃមួយ បានឃើញព្រះមានព្រះភាគព្រះនាមវិបស្សី កំពុងយាងមកតាមអាកាស មានចិត្តជ្រះថ្លា បានថ្វាយផ្លែខ្នុរសម្ល ។*

*ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតជាបុត្តអ្នកប្រមង់ ជាប្រធាននៃកុលបុត្តក្នុងត្រកូល ៥០០ ក្នុងស្រុកអ្នកប្រមង់ ក្បែរទ្វារនគរសាវត្ថី ។ មាតាបិតាបានដាក់ឈ្មោះថា* **យសោជៈ ។** *កុលបុត្តនោះ ចម្រើនវ័យហើយ បានយកសំណាញ់ទៅនេសាទត្រង់ស្ទឹងអចិរវតី ដើម្បីចាប់ត្រី មួយអន្លើដោយកូនអ្នកប្រមង់ដែលជាសម្លាញ់របស់ខ្លួន ។ បណ្តាត្រីទាំងនោះ ត្រីធំមួយ មានពណ៌ដូចមាស ចូលក្នុងសំណាញ់ ។ អ្នកប្រមង់ទាំងនោះ នាំគ្នាយកត្រីទៅថ្វាយព្រះបាទ បសេនទិកោសលដើម្បីទត ។ ព្រះរាជាត្រាស់ថា ព្រះមានព្រះភាគប៉ុណ្ណោះ ទើបទ្រង់ជ្រាបហេតុដែលត្រីនេះមានពណ៌ដូចមាស ហើយទ្រង់ឲ្យពួកកុមារទាំងនោះ យកត្រីទៅថ្វាយព្រះមានព្រះភាគទត ។ ព្រះមានព្រះភាគ*

ត្រាស់ថា ត្រីនេះ នាកាលសាសនារបស់ព្រះកស្សបសម្មាសម្ពុទ្ធកំពុងសាប សូន្យ បួសហើយ បដិបត្តិខុស ពោលបន្ទាប់ទូវពុទ្ធដីកា ទើបទៅកើតក្នុង នរក ឆេះក្នុងនរកអស់មួយពុទ្ធន្តរ ចុតិអំពីនរកនោះហើយ ក៏មកកើតជាត្រីធំ ក្នុងស្ទឹងអចិរវតី ហើយទ្រង់ឲ្យត្រីនោះឯងប្រាប់ភាពដែលខ្លួន និងប្អូនស្រីកើត ក្នុងនរក និងប្រាប់ភាពដែលព្រះថេរៈជាបងប្រុសបរិនិព្វានហើយ ទើបទ្រង់ សម្ដែងកបិលសូត្រ ព្រោះអត្ថុប្បត្តិហេតុនេះ ។

យសោជកុមារ កាលបានស្ដាប់ព្រះធម្មទេសនារបស់ព្រះមានព្រះភាគ ហើយ កើតសេចក្ដីសង្វេគ ទើបបួសក្នុងសម្នាក់របស់ព្រះសាស្ដា មួយអន្លើ ដោយសម្លាញ់របស់ខ្លួន ស្នាក់នៅក្នុងទីដ៏សមគួរ ថ្ងៃមួយ ព្រះថេរៈ និងបរិវារ បានទៅកាន់វត្តជេតពន ដើម្បីថ្វាយបង្គំព្រះមានព្រះភាគ ។ ក្នុងការមករបស់ ព្រះថេរៈ មានសំឡេងកងរំពង ដោយការរៀបចំសេនាសនៈជាដើម ។ អ្នក សិក្សាគួរជ្រាបរឿងទាំងអស់ដោយន័យដែលមានមកហើយ ក្នុងគម្ពីរឧទានថា ព្រះសាស្ដា កាលបានស្ដាប់សំឡេងនោះហើយ ទ្រង់បានបណ្ដេញយសោជៈ មួយអន្លើដោយបរិវារ ឯព្រះយសោជៈដែលត្រូវបណ្ដេញហើយ មានចិត្ត សង្វេគ ដូចសេះអាជានេយ្យដែលវាយដោយរំពាត់ ទើបសម្រាកត្រង់ឆ្នេរ ស្ទឹងវគ្គុមុទា មួយអន្លើដោយបរិវារ ព្យាយាមចម្រើនវិបស្សនា បានសម្រេច អភិញ្ញា ៦ ខាងក្នុងវស្សានោះឯង ។ សមដូចគាថាព័ន្ធដែលលោកពោល ក្នុងអបទានថា

ក្នុងកាលនោះ ខ្ញុំជាអារាមិកជន ( អ្នកថែសួនច្បារ ) នៅក្នុង

នគរពន្ធុមតី បានឃើញព្រះពុទ្ធ ព្រះអង្គប្រាសចាកធូលី គឺរាគៈ កំពុងស្តេចទៅក្នុងអាកាស ។ ខ្ញុំបានយកផ្លែខ្នុរសម្លថ្វាយព្រះពុទ្ធដ៏ប្រសើរ ឯព្រះសម្ពុទ្ធមានយសដ៏ធំ មានព្រះហឫទ័យស្ងប់រម្ងាប់ បានទ្រង់ឋិតនៅក្នុងអាកាស ទទួលយក ។ ខ្ញុំមានការកើតឡើងនៃបីតិ ដែលជាគុណ នាំមកនូវសេចក្តីសុខក្នុងបច្ចុប្បន្ន ព្រោះតែថ្វាយផ្លែខ្នុរដល់ព្រះពុទ្ធ ដោយចិត្តជ្រះថ្លា ។ ក្នុងកាលនោះឯង ខ្ញុំមានបីតិដ៏ទូលំទូលាយផង មានសេចក្តីសុខដ៏ឧត្តមផង រតនៈតែងកើតឡើងដល់ខ្ញុំ ដែលកើតហើយក្នុងឋានទាំងពួង ។ ក្នុងកប្ប ទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ ឱ ដំណើរដែលខ្ញុំមកក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយដោយលំដាប់ សាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើហើយ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះសាស្តាត្រាស់ឲ្យហៅព្រះយសោជៈ មួយអន្លើដោយបរិវារដែលជាអ្នកមានអភិញ្ញា ៦ ហើយ ទ្រង់បានធ្វើការទទួលដោយអនេញ្ជសមាបត្តិ លោកសមាទានធុតង្គធម៌គ្រប់ទាំង ១៣ ។ ដោយហេតុនោះ រាងកាយរបស់

---

១- ក្នុងអបទាន ជាលពុជទាយកត្ថេរ ។

ព្រះថេរៈក៏ស្គាំងស្គមសៅហ្មង ពណ៌សម្បុរក៏អាប់ឱនទៅ ។ ព្រះមានព្រះភាគកាលទ្រង់សរសើរព្រះថេរៈដោយភាពជាអ្នកប្រាថ្នាតិចក្រៃលែង ទើបត្រាស់គាថាទី ១ ថា

( ព្រះមានព្រះភាគទ្រង់ត្រាស់ថា ) នរៈ គឺយសោជត្ថេរនេះ មានអវយវៈប្រាកដស្មើដោយថ្នាំងនៃវល្លិ មានខ្លួនស្គម រវីមរវាមដោយសរសៃ ដឹងប្រមាណក្នុងបាយ និងទឹក ជាអ្នកមានចិត្តមិនរួញរា ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កាលាបព្វង្គសង្កាសោ** សេចក្ដីថា មានខ្លួនដូចគ្នានឹងថ្នាំងវល្លិលែនពែន ព្រោះមានអវយវៈរាងកាយស្គម តាំងនៅដោយលំបាក ដោយប្រាសចាកសាច់ ហេតុនោះ ទើបទ្រង់ត្រាស់ថា **កិសោ ធមនិសណ្ឋតោ** ប្រែថា មានខ្លួនស្គមរវីមរវាមដោយសរសៃ ។ បទថា **កិសោ** បានដល់ មានរូបកាយស្គម ព្រោះបំពេញមោនេយ្យបដិបទា ( បដិបទារបស់មុនី ) ។ បទថា **ធមនិសណ្ឋតោ** សេចក្ដីថា មានខ្លួនដល់ព្រមដោយសរសៃ អធិប្បាយថា មានរូបរាងដេរដាសទៅដោយសរសៃធំៗ ដែលប្រាកដច្បាស់ ព្រោះមានសាច់ និងឈាមតិច ។

បទថា **មត្តញ្ញូ** បានដល់ ជាអ្នកដឹងប្រមាណក្នុងការស្វែងរក ការទទួល ការឆាន់ និងការលះបង់ ។

បទថា **អលីនមនសោ** បានដល់ ជាអ្នកមានចិត្តមិនរួញរា ព្រោះមិនត្រូវសេចក្ដីខ្ជិលច្រអូសជាដើមគ្របសង្កត់ គឺជាអ្នកមានការប្រព្រឹត្តមិនខ្ជិល

ប្រុស ។

បទថា **ឆរោ** បានដល់ បុរស គឺអ្នកសម្បូរដោយលក្ខណៈរបស់បុរស ព្រោះនាំធុរៈរបស់កូនប្រុសទៅបាន អធិប្បាយថា បុរសដែលបានការ ។

ព្រះថេរៈកាលព្រះសាស្តាទ្រង់សរសើរយ៉ាងនេះហើយ កាលនឹងពោលធម៌ដែលសមគួរដល់ខ្លួនដែលជាបុគ្គលត្រូវព្រះសាស្តាសរសើរហើយ ដល់ភិក្ខុទាំងឡាយ ដោយចង្អុលបង្ហាញដល់អធិវាសនខន្តី វិរិយារម្ភៈ និងការត្រេកអរក្នុងវិវេករបស់ខ្លួន ទើបបានភាសិត ២ គាថាថា

យសោជត្ថេរ ពោលថា ភិក្ខុ ( នៅ ) ក្នុងព្រៃតូច ឬព្រៃធំ បើទុកជាសត្វរបោម និងមូសខាំហើយ ក៏គប្បីជាអ្នកមានស្មារតីអត់ទ្រាំចំពោះអន្តរាយ មានរបោមជាដើម ក្នុងព្រៃនោះ ដូចដំរីដ៏ប្រសើរ អត់ទ្រាំក្នុងទីជាប្រធាននៃសង្គ្រាម ។ ភិក្ខុតែម្នាក់ឯង (រមែងនៅជាសុខ) ដូចគ្នានឹងព្រហ្ម ភិក្ខុនៅរួមគ្នា ២ រូប ( រមែងមានសេចក្តីខ្ចាំងខ្ចប់ ) ដូចគ្នានឹងទេវតា ភិក្ខុ ( នៅរួមគ្នា ) ៣ រូប ដូចគ្នានឹងជនអ្នកស្រុក ភិក្ខុមានចំនួនច្រើនរូប លើសពីនោះទៅ ជាហេតុនាំឲ្យជ្រួលជ្រើម ( ដូចគ្នានឹងពួកមហាជនដែលប្រជុំគ្នា ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឆាគោ សង្គាមសីសេវ** សេចក្តីថា ដូចឧបមាមួយថា ដំរីអាជានេយ្យដ៏ប្រសើរ អត់ធន់នឹងគ្រឿងប្រហារ មានដាវលំពែងសម្រាប់ចាក់ និងលំពែងសម្រាប់ពួយជាដើមក្នុងសមរភូមិ ហើយ

កម្ចាត់សេនានុភាពបច្ចាមិត្តបាន យ៉ាងណា ភិក្ខុក៏ដូច្នោះ គួរមានសតិសម្ប-ជញ្ញៈ អត់ធន់នឹងអន្តរាយ មានរបោមជាដើមក្នុងព្រៃធំ គឺក្នុងដងព្រៃ ព្រោះកាលអត់ធន់បានហើយ គប្បីកម្ចាត់មារ និងសេនាបាន ដោយកម្លាំងនៃភាវនា ។

បទថា **យថា ព្រហ្មា** សេចក្តីថា ព្រះព្រហ្មតែមួយ មិនមានអ្នករំខានជាអ្នកនៅដោយឈានសុខជានិច្ច យ៉ាងណា បទថា **តថា ឯកោ** សេចក្តីថា ភិក្ខុនៅតែឯង មិនមានសម្លាញ់ ក៏ដូច្នោះដូចគ្នា នឹងចម្រើនសេចក្តីសុខដែលកើតអំពីវិវេកជាផាសុក ។ សមដូចលោកពោលថា សេចក្តីសុខរបស់សមណៈនៃភិក្ខុដែលត្រាច់ទៅតែម្នាក់ឯង ជាសេចក្តីសុខដ៏ឧត្តម ។ ដោយបទថា **យថា ព្រហ្មា តថា ឯកោ** នេះ ព្រះថេរៈឲ្យឱវាទថា ភិក្ខុអ្នកនៅមួយអង្គឯងជាប្រក្រតី ជាបុគ្គលស្មើដូចព្រហ្ម ។

បទថា **យថា ទេវោ តថា ទុវេ** សេចក្តីថា ទេវតាទាំងឡាយគង់មានការសាំញ៉ាំចិត្តជាខណៈៗ យ៉ាងណា សូម្បីការប៉ះខ្ទប់គ្នា ព្រោះការនៅរួមគ្នាក៏គង់មានដល់ភិក្ខុ ២ រូប ដូច្នោះ ។

ព្រោះហេតុនោះ ទើបលោកពោលថា ភិក្ខុដូចគ្នានឹងទេវតា ព្រោះនៅជាមួយសម្លាញ់ ។

បទថា **យថា គាមោ តថា តយោ** សេចក្ដីថា ក្នុងបាលីនេះប៉ុណ្ណោះ កាលនៅរួមគ្នារបស់ភិក្ខុ ៣ រូប ដូចការនៅរួមរបស់អ្នកស្រុក អធិប្បាយថា មិនមែនការនៅដោយវិវេក ។

បទថា **កោលាហលំ តតុត្តរឹ** សេចក្ដីថា ការនៅរួមគ្នាលើស ៣ នាក់ ឬច្រើនជាងនោះ ជាកោលាហល អធិប្បាយថា ដូចការនៅជួបជុំរបស់ពួកមនុស្សដែលមានសំឡេងអឺងកង ព្រោះដូច្នោះ ភិក្ខុគួរនៅម្នាក់ឯងជាប្រក្រតី ។៙

**អដ្ឋកថា យសោជត្ថេរគាថា ចប់**

# សុត្តន្តបិដក

## សាជិមត្តិយត្ថេរគាថា

[ ១៨០ ] សទ្ធារបស់អ្នក មានក្នុងកាលមុន ប៉ុន្តែក្នុងថ្ងៃនេះ សទ្ធានោះ បែរជាមិនមានដល់អ្នកវិញ បច្ច័យណា ដែលជារបស់អ្នក បច្ច័យនោះ ចូរជារបស់អ្នកវិញចុះ ទុច្ចរិត មិនមានដល់អាត្មាទេ ។ ព្រោះថាសទ្ធា ( របស់បុថុជ្ជន ) ជាធម្មជាតឃ្លេងឃ្លោង មិនទៀង សទ្ធាយ៉ាងនេះ អាត្មាបានឃើញជាក់ច្បាស់ហើយ សត្វទាំងឡាយ ជួនកាលត្រេកអរ ជួនកាលប្រាសចាកសេចក្តីត្រេកអរ ( ព្រោះហេតុនោះ ) អ្នកប្រាជ្ញនឹងឈ្នះចំពោះការត្រេកអរ និងមិនត្រេកអរនោះ ដូចម្តេចកើត ។ កត្តដែលគេចម្អិនបម្រុងអ្នកប្រាជ្ញ បន្តិចៗ រាល់ៗ ត្រកូល អាត្មានឹងត្រាច់ទៅ ដើម្បីដុំបាយ ( ព្រោះ ) កម្លាំងស្នងរបស់អាត្មាមាននៅឡើយ ។

សាជិមត្តិយត្ថេរ

# អដ្ឋកថា

## សាជិមត្តិយត្ថេរគាថា

[ ១៨០ ] គាថារបស់ព្រះសាជិមត្តិយត្ថេរ មានពាក្យផ្ដើមថា **អហុ តុយ្ហំ បុរេ សទ្ធា** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ បានសន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ។ ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមសិទ្ធត្ថ កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្ដីហើយ ។ ថ្ងៃមួយ ឃើញព្រះសាស្ដា មានចិត្តជ្រះថ្លា បានប្រគេនផ្ចិតស្លឹកត្នោត ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅមកក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងដែនមគធៈ មានឈ្មោះថា **សាជិមត្តិយៈ** ចម្រើនវ័យហើយ បួសក្នុងសម្នាក់ភិក្ខុ នៅព្រៃព្រោះជាអ្នកដល់ព្រមដោយហេតុ បំពេញវិបស្សនាកម្មដ្ឋាន បាននូវអភិញ្ញា ៦ ។ សមដូចគាថាព័ន្ធដែលលោកពោលក្នុងអបទានថា

ខ្ញុំបានថ្វាយផ្ចិតស្លឹកត្នោត ដែលគេរំលេចដោយផ្កាម្លិះទាំងឡាយ
ដល់ព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថៈ ខ្ញុំបានបាំងថ្វាយព្រះពុទ្ធ
មានយសធំ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែល
ខ្ញុំបានថ្វាយផ្ចិតស្លឹកត្នោត ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃ
ផ្ចិតស្លឹកត្នោត ។ ឱ ដំណើរដែលខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធរបស់

ខ្ញុំ លុះណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយដោយលំដាប់ ពុទ្ធ-សាសនា ខ្ញុំក៏បានធ្វើហើយ ។ កិលេសទាំងឡាយ ខ្ញុំបានដុត បំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិ ហើយ ដូច្នេះ(១) ។

១- ក្នុងអបទាន ជាសុមនតាលវណ្តិយត្ថេរ ។

ម្យ៉ាងទៀត កាលលោកបានជាព្រះអរិយបុគ្គលមានអភិញ្ញា ៦ ហើយ ក៏ពោលដាស់តឿនភិក្ខុទាំងឡាយ និងសម្តែងធម៌ដល់មហាជន ឲ្យតាំងនៅ ក្នុងសរណៈ និងសីល ទាំងបានធ្វើត្រកូលដទៃដែលមិនមានសទ្ធា ឲ្យមាន សទ្ធា មិនជ្រះថ្លាឲ្យជ្រះថ្លា ព្រោះហេតុនោះ ទើបមនុស្សទាំងឡាយ ក្នុង ត្រកូលនោះ ជ្រះថ្លាក្នុងព្រះថេរៈច្រើន ។ បណ្តាមនុស្សទាំងនោះ ទារិកាម្នាក់ មានរូបល្អគួរគយគន់អង្គាសព្រះថេរៈ ដែលចូលទៅបិណ្ឌបាត ដោយកោដន និងសេចក្តីគោរព ។

ថ្ងៃមួយ មារគិតថា ការអប្បយសនឹងមានដល់ព្រះថេរៈ ដោយឧបាយ យ៉ាងនេះ ព្រះថេរៈនឹងតាំងនៅមិនបានក្នុងព្រះសាសនានេះ ហើយនិម្មិតខ្លួន ជាព្រះថេរៈ ចាប់ដៃទារិកានោះ ។ ទារិកាដឹងថា សម្ផស្សដៃនេះ មិនមែន របស់មនុស្ស បានឲ្យមារលែងដៃ មនុស្សក្នុងផ្ទះបានឃើញហេតុការណ៍នោះ ហើយ កើតសេចក្តីមិនជ្រះថ្លាក្នុងព្រះថេរៈ ស្អែកឡើង ព្រះថេរៈមិនជ្រាប ហេតុការណ៍នោះ បាននិមន្តទៅបិណ្ឌបាតត្រង់ផ្ទះនោះតាមទម្លាប់ មនុស្សទាំង ឡាយក្នុងផ្ទះនោះ មិនបានធ្វើនូវការអើពើ ។ ព្រះថេរៈរឭកដល់ហេតុការណ៍

នោះ បានឃើញកិរិយារបស់មារ ទើបអធិដ្ឋានថា សូមគម្រង់ផ្កាជាប់ត្រង់កមារនោះ មារក៏ចូលមករកព្រះថេរៈ ដើម្បីឲ្យព្រះថេរៈដោះគម្រង់ផ្កានោះចេញ ប្រាប់កិរិយាដែលខ្លួនធ្វើ ក្នុងថ្ងៃកន្លងមក ព្រះថេរៈគំរាមមារនោះហើយ ទើបដោះឲ្យ ។ ម្ចាស់ផ្ទះបានឃើញហេតុការណ៍នោះ ទើបនាំគ្នាសូមខមាទោសព្រះថេរៈថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់អភ័យទោសចុះ ហើយពិតបន្តថា បពិត្រលោកម្ចាស់ ចាប់ពីថ្ងៃនេះទៅ ខ្ញុំម្នាក់ឯងប៉ុណ្ណោះសូមឧបដ្ឋាកដល់លោកម្ចាស់ ។ ព្រះថេរៈកាលពោលធម្មកថាដល់ជនទាំងនោះ ក៏បានពោល ៣ គាថាថា

សទ្ធារបស់អ្នក មានក្នុងកាលមុន ប៉ុន្តែក្នុងថ្ងៃនេះ សទ្ធានោះ បែរជាមិនមានដល់អ្នកវិញ បច្ច័យណា ដែលជារបស់អ្នក បច្ច័យនោះ ចូរជារបស់អ្នកវិញចុះ ទុច្ចរិត មិនមានដល់អាត្មាទេ ។ ព្រោះថា សទ្ធា ( របស់បុថុជ្ជន ) ជាធម្មជាតឃ្លេងឃ្លោង មិនទៀង សទ្ធាយ៉ាងនេះ អាត្មាបានឃើញជាក់ច្បាស់ហើយ សត្វទាំងឡាយ ជួនកាលត្រេកអរ ជួនកាលប្រាសចាកសេចក្តីត្រេកអរ ( ព្រោះហេតុនោះ ) អ្នកប្រាជ្ញនឹងឈ្នះចំពោះការត្រេកអរ និងមិនត្រេកអរនោះ ដូចម្តេចកើត ។ ភត្តដែលគេចម្អិនបម្រុងអ្នកប្រាជ្ញ បន្តិចៗ រាល់ៗ ត្រកូល អាត្មានឹងត្រាច់ទៅ ដើម្បីដុំបាយ ( ព្រោះ ) កម្លាំងស្នងរបស់អាត្មាមាននៅឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អហុ តុយ្ហំ បុរេ សទ្ធា សា តេ អជ្ជ ន**

**វិជ្ជតិ** សេចក្តីថា នែឧបាសក ថ្ងៃមុន អ្នកទាំងឡាយមានសទ្ធាក្នុងអាត្មា ដោយន័យជាដើមថា លោកម្ចាស់ជាអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើ តែក្នុងថ្ងៃនេះ គឺឥឡូវនេះ សទ្ធារបស់អ្នក មិនមាន ព្រោះហេតុនោះ ទើបបទថា **យំ តុយ្ហំ តុយ្ហមេវេតំ** អធិប្បាយថា ការឲ្យបច្ច័យ ៤ ឯណា បច្ច័យនោះ ចូរជារបស់ញោមចុះ អាត្មាមិនត្រូវការដោយរបស់នោះ ព្រោះថា ធម្មតាទានបុគ្គលមានចិត្តជ្រះថ្លាដោយប្រពៃ ទើបគួរឲ្យ ។

ម្យ៉ាងទៀត បទថា **យំ តុយ្ហំ តុយ្ហមេវេតំ** នេះ មានអត្ថថា ថ្ងៃនេះ ការមិនគោរពក្នុងអាត្មារបស់ញោមឯណា ការមិនគោរពនោះ ក៏ជារបស់ញោមនោះឯង ផលនៃការមិនគោរព ញោមនោះឯងជាអ្នកសោយ មិនមែនអាត្មាទេ ។

បទថា **នត្ថិ ទុច្ចរិតំ មម** សេចក្តីថា ឈ្មោះថា ទុច្ចរិតរបស់អាត្មាមិនមាន ព្រោះកិលេសទាំងឡាយ ដែលជាហេតុនៃទុច្ចរិត អាត្មាកាត់ផ្តាច់ហើយ ដោយអរិយមគ្គ ។

បទថា **អនិច្ចា ហិ ចលា សទ្ធា** សេចក្តីថា ព្រោះហេតុដែលសទ្ធាជារបស់បុថុជ្ជន ជារបស់មិនទៀង មិនប្រព្រឹត្តទៅដោយចំណែកមួយ ដូច្នោះឯង ទើបជារបស់ឃ្លេងឃ្លោង មិនតាំងមាំ ដូចត្រឡាចដាក់លើខ្នងសេះ និងដូចបង្គោលដែលដោតលើអង្កាម ។

បទថា **ឯវំ ទិដ្ឋា ហិ សា មយា** សេចក្តីថា សទ្ធានោះយ៉ាងនេះ អាត្មាឃើញហើយ គឺដឹងច្បាស់ហើយក្នុងខ្លួនញោម ។

បទថា **រជ្ជន្តិបិ វិរជ្ជន្តិ** សេចក្តីថា ដើមឡើយសត្វទាំងឡាយនេះ ធ្វើនូវសេចក្តីស្រឡាញ់ណាមួយ ដោយអំណាចការស្និទ្ធស្នាលជាមិត្រ តែដួនកាលក៏នឿយណាយ គឺមានចិត្តសោយ ព្រោះសទ្ធាមិនមាំទាំ ដោយប្រការដូច្នេះ ។ បទថា **តត្ថ កឹ ជិយ្យតេ មុនិ** សេចក្តីថា មុនី គឺអ្នកបួសនឹងយកឈ្នះធ្វើអ្វី ក្នុងសេចក្តីស្រឡាញ់ និងការនឿយណាយរបស់បុថុជ្ជននោះ អធិប្បាយថា មុនីនោះ នឹងមានសេចក្តីវិនាសអ្វី ។

ព្រះថេរៈ កាលសម្តែងថា អ្នកកុំគិតយ៉ាងនេះថា បើលោកម្ចាស់មិនទទួលបច្ច័យរបស់អញ លោកម្ចាស់នឹងញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅបានដូចម្តេច ទើបពោលគាថាថា **បចន្តិ** ជាដើម ។

អត្ថនៃគាថានោះ មានដូច្នេះថា ធម្មតាភត្តាហាររបស់មុនី គឺអ្នកបួសមនុស្សចម្អិនរាល់ថ្ងៃ មួយត្រកូលបន្តិចៗ តាមលំដាប់ផ្ទះ មិនមែនចម្អិនតែក្នុងផ្ទះរបស់ញោមប៉ុណ្ណោះទេ ។

បទថា **បិណ្ឌិកាយ ចរិស្សាមិ អត្ថិ ជង្ឃពលំ មម** សេចក្តីថា ព្រះថេរៈសម្តែថា អាត្មានៅមានកម្លាំងស្មង អាត្មាមិនមែនមនុស្សបាក់ស្មង មិនមែនមនុស្សខ្វិន នឹងមិនមែនអ្នកមានរោគជើង ព្រោះហេតុនោះ អាត្មានឹងដើរទៅបិណ្ឌបាត ដើម្បីកិក្ខាដែលលាយឡំគ្នា គឺអាត្មានឹងដើរបិណ្ឌបាតចិញ្ចឹមជីវិតតាមន័យដែលព្រះសាស្តាត្រាស់ ( ក្នុងធម្មបទថា ) ថា **យថាបិ ភមរោ បុប្ផំ** ដូច្នោះ ៕៚

**អដ្ឋកថាសាជិមត្តិយត្ថេរគាថា ចប់**

# សុត្តន្តបិដក

## ឧទាលិត្ថេរគាថា

[ ១៨១ ] កុលបុត្ត ចេញ ( ចាកឃរាវាស ) ដោយសទ្ធាហើយ បួសថ្មី ជានវកិក្ខុ គប្បីគប់រកកល្យាណមិត្តទាំងឡាយ ដែលជាអ្នកមានការចិញ្ចឹមជីវិតដោយបរិសុទ្ធ អ្នកមិនខ្ជិលច្រអូស ។ កុលបុត្ត ចេញ ( ចាក-ឃរាវាស ) ដោយសទ្ធា បួសថ្មីជានវកិក្ខុ អ្នកមានប្រាជ្ញា កាលនៅក្នុងពួកគប្បីសិក្សានូវវិន័យ ។ កុលបុត្ត ចេញ ( ចាកឃរាវាស ) ដោយសទ្ធា បួសថ្មី ជានវកិក្ខុ ជាអ្នកឈ្លាស ក្នុងហេតុដែលគួរ និងមិនគួរទាំងឡាយ គប្បីប្រព្រឹត្តកុំឲ្យ ( ពួកកិលេសមានតណ្ហាជាដើម ) ប្រព្រឹត្តទៅក្នុងខាងមុខបាន ។

ឧបាលិត្ថេរ

# អដ្ឋកថា

## ឧទាលិត្ថេរគាថា

[ ១៨១ ] គាថារបស់ព្រះឧបាលិត្ថេរ មានពាក្យផ្តើមថា **សទ្ធាយ អភិនិក្ខម្ម** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះ ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កើតក្នុងផ្ទះមានត្រកូល ក្នុងនគរហង្សវតី ។ ថ្ងៃមួយ ស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តា បានឃើញព្រះសាស្តាទ្រង់តែងតាំងភិក្ខុមួយរូប ក្នុងតំណែង

ឯតទគ្គៈ គឺជាកំពូលជាងភិក្ខុទាំងឡាយ ខាងទ្រទ្រង់នូវព្រះវិន័យ ធ្វើកម្ម គឺបុញ្ញាធិការហើយ បានប្រាថ្នាឋានន្តរនោះ ។ កុលបុត្តនោះ បំពេញកុសលដរាបដល់អស់ជីវិតហើយ អន្ទោលទៅមកក្នុងទេវតា និងមនុស្សទាំងឡាយ លុះដល់ពុទ្ធុប្បាទនេះ បដិសន្ធិក្នុងផ្ទះជាងកោរកាត់ មាតាបិតាបានដាក់ឈ្មោះកុលបុត្តនោះថា **ឧបាលី** ។ កុលបុត្តនោះ ចម្រើនវ័យហើយ ជាទីប្រោសប្រាណរបស់ស្តេច ៦ អង្គ មានអនុរុទ្ធរាជកុមារជាដើម ។ កាលព្រះតថាគតគង់ត្រង់អនុបិយអម្ពវ័ន បានចេញបួស មួយអន្លើដោយក្សត្រ ៦ អង្គ ដែលចេញទៅដើម្បីបព្វជ្ជា ។ ការបួសរបស់កុលបុត្តនោះមានហើយក្នុងព្រះបាលី ។

ព្រះថេរៈ កាលបព្វជ្ជាឧបសម្បទាហើយ បានទទួលយកកម្មដ្ឋាន ក្នុងសម្នាក់របស់ព្រះសាស្តា ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់អនុញ្ញាតឲ្យខ្ញុំព្រះអង្គនៅព្រៃចុះ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ បើអ្នកនៅព្រៃ ធុរៈមួយប៉ុណ្ណោះនឹងចម្រើន តែបើបដិបត្តិក្នុងសម្នាក់របស់តថាគត គន្ថធុរៈផង វិបស្សនាធុរៈផង នឹងបរិបូណ៌ ។ ព្រះថេរៈទទួលព្រះពុទ្ធតម្រាស់ហើយ បំពេញវិបស្សនាកម្មដ្ឋាន មិនយូរប៉ុន្មានក៏បាន សម្រេចអរហត្តផល ។ សមដូចគាថាព័ន្ធដែលលោកពោលក្នុងអបទានថា

ខ្ញុំកើតជាព្រាហ្មណ៍ ឈ្មោះសុជាត ក្នុងក្រុងហង្សវតី ជាអ្នកសន្សំនូវទ្រព្យសម្បត្តិ ចំនួន ៨០ កោដិ មានទ្រព្យ និងស្រូវជាច្រើន ។ ខ្ញុំជាអ្នកបង្រៀនមន្ត ចេះចាំមន្ត សម្រេចត្រៃវេទ ដល់នូវត្រើយក្នុងធម៌របស់ខ្លួន គឺក្បួនទាយលក្ខណៈ និងក្បួន

ឈ្មោះឥតិហាសៈ ។ ក្នុងគ្រានោះ ពួកបរិព្វាជក អ្នកមានផ្នួងសក់មួយ ពួកពុទ្ធសាវ័ករបស់ព្រះគោតម និងពួកតាបសអ្នកប្រព្រឹត្តតបៈ តែងនាំគ្នាត្រាច់ទៅលើផែនដី ។ ពួកទាំងនោះតែងចោមរោមខ្ញុំ ពួកជនជាច្រើន តែងបូជាខ្ញុំ ដោយសម្គាល់ថាជាព្រាហ្មណ៍ មានកិត្តិសព្ទល្បីល្បាញ ខ្ញុំមិនបូជាជនណាមួយ ។ វេលានោះ ខ្ញុំជាមនុស្សរឹងត្អឹងដោយមានះ មិនឃើញបុគ្គលគួរបូជា ទាំងពាក្យថា ព្រះពុទ្ធ ក៏មិនដែលមាន ព្រោះព្រះជិនស្រី ទ្រង់មិនទាន់កើតឡើងនៅឡើយ ។ លុះកន្លងថ្ងៃនិងយប់ទៅ ព្រះពុទ្ធទ្រង់ព្រះនាមបទុមុត្តរៈ ទ្រង់មានបញ្ញាចក្ខុកម្ចាត់បង់នូវងងឹតទាំងពួង ទ្រង់កើតឡើងក្នុងលោក ។ កាលបើពួកជនជាអ្នកប្រាជ្ញ មានចំនួនច្រើនផ្សាយទៅផង សាសនារីកក្រាស់ក្រែលផង គ្រានោះ ព្រះសម្ពុទ្ធស្តេចចូលទៅកាន់ក្រុងហង្សវតី ។ ព្រះពុទ្ធមានបញ្ញាចក្ខុនោះ ទ្រង់សម្តែងធម៌ដើម្បីប្រយោជន៍ ដល់ព្រះបិតាក្នុងវេលានោះ ពួកបរិស័ទប្រមាណមួយយោជន៍ ដោយជុំវិញ ( មកគាល់ព្រះអង្គ ) តាមកាល ដ៏គួរនោះ ។ គ្រានោះ តាបស ឈ្មោះសុនន្ទៈ ដែលពួកមនុស្សរាប់អាន បានបិទបាំងពុទ្ធបរិស័ទទាំងអស់ដោយផ្កាទាំងឡាយ ។ កាលព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រកាសសច្ចៈទាំង ៤ ក្នុងមណ្ឌប ដ៏ហើយដោយផ្កាដ៏ប្រសើរ ពួក

បរិស័ទ មួយសែនកោដិ ក៏បានសម្រេចធម្មាភិសម័យ ។ ព្រះសម្ពុទ្ធទ្រង់បន្ទូរភ្លៀង គឺព្រះធម៌ អស់ ៧ យប់ ៧ ថ្ងៃ លុះដល់ថ្ងៃទី ៨ ព្រះជិនស្រី ក៏ទ្រង់បានទំនាយនូវតាបសឈ្មោះសុនន្ទៈថា សុនន្ទតាបសនេះ កាលអន្ទោលទៅក្នុងភព គឺទេវលោក ឬមនុស្សលោក នឹងបានជាអ្នកប្រសើរជាងទេវតាទាំងជាងមនុស្សទាំងអស់ នឹងអន្ទោលទៅក្នុងភពទាំងឡាយ ។ លុះដល់វេលាមួយសែនកប្ប នឹងមានព្រះសម្ពុទ្ធ ព្រះនាមគោតម កើតឡើងក្នុងត្រកូលឱក្កាកៈ នឹងបានជាសាស្ដាក្នុងលោក ។ សុនន្ទតាបសនេះ នឹងបានជាទាយាទក្នុងធម៌ ជាឱរស ជាធម្មនិម្មិត ជាសាវកឈ្មោះបុណ្ណៈ ជាបុត្តនៃនាងមន្តានីរបស់ព្រះសាស្ដានោះ ។ លុះព្រះសម្ពុទ្ធ បានព្យាករសុនន្ទតាបសយ៉ាងនេះហើយ បានញ៉ាំងជនទាំងពួងឲ្យរីករាយទ្រង់សម្ដែងតាមកម្លាំងរបស់ព្រះអង្គ ។ វេលានោះ ពួកបរិស័ទបានប្រណម្យអញ្ជលីនមស្ការចំពោះសុនន្ទតាបស សុនន្ទតាបសក៏ធ្វើសក្ការបូជាចំពោះព្រះសម្ពុទ្ធ រួចហើយ ទើបធ្វើគតិរបស់ខ្លួនឲ្យស្អាត ។ ខ្ញុំបានស្ដាប់ព្រះពុទ្ធដីការបស់ព្រះមុនី ( ព្រះនាមបទុមុត្តរៈ ) ក៏មានបំណងក្នុងវេលានោះថា អាត្មាអញនឹងបានឃើញព្រះគោតម យ៉ាងណា នឹងធ្វើសក្ការបូជាយ៉ាងនោះ ។ លុះខ្ញុំគិតយ៉ាងនេះរួចហើយ ទើបគិតរកបុញ្ញកិរិយាវត្ថុ

ដែលខ្ញុំគួរធ្វើថា អាត្មាអញនឹងប្រព្រឹត្តអំពើអ្វីហ្ន៎ ក្នុងបុញ្ញក្ខេត្តដ៏ប្រសើរ ។ ឯភិក្ខុជាអ្នកសូត្រអង្គនេះ ព្រះមានព្រះភាគបានតាំងថា ជាអ្នកប្រសើរខាងព្រះវិន័យ ជាងភិក្ខុអ្នកសូត្រទាំងពួង ក្នុងសាសនា ដូច្នេះ អាត្មាអញនឹងប្រាថ្នាយកតំណែងនោះ ។ ទ្រព្យរបស់អាត្មាអញនេះច្រើនណាស់ រាប់មិនអស់ ឧបមាដូចសាគរ បុគ្គលមិនអាចនឹងឲ្យញាប់ញ័របានឡើយ ហេតុនោះ អាត្មាអញគួរសាងអារាម ថ្វាយព្រះសម្ពុទ្ធដោយទ្រព្យនោះ ។ ខ្ញុំបានសាងអារាមមួយ ឈ្មោះសោភនៈនៅខាងមុខទីក្រុង ឲ្យជាអារាមសម្រាប់សង្ឃ អស់ចំនួនមួយសែនកហាបណៈ ។ ខ្ញុំបានសាងផ្ទះ មានកំពូលផង ប្រាសាទវែងផង មណ្ឌបផង ប្រាសាទមានដំបូលរលីងផង គុហាផងទីចង្រ្កមដ៏ល្អផង ក្នុងអារាមរបស់សង្ឃ ។ មួយទៀត ខ្ញុំបានសាងរោងកម្តៅកាយ រោងភ្លើង រោងទឹក បន្ទប់សម្រាប់ស្រង់ទឹក ថ្វាយចំពោះព្រះភិក្ខុសង្ឃ ។ ខ្ញុំបានថ្វាយជើងម៉ា តាំងគ្រឿងប្រើប្រាស់ ភាជន៍ ភេសជ្ជៈ ទាំងអស់នុ៎ះ សម្រាប់អារាម ។ ខ្ញុំបានតម្កល់ទុកបុគ្គលអ្នករក្សា ឲ្យគេធ្វើកំពែងយ៉ាងមាំ ( ការពារ ) កុំឲ្យមានសត្រូវណាមួយ មកបៀតបៀនព្រះអង្គ ទ្រង់ជាតាទិបុគ្គល មានព្រះហឫទ័យស្ងប់រម្ងាប់ ។ ខ្ញុំបានឲ្យគេសាងអាវាស ជាអារាមសម្រាប់សង្ឃ អស់ចំនួន

ទ្រព្យមួយសែន លុះសាងអារាម មានសភាពស្តុកស្តម្ភរួចហើយ ក៏បានបង្អោនថ្វាយដល់ព្រះសម្មាសម្ពុទ្ធថា បពិត្រព្រះមុនី អារាម ខ្ញុំបានឲ្យគេសាងស្រេចហើយ សូមព្រះអង្គទទួលយក បពិត្រព្រះធីរៈ ខ្ញុំព្រះអង្គនឹងថ្វាយទានចំពោះព្រះអង្គ បពិត្រព្រះអង្គមានចក្ខុ សូមព្រះអង្គទ្រង់ទទួលនិមន្តន៍ ។ ព្រះលោកនាយក ព្រះនាមបទុមុត្តរៈ ទ្រង់ជ្រាបច្បាស់នូវសត្វលោក ទ្រង់គួរទទួលយកនូវគ្រឿងបូជា ទ្រង់ទទួលនិមន្តន៍ហើយ ព្រោះទ្រង់ជ្រាបនូវបំណងរបស់ខ្ញុំ ។ លុះខ្ញុំបានដឹងថា ព្រះអង្គទ្រង់ទទួលនិមន្តន៍ហើយ ទើបចាត់ចែងនូវភោជនាហារ បម្រុងថ្វាយដល់ព្រះសព្វញ្ញូ ទ្រង់ស្វែងរកគុណដ៏ធំ រួចហើយ ទើបក្រាបទូលកត្តកាល ។ លុះខ្ញុំក្រាបទូលនូវកត្តកាលរួចហើយ ទើបព្រះលោកនាយក ព្រះនាមបទុមុត្តរៈ ស្តេចមកកាន់អារាមរបស់ខ្ញុំ ( មួយអន្លើ ) ដោយព្រះខីណាស្រព ប្រមាណមួយពាន់អង្គ ។ ខ្ញុំដឹងនូវវេលាដែលព្រះអង្គ ទ្រង់គង់ស៊ប់ហើយ ក៏បានញុំាងព្រះអង្គឲ្យឆ្អែតស្កប់ស្កល់ ដោយបាយ និងទឹក លុះខ្ញុំដឹងនូវវេលាដែលព្រះអង្គសោយស្រេចហើយ ទើបក្រាបបង្គំទូលនូវពាក្យនេះថា បពិត្រព្រះមហាមុនី ខ្ញុំព្រះអង្គបានជាវទីដី អស់តម្លៃមួយសែនកហាបណៈ បានឲ្យគេសាងអារាម ឈ្មោះសោភនៈ ដោយតម្លៃកហាបណៈប៉ុណ្ណោះដែរ

សូមព្រះអង្គទ្រង់ទទួល ។ ដោយការថ្វាយភូមិនេះផង ដោយការតម្កល់ចេតនាទាំងនេះផង ខ្ញុំព្រះអង្គ កាលទៅកើតក្នុងភព ( ណាៗ ) សូមឲ្យបានសម្រេច តាមដែលខ្ញុំព្រះអង្គប្រាថ្នា ។

ព្រះសម្ពុទ្ធ ទ្រង់បានទទួលសង្ឃារាម ដែលខ្ញុំបានសាងល្អហើយ ព្រះអង្គគង់កណ្តាលនៃជំនុំភិក្ខុសង្ឃ ហើយទ្រង់ត្រាស់នូវព្រះពុទ្ធដីកានេះថា បុគ្គលណា បានថ្វាយសង្ឃារាមដែលខ្លួនបានសាងល្អហើយ ដល់ព្រះពុទ្ធ តថាគតនឹងព្យាករបុគ្គលនោះ អ្នកទាំងឡាយ ចូរស្តាប់តថាគតសម្តែងចុះ ។ សេនាមានអង្គ ៤ គឺដំរី សេះ រថ ពលថ្មើរជើង រមែងចោមបុគ្គលនេះជានិច្ច នេះជាផលនៃសង្ឃារាម ។ តូរ្យតន្ត្រី ៦០ ពាន់ និងស្គរប្រដាប់ល្អហើយ រមែងចោមរោមបុគ្គលនេះជានិច្ច នេះជាផលនៃសង្ឃារាម ។ ពួកនារីចំនួន ៨៦ ពាន់ ស្អិតស្អាងល្អហើយ សីងស្លៀកសំពត់ និងគ្រឿងអាភរណៈដ៏វិចិត្រ ពាក់កណ្តាលជាវិការៈនៃកែវមណី ។ ( នារីទាំងនោះ ) មានមុខស្រស់រីករាយ មានសរីរៈល្អ មានចង្កេះរៀវ រមែងចោមរោមបុគ្គលនេះជានិច្ច នេះផលនៃសង្ឃារាម ។ បុគ្គលនេះនឹងត្រេកអរក្នុងទេវលោក អស់ ៣០ ពាន់កប្ប បានជាធំជាងទេវតា សោយទេវរាជ្យ អស់ចំនួនមួយពាន់ដង ។ នឹងបានសម្បត្តិទាំងពួង ដែលទេវរាជគប្បីបាន ជាអ្នកមានភោគៈមិន

ខ្ទះខាត ហើយសោយរាជ្យក្នុងឋានទេវលោក ។ នឹងបានជាស្តេចចក្រពត្តិក្នុងដែន អស់មួយពាន់ដង នឹងបានជាស្តេចផែនដីដ៏ស្តុកស្តម្ភ គណនារាប់មិនបាន ។ លុះដល់មួយសែនកប្បទៀត ព្រះគោតមបរមគ្រូ កើតក្នុងត្រកូលឱក្កាកៈ នឹងបានជាសាស្តាក្នុងលោក ។ បុគ្គលនេះ នឹងបានជាឱរស ជាទាយាទក្នុងធម៌ ជាធម្មនិម្មិត មាននាមថាឧបាលិ នឹងបានជាសាវកនៃព្រះសាស្តាអង្គនោះ ។ នឹងដល់នូវត្រើយ ក្នុងព្រះវិន័យផង ឈ្លាសវៃក្នុងហេតុ និងមិនមែនហេតុផង ទ្រទ្រង់នូវសាសនារបស់ព្រះជិនស្រី ទាំងជាបុគ្គលមិនមានអាសវៈ ។ ព្រះគោតម ជាបុគ្គលប្រសើរក្នុងសក្យត្រកូល ទ្រង់ជ្រាបដំណើរនុ៎ះ សព្វគ្រប់ហើយ ទ្រង់គង់ក្នុងកណ្តាលនៃភិក្ខុសង្ឃ ហើយនឹងតាំងឧបាលិនុ៎ះ ក្នុងឋានៈជាឯតទគ្គៈ ។

ខ្ញុំប្រាថ្នានូវសាសនា គឺពាក្យប្រៀនប្រដៅរបស់ព្រះអង្គ អាស្រ័យនូវកប្បរាប់មិនបាន ប្រយោជន៍ គឺការអស់ទៅនៃសញ្ញោជនៈទាំងពួងនោះ ខ្ញុំក៏បានសម្រេចហើយ ។ បុរសជាប់ក្នុងដែកអណ្តោត ត្រូវរាជទណ្ឌគំរាមហើយ មិនបានស្រួលក្នុងដែកអណ្តោត ប្រាថ្នាចង់ឲ្យរួចវិញ ដូចម្តេចមិញ ។ បពិត្រព្រះអង្គមានព្យាយាមធំ ខ្ញុំព្រះអង្គត្រូវអាជ្ញា គឺភពគំរាមហើយ ជាប់នៅហើយក្នុងដែកអណ្តោត គឺកម្ម បិតនៅហើយ

ដោយកម្លាំងវេទនា គឺសេចក្តីស្រេកឃ្លាន ។ មិនបានស្រួល ក្នុងកព ក្តៅក្រហាយដោយភ្លើងទាំង ៣ ស្វែងរកឧបាយ ដើម្បីនឹងរួចស្រឡះ ដូចបុរសដែលប្រាថ្នា ដើម្បីរួចចាករាជទណ្ឌ យ៉ាងនោះ ។ មួយទៀត បុរសអ្នកក្មៀវក្លា ត្រូវពិសបៀតបៀន ហើយ គេក៏គប្បីស្វែងរកនូវឱសថ ជាឧបាយដើម្បីបន្សាបនូវពិស ។ កាលស្វែងរក ក៏បានឃើញនូវឱសថ ដែលជាគ្រឿងបន្សាបនូវពិស ក៏ផឹកនូវឱសថនោះ ហើយក៏បានសេចក្តីសុខ ព្រោះរួចផុតអំពីពិស យ៉ាងណាមិញ ។ បពិត្រព្រះអង្គមាន ព្យាយាមដ៏ធំ ខ្ញុំព្រះអង្គ ក៏ដូចជាជនអ្នកលង់នៅក្នុងពិស ត្រូវអវិជ្ជាបៀតបៀនហើយ បានស្វែងរកឱសថ គឺព្រះសទ្ធម្ម ។ កាលស្វែងរកឱសថ គឺធម៌ ក៏ប្រទះនូវសាសនា របស់ព្រះសក្យមុនីសម្ពុទ្ធ ជាឱសថ គឺសច្ចៈដ៏ប្រសើរបំផុត ជាថ្នាំសម្រាប់បន្ទោបង់នូវសរទាំងពួង ។ ខ្ញុំព្រះអង្គបានផឹកឱសថ គឺធម៌ ហើយដកនូវពិសទាំងពួងចោលចេញ ក៏បានឃើញព្រះនិព្វាន ជាគុណឥតមានចាស់ស្លាប់ មានសភាពត្រជាក់ ក៏យ៉ាងនោះដែរ ។ បុរសត្រូវខ្មោចគំរាមហើយ ត្រូវគ្រោះថ្នាក់ គឺខ្មោចបៀតបៀនហើយ គប្បីស្វែងរកពេទ្យ សម្រាប់ចាប់ខ្មោច ដើម្បីឲ្យរួចផុតអំពីខ្មោច ។ បុរសនោះ កំពុងតែស្វែងរក ក៏បានឃើញបុគ្គលអ្នកឈ្លាសវៃ ក្នុងវិជ្ជាចាប់ខ្មោច បុគ្គល

នោះ ក៏បានបំបរបង់ខ្មោច ព្រមទាំងធ្វើឫសគល់ឲ្យវិនាស អំពីបុរសនោះចេញ យ៉ាងណាមិញ ។ បពិត្រព្រះអង្គមានព្យាយាមធំ ខ្ញុំព្រះអង្គត្រូវគ្រោះថ្នាក់ គឺងងឹតបៀតបៀនហើយ ក៏ខំស្វែងរកពន្លឺ គឺញាណ ដើម្បីឲ្យផុតអំពីងងឹត ក៏បានប្រទះឃើញព្រះសក្យមុនី ទ្រង់ជម្រះងងឹត គឺកិលេស រួចហើយ ព្រះអង្គទ្រង់កម្ចាត់ងងឹតរបស់ខ្ញុំព្រះអង្គ ដូចជាពេទ្យចាប់ខ្មោច បានបណ្ដេញបង់នូវខ្មោចចេញ ។ ខ្ញុំព្រះអង្គបានផ្ដាច់បង់នូវខ្សែ គឺសង្សារ ហាមឃាត់នូវខ្សែ គឺតណ្ហា ដកចោលនូវកពទាំងអស់ ប្រៀបដូចពេទ្យចាប់ខ្មោច ( បៀតបៀនខ្មោច ) ឲ្យអស់ឫសគល់ ក៏យ៉ាងនោះដែរ ។ សត្វគ្រុឌចាបយកពួកនាគជាចំណីរបស់ខ្លួន ធ្វើមហាស្រះទំហំ ១០០ យោជន៍ដោយជុំវិញឲ្យរំភើបញាប់ញ័រ ។ លុះគ្រុឌនោះចាបយកនាគ ធ្វើឲ្យមានក្បាលចុះក្រោម ឲ្យបានសេចក្ដីលំបាក ហើយនាំយកទៅកាន់ទីតាមសេចក្ដីប្រាថ្នារបស់ខ្លួន យ៉ាងណាមិញ ។ បពិត្រព្រះអង្គមាន ព្យាយាមធំ ខ្ញុំព្រះអង្គមានកម្លាំងខ្លាំងដូចគ្រុឌ ខ្ញុំព្រះអង្គកំពុងស្វែងរកអសង្ខតធម៌ គឺព្រះនិព្វាន ហើយបានខ្ជាក់ទោសចោលចេញអស់ហើយ ។ ខ្ញុំព្រះអង្គបានឃើញព្រះធម៌ដ៏ប្រសើរ ជាចំណែកនៃសេចក្ដីស្ងប់រម្ងាប់ មិនមានគុណជាតដទៃប្រសើរលើស ហើយកាន់យកនូវធម៌នោះ ដូចគ្រុឌចាបយក

នាគ ក៏យ៉ាងនោះដែរ ។ វល្លិឈ្មោះអាសាវតី កើតក្នុងចិត្ត-
លតាវ័ន កន្លងទៅមួយពាន់ឆ្នាំ វល្លិនោះក៏កើតផ្លែមួយឡើង ។
ពួកទេវតា ( ក្នុងឋានតាវត្តិង្ស ) តែងនាំគ្នាចូលទៅអង្គុយជិត
វល្លិនោះ ដែលមានផ្លែយូរៗ ម្ដង តាមពិត វល្លិឈ្មោះអាសាវតី
នោះ មានផ្លែដ៏ឧត្ដម ជាទីពេញចិត្តរបស់ពួកទេវតា យ៉ាងនេះ ។
ចំណែកខាងខ្ញុំព្រះអង្គ ខំបម្រើព្រះមុនីអង្គនោះ រាប់សែនកប្ប
( ប៉ុណ្ណោះ ) តែងនមស្ការ រាល់ព្រឹកល្ងាច ដូចជាពួកទេវតា
តែងចូលទៅអង្គុយជិតវល្លិអាសាវតី ។ ការបម្រើ ( របស់ខ្ញុំ
ព្រះអង្គ ) មិនឥតអំពើ ទាំងការនមស្ការក៏មិនជាមោឃ ពុទ្ធុ-
ប្បាទក្ខណៈ ក៏មិនបានប្រព្រឹត្តកន្លងនូវខ្ញុំព្រះអង្គ អស់កាលជា
យូរអង្វែង ។ ឥឡូវនេះ ខ្ញុំព្រះអង្គត្រិះរិះទៅ មិនឃើញបដិសន្ធិ
ក្នុងភពថ្មីទៀតទេ ខ្ញុំព្រះអង្គមិនមានឧបធិក្កិលេស រួចស្រឡះ
បាកសង្ខារ មានចិត្តស្ងប់រម្ងាប់ ។ ធម្មតាផ្កាឈូក តែងរីក
ដោយសាររស្មីនៃព្រះអាទិត្យ យ៉ាងណាមិញ បពិត្រព្រះអង្គ
មានព្យាយាមធំ ខ្ញុំព្រះអង្គបានរីក ដោយសាររស្មីព្រះពុទ្ធ
ក៏យ៉ាងនោះដែរ ។ កំណើតកុកស មិនមានឈ្មោល សព្វៗ
កាលទេ កាលបើមេឃគំរាម ( ផ្គរលាន់ ) កុកទាំងនោះ ក៏
កាន់យកនូវគភ៌សព្វៗ កាល ។ កុកទាំងនោះ ទ្រទ្រង់គភ៌អស់
កាលដ៏យូរ ដរាបទាល់តែមេឃលែងគំរាម ទាល់តែមេឃបង្អុរ

ភ្លៀង ទើបកុកទាំងនោះ រួចផុតចាកការៈ យ៉ាងណាមិញ ។ កាលព្រះពុទ្ធព្រះនាមបទុមុត្តរៈ ទ្រង់គំរាមដោយមេឃ គឺធម៌ ខ្ញុំព្រះអង្គបានកាន់យកនូវគភ៌ គឺធម៌ ដោយសំឡេងនៃមេឃ គឺធម៌ ។ ខ្ញុំព្រះអង្គទ្រទ្រង់នូវគភ៌ គឺបុណ្យ រាប់សែនកប្ប មេឃ គឺធម៌ មិនគំរាម ( ដរាបណា ) ខ្ញុំក៏មិនបានរួចចាក ការៈធ្ងន់ ( ដរាបនោះ ) ។ បពិត្រព្រះសក្យមុនី ពេលណា ព្រះអង្គទ្រង់គំរាមដោយមេឃ គឺធម៌ ក្នុងក្រុងកបិលពស្ដុ ដែលជាទីត្រេកអរ ខ្ញុំព្រះអង្គក៏បានរួចចាកការៈដ៏ធ្ងន់ យ៉ាង នោះដែរ ។ ខ្ញុំព្រះអង្គ ( បានទាំងធ្វើឲ្យជាក់ច្បាស់ ) នូវ សុញ្ញតវិមោក្ខផង អនិមិត្តវិមោក្ខផង អប្បណិហិតវិមោក្ខផង ត្រាស់ដឹងនូវធម៌ទាំងពួង គឺផលទាំង ៤ ផង ទម្លាយនូវធម៌ គឺបណ្ដាញនោះផង ។

ខ្ញុំព្រះអង្គ ប្រាថ្នានូវសាសនារបស់ព្រះអង្គ រាប់កប្ប ប្រមាណមិនបាន ប្រយោជន៍ គឺចំណែកនៃសេចក្ដីស្ងប់ដ៏ ប្រសើរបំផុត ខ្ញុំព្រះអង្គបានសម្រេចហើយ ។ ខ្ញុំព្រះអង្គដល់ នូវត្រើយ ក្នុងព្រះវិន័យ ដូចភិក្ខុអ្នកស្វែងរកនូវគុណ អ្នក សូត្រ ( ក្នុងជំនាន់សាសនាព្រះពុទ្ធ ព្រះនាមបទុមុត្តរៈនោះ ដែរ ) ភិក្ខុជាអ្នកមានគុណស្មើនឹងខ្ញុំព្រះអង្គមិនមានឡើយ ខ្ញុំ ព្រះអង្គទ្រទ្រង់សាសនា ។ សេចក្ដីសង្ស័យរបស់ខ្ញុំព្រះអង្គ ក្នុង

វិន័យទុំះផង ក្នុងខន្ធកវិន័យផង ក្នុងតិកច្ឆេទៈផង ក្នុងបញ្ចកៈ ផង សូម្បីតែអក្ខរៈមួយ ឬក៏ព្យញ្ជនៈមួយ មិនមានឡើយ ។ ខ្ញុំព្រះអង្គដល់នូវត្រើយក្នុងព្រះវិន័យទាំងពួង វាងវៃក្នុងការសង្កត់សង្កិនភិក្ខុបាបផង ក្នុងបដិកម្ម គឺការសម្ដែងអាបត្តិផង ក្នុងហេតុដ៏គួរ និងមិនគួរផង ក្នុងឱសារណកម្ម គឺហៅភិក្ខុចូលកាន់ទីប្រជុំសង្ឃ ក្នុងកាលញុំាងភិក្ខុឲ្យចេញចាកអាបត្តិផង ។ ខ្ញុំព្រះអង្គបានរៀបទុកដាក់នូវចំណែកក្នុងវិន័យផង ក្នុងខន្ធកៈផង ក្នុងឧភតោវិភង្គផង ហើយគប្បីឲ្យប្រជុំចុះដោយកិច្ចបាន ។ ខ្ញុំព្រះអង្គជាអ្នកឈ្លាសវៃ ក្នុងវោហារផង វាងវៃក្នុងហេតុចម្រើន និងហេតុមិនចម្រើនផង សភាពដែលខ្ញុំព្រះអង្គ មិនបេះដឹង ( នោះ ) មិនមានឡើយ ខ្ញុំព្រះអង្គ ជាភិក្ខុឯកក្នុងសាសនារបស់ព្រះសាស្ដា ។ ក្នុងថ្ងៃនេះ ខ្ញុំព្រះអង្គជាបុគ្គលយល់រូប ក្នុងសាសនានៃព្រះពុទ្ធជាសក្យបុត្ត ហើយបន្ទោបង់នូវកង្ខាទាំងពួង កាត់បង់នូវសង្ស័យទាំងអស់បាន ។ ខ្ញុំព្រះអង្គ ( ដឹងច្បាស់ ) នូវបទផង អនុបទផង អក្ខរៈផង ព្យញ្ជនៈផង ឈ្លាសវៃក្នុងហេតុសព្វអន្លើ គឺហេតុជាទីតាំង ( ខាងដើម ) និងហេតុជាទីតាំងខាងចុង ( នៃសិក្ខាបទ ) ។ ព្រះរាជាមានកម្លាំង ទ្រង់សង្កត់សង្កិននូវពួកស្ដេចជាសត្រូវ លុះទ្រង់ឈ្នះសង្គ្រាមហើយ ទើបសាងទីក្រុង ក្នុងដែនដែលទ្រង់

ឈ្នះហើយនោះ ។ ទ្រង់ឲ្យជាងធ្វើកំពែង ស្នាមភ្លោះ សសរខឿន ខ្លោងទ្វារ និងប៉មទាំងឡាយផ្សេងៗ ជាច្រើន ក្នុងនគរ ។ ទ្រង់ឲ្យជាងធ្វើនូវផ្លូវត្រឡែងកែង ផ្លូវថ្នល់ រានផ្សារជាចន្លោះដែលតាក់តែងល្អ ព្រមទាំងសភា សម្រាប់វិនិច្ឆ័យនូវសេចក្តីចម្រើន និងសេចក្តីមិនចម្រើន ក្នុងនគរនោះ ។ ព្រះរាជាអង្គនោះ ទ្រង់តាំងសេនាមាត្យដើម្បីឲ្យសង្កត់សង្កិននូវពួកសត្រូវឲ្យស្គាល់ទោស និងមិនមែនទោស ដើម្បីរក្សានូវពួកពល ។ ព្រះរាជាអង្គនោះ ទ្រង់តាំងបុរសអ្នករក្សានូវកណ្ឌៈ ជាអ្នកឈ្លាសវៃក្នុងការទុកដាក់ ដើម្បីប្រយោជន៍រក្សានូវកណ្ឌៈ ដោយព្រះរាជបំណងថា កុំឲ្យកណ្ឌៈរបស់អាត្មាអញវិនាសទៅបានឡើយ ។ បុរសនោះ ជាអ្នកមានចិត្តស្វាមីភក្តិចំពោះព្រះរាជា ព្រោះព្រះរាជាប្រាថ្នាការចម្រើនដល់បុរសណា ទ្រង់ក៏ព្រះរាជទាននូវឥស្សរៈ ក្នុងការវិនិច្ឆ័យអធិករណ៍ដល់បុរសនោះ ដើម្បីប្រតិបត្តិ កុំឲ្យបែកមិត្ត ។ ព្រះរាជានោះ ទ្រង់តាំងបុរសអ្នកវាងវៃក្នុងឧប្បាទហេតុទាំងឡាយផង ក្នុងនិមិត្តទាំងឡាយផង ក្នុងលក្ខណៈទាំងឡាយផង ជាអ្នកបង្រៀនមន្ត ចេះចាំមន្តក្នុងឋានៈជាបុរោហិត ។ ព្រះរាជាបរិបូណ៌ដោយអង្គទាំងឡាយនុ៎ះហើយ ទើបហៅថា ក្សត្រិយ៍ បុរសទាំងនោះ តែងរក្សាព្រះរាជានោះ សព្វៗ កាល ដូចសត្វចាកក្រពាក រក្សាក្រុមញាតិ

ដែលដល់សេចក្ដីទុក្ខ ។ បពិត្រព្រះអង្គ មានព្យាយាមធំ អ្នក
ផងតែងហៅព្រះអង្គថា ធម្មរាជរបស់សត្វលោក ព្រមទាំង
ទេវលោក ដូចក្សត្រិយ៍ដែលកម្ចាត់សត្រូវហើយ ដូច្នោះដែរ ។
ព្រះធម្មរាជនោះ ទ្រង់ញាំញីនូវពួកតិរ្ថិយទាំងឡាយផង នូវមារ
ព្រមទាំងសេនាផង ទ្រង់ទម្លាយមោហន្ធការដ៏ងងឹត រួចហើយ
កសាងធម្មនគរ ។ បពិត្រព្រះអង្គមានបញ្ញាជាគ្រឿងទ្រទ្រង់
ឯក្នុងធម្មនគរនោះ មានសីលជាកំពែង មានញាណរបស់
ព្រះអង្គជាខ្លោងទ្វារ មានសទ្ធារបស់ព្រះអង្គ ជាសសរខឿន
មានការសង្រួម ជានាយឆ្មាំទ្វារ ។ បពិត្រព្រះមុនី សតិប្បដ្ឋាន
ជាប៉ម បញ្ញារបស់ព្រះអង្គ ជាផ្លូវថ្នល់ ឥទ្ធិបាទ ជាផ្លូវត្រឡែង
កែង ថ្នល់ គឺពោធិបក្ខិយធម៌ទាំង ៣៧ ព្រះអង្គទ្រង់និម្មិតទុក
ល្អហើយ ។ ព្រះសូត្រ ព្រះអភិធម្ម និងព្រះវិន័យ ពុទ្ធវចនៈ
មានអង្គ ៩ ទាំងអស់នុ៎ះ ជាធម្មសភារបស់ព្រះអង្គ ។ សុញ្ញ-
តវិហារ អនិមិត្តវិហារ អប្បណិហិតវិហារ ការមិនមានតណ្ហា
ជាគ្រឿងញាប់ញ័រ និងការរម្ងត់ទុក្ខ នេះជាធម្មកុដិរបស់ព្រះអង្គ ។
ព្រះថេរៈជាបុគ្គលប្រសើរខាងប្រាជ្ញា ដែលព្រះអង្គតាំងទុក
ហើយ ជាអ្នកវាងវៃក្នុងប្រាជ្ញា មានឈ្មោះថា សារីបុត្ត ជា
ធម្មសេនាបតីរបស់ព្រះអង្គ ។ បពិត្រព្រះមុនី ព្រះថេរៈដែល
ឈ្លាសវៃក្នុងចុតូបបាតញ្ញាណ គឺប្រាជ្ញាដែលដឹងនូវចុតិ និង

បដិសន្ធិរបស់សត្វ ដល់នូវត្រើយនៃឫទ្ធិ មានឈ្មោះថា កោលិតៈ ជាបុរោហិតរបស់ព្រះអង្គ ។ បពិត្រព្រះមុនី ព្រះថេរៈឈ្មោះកស្សបៈ អ្នកទ្រទ្រង់វង្សបុរាណ មានតេជៈដ៏ខ្ពង់ខ្ពស់ ដែលគេគ្របសង្កត់បានដោយក្រ ប្រសើរក្នុងគុណ មានការកម្ចាត់បង់នូវទោសជាដើម គឺទ្រទ្រង់ធុតង្គទាំង ១៣ ជាអ្នកសម្រាប់ពិភាក្សារបស់ព្រះអង្គ ។ បពិត្រព្រះមុនី ព្រះថេរៈជាពហុស្សូត អ្នកទ្រទ្រង់ធម៌ ចេះចាំពុទ្ធវចនៈទាំងអស់ក្នុងសាសនា មាននាមថា អានន្ទ ជាអ្នករក្សាធម៌របស់ព្រះអង្គ ។ ព្រះមានព្រះភាគរបស់ខ្ញុំ ជាអ្នកស្វែងរកគុណដ៏ធំ ទ្រង់ប្រទានការវិនិច្ឆ័យ ក្នុងវិន័យដែលវិញ្ញូភិក្ខុទាំងឡាយសម្តែងហើយដល់ខ្ញុំព្រះអង្គ រំលងព្រះថេរៈទាំងអស់នុ៎ះ ។ ពុទ្ធសាវកណាមួយ សួរបញ្ហាក្នុងវិន័យ ( នឹងខ្ញុំព្រះអង្គ ) ខ្ញុំព្រះអង្គមិនបាច់គិត ក្នុងបញ្ហានោះទេ ខ្ញុំព្រះអង្គប្រាប់សេចក្តីនោះតែម្តង ។ ពុទ្ធក្ខេត្តកំណត់ត្រឹមណា វៀរលែងតែព្រះមហាមុនីចេញ មិនមានភិក្ខុណា នឹងស្មើដោយខ្ញុំព្រះអង្គក្នុងវិន័យ តើនឹងមានភិក្ខុប្រសើរលើសខ្ញុំព្រះអង្គពីណា ។ ព្រះគោតម ទ្រង់គង់ក្នុងកណ្តាលជំនុំភិក្ខុសង្ឃ ហើយទ្រង់ប្រកាសយ៉ាងនេះថា ភិក្ខុណាមួយ ជាអ្នកស្មើដោយឧបាលិ ក្នុងវិន័យ និងខន្ធកៈ មិនមានឡើយ ។ សត្ថុសាសនាមានអង្គ ៩ ដែលព្រះពុទ្ធសម្តែង

ហើយ ទាំងអម្បាលម៉ាន ខ្ញុំព្រះអង្គជាអ្នកឃើញឫសគល់របស់វិន័យ ( កាត់បង់ ) នូវសេចក្ដីជាប់ចំពាក់ទាំងពួង ដែលព្រះអង្គសម្ដែងហើយ ក្នុងវិន័យ ។ ព្រះគោតម ជាបុគ្គលប្រសើរក្នុងសក្យត្រកូល ទ្រង់ពួកឃើញនូវអំពើរបស់ខ្ញុំ ហើយគង់ក្នុងភិក្ខុសង្ឃ ទ្រង់តម្កល់ខ្ញុំក្នុងទីជាឯតទគ្គៈ ។ ខ្ញុំបានប្រាថ្នាយកនូវតំណែងនេះ រាប់សែនកប្បមកហើយ ឥឡូវនេះប្រយោជន៍នោះ ខ្ញុំបានសម្រេចហើយ ខ្ញុំបានដល់នូវត្រើយក្នុងព្រះវិន័យហើយ ។ កាលពីដើម ខ្ញុំជានាយខ្មាន់ព្រះកេសជាអ្នកបណ្ដុះសេចក្ដីត្រេកអរដល់ពួកសក្យៈ លះបង់កំណើតនោះចោលចេញ បានមកជាបុត្តរបស់ព្រះមហាមហេសី-សម្ពុទ្ធវិញ ។ ក្នុងកប្បទី ២ រាប់អំពីកប្បនេះទៅ មានក្សត្រិយ៍ឈ្មោះអញ្ជសៈ មានតេជះរកទីបំផុតគ្មាន មានយសរាប់មិនបាន ជាម្ចាស់ផែនដី មានទ្រព្យច្រើន ។ ខ្ញុំជាព្រះរាជបុត្តរបស់ព្រះរាជានោះ ជាក្សត្រិយ៍ឈ្មោះចន្ទនៈ ជាអ្នករឹងត្អឹងដោយស្រវឹងព្រោះជាតិផង ដោយស្រវឹងព្រោះយសសក្តិ និងភោគៈផង ។ មានពួកដំរីមាតង្គៈចំនួន ១ សែន សុទ្ធតែចុះប្រេង ដោយហេតុ ៣ ប្រការ ដ៏ប្រដាប់ដោយគ្រឿងអលង្ការទាំងពួង ចោមរោមខ្ញុំ សព្វៗ កាល ។ វេលានោះ ខ្ញុំមានពួកពលរបស់ខ្លួនចោមរោមហើយ ប្រាថ្នាទៅកាន់ឧទ្យាន ឡើង

ជិះដំរី ឈ្មោះសិរិកៈ ចេញអំពីនគរទៅ ។ ស្រាប់តែមានព្រះបច្ចេកសម្ពុទ្ធ ព្រះនាមរេវតៈ ទ្រង់បរិបូណ៌ដោយចរណៈ មានទ្វារគ្រប់គ្រង សង្រួមល្អ បានឧិមន្តមកចំពោះមុខខ្ញុំ ។ វេលានោះ ខ្ញុំបានបរដំរីឈ្មោះសិរិកៈ ទៅឲ្យបៀតបៀនព្រះសម្ពុទ្ធលំដាប់នោះ ដំរីក៏ក្រោធខឹងមិនលើកជើង ។ លុះខ្ញុំឃើញដំរីមានចិត្តខឹង ក៏ក្រេវក្រោធនឹងព្រះពុទ្ធជាម្ចាស់ បៀតបៀនព្រះសម្ពុទ្ធហើយ ក៏ទៅក្នុងឧទ្យាន ។ ខ្ញុំមិនបាននូវសេចក្តីសុខស្រួល ក្នុងឧទ្យាននោះ ក្បាល ( របស់ខ្ញុំ ) ហាក់ដូចជាភ្លើងឆេះខ្ញុំក្តៅអន្ទះអន្ទែង ដោយសេចក្តីក្រហល់ក្រហាយ ដូចត្រីជាប់សន្ទូច ។ ផែនដីដែលមានសាគរជាទីបំផុត ហាក់ដូចជាដុតកម្តៅខ្ញុំ ទើបខ្ញុំចូលទៅកាន់សម្នាក់នៃព្រះបិតា ហើយក្រាបបង្គំទូលថា យើងខ្ញុំបៀតបៀនព្រះពុទ្ធសយម្ភូណា ដូចបុគ្គលបៀតបៀនអាសិរពិស ដែលកំពុងក្រោធ ឬដូចបុគ្គលបៀតបៀនគំនរភ្លើង ដែលឆេះរាលមក ឬក៏ដូចបុគ្គលបៀតបៀនដំរីមានភ្លុកដែលចុះប្រេង ។ ព្រះពុទ្ធជាម្ចាស់អង្គនោះ មានតបៈដ៏ខ្ពង់ខ្ពស់ ក្លៀវក្លា ជាព្រះជិនស្រី យើងខ្ញុំបៀតបៀនហើយ យើងខ្ញុំទាំងអស់គ្នា នឹងវិនាស យើងខ្ញុំនឹងញ៉ាំងព្រះសយម្ភូជាមុនីអង្គនោះ ឲ្យអត់ទោស ។ ប្រសិនបើយើងខ្ញុំ នឹងមិនបានញ៉ាំងព្រះពុទ្ធដែលមានខ្លួនទូន្មានហើយ មានព្រះហឫទ័យខ្ជាប់

ដ្ឋនោះ ឲ្យអត់ទោសទេ ដែនរបស់យើងខ្ញុំ មុខជាវិនាស ថយពីថ្ងៃទី ៧ ទៅមិនខាន ។ ក្សត្រិយ៍ ៤ ព្រះអង្គ ព្រះនាមសុមេខលៈ ១ កោសេយ្យៈ ១ សិគ្គវៈ ១ សត្តកៈ ១ ជាមួយនឹងពួកសេនានោះ បានបៀតបៀនឥសីទាំងឡាយ ហើយដល់នូវសេចក្តីវិនាស ។ ពួកឥសីអ្នកសង្រួម ប្រព្រឹត្តព្រហ្មចរិយធម៌ ក្រោធខឹងក្នុងកាលណា រមែងធ្វើសត្វលោក ព្រមទាំងទេវលោក ទាំងសមុទ្រ និងភ្នំ ឲ្យវិនាសទៅបាន ។ ខ្ញុំបានប្រជុំពួកបុរស ក្នុងទី ៣ ពាន់យោជន៍ បានចូលទៅគាល់ព្រះសយម្ភូ ដើម្បីនឹងសម្តែងទោស ។ ពួកបុរសទាំងពួង ស្លៀកសំពត់ទទឹក មានក្បាលទទឹក ធ្វើក្រពុំប្រាមដៃក្រាបទៀបព្រះពុទ្ធ ហើយទូលថា បពិត្រព្រះអង្គមានព្យាយាមធំ សូមព្រះអង្គអត់ទោស ( ព្រោះ ) ជនសូមទោសនឹងព្រះអង្គ សូមព្រះអង្គរម្ងាប់ក្រវល់ក្រវាយ សូមព្រះអង្គកុំធ្វើដែន ( របស់យើងខ្ញុំ ) ឲ្យវិនាសឡើយ ។ ( ប្រសិនបើព្រះអង្គមិនអនុគ្រោះទេ ) ពួកបុរសទាំងអស់ ព្រមទាំងទេវតា និងមនុស្ស ទាំងអ្នកធ្វើទាន ទាំងអ្នកថែរក្សា គេនឹងយកញញួរដែកមកទម្លាយអំបែងក្បាលយើងខ្ញុំ សព្វៗ កាល ។ ( ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា ) ភ្លើងមិនឋិតនៅក្នុងទឹក ពូជមិនដុះលើថ្មភ្នំ ជន្តុវមិនឋិតនៅក្នុងឱសថ សេចក្តីក្រោធមិនកើតក្នុង

ព្រះពុទ្ធ ។ ផែនដីមិនកម្រើក សមុទ្រសាគរប្រមាណមិនបាន អាកាសរកទីបំផុតគ្មាន យ៉ាងណាមិញ ព្រះពុទ្ធទាំងឡាយ មានព្រះហឫទ័យ មិនរញ្ជួយញាប់ញ័រ ក៏យ៉ាងនោះដែរ ។ ព្រះពុទ្ធទាំងឡាយ មានព្យាយាមធំ មានខ្វួនទូន្មាន ទ្រង់អត់ធន់ មានតបៈ ពួកបុគ្គលអ្នកអំណត់អត់ធន់ មិនមានការលុះក្នុងអគតិ ។ ព្រះបច្ចេកសម្ពុទ្ធ ទ្រង់ពោលដូច្នេះហើយ ទើបរម្ងាប់ក្រវល់ក្រវាយរបស់ខ្ញុំ ហើយហោះទៅតាមអាកាស ក្នុងទីចំពោះមុខមហាជន ក្នុងកាលនោះ ។ បពិត្រព្រះអង្គ មានព្យាយាម ព្រោះអំពើនោះហើយ បានជាខ្ញុំព្រះអង្គចូលទៅកាន់ភាពជាអ្នកថោកទាប លុះកន្លងជាតិនោះមកហើយ ក៏បានចូលទៅកាន់អភយបុរី គឺព្រះនិព្វាន ។ បពិត្រព្រះអង្គ មានព្យាយាមធំ វេលានោះ ព្រះពុទ្ធបានញុំាងខ្ញុំព្រះអង្គដែលកំពុងក្តៅក្រហាយ នៅមិនទាន់រលត់ ឲ្យបន្ទោបង់ក្រវល់ក្រវាយចេញ ខ្ញុំព្រះអង្គបានញុំាងព្រះសយម្ភូឲ្យអត់ទោស ។ បពិត្រព្រះអង្គមានព្យាយាមធំ ក៏ក្នុងថ្ងៃនេះ ព្រះអង្គបានញុំាងខ្ញុំព្រះអង្គដែលកំពុងក្តៅក្រហាយ ដោយភ្លើងទាំង ៣ ឲ្យរលត់ផង ញុំាងភ្លើងទាំង ៣ ឲ្យរលត់ផង ឥឡូវនេះ ខ្ញុំព្រះអង្គបានដល់នូវភាពត្រជាក់ហើយ ។ លោកទាំងឡាយណា មានការតម្កល់នូវសោតប្រសាទ លោកទាំងនោះ ចូរស្តាប់ខ្ញុំចុះ ខ្ញុំនឹង

ប្រាប់ប្រយោជន៍ដល់អ្នក ដូចជាចំណែកដែលខ្ញុំបានឃើញ ។ ខ្ញុំបានមើលឆាយព្រះសយម្ភូនោះ ដែលមានព្រះហឫទ័យស្ងប់រម្ងាប់ មានព្រះហឫទ័យខ្ជាប់ខ្ជួនដោយកម្មនោះហើយ បានជាក្នុងថ្ងៃនេះ ខ្ញុំមកកើតក្នុងកំណើតថោកទាប ។ អ្នកទាំងឡាយ កុំឲ្យខណៈឃ្លាតទៅទទេ ព្រោះបុគ្គលដែលខណៈកន្លងហើយ រមែងសោកសៅ អ្នកទាំងឡាយ គប្បីព្យាយាមក្នុងប្រយោជន៍របស់ខ្លួន ( ព្រោះ ) ខណៈប្រាកដដល់អ្នកទាំងឡាយហើយ ។ ជនពួកខ្លះ បានថ្នាំក្អួត ជនពួកខ្លះ បានថ្នាំបញ្ចុះ ជនពួកខ្លះ បានថ្នាំពិសដែលខ្លាំង ជនពួកខ្លះ បានឱសថ ។ ថ្នាំក្អួតសម្រាប់ពួកបុគ្គល អ្នកប្រតិបត្តិ ( នូវមគ្គ ) ថ្នាំបញ្ចុះសម្រាប់ពួកបុគ្គលអ្នកឋិតនៅក្នុងផល ឱសថសម្រាប់ពួកបុគ្គលអ្នកបាននូវផល ជាអ្នកស្វែងរកបុញ្ញក្ខេត្ត ។ ពិសដែលខ្លាំងសម្រាប់បុគ្គល អ្នកប្រតិបត្តិខុសចាកសាសនា អាសិរពិសដែលមានពិសកាច តែងដុតនរៈនោះតែមួយដង ។ ពិសដ៏ខ្លាំងដែលបុគ្គលផឹកហើយ បៀតបៀនជីវិត បានតែមួយដង ឯបុគ្គលអ្នកប្រតិបត្តិខុសចាកសាសនា រមែងក្តៅក្រហាយអស់កោដិនៃកប្ប ។ គេតែងឆ្លងចាកលោក ព្រមទាំងទេវលោក ដោយការអត់ធន់ ១ ដោយការមិនបៀតបៀន ១ ដោយមានចិត្តមេត្តា ១ ហេតុនោះ បុគ្គលមិនគប្បីឲ្យធ្លាក់ក្នុងនឹងព្រះពុទ្ធ

ទាំងនោះ ។ ព្រះពុទ្ធទាំងឡាយ មានព្រះហឫទ័យស្មើដោយផែនដី មិនជាប់ចំពាក់ក្នុងលាភ និងអលាភ ក្នុងការរាប់អានក្នុងការមើលងាយ ហេតុនោះ បុគ្គលមិនគប្បីឲ្យភ្លាំភ្លងនឹងព្រះពុទ្ធទាំងនោះ ។ ព្រះមុនីមានហឫទ័យស្មើ ចំពោះសត្វទាំងពួង គឺទេវទត្ត ខ្មាន់ធ្នូ ចោរអង្គុលិមាល រាហុល និងដំរីធនបាល ។ ព្រះពុទ្ធមិនមានសេចក្តីស្អប់ជនទាំងនុ៎ះ មិនមានសេចក្តីស្រឡាញ់ជនទាំងនុ៎ះទេ មានព្រះហឫទ័យស្មើចំពោះជនទាំងអស់ គឺចំពោះខ្មាន់ធ្នូ និងចំពោះឱរស ។ បុគ្គលបើឃើញសំពត់កាសាវៈ ជាទង់ជ័យរបស់ព្រះពុទ្ធ ដែលប្រឡាក់ដោយលាមក ដែលគេចោលហើយ ក្នុងផ្លូវ គប្បីធ្វើអញ្ជលី ថ្វាយបង្គំដោយត្បូង ។ ព្រះសម្ពុទ្ធទាំងឡាយ ដែលកន្លងទៅហើយក្តី ក្នុងបច្ចុប្បន្ននេះក្តី ក្នុងអនាគតក្តី តែងបរិសុទ្ធដោយទង់ជ័យនេះ ព្រោះហេតុនោះ ព្រះសម្ពុទ្ធទាំងនុ៎ះបុគ្គលគប្បីនមស្ការ ។ ខ្ញុំចាំវិន័យដោយប្រពៃ គួរតាមអធ្យាស្រ័យរបស់ព្រះសាស្តា ដោយហឫទ័យ ខ្ញុំតែងនមស្ការវិន័យនោះសព្វៗ កាល ។ វិន័យជាទីអាស្រ័យ វិន័យជាទីឈរទាំងជាទីចង្ក្រមរបស់ខ្ញុំ ខ្ញុំតែងដេកនៅក្នុងវិន័យ វិន័យជាទីគោចររបស់ខ្ញុំ ។ បពិត្រព្រះអង្គមានព្យាយាមធំ ឧបាលិដល់នូវត្រើយក្នុងវិន័យផង ឈ្លាសវៃក្នុងសមថៈផង តែងថ្វាយបង្គំនូវ

ព្រះបាទារបស់ព្រះសាស្តា ។ ខ្ញុំព្រះអង្គនោះ នឹងត្រាច់ទៅអំពីស្រុកមួយទៅកាន់ស្រុកមួយ អំពីបុរីមួយទៅកាន់បុរីមួយ ហើយនមស្ការនូវព្រះសម្ពុទ្ធផង នូវភាពនៃធម៌ជាធម៌ល្អផង ។ ខ្ញុំព្រះអង្គជុតកិលេសទាំងឡាយហើយ ដកចោលនូវភពទាំងអស់ហើយ អាសវៈទាំងពួង អស់រលីងហើយ ឥឡូវនេះ ភពថ្មីមិនមានទេ ។ ឱ ដំណើរដែលខ្ញុំមកក្នុងសម្នាក់របស់ព្រះពុទ្ធដ៏ប្រសើរ ( នេះ ) ជាដំណើរមកដោយល្អ វិជ្ជាទាំង ៣ ខ្ញុំព្រះអង្គបានសម្រេចហើយ សាសនារបស់ព្រះសម្ពុទ្ធ ខ្ញុំព្រះអង្គក៏បានប្រតិបត្តិហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះសម្ពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ ។

ក្នុងទីនោះ ព្រះសាស្តាឲ្យព្រះថេរៈរៀនព្រះវិនយបិដកទាំងអស់ ដោយព្រះអង្គឯង ថ្ងៃមួយ លោកបានវិនិច្ឆ័យ ៣ រឿង គឺរឿងភារុកច្ឆៈ ១ រឿងអជ្ជុកៈ ១ រឿងព្រះកុមារកស្សបៈ ១ កាលវិនិច្ឆ័យស្រេច ព្រះសាស្តាទ្រង់ប្រទានសាធុការ ទ្រង់អាស្រ័យការវិនិច្ឆ័យរឿងទាំង ៣ ឲ្យជាអត្ថុប្បត្តិហេតុ ទ្រង់តែងតាំងព្រះថេរៈក្នុងតំណែងជាឯតទគ្គៈ លើសភិក្ខុទាំងឡាយខាងទ្រទ្រង់ព្រះវិនយ ។ ថ្ងៃមួយ ក្នុងថ្ងៃឧបោសថ ពេលសម្តែងបាតិមោក្ខ ព្រះថេរៈកាលឲ្យឱវាទដល់ភិក្ខុទាំងឡាយ ទើបពោល ៣ គាថាថា

កុលបុត្ត ចេញ ( ចាកឃរាវាស ) ដោយសទ្ធាហើយ បួសថ្មី

ជានវភិក្ខុ គប្បីគប់រកកល្យាណមិត្តទាំងឡាយ ដែលជាអ្នកមានការចិញ្ចឹមជីវិតដោយបរិសុទ្ធ អ្នកមិនខ្ជិលច្រអូស ។ កុលបុត្តចេញ ( ចាកឃរាវាស ) ដោយសទ្ធា បួសថ្មីជានវភិក្ខុ អ្នកមានប្រាជ្ញា កាលនៅក្នុងពួក គប្បីសិក្សានូវវិន័យ ។ កុលបុត្តចេញ ( ចាកឃរាវាស ) ដោយសទ្ធា បួសថ្មី ជានវភិក្ខុ ជាអ្នកឈ្លាស ក្នុងហេតុដែលគួរ និងមិនគួរទាំងឡាយ គប្បីប្រព្រឹត្តកុំឲ្យ ( ពួកកិលេស មានតណ្ហាជាដើម ) ប្រព្រឹត្តទៅក្នុងខាងមុខបាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សទ្ធាយ** សេចក្តីថា ព្រោះសទ្ធាជាហេតុ អធិប្បាយថា មិនមែនដើម្បីចិញ្ចឹមជីវិត ។ ម្យ៉ាងទៀត បទថា **សទ្ធាយ** បានដល់ ជឿកម្ម ផលនៃកម្ម និងគុណព្រះរតនត្រ័យ ។

បទថា **អភិនិក្ខម្ម** សេចក្តីថា ចេញចាកការគ្រប់គ្រងផ្ទះ ។ បទថា **នវបព្វជិតោ** បានដល់ ជាអ្នកបួសថ្មី គឺបួសក្នុងបឋមវ័យនោះឯង ។

បទថា **នវោ** បានដល់ នៅថ្មី គឺនៅកំលោះ ចំពោះការសិក្សាក្នុងសាសនា ។ បទថា **មិត្តេ ភជេយ្យ កល្យាណេ សុទ្ធាជីវេ អតន្ទិតេ** សេចក្តីថា គួរសេពគប់ គឺគួរចូលទៅរកកល្យាណមិត្រដែលមានលក្ខណៈដូចបានពោលហើយ ដោយន័យថា ភិក្ខុជាអ្នក ( ធ្វើខ្លួន ) ឲ្យជាទីស្រឡាញ់ផង គួរគោរពផង គួរសរសើរផង ដូច្នេះជាដើម ឈ្មោះថា **សុទ្ធាជីវេ** ព្រោះវៀរចាកមិច្ឆាជីវៈ និងឈ្មោះថា **អតន្ទិតេ** ព្រោះជាអ្នកប្រារព្ធសេចក្តីព្យាយាម

ហើយ បានដល់ គួរសេពគប់ដោយការទទួលយកឱវាទានុសាសនីរបស់លោកទាំងនោះ ។

បទថា **សង្ឃស្មឹ វិហរំ** បានដល់ ស្នាក់នៅក្នុងពួក គឺក្នុងជំនុំសង្ឃ ដោយការបំពេញវត្ត និងបដិវត្ត ។

បទថា **សិក្ខេថ វិនយំ ពុធោ** សេចក្ដីថា គប្បីជាអ្នកឈ្លាសក្នុងការដឹង និងការយល់ គឺសិក្សាវិនយបរិយត្តិ ដ្បិតថា ព្រះវិន័យ ជាអាយុនៃសាសនា កាលព្រះវិន័យតាំងនៅ សាសនាក៏ឈ្មោះថាតាំងនៅ តែអាចារ្យពួកខ្លះពោលថា **ពុទ្ធោ** ឯសេចក្ដីក៏យ៉ាងនេះដូចគ្នា ។

បទថា **កប្បាកប្បេសុ** សេចក្ដីថា ជាអ្នកឈ្លាសក្នុងរបស់ដែលគួរនិងមិនគួរ គឺជាអ្នកឈ្លាសល្អិតល្អន់ក្នុងវត្ថុនោះៗ ដោយអំណាចព្រះសូត្រនិងដោយអនុលោមតាមព្រះសូត្រ ។

បទថា **អបុរក្ខតោ** បានដល់ មិនគួរជាអ្នកប្រព្រឹត្តយកមុខយកមាត់ គឺមិនប្រាថ្នាភាពជាប្រធានក្នុងទីណាមួយ ដោយតណ្ហាជាដើមឡើយ ។

**អដ្ឋកថា ឧទាលិត្ថេរគាថា ចប់**

# សុត្តន្តបិដក

## ឧត្តរថាលត្ថេរគាថា

[ ១៨២ ] ឱហ្ន៎ កាមគុណទាំង ៥ ញ៉ាំងអាត្មាអញជាបណ្ឌិតមានសមត្ថភាពគិតនូវប្រយោជន៍ ឲ្យធ្លាក់ចុះក្នុងលោក ព្រោះតែសេចក្តីវង្វេងទេតើ ។ អាត្មាអញ ចូលទៅក្នុងវិស័យនៃកិលេសមារ ត្រូវសរ គឺរាគៈមុតជាប់ហើយ តែអាចស្ទុះរួច ចាកអន្ទាក់នៃមច្ចុរាជបាន ។ កាមទាំងពួងអាត្មាអញបានលះបង់ហើយ ភពទាំងពួង អាត្មាអញបានទម្លាយចោលហើយជាតិសង្សារអស់ហើយ ឥឡូវនេះ ភពថ្មីមិនមាន ។

ឧត្តរបាលិត្ថេរ

# អដ្ឋកថា

## ឧត្តរថាលត្ថេរគាថា

[ ១៨២ ] គាថារបស់ព្រះឧត្តរបាលត្ថេរ មានពាក្យផ្តើមថា **បណ្ឌិតំ វត មំ សន្តំ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗបានធ្វើស្ពានត្រង់ផ្លូវជាទីយាងរបស់ព្រះមានព្រះភាគ ព្រះនាមវិបស្សី ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅមកក្នុងទេវតា និង មនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ បានកើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងនគរសាវត្ថី មានឈ្មោះថា **ឧត្តរបាល:** ចម្រើនវ័យហើយ បានឃើញយមកប្បាដិហារ្យ បាននូវសទ្ធា បួសហើយ បំពេញនូវសមណធម៌ ។ ថ្ងៃមួយ កាលរឭកដល់អារម្មណ៍ដែលធ្លាប់សេពមក មិនដាក់ចិត្តដោយឧបាយ កាមរាគៈក៏កើតឡើង ។ រំពេចនោះ លោកសង្កត់ចិត្តរបស់ខ្លួនបាន ដូចបុរសចាប់ចោរមួយអន្ទើដោយវត្ថុតាងបាន កើតនូវសេចក្តីសង្វេគ សង្កត់នូវកិលេសដោយមនសិការដល់ធម៌ ដែលជាបដិបក្ខចំពោះកិលេសនោះ ហើយបំពេញវិបស្សនាកម្មដ្ឋាន ប្រកបការបំពេញវិបស្សនា រហូតសម្រេចអរហត្ត សមដូចគាថាព័ន្ធដែលលោកពោលនៅក្នុងអបទានថា

ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានឲ្យគេធ្វើស្ពានថ្វាយ ក្នុងទីចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគ ព្រះនាមវិបស្សី កំពុងចង្រ្កម ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានឲ្យគេធ្វើស្ពាន ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយស្ពាន ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

១- ក្នុងអបទាន ជាសេតុទាយកត្ថេរ ។

ម្យ៉ាងទៀត កាលលោកសម្រេចអរហត្តផលហើយ ពិចារណាមើលបដិបទារបស់ខ្លួន កាលនឹងបន្លឺសីហនាទ ទើបពោល ៣ គាថាថា

ឱហ្ន៍ កាមគុណទាំង ៥ ញុំាងអាត្មាអញជាបណ្ឌិត មានសមត្ថ-
ភាព គិតនូវប្រយោជន៍ ឲ្យធ្លាក់ចុះក្នុងលោក ព្រោះតែសេចក្តី
វង្វេងទេតើ ។ អាត្មាអញ ចូលទៅក្នុងវិស័យនៃកិលេសមារ ត្រូវ
សរ គឺរាគៈមុតជាប់ហើយ តែអាចស្ទុះរួច ចាកអន្ទាក់នៃមច្ចុរាជ
បាន ។ កាមទាំងពួង អាត្មាអញបានលះបង់ហើយ ភពទាំងពួង
អាត្មាអញបានទម្លាយចោលហើយ ជាតិសង្សារអស់ហើយ
ឥឡូវនេះ ភពថ្មីមិនមាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បណ្ឌិតំ វត មំ សន្តំ** សេចក្តីថា ឲ្យអាត្មាអញដែលសម្បូរដោយបញ្ញា ដែលបានដល់បញ្ញាដែលសម្រេចដោយការស្តាប់ និងការគិត ។

បទថា **អលមត្ថវិចិន្តកំ** សេចក្តីថា អាចគិតនូវប្រយោជន៍ទាំងឡាយរបស់ខ្លួនឯងផង របស់អ្នកដទៃផង ។ ម្យ៉ាងទៀត សេចក្តីថា ជាអ្នកគិតនូវអត្ថដែលល្មមប្រមាណ គឺសមគួរ ឬជាអ្នកឃើញអត្ថដែលអាចកម្ចាត់កិលេសបាន ។ ព្រះថេរៈឲ្យវត្តគ្រប់យ៉ាង ( ពោលដល់គុណសម្បត្តិទាំងអស់ ) នេះ ព្រោះថា ខ្លួនជាអ្នកមានភពចុងក្រោយ ។

បទថា **បញ្ច កាមគុណា** បានដល់ កាមគុណ ៥ ចំណែក មានរូបជាដើម ។

បទថា **លោកេ** ជាពាក្យសម្តែងដល់ស្ថានទីដែលកាមទាំងនោះប្រព្រឹត្តទៅ ។ បទថា **សម្មោហា** សេចក្តីថា ជាគ្រឿងវង្វេង គឺជាហេតុធ្វើទុកក្នុង

ចិត្តដោយអយោនិសោមនសិការ ។ម្យ៉ាងទៀត បទថា **សម្មោហា** បានដល់ វង្វេង គឺវត្ថុដែលធ្វើឲ្យវង្វេង ។

បទថា **ចាវយិំសុ** សេចក្តីថា ឲ្យធ្លាក់ចុះទៅចាកភាពជាអ្នកប្រាជ្ញ ម្យ៉ាងទៀត អធិប្បាយថា ឲ្យអាត្មាអញដែលបំណងជាកំពូលជាងសត្វលោកធ្លាក់ទៅក្នុងលោក ។

បទថា **បក្ខន្ទា** បានដល់ ធ្លាក់ចូលទៅ ។ បទថា **មារវិសយេ** បានដល់ ក្នុងវិស័យនៃកិលេស គឺទីដែលកិលេសមារប្រព្រឹត្តទៅ អធិប្បាយថា ទៅកាន់អំណាចរបស់កិលេសមារនោះ ។ ម្យ៉ាងទៀត បានដល់ ជាប់តាមមារនោះទៅ ក្នុងស្ថានទីដែលជាអំណាចរបស់ទេវបុត្តមារ ។ បទថា **ឧទ្ធ-សល្លសមប្បិតោ** សេចក្តីថា ត្រូវព្រួញមុតយ៉ាងជ្រៅ គឺជាប់ស្អិត ម្យ៉ាងទៀត ត្រូវព្រួញដែលស្អិត គឺត្រូវព្រួញរាគៈដោតដល់ហទយៈ ។

បទថា **អសក្ខឹ មច្ចុរាជស្ស អហំ បាសា បមុច្ចិតុំ** សេចក្តីថា ខ្ញុំប្រើអង្គំ គឺអរិយមគ្គដកនូវព្រួញ មានរាគៈជាដើមបានហើយ ដោយមិនមានសេសសល់ ផុតចាកអន្ទាក់របស់ស្តេចមច្ចុ ពោល គឺចំណង គឺរាគៈបានហើយ គឺដោះខ្លួនចាកអន្ទាក់នោះបានហើយ ។

គួរជ្រាបវិនិច្ឆ័យបន្ទាប់អំពីនោះថា បទថា **សព្វេ កាមា បហីនា មេ ភវា សព្វេ បទាលិតា** សេចក្ដីថា កិលេសកាមមានច្រើនប្រភេទ ដោយចែកទៅតាមវត្ថុ និងអារម្មណ៍ ខ្ញុំលះបានអស់ហើយដោយការកាត់ដោយអរិយមគ្គ ព្រោះថា កាលលះកិលេសកាមទាំងឡាយបានហើយ សូម្បីវត្ថុកាមក៏ឈ្មោះថា លះបានហើយដូចគ្នា ។ មួយវិញទៀត ភពទាំងឡាយ មានកាមភពនិងកម្មភពជាដើម ខ្ញុំទម្លាយ គឺកម្ចាត់បានអស់ហើយ ដោយដាវ គឺមគ្គញ្ញាណ ព្រោះថា កាលទម្លាយកម្មភពបានហើយ ឧបបត្តិភព ក៏ឈ្មោះថា ទម្លាយបានហើយដូចគ្នា ព្រោះទម្លាយកម្មភពបានយ៉ាងនេះឯង ជាតិសង្សារអស់ហើយ ឥឡូវនេះ ភពថ្មីមិនមាន ។ អត្ថរបស់បទនោះ បានអធិប្បាយខាងដើមហើយ ។ គាថានេះ បានជាគាថាព្យាករអរហត្តផលរបស់ព្រះថេរៈ ។៙

**អដ្ឋកថា ឧត្តរថាលត្ថេរគាថា ចប់**

# សុត្តន្តបិដក

## អភិភូតត្ថេរគាថា

[ ១៨៣ ] នែពួកញាតិទាំងអស់ ដែលមកជួបជុំក្នុងទីនេះ អ្នកទាំងឡាយចូរប្រុងស្តាប់ចុះ អាត្មាសូមសម្តែងធម៌ដល់អ្នកទាំងឡាយថា ការកើតរឿយៗ ជាហេតុនាំមកនូវទុក្ខ ។ អ្នកទាំងឡាយ ចូរប្រារព្ធព្យាយាម ចូរគេចចេញ ( ចាកសេចក្តីខ្ជិល ) ចូរប្រកប ( នូវសិក្ខា មានអធិសីលសិក្ខាជាដើម ) ក្នុងព្រះពុទ្ធសាសនា ចូរកម្ចាត់បង់នូវសេនានៃមច្ចុ ឲ្យដូចជាដំរីកម្ចាត់បង់នូវផ្ទះ ដែលធ្វើដោយដើមបបុស ដូច្នោះចុះ ។ បុគ្គលណាជាអ្នកមិនមានសេចក្តីប្រមាទក្នុងធម្មវិន័យនេះ បុគ្គលនោះ នឹងលះបង់នូវជាតិសង្សារ ធ្វើនូវទីបំផុតនៃទុក្ខបាន ។

អភិភូតត្ថេរ

# អដ្ឋកថា

## អភិភូតត្ថេរគាថា

[ ១៨៣ ] គាថារបស់ព្រះអភិភូតត្ថេរ មានពាក្យផ្តើមថា **សុណាថ ញាតយោ សព្វេ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើមកហើយ ក្នុង

ព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភព នោះៗ ។ ក្នុងសាសនានៃព្រះមានព្រះភាគ ព្រះនាមវេស្សភូ កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្តីហើយ ជ្រះថ្លាក្រៃលែងក្នុងព្រះសាសនា ព្រោះអាស្រ័យកល្យាណមិត្តដែលមានចិត្តធ្ងន់ កាលព្រះសាស្តាបរិនិព្វានហើយ មហាជននាំគ្នាធ្វើនូវឧស្សាហ៍ ដើម្បីទទួលយកព្រះធាតុរបស់ព្រះអង្គ កុលបុត្តនោះ បាននាំយកទឹកក្រអូប លត់ជើងថ្ករមុនជនទាំងពួងដោយខ្លួនឯង ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅមកក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងរាជត្រកូល ក្នុងវេដ្ឋបុរៈ បានទទួលនាមថា **អភិភូត** អំណើះឥតអំពីព្រះជនក ក៏បានសោយរាជសម្បត្តិ ។ ក្នុងសម័យនោះ ព្រះមានព្រះភាគទ្រង់ចារិកទៅកាន់ជនបទ ដល់នគរនោះ គ្រានោះ ព្រះរាជាអង្គនោះទ្រង់បានដំណឹងថា ព្រះសាស្តាយាងមកដល់នគររបស់យើង បានយាងទៅកាន់សម្នាក់របស់ព្រះសាស្តា ស្តាប់ព្រះធម្មទេសនាហើយ ។ ក្នុងថ្ងៃទី ២ បានថ្វាយមហាទាន ។ ព្រះមានព្រះភាគ សម្រេចភត្តកិច្ចហើយ កាលអនុមោទនា ឲ្យសមគួរដល់អធ្យាស្រ័យនៃព្រះរាជានោះឯង ទើបទ្រង់សម្តែងធម៌ទេសនាដោយពិស្តារ ព្រះរាជាស្តាប់ព្រះធម្មទេសនាហើយ បាននូវព្រះរាជបសាទសទ្ធា លះបង់រាជសម្បត្តិ ចេញបួស បានធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

កាលសរីរៈរបស់ព្រះវេស្សភូ ទ្រង់ស្វែងរកនូវគុណដ៏ធំ ដែលជន
កំពុងបូជាភ្លើង ខ្ញុំបានយកទឹកអប់រំលត់ជើងថ្ករ ។ ក្នុងកប្បទី ៣១

អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំរម្ងត់ជើងប្ការ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃទឹកអប់ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ម្យ៉ាងទៀត កាលព្រះថេរៈសម្រេចអរហត្តផលហើយ សម្ងំនៅដោយវិមុត្តិសុខ មនុស្សទាំងអស់ គឺព្រះញាតិ អមាត្យ រាជបរិវារ អ្នកនគរ និងអ្នកជនបទ នាំគ្នាមកប្រជុំគ្នា យំខ្សឹកខ្សួលថា បពិត្រលោកម្ចាស់ ហេតុអ្វីទើបលោកម្ចាស់បួស ធ្វើឲ្យពួកខ្ញុំមិនមានទីពឹង ។ ព្រះថេរៈឃើញមនុស្សទាំងឡាយនោះ ដែលមានពួកញាតិជាប្រមុខ នាំគ្នាខ្សឹកខ្សួល ទើបពោលធម្មកថាលួងលោមមនុស្សទាំងនោះ ដោយបំណងប្រាប់ហេតុនៃបព្វជ្ជារបស់ខ្លួន ទើបភាសិត ៣ គាថាថា

នៃពួកញាតិទាំងអស់ ដែលមកជួបជុំក្នុងទីនេះ អ្នកទាំងឡាយចូរប្រុងស្តាប់ចុះ អាត្មាសូមសម្តែងធម៌ដល់អ្នកទាំងឡាយថា ការកើតរឿយៗ ជាហេតុនាំមកនូវទុក្ខ ។ អ្នកទាំងឡាយ ចូរប្រារព្ធព្យាយាម ចូរគេចចេញ ( ចាកសេចក្តីខ្ជិល ) ចូរប្រកប ( នូវសិក្ខា មានអធិសីលសិក្ខាជាដើម ) ក្នុងព្រះពុទ្ធសាសនា ចូរកម្ចាត់បង់នូវសេនានៃមច្ចុ ឲ្យដូចជាដំរីកម្ចាត់បង់នូវផ្ទះ ដែលធ្វើដោយដើមបបុស ដូច្នោះចុះ ។ បុគ្គលណា ជាអ្នកមិនមាន

---

១- ក្នុងអបទាន ជាចិតកនិព្វាបកត្ថេរ ។

សេចក្តីប្រមាទក្នុងធម្មវិន័យនេះ បុគ្គលនោះ នឹងលះបង់នូវជាតិសង្សារ ធ្វើនូវទីបំផុតនៃទុក្ខបាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សុណាថ** សេចក្តីថា ចូរស្ងប់ចិត្ត ហើយស្តាប់ អធិប្បាយថា ចូរចាំទុកនូវពាក្យដែលអាត្មាកំពុងពោលនេះតាមគន្លងនៃសោតទ្វារ ដែលបានផ្ទៀងស្តាប់ហើយ ។ ពាក្យថា **ញាតយោ** ជាពាក្យហៅមនុស្សទាំងនោះ មានព្រះញាតិជាប្រធាន ។ ដោយពាក្យនេះ ព្រះថេរៈបានពោលថា នៃពួកញាតិទាំងអស់ ដែលមកជួបជុំក្នុងទីនេះ អធិប្បាយថា ញាតិទាំងឡាយ មានចំនួនប៉ុនណា គឺមានប្រមាណប៉ុនណា ដែលមកព្រមគ្នាហើយ ក្នុងសមាគមនេះ ឬដែលព្រមព្រៀងគ្នាក្នុងការបួសរបស់អាត្មានេះ ។

ឥឡូវនេះ ព្រះថេរៈកាលជាស់តឿនថា អាត្មាសូមសម្តែងធម៌ដល់អ្នកទាំងឡាយ ដោយអាងដល់ពាក្យប្រាប់ឲ្យស្តាប់ដោយពាក្យថា ចូរប្រុងស្តាប់ចុះ ដូច្នេះហើយ បានប្រារព្ធដើម្បីសម្តែងដោយន័យជាដើមថា ការកើតរឿយៗជាហេតុនាំមកនូវទុក្ខ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទទាំងនោះដូចតទៅ ឈ្មោះថា ការកើត ក្នុងបទថា **ទុក្ខា ជាតិ បុនប្បុនំ** នេះ ឈ្មោះថា **ទុក្ខា** ព្រោះជាទីតាំងនៃទុក្ខច្រើនប្រភេទ មានការឈានចុះកាន់គភ៌ជាមូល និងបែកប្រភេទជាជរាជាដើម ការកើតដែលប្រព្រឹត្តទៅហើយ ម្តងហើយ ម្តងទៀត ជាទុក្ខច្រើនយ៉ាង តែព្រះថេរៈ កាលនឹងសម្តែងថា សេចក្តីព្យាយាមដើម្បីរម្ងាប់ការកើតនោះ ជា

កិច្ចដែលគួរធ្វើ ទើបពោលពាក្យជាដើមថា **អារភថ** ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **អារភថ** សេចក្ដីថា ចូរធ្វើសេចក្ដីព្យាយាម បានដល់ អារម្ភធាតុ ។

បទថា **និក្ខមថ** សេចក្ដីថា ចូរធ្វើសេចក្ដីព្យាយាមឲ្យក្រៃលែងឡើង បានដល់ **និក្ខមធាតុ** គឺការឈានតទៅ ព្រោះជាបុគ្គលឈានចេញទៅ ហើយចាកអកុសលធម៌ ដែលជាចំណែករបស់សេចក្ដីខ្ជិលច្រអូស ។ បទថា **យុញ្ជថ ពុទ្ធសាសនេ** សេចក្ដីថា ព្រោះអារម្ភធាតុ និងនិក្កមធាតុទាំងឡាយ រមែងសម្បូរដល់បុគ្គលដែលតាំងមាំក្នុងធម៌ទាំងឡាយនេះ គឺការសង្រួមក្នុងសីល ភាពជាអ្នកមានទ្វារគ្រប់គ្រងហើយ ក្នុងឥន្ទ្រិយទាំងឡាយ ភាពជាអ្នកដឹងនូវប្រមាណក្នុងការបរិភោគ និងការដឹងខ្លួនយ៉ាងក្រៃលែង ដោយអំណាចនៃការប្រកបសេចក្ដីព្យាយាមរឿយៗ ដូច្នោះ អ្នកទាំងឡាយដែលនៅក្នុងទីនេះ ចូរជាអ្នកខ្នះខ្នែងក្នុងពាក្យប្រៀនប្រដៅរបស់ព្រះមានព្រះភាគ ពោលគឺសមថៈ និងវិបស្សនា ឬក្នុងសីលសិក្ខាជាដើម ។

បទថា **ធុនាថ មច្ចុនោ សេនំ នឡាគារំវ កុញ្ជរោ** សេចក្ដីថា កាលអ្នកទាំងឡាយបដិបត្តិយ៉ាងនេះ នឹងកម្ចាត់ គឺញាំញី បានដល់ ទម្លាយនូវ

គំនរកិលេស ពោល គឺសេនារបស់ស្តេចមច្ចុនោះ ព្រោះសត្វទាំងឡាយ ទៅកាន់អំណាចរបស់ស្តេចមច្ចុ ដែលជាធំក្នុងលោកធាតុទាំង ៣ ដែលជាក្រុមនៃកិលេស មិនមានកម្លាំង គឺមានកម្លាំងថមថយ ឧបមាដូចដីរដែលប្រកបដោយកម្លាំងមហិមា កាច់បំបាក់នូវផ្ទះ ដែលធ្វើដោយដើមបបុស ឲ្យខ្ទាត់ខ្ទាយទៅមួយរំពេចនោះឯង ។

ម្យ៉ាងទៀត ព្រះថេរៈ កាលសម្តែងដល់ភាពជាអ្នកធ្វើឧស្សាហៈក្នុងព្រះពុទ្ធសាសនាយ៉ាងនេះថា បុគ្គលនៅម្នាក់ឯង ជាអ្នកឈានកន្លងនូវជាតិទុក្ខបាន បានពោលគាថាទី ៣ ដោយពាក្យជាដើមថា **យោ ឥមស្មឹ** ជាដើម ពាក្យនោះ មានអត្ថងាយយល់ហើយ ។៚

**អដ្ឋកថា អភិក្កន្តត្ថេរគាថា ចប់**

# សុត្តន្តបិដក

## គោតមត្ថេរគាថា

[ ១៨៤ ] អាត្មាអញ កាលអន្ទោលទៅ ( ក្នុងសង្សារ ) បានទៅកាន់នរកញយៗ ផង ទៅកាន់ប្រេតវិស័យញយៗ ផង បានកើតក្នុងកំណើតតិរច្ឆានវេទុក្ខជាញយៗ ផង ហើយអាត្មាអញនៅ ( វេទុក្ខ ) អស់កាលយូរអនេក ។ ម្យ៉ាងទៀត ភពជារបស់មនុស្ស អាត្មាអញធ្លាប់បានហើយ ចួនកាល អាត្មាអញបានទៅកើតក្នុងពួកនៃទេវតាក្នុងឋានសួគ៌ ចួនកាល អាត្មាអញឋិតនៅក្នុងរូបភព ក្នុងអរូបភព ក្នុងនេវសញ្ញីភព ក្នុងអសញ្ញីភព ( និងនេវសញ្ញីនាសញ្ញីភព ) ។ ភពទាំងឡាយដែលប្រកបដោយបច្ច័យ អាត្មាបានដឹងច្បាស់ហើយថា ជារបស់ឥតខ្លឹម ជារបស់បច្ច័យតាក់តែងហើយ ជារបស់ឃ្លេងឃ្លោង ( ដោយអំណាចជរាជាដើម ) ជារបស់ប្រព្រឹត្តទៅដោយការបែកធ្លាយសព្វៗ កាល អាត្មាអញដឹងច្បាស់នូវសភាវៈនៃសង្ខតធម៌នោះ ជាសភាវៈកកើតក្នុងខ្លួន ហើយជាអ្នកមានស្មារតី បាននូវសេចក្តីស្ងប់រម្ងាប់មែនពិត ។

គោតមត្ថេរ

# អដ្ឋកថា

## គោតមត្ថេរគាថា

[ ១៨៤ ] គាថារបស់ព្រះគោតមត្ថេរ មានពាក្យផ្តើមថា **សំសរំ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ។ ក្នុងកាលព្រះមានព្រះភាគព្រះនាមសិខីបរិនិព្វានហើយ កាលទេវតា និងមនុស្សទាំងឡាយនាំគ្នាបូជាជើងថ្ករបស់ព្រះមានព្រះភាគអង្គនោះ ក៏បានបូជាជើងថ្ករ ដោយផ្កាចម្ប៉ា ៨ ទង ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅមកក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ បដិសន្ធិក្នុងសក្យត្រកូល មាននាម និងគោត្តថា គោតមនោះឯង ទ្រង់ចម្រើនវ័យហើយ ក្នុងកាលប្រជុំពួកញាតិរបស់ព្រះសាស្តា បាននូវសទ្ធា ចេញបួស ចម្រើនវិបស្សនា ក៏បានសម្រេចអភិញ្ញា ៦ ។ ដោយហេតុនោះ សមដូចគាថាព័ន្ធដែលលោកពោលនៅក្នុងអបទានថា

កាលព្រះមានព្រះភាគព្រះនាមសិខី ជាលោកពន្ធុ ដែលជនកំពុងបូជាភ្លើង ខ្ញុំបានបូជាផ្កាចម្ប៉ា ៨ ទង ចំពោះជើងថ្ករ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ

ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ម្យ៉ាងទៀត កាលលោកសម្រេចអភិញ្ញា ៦ ហើយ សម្ងំដោយវិមុត្តិសុខ ថ្ងៃមួយ ត្រូវពួកញាតិទាំងឡាយសួរថា ហេតុអ្វី ទើបលោកម្ចាស់បោះបង់ពួកយើងទៅបួស កាលប្រកាសទុក្ខដែលខ្លួនបានសោយហើយក្នុងសង្សារនោះឯង និងនិព្វានសុខ ដែលខ្លួនបានសម្រេចក្នុងបច្ចុប្បន្ន ទើបសម្ដែងធម៌ថ្វាយព្រះញាតិទាំងនោះដោយ ៣ គាថាថា

អាត្មាអញ កាលអន្ទោលទៅ ( ក្នុងសង្សារ ) បានទៅកាន់នរកញយៗ ផង ទៅកាន់ប្រេតវិស័យញយៗ ផង បានកើតក្នុងកំណើតតិរច្ឆានរងទុក្ខជាញយៗ ផង ហើយអាត្មាអញនៅ ( រងទុក្ខ ) អស់កាលយូរអនេក ។ ម្យ៉ាងទៀត ភពជារបស់មនុស្សអាត្មាអញធ្លាប់បានហើយ ចួនកាល អាត្មាអញបានទៅកើតក្នុងពួកនៃទេវតាក្នុងឋានសួគ៌ ចួនកាល អាត្មាអញឋិតនៅក្នុងរូបភពក្នុងអរូបភព ក្នុងនេវសញ្ញីភព ក្នុងអសញ្ញីភព ( និងនេវសញ្ញីនាសញ្ញីភព ) ។ ភពទាំងឡាយ ដែលប្រកបដោយបច្ច័យ អាត្មាបានដឹងច្បាស់ហើយថា ជារបស់ឥតខ្លឹម ជារបស់បច្ច័យតាក់តែងហើយ ជារបស់ឃ្លេងឃ្លោង ( ដោយអំណាចជរាជាដើម ) ជារបស់ប្រព្រឹត្តទៅ ដោយការបែកធ្លាយសព្វៗ កាល អាត្មាអញដឹងច្បាស់នូវសភាវៈនៃសង្ខតធម៌នោះ ជាសភាវៈកកើតក្នុងខ្លួន

---

១- ក្នុងអបទាន ជាចិតកបូជកត្ថេរ ។

ហើយ ជាអ្នកមានស្មារតី បានទូវសេចក្ដីស្ងប់រម្ងាប់មែនពិត ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សំសរំ** សេចក្ដីថា អន្ទោលទៅមកក្នុងសង្សារដែលមិនមានខាងដើម អធិប្បាយថា អន្ទោលទៅមកដោយអំណាចនៃចុតិ និងបដិសន្ធិ ក្នុងគតិទាំង ៥ ដោយកម្ម និងកិលេសទាំងឡាយ ។ **ហិ** សព្ទ ត្រឹមតែជានិបាត ។

បទថា **និរយំ អគច្ឆិស្សំ** សេចក្ដីថា ចូលដល់នរកធំទាំង ៨ រណ្ដៅមានសញ្ជីវនរកជាដើម និងឧស្សទនរក ១៦ រណ្ដៅ មានកុក្កុឡនរកជាដើម ដោយអំណាចនៃបដិសន្ធិ ។ ពាក្យថា **បុនប្បុនំ** នេះ គួរនាំមកប្រកបក្នុងពាក្យថា **និរយំ អគច្ឆិស្សំ** នេះផងដែរ ។

បទថា **បេតលោកំ** បានដល់ បិត្តិវិស័យ អធិប្បាយថា បានដល់អត្តភាពប្រេត មានខុប្បិបាសាប្រេតជាដើម ។

បទថា **អាគមំ** បានដល់ ចូលដល់ គឺកើតឡើងដោយអំណាចនៃបដិសន្ធិ ។

បទថា **បុនប្បុនំ** បានដល់ ទៅមកៗ ។ បទថា **ទុក្ខមម្ហិបិ** សេចក្ដីថា បានទទួលទុក្ខដោយទុក្ខទាំងឡាយ មានការវាយដោយផ្ដៅដែលរឹង និងចាក់គ្នានិងគ្នាដោយស្នែដែលមុតជាដើម ។ បទថា **ទុក្ខមម្ហិបិ** នេះ លោកពោលដោយអំណាចនៃលិង្គវិបល្លាស ( ដែលត្រូវជា **ទុក្ខមាយបិ** ព្រោះជាវិសេសនៈនៃ **តិរច្ឆានយោនិយា** ) ។ បទថា **តិរច្ឆានយោនិយំ** បានដល់

ក្នុងកំណើតតិរច្ឆាន បែកប្រភេទជាម្រឹគ និងបក្សីជាដើម ។

បទថា **ឆេកធា ហិ** សេចក្តីថា អាត្មានៅក្នុងភពមកយូរហើយ គឺអស់កាលវែងឆ្ងាយហើយ ជាអនេកប្រការ ដោយអំណាចសត្វជើង ៤ មានឱដ្ឋ គោ និងពពែជាដើម ទាំងដោយអំណាចសត្វស្ពាប មានក្អែក ត្មុំ និងស្មាំង ជាដើម និងច្រើនវារៈ គឺសោយទុក្ខដោយអំណាចនៃភ័យ មានចិត្តតក់ស្លុត ជានិច្ចជាដើម ដើម្បីសម្តែងឲ្យឃើញថា សត្វដែលកើតក្នុងកំណើតតិរច្ឆាន ត្រឡប់ទៅត្រឡប់មកក្នុងកំណើតតិរច្ឆាននោះឯង អស់កាលយូរ ព្រោះមោហៈ ទើបព្រះថេរៈពោលពាក្យថា **ចិរំ** ក្នុងទីនេះ ។

បទថា **មានុសោបិ ច ភវោភិរាធិតោ** សេចក្តីថា សូម្បីអត្តភាពជាមនុស្ស ក៏អាត្មាបានទទួលមកហើយ គឺសម្រេចមកហើយ បានដល់ បានមកហើយ ដោយកុសលកម្មបែបនោះ ប្រជុំគ្នាជាហេតុ ។ ក្នុងរឿងនេះ គួរលើកយកកាណកច្ឆបោបមសូត្រ ( ព្រះសូត្រដែលពោលអំពីអណ្តើកខ្វាក់ក្នុងមហាសមុទ្រ ) មកជាឧទាហរណ៍ ។

បទថា **សគ្គកាយមគមំ សកឹ សកឹ** សេចក្តីថា អាត្មាបានចូលដល់ពួកទេវតាជាន់កាមាវចរ ពោល គឺការទៅកាន់ស្ថានសួគ៌ ដោយអំណាចនៃការកើតឡើងម្តងម្កាល គឺកាលខ្លះ សម័យខ្លះ ។

បទថា **រូបធាតុសុ** បានដល់ ក្នុងរូបភព មានភវគ្គព្រហ្មដែលជាបុថុជ្ជនជាទីបំផុត ។

បទថា **អរូបធាតុសុ** បានដល់ ក្នុងអរូបភពទាំងឡាយ ។

បទថា **នេវសញ្ញិសុ អសញ្ញិសដ្ឋិតំ** សេចក្តីថា មិនមែនត្រឹមតែកើតក្នុងរូបភព និងអរូបភពតែប៉ុណ្ណោះទេ ដោយពិត សូម្បីក្នុងនេវសញ្ញីនាសញ្ញីភព និងក្នុងអសញ្ញីភព ក៏កើតឡើង តាំងនៅហើយ ។ គួរនាំបទថា **មយា** ( ដែលខ្ញុំ ) មកប្រកបបចូលផង ។ ក្នុងគាថានេះ លោកកាន់យក **នេវសញ្ញីនាសញ្ញីភព** ដោយសព្ទថា **នេវសញ្ញី** ។ គប្បីជ្រាបថា សូម្បីភពទាំង ២ នេះ លោកកាន់យកដោយសព្ទថា **រូបធាតុ** និង **អរូបធាតុ** ក៏ពិត តែសត្វពួកណា ក្រៅសាសនានេះ មានការសម្គាល់ក្នុងភពនោះថា ទៀងពិត និងមានសេចក្តីសម្គាល់ថា ជាការរួចផុតក្នុងភព ដើម្បីសម្តែងឲ្យឃើញថា ការសម្គាល់នោះ របស់សត្វទាំងនោះខុស ទើបលោកញែកចេញអំពីគ្នា ។

ព្រះថេរៈកាលសម្តែងការសោយវដ្តទុក្ខរបស់ខ្លួនក្នុងសង្សារ ដែលមិនមានខាងដើម និងព្រោះភាពដែលលោកកាត់ផ្តាច់នូវឫសគល់នៃភពដោយ ២ គាថាយ៉ាងនេះហើយ ឥឡូវនេះ កាលនឹងសម្តែងការសោយវិវដ្តសុខ ព្រោះកាត់នូវវដ្តទុក្ខនោះ ទើបពោលគាថាទី ៣ ដោយន័យថា **សម្ភវា** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **សម្ភវា** បានដល់ ភពទាំងឡាយ ព្រោះថាភពទាំងឡាយ មានកាមភពជាដើមនោះឯង មានដោយការប្រជុំនៃហេតុបច្ច័យ ព្រោះហេតុនោះ ទើបក្នុងគាថានេះ ភព លោកពោលថា **សម្ភវ**។

បទថា **សុវិទិតា** សេចក្តីថា ដឹងល្អហើយ ដោយមគ្គបញ្ញា ដែលប្រកបដោយវិបស្សនាបញ្ញា ។

បទថា **អសារកា** ជាដើម ជាពាក្យសម្តែងដល់អាការដែលលោក ទាំងនោះដឹងល្អហើយ ។

បណ្តាបទទាំងនោះ បទថា **អសារកា** សេចក្តីថា វៀរចាកសារៈ មាននិច្ចសារៈជាដើម ។

បទថា **សង្ខតា** សេចក្តីថា ដែលបច្ច័យទាំងឡាយប្រជុំតាក់តែងឡើង ។

បទថា **បចលិតា** សេចក្តីថា ញាប់ញ័រដោយប្រការផ្សេងៗ គឺមិនតាំងនៅមាំ ព្រោះការកើត និងការចាស់ជាដើម ព្រោះត្រូវបច្ច័យប្រជុំតាក់តែងនោះឯង ។

បទថា **សទេរិតា** សេចក្តីថា ញាប់ញ័រហើយ គឺជារបស់គ្រោតគ្រាតព្រោះបែកធ្លាយទៅ បានដល់ ដល់នូវការទ្រុឌទ្រោមទៅ អធិប្បាយថា ធ្លុះធ្លាយទៅគ្រប់ៗ កាល គឺសព្វកាល ។

បទថា **តំ វិទិត្វា មហាមត្តសម្ភវំ** សេចក្តីថា ខ្ញុំកាលដឹងច្បាស់នូវភាពនោះ គឺសភាពដែលត្រូវតាក់តែងតាមដែលពោលហើយ ដែលកើត

*ក្នុងខ្លួន គឺសម្កពហើយក្នុងខ្លួន បានដល់ ទាក់ទងដោយខ្លួន មិនទាក់ទងដោយអ្នកដទៃ ដោយអំណាចជាតិជាធំជាដើម ដោយអំណាចការសម្រេចដោយការកំណត់ដឹងហើយ ទើបជាអ្នកមានស្មារតី ដោយសតិដែលសម្បយុត្តនឹងមគ្គប្បញ្ញា បានសម្រេច គឺដល់ បានដល់ ដល់ហើយ ដោយលំដាប់ដោយអរិយមគ្គការនៃនានូវសន្តិធម៌នោះឯង គឺព្រះនិព្វាននោះឯង ដែលជាបដិបក្ខចំពោះភពនោះ ព្រះថេរៈបានព្យាករអរហត្តផល ដល់ព្រះញាតិទាំងនោះ ដោយការសម្តែងធម៌ដោយប្រការដូចពោលមកនេះ ។*

**អដ្ឋកថា គោតមត្ថេរគាថា ចប់**

# សុត្តន្តបិដក

## ហារិតត្ថេរគាថា

[ ១៨៥ ] បុគ្គលណា មិនធ្វើនូវកិច្ចដែលគួរធ្វើក្នុងកាលមុន ហើយចង់ធ្វើក្នុងកាលក្រោយវិញ បុគ្គលនោះ រមែងឃ្លាតចាកឋានៈជាសុខផង ក្តៅក្រហាយរឿយៗ ក្នុងកាលជាក្រោយផង ។ បុគ្គលធ្វើអំពើណា ត្រូវនិយាយចំពោះតែអំពើនោះ មិនធ្វើអំពើណា មិនត្រូវនិយាយចំពោះអំពើនោះទេ បណ្ឌិតទាំងឡាយ តែងកំណត់ដឹងច្បាស់នូវបុគ្គលមិនធ្វើ បានតែនិយាយ ។ សេចក្តីទុក្ខរលត់ទៅក្នុងព្រះនិព្វានណា ព្រះនិព្វាននោះ ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់សម្តែងហើយ ជាគុណជាត មិនមានសេចក្តីសោក ប្រាសចាកធូលី ជាទីក្សេមក្សាន្ត នាំមកនូវសុខដោយប្រពៃមែនពិត ។

ហារិតត្ថេរ

# អដ្ឋកថា

## ហារិតត្ថេរគាថា

[ ១៨៥ ] គាថារបស់ព្រះហារិតត្ថេរ មានពាក្យផ្តើមថា **យោ បុព្ពេ ករណីយានិ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះ ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ

កើតហើយក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្ដីហើយ លុះព្រះសាស្ដាបរិនិព្វានហើយ មហាជននាំគ្នាបូជាដើមថ្កូវរបស់ទ្រង់ កុលបុត្តនេះ បានធ្វើការបូជាដោយគ្រឿងក្រអូប ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅមកក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលព្រាហ្មណ៍ក្នុងក្រុងសាវត្ថី មានឈ្មោះថា **ហារិតៈ** ចម្រើនវ័យហើយ អាស្រ័យការប្រកាន់ខ្លួនព្រោះជាតិ ទើបហៅអ្នកដទៃដោយវាទៈថា អ្នកថោកទាប កុលបុត្តនោះ ទៅកាន់សម្នាក់របស់ភិក្ខុទាំងឡាយ ស្ដាប់ធម៌ហើយ ទើបចេញបួស មិនលះបង់ការហៅអ្នកដទៃថា អ្នកថោកទាប ព្រោះប្រព្រឹត្តមកយូរហើយ ។ ថ្ងៃមួយ លោកបានស្ដាប់ធម៌ក្នុងសម្នាក់ព្រះសាស្ដា កើតសេចក្ដីសង្វេគ ផ្ដើមវិបស្សនាកម្មដ្ឋាន ពិចារណាមើលការប្រព្រឹត្តទៅនៃចិត្តរបស់ខ្លួន បានឃើញចិត្តត្រូវមានះ និងឧទ្ធច្ចៈក្ដោបក្ដាប់ហើយ ទើបលះមានះ និងឧទ្ធច្ចៈ ញុំាងវិបស្សនាឲ្យក្រៃលែងឡើង បានសម្រេចអរហត្តផល សមដូចគាថាព័ន្ធដែលលោកពោលនៅក្នុងអបទានថា

កាលពួកជនកំពុងធ្វើដើមថ្កូវ កំពុងនាំមកនូវគ្រឿងក្រអូបផ្សេងៗ
ខ្ញុំក៏មានចិត្តជ្រះថ្លា មានចិត្តរីករាយ បានបូជានូវគ្រឿងក្រអូបមួយក្ដាប់ ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាដើមថ្កូវក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាដើមថ្កូវ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ

ភពទាំងអស់ ខ្ញុំបានដកចោលហើយ ខ្ញុំមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្ទឹង ។ ឱ ខ្ញុំមកល្អហើយ ក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ម្យ៉ាងទៀត កាលបានជាព្រះអរហន្តហើយ សោយវិមុត្តិសុខ បានព្យាករអរហត្តផល ដោយការឲ្យឱវាទដល់ភិក្ខុទាំងឡាយដោយ ៣ គាថាថា

បុគ្គលណា មិនធ្វើនូវកិច្ចដែលគួរធ្វើក្នុងកាលមុន ហើយចង់ធ្វើក្នុងកាលក្រោយវិញ បុគ្គលនោះ រមែងឃ្លាតចាកឋានៈជាសុខផង ក្តៅក្រហាយរឿយៗ ក្នុងកាលជាក្រោយផង ។ បុគ្គលធ្វើអំពើណា ត្រូវនិយាយចំពោះតែអំពើនោះ មិនធ្វើអំពើណា មិនត្រូវនិយាយចំពោះអំពើនោះទេ បណ្ឌិតទាំងឡាយ តែងកំណត់

---

១- ក្នុងអបទានជា គន្ធបូជកត្ថេរ ។

ដឹងច្បាស់នូវបុគ្គល មិនធ្វើ បានតែនិយាយ ។ សេចក្តីទុក្ខរលត់ទៅក្នុងព្រះនិព្វានណា ព្រះនិព្វាននោះ ដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងហើយ ជាគុណជាត មិនមានសេចក្តីសោក ប្រាសចាកធូលី ជាទីក្សេមក្សាន្ត នាំមកនូវសុខដោយ ប្រពៃមែនពិតដូច្នេះ ។

អត្ថនៃគាថាទាំងនេះ បានពោលហើយខាងដើមនោះឯង ( ក្នុងគាថារបស់ព្រះពាកុលត្ថេរ ) ។ល។

## អដ្ឋកថា ហារិតត្ថេរគាថា ចប់

# សុត្តន្តបិដក

## វិមលត្ថេរគាថា

[ ១៨៦ ] កុលបុត្ត កាលប្រាថ្នាសេចក្តីសុខមិនកម្រើក គប្បីចៀសវាងនូវបាបមិត្តទាំងឡាយ ហើយគប់រកនូវបុគ្គលខ្ពង់ខ្ពស់ទាំងឡាយផង គប្បីតាំងនៅក្នុងឱវាទ របស់កល្យាណមិត្តនោះផង ។ បុគ្គលតោងកំណាត់ឈើតូច រមែងលិចចុះក្នុងសមុទ្រធំ យ៉ាងណា កុលបុត្តអាស្រ័យនូវបុគ្គលខ្ជិលច្រអូសហើយ ទុកជារស់នៅស្រួល ក៏រមែងលិចចុះ យ៉ាងនោះដែរ ។ ព្រោះហេតុនោះ បុគ្គលគប្បីចៀសវាងនូវបុគ្គលអ្នកខ្ជិលច្រអូស មានព្យាយាមថោកទាបនោះចេញ ។ កុលបុត្តគប្បីនៅរួមជាមួយនឹងពួកអរិយៈ អ្នកមានចិត្តស្ងប់ស្ងាត់ អ្នកចម្រើនឈាន មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ជាបណ្ឌិត មានព្យាយាមតឹងរ៉ឹងជានិច្ច ។

វិមលត្ថេរ

**ឧទ្ទាន**

និយាយអំពីលោកអ្នកស្វែងរកគុណ គឺអង្គណិកភារទ្វាជត្ថេរ ១ បច្ចយត្ថេរ ១ ពាកុលត្ថេរ ១ ធនិយត្ថេរ ១ មាតង្គបុត្តត្ថេរ ១ ខុជ្ជសោភិតត្ថេរ ១ វារណត្ថេរ ១ ម្យ៉ាងទៀត លោកអ្នកធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន គឺបស្សិកត្ថេរ ១ យសោជត្ថេរ ១ សាដិមត្តិយត្ថេរ ១ ឧបាលិត្ថេរ ១ ឧត្តរបាលត្ថេរ ១ អភិភូតត្ថេរ ១ គោតមត្ថេរ ១ ហារិតត្ថេរ ១ វិមលត្ថេរ ១ ព្រះថេរៈទាំងឡាយ ១៦ អង្គ បានសម្តែងនូវគាថា ៤៨ ដែលមកក្នុងតិកនិបាត ។

**តិកនិបាត ចប់**

# អដ្ឋកថា

## វិមលត្ថេរគាថា

[ ១៨៦ ] គាថារបស់ព្រះវិមលត្ថេរ មានពាក្យផ្តើមថា **ធាបមិត្តេ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ព្រះវិមលត្ថេរនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃវិវដ្ត ក្នុងភពនោះៗ ក្នុងសាសនារបស់ព្រះពុទ្ធព្រះនាមបទុមុត្តរៈ កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្តីហើយ កាលព្រះសាស្តាបរិនិព្វានហើយ ថ្ងៃនក្ខត្តឫក្សកីឡាកន្លងទៅហើយ កាលឧបាសក ឧបាសិកាទាំងឡាយ ទទួលយក

ពុទ្ធសរីរៈទៅកាន់ទីថ្វាយព្រះភ្លើង កុលបុត្តនោះ រឭកដល់ពុទ្ធគុណរបស់ព្រះសាស្តាហើយ មានចិត្តជ្រះថ្លា បានធ្វើការបូជាដោយផ្កាម្ទិះ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅមកក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងនគរពារាណសី មានឈ្មោះថា **វិមល** ចម្រើនវ័យហើយ អាស្រ័យព្រះសោមមិត្តត្ថេរ បួសក្នុងព្រះសាសនា ត្រូវព្រះសោមមិត្តត្ថេរនោះឯងដាស់តឿន ផ្តើមបំពេញវិបស្សនា មិនយូរប៉ុន្មានក៏បានសម្រេចអរហត្តផល ដោយហេតុនោះ ទើបលោកពោលក្នុងអបទានថា

កាលព្រះសរីរៈ ( នៃព្រះសម្ពុទ្ធ ) ដែលពួកជនកំពុងហែចេញ ស្គរគេកំពុងប្រគំថ្វាយ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានបូជាផ្កាម្ទិះ ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាព្រះសរីរៈ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ម្យ៉ាងទៀត កាលសម្រេចអរហត្តផលហើយ កាលនឹងឲ្យឱវាទដល់ភិក្ខុ ដែលជាសម្លាញ់របស់ខ្លួន បានភាសិត ៣ គាថាថា

កុលបុត្ត កាលប្រាថ្នាសេចក្តីសុខមិនកម្រើក គប្បីចៀសវាងនូវបាបមិត្តទាំងឡាយ ហើយគប់រកនូវបុគ្គលខ្ពង់ខ្ពស់ទាំងឡាយផង

---

១- ក្នុងអបទាន ជាសត្តិបណ្ណិយត្ថេរ ។

គប្បីតាំងនៅក្នុងឱវាទរបស់កល្យាណមិត្តនោះផង ។ បុគ្គលតោង កំណាត់ឈើតូច រមែងលិចចុះក្នុងសមុទ្រធំ យ៉ាងណា កុលបុត្ត អាស្រ័យនូវបុគ្គលខ្ជិលច្រអូសហើយ ទុកជារស់នៅស្រួល ក៏ រមែងលិចចុះ យ៉ាងនោះដែរ ។ ព្រោះហេតុនោះ បុគ្គលគប្បី ចៀសវាងនូវបុគ្គលអ្នកខ្ជិលច្រអូស មានព្យាយាមថោកទាបនោះ ចេញ ។ កុលបុត្តគប្បីនៅរួមជាមួយនឹងពួកអរិយៈ អ្នកមានចិត្ត ស្ងប់ស្ងាត់ អ្នកចម្រើនឈាន មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ជាបណ្ឌិត មានព្យាយាមតឹងរ៉ឹងជានិច្ច ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ចាបមិត្តេ** បានដល់ មិនជាកល្យាណមិត្ត គឺមិនមែនសប្បុរស ជាអ្នកមានសេចក្តីព្យាយាមធូរថយ ។

បទថា **វិវជ្ជេត្វា** សេចក្តីថា វៀរចាកបាបមិត្តនោះអំពីចម្ងាយ ដោយ ការមិនគប់រក ។

បទថា **ភជេយ្យុត្តមបុគ្គលំ** សេចក្តីថា គួរសេពកល្យាណមិត្តដែលជា សប្បុរស ជាបណ្ឌិត ដោយការទទួលយកឱវាទានុសាសនី ។

*បទថា* **ឱវាទេ ចស្ស តិដ្ឋេយ្យ** *សេចក្ដីថា គួរតាំងនៅក្នុងឱវាទរបស់កល្យាណមិត្តនោះ ដោយបដិបត្តិតាមពាក្យប្រៀនប្រដៅ គឺតាមពាក្យណែនាំ ។*

*បទថា* **បត្តោព្តោ** *បានដល់ ប្រាថ្នា ។ បទថា* **អចលំ សុខំ** *បានដល់ទាំងនិព្វានសុខ ទាំងផលសុខ ដ្បិតថា សេចក្ដីសុខនោះ លោកហៅថា* **អចល** *ព្រោះជាសុខមិនកម្រើក ពាក្យដ៏សេស មានអត្ថដូចពោលមកហើយនោះឯង ។*

**អដ្ឋកថាវិមលត្ថេរគាថា ចប់**

**វគ្គទី ៥ ចប់**

**ថេរគាថា តិកនិបាត ចប់**

# សុត្តន្តបិដក

# ថេរគាថា ចតុក្កនិបាត

## នាគសមាលត្ថេរគាថា

[ ១៨៧ ] ស្រ្តីរបាំម្នាក់ មានខ្លួនស្អិតស្អាងហើយ មានសំពត់ស្លៀកល្អ ទ្រទ្រង់ផ្កាកម្រង ប្រោះព្រំដោយខ្លឹមចន្ទន៍ រាំក្នុងតូរ្យតន្ត្រី ត្រង់កណ្តាលផ្លូវធំ ៗ អាត្មាអញកំពុងដើរចូលទៅ ( កាន់ក្រុង ) ដើម្បីបិណ្ឌបាត ហើយក្រឡេកមើលទៅឃើញស្រ្តីរបាំនោះ ដែលមានខ្លួនស្អិតស្អាងហើយ មានសំពត់ស្លៀកល្អ ហាក់ដូចជាអន្ទាក់នៃមច្ចុ ដែលមច្ចុដំឡើងហើយ ។ លំដាប់នោះ ការធ្វើទុកក្នុងចិត្ត ដោយឧបាយនៃប្រាជ្ញា ក៏កើតឡើងដល់អាត្មាអញ ទោសក៏កើតឡើងប្រាកដ ដល់អាត្មាអញ និព្វិទាញាណ ក៏តាំងនៅព្រម ។ ចិត្តរបស់អាត្មាអញ ក៏រួចស្រឡះ ( ចាកកិលេស ) ព្រោះវិបស្សនាញាណនោះ អ្នកចូរមើលនូវភាពនៃធម៌ ជាធម៌ល្អ វិជ្ជា ៣ អាត្មាអញ បានដល់ដោយលំដាប់ហើយ សាសនានៃព្រះពុទ្ធ អាត្មាអញបានធ្វើហើយ ។

នាគសមាលត្ថេរ

# អដ្ឋកថា
# ថេរគាថា ចតុក្កនិបាត

## នាគសមាលត្ថេរគាថា

[ ១៨៧ ] គាថារបស់ព្រះនាគសមាលត្ថេរ មានពាក្យផ្ដើមថា **អលង្កតា** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា ក្នុងសាសនាព្រះមានព្រះភាគ ព្រះនាមបទុមុត្តរៈ កុលបុត្តនេះ កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្ដីហើយ ក្នុងគិម្ហសម័យ បានឃើញព្រះសាស្ដាយាងលើផែនដីដ៏ក្ដៅ ដោយពន្លឺព្រះអាទិត្យ មានចិត្តជ្រះថ្លា ទើបថ្វាយឆត្រដល់ព្រះសាស្ដា ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងសក្យរាជត្រកូល បានឈ្មោះថា នាគសមាលៈ ចម្រើនវ័យហើយ បាននូវសទ្ធាក្នុងសមាគមនៃពួកញាតិ បួសហើយ បានជាអ្នកឧបដ្ឋាកព្រះមានព្រះភាគ អស់កាលបន្តិចបន្តួច ។ ថ្ងៃមួយ ចូលទៅបិណ្ឌបាតក្នុងព្រះនគរ ឃើញអ្នករបាំម្នាក់ ប្រដាប់តាក់តែងហើយរាំ ក្នុងកាលអ្នកតន្ត្រីប្រគំត្រង់ផ្លូវធំ ផ្ដើមតាំងនូវការអស់ទៅសូន្យទៅថា វាយោធាតុដែលធ្វើឲ្យវិចិត្រនេះ រមែងធ្វើឲ្យករជកាយប្ដូរផ្លាស់ទីកន្លែងទៅ ដោយអំណាចការកម្រើកកាយ សង្ខារទាំងឡាយមិនទៀងហ្ន៎ ដូច្នេះហើយ បានធ្វើការខ្វល់ខ្វាយក្នុងវិបស្សនា សម្រេចអរហត្ត សមដូចគាថាព័ន្ធដែល

លោកពោលក្នុងអបទានថា

ផែនដីកំពុងក្តៅដូចរងើកភ្លើង ផែនដីកំពុងប្រព្រឹត្តទៅ ដូចជាផេះ ព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ ទ្រង់ចង្ក្រមក្នុងទីវាល ។ ខ្ញុំបានបាំងឆត្រស ដើរទៅកាន់ផ្លូវឆ្ងាយ ខ្ញុំឃើញព្រះសម្ពុទ្ធហើយក៏កើតគំនិតក្នុងទីនោះថា ផែនដីផ្សាយចេញនូវថ្ងៃបណ្តើរកូនផែនដីនេះក្តៅដូចជារងើកភ្លើង ខ្យល់ធំខ្លាំងតាំងឡើង បំប៉ើងនូវធូលីទៅកាន់សរីរកាយ ។ ឆត្រនេះសម្រាប់ការពារខ្យល់ និងកម្តៅថ្ងៃ កម្ចាត់បង់នូវត្រជាក់ និងក្តៅ សូមព្រះអង្គទទួលយកនូវឆត្រនេះចុះ ខ្ញុំព្រះអង្គនឹងបានព្រះនិព្វាន ។ កាលនោះ ព្រះជិនស្រីព្រះនាមបទុមុត្តរៈ មានយសច្រើន ទ្រង់អនុគ្រោះប្រកបដោយសេចក្តីករុណា ទ្រង់បានទទួលយក ព្រោះជ្រាបនូវតម្រិះរបស់ខ្ញុំ ។ ខ្ញុំកើតជាព្រះឥន្ទ ជាស្តេចទេវតា សោយរាជ្យក្នុងទេវលោកអស់ ៣០ កប្ប បានជាស្តេចចក្រពត្តិអស់ ៥០០ ដង ។ បានសោយបទេសរាជដ៏ធំទូលាយ រាប់ជាតិមិនអស់ ខ្ញុំបានទទួលផលនៃកម្មរបស់ខ្លួន ដែលខ្លួនធ្វើល្អហើយក្នុងកាលមុន ។ នេះជាតិជាទីបំផុតរបស់ខ្ញុំ ភពខាងក្រោយកំពុងប្រព្រឹត្តទៅ ថ្ងៃនេះ ឆត្រស គេតែងបាំងឲ្យខ្ញុំសព្វៗ កាល ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយឆត្រក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយឆត្រ ។ កិលេសទាំង-

ឡាយ ខ្ញុំដុតបំផ្លាញ ហើយ ។បេ។ ទាំងសាសនារបស់ ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

កាលព្រះថេរៈសម្រេចអរហត្តហើយ បានព្យាករអរហត្តផល ដោយប្រារព្ធបដិបទារបស់ខ្លួនជាប្រធាន ៤ គាថាថា

ស្ត្រីរបាំម្នាក់ មានខ្លួនស្អិតស្អាងហើយ មានសំពត់ស្លៀកល្អ ទ្រទ្រង់ផ្កាកម្រង ប្រោះព្រំដោយខ្លឹមចន្ទន៍ រាំក្នុងតូរ្យតន្ត្រី ត្រង់កណ្តាលផ្លូវធំ ។ អាត្មាអញកំពុងដើរចូលទៅ ( កាន់ក្រុង ) ដើម្បីបិណ្ឌបាត ហើយក្រឡេកមើលទៅឃើញស្ត្រីរបាំនោះ ដែលមានខ្លួនស្អិតស្អាងហើយ មានសំពត់ស្លៀកល្អ ហាក់ដូចជាអន្ទាក់នៃមច្ចុ ដែលមច្ចុដាំឡើងហើយ ។ លំដាប់នោះ ការធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា ក៏កើតឡើងដល់អាត្មាអញ ទោសក៏កើតឡើងប្រាកដដល់អាត្មាអញ និព្វិទាញាណ ក៏តាំងនៅព្រម ។ ចិត្តរបស់អាត្មាអញ ក៏រួចស្រឡះ ( ចាកកិលេស ) ព្រោះវិបស្សនាញាណនោះ អ្នកចូរមើលនូវភាពនៃធម៌ ជាធម៌ល្អ វិជ្ជា ៣ អាត្មាអញ បានដល់ដោយលំដាប់ហើយ សាសនានៃព្រះពុទ្ធ អាត្មាអញ បានធ្វើហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អលង្កតា** សេចក្តីថា មានខ្លួនប្រដាប់ដោយអាភរណៈ មានកងដៃជាដើម ។ បទថា **សុវសនា** បានដល់ សំពត់

---

១- ក្នុងអបទានជា ឯកច្ឆត្តិយត្ថេរ ។

ស្បៀកដែលល្អ គឺស្បៀកសំពត់ដ៏ស្អាត ។ បទថា **មាលិនី** បានដល់ ទ្រទ្រង់នូវផ្កា គឺមានកម្រងផ្កាប្រដាប់ហើយ ។ បទថា **ចន្ទនុស្សទា** បានដល់ មានរាងកាយលាបដោយលម្អិតខ្លឹមចន្ទន៍ ។ បទថា **មជ្ឈេ មហាបថេ នារី តុរិយេ នច្ចតិ នដ្ដកី** សេចក្តីថា ស្រីអ្នករបាំ គឺស្រីអ្នករាំម្នាក់ ក្នុងទីតាមដែលពោលហើយ រាំក្នុងវង់តន្ត្រីដែលមានអង្គ ៥ ត្រង់ផ្លូវ ក្នុងព្រះនគរ គឺធ្វើនូវការរាំតាមសំណូមពរ ។ បទថា **បិណ្ឌិកាយ** បានដល់ ដើម្បីភិក្ខា ។ បទថា **បវិដ្ឋោហំ** បានដល់ ខ្ញុំចូលទៅកាន់ព្រះនគរ ។ បទថា **គច្ឆន្តោ នំ ឧទិក្ខិសំ** សេចក្តីថា កាលដើរទៅលើផ្លូវក្នុងនគរ សម្លឹងមើលផ្លូវ ដើម្បីការពារអន្តរាយ បានឃើញស្រីរបាំនោះ ។ សួរថា ដូចអ្វី ឆ្លើយថា ហាក់ដូចជាអន្ទាក់នៃមច្ចុ ដែលមច្ចុដំឡើងហើយ អធិប្បាយថា អារម្មណ៍ មានរូបជាដើម ដែលជាអន្ទាក់នៃមច្ចុ គឺនៃមច្ចុរាជដែលដំឡើង គឺដាក់ក្នុងលោករមែងនាំមកនូវសេចក្តីវិនាសដល់សត្វទាំងឡាយ ដោយចំណែកមួយ យ៉ាងណា ស្រីអ្នករបាំនោះក៏ដូច្នោះ រមែងនាំមកនូវសេចក្តីវិនាសដោយចំណែកមួយ ដល់អន្ធបុថុជ្ជនដែលតាំងនៅក្នុងឋានៈដែលខ្វះការពិចារណា ព្រោះហេតុនោះ ទើបលោកពោលថា ហាក់ដូចជាអន្ទាក់នៃមច្ចុ ។

បទថា **តតោ** បានដល់ ព្រោះហាក់ដូចជាអន្ទាក់នៃមារនោះ ។ បទថា **មេ** ស្មើគ្នានឹង **មយ្ហំ** ប្រែថា ដល់ខ្ញុំ ។ បទថា **មនសិកាកោ យោនិសោ ឧទបជ្ជថ** សេចក្តីថា ធ្វើទុកក្នុងចិត្តដោយឧបាយកើតឡើងហើយ យ៉ាងនេះថា រាងខ្លួននេះ ដែលចងដោយសរសៃ បូកលាបដោយសាច់ បិទបាំងដោយ

ស្បែក មិនស្អាត មានក្លិនស្អុយ និងគួរខ្ពើម មិនទៀង ត្រូវអស់ និងត្រូវគក់ប្របាច់ មានការទ្រុឌទ្រោម និងបែកធ្លាយជាធម្មតា ទើបសម្តែងអាការដែលប្លែកបែបនេះ ។

បទថា **អាទីនវោ បាតុរហុ** សេចក្តីថា កាលពោលដោយមាតិកា គឺការចូលទៅទ្រទ្រង់នូវសភាវៈរបស់កាយយ៉ាងនេះ កាលខ្ញុំមនសិការដល់ការកើតឡើង និងការវិនាសទៅ និងការបែកធ្លាយ មួយអន្លើដោយ កិច្ច ( តាមសេចក្តីពិត ) នៃកាយនោះ និងនៃចិត្ត និងចេតសិកដែលអាស្រ័យកាយនោះ និងកាលចិត្ត និងចេតសិកប្រាកដដោយភាពជាភ័យ ដូចកាលយក្ខនិងអារក្ខទឹកជាដើមប្រាកដឡើង អាទីនវ គឺទោស មានអាការជាច្រើនប្រាកដដល់ខ្ញុំ ព្រោះហេតុនោះ ទីងឃើញអានិសង្សក្នុងព្រះនិព្វាន ដោយជាបដិបក្ខចំពោះអាទីនវនោះ ។

បទថា **និព្វិទា សមតិដ្ឋថ** សេចក្តីថា ការនឿយណាយ រមែងសម្រេចដោយអានុភាពនៃអាទីនវានុបស្សនា ( ការតាមពិចារណាឃើញទោស ) ។ និព្វិទាញាណ ក៏ចុះស៊ប់ក្នុងហទយៈរបស់ខ្ញុំ ។ ចិត្ត ក្នុងការប្រកាន់រូបធម៌ និងនាមធម៌ទាំងនោះ សូម្បីត្រឹមមួយស្របក់ ក៏មិនប្រាកដដោយពិត កើតត្រឹមតែឧបេក្ខា ក្នុងរូបធម៌ នាមធម៌ប៉ុណ្ណោះ ដោយអំណាចភាពជាបុគ្គលប្រាថ្នានឹងរួចផុតជាដើម ។

*បទថា* **តតោ** *សេចក្ដីថា ខាងមុខអំពីវិបស្សនាញាណ ។ បទថា* **ចិត្តំ វិមុច្ចិ មេ** *សេចក្ដីថា ចិត្តរបស់ខ្ញុំបានរួចផុតហើយចាកកិលេសទាំងពួង តាមលំដាប់នៃមគ្គ ដែលប្រព្រឹត្តទៅក្នុងលោកុត្តរភាវនា ។ លោកសម្ដែងហេតុកើតឡើងនៃផលដល់ពាក្យនោះ ។ ព្រោះក្នុងខណៈនៃមគ្គចិត្ត កិលេសទាំងឡាយ ឈ្មោះថា កំពុងរួចផុតក្នុងខណៈនៃផលចិត្ត កិលេសទាំងឡាយ ឈ្មោះថា រួចផុតហើយ ដូច្នេះឯង ។ ពាក្យដ៏សេស មានន័យដូចពោលហើយខាងដើម នោះឯង ៕*

**អដ្ឋកថា ឆាគសមាលត្ថេរគាថា ចប់**

# សុត្តន្តបិដក

## ភគុត្ថេរគាថា

[ ១៨៨ ] ខ្ញុំព្រះអង្គត្រូវមិទ្ធៈគ្របសង្កត់ហើយ ចេញអំពីវិហារ ឡើងកាន់ទីចង្ក្រម ក៏ដួលចុះលើផែនដីក្នុងទីចង្ក្រមនោះឯង ។ ខ្ញុំព្រះអង្គមានចិត្តតម្កល់មាំល្អខាងក្នុង ហើយបោសសម្អាតខ្លួន ឡើងកាន់ទីចង្ក្រម ដើរចង្ក្រមក្នុងទីចង្ក្រមម្តងទៀត ។ លំដាប់នោះ ការធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា ក៏កើតឡើងដល់ខ្ញុំព្រះអង្គ ទោសក៏កើតប្រាកដ និព្វិទាញាណក៏តាំងនៅព្រម ។ ចិត្តរបស់ខ្ញុំព្រះអង្គ ក៏រួចស្រឡះ (ចាកកិលេស ) ព្រោះវិបស្សនាញាណនោះ អ្នកចូរមើលនូវភាពនៃធម៌ ជាធម៌ល្អ វិជ្ជា ៣ ខ្ញុំព្រះអង្គបានដល់ដោយលំដាប់ហើយ សាសនានៃព្រះពុទ្ធ ខ្ញុំព្រះអង្គបានធ្វើហើយ ។

ភគុត្ថេរ

# អដ្ឋកថា

## ភគុត្ថេរគាថា

[ ១៨៨ ] គាថារបស់ព្រះភគុត្ថេរ មានពាក្យផ្ដើមថា **អហំ មិទ្ធេន** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា ក្នុងសាសនាព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កុលបុត្តនេះ កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្ដីហើយ កាលព្រះសាស្ដា បរិនិព្វានហើយ កុលបុត្តនោះ បូជាព្រះធាតុរបស់ព្រះមានព្រះភាគនោះដោយផ្កាទាំងឡាយ ដោយបុញ្ញកម្មនោះ កើតក្នុងទេវតាជាន់និម្មានរតី អន្ទោលទៅមកក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងសក្យត្រកូល មានឈ្មោះថា **ភគុ** ចម្រើនវ័យហើយ ចេញបួស មួយអន្លើដោយព្រះអនុរុទ្ធ និងព្រះកិម្ពិលៈ នៅក្នុងពាលកលោណកគាម ។ ថ្ងៃមួយ ដើម្បីនឹងបន្ទោបង់ថីនមិទ្ធៈដែលគ្របសង្កត់ ទើបចេញអំពីវិហារ ឡើងកាន់ទីចង្ក្រមក៏ដួលចុះ ធ្វើនូវការដួលនោះឲ្យជាកង្វេរ បន្ទោបង់នូវថីនមិទ្ធៈ ចម្រើនវិបស្សនា សម្រេចអរហត្តហើយ សមដូចគាថាព័ន្ធដែលលោកពោលក្នុងអបទានថា

> កាលព្រះមានព្រះភាគ ព្រះនាមបទុមុត្តរៈមានយសធំ ទ្រង់បរិ-
> និព្វានហើយ ខ្ញុំយកផ្កាដាក់ក្នុងប្រអប់ ទៅបូជានូវព្រះសរីរៈព្រះ
> អង្គ ។ ព្រោះញុំាងចិត្តឲ្យជ្រះថ្លាក្នុងព្រះសរីរៈនោះ ខ្ញុំក៏បានទៅ
> កើតក្នុងទេវលោក ឈ្មោះនិម្មានរតី លុះខ្ញុំទៅកើតក្នុងទេវលោក
> ហើយ រឭកឃើញនូវបុញ្ញកម្មនោះ ។ ភ្លៀងផ្កាបន្ទរចុះមកអំពី
> អាកាសសម្រាប់ខ្ញុំសព្វៗ កាល ខ្ញុំកើតក្នុងពួកមនុស្សបានជាស្ដេច

មានយសច្រើន ។ ភ្លៀងផ្កាបន្ទុរចុះមកក្នុងទីនោះសព្វៗ កាល
សម្រាប់ខ្ញុំដែលជាអ្នកឃើញនូវធម៌ទាំងពួងដោយរហ័ស ព្រោះការ
បូជាផ្កាចំពោះព្រះសរីរកាយនៃព្រះពុទ្ធ ។ នេះភពជាទីបំផុតរបស់
ខ្ញុំ ភពខាងក្រោយកំពុងប្រព្រឹត្តទៅ ថ្ងៃនេះភ្លៀងផ្កាបន្ទុរចុះសម្រាប់
ខ្ញុំក្នុងកាលទាំងពួង ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រោះ
ហេតុដែលខ្ញុំបានបូជាផ្កា ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ
នេះជាផលនៃការបូជានូវព្រះសរីរកាយ ។ កិលេសទាំងឡាយ ខ្ញុំ
ដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បាន
ប្រតិបត្តិហើយ ដូច្នេះ[១] ។

១- ក្នុងអបទានជា ជាតិបុប្ផិយត្ថេរ ។

កាលលោកសម្រេចអរហត្តហើយ ឲ្យពេលវេលាកន្លងទៅដោយសេចក្តីសុខដែលកើតអំពីផល និងដោយសេចក្តីសុខក្នុងព្រះនិព្វាន កាលព្រះសាស្តាយាងចូលទៅរក ដើម្បីទ្រង់សរសើរ ការនៅតែម្នាក់ឯង ហើយត្រាស់សួរថា ម្នាលភិក្ខុ អ្នកមិនប្រមាទទេឬ កាលនឹងប្រកាសការនៅដោយមិនប្រមាទរបស់ខ្លួន ទើបបានភាសិត ៤ គាថាថា

ខ្ញុំព្រះអង្គត្រូវមិទ្ធៈគ្របសង្កត់ហើយ ចេញអំពីវិហារ ឡើងកាន់ទីចង្ក្រម ក៏ដួលចុះលើផែនដីក្នុងទីចង្ក្រមនោះឯង ។ ខ្ញុំព្រះអង្គមានចិត្តតម្កល់មាំល្អខាងក្នុង ហើយបោសសម្អាតខ្លួន ឡើងកាន់ទីចង្ក្រម ដើរចង្ក្រម ក្នុងទីចង្ក្រមម្តងទៀត ។ លំដាប់នោះ ការធ្វើ

ទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា ក៏កើតឡើងដល់ខ្ញុំព្រះអង្គ ទោស ក៏កើតប្រាកដ និព្វិទាញាណ ក៏តាំងនៅព្រម ។ ចិត្តរបស់ខ្ញុំព្រះអង្គ ក៏រួចស្រឡះ ( ចាកកិលេស ) ព្រោះវិបស្សនាញាណនោះ អ្នកចូរមើលនូវភាពនៃធម៌ ជាធម៌ល្អ វិជ្ជា ៣ ខ្ញុំព្រះអង្គបានដល់ ដោយលំដាប់ហើយ សាសនានៃព្រះពុទ្ធ ខ្ញុំព្រះអង្គបានធ្វើហើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **មិច្ឆេន បក្កោតា** សេចក្ដីថា ត្រូវមិទ្ធៈ ដែលជាសភាវៈឥតអំណាច និងជាសភាវៈរួញរា ពោល គឺការខ្ជិលច្រអូស នៃកាយគ្របសង្កត់ ។

បទថា **វិហារា** បានដល់ ចាកសេនាសនៈ ។

បទថា **ឧបនិក្ខមឹ** បានដល់ ចេញទៅដើម្បីដើរចង្ក្រម ។

បទថា **តត្ថេវ បបតឹ ឆមា** សេចក្ដីថា ដួលចុះត្រង់ផែនដី ព្រោះត្រូវ ងងុយគ្របសង្កត់ត្រង់ក្នាក់ដែចង្ក្រមនោះឯង ។

បទថា **គត្តានិ បរិមជ្ជិត្វា** សេចក្ដីថា ជោសអវយវៈក្នុងកាយ របស់ខ្លួន ដែលប្រឡាក់ធូលី ព្រោះដួលចុះត្រង់ផែនដី ។

បទថា **បុនចារុយ្ហ ចង្កមំ** សេចក្តីថា មិនធ្វើមុខក្រញូវថា ឥឡូវនេះ អញជួលហើយ ឡើងកាន់ទីចង្រ្កមម្តងទៀត ។

បទថា **អជ្ឈត្តំ សុសមាហិតោ** ប្រកបសេចក្តីថា ខ្ញុំមានចិត្តតាំងមាំ ហើយដោយល្អ គឺជាអ្នកមានចិត្ត មានអារម្មណ៍តែមួយ ក្នុងកម្មដ្ឋាន ដែលជាអារម្មណ៍ខាងក្នុង ដោយការសង្កត់នីវរណៈដើរចង្រ្កម ។ ពាក្យ ដ៏សេស មានន័យដូចពោលហើយនោះឯង ។ គាថានេះឯង ជាការ ព្យាករណ៍ អរហត្តផលរបស់ព្រះថេរៈ ។៚

**អដ្ឋកថា ភគុត្ថេរគាថា ចប់**

# សុត្តន្តបិដក

## សភិយត្ថេរគាថា

[ ១៨៩ ] បរជនទាំងឡាយ រមែងមិនដឹងថា យើងទាំងឡាយនឹងវិនាស ក្នុងកណ្តាលនៃពួកនេះ ដូច្នេះឡើយ ចំណែកឯជនទាំងឡាយណាជាបណ្ឌិតក្នុងពួកនោះ រមែងដឹងច្បាស់ ឯការឈ្លោះប្រកែក តែងស្ងប់រម្ងាប់អំពីសម្នាក់នៃជនទាំងឡាយជាបណ្ឌិតនោះ ។ កាលណាបើជនទាំងឡាយមិនដឹង ( នូវឧបាយនៃការស្ងប់រម្ងាប់នៃវិវាទ ) រមែងប្រព្រឹត្តទៅ ហាក់ដូចជាមិនស្លាប់ ( កាលនោះវិវាទក៏មិនស្ងប់រម្ងាប់ឡើយ ) ចំណែកជនទាំងឡាយណាដឹងច្បាស់ធម៌ ( ជនទាំងឡាយនោះ ) កាលបើពួកសត្វ មានសេចក្តីក្តៅក្រហាយ ខ្លួនជាអ្នកមិនមានសេចក្តីក្តៅក្រហាយឡើយ ។ កម្មណាមួយធូរថយក្តី វត្តណាមួយសៅហ្មងក្តី ព្រហ្មចរិយៈណាមួយ ដែលបុគ្គលរឭកដោយសេចក្តីរង្កៀសក្តី កម្ម ៣ យ៉ាងនោះ ជារបស់មិនមានផលច្រើនឡើយ ។ បុគ្គលណាមិនមានសេចក្តីគោរព ក្នុងព្រហ្មចារីបុគ្គលទាំងឡាយ ( បុគ្គលនោះ ) រមែងជាអ្នកឆ្ងាយចាកព្រះសទ្ធម្ម ដូចជាមេឃឆ្ងាយអំពីផែនដី ។

សភិយត្ថេរ

# អដ្ឋកថា

## សភិយត្ថេរគាថា

[ ១៨៩ ] គាថារបស់ព្រះសភិយត្ថេរ មានពាក្យផ្ដើមថា **បរេ ច** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងសាសនារបស់ព្រះពុទ្ធព្រះនាមកកុសន្ធៈ កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្ដីហើយ ។ ថ្ងៃមួយ ឃើញព្រះសាស្ដាយាងទៅដើម្បីគង់នៅជាសុខក្នុងវេលាថ្ងៃ មានចិត្តជ្រះថ្លា បានថ្វាយស្បែកជើងដល់ព្រះសាស្ដា ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ កាលព្រះសាស្ដាព្រះនាមកស្សបៈបរិនិព្វានហើយ កាលសុវណ្ណចេតិយប្រតិស្ឋានហើយ មួយអន្លើដោយកុលបុត្ត ៦ នាក់ មានខ្លួនជាគម្រប់ ៧ បួសក្នុងសាសនា រៀនកម្មដ្ឋានក្នុងព្រៃ កាលមិនអាចឲ្យគុណវិសេសកើតឡើងបាន ទើបពោលនឹងកុលបុតដ៏សេសថា ពួកយើងកាលត្រាច់ទៅបិណ្ឌបាត ក៏ឈ្មោះថា នៅមានអាល័យក្នុងជីវិត ព្រោះមានការអាល័យក្នុងជីវិត ពួកយើងមិនអាចសម្រេចលោកុត្តរធម៌បាន ការធ្វើកាលកិរិយាទាំងជាបុថុជ្ជន រមែងជាទុក្ខ ណ្ហើយចុះ ពួកយើងនឹងចងជណ្ដើរឡើងកាន់ភ្នំ មិនអាល័យក្នុងកាយ និងជីវិត ធ្វើសមណធម៌ ។ ភិក្ខុទាំងនោះ បានធ្វើយ៉ាងនោះ ។

លំដាប់នោះ ព្រះមហាថេរៈបានអភិញ្ញា ៦ ក្នុងថ្ងៃនោះឯង ព្រោះភាព

ដែលខ្ជួនដល់ព្រមដោយធម៌ដែលជាឧបនិស្ស័យ នាំបិណ្ឌបាតមកអំពីឧត្តរកុរុ-ទ្វីប ចូលទៅឲ្យភិក្ខុទាំងនោះ ភិក្ខុក្រៅអំពីនេះពោលថា បពិត្រលោកម្ចាស់ លោកម្ចាស់ធ្វើកិច្ចស្រេចហើយ កិច្ចត្រឹមតែចរចាប្រាស្រ័យជាមួយលោកម្ចាស់ ជាការយឺតយូរ ។ ពួកយើងធ្វើចំពោះសមណធម៌ប៉ុណ្ណោះ សូមលោកម្ចាស់ប្រកបរឿយៗ នូវសុខវិហារធម៌ ក្នុងធម៌ដែលលោកម្ចាស់ឃើញហើយចុះ ដូច្នេះហើយ បានឃាត់នូវបិណ្ឌបាត ។ ព្រះថេរៈមិនអាចឲ្យភិក្ខុទាំងនោះទទួលបាន ក៏និមន្តទៅហើយ ។

លំដាប់នោះ លុះកន្លងទៅ ២-៣ បណ្ដាភិក្ខុទាំងនោះ ភិក្ខុមួយរូប ធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល មានអភិញ្ញាជាគ្រឿងចោមរោម បានពោលយ៉ាងនោះដូចគ្នា ត្រូវភិក្ខុទាំងនោះហាមហើយ ក៏និមន្តទៅ ។

បណ្ដាភិក្ខុទាំងនោះ ភិក្ខុជាខីណាស្រព បរិនិព្វានហើយ ។ ភិក្ខុដែលជាអនាគាមី កើតក្នុងជាន់សុទ្ធាវាស ភិក្ខុក្រៅអំពីនោះ ធ្វើកាលកិរិយាទាំងជាបុថុជ្ជននោះឯង សោយទិព្វសម្បត្តិ ដោយអនុលោម និងបដិលោម ក្នុងកាមាវចរសួគ៌ ៦ ជាន់ ។ ក្នុងសាសនានៃព្រះមានព្រះភាគរបស់យើង ចុតិអំពីទេវលោក មួយរូបបដិសន្ធិក្នុងមល្លរាជត្រកូល មួយរូបបដិសន្ធិក្នុងគន្ធាររាជត្រកូល មួយរូបបដិសន្ធិក្នុងបច្ចន្តប្បទេស មួយរូបបដិសន្ធិក្នុងផ្ទៃរបស់កុលទារិកា មួយរូបកើតក្នុងក្រុងរាជគ្រឹះ ឯសភិយៈ បដិសន្ធិក្នុងផ្ទៃរបស់បរិព្វាជិកាមួយរូប ។

បានឮថា បរិព្វាជិកានោះ ជាបុត្រីរបស់ក្សត្រមួយអង្គ ។ ព្រះរាជ-

*មាតាបិតា បានប្រគល់ធីតានោះឲ្យដល់បរិព្វាជកម្នាក់ ដោយគិតថា ធីតារបស់យើង ចូរបេះលទ្ធិដទៃចុះ ។ លំដាប់នោះ បរិព្វាជកម្នាក់បដិបត្តិខុសជាមួយនាង នាងតាំងគភ៌ជាមួយបរិព្វាជកនោះ បរិព្វាជកឃើញនាងមានគភ៌បានឲ្យចេញទៅហើយ នាងទៅនៅក្នុងទីដទៃ ប្រសូតបុត្តក្នុងសភា ( សាលាសម្នាក់ ) ក្នុងរវាងផ្លូវ ព្រោះហេតុនោះ ទើបកុលបុត្តនោះបានឈ្មោះថា* **សភិយ:** *តាមនោះឯង ។*

*កុលបុត្តនោះចម្រើនវ័យហើយ បួសជាបរិព្វាជក រៀនសាស្ត្រផ្សេងៗជាមហាវាទី ត្រាច់ខ្វល់ខ្វាយក្នុងវាទ: មិនឃើញបុគ្គលដទៃស្មើខ្លួន ទើបសាងអាស្រមក្បែរទ្វារនគរ ឲ្យខត្តិយកុមារជាដើមសិក្សាសិល្ប: នាំយកបញ្ហា ២០ ដែលមាតារបស់ខ្លួនស្អប់ខ្ពើមភាពជាស្រី ញុំាងឈានឲ្យកើតឡើងហើយកើតក្នុងព្រហ្មលោក ចងគាថានោះឲ្យ សួរសមណព្រាហ្មណ៍នោះៗ ។ ឯសមណព្រាហ្មណ៍ទាំងនោះ មិនអាចព្យាករបញ្ហាទាំងនោះរបស់សភិយ:បានឡើយ តែក្នុងអដ្ឋកថាសភិយសូត្រពោលថា សទ្ធាវាសព្រហ្មបានចងនូវប្រស្នាទាំងនោះឲ្យ ។*

*ក្នុងកាលដែលព្រះមានព្រះភាគ ប្រកាសព្រះធម្មចក្កដ៏ប្រសើរ យាងមកកាន់ក្រុងរាជគ្រឹះដោយលំដាប់ គង់នៅក្នុងវេឡុវនមហាវិហារ សភិយ: បានទៅក្នុងទីនោះ ចូលគាល់ព្រះសាស្តា សួរបញ្ហាទាំងនោះ ។ ព្រះសាស្តាបានព្យាករបញ្ហាទាំងនោះដល់សភិយ: ព្រោះហេតុនោះ រឿងទាំងអស់ គប្បីជ្រាបដោយន័យដែលមកហើយ ក្នុងសភិយសូត្រ ។ ឯសភិយ: កាលព្រះ*

មានព្រះភាគទ្រង់ព្យាករបញ្ហាទាំងនោះហើយ បានទូវសទ្ធា បួសហើយ ផ្តើមបំពេញវិបស្សនា សម្រេចអរហត្ត សមដូចគាថាព័ន្ធដែលលោកពោលក្នុងអបទានថា

ខ្ញុំបានថ្វាយកម្រាលសម្រាប់ជាន់ ដល់ព្រះមុនី ព្រះនាមកកុសន្ធៈ ជាខីណាសវព្រាហ្មណ៍ មានព្រហ្មចរិយធម៌នៅហើយ ដែលស្តេចទៅកាន់ទីជាទីសម្រាកក្នុងវេលាថ្ងៃ ។ ក្នុងកប្បនេះឯង ព្រោះហេតុដែលខ្ញុំបានថ្វាយទាន ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃកម្រាលសម្រាប់ជាន់ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

១- ក្នុងអបទានជា អក្កមនទាយកត្ថេរ ។

ព្រះថេរៈបានជាព្រះអរហន្តហើយ កាលទេវទត្តព្យាយាមបំបែកសង្ឃ កាលឲ្យឱវាទដល់ភិក្ខុទាំងឡាយ ដែលជាបក្ខពួករបស់ទេវទត្ត ទើបសម្តែង ៤ គាថាថា

បរជនទាំងឡាយ រមែងមិនដឹងថា យើងទាំងឡាយនឹងវិនាស ក្នុងកណ្តាលនៃពួកនេះ ដូច្នេះឡើយ ចំណែកឯជនទាំងឡាយណា ជាបណ្ឌិតក្នុងពួកនោះ រមែងដឹងច្បាស់ ឯការឈ្លោះប្រកែក តែងស្ងប់រម្ងាប់អំពីសម្នាក់នៃជនទាំងឡាយជាបណ្ឌិតនោះ ។ កាលណាបើជនទាំងឡាយមិនដឹង ( នូវឧបាយនៃការស្ងប់រម្ងាប់នៃវិវាទ ) រមែង

ប្រព្រឹត្តទៅ ហាក់ដូចជាមិនស្ងាប់ ( កាលនោះ វិវាទក៏មិនស្ងប់រម្ងាប់ឡើយ ) ចំណែកជនទាំងឡាយណា ដឹងច្បាស់ធម៌ ( ជនទាំងឡាយនោះ ) កាលបើពួកសត្វ មានសេចក្តីក្តៅក្រហាយ ខ្លួនជាអ្នកមិនមានសេចក្តីក្តៅក្រហាយឡើយ ។ កម្មណាមួយ ធូរថយក្តីវត្តណាមួយ សៅហ្មងក្តី ព្រហ្មចរិយៈណាមួយ ដែលបុគ្គលរឭកដោយសេចក្តីរង្កៀសក្តី កម្ម ៣ យ៉ាងនោះ ជារបស់មិនមានផលច្រើនឡើយ ។ បុគ្គលណា មិនមានសេចក្តីគោរពក្នុងព្រហ្មចារីបុគ្គលទាំងឡាយ ( បុគ្គលនោះ ) រមែងជាអ្នកឆ្ងាយចាកព្រះសទ្ធម្ម ដូចជាមេឃឆ្ងាយអំពីផែនដី ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បរេ** សេចក្តីថា ពួកជនដទៃ វៀរចាកបណ្ឌិតនោះ ដែលជាអ្នកខ្វល់ខ្វាយក្នុងការឈ្លោះ ដោយអំណាចសម្តែងវត្ថុដែលធ្វើនូវការបំបែកមានជាដើមថា សម្តែងអធម៌ថាជាធម៌ សម្តែងធម៌ថាជាអធម៌ ឈ្មោះថា ជនពួកដទៃ ។ ជនទាំងនោះ ញ៉ាំងវិវាទក្នុងកណ្តាលសង្ឃនោះ រមែងមិនដឹងថា ពួកយើងលំបាក គឺវិនាសអន្តរធាន បានដល់ទៅកាន់សម្នាក់របស់មច្ចុរៀយៗ ។ បទថា **យេ ច តត្ថ វិជានន្តិ** សេចក្តីថា ក្នុងទីប្រជុំនោះ បណ្ឌិតរមែងដឹងថា ពួកយើងទៅកាន់ទីជិតមច្ចុរាជ ។

បទថា **តតោ សម្មន្តិ មេធគា** សេចក្តីថា ជនទាំងនោះ កាលដឹងយ៉ាងនេះ ញ៉ាំងយោនិសោមនសិការឲ្យកើត រមែងបដិបត្តិដើម្បីរម្ងាប់នូវជម្លោះ គឺការឈ្លោះ ។ បន្ទាប់អំពីនោះ ជម្លោះទាំងនោះរបស់ជនទាំងនោះ

តែងស្ងប់ ដោយកិច្ចបដិបត្តិរបស់ជនទាំងនោះ ។

ម្យ៉ាងទៀត ក្នុងបទថា **បរេ ច** គប្បីជ្រាបពាក្យអធិប្បាយដូច្នេះថា ជនពួកណា ឈ្មោះថា **បរេ** ព្រោះជាអ្នកនៅខាងក្រៅសាសនា ដោយមិនព្រមទទួលឱវាទានុសាសនីរបស់ព្រះសាស្តា វិវាទរមែងមិនស្ងប់ ដរាបណាជនទាំងនោះមិនដឹងថា ព្រោះពួកយើងកាន់យកខុស ទើបលំបាក គឺវិនាសនៅក្នុងទីនេះ គឺក្នុងលោកនេះ ព្រោះកាន់យកខុសអំពីពាក្យប្រៀនប្រដៅ តែក្នុងកាលណា ព្រោះការលះបង់នូវការប្រកាន់នោះ ជនទាំងនោះ វិលមកដឹងតាមសេចក្តីពិត ដោយដឹងថា អធម៌ជាអធម៌ ធម៌ជាធម៌ជាដើម ក្នុងកាលជនទាំងនោះខ្វល់ខ្វាយក្នុងវិវាទក្នុងកណ្តាលសង្ឃនោះ ក្នុងកាលនោះ ការប្រឹងប្រែង ពោល គឺការវិវាទរមែងស្ងប់ ព្រោះអាស្រ័យបុរសដែលជាបណ្ឌិតអំពីសម្នាក់នៃជនទាំងនោះ ។

បទថា **យទា** បានដល់ ក្នុងកាលណា ។ បទថា **អវិជានន្តា** សេចក្តីថា កាលមិនដឹងវិធីរម្ងាប់វិវាទ ឬមិនដឹងធម៌ និងអធម៌ តាមសេចក្តីពិត ។

បទថា **ឥរិយន្ត្យមរា វិយ** សេចក្តីថា ជាអ្នករាយមាយ ជាអ្នកលើកតម្កើងខ្លួន ជាអ្នកមានមាយា មានមាត់រឹង មានវាចាចាក់បណ្តោយប្រព្រឹត្តទៅ គឺកំពុងប្រព្រឹត្ត បានដល់ ត្រាច់ទៅ ដូចជនដែលមិនស្លាប់ ឬដូចបុគ្គលដែលឈានកន្លងនូវការចាស់ ការស្លាប់បាន ដូច្នោះ ។ ក្នុងកាលនោះ វិវាទមិនស្ងប់បានឡើយ ។

បទថា **វិជានន្តិ ច យេ ធម្មំ អាតុរេសុ អនាតុរា** សេចក្តីថា ជនពួកណារមែងដឹងតាមសេចក្តីពិត នូវសាសនធម៌របស់ព្រះសាស្តា ជនទាំងនោះ កាលសត្វទាំងឡាយនាំគ្នាក្តៅក្រហាយព្រោះរោគ គឺកិលេស ជាអ្នកមិនក្តៅក្រហាយ ជាអ្នកអស់កិលេស មិនមានទុក្ខ អធិប្បាយថា រំពាទ រមែងស្ងប់ដោយឥតសេសសល់ ដោយអំណាចនៃជនទាំងនោះ ។

បទថា **យំ កិញ្ចិ សិថិលំ កម្មំ** សេចក្តីថា កុសលកម្មឯណាមួយដែលកាន់យកដោយអាការធូរថយ ដោយការធ្វើយឺតយូរ គឺធ្វើដោយធូរថយ ។

បទថា **សង្កិលិដ្ឋំ** បានដល់ ការសមាទានវត្តដែលសៅហ្មង ដោយការត្រាច់ទៅក្នុងទីអគោចរ មានកន្លែងស្រីពេស្យាជាដើម ឬដោយមិច្ឆាជីវៈមានការបោកបញ្ឆោតជាដើម ។

បទថា **សង្កស្សរំ** សេចក្តីថា គប្បីរឭកដោយសេចក្តីរង្កៀស គឺបុគ្គលដទៃគប្បីបានឮកម្ម ដែលមិនសមគួរណាមួយក្នុងវិហារហើយ មិនរង្កៀសថា បុគ្គលនោះធ្វើ ឬមិនមែនហ្ន៎ ឃើញសង្ឃប្រជុំគ្នាដោយអំណាចកិច្ចឯណានីមួយ មានកិច្ច គឺឧបោសថជាដើមហើយ រឭក រង្កៀស សង្ស័យ ដោយសេចក្តីសង្ស័យរបស់ខ្លួនយ៉ាងនេះថា ភិក្ខុទាំងនេះ ដឹងការប្រព្រឹត្តរបស់អញពិត មានបំណងនឹងលើកវត្តអញ ទើបប្រជុំគ្នា ។

បទថា **ន តំ ហោតិ** សេចក្តីថា ព្រហ្មចរិយៈ គឺការធ្វើសមណធម៌យ៉ាងនេះ មិនមានផលច្រើនដល់បុគ្គលនោះ ទាំងមិនមានផលច្រើន ដល់បុគ្គលអ្នកឲ្យបច្ច័យដល់បុគ្គលនោះ ព្រោះបច្ច័យនោះ មិនធ្វើឲ្យកើតផល

ច្រើន ព្រោះហេតុនោះ គប្បីជាអ្នកមានការប្រព្រឹត្តដុសខាត់ ។ ឯបុគ្គល ដែលមានការប្រព្រឹត្តដុសខាត់ មិនមានឱកាសទាស់ទែងគ្នាឡើយ ។

បទថា **គារវោ ឆ្លបលក្ខតិ** សេចក្តីថា បុគ្គលណាមិនមានការគោរព គឺមិនមានការធ្វើសេចក្តីគោរពក្នុងសព្រហ្មចារីទាំងឡាយដែលគួរគោរព ដោយ មិនទទួលយកអនុសាសនីដោយគោរព ។

បទថា **អារកា ហោតិ សទ្ធម្មា** សេចក្តីថា បុគ្គលនោះ គឺបែបនោះ រមែងនៅក្នុងទីឆ្ងាយចាកបដិបត្តិសទ្ធម្មខ្ទះ ចាកបដិវេធសទ្ធម្មខ្ទះ ព្រោះគ្រូ ទាំងឡាយ រមែងមិនឲ្យបុគ្គលនោះសិក្សានូវបដិបត្តិសទ្ធម្ម និងបដិវេធសទ្ធម្ម នោះ ។ កាលបុគ្គលនោះមិនសិក្សា មិនយកចិត្តទុកដាក់ មិនបដិបត្តិ កាល មិនបដិបត្តិ តើនឹងចាក់ធ្លុះសច្ចៈអំពីណាកើត ព្រោះហេតុនោះ ទើបលោក ពោលថា រមែងជាអ្នកឆ្ងាយចាកព្រះសទ្ធម្ម ។ សួរថា ដូចអ្វី ឆ្លើយថា ដូច មេឃឆ្ងាយអំពីផែនដីដូច្នោះ អធិប្បាយថា នៅក្នុងទីឆ្ងាយដោយសភាវៈ ដូច មេឃ គឺអាកាស និងផែនដី គឺបឋវីធាតុ ដូច្នោះ គឺមិនមានសភាវៈលាយឡំ គ្នាក្នុងកាលណាឡើយ ។ ដោយហេតុនោះឯង ទើបលោកពោល ( ក្នុង ខុទ្ទកនិកាយ ជាតក ) ថា

អាកាស និងដី ឋិតនៅក្នុងទីឆ្ងាយអំពីគ្នា អ្នកប្រាជ្ញទាំងឡាយ
បានពោលនូវច្រាំងសមុទ្រថាឆ្ងាយ បពិត្រព្រះរាជា អ្នកប្រាជ្ញទាំង
ឡាយ បានពោលនូវធម៌ របស់ពួកសប្បុរស និងពួកអសប្បុរស
ថា ឆ្ងាយជាងនោះទៅទៀត ដូច្នេះ ។៙

# សុត្តន្តបិដក

## ឆក្កនិបាតគាថា

[ ១៩០ ] ថ្វីយ ! នៃនាង ជាស្រីពេញ ( ដោយរបស់មិនស្អាត ) មាន ក្លិនស្អុយ ជាពួកនៃមារ មានកាយទទឹក ( ដោយកិលេស ) រន្ធទាំង ៩ ក្នុងកាយរបស់នាង តែងហូរហៀរសព្វៗ កាល ។ នាងកុំសម្គាល់រឿងចាស់ កុំញ៉ាំងព្រះតថាគតទាំងឡាយ ឲ្យត្រេកអរឡើយ សូម្បីក្នុងឋានសួគ៌ ម្ដេច ព្រះតថាគតទាំងឡាយនោះ ក៏មិនត្រេកអរទៅហើយ នឹងបាច់និយាយទៅថ្វី ក្នុងឋានមនុស្ស ។ ចំណែកបុគ្គលទាំងឡាយណា ជាមនុស្សល្ងង់ខ្លៅ ឥត ប្រាជ្ញា មានគំនិតអាក្រក់ ដែលមោហៈបិទបាំងហើយ ពួកបុគ្គលប្រាកដដូច្នោះ ទើបត្រេកអរក្នុងអន្ទាក់ ដែលមារដំឡើងហើយនោះ ។ រាគៈ ទោសៈ និង អវិជ្ជា ជនទាំងឡាយណា លះបង់បានហើយ ជនទាំងឡាយនោះ ឈ្មោះថា មានខ្សែនៃតណ្ហាកាត់ដាច់ហើយ ឈ្មោះថា មិនមានចំណង រមែងមិន ត្រេកអរក្នុងអន្ទាក់នៃមារនោះឡើយ ។

នន្ទកត្ថេរ

# អដ្ឋកថា

## ឆន្នកត្ថេរគាថា

[ ១៩០ ] គាថារបស់ព្រះឆន្នកត្ថេរ មានពាក្យផ្ដើមថា **ធិរត្ថុ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា ក្នុងសាសនាព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ ព្រះថេរៈនេះជាសេដ្ឋី មានសម្បត្តិច្រើន ក្នុងហង្សវតីនគរ កំពុងស្ដាប់ធម៌ ក្នុងសម្នាក់ព្រះសាស្ដា ឃើញព្រះសាស្ដាស្ថាបនាភិក្ខុមួយរូប ក្នុងតំណែងឯតទគ្គៈ នៃភិក្ខុខាងឲ្យឱវាទដល់ភិក្ខុទាំងឡាយ ក៏ប្រាថ្នាតំណែងនោះ បូជាព្រះមានព្រះភាគដោយសំពត់ មានតម្លៃមួយសែន ហើយបានតាំងសេចក្ដីប្រាថ្នា និងឲ្យការបូជាដោយប្រទីប ក្នុងពោធិព្រឹក្សដល់ព្រះសាស្ដា ។ តាំងអំពីនោះមក កុលបុត្តនោះអន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងសាសនាព្រះមានព្រះភាគ ទ្រង់ព្រះនាមកកុសន្ធៈ កើតជាបក្សីករវិក បន្លឺសំឡេងដ៏ពីរោះធ្វើប្រទក្សិណព្រះសាស្ដា ក្នុងកាលជាខាងក្រោយ កើតជាសត្វក្ងោក មានចិត្តជ្រះថ្លា បន្លឺសំឡេងដ៏ពីរោះ ៣ ដង ត្រង់គុហា ដែលជាលំនៅរបស់ព្រះបច្ចេកពុទ្ធមួយអង្គ ធ្វើបុណ្យក្នុងទីនោះៗ ដោយអាការយ៉ាងនេះ ក្នុងសាសនានៃព្រះមានព្រះភាគរបស់យើងទាំងឡាយ កើតក្នុងផ្ទះមាតុកូល ក្នុងក្រុងសាវត្ថី មានឈ្មោះថា **ឆន្នកៈ** ចម្រើនវ័យហើយ ស្ដាប់ធម៌ក្នុងសម្នាក់ព្រះសាស្ដា មានសទ្ធា បួសហើយ ចម្រើនវិបស្សនា សម្រេចអរហត្ត សមដូចគាថាព័ន្ធដែលលោកពោលក្នុងអបទានថា

ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានអុជគប់ភ្លើង ៣ ( តម្កល់ទុក ) ត្រង់ដើមពោធិព្រឹក្សដ៏ឧត្តម របស់ព្រះពុទ្ធព្រះនាមបទុមុត្តរៈ ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំអុជគប់ភ្លើង ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការឲ្យនូវគប់ភ្លើង ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយដូច្នេះ[១] ។

កាលលោកបានជាព្រះអរហន្តហើយ សម្ងំដោយសេចក្តីសុខ ដែលកើតអំពីវិមុត្តិ ត្រូវព្រះសាស្តាទ្រង់ត្រាស់ឲ្យទូន្មានភិក្ខុទាំងឡាយ ក្នុងឧបោសថ ថ្ងៃមួយ បានឲ្យភិក្ខុនី ៥០០ សម្រេចអរហត្តដោយឱវាទត្រឹមតែម្តងប៉ុណ្ណោះ ដោយហេតុនោះ ទើបព្រះសាស្តាតាំងព្រះថេរៈ ក្នុងតំណែងឯតទគ្គៈជាងភិក្ខុទាំងឡាយ ខាងឲ្យឱវាទដល់ភិក្ខុនី ។ ថ្ងៃមួយ កិរិយាចាស់ឃើញព្រះថេរៈកំពុងត្រាច់បិណ្ឌបាតក្នុងក្រុងសាវត្ថី ទើបសើច ដោយអំណាចនៃកិលេស ។ ព្រះថេរៈឃើញកិរិយានោះរបស់ស្រីនោះ កាលនឹងសម្តែងធម៌ ដោយលើកយកការប្រកាសភាពជារបស់បដិកូលនៃសរីរៈ ទើបពោលគាថាដូច្នេះថា

ថ្មីយ ! នៃនាង ជាស្រីពេញ ( ដោយរបស់មិនស្អាត ) មានក្លិនស្អុយ ជាពួកនៃមារ មានកាយទទឹក ( ដោយកិលេស ) រន្ធ

១- ក្នុងអបទាន ជាតិណ្ហុក្កធារិយត្ថេរ ។

ទាំង ៩ ក្នុងកាយរបស់នាង តែងហូរហៀរសព្វៗ កាល ។ នាង កុំសម្គាល់រឿងចាស់ កុំញុំាងព្រះតថាគតទាំងឡាយ ឲ្យត្រេកអរ ឡើយ សូម្បីក្នុងឋានសួគ៌ ម្ដេចព្រះតថាគតទាំងឡាយនោះ ក៏ មិនត្រេកអរទៅហើយ នឹងបាច់និយាយទៅថ្វី ក្នុងឋានមនុស្ស ។ ចំណែកបុគ្គលទាំងឡាយណា ជាមនុស្សល្ងង់ខ្លៅ ឥតប្រាជ្ញា មានគំនិតអាក្រក់ ដែលមោហៈបិទបាំងហើយ ពួកបុគ្គលប្រាកដ ដូច្នោះ ទើបត្រេកអរក្នុងអន្ទាក់ ដែលមារដំឡើងហើយនោះ ។ រាគៈ ទោសៈ និងអវិជ្ជា ជនទាំងឡាយណា លះបង់បានហើយ ជនទាំងឡាយនោះ ឈ្មោះថា មានខ្សែនៃតណ្ហាកាត់ដាច់ហើយ ឈ្មោះថា មិនមានចំណង រមែងមិនត្រេកអរក្នុងអន្ទាក់នៃមារនោះ ឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ធិ** ជានិបាត ប្រើក្នុងអត្ថថា គួរតិះដៀល រ អក្ខរៈ ក្នុងបទថា **រត្ថុ** គ្រាន់តែធ្វើការភ្ជាប់បទ អធិប្បាយថា រាងកាយជា របស់គួរតិះដៀល ខ្ញុំរង្កៀសរាងកាយនោះ ដែលពេញទៅដោយរបស់គួរខ្ពើម អាការគួរតិះដៀល ចូរជារបស់នាងចុះ ។

បទថា **ប្ចូរេ** ជាដើម ជាពាក្យប្រាប់ឲ្យដឹងថា រាងកាយនោះជារបស់គួរ តិះដៀល ។ បទថា **ប្ចូរេ** បានដល់ ក្នុងសរីរកាយដែលពេញទៅដោយរបស់ គួរខ្ពើមក្រៃលែង គឺសាកសពច្រើនប្រភេទ បានដល់ ដោយវត្ថុដែលមិន ស្អាត មានប្រការផ្សេងៗ ។

បទថា **ទុគ្គន្ធេ** បានដល់ មានសភាវៈមានក្លិនស្អុយ ព្រោះពេញទៅដោយសាកសពនោះឯង ។

បទថា **មារបក្ខេ** សេចក្ដីថា ព្រោះហេតុដែលវត្ថុជាសត្រូវរមែងញ៉ាំងកិលេសមារឲ្យចម្រើន ព្រោះបុថុជ្ជនល្ងង់ខ្លៅ មានការដាក់ចិត្តដោយមិនមែនឧបាយជានិមិត្ត និងរមែងឲ្យឱកាសដល់ទេវបុត្តមារចូលសណ្ឋិត ព្រោះដូច្នោះទើបជាចំណែកនៃមារ ។ ដោយហេតុនោះ ទើបលោកពោលថា **មារបក្ខេ** ដូច្នេះ ។

បទថា **អវស្សុតេ** សេចក្ដីថា ដែលទទឹកទៅដោយការហូរចេញរបស់កិលេស និងដោយការហូរចេញនៃរបស់មិនស្អាតក្នុងទីនោះៗ អស់កាលទាំងពួង ។

ឥឡូវនេះ លោកសម្ដែងដល់ឋានៈ ជាទីហូរចេញនៃរបស់មិនស្អាតនៃស្រីនោះ ដែលលោកពោលថា រន្ធទាំង ៩ ក្នុងកាយរបស់នាង តែងហូរហៀរសព្វៗ កាល ដោយន័យថា ពពឹកភ្នែកហូរចេញអំពីភ្នែកជាដើម ។

ស្រីនោះ កាលដឹងតាមសេចក្ដីពិតនូវកាយដែលមានទ្វារ ៩ ពេញទៅដោយរបស់មិនស្អាត ហូរចេញជានិច្ចដោយអាការយ៉ាងនេះ កុំសម្គាល់ការសើច ការនិយាយលេង ការចំអកចំអន់ ដែលប្រព្រឹត្តទៅក្នុងការមិនដឹងដល់រឿងរ៉ាវចាស់ថា កុំសម្គាល់ដល់រឿងចាស់ គឺនាងកុំគិតថា ឥឡូវនេះព្រះថេរៈនឹងបដិបត្តិយ៉ាងនេះ ។

បទថា **មាសាទេសិ តថាគតេ** សេចក្ដីថា នាងកុំមកលួងលោមដោយ

ការមើលងាយ និងដោយអំណាចកិលេស នូវព្រះអរិយសាវកដែលប្រព្រឹត្តទៅយ៉ាងនោះ ដោយអត្ថថា មានមគ្គផលជាទីមកយ៉ាងនោះ គឺដោយប្រការនោះ ដូចលួងលោមសត្វប្រក្រតីឡើយ ព្រោះលោកទាំងនោះ ក៏ដូចពុទ្ធ-សាវកក្នុងកាលមុន ដោយការដល់ព្រមដោយធម៌ ដែលជាឧបនិស្ស័យ ឬដូចពុទ្ធសាវកទាំងនោះដែលទៅ គឺប្រព្រឹត្តទៅ ដោយកិច្ចបដិបត្តិប្រពៃ ឬដូចលោកអ្នកដែលមកដល់ គឺសម្រេច បានដល់ ឈមចុះនូវលក្ខណៈដែលពិតនៃរូបធម៌នាមធម៌ និងធម៌ដែលពិត គឺអរិយសច្ច ។ នាងពោលហេតុដែលនាងត្រូវលួងលោមឲ្យត្រេកអរមិនបាន ។ បទថា **សក្កោមិ តេ ន រជ្ជន្តិ កិមង្គំ បន មានុសេ** អធិប្បាយថា ពុទ្ធសាវកទាំងនោះ រមែងមិនត្រេកអរក្នុងស្ថានសួគ៌ដែលមានសុខ ដែលព្រះសព្វញ្ញុពុទ្ធមិនអាចពណ៌នាឲ្យអស់បានដោយការប្រាប់ គឺរមែងមិនញុំាងរាគៈឲ្យកើត ព្រោះឃើញទោសក្នុងសង្ខារទាំងឡាយដោយល្អហើយ នឹងពោលទៅថ្វីដល់កាមគុណដែលជារបស់មនុស្សដែលដូចជាគំនរលាមក គឺក្នុងករណីនោះ មិនចាំបាច់ពោលដោយពាក្យថាមិនត្រេកអរ ។

បទថា **យេ ច ខោ** សេចក្តីថា ជនពួកណា ឈ្មោះថា **ពាលា** ព្រោះប្រកបដោយភាពជាពាល ឈ្មោះថា **ទុម្មេធា** ព្រោះមិនមានបញ្ញា ដែលមានឱជៈកើតអំពីធម៌ ឈ្មោះថា **ទុម្មន្តី** ព្រោះគិតតែវត្ថុដែលអាក្រក់ ដោយតាមឃើញនូវវត្ថុដែលមិនស្អាត ថាស្អាត ឈ្មោះថា **មោហាចារុតា** ព្រោះជាអ្នកមានចិត្តត្រូវមោហៈ គឺការមិនដឹងបិទបាំង ដោយប្រការទាំងពួង បុថុជ្ជនល្ងង់

ខ្វៅ ក៏ដូច្នោះ គឺដូចគ្នាយ៉ាងនោះ រមែងត្រេកអរ បានដល់ ត្រេកត្រអាល ជាប់ជំពាក់ ងប់ជ្រប់ តាំងនៅក្នុងកាមគុណទាំងនោះ គឺនៅក្នុងចំណងដែលសន្មតថា ជាស្រីនោះ ដែលមារដំឡើង បានដល់ ក្នុងអន្ទាក់មារ ដែលមារដាក់ ។

បទថា **វិភជិត្វា** សេចក្តីថា ជនទាំងឡាយណា គឺព្រះទីណាស្រេតខ្ទាក់ គឺលះបានជាសមុច្ឆេទនូវរាគៈ ដែលមានសភាវៈដោះបានលំបាក ដូចសំពត់ដែលប្រឡាក់ដោយប្រេង នូវទោសៈដែលមានសភាវៈប្រទូស ដូចសត្រូវបានឱកាស និងនូវអវិជ្ជា ដែលមានសភាវៈមិនដឹង ដោយការខ្ទាក់ដោយអរិយមគ្គ ដោយប្រការទាំងពួង ជនទាំងនេះក៏ដូច្នោះ កាត់តណ្ហាដូចសរសៃអំបោះដែលជាគ្រឿងនាំសត្វទៅកាន់ភពបានហើយ ដោយសស្ត្រាគឺអរហត្តមគ្គ លំដាប់នោះ ឈ្មោះថា មិនមានចំណង ព្រោះមិនមានចំណងក្នុងទីណាមួយ រមែងមិនត្រេកអរក្នុងអន្ទាក់របស់មារតាមដែលពោលហើយនោះ ។ ព្រះថេរៈសម្តែងធម៌ដល់ស្រីនោះហើយ និមន្តទៅ ដោយប្រការដូច្នេះ ៕

## អដ្ឋកថា ឆន្នកត្ថេរគាថា ចប់

# សុត្តន្តបិដក

## ជម្ពុកត្ថេរគាថា

[ ១៩១ ] ខ្ញុំព្រះអង្គទ្រទ្រង់នូវក្អែល បរិភោគកក្ក ១ ខែម្ដង បានដកសក់ និងពុកមាត់អស់ ៥៥ ឆ្នាំ ។ ខ្ញុំបានឈរដោយជើងតែម្ខាង វៀរការអង្គុយស៊ីលាមកក្រៀម មិនត្រេកអរនឹងការនិមន្តចំពោះ ។ ខ្ញុំបានធ្វើបាបកម្មដ៏ច្រើន ដែលជាអំពើនាំទៅកាន់ទុគ្គតិប្រាកដដូច្នេះ ក៏ត្រូវជំនន់ធំ គឺទិដ្ឋិបន្សាត់ទៅហើយ បានដល់នូវព្រះពុទ្ធជាទីពឹង ។ អ្នកចូរមើលនូវការដល់សរណៈ ចូរមើលភាពនៃធម៌ ជាធម៌ល្អ វិជ្ជា ៣ ខ្ញុំបានដល់ដោយលំដាប់ហើយ សាសនានៃព្រះពុទ្ធ ខ្ញុំក៏បានធ្វើហើយ ។

ជម្ពុកត្ថេរ

# អដ្ឋកថា

## ជម្ពុកត្ថេរគាថា

[ ១៩១ ] គាថារបស់ព្រះជម្ពុកត្ថេរ មានពាក្យផ្ដើមថា **បញ្ចបញ្ញាស** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមតិស្សៈ កើតក្នុងផ្ទះមានត្រកូល ដល់នូវ

ភាពជាអ្នកដឹងក្តីហើយ ជឿក្នុងសម្មាសម្ពោធិញ្ញាណរបស់ព្រះសាស្តា ថ្វាយបន្ទំពោធិព្រឹក្សហើយ បូជាដោយការបក់ផ្ចិត ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ លុះដល់សាសនាព្រះមានព្រះភាគព្រះនាមកស្សបៈ កុលបុត្តនេះកើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្តីហើយ បួសក្នុងសាសនា បានជាមេវត្តក្នុងអារាមដែលឧបាសកម្នាក់សាងប្រគេន ឧបាសកនោះឧបដ្ឋាកចៅអាវាសនោះ ។ ថ្ងៃមួយ ព្រះវិណាស្រពមួយអង្គ ដណ្តប់ចីវរចាស់ៗ ចេញអំពីព្រៃ បែរមុខទៅកាន់ស្រុក ដើម្បីកោរសក់ ឧបាសកនោះឃើញព្រះថេរៈហើយ ជ្រះថ្លាក្នុងឥរិយាបថ ឲ្យជាងការកាត់ កោរសក់ និងពុកមាត់ ឲ្យឆាន់ភោជនដ៏ប្រណីត និងចីវរល្អៗ និមន្តដោយពាក្យថា សូមលោកម្ចាស់នៅក្នុងទីនេះឯង ។

ភិក្ខុចៅអាវាសដោយប្រក្រតីជាអ្នកច្រណែន និងមានសេចក្តីកំណាញ់ពោលនឹងព្រះថេរៈវិណាស្រពថា នែភិក្ខុ កាលដែលលោកយកម្រាមដៃដកសក់ បរិភោគលាមក និងមូត្រជាអាហារ មិនស្លៀកសំពត់ ប្រសើរជាងការឲ្យឧបាសកដែលថោកទាបនេះ ឧបដ្ឋាក នៅក្នុងទីមានសភាពបែបនេះ ។ កាលពោលយ៉ាងនេះហើយ រំពេចនោះ ភិក្ខុនោះ ក៏ចូលទៅកាន់វច្ចកុដិយកដៃក្បង់លាមកបរិភោគ និងផឹកនូវទឹកមូត្រ ។ ព្រះថេរៈតាំងនៅដោយទំនងនេះ ដរាបដល់អស់អាយុ ធ្វើកាលកិរិយាហើយ ឆេះក្នុងនរក មានមូត្រនិងលាមកជាអាហារ ដោយសេសសល់ផលកម្មនោះឯង មកកើតជាមនុស្ស

ក៏បានជានិគ្រន្ថ មានលាមកជាអាហារ ៥០០ ជាតិ ។

ក្នុងពុទ្ធុប្បាទនេះ កើតក្នុងកំណើតមនុស្ស ក្នុងត្រកូលអ្នកទុគ៌ត ព្រោះកម្លាំងកម្មនៃការប្រទូស្តព្រះអរិយៈ កាលជនទាំងឡាយឲ្យបៅដោះ ទឹកដោះ ឬ សប្បិ ក៏បោះវត្ថុទាំងនោះចោល ផឹកតែទឹកមូត្រប៉ុណ្ណោះ គេឲ្យបរិភោគបាយ ក៏បោះចោល ហើយទំពាស៊ីតែលាមកប៉ុណ្ណោះ កុលបុត្តនោះ ធំចម្រើនវ័យ ដោយការបរិភោគលាមក និងផឹកទឹកមូត្រដោយអាការយ៉ាងនេះ ចម្រើនវ័យ ហើយក៏បរិភោគតែលាមក និងមូត្រប៉ុណ្ណោះ ។ ពួកមនុស្សកាលមិនអាចហាម នូវការបរិភោគលាមក និងមូត្រនោះបាន ក៏បោះបង់ចោល ។ កុលបុត្តនោះ កាលពួកញាតិបោះបង់ហើយ ក៏បួសជាអចេលក៍ មិនងូតទឹក លាបខ្លួន ដោយល្អងធូលី ដកសក់ និងពុកមាត់ ហាមនូវឥរិយាបថដទៃ ឈរដោយជើងតែម្យ៉ាង មិនត្រេកអរក្នុងការនិមន្ត អធិដ្ឋានវត្ត គឺការអត់អាហារប្រចាំខែ ប្រើចុងស្បូវជួសអាហារដែលបុគ្គលត្រូវការបុណ្យ ឲ្យលិទ្ធដោយចុងអណ្តាត ក្នុងពេលថ្ងៃ មួយខែម្តង ចំណែកក្នុងពេលយប់ ក៏មិនបរិភោគលាមកស្រស់ ដោយគិតថា មានសត្វល្អិត បរិភោគតែលាមកក្រៀមប៉ុណ្ណោះ ។ អាជីវក នោះ ធ្វើយ៉ាងនេះ អស់កាល ៥៥ ឆ្នាំ មហាជនយល់ថា ជាអ្នកមានតបៈ ច្រើន មានការប្រាថ្នាតិចក្រៃលែង ទើបបង្អោនទៅ ទោរទន់ទៅក្នុងកុលបុត្ត នោះ ។

លំដាប់នោះ ព្រះមានព្រះភាគ ទតឃើញធម៌ដែលជាឧបនិស្ស័យនៃ អរហត្ត រុងរឿងខាងក្នុងហទយៈរបស់កុលបុត្រនោះ ដូចប្រទីបដែលឆេះក្នុង

ឆ្នាំង ដូច្នោះហើយ ទ្រង់យាងទៅក្នុងទីនោះ សម្ដែងធម៌ ឲ្យកុលបុត្តនោះ តាំងនៅក្នុងសោតាបត្តិផល ឲ្យឧបសម្បទាជាឯហិភិក្ខុឧបសម្បទា កុលបុត្តនោះ ខ្វល់ខ្វាយក្នុងវិបស្សនា តាំងនៅក្នុងអរហត្ត ។

ក្នុងរឿងនេះមានសេចក្ដីសង្ខេបត្រឹមប៉ុណ្ណេះ ឯសេចក្ដីពិស្ដារ គប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងអដ្ឋកថាធម្មបទថា **មាសេ មាសេ កុសគ្គេន** ឯណោះចុះ ។ កុលបុត្តនោះ តាំងនៅក្នុងអរហត្តហើយ ក្នុងកាលបរិនិព្វានកាលសម្ដែងថា ខ្ញុំបដិបត្តិខុសខាងដើម អាស្រ័យព្រះសម្មាសម្ពុទ្ធ សម្រេចធម៌ដែលសាវកគួរសម្រេច ទើបពោល ៤ គាថាថា

ថ្វីយ ! នៃនាង ជាស្រីពេញ (ដោយរបស់មិនស្អាត ) មានក្លិនស្អុយ ជាពួកនៃមារ មានកាយទទឹក ( ដោយកិលេស ) រន្ធទាំង ៩ ក្នុងកាយរបស់នាង តែងហូរហៀរសព្វៗ កាល ។ នាងកុំសម្គាល់រឿងចាស់ កុំញ៉ាំងព្រះតថាគតទាំងឡាយ ឲ្យត្រេកអរឡើយ សូម្បីក្នុងឋានសួគ៌ ម្ដេចព្រះតថាគតទាំងឡាយនោះ ក៏មិនត្រេកអរទៅហើយ នឹងបាច់និយាយទៅថ្វី ក្នុងឋានមនុស្ស ។ ចំណែកបុគ្គលទាំងឡាយណា ជាមនុស្សល្ងង់ខ្លៅ ឥតប្រាជ្ញា មានគំនិតអាក្រក់ ដែលមោហៈបិទបាំងហើយ ពួកបុគ្គលប្រាកដដូច្នោះ ទើបត្រេកអរក្នុងអន្ទាក់ ដែលមារដំឡើងហើយនោះ ។ រាគៈ ទោសៈ និងអវិជ្ជា ជនទាំងឡាយណា លះបង់បានហើយ ជនទាំងឡាយនោះ ឈ្មោះថា មានខ្សែនៃតណ្ហាកាត់ផាច់ហើយ

ឈ្មោះថា មិនមានចំណង់ រមែងមិនត្រេកអរក្នុងអន្ទាក់នៃមារនោះឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បង្កបញ្ញាសវស្សា រជោជល្លធារយឹ** សេចក្ដីថា មានការទ្រទ្រង់នូវធូលី ពោល គឺលម្អងដែលហុយមកជាប់ត្រង់រាងកាយ និងធូលី ពោល គឺមន្ទិលនៃរាងកាយជាង ៥៥ ឆ្នាំ ដោយហាមការងូតទឹក ព្រោះចូលដល់នូវការបួសជាអចេលក៍ ។

បទថា **ភុញ្ជន្តោ មាសិកំ ភត្តំ** សេចក្ដីថា ទំពាស៊ីលាមកក្នុងរាត្រីធ្វើជាកាន់វត្តអត់អាហារប្រចាំខែ ដើម្បីបញ្ឆោតសត្វលោក បរិភោគភោជនដែលអ្នកត្រូវការបុណ្យឲ្យ ដោយដាក់ត្រង់ចុងអណ្ដាតមួយខែម្ដង ។

បទថា **អលោចយឹ** សេចក្ដីថា ប្រើដៃដកសក់ និងពុកមាត់ ដែលមានឫសផុយ ព្រោះដាក់ផេះដើម្បីការដកនោះ ។

បទថា **ឯកបាទេន អដ្ឋាសឹ អាសនំ បរិវជ្ជយឹ** សេចក្ដីថា វៀរការអង្គុយដោយប្រការទាំងពួង កាលឈរក៏លើកដៃទាំង ២ ឡើង ឈរដោយជើងមួយប៉ុណ្ណោះ ។

បទថា **ឧច្ចេសំ** សេចក្ដីថា អញ្ជើញ អាចារ្យពួកខ្លះពោលថា **ឧទ្ទិស្ស-កតំ** ប្រែថា ធ្វើចំពោះ ក៏មាន ។

បទថា **ន សាទិយឹ** បានដល់ មិនទទួល អធិប្បាយថា បដិសេធ ។

បទថា **ឯតាទិសំ ករិត្វាន ពហុំ ទុគ្គតិគាមិនំ** សេចក្ដីថា បានធ្វើបាបកម្មច្រើន ដែលជាហេតុឲ្យទៅទុគ្គតិ ដែលធ្វើឲ្យកើតវិបាកបែបនោះ គឺ

មានសភាពបែបនោះ ទាំងក្នុងជាតិមុន និងក្នុងជាតិនេះ ។

បទថា **វុយ្ហមានោ មហោឃេន** សេចក្តីថា ត្រូវជំនន់ធំ មានកាមោឃជាដើម ពោលដោយពិសេស បានដល់ ទិដ្ឋោឃៈ ដែលទាញទៅកាន់សមុទ្រ គឺអបាយ ។

បទថា **ពុទ្ធំ សរណមាគមំ** សេចក្តីថា បានអត្តភាពជាមនុស្ស ព្រោះខ្វះបុញ្ញកម្ម ដ្បិតឱកាសនៃបុញ្ញកម្ម បានដោយកម្រ ឥឡូវនេះ បានដល់ ព្រះពុទ្ធ ថាជាសរណៈ ព្រោះកម្លាំងនៃបុណ្យ គឺបានជ្រះថ្លាក្នុងព្រះសាស្តា ដោយការជ្រះថ្លាមិនញាប់ញ័រថា ព្រះមានព្រះភាគត្រាស់ដឹងប្រពៃដោយព្រះអង្គឯង ។

បទថា **សរណាគមនំ បស្ស បស្ស ធម្មសុធម្មតំ** សេចក្តីថា ចូរអ្នកឃើញការដល់សរណគមន៍របស់ខ្ញុំ ដែលជាប្រកពកើត និងចូរឃើញថា ធម៌គឺពាក្យប្រៀនប្រដៅ ជាធម៌ល្អ ដែលធ្វើឲ្យខ្ញុំសូម្បីបដិបត្តិខុសមកហើយ ត្រូវព្រះសាស្តាទាញមកកាន់គុណសម្បត្តិបែបនេះ ដោយឱវាទម្តងប៉ុណ្ណោះ ។

ដោយបទថា **តិស្សោ វិជ្ជា** ជាដើម លោកសម្ដែងដល់សម្បត្តិនោះ ។ ដោយហេតុនោះ ទើបលោកពោលក្នុងអបទានថា

ខ្ញុំបានទៅថ្វាយបង្គំពោធិព្រឹក្ស របស់ព្រះមានព្រះភាគ ព្រះនាមតិស្សៈ រួចហើយ ខ្ញុំកាន់ផ្ចិតបក់នូវសីហាសនៈ ( អាសនៈដ៏ប្រសើរ ) ដែលគេតម្កល់ក្នុងទីនោះ ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបក់នូវសីហាសនៈ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបក់ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។ល។

**អដ្ឋកថាជម្ពុកត្ថេរគាថា ចប់**

---

១- ក្នុងអបទាន ជាសីហាសនពីជិយត្ថេរ ។

# សុត្តន្តបិដក

## សេនកត្ថេរគាថា

[ ១៩២ ] ឱ អាត្មាអញមកល្អហើយ ដើម្បីគយផគ្គុមហោស្រព ជិតកំពង់ឈ្មោះគយា អាត្មាអញបានឃើញព្រះសម្ពុទ្ធ កំពុងតែសម្តែងធម៌ដ៏ឧត្តម ព្រះអង្គមានពន្លឺច្រើន ជាគណាចារ្យ ដល់នូវឋានៈដ៏ប្រសើរ ដឹកនាំសត្វលោក ទ្រង់ឈ្នះមនុស្សលោក ព្រមទាំងទេវលោក ទ្រង់មានការឃើញប្រឹងមិនបាន ជាមហានាគ មានព្យាយាមធំ មានសេចក្តីរុងរឿងធំ មិនមានអាសវៈ មានអាសវៈទាំងពួង អស់រលីងហើយ ជាសាស្តាមិនមានភ័យអំពីណាឡើយ ។ ព្រះមានព្រះភាគអង្គនោះ បានញុំាងអាត្មាអញឈ្មោះសេនកៈ អ្នកមានសេចក្តីសៅហ្មង អស់កាលយូរ ដែលចំណង គឺទិដ្ឋិចងទុកហើយ ឲ្យរួចស្រឡះចាកកិលេសគ្រឿងចាក់ស្រែះទាំងពួងបាន ។

*សេនកត្ថេរ*

# អដ្ឋកថា

## សេនកត្ថេរគាថា

[ ១៩២ ] គាថារបស់ព្រះសេនកត្ថេរ មានពាក្យផ្តើមថា **ស្វាគតំ វត** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្រនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ

ក្នុងសាសនាព្រះមានព្រះភាគព្រះនាមសិខី កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្តីហើយ ថ្ងៃមួយ ឃើញព្រះសាស្តា មានចិត្តជ្រះថ្លា បូជាព្រះមានព្រះភាគដោយសំណុំកន្ទុយក្ងោក ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលព្រាហ្មណ៍ គឺក្នុងផ្ទៃប្អូនស្រីនៃព្រះឧរុវេលកស្សបត្ថេរ មានឈ្មោះថា សេនកៈ ។ កុលបុត្តនោះចម្រើនវ័យហើយ ដល់នូវការសម្រេចក្នុងសិប្បវិជ្ជារបស់ពួកព្រាហ្មណ៍ នៅគ្រប់គ្រងឃរាវាស ។

សម័យនោះ មហាជននាំគ្នាលេងមហោស្រព ក្នុងឧត្តរផគ្គុណនក្ខត្តឫក្សក្នុងខែផល្គុនរាល់ៗ ឆ្នាំ ធ្វើពិធីមុជទឹកត្រង់កំពង់ ក្បែរស្ទឹងគយា ដោយហេតុនោះ ជនទាំងឡាយហៅមហោស្រពនោះថា គយាផគ្គុណី ដូច្នេះ ។

លំដាប់នោះ ព្រះមានព្រះភាគ គង់នៅត្រង់កំពង់គយា ដើម្បីអនុគ្រោះវេនេយ្យសត្វក្នុងថ្ងៃមហោស្រពនោះ ឯមហាជនចេញអំពីទីផ្សេងៗ ទៅកាន់ទីនោះ ដោយបំណងផ្ងូតត្រង់កំពង់ ។ ក្នុងសម័យនោះ សេនកៈទៅកាន់ទីនោះ ដើម្បីផ្ងូតទឹក ឃើញព្រះសាស្តាកំពុងសម្តែងធម៌ ស្តាប់ធម៌ហើយបាននូវសទ្ធា ហើយបួស ប្រកបវិបស្សនា មិនយូរប៉ុន្មាន ក៏សម្រេចអរហត្ត សមដូចគាថាព័ន្ធដែលលោកពោលក្នុងអបទានថា

ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានយកផ្ចិតស្លាបក្ងោក ចូល
ទៅថ្វាយព្រះលោកនាយក ។ ភ្លើងទាំងបីរបស់ខ្ញុំ រលត់ហើយ

ខ្ញុំបាននូវសេចក្ដីសុខដ៏ធំទូលាយ ដោយសារផ្ចិតស្វាបក្ដោកនេះផង ដោយការតម្កល់នូវចេតនានេះផង ។ ឱហ្ន៎ ព្រះពុទ្ធ ឱហ្ន៎ ព្រះធម៌ ឱហ្ន៎ សម្បទារបស់ព្រះសាស្ដានៃយើងទាំងឡាយ ខ្ញុំបាននូវសេចក្ដីសុខដ៏ធំទូលាយ ព្រោះបានថ្វាយផ្ចិតស្វាបក្ដោក ។ ភ្លើងទាំង ៣ របស់ខ្ញុំ រលត់ហើយ ភពទាំងពួង ខ្ញុំដកចោលហើយ អាសវៈទាំងពួង អស់រលីងហើយ ឥឡូវនេះ ភពថ្មីមិនមានទៀតឡើយ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានឲ្យទាន ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផ្ចិតស្វាបក្ដោក ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

១- ក្នុងអបទាន ជាមោរហត្ថិយត្ថេរ ។

កាលសម្រេចអរហត្តហើយ បានពិចារណាកិច្ចបដិបត្តិរបស់ខ្លួន កើតនូវសោមនស្ស បានពោល ៤ គាថា ដោយអំណាចឧទានថា

ឱ អាត្មាអញមកល្អហើយ ដើម្បីគយផគ្គុមហោស្រព ជិតកំពង់ឈ្មោះគយា អាត្មាអញបានឃើញព្រះសម្ពុទ្ធ កំពុងតែសម្ដែងធម៌ដ៏ឧត្ដម ព្រះអង្គមានពន្លឺច្រើន ជាគណាចារ្យ ដល់នូវឋានៈដ៏ប្រសើរ ដឹកនាំសត្វលោក ទ្រង់ឈ្នះមនុស្សលោក ព្រមទាំងទេវលោក ទ្រង់មានការឃើញ ប្រឹងមិនបាន ជាមហានាគ មានព្យាយាមធំ មានសេចក្ដីរុងរឿងធំ មិនមានអាសវៈ មានអាសវៈ

ទាំងពួង អស់រលីងហើយ ជាសាស្តា មិនមានភ័យអំពីណា ឡើយ ។ ព្រះមានព្រះភាគអង្គនោះ បានញ៉ាំងអាត្មាអញឈ្មោះ សេនកៈ អ្នកមានសេចក្តីសៅហ្មង អស់កាលយូរ ដែលចំណង គឺទិដ្ឋិចងទុកហើយ ឲ្យរួចស្រឡះ ចាកកិលេសគ្រឿងចាក់ស្រេះ ទាំងពួងបាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ស្វាគតំ វត មេ អាសិ** សេចក្តីថា ការ ដែលខ្ញុំបានមកក្នុងទីជិតកំពង់ ក្នុងផល្គុនមាសនេះ ជាការមកល្អហើយហ្ន៎ ម្យ៉ាងទៀត ការមករបស់ខ្ញុំ ជាការល្អហ្ន៎ ។

បទថា **គយាយំ** បានដល់ ទីជិតកំពង់គយា ។

បទថា **គយផគ្គុយា** សេចក្តីថា ក្នុងឧត្តរផគ្គុណានក្ខត្តឫក្ស គឺខាងចុង ខែផល្គុន ដែលបានឈ្មោះថា **គយផគ្គុ**។

បទថា **យំ** ជាដើម ជាបទសម្តែងហេតុនៃការមកល្អ ។ បណ្តាបទ ទាំងនោះ បទថា **យំ** ស្មើគ្នានឹង **យស្មា** ប្រែថា ព្រោះហេតុណា ។

បទថា **អទ្ទសាសឹ** ប្រែថា បានឃើញហើយ ។

បទថា **សម្ពុទ្ធំ** សេចក្តីថា ឈ្មោះថា **សម្ពុទ្ធ** ព្រោះត្រាស់ដឹងធម៌ទាំង ពួងដោយប្រពៃ និងដោយព្រះអង្គឯង ។

បទថា **ទេសេន្តំ ធម្មមុត្តមំ** សេចក្តីថា ត្រាស់ដឹងនូវធម៌ដ៏ឧត្តម គឺ ប្រសើរជាងធម៌ទាំងពួង បានដល់ ធម៌ជាគ្រឿងនាំសត្វចេញចាកទុក្ខដោយ ពិត គួរដល់អធ្យាស្រ័យរបស់វេនេយ្យសត្វ ។

*បទថា* **មហប្បត្តំ** *បានដល់ ប្រកបដោយរស្មីនៃសរីរៈ និងដោយរស្មីនៃញាណដ៏ធំ ។*

*បទថា* **គណាចរិយំ** *សេចក្តីថា ឈ្មោះថា* **គណាចរិយ** *ព្រោះជាគណៈ មានភិក្ខុបរិស័ទជាដើមសិក្សាអាចារ ដោយការទូន្មានដ៏ឧត្តម ។ ឈ្មោះថា* **អគ្គប្បត្តំ** *ព្រោះសម្រេចនូវគុណ មានសីលជាដើម ដែលជាគុណដ៏ឧត្តម។ ឈ្មោះថា* **វិនាយកំ** *ព្រោះទូន្មានទេវតា និងមនុស្សជាដើម ដោយការទូន្មានដ៏ឧត្តម និងព្រោះព្រះអង្គមិនមានអ្នកទូន្មាន ឈ្មោះថា* **សទេវកស្ស-លោកស្ស ជិនំ** *ព្រោះជាអ្នកឈ្នះដ៏កំពូលក្នុងលោក ព្រមទាំងទេវលោក ជាបុគ្គលដែលបុគ្គលណាម្នាក់ គ្របសង្កត់មិនបាន ព្រោះទ្រង់ជាអ្នកនាំសត្វលោកទាំងអស់ និងព្រោះទ្រង់ជាអ្នកឈ្នះមារទាំង ៥ បាន ឈ្មោះថា* **អតុលទស្សនំ** *ព្រោះមានរូបកាយប្រដាប់ដោយមហាបុរិសលក្ខណៈ ៣២ និងអនុព្យញ្ជនៈ ៨០ ជាដើម និងព្រោះមានធម្មកាយដែលប្រដាប់ដោយគុណ មានទសពលញ្ញាណ និងចតុវេសារជ្ជញ្ញាណជាដើម និងមានញាណ-ទស្សនៈ ដែលមនុស្សលោក ព្រមទាំងទេវលោកទាំងអស់ គប្បីប្រមាណមិនបាន ព្រោះមានទស្សនៈមិនមានបុគ្គលស្មើ ។*

*ឈ្មោះថា* **មហានាគំ** *ព្រោះដូចដំរីធំដ៏ប្រសើរ ព្រោះដល់ព្រមដោយគតិ កម្លាំង និងសេចក្តីព្យាយាមជាដើម ព្រោះមានអានុភាពច្រើន ក្នុងបណ្តាបុគ្គលប្រសើរ គឺព្រះខីណាស្រព ។ ឈ្មោះថា* **មហាវីរំ** *ព្រោះមានការ*

ក្លាហាន ច្រើនដោយញាំញីមារ និងសេនាបាន ។

បទថា **មហាជុតឹ** សេចក្ដីថា ជាអ្នកមានសេចក្ដីរុងរឿងច្រើន គឺជាអ្នកមានតេជះច្រើន ។ ឈ្មោះថា **អនាសវំ** ព្រោះទ្រង់មិនមានអាសវៈ ទាំង ៤ ។ ឈ្មោះថា **សព្វាសវបរិក្ខីណំ** ព្រោះអាសវៈទាំងពួង មួយអន្លើដោយវាសនារបស់ព្រះអង្គអស់ហើយ ។ ដើម្បីសម្ដែងថា សាវកពុទ្ធ និងព្រះបច្ចេកពុទ្ធ ជាអ្នកអស់អាសវៈតែម្យ៉ាង ( តែវាសនានៅមាន ) ចំណែកសព្វញ្ញុពុទ្ធទាំងឡាយ ធ្វើអាសវៈ មួយអន្លើដោយវាសនាឲ្យអស់ទៅ ព្រះថេរៈកាលពោលថា **អនាសវំ** ហើយ ទើបពោលទៀតថា **សព្វាសវ-បរិក្ខីណំ** ។ ដោយហេតុនោះ ទើបព្រះថេរៈពោលថា ឈ្មោះថា **សព្វាសវ-បរិក្ខីណំ** ព្រោះទ្រង់អស់អាសវៈទាំងពួង មួយអន្លើដោយវាសនាហើយ ។

ឈ្មោះថា **សត្ថារំ** ព្រោះទ្រង់ប្រៀនប្រដៅវេនេយ្យសត្វតាមសមគួរដោយប្រយោជន៍ក្នុងបច្ចុប្បន្ន និងប្រយោជន៍ក្នុងសម្បរាយកព និងបរមត្ថ-ប្រយោជន៍ ឈ្មោះថា **អកុតោភយំ** ព្រោះមិនមានភ័យអំពីទីណា ព្រោះជាអ្នកក្លៀវក្លាដោយវេសារជ្ជញាណ ៤ មានពាក្យអធិប្បាយថា ព្រោះខ្ញុំបាន

ឃើញព្រះសម្មាសម្ពុទ្ធ មានសភាពបែបនោះ ដូច្នោះ ទើបអាត្មាអញ ឈ្មោះថា មកល្អហើយ ។

ឥឡូវនេះ ដើម្បីនឹងសម្តែងគុណដែលខ្លួនបានហើយ ព្រោះបានឃើញ ព្រះសាស្តា ទើបពោលគាថាទី ៤ ។

គាថាទី ៤ នោះ មានអធិប្បាយដូច្នេះថា ព្រះសេនកៈប្រកាសការ ជ្រះថ្លាក្រៃលែងក្នុងព្រះមានព្រះភាគថា ព្រះមានព្រះភាគអង្គនោះ ជាសាស្តា របស់ខ្ញុំ កាលដោះខ្ញុំដែលសៅហ្មងដោយវត្ថុដែលសៅហ្មង អស់កាលយូរ ក្នុងសង្សារ ដែលមានទីបំផុតខាងដើម និងខាងចុងដឹងមិនបាន ដូចឃ្លោក ពេញទៅដោយទឹកបាយ ដូចក្លាក់ដាក់តក្កៈ និងដូចសំពត់ចាស់ប្រឡាក់ប្រេង ដែលត្រូវចំណង គឺទិដ្ឋិចង ត្រង់បង្គោល គឺសក្កាយទិដ្ឋិ ដូចឆ្កែត្រូវខ្សែចង ត្រង់បង្គោល ឲ្យផុតចាកចំណងនោះ ឈ្មោះថា ព្រះមានព្រះភាគអង្គនោះ បានញ៉ាំងអាត្មាអញឈ្មោះសេនកៈ ឲ្យផុតចំណងទាំងពួង មានអភិជ្ឈា ជាដើម ដោយព្រះហស្ត គឺអរិយមគ្គ ។

## អដ្ឋកថា សេនកត្ថេរគាថា ចប់

# សុត្តន្តបិដក

## សម្ពុតត្ថេរគាថា

[ ១៩៣ ] បុគ្គលណា ប្រញាប់ប្រញាល់ ក្នុងកាលដែលគួរសន្សឹម បែរជាសន្សឹម ក្នុងកាលដែលគួរប្រញាប់ប្រញាល់ បុគ្គលនោះ ឈ្មោះថា ពាល រមែងបាននូវទុក្ខ ព្រោះការចាត់ចែងមិនមែនដោយឧបាយនៃប្រាជ្ញា ។ ប្រយោជន៍ទាំងឡាយរបស់បុគ្គលនោះ រមែងសាបសូន្យ ដូចព្រះចន្ទ្រក្នុងកាឡបក្ខ បុគ្គលនោះ រមែងដល់នូវភាពជាអ្នកមិនមានយសផង បែកចាកពួកមិត្តផង ។ បុគ្គលណា សន្សឹមក្នុងកាលដែលគួរសន្សឹម ប្រញាប់ប្រញាល់ ក្នុងកាលដែលគួរប្រញាប់ប្រញាល់ បុគ្គលនោះ ឈ្មោះថា បណ្ឌិត រមែងបានសេចក្តីសុខ ព្រោះការចាត់ចែងដោយឧបាយនៃប្រាជ្ញា ។ ប្រយោជន៍របស់បុគ្គលនោះ រមែងពេញបរិបូណ៌ ដូចជាព្រះចន្ទ្រក្នុងសុក្កបក្ខ បុគ្គលនោះ រមែងដល់នូវយស និងកេរ្តិ៍ឈ្មោះផង មិនបែកចាកពួកមិត្តផង ។

សម្ពុតត្ថេរ

# អដ្ឋកថា

## សម្មុតត្ថេរគាថា

[ ១៩៣ ] គាថារបស់ព្រះសម្មុតត្ថេរ មានពាក្យផ្ដើមថា **យោ ឧទ្ធកាលេ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ កាលលោកជាតុមិនមានព្រះពុទ្ធ កើតក្នុងកំណើតកិន្នរ ត្រង់ច្រាំងស្ទឹងចន្ទភាគា ។ ថ្ងៃមួយ ឃើញព្រះបច្ចេកពុទ្ធមួយអង្គ មានចិត្តជ្រះថ្លា ថ្វាយបង្គំហើយ ធ្វើអញ្ជលី បូជាដោយផ្កាអង្គ្រង ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងផ្ទះមានត្រកូល មានឈ្មោះថា សម្មុតៈ កុលបុត្តនោះចម្រើនវ័យហើយ ក្រោយព្រះមានព្រះភាគបរិនិព្វាន បានស្ដាប់ធម៌ក្នុងសម្នាក់របស់ព្រះធម្មភណ្ឌាគារិក បាននូវសទ្ធា បួសហើយ បំពេញសមណធម៌ ចម្រើនវិបស្សនា សម្រេចអរហត្ត សមដូចគាថាព័ន្ធដែលលោកពោលក្នុងអបទានថា

កាលនោះ ខ្ញុំកើតជាកិន្នរ នៅទៀបច្រាំងស្ទឹងចន្ទភាគា បានឃើញព្រះពុទ្ធ ទ្រង់ប្រាសចាកធូលី គឺកិលេស ត្រាស់ដឹងដោយព្រះអង្គឯង ទ្រង់ឈ្នះមារ ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ ត្រេកអរធ្វើនូវអញ្ជលីកម្ម បានយកផ្កាអង្គ្រងទៅបូជាព្រះសយម្ភូ ។ ព្រោះអំពើដែលខ្ញុំធ្វើល្អនោះផង ព្រោះការតម្កល់ចេតនានោះផង លុះខ្ញុំ

លះបង់នូវរាងកាយជាកិន្នរហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។
ខ្ញុំជាធំជាងទេវតា បានសោយរាជ្យក្នុងទេវលោក អស់ ៣៦ ដង
បានសោយរាជ្យជាស្តេចចក្រពត្តិមហារាជអស់ ១០ ដង ។ បាន
សោយប្រទេសរាជដ៏ធំទូលាយ រាប់ជាតិមិនអស់ ( ព្រោះ ) ពូជ
បានព្រោះក្នុងព្រះសយម្ភូ ជាស្រែដ៏ល្អ ។ ខ្ញុំមានកុសល ខ្ញុំបានចូល
ទៅកាន់ផ្នួស ខ្ញុំជាបុគ្គលគួរគេបូជាក្នុងសាសនានៃព្រះសក្យបុត្រ
ក្នុងថ្ងៃនេះ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។
ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

កាលសម្រេចអរហត្តហើយ នៅដោយវិហារសុខ ដែលកើតអំពីវិមុត្តិ កាលព្រះមានព្រះភាគបរិនិព្វានបាន ១០០ ឆ្នាំ កាលភិក្ខុដែលជាបុត្តនៃស្តេចវជ្ជី អ្នកក្រុងវេសាលីសរសើរវត្ថុ ១០ ប្រការ កាលព្រះខីណាស្រព ៧០០ ដែលព្រះយសកាកណ្ឌកបុត្តត្រេរជាស់តឿនឲ្យអាចហ៊ាន ទម្លាយនូវទិដ្ឋិនោះ លើកតម្កើងព្រះសទ្ធម្ម ធ្វើសង្គាយនាព្រះធម្មវិន័យ ព្រោះសេចក្តីសង្វេគក្នុងធម៌ ក្នុងកាលដែលភិក្ខុអ្នកក្រុងវជ្ជីបុត្រសម្តែងសត្ថុសាសនៈក្រៅធម៌ ក្រៅវិន័យ ព្រះថេរៈក៏ពោលគាថានេះ ព្យាករអរហត្តផលថា

បុគ្គលណា ប្រញាប់ប្រញាល់ ក្នុងកាលដែលគួរសន្សឹម បែរជា
សន្សឹម ក្នុងកាលដែលគួរប្រញាប់ប្រញាល់ បុគ្គលនោះឈ្មោះថា
ពាល រមែងបាននូវទុក្ខ ព្រោះការចាត់ចែងមិនមែនដោយឧបាយ

---

១- ក្នុងអបទានជា អជ្ជុនបុប្ផិយត្ថេរ ។

*នៃប្រាជ្ញា ។ ប្រយោជន៍ទាំងឡាយរបស់បុគ្គលនោះ រមែងសាប សូន្យ ដូចព្រះចន្ទ្រក្នុងកាឡបក្ខ បុគ្គលនោះ រមែងដល់នូវភាព ជាអ្នកមិនមានយសផង បែកចាកពួកមិត្តផង ។ បុគ្គលណា សន្សំមក្នុងកាលដែលគួរសន្សំម ប្រញាប់ប្រញាល់ ក្នុងកាល ដែលគួរប្រញាប់ប្រញាល់ បុគ្គលនោះ ឈ្មោះថា បណ្ឌិត រមែង បានសេចក្តីសុខ ព្រោះការចាត់ចែងដោយឧបាយនៃប្រាជ្ញា ។ ប្រយោជន៍របស់បុគ្គលនោះ រមែងពេញបរិបូណ៌ ដូចជាព្រះចន្ទ្រ ក្នុងសុក្កបក្ខ បុគ្គលនោះ រមែងដល់នូវយស និងកេរ្តិ៍ឈ្មោះផង មិនបែកចាកពួកមិត្តផង ដូច្នេះ ។*

*បណ្តាបទទាំងនោះ បទថា* **យោ ទន្ធកាលេ តរតិ** *សេចក្តីថា កាល កើតសេចក្តីសង្ស័យក្នុងព្រះវិន័យ ក្នុងរឿងដែលធ្វើណាមួយថា វត្ថុនេះ គួរ ឬមិនគួរហ្ន៎ ដូច្នេះ ក៏ប្រញាប់ធ្វើនូវការកន្ទងល្មើស ក្នុងវេលាដែលគួរបង្អង់ គឺក្នុងវេលាដែលគួរបង្អង់ក្នុងកិច្ចនោះ ទម្រាំសាកសួរព្រះវិនយធរដែលជា អ្នកជំនាញ ឲ្យអស់សេចក្តីសង្ស័យសិន ។*

*បទថា* **តរណីយេ ច ទន្ធយេ** *សេចក្តីថា សម្រាប់គ្រហស្ថ កាលកិច្ច ដែលគួរប្រញាប់ធ្វើ ដូចជាការដល់សរណៈ និងការសមាទានសីលជាដើម សម្រាប់បព្វជិត ដូចជាការធ្វើវត្ត និងបដិវត្តជាដើម និងការតាមប្រកបសមថៈ និងវិបស្សនា ដែលគួរប្រញាប់ប្រញាល់ មិនប្រញាប់ប្រកបកិច្ចនោះ បង្អែ បង្អង់ ដោយគិតថា អញនឹងធ្វើក្នុងខែ ឬក្នុងបក្ខដែលនឹងមកដល់ គឺមិនធ្វើ*

កិច្ចនោះ បណ្តោយពេលវេលាឲ្យកន្លងទៅ ។

បទថា **អយោនិសោសំវិធានេន** សេចក្តីថា បុគ្គលពាល អប្បឥត ប្រាជ្ញា ប្រញាប់ធ្វើនូវកិច្ចដែលគួរបង្អង់ និងបង្អង់ក្នុងកិច្ចដែលគួរប្រញាប់ រមែងជួបនូវទុក្ខ គឺសេចក្តីវិនាសក្នុងឥឡូវនេះ និងក្នុងកាលតទៅ ដោយការ មិនចាត់ចែងឲ្យត្រូវទំនង គឺព្រោះមិនមានការចាត់ចែងឲ្យត្រូវឧបាយ ។

បទថា **តស្សត្ថា បរិហាយន្តិ** សេចក្តីថា ប្រយោជន៍ទាំងឡាយ មាន ប្រយោជន៍បច្ចុប្បន្នជាដើមរបស់បុគ្គលនោះ គឺបែបនោះ រមែងសាបសូន្យ ដូចព្រះចន្ទ្រក្នុងកាឡបក្ខ គឺរមែងដល់នូវការអស់ទៅសូន្យទៅរាល់ៗ ថ្ងៃ បុគ្គលនោះ រមែងដល់ គឺរមែងជួបនូវការមិនមានយស គឺដល់នូវភាពជា បុគ្គលដែលវិញ្ញូជនគប្បីតិះដៀល ដោយន័យជាដើមថា បុគ្គលនោះ ជាអ្នក មិនមានសទ្ធា មិនមានការជ្រះថ្លា ខ្ជិលច្រអូស មានការព្យាយាមថយ ។

បទថា **មិត្តេហិ ច វិរុជ្ឈតិ** សេចក្តីថា បុគ្គលនោះ សាបសូន្យចាក កល្យាណមិត្តដែលជាអ្នកឲ្យឱវាទថា ចូរបដិបត្តិយ៉ាងនេះ កុំបដិបត្តិយ៉ាងនេះ ព្រោះមិនព្រមទទួលឱវាទ ដោយប្រកាន់ថា បុគ្គលណាមិនចាំបាច់ស្តីថាអញ ដូច្នេះ ។

២ គាថាដ៏សេស គប្បីជ្រាបសេចក្ដីដោយបរិយាយផ្សេងៗ ។ តែក្នុងទីនេះ អាចារ្យពួកខ្លះ អធិប្បាយថា បទថា **តរតិ** ( ប្រញាប់ ) **ឆន្ទយេ** ( បង្អង់ ) ក្នុងការលើក និងការសង្កត់ចិត្ត ក្នុងការការពារ ដោយភាពជាប្រយោជន៍ អធិប្បាយនេះ គួរប្រើក្នុងគាថាក្រោយ ។ ព្រោះ ២ គាថាដើម ព្រះថេរៈពោលសំដៅដល់វជ្ជីបុត្តភិក្ខុ ដែលមិនធ្វើសមណធម៌ ដែលគួរធ្វើតាំងអំពីបួសមក បែរជាមកសម្ដែងវត្ថុ ១០ ប្រការ ព្រោះគាប់ចិត្តក្នុងការវិកវរ ទើបសង្ឃបណ្ដេញចេញ តែ ២ គាថាខាងក្រោយ លោកពោលសំដៅដល់បុគ្គលដែលបដិបត្តិប្រពៃទាំងឡាយ ដូចគ្នានឹងខ្លួន ( ព្រះថេរៈ ) ដែលធ្វើប្រយោជន៍ខ្លួនសម្រេចហើយតាំងនៅ ។

**អដ្ឋកថាសម្ភូតត្ថេរគាថា ចប់**

# សុត្តន្តបិដក

## រាហុលត្ថេរគាថា

[ ១៩៤ ] សព្រហ្មចារីបុគ្គលទាំងឡាយ ស្គាល់ច្បាស់នូវអាត្មាអញថា រាហុលដ៏ចម្រើន ជាអ្នកប្រកបដោយគុណទាំង ២ យ៉ាង គឺជាតិ និងប្រតិបត្តិ ព្រោះអាត្មាអញជាកូននៃព្រះពុទ្ធផង ជាអ្នកមានបញ្ញាចក្ខុ ក្នុងធម៌ទាំងឡាយផង អាសវៈរបស់អាត្មាអញ អស់ហើយផង ភពថ្មីទៀតអាត្មាអញមិនមានផង អាត្មាអញជាព្រះអរហន្ត គួរដល់ទក្ខិណា មានវិជ្ជា ៣ ឃើញព្រះនិព្វានឈ្មោះអមតៈ ។ សត្វទាំងឡាយជាអ្នកងងឹត ព្រោះកាម ត្រូវបណ្តាញរួបរឹតហើយ ត្រូវជំបូល គឺតណ្ហាបិទបាំងហើយ ត្រូវមារចងហើយ ដូចត្រីជាប់នៅក្នុងមាត់លបដូច្នោះ ។ អាត្មាអញលះបង់កាមនោះហើយ បានកាត់នូវចំណងនៃមារ ដកតណ្ហា ព្រមទាំងឫសចេញហើយ ជាអ្នកមានសេចក្តីត្រជាក់កើតហើយ មានទុក្ខរលត់ហើយ ។

រាហុលត្ថេរ

# អដ្ឋកថា

## រាហុលត្ថេរគាថា

[ ១៩៤ ] គាថារបស់ព្រះរាហុលត្ថេរ មានពាក្យផ្តើមថា **ឧភយេនេវ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ។ ក្នុងសាសនារបស់ព្រះពុទ្ធព្រះនាមបទុមុត្តរៈ កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្តីហើយ ឃើញព្រះសាស្តាស្ថាបនាភិក្ខុមួយរូប ក្នុងតំណែងជាឯតទគ្គៈ នៃភិក្ខុដែលប្រាថ្នាចំពោះការសិក្សា ខ្លួនឯងក៏ប្រាថ្នាតំណែងនោះ បំពេញបុណ្យជាច្រើន មានបោសសេនាសនៈឲ្យស្អាត និងអុជប្រទីបឲ្យភ្លឺជាដើម ហើយបានតាំងនូវសេចក្តីប្រាថ្នា ។

កាលចុតិចាកអត្តភាពនោះហើយ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ អាស្រ័យព្រះពោធិសត្វនៃយើង កើតក្នុងផ្ទៃរបស់ព្រះនាងយសោធរាទេវី មាននាមថា **រាហុល** ចម្រើនដោយខត្តិយ-បរិវារ ។ វិធីបព្វជ្ជារបស់ព្រះថេរៈ មកហើយក្នុងខន្ធកៈនោះឯង ។ កាលព្រះថេរៈបួសហើយ បានទទួលព្រះឱវាទដោយសុត្តបទដ៏ច្រើន ក្នុងសម្នាក់ព្រះសាស្តា មានញាណចាស់ក្លា បំពេញវិបស្សនា សម្រេចអរហត្ត សមដូចគាថាព័ន្ធដែលលោកពោលក្នុងអបទានថា

ខ្ញុំបានក្រាលកញ្ចក់ ក្នុងប្រាសាទ ៧ ជាន់ ថ្វាយព្រះមាន
ព្រះភាគព្រះនាមបទុមុត្តរៈ ជាច្បងក្នុងលោក ទ្រង់ប្រកប

តាទិគុណ ។ ព្រះមហាមុនិ ជាធំជាងសត្វជើងពីរ ព្រះអង្គប្រសើរជាងនរៈ មានពួកព្រះខីណាស្រព មួយពាន់អង្គចោមរោម ស្តេចចូលទៅកាន់គន្ធកុដិ ។ ព្រះសាស្តា ជាទេវតាប្រសើរជាងទេវតា ព្រះអង្គប្រសើរជាងនរៈ ទ្រង់ញុំាងគន្ធកុដិឲ្យរុងរឿង ឋិតនៅក្នុងកណ្តាលភិក្ខុសង្ឃ ហើយសម្តែងនូវគាថាទាំងឡាយនេះថា

ទីសេយ្យាសន៍នេះ ដែលបុគ្គលណា ធ្វើឲ្យរុងរឿងហើយ ដូចកញ្ចក់ ដែលគេក្រាលដោយល្អល្អះ តថាគតនឹងសម្តែងសរសើរបុគ្គលនោះ អ្នកទាំងឡាយ ចូរស្តាប់តថាគតសម្តែងចុះ ។ ប្រាសាទណាមួយ ជាទីស្រឡាញ់ពេញចិត្ត ប្រាសាទទាំងនោះ សុទ្ធតែជាវិការនៃមាស ទាំងជាវិការនៃកែវពៃទូរ្យ នឹងកើតឡើងសម្រាប់បុគ្គលនេះ ។ បុគ្គលនោះនឹងសោយរាជ្យ ជាធំជាងទេវតា អស់ ៦៤ ដង ក្នុងជាតិជាលំដាប់មក នឹងបានជាស្តេចចក្រពត្តិ អស់មួយពាន់ដង ក្នុងកប្បទី ២១ នឹងបានជាស្តេចចក្រពត្តិព្រះនាមវិមលៈ ។ ជាឥស្សរៈលើផែនដី មានសមុទ្រទាំង ៤ ព័ទ្ធជុំវិញ ជាស្តេចឈ្នះសង្គ្រាម ។ ទីក្រុង ( របស់ព្រះបាទវិមលៈនោះ ) ឈ្មោះរេណុវតី ដែលគេស្ថាបនាដោយឥដ្ឋ មានបណ្តោយ ៣០០ យោជន៍ ប្រកបដោយជ្រុង ៤ ។ ប្រាសាទឈ្មោះសុទស្សនៈ

ប្រកបដោយផ្ទះកំពូល ដ៏ប្រសើរ ស្អិតស្អាងដោយកែវ ៧ ប្រការ ដែលវិស្វករបានសាងថ្វាយ ។ ទីក្រុងនោះស្ងប់ស្ងាត់ចាកសំឡេងទាំង ១០ ដ៏ដេរដាសដោយពួកវិជ្ជាធរ ដូចជាទីក្រុងឈ្មោះសុទស្សនៈ របស់ទេវតាទាំងឡាយដែរ ។ កាលព្រះអាទិត្យរះឡើង ពន្លឺរបស់ក្រុងនោះ នឹងរុងរឿងជានិច្ចដោយជុំវិញ អស់ចម្ងាយ ៨ យោជន៍ ។ ក្នុងកប្បទីមួយសែន ព្រះសាស្តាព្រះនាមគោតម កើតក្នុងឱក្កាកត្រកូល នឹងត្រាស់ដឹងក្នុងលោក ។ កុលបុត្រនោះ នឹងច្យុតចាកឋានតុសិតនោះមកវិញ ត្រូវកុសលមូលជាស់តឿន បានមកកើតជាព្រះរាជឱរស របស់ព្រះមានព្រះភាគ ព្រះនាមគោតម ។ កុលបុត្រនោះ ប្រសិនបើនៅគ្រប់គ្រងផ្ទះ នឹងបានជាស្តេចចក្រពត្តិ តែមិនមានហេតុ ដែលឲ្យកុលបុត្តជាតាទិបុគ្គលនុ៎ះ បានដល់នូវសេចក្តីត្រេកអរក្នុងផ្ទះឡើយ កុលបុត្រនោះនឹងចេញចាកផ្ទះទៅបួស ជាអ្នកមានវត្តល្អ នឹងបានជាព្រះអរហន្ត ឈ្មោះរាហុល ។

ព្រះមហាមុនី ព្រះអង្គមានប្រាជ្ញាចាស់ បរិបូណ៌ដោយសីល ទ្រង់រក្សាខ្ញុំ ថែទាំខ្ញុំ ដូចជាមេបក្សីត្រដេវិចរក្សាស៊ុតពុំនោះសោត ដូចជាមេចាមរី រក្សារោម ។ ខ្ញុំបានដឹងធម៌របស់ព្រះគោតមសម្ពុទ្ធនោះត្រេកអរក្នុងសាសនា ហើយ

កំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ ។
បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យ
ជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បាន
ប្រតិបត្តិហើយ ដូច្នេះ ។

កាលព្រះថេរៈសម្រេចអរហត្តហើយ ពិចារណាបដិបទារបស់ខ្លួន កាលនឹងព្យាករអរហត្តផល ទើបពោល ៤ គាថាថា

សព្រហ្មចារីបុគ្គលទាំងឡាយ ស្គាល់ច្បាស់នូវអាត្មាអញថា
រាហុលដ៏ចម្រើន ជាអ្នកប្រកបដោយគុណទាំង ២ យ៉ាង គឺជាតិ
និងប្រតិបត្តិ ព្រោះអាត្មាអញជាកូននៃព្រះពុទ្ធផង ជាអ្នកមាន
បញ្ញាចក្ខុក្នុងធម៌ទាំងឡាយផង អាសវៈរបស់អាត្មាអញអស់
ហើយផង ភពថ្មីទៀត អាត្មាអញមិនមានផង អាត្មាអញជាព្រះ
អរហន្ត គួរដល់ទក្ខិណា មានវិជ្ជា ៣ ឃើញព្រះនិព្វានឈ្មោះ
អមតៈ ។ សត្វទាំងឡាយ ជាអ្នកងងឹតព្រោះកាម ត្រូវបណ្ដាញ
រួបរឹតហើយ ត្រូវដំបូល គឺតណ្ហាបិទបាំងហើយ ត្រូវមារចងហើយ
ដូចត្រីជាប់នៅក្នុងមាត់លប ដូច្នោះ ។ អាត្មាអញ លះបង់កាម
នោះហើយ បានកាត់នូវចំណងនៃមារ ដកតណ្ហា ព្រមទាំងឫស
ចេញហើយ ជាអ្នកមានសេចក្ដីត្រជាក់កើតហើយ មានទុក្ខរលត់
ហើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឧភយេនេវ សម្បន្នោ** សេចក្ដីថា សម្បូរ

គឺប្រកបដោយសម្បត្តិទាំង ២ គឺជាតិសម្បត្តិ និងបដិបត្តិសម្បត្តិ ។

បទថា **រាហុលភទ្ទោតិ មំ វិទូ** សេចក្តីថា សព្រហ្មចារីទាំងឡាយរមែងស្គាល់ខ្ញុំថា រាហុលដ៏ចម្រើន ។ ពិតហើយ ព្រះបាទសុទ្ធោទនមហារាជទ្រង់ជ្រាបថា រាហុលប្រសូតហើយ ទ្រង់អាស្រ័យពាក្យដែលព្រះពោធិសត្វពោលថា រាហុលប្រសូតហើយ ចំណងកើតហើយ ទើបទ្រង់កាន់យកព្រះនាមថា **រាហុល** ។ ក្នុងសេចក្តីនោះ ព្រះរាហុលកាន់យកបរិយាយ ដែលព្រះបិតាត្រាស់ហើយ តាំងអំពីដើមនោះឯង ទើបពោលថា សព្រហ្មចារីបុគ្គលទាំងឡាយ ស្គាល់ច្បាស់នូវអាត្មាអញថា រាហុលដ៏ចម្រើន ។ ពាក្យថា **ភទ្ទោ** នេះ ជាពាក្យសម្តែងដល់ការសរសើរ ។

ឥឡូវនេះ ដើម្បីសម្តែងសម្បត្តិទាំង ២ នោះ ទើបលោកពោលថា **យញ្ចម្ហិ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **យំ** ស្មើគ្នានឹង **យស្មា** ប្រែថា ព្រោះហេតុណា ។ **ច** សព្ទ មានអត្ថថា រួមបញ្ចូលផង ។

បទថា **អម្ហិ បុត្តោ ពុទ្ធស្ស** សេចក្តីថា ខ្ញុំជារាជឱរសរបស់ព្រះពុទ្ធ ។

បទថា **ធម្មេសុ** បានដល់ ក្នុងធម៌ ទាំងដែលជាលោកិយ និងលោកុត្តរ អធិប្បាយថា ក្នុងធម៌ គឺសច្ចៈ ៤ ។

បទថា **ចក្ខុមា** ប្រកបសេចក្តីថា ខ្ញុំជាអ្នកមានចក្ខុ ដោយចក្ខុ គឺបញ្ញាដែលសម្បយុត្តដោយមគ្គ ។

ដើម្បីសម្តែងសម្បត្តិទាំង ២ ដោយបរិយាយដទៃៗ ទៀត ទើបពោល

ថា **យញ្ច មេ អាសវា ខីណា** អាសវៈរបស់អាត្មាអញអស់ហើយផង ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **ទក្ខិណេយ្យោ** បានដល់ គួរដល់ទក្ខិណា ។

បទថា **អមតទ្ទសោ** បានដល់ ជាអ្នកឃើញនូវព្រះនិព្វាន ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ។

ឥឡូវនេះ ពួកសត្វរមែងអន្ទោលទៅក្នុងសង្សារ ដូចត្រីដែលជាប់ក្នុងលប ព្រោះមិនមានវិជ្ជាសម្បត្តិ និងវិមុត្តិសម្បត្តិណា ដើម្បីសម្ដែងសម្បត្តិទាំង ២ នោះក្នុងខ្លួន ទើបពោល ២ គាថាថា **កាមន្ធា** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **កាមន្ធា** ព្រោះងងឹតព្រោះកាម ឬងងឹតក្នុងកាម អធិប្បាយថា ដែលកិលេសកាម មានឆន្ទរាគៈជាដើម ធ្វើឲ្យដូចមនុស្សខ្វាក់ ព្រោះមិនឃើញទោសក្នុងវត្ថុកាម មានរូបជាដើម ។

បទថា **ជាលបច្ឆន្នា** សេចក្ដីថា ត្រូវសំណាញ់ គឺតណ្ហាដែលផ្សាយទៅក្នុងអារម្មណ៍ផ្សេងៗ ដែលបិទបាំងភព ៣ ទាំងមូល គឺចងដោយប្រការផ្សេងៗ ។

បទថា **តណ្ហាឆទនឆាទិតា** សេចក្ដីថា ត្រូវដំបូល គឺតណ្ហានោះឯងបិទបាំង គឺបិទបាំងដោយប្រការទាំងពួង ។

បទថា **បមត្តពន្ធុនា ពទ្ធា មច្ឆាវ កុមិនាមុខេ** សេចក្ដីថា សត្វទាំងនេះត្រូវមារចងដោយសេចក្ដីប្រមាទ គឺត្រូវកាមពន្ធឯណាចង រមែងមិនរួចផុតចាកចំណងនោះ គឺភ្ជាប់ខាងក្នុងចំណងនោះឯង ដូចត្រីជាប់ត្រង់មាត់លប ឬ

ជាប់ត្រង់សំណាញ់របស់អ្នកប្រមង់ ។

អធិប្បាយថា ខ្ញុំដកនូវកាមមានបែបនោះ ដែលដូចជាចំណាង គឺលះបង់ដោយកិច្ចបដិបត្តិដែលជាចំណែកខាងដើម ហើយកាត់នូវចំណាងនៃកិលេសមារ ប្រើសស្ត្រា គឺអរិយមគ្គ កាប់ក្ការមិនឲ្យសេសសល់ ដកនូវតណ្ហា មានកាមតណ្ហាជាដើម មួយអន្លើដោយឫស គឺអវិជ្ជាជាអ្នកត្រជាក់ ព្រោះមិនមានសេចក្តីក្រវល់ក្រវាយ និងកំដៅនៃកិលេសទាំងពួង រម្ងត់ឥតសេសសល់ ដោយសឧបាទិសេសនិព្វានធាតុ ។៙

**អដ្ឋកថារាហុលត្ថេរគាថា ចប់**

# សុត្តន្តបិដក

## ចន្ទនត្ថេរគាថា

[ ១៩៥ ] ប្រពន្ធ ( របស់ខ្ញុំ ) ស្អិតស្អាងដោយមាស មានពួកទាសី ដើរចោមរោម ពកូនដោយចង្កេះ ចូលមករកខ្ញុំ ។ លុះខ្ញុំឃើញមាតារបស់កូនខ្ញុំនោះ ប្រដាប់ដោយគ្រឿងអាភរណៈ មានការស្លៀកពាក់ល្អហើយដើរមក ហាក់ដូចជាអន្ទាក់នៃមច្ចុ ដែលមារដំឡើងហើយ ។ លំដាប់នោះ ការធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា ក៏កើតឡើងដល់ខ្ញុំ ទោសក៏កើតឡើងប្រាកដ សេចក្ដីទ្រាន់ណាស់ ក៏តាំងនៅមាំ ។ តពីនោះមក ចិត្តរបស់ខ្ញុំរួចស្រឡះ អ្នកចូរមើលនូវភាពនៃធម៌ជាធម៌ល្អ ត្រៃវិជ្ជា ខ្ញុំបានដល់ដោយលំដាប់ហើយ សាសនានៃព្រះពុទ្ធ ខ្ញុំក៏បានធ្វើហើយ ។

ចន្ទនត្ថេរ

# អដ្ឋកថា

## ចន្ទនត្ថេរគាថា

[ ១៩៥ ] គាថារបស់ព្រះចន្ទនត្ថេរ មានពាក្យផ្ដើមថា **ជាតរូបេន** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ។

ក្នុងកប្បទី ៣១ អំពីភទ្ទនេះ កាលលោកជាតុមិនមានព្រះពុទ្ធ កើតជារុក្ខទេវតា ឃើញព្រះបច្ចេកពុទ្ធព្រះនាមសុទស្សនៈ ត្រង់ចន្លោះភ្នំ មានចិត្តជ្រះថ្លា បានបូជាដោយផ្កាអញ្ចន មានពណ៌ខៀវ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងផ្ទះមានត្រកូល ដល់ព្រមដោយសម្បត្តិក្នុងក្រុងសាវត្ថី មានទាមថា **ចន្ទនៈ** ចម្រើនវ័យហើយ នៅគ្រប់គ្រងផ្ទះ បានស្តាប់ធម៌ក្នុងសម្នាក់ព្រះសាស្តា បានជាព្រះសោតាបន្ន ។

លុះបានកូនម្នាក់ លះយកវាសបួស ចម្រើនវិបស្សនាកម្មដ្ឋាន នៅក្នុងព្រៃ មកកាន់ក្រុងសាវត្ថី ដើម្បីថ្វាយបង្គំព្រះសាស្តា ហើយស្នាក់ក្នុងព្រៃខ្មោច ភរិយាចាស់ដឹងថា ព្រះថេរៈមកហើយ ក៏ប្រដាប់តាក់តែង នាំកុមារព្រមទាំងបរិវារជាច្រើន ទៅកាន់សម្នាក់របស់ព្រះថេរៈ ដោយគិតថា អញនឹងលួងលោមឲ្យព្រះថេរៈសឹក ដោយមាយាស្រីជាដើម ។ ព្រះថេរៈឃើញស្រីនោះកំពុងដើរមក អំពីចម្ងាយ គិតថា ឥឡូវនេះ អញមិនមែនជាវិស័យរបស់នាង ទើបបំពេញវិបស្សនាតាមដែលអប់រំ ជាអ្នកមានអភិញ្ញា ៦ សមដូចគាថាព័ន្ធដែលលោកពោលក្នុងអបទានថា

ក្នុងទីជិតនៃព្រៃហេមពាន្ត មានភ្នំមួយឈ្មោះអចលៈ ព្រះសម្ពុទ្ធព្រះនាមសុទស្សៈ គង់នៅក្នុងចន្លោះភ្នំនោះ ។ ខ្ញុំបានយកផ្កាអំពីព្រៃហិមពាន្ត ហើយទៅកាន់អាកាស បានឃើញព្រះសម្ពុទ្ធទ្រង់ឆ្លងឱឃៈ មិនមានអាសវៈក្នុងទីនោះ ។ កាលនោះ ខ្ញុំយកផ្កា

អញ្ជ័នខៀវមកតម្កល់លើក្បាល ហើយបូជាព្រះពុទ្ធទ្រង់ត្រាស់ដឹងឯង ទ្រង់ស្វែងរកនូវគុណដ៏ធំ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កាក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈបានអភិញ្ញាហើយ ឈរលើអាកាស សម្តែងធម៌ដល់នាង ឲ្យស្រីនោះតាំងនៅក្នុងសរណៈ និងសីលហើយ និមន្តទៅកាន់ទីដែលខ្លួនធ្លាប់នៅអាស្រ័យក្នុងកាលមុន ។ ភិក្ខុជាសម្លាញ់សួរថា អាវុសោ ឥន្ទ្រិយរបស់លោកថ្លូវផង់ម្ល៉េះ លោកចាក់ធ្លុះសច្ចៈហើយទេដឹង កាលសម្តែងបដិបទារបស់ខ្លួន ទើបព្យាករអរហត្តផល ដោយគាថានេះថា

ប្រពន្ធ ( របស់ខ្ញុំ ) ស្អិតស្អាងដោយមាស មានពួកទាសី ដើរចោមរោម ពកូនដោយចង្កេះ ចូលមករកខ្ញុំ ។ លុះខ្ញុំឃើញមាតារបស់កូនខ្លួននោះ ប្រដាប់ដោយគ្រឿងអាភរណៈ មានការស្លៀកពាក់ល្អ ហើយដើរមក ហាក់ដូចជាអន្ទាក់នៃមច្ចុ ដែលមារដំឡើងហើយ ។ លំដាប់នោះ ការធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញាក៏កើតឡើងដល់ខ្ញុំ ទោសក៏កើតឡើងប្រាកដ សេចក្តីទ្រាន់ណាស់ក៏តាំងនៅមាំ ។ តពីនោះមក ចិត្តរបស់ខ្ញុំរួចស្រឡះអ្នកចូរមើល

---

១- ក្នុងអបទានជា កុដជបុប្ផិយត្ថេរ ។

នូវភាពនៃធម៌ជាធម៌ល្អ ត្រៃវិជ្ជា ខ្ញុំបានដល់ដោយលំដាប់ហើយ សាសនានៃព្រះពុទ្ធ ខ្ញុំក៏បានធ្វើហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ជាតរូបេន សញ្ឆន្នា** សេចក្តីថា មានរាងកាយគ្របដោយគ្រឿងប្រដាប់ មានគ្រឿងប្រដាប់ក្បាលជាដើម សម្រេចហើយដោយមាស អធិប្បាយថា ប្រដាប់ដោយអាភរណៈទាំងពួង ។

បទថា **ទាសី គណាបុរក្ខតា** សេចក្តីថា ដែលពួកទាសីរបស់ខ្លួនដែលប្រដាប់តាក់តែងហើយតាមសមគួរ ចោមរោមខាងមុខខាងក្រោយ ។

បទថា **អង្កេន បុត្តមាទាយ** សេចក្តីថា ពបុត្រត្រង់ចង្កេះរបស់ខ្លួនដោយគិតថា ព្រះថេរៈឃើញកូននេះហើយ នឹងកើតសេចក្តីត្រេកអរតាមបែបអ្នកនៅគ្រប់គ្រងផ្ទះ ។

បទថា **អាយន្តី** ប្រែថា កំពុងដើរមក ។

បទថា **សកបុត្តស្ស មាតរំ** បានដល់ ស្រីដែលឲ្យកំណើតដល់បុត្ររបស់ខ្ញុំ គឺអតីតកិរិយារបស់ខ្ញុំ ។ ព្រះថេរៈកាន់យកការផ្តាច់ផ្តិលកាមរាគៈរបស់ខ្លួនថា សំខាន់ ទើបពោលពាក្យទាំងអស់នេះ ។ បទថា **យោនិសោ ឧទបជ្ជថ** សេចក្តីថា ធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា កើតឡើងហើយយ៉ាងនេះថា សម្បត្តិបែបនេះ ត្រូវជរាព្យាធិ និងមរណៈគ្របសង្កត់ ឱ ! សង្ខារទាំងឡាយមិនទៀង មិនស្ថិតស្ថេរ បង្អាប់បញ្ញាមិនបានហ្ន៎ ។ ពាក្យដ៏សេសមានន័យដូចបានពោលហើយខាងដើមនោះឯង ។៚

អដ្ឋកថា ចន្ទនត្ថេរគាថា ចប់

# សុត្តន្តបិដក

## ធម្មិកត្ថេរគាថា

[ ១៩៦ ] ធម៌រមែងរក្សាបុគ្គលអ្នកប្រព្រឹត្តធម៌ដោយពិត ធម៌ដែលបុគ្គលសន្សំហើយ រមែងនាំមកនូវសេចក្តីសុខ នេះជាអានិសង្សក្នុងធម៌ដែលបុគ្គលសន្សំល្អហើយ បុគ្គលអ្នកប្រព្រឹត្តធម៌ រមែងមិនទៅកាន់ទុគ្គតិ ។ សភាវៈទាំង ២ គឺកុសលធម៌ ១ អកុសលធម៌ ១ មិនមែនមានផលស្មើគ្នាទេ អកុសលធម៌ នាំសត្វទៅកាន់នរក កុសលធម៌ ញុំាងសត្វឲ្យដល់នូវសុគតិ ។

ព្រោះហេតុនោះ បុគ្គលកាលមានចិត្តរីករាយចំពោះព្រះសុគត ជាតាទិបុគ្គលយ៉ាងនេះ គប្បីធ្វើសេចក្តីពេញចិត្តក្នុងធម៌ទាំងឡាយ សាវកទាំង-ឡាយរបស់ព្រះសុគតដ៏ប្រសើរ ឋិតនៅក្នុងធម៌ ជាអ្នកប្រាជ្ញ បានដល់នូវទីពឹងដ៏ប្រសើរលើស រមែងនាំខ្លួនចេញ ( ចាកវដ្តទុក្ខបាន ) ។

ឫសគល់នៃបូស គឺអវិជ្ជា ខ្ញុំព្រះអង្គបានកម្ចាត់បង់ហើយ បណ្តាញគឺតណ្ហា ខ្ញុំព្រះអង្គបានដកចោលហើយ ។

ខ្ញុំព្រះអង្គនោះ មានសង្សារអស់ហើយ កិលេសជាគ្រឿងខ្វល់ មិនមានដល់ខ្ញុំព្រះអង្គឡើយ ដូចជាព្រះចន្ទ្រក្នុងថ្ងៃពេញបូណ៌មី ដែលប្រាសចាកទោស គឺពពកជាដើម ។

ធម្មិកត្ថេរ

# អដ្ឋកថា

## ធម្មិកត្ថេរគាថា

[ ១៩៦ ] គាថារបស់ព្រះធម្មិកត្ថេរ មានពាក្យផ្ដើមថា **ធម្មោ ហវេ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមសិខី កើតជាព្រានព្រៃ ថ្ងៃមួយ កាលព្រះសាស្ដាទ្រង់សម្ដែងធម៌ដល់បរិស័ទក្នុងព្រៃ កាន់យកនិមិត្តនៃទេសនាថា នេះ ហៅថា ធម៌ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងកោសលរដ្ឋ បានឈ្មោះថា **ធម្មិកៈ** ចម្រើនវ័យហើយ កើតសេចក្ដីជ្រះថ្លា ក្នុងកាលដែលព្រះមានព្រះភាគទទួលវត្តជេតពនមហាវិហារ បួសហើយ បានជាមេវត្តក្នុងអាវាសមួយកន្លែង ជាអ្នកសម្លឹងទោសក្នុងវត្ត និងមិនមែនវត្តរបស់ភិក្ខុដែលជាអាគន្តុកៈ ហើយអត់ធន់មិនបាន ។ ដោយហេតុនោះ ភិក្ខុទាំងឡាយ ក៏នាំគ្នាលះបង់វិហារនោះ ចៀសចេញទៅ ព្រះថេរៈនៅមួយអង្គឯង ឧបាសកដែលជាម្ចាស់របស់វិហារស្ដាប់ហេតុនោះហើយ ទូលរឿងនោះដល់ព្រះមានព្រះភាគ ។ ព្រះសាស្ដាត្រាស់ហៅភិក្ខុនោះមកសួរសេចក្ដីនោះ កាលភិក្ខុនោះទូលថា យ៉ាងនោះឯងព្រះអង្គ ទើបត្រាស់ថា ភិក្ខុនេះ មិនមែនមិនអត់ធន់តែក្នុងឥឡូវនេះទេ សូម្បីក្នុងកាលមុន ក៏មិនអត់ធន់ដូចគ្នា កាលភិក្ខុ

ទាំងឡាយទូលអារាធនាហើយ ទើបសម្តែងវុក្ខធម្មជាតក កាលទ្រង់ប្រទាន ឱវាទដល់ព្រះថេរៈឲ្យក្រៃលែង ទើបត្រាស់ ៤ គាថាថា

ធម៌រមែងរក្សាបុគ្គលអ្នកប្រព្រឹត្តធម៌ដោយពិត ធម៌ដែលបុគ្គលសន្សំហើយ រមែងនាំមកនូវសេចក្តីសុខ នេះជាអានិសង្សក្នុងធម៌ដែលបុគ្គលសន្សំល្អហើយ បុគ្គលអ្នកប្រព្រឹត្តធម៌ រមែងមិនទៅកាន់ទុគ្គតិ ។ សភាវៈទាំង ២ គឺកុសលធម៌ ១ អកុសលធម៌ ១ មិនមែនមានផលស្មើគ្នាទេ អកុសលធម៌ នាំសត្វទៅកាន់នរក កុសលធម៌ ញ៉ាំងសត្វឲ្យដល់នូវសុគតិ ។

ព្រោះហេតុនោះ បុគ្គលកាលមានចិត្តរីករាយចំពោះព្រះសុគត ជាតាទិបុគ្គលយ៉ាងនេះ គប្បីធ្វើសេចក្តីពេញចិត្តក្នុងធម៌ទាំងឡាយ សាវកទាំងឡាយរបស់ព្រះសុគតដ៏ប្រសើរ ឋិតនៅក្នុងធម៌ ជាអ្នកប្រាជ្ញ បានដល់នូវទីពឹងដ៏ប្រសើរលើស រមែងនាំខ្លួនចេញ ( ចាកវដ្តទុក្ខបាន ) ។

ឫសគល់នៃបូស គឺអវិជ្ជា ខ្ញុំព្រះអង្គបានកម្ចាត់បង់ហើយ បណ្តាញ គឺតណ្ហា ខ្ញុំព្រះអង្គបានដកចោលហើយ ។

ខ្ញុំព្រះអង្គនោះ មានសង្សារអស់ហើយ កិលេសជាគ្រឿងខ្វល់ មិនមានដល់ខ្ញុំព្រះអង្គឡើយ ដូចជាព្រះចន្ទ្រ ក្នុងថ្ងៃពេញបូណ៌មី ដែលប្រាសចាកទោស គឺពពកជាដើម ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ធម្មោ** បានដល់ សុចរិតធម៌ ដែលជា

លោកិយផង លោកុត្តរផង ។

បទថា **រក្ខតិ** សេចក្ដីថា រមែងរក្សាចាកអបាយទុក្ខ ធម៌ដែលជាឧបនិស្ស័យនៃព្រះនិព្វាន រមែងរក្សាចាកសង្សារទុក្ខ ។

បទថា **ធម្មចារី** បានដល់ ប្រព្រឹត្ត គឺបដិបត្តិធម៌នោះ ។

បទថា **សុចិណ្ណោ** សេចក្ដីថា ធម៌ដែលបុគ្គលប្រព្រឹត្តល្អហើយ គឺជឿកម្ម និងផលនៃកម្ម ធ្វើនូវការគោរពកោតក្រែងសន្សំហើយ ។

បទថា **សុខំ** បានដល់ សេចក្ដីសុខ ទាំងជាលោកិយ និងលោកុត្តរ ។ ក្នុងសុខ ២ យ៉ាងនោះ សម្រាប់លោកិយសុខ ធម៌ មានកាមាវចរធម៌ជាដើម រមែងនាំមក គឺឲ្យសម្រេចសេចក្ដីសុខតាមសមគួរ ទាំងក្នុងជាតិនេះ ឬក្នុងជាតិខាងមុខ ឬក្នុងបរិយាយដទៃ ។ ចំណែកលោកុត្តរសុខ គួរពោលបានថា ធម៌ដែលបុគ្គលតាំងនៅក្នុងឧបនិស្ស័យនៃព្រះនិព្វាន ប្រព្រឹត្តហើយ រមែងនាំសេចក្ដីសុខមកឲ្យតៗ ទៅ ព្រោះបុគ្គលមិនមានធម៌ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក៏មិនមានសុខនោះ ។ បទថា **ឯសានិសំសោ ធម្មេ សុចិណ្ណេ ន ទុគ្គតឹ គច្ឆតិ ធម្មចារី** សេចក្ដីថា បុគ្គលដែលប្រព្រឹត្តធម៌ កាលប្រព្រឹត្តល្អហើយ រមែងមិនទៅកាន់ទុគ្គតិ ព្រោះការប្រព្រឹត្តធម៌ល្អនោះជាហេតុ នេះឯងជាអានិសង្ស ជាផលក្នុងធម៌ដែលប្រព្រឹត្តល្អហើយ ។

ព្រោះការទៅកាន់សុគតិ ក៏ដោយសារធម៌នោះឯង ហើយការទៅកាន់ទុគ្គតិ ក៏ព្រោះអធម៌នោះឯង ដូច្នោះ ដើម្បីសម្ដែងថា សភាវៈ ២ គឺធម៌ និងអធម៌ មានផលមិនលាយឡំគ្នាឡើយ ទើបត្រាស់ ២ គាថា ដោយន័យថា

**ន ហិ ធម្មោ អធម្មោ ច ឧភោ សមវិបាកិនោ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **អធម្មោ** បានដល់ ទុច្ចរិតដែលជាបដិបក្ខចំពោះធម៌ ។ បទថា **សមវិបាកិនោ** បានដល់ មានវិបាកស្មើគ្នា គឺមានផលស្មើគ្នា ។

បទថា **តស្មា** សេចក្តីថា ព្រោះធម៌ និងអធម៌ មានវិបាកផ្សេងគ្នាតាមដែលពោលហើយ ។

បទថា **ឆន្ទំ** បានដល់ មានការពេញចិត្តក្នុងភាពជាអ្នកប្រាថ្នានឹងធ្វើ ។

បទថា **ឥតិ មោទមានោ សុគតេន តាទិនា** ប្រកបសេចក្តីថា កាលកុលបុត្តត្រេកអរ គឺដល់នូវការត្រេកអរដោយព្រះសុគត ដែលត្រង់យាងទៅល្អហើយ ដែលមាននាមថា តាទិបុគ្គល គឺជាអ្នកមានហេតុ ព្រោះដល់នូវភាពជាអ្នកមិនញាប់ញ័រក្នុងឥដ្ឋារម្មណ៍ជាដើម ជាអ្នកប្រទានឱវាទ មានប្រការដូចពោលមកនេះ គឺយ៉ាងនេះ គប្បីធ្វើនូវការពេញចិត្តក្នុងធម៌ទាំងឡាយ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងវដ្តៈ ដោយពាក្យមានប្រមាណប៉ុណ្ណោះហើយ ឥឡូវនេះ កាលសម្តែងព្រះនិព្វាន ទើបត្រាស់ពាក្យជាដើមថា **ធម្មេ ឋិតា** ដូច្នេះជាដើម ។

ពាក្យនេះ មានអធិប្បាយដូច្នេះថា ព្រោះសាវករបស់ព្រះសុគតដ៏ប្រសើរ និងនៃព្រះសម្មាសម្ពុទ្ធដ៏ប្រសើរក្នុងបណ្តាព្រះសុគតដ៏ប្រសើរ ជាអ្នកប្រាជ្ញដែលតាំងនៅក្នុងធម៌របស់ព្រះសម្មាសម្ពុទ្ធអង្គនោះ ជាអ្នកដល់នូវសរណៈដ៏ប្រសើរក្រៃលែង រមែងស្ទុះចេញ គឺរមែងចេញចាកទុក្ខក្នុងវដ្តៈ

ទាំងមូល ដោយការៈជាអ្នកតាំងនៅក្នុងធម៌ ពោល គឺសរណគមន៍នោះឯង ព្រោះដូច្នោះ គួរធ្វើការពេញចិត្តក្នុងធម៌ទាំងឡាយ ។

កាលព្រះសាស្តាទ្រង់សម្តែងធម៌ដោយ ៣ គាថាទាំងនេះយ៉ាងនេះ ព្រះធម្មិកត្ថេរអន្ទុយចម្រើនវិបស្សនា តាមក្រសែទេសនានោះឯង សម្រេចអរហត្តហើយ ។ សមដូចគាថាព័ន្ធដែលលោកពោលក្នុងអបទានថា

ក្នុងភពមុន ខ្ញុំកើតជាព្រានម្រឹគនៅក្នុងព្រៃធំ ខ្ញុំបានឃើញព្រះសម្ពុទ្ធទ្រង់ប្រាសចាកធូលី មានពួកទេវតាចោមរោមហើយ កំពុងប្រកាសនូវសច្ចៈ ៤ សម្តែងនូវអមតបទ ។ ខ្ញុំបានស្តាប់ធម៌ដ៏ពីរោះរបស់ព្រះពុទ្ធ ព្រះនាមសិខីជាផៅពង្សនៃសត្វលោក ។ ខ្ញុំធ្វើចិត្តឲ្យជ្រះថ្លា ក្នុងឃោសសព្ទរបស់ព្រះសិខីសម្ពុទ្ធ ដែលរកបុគ្គលប្រៀបស្មើមិនមាន ខ្ញុំញុំាងចិត្តឲ្យជ្រះថ្លាក្នុងព្រះអង្គ ហើយបានឆ្លងនូវភព ដែលសត្វហែលឆ្លងបានដោយកម្រ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបាននូវសញ្ញាក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃឃោសសញ្ញា ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្ទឹង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់

ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈតាំងនៅហើយក្នុងអរហត្ត ដោយប្រការនោះ ។ កាលសម្រេចអរហត្តហើយ កាលក្រាបទូលគុណវិសេសដែលខ្លួនសម្រេចដល់ព្រះសាស្ដា ទើបព្យាករអរហត្តផលដោយគាថាខាងចុង ។

បណ្ដាបទទាំងនោះ បទថា **វិប្បមុត្តោ** បានដល់ កម្ចាត់ហើយ អធិប្បាយថា រលាស់ចេញដោយមគ្គញាណ ។ បទថា **តណ្ហាមូលោ** បានដល់ អវិជ្ជាពិតហើយ អវិជ្ជានោះ រមែងហើមឡើង រមែងហូរចេញ ( នូវកិលេសជាដើម ) អធិប្បាយថា ជាមូល គឺជាហេតុនៃឧបាទានក្ខន្ធ ៥ ដែលមានឈ្មោះថា បូស ដូចព្រះតម្រាស់ថា ម្នាលភិក្ខុ ពាក្យថា បូសនេះ ជាឈ្មោះនៃឧបាទានក្ខន្ធ ៥ ព្រោះប្រកបដោយឫសគល់របស់ទុក្ខ ។ ព្រោះជាទីហូរចេញនៃរបស់ដែលមិនស្អាត គឺកិលេស និងព្រោះហើមឡើង ទុំ បែកទៅដោយការកើត ចាស់ និងស្លាប់ ។

បទថា **តណ្ហាជាលោ សមូហតោ** សេចក្ដីថា សំណាញ់ ពោល គឺតណ្ហាដែលដកឡើងហើយដោយមគ្គ ។

បទថា **សោ ខីណសំសារោ ន ចត្ថិ កិញ្ចនំ** សេចក្ដីថា ខ្ញុំ ឈ្មោះថាជាអ្នកអស់សង្សារហើយ ព្រោះលះនូវតណ្ហា និងអវិជ្ជាបានហើយយ៉ាងនេះ ព្រោះខ្ញុំលះមូលនៃភពបានហើយនោះឯង ទើបកិលេសជាគ្រឿងកង្វល់ មានរាគៈជាដើម មិនមាន ព្រោះកើតឡើងមិនបាន ។

---

១- ក្នុងអបទាន ជាឃោសសញ្ញកត្ថេរ ។

បទថា **ចន្ទោ យថា ទោសិនា បុណ្ណមាសិយំ** សេចក្ដីថា ព្រះចន្ទប្រាសចាកទោស មានពពក និងអ័ព្ទជាដើម ក្នុងកាលព្រះចន្ទពេញវង់ ក្នុងថ្ងៃ ១៥ កើត យ៉ាងណា ឯខ្ញុំក៏ដូច្នោះ ឈ្មោះថា ជាអ្នកប្រាសចាកកិលេសជាគ្រឿងកង្វល់ មានរាគៈជាដើម ព្រោះសម្រេចអរហត្ត បានជាអ្នកមានទូវចំណែកនៃធម៌ដ៏បរិបូណ៌ ដូច្នេះឯង ។ល។

**អដ្ឋកថាធម្មិកត្ថេរគាថា ចប់**

# សុត្តន្តបិដក

## សប្បកាត្ថេរគាថា

[ ១៩៧ ] កុកមានស្លាបសស្អាត ត្រូវភ័យអំពីមេឃខ្មៅគំរាមហើយ ក៏ស្វែងរកសម្បុក ហើយទៅកាន់សម្បុក ក្នុងកាលណា កាលណោះ ទន្លេឈ្មោះអជករណី ក៏ញុំាងអាត្មាអញឲ្យត្រេកអរ ។ កុកមានស្លាបសស្អាត ត្រូវភ័យអំពីមេឃខ្មៅគំរាមហើយ មិនឃើញទីពួន ក៏ស្វែងរកទីពួន ក្នុងកាលណា កាលណោះ ទន្លេឈ្មោះអជករណី ញុំាងអាត្មាអញឲ្យត្រេកអរ ។

ដើមព្រីងទាំងឡាយ ញុំាងប្រាំងនៃទន្លេទាំង ២ ក្នុងទីនោះ ( ដែលឋិតនៅ ) ខាងក្រោយនៃគុហាធំឲ្យល្អ មិនមែនញុំាងសត្វណាមួយ ក្នុងទីនោះឲ្យត្រេកអរបានទេ ។

កង្កែបទាំងឡាយ មានសំឡេងពីរោះ ប្រាសចាកពួកនៃពស់ រមែងយំកងរំពង ។ ថ្ងៃនេះ មិនមែនជាសម័យនៅប្រាសចាកភ្នំ និងទន្លេទេ ព្រោះទន្លេអជករណី ជាទីក្សេមសប្បាយ រីករាយដោយប្រពៃ ។

សប្បកត្ថេរ

# អដ្ឋកថា

## សប្បកត្ថេរគាថា

[ ១៩៧ ] គាថារបស់ព្រះសប្បកត្ថេរ មានពាក្យផ្ដើមថា **យទា ពលាកា** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងកប្បទី ៣១ រាប់ថយអំពីកទុកប្បនេះ កើតជានាគមានអនុភាពច្រើន កាលព្រះបច្ចេកពុទ្ធព្រះនាមសម្ភវៈ គង់ចូលសមាបត្តិក្នុងទីវាល កុលបុត្តនេះ កាន់យកផ្កាឈូកជំបាំងលើសីសៈថ្វាយ ធ្វើនូវការបូជា ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងក្រុងសាវត្ថី មានឈ្មោះថា **សប្បកៈ** ដល់នូវភាពជាអ្នកដឹងក្ដីហើយ ស្ដាប់ធម៌ក្នុងសម្នាក់ព្រះសាស្ដា បាននូវសទ្ធា បួសហើយ រៀនកម្មដ្ឋានទៅត្រង់លេណគិរីវិហារក្បែរឆ្នេរស្ទឹងឈ្មោះអជករណី មិនយូរប៉ុន្មានក៏សម្រេចអរហត្ត សមដូចគាថាព័ន្ធដែលលោកពោលក្នុងអបទានថា

ក្នុងទីជិតព្រៃហិមពាន្ត មានភ្នំមួយឈ្មោះរោមសៈ កាលនោះ
ព្រះសម្ពុទ្ធព្រះនាមអភិសម្ភវៈ ទ្រង់គង់ក្នុងទីវាលជិតភ្នំនោះ ។ ខ្ញុំ
ចេញអំពីលំនៅ បានយកផ្កាឈូកបាំងថ្វាយព្រះអង្គ លុះខ្ញុំយក
ផ្កាឈូកមួយបាំងថ្វាយអស់មួយថ្ងៃហើយ ខ្ញុំត្រឡប់មកកាន់លំនៅ
វិញ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបាន

បូជាព្រះពុទ្ធ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផល នៃពុទ្ធបូជា ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ(១) ។

១- ក្នុងអបទាន ជាបទុមធារិយត្ថេរ ។

ព្រះថេរៈសម្រេចអរហត្តហើយ មកកាន់ក្រុងសាវត្ថីដើម្បីថ្វាយបង្គំព្រះសាស្តា កាលញាតិទាំងឡាយឧបដ្ឋាកក្នុងទីនោះ ២-៣ ថ្ងៃ សម្តែងធម៌ឲ្យញាតិទាំងឡាយតាំងនៅក្នុងសរណៈ និងសីល មានបំណងនឹងត្រឡប់ទៅកាន់លំនៅអំពីមុនក៏ប្រាប់ដល់ញាតិ ។ ញាតិទាំងឡាយអង្វរថា សូមលោកម្ចាស់នៅក្នុងទីនេះចុះ ពួកខ្ញុំនឹងបដិបត្តិ ព្រះថេរៈសម្តែងអាការថា ពិតជាទៅ កាលប្រកាសនូវការត្រេកអរក្រៃលែងក្នុងវិវេក ដោយអាងដល់លំនៅ ដែលលោកធ្លាប់នៅ ទើបពោល ៤ គាថាថា

កុកមានស្លាបសស្អាត ត្រូវភ័យអំពីមេឃខ្មៅគំរាមហើយ ក៏ស្វែងរកសម្បុក ហើរទៅកាន់សម្បុក ក្នុងកាលណា កាលណោះ ទន្លេឈ្មោះអជករណី ក៏ញុំាងអាត្មាអញឲ្យត្រេកអរ ។ កុកមានស្លាបសស្អាត ត្រូវភ័យអំពីមេឃខ្មៅគំរាមហើយ មិនឃើញទីពួន ក៏ស្វែងរកទីពួន ក្នុងកាលណា កាលណោះ ទន្លេឈ្មោះអជ-ករណី ញុំាងអាត្មាអញឲ្យត្រេកអរ ។

ដើមព្រីងទាំងឡាយ ញុំាងប្រាំងនៃទន្លេទាំង ២ ក្នុងទីនោះ ( ដែលឋិតនៅ ) ខាងក្រោយនៃគុហាធំឲ្យល្អ មិនមែនញុំាង

សត្វណាមួយ ក្នុងទីនោះ ឲ្យត្រេកអរបានទេ ។

កន្លែបទាំងឡាយ មានសំឡេងពីរោះ ប្រាសចាកពួកនៃពស់ រមែងយំកងរំពង ។ ថ្ងៃនេះ មិនមែនជាសម័យនៅប្រាសចាកភ្នំ និងទន្លេទេ ព្រោះទន្លេអជករណី ជាទីក្សេមសប្បាយរីករាយ ដោយប្រពៃ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យទា** បានដល់ ក្នុងកាលណា ។ បទថា **ពលាកា** ប្រែថា កុក ។

បទថា **សុចិបណ្ឌរច្ឆទា** បានដល់ មានរោមសស្អាតបរិសុទ្ធ ។

បទថា **កាឡស្ស មេឃស្ស ភយេន តជ្ជិតា** សេចក្តីថា ត្រូវភ័យអំពីភ្លៀង និងការគំរាមនៃមេឃក្នុងរដូវវស្សាដែលខ្មៅងងឹត ដូចគ្មានទីងភ្នំអញ្ជនខ្មៅ ព្រោះជប់ទឹកគំរាមហើយ ធ្វើឲ្យភ័យខ្លាចហើយ ។

បទថា **បលេហិតិ** សេចក្តីថា ហើរទៅអំពីទីរកស៊ី ។ បទថា **អាលយំ** បានដល់ លំនៅ គឺសម្បុករបស់ខ្លួន ។ បទថា **អាលយេសិនី** សេចក្តីថា ប្រាថ្នានឹងជ្រកកោនក្នុងសម្បុកប៉ុណ្ណោះ ។ បទថា **តទា នទី អជករណី រមេតិ មំ** សេចក្តីថា ក្នុងរដូវភ្លៀងធ្លាក់នោះ ស្ទឹងឈ្មោះអជករណីពេញទៅដោយទឹកថ្មី កួចយកវត្ថុដែលកួចទៅបានអំពីមាត់ច្រាំង រមែងញុំាងខ្ញុំឲ្យត្រេកអរ គឺញុំាងចិត្តរបស់ខ្ញុំឲ្យត្រេកអរ ព្រោះហេតុនោះ ទើបប្រកាសនូវការត្រេកអរក្នុងវិវេក ដោយសម្តែងអាងដល់កាលពិសេសក្នុងរដូវ និងបទេស ។

បទថា **សុវិសុទ្ធបណ្ឌរា** បានដល់ មានពណ៌សស្អាតបរិសុទ្ធ អធិប្បាយ

ថា មានពណ៌មិនលាយឡំ គឺមានពណ៌សសុទ្ធ ។

បទថា **បរិយេសតិ** ប្រែថា រមែងស្វែងរក ។ បទថា **លេណំ** បានដល់ ទីលំនៅ ។ បទថា **អលេណាទស្សិនី** បានដល់ មិនឃើញលំនៅ អធិប្បាយថា ឈ្មោះថា មិនឃើញទីជ្រកកោន ព្រោះកាលមុន មិនមានទីនៅប្រចាំ ឥឡូវនេះ ក្នុងរដូវភ្លៀងធ្លាក់ ត្រូវសេចក្ដីត្រហឹមរបស់មេឃគំរាមទើបត្រូវចេញអំពីសម្បុក ស្វែងរកលំនៅ ព្រោះដូច្នោះ ទើបត្រូវធ្វើសម្បុកសម្រាប់នៅជាប្រចាំ ។

បទថា **កំ នុ តត្ថ ។បេ។ បជ្ជតោ** សេចក្ដីថា ដើមព្រីងទាំងឡាយមានមែកដែលទ្រទ្រង់នូវផ្លែធ្ងន់ចុះ មានស្លឹកជាម្ជប់ត្រជាក់ល្អ អស់កាលជានិច្ច ធ្វើឲ្យប្រាំងទាំងពីរនៃស្ទឹងអជករណី ខាងក្រោយគុហាធំ ដែលជាលំនៅរបស់ខ្ញុំ ស្អាតក្នុងទីនោះ គឺទាំងត្រើយនាយ និងត្រើយអាយ នឹងញុំាងសត្វណាមួយ មិនឲ្យត្រេកអរក្នុងទីនោះហ្ន៎ គឺឲ្យសត្វទាំងពួងត្រេកអរនោះឯង ។

បទថា **តាមតមទសង្ឃសុប្បហីនា** សេចក្ដីថា ពិស លោក ហៅថា **អមត** ពស់ពិសទាំងឡាយសម្បូរដោយពិសនោះ ព្រោះហេតុនោះ ទើបឈ្មោះថា **អមតមទា** បានដល់ ពស់ ពួកនៃពស់ទាំងនោះ ឈ្មោះថា **អមតមទសង្ឃា** បង្កើបលះហើយ គឺប្រាសចាកហើយដោយល្អ អំពីពស់ពិសនោះ ។

កង្កែបទាំងឡាយមានសំឡេងពីរោះ នាំគ្នាយំដោយសំឡេងពីរោះ គឺរមែងធ្វើទីនោះឲ្យជេរជាសដោយសំឡេងដ៏ពីរោះ ។

*បទថា* **ឆាជ្ជ គិរិនទិហិ វិប្បវាសសមយោ** *សេចក្តីថា ថ្ងៃនេះ គឺឥឡូវនេះ មិនជាសម័យដែលប្រាសចាកទឹកដែលធ្លាក់អំពីភ្នំ តែបើពោលដោយពិសេស ស្ទឹងអជករណីមិនមានភ័យ ព្រោះវៀរចាកត្រីកាច និងក្រពើជាដើម ។*

*ឈ្មោះថា* **សិវា** *ព្រោះសម្បូរដោយផ្ទៃដី កំពង់ និងឆ្នេរខ្សាច់ដែលល្អ អធិប្បាយថា គួរត្រេកអរ គួររីករាយនៃចិត្ត ព្រោះដូច្នោះ ចិត្តរបស់ខ្ញុំរមែងត្រេកអរក្នុងទីនោះឯង ។*

*កាលពោលយ៉ាងនេះហើយ ព្រះថេរៈក៏លះនូវញាតិទាំងឡាយ ទៅកាន់លំនៅនៃខ្លួនវិញ ។ ពាក្យដែលជាគាថានេះឯង ជាពាក្យព្យាករអរហត្តផលរបស់ព្រះថេរៈ ព្រោះពោលដល់ការត្រេកអរក្រៃលែងក្នុងសុញ្ញាគារ ដូច្នេះឯង ។*

**អដ្ឋកថា សប្បកត្ថេរគាថា ចប់**

# សុត្តន្តបិដក

## មុទិតត្ថេរគាថា

[ ១៩៨ ] ខ្ញុំត្រូវការចិញ្ចឹមជីវិត បព្វជ្ជាបានឧបសម្បទាហើយ តែតពីនោះមក ក៏ត្រឡប់បាននូវសទ្ធា មានព្យាយាមមាំ ខំប្រឹងប្រែងមាំ ។ កាយនេះចូរបែកធ្លាយចុះ ដុំនៃសាច់ទាំងឡាយ ចូរខ្ចាត់ខ្ចាយទៅចុះ ស្មងទាំងឡាយរបស់ខ្ញុំ ចូររបូតធ្លាក់ចាកតំណនៃជង្គង់ទាំងពីរចុះ ។ កាលបើសរ គឺតណ្ហា មិនទាន់ខ្ចាត់ចេញទេ ខ្ញុំនឹងមិនស៊ី មិនផឹក នឹងមិនចេញអំពីកុដិ ទាំងមិនទម្រេត សូម្បីតែមួយបង្អៀងឡើយ ។ អ្នកចូរមើលសេចក្តីព្យាយាមប្រឹងប្រែងដ៏មាំរបស់ខ្ញុំនោះ កាលនៅយ៉ាងនេះ វិជ្ជា ៣ ខ្ញុំបានដល់ដោយលំដាប់ហើយ សាសនានៃព្រះពុទ្ធ ខ្ញុំក៏បានធ្វើហើយ ។

**មុទិតត្ថេរ**

### ឧទ្ទាន

និយាយអំពីព្រះថេរៈទាំងឡាយ ជាសាវ័កនៃព្រះពុទ្ធ ១០ អង្គនេះ គឺនាគសមាលត្ថេរ ១ ភគុត្ថេរ ១ សភិយត្ថេរ ១ នន្ទកត្ថេរ ១ ជម្ពុកត្ថេរ ១ សេនកត្ថេរ ១ សម្ភូតត្ថេរ ១ រាហុលត្ថេរ ១ ចន្ទនត្ថេរ ១ ។ ព្រះថេរៈ ៣ អង្គទៀត គឺធម្មិកត្ថេរ ១ សប្បកត្ថេរ ១ មុទិតត្ថេរ ១ ឯគាថាមាន ៥២ ចំណែកខាងព្រះថេរៈទាំងអស់ មាន ១៣ អង្គ ។

**ចតុក្កនិបាត ចប់**

# អដ្ឋកថា

## មុទិតត្ថេរគាថា

[ ១៩៨ ] គាថារបស់ព្រះមុទិតត្ថេរ មានពាក្យផ្ដើមថា **បព្វជឹ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមវិបស្សី កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្ដីហើយ ថ្ងៃមួយ ឃើញព្រះសាស្ដា មានចិត្តជ្រះថ្លា បានថ្វាយគ្រែមួយ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលគហបតី ក្នុងកោសលរដ្ឋ មានឈ្មោះថា មុទិតៈ ដល់នូវភាពជាអ្នកដឹងក្ដីហើយ ។ សម័យនោះ ត្រកូលនោះ មានរឿងដែលជាប់ពាក់ព័ន្ធជាមួយព្រះរាជា ។ កុលបុត្តនោះ ខ្លាចចំពោះរាជភ័យ គេចចូលទៅកាន់ព្រៃ ចូលទៅកាន់លំនៅរបស់ព្រះខីណាស្រពមួយរូប ។

ព្រះថេរៈដឹងថា កុលបុត្តនោះខ្លាច ទើបលួងលោមថា អ្នកកុំខ្លាចឡើយ ។ កុលបុត្តសួរថា បពិត្រលោកម្ចាស់ ភ័យរបស់ខ្ញុំនេះ នឹងស្ងប់ដោយកាលមានប្រមាណប៉ុនណាហ្ន៎ កាលព្រះថេរៈពោលថា ៧-៨ ខែ ទើបពោលថា ខ្ញុំមិនអាចនៅសម្ងំអស់កាល មានប្រមាណប៉ុណ្ណោះឡើយ ខ្ញុំនឹងបួស សូមលោកម្ចាស់ឲ្យខ្ញុំបួសចុះ ដូច្នេះហើយ ទើបបួសដើម្បីរក្សាជីវិត ព្រះថេរៈឲ្យ

កុលបុត្តនោះបួសហើយ ។

កាលបួសហើយ កុលបុត្តនោះ ក៏ក្លាយជាអ្នកមានសទ្ធាក្នុងសាសនា ទោះបីភ័យស្ងប់ហើយ ក៏បម្រើនសមណធម៌រឿយៗ រៀនកម្មដ្ឋានហើយ ចម្រើនវិបស្សនា ធ្វើប្តេជ្ញាដោយន័យជាដើមថា បើអាត្មាអញមិនទាន់សម្រេចអរហត្ត នឹងមិនចេញទៅក្រៅបន្ទប់នេះ ហើយបំពេញវិបស្សនា សម្រេចអរហត្ត សមដូចគាថាព័ន្ធដែលលោកពោលក្នុងអបទានថា

ខ្ញុំមានចិត្តជ្រះថ្លា បានថ្វាយបង្គន់មួយដោយដៃរបស់ខ្លួន ចំពោះព្រះមានព្រះភាគ ព្រះនាមវិបស្សីជាច្បងក្នុងលោក ជាតាទិបុគ្គល ។ ខ្ញុំបានយានដំរី យានសេះ យានទិព្វ ហើយបានដល់នូវធម៌ជាទីក្ស័យនៃអាសវៈ ដោយសារការថ្វាយនូវបង្គន់នោះ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយបង្គន់ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយបង្គន់ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

កាលសម្រេចអរហត្តហើយ សោយវិមុត្តិសុខ ត្រូវពួកភិក្ខុជាសម្លាញ់សួរដល់ការដែលលោកសម្រេចធម៌ កាលនឹងសម្តែងកិច្ចបដិបត្តិរបស់ខ្លួន ក៏បានពោល ៤ គាថាថា

ខ្ញុំត្រូវការចិញ្ចឹមជីវិត បព្វជ្ជាបានឧបសម្បទាហើយ តែតពីនោះ

---

១- ក្នុងអបទាន ជាវច្ចកទាយកត្ថេរ ។

មក ក៏ត្រឡប់បាននូវសទ្ធា មានព្យាយាមមាំ ខំប្រឹងប្រែងមាំ ។ កាយនេះ ចូរបែកធ្លាយចុះ ដុំនៃសាច់ទាំងឡាយ ចូរខ្ចាត់ខ្ចាយទៅចុះ ស្មងទាំងឡាយរបស់ខ្ញុំ ចូររបូតធ្លាក់ចាកតំណនៃជង្គង់ទាំងពីរចុះ ។ កាលបើសរ គឺតណ្ហា មិនទាន់ខ្ចាត់ចេញទេ ខ្ញុំនឹងមិនស៊ី មិនផឹក នឹងមិនចេញអំពីកុដិ ទាំងមិនទម្រេត សូម្បីតែមួយបង្អៀងឡើយ ។ អ្នកចូរមើលសេចក្តីព្យាយាម ប្រឹងប្រែងដ៏មាំរបស់ខ្ញុំនោះ កាលនៅយ៉ាងនេះ វិជ្ជា ៣ ខ្ញុំបានដល់ដោយលំដាប់ហើយ សាសនានៃព្រះពុទ្ធ ខ្ញុំក៏បានធ្វើហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ជីវិកត្ថោ** បានដល់ ត្រូវការនឹងរស់នៅ គឺជាអ្នកបានប្រយោជន៍ក្នុងការរស់នៅ អធិប្បាយថា ខ្ញុំបួសដើម្បីចិញ្ចឹមជីវិតយ៉ាងនេះថា អញបួសក្នុងទីនេះ នឹងផុតភ័យ មិនលំបាក រស់នៅដោយសប្បាយ ។ បទថា **លទ្ធាន ឧបសម្បទំ** សេចក្តីថា តាំងនៅក្នុងបព្វជ្ជាជាសាមណេរមុនហើយ បានឧបសម្បទាដោយញត្តិចតុត្ថកម្មជាក្រោយ ។

បទថា **តតោ សទ្ធំ បដិលភឹ** សេចក្តីថា តាំងពីពេលដែលព្រះថេរៈឧបសម្បទាហើយ លោកក៏សេពគប់តែកល្យាណមិត្ត រៀនមាតិកា ២ អនុមោទនា ៣ សូត្រខ្លះៗ សមថកម្មដ្ឋាន និងវិបស្សនាវិធី ឃើញភាពដែលព្រះពុទ្ធមានអានុភាពច្រើន បាននូវសទ្ធាក្នុងព្រះរតនត្រ័យថា ព្រះមានព្រះភាគត្រាស់ដឹងឯងដោយប្រពៃ ។ ព្រះធម៌ដែលទ្រង់ត្រាស់ល្អហើយ ព្រះសង្ឃបដិបត្តិល្អហើយ ។

*បទថា* **ឧឡ្ហវីរិយោ បរក្កមឹ** *សេចក្តីថា ជាអ្នកបាននូវសទ្ធាយ៉ាងនេះហើយ ចម្រើនវិបស្សនា ជាអ្នកមានសេចក្តីព្យាយាមមាំទាំ ដើម្បីចាក់ធ្លុះសច្ចៈ មិនយូរប៉ុន្មានបានតាំងសេចក្តីព្យាយាមដោយប្រពៃ ដើម្បីលះនូវអកុសលធម៌ ដើម្បីញ៉ាំងកុសលធម៌ឲ្យដល់ព្រម ។*

*ដើម្បីសម្តែងការព្យាយាម ទើបពោលពាក្យជាដើមថា* **កាមំ** *ដូច្នេះ ។ បទថា* **កាមំ** *សេចក្តីថា ចូរបែកទៅតាមប្រាថ្នា ឬដោយចំណែកមួយ ។*

*បទថា* **អយំ កាយោ** *សេចក្តីថា កាយស្អុយរបស់ខ្ញុំនេះ បើបែកធ្លាយទៅដោយសេចក្តីព្យាយាមដុតកម្តៅកិលេសនេះ ចូរបែកទៅ គឺចូរបែកធ្លាយទៅ ។ បទថា* **មំសបេសី វិសីយរុំ** *សេចក្តីថា បើចម្រៀកសាច់ក្រៀមទៅអំពីកាយនេះ ដោយការប្រឹងប្រែងនេះ ក៏ចូរក្រៀមស្ងួតចុះ គឺចូរបែកធ្លាយទៅ ដោយជុំវិញចុះ ។*

*បទថា* **ឧភោ ជណ្ណុកសន្ធីហិ ជង្ឃាយោ បបតន្តុ មេ** *សេចក្តីថា ស្មងទាំង ២ របស់ខ្ញុំ មួយអន្លើដោយទីតនៃស្មង ចូរធ្លាក់ទៅត្រង់ផែនដីចុះ បាលីថា* **មំ** *ដូច្នេះក៏មាន បាលីនោះ ក៏មានន័យដូចគ្នា ។ ពាក្យដ៏សេសមានន័យដូចពោលហើយ ខាងដើមនោះឯង ។*

**អដ្ឋកថា មុទិតត្ថេរគាថា ចប់**

**អដ្ឋកថា ចតុក្កនិបាត ចប់**

# សុត្តន្តបិដក

# ថេរគាថា បញ្ចកនិបាត

## រាជទត្តត្ថេរគាថា

[ ១៩៩ ] ភិក្ខុទៅកាន់ទីស្មសាន បានឃើញសាកសពស្ត្រី ដែលគេលះបង់ចោលក្នុងព្រៃស្មសាន ត្រូវពួកជន្តុវរុកជញ្ជែង ស៊ីចុះជ្វាយ ។ ពួកជនខ្លះ ដែលឃើញសាកសពស្លាប់ដ៏លាមក ក៏ខ្ពើមរអើម តែកាមរាគៈកើតឡើងប្រាកដ ( ក្នុងសាកសពនោះ ) ដូចជាបុគ្គលខ្វាក់ អសុចិហូរហៀរ ( តាមទ្វារទាំង ៩ ) ។ តែអាត្មាអញ ចៀសចេញអំពីទីនោះ ថយជាងមួយចំអិនបាយ ជាអ្នកមានស្មារតីដឹងខ្លួន ចូលទៅកាន់ទីសមគួរ ។ លំដាប់នោះ ការធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ក៏កើតឡើងដល់អាត្មាអញ ទោសក៏កើតប្រាកដ ( ដល់អាត្មាអញ ) សេចក្តីនឿយណាយក៏តាំងនៅព្រម ( ក្នុងហឫទ័យនៃអាត្មាអញ ) លំដាប់នោះ ចិត្តរបស់អាត្មាអញ ក៏រួចស្រឡះ ( ចាកកិលេស ) អ្នកចូរមើលនូវភាពនៃធម៌ ជាធម៌ល្អ វិជ្ជាទាំង ៣ អាត្មាអញបានដល់ដោយលំដាប់ហើយ សាសនានៃព្រះពុទ្ធ អាត្មាអញក៏បានធ្វើហើយ ។

*រាជទត្តត្ថេរ*

# អដ្ឋកថា

# បញ្ចកនិបាត

## រាជទត្តត្ថេរគាថា

[ ១៩៩ ] ក្នុងបញ្ចកនិបាត គាថារបស់ព្រះរាជទត្តត្ថេរ មានពាក្យផ្ដើមថា **ភិក្ខុ សីវថិកំ គន្ត្វា** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងកប្បទី ១៤ អំពីភទ្ទកប្បនេះ ជាកប្បដែលមិនមានព្រះពុទ្ធ កុលបុត្តនោះកើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្ដីហើយ ។ ថ្ងៃមួយ ចូលទៅកាន់ព្រៃ ដោយករណីយកិច្ចឯណានីមួយ ឃើញព្រះបច្ចេកពុទ្ធមួយអង្គអង្គុយត្រង់គល់ឈើក្នុងព្រៃនោះ មានចិត្តជ្រះថ្លា ប្រគេនផ្លែម្កាក់ដែលរលោងល្អមួយផ្លែ ។

ដោយបុញ្ញកម្មនោះ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលនៃឈ្មួញរទេះ ក្នុងក្រុងសាវត្ថី មាតាបិតាបានដាក់ឈ្មោះឲ្យថា រាជទត្ត ព្រោះសូម ( បន់ស្រន់ ) ព្រះបាទវេស្សវ័ណ-មហារាជបានមក ។

កុលបុត្តនោះចម្រើនវ័យហើយ យករទេះ ៥០០ ដាក់ទំនិញ ទៅកាន់

នគររាជគ្រឹះ ធ្វើការលក់ដូរ ។

សម័យនោះ ស្រីគណិកាម្នាក់ក្នុងក្រុងរាជគ្រឹះ មានរូបស្អាត គួរមើល គួរសរសើរ ព្រោះប្រកបដោយសម្រស់ដ៏ក្រៃលែង បានទ្រព្យមួយថ្ងៃមួយពាន់ ។ គ្រានោះ ពាណិជ្ជបុត្តបានឲ្យទ្រព្យ ១០០០ ដល់ស្រីនោះ រាល់ៗថ្ងៃ សម្រេចការនៅរួមគ្នា មិនយូរប៉ុន្មាន ទ្រព្យទាំងអស់ក៏អស់ទៅ ធ្លាក់ខ្លួនក្រ មិនមានសូម្បីត្រឹមតែអាហារ និងសម្លៀកបំពាក់ ត្រាច់ទៅកាន់ទីផ្សេងៗដល់នូវសេចក្តីសង្វេគហើយ ។ ថ្ងៃមួយ ទៅកាន់វត្តវេឡុវនមហាវិហារ ព្រមនឹងឧបាសកទាំងឡាយ ។

សម័យនោះ ព្រះសាស្តាចោមរោមដោយបរិស័ទជាច្រើន គង់សម្តែងធម៌ កុលបុត្តនោះ អង្គុយខាងចុងបរិស័ទ ស្តាប់ធម៌ក្នុងសម្នាក់ព្រះសាស្តាបាននូវសទ្ធា បួសហើយ សមាទានធុតង្គនៅក្នុងព្រៃ ។ ក្នុងកាលនោះពាណិជ្ជបុត្តម្នាក់បានឲ្យទ្រព្យ ១០០០ ហើយនៅរួមជាមួយស្រីគណិកានោះស្រីនោះឃើញរតនៈមានតម្លៃច្រើន ក្នុងដៃរបស់ពាណិជ្ជបុត្តនោះ មានចិត្តចង់បាន ទើបឲ្យអ្នកលេងជទៃសម្លាប់ ហើយកាន់យករតនៈនោះ ។ លំដាប់នោះពួកមនុស្សដឹងរឿងនោះរបស់ពាណិជ្ជបុត្តនោះហើយ ក៏បញ្ជូនអ្នកស៊ើបការទៅ ចារបុរសទាំងនោះចូលទៅកាន់ផ្ទះស្រីនោះក្នុងរាត្រី នាំគ្នាសម្លាប់ស្រីនោះឲ្យស្លាប់ ដោយមិនធ្វើឲ្យស្នៀករលាត់ បោះចោលក្នុងព្រៃខ្មោច ។

ព្រះរាជទត្តត្ថេរ និមន្តទៅក្នុងព្រៃខ្មោច ដើម្បីកាន់យកអសុភនិមិត្ត ចូលទៅធ្វើទុកក្នុងចិត្តនូវសាកសពរបស់ស្រីគណិកានោះ ដោយជារបស់បដិកូល

ធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា អស់វារៈបន្តិចបន្តួច ធ្វើទុកក្នុងចិត្តដោយមិនមែនឧបាយប្រាជ្ញា ធ្វើឲ្យកើតកាមរាគៈក្នុងសរីរៈនោះ ព្រោះជាសាកសពដែលស្លាប់មិនទាន់យូរ ១ ព្រោះស្បែកមិនទាន់ត្រូវឆ្កែស្រុក និងឆ្កែចចកកកេរស៊ី ១ ព្រោះជាទីតាំងនៃអារម្មណ៍ដែលជាសត្រូវ គឺមានភេទដូចគ្នា ១ ព្រះថេរៈមានចិត្តសង្វេគក្រៃលែង ទើបគំរាមចិត្តរបស់ខ្លួន គេចទៅក្នុងចំណែកម្ខាងមួយអន្ទាន់ស្លាប ហើយកាន់យកចំពោះអសុភនិមិត្ត ដែលប្រាកដខាងដើម ធ្វើទុកក្នុងចិត្តដោយឧបាយ ធ្វើឈានឲ្យកើតឡើង ធ្វើឈាននោះឲ្យជាបាទ ផ្តើមតាំងវិបស្សនា សម្រេចអរហត្តខណៈនោះឯង សមដូចគាថាព័ន្ធដែលលោកពោលក្នុងអបទានថា

ខ្ញុំបានឃើញព្រះសម្ពុទ្ធ ជាព្រះសយម្ភូ គង់នៅក្នុងព្រៃធំ ព្រះអង្គទ្រង់ឈ្នះកិលេសមារ ហើយយកផ្លែម្កាក់ទៅថ្វាយព្រះសយម្ភូ ។
ក្នុងកប្បទី ៣១ អំពីភទ្ទកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែម្កាក់ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយផ្លែម្កាក់ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

កាលលោកសម្រេចអរហត្តហើយ ពិចារណាកិច្ចបដិបត្តិរបស់ខ្លួន កើតបីតិសោមនស្ស បានពោល ៥ គាថាថា

ភិក្ខុទៅកាន់ទីស្មសាន បានឃើញសាកសពស្ត្រី ដែលគេលះបង់

---

១- ក្នុងអបទានជា អម្ពាដកទាយកត្ថេរ ។

បោលក្នុងព្រៃស្មសាន ត្រូវពួកជន្ធូវុកជញ្ជែង ស៊ីផុះផ្លាយ ។ ពួកជនខ្វះ ដែលឃើញសាកសពស្លាប់ដ៏លាមក ក៏ខ្ពើមរអើម តែកាមរាគៈកើតឡើងប្រាកដ ( ក្នុងសាកសពនោះ ) ដូចជាបុគ្គលខ្វាក់ អសុចិហូរហៀរ ( តាមទ្វារទាំង ៩ ) ។ តែអាត្មាអញចៀសចេញអំពីទីនោះ ថយជាងមួយចម្អិនបាយ ជាអ្នកមានស្មារតី ដឹងខ្លួន ចូលទៅកាន់ទីសមគួរ ។ លំដាប់នោះ ការធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ក៏កើតឡើងដល់អាត្មាអញ ទោសក៏កើតប្រាកដ ( ដល់អាត្មាអញ ) សេចក្តីនឿយណាយ ក៏តាំងនៅព្រម ( ក្នុងហឫទ័យនៃអាត្មាអញ ) លំដាប់នោះ ចិត្តរបស់អាត្មាអញ ក៏រួចស្រឡះ ( ចាកកិលេស ) អ្នកចូរមើលនូវភាពនៃធម៌ជាធម៌ល្អ វិជ្ជាទាំង ៣ អាត្មាអញបានដល់ដោយលំដាប់ហើយ សាសនានៃព្រះពុទ្ធ អាត្មាអញក៏បានធ្វើហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ភិក្ខុ សិវថិកំ គន្ត្វា** សេចក្តីថា ឈ្មោះថាភិក្ខុ ព្រោះឃើញភ័យក្នុងសង្សារ ចូលទៅកាន់ព្រៃខ្មោចស្រស់ ដើម្បីអសុភកម្មដ្ឋាន ។

ពាក្យថា **ភិក្ខុ** នេះ ព្រះថេរៈសំដៅយកខ្លួនឯង ។ គប្បីជ្រាបវិគ្គហៈក្នុងបទថា **ឥត្ថិ** ដូចតទៅនេះ មាតុគ្រាម ឈ្មោះថា **ឥ** ព្រោះជាទីតាំង គឺជាទីសន្សំសុក្កៈ ( ទឹកកាម ) និងឈាម ដោយការៈជាទីឲ្យសត្វបន្តកំណើត **ឥ** នោះឯង ហៅថា **ឥត្ថី** ក៏បាន តាមលក្ខណៈរបស់ភាសា ។ មួយវិញទៀត

ក្នុងបណ្តាស្រី មានស្រីអារជាដើម ក៏ហៅថា ស្រី ព្រោះដូចគ្នានឹងស្រីនោះ និងព្រោះមិនកន្លងសភាវៈជាស្រីទៅបាន ដោយបទថា **ឥត្ថី** នេះ ព្រះថេរៈពោលដល់សាកសពស្រី ។

បទថា **ឧជ្ឈិតំ** បានដល់ ដែលគេបោះបង់ហើយ គឺដែលគេបោះចោលហើយ ព្រោះជាវត្ថុដែលគួរបោះចោលនោះឯង បានដល់ ដែលគេចោលហើយ ដោយភាវៈដែលមិនមានសេចក្តីអាល័យ ។

បទថា **ខជ្ជន្តី កិមិហី ផុដំ** សេចក្តីថា ជារបស់ពេញទៅដោយពួកដង្កូវរួងជញ្ជក់ ។

បទថា **យំ ហិ ឯកេ ជិគុច្ឆន្តិ មតំ ទិស្វាន ចាបកំ** សេចក្តីថា ជាអ្នកមាននិស្ស័យស្រឡាញ់ការស្អាត រមែងខ្ពើម មិនប្រាថ្នានឹងមើលសាកសពដែលជារបស់អាក្រក់ ថោកថយ លាមក ព្រោះប្រាសចាកអាយុ ភ្លើងធាតុនិងវិញ្ញាណ ។

បទថា **កាមរាគោ ចាតុរហុ** សេចក្តីថា កាមរាគៈបានប្រាកដ គឺបានកើតដល់ខ្ញុំហើយ ព្រោះមិនមានការដាក់ចិត្តដោយឧបាយប្រាជ្ញា ក្នុងសាកសពនោះ ។

បទថា **អន្ធោវ សវតី អហុ** សេចក្តីថា របស់ដែលមិនស្អាតហូរចេញអំពីទ្វារទាំង ៩ ក្នុងសាកសពនោះ កាលសាកសពកំពុងហូរ ខ្ញុំក៏ដូចបុគ្គលខ្វាក់ ព្រោះមិនឃើញរបស់មិនស្អាត ដោយហេតុនោះ ទើបលោកពោលថា

បុគ្គលប្រកបដោយតម្រេក រមែងមិនដឹងអត្ថ បុគ្គលប្រកប

ដោយតម្រេក រមែងមិនឃើញធម៌ តម្រេកគ្របសង្កត់ជនក្នុងកាល

ណា ងងឹត រមែងមានក្នុងកាលនោះ ដូច្នេះ ។

និងថា នែព្រាហ្មណ៍ កាមច្ឆន្ទៈ ធ្វើឲ្យបុគ្គលខ្វាក់ និងធ្វើឲ្យបុគ្គលមិនមានចក្ខុ ដូច្នេះជាដើម តែក្នុងទីនេះ អាចារ្យពួកខ្លះ ចុះ **ត** អក្ខរៈអាគម ហើយពោលពាក្យអធិប្បាយថា មិនប្រព្រឹត្តទៅក្នុងអំណាច ព្រោះត្រូវកិលេសចោមរោម ឬប្រព្រឹត្តទៅក្នុងអំណាចនៃកិលេស ។ អាចារ្យពួកខ្លះពោលបាលីថា **អន្ធោវ អសតិ អហុ** ខ្ញុំដូចមនុស្សខ្វាក់ ព្រោះមិនមានសតិ និងព្រោះប្រកបដោយកាមរាគៈ តែពាក្យទាំង ២ មិនមានក្នុងបាលី ។

បទថា **ឱរំ ឱគណចារកម្ហា** សេចក្តីថា ក្នុងវេលាដាំបាយឆ្អិនម្តង គឺក្នុងវេលាចាក់អង្ករចេញពីនាឡិ ផ្ទុំហើយឆ្អិនដោយប្រើពេលប៉ុនណា កាលបន្ទោបង់នូវរាគៈ ខ្ញុំក៏ចៀសចេញអំពីទីនោះ ដោយប្រើពេលរហ័សជាងនោះបន្តិចបន្តួច ។ រាគៈកើតឡើងហើយដល់ខ្ញុំ ដែលឈរក្នុងទីណា ខ្ញុំចៀសទៅ គឺគេចចេញទៅអំពីទីនោះ ។ ខ្ញុំចៀសទៅ មានសតិសម្បជញ្ញៈ ចូលទៅតាំងសមណសញ្ញា ឈ្មោះថា មានសតិ ដោយមនសិការដល់សតិប្បដ្ឋាន និងជាបុគ្គលឈ្មោះថា មានសម្បជញ្ញៈ ព្រោះដឹងសភាវៈនៃធម៌ដោយប្រពៃនោះឯង ចូលទៅកាន់ទីសមគួរនាចំណែកម្ខាង បានអង្គុយចូលសមាធិ ។ កាលខ្ញុំអង្គុយហើយ បន្ទាប់ពីនោះ យោនិសោមនសិការកើតឡើងដល់ខ្ញុំហើយ ។ បទថា **តតោ មេ មនសីការោ យោនិសោ ឧទបជ្ជថ** ដូច្នេះជាដើម មានន័យដូចពោលមកហើយនោះឯង ៕

# សុត្តន្តបិដក

## សុភាសិតត្ថេរគាថា

[ ២០០ ] បុរសអ្នកប្រាថ្នានូវកិច្ចប្រកបខ្លួន ក្នុងអំពើដែលមិនគួរប្រកប ប្រសិនបើត្រាច់ទៅ មិនគប្បីបាន ( នូវប្រយោជន៍នោះទេ ) នោះឯង ជាលក្ខណៈនៃចំណែកខាងអាក្រក់ ។

ការដែលរស់នៅដោយលំបាក អាត្មាអញបានដកចោលហើយ បើបុគ្គលណា លះបង់ធម៌យ៉ាងឯក គឺអប្បមាទ បុគ្គលនោះ ទុកដូចជាមនុស្សចង្រៃ ម្យ៉ាងទៀត បើបុគ្គលណា លះបង់នូវឥន្ទ្រិយទាំងអស់ ( សទ្ធា វិរិយៈ សតិ សមាធិ បញ្ញា ) បុគ្គលនោះ ទុកដូចជាមនុស្សខ្វាក់ ព្រោះមិនឃើញនូវរបស់ដែលស្មើគ្នា និងមិនស្មើគ្នា ។

ពិតណាស់ បុគ្គលធ្វើអំពើណា ត្រូវនិយាយចំពោះតែអំពើនោះ មិនធ្វើនូវអំពើណា មិនត្រូវនិយាយចំពោះអំពើនោះទេ បណ្ឌិតទាំងឡាយ តែងកំណត់ដឹងនូវបុគ្គលអ្នកមិនធ្វើ បានតែនិយាយ ។ ផ្កាដ៏រុងរឿង មានពណ៌ល្អ តែមិនមានក្លិនក្រអូប យ៉ាងណា វាចាជាសុភាសិត រមែងឥតផលដល់បុគ្គលអ្នកមិនធ្វើតាម ក៏យ៉ាងនោះដែរ ។ ផ្កាដ៏រុងរឿង មានពណ៌ល្អ ប្រកបដោយក្លិនក្រអូប យ៉ាងណា វាចាជាសុភាសិត រមែងមានផលដល់បុគ្គលអ្នកធ្វើតាម ក៏យ៉ាងនោះដែរ ។

សុភូទត្ថេរ

# អដ្ឋកថា

## សុភូតត្ថេរគាថា

[ ២០០ ] គាថារបស់ព្រះសុភូតត្ថេរ មានពាក្យផ្ដើមថា **អយោគេ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមកស្សបៈ កើតក្នុងត្រកូលគហបតីមហាសាល ក្នុងក្រុងពារាណសី ដល់នូវភាពជាអ្នកដឹងក្ដីហើយ ថ្ងៃមួយស្ដាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្ដា មានចិត្តជ្រះថ្លា តាំងនៅក្នុងសរណៈនិងសីល បានលាបព្រះគន្ធកុដិដោយគន្ធជាតិ ៤ យ៉ាង ក្នុងមួយខែ ៨ ដងរាល់ខែ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះមានរាងកាយក្រអូប ក្នុងទីដែលកើតហើយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលគហបតី ក្នុងមគធរដ្ឋ មានឈ្មោះថា **សុភូតៈ** ចម្រើនវ័យហើយ លះឃរាវាស ព្រោះភាពដែលខ្លួនមានអធ្យាស្រ័យក្នុងការរលាស់ចេញចាកទុក្ខ ទើបបួសក្នុងសម្នាក់តិរ្ថិយ កាលមិនបានវត្ថុដែលជាសារៈក្នុងលទ្ធិនោះ ឃើញសមណព្រាហ្មណ៍ជាច្រើន មានឧបតិស្សៈ កោលិតៈ និងសេលៈជាដើម បួសក្នុងសម្នាក់ព្រះសាស្ដា សោយសុខក្នុងភាពជាសមណៈ បាននូវសទ្ធាក្នុងព្រះសាសនា បួសហើយ ឲ្យអាចារ្យ និងឧបជ្ឈាយ៍ត្រេកអរ រៀនកម្មដ្ឋាន នៅដោយវិវេក ចម្រើនវិបស្សនា បានសម្រេចអរហត្ត សមដូចគាថាព័ន្ធដែលលោកពោលក្នុងអបទានថា

ក្នុងកប្បនេះ ព្រះសម្ពុទ្ធព្រះនាមកស្សបៈ មានផៅពង្សដ៏ប្រសើរ មានយសធំ ទ្រង់ប្រសើរជាងអ្នកប្រាជ្ញទាំងឡាយ ទ្រង់កើតឡើងហើយ ។ ព្រះអង្គប្រកបដោយអនុព្យញ្ជនៈ មានលក្ខណៈដ៏ប្រសើរ ៣២ ប្រការ មានពន្លឺមួយព្យាមជុំវិញ ព្រោងព្រាតដោយបណ្តាញគឺរស្មី ។ ព្រះអង្គញុាំងលោកឲ្យត្រេកអរ ដូចជាព្រះចន្ទ ទ្រង់ធ្វើនូវពន្លឺ ដូចជាព្រះអាទិត្យ ទ្រង់រម្ងត់ទុក្ខ ដូចជាភ្លៀង ទ្រង់ជាអណ្តូងនៃគុណ ដូចជាសាគរ ។ ព្រះអង្គមានសីល ដូចជាធរណី មានសមាធិ ដូចជាភ្នំហិមពាន្ត មានបញ្ញា ដូចជាអាកាស មិនមានអ្វីទើស ដូចខ្យល់ ។ កាលនោះ ខ្ញុំកើតក្នុងមហាត្រកូលមានទ្រព្យនិងស្រូវច្រើន សន្សំរតនៈផ្សេងៗ ក្នុងក្រុងពារាណសី ។ ខ្ញុំចូលទៅរកព្រះលោកនាយក ដែលគង់នៅដោយបរិវារច្រើន បានស្តាប់អមតធម៌ដ៏គួរជល់ចិត្ត ។ ព្រះអង្គទ្រទ្រង់លក្ខណៈ ៣២ ប្រការ ដូចជាព្រះចន្ទ មាននក្ខត្តឫក្សដ៏ល្អ ទ្រង់បរិបូណ៌ដោយអនុព្យញ្ជនៈ ដូចជាដើមសាលរាជ មានផ្ការីក ។ ទ្រង់មានបណ្តាញគឺរស្មីបិទបាំង ដូចជាមាសមិនប្រែពណ៌ដែលជាងមាសដុតហើយ មានពន្លឺមួយព្យាមផ្សាយជុំវិញ ដូចជាព្រះអាទិត្យមានរស្មីដ៏ច្រើន ។ ព្រះជិនស្រីប្រសើរ មានព្រះភក្ត្រដូចមាស ឬដូចជាភ្នំ ជាទីរីករាយ មានព្រះហឫទ័យពេញដោយករុណា ( ប្រកប ) ដោយគុណ ដូចជាសាគរ ។ មានកេត្តិ៍ឈ្មោះល្បីល្បាញក្នុងលោក ដូចជាភ្នំដ៏ឧត្តម

ឈ្មោះសិនេរុ ទ្រង់ជាអ្នកប្រាជ្ញផ្សាយចេញទៅដោយយស ជាមុនី ដូចជាអាកាស ។ ព្រះលោកនាយក មានព្រះហឫទ័យមិនជាប់ជំពាក់ក្នុងទីទាំងពួង ដូចជាខ្យល់ ជាមុនីទី ៧ ជាទីពឹងរបស់ពួកសត្វទាំងអស់ ដូចជាផែនដី ។ ព្រះអង្គមិនប្រឡាក់ដោយលោក ដូចជាផ្កាឈូកមិនទទឹកដោយទឹក ទ្រង់រុងរឿងដូចជាគំនរភ្លើងឆេះគុម្ពកុរាទៈ ។ ទ្រង់ញ៉ាំងពិស គឺកិលេស ឲ្យវិនាសក្នុងទីទាំងពួង ដូចជាឱសថ ទ្រង់ស្អិតស្អាងគ្រឿងក្រអូប គឺគុណ ដូចជាភ្នំគន្ធមាទនៈ ។ ព្រះអង្គជាអ្នកប្រាជ្ញ ជាអណ្តូងនៃគុណទាំងឡាយ ដូចជាសាគរ ជាទីកើតនៃរតនៈទាំងឡាយ ព្រះអង្គជាអាជានេយ្យនៃនរជន ទ្រង់នាំចេញនូវមន្ទិល គឺកិលេស ដូចជាស្ទឹងសិន្ធុ ។ ព្រះអង្គញាំញីនូវមារ និងសេនានៃមារ ដូចជាមហាយោធាធំ ឈ្នះ ( នូវបច្ចាមិត្ត ) ជាឥស្សរៈដោយរតនៈ គឺពោជ្ឈង្គ ដូចជាស្តេចចក្រពត្តិ ។ ព្រះអង្គជាពេទ្យរក្សានូវព្យាធិ គឺទោសៈ ដូចជាគ្រូពេទ្យដ៏ធំ ព្រះអង្គវះនូវពក គឺទិដ្ឋិ ដូចជាគ្រូពេទ្យវះដ៏ប្រសើរ ។ កាលនោះឯង ព្រះជិនស្រី ព្រះអង្គជាពន្លឺរបស់លោក ទេវតា និងមនុស្សធ្វើសក្ការៈហើយ ជាព្រះអាទិត្យរបស់នរៈ ទ្រង់សម្តែងធម៌ក្នុងពួកបរិស័ទ ។ ព្រះអង្គទ្រង់ទូន្មានប្រៀនប្រដៅថា បុគ្គលមានភោគៈច្រើន ព្រោះឲ្យទាន ទៅកើតសុគតិ ព្រោះសីល បានព្រះនិព្វាន ព្រោះភាវនា ។ ពួកបរិស័ទទាំងអស់ ស្តាប់នូវទេសនា

នោះ ដែលមានអានិសង្សធំ មានលម្អខាងដើម កណ្តាល និង ខាងចុង ដូចជាអមតធម៌ មានរសដ៏ធំ ។ លុះខ្ញុំស្តាប់នូវធម៌ ដែល មានរសផ្អែមល្ហែមហើយ ក៏ជ្រះថ្លាក្នុងសាសនាព្រះជិនស្រី ដល់ នូវព្រះសុគតជាទីពឹង នមស្ការជាបដល់អស់ជីវិត ។ កាលនោះ ខ្ញុំលាបនូវគន្ធកុដិរបស់ព្រះមុនី ដោយក្លិនក្រអូបមានជាតិ ៤ អស់ ៨ ថ្ងៃ ក្នុងមួយខែ ហើយតម្កល់ទុកនូវគ្រឿងក្រអូបនោះ ដើម្បី សរីរៈដែលមិនមានក្លិនក្រអូប ។

កាលនោះ ព្រះជិនស្រីសម្ពុទ្ធ ទ្រង់ទំនាយនូវការបានខ្លួនមាន ក្លិនក្រអូបថា បុគ្គលណាបានលាបនូវគន្ធកុដិ ដោយក្លិនក្រអូបអស់ វារៈម្តង ព្រោះតែវិបាកនៃកុសលកម្មនោះ បុគ្គលនោះលុះកើតក្នុង ទីណាក៏ដោយ នឹងមានរាងកាយ មានក្លិនក្រអូបក្នុងទីទាំងពួង ជា អ្នកប្រកបដោយក្លិន គឺសីលគុណ មិនមានអាសវៈ នឹងបរិនិព្វាន ។ ដោយកុសលកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់នូវចេតនា នោះផង លុះខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ ក៏បានទៅ កើតក្នុងឋានតាវត្តិង្ស ។ ឥឡូវនេះ ដល់មកបច្ឆិមភព ខ្ញុំបានមក កើតក្នុងត្រកូលព្រាហ្មណ៍ កាលខ្ញុំនៅក្នុងផ្ទៃនៃមាតា មាតា ( របស់ ខ្ញុំ ) ជាស្រីមានកាយក្លិនក្រអូប ។ កាលណា ខ្ញុំចេញចាកផ្ទៃនៃ មាតា កាលនោះ ក្រុងសាវត្ថី ផ្សាយចេញដោយគ្រឿងក្រអូប ទាំងពួង ហាក់ដូចជាគេអប់ ។ ភ្លៀងជាវិការនៃផ្កាក្រអូប មានក្លិន

ដូចជាក្លិនទិព្វ ជាទីរីករាយនៃចិត្តផង ធូបទាំងឡាយមានថ្លៃដ៏ច្រើនផង ក៏ផ្សាយចេញក្នុងខណៈនោះ ។ ខ្ញុំកើតក្នុងផ្ទះណា ទេវតាទាំងឡាយ អប់នូវផ្ទះនោះ ដោយគ្រឿងក្រអូបទាំងពួងផង ដោយធូប និងផ្កាទាំងឡាយផង ដោយក្លិនទិព្វផង ។ កាលណា ខ្ញុំនៅក្មេង កំពុងចម្រើន ឋិតនៅក្នុងបឋមវ័យ កាលនោះ ព្រះនរសារថី ទ្រង់ទូន្មាននូវជនដ៏សេស ព្រមទាំងបរិស័ទ ។ ព្រះអង្គប្រកបដោយបរិស័ទទាំងឡាយទាំងពួងនោះ ស្តេចមកកាន់ក្រុងសាវត្ថី កាលនោះ ខ្ញុំបានឃើញនូវអានុភាពនៃព្រះពុទ្ធនោះហើយ ក៏បួស ។ ខ្ញុំអប់រំធម៌ដ៏ប្រសើរទាំង ៤ គឺសីល សមាធិ បញ្ញា និងវិមុត្តិ ហើយបានដល់នូវការអស់ទៅនៃអាសវៈ ។ ខ្ញុំបួសក្នុងកាលណាផង ខ្ញុំបានជាព្រះអរហន្តក្នុងកាលណាផង ខ្ញុំបរិនិព្វានក្នុងកាលណាផង ភ្លៀងមានក្លិនក្រអូប ក៏បង្អុរចុះក្នុងកាលនោះៗ ។

ក្លិនរបស់សរីរៈខ្ញុំ ជាក្លិនដ៏ប្រសើរ គ្របសង្កត់នូវក្លិននៃ
ខ្លឹមចន្ទន៍ ផ្កាចម្ប៉ា និងផ្កាឧប្បលមានថ្លៃច្រើន ម្យ៉ាងទៀត
ខ្ញុំទៅក្នុងទីណាក៏ដោយ តែងផ្សាយក្លិនក្រអូប គ្រប
សង្កត់នូវក្លិនដទៃដោយសព្វគ្រប់ ។

កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

---

១- ក្នុងអបទានជា ចូឡសុគន្ធត្ថេរ ។

កាលសម្រេចអរហត្តហើយ គិតដល់ទុក្ខ គឺអត្តកិលមថានុយោគដែលខ្លួនបានទទួលក្នុងកាលបួសក្នុងពួកតិរ្ថិយ និងសុខដែលកើតអំពីឈានជាដើមដែលខ្លួនបានទទួលកាលបួសក្នុងសាសនា កាលនឹងព្យាករអរហត្តផលដោយលើកយកការពិចារណាបដិបទារបស់ខ្លួន បានពោលគាថាទាំង ៥ ថា

បុរសអ្នកប្រាថ្នានូវកិច្ច ប្រកបខ្លួន ក្នុងអំពើដែលមិនគួរប្រកប
ប្រសិនបើត្រាច់ទៅ មិនគប្បីបាន ( នូវប្រយោជន៍នោះទេ )
នោះឯង ជាលក្ខណៈនៃចំណែកខាងអាក្រក់ ។

ការដែលរស់នៅដោយលំបាក អាត្មាអញបានដកចោលហើយ បើ
បុគ្គលណា លះបង់ធម៌យ៉ាងឯក គឺអប្បមាទ បុគ្គលនោះ ទុក
ដូចជាមនុស្សចង្រៃ ម្យ៉ាងទៀត បើបុគ្គលណា លះបង់នូវឥន្ទ្រិយ
ទាំងអស់ ( សទ្ធា វិរិយៈ សតិ សមាធិ បញ្ញា ) បុគ្គលនោះ
ទុកដូចជាមនុស្សខ្វាក់ ព្រោះមិនឃើញនូវរបស់ដែលស្មើគ្នា និង
មិនស្មើគ្នា ។

ពិតណាស់ បុគ្គលធ្វើអំពើណា ត្រូវនិយាយចំពោះតែអំពើ
នោះ មិនធ្វើនូវអំពើណា មិនត្រូវនិយាយចំពោះអំពើនោះទេ
បណ្ឌិតទាំងឡាយ តែងកំណត់ដឹង នូវបុគ្គលអ្នកមិនធ្វើ បានតែ
និយាយ ។ ផ្កាដ៏រុងរឿង មានពណ៌ល្អ តែមិនមានក្លិនក្រអូប
យ៉ាងណា វាចាជាសុភាសិត រមែងឥតផលដល់បុគ្គលអ្នកមិនធ្វើ
តាម ក៏យ៉ាងនោះដែរ ។ ផ្កាដ៏រុងរឿង មានពណ៌ល្អ ប្រកបដោយ

ក្ខិនក្រអូប យ៉ាងណា វាចាជាសុភាសិត រមែងមានផល ដល់បុគ្គលអ្នកធ្វើតាម ក៏យ៉ាងនោះដែរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អយោគេ** បានដល់ ក្នុងទីបំផុត ២ យ៉ាង ដែលមិនគួរប្រកប គឺមិនគួរសេព តែក្នុងទីនេះ គប្បីជ្រាបអត្ថដោយអំណាចនៃអត្តកិលមថានុយោគ ប្រកបរឿយៗ ក្នុងការទូន្មានខ្លួន ។

បទថា **យុញ្ជំ** សេចក្តីថា ប្រកបខ្លួន គឺធ្វើខ្លួនឲ្យប្រកបក្នុងទីបំផុត ២ យ៉ាងនោះ គឺបដិបត្តិយ៉ាងនោះ ។

បទថា **កិច្ចមិច្ឆកោ** សេចក្តីថា ប្រាថ្នាកិច្ចដែលនាំប្រយោជន៍ទាំង ២ មកឲ្យ បើគប្បីប្រព្រឹត្តក្នុងកិច្ចមិនគួរប្រកប ដោយជាបដិបក្ខចំពោះកិច្ចដែលគួរប្រកបនោះសោត ។

បទថា **នាធិគច្ឆេយ្យ** អធិប្បាយថា មិនសម្រេចហិតសុខតាមដែលបំណង ព្រោះហេតុនោះ ខ្ញុំត្រូវបោកបញ្ឆោតដោយមតិរបស់ពួកតិរ្ថិយ ទើបប្រកបក្នុងវត្ថុដែលមិនគួរប្រកបនោះ ជាលក្ខណៈនៃចំណែកខាងអាក្រក់ គឺជាសភាពមិនមែនបុណ្យរបស់ខ្ញុំ ព្រះថេរៈសម្តែងថា ខ្ញុំវង្វេងព្រោះកម្មចាស់ ទើបប្រកបក្នុងវត្ថុមិនគួរប្រកប ។

បទថា **អព្ពូឡ្ហំ អឃគតំ វិជិតំ**[1] សេចក្តីថា កិលេស មានរាគៈជាដើម ឈ្មោះថា **អឃ** ( កិលេសដែលធ្វើឲ្យលំបាក ) ព្រោះមានការបៀតបៀនជាសភាវៈ **អឃ** នោះឯង ជា **អឃគត** ។ ដែននៃកិលេសដែលធ្វើឲ្យ

---

១- បិដកខ្មែរជា ជីវិតំ ។

លំបាក គឺការប្រព្រឹត្តទៅក្នុងសង្សារ ។ ការយកឈ្មោះកិលេស ដែលធ្វើឲ្យលំបាកទាំងនោះ ជាការសោយកុសលធម៌[១] ព្រះថេរៈពោល **អយតតំ វិជិតំ** ព្រោះមិនលុបនិគ្គហិត អធិប្បាយថា បុគ្គលណាមិនទាន់លះអយៈបាន បុគ្គលនោះក៏រស់នៅយ៉ាងនោះ គឺដកកិលេសមិនបាន ព្រោះធ្វើកិលេសដែលធ្វើឲ្យលំបាក ដែលលះមិនបាននោះឲ្យជាដែន ។

បទថា **ឯកកោ ឱស្សជ្ជេយ្យ** សេចក្តីថា បើលះ គឺលះនូវធម៌ដែលឈ្មោះថា **ឯក** ព្រោះមិនមានពីរ និងព្រោះជាធំ ដែលបានដល់ លះនូវសេចក្តីមិនប្រមាទ ម្យ៉ាងទៀត លះនូវសេចក្តីព្យាយាមប្រពៃ បុគ្គលនោះគប្បីដូចជាបុគ្គលខ្មៅ គឺបុគ្គលកាឡកិណី ។

បទថា **សព្វានិបិ ចេ ឱស្សជ្ជេយ្យ** សេចក្តីថា បើបុគ្គលនោះលះបង់សទ្ធិន្ទ្រិយ វិរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ និងបញ្ញិន្ទ្រិយ ដែលបន្ទុំដោយវិមុត្តិទាំងអស់ គឺបើលះបង់ដោយការមិនអប់រំ បុគ្គលនោះគប្បីដូចជាមនុស្សខ្វាក់ ព្រោះមិនឃើញធម៌ដែលស្ងប់ និងធម៌ដែលមិនស្ងប់ ។

សព្ទថា **យថា** ជានិបាត ប្រើក្នុងអត្ថប្រៀបធៀប ។ បទថា **រុចិរំ** ប្រែថា ស្អាត ។ បទថា **វណ្ណវន្តំ** បានដល់ បរិបូណ៌ដោយពណ៌ និងសណ្ឋាន ។

បទថា **អគន្ធកំ** បានដល់ ប្រាសចាកក្លិន មានផ្កាចារ ផ្កាអញ្ចាន់ខៀវ និងផ្កាជយព្រឹក្សជាដើម ។

---

១- ប្រែមកពីបាលីថា កុសលា ធម្មា ភិកវោ ។

បទថា **ឯវំ សុភាសិតា វាចា** សេចក្តីថា ពុទ្ធវចនៈ គឺបិដក ៣ ឈ្មោះថា វាចាសុភាសិត ដែលដូចគ្នានឹងផ្កា សម្បូរដោយពណ៌ និងសណ្ឋាន ។ ក្លិនរមែងមិនផ្សាយទៅក្នុងសរីរៈនៃបុគ្គលដែលទ្រទ្រង់នូវផ្កា ដែលមិនមានក្លិន យ៉ាងណា ពុទ្ធវចនៈក៏ដូច្នោះ បុគ្គលណា មិនប្រព្រឹត្តស្មើ ដោយកិច្ច មានការស្តាប់ដោយគោរពជាដើម រមែងមិននាំមកនូវក្លិន គឺសុតៈ និងក្លិន គឺកិច្ចបដិបត្តិ គឺមិនមានផលដល់បុគ្គលនោះ ដែលមិនប្រព្រឹត្តដោយគោរព ឈ្មោះថា មិនធ្វើកិច្ច ដែលគប្បីធ្វើក្នុងពុទ្ធវចនៈនោះ ព្រោះហេតុនោះ ទើបលោកពោលថា វាចាជាសុភាសិត រមែងឥតផលដល់បុគ្គលអ្នកមិនធ្វើតាមក៏យ៉ាងនោះដែរ ។

បទថា **សុគន្ធកំ** បានដល់ ផ្កាប្រអូប មានផ្កាម្លិះ ផ្កាចម្ប៉ា និងផ្កាឧប្បលខៀវជាដើម ។

បទថា **ឯវំ** សេចក្តីថា ក្លិនរមែងផ្សាយទៅក្នុងសរីរៈនៃបុគ្គលដែលទ្រទ្រង់នូវផ្កា យ៉ាងណា វាចាដែលជាសុភាសិត ពោល គឺពុទ្ធវចនៈ គឺបិដក ៣ ក៏ដូច្នោះ រមែងមានផល គឺរមែងមានផលច្រើន មានអានិសង្សច្រើន ដល់បុគ្គលធ្វើកិច្ចដែលគួរធ្វើក្នុងពុទ្ធវចនៈនោះ ដោយកិច្ច មានការស្តាប់ដោយគោរពជាដើម ព្រោះហេតុនោះ គប្បីបដិបត្តិតាមឱវាទ គឺគប្បីធ្វើយ៉ាងណា គប្បីពោលយ៉ាងនោះ ។ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ។៚

**អដ្ឋកថាសុភូតត្ថេរគាថា ចប់**

# សុត្តន្តបិដក

## គិរិមានន្ទត្ថេរគាថា

[ ២០១ ] ភ្លៀងបង្អុរចុះតាមសមគួរ ដល់ការគ្រហឹមនៃមេឃដ៏ពីរោះ កុដិអាត្មាប្រក់ស្រួលហើយ ឥតមានខ្យល់ចេញចូលបានទេ អាត្មាមានចិត្តស្ងប់រម្ងាប់នៅក្នុងកុដិនោះ ម្នាលមេឃ ម្តេចហ្ន៎ បើអ្នកប្រាថ្នា ចូរបង្អុរភ្លៀងមកចុះ ។

ភ្លៀងបង្អុរចុះ តាមសមគួរដល់ការគ្រហឹមនៃមេឃ ដ៏ពីរោះ
កុដិអាត្មាប្រក់ស្រួលហើយ ឥតមានខ្យល់ចេញចូលបានទេ
អាត្មាមានចិត្តស្ងប់រម្ងាប់ នៅក្នុងកុដិនោះ ម្នាលមេឃ ម្តេច
ហ្ន៎ បើអ្នកប្រាថ្នា ចូរបង្អុរភ្លៀងមកចុះ ។បេ។ អាត្មាជាអ្នក
ប្រាសចាករាគៈ នៅក្នុងកុដិនោះ ។បេ។ អាត្មាជាអ្នកប្រាស
ចាកទោសៈ នៅក្នុងកុដិនោះ ។បេ។ អាត្មាជាអ្នកប្រាសចាក
មោហៈ នៅក្នុងកុដិនោះ ម្នាលមេឃ ម្តេចហ្ន៎ បើអ្នកប្រាថ្នា
ចូរបង្អុរភ្លៀងមកចុះ ។

**គិរិមានន្ទត្ថេរ**

# អដ្ឋកថា

## គិរិមានន្ទត្ថេរគាថា

[ ២០១ ] គាថារបស់ព្រះគិរិមានន្ទត្ថេរ មានពាក្យផ្ដើមថា **វស្សតិ ទេវោ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើមកហើយ ក្នុងព្រះសម្ពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមសុមេធ កើតក្នុងផ្ទះមានត្រកូល ចម្រើនវ័យហើយ នៅគ្រប់គ្រងផ្ទះ កាលភរិយា និងកូនធ្វើកាលកិរិយាហើយ ដល់ព្រមទៅដោយសរ គឺសេចក្ដីសោក ចូលទៅកាន់ព្រៃ ព្រះសាស្ដាយាងទៅកាន់ទីនោះ សម្ដែងធម៌ ដកនូវព្រួញ គឺសេចក្ដីសោកបានហើយ មានចិត្តជ្រះថ្លា បូជាដោយគ្រឿងក្រអូប និងផ្កា ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ផ្គងអញ្ជលីលើសិរសា ពោលសរសើរ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតជាបុត្តនៃបុរោហិតរបស់ព្រះបាទពិម្ពិសារ ក្នុងក្រុងរាជគ្រឹះ មានឈ្មោះថា **គិរិមានន្ទ** ដល់នូវភាពជាអ្នកដឹងក្ដីហើយ ឃើញពុទ្ធានុភាពរបស់ព្រះពុទ្ធ ក្នុងកាលយាងទៅកាន់ក្រុងរាជគ្រឹះ បាននូវសទ្ធា បព្វជ្ជា ធ្វើសមណធម៌ក្នុងស្រុក អស់ ២-៣ ថ្ងៃ រួចទៅកាន់ក្រុងរាជគ្រឹះ ដើម្បីថ្វាយបង្គំព្រះសាស្ដា ។

ព្រះបាទពិម្ពិសារ ទ្រង់ដឹងការមករបស់ព្រះថេរៈ ទើបយាងចូលទៅរកទ្រង់បវារណាថា សូមលោកម្ចាស់នៅក្នុងទីនេះឯង ខ្ញុំនឹងឧបដ្ឋាកដោយបច្ច័យ

៤ ហើយយានទៅ ទ្រង់រឭកមិនបាន ព្រោះមានកិច្ចច្រើន ។ ទេវតាទាំង-ឡាយគិតថា ព្រះថេរៈនៅក្នុងទីវាល ទើបឃាត់នូវភ្លៀង ព្រោះខ្លាចព្រះថេរៈសើម ។ ព្រះរាជាទ្រង់ជ្រាបហេតុដែលភ្លៀងមិនធ្លាក់ ទើបធ្វើកុដិប្រគេនព្រះថេរៈ ។ ព្រះថេរៈនៅក្នុងកុដិ ធ្វើសម្មាវាយាមៈ ព្រោះបានសេនាសនៈជាទីសប្បាយ ប្រកបព្យាយាមជានិច្ច បំពេញវិបស្សនា សម្រេចអរហត្តសមដូចគាថាព័ន្ធដែលលោកពោលក្នុងអបទានថា

ភរិយារបស់ខ្ញុំ ធ្វើមរណកាលហើយ កូនប្រុសរបស់ខ្ញុំ
ទៅកាន់ព្រៃស្មសានហើយ មាតា បិតា និងបងប្រុស
គេដុតលើជើងថ្ករតែមួយ ។ ខ្ញុំមានខ្លួនក្តៅសព្វ ស្គម
ស្លេកស្លាំង ព្រោះតែសេចក្តីសោកនោះ មិនតែប៉ុណ្ណោះ
ចិត្តរបស់ខ្ញុំ ក៏ក្រឡុកច្នួត ខ្ញុំត្រូវសេចក្តីសោកនោះ គ្រប
សង្កត់ហើយ ។ ខ្ញុំលុះត្រូវសរ គឺសេចក្តីសោកគ្របសង្កត់
ហើយ ក៏បានចូលទៅកាន់ទីជាយព្រៃ បរិភោគតែផ្លែឈើ
ដែលជ្រុះ ហើយនៅទៀបគល់ឈើ ។ ព្រះសម្ពុទ្ធជិនស្រី
ព្រះនាមសុមេធៈ ទ្រង់ធ្វើនូវទីបំផុតនៃទុក្ខ ព្រះអង្គមាន
ប្រាថ្នានឹងស្រង់ខ្ញុំ ទើបស្តេចមក ក្នុងសម្នាក់របស់ខ្ញុំ ។
ខ្ញុំលុះឮសូរព្រះបាទ នៃព្រះសុមេធសម្ពុទ្ធជាមហេសី ក៏បាន
ងាកក្បាលរមិលមើលព្រះមហាមុនី ។ ព្រះសម្មាសម្ពុទ្ធទ្រង់
មានព្យាយាមធំ ស្តេចបានចូលមកជិតខ្ញុំ ខ្ញុំក៏មានបីតិកើត

ឡើង គ្រានោះ ខ្ញុំឃើញព្រះលោកនាយកនោះហើយ ជាអ្នកមានចិត្តតាំងនៅក្នុងអារម្មណ៍តែមួយ ។ ខ្ញុំត្រឡប់បានស្មារតីវិញ បានប្រគេនស្លឹកឈើមួយក្តាប់ ព្រះមានព្រះភាគមានបញ្ញាចក្ខុ ទ្រង់គង់ក្នុងទីនោះ ដោយសេចក្តីអនុគ្រោះ ។

ព្រះសុមេធសម្ពុទ្ធមានជោគ ជាលោកនាយក លុះគង់ក្នុងទីនោះហើយ ទ្រង់សម្តែងធម៌ជាគ្រឿងបន្ទោបង់នូវសរ គឺសេចក្តីសោករបស់ខ្ញុំថា សត្វទាំងឡាយមកអំពីភពនោះ ក៏អ្នកមិនបានហៅមក ដល់ទៅអំពីភពនេះវិញ ក៏អ្នកមិនបានអនុញ្ញាតឲ្យទៅ គេមកយ៉ាងណា គេក៏ទៅយ៉ាងនោះ ការខ្សឹកខ្សួលទៅរកជនទាំងនោះធ្វើអ្វី ។ ពួកសត្វស្វាបទាំងឡាយកាលភ្លៀងបង្អុរចុះ ក៏នាំគ្នាហើរចូល ព្រោះចំណីរបស់ខ្លួនសត្វទាំងនោះ ហើរចូលទៅ ត្រឹមតែភ្លៀងកំពុងធ្លាក់ចុះ ។ កាលភ្លៀងរាំងហើយ សត្វទាំងឡាយនោះ ក៏ហើរទៅកាន់ទីតាមប្រាថ្នា យ៉ាងណាមិញ មាតាបិតារបស់អ្នក ក៏យ៉ាងនោះដែរ ការខ្សឹកខ្សួលទៅរកជនទាំងនោះធ្វើអ្វី ។ ពួកភ្ញៀវដែលទើបមកដល់ថ្មីៗ រមែងកម្រើកញាប់ញ័រ ក្នុងកាលទៅវិញយ៉ាងណា មាតាបិតារបស់អ្នក ក៏យ៉ាងនោះដែរ ការខ្សឹកខ្សួលទៅរកជនទាំងនោះធ្វើអ្វី ។ ពស់សកសំណាកចាស់ចោលហើយលូនទៅ យ៉ាងណា មាតាបិតារបស់អ្នក តែងតែ

លះបង់រាងកាយចោលក្នុងលោកនេះ ក៏យ៉ាងនោះដែរ ។

ខ្ញុំកាលបានដឹងព្រះវាចានៃព្រះពុទ្ធ ក៏លះបង់នូវសេរ គឺសេចក្ដីសោកបាន ហើយញ៉ាំងប្រាមោទ្យឲ្យកើត បានថ្វាយបង្គំព្រះពុទ្ធដ៏ប្រសើរ ។ លុះខ្ញុំថ្វាយបង្គំព្រះមហានាគ ហើយបូជានូវផ្កាឈើក្នុំដ៏បរិបូណ៌ដោយក្លិនជាទិព្វ ចំពោះព្រះលោកនាយក ព្រះនាមសុមេធៈ ។ ខ្ញុំបូជាព្រះសម្ពុទ្ធរួច ធ្វើអញ្ជលីលើត្បូង រឭកនូវគុណដ៏ប្រសើរ សរសើរព្រះលោកនាយកថា បពិត្រព្រះអង្គមានព្យា-យាមធំ ព្រះអង្គជាសព្វញ្ញូលោកនាយក ទ្រង់ឆ្លងនូវវាលវដ្តសង្សារហើយ បពិត្រមហាមុនី ព្រះអង្គទ្រង់ស្រង់សត្វទាំងពួងដោយញាណ ។ បពិត្រព្រះមុនី ព្រះអង្គទ្រង់ផ្តាច់បង់នូវសេចក្តីងឿងឆ្ងល់និងសេចក្តីសង្ស័យ បពិត្រព្រះអង្គមានចក្ខុ ព្រះអង្គទ្រង់ញ៉ាំងមគ្គផលឲ្យសម្រេចដល់ខ្ញុំ ដោយញាណរបស់ព្រះអង្គ ។ ព្រះអរហន្តទាំងឡាយ ដែលដល់នូវសេចក្តីសម្រេច បានអភិញ្ញា ៦ មានឫទ្ធិច្រើន ត្រាច់ទៅក្នុងអាកាសបាន ជាអ្នកប្រាជ្ញ តែងចោមរោមក្នុងខណៈនោះ ។ សាវកទាំងឡាយ កំពុងប្រតិបត្តិក្តី ជាសេក្ខបុគ្គលក្តី ឋិតនៅក្នុងផលក្តី សាវករបស់ព្រះអង្គទាំងនោះបែកផ្កាហើយ ដូចផ្កាឈូក ក្នុងពេលព្រះអាទិត្យទើបនឹងរះ ។ មហាសមុទ្រមិនកម្រើក ជ្រៅថ្លឹងមិនបាន កម្របុគ្គលឆ្លងបានយ៉ាងណា បពិត្រព្រះ អង្គមានចក្ខុ ព្រះអង្គបរិបូណ៌ដោយញាណ

ប្រមាណមិនបាន ក៏យ៉ាងនោះ ។ ខ្ញុំថ្វាយបង្គំព្រះជិនស្រីមានចក្ខុ មានយសច្រើន ហើយនមស្ការទិសទាំង ៤ ក៏ដើរថយក្រោយទៅ ។ កាលខ្ញុំច្យុតចាកទេវលោក អន្ទោលទៅក្នុងភពតូច ភពធំ ចុះមកចាប់ផ្ទៃនៃមាតា ជាអ្នកដឹងខ្លួន មានស្មារតី ។ ខ្ញុំចេញចាកផ្ទះ ចូលទៅកាន់ផ្នួស មានព្យាយាមកម្ចាត់បង់កិលេស មានប្រាជ្ញាចាស់ មានការពួនសម្ងំជាគោចរ ។ ក្នុងកាលនោះ ខ្ញុំតាំងសេចក្តីព្យាយាម ញុំាងព្រះមហាមុនីឲ្យត្រេកអរ ហើយប្រព្រឹត្តទៅ ដូចព្រះចន្ទ្រផុតស្រឡះចាកពពក ។ ខ្ញុំជាអ្នកប្រកបរឿយៗនូវវិវេក ស្ងប់ស្ងាត់ ឥតមានឧបធិក្កិលេស កំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ ។ ក្នុងកប្បទី ៣ ម៉ឺន ព្រោះហេតុដែលខ្ញុំបានបូជានូវព្រះពុទ្ធ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយ ខ្ញុំដុតចោលហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ ។

កាលភ្លៀងធ្លាក់ ហាក់ដូចសម្តែងសេចក្តីត្រេកអរដល់ព្រះថេរៈសម្រេចអរហត្ត ព្រះថេរៈកាលព្យាករអរហត្តផលនោះ ដោយផ្តើនឲ្យភ្លៀងធ្លាក់ខ្លាំងឡើង ទើបពោល ៥ គាថាថា

ភ្លៀងបង្អុរចុះ តាមសមគួរដល់ការគ្រហឹមនៃមេឃដ៏ពីរោះ កុដិអាត្មាប្រក់ស្រួលហើយ ឥតមានខ្យល់ចេញចូលបានទេ អាត្មាមានចិត្តស្ងប់រម្ងាប់ នៅក្នុងកុដិនោះម្នាលមេឃ ម្តេចហ៎ បើអ្នក

ប្រាថ្នា ចូរបង្អុរភ្លៀងមកចុះ ។

ភ្លៀងបង្អុរចុះ តាមសមគួរដល់ការគ្រហឹមនៃមេឃដ៏ពីរោះ កុដិអាត្មាប្រក់ស្រួលហើយ ឥតមានខ្យល់ចេញចូលបានទេ អាត្មាមានចិត្តស្ងប់រម្ងាប់ នៅក្នុងកុដិនោះ ម្នាលមេឃ ម្តេចហ៎ បើអ្នកប្រាថ្នា ចូរបង្អុរភ្លៀងមកចុះ ។បេ។ អាត្មាជាអ្នកប្រាសចាករាគៈនៅក្នុងកុដិនោះ ។បេ។ អាត្មាជាអ្នកប្រាសចាកទោសៈ នៅក្នុងកុដិនោះ ។បេ។ អាត្មាជាអ្នកប្រាសចាកមោហៈ នៅក្នុងកុដិនោះ ម្នាលមេឃ ម្តេចហ៎ បើអ្នកប្រាថ្នា ចូរបង្អុរភ្លៀងមកចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យថាសុគីតំ** បានដល់ ដូចចម្រៀងដ៏ពីរោះ អធិប្បាយថា សមគួរដល់ការគ្រហឹមនៃមេឃដ៏ពីរោះល្អនោះឯង ។ ពិតហើយ មេឃកាលតាំងឡើង ១០០ ស្រទាប់ ១០០០ ស្រទាប់ ហើយគ្រហឹម ប្រកបដោយផ្ទេកបន្ទោរ តែភ្លៀងមិនធ្លាក់ រមែងមិនស្អាត បើមេឃមិនគ្រហឹម ធ្លាក់ភ្លៀងតែម្យ៉ាង ក៏មិនស្អាតដូចគ្នា កាលបើប្រកបដោយហេតុទាំងពីរយ៉ាងនោះហើយ ភ្លៀងធ្លាក់ចុះមក រមែងស្អាត ព្រោះហេតុនោះ ទើប

ព្រះថេរៈពោលថា **វស្សតិ ទេវោ យថាសុគីតំ** ភ្លៀងបង្អុរចុះ តាមសមគួរដល់ការគ្រហឹមនៃមេឃដ៏ពីរោះ និងសមដូចព្រះតម្រាស់ ( ក្នុងមច្ឆជាតក ) ថា បពិត្រមេឃ ចូរអ្នកញ៉ាំងផ្គរឲ្យលាន់ឡើង ដូច្នេះ និងព្រះតម្រាស់ ( ក្នុងអង្គុត្តរនិកាយ ចតុក្កនិបាត ) ថា មេឃគ្រហឹមផង បង្អុរភ្លៀងផង ដូច្នេះ ។

បទថា **តស្សំ វិហរាមិ** សេចក្តីថា ខ្ញុំនៅក្នុងកុដិនោះ ដោយបន្ទប់អរិយវិហារធម៌ គឺដោយឥរិយាបថវិហារ ។

បទថា **វូបសន្តចិត្តោ** បានដល់ មានចិត្តស្ងប់ដោយប្រពៃ ដោយសមាធិដែលសម្បយុត្តដោយអរហត្តផល ។

វលាហកទេវបុត្រទទួលនូវពាក្យដែលព្រះថេរៈ ពោលយ៉ាងនេះ ច្រើនដង ដោយសិរសា ទើបញ៉ាំងភ្លៀងធំ ឲ្យធ្លាក់ចុះពេញទីទាប និងទីទួលដោយប្រការដូច្នេះ ។

## អដ្ឋកថាគិរិមានន្ទត្ថេរគាថា ចប់

# សុត្តន្តបិដក

## សុមង្គលត្ថេរគាថា

[ ២០២ ] បណ្ដាធម៌ទាំងឡាយ ព្រះឧបជ្ឈាយ៍ប្រាថ្នាចំពោះធម៌ណា អនុគ្រោះខ្ញុំ អ្នកប្រាថ្នាព្រះនិព្វានឈ្មោះអមតៈ សោឡសកិច្ច ដែលគួរធ្វើ ខ្ញុំក៏បានធ្វើហើយ ។ មគ្គធម៌ ជាធម៌មិនមានអន្តរាយ ខ្ញុំបានដល់ដោយលំដាប់ហើយ បានធ្វើឲ្យជាក់ច្បាស់ហើយ ដោយខ្លួនឯង ខ្ញុំមានញាណដ៏បរិសុទ្ធ ឥតសង្ស័យ បានធ្វើឲ្យជាក់ច្បាស់ក្នុងសម្នាក់នៃលោក ។ ខ្ញុំដឹងនូវបុព្វេនិវាស ទិព្វចក្ខុ ខ្ញុំបានជម្រះស្អាតហើយ ប្រយោជន៍របស់ខ្លួន គឺព្រះអរហត្ត ខ្ញុំបានដល់ដោយលំដាប់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ ខ្ញុំជាអ្នកមិនប្រមាទ បានស្ដាប់ បានរៀនល្អនូវសិក្ខា ក្នុងពាក្យប្រៀនប្រដៅរបស់លោក អាសវៈទាំងពួងរបស់ខ្ញុំអស់ហើយ ឥឡូវកពថ្មី មិនមានទេ ។ លោកប្រៀនប្រដៅខ្ញុំដោយវត្តដ៏ប្រសើរ ជាអ្នកអនុគ្រោះ ទំនុកបម្រុង ( នូវខ្ញុំ ) ឱវាទរបស់លោកមិនឥតអំពើឡើយ ខ្ញុំជាសិស្សបានរៀនសូត្រហើយ ។

សុមនត្ថេរ

# អដ្ឋកថា

## សុមនត្ថេរគាថា

[ ២០២ ] *គាថារបស់ព្រះសុមនត្ថេរ មានពាក្យផ្ដើមថា* **យំ បត្ថយមានោ** *ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។*

*បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងកប្បទី ៩៥ រាប់ថយអំពីភទ្ទកប្បនេះ ចក្កវាឡទទេ មិនមានព្រះពុទ្ធ កើតឡើងក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្ដីហើយ ឃើញព្រះបច្ចេកពុទ្ធមួយអង្គអាពាធ បានប្រគេនផ្លែសម៉មួយ ។*

*ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលគហបតី ក្នុងកោសលរដ្ឋ មានឈ្មោះថា* **សុមនៈ** *ចម្រើនដោយសេចក្ដីសុខ ។ ឪពុកធំរបស់កុលបុត្តនោះបួសហើយ បានជាព្រះអរហន្ត នៅក្នុងព្រៃ កាលសុមនៈចម្រើនវ័យហើយទើបឲ្យបព្វជ្ជា ព្រះថេរៈឲ្យកម្មដ្ឋានដែលសមគួរដល់ចរិត ។ កុលបុត្តនោះប្រកបសេចក្ដីព្យាយាមក្នុងកម្មដ្ឋាននោះ ញុំាងឈាន ៤ និងអភិញ្ញា ៥ ឲ្យកើតលំដាប់នោះ ព្រះថេរៈបានប្រាប់វិបស្សនាវិធីដល់កុលបុត្តនោះ លោកចម្រើនវិបស្សនា ក្នុងកាលមិនយូរឡើយ ក៏តាំងនៅក្នុងអរហត្ត សមដូចគាថាព័ន្ធដែលលោកពោលក្នុងអបទានថា*

*ខ្ញុំកំពុងតែនាំយកនូវផ្លែសម៉ ផ្លែកន្ទួតព្រៃ ផ្លែស្វាយ ផ្លែព្រីង ផ្លែសម៉ពិភេទក៍ ផ្លែពុទ្រា ផ្លែក្រខុប និងផ្លែញៀរដោយខ្លួនឯង ។*

ខ្ញុំបានឃើញព្រះសម្ពុទ្ធ ជាអ្នកប្រាជ្ញ ព្រះអង្គគង់នៅក្នុងញកភ្នំ ទ្រង់មានឈាន ត្រេកអរក្នុងឈាន ជាមហាមុនីដ៏មាំមួន ដែលកំពុងត្រូវអាពាធបៀតបៀន ។ ខ្ញុំយកផ្លែសម៉ទៅថ្វាយព្រះសយម្ភូ កេសជ្ជៈគ្រាន់តែខ្ញុំធ្វើរួចហើយ ព្យាធិក៏រម្ងាប់ក្នុងខណៈនោះភ្លាម ។ ព្រះសម្ពុទ្ធទ្រង់លះបង់សេចក្តីក្រវល់ក្រវាយ បានធ្វើអនុមោទនាព្រោះកេសជ្ជៈទាននេះផង ព្រោះការរម្ងាប់នូវព្យាធិនេះផងថា អ្នកកើតជាទេវតាក្តី ជាមនុស្សក្តី ឬកើតក្នុងជាតិដទៃក្តី សូមឲ្យជាអ្នកដល់នូវសេចក្តីសុខក្នុងទីទាំងពួង មួយទៀត សូមកុំឲ្យព្យាធិកើតមានដល់អ្នកឡើយ ។ ព្រះសម្ពុទ្ធជាព្រះសយម្ភូ ទ្រង់ឈ្នះកិលេស ជាអ្នកប្រាជ្ញ លុះត្រាស់ពាក្យនេះហើយ ក៏ទ្រង់ហោះទៅឯអាកាស ដូចជាស្តេចហង្សដែលហើរទៅឰដ៏អាកាស ។ កាលដែលខ្ញុំបានថ្វាយផ្លែសម៉ដល់ព្រះសយម្ភូ ជាមហេសី ព្យាធិក៏មិនកើតឡើងដល់ខ្ញុំរហូតជាតិនេះ ។ នេះរាងកាយខាងក្រោយបំផុតរបស់ខ្ញុំ ភពខាងក្រោយកំពុងប្រព្រឹត្តទៅ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយកេសជ្ជៈ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃកេសជ្ជៈ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ

ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈតាំងនៅក្នុងអរហត្តហើយ ថ្ងៃមួយ បានទៅកាន់ទីឧបដ្ឋាកព្រះថេរៈដែលជាឪពុកធំ ព្រះថេរៈសួរដល់ការសម្រេចរបស់លោក កាលព្យាករការសម្រេចនោះ ទើបព្យាករអរហត្តផល បន្លឺសីហនាទដោយ ៥ គាថាថា

បណ្តាធម៌ទាំងឡាយ ព្រះឧបជ្ឈាយ៍ប្រាថ្នាចំពោះធម៌ណា អនុគ្រោះខ្ញុំ អ្នកប្រាថ្នាព្រះនិព្វានឈ្មោះអមតៈ សោឡសកិច្ច ដែលគួរធ្វើ ខ្ញុំក៏បានធ្វើហើយ ។ មគ្គធម៌ ជាធម៌មិនមានអន្តរាយ ខ្ញុំបានដល់ដោយលំដាប់ហើយ បានធ្វើឲ្យជាក់ច្បាស់ហើយ ដោយខ្លួនឯង ខ្ញុំមានញាណដ៏បរិសុទ្ធ ឥតសង្ស័យ បានធ្វើឲ្យជាក់ច្បាស់ក្នុងសម្នាក់នៃលោក ។ ខ្ញុំដឹងនូវបុព្វេនិវាស ទិព្វចក្ខុ ខ្ញុំបានជម្រះស្អាតហើយ ប្រយោជន៍របស់ខ្លួន គឺព្រះអរហត្ត ខ្ញុំបានដល់ដោយលំដាប់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ ខ្ញុំជាអ្នកមិនប្រមាទ បានស្តាប់ បានរៀនល្អនូវសិក្ខា ក្នុងពាក្យប្រៀនប្រដៅរបស់លោក អាសវៈទាំងពួងរបស់ខ្ញុំអស់ហើយ ឥឡូវកពថ្មី មិនមានទេ ។ លោកប្រៀនប្រដៅខ្ញុំដោយវត្តដ៏ប្រសើរ ជាអ្នកអនុគ្រោះ ទំនុកបម្រុង ( នូវខ្ញុំ ) ឱវាទ របស់លោក មិនឥតអំពើឡើយ ខ្ញុំជាសិស្សបានរៀនសូត្រហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យំ បត្ថយមានោ ធម្មេសុ ឧបជ្ឈាយោ**

---

១- ក្នុងអបទាន ជាហរីតកិទាយកត្ថេរ ។

**អនុគ្គហិ អមតំ អភិកង្ខតំ** សេចក្ដីថា ក្នុងបណ្ដាធម៌មិនមានទោស មានសមថៈ និងវិបស្សនាជាដើម ឧបជ្ឈាយ៍របស់ខ្ញុំ កាលប្រាថ្នា គឺទន្ទឹងនូវធម៌ណា រមែងអនុគ្រោះខ្ញុំ ដែលជាអ្នកទន្ទឹងនូវអមតៈ គឺព្រះនិព្វានដោយអំណាចការឲ្យឱវាទ ។

បទថា **កតំ កត្តព្វកំ មយា** សេចក្ដីថា ខ្ញុំធ្វើកិច្ច គឺញ៉ាំងសោឡសកិច្ច មានបរិញ្ញាកិច្ចជាដើម ដែលគប្បីធ្វើដើម្បីសម្រេចនិព្វាននោះ ឲ្យសម្រេចហើយ ។

លំដាប់នោះ ព្រះថេរៈធ្វើឲ្យជាក់ច្បាស់នូវមគ្គធម៌ទាំង ៤ ដែលសម្រេចហើយដោយលំដាប់ គឺដែលដល់ចំពោះហើយ ។

បទថា **សយំ ធម្មោ អធីតិហោ** សេចក្ដីថា ធម៌ គឺព្រះនិព្វាន និងធម៌ គឺផល ខ្ញុំបានដឹងឯងហើយ មិនចាំបាច់ពោលអាងអ្នកដទៃ មិនសង្ស័យ ឃើញច្បាស់ដោយខ្លួនឯងហើយ បាននូវអរិយមគ្គ ដកនូវសេចក្ដីសង្ស័យ ដែលរាប់ថា ជាពាក្យប្រៀនប្រដៅ ដែលមកហើយអំពីអាចារ្យក្នុងកាលមុន ដែលប្រព្រឹត្តទៅថា **ឥតិហ** ប្រែថា ធម៌ នេះមានមកអំពីមុនយ៉ាងនេះ **ឥតិកិរ** ប្រែថា បានឮថា ធម៌នេះមានមកអំពីកាលមុនយ៉ាងនេះ ។ ព្រោះហេតុនោះ ទើបលោកពោលថា ខ្ញុំជាអ្នកមានញាណដ៏បរិសុទ្ធ អស់សេចក្ដីសង្ស័យជាដើម ។

បណ្ដាបទទាំងនោះ បទថា **វិសុទ្ធញាណោ** ឈ្មោះថា ជាអ្នកមានញាណបរិសុទ្ធ ព្រោះបរិសុទ្ធចាកកិលេសទាំងពួង ។

*បទថា* **តវន្តិកេ** *ប្រែថា ក្នុងទីជិតលោក ។ បទថា* **សមន្តោ** *បានដល់ អរហត្ត ។ បទថា* **សិក្ខា** *បានដល់ អធិសីលសិក្ខាជាដើម ។*

*បទថា* **សុស្សុតា** *បានដល់ ស្តាប់ដោយល្អ ដោយអំណាចការធ្វើ បរិយត្តិពហុសច្ចៈ និងបដិវេធពហុសច្ចៈឲ្យបរិបូណ៌ ។*

*បទថា* **តវ សាសនេ** *បានដល់ តាំងនៅក្នុងឱវាទ ក្នុងពាក្យប្រៀនប្រដៅរបស់លោក ។*

*បទថា* **អរិយវតា** *សេចក្តីថា ដោយការសមាទានបដិបទា មានសីលវិសុទ្ធិជាដើម ។*

*បទថា* **អន្តេវាសិម្ហិ សិក្ខិតោ** *សេចក្តីថា ខ្ញុំ ឈ្មោះថា ជាអន្តេវាសិក ព្រោះនៅប្រព្រឹត្តព្រហ្មចរិយៈក្នុងសម្នាក់របស់លោក សិក្សាហើយ ទើបជា អ្នកមានអធិសីលសិក្ខាជាដើម ដែលសិក្សាហើយ ដូច្នេះ ។*

**អដ្ឋកថាសុមនត្ថេរគាថា ចប់**

# សុត្តន្តបិដក

## វឌ្ឍត្ថេរគាថា

[ ២០៣ ] មានសេចក្តីតំណាលថា ឱហ្ន៎ មាតាបានបង្ហាញនូវជន្ទញ ( ឱវាទ ) ដល់អាត្មាអញ អាត្មាអញដែលមាតាប្រៀនប្រដៅ បានស្តាប់ពាក្យរបស់លោកហើយ ជាអ្នកមានព្យាយាមមុតមាំហើយ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន បានដល់នូវសម្ពោធិដ៏ឧត្តម ។ អាត្មាអញជាអរហន្តទក្ខិណេយ្យ-បុគ្គល មានត្រៃវិជ្ជា ឃើញព្រះនិព្វានឈ្មោះអមតៈ អាត្មាអញឈ្នះសេនានៃមារ ជាអ្នកមិនមានអាសវៈ អាសវៈទាំងឡាយណា របស់អាត្មាអញ ខាងក្នុងក្តី ខាងក្រៅក្តី អាសវៈទាំងអស់នោះ អាត្មាអញកាត់ផ្តាច់ហើយ ឥតមានសេសសល់ ទាំងមិនកើតទៀតទេ ។ បងស្រីមានសេចក្តីក្លៀវក្លា បានពោលនូវសេចក្តីនេះ នាងទំនងជាមិនមានសេចក្តីស្រឡាញ់ចំពោះអាត្មាដោយពិតព្រៃ ( មានអវិជ្ជាជាដើម ) មិនមាន ( ក្នុងសន្តានរបស់នាង ) ទេ ។ សេចក្តីទុក្ខមានទីបំផុតជុំវិញ អាត្មាបានធ្វើហើយ រាងកាយនេះជាទីបំផុត ( របស់អាត្មា ) សង្សារ គឺជាតិ និងមរណៈមិនមាន ឥឡូវនេះ ភពថ្មីមិនមានទេ ។

វឌ្ឍត្ថេរ

# អដ្ឋកថា

## វឌ្ឍត្ថេរគាថា

[ ២០៣ ] គាថារបស់ព្រះវឌ្ឍត្ថេរ មានពាក្យផ្ដើមថា **សាធូ ហិ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលនៃគហបតី ក្នុងភារុកច្ឆនគរ បានឈ្មោះថា **វឌ្ឍៈ** ចម្រើនវ័យដោយលំដាប់ ។ សម័យនោះ មាតារបស់កុលបុត្តនោះកើតសេចក្ដីសង្វេគក្នុងសង្សារ បានប្រគល់បុត្តឲ្យដល់ពួកញាតិ ហើយបួសក្នុងសម្នាក់ភិក្ខុនីទាំងឡាយ បំពេញវិបស្សនា សម្រេចអរហត្ត ។ សម័យតមក ឲ្យបុត្តដែលដល់នូវភាពជាអ្នកដឹងក្ដីហើយ បួសក្នុងសម្នាក់ព្រះវេឡុទន្តត្ថេរ ។ បួសហើយ រៀនពុទ្ធវចនៈ ជាពហុស្សូត ជាធម្មកថិក ខាងគន្ថធុរៈ ថ្ងៃមួយ គិតថា អាត្មាអញត្រឹមតែម្នាក់ឯង នឹងប្រញាប់ប្រញាល់ ទៅសួរសុខទុក្ខមាតា ទើបទៅកាន់សម្នាក់ភិក្ខុនី មាតាឃើញព្រះថេរៈហើយ សួរថា ព្រោះហេតុអ្វី ទើបលោកម្ចាស់ប្រញាប់ប្រញាល់មក ក្នុងទីនេះតែម្នាក់ឯង ។ កាលត្រូវមាតាសួរ ក៏កើតនូវសេចក្ដីសង្វេគថា អញធ្វើកម្មមិនគួរ ទៅកាន់វិហារ អង្គុយក្នុងទីសម្រាកក្នុងពេលថ្ងៃ ចម្រើនវិបស្សនា សម្រេចអរហត្ត កាលនឹងព្យាករអរហត្តផល ដោយបំណងប្រកាសគុណនៃឱវាទរបស់មាតា ទើបពោលគាថាដូច្នេះថា

មានសេចក្តីតំណាលថា ឱហ្ន៎ មាតាបានបង្ហាញនូវជន្ទួញ ( ឱវាទ ) ដល់អាត្មាអញ អាត្មាអញដែលមាតាប្រៀនប្រដៅ បានស្តាប់ពាក្យរបស់លោកហើយ ជាអ្នកមានព្យាយាមមុតមាំហើយ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន បានដល់នូវសម្ពោធិដ៏ឧត្តម ។ អាត្មាអញជាអរហន្តទក្ខិណេយ្យបុគ្គល មានត្រៃវិជ្ជា ឃើញព្រះនិព្វានឈ្មោះអមតៈ អាត្មាអញឈ្នះសេនានៃមារ ជាអ្នកមិនមានអាសវៈ អាសវៈទាំងឡាយណា របស់អាត្មាអញ ខាងក្នុងក្តី ខាងក្រៅក្តី អាសវៈទាំងអស់នោះ អាត្មាអញកាត់ផ្តាច់ហើយ ឥតមានសេសសល់ ទាំងមិនកើតទៀតទេ ។ បងស្រី មានសេចក្តីក្លៀវក្លា បានពោលនូវសេចក្តីនេះ នាងទំនងជាមិនមានសេចក្តីស្រឡាញ់ចំពោះអាត្មាដោយពិត ព្រៃ ( មានអវិជ្ជាជាដើម ) មិនមាន ( ក្នុងសន្តានរបស់នាង ) ទេ ។ សេចក្តីទុក្ខមានទីបំផុតជុំវិញ អាត្មាបានធ្វើហើយ រាងកាយនេះ ជាទីបំផុត ( របស់អាត្មា ) សង្សារ គឺជាតិ និងមរណៈមិនមាន ឥឡូវនេះ ភពថ្មីមិនមានទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សាធុ ហិ កិរ មេ មាតា បតោទំ ឧបធំសយិ** សេចក្តីថា ល្អហ្ន៎ មាតាបង្ហាញនូវជន្ទួញ គឺឱវាទដល់ខ្ញុំ កាលនឹងបន្ថែមវីរិយៈ និងសេចក្តីអង់អាចដល់ខ្ញុំ ដោយជន្ទួញនោះ ទើបចាក់ត្រង់ក្បាល គឺបញ្ញា ។

បទថា **យស្សា** បានដល់ មាតារបស់ខ្ញុំ ។ បទថា **សម្ពោធិ** បានដល់

អរហត្ត ក្នុងសេចក្តីនេះ មានយោជនាដូច្នេះថា ខ្ញុំកាលមាតាអ្នកឲ្យកំណើតទូន្មាន ស្តាប់ពាក្យដែលលោកទូន្មានហើយ ប្រារព្ធសេចក្តីព្យាយាម មានចិត្តឯក សម្រេចសម្មោធិញ្ញាណដ៏ឧត្តម គឺផលដ៏ប្រសើរ បានដល់ អរហត្ត ខ្ញុំ ឈ្មោះថា **អរហា** ព្រោះជាអ្នកឆ្ងាយចាកកិលេសនោះឯង ឈ្មោះថា **ទក្ខិណេយ្យោ** ជាអ្នកគួរដល់ទក្ខិណា ព្រោះជាបុញ្ញក្ខេត្ត ឈ្មោះថា **តេវិជ្ជោ** ព្រោះមានវិជ្ជា ៣ មានបុព្វេនិវាសញ្ញាណជាដើម ឈ្មោះថា **អមតទ្ទសោ** ព្រោះធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ឈ្នះសេនា គឺវាហនៈរបស់កិលេស និងរបស់<u>នមុចិមារ</u> ដោយសេនា គឺពោធិបក្ខិយធម៌ ទើបជាបុគ្គលឈ្មោះថា **អនាសវោ** ព្រោះឈ្នះសេនានៃមារនោះឯង ទើបនៅជាសុខ ។

ឥឡូវនេះ កាលធ្វើអត្ថដែលលោកពោលថា **អនាសវោ** ឲ្យប្រាកដច្បាស់ ទើបពោលគាថាថា **អជ្ឈត្តញ្ច** ដូច្នេះជាដើម ។

អត្ថនៃគាថានោះ មានដូចតទៅនេះ អាសវៈទាំងឡាយណា ដែលជាខាងក្នុង មានវត្ថុខាងក្នុងជាទីតាំង និងដែលជាខាងក្រៅ មានវត្ថុខាងក្រៅជាទីតាំង មាន គឺកើតមុនការសម្រេចអរិយមគ្គរបស់ខ្ញុំ អាសវៈទាំងអស់នោះខ្ញុំផ្តាច់ផ្តិលហើយ ដោយមិនសេសសល់ កាត់ផ្តាច់អស់ហើយ គឺលះបានហើយដោយអរិយមគ្គ ឥឡូវនេះ មិនកើតឡើងទៀត ក្នុងកាលណាឡើយ គឺនឹងមិនកើតទៀតឡើយ ។

ឥឡូវនេះ កាលធ្វើពាក្យមាតាឲ្យដូចជាជន្ទួញ ទើបសរសើរមាតា ព្រោះហេតុដែលខ្លួនសម្រេចអរហត្តទើបពោលគាថាថា **វិសារទា** ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **វិសារទា ខោ** បានដល់ ប្រាសចាកនូវការខ្លាចដោយចំណែកមួយ ។ កាលលើកសភាវៈដែលខ្លួនជាបុត្ត គឺឱរសរបស់ព្រះសាស្ដា ព្រោះមាតា និងខ្លួន សម្រេចអរហត្ត ដោយអាការយ៉ាងនេះ ទើបហៅមាតាថា **ភគិនី** ( បងស្រី ) ដូច្នេះ ។

បទថា **ឯតមត្ថំ អភាសយិ** សេចក្ដីថា បានពោលអត្ថដែលជាឱវាទដល់ខ្ញុំ អធិប្បាយថា មាតាដែលឲ្យឱវាទដល់ខ្ញុំយ៉ាងនេះ មិនរាប់ថា ជាអ្នកក្បៀនក្បាតែម្យ៉ាងប៉ុណ្ណោះទេ ដោយពិត នាងក៏ជាអ្នកមិនមានកិលេសជាគ្រឿងជាប់ចំពាក់ក្នុងខ្ញុំ មិនមានសេចក្ដីស្និទ្ធស្នាលក្នុងបុត្ររបស់ខ្លួន ប្រយោជន៍អ្វីដោយការគិតនោះ ព្រោះព្រៃ ( មានអវិជ្ជាជាដើម ) មិនមាន ( ក្នុងសន្ដានរបស់នាង ) ទេ គឺកិលេសដូចជាព្រៃទាំងឡាយ មានអវិជ្ជាជាដើម មិនមានក្នុងសន្ដានរបស់លោក ដែលទូន្មានឲ្យខ្ញុំប្រកបក្នុងការអស់កព ។

ឥឡូវនេះ កាលសម្ដែងថា ខ្ញុំប្រព្រឹត្តតាមឱវាទដោយអាការដែលនាងទូន្មាននោះឯង ទើបពោលគាថាចុងក្រោយថា **បរិយន្តកតំ** សេចក្ដីទុក្ខមានទីបំផុតជុំវិញ អាត្មាបានធ្វើហើយ ដូច្នេះជាដើម ។ អត្ថនៃពាក្យដែលជាគាថានេះយល់បានងាយហើយ ។

**អដ្ឋកថាវឌ្ឍមានត្ថេរគាថា ចប់**

# សុត្តន្តបិដក

## ឆដ្ឋកស្សបត្ថេរគាថា

[ ២០៤ ] អាត្មាអញបានស្តាប់ធម៌ របស់ព្រះពុទ្ធណាហើយ វៀរបង់មិច្ឆាទិដ្ឋិ ព្រះពុទ្ធនោះ យាងមកហើយកាន់ស្ទឹងនេរញ្ជរា ដើម្បីប្រយោជន៍ដល់អញមែនពិត ។ អាត្មាអញបានបូជាយញ្ញទាំងឡាយខ្ពស់ និងទាប បានបូជាភ្លើង កាលនូវជាបុថុជ្ជន ងងឹតងងល់ សម្គាល់ថា ការបូជានេះឯង ជាសេចក្តីបរិសុទ្ធ ។ អាត្មាអញស្ទុះទៅកាន់ព្រៃស្បាត គឺទិដ្ឋិ ត្រូវសេចក្តីស្ទាបអង្អែល ( ខុស ) ឲ្យដល់នូវសេចក្តីវង្វេង ងងឹតមិនដឹង សម្គាល់ផ្លូវមិនបរិសុទ្ធ ថាជាផ្លូវបរិសុទ្ធ ។ មិច្ឆាទិដ្ឋិ អាត្មាអញបានលះបង់ហើយ ភពទាំងពួង អាត្មាអញបានទម្លុះទម្លាយហើយ អាត្មាអញបូជាភ្លើង គឺព្រះសម្មាសម្ពុទ្ធ ជាទក្ខិណេយ្យបុគ្គល ថ្វាយបង្គំនូវព្រះតថាគត ។ មោហៈទាំងពួង អាត្មាអញបានលះបង់ហើយ ភវតណ្ហា អាត្មាអញបានទម្លុះទម្លាយចេញហើយ ជាតិសង្សារអស់រលីងហើយ ឥឡូវនេះ ភពថ្មីទៀត នៃអាត្មាអញ មិនមានទេ ។

**នទីកស្សបត្ថេរ**

# អដ្ឋកថា

## នទីកស្សបត្ថេរគាថា

[ ២០៤ ] គាថារបស់ព្រះនទីកស្សបត្ថេរ មានពាក្យផ្តើមថា **អត្ថាយ វត មេ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្តុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្តីហើយ ថ្ងៃមួយ បានឃើញព្រះសាស្តាកំពុងបិណ្ឌបាត មានចិត្តជ្រះថ្លា បានថ្វាយផ្លែស្វាយមួយ មានពណ៌ដូចមនោសិលា ដែលជាផ្លែថ្នាំងនៃដើមស្វាយដែលខ្លួនដាំ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតជាប្អូនប្រុសរបស់ឧរុវេលកស្សបៈ ក្នុងត្រកូលព្រាហ្មណ៍ នាមគធវឌ្ឍ ។ ចម្រើនវ័យហើយ មិនប្រាថ្នាការគ្រប់គ្រងផ្ទះ ព្រោះមានអធ្យាស្រ័យក្នុងការលោះចេញ ទើបបួសជាតាបស មួយអន្លើដោយតាបស ៣០០ ធ្វើអាស្រមត្រង់ឆ្នេរស្ទឹងនេរញ្ជរា ។ ពិតហើយ ព្រោះលោកនៅត្រង់ឆ្នេរស្ទឹង និងព្រោះជាកស្សបគោត្ត ទើបមាននាមថា **នទីកស្សបៈ** ព្រះមានព្រះភាគបានប្រទានឧបសម្បទាដល់ព្រះថេរៈ មួយអន្លើដោយបរិវារដោយឯហិភិក្ខុភាវៈ ។ រឿងទាំងអស់មកហើយក្នុងខន្ធកៈនោះឯង ។ ព្រះថេរៈតាំងនៅក្នុងអរហត្ត ដោយអាទិត្តបរិយាយសូត្រ សមដូចគាថាព័ន្ធដែលលោកពោលក្នុងអបទានថា

កាលព្រះសម្ពុទ្ធ ព្រះនាមបទុមុត្តរៈជាច្បងក្នុងលោក ព្រះអង្គមិនញាប់ញ័រដោយលោកធម៌ ទ្រទ្រង់នូវយសដ៏ឧត្តម ទ្រង់ស្តេចយាងបិណ្ឌបាត ។ ខ្ញុំមានចិត្តជ្រះថ្លា បានយកផ្លែឈើថ្មោង ចូលទៅថ្វាយព្រះសាស្តា ព្រះអង្គជាទក្ខិណេយ្យបុគ្គល ជាអ្នកប្រាជ្ញធំ ( ហើយពោលថា ) បពិត្រព្រះអង្គជាធំជាងសត្វជើងពីរជាច្បងក្នុងលោក ប្រសើរជាងពួកជន ខ្ញុំព្រះអង្គសូមលះបង់នូវការឈ្នះ និងការចាញ់ ហើយដល់នូវធម៌មិនកម្រើក គឺព្រះនិព្វាន ដោយកុសលកម្មនោះ ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានឲ្យទាន ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃទានថ្មោង ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

១- ក្នុងអបទាន ជាជម្ពុផលិយត្ថេរ ។

ព្រះថេរៈកាលតាំងនៅក្នុងអរហត្តហើយ ក្រោយមក ពិចារណាកិច្ចបដិបត្តិរបស់ខ្លួន កាលព្យាករអរហត្តផល ដោយប្រារព្ធដល់ការដកនូវទិដ្ឋិជាប្រធាន ទើបពោល ៥ គាថាថា

អាត្មាអញបានស្តាប់ធម៌ របស់ព្រះពុទ្ធណា ហើយវៀរបង់មិច្ឆាទិដ្ឋិ ព្រះពុទ្ធនោះ យាងមកហើយកាន់ស៊ីងនេរញ្ជរា ដើម្បីប្រយោជន៍ដល់អញមែនពិត ។ អាត្មាអញបានបូជាយញ្ញទាំងឡាយ ខ្ពស់

និងទាបបានបូជាភ្លើង កាលនៅជាបុថុជ្ជន ងងឹតងងល់ សម្គាល់ថា ការបូជានេះឯង ជាសេចក្តីបរិសុទ្ធ ។ អាត្មាអញ ស៊ុះទៅកាន់ព្រៃស្បាត គឺទិដ្ឋិ ត្រូវសេចក្តីស្មាបអង្អែល ( ខុស ) ឲ្យដល់នូវសេចក្តីវង្វេង ងងឹតមិនដឹង សម្គាល់ផ្លូវមិនបរិសុទ្ធ ថាជាផ្លូវបរិសុទ្ធ ។ មិច្ឆាទិដ្ឋិ អាត្មាអញបានលះបង់ហើយ ភពទាំងពួង អាត្មាអញបានទម្លុះទម្លាយហើយ អាត្មាអញបូជាភ្លើង គឺព្រះសម្មាសម្ពុទ្ធ ជាទក្ខិណេយ្យបុគ្គល ថ្វាយបង្គំនូវព្រះតថាគត ។ មោហៈទាំងពួង អាត្មាអញបានលះបង់ហើយ ភវតណ្ហា អាត្មាអញបានទម្លុះទម្លាយចេញហើយ ជាតិសង្សារ អស់រលីងហើយ ឥឡូវនេះ ភពថ្មីទៀតនៃអាត្មាអញ មិនមានទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អត្ថាយ វត មេ** សេចក្តីថា ដើម្បីជាប្រយោជន៍ គឺដើម្បីជាប្រយោជន៍ និងសេចក្តីចម្រើនដល់អញហ្ន៎ ។

បទថា **ពុទ្ធោ** បានដល់ ព្រះសព្វញ្ញុពុទ្ធ ។

បទថា **នទឹ នេរញ្ជរំ អគា** សេចក្តីថា បានទៅកាន់ស្ទឹងឈ្មោះនេរញ្ជរា អធិប្បាយថា ទៅកាន់អាស្រមរបស់ឧរុវេលកស្សបៈបងប្រុសរបស់ខ្ញុំ ក្បែរឆ្នេរស្ទឹងនោះ ។

ឥឡូវនេះ ដើម្បីលម្អិតសេចក្តីតាមដែលពោលហើយ ទើបលោកពោលថា **យស្សាហំ** ដូច្នេះជាដើម ។

បទថា **យស្ស** បានដល់ របស់ព្រះមានព្រះភាគអង្គណា ។

បទថា **ធម្មំ សុត្វាន** សេចក្តីថា ស្តាប់ធម៌ដែលទាក់ទងដោយសច្ចៈ ៤ គឺបានទទួលស្តាប់តាមក្រសែនៃសោតទ្វារ ។

បទថា **មិច្ឆាទិដ្ឋឹ វិវជ្ជយឹ** សេចក្តីថា លះនូវការឃើញខុស ដែលប្រព្រឹត្តទៅដោយន័យជាដើមថា សេចក្តីបរិសុទ្ធ រមែងមានដោយយញ្ញជាដើម ។

ដើម្បីសម្តែងឲ្យពិស្តារនូវការដែលពោលដោយបទថា **មិច្ឆាទិដ្ឋឹ វិវជ្ជយឹ** នេះ ទើបពោលពាក្យជាដើមថា **យជឹ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **យជឹ ឧច្ចាវចេ យញ្ញេ** សេចក្តីថា បូជាយញ្ញដែលប្រាកដ គឺយញ្ញផ្សេងៗ មានការបួងសួងព្រះចន្ទ និងការបូជាដោយលាជ និងទឹកដែលគួរផឹកជាដើម ។

បទថា **អគ្គិហុត្តំ ជុហឹ អហំ** សេចក្តីថា កាលខ្ញុំសរសើរការបូជាដោយអំណាចការបូជាយញ្ញទាំងនោះ ទើបបម្រើភ្លើង ។

បទថា **ឯសា សុទ្ធីតិ មញ្ញន្តោ** សេចក្តីថា សម្គាល់ថា យញ្ញកិរិយា គឺការបម្រើភ្លើងនេះ ជាការបរិសុទ្ធ ដោយភាពជាហេតុឲ្យបរិសុទ្ធ គឺជាការបរិសុទ្ធចាកសង្សារ រមែងមានដល់ខ្ញុំ ដោយអាការយ៉ាងនេះ ។

បទថា **អន្ធភូតោ បុថុជ្ជនោ** សេចក្តីថា ឈ្មោះថា **អន្ធភូតោ បុថុជ្ជនោ** ព្រោះខ្វាក់ដោយអវិជ្ជា ដ្បិតមិនមានភ្នែក គឺបញ្ញា ។ ព្រៃស្គុក គឺទិដ្ឋិ ឈ្មោះថា **ទិដ្ឋិគហណំ** ព្រោះអត្ថថា ឆ្លងបានដោយលំបាក ដូចព្រៃក្រាស់ និងភ្នំខ្ពស់ជាដើម ទើបស្ទុះទៅ គឺចូលទៅកាន់ព្រៃស្គុក គឺទិដ្ឋិនោះ

ព្រោះហេតុនោះ ទើបឈ្មោះថា **ទិដ្ឋិគហណបក្ខន្ទោ** ប្រែថា ស្ទុះទៅកាន់ព្រៃស្បាត គឺទិដ្ឋិ ។

បទថា **បរាមាសេន** សេចក្តីថា ដោយការឈានកន្លងសេចក្តីពិតនៃធម៌ ទៅប្រកាន់ខុស ពោល គឺការប្រកាន់ដោយការជឿខុសថា នេះប៉ុណ្ណោះពិត ។

បទថា **មោហិតោ** សេចក្តីថា ឲ្យដល់នូវភាពជាអ្នកវង្វេង ។

បទថា **អសុទ្ធិំ មញ្ញិសំ សុទ្ធិំ** សេចក្តីថា សម្គាល់ គឺយល់ក្នុងផ្លូវដែលមិនបរិសុទ្ធ ថាបរិសុទ្ធ ដូច្នេះ ។

លោកពោលហេតុក្នុងសេចក្តីនោះថា ជាបុគ្គលងងឹត មិនដឹង អធិប្បាយថា ជាបុគ្គលងងឹតដោយអវិជ្ជា ដូច្នោះ ទើបមិនដឹងធម៌ និងអធម៌ ធម៌ដែលដែលគួរ និងធម៌មិនគួរ ទើបសម្គាល់យ៉ាងនោះ ។

បទថា **មិច្ឆាទិដ្ឋិ បហីនា មេ** សេចក្តីថា កាលខ្ញុំស្តាប់ធម្មកថា គឺសច្ចៈ ៤ ក្នុងទីចំពោះព្រះភក្ត្រព្រះសាស្តាយ៉ាងនោះ បដិបត្តិដោយឧបាយប្រាជ្ញា លះនូវមិច្ឆាទិដ្ឋិទាំងអស់ ដោយសម្មាទិដ្ឋិ ដែលសម្បយុត្តដោយអរិយមគ្គ ដោយសមុច្ឆេទប្បហាន ។

បទថា **ភវា** សេចក្តីថា ភពទាំងពួង មានកាមភពជាដើម ខ្ញុំទម្លាយហើយ គឺកម្ចាត់ហើយដោយសស្ត្រា គឺអរិយមគ្គ ។

បទថា **ជុហាមិ ទក្ខិណេយ្យគ្គឹ** សេចក្តីថា ខ្ញុំលះនូវភ្លើង មានភ្លើងដែលបុគ្គលគប្បីបូជាជាដើម ហើយបូជា គឺបម្រើទក្ខិណេយ្យគ្គិ គឺព្រះសម្មា-

សម្ពុទ្ធ ព្រោះទ្រង់ជាព្រះទក្ខិណេយ្យបុគ្គលនៃលោក ព្រមទាំងទេវលោក និង ព្រោះជុតនូវបាបទាំងពួង ការបម្រើទក្ខិណេយ្យគ្គិរបស់ខ្ញុំនេះ មិនបានសំដៅ វត្ថុ មានទឹក នវនីត តក្កៈ និងសប្បិជាដើមឡើយ ជាការនមស្ការព្រះសាស្ដា ប៉ុណ្ណោះ ព្រោះដូច្នោះ ទើបព្រះថេរៈពោលថា **នមស្សាមិ តថាគតំ** ប្រែថា ខ្ញុំថ្វាយបង្គំនូវព្រះតថាគត ។

ម្យ៉ាងទៀត បទថា **ជុហាមិ ទក្ខិណេយ្យគ្គឹ** សេចក្ដីថា រមែងបូជា គឺ បម្រើខ្លួន ដែលជាទក្ខិណេយ្យគ្គិ ដោយការធ្វើទក្ខិណារបស់ទាយកឲ្យមានផល ច្រើន និងដោយការជុតបាប គឺរមែងបម្រើ រមែងបរិហារយ៉ាងនោះ កាល មុន ខ្ញុំថ្វាយបង្គំអគ្គិទេព តែឥឡូវនេះ ខ្ញុំថ្វាយបង្គំព្រះតថាគត ។

បទថា **មោហា សព្វេ បហីនា មេ** សេចក្ដីថា មោហៈទាំងពួង មាន ការមិនដឹងទុក្ខជាដើម ខ្ញុំលះបានហើយ គឺកាត់ផ្ដាច់ហើយ ព្រោះហេតុនោះ ទើបខ្ញុំឈ្មោះថា ទម្លាយភវតណ្ហាបានហើយ ។

**មេ** ( អាត្មាអញ ) សព្វ គប្បីនាំមកប្រកបចូលក្នុងបទទាំង ៣ ថា ភវតណ្ហា អាត្មាអញបានទម្លុះទម្លាយចេញហើយ ជាតិសង្សារ អាត្មាអញ អស់រលីងហើយ ឥឡូវនេះ ភពថ្មីទៀតនៃអាត្មាអញមិនមានទេ ដូច្នេះ ៕

**អដ្ឋកថា ឧទិកស្សបត្ថេរគាថា ចប់**

# សុត្តន្តបិដក

## គយាកស្សបត្ថេរគាថា

[ ២០៥ ] អាត្មាអញចុះទឹកក្នុងកំពង់ឈ្មោះគយា ក្នុងមួយថ្ងៃ ៣ ដង គឺពេលព្រឹក ថ្ងៃត្រង់ ល្ងាច ក្នុងកាលមហោស្រពឈ្មោះគយផគ្គុ បាបណា ដែលអាត្មាអញធ្វើហើយ ក្នុងជាតិទាំងឡាយដទៃ អំពីកាលមុន ឥឡូវនេះ អាត្មាអញបណ្តែតចោលនូវបាបនោះ ក្នុងកំពង់ឈ្មោះគយានេះ ទិដ្ឋិយ៉ាងនេះ មានហើយក្នុងកាលមុន ។ អាត្មាអញស្តាប់វាចាជាសុភាសិត ជាបទប្រកប ដោយធម៌ និងអត្ថ ហើយពិចារណានូវសេចក្តីតាមគួរដល់ការពិត ដោយ ឧបាយនៃប្រាជ្ញា ។ អាត្មាអញមានបាបទាំងពួង លាងចេញហើយ មិនមាន មន្ទិល មានកិលេសលាងចេញហើយ ជាអ្នកស្អាតបរិសុទ្ធ ជាពុទ្ធទាយាទ ( អ្នកគួរទទួលនូវមត៌កនៃព្រះពុទ្ធ ) ជាកូនកើតអំពីព្រះឧរនៃព្រះពុទ្ធ ។ អាត្មា អញ ចុះកាន់ខ្សែនៃមគ្គប្រកបដោយអង្គ ៨ ហើយ បណ្តែតចោលនូវបាប ទាំងពួង ដល់នូវវិជ្ជា ៣ ហើយ សាសនារបស់ព្រះពុទ្ធ អាត្មាអញបាន ធ្វើហើយ ។

គយាកស្សបត្ថេរ

# អដ្ឋកថា

## គយាកស្សបត្ថេរគាថា

[ ២០៥ ] គាថារបស់ព្រះគយាកស្សបត្ថេរ មានពាក្យផ្ដើមថា **ចាតោ មជ្ឈន្តិកំ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ។ ក្នុងកប្បទី ៣១ រាប់អំពីភទ្ទកប្បនេះ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមសិខី កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្ដីហើយ លះការគ្រប់គ្រងផ្ទះ ព្រោះមានអជ្ឈាស្រ័យក្នុងការចេញចាកទុក្ខ បួសជាតាបស ធ្វើអាស្រមក្នុងដងព្រៃ មានឫសឈើ និងផ្លែឈើជាអាហារ ។ សម័យនោះ ព្រះមានព្រះភាគយាងទៅមួយអង្គឯង មិនមានសម្លាញ់ ទៅកាន់អាស្រមរបស់កុលបុត្តនោះ ។ កុលបុត្តនោះ ឃើញព្រះមានព្រះភាគហើយ មានចិត្តជ្រះថ្លា ទើបចូលទៅគាល់ថ្វាយបង្គំហើយ ឈរក្នុងចំណែកម្ខាង សម្លឹងមើលបានបង្អោនផ្លែពុទ្រា ដែលមានរសឆ្ងាញ់ ថ្វាយដល់ព្រះសាស្ដា ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលព្រាហ្មណ៍ ចម្រើនវ័យហើយ លះនូវការគ្រប់គ្រងផ្ទះ ព្រោះមានអជ្ឈាស្រ័យក្នុងនិស្សរណៈ បួសជាតាបសមួយអន្លើដោយតាបស ២០០ នៅត្រង់គយាបទេស ។ ព្រោះលោកនៅត្រង់គយាបទេស និងជាកស្សបគោត្ត ទើបបានឈ្មោះថា **គយាកស្សបៈ** ។

ព្រះមានព្រះភាគ ទ្រង់ប្រទានឯហិភិក្ខុឧបសម្បទា មួយអន្លើដោយបរិស័ទ ហើយទ្រង់ទូន្មានដោយអាទិត្តបរិយាយសូត្រ តាំងនៅក្នុងអរហត្តសមដូចគាថាព័ន្ធដែលលោកពោលក្នុងអបទានថា

កាលនោះ ខ្ញុំស្លៀកស្បែកខ្លា ទ្រទ្រង់សំពត់សម្បកឈើ បានរែកផ្លែពុទ្រាមួយអម្រែក ទៅឯអាស្រមរបស់ខ្ញុំ ។ ក្នុងកាលនោះ ព្រះសម្ពុទ្ធព្រះនាមសិខី ព្រះអង្គមិនមានបុគ្គលជាគម្រប់ពីរ រុងរឿងសព្វៗ កាល ទ្រង់ស្តេចចូលទៅក្នុងអាស្រមរបស់ខ្ញុំ តែមួយព្រះអង្គឯង ។ ខ្ញុំញុំាងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា ហើយថ្វាយបង្គំព្រះសម្ពុទ្ធ ព្រះអង្គមានវត្តល្អ រួចកាន់យកនូវផ្លែពុទ្រា ដោយដៃទាំងពីរ ថ្វាយដល់ព្រះពុទ្ធ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែពុទ្រា ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយផ្លែពុទ្រា ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ ។

១- ក្នុងអបទាន ជាកោលទាយកត្ថេរ ។

ព្រះថេរៈតាំងនៅក្នុងអរហត្តហើយ ពិចារណាបដិបទារបស់ខ្លួន កាលនឹងព្យាករអរហត្តផល ដោយប្រារព្ធការបន្សាត់បាបជាប្រធាន ទើបពោល ៥ គាថាថា

អាត្មាអញចុះទឹកក្នុងកំពង់ឈ្មោះគយា ក្នុងមួយថ្ងៃ ៣ ដង គឺ

ពេលព្រឹក ថ្ងៃត្រង់ ល្ងាច ក្នុងកាលមហោស្រពឈ្មោះគយផគ្គុ បាបណា ដែលអាត្មាអញធ្វើហើយ ក្នុងជាតិទាំងឡាយដទៃ អំពីកាលមុន ឥឡូវនេះ អាត្មាអញបណ្តែតចោលនូវបាបនោះ ក្នុងកំពង់ឈ្មោះគយានេះ ទិដ្ឋិយ៉ាងនេះ មានហើយក្នុងកាលមុន ។ អាត្មាអញស្តាប់វាចាជាសុភាសិត ជាបទប្រកប ដោយធម៌ និងអត្ថ ហើយពិចារណានូវសេចក្តីតាមគួរដល់ការពិត ដោយឧបាយនៃប្រាជ្ញា ។ អាត្មាអញមានបាបទាំងពួង លាងចេញហើយ មិនមានមន្ទិល មានកិលេសលាងចេញហើយ ជាអ្នកស្អាតបរិសុទ្ធ ជាពុទ្ធទាយាទ ( អ្នកគួរទទួលនូវមត៌កនៃព្រះពុទ្ធ ) ជាកូនកើតអំពីព្រះឱរនៃព្រះពុទ្ធ ។ អាត្មាអញចុះកាន់ខ្សែនៃមគ្គ ប្រកបដោយអង្គ ៨ ហើយ បណ្តែតចោលនូវបាបទាំងពួង ដល់នូវវិជ្ជា ៣ ហើយ សាសនារបស់ព្រះពុទ្ធ អាត្មាអញបានធ្វើហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ គាថាដំបូង មានសេចក្តីសង្ខេបដូចតទៅនេះ ក្នុងពេលព្រឹក គឺក្នុងពេលព្រះអាទិត្យរះ ក្នុងពេលថ្ងៃត្រង់ គឺក្នុងពេលថ្ងៃត្រង់ ក្នុងពេលល្ងាច គឺក្នុងពេលល្ងាច អធិប្បាយថា ខ្ញុំចុះទឹកមួយថ្ងៃ ៣ ដង គឺមួយថ្ងៃ ៣ វារៈ ខ្ញុំនោះ កាលចុះ មិនថាចុះក្នុងណា វេលាណាក៏បាន ដោយពិត ត្រូវប្រកបវិធីចុះទឹករាល់ៗ ឆ្នាំ ត្រង់ស៊ីងគយា គឺត្រង់កំពង់គយា ដែលប្រកាន់ថា ជាទីបន្សាត់បាបរបស់មហាជន ក្នុងស៊ីងគយា នាទេសកាលគយផគ្គុណី គឺក្នុងនក្ខត្តប្ញក្សផគ្គុណី ខាងចុងខែផល្គុន ហៅថា ផគ្គុនក្ខត្តប្ញក្ស ។

ឥឡូវនេះ ដើម្បីនឹងសម្តែងបំណងចុះងូតទឹកក្នុងកាលនោះ ទើបលោកពោលគាថាថា **យំ មយា** ដូច្នេះជាដើម ។

ពាក្យជាគាថានោះ មានអធិប្បាយថា កាលមុន គឺមុនការចូលដល់សាសនារបស់ព្រះសាស្តា ខ្ញុំមានការឃើញយ៉ាងនេះ គឺឃើញវិបរិតយ៉ាងនេះថា បាបកម្មឯណាដែលខ្ញុំសន្សំក្នុងកាលមុន គឺក្នុងជាតិដទៃអំពីជាតិនេះ បាបកម្មនោះ ឥឡូវនេះ ខ្ញុំបន្សាត់ហើយ គឺធ្វើឲ្យប្រាសចាកទៅ ខ្ចាត់ចោលហើយ ដោយការចុះកាន់ទឹកក្នុងកំពង់គយានេះ និងក្នុងតិបឹគយាផគ្គុនេះ ។

បទថា **ធម្មត្ថសហិតំ បទំ** ជាបទសម្តែងលម្អិត ដោយមិនលុបវិភត្តិ ខ្ញុំបានស្តាប់វាចាដែលជាសុភាសិត គឺព្រះតម្រាស់របស់ព្រះសម្មាសម្ពុទ្ធ ដែលជាចំណែកប្រកបដោយធម៌ និងអត្ថ គឺដែលប្រកបដោយហេតុ និងផលខាងដើម កណ្តាល និងខាងចុង ជាវាចានាំសត្វចេញចាកទុក្ខដោយល្អ គឺដោយចំណែកមួយ ហើយពិចារណាអត្ថនៃទុក្ខជាដើម ឈ្មោះថា **តថំ** ព្រោះជារបស់ពិត ដោយភាពជាបរមត្ថ ដែលព្រះសម្មាសម្ពុទ្ធទ្រង់ប្រកាសហើយ ឈ្មោះថា **យាថាវកំ** ព្រោះមិនមានការប្រព្រឹត្តខុសប្លែកក្នុងភាពជាឧបាយនៃ

ការប្រព្រឹត្តទៅ គឺទុក្ខ និងការត្រឡប់ គឺនិរោធ តាមសមគួរ ដោយឧបាយនៃប្រាជ្ញា គឺដោយការៈនៃកិច្ច មានការកំណត់ដឹងជាដើមដោយឧបាយ គឺពិចារណាថា ទុក្ខសច្ច គួរកំណត់ដឹង សមុទយសច្ច គួរលះ និរោធសច្ច គួរធ្វើឲ្យជាក់ច្បាស់ មគ្គសច្ច គួរធ្វើឲ្យកើត អធិប្បាយថា ឃើញហើយ ចាក់ធ្លុះហើយ ដោយញាណចក្ខុ ។

បទថា **និន្ហាតសព្វបាបោម្ហិ** សេចក្តីថា ខ្ញុំជាអ្នកខ្ជាក់នូវបាបទាំងពួង ដោយអរិយមគ្គ អរិយផល ព្រោះចាក់ធ្លុះនូវសច្ចៈ ដោយអាការយ៉ាងនេះនោះឯង ព្រោះហេតុនោះ ទើបខ្ញុំជាបុគ្គលឈ្មោះថា **និម្មលោ** ព្រោះមិនមានមន្ទិល ដោយមិនមានមន្ទិល គឺរាគៈជាដើម ព្រោះហេតុនោះ ទើបខ្ញុំជាបុគ្គលឈ្មោះថា **បយតោ សុចិ សុទ្ធោ** ព្រោះមានកាយសមាចារបរិសុទ្ធ ព្រោះមានវចីសមាចារបរិសុទ្ធ និងព្រោះមានមនោសមាចារបរិសុទ្ធ ឈ្មោះថា **ទាយាទោ** ព្រោះជាខាងដើមរបស់ធម្មទាយាទ ដែលជាលោកុត្តរនៃព្រះមានព្រះភាគ ដែលឈ្មោះថា **សុទ្ធស្ស** ព្រោះបរិសុទ្ធចាកមន្ទិល គឺកិលេសទាំងពួង មួយអន្លើដោយវាសនា មានពាក្យអធិប្បាយប្រកបសេចក្តីថា ជា

ឱរសេ គឺជាបុត្តរបស់ព្រះមានព្រះភាគសម្ពុទ្ធនោះឯង ព្រោះមានអភិជាតិ ដែលកើតអំពីព្យាយាម គឺទ្រូង ដែលមានទេសនាញាណជាសមុដ្ឋាន ។ ដើម្បីប្រកាសថា ខ្លួនជាអ្នកដួតហើយដោយបរមត្ថទៀត ទើបពោលគាថាចុងក្រោយថា **ឱគយ្ហ** ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **ឱគយ្ហ** សេចក្ដីថា ឈមចុះហើយ គឺចូលទៅហើយ ដោយលំដាប់ ។ បទថា **អដ្ឋង្គិកំ សោតំ** បានដល់ ក្រសែនៃមគ្គ ដែលជាទីប្រជុំនៃអង្គ ៨ មានសម្មាទិដ្ឋិជាដើម ។ បទថា **សព្វំ ចាបំ បវាហយឹ** សេចក្ដីថា ខ្ជាក់ហើយនូវមន្ទិល គឺបាប មិនមានចំណែកសេសសល់ គឺជាអ្នកខ្ជាក់ហើយដោយបរមត្ថ ព្រោះបន្សាត់ក្នុងស្ទឹង គឺអរិយមគ្គ ។ បន្ទាប់អំពីនោះ ពាក្យថា ដល់នូវវិជ្ជា ៣ ហើយ សាសនារបស់ព្រះពុទ្ធអាត្មាអញបានធ្វើហើយ ដូច្នេះ ពាក្យនេះ មានអត្ថដូចពោលហើយនោះឯង ៕

**អដ្ឋកថា គយាកស្សបត្ថេរគាថា ចប់**

# សុត្តន្តបិដក

## វក្កលិត្ថេរគាថា

[ ២០៦ ] ( ព្រះមានព្រះភាគត្រាស់សួរថា ) ម្នាលភិក្ខុ អ្នកត្រូវរោគដែលកើតអំពីខ្យល់ គ្របសង្កត់ហើយ នៅក្នុងព្រៃធំ មានគោចរលះបង់ហើយ ( ក្រចតុប្បច្ច័យ ) ជាទីសៅហ្មង តើនឹងធ្វើដូចម្តេច ។

( ព្រះវក្កលិត្ថេរក្រាបបង្គំទូលថា ) ខ្ញុំព្រះអង្គផ្សាយចិត្តទៅកាន់កាយទាំងមូល ដោយសុខដែលកើតអំពីបីតិដ៏លើសលុប អត់ទ្រាំនូវបច្ច័យដ៏សៅហ្មង នៅក្នុងព្រៃធំ ។ ខ្ញុំព្រះអង្គចម្រើនសតិប្បដ្ឋានទាំងឡាយផង សម្មប្បធានផង ឥទ្ធិបាទផង ឥន្ទ្រិយផង ពលផង ចម្រើនពោជ្ឈង្គផង អដ្ឋង្គិកមគ្គផង នៅក្នុងព្រៃធំ ។ ខ្ញុំព្រះអង្គឃើញ ( នូវសព្រហ្មចារីបុគ្គលទាំងឡាយ ) អ្នកមានព្យាយាមតឹងតែងហើយ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន មានព្យាយាមប្រឹងប្រែងដ៏មាំអស់កាលជានិច្ច មានសេចក្តីព្រមព្រៀងគ្នា ប្រកបដោយភាពជាសមណៈនៅក្នុងព្រៃធំ ។ ខ្ញុំព្រះអង្គនឹករឿយៗ នូវព្រះសម្ពុទ្ធ ព្រះអង្គមានខ្លួនទូន្មានបានហើយ មានព្រះហឫទ័យតាំងមាំហើយ មិនខ្ជិលច្រអូស អស់យប់ និងថ្ងៃ នៅក្នុងព្រៃធំ ។

វក្កលិត្ថេរ

# អដ្ឋកថា

## វក្កលិត្ថេរគាថា

[ ២០៦ ] គាថារបស់ព្រះវក្កលិត្ថេរ មានពាក្យផ្ដើមថា **វាតរោគាភិនីតោ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កើតក្នុងផ្ទះមានត្រកូល ក្នុងហង្សវតីនគរ ដល់នូវភាពជាអ្នកដឹងក្ដីហើយ ទៅកាន់វិហារជាមួយឧបាសកទាំងឡាយ ដែលទៅកាន់សម្នាក់ព្រះសាស្ដា ឈរខាងចុងបរិស័ទស្ដាប់ធម៌ ឃើញព្រះសាស្ដាទ្រង់ស្ថាបនាភិក្ខុមួយរូប ក្នុងតំណែងជាឯតទគ្គៈជាងភិក្ខុដែលបង្អោនទៅក្នុងសទ្ធា ខ្លួនឯងក៏ប្រាថ្នាតំណែងនោះ ទើបថ្វាយទានអស់ ៧ ថ្ងៃ បានតាំងសេចក្ដីប្រាថ្នា ។ ព្រះសាស្ដាទតឃើញសេចក្ដីប្រាថ្នានោះ មិនមានអន្តរាយ ទើបទ្រង់ព្យាករ ។

កុលបុត្តនោះធ្វើកុសលជរាបដល់អស់ជីវិត អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងសាសនានៃព្រះសាស្ដារបស់យើងទាំងឡាយ កើតក្នុងត្រកូលព្រាហ្មណ៍ នាក្រុងសាវត្ថី ញាតិទាំងឡាយបានដាក់ឈ្មោះថា **វក្កលិ** ។ កុលបុត្តនោះចម្រើនវ័យហើយ រៀននូវវេទ ៣ ដល់នូវការសម្រេចក្នុងសិប្បៈនៃព្រាហ្មណ៍ ឃើញព្រះសាស្ដាហើយ មិនឆ្អែតក្នុងការឃើញព្រះរូបសម្បត្តិ ទើបត្រាច់ទៅជាមួយព្រះសាស្ដាប៉ុណ្ណោះ គិតថា បើអញនៅគ្រប់គ្រងផ្ទះ នឹងមិនបានឃើញព្រះសាស្ដាអស់កាលជានិច្ចឡើយ ទើបបួសក្នុងសម្នាក់ព្រះមុនី

ឈរក្នុងទីដែលអាចឃើញព្រះទសពល ក្នុងវេលាដ៏សេស វៀរតែពេលធាន់ពេលបដិបត្តិសរីរៈ ទើបលះកិច្ចដទៃ សម្លឹងមើលតែព្រះមានព្រះភាគប៉ុណ្ណោះ ។

ព្រះសាស្តា ទ្រង់រង់ចាំភាពចាស់ក្លានៃញាណរបស់ព្រះថេរៈៗ ត្រាច់ទៅដោយការមើលព្រះរូបប៉ុណ្ណោះអស់កាលយូរ ព្រះសាស្តាក៏មិនត្រាស់ពាក្យណាមួយ ។ ថ្ងៃមួយ ទើបត្រាស់ ( សំយុត្តនិកាយ ខន្ធវារវគ្គ ) ថា កុំឡើយ វក្កលិ ប្រយោជន៍អ្វីដោយកាយស្អុយ ដែលអ្នកឃើញហើយនេះ ។ ម្នាលវក្កលិ បុគ្គលណា ឃើញធម៌ បុគ្គលនោះ ឈ្មោះថា ឃើញតថាគត បុគ្គលណា ឃើញតថាគត បុគ្គលនោះ ឈ្មោះថា ឃើញធម៌ ។ ម្នាលវក្កលិ ព្រោះថា កាលបើបុគ្គលឃើញធម៌ ឈ្មោះថា ឃើញតថាគត កាលបើបុគ្គលឃើញតថាគត ឈ្មោះថា ឃើញធម៌ ដូច្នេះ ។

កាលព្រះសាស្តាត្រាស់យ៉ាងនោះ ព្រះថេរៈក៏មិនអាចលះបង់នូវការមើលព្រះសាស្តា ហើយទៅកាន់ទីដទៃបាន ។ លំដាប់នោះ ព្រះសាស្តាទ្រង់ព្រះតម្រិះថា ភិក្ខុនេះ បើមិនបាននូវសេចក្តីសង្វេគ នឹងមិនត្រាស់ដឹង ដូច្នេះ ក្នុងថ្ងៃចូលវស្សា ទើបបណ្តេញព្រះថេរៈ ដោយព្រះតម្រាស់ថា ម្នាលវក្កលិ អ្នកចូរចៀសចេញទៅ ។ ព្រះថេរៈត្រូវព្រះសាស្តាទ្រង់បណ្តេញ មិនអាចនៅក្នុងទីចំពោះព្រះភក្ត្របាន ទើបគិតថា ប្រយោជន៍អ្វី ដោយការរស់នៅរបស់អញ ដែលមិនឃើញព្រះសាស្តា ដូច្នេះហើយ ទើបឡើងកាន់ភ្នំគិជ្ឈកូដត្រង់ទីដែលមានជ្រោះ ។ ព្រះសាស្តាទ្រង់ជ្រាបរឿងនោះរបស់ព្រះថេរៈ ទើបទ្រង់ព្រះតម្រិះថា ភិក្ខុនេះមិនបាននូវការស្រោកស្រាន្តចិត្តអំពីសម្នាក់របស់តថាគត

នឹងញ៉ាំងធម៌ដែលជាឧបនិស្ស័យនៃមគ្គផលឲ្យវិនាសទៅ កាលទ្រង់បញ្ចេញព្រះរស្មីដើម្បីបង្ហាញព្រះកាយ ទើបត្រាស់ព្រះគាថា ( ក្នុងព្រះធម្មបទ ) ថា

ភិក្ខុអ្នកក្រាស់ដោយសេចក្ដីរីករាយ ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា
រមែងបាននូវបទដ៏ស្ងប់ ជាទីរម្ងាប់នូវសង្ខារ នាំមកនូវសេចក្ដីសុខ
ដូច្នេះ ។

ហើយទ្រង់លាព្រះហស្ត ត្រាស់ថា ម្នាលវក្កលិ អ្នកចូរមកចុះ ព្រះថេរៈគិតថា អញឃើញព្រះទសពលហើយ សូម្បីការត្រាស់ហៅថា ចូរមក អញក៏បានហើយ ដូច្នេះហើយ កើតបីតិ និងសោមនស្សដ៏មានកម្លាំង មិនដឹងថាមកអំពីណា នឹងទៅទីណា ទើបលោតទៅក្នុងអាកាស ក្នុងទីចំពោះព្រះភក្ត្ររបស់ព្រះសាស្ដា ដោយប្រើជើងម្ខាងជាន់ត្រង់កំពូលភ្នំ អាវជ្ជនៈដល់គាថាដែលព្រះសាស្ដាត្រាស់ សង្កត់បីតិក្នុងអាកាសនោះឯង សម្រេចអរហត្តមួយអន្លើដោយបដិសម្ភិទា ដូច្នេះ រឿងនេះ មកហើយក្នុងអដ្ឋកថា អង្គុត្តរ-និកាយ និងអដ្ឋកថាធម្មបទ ។

តែក្នុងសូត្រនេះ អាចារ្យពួកខ្លះពោលយ៉ាងនេះថា ព្រះវក្កលិត្ថេរកាលព្រះសាស្ដាទ្រង់ទូន្មានដោយន័យជាដើមថា កុំឡើយ វក្កលិ ប្រយោជន៍អ្វីដោយកាយស្អុយ ដែលអ្នកឃើញហើយនេះ ... ដូច្នេះ ឈរនៅលើភ្នំផ្ដើមចម្រើនវិបស្សនា ព្រោះលោកមានសទ្ធាជាកម្លាំងនោះឯង ទើបវិបស្សនាមិនចុះកាន់វិថី ព្រះមានព្រះភាគទ្រង់ជ្រាបដូច្នោះ ទើបបានឲ្យព្រះថេរៈជម្រះកម្មដ្ឋានឲ្យបរិសុទ្ធប្រទានឲ្យ ព្រះថេរៈក៏មិនអាចឲ្យវិបស្សនាដល់ទីបំផុតបាន

ទៀត ។ លំដាប់នោះ រោគខ្យល់ ព្រោះការអត់នូវអាហារ បានកើតដល់ព្រះថេរៈ ។ ព្រះមានព្រះភាគទ្រង់ជ្រាបថា រោគខ្យល់បៀតបៀន ទើបយាងទៅក្នុងទីនោះ កាលត្រាស់សួរ ទើបត្រាស់ថា

ម្នាលភិក្ខុ អ្នកត្រូវរោគ ដែលកើតអំពីខ្យល់ គ្របសង្កត់ហើយ
នៅក្នុងព្រៃធំ មានគោចរលះបង់ហើយ ( ក្រចតុប្បច្ច័យ )
ជាទីសៅហ្មង តើនឹងធ្វើដូចម្តេច ដូច្នេះ ។

ព្រះថេរៈបានស្តាប់ដូច្នោះ ទើបក្រាបទូលដោយ ៤ គាថាថា

ខ្ញុំព្រះអង្គផ្សាយចិត្តទៅកាន់កាយទាំងមូល ដោយសុខដែលកើតអំពីបីតិដ៏លើសលុប អត់ទ្រាំនូវបច្ច័យដ៏សៅហ្មង នៅក្នុងព្រៃធំ ។ ខ្ញុំព្រះអង្គចម្រើនសតិប្បដ្ឋានទាំងឡាយផង សម្មប្បធានផង ឥទ្ធិបាទផង ឥន្ទ្រិយផង ពលផង ចម្រើនពោជ្ឈង្គផង អដ្ឋង្គិកមគ្គផង នៅក្នុងព្រៃធំ ។ ខ្ញុំព្រះអង្គឃើញ ( នូវសព្រហ្មចារីបុគ្គលទាំងឡាយ ) អ្នកមានព្យាយាមតឹងតែងហើយ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន មានព្យាយាមប្រឹងប្រែង ដ៏មាំអស់កាលជានិច្ច មានសេចក្តីព្រមព្រៀងគ្នា ប្រកបដោយភាពជាសមណៈនៅក្នុងព្រៃធំ ។ ខ្ញុំព្រះអង្គនឹករឿយៗ នូវព្រះសម្ពុទ្ធ ព្រះអង្គមានខ្លួនទូន្មានបានហើយ មានព្រះហឫទ័យតាំងមាំហើយ មិនខ្ជិលច្រអូស អស់យប់ និងថ្ងៃ នៅក្នុងព្រៃធំ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វាតរោគាភិនីតោ** សេចក្តីថា ត្រូវរោគ

ខ្យល់នាំទៅកាន់ភាពមិនរឹងប៉ឹង គឺត្រូវព្យាធិដែលកើតអំពីរោគខ្យល់ គ្រប
សង្កត់ ។ ព្រះសាស្តាហៅព្រះថេរៈថា **ត្វំ** ( ម្នាលភិក្ខុ ) ។

បទថា **វិហរំ** សេចក្តីថា នៅដោយឥរិយាបថវិហារនោះ ។

បទថា **កាននេ វនេ** សេចក្តីថា ក្នុងព្រៃដែលជាព្រៃជ្រៅ អធិប្បាយ
ថា ក្នុងព្រៃធំ ។

បទថា **បវិទ្ធគោចរេ** សេចក្តីថា ជាទីប្រាសចាកគោចរ គឺជាទីដែល
រកបច្ច័យបានលំបាក ឈ្មោះថា **លូខេ** គឺក្នុងទីសៅហ្មង ព្រោះមិនមាន
ភេសជ្ជៈ មានសប្បិជាដើមដែលជាថ្នាំកែរោគខ្យល់ និងព្រោះជាទឹកដីដែល
អត្តខាត់ ។

បទថា **កថំ ភិក្ខុ ករិស្សសិ** សេចក្តីថា ព្រះមានព្រះភាគត្រាស់សួរថា
ម្នាលភិក្ខុ អ្នកនឹងធ្វើដូចម្តេច ។

ព្រះថេរៈបានស្តាប់ដូច្នោះ កាលនឹងប្រកាសការនៅជាសុខរបស់ខ្លួន
ដោយបីតិ និងសោមនស្សដែលប្រាសចាកអាមិស ទើបពោលពាក្យថា **បីតិ
សុខេន** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **បីតិ សុខេន** សេចក្តីថា ដោយបីតិដែល
មានការអណ្តែតជាលក្ខណៈ និងមានការជ្រួតជ្រាបផ្សាយទៅជាលក្ខណៈ និង
ដោយសុខដែលសម្បយុត្តដោយបីតិនោះ ។ ព្រោះហេតុនោះ ទើបព្រះថេរៈ
ពោលថា **វិបុលេន** គឺដោយលើសលុប ។

បទថា **ផរមានោ សមុស្សយំ** សេចក្តីថា ខ្ញុំព្រះអង្គញ៉ាំងរូបដែល

ប្រណីត ដែលកើតអំពីបីតិ និងសុខតាមដែលពោលហើយ ឲ្យផ្សាយទៅក្នុងរាងកាយទាំងមូល គឺធ្វើឲ្យពាល់ត្រូវមិនដាច់ខ្សែ ។

បទថា **លទ្ធម្បិ អភិសម្ភោន្តោ** សេចក្តីថា គ្របសង្កត់ គឺគ្របសង្កត់បច្ច័យដែលសៅហ្មង ដែលកើតឡើង ព្រោះនៅក្នុងព្រៃដែលជាហេតុឲ្យប្រព្រឹត្តជុសខាត់ ទាំងដែលអត់សង្កត់បានដោយក្រ ។

បទថា **វិហរិស្សាមិ កាននេ** សេចក្តីថា ខ្ញុំព្រះអង្គនឹងនៅក្នុងព្រៃដោយសុខដែលកើតអំពីឈាន និងសុខដែលកើតអំពីវិបស្សនា ។ ដោយហេតុនោះទើបលោកពោល ( ក្នុងវិនយបិដកមហាវិភង្គ ) ថា តថាគតសោយសុខដោយកាយផង និង ( ព្រះតម្រាស់ក្នុងធម្មបទ ) ថា

ភិក្ខុពិចារណាការកើតឡើង និងការវិនាសខន្ធទាំងឡាយ ក្នុងកាលណា ក្នុងកាលនោះ ភិក្ខុនោះ រមែងបាននូវបីតិ និងបាមោជ្ជ បីតិ និងបាមោជ្ជនោះ ឈ្មោះថា ជាអមតធម៌របស់បណ្ឌិត អ្នកដឹងនូវធម៌ទាំងឡាយ ដូច្នេះ ។

បទថា **ភាវេន្តោ សតិប្បដ្ឋានេ** សេចក្តីថា សតិប្បដ្ឋាន ៤ មានកាយានុបស្សនាសតិប្បដ្ឋានជាដើម ដែលទាក់ទងក្នុងមគ្គឲ្យកើត និងឲ្យចម្រើន ។

បទថា **ឥន្ទ្រិយានិ** បានដល់ ឥន្ទ្រិយ ៥ មានសទ្ធិន្ទ្រិយជាដើម ដែលទាក់ទងក្នុងមគ្គនោះឯង ។

បទថា **ពលានិ** បានដល់ ពល ៥ មានសទ្ធាជាដើមក៏ដូចគ្នា ។ បទថា

**ពោជ្ឈង្គានិ** បានដល់ ពោជ្ឈង្គ ៧ មានសតិសម្ពោជ្ឈង្គជាដើមក៏ដូចគ្នា ។ ដោយ ៥ សព្ទ លោកសង្គ្រោះសម្មប្បធាន ឥទ្ធិបាទ និងអដ្ឋង្គិកមគ្គចូលផង ដែរ ។

ព្រោះថា ធម៌ទាំងនោះ ចាំបាច់នាំមករាប់ចូលផងដែរ ដោយនាំមក ជាមួយគ្នា ព្រោះខ្វះមិនបាន ។

បទថា **វិហរិស្សាមិ** សេចក្តីថា ខ្ញុំព្រះអង្គ កាលចម្រើនពោធិបក្ខិយ- ធម៌តាមដែលពោលហើយ នៅដោយសេចក្តីសុខដែលកើតអំពីមគ្គ ដោយ សុខដែលកើតអំពីផល ដែលសម្រេចអំពីការត្រាស់ដឹងមគ្គនោះ និងដោយ សុខ គឺព្រះនិព្វាន ។

បទថា **អារទ្ធវិរិយេ** សេចក្តីថា បុគ្គលប្រកបព្យាយាម ដោយអំណាច សម្មប្បធាន ៤ ។ បទថា **បហិតត្តេ** បានដល់ ជាអ្នកមានចិត្តស្ងួនទៅ ចំពោះហើយ កាន់ព្រះនិព្វាន ។ បទថា **និច្ចំ ទឡ្ហបរក្កមេ** បានដល់ ជាអ្នក មានសេចក្តីព្យាយាមមិនថមថយសព្វកាល ។ ឈ្មោះថា **សមគ្គេ** ដោយ អំណាចមិនវិវាទគ្នា និងដោយអំណាចនៃកាយសាមគ្គី ។ ព្រោះឃើញ សព្រហ្មចារីទាំងឡាយដែលប្រកបដោយភាពជាអ្នកស្មើគ្នា ដោយទិដ្ឋិ និង សីល ។ ដោយពាក្យនោះ លោកសម្តែងដល់ការដល់ព្រមដោយកល្យាណ- មិត្ត ។

បទថា **អនុស្សរន្តោ សម្ពុទ្ធំ** សេចក្តីថា ខ្ញុំនឹងមិនខ្ជិលប្រអូស រឭក ដល់ព្រះសាស្តា ដែលឈ្មោះថា **សម្មាសម្ពុទ្ធ** ព្រោះត្រាស់ដឹងនូវធម៌ទាំងពួង

ដោយប្រពៃ និងដោយព្រះអង្គឯង ឈ្មោះថា **អគ្គំ** ព្រោះជាអ្នកឧត្តមជាងសត្វទាំងពួង ឈ្មោះថា **ឧត្តំ** ដោយការទូន្មានដ៏ឧត្តម ឈ្មោះថា **សមាហិតំ** ដោយសមាធិដ៏កំពូល ដោយន័យថា **ឥតិបិ សោ ភគវា អរហំ** ដូច្នេះជាដើម ទាំងពេលយប់ និងពេលថ្ងៃសព្វកាល ។ ដោយពាក្យនេះ លោកពោលដល់ការប្រកបកម្មដ្ឋានក្នុងទីទាំងពួង ដោយសម្តែងដល់ការប្រកបក្នុងការបម្រើនពុទ្ធានុស្សតិ និងដោយពាក្យដើម លោកពោលដល់ការប្រកបបារិហារិយកម្មដ្ឋាន ។

ព្រះថេរៈកាលពោលយ៉ាងនេះ ទើបបំពេញវិបស្សនាសម្រេចអរហត្តសមដូចគាថាព័ន្ធដែលលោកពោលក្នុងអបទានថា

ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រះនាយកព្រះនាមបទុមុត្តរៈ មានព្រះនាមខ្ពង់ខ្ពស់ មានគុណរាប់មិនបានត្រាស់ឡើងហើយក្នុងលោក ។ ព្រះអង្គមានអាការ និងព្រះឱស្ឋដូចផ្កាឈូក មានព្រះឆវីវណ្ណល្អ មិនមានមន្ទិលដូចផ្កាឈូក មិនជាប់ជំពាក់ដោយលោក ដូចផ្កាឈូកមិនប្រឡាក់ដោយទឹក ។ ព្រះអង្គជាអ្នកប្រាជ្ញមានព្រះនេត្រដូចត្របកឈូក ជាទីត្រេកអរដូចផ្កាឈូក ទ្រង់មានក្លិនវិសេសដូចផ្កាឈូក ព្រោះហេតុនោះឯង ទើបព្រះអង្គ មានព្រះនាមថា បទុមុត្តរៈ ។ ព្រះអង្គជាច្បងក្នុងលោក ទ្រង់មិនមានមានះ មានឧបមាដូចភ្នែកនៃពួកជនខ្វាក់ ទ្រង់មានភេទស្ងប់រម្ងាប់ ជាកំណប់នៃគុណ ទ្រង់មានករុណាគុណ និងបញ្ញាគុណ

ដូចសាគរ ។ ជួនកាល ព្រះមហាវីរៈនោះ មានពួកព្រហ្ម ទេវតា និងអសុរបូជា ព្រះអង្គឧត្តមជាងពួកជន ក្នុងកណ្តាលប្រជុំជនដែលកុះករដោយទេវតា និងមនុស្ស ។ ព្រះមហាវីរៈ ទ្រង់ញុំាងបរិស័ទទាំងពួងឲ្យត្រេកអរដោយព្រះឱស្ឋ មានក្លិនក្រអូបផងដោយព្រះសូរសៀងដ៏ពីរោះផង ទ្រង់សរសើរសាវ័ករបស់ព្រះអង្គថា សាវ័កនេះជាសទ្ធាធិមុត្ត មានប្រាជ្ញាល្អ មានអាល័យក្នុងការឃើញតថាគត បុគ្គលដទៃបែបនេះ មិនមានដូចវក្កលិភិក្ខុនេះឡើយ ។ កាលនោះ ខ្ញុំកើតជាកូនរបស់ព្រាហ្មណ៍ នៅក្នុងក្រុងហង្សវតី លុះបានស្តាប់ព្រះពុទ្ធដីកានេះហើយ ក៏ប្រាថ្នានូវតំណែងនោះ ។ កាលនោះ ខ្ញុំនិមន្តព្រះតថាគត ទ្រង់មិនមានមន្ទិលនោះព្រមទាំងសាវ័កឲ្យគង់ឆាន់ អស់ ៧ ថ្ងៃ ក្រោមបាំសំពត់ ។ ខ្ញុំក្រាបចុះដោយសិរ្សៈ មុជចុះក្នុងសាគរ គឺអនន្តគុណរបស់ព្រះអង្គ មានបីតិពេញលេញ ទើបពោលពាក្យនេះថា បពិត្រមហាមុនី ឥសី គឺភិក្ខុអង្គណា ជាសទ្ធាធិមុត្តក្នុងសាសនានេះ ដែលព្រះអង្គសរសើរហើយថា ជាច្បងជាងភិក្ខុអ្នកមានសទ្ធា ខ្ញុំព្រះអង្គសូមបានដូចភិក្ខុនោះ ក្នុងកាលអនាគត ។ លុះខ្ញុំពោលយ៉ាងនេះហើយ ទើបមហាមុនីទ្រង់ព្យាយាមធំ មានការឃើញមិនកំបាំងទ្រង់បន្លឺឡើងនូវព្រះពុទ្ធដីកានេះ ក្នុងកណ្តាលបរិស័ទថា

អ្នកទាំងឡាយ ចូរមើលមាណពនេះ ដែលស្លៀកសំពត់

សាច់ម៉ដ្ឋ មានសម្បុរលឿង ជាអ្នកមានអវយវៈដូចគ្រឿងបូជា ដែលបិទដោយមាស ជាទីត្រូវភ្នែកត្រូវចិត្តរបស់ជន ។ មាណព នេះនឹងបានជាសាវករបស់ព្រះគោតមមហេសី ប្រសើរលើសជាង ពួកភិក្ខុដែលជាសទ្ធាធិមុត្ត ក្នុងកាលជាអនាគត ។ មាណពនេះ ទោះកើតជាទេវតា ឬជាមនុស្ស ជាអ្នកវៀរចាកសេចក្តីក្តៅក្រហាយ ទាំងពួង បរិបូណ៌ដោយភោគៈទាំងពួង ជាអ្នកអន្ទោលទៅទាំងមាន សេចក្តីសុខ ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រះសាស្តាព្រះនាម គោតម ទ្រង់កើតក្នុងត្រកូលឱក្កាកៈ នឹងត្រាស់ឡើងក្នុងលោក ។ មាណពនេះ នឹងបានជាធម្មទាយាទរបស់ព្រះអង្គ ជាឱរស ជា ធម្មនិម្មិត មាននាមថាវក្កលិ ជាសាវករបស់ព្រះសាស្តា ។

ខ្ញុំលះរាងកាយរបស់មនុស្សហើយ បានទៅកើតក្នុងឋាន តាវត្តិង្សដោយសេសនៃកម្មនោះផង ដោយការតាំងទុកនូវចេតនា នោះផង ។ ខ្ញុំអន្ទោលទៅក្នុងភពតូចភពធំ ជាអ្នកមានសេចក្តី សុខក្នុងភពទាំងពួង ខ្ញុំមកកើតក្នុងត្រកូលមួយក្នុងក្រុងសាវត្ថី ។ មាតាមានភ័យអំពីបិសាចបៀតបៀននូវខ្ញុំ ដែលនៅល្អិតទន់ដូច ទឹកដោះខាប់កំពុងនៅជេកផ្សារ ល្អិតទន់ដូចត្រួយឈើ ។ មាតា ផ្តេកខ្ញុំទៀបបាទមូលរបស់ព្រះមហេសី លុះគាត់មានចិត្តចង់ថ្វាយ ( ទើបពោលថា ) បពិត្រព្រះលោកនាថ ខ្ញុំព្រះអង្គ ថ្វាយទារក នេះចំពោះព្រះអង្គ បពិត្រព្រះនាយក ខ្ញុំព្រះអង្គ សូមដល់នូវ

ព្រះអង្គ ជាទីពឹង ទីរឭក ។ គ្រានោះ ព្រះមហាមុនីនោះ ដែលជាទីពឹងនៃពួកសត្វអ្នកខ្លាច ទ្រង់ទទួលនូវខ្ញុំដោយព្រះហស្តដ៏ទន់ដូចផ្កា មានក្រឡាប្រទាក់ដូចសំណាញ់ មានជួរស្នាមវិលវង់ដូចចក្រ ។ ចាប់ដើមតាំងពីកាលនោះ ខ្ញុំបានព្រះសម្ពុទ្ធរក្សាហើយដោយអំពើមិនគួរគេរក្សាបាន ខ្ញុំរួចស្រឡះចាកព្យាធិទាំងពួងចម្រើនដោយសេចក្តីសុខ ។ បើខ្ញុំវៀរចាកព្រះសុគតហើយ ក៏កើតអផ្សុកមួយរំពេច លុះខ្ញុំអាយុ ៧ ឆ្នាំរាប់អំពីកំណើត ក៏បានចូលទៅកាន់ផ្នួស ។ ខ្ញុំមិនឆ្អែតចិត្តនឹងព្រះសុគត ទ្រង់ពេញលេញដោយបារមីទាំងពួង មានព្រះនេត្រខៀវស្រស់ មានព្រះរូបល្អពេញដោយរបស់ស្អាតទាំងអស់ ។ កាលនោះ ព្រះជិនស្រី ទ្រង់ជ្រាបថា ខ្ញុំមានសេចក្តីត្រេកអរក្នុងរូបរបស់ព្រះពុទ្ធហើយ ក៏ទ្រង់ទូន្មាននូវខ្ញុំថា នែវក្កលិ កុំឡើយ អ្នកត្រេកអរក្នុងរូបដែលជនពាលត្រេកអរហើយ នឹងមានប្រយោជន៍អ្វី ព្រោះថា បុគ្គលណាជាបណ្ឌិត បានឃើញព្រះសទ្ធម្ម បុគ្គលនោះ ឈ្មោះថា ឃើញតថាគត បុគ្គលណា កាលមិនឃើញព្រះសទ្ធម្ម សូម្បីឃើញតថាគត បុគ្គលនោះ ក៏ឈ្មោះថា មិនឃើញដែរ ។ រាងកាយ

ជារបស់មានទោស រកទីបំផុតគ្មាន មានឧបមាដូចដើមឈើមាន ពិស ជាលំនៅនៃរោគទាំងពួង ជាគំនរនៃកងទុក្ខទាំងអស់ ។ អ្នក គួរនឿយណាយចាកកាយនោះ គួរឃើញនូវការកើតឡើង និងការ សូន្យនៃខន្ធទាំងឡាយក្នុងរូបចុះ អ្នកនឹងដល់នូវព្រះនិព្វាន ជាទី បំផុតនៃកិលេសទាំងពួង ដោយសេចក្តីសុខ ។ លុះព្រះនាយក ទ្រង់ស្វែងរកនូវប្រយោជន៍អគ្គនោះ ប្រៀនប្រដៅខ្ញុំយ៉ាងនេះរួច ហើយ ខ្ញុំក៏ឡើងភ្នំគិជ្ឈកូដ នៅសញ្ជប់សញ្ជឹង ត្រង់ប្រកភ្នំ ។ ព្រះ ជិនស្រីមហាមុនី ទ្រង់ឋិតនៅនាជើងភ្នំ ញុំាងខ្ញុំឲ្យត្រេកអរ ទ្រង់ ត្រាស់ហៅខ្ញុំថា ម្នាលវក្កលិ ខ្ញុំបានឮព្រះពុទ្ធដីកានោះហើយ ក៏ មានចិត្តរីករាយ ។ កាលនោះ ខ្ញុំស្ទុះទៅត្រង់ជ្រោះភ្នំ មានជម្រៅ ច្រើនរយជួរបុរស ដើរទៅកាន់ផែនដីដោយស្រួល ដោយពុទ្ធា-នុភាព ។ ព្រះមហាមុនីទ្រង់សម្តែងធម៌ គឺការកើតឡើង និងការ សូន្យនៃខន្ធទាំងឡាយម្តងទៀត ខ្ញុំបានដឹងនូវធម៌នោះហើយ ក៏ បានដល់នូវអរហត្តផល ។ គ្រានោះ ព្រះសម្ពុទ្ធមានប្រាជ្ញាច្រើន ទ្រង់ដល់នូវទីបំផុតនៃចរណៈ ទ្រង់តាំងខ្ញុំជាកំពូលនៃពួកភិក្ខុដែល ជាសទ្ធាធិមុត្ត ក្នុងកណ្តាលបរិស័ទច្រើន ។ ក្នុងកប្បទីមួយសែន

អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំង-ឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ ។

ព្រះថេរៈសម្រេចអរហត្តហើយ កាលព្យាករអរហត្តផល បានពោលគាថានេះដដែលទៀត ។ លំដាប់នោះ ព្រះសាស្តាគង់ក្នុងកណ្តាលភិក្ខុសង្ឃ ទើបទ្រង់ស្ថាបនាព្រះថេរៈក្នុងតំណែងឯតទគ្គៈ ជាងភិក្ខុដែលរួចផុតដោយសទ្ធា ដោយប្រការដូច្នេះ ។ល។

**អដ្ឋកថា វក្កលិត្ថេរគាថា ចប់**

# សុត្តន្តបិដក

## វិជិតសេនត្ថេរគាថា

[ ២០៧ ] ម្នាលចិត្ត អញនឹងហាមឃាត់ឯង ដូចជាគេបង្ខាំងដំរីទុកក្នុងក្រោលមានទ្វារប្រកបដោយរនុក ទាំងមិនបណ្តោយឯង ដែលជាបណ្តាញនៃកាម ដែលកើតអំពីសរីរៈ ឲ្យទៅក្នុងបាបធម៌ទេ ។ ឯងអញហាមឃាត់ហើយ នឹងទៅណាមិនបានទេ ដូចជាដំរីដែលមិនបាននូវចន្លោះទ្វារ ( ដើម្បីចេញ ) ម្នាលចិត្តខិលខូច ឯងនឹងប្រព្រឹត្តឈ្លានពាន ត្រេកអរក្នុងបាបធម៌រឿយៗ ទៀតមិនបានទេ ។ ហ្មដំរីអ្នកមានកម្លាំង ធ្វើដំរីដែលមិនទាន់ពង្រាបទើបចាប់បានថ្មី ជាសត្វមិនប្រាជ្ញាឲ្យត្រឡប់វិលបានយ៉ាងណា អញនឹងឲ្យឯងវិលត្រឡប់យ៉ាងនោះដែរ ។ នាយសារថីដ៏ប្រសើរ ជាអ្នកឈ្លាសក្នុងការបង្ហាត់សេះដ៏ប្រសើរ បង្ហាត់សេះអាជានេយ្យយ៉ាងណា អញនឹងតាំងនៅក្នុងពលធម៌ ៥ ហើយទូន្មានឯងយ៉ាងនោះដែរ ។ អញនឹងចងឯងដោយសតិអញមានខ្លួនប្រុងប្រយ័ត្នហើយ នឹងទូន្មានឯង ម្នាលចិត្ត ឯងអញសង្កត់សង្កិនក្នុងធុរៈ គឺព្យាយាម កុំទៅឆ្ងាយអំពីទីនេះឡើយ ។

វិជិតសេនត្ថេរ

# អដ្ឋកថា

## វិជិតសេនត្ថេរគាថា

[ ២០៧ ] គាថារបស់ព្រះវិជិតសេនត្ថេរ មានពាក្យផ្ដើមថា **ឱលគ្គិស្សាមិ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមអត្ថទស្សី កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្ដីហើយ លះនូវការគ្រប់គ្រងផ្ទះ បួសជាឥសីនៅក្នុងព្រៃ ឃើញព្រះមានព្រះភាគយាងទៅតាមអាកាស មានចិត្តជ្រះថ្លា ទើបសម្ដែងអាការជ្រះថ្លា ឈរផ្គងអញ្ជលី ។ ព្រះសាស្ដាទ្រង់ជ្រាបអធ្យាស្រ័យរបស់កុលបុត្តនោះ ទើបចុះអំពីអាកាស កុលបុត្តនោះ ក៏បង្អោនផ្លែឈើដែលមានរសផ្អែមគួរជាទីត្រេកអរ ចូលទៅថ្វាយ ព្រះមានព្រះភាគទ្រង់ទទួលដោយសេចក្ដីអនុគ្រោះ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលហត្ថាចារ្យ ក្នុងកោសលរដ្ឋ មានឈ្មោះថា **វិជិតសេន** ដល់នូវភាពជាអ្នកដឹងក្ដីហើយ ។ ហត្ថាចារ្យ ២ នាក់ ម្នាក់ឈ្មោះសេន ម្នាក់ឈ្មោះឧបសេន ជាឪពុកធំរបស់កុលបុត្តនោះ ស្ដាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្ដា បាននូវសទ្ធា បួសហើយ បំពេញវិបស្សនាធុរៈ សម្រេចអរហត្តហើយ ។

វិជិតសេនដល់នូវការសម្រេចក្នុងសិប្បៈដំរី មានចិត្តជាប់ជំពាក់ក្នុងការគ្រប់គ្រងផ្ទះ ព្រោះភាពដែលខ្លួនមានអធ្យាស្រ័យក្នុងនិស្សរណៈ ឃើញនូវយមកប្បាដិហារ្យរបស់ព្រះសាស្តា បាននូវសទ្ធា បួសក្នុងសម្នាក់របស់ព្រះថេរៈដែលជាលោកអ៊ំ ចម្រើនវិបស្សនាតាមពាក្យប្រៀនប្រដៅរបស់ព្រះថេរៈដែលជាលោកអ៊ំទាំងពីរនោះ ប្រព្រឹត្តតាមវិបស្សនាវិថី កាលទូន្មានចិត្តរបស់ខ្លួន ដែលស្ទុះទៅក្នុងអារម្មណ៍ផ្សេងៗ ខាងក្រៅ ទើបពោលគាថាថា

ម្នាលចិត្ត អញនឹងហាមឃាត់ឯង ដូចជាគេបង្ខាំងដំរីទុកក្នុងក្រោលមានទ្វារប្រកបដោយរនុក ទាំងមិនបណ្តោយឯង ដែលជាបណ្តាញនៃកាម ដែលកើតអំពីសរីរៈ ឲ្យទៅក្នុងបាបធម៌ទេ ។ ឯងអញហាមឃាត់ហើយ នឹងទៅណាមិនបានទេ ដូចជាដំរីដែលមិនបាននូវចន្លោះទ្វារ ( ដើម្បីចេញ ) ម្នាលចិត្តខិលខូច ឯងនឹងប្រព្រឹត្តឈ្លានពាន ត្រេកអរក្នុងបាបធម៌រឿយៗ ទៀតមិនបានទេ ។ ហ្មដំរីអ្នកមានកម្លាំង ធ្វើដំរីដែលមិនទាន់ពង្រាប ទើបចាប់បានថ្មី ជាសត្វមិនប្រាថ្នាឲ្យត្រឡប់វិលបានយ៉ាងណា អញនឹងឲ្យឯង វិលត្រឡប់យ៉ាងនោះដែរ ។ នាយសារថីដ៏ប្រសើរ ជាអ្នកឈ្លាសក្នុងការបង្ហាត់សេះដ៏ប្រសើរ បង្ហាត់សេះអាជានេយ្យយ៉ាងណា អញនឹងតាំងនៅក្នុងពលធម៌ ៥ ហើយទូន្មានឯងយ៉ាងនោះដែរ ។ អញនឹងចងឯងដោយសតិ អញមានខ្លួនប្រុងប្រយ័ត្ន ហើយ នឹងទូន្មានឯង ម្នាលចិត្ត ឯងអញសង្កត់សង្កិនក្នុងធុរៈ គឺ

ព្យាយាម កុំទៅឆ្ងាយអំពីទីនេះឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ខិលត្តិស្សាមិ** សេចក្ដីថា អញនឹងរាំង ប្រយ័ត្ន គឺនឹងហាម ។ បទថា **តេ** ស្មើគ្នានឹង **តំ** ប្រែថា នូវចិត្តនោះ ។ ពិតហើយ បទថា **តេ** នេះ ជាឆដ្ឋីវិភត្តិ ប្រើក្នុងអត្ថនៃទុតិយាវិភត្តិ ។ ម្យ៉ាងទៀត គប្បីនាំបាលីដ៏សេសមកភ្ជាប់ដោយបទថា **តេ គមនំ** ។ បទថា **ហត្ថិនំ** ស្មើគ្នានឹង **ហត្ថី** ប្រែថា នូវដំរី ។ ព្រះវិជិតសេនហៅចិត្តរបស់ខ្លួនថា ម្នាលចិត្ត ។

កាលនឹងសម្ដែងអាការដែលប្រាថ្នានឹងហាមចិត្តនោះ ទើបពោលថា **អាណិទ្វារេវ ហត្ថិនំ** ។ ទ្វារតូចរបស់ព្រះនគរដែលទាក់ទងនឹងកំពែង ឈ្មោះថា **អាណិទ្វារ** ។ ទ្វារនេះ កាលគេដាក់គន្លឹះត្រង់រនុកហើយ សូម្បីអ្នកនៅខាងក្នុង បើវៀរគ្រឿងយន្ត ក៏បើកមិនចេញ ដែលជាហេតុមិនអាចឲ្យមនុស្ស គោ សេះ ក្របីជាដើម ចេញទៅបាន ជាទីដែលហ្មដំរីល្បួងលោមចិត្តដំរី ដែលចង់ចេញទៅខាងក្រៅនគរ ឲ្យឈប់នៅត្រង់នោះ ។

ម្យ៉ាងទៀត ទ្វារមានរនុក ឈ្មោះថា **អាណិទ្វារ** ត្រង់អាណិទ្វារនោះ គេដាក់រនុកខ្ទាស់ ហើយដោតគន្លឹះ ពោល គឺស្នៀតធ្វើអំពីឈើ ត្រង់ដំណាប់នោះឯង ។

បទថា **ចាបេ** សេចក្ដីថា នឹងមិនប្រកប គឺមិនតម្កល់ចិត្តនោះក្នុងបាបធម៌ មានអភិជ្ឈាជាដើម ដែលកើតឡើងក្នុងអារម្មណ៍ មានរូបជាដើម ។ បទថា **កាមជាល** សេចក្ដីថា ជាសំណាញ់នៃកាម ។ ដូចសំណាញ់របស់នាយព្រាន

អ្នកចាប់ត្រី និងនាយព្រានអ្នកចាប់ម្រឹគ ជាគ្រឿងជួយឲ្យនាយព្រានចាប់ត្រីជាដើមបានតាមប្រាថ្នា យ៉ាងណា ចិត្តដែលធ្លាក់ទៅ ព្រោះអយោនិសោមនសិការ ក៏ជាឧបករណ៍ ឲ្យមារធ្វើតាមប្រាថ្នា ក៏ដូច្នោះ ។ ព្រោះហេតុនោះឯង ទើបមារនោះញុំាងសត្វទាំងឡាយ ឲ្យធ្លាក់ទៅក្នុងសេចក្តីវិនាស ។

បទថា **សរីរជ** បានដល់ ដែលកើតក្នុងសរីរៈ ។ ពិតហើយ ចិត្តក្នុងបញ្ចវោការភព ( ភពរបស់សត្វដែលមានខន្ធ ៥ ) លោកហៅថា កើតក្នុងសរីរៈ ព្រោះមានការប្រព្រឹត្តទៅទាក់ទងដោយរូប ។

បទថា **តំ ឱលគ្គោ ន គច្ឆសិ** សេចក្តីថា ម្នាលចិត្តបាប អ្នកដែលខ្ញុំឃាត់ហើយដោយជន្ទួញ គឺសតិ និងបញ្ញា ឥឡូវនេះ នឹងមិនទៅតាមគាប់ចិត្ត គឺនឹងមិនបានប្រព្រឹត្តទៅតាមប្រាថ្នា ដោយអំណាចអយោនិសោមនសិការ ។

សួរថា ដូចអ្វី ឆ្លើយថា ដូចជាគេបង្ខាំងដំរីក្នុងក្រោល មានទ្វារប្រកបដោយទន្ទុកដូច្នោះ អធិប្បាយថា ដូចដំរី កាលមិនបានទ្វារដើម្បីចេញទៅអំពីនគរ ឬចាកគ្រឿងរាំងរបស់ដំរី ។

បទថា **ចិត្តកលិ** បានដល់ ចិត្តកាឡកិណី ។

បទថា **បុនប្បុនំ** បានដល់ ទៅមកៗ ។ បទថា **បសយ្ហ** សេចក្តីថា ដោយអំណាចការទទឹងទាស់ ។ បទថា **ចារយតោ** បានដល់ ត្រេកអរក្នុងបាបកម្ម អធិប្បាយថា ឥឡូវនេះ នឹងប្រព្រឹត្តដូចមុនមិនបាន គឺអញនឹងមិនឲ្យប្រព្រឹត្តបែបនោះ ។

បទថា **អទន្តំ** សេចក្តីថា មិនបានទូន្មាន គឺមិនទាន់ឲ្យសិក្សានូវបែបបទ

របស់ដំរី ។

បទថា **ឆវគ្គហំ** បានដល់ ចាប់បានមកមិនយូរ ។

បទថា **អង្កុសគ្គហោ** បានដល់ នាយហត្ថាចារ្យ ។ បទថា **ពលវា** បានដល់ មានកម្លាំង ដោយកម្លាំងកាយ និងកម្លាំងប្រាជ្ញា ។

បទថា **អាវត្តេតិ អកាមំ** សេចក្តីថា ឲ្យឯងដែលមិនប្រាថ្នានោះឯងត្រឡប់ដោយការឃាត់ ។ បទថា **ឯវំ អាវត្តយិស្សំ** សេចក្តីថា នាយហត្ថាចារ្យនឹងឲ្យដំរីតាមដែលពោលហើយត្រឡប់ យ៉ាងណា អញនឹងឲ្យចិត្តអាក្រក់នេះ ត្រឡប់ចាកការស្និទ្ធស្នាលនឹងទុច្ចរិតក៏ដូច្នោះ ។

បទថា **វរហយទមកុសលោ** សេចក្តីថា ជាអ្នកឈ្លាសក្នុងការទូន្មានសេះដែលគួរទូន្មានទាំងឡាយដ៏ឧត្តម ។ បន្ទាប់អំពីនោះ សារថីដ៏ប្រសើរ គឺបុគ្គលវិសេស ក្នុងបណ្តានាយសារថីដែលទូន្មានសេះដែលគួរបង្ហឹក រមែងទូន្មានសេះអាជានេយ្យ គឺសេះដែលគួរទូន្មាន រមែងទូន្មាន គឺរមែងបង្ហាត់ដោយពាក្យផ្អែម និងពាក្យគ្រោតគ្រាតតាមគួរដល់កាលៈ និងទេសៈ បានដល់ធ្វើឲ្យអស់ព្យសន៍ ។

បទថា **បតិដ្ឋិតោ បញ្ចសុ ពលេសុ** សេចក្តីថា បុគ្គលតាំងនៅហើយក្នុងពល ៥ មានសទ្ធាជាដើម នឹងទូន្មាន គឺនឹងទូន្មានចិត្តនោះដោយការហាមចាកភាពជាអ្នកមិនមានសទ្ធាជាដើម ។

បទថា **សតិយា តំ និពន្ធិស្សំ** សេចក្តីថា នែចិត្តអាក្រក់ អញមិនឲ្យឯងទៅខាងក្រៅអារម្មណ៍ដែលជាខាងក្នុង ហើយនឹងចង គឺនឹងបញ្ជាអ្នកទុក

ត្រង់សសរ គឺកម្មដ្ឋាន ដោយខ្សែ គឺសតិ ។

បទថា **បយុត្តោ តេ ឧមេស្សាមិ** សេចក្តីថា អញចង គឺខ្ញុំ ខ្វាយប្រកបឯងទុកត្រង់សសរ គឺកម្មដ្ឋាននោះ ហើយទូន្មានឯង គឺនឹងឲ្យឯង បរិសុទ្ធចាកមន្ទិល គឺកិលេស ។

បទថា **វីរិយធុរនិគ្គហិតោ** សេចក្តីថា សេះតាមដែលពោលហើយ នោះដែលនាយសារថីអ្នកឈ្លាសប្រកបត្រង់នឹម គឺចងត្រង់នឹម នៅក្នុងចន្លោះ នឹម មិនកន្លងនឹមទៅបាន យ៉ាងណា នៃចិត្ត សូម្បីឯងក៏ដូច្នោះ ត្រូវអញសង្កត់ ត្រង់នឹម គឺសេចក្តីព្យាយាម មិនឲ្យប្រព្រឹត្តទៅដោយប្រការដទៃ ព្រោះ អញធ្វើដោយគោរព ព្រោះអញធ្វើជាប់គ្នា ក៏ចេញទៅខាងក្រៅចាកអារម្មណ៍ ដែលជាខាងក្នុងមិនបាន ព្រោះកាលចិត្តប្រកបក្នុងភាវនា អារម្មណ៍ដទៃចាក កម្មដ្ឋាន ជាអារម្មណ៍ជិត ក៏នឹងនៅឆ្ងាយ ដោយលក្ខណៈ ព្រះថេរៈកាល សង្កត់ចិត្តដោយគាថាទាំងនេះ ចម្រើនវិបស្សនាសម្រេចអរហត្តហើយ សម ដូចគាថាព័ន្ធដែលលោកពោលក្នុងអបទានថា

ព្រះសម្ពុទ្ធមានវណ្ណៈដូចមាស មានលក្ខណៈ ៣២ ដ៏ប្រសើរ ទ្រង់ស្តេចទៅកាន់ជាយព្រៃធំ ព្រះអង្គដូចជាសាលរាជព្រឹក្ស មាន ផ្ការីកហើយ ។ ខ្ញុំក្រាលកម្រាលស្មៅ រួចហើយ អារាធនាព្រះ សម្ពុទ្ធដ៏ប្រសើរថា សូមព្រះសម្ពុទ្ធអនុគ្រោះខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គ ប្រាថ្នានឹងថ្វាយចង្ហាន់ ។ ឯព្រះសម្ពុទ្ធ ទ្រង់ព្រះនាមអត្ថទស្សី ទ្រង់អនុគ្រោះប្រកបដោយករុណា ទ្រង់មានយសធំ ទ្រង់ជ្រាបនូវ

សេចក្តីត្រិះរិះរបស់ខ្ញុំ ហើយស្តេចចូលទៅក្នុងអាស្រមរបស់ខ្ញុំ ។ ព្រះសម្ពុទ្ធស្តេចចូលទៅគង់លើកម្រាលស្លឹកឈើ ខ្ញុំបានយកផ្លែក្រខុបថ្វាយព្រះពុទ្ធដ៏ប្រសើរ ។ កាលខ្ញុំកំពុងសម្លឹងមើល ព្រះជិនស្រីទ្រង់សោយរួចហើយ ខ្ញុំក៏ញុំាងចិត្តឲ្យជ្រះថ្លាចំពោះព្រះអង្គ ហើយថ្វាយបង្គំព្រះជិនស្រី ក្នុងកាលនោះ ក្នុងកប្បទី ១៨០០ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែឈើ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយផ្លែឈើ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បាន ប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈកាលសម្រេចអរហត្តហើយ កាលនឹងព្យាករអរហត្ត ទើបពោលនូវគាថាទាំងនេះ ។ល។

## អដ្ឋកថាវិជិតសេនត្ថេរគាថា ចប់

---

១- ក្នុងអបទាន ជាកណ្ហាតកទាយកត្ថេរ ។

# សុត្តន្តបិដក

## យសទត្ថេរគាថា

[ ២០៨ ] បុគ្គលអប្បឥតប្រាជ្ញា មានចិត្តប្រក្អួតប្រណាំង ទុកជាស្តាប់ពាក្យប្រៀនប្រដៅរបស់ព្រះជិនស្រី គង់ជាអ្នកឆ្ងាយអំពីព្រះសទ្ធម្ម ដូចផែនដីឆ្ងាយអំពីមេឃ ។ បុគ្គលអប្បឥតប្រាជ្ញា មានចិត្តប្រក្អួតប្រណាំង ទុកជាស្តាប់ពាក្យប្រៀនប្រដៅរបស់ព្រះជិនស្រី ក៏គង់សាបសូន្យចាកព្រះសទ្ធម្ម ដូចព្រះចន្ទ្រក្នុងកាឡបក្ខ ( រនោច ) ។ បុគ្គលអប្បឥតប្រាជ្ញា មានចិត្តប្រក្អួតប្រណាំង ទុកជាស្តាប់ពាក្យប្រៀនប្រដៅរបស់ព្រះជិនស្រី ក៏គង់រីងស្ងួតក្នុងព្រះសទ្ធម្ម ដូចជាត្រីរីងស្ងួតក្នុងទីមានទឹកតិច ។ បុគ្គលអប្បឥតប្រាជ្ញា មានចិត្តប្រក្អួតប្រណាំង ទុកជាស្តាប់ពាក្យប្រៀនប្រដៅរបស់ព្រះជិនស្រី គង់មិនលូតលាស់ក្នុងព្រះសទ្ធម្ម ដូចជាពូជស្អុយមិនដុះក្នុងស្រែ ។ លុះតែបុគ្គលណា មានចិត្តគ្រប់គ្រងហើយ ស្តាប់ពាក្យប្រៀនប្រដៅរបស់ព្រះជិនស្រី បុគ្គលនោះ ទើបញ៉ាំងអាសវៈទាំងពួងឲ្យអស់ទៅ ធ្វើឲ្យជាក់ច្បាស់នូវធម៌មិនកម្រើក ( អរហត្តផល ) ដល់នូវសេចក្តីស្ងប់ដ៏ឧត្តម គឺអនុបាទិសេសនិព្វាន ជាអ្នកមិនមានអាសវៈ រមែងបរិនិព្វាន ។

**យសទត្ថេរ**

# អដ្ឋកថា

## យសទត្តត្ថេរគាថា

[ ២០៨ ] គាថារបស់ព្រះយសទត្តត្ថេរ មានពាក្យផ្ដើមថា **ឧបារម្ភចិត្តោ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ។ ពិតហើយ ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កើតក្នុងត្រកូលព្រាហ្មណ៍ ដល់នូវការសម្រេចក្នុងសិប្បវិជ្ជារបស់ពួកព្រាហ្មណ៍ លះនូវកាមទាំងឡាយ បួសជាឥសីក្នុងព្រៃ ។ ថ្ងៃមួយ ឃើញព្រះសាស្ដា មានចិត្តជ្រះថ្លា ផ្គងអញ្ជលីសរសើរ ។ ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលនៃស្ដេចមល្លៈ ក្នុងមល្លរដ្ឋ មានឈ្មោះថា **យសទត្ត** ចម្រើនវ័យហើយ ទៅកាន់នគរតក្កសិលា សិក្សាសិប្បៈទាំងពួង ចារិកទៅជាមួយបរិព្វាជកឈ្មោះសភិយៈ ចូលទៅគាល់ព្រះមានព្រះភាគ ក្នុងនគរសាវត្ថីដោយលំដាប់ កាលព្រះមានព្រះភាគទ្រង់ឆ្លើយបញ្ហា ដែលសភិយបរិព្វាជកសួរ កុលបុត្តនេះក៏អង្គុយស្ដាប់សម្ងំរកទោស ( ចាំចាប់កំហុស ) ថា អញនឹងសម្ដែងទោសក្នុងវាទៈរបស់ព្រះសមណគោតម ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ជ្រាបវារៈចិត្តរបស់កុលបុត្តនោះ កាលនឹងប្រទានឱវាទ ក្នុងកាលចប់សភិយសុត្តទេសនា ទើបប្រទានឱវាទដោយ ៥ គាថាថា

បុគ្គលអប្បឥតប្រាជ្ញា មានចិត្តប្រកួតប្រណាំង ទុកជាស្ដាប់ពាក្យ

ប្រៀនប្រដៅរបស់ព្រះជិនស្រី គង់ជាអ្នកឆ្ងាយអំពីព្រះសទ្ធម្ម ដូចផែនដីឆ្ងាយអំពីមេឃ ។ បុគ្គលអប្បឥតប្រាជ្ញា មានចិត្តប្រកួតប្រណាំង ទុកជាស្តាប់ពាក្យប្រៀនប្រដៅរបស់ព្រះជិនស្រី ក៏គង់សាបសូន្យចាកព្រះសទ្ធម្ម ដូចព្រះចន្ទ្រក្នុងកាឡបក្ខ ( រនោច ) ។ បុគ្គលអប្បឥតប្រាជ្ញា មានចិត្តប្រកួតប្រណាំង ទុកជាស្តាប់ពាក្យប្រៀនប្រដៅរបស់ព្រះជិនស្រី ក៏គង់រីងស្ងួតក្នុងព្រះសទ្ធម្ម ដូចជាត្រីរីងស្ងួតក្នុងទីមានទឹកតិច ។ បុគ្គលអប្បឥតប្រាជ្ញា មានចិត្តប្រកួតប្រណាំង ទុកជាស្តាប់ពាក្យប្រៀនប្រដៅរបស់ព្រះជិនស្រី គង់មិនលូតលាស់ក្នុងព្រះសទ្ធម្ម ដូចជាពូជស្អុយមិនដុះក្នុងស្រែ ។ លុះតែបុគ្គលណា មានចិត្តគ្រប់គ្រងហើយ ស្តាប់ពាក្យប្រៀនប្រដៅរបស់ព្រះជិនស្រី បុគ្គលនោះ ទើបញ៉ាំងអាសវៈទាំងពួងឲ្យអស់ទៅ ធ្វើឲ្យជាក់ច្បាស់នូវធម៌មិនកម្រើក ( អរហត្តផល ) ដល់នូវសេចក្តីស្ងប់ដ៏ឧត្តម គឺអនុបាទិសេសនិព្វាន ជាអ្នកមិនមានអាសវៈ រមែងបរិនិព្វាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧចារម្ភចិត្តោ** បានដល់ មានចិត្តប្រណាំងប្រជែង អធិប្បាយថា មានបំណងនឹងចាប់កំហុស ។ បទថា **ទុម្មេធោ** បានដល់ ជាអ្នកមានប្រាជ្ញាថោកថយ ។

បទថា **អារកា ហោតិ សទ្ធម្មា** សេចក្តីថា បុគ្គលនោះ គឺបុគ្គលបែបនោះ រមែងជាអ្នកនៅក្នុងទីឆ្ងាយអំពីបដិបត្តិសទ្ធម្ម ដូចផែនដីឆ្ងាយអំពីមេឃ

ដូច្នោះ នឹងពោលថ្វីដល់បដិវេធសទ្ធម្មនោះ ។ បុគ្គលដែលពេញចិត្តក្នុងការចាប់កំហុស ដោយន័យជាដើមថា អ្នកមិនដឹងនូវទៅដល់ធម្មវិន័យនេះ បដិបត្តិសទ្ធម្ម ដែលជាធម្មជាតស្ងប់ប្រណីត នឹងមានអំពីណា ។

បទថា **បរិហាយតិ សទ្ធម្មា** សេចក្តីថា អ្នកសាបសូន្យចាកលោកុត្តរធម៌ ៩ ទាំងចាកព្រះសទ្ធម្ម មានសទ្ធាដែលជាចំណែកខាងដើមជាដើម ។

បទថា **បរិសុស្សតិ** សេចក្តីថា រមែងក្រៀមស្ងួតចាកការមិនមានធម៌ដែលជាកុសល មានបីតិ និងបាមោជ្ជជាដើម របស់បុគ្គលដែលធ្វើកិច្ចឲ្យកើតការត្រេកកាយ ត្រេកចិត្ត ។

បទថា **ន វិរូហតិ** សេចក្តីថា រមែងមិនដល់នូវការចម្រើន ។

បទថា **បូតិកំ** សេចក្តីថា ដល់នូវភាពជារបស់ស្អុយ ព្រោះមិនមានការដាក់អាចម៍គោ ( ធ្វើជាជី ) ជាដើម ។

បទថា **តុដ្ឋេន ចិត្តេន** ជាតតិយាវិភត្តិ ប្រើក្នុងលក្ខណៈនៃឥត្ថម្ភូត ( ប្រែថា មាន ) អធិប្បាយថា ជាអ្នកមានចិត្តត្រេកអរីករាយ ។

បទថា **ខេបេត្វា** បានដល់ កាត់ផ្តាច់ហើយ ។

បទថា **អកុប្បតំ** បានដល់ នូវអរហត្ត ។ បទថា **បប្បុយ្យ** ប្រែថា សម្រេចហើយ ។ បទថា **បរមំ សន្តឹ** បានដល់ អនុបាទិសេសនិព្វាន ។

ការសម្រេចអនុបាទិសេសនិព្វាននោះ គឺការរង់ចាំកាល ( ស្លាប់ ) តែម្យ៉ាង ប៉ុណ្ណោះ មិនមានវិធីណាឡើយ ព្រោះហេតុនោះ ដើម្បីសម្តែងអនុបាទិសេ-សនិព្វាននោះ ទើបលោកពោលថា ជាអ្នកមិនមានអាសវៈ តែងបរិនិព្វាន ។

កុលបុត្តនោះ កាលព្រះសាស្តាឲ្យឱវាទយ៉ាងនេះហើយ ក៏កើតសេចក្តីសង្វេគ បួសហើយ ចម្រើនវិបស្សនា មិនយូរប៉ុន្មានក៏សម្រេចអរហត្តសមដូចគាថាព័ន្ធដែលលោកពោលក្នុងអបទានថា

ខ្ញុំឃើញព្រះសម្ពុទ្ធ ទ្រង់ឧត្តមជាងសត្វជើងពីរ ទ្រង់រុងរឿងដូចផ្កាកណិការ ឬដូចដើមទីបព្រឹក្ស ដ៏ភ្លឺព្រោងព្រាត ពុំនោះសោត ដូចជាមាសក្លីវទ្នាលប្រាលផ្លៅ ។ ខ្ញុំតម្កល់ទុកនូវថូទឹក សំពត់សម្បកឈើ និងកុណ្ឌីទឹក ហើយធ្វើសំពត់ស្បែកខ្លាធៀងស្មាម្ខាង ពោលសរសើរនូវព្រះពុទ្ធដ៏ប្រសើរថា បពិត្រព្រះមហាមុនី ព្រះអង្គទ្រង់កម្ចាត់បង់នូវងងឹតអន្ធការ ដ៏ជេរជាសដោយបណ្តាញ គឺមោហៈ ទ្រង់សម្តែងនូវពន្លឺ គឺញាណ ព្រះអង្គទ្រង់ឆ្លងទុក្ខផុតហើយ ព្រះអង្គទ្រង់ស្រោចស្រង់នូវលោកទាំងអស់នេះ ដែលមិនទាន់រើខ្ទនរួច ដំណើរនៃផែនដីមានកំណត់ត្រឹមណា សេចក្តីប្រៀបផ្ទឹមដោយញាណរបស់ព្រះអង្គ មិនមានកំណត់ត្រឹមនោះឡើយ ។

ព្រះសម្ពុទ្ធ ដែលអ្នកប្រាជ្ញទាំងឡាយ ហៅថា សព្វញ្ញូ សព្វញ្ញូ ព្រោះញាណនោះ ខ្ញុំសូមថ្វាយបង្គំនូវព្រះសព្វញ្ញូអង្គនោះ ដែលមានព្យាយាមធំ ទាំងមិនមានអាសវៈ ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រោះហេតុដែលខ្ញុំពោលសរសើរនូវព្រះសម្ពុទ្ធដ៏ប្រសើរក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃសេចក្តីសរសើរនូវព្រះញាណ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិរួចហើយ ដូច្នេះ ។

ព្រះថេរៈលុះសម្រេចអរហត្តហើយ កាលព្យាករអរហត្តផល ក៏បានពោលគាថាទាំងនេះដូចគ្នា ។[១]

## អដ្ឋកថា យសទត្តត្ថេរគាថា ចប់

១- ក្នុងអបទាន ជាញាណត្ថវិកត្ថេរ ។

# សុត្តន្តបិដក

## សោណកុដិកណ្ណត្ថេរគាថា

[ ២០៩ ] ខ្ញុំបានឧបសម្បទាផង បានផុតស្រឡះ ជាអ្នកមិនមានអាសវៈផង ខ្ញុំបានឃើញព្រះមានព្រះភាគអង្គនោះផង ទាំងបាននៅជាមួយក្នុងកុដិផង ។ ព្រះមានព្រះភាគ ទ្រង់ធ្វើរាត្រីជាច្រើន ( យប់ជ្រៅ ) ឲ្យកន្លងទៅក្នុងទីវាល ព្រះសាស្តាឈ្លាសក្នុងការនៅ បានស្តេចចូលទៅកាន់កុដិក្នុងពេលនោះ ។ ព្រះគោតមទ្រង់ក្រាលសង្ឃាដិ ហើយសម្រេចសីហសេយ្យាដូចជាសត្វសីហៈ ដែលលះបង់សេចក្តីភ័យស្ញប់ស្ញែង ដេកក្នុងគុហាថ្មកែវ ។ លំដាប់នោះ ព្រះសោណៈជាសាវកនៃព្រះសម្មាសម្ពុទ្ធ អ្នកពោលពាក្យពីរោះ បានពោលនូវព្រះសទ្ធម្ម ចំពោះព្រះភក្ត្រព្រះពុទ្ធដ៏ប្រសើរ ។ បានកំណត់ដឹងនូវបញ្ចក្ខន្ធ បានចម្រើននូវមគ្គដ៏ប្រសើរ ហើយដល់នូវទីស្ងប់ដ៏ឧត្តម ជាបុគ្គលមិនមានអាសវៈ នឹងបរិនិព្វាន ។

សោណកុដិកណ្ណត្ថេរ

# អដ្ឋកថា

## សោណកុដិកណ្ណត្ថេរគាថា

[ ២០៩ ] គាថារបស់ព្រះសោណកុដិកណ្ណត្ថេរ មានពាក្យផ្ដើមថា **ឧបសម្បទា ច មេ លទ្ធា** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កុលបុត្តនេះកើតជាសេដ្ឋី សម្បូរដោយសម្បត្តិ ក្នុងនគរហង្សវតី តាំងនៅដោយឥស្សរិយសម្បត្តិដ៏ឧឡារ ថ្ងៃមួយ ឃើញព្រះសាស្ដាចោមរោមដោយព្រះទីណាស្រពមួយសែនអង្គ ទ្រង់ចូលកាន់នគរដោយពុទ្ធានុភាពធំ ដោយពុទ្ធលីលាធំ មានចិត្តជ្រះថ្លា ថ្វាយបង្គំហើយ បានឈរផ្គងអញ្ជលីក្នុងបច្ឆាកត្ត ។ កុលបុត្តនោះ មួយអន្លើដោយឧបាសកទាំងឡាយ ទៅកាន់វិហារ ស្ដាប់ធម៌ក្នុងសម្នាក់របស់ព្រះមានព្រះភាគ ឃើញព្រះសាស្ដាស្ថាបនាភិក្ខុមួយរូបក្នុងតំណែងឯតទគ្គៈជាងភិក្ខុអ្នកពោលពាក្យដ៏ពីរោះ ខ្លួនឯងក៏ប្រាថ្នាតំណែងនោះ ទើបបានថ្វាយមហាទាន ហើយតាំងសេចក្ដីប្រាថ្នា ។ ព្រះសាស្ដាទ្រង់ជ្រាបការប្រាថ្នានៃកុលបុត្តនោះមិនមានអន្តរាយ ទើបទ្រង់ព្យាករថា ក្នុងអនាគតអ្នកនឹងបានជាកំពូលជាងភិក្ខុទាំងឡាយ ខាងមានពាក្យសម្ដីពីរោះ ក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធព្រះនាមគោតម ។

កុលបុត្តនោះបំពេញបុញ្ញកម្មក្នុងជាតិនោះដរាបដល់អស់ជីវិត អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមវិបស្សី បួសក្នុងសាសនា បំពេញវត្ត និងបដិវត្តឲ្យបរិបូណ៌ បាន

ដេរចីវរ ប្រគេនដល់ភិក្ខុមួយរូប កាលកប្បសាបសូន្យមិនមានព្រះពុទ្ធ កើតជាជាងតម្បាញក្នុងនគរពារាណសី បានតជាយចីវរដែលរហែកដល់ព្រះបច្ចេកពុទ្ធមួយអង្គ ។ កុលបុត្តនោះ បានបំពេញបុណ្យក្នុងភពនោះៗ ដោយអាការយ៉ាងនេះ ក្នុងពុទ្ធុប្បាទនេះ កើតជាបុត្តសេដ្ឋី មានសម្បត្តិច្រើន ក្នុងកុររឃរនគរ នាដែនអវន្តី ពួកញាតិបានឲ្យឈ្មោះថា **សោណៈ** ។ ព្រោះកុលបុត្តនោះទ្រទ្រង់នូវកុណ្ឌលដែលមានតម្លៃមួយកោដិ កាលគួរហៅថា **កោដិកណ្ណៈ** ក៏ត្រឡប់ជាពោលថា **កុដិកណ្ណៈ** ។

កុលបុត្តនោះចម្រើនវ័យដោយលំដាប់ គ្រប់គ្រងទ្រព្យ កាលព្រះមហាកច្ចាយនៈអាស្រ័យផ្ទះមានត្រកូល ក្នុងបវត្តបពិត ស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះថេរៈ តាំងនៅក្នុងសរណៈ និងសីល ឧបដ្ឋាកព្រះថេរៈដោយបច្ច័យ ៤ ។

ចំណេរកាលយូរក្រោយមក កុលបុត្តនោះកើតសេចក្ដីសង្វេគ បួសជាសាមណេរនៅក្នុងសម្នាក់របស់ព្រះថេរៈៗ រកសង្ឃទសវគ្គបានដោយលំបាក ព្រោះខ្វះភិក្ខុ លុះឧបសម្បទាហើយ នៅក្នុងសម្នាក់ព្រះថេរៈអស់កាលបន្តិចបន្តួច លាព្រះថេរៈទៅកាន់ក្រុងសាវត្ថី ដើម្បីថ្វាយបង្គំព្រះសាស្តា បាននៅក្នុងគន្ធកុដិជាមួយព្រះសាស្តា ត្រូវព្រះសាស្តានិមន្តឲ្យសូធ្យសរភញ្ញក្នុងវេលាទៀបភ្លឺ ។ ក្នុងទីបំផុតនៃគាថាឧទានថា **ធិស្វា អាទីនវំ លោកេ** ដូច្នេះ ព្រះសាស្តាក៏ឲ្យសាធុការ ដោយការពោល ១៦ ព្រះសូត្រ ក្នុងអដ្ឋកវគ្គ ហើយចម្រើនវិបស្សនាសម្រេចអរហត្ត សមដូចគាថាព័ន្ធដែលលោកពោលក្នុងអបទានថា

ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ទ្រង់គួរទទួលគ្រឿងបូជា ក្នុងកាលនោះ ព្រះអង្គស្តេចចូលទៅក្នុងទីក្រុង មួយអន្លើដោយភិក្ខុមួយសែនអង្គ សុទ្ធតែជាអ្នកស្ងាត់ស្ងាញ ។ កាលព្រះសម្ពុទ្ធទ្រង់មានព្រះហឫទ័យស្ងប់រម្ងាប់ មិនញាប់ញ័រដោយលោកធម៌ ស្តេចចូលទៅក្នុងទីក្រុង ក្នុងខណៈនោះ មានសំឡេងគឹកកង ក្នុងការក្រោកទទួលត្រង់ប្រកផ្លូវ ។ ក្នុងកាលនោះ ព្រះសម្ពុទ្ធស្តេចចូលទៅក្នុងបុរី ពិណទាំងឡាយ បុគ្គលឥតប្រគំ ឥតវាយឡើយ ក៏ស្រាប់តែប្រគំដោយខ្លួនឯង ដោយអានុភាពនៃព្រះពុទ្ធ ។ ខ្ញុំក៏នមស្ការនូវព្រះពុទ្ធដ៏ប្រសើរ ព្រះនាមបទុមុត្តរៈ ជាអ្នកប្រាជ្ញធំផង ឃើញនូវបាដិហារ្យហើយ ញ៉ាំងចិត្តឲ្យជ្រះថ្លាក្នុងបាដិហារ្យនោះផងថា ឱ ! ព្រះពុទ្ធ ឱ ! ព្រះធម៌ ឱ ! សម្បទានៃព្រះសាស្តារបស់យើងទាំងឡាយ តូរ្យតន្ត្រីទាំងឡាយ សូម្បីឥតចេតនាសោះ ក៏បែរជាប្រគំដោយខ្លួនឯង ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបាននូវសញ្ញា ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃសេចក្តីសម្គាល់ក្នុងព្រះសម្ពុទ្ធ ។ កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរៈតាំងនៅក្នុងអរហត្តហើយ សូមពរ ៥ ប្រការ តាមដែល

---

១- ក្នុងអបទាន ជាបាដិហិរសញ្ញកត្ថេរ ។

ឧបជ្ឈាយ៍ផ្តាំ គឺក្នុងបច្ចន្តជនបទ ឧបសម្បទាដោយគណៈ មានព្រះវិនយធរ ជាគម្រប់ប្រាំ ១ ងូតទឹកបានជានិច្ច ១ ប្រើកម្រាលស្បែកបាន ១ ប្រើស្បែកជើងច្រើនជាន់បាន ១ នៅប្រាសចាកចីវរ ( ករណីចីវរដែលផ្ញើប្រគេន ) បាន ១ ។ បានពរទាំងនោះអំពីព្រះសាស្តាហើយ ទៅកាន់លំនៅខ្លួនវិញ ប្រាប់នូវសេចក្តីនោះដល់ឧបជ្ឈាយ៍ ។ ក្នុងរឿងនេះ មានសេចក្តីសង្ខេបប្រមាណប៉ុណ្ណេះ ឯសេចក្តីពិស្តារ គប្បីជ្រាបដោយន័យដែលមកហើយក្នុងអដ្ឋកថានៃឧទាន ។ តែក្នុងអដ្ឋកថាអង្គុត្តរនិកាយពោលថា ព្រះថេរៈបានបំពេញឧបសម្បទាហើយ រៀនកម្មដ្ឋានក្នុងសម្នាក់ឧបជ្ឈាយ៍របស់ខ្លួន ចម្រើនវិបស្សនាហើយ សម្រេចអរហត្ត ។

ក្នុងកាលតមក ព្រះថេរៈនៅដោយសុខដែលកើតអំពីវិមុត្តិ ពិចារណាបដិបទារបស់ខ្លួន កើតនូវសោមនស្ស បានពោល ៥ គាថា ដោយអំណាចឧទានថា

ខ្ញុំបានឧបសម្បទាផង បានផុតស្រឡះ ជាអ្នកមិនមានអាសវៈផង ខ្ញុំបានឃើញព្រះមានព្រះភាគអង្គនោះផង ទាំងបាននៅជាមួយក្នុងកុដិផង ។ ព្រះមានព្រះភាគ ទ្រង់ធ្វើរាត្រីជាច្រើន ( យប់ជ្រៅ ) ឲ្យកន្លងទៅក្នុងទីវាល ព្រះសាស្តាឈ្លាសក្នុងការនៅ បានស្តេចចូលទៅកាន់កុដិក្នុងពេលនោះ ។ ព្រះគោតមទ្រង់ក្រាលសង្ឃាដិហើយសម្រេចសីហសេយ្យា ដូចជាសត្វសីហៈ ដែលលះបង់សេចក្តីភ័យស្ញប់ស្ញែង ដេកក្នុងគុហាថ្មកែវ ។ លំដាប់នោះ ព្រះ

សោណៈជាសាវកនៃព្រះសម្មាសម្ពុទ្ធ អ្នកពោលពាក្យពីរោះ បាន
ពោលនូវព្រះសទ្ធម្ម ចំពោះព្រះភក្ត្រព្រះពុទ្ធដ៏ប្រសើរ ។ បាន
កំណត់ដឹងនូវបញ្ចក្ខន្ធ បានចម្រើននូវមគ្គដ៏ប្រសើរ ហើយដល់នូវ
ទីស្ងប់ដ៏ឧត្តម ជាបុគ្គលមិនមានអាសវៈ នឹងបរិនិព្វាន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឧបសម្បទា ច មេ លទ្ធា** សេចក្ដីថា ឧបសម្បទានោះ ដែលខ្ញុំបានដោយលំបាក ព្រោះត្រូវប្រជុំសង្ឃឲ្យគ្រប់ ១០ អង្គ ឯឧបសម្បទាណា ដែលព្រះមានព្រះភាគទ្រង់អនុញ្ញាតដោយគណៈមានព្រះវិនយធរជាគម្រប់ ៥ ក្នុងបច្ចន្តជនបទទាំងអស់ ដោយអំណាចការប្រទានពរ ព្រះថេរៈពោលសំដៅដល់ឧបសម្បទា ២ យ៉ាងនោះ ។ ច សព្ទប្រើក្នុងអត្ថប្រមូលមក ។ ដោយ ច សព្ទនោះ លោកសង្គ្រោះយកពរដែលបានអំពីសម្នាក់ព្រះសាស្ដាក្រៅអំពីនេះផងដែរ ។

បទថា **វិមុត្តោ ចម្ហិ អនាសវោ** សេចក្ដីថា ខ្ញុំជាអ្នករួចផុតហើយដោយការរួចចាកប្រកពកើតនៃកិលេសទាំងអស់ ដោយអរហត្តមគ្គ ។ ប្រកបសេចក្ដីថា ខ្ញុំជាអ្នកមិនមានអាសវៈ ដោយកាមាសវៈនោះឯង ។

បទថា **សោ ច មេ ភគវា ទិដ្ឋោ** សេចក្ដីថា ខ្ញុំចេញអំពីអវន្តី ទៅកាន់ក្រុងសាវត្ថី ដើម្បីជាប្រយោជន៍ដល់ព្រះមានព្រះភាគអង្គណា ព្រះមានព្រះភាគអង្គនោះ ដែលខ្ញុំមិនធ្លាប់ឃើញ ខ្ញុំបានឃើញហើយ ។

បទថា **វិហារេ ច សហាវសឹ** សេចក្ដីថា ខ្ញុំបានឃើញព្រះមានព្រះភាគតែម្យ៉ាងប៉ុណ្ណោះក៏មិនមែន ដោយពិត ខ្ញុំបាននៅរួមជាមួយព្រះសាស្ដា

ដែលទ្រង់ឃើញហេតុ ហើយឲ្យនៅក្នុងព្រះគន្ធកុដិរបស់ព្រះអង្គក្នុងវិហារផង ដែរ អាចារ្យពួកខ្លះពោលថា បទថា **វិហារេ** បានដល់ ក្នុងទីជិតវិហារ ។

បទថា **ពហុទេវ រត្តឹ** សេចក្តីថា ព្រះមានព្រះភាគគង់សម្ងំក្នុងទីវាល អស់រាត្រីជាច្រើន ដោយការសម្តែងធម៌ និងដោយការជម្រះកម្មដ្ឋានដល់ភិក្ខុទាំងឡាយ អស់បឋមយាម និងដោយការកាត់សេចក្តីសង្ស័យរបស់ទេវតា និងព្រហ្មអស់មជ្ឈិមយាម ។

បទថា **វិហារកុសលោ** បានដល់ ជាអ្នកឈ្លាសក្នុងទិព្វវិហារ ព្រហ្ម-វិហារ អនេញ្ជវិហារ និងអរិយវិហារ ។

បទថា **វិហារំ ឧាវិសី** សេចក្តីថា ចូលទៅកាន់ព្រះគន្ធកុដិ ដើម្បីបន្ទោបង់នូវការចុកស្រពន់ ដែលកើតឡើងព្រោះការអង្គុយ និងការបង្ក្រមហួសពេលវេលា ។

បទថា **សន្ថរិត្វាន សង្ឃាដឹ សេយ្យំ កប្បេសិ** សេចក្តីថា ក្រាលដោយសង្ឃាដី ៤ ជាន់ ហើយទ្រង់សម្រេចសីហសេយ្យា ដោយហេតុនោះទើបលោកពោលថា ព្រះគោតមដូចជាសត្វសីហៈ ដែលលះបង់សេចក្តីភ័យស្ញប់ស្ញែង ដេកក្នុងគុហាថ្មកែវ ដូច្នេះ ។

ព្រះថេរៈប្រារព្ធព្រះមានព្រះភាគ ដោយគោត្តថា **គោតមោ** ក្នុងគាថានេះ ។ បទថា **សីហោ សេលគុហាយំវ** បានដល់ ក្នុងគុហានៃភ្នំ ដែលសម្រេចហើយអំពីថ្ម សីហមិគរាជលះនូវការខ្លាចបាន ព្រោះជាសត្វមានតេជះខ្ពស់ សម្រេចការដេកដោយបង្អៀងស្តាំ យកជើងត្រួតលើជើង យ៉ាងណា

ព្រះគោតមក៏ដូច្នោះ ជាអ្នកលះនូវការភ័យខ្លាច ព្រោះកាត់នូវកិលេស ដែលជាហេតុឲ្យតក់ស្លុត ឲ្យព្រឺរោម ព្រឺស្បែកបានហើយ ទ្រង់សម្រេចសីហ-សេយ្យា ។

បទថា **តតោ** បានដល់ ខាងក្រោយ អធិប្បាយថា ព្រះថេរៈ ដែលព្រះសាស្ដាសម្រេចសីហសេយ្យាហើយ ទ្រង់ក្រោកឡើងអំពីទីនោះ និមន្តថា ម្នាលភិក្ខុ ចូរអ្នកពោលធម៌តាមដែលអ្នកស្ទាត់ជំនាញ ។

បទថា **កល្យាណវាក្ករណោ** បានដល់ ជាអ្នកពោលនូវធម៌ដ៏ពីរោះ អធិប្បាយថា លំដាប់នៃពាក្យ ដល់ព្រមដោយល្អ ។

បទថា **សោណោ អភាសិ សទ្ធម្មំ** សេចក្ដីថា ព្រះសោណកុដិកណ្ណៈ បានពោលព្រះសូត្រក្នុងអដ្ឋកវគ្គ ១៦ សូត្រ ដោយប្រចក្សចំពោះព្រះភក្ត្រ ព្រះសម្ពុទ្ធដ៏ប្រសើរ ព្រោះហេតុនោះ ទើបព្រះថេរៈពោលទូន្មានខ្លួននោះឯង ដូចអ្នកដទៃ ដោយគាថាដូចពោលមកនេះ ។

បទថា **បញ្ចក្ខន្ធេ បរិញ្ញាយ** សេចក្ដីថា កំណត់ដឹងឧបាទានក្ខន្ធ ៥ ដោយបរិញ្ញាទាំង ៣ ហើយ កាលកំណត់ដឹងឧបាទានក្ខន្ធ ៥ នោះឯង ធ្វើផ្លូវ គឺអរិយមគ្គមានអង្គ ៨ ឲ្យកើតហើយ សម្រេចនូវការស្ងប់ក្រៃលែង គឺព្រះនិព្វានតាំងនៅ ជាអ្នកមិនមានអាសវៈ បន្ទាប់អំពីនោះ គឺនឹងបរិនិព្វាន ក្នុងឥឡូវនេះ គឺនឹងនិព្វានដោយអំណាចអនុបាទិសេសនិព្វាន ដូច្នេះ ។

**អដ្ឋកថា សោណកុដិកណ្ណត្ថេរគាថា ចប់**

# សុត្តន្តបិដក

## កោសិយត្ថេរគាថា

[ ២១០ ] បុគ្គលណា ជាអ្នកប្រាជ្ញ អ្នកដឹងឱវាទរបស់គ្រូទាំងឡាយ គប្បីនៅក្នុងឱវាទរបស់គ្រូនោះផង គប្បីញ៉ាំងសេចក្តីស្រឡាញ់ឲ្យកើតផង បុគ្គលនោះ ឈ្មោះថា ជាអ្នកមានភក្តីផង ឈ្មោះថា ជាអ្នកប្រាជ្ញផង ទាំងបុគ្គលនោះ មុខជានឹងមានសេចក្តីវិសេសក្នុងធម៌ទាំងឡាយ ព្រោះដឹង ( នូវសច្ចធម៌ ) ។ អន្តរាយទាំងឡាយ ដ៏ខ្លាំងក្លាកើតឡើងហើយ តែមិនបានគ្របសង្កត់នូវបុគ្គលណា ជាអ្នកពិចារណា បុគ្គលនោះ ឈ្មោះថា ជាអ្នកមានកម្លាំងផង ឈ្មោះថា ជាអ្នកប្រាជ្ញផង ទាំងជាអ្នកវិសេសក្នុងធម៌ទាំងឡាយ ព្រោះដឹង ( នូវសច្ចធម៌ ) ។ បុគ្គលណា នឹងធឹងមិនញាប់ញ័រ ជាអ្នកមានបញ្ញាជ្រៅដូចសមុទ្រ ឃើញនូវសេចក្តីដ៏ល្អិត បុគ្គលនោះ ឈ្មោះថា ជាអ្នកដែលកិលេសដឹកនាំមិនបានផង ជាអ្នកប្រាជ្ញផង ទាំងជាអ្នកវិសេសក្នុងធម៌ទាំងឡាយ ព្រោះដឹង ( នូវសច្ចធម៌ ) ។ បុគ្គលណា ជាអ្នកចេះដឹងច្រើន ជាអ្នកចងចាំនូវធម៌ ទាំងជាអ្នកប្រព្រឹត្តនូវធម៌ដ៏សមគួរដល់ធម៌ បុគ្គលនោះ ឈ្មោះថា ជាអ្នកប្រាកដស្មើដោយគ្រូនោះផង ជាអ្នកប្រាជ្ញផង ទាំងជាអ្នកវិសេសក្នុងធម៌ទាំងឡាយ ព្រោះដឹង ( នូវសច្ចធម៌ ) ។ បុគ្គលណា ដឹងនូវសេចក្តីនៃភាសិតផង លុះដឹងនូវសេចក្តីនៃភាសិតហើយ ធ្វើតាមផង បុគ្គលនោះ ឈ្មោះថា ជាអ្នកច្នងផុតនូវសេចក្តីសង្ស័យផង ជាអ្នកប្រាជ្ញផង ទាំងជាអ្នកវិសេសក្នុងធម៌ទាំងឡាយ ព្រោះដឹង ( នូវសច្ចធម៌ ) ។

កោសិយត្ថេរ

**ឧទ្ទាន**

គាថា ៦៥ ក្នុងគាថាទាំងនោះ ព្រះថេរៈ ១២ អង្គ សម្តែង គឺ រាជទត្តត្ថេរ ១ សុភូតត្ថេរ ១ គិរិមានន្ទត្ថេរ ១ សុមនត្ថេរ ១ វឌ្ឍត្ថេរ ១ នទីកស្សបត្ថេរ ១ គយាកស្សបត្ថេរ ១ វក្កលិត្ថេរ ១ វិជិតសេនត្ថេរ ១ យសទត្តត្ថេរ ១ សោណកុដិកណ្ណត្ថេរ ១ កោសិយត្ថេរ ១ ។

បញ្ចកនិបាត ចប់

# អដ្ឋកថា

## កោសិយត្ថេរគាថា

[ ២១០ ] គាថារបស់ព្រះកោសិយត្ថេរ មានពាក្យផ្តើមថា **យោ វេ គរូនំ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងកពនោះៗ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមវិបស្សី កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្តីហើយ ថ្ងៃមួយ ឃើញព្រះសាស្តា មានចិត្តជ្រះថ្លា បានថ្វាយអំពៅមួយកំណាត់ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលព្រាហ្មណ៍ នាមគជវគ្គ ញាតិឲ្យ

ឈ្មោះដោយអំណាចគោត្តថា **កោសិយៈ** ។ កុលបុត្តនោះដល់នូវភាពជាអ្នកដឹងក្តីហើយ ចូលទៅរកព្រះធម្មសេនាបតីរឿយៗ ស្តាប់ធម៌ក្នុងសម្នាក់ព្រះថេរៈ បាននូវសទ្ធាក្នុងសាសនា ព្រោះបានស្តាប់ធម៌នោះ បួសហើយ ប្រកបរឿយៗ នូវកម្មដ្ឋាន មិនយូរប៉ុន្មានក៏បានសម្រេចអរហត្ត សមដូចគាថាព័ន្ធដែលលោកពោលក្នុងអបទានថា

ខ្ញុំកើតជាអ្នករក្សាទ្វារក្នុងនគរពន្ធុមតី បានឃើញព្រះពុទ្ធ ព្រះអង្គមានធូលីទៅប្រាសហើយ ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានយកអំពៅមួយកំណាត់ ទៅថ្វាយព្រះពុទ្ធដ៏ប្រសើរ ព្រះនាមវិបស្សី ព្រះអង្គជាអ្នកស្វែងរកនូវគុណដ៏ធំ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយអំពៅ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃអំពៅមួយកំណាត់ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយដូច្នេះ[១] ។

ព្រះថេរៈកាលសម្រេចអរហត្តហើយ ពិចារណាបដិបទារបស់ខ្លួន កាលនឹងសរសើរការនៅរួមជាមួយគ្រូ និងចូលទៅអាស្រ័យជាមួយសប្បុរស ទើបពោលគាថាទាំង ៥ នេះថា

បុគ្គលណា ជាអ្នកប្រាជ្ញ អ្នកដឹងឱវាទរបស់គ្រូទាំងឡាយ គប្បី

---

១- ក្នុងអបទាន ជាឧច្ឆុខណ្ឌិកត្ថេរ ។

នៅក្នុងឱវាទរបស់គ្រូនោះផង គប្បីញុំាងសេចក្ដីស្រឡាញ់ឲ្យកើតផង បុគ្គលនោះ ឈ្មោះថា ជាអ្នកមានកក្ដីផង ឈ្មោះថា ជាអ្នកប្រាជ្ញផង ទាំងបុគ្គលនោះ មុខជានឹងមានសេចក្ដីវិសេស ក្នុងធម៌ទាំងឡាយ ព្រោះដឹង ( នូវសច្ចធម៌ ) ។ អន្តរាយទាំងឡាយដ៏ខ្លាំងក្លាកើតឡើងហើយ តែមិនបានគ្របសង្កត់នូវបុគ្គលណា ជាអ្នកពិចារណា បុគ្គលនោះ ឈ្មោះថា ជាអ្នកមានកម្លាំងផង ឈ្មោះថា ជាអ្នកប្រាជ្ញផង ទាំងជាអ្នកវិសេសក្នុងធម៌ទាំងឡាយ ព្រោះដឹង ( នូវសច្ចធម៌ ) ។ បុគ្គលណា នឹងជឹងមិនញាប់ញ័រជាអ្នកមានបញ្ញាជ្រៅដូចសមុទ្រ ឃើញនូវសេចក្ដីដ៏ល្អិត បុគ្គលនោះ ឈ្មោះថា ជាអ្នកដែលកិលេសដឹកនាំមិនបានផង ជាអ្នកប្រាជ្ញផង ទាំងជាអ្នកវិសេសក្នុងធម៌ទាំងឡាយ ព្រោះដឹង ( នូវសច្ចធម៌ ) ។ បុគ្គលណា ជាអ្នកចេះដឹងច្រើន ជាអ្នកចងចាំនូវធម៌ ទាំងជាអ្នកប្រព្រឹត្តនូវធម៌ដ៏សមគួរដល់ធម៌ បុគ្គលនោះ ឈ្មោះថា ជាអ្នកប្រាកដស្មើដោយគ្រូនោះផង ជាអ្នកប្រាជ្ញផង ទាំងជាអ្នកវិសេសក្នុងធម៌ទាំងឡាយ ព្រោះដឹង ( នូវសច្ចធម៌ ) ។ បុគ្គលណា ដឹងនូវសេចក្ដីនៃភាសិតផង លុះដឹងនូវសេចក្ដីនៃភាសិតហើយ ធ្វើតាមផង បុគ្គលនោះ ឈ្មោះថា ជាអ្នកឆ្លងផុតនូវសេចក្ដីសង្ស័យផង ជាអ្នកប្រាជ្ញផង ទាំងជាអ្នកវិសេស ក្នុងធម៌ទាំងឡាយ ព្រោះដឹង ( នូវសច្ចធម៌ ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យោ** បានដល់ បុគ្គលណាម្នាក់ ក្នុងបណ្តាបរិស័ទ ៤ មានខត្តិយបរិស័ទជាដើម ។ បទថា **វេ** ប្រែថា ជាពាក្យប្រាកដ ។ បទថា **គរូនំ** បានដល់ បណ្ឌិតដែលប្រកបដោយគុណ មានសីលជាដើម ។

បទថា **វចនញ្ញូ** អធិប្បាយថា ជាអ្នកដឹងនូវពាក្យ គឺពាក្យប្រៀនប្រដៅរបស់បណ្ឌិតទាំងនោះ ហើយបដិបត្តិតាមពាក្យប្រៀនប្រដៅ កាលបដិបត្តិហើយ ដឹងនូវផលនៃកិច្ចបដិបត្តិនោះ ។

បទថា **ធីរោ** បានដល់ បុគ្គលដែលដល់ព្រមដោយបញ្ញា ។

បទថា **វសេ ច តម្ហិ ជនយេថ បេមំ** សេចក្តីថា គប្បីនៅក្នុងពាក្យ គឺក្នុងឱវាទរបស់គ្រូទាំងឡាយនោះ គឺគប្បីបដិបត្តិតាមពាក្យប្រៀនប្រដៅ កាលបដិបត្តិហើយ គប្បីឲ្យកើត គឺឲ្យកើតនូវសេចក្តីស្រឡាញ់ គោរពក្នុងពាក្យប្រៀនប្រដៅទាំងនោះថា អញនឹងជាបុគ្គលកន្លងផុតទុក្ខ មានជាតិទុក្ខជាដើមនេះ ដោយឱវាទនេះហ្ន៎ ។ ពាក្យទាំង ២ នេះ ជាពាក្យអធិប្បាយសេចក្តីដែលពោលហើយ ដោយ ២ បទថា **គរូនំ វចនញ្ញូ ធីរោ** បុគ្គលណាជាអ្នកប្រាជ្ញ អ្នកដឹងឱវាទរបស់គ្រូទាំងឡាយ ដូច្នេះ ។

បទថា **សោ** សេចក្តីថា បុគ្គលណាជាធីរជន ដឹងនូវពាក្យរបស់គ្រូទាំងឡាយ បុគ្គលនោះ ឈ្មោះថា ជាអ្នកមានភក្តីក្នុងគ្រូទាំងនោះ ដោយកិច្ចបដិបត្តិតាមពាក្យប្រៀនប្រដៅ និងឈ្មោះថា ជាអ្នកប្រាជ្ញ ព្រោះមិនកន្លងនូវពាក្យប្រៀនប្រដៅនោះ សូម្បីដោយហេតុនៃជីវិត ។

បទថា **ញត្វា ច ធម្មេសុ វិសេសិ អស្ស** សេចក្តីថា កាលបដិបត្តិ

យ៉ាងនេះ ជាអ្នកដល់នូវភាពជាបុគ្គលវិសេស ដែលហៅថា ជាអ្នកមានវិជ្ជា ៣ មានអភិញ្ញា ៦ សម្រេចបដិសម្ភិទា ដោយគុណមានវិជ្ជា ៣ ជាដើម ក្នុងបណ្ដាធម៌ដែលជាលោកិយ និងជាលោកុត្តរ ព្រោះហេតុនៃការដឹងអរិយសច្ច ៤ ដោយបដិបទានោះ ។

បទថា **យំ** សេចក្ដីថា អន្តរាយដែលប្រាកដ មានត្រជាក់ ក្ដៅ ឃ្លានស្រេកជាដើម និងអន្តរាយដែលកំបាំង មានរាគៈជាដើម ដែលបានរោហារថា អន្តរាយ ព្រោះធ្វើអន្តរាយចំពោះកិច្ចបដិបត្តិដ៏ខ្លាំងក្លាកើតឡើងហើយ គឺមានកម្លាំង រមែងធ្វើបុគ្គល ( នោះ ) ឲ្យញាប់ញ័រមិនបាន គឺមិនធ្វើបុគ្គលណាម្នាក់ឲ្យញាប់ញ័រ ។

សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះជាអ្នកពិចារណា អធិប្បាយថា បុគ្គលពិចារណា គឺបុគ្គលតាំងនៅក្នុងកម្លាំងនៃការពិចារណា ។ បទថា **សោ** សេចក្ដីថា បុគ្គលណាសូម្បីត្រូវអន្តរាយដ៏ខ្លាំងក្លាគ្របសង្កត់មិនបាន បុគ្គលនោះក៏ជាបុគ្គលឈ្មោះថា មានកម្លាំង មានបញ្ញា មានសេចក្ដីព្យាយាមមាំ និងឈ្មោះថា ជាបណ្ឌិត ព្រោះដល់ព្រមដោយកម្លាំង គឺបញ្ញា ដែលអាចគ្របសង្កត់សត្រូវ គឺកិលេស មិនមានចំណែកសេសសល់ ។

បទថា **ញត្វា ច ធម្មេសុ វិសេសិ អស្ស** នេះ មានអត្ថដូចពោលហើយនោះឯង ។

បទថា **សមុទ្ទោវ ឋិតោ** សេចក្ដីថា មានការតាំងនៅជាសភាវៈ ដូចមហាសមុទ្រ ដូច្នោះ ។ ដូចមហាសមុទ្រ ត្រង់ក្នុំសិនេរុ ដែលមានជម្រៅ

៨៤០០០ យោជន៍ តាំងនៅមិនញាប់ញ័រ មិនទោរទន់ ដោយកម្លាំងខ្យល់តាមប្រក្រតី ដែលតាំងឡើងអំពីទិសទាំង ៨ និងមានជម្រៅ យ៉ាងណា ធីរជនក៏ដូច្នោះ តាំងនៅមិនញាប់ញ័រ ព្រោះមិនទោរទន់ដោយកម្លាំងខ្យល់ គឺកិលេស និងដោយខ្យល់ គឺវាទៈរបស់ពួកតិរ្ថិយ ។ ធីរជន ឈ្មោះថា ជាអ្នកមានបញ្ញាជ្រៅ និងជាអ្នកឃើញប្រយោជន៍ដ៏ល្អិត ព្រោះដឹងច្បាស់នូវអត្ថនៃបដិច្ចសមុប្បាទជាដើម ដែលជ្រាលជ្រៅ ដែលបុគ្គលមិនសន្សំបញ្ញាសួន់មិនបាន ជាធម៌ល្អិតសុខុម ។ ឈ្មោះថា ជាអ្នកប្រាជ្ញផង ឈ្មោះថា ជាអ្នកដែលកិលេសដឹកនាំមិនបានផង គឺជាបុគ្គលមិនញាប់ញ័រ ។ម្យ៉ាងទៀត ឈ្មោះថា ជាអ្នកដែលកិលេសដឹកនាំមិនបាន ព្រោះមិនទោរទន់ដោយអំណាចនៃកិលេស ឬដោយមារណាមួយ មានទេវបុត្តមារជាដើម ឈ្មោះថា ជាបណ្ឌិត ព្រោះអត្ថដូចពោលហើយ ។ ពាក្យដ៏សេស មានអត្ថដូចពោលហើយនោះឯង ។

បទថា **ពហុស្សុតោ** សេចក្តីថា ឈ្មោះថា ជាពហូសូត ដោយអំណាចភាពជាពហូសូតខាងបរិយត្តិ និងឈ្មោះថា **ពហុស្សុតោ** ព្រោះមានសុតៈ គឺសុត្តៈ និងគេយ្យៈជាដើម ឈ្មោះថា **ធម្មធរោ** ព្រោះទ្រទ្រង់នូវធម៌នោះឯង មិនឲ្យវិនាស ដូចខ្លាញ់នៃរាជសីហ៍ ដែលគេដាក់ក្នុងភាជន៍មាស ដូច្នោះ ។

បទថា **ធម្មស្ស ហោតិ អនុធម្មចារី** សេចក្តីថា ឈ្មោះថា **ធម្មស្ស ហោតិ អនុធម្មចារី** ព្រោះដឹងអត្ថ ដឹងធម៌ តាមដែលស្តាប់មក តាមដែលរៀនមក ហើយប្រព្រឹត្ត គឺបដិបត្តិនូវធម៌ដែលសមគួរដល់លោកុត្តរធម៌

៩ ដូចជាចតុប្បារិសុទ្ធិសីល ធុតង្គ និងអសុភកម្មដ្ឋានជាដើម ដែលហៅថា បុព្វភាគបដិបទា គឺទន្ទឹងនូវការចាក់ធ្លុះថា ថ្ងៃនេះៗ ដូច្នេះ ។

បទថា **សោ តាទិសោ នាម ច ហោតិ បណ្ឌិតោ** សេចក្ដីថា បុគ្គលណាជាពហូសូត ទ្រទ្រង់នូវធម៌ និងប្រព្រឹត្តធម៌សមគួរដល់ធម៌ ព្រោះអាស្រ័យគ្រូណា បុគ្គលនោះឯងក៏ដូច្នោះ គឺដូចគ្នានឹងគ្រូនោះ ឈ្មោះថា ជាបណ្ឌិត ព្រោះមានភាវៈនៃកិច្ចបដិបត្តិដូចគ្នា ។

បុគ្គលបែបនោះ ទាំងជាអ្នកវិសេសក្នុងធម៌ទាំងឡាយ ។ ពាក្យនោះបានពោលអធិប្បាយហើយ ។

បទថា **អត្ថញ្ញូ យោ ជានាតិ ភាសិតស្ស** សេចក្ដីថា បុគ្គលណារមែងដឹងអត្ថនៃព្រះបរិយត្តិធម៌ ដែលព្រះសម្មាសម្ពុទ្ធត្រាស់ហើយ កាលដឹងតែងដឹងអត្ថតាមដែលពោលហើយ ក្នុងទីនោះៗ ថា សីល ត្រាស់ក្នុងទីនេះ សមាធិ ត្រាស់ក្នុងទីនេះ បញ្ញាត្រាស់ក្នុងទីនេះ ហើយធ្វើដោយប្រការនោះ គឺបដិបត្តិតាមដែលព្រះសាស្ដាទ្រង់ប្រៀនប្រដៅ ។

បទថា **អត្ថន្តរោ នាម ស ហោតិ បណ្ឌិតោ** សេចក្ដីថា បុគ្គលនោះគឺបែបនោះ ជាអ្នកនៅខាងក្នុងហេតុផល រមែងឈ្មោះថាជាបណ្ឌិត ព្រោះជាអ្នកធ្ងន់ក្នុងប្រយោជន៍ គឺព្រោះធ្វើត្រឹមតែការដឹងប្រយោជន៍នៃសីលជាដើម ឲ្យជាឧបនិស្ស័យ ។ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ។

ក្នុងគាថាទាំងនេះ គប្បីជ្រាបថា គាថាដើម ព្រះថេរៈពោលដល់ភាពជាបុគ្គលវិសេស ដែលមានសទ្ធាជាឧបនិស្ស័យ ដោយន័យជាដើមថា **យោ**

*ថ* **តរុណំ** *ដូច្នេះ ។ ដោយគាថាទី ២ លោកពោលដល់ភាពជាបុគ្គលវិសេស ដែលមានវីរិយៈជាឧបនិស្ស័យ ដោយន័យជាដើមថា* **យំ អាបធា** *ដូច្នេះ ។ ដោយគាថាទី ៣ លោកពោលដល់ភាពជាអ្នកវិសេស ដែលមានសមាធិជាឧបនិស្ស័យ ដោយន័យជាដើមថា* **យោ ច សមុទ្ទោវ ឋិតោ** *ដូច្នេះ ។ ដោយគាថាទី ៤ លោកពោលដល់ភាពជាអ្នកវិសេស ដែលមានសតិជាឧបនិស្ស័យ ដោយន័យជាដើមថា* **ពហុស្សុតោ** *ដូច្នេះ ។ ដោយគាថាទី ៥ គប្បីជ្រាបថា លោកពោលដល់ភាពជាបុគ្គលវិសេស ដែលមានបញ្ញាជាឧបនិស្ស័យ ដោយន័យជាដើមថា* **អត្ថញ្ញូ យោ ជានាតិ** *ដូច្នេះ ។ល។*

**អដ្ឋកថាកោសិយត្ថេរគាថា ចប់**

**ថេរគាថាបញ្ចកនិបាត ចប់**

# សុត្តន្តបិដក
# ថេរគាថា ចត្តាលិសនិបាត

## ឧរុវេលកស្សបត្ថេរគាថា

[ ២១១ ] ខ្ញុំឃើញបាដិហារ្យរបស់ព្រះគោតម ព្រះអង្គមានយសដល់ម្ល៉ោះ ក៏នៅតែមិនក្រាបសំពះ ព្រោះតែសេចក្តីប្រណែន នឹងសេចក្តីប្រកាន់ឲ្យកាន់ស្រឡាំ ។ ព្រះសាស្តាជាសារថីរបស់ជន ទ្រង់ជ្រាបសេចក្តីត្រិះរិះរបស់ខ្ញុំហើយ បានដាស់តឿន លំដាប់នោះ ខ្ញុំមានសេចក្តីសង្វេគ និងសេចក្តីព្រឺរោម ដែលមិនធ្លាប់កើតៗ ហើយ ។ កាលខ្ញុំនៅជាជដិលក្នុងកាលមុន ការសម្រេចលាភសក្ការៈណាតិចតួច គ្រានោះ ខ្ញុំលះបង់នូវការសម្រេច គឺលាភសក្ការៈនោះហើយ មកបួសក្នុងសាសនាព្រះជិនស្រី ។ កាលពីដើម ខ្ញុំជាអ្នកត្រេកអរដោយការបូជា ធ្វើកាមធាតុជាប្រធាន កាលខាងក្រោយមក ខ្ញុំបានដករាគៈ ទោសៈ និងមោហៈចោលហើយ ។ ខ្ញុំដឹងខន្ធដែលធ្លាប់អាស្រ័យនៅក្នុងកាលពីដើម បានជម្រះទិព្វចក្ខុឲ្យស្អាត ជាអ្នកមានឫទ្ធិ ដឹងចិត្តអ្នកដទៃ ទាំងបានសម្រេចទិព្វសោត ។ មួយទៀត កុលបុត្តចេញចាកផ្ទះមកបួសក្នុងធម្មវិន័យ ដើម្បីប្រយោជន៍ណា ប្រយោជន៍នោះ ខ្ញុំបានដល់ហើយតាមលំដាប់ ទាំងធ្វើឲ្យអស់សំយោជនធម៌ទាំងពួង ។

*ឧរុវេលកស្សបត្ថេរ*

# អដ្ឋកថា
# ថេរគាថា ឆក្កនិបាត

## ឧរុវេលកស្សបត្ថេរគាថា

[ ២១១ ] ក្នុងឆក្កនិបាត គាថារបស់ព្រះឧរុវេលកស្សបត្ថេរ មានពាក្យផ្ដើមថា **ទិស្វាន បាដិហីរានិ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនោះក៏ជាអ្នកមានបុញ្ញាធិការធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កើតក្នុងផ្ទះមានត្រកូល ដល់នូវការចម្រើនវ័យហើយ ស្ដាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្ដា បានឃើញព្រះសាស្ដាស្ថាបនាភិក្ខុមួយរូប ក្នុងតំណែងឯតទគ្គៈ ខាងមានបរិស័ទច្រើន ខ្លួនឯងក៏ប្រាថ្នាតំណែងនោះ ទើបថ្វាយមហាទាន ហើយធ្វើសេចក្ដីប្រាថ្នា ។ ឯព្រះមានព្រះភាគបានឃើញថា ការប្រាថ្នានៃកុលបុត្តនេះ មិនមានអន្តរាយ ទើបទ្រង់ព្យាករថា ក្នុងអនាគតកាល កុលបុត្តនេះ នឹងជាកំពូលជាងភិក្ខុខាងមានបរិវារច្រើន ក្នុងសាសនារបស់ព្រះគោតមសម្ពុទ្ធ ។

កុលបុត្តនោះធ្វើបុណ្យក្នុងជាតិនោះ ដរាបដល់អស់អាយុ ចុតិអំពីជាតិនោះហើយ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងទីបំផុត ៩២

កប្ប រាប់អំពីកប្បនេះ កើតជាប្អូនប្រុសមាតាជទៃនៃព្រះមានព្រះភាគព្រះនាមផុស្សៈ មានប្អូនប្រុសដទៃ ២ អង្គទៀត បងប្អូនទាំង ៣ នោះ បូជាព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយការនៅយ៉ាងក្រៃលែង ធ្វើកុសលដរាបអស់អាយុ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ មុនព្រះមានព្រះភាគនៃយើងកើតឡើង កើតជាបងប្អូនប្រុសនឹងគ្នាតាមលំដាប់ ក្នុងត្រកូលព្រាហ្មណ៍ ក្នុងក្រុងសាវត្ថី ទាំង ៣ នាក់ មានឈ្មោះថា កស្សបៈព្រោះជាកស្សបគោត្ត ។

បងប្អូនទាំង ៣ នោះ ធំហើយ ក៏រៀនត្រៃវេទ ។ បណ្ដាបងប្អូនប្រុសទាំង ៣ នោះ បងប្រុសច្បង មានមាណពជាបរិវារ ៥០០ ប្អូនកណ្ដាល ៣០០ ប្អូនពៅ ២០០ ។ បងប្អូនទាំង ៣ នោះ ពិចារណាមើលសារៈក្នុងគម្ពីររបស់ខ្លួន ឃើញតែប្រយោជន៍បច្ចុប្បន្នប៉ុណ្ណោះ ទើបពេញចិត្តក្នុងការបួស ។ បណ្ដាបងប្អូនទាំង ៣ នោះ បងប្រុស មួយអន្លើដោយបរិវារ ទៅកាន់តំបន់ឧរុវេលា បួសជាឥសី ទើបមានឈ្មោះថា ឧរុវេលកស្សបៈ ប្អូនប្រុសបួសត្រង់ស្ទឹងបត់នៃស្ទឹងមហាគង្គា ទើបមានឈ្មោះថា នទីកស្សបៈ ប្អូនប្រុសពៅបួសត្រង់គយាសីសបទេស ទើបមានឈ្មោះថា គយាកស្សបៈ ។

កាលបងប្អូនទាំង ៣ នោះបួសជាឥសី នៅក្នុងទីនោះៗ យ៉ាងនេះហើយ ពេលវេលាកន្លងទៅជាច្រើន ព្រះពោធិសត្វនៃយើងទាំងឡាយ ទ្រង់ចេញមហាភិនេស្ក្រមណ៍ ទ្រង់ចាក់ធ្លុះនូវសព្វញ្ញុតញ្ញាណ ទ្រង់ប្រកាសព្រះធម្មចក្រដោយលំដាប់ ទ្រង់ឲ្យបញ្ចវគ្គិយត្ថេរតាំងនៅក្នុងអរហត្ត ទ្រង់ទូន្មាន

សម្លាញ់ ៥៤ នាក់ មានយសជាប្រធាន ហើយទ្រង់បញ្ជូនព្រះអរហន្ត ៦០ អង្គទៅ ដោយព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចូរពួកអ្នកត្រាច់ចារិកទៅ ដូច្នេះជាដើម ហើយទ្រង់ទូន្មានកទ្ទវគ្គិយកុមារ ហើយយាងទៅកាន់លំនៅ របស់ឧរុវេលកស្សបៈ ទ្រង់ចូលទៅកាន់រោងបូជាភ្លើង ដើម្បីគង់ ទ្រង់ទូន្មាន ឧរុវេលកស្សបៈ មួយអន្លើដោយបរិស័ទ ដោយបាដិហារ្យ ៣៥០០ មានការ ទូន្មាន ស្តេចនាគដែលនៅត្រង់រោងភ្លើងជាដើម ហើយទ្រង់ឲ្យបព្វជ្ជា ។ ឯ ប្អូនប្រុសទាំង ២ ដឹងថា ឧរុវេលកស្សបៈនោះបួសហើយ ព្រមទាំងបរិវារ នាំគ្នាមកបួសក្នុងសម្នាក់របស់ព្រះសាស្តា ។ ជនទាំងអស់នោះឯង បានជា ឯហិភិក្ខុ ទ្រទ្រង់នូវបាត្រ និងចីវរដែលសម្រេចដោយឫទ្ធិ ។

ព្រះសាស្តាទ្រង់នាំសមណៈ ១០០០ អង្គនោះ ទៅកាន់គយាសីសប្រទេស ហើយគង់លើថ្មដា ឲ្យសមណៈទាំងអស់ តាំងនៅក្នុងអរហត្តដោយ អាទិត្តបរិយាយទេសនា សមដូចគាថាព័ន្ធដែលលោកពោលក្នុងអបទានថា

ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ជាអ្នកប្រាជ្ញ ទ្រង់ជ្រាបច្បាស់នូវ
លោកទាំងមូល មានបញ្ញាចក្ខុ ទ្រង់ឧប្បត្តិឡើងក្នុងកប្បទីមួយ
សែនអំពីកប្បនេះ ។ ព្រះពុទ្ធជាម្ចាស់ទ្រង់ប្រទានឱវាទ ញ៉ាំង
សត្វឲ្យត្រាស់ដឹង ចម្លងសត្វទាំងពួង ទ្រង់ឈ្លាសក្នុងទេសនា
ស្តេចញ៉ាំងប្រជុំជនច្រើនឲ្យឆ្លង ( ចាកលោក ) ។ ព្រះអង្គមាន
សេចក្តីអនុគ្រោះ មានសេចក្តីអាណិតអាសូរ ស្វែងរកនូវប្រ-
យោជន៍ដល់សត្វទាំងពួង បានញ៉ាំងពួកតិរ្ថិយទាំងពួង ដែលមក

ប្រជុំគ្នា ឲ្យតាំងនៅស៊ប់ក្នុងសីល ៥ ។ សាសនានេះមិនវឹកវរ សូន្យចាកពួកតិរ្ថិយ វិចិត្រដោយពួកព្រះអរហន្ត ជាអ្នកស្ទាត់ជំនាញ ប្រកបដោយតាទិគុណ ។ ព្រះមហាមុនីនោះ មានកម្ពស់ ៥៨ ហត្ថ ប្រាកដស្មើដោយគ្រឿងបូជា ជាវិការនៃមាស មានលក្ខណៈដ៏ប្រសើរ ៣២ ប្រការ ។ មានព្រះជន្មមួយសែនឆ្នាំ កាលព្រះអង្គគង់ព្រះជន្មនៅឡើយ បានញុំាងពួកជនច្រើនឲ្យឆ្លង ( ចាកលោក ) កាលនោះ ខ្ញុំកើតជាព្រាហ្មណ៍ ដែលលោកសន្មតថា ជាសប្បុរស នៅក្នុងក្រុងហង្សវតី បានចូលទៅជិតព្រះពុទ្ធជាពន្លឺនៃលោក ហើយស្ដាប់ធម្មទេសនា ។ ក្នុងកាលនោះ ខ្ញុំបានឃើញព្រះមានបុណ្យកំពុងតាំងមហាបុរសសាវ័ក ក្នុងទីជាឯតទគ្គៈ ក្នុងកណ្ដាលមហាបរិស័ទ ខ្ញុំបានឮហើយ ក៏ត្រេកអរ ។ ខ្ញុំនិមន្តព្រះមហាជិនស្រី ព្រមទាំងបរិវារជាច្រើន បានថ្វាយទានជាមួយនឹងពួកព្រាហ្មណ៍មួយពាន់នាក់ ។ លុះថ្វាយមហាទានហើយ ក៏ក្រាបថ្វាយបង្គំព្រះនាយក ឋិតនៅក្នុងទីដ៏សមគួរ ត្រេកអរហើយ ក៏ពោលពាក្យនេះថា បពិត្រព្រះអង្គមានព្យាយាម ដោយសេចក្ដីជឿចំពោះព្រះអង្គផង ដោយគុណដ៏ក្រៃលែងផង បរិស័ទច្រើន សូមសម្រេចដល់ខ្ញុំព្រះអង្គ ដែលកើតក្នុងទីនោះៗ ។

គ្រានោះ ព្រះសាស្ដាមានព្រះសូរសៀងក្បោះក្បាយ ដូចជា

កម្មរនៃដីរ ពីព្រោះដូចសត្វករវិក បានត្រាស់ចំពោះបរិស័ទថា អ្នកទាំងឡាយ ចូរមើលព្រាហ្មណ៍នុ៎ះ មានសម្បុរដូចមាស មានកំភួនដៃធំ មានមុខ និងភ្នែកដូចផ្កាឈូក មានរោមដ៏ខៀវងឡើង ជាអ្នកត្រេកអរ មានសេចក្តីជឿក្នុងគុណរបស់តថាគត ។ ព្រាហ្មណ៍នេះ ប្រាថ្នានូវតំណែងនៃភិក្ខុ ដែលមានសំឡេងដូចជាសីហៈនោះ នឹងបាននូវតំណែងនុ៎ះដូចបំណង ក្នុងកាលជាអនាគត ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ មានព្រះមហាបុរស សម្ភពក្នុងត្រកូលស្តេចឱក្កាកៈ នឹងបានជាព្រះសាស្តាក្នុងលោក ព្រះនាមគោតម ។ ព្រាហ្មណ៍នេះ ជាឱរសដែលធម៌និម្មិត ជាអ្នកទទួលមត៌កក្នុងធម៌របស់ព្រះគោតមនោះ នឹងបានជាសាវ័កនៃព្រះសាស្តា មាននាមថាកស្សបៈ ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ នឹងមានព្រះសាស្តាព្រះនាមផុស្សៈ ព្រះអង្គប្រសើរ រកបុគ្គលប្រៀបផ្ទឹមមិនបាន ឥតមានបុគ្គលស្មើ ជានាយក ជាកំពូលនៃលោក ។ ព្រះអង្គកម្ចាត់បង់នូវងងឹតទាំងពួង ទ្រង់ដោះនូវបណ្តាញធំ គឺតណ្ហា ស្តេចបង្អុរចុះនូវភ្លៀង គឺអមតៈ ហើយញ៉ាំងមនុស្សលោកព្រមទាំងទេវលោក ឲ្យឆ្អែតស្កប់ស្កល់ ( ដោយទឹកអម្រឹតនោះ ) ។ កាលនោះ យើងទាំងអស់គ្នា ៣ នាក់ជាបងប្អូន ជាអាមាត្យរបស់ស្តេចពារាណសី ជាទីទុកព្រះហឫទ័យនៃព្រះរាជា ។ ជាអ្នកមានព្យាយាមអង់អាច មានកម្លាំង ឈ្នះក្នុងសង្គ្រាម គ្រានោះ

ស្រុកបច្ចន្តគ្រាមកើតបះបោរ ម្ចាស់ផែនដីក៏ត្រាស់បង្គាប់យើង ប្រៀនប្រដៅយើងថា អ្នកទាំងឡាយ មកអាយ ចូរទៅកាន់បច្ចន្តគ្រាម បង្ក្រាបពលផែនដី ធ្វើដែនរបស់អញឲ្យបានក្សេមក្សាន្ត ហើយត្រឡប់មកវិញចុះ ។ លំដាប់នោះ ពួកយើងក្រាបទូលសូមពរថា បើព្រះអង្គប្រទាននូវព្រះពុទ្ធជានាយកដល់យើង ដើម្បីបានបម្រើ យើងទាំងឡាយនឹងបង្ក្រាបសត្រូវទាំងនោះ ក្នុងបច្ចន្តគ្រាមនោះ ឲ្យខាងតែបាន ។ គ្រានោះ ពួកយើងបានទទួលហើយ ទើបស្តេចបញ្ជូនទៅដើម្បីរក្សាស្រុក ពួកយើងក៏ធ្វើបច្ចន្តគ្រាមឲ្យមានគ្រឿងសស្ត្រាដាក់ចុះ រួចហើយ ត្រឡប់មកកាន់ក្រុងពារាណសីនោះវិញ ។ បានសូមការបម្រើព្រះសាស្តា ជាលោកនាយកនឹងព្រះរាជា លុះបានព្រះមុនីដ៏ប្រសើរមកហើយ ទើបនាំគ្នាបូជាព្រះអង្គនោះ ដរាបដល់អស់ជីវិត ។ ពួកយើងជាអ្នកមានសីល មានសេចក្តីករុណា មានចិត្តប្រកបដោយភាវនា បានប្រគេននូវសំពត់មានតម្លៃផង នូវភោជនមានរសដ៏ថ្លៃថ្លាផង នូវសេនាសនៈជាទីត្រេកអរផង នូវភេសជ្ជៈជាប្រយោជន៍ផង ដែលកើតឡើងដោយធម៌ដល់ព្រះមុនី ព្រមទាំងព្រះសង្ឃ ហើយបម្រើព្រះនាយកដោយមេត្រីចិត្តសព្វកាល ។ កាលដែលព្រះអង្គ ជាកំពូលនៃលោក ទ្រង់បរិនិព្វានទៅ ពួកយើងក៏នាំគ្នាធ្វើការបូជាសមគួរតាមកម្លាំងធនធាន ។ ពួកយើងទាំងអស់គ្នា ច្យុតអំពី

មនុស្សលោកនោះ បានទៅកើតក្នុងឋានតាវត្តិង្ស សោយមហាសុខក្នុងឋានតាវត្តិង្សនោះ នេះជាផលនៃពុទ្ធបូជា ។ ជាងក្រងផ្កា បាននូវផ្កា រមែងសម្តែងនូវការធ្វើរំលេចផ្សេងៗ ច្រើនយ៉ាង យ៉ាងណាមិញ ចំណែកខាងខ្ញុំ កាលកើតក្នុងភពបានជាធំក្នុងដែនវិទេហៈ ក៏យ៉ាងនោះដែរ ។ ខ្ញុំមានអាសយធម៌ ត្រូវមិច្ឆាទិដ្ឋិកម្ចាត់បង់ ( ព្រោះជឿ ) តាមពាក្យអចេល ឈ្មោះគុណៈ ក៏ឡើងកាន់ផ្លូវនរក មិនបានកាន់យកឱវាទរបស់នាងរុចាជាធីតានៃខ្ញុំ ។ លុះបាននារទព្រហ្មមកប្រៀនប្រដៅដោយវិធីច្រើនយ៉ាង ក៏បានស្ងប់រម្ងាប់ហើយលះបង់ទិដ្ឋិអាក្រក់ចោលចេញ ។ ខ្ញុំបានបំពេញកម្មបថទាំង ១០ ដោយវិសេស លុះលះបង់រាងកាយរបស់មនុស្សហើយ ក៏បានទៅកើតក្នុងឋានសួគ៌ ដូចជានៅក្នុងលំនៅរបស់ខ្លួន ។ លុះដល់បច្ឆិមភព ខ្ញុំជាអ្នកមានផៅពង្សដ៏ប្រសើរ គឺកើតក្នុងត្រកូលព្រាហ្មណ៍ក្នុងក្រុងពារាណសី ជាក្រុងធំទូលាយ ។ ខ្ញុំត្រូវមច្ចុ ព្យាធិនិងជរាមកគ្របសង្កត់ហើយ បានចូលទៅក្នុងព្រៃមហាវ័ន ស្វែងរកផ្លូវព្រះនិព្វាន ហើយក៏ចូលបួសក្នុងពួកជដិល ។ គ្រានោះ ប្អូនរបស់ខ្ញុំទាំង ២ នាក់ ក៏បួសជាមួយនឹងខ្ញុំដែរ ខ្ញុំបានកសាងអាស្រមនៅក្នុងឧរុវេលប្រទេស ។ ខ្ញុំឈ្មោះកស្សបៈតាមគោត្ត នៅក្នុងឧរុវេលប្រទេស ព្រោះនៅក្នុងឧរុវេលប្រទេសនោះ បានជានាមបញ្ញត្តិរបស់ខ្ញុំថា ឧរុវេលកស្សបៈ ។ ប្អូនរបស់ខ្ញុំម្នាក់នៅក្បែរ

ស៊ីង មានទាមថានទីកស្សបៈ ( ប្អូនម្នាក់ទៀត ) នៅក្នុងប្រទេស គយា ក៏មាននាមប្រាកដថាគយាកស្សបៈ ។ ប្អូនពៅមានសិស្ស ២០០ ប្អូនកណ្តាលមានសិស្ស ៣០០ ខ្ញុំឯងមានសិស្ស ៥០០ ឥតខ្វះ សិស្សទាំងអស់នោះប្រព្រឹត្តតាមខ្ញុំ ។ គ្រានោះ ព្រះពុទ្ធ ជាកំពូលនៃលោក ជានរសារថីទ្រង់ចូលទៅរកខ្ញុំ បានធ្វើបាដិហារ្យ ផ្សេងៗ ទូន្មានខ្ញុំ ។ ខ្ញុំបានបួសជាឯហិភិក្ខុ ព្រមដោយបរិវារមួយ ពាន់ ហើយបានសម្រេចអរហត្ត មួយអន្លើដោយជនទាំងនោះគ្រប់ គ្នា ។ មិនមែនត្រឹមតែពួកជនទាំងនោះទេ មានទាំងពួកជនដទៃជា ច្រើនចោមរោមខ្ញុំដោយយស ខ្ញុំក៏អាចប្រៀនប្រដៅ ( ជនទាំង នោះ ) បាន លំដាប់ពីនោះមក ព្រះពុទ្ធជាឥសីទី ៧ ទ្រង់តាំងខ្ញុំ ក្នុងទីជាឯតទគ្គៈ ខាងឯមានបរិស័ទច្រើន ។ ឱហ្ន៎ ! ការបូជាដែល ខ្ញុំបានធ្វើចំពោះព្រះពុទ្ធ កើតផលដល់ខ្ញុំវិញ ។ កិលេសទាំង- ឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ ។

កាលសម្រេចអរហត្តហើយ ទើបពិចារណាកិច្ចបដិបត្តិរបស់ខ្លួន កាល នឹងបន្លឺសីហនាទ ទើបពោល ៦ គាថាថា

ខ្ញុំឃើញបាដិហារ្យរបស់ព្រះគោតម ព្រះអង្គមានយសដល់ម៉្លោះ ក៏នៅតែមិនក្រាបសំពះ ព្រោះតែសេចក្តីប្រណែន និងសេចក្តី ប្រកាន់ ឲ្យកាន់ប្រឡំ ។ ព្រះសាស្តាជាសារថីរបស់ជន ទ្រង់

ជ្រាបសេចក្តីត្រិះរិះរបស់ខ្ញុំហើយ បានជាស់តឿន លំដាប់នោះ ខ្ញុំមានសេចក្តីសង្វេគ និងសេចក្តីព្រឺរោម ដែលមិនធ្លាប់កើតៗហើយ ។ កាលខ្ញុំនៅជាជដិលក្នុងកាលមុន ការសម្រេចលាភសក្ការៈណាតិចតួច គ្រានោះ ខ្ញុំលះបង់នូវការសម្រេច គឺលាភសក្ការៈនោះហើយ មកបួសក្នុងសាសនាព្រះជិនស្រី ។ កាលពីដើម ខ្ញុំជាអ្នកត្រេកអរ ដោយការបូជា ធ្វើកាមធាតុជាប្រធាន កាលខាងក្រោយមក ខ្ញុំបានដករាគៈ ទោសៈ និងមោហៈចោលហើយ ។ ខ្ញុំដឹងខន្ធដែលធ្លាប់អាស្រ័យនៅក្នុងកាលពីដើម បានជម្រះទិព្វចក្ខុឲ្យស្អាត ជាអ្នកមានឫទ្ធិ ដឹងចិត្តអ្នកដទៃ ទាំងបានសម្រេចទិព្វសោត ។ មួយទៀត កុលបុត្តចេញចាកផ្ទះ មកបួសក្នុងធម្មវិន័យ ដើម្បីប្រយោជន៍ណា ប្រយោជន៍នោះ ខ្ញុំបានដល់ហើយតាមលំដាប់ ទាំងធ្វើឲ្យអស់សំយោជនធម៌ទាំងពួង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ទិស្វាន បាដិហីរានិ** សេចក្តីថា បានឃើញបាដិហារ្យ ៣៥០០ មានការទូន្មានស្តេចនាគជាដើម ។ ពិតហើយ បទថា **បាដិហីរំ ១ បាដិហេរំ ១ បាដិហារិយំ ១** ដោយអត្ថដូចគ្នាតែមួយ ផ្សេងតែព្យញ្ជនៈប៉ុណ្ណោះ ។

បទថា **យសស្សិនោ** បានដល់ មានកិត្តិសព្ទផ្សាយទៅក្នុងលោក ព្រមទាំងទេវលោក តាមសេចក្តីពិតដោយន័យជាដើមថា **ឥតិបិ សោ ភគវា** ដូច្នេះ ។

បទថា **ឆ តាវាហំ បណិបតឹ** សេចក្តីថា ព្រះមានព្រះភាគ ទ្រង់មិនទាន់បានជ្រាបខ្ញុំក្រាបបណាថា ម្នាលកស្សបៈ អ្នកមិនមែនជាព្រះអរហន្ត ទាំងមិនទាន់សម្រេចអរហត្តមគ្គ អ្នកក៏មិនមានបដិបទា ជាព្រះអរហន្ត ឬគ្រឿងសម្រេចអរហត្តមគ្គ ដូច្នេះ ខ្ញុំក៏មិនធ្វើការនមស្ការដេកាបនោះ ព្រោះហេតុអ្វី ព្រោះខ្ញុំបោកបញ្ឆោតដោយសេចក្តីប្រណែន និងមានះ អធិប្បាយថា ជាអ្នកបោកបញ្ឆោត គឺបោកបញ្ឆោតដោយសេចក្តីប្រណែន ដែលមានលក្ខណៈមិនអត់ធន់ចំពោះសម្បត្តិរបស់អ្នកដទៃ យ៉ាងនេះថា កាលអញចូលជាសាវ័ករបស់បុរសនេះ អញនឹងសាបសូន្យលាភសក្ការៈ លាភសក្ការៈនឹងចម្រើនដល់បុរសនេះ និងដោយមានះ មានលក្ខណៈលើកខ្លួនយ៉ាងនេះថា អាត្មាអញជាបុគ្គលដែលជនជាច្រើន សន្មតឲ្យធ្វើជាមេគណៈ ។

បទថា **មម សង្កប្បមញ្ញាយ** សេចក្តីថា ទ្រង់ជ្រាបនូវការត្រិះរិះខុសរបស់ខ្ញុំ អធិប្បាយថា ទ្រង់ជ្រាបនូវការត្រិះរិះខុសដែលខ្ញុំបានឃើញបាដិហារ្យដែលព្រះមានព្រះភាគទ្រង់សម្តែងដោយឧត្តរិមនុស្សធម៌ សូម្បីគិតថា មហាសមណៈមានឫទ្ធិច្រើន មានអានុភាពច្រើន ក៏គង់មានមិច្ឆាវិតក្កប្រព្រឹត្តទៅយ៉ាងនេះថា មិនទាន់ជាព្រះអរហន្តដូចអញ ព្រះសាស្តាទ្រង់រង់ចាំកាលចាស់ក្លានៃញាណ ទើបទ្រង់ព្រងើយ ក្រោយមក ទ្រង់ធ្វើទឹកឲ្យស្ងួតដោយជុំវិញត្រង់កណ្តាលស្ទឹងនេរញ្ជរា ទ្រង់ចង្ក្រមត្រង់ផែនដី ដែលហុយដោយធូលី ហើយទ្រង់ឈរក្នុងទូក ដែលជដិលនោះនាំមក ក្នុងកាលនោះ ទ្រង់ក៏ដឹងការត្រិះរិះខុសដែលខ្ញុំគិតថា មហាសមណៈមានឫទ្ធិច្រើនដូច្នេះជាដើម និងគិត

បន្តទៀតថា បុគ្គលអ្នកមានឫទ្ធិដូច្នេះ ក៏មិនមែនជាព្រះអរហន្តដូចអញ ។

បទថា **ចោទេសិ នរសារថិ** សេចក្តីថា ក្នុងកាលនោះ ព្រះសាស្តាជាសារថី ទូន្មានបុរស ទ្រង់ជ្រាបការចាស់ក្លានៃញាណរបស់ខ្ញុំហើយ ទើបទ្រង់ប្រាស្រ័យ គឺសង្កត់សង្កិនខ្ញុំ ដោយន័យជាដើមថា អ្នកមិនមែនជាព្រះអរហន្តឡើយ ដូច្នេះ ។

បទថា **តតោ មេ អាសិ សំវេគោ អព្ភុតោ លោមហំសនោ** សេចក្តីថា បន្ទាប់អំពីនោះ គឺព្រោះការទាក់ទងតាមដែលពោលហើយ ជាហេតុ ខ្ញុំកើតការសង្វេគ គឺកើតនូវញាណ ព្រមទាំងការក្រែងខ្លាចបាប ដែលមិនធ្លាប់កើត ព្រោះមិនធ្លាប់មានមកអស់កាលមានប្រមាណប៉ុណ្ណេះ ឈ្មោះថា ព្រឺរោម ព្រឺស្បែក ព្រោះប្រព្រឹត្តទៅដោយអំណាចព្រឺរោម ព្រឺស្បែក ក៏មានដល់ខ្ញុំថា អញមិនមែនជាព្រះអរហន្តឡើយ សម្គាល់ថា ជាព្រះអរហន្ត ។

បទថា **ជដិលភូតស្ស** បានដល់ ជាតាបស ។ បទថា **សិទ្ធិ** បានដល់ មាំទាំដោយលាភសក្ការៈ ។ បទថា **បរិត្តិកា** បានដល់ មានប្រមាណតិច ។ បទថា **តាហំ** កាត់ជា **តំ អហំ** ។ បទថា **តទា** បានដល់ ក្នុងកាលកើតសេចក្តីសង្វេគ ដោយការប្រាស្រ័យរបស់ព្រះមានព្រះភាគ ។

បទថា **និរាកត្វា** បានដល់ នាំចេញទៅ គឺចោលទៅ អធិប្បាយថា ជាអ្នកមិនជាប់ជំពាក់ ។

អាចារ្យខ្លះពោលថា បទថា **ឥទ្ធិ** បានដល់ ឫទ្ធិដែលសម្រេចដោយការចម្រើនភាវនា ។ ពាក្យនោះ មិនត្រឹមត្រូវ ព្រោះក្នុងពេលនោះ ឧរុវេល-

កស្សបៈមិនទាន់បានឈាន ។ ពិតហើយ សមដូចព្រះឧរុវេលកស្សបៈពោលថា កាមធាតុជាប្រធាន ។

បទថា **យញ្ញេន សន្តុដ្ឋោ** សេចក្តីថា ត្រេកអរ គឺសម្គាល់កិច្ចដែលសម្រេចហើយ ដោយការបូជាយញ្ញ ដោយយល់ថា អញបូជាយញ្ញហើយ នឹងបានសោយសុខក្នុងស្ថានសួគ៌ បានធ្វើការលះបង់ដោយការបូជាយញ្ញ មានប្រមាណប៉ុណ្ណេះ ។

បទថា **កាមធាតុបុរក្ខតោ** សេចក្តីថា ជាអ្នកមានការចង់បានដែលប្រារព្ធកាមសុគតិកើតឡើង គឺប្រាថ្នានូវកាមលោក នៅដោយការបូជាយញ្ញ ។ បើយញ្ញនោះប្រកបព្រមដោយបាណាតិបាត បុគ្គលណាម្នាក់ មិនអាចបាននូវសុគតិដោយយញ្ញនោះ ព្រោះអកុសលមិនកើតផលដែលគួរប្រាថ្នា គួរត្រេកអរ តែកាលកុសលចេតនា មានទានជាដើម មាននៅក្នុងយញ្ញនោះ បុគ្គលគប្បីទៅកាន់សុគតិបាន ព្រោះបច្ច័យប្រជុំគ្នា ។

បទថា **បច្ឆា** បានដល់ ក្នុងកាលខាងក្រោយអំពីការបួសជាតាបស គឺក្នុងកាលដែលលះលទ្ធិតាបសហើយ ប្រកបកម្មដ្ឋានដែលសម្បយុត្តដោយសច្ចៈ ៤ តាមឱវាទរបស់ព្រះសាស្តា ។

បទថា **សមូហនឹ** សេចក្តីថា ខ្ញុំបំពេញវិបស្សនា ហើយដកបានដោយឥតសេសសល់នូវរាគៈ ទោសៈ មោហៈ ដោយលំដាប់នៃមគ្គ ។

ព្រោះហេតុដែលព្រះថេរៈនេះ ដកនូវរាគៈជាដើមបានដោយអរិយមគ្គនោះ ជាអ្នកមានអភិញ្ញា ៦ ដូច្នោះ កាលសម្តែងថា ខ្ញុំមានអភិញ្ញា ៦ ទើប

ពោលពាក្យថា **បុព្វេនិវាសំ ជានាមិ** ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **បុព្វេនិវាសំ ជានាមិ** សេចក្ដីថា ខ្ញុំដឹង គឺត្រាស់ដឹងដោយប្រចក្សនូវខន្ធបញ្ចកៈ ដែលធ្លាប់នៅអាស្រ័យក្នុងកាលមុនរបស់ខ្លួន និងរបស់អ្នកដទៃ គឺខន្ធដែលកើតឡើងហើយ និងសភាវៈដែលទាក់ទងដោយខន្ធក្នុងអតីតជាតិទាំងឡាយ ដោយបុព្វេនិវាសញ្ញាណ ដូចឃើញផ្លែកន្ទួតព្រៃលើបាតដៃ ។

បទថា **ទិព្វចក្ខុ វិសោធិតំ** សេចក្ដីថា ខ្ញុំជម្រះទិព្វចក្ខុញ្ញាណឲ្យបរិសុទ្ធ គឺខ្ញុំបានញាណដែលអាចធ្វើរូបជារបស់ទិព្វផង ជារបស់មនុស្សផង ដែលនៅឆ្ងាយ នៅក្រោជញ្ជាំង និងដែលល្អិតក្រៃលែងឲ្យជាក់ច្បាស់ ដូចរូបប្រក្រតីដែលឃើញដោយភ្នែកតាមប្រក្រតី ដោយធ្វើឲ្យបរិសុទ្ធ ដោយការចម្រើនភាវនា ។

បទថា **ឥទ្ធិមា** បានដល់ ជាអ្នកមានឫទ្ធិដោយឫទ្ធិទាំងឡាយ មានអធិដ្ឋានឫទ្ធិ និងវិកុព្វនឫទ្ធិ គឺការសម្ដែងឫទ្ធិជាដើម អធិប្បាយថា ជាអ្នកបាននូវញាណដែលសម្ដែងឫទ្ធិបានផ្សេងៗ ឈ្មោះថា ជាអ្នកដឹងចិត្តរបស់អ្នកដទៃ ព្រោះដឹងចិត្តរបស់អ្នកដទៃ មានចិត្តប្រកបដោយរាគៈជាដើម លោកអធិប្បាយ

ថា ជាអ្នកបានទូវចេតោបរិយញ្ញាណ គឺញាណដែលកំណត់ដឹងចិត្តរបស់អ្នកដទៃ ។

បទថា **ទិព្វសោតញ្ច ធាតុំ** សេចក្តីថា បានទិព្វសោតញ្ញាណផង ។ បទថា **សោ មេ អត្ថោ អនុប្បត្តោ សព្វសំយោជនក្ខយោ** សេចក្តីថា ប្រយោជន៍ដែលជាធម្មជាតអស់ទៅនៃសំយោជនៈទាំងពួង ឬគប្បីបានព្រោះការអស់ ( សំយោជនៈ ) គឺទាំងប្រយោជន៍ខ្លួន និងប្រយោជន៍របស់អ្នកដទៃ ខ្ញុំបានសម្រេចហើយ ដោយការសម្រេចអរិយមគ្គ ។ គប្បីជ្រាបថា ព្រះថេរៈព្យាករព្រះអរហត្តដោយគាថានេះ ដោយប្រការដូច្នេះ ។៚

**អដ្ឋកថា ឧរុវេលកស្សបត្ថេរគាថា ចប់**

# សុត្តន្តបិដក

## តេកិច្ឆកានិត្ថេរគាថា

[ ២១២ ] ( មារនិយាយថា ) ស្រូវគេនាំទៅទុកដាក់ហើយ ស្រូវគេគរទុកក្នុងលានហើយ ខ្ញុំនៅតែមិនបានដុំបាយ តើខ្ញុំនឹងធ្វើដូចម្តេច ។

( ព្រះថេរៈនិយាយថា ) អ្នកចូរជ្រះថ្លារឭកចំពោះព្រះពុទ្ធ មានគុណមិនមានប្រមាណ អ្នកនឹងជាបុគ្គលមានសរីរៈដែលបីតិពាល់ត្រូវ មានចិត្តរីករាយរឿយៗ មិនខាន ។ ចំពោះធម៌មានគុណមិនមានប្រមាណ ។បេ។ ចំពោះសង្ឃមានគុណមិនមានប្រមាណ ។បេ។

( មារនិយាយថា ) លោកនៅក្នុងទីវាលល្ហល្ហេវផង រាត្រីនេះ ត្រជាក់មានសន្សើមធ្លាក់ចុះផង ។ លោកកុំបណ្តោយឲ្យត្រជាក់គ្របសង្កត់ឲ្យលំបាកឡើយ ចូរលោកចូលទៅក្នុងកុដិដែលមានទ្វារខ្ទាស់គន្លឹះជាប់មាំ ។

( ព្រះថេរៈតបថា ) អាត្មាពាល់ត្រូវអប្បមញ្ញាទាំង ៤ ដល់នូវសេចក្តីសុខ ដោយសារអប្បមញ្ញាទាំងនោះ មិនញាប់ញ័រ មិនលំបាក ដោយត្រជាក់ទេ ។

តេកិច្ឆកានិត្ថេរ

# អដ្ឋកថា

## តេកិច្ឆការិត្ថេរគាថា

[ ២១២ ] គាថារបស់ព្រះតេកិច្ឆកានិត្ថេរ មានពាក្យផ្ដើមថា **អតិហិតា វីហិ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកមកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ។ ក្នុងកប្បទី ៩១ រាប់ថយក្រោយអំពីភទ្ទកប្បនេះ ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមវិបស្សី កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្ដីហើយ បានសម្រេចវេជ្ជសាស្ត្រ បានធ្វើព្រះថេរៈឈ្មោះអសោក ដែលជាអ្នកឧបដ្ឋាករបស់ព្រះមានព្រះភាគវិបស្សី ដែលអាពាធឲ្យជាសះស្បើយ និងបានចម្អិនថ្នាំដល់សត្វដទៃ ដែលត្រូវរោគាបៀតបៀន ដោយសេចក្ដីអនុគ្រោះ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតជាបុត្តរបស់ព្រាហ្មណ៍ ឈ្មោះសុពុទ្ធៈ ។ ញាតិទាំងឡាយដាក់ឈ្មោះថា **តេកិច្ឆកានិ** ព្រោះពេលដែលកុលបុត្តនោះនៅក្នុងគភ៌ ពួកគ្រូពេទ្យបាននាំគ្នាថែរក្សា ឲ្យប្រាសចាកនូវអន្តរាយ ។

កុលបុត្តនោះសិក្សាវិជ្ជា និងសិប្បៈដែលសមគួរដល់ត្រកូលរបស់ខ្លួនទើបចម្រើន ។

ក្នុងកាលនោះ ព្រាហ្មណ៍ចាណក្កៈបានឃើញនូវការមុតស្រួចនៃបញ្ញា និងការឈ្លាសវៃក្នុងឧបាយ ក្នុងកិច្ចផ្សេងៗ របស់សុពុទ្ធព្រាហ្មណ៍ ត្រូវ

សេចក្តីប្រណែនគ្របសង្កត់ថា សុពុទ្ធៈនេះ បានទូវតំណែងក្នុងរាជត្រកូលនេះ គប្បីសង្កត់សង្កិនអញ ទើបឲ្យព្រះបាទចន្ទគុត្តចាប់ដាក់គុក ។

តេកិច្ឆកានិបានដំណឹងថា ឪពុកត្រូវគេឃុំឃាំងក្នុងគុក ក៏ភ័យខ្លាច ទើបគេចទៅកាន់សម្នាក់របស់ព្រះសាណវាសិត្ថេរ ពោលទូវហេតុការណ៍ ដែលគួរសង្វេគរបស់ខ្លួនដល់ព្រះថេរៈ ហើយបួស រៀនទូវកម្មដ្ឋាន ជាអ្នកសមាទានការនៅកណ្តាលវាលជាវត្ត និងសមាទានការអង្គុយជាវត្ត មិនខ្លាចចំពោះរងា និងក្តៅ ធ្វើតែសមណធម៌ប៉ុណ្ណោះ ដោយពិសេស ប្រកបព្យាយាមក្នុងវិហារគាវនា ។

មារមានចិត្តបាបឃើញដូច្នោះ គិតថា អញនឹងមិនឲ្យសមណៈនេះកន្លងផុតវិស័យរបស់អញទៅបាន បំណងនឹងធ្វើឲ្យរាយមាយ ក្នុងកាលអ្នកស្រែស្ទូងស្រេច ទើបកាឡាខ្លួនជាអ្នកចាំស្រែ ចូលទៅរកព្រះថេរៈ ដើម្បីនឹងចំអកទើបពោលថា

ស្រូវគេនាំទៅទុកដាក់ហើយ ស្រូវគេគរទុកក្នុងលានហើយ ខ្ញុំ
នៅតែមិនបានដុំបាយ តើខ្ញុំនឹងធ្វើដូចម្តេច ដូច្នេះ ។

ព្រះថេរៈបានស្តាប់ដូច្នោះទើបពោលថា

ចូរអ្នកជ្រះថ្លារឭកចំពោះព្រះពុទ្ធ មានគុណមិនមានប្រមាណ អ្នក
នឹងជាបុគ្គលមានសរីរៈដែលបីតិពាល់ត្រូវ មានចិត្តរីករាយរឿយៗ
មិនខាន ។ ចំពោះធម៌មានគុណមិនមានប្រមាណ ។បេ។ ចំពោះ
សង្ឃមានគុណមិនមានប្រមាណ ។បេ។ ដូច្នេះ ។

មារបានស្តាប់ដូច្នោះ ទើបពោលថា

លោកនៅក្នុងទីវាលល្ហល្ហេវផង រាត្រីនេះ ត្រជាក់ មានសន្សើម ធ្លាក់ចុះផង ។ លោកកុំបណ្តោយឲ្យត្រជាក់គ្របសង្កត់ឲ្យលំបាកឡើយ ចូរលោកចូលទៅក្នុងកុដិដែលមានទ្វារខ្ទាស់គន្លឹះ ជាប់មាំ ដូច្នេះ ។

លំដាប់នោះ ព្រះថេរៈក៏ពោលថា

អាត្មាពាល់ត្រូវអប្បមញ្ញាទាំង ៤ ដល់នូវសេចក្តីសុខ ដោយសារអប្បមញ្ញាទាំងនោះ មិនញាប់ញ័រ មិនលំបាក ដោយត្រជាក់ទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អតិហិតា វីហិ** សេចក្តីថា ស្រូវខ្សាយដែលគេនាំទៅដាក់ក្នុងជង្រុក អធិប្បាយថា រក្សាក្នុងជង្រុកនោះ ឬនាំចេញអំពីលានមកកាន់ផ្ទះ ។ ក្នុងទីនេះ **វីហិ** សព្ទ លោកសង្គ្រោះយកធញ្ញាហារដទៃផងដែរ ។ ឯស្រូវសាលីដោយច្រើន ទុំក្រោយស្រូវខ្សាយ ដោយហេតុនោះ ទើបមារពោលថា ស្រូវសាលីគេគរក្នុងលានហើយ អធិប្បាយថា ទៅកាន់លាន គឺទីដែលបោកបែនស្រូវ បានដល់ នៅត្រង់លាននោះ ដោយគរជាគំនរដោយការបែន និងការបោកជាដើម ។ ក្នុងទីនេះ ដើម្បីសម្តែងស្រូវខ្សាយជាប្រធាន ទើបកាន់យកស្រូវសាលីដោយឡែក ។ ដោយស្រូវទាំង ២ នោះ មារសម្តែងថា ធញ្ញជាតិ ក៏តាំងនៅពេញទាំងក្នុងស្រុក និងក្រៅស្រុក ។

បទថា **ឆ ច លភេ បិណ្ឌំ** សេចក្តីថា មារបានធ្វើនូវការចំអកថា ក្នុង

កាលធញ្ញាហារកេបានងាយយ៉ាងនេះ គឺក្នុងកាលមានកិច្ចារកេបានងាយ សូម្បីត្រឹមតែដុំបាយ ខ្ញុំក៏មិនបាន ឥឡូវនេះ ខ្ញុំនឹងធ្វើដូចម្តេច អធិប្បាយថា ខ្ញុំនឹងធ្វើដូចម្តេច គឺនឹងញុំាងជីវិតឲ្យប្រព្រឹត្តទៅបានដូចម្តេច ។

ព្រះថេរៈបានស្តាប់ដូច្នោះ ទើបគិតថា បុគ្គលគួរអាណិតនេះ ប្រកាសប្រវត្តិរបស់ខ្លួនដល់អញ ឯអញគួរទូន្មានខ្លួនដោយខ្លួនឯង មិនគួរពោលពាក្យណាមួយ កាលនឹងបង្រៀនខ្លួន ចូលទៅរឭកដល់វត្ថុទាំង ៣ គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ទើបបានពោល ៣ គាថា ដោយន័យជាដើមថា **ពុទ្ធមប្ប-មេយ្យំ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **ពុទ្ធមប្បមេយ្យំ អនុស្សរ បសន្នោ** សេចក្តីថា ព្រះមានព្រះភាគ ឈ្មោះថា **ពុទ្ធ** ព្រោះទៅប្រាសចាកជាសមុច្ឆេទអំពីការដេកលក់ គឺអវិជ្ជា ព្រមទាំងវាសនា និងព្រោះទ្រង់រីកហើយ ដោយវិជ្ជា ឈ្មោះថា **ពុទ្ធមប្បមេយ្យំ** ព្រោះមិនមានកិលេស មានរាគៈជាដើម ដែលជាគ្រឿងធ្វើនូវប្រមាណ ព្រោះជាអ្នកដល់ព្រមដោយព្រះគុណប្រមាណមិនបាន និងព្រោះជាស្រែបុណ្យដែលប្រមាណមិនបាន ។ ឈ្មោះថា **បសន្នោ** គឺមានចិត្តជ្រះថ្លា ដោយការជ្រះថ្លាក្រៃលែង ដែលមានការជឿជាលក្ខណៈ ចូររឭក គឺចូរញុំាងសតិដែលមានព្រះពុទ្ធជាអារម្មណ៍ ឲ្យប្រព្រឹត្តទៅរឿយៗ ដោយន័យថា **ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ** ដូច្នេះជាដើម អ្នកនឹងជាអ្នកមានសរីរៈដែលបីតិពាល់ត្រូវហើយ ។

បទថា **សតតមុទគ្គោ** សេចក្តីថា អ្នកកាលរឭកដល់នោះឯង ជាអ្នក

មានសរីរៈដែលបីតិ ដែលមានលក្ខណៈជ្រួតជ្រាបពាល់ត្រូវហើយរឿយៗ គឺ សព្វៗ កាល គឺជាអ្នកមានសរីរៈត្រូវគ្របសង្កត់ដោយរូបដ៏ប្រណីត ដែលមានបីតិជាសមុដ្ឋាន គប្បីមានចិត្តត្រេកអរ ដោយឧព្វេង្គាបីតិ និងអាចធ្វើកាយឲ្យអណ្តែតឡើងកាន់អាកាសបាន គប្បីសោយបីតិ និងសោមនស្សដ៏ក្រៃលែង មានព្រះពុទ្ធជាអារម្មណ៍ ដោយពុទ្ធានុស្សតិ ដែលជាហេតុមិនឲ្យសូម្បីតែការឃ្លាន និងការស្រេកគ្របសង្កត់បាន រងា និងក្តៅ ក៏គ្របសង្កត់មិនបានដូចគ្នា ។

បទថា **ធម្មំ** បានដល់ លោកុត្តរធម៌ដ៏ប្រសើរ ។ បទថា **សង្ឃំ** បានដល់ ព្រះសង្ឃដែលសម្រេចប្រយោជន៍ក្រៃលែង ដែលជាអរិយសង្ឃ ។ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ។

ក្នុងបទថា **អនុស្សរ** នេះ គប្បីប្រកបសេចក្តីថា ចូររឭកដល់ព្រះធម៌ ដោយន័យថា **ស្វាក្ខាតោ ភគវតា ធម្មោ** ដូច្នេះជាដើម និងរឭកដល់ព្រះសង្ឃ ដោយន័យថា **សុបដិបន្នោ ភគវតោ សាវកសង្ឃោ** ដូច្នេះជាដើម ។

កាលព្រះថេរៈទូន្មានខ្លួន ដោយការបង្អោនរឭកដល់គុណព្រះរតនត្រ័យយ៉ាងនេះហើយ មារបំណងនឹងឲ្យព្រះថេរៈនោះ ចេញចាកអំពីវិវេក កាលនឹងសម្តែងខ្លួន ហាក់បីដូចជាបុគ្គលមានបំណងល្អ ទើបពោលគាថាទី ៥ ថា **អព្ភោកាសេ វិហរសិ** ដូច្នេះ ។

គាថានោះ មានសេចក្តីថា ភិក្ខុចូលនៅ គឺសម្រេចឥរិយាបថត្រង់ទួល

កណ្ដាលវាល ដែលមិនមានអ្វីមួយបិទបាំង ។

រាត្រីរងានេះ ទាក់ទងក្នុងសម័យសន្សើមធ្លាក់ កំពុងប្រព្រឹត្តទៅ ឈ្មោះថា រាត្រីត្រជាក់ ។ ព្រោះដូច្នោះ លោកកុំត្រូវសេចក្ដីរងាគ្របសង្កត់លំបាកឡើយ គឺកុំជាអ្នកចង្អៀតចង្អល់ កុំលំបាក សូមលោកចូលទៅកាន់សេនាសនៈដែលមានសន្ទះទ្វារ និងសន្ទះបង្អួចជិតល្អ គឺមានសន្ទះទ្វារ សន្ទះបង្អួចបិទហើយ នឹងនៅជាសុខ ដោយប្រការដូច្នេះ ។

ព្រះថេរៈបានស្ដាប់ដូច្នោះ កាលនឹងសម្ដែងថា ខ្ញុំមិនមានប្រយោជន៍ក្នុងការស្វែងរកសេនាសនៈ ក្នុងទីនេះ ខ្ញុំក៏នៅជាសុខ ទើបពោលគាថាទី ៦ ដោយន័យជាដើមថា **ផុសិស្សំ ចតស្សោ អប្បមញ្ញាយោ** ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **ផុសិស្សំ ចតស្សោ អប្បមញ្ញាយោ** សេចក្ដីថា ខ្ញុំនឹងចម្រើន នឹងបំពេញនូវព្រហ្មវិហារ ៤ ដែលបានឈ្មោះថាអប្បមញ្ញា ព្រោះមានអារម្មណ៍ប្រមាណមិនបាន គឺមិនចូលសមាបត្តិតាម កាលដែលសមគួរ ។

បទថា **តាហិ ច សុខិតោ វិហារិស្សំ** សេចក្ដីថា ខ្ញុំនឹងជាអ្នកមាននូវសេចក្ដីសុខ គឺកើតនូវសុខ បានដល់ សម្រេចឥរិយាបថទាំង ៤ ដោយអប្បមញ្ញាទាំងនោះ ដោយហេតុនោះ ទើបខ្ញុំមានសេចក្ដីសុខតែម្យ៉ាងសព្វកាល សេចក្ដីទុក្ខមិនមាន ។

ព្រោះខ្ញុំនឹងមិនលំបាកដោយសេចក្ដីរងា គឺខ្ញុំនឹងមិនលំបាក ដោយការរងា ក្នុង ៨ ថ្ងៃ ខាងចុងរដូវសន្សើមធ្លាក់ ខ្ញុំមិនញាប់ញ័រ គឺនឹងជាអ្នកមាន

សេចក្តីសុខ ដោយសេចក្តីសុខដែលកើតពីសមាបត្តិនោះឯង ព្រោះលះបាន ជាសមុច្ឆេទនូវព្យាបាទជាដើម ដែលជាហេតុធ្វើចិត្តឲ្យញាប់ញ័រ និងព្រោះ មិនមានការញាប់ញ័រដែលកើតអំពីបច្ច័យ ។ ព្រះថេរៈ កាលពោលគាថានេះ យ៉ាងនេះហើយ បានចម្រើនវិបស្សនា ធ្វើឲ្យជាក់ច្បាស់នូវអរហត្ត សមដូច គាថាព័ន្ធដែលលោកពោលក្នុងអបទានថា

ខ្ញុំជាពេទ្យមានវិជ្ជសាស្ត្រសិក្សាល្អហើយ នៅក្នុងនគរពន្ធុមតី ជា អ្នកនាំមកនូវសេចក្តីសុខដល់មហាជន ពិសេសចំពោះពួកជនអ្នក មានជំងឺ មានទុក្ខខ្លាំង ។ ខ្ញុំឃើញសមណៈអ្នកមានសីល មាន សេចក្តីរុងរឿងច្រើន ដែលកំពុងឈឺថ្កាត់ ក្នុងកាលនោះ ក៏មាន ចិត្តជ្រះថ្លា មានចិត្តរីករាយ បានប្រគេនភេសជ្ជៈ ។ សមណៈ នោះ ឈ្មោះ អសោកៈ មានឥន្ទ្រិយសង្រួមល្អ ជាឧបដ្ឋាករបស់ ព្រះវិបស្សីសម្ពុទ្ធ ក៏សះជាពេគ ដោយភេសជ្ជៈនោះ ។ ក្នុងកប្ប ទី ៩១ អំពីកប្បនោះ ព្រោះហេតុដែលខ្ញុំបានប្រគេនឱសថ ខ្ញុំមិន ដែលស្គាល់ទុគ្គតិ នេះជាផលនៃភេសជ្ជៈ ។ ក្នុងកប្បទី ៨ អំពី កប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ព្រះនាមសព្វោសថៈ ទ្រង់

បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ដូច្នេះ[១] ។

ក្នុងទីនេះ គប្បីជ្រាបថា ព្រះសង្គីតិកាចារ្យបានចងក្រងគាថាទាំងនេះទុកក្នុងតតិយសង្គាយនា ព្រោះព្រះថេរៈនេះ កើតក្នុងរជ្ជកាលនៃព្រះបាទពិន្ទុសារ ។

**អដ្ឋកថា តេកិច្ឆការិត្ថេរគាថា ចប់**

១- ក្នុងអបទាន ជាតិកិច្ឆកត្ថេរ ។

# សុត្តន្តបិដក

## មហានាគត្ថេរគាថា

[ ២១៣ ] បុគ្គលដែលមិនមានសេចក្តីគោរព ក្នុងពួកសព្រហ្មចារី រមែងសាបសូន្យចាកព្រះសទ្ធម្ម ដូចត្រីក្នុងទីមានទឹកតិច ។ បុគ្គលដែលមិនមានសេចក្តីគោរព ក្នុងពួកសព្រហ្មចារី រមែងមិនលូតលាស់ក្នុងព្រះសទ្ធម្ម ដូចពូជស្អុយ ( ដែលមិនលូតលាស់ ) ក្នុងស្រែ ។ បុគ្គលដែលមិនមានសេចក្តីគោរព ក្នុងពួកសព្រហ្មចារី រមែងឆ្ងាយអំពីព្រះនិព្វាន ក្នុងសាសនានៃព្រះពុទ្ធ ជាស្តេចហេតុធម៌ ។ បុគ្គលដែលមានសេចក្តីគោរព ក្នុងពួកសព្រហ្មចារី រមែងមិនសាបសូន្យចាកព្រះសទ្ធម្ម ដូចត្រីនៅក្នុងទីមានទឹកច្រើន ។ បុគ្គលដែលមានសេចក្តីគោរព ក្នុងពួកសព្រហ្មចារី ទើបដុះដាលក្នុងព្រះសទ្ធម្ម ដូចពូជដ៏ល្អ ( លូតលាស់ ) ក្នុងស្រែ ។ បុគ្គលដែលមានសេចក្តីគោរព ក្នុងពួកសព្រហ្មចារី រមែងឋិតនៅក្នុងទីជិតព្រះនិព្វាន ក្នុងសាសនានៃព្រះពុទ្ធ ជាស្តេចហេតុធម៌ ។

មហានាគត្ថេរ

# អដ្ឋកថា

## មហានាគត្ថេរគាថា

[ ២១៣ ] គាថារបស់ព្រះមហានាគត្ថេរ មានពាក្យផ្ដើមថា **យស្ស សព្រហ្មចារីសុ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមកកុសន្ធៈ កើតក្នុងផ្ទះមានត្រកូល ជាអ្នកដឹងក្ដីហើយ ថ្ងៃមួយ បានឃើញព្រះមានព្រះភាគកកុសន្ធោ ទ្រង់ចូលកាន់ព្រៃ គង់ត្រង់គល់ឈើមួយដើម ដោយសេចក្ដីសុខក្នុងឈាន មានចិត្តជ្រះថ្លា បានថ្វាយផ្លែទទឹមដល់ព្រះមានព្រះភាគអង្គនោះ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតជាបុត្តរបស់ព្រាហ្មណ៍ឈ្មោះមធុវាសេដ្ឋៈ ក្នុងនគរសាកេត កុលបុត្តនោះមានឈ្មោះថា **មហានាគ** ដល់នូវភាពជាអ្នកដឹងក្ដីហើយ ។ កាលព្រះមានព្រះភាគគង់នៅក្នុងព្រៃអញ្ជនៈ ជិតនគរសាកេត បានឃើញបាដិហារ្យរបស់ព្រះគវម្បតិត្ថេរ ( ដែលព្រះថេរៈឃាត់នូវជំនន់ទឹកស្ទឹង ) បាននូវសទ្ធា បួសក្នុងសម្នាក់ព្រះថេរៈនោះឯង តាំងនៅក្នុងឱវាទរបស់ព្រះថេរៈ ក៏សម្រេចនូវអរហត្ត ។ សមដូចគាថាព័ន្ធដែលលោកពោលក្នុងអបទានថា

ព្រះសម្ពុទ្ធព្រះនាមកកុសន្ធៈ មានព្យាយាមធំ ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង ព្រះអង្គទ្រង់ចៀសចេញចាកពួក ហើយស្តេចទៅតាមចន្លោះព្រៃ ។ ខ្ញុំយកផ្លែសម៉ពិភេទក៍ដោតនឹងវល្លិ៍ សម័យនោះ ព្រះមានព្រះភាគទ្រង់ចម្រើនឈានត្រង់ចន្លោះភ្នំ ខ្ញុំបានឃើញព្រះមានព្រះភាគ ជាទេវតាក្រៃលែងជាងទេវតា ក៏មានចិត្តជ្រះថ្លា ហើយថ្វាយផ្លែសម៉ពិភេទក៍ដល់ព្រះអង្គ ជាអ្នកប្រាជ្ញ ជាទក្ខិ-ណេយ្យបុគ្គល ។ ក្នុងកប្បនេះឯង ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែសម៉ពិភេទក៍ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផ្លែសម៉ពិភេទក៍ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយដូច្នេះ[១] ។

កាលព្រះថេរៈសម្រេចអរហត្តហើយ នៅសម្ងំជាសុខ ដែលកើតអំពីវិមុត្តិ ឃើញឆព្វគ្គិយភិក្ខុមិនធ្វើសេចក្តីគោរពក្នុងសព្រហ្មចារីទាំងឡាយ ទើបពោល ៦ គាថា ទាក់ទងដោយការឲ្យឱវាទដល់ឆព្វគ្គិយភិក្ខុនោះថា

បុគ្គលដែលមិនមានសេចក្តីគោរព ក្នុងពួកសព្រហ្មចារី រមែងសាបសូន្យចាកព្រះសទ្ធម្ម ដូចត្រីក្នុងទីមានទឹកតិច ។ បុគ្គលដែលមិនមានសេចក្តីគោរព ក្នុងពួកសព្រហ្មចារី រមែងមិនលូតលាស់ក្នុងព្រះសទ្ធម្ម ដូចពូជស្អុយ ( ដែលមិនលូតលាស់ )

---

១- ក្នុងអបទានជា វិភេទកពីជិយត្ថេរ ។

ក្នុងស្រែ ។ បុគ្គលដែលមិនមានសេចក្តីគោរព ក្នុងពួកសព្រហ្ម-ចារី រមែងឆ្ងាយអំពីព្រះនិព្វាន ក្នុងសាសនានៃព្រះពុទ្ធ ជាស្តេចហេតុធម៌ ។ បុគ្គលដែលមានសេចក្តីគោរព ក្នុងពួកសព្រហ្មចារី រមែងមិនសាបសូន្យចាកព្រះសទ្ធម្ម ដូចត្រីនៅក្នុងទីមានទឹកច្រើន ។ បុគ្គលដែលមានសេចក្តីគោរព ក្នុងពួកសព្រហ្មចារី ទើបដុះដាលក្នុងព្រះសទ្ធម្ម ដូចពូជដ៏ល្អ ( លូតលាស់ ) ក្នុងស្រែ ។ បុគ្គលដែលមានសេចក្តីគោរព ក្នុងពួកសព្រហ្មចារី រមែងឋិតនៅក្នុងទីជិតព្រះនិព្វាន ក្នុងសាសនានៃព្រះពុទ្ធ ជាស្តេចហេតុធម៌ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សព្រហ្មចារីសុ** សេចក្តីថា ឈ្មោះថា **សព្រហ្មចារី** ព្រោះប្រព្រឹត្តធម៌ដ៏ប្រសើរ មានសីលជាដើមស្មើគ្នា គឺសហធម្មិកដែលដល់នូវការស្មើគ្នាដោយសីល និងទិដ្ឋិ ។ ក្នុងសព្រហ្មចារីនិងសហធម្មិកទាំងនោះ ។

បទថា **គារវោ** បានដល់ ភាពជាអ្នកមានសេចក្តីគោរព គឺធ្វើនូវការគោរពដែលមានគុណ មានសីលជាដើមជាហេតុ ។

បទថា **នូបលព្ភតិ** បានដល់ មិនមាន គឺមិនប្រព្រឹត្តទៅ អធិប្បាយថា មិនចូលទៅតាំងនៅ ។

បទថា **និព្វានា** បានដល់ ចាកការធ្វើកិលេសឲ្យរលត់ គឺចាកការអស់ទៅនៃកិលេស ។

បទថា **ធម្មរាជស្ស** បានដល់ ព្រះសាស្តា ។ ពិតហើយ ព្រះសាស្តា ឈ្មោះថាជា **ធម្មរាជា** ព្រោះញ៉ាំងលោក និងទេវលោកឲ្យត្រេកអរ គឺឲ្យពេញចិត្តដោយធម៌ ដែលជាលោកិយ និងលោកុត្តរតាមសមគួរ ។

បទថា **ធម្មរាជស្ស សាសនេ** នេះ ក្នុងគាថានោះ ឈ្មោះថា **ព្រះនិព្វាន** រមែងមានក្នុងសាសនារបស់ព្រះធម្មរាជាប៉ុណ្ណោះ មិនមានក្នុងសាសនាដទៃឡើយ ។

ក្នុងគាថានោះ លោកសម្តែងថា បុគ្គលណាវៀរចាកសេចក្តីគោរពក្នុងសព្រហ្មចារី បុគ្គលនោះជាអ្នកឆ្ងាយចាកសាសនារបស់ព្រះធម្មរាជា ដូចឆ្ងាយចាកព្រះនិព្វាន ដូច្នោះ ។

បទថា **ពហោទកេ** កាត់បទជា **ពហុ ឧទកេ** ប្រែថា ក្នុងទឹកច្រើន ។ បទថា **សន្តិកេ ហោតិ និព្វានំ** សេចក្តីថា ព្រះនិព្វានរមែងមានក្នុងសម្នាក់ គឺក្នុងទីជិតបុគ្គលនោះ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ។

គាថាទាំងនេះឯង ជាគាថាព្យាករអរហត្តផលរបស់ព្រះថេរៈ ។៙

**អដ្ឋកថា មហានាគត្ថេរគាថា ចប់**

# សុត្តន្តបិដក

## កុល្លត្ថេរគាថា

[ ២១៤ ] កុល្លភិក្ខុ ទៅកាន់ព្រៃខ្មោច បានឃើញខ្មោចស្រីដែលគេបោល បោះបង់ក្នុងព្រៃស្មសាន មានដង្កូវកំពុងតែប្រជែងគ្នាស៊ីដេរដាស ។

( ព្រះសាស្តាត្រាស់ថា ) ម្នាលកុល្លៈ អ្នកចូរមើលសរីរៈ ដែលក្តៅរោលរាលមិនស្អាត មានក្លិនស្អុយ មានវត្ថុមិនស្អាត ដែលហូរឡើង ហូរចុះ ជាសរីរៈដែលពួកមនុស្សពាល តែងត្រេកអរក្រៃពេក ។

( ព្រះកុល្លត្ថេរពោលថា ) ខ្ញុំកាន់កញ្ចក់ គឺធម៌ ចុះមើលកាយនេះ ជារបស់អសារឥតការ ទាំងខាងក្នុងខាងក្រៅ ព្រោះបានសម្រេចដោយញាណទស្សនៈ ។ សរីរៈនៃខ្ញុំនេះ យ៉ាងណា សរីរៈនៃស្រីនុ៎ះយ៉ាងនោះដែរ សរីរៈស្រីនុ៎ះយ៉ាងណា សរីរៈនៃខ្ញុំនេះ ក៏យ៉ាងនោះដែរ សភាវៈខាងក្រោមយ៉ាងណា សភាវៈខាងលើយ៉ាងនោះ សភាវៈខាងលើយ៉ាងណា សភាវៈខាងក្រោមយ៉ាងនោះដែរ ។ វេលាថ្ងៃយ៉ាងណា វេលាយប់យ៉ាងនោះដែរ វេលាយប់យ៉ាងណា វេលាថ្ងៃយ៉ាងនោះដែរ ខាងមុខយ៉ាងណា ខាងក្រោយយ៉ាងនោះដែរ ខាងក្រោយយ៉ាងណា ខាងមុខយ៉ាងនោះដែរ ។ សេចក្តីត្រេកអរដោយតុរិយតន្ត្រីប្រកបដោយអង្គ ៥ ប្រាកដដូច្នោះ ក៏មិនដូចសេចក្តីត្រេកអររបស់អ្នកមានចិត្តមូលតែមួយ ឃើញច្បាស់នូវធម៌ដោយប្រពៃទេ ។

កុល្លត្ថេរ

# អដ្ឋកថា

## កុល្លត្ថេរគាថា

[ ២១៤ ] គាថារបស់ព្រះកុល្លត្ថេរ មានពាក្យផ្ដើមថា **កុល្លោ សិវថិកំ** ដូច្នេះ ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ។ ក្នុងពុទ្ធុប្បាទនេះ កើតនៅក្នុងត្រកូលកុដុម្ពិកៈ ក្នុងនគរសាវត្ថី មានឈ្មោះថា **កុល្លៈ** ដល់នូវភាពជាអ្នកដឹងក្ដីហើយ បានស្ដាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្ដា បាននូវសទ្ធា បួសហើយ ។ ព្រះថេរៈជាអ្នកមានរាគៈខ្លាំងជាប្រក្រតី ព្រោះជារាគចរិត ព្រោះហេតុនោះ ទើបកិលេសទាំងឡាយគ្របសង្កត់ចិត្តរបស់ព្រះថេរៈជានិច្ច ។

លំដាប់នោះ ព្រះសាស្ដា ទ្រង់ជ្រាបវារចិត្តរបស់ព្រះថេរៈ ទើបទ្រង់ប្រទានអសុភកម្មដ្ឋានថា ម្នាលកុល្លៈ អ្នកគប្បីត្រាច់ទៅក្នុងព្រៃខ្មោចរឿយៗ ព្រះថេរៈក៏ចូលទៅកាន់ព្រៃស្មសាន ឃើញអសុភនោះៗ មានសាកសពហើមប៉ោងជាដើម ទើបញុំាងមនសិការដល់អសុភឲ្យកើតឡើងក្នុងខណៈនោះ លុះចេញអំពីព្រៃប៉ុណ្ណោះ ក៏ត្រូវរាគៈគ្របសង្កត់ទៀត ។ ព្រះសាស្ដាទ្រង់ជ្រាបរឿងរបស់ព្រះថេរៈ ថ្ងៃមួយ ក្នុងកាលដែលព្រះថេរៈទៅកាន់ព្រៃស្មសាន ទ្រង់ក៏និម្មិតរូបស្រីក្មេងម្នាក់ដែលស្លាប់ថ្មីៗ មានពណ៌សម្បុរល្អ ព្រះថេរៈឃើញរូបស្រីនោះ ក៏កើតរាគៈយ៉ាងធាប់រហ័ស ដូចកើតក្នុងរបស់ដែលជាវិសភាគដែលមានជីវិត ដូច្នោះ ។

លំដាប់នោះ កាលព្រះថេរៈកំពុងសម្លឹងមើលនោះឯង ព្រះសាស្តាទ្រង់ក៏ធ្វើរូបស្រីនោះឲ្យមានរបស់មិនស្អាតហូរចេញអំពីមុខដំបៅទាំង ៩ មានពួកដង្កូវពពាក់ពពូនគួរខ្ពើម មានក្លិនស្អុយគួរខ្ពើម គួរបដិកូលក្រៃពេក ។ ព្រះថេរៈសម្លឹងមើលរូបនោះ មានចិត្តប្រាសចាកតម្រេកហើយ ។ លំដាប់នោះព្រះសាស្តាទ្រង់ផ្សាយឱភាសទៅ ដើម្បីញ៉ាំងស្មារតីឲ្យកើតដល់ព្រះថេរៈទើបត្រាស់ថា

ម្នាលកុល្ល: អ្នកចូរមើលសរីរៈ ដែលក្តៅរោលរាលមិនស្អាត
មានក្លិនស្អុយ មានវត្ថុមិនស្អាត ដែលហូរឡើងហូរចុះ ជាសរីរៈ
ដែលពួកមនុស្សពាល តែងត្រេកអរក្រៃពេក ដូច្នេះ ។

ព្រះថេរៈស្តាប់ដូច្នោះ ពិចារណាសភាវៈនៃរាងកាយ ដោយប្រពៃនោះឯង បានទូវអសុភសញ្ញា ធ្វើឈានឲ្យកើតក្នុងអសុភសញ្ញានោះ ហើយធ្វើបឋមជ្ឈាននោះឲ្យជាបាទ ចម្រើនវិបស្សនាសម្រេចអរហត្តហើយ ពិចារណាកិច្ចបដិបត្តិរបស់ខ្លួន ទើបពោលគាថាទាំងនេះដោយអំណាចឧទានថា

កុល្លភិក្ខុ ទៅកាន់ព្រៃខ្មោច បានឃើញខ្មោចស្រីដែលគេចោល
បោះបង់ក្នុងព្រៃស្មសាន មានដង្កូវកំពុងតែប្រជែងគ្នាស៊ីដេរដាស ។
ខ្ញុំកាន់កញ្ចក់ គឺធម៌ ធ្លុះមើលកាយនេះ ជារបស់អសារឥតការ
ទាំងខាងក្នុងខាងក្រៅ ព្រោះបានសម្រេចដោយញាណទស្សនៈ ។
សរីរៈនៃខ្ញុំនេះ យ៉ាងណា សរីរៈនៃស្រីនុ៎ះ យ៉ាងនោះដែរ សរីរៈ
ស្រីនុ៎ះ យ៉ាងណា សរីរៈនៃខ្ញុំនេះ ក៏យ៉ាងនោះដែរ សភាវៈខាង

ក្រោម យ៉ាងណា សភាវៈខាងលើ យ៉ាងនោះ សភាវៈខាងលើ យ៉ាងណា សភាវៈខាងក្រោម យ៉ាងនោះដែរ ។ វេលាថ្ងៃ យ៉ាងណា វេលាយប់ យ៉ាងនោះដែរ វេលាយប់ យ៉ាងណា វេលាថ្ងៃ យ៉ាងនោះដែរ ខាងមុខ យ៉ាងណា ខាងក្រោយ យ៉ាងនោះដែរ ខាងក្រោយ យ៉ាងណា ខាងមុខ យ៉ាងនោះដែរ ។ សេចក្តីត្រេកអរដោយតុរិយតន្ត្រីប្រកបដោយអង្គ ៥ ប្រាកដដូច្នោះ ក៏មិនដូចសេចក្តីត្រេកអររបស់អ្នកមានចិត្តមូលតែមួយ ឃើញច្បាស់នូវធម៌ដោយប្រពៃទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កុល្លោ** នេះ ព្រះថេរៈពោលដល់ខ្លួនឯងធ្វើឲ្យដូចជាអ្នកដទៃ ។

បទថា **អាតុរំ** បានដល់ ត្រូវសេចក្តីទុក្ខច្រើនប្រការគ្របសង្កត់ជានិច្ច ។

បទថា **អសុចឹ** បានដល់ វៀរចាកការស្អាត គឺគួរខ្ពើម ជាវត្ថុបដិកូល ។ បទថា **បូតឹ** ប្រែថា មានក្លិនស្អុយ ។

បទថា **បស្ស** សេចក្តីថា ចូរមើលដោយសភាវៈ ។ ដោយបទថា **កុល្ល** នេះ ព្រះមានព្រះភាគត្រាស់ហៅព្រះថេរៈក្នុងកាលប្រទានឱវាទ ។ តែក្នុងគ្រាបន្លឺឧទាន ព្រះថេរៈពោលនឹងខ្លួនឯង ។

បទថា **សមុស្សយំ** ប្រែថា សរីរៈ ។ បទថា **ឧគ្ឃរន្តំ** បានដល់ មានរបស់មិនស្អាតហូរចេញតាមមុខដំបៅខាងលើ ។ បទថា **បគ្ឃរន្តំ** បានដល់ នឹងមានរបស់មិនស្អាតហូរចេញដោយជុំវិញមុខដំបៅខាងក្រោម ។

បទថា **ពាលានំ អភិនន្ទិតំ** សេចក្តីថា ដែលពួកបុគ្គលពាល គឺពួកអន្ធបុថុជ្ជនប្រកាន់មាំត្រេកអរ ថាអញ ថារបស់អញ ដោយការត្រេកអរ គឺទិដ្ឋិ និងតណ្ហាទាំងឡាយ ។

បទថា **ធម្មាទាសំ** បានដល់ កញ្ចក់ដែលសម្រេចហើយដោយធម៌ ដូចសត្វទាំងឡាយឃើញគុណ និងទោស ត្រង់មុខ និងត្រង់រាងកាយរបស់ខ្លួន យ៉ាងណា វិបស្សនាញាណដែលជាហេតុឲ្យព្រះយោគាវចរឃើញតាមសេចក្តីពិតនូវធម៌ គឺសេចក្តីសៅហ្មង និងសេចក្តីផូរផង់ ក្នុងអត្តភាពក៏ដូច្នោះ លោកហៅថា **ធម្មាទាសំ** គឺកញ្ចក់ធម៌ក្នុងទីនេះ ។ ធ្វើវិបស្សនាញាណនោះឲ្យកើតឡើងក្នុងសន្តានរបស់ខ្លួន ដើម្បីសម្រេចដល់ញាណទស្សនៈ គឺធម្មចក្ខុ ពោល គឺមគ្គញ្ញាណ ។

បទថា **បច្ចវេក្ខឹ ឥមំ កាយំ** សេចក្តីថា ខ្ញុំបានពិចារណាដោយចំពោះ គឺឃើញដោយញាណចក្ខុនូវករជកាយនេះ ឈ្មោះថា **តុច្ឆំ** ព្រោះវៀរចាកការទៀង និងខ្លឹម ។ ឈ្មោះថា **សន្តរពាហិរំ** ព្រោះចែកចេញជាសន្តានខ្លួន និងសន្តានអ្នកដទៃ ។

ដើម្បីសម្តែងវិធីដែលលោកពិចារណាមើល ទើបព្រះថេរៈពោលថា សរីរៈនៃខ្ញុំនេះ យ៉ាងណា ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **យថា ឥទំ តថា ឯតំ** សេចក្តីថា អសុភពោល គឺសរីរៈនៃខ្ញុំនេះ សម្តែងកិរិយាដែលប្រៀបដោយមាយាផ្សេងៗ ច្រើនប្រភេទ ព្រោះអាយុ ភ្លើងធាតុ និងវិញ្ញាណមិនប្រាសទៅ យ៉ាងណា សរីរៈ

ដែលស្លាប់ហើយនេះ ក៏ដូច្នោះដូចគ្នា មានហើយព្រោះធម៌ទាំងនោះមិនទាន់ប្រាសទៅក្នុងកាលមុន ។ សរីរៈដែលស្លាប់ហើយក្នុងឥឡូវនេះ មិនសម្តែងកិរិយាណាមួយ ព្រោះមិនមានធម៌ទាំងនោះ យ៉ាងណា សូម្បីសរីរៈរបស់អាត្មាអញក៏ដូច្នោះ នឹងវិនាសទៅពិត ព្រោះធម៌ទាំងនោះប្រាសទៅ ។ ឧបមាថា ឥឡូវនេះ សរីរៈរបស់អញនេះមិនទាន់ស្លាប់ មិនទាន់ដេកក្នុងព្រៃស្មសាន គឺមិនទាន់ដល់ភាវៈនៃសពដែលហើមប៉ោងជាដើម យ៉ាងណា សូម្បីសរីរៈដែលស្លាប់ហើយក្នុងឥឡូវនេះ ក៏ដូច្នោះ ក្នុងកាលមុន ក៏មិនទាន់ស្លាប់ ... មិនទាន់ជាសាកសពហើមប៉ោង ... ។ម្យ៉ាងទៀត សរីរៈដែលស្លាប់ហើយក្នុងឥឡូវនេះ ដេកក្នុងព្រៃស្មសាន ចូលដល់ភាវៈ ជាសាកសពហើមប៉ោងជាដើម យ៉ាងណា សរីរៈនៃអញនេះ ក៏នឹងទៅជាដូច្នោះ ។

ម្យ៉ាងទៀត សរីរៈរបស់អញនេះមិនស្អាត មានក្លិនស្អុយ គួរខ្ពើម ជារបស់បដិកូល មិនទៀង ជាទុក្ខ ជាអនត្តា យ៉ាងណា សរីរៈដែលស្លាប់ហើយក៏ដូច្នោះ ។ ម្យ៉ាងទៀត សរីរៈដែលស្លាប់ហើយនោះ មានសភាវៈមិនស្អាតជាដើម និងមានសភាវៈមិនទៀងជាដើម យ៉ាងណា សូម្បីសរីរៈរបស់អញនេះ ក៏ដូច្នោះ ។

បទថា **យថា អធោ តថា ឧទ្ធំ** សេចក្តីថា កាយនេះ ខាងក្រោមពីផ្ចិតចុះទៅ មិនស្អាត មានក្លិនស្អុយ គួរខ្ពើម បដិកូល មិនទៀង ជាទុក្ខ និងជាអនត្តា យ៉ាងណា ខាងលើ គឺពីផ្ចិតឡើងទៅ ក៏មានសភាវៈមិនស្អាតជាដើម ដូច្នោះ ។

បទថា **យថា ឧទ្ធំ តថា អធោ** សេចក្តីថា ម្យ៉ាងទៀត ខាងលើ តាំងអំពីផ្ចិតឡើងទៅ មានសភាវៈមិនស្អាតជាដើម យ៉ាងណា ខាងក្រោម គឺអំពីផ្ចិតចុះទៅ ក៏ដូច្នោះ ។

បទថា **យថា ទិវា តថា រត្តឹ** សេចក្តីថា កាយនេះ ក្នុងពេលថ្ងៃ មានរបស់មិនស្អាតហូរចេញ ដោយន័យជាដើមថា ពពឹកក្អែកហូរចេញអំពីក្អែក យ៉ាងណា សូម្បីក្នុងពេលយប់ ក៏ដូច្នោះ ។

បទថា **យថា រត្តឹ តថា ទិវា** សេចក្តីថា ម្យ៉ាងទៀត ក្នុងពេលយប់ កាយនេះមានរបស់មិនស្អាតហូរចេញ យ៉ាងណា សូម្បីក្នុងពេលថ្ងៃ ក៏ដូច្នោះ ដោយការចែកពេលវេលា កាយនេះមិនមានការប្លែកផ្សេងគ្នាឡើយ ។

បទថា **យថា បុរេ តថា បច្ឆា** សេចក្តីថា កាយនេះ ពេលមុន គឺក្នុងគ្រាមុន បានដល់ ក្នុងកាលកំលោះក្រមុំ ក៏ជារបស់មិនស្អាត មានក្លិនស្អុយ គួរខ្ពើម បដិកូល យ៉ាងណា ខាងក្រោយ គឺក្នុងវេលាចាស់ ក៏ដូច្នោះ ខាងក្រោយ គឺក្នុងពេលចាស់ មានសភាពមិនស្អាតជាដើម យ៉ាងណា កាលមុន គឺក្នុងគ្រាជាកំលោះក្រមុំ ក៏ដូច្នោះ ។ ម្យ៉ាងទៀត ក្នុងសេចក្តីនេះ គប្បីជ្រាបអត្ថយ៉ាងនេះថា កាលមុន គឺក្នុងអតីតកាល បានដល់ ក្នុងវេលានៅមានវិញ្ញាណ មានសភាវៈមិនស្អាតជាដើម យ៉ាងណា និងមានសភាវៈ មិនទៀងជាដើម យ៉ាងណា ខាងក្រោយ គឺក្នុងអនាគតកាល បានដល់ ក្នុងពេលមិនមានវិញ្ញាណ ក៏ដូច្នោះ ។

បទថា **បញ្ចង្គិកេន តុរិយេន** សេចក្តីថា គ្រែកអរបែបនោះ គឺយ៉ាង

នោះ បានដល់ ការគាប់ចិត្តក្នុងសេចក្ដីសុខ រមែងមិនមានដល់ឥស្សរជន ដែលដល់ព្រមដោយកាមសុខ ដែលគេបម្រើដោយតូរ្យតន្ត្រី ៥ គឺប្រកបទៅ ដោយអង្គ ៥ យ៉ាងនេះ គឺ **អាតត** ស្គរដែលពាសស្បែកតែម្ខាង ១ **វិតត** ស្គរដែលពាសស្បែកទាំងសងខាង ១ **អាតតវិតត** គឺពាសទាំងអស់ ១ **ឃន** គ្រឿងដំ មានធាបជាដើម ១ **សុសិរ** គ្រឿងផ្លុំមានប៉ីជាដើម ១ ។

បទថា **យថា ឯកគ្គចិត្តស្ស សម្មា ធម្មំ វិបស្សតោ** សេចក្ដីថា សេចក្ដីត្រេកអរក្នុងកាម រមែងមិនចូលដល់សូម្បីត្រឹមតែមួយចម្រៀកនៃការ ត្រេកអរក្នុងធម៌របស់ព្រះយោគាវចរ ដែលបំពេញសមថៈ និងវិបស្សនា ឲ្យជាគូគ្នា ហើយពិចារណាការកើត និងការរលត់នៃខន្ធទាំងឡាយ ដោយ វិបស្សនាដែលប្រព្រឹត្តតាមវិថី ដោយការៈដែលឥន្ទ្រិយ មានរស គឺមានកិច្ច តែមួយ សមដូចព្រះមានព្រះភាគត្រាស់ថា

> ភិក្ខុពិចារណាការកើតឡើង និងការវិនាសខន្ធទាំងឡាយ ក្នុង កាលណា ក្នុងកាលនោះ ភិក្ខុនោះ រមែងបាននូវបីតិ និងបាមោជ្ជ បីតិ និងបាមោជ្ជនោះ ឈ្មោះថា ជាអមតធម៌របស់បណ្ឌិត អ្នក ដឹងនូវធម៌ទាំងឡាយ ដូច្នេះ ។

គាថានេះឯង បានជាគាថាព្យាករអរហត្តផលរបស់ព្រះថេរៈ ។៚

**អដ្ឋកថា កុល្លត្ថេរគាថា ចប់**

# សុត្តន្តបិដក

## មាលុង្ក្យបុត្តត្ថេរគាថា

[ ២១៥ ] តណ្ហាតែងចម្រើនដល់មនុស្ស អ្នកប្រព្រឹត្តប្រមាទជាប្រក្រតី ដូចពួរជ្រៃ បុគ្គលនោះ តែងស្ទុះទៅកាន់ភពតូចភពធំ ដូចស្វា កាលប្រាថ្នាផ្លែឈើ ស្ទុះទៅក្នុងព្រៃដូច្នោះ ។ តណ្ហានុ៎ះ ជាទោសជាតិដ៏លាមក ផ្សាយទៅក្នុងអារម្មណ៍ផ្សេងៗ ក្នុងលោក គ្របសង្កត់បុគ្គលណា សេចក្តីសោកតែងចម្រើនដល់បុគ្គលនោះ ដូចស្មៅវីរណ្ណាស ដែលត្រូវភ្លៀងធ្លាក់ចុះជព្រំហើយ តែងចម្រើនឡើង ដូច្នោះ ។ ចំណែកជនណា គ្របសង្កត់តណ្ហាដ៏លាមកក្នុងលោក ដែលឆ្លងដោយកម្រនុ៎ះបាន សេចក្តីសោក តែងធ្លាក់ចេញចាកជននោះឯង ដូចតំណក់ទឹកធ្លាក់ចុះចាកស្លឹកឈូក ។ ហេតុនោះ បានជាតថាគតប្រាប់ដល់អ្នកទាំងឡាយ អ្នកទាំងឡាយមានប៉ុន្មានរូប ដែលមកប្រជុំក្នុងទីនេះ សេចក្តីចម្រើន ចូរមានដល់អ្នកទាំងឡាយទាំងប៉ុណ្ណោះរូបចុះ អ្នកទាំងឡាយ ចូររម្លើងឫសនៃតណ្ហាចោលចេញ ដូចបុគ្គលដែលត្រូវការដោយស្មៅក្លាំងជីកស្មៅវីរណ្ណាសចោលចេញ មារកុំរុករៀនអ្នកទាំងឡាយរឿយៗ ដូចខ្សែទឹកកាច់បំបាក់ដើមបបុសដូច្នោះឡើយ ។ អ្នកទាំងឡាយ ចូរធ្វើតាមនូវពុទ្ធវចនៈ កុំឲ្យខណៈកន្លងនូវអ្នកទាំងឡាយបាន ព្រោះថា បុគ្គលទាំងឡាយ ដែលខណៈកន្លងហើយ តែងសោកសៅពេញបន្ទុកក្នុងនរក ។សេចក្តីប្រមាទទុកជា

ធូលី ធូលីកើតឡើងព្រោះសេចក្ដីប្រមាទ ( ព្រោះហេតុនោះ ) បុគ្គលគួរតែដកនូវសរ គឺសេចក្ដីប្រមាទរបស់ខ្លួនចេញ ដោយសេចក្ដីមិនប្រមាទដោយវិជ្ជា ។

មាលុង្ក្យបុត្តត្ថេរ

# អដ្ឋកថា

## មាលុក្យបុត្តត្ថេរគាថា

[ ២១៥ ] គាថារបស់ព្រះមាលុង្ក្យបុត្តត្ថេរ មានពាក្យផ្ដើមថា **មនុជស្ស** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើហើយ ក្នុងព្រះសម្ពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងពុទ្ធុប្បាទនេះ កើតជាបុត្តរបស់ព្រាហ្មណ៍ដែលតាំងនៅក្នុងឋានៈដ៏ខ្ពស់របស់ព្រះបាទកោសល ក្នុងក្រុងសាវត្ថី ។

មាតារបស់កុលបុត្តនោះ ឈ្មោះថា មាលុង្ក្យា ។ ដោយអំណាចនៃនាងមាលុង្ក្យានោះ ទើបកុលបុត្តនោះប្រាកដនាមថា **មាលុង្ក្យបុត្ត** ។ កុលបុត្តនោះធំចម្រើនវ័យឡើង ព្រោះមានអធ្យាស្រ័យក្នុងនិស្សរណៈ គឺការរលាស់ចេញចាកកិលេស ទើបលះឃរាវាស ចេញបួសជាបរិព្វាជក ត្រាច់

ទៅ បានស្តាប់ធម៌ក្នុងសម្នាក់ព្រះសាស្តា បាននូវសទ្ធាក្នុងសាសនា បួស ហើយ បំពេញវិបស្សនាកម្មដ្ឋាន មិនយូរប៉ុន្មានក៏បានអភិញ្ញា ៦ ។ ព្រះថេរៈ បានទៅកាន់ត្រកូលញាតិ ដើម្បីអនុគ្រោះញាតិ ។ ញាតិទាំងឡាយអង្គាស ព្រះថេរៈដោយខាទនីយ និងភោជនីយាហារដ៏ប្រណីត បំណងនឹងលួងលោម ដោយទ្រព្យ ទើបយកទ្រព្យមកគរជាគំនរធំអំពីខាងមុខ ហើយអង្វរថា ទ្រព្យ នេះជារបស់លោក សូមលោកសឹកមកគ្រប់គ្រងកូនប្រពន្ធ ធ្វើបុណ្យទាំង-ឡាយ ដោយទ្រព្យនេះចុះ ។ ព្រះថេរៈកាលប្តូរអធ្យាស្រ័យរបស់ញាតិទាំង នោះ ឈរក្នុងអាកាស សម្តែងធម៌ដោយ ៦ គាថាថា

តណ្ហាតែងចម្រើនដល់មនុស្ស អ្នកប្រព្រឹត្តប្រមាទជាប្រក្រតី ដូច ពួរជ្រៃ បុគ្គលនោះ តែងស្ទុះទៅកាន់ភពតូចភពធំ ដូចស្វា កាល ប្រាថ្នាផ្លែឈើ ស្ទុះទៅក្នុងព្រៃ ដូច្នោះ ។តណ្ហាទុ៎ះ ជាទោសជាតិ ដ៏លាមក ផ្សាយទៅក្នុងអារម្មណ៍ផ្សេងៗ ក្នុងលោក គ្របសង្កត់ បុគ្គលណា សេចក្តីសោក តែងចម្រើនដល់បុគ្គលនោះ ដូចស្បូវ វណ្ណាស ដែលត្រូវភ្លៀងធ្លាក់ចុះជញ្រាំហើយ តែងចម្រើនឡើង ដូច្នោះ ។ ចំណែកជនណា គ្របសង្កត់តណ្ហាដ៏លាមកក្នុងលោក ដែលឆ្លងដោយកម្រទុ៎ះបាន សេចក្តីសោក តែងធ្លាក់ចេញចាកជន នោះឯង ដូចតំណក់ទឹកធ្លាក់ចុះចាកស្លឹកឈូក ។ ហេតុនោះ បាន ជាតថាគតប្រាប់ដល់អ្នកទាំងឡាយ អ្នកទាំងឡាយមានប៉ុន្មានរូប ដែលមកប្រជុំក្នុងទីនេះ សេចក្តីចម្រើន ចូរមានដល់អ្នកទាំង-

ឡាយទាំងប៉ុណ្ណោះរួបចុះ អ្នកទាំងឡាយ ចូររម្លើងឫសនៃតណ្ហាចោលចេញ ដូចបុគ្គលដែលត្រូវការដោយស្បូវភ្លាំង ជីកស្បូវរណ្ដាសចោលចេញ មារកុំរុករៀនអ្នកទាំងឡាយរឿយៗ ដូចខ្សែទឹកកាច់បំបាក់ដើមបបុស ដូច្នោះឡើយ ។ អ្នកទាំងឡាយ ចូរធ្វើតាមនូវពុទ្ធវចនៈ កុំឲ្យខណៈកន្លងនូវអ្នកទាំងឡាយបាន ព្រោះថា បុគ្គលទាំងឡាយ ដែលខណៈកន្លងហើយ តែងសោកសៅពេញបន្ទុកក្នុងនរក ។ សេចក្ដីប្រមាទទុកជាធូលី ធូលីកើតឡើងព្រោះសេចក្ដីប្រមាទ ( ព្រោះហេតុនោះ ) បុគ្គលគួរតែដកនូវសរ គឺសេចក្ដីប្រមាទរបស់ខ្លួនចេញ ដោយសេចក្ដីមិនប្រមាទដោយវិជ្ជា ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **មនុជស្ស** បានដល់ ដល់សត្វ ។ បទថា **បមត្តចារិនោ** បានដល់ ប្រព្រឹត្តប្រមាទ ដោយសេចក្ដីប្រមាទ មានការបណ្ដោយសតិជាលក្ខណៈ ។ ឈាន វិបស្សនា មគ្គ និងផលទាំងឡាយរមែងមិនចម្រើន ។ ដូចពួរជ្រៃរួបរឹមដើមឈើទាំងឡាយ រមែងចម្រើនដើម្បីវិនាសនៃដើមឈើនោះ យ៉ាងណា តណ្ហាដែលអាស្រ័យទ្វារ ៦ កើតរឿយៗក្នុងអារម្មណ៍ មានរូបជាដើម រមែងចម្រើនដល់សត្វនោះ ដូច្នោះ តណ្ហាកាលចម្រើននោះឯង រមែងធ្វើបុគ្គលដែលប្រព្រឹត្តទៅក្នុងអំណាច ឲ្យធ្លាក់ចុះក្នុងអបាយ ដូចពួរជ្រៃរឹតរុំដើមឈើ ដែលជាទីអាស្រ័យរបស់ខ្លួន ឲ្យរលំដូច្នោះ ។

បទថា **សោ បរិប្លវតិ** សេចក្តីថា បុគ្គលដែលប្រព្រឹត្តទៅក្នុងអំណាចនៃតណ្ហានោះ រមែងច្រេច្ឆា គឺស្ទុះទៅក្នុងភពតូចភពធំ ទៅមកៗ ។ សួរថា ដូចអ្វី ឆ្លើយថា ដូចស្វាកាលប្រាថ្នាផ្លៃឈើ ស្ទុះទៅក្នុងព្រៃ ដូច្នោះ អធិប្បាយថា ពានរត្រូវការផ្លៃឈើ ស្ទុះទៅក្នុងព្រៃ ចាប់នូវមែកមួយ របស់ដើមឈើ លែងនូវមែកនោះ ហើយចាប់មែកដទៃ លែងមែកដទៃ ចាប់មែកដទៃទៀត ព្រោះហេតុនោះ ទើបពោលមិនបានថា ស្វានោះ មិនបានមែកឈើ ទើបអង្គុយសំកុក ដូច្នេះ យ៉ាងណា បុគ្គលដែលប្រព្រឹត្តទៅក្នុងអំណាចតណ្ហា ក៏ដូច្នោះដូចគ្នា ស្ទុះទៅក្នុងភពតូចភពធំ ទើបពោលមិនថា មិនតោងអារម្មណ៍ ទើបមិនប្រព្រឹត្តទៅ ព្រោះតណ្ហា ។

បទថា **យំ** សំដៅដល់ បុគ្គលណា ។ តណ្ហាដែលប្រព្រឹត្តទៅក្នុងទ្វារ ៦ នោះ ហៅថា **ជម្មី** ព្រោះភាពជារបស់លាមក ហៅថា **វិសត្តិកា** ព្រោះមានអាហារជាពិស ព្រោះមានផ្កាជាពិស ព្រោះមានផ្លៃជាពិស ព្រោះមានការបរិភោគជាពិស និងព្រោះយឺតយូរ គឺជាប់ជំពាក់ក្នុងអារម្មណ៍ មានរូបជាដើម រមែងគ្របសង្កត់ គឺញាំញីបុគ្គលនោះ អធិប្បាយថា កាលភ្លៀងធ្លាក់រឿយៗ ស្បូវ គឺស្បូវភ្លាំងខ្លះ ដែលភ្លៀងស្រក់ត្រូវ រមែងចម្រើនក្នុងព្រៃ យ៉ាងណា សេចក្តីសោកទាំងឡាយ ដែលមានវដ្តៈជាមូល រមែងចម្រើន គឺដល់នូវសេចក្តីចម្រើនក៏ដូច្នោះ ។

បទថា **យោ ចេតំ ។បេ។ ទុរច្ចយំ** សេចក្តីថា ឯបុគ្គលណារមែងអត់សង្កត់ គឺគ្របសង្កត់តណ្ហាដែលមានប្រការដូចពោលហើយយ៉ាងនេះ ដែល

ឈ្មោះថា **សុមហគេ** ព្រោះកន្លងបានលំបាក លះបានលំបាក សេចក្ដីសោក មានវដ្តៈជាមូល រមែងធ្លាក់ទៅអំពីបុគ្គលនោះ អធិប្បាយថា សេចក្ដីសោក រមែងមិនតាំងនៅ ដូចតំណក់ទឹកដែលធ្លាក់លើស្លឹកឈូក គឺស្លឹកបទុម រមែងមិនតាំងនៅ ដូច្នោះ ។

បទថា **តំ វោ វទាមិ** សេចក្ដីថា ព្រោះហេតុនោះ ទើបអាត្មាពោលនឹងអ្នកទាំងឡាយ ។

បទថា **ភទ្ទំ វោ** សេចក្ដីថា សេចក្ដីចម្រើន ចូរមានដល់ពួកអ្នក អធិប្បាយថា ពួកអ្នកកុំដល់នូវសេចក្ដីវិនាស គឺការអន្តរធាន ដូចបុគ្គលធ្វើតាមតណ្ហានោះឡើយ ។

បទថា **យាវន្តេត្ថ សមាគតា** សេចក្ដីថា មានប្រមាណប៉ុន្មាននាក់ ដែលមកប្រជុំគ្នាក្នុងទីនេះ ។ បើមានពាក្យសួរជ្រៀតចូលមកថា ព្រះថេរៈពោលដល់អ្វី ឆ្លើយថា ព្រះថេរៈពោលថា អ្នកទាំងឡាយ ចូររម្លើងឫសនៃតណ្ហាចោលចេញ គឺអ្នកទាំងឡាយ ចូរជីក គឺដកនូវឫសដែលជាហេតុនៃតណ្ហា ដែលប្រព្រឹត្តទៅក្នុងទ្វារ ៦ នេះ បានដល់ រម្លើងនូវកិលេស មានអវិជ្ជាជាដើមដោយចប គឺអរហត្តមគ្គញាណ ។ សួរថា ដូចអ្វី ឆ្លើយថា ដូចបុគ្គលដែលត្រូវការដោយស្មៅក្លាំង ជីកស្មៅវណ្ណាសចោលចេញ ដូច្នោះ អធិប្បាយថា អ្នកទាំងឡាយ ចូរជីកឫសគល់នៃតណ្ហានោះ ដូចបុរសត្រូវការស្មៅក្លាំង យកចបធំជីកស្មៅឈ្មោះឧសីរៈ និងមានឈ្មោះម្យ៉ាងទៀតថា ទីរណៈ ដូច្នោះ ។

បទថា **មា វោ នឡំវ សោតោវ មារោ ភញ្ជិ បុនប្បុនំ** សេចក្តីថា កិលេសមារ មច្ចុមារ និងទេវបុត្តមារ កុំរុករានពួកអ្នករឿយៗ ដូចខ្សែទឹកហូរមកដោយកម្លាំងដ៏ខ្លាំង កាច់បំបាក់នូវដើមបបុស ដែលដុះនៅតាមមាត់ស្ទឹង ដូច្នោះ ។

ព្រោះហេតុនោះ អ្នកទាំងឡាយ ចូរធ្វើតាមពុទ្ធវចនៈ គឺចូរធ្វើតាមព្រះតម្រាស់របស់ព្រះមានព្រះភាគ ដែលត្រាស់ ( ក្នុងទ្វេធាវិតក្កសូត្រ ) ដោយន័យជាដើមថា **ឈាយថ ភិក្ខវេ មា បមាទត្ថ** អ្នកទាំងឡាយសម្លឹង ( មើលនូវគល់ឈើទាំងនុ៎ះ នូវសុញ្ញាគារទាំងនុ៎ះ ) ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំប្រមាទ គឺចូរញ៉ាំងបដិបទាឲ្យដល់ព្រមតាមដែលតថាគតប្រៀនប្រដៅ ។

បទថា **ខណោ វោ មា ឧបច្ចគា** សេចក្តីថា ពិតហើយ បុគ្គលណាមិនធ្វើតាមពុទ្ធវចនៈ ខណៈទាំងអស់នេះ គឺខណៈដែលព្រះពុទ្ធទ្រង់កើតឡើង ១ ខណៈដែលបានកើតឡើងក្នុងប្រទេសសមគួរ ១ ខណៈដែលបានសម្មាទិដ្ឋិ ១ ខណៈដែលមានអាយតនៈទាំង ៦ មិនខ្វះខាត ១ រមែងកន្លងបុគ្គលនោះ ខណៈនោះ កុំបីកន្លងអ្នកទាំងឡាយឡើយ ។

បទថា **ខណាតីតា** សេចក្តីថា បុគ្គលណាកន្លងខណៈនោះទៅ ឬថាខណៈនោះកន្លងបុគ្គលណាទៅ បុគ្គលនោះនឹងចង្អៀតគ្នាក្នុងនរក គឺកើតក្នុងនរក សោយសោកអស់កាលយូរ ។

បទថា **បមាទោ រជោ** សេចក្តីថា សេចក្តីប្រមាទមានលក្ខណៈបណ្តែត

បណ្តាយសតិក្នុងអារម្មណ៍ទាំងឡាយ មានរូបជាដើម ឈ្មោះថា ជាធូលី ព្រោះមានសភាពសៅហ្មង និងព្រោះលាយឡំដោយធូលី គឺរាគៈជាដើម ។

បទថា **បមាទានុបតិតោ រជោ** សេចក្តីថា ឈ្មោះថា ធូលីណាមួយ មានរាគៈជាដើម ធូលីទាំងអស់នោះកើតអំពីសេចក្តីប្រមាទ គឺកើតឡើងដោយអំណាចសេចក្តីប្រមាទនោះឯង ។

បទថា **អប្បមាទេន** បានដល់ ដោយសេចក្តីមិនប្រមាទ គឺដោយអប្បមាទប្បដិបត្តិ ។

បទថា **វិជ្ជាយ** បានដល់ ដោយវិជ្ជាដែលសម្បយុត្តដោយអរិយមគ្គ ។

បទថា **អព្វុហេ សល្លមត្តនោ** សេចក្តីថា គប្បីទាញឡើង គឺគប្បីដកនូវសរ មានរាគៈជាដើម ដែលជាប់នៅក្នុងហទយៈរបស់ខ្លួនចេញ ។ល។

**អដ្ឋកថា មាលុង្ក្យបុត្តត្ថេរគាថា ចប់**

# សុត្តន្តបិដក

## សប្បទាសត្ថេរគាថា

[ ២១៦ ] ចាប់ដើមតាំងពីខ្ញុំបួសមក ២៥ ឆ្នាំ មិនដែលបានសេចក្តីស្ងប់ចិត្ត អស់កាលសូម្បីត្រឹមតែមួយផ្ទាត់ម្រាមដៃសោះ ។ ខ្ញុំត្រូវកាមរាគគ្របសង្កត់ មិនបាននូវឯកគ្គតាចិត្ត ផ្គងដៃកន្ទក់កន្ទេញ ហើយចេញពីលំនៅទៅ ។ អាត្មាអញ ( នឹងទម្លាក់ខ្លួនអំពីដើមឈើ ) ឬនឹងយកកាំបិតមក ( ចាក់សម្លាប់ ) ប្រយោជន៍អ្វីដោយការរស់នៅរបស់អញ មនុស្សប្រហែលយ៉ាងអញ មិនសមបើធ្វើមរណកាលដោយការលាសិក្ខាទេ ។ គ្រានោះ ខ្ញុំយកកាំបិតកោរ ចូលទៅអង្គុយលើគ្រែ ផ្ទាប់កាំបិតកោរ ( ត្រង់បំពង់ក ) ដើម្បីអារសរសៃបំពង់ករបស់ខ្លួន ។ លំដាប់នោះ ខ្ញុំមានការធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ទោសកើតឡើងប្រាកដ សេចក្តីនឿយណាយ ក៏តាំងឡើងព្រម ។ តពីនោះមក ចិត្តខ្ញុំក៏ផុតស្រឡះ អ្នកចូរឃើញធម៌ជាធម៌ល្អ វិជ្ជា ៣ អាត្មាអញបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធ អាត្មាអញបានធ្វើស្រេចហើយ ។

សប្បទាសត្ថេរ

# អដ្ឋកថា

## សព្វទាសត្ថេរគាថា

[ ២១៦ ] គាថារបស់ព្រះសព្វទាសត្ថេរ មានពាក្យផ្ដើមថា **បណ្ណាវីសតិ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងពុទ្ធុប្បាទនេះ កើតជាកូនរបស់បុរោហិតនៃព្រះបាទសុទ្ធោទនៈ ក្នុងនគរកបិលពស្តុ មានឈ្មោះថា **សព្វទាស** ចម្រើនវ័យហើយ បាននូវសទ្ធាក្នុងសមាគមព្រះញាតិរបស់ព្រះសាស្ដា ទើបបួស ព្រោះកិលេសគ្របសង្កត់ ទើបមិនបាននូវចេតោសមាធិ កើតនូវសេចក្ដីសង្ស័យក្នុងការប្រព្រឹត្តព្រហ្មចរិយៈ ក្រោយមក ទើបនាំសម្រាមក ចម្រើននូវយោនិសោមនសិការ ក៏បានសម្រេចអរហត្ត កាលនឹងព្យាករអរហត្តផល បានពោលគាថាទាំងនេះថា

ចាប់ដើមតាំងពីខ្ញុំបួសមក ២៥ ឆ្នាំ មិនដែលបានសេចក្ដីស្ងប់ចិត្ត
អស់កាលសូម្បីត្រឹមតែមួយផ្ទាត់ម្រាមដៃសោះ ។ ខ្ញុំត្រូវកាមរាគ
គ្របសង្កត់ មិនបាននូវឯកគ្គតាចិត្ត ផ្គងដៃកន្ទក់កន្ទេញ ហើយ
ចេញពីលំនៅទៅ ។ អាត្មាអញ ( នឹងទម្លាក់ខ្លួនអំពីដើមឈើ )
ឬនឹងយកកាំបិតមក ( ចាក់សម្លាប់ ) ប្រយោជន៍អ្វីដោយការរស់
នៅរបស់អញ មនុស្សប្រហែលយ៉ាងអញ មិនសមបើធ្វើ
មរណកាល ដោយការលាសិក្ខាទេ ។ គ្រានោះ ខ្ញុំយកកាំបិតកោរ
ចូលទៅអង្គុយលើគ្រែ ផ្ទាប់កាំបិតកោរ ( ត្រង់បំពង់ក ) ដើម្បីអារ

សរសៃបំពង់ករបស់ខ្លួន ។ លំដាប់នោះ ខ្ញុំមានការធ្វើទុកក្នុងចិត្ត ដោយឧបាយប្រាជ្ញា ទោសកើតឡើងប្រាកដ សេចក្តីនឿយណាយ ក៏តាំងឡើងព្រម ។ តពីនោះមក ចិត្តខ្ញុំក៏ផុតស្រឡះ អ្នកចូរឃើញធម៌ជាធម៌ល្អ វិជ្ជា ៣ អាត្មាអញបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធ អាត្មាអញបានធ្វើស្រេចហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បណ្ណវីសតិវស្សានិ យតោ បព្វជិតោ អហំ** សេចក្តីថា ចាប់តាំងពីខ្ញុំបួសនោះ អស់កាល ២៥ ឆ្នាំ ។

បទថា **អច្ឆរាសង្ឃាតមត្តម្បិ ចេតោសន្តិមនជ្ឈគំ** សេចក្តីថា ខ្ញុំនោះប្រព្រឹត្តព្រហ្មចរិយៈមកអស់កាលប្រមាណប៉ុណ្ណោះ មិនបាននូវការស្ងប់ចិត្ត ការតាំងមាំនៃចិត្ត ត្រឹមមួយខណៈផ្ទាត់ម្រាមដៃ គឺសូម្បីត្រឹមតែផ្ទាត់ម្រាមដៃ ។

ព្រះថេរៈមិនបានឯកគ្គតាចិត្ត ដោយប្រការដូច្នេះ ទើបពោលហេតុក្នុងសេចក្តីនេះថា ខ្ញុំត្រូវកាមរាគគ្របសង្កត់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អដ្ដិតោ** ប្រែថា បៀតបៀន អធិប្បាយថា គ្របសង្កត់ ។

បទថា **ពាហា បគ្គយ្ហ កន្ទន្តោ** សេចក្តីថា ងើយមុខឡើង ផ្គងដៃទាំង ២ កន្ទក់កន្ទេញថា ក្នុងកាលដែលខ្ញុំបួសក្នុងសាសនា ដែលជាគ្រឿងរលាស់ចេញចាកទុក្ខហើយ មិនអាចរើខ្លួនអំពីភក់ គឺកិលេសបាន នេះមិនសមគួរក្នុងសាសនានេះ ។

បទថា **វិហារា ឧបនិក្ខមឹ** ប្រែថា ចេញទៅខាងក្រៅវិហារ ដែលជា

លំនៅ ដើម្បីសម្តែងបំណាច់ដែលចេញទៅ ទើបលោកពោលពាក្យជាដើមថា នឹងយកកាំបិតមក ដូច្នេះ ។

**វា** សទ្ទ ក្នុងបទថា **សត្ថំ វា អាហរិស្សាមិ** ក្នុងគាថានោះ ប្រើក្នុងអត្ថថា ជ្រើសរើសយកឧបាយណាមួយ ។ ដោយ **វា** សព្ទនោះ លោកសង្គ្រោះយកវិធីសម្លាប់ខ្លួនដូចជាលោតអំពីដើមឈើ ឬចង-កឲ្យស្លាប់ ទុកផងដែរ ។ បទថា **សិក្ខំ** បានដល់ អធិសីលសិក្ខា ។

បទថា **បច្ចក្ខំ** បានដល់ លា គឺលះបង់ បាលីថា **បច្ចក្ខា** ដូច្នេះ ក៏មាន អធិប្បាយថា ដោយការលាសិក្ខា ។

បទថា **កាលំ** ប្រែថា ស្លាប់ អធិប្បាយថា ឈ្មោះថា មនុស្សដូចអញ គប្បីស្លាប់ដោយការលាសិក្ខាបានដូចម្តេច ។ ពិតហើយ ការលាសិក្ខា ឈ្មោះថា ការស្លាប់ក្នុងអរិយវិន័យ ។

សមដូចព្រះមានព្រះភាគត្រាស់ ( ក្នុងមជ្ឈិមនិកាយ សុនក្ខត្តសូត្រ ) ថា ម្នាលសុនក្ខត្ត ពាក្យថា **មរណៈ** នេះ សំដៅយកភិក្ខុដែលពោលលាសិក្ខា ក្នុងវិន័យរបស់ព្រះអរិយៈ ហើយទៅប្រព្រឹត្តខ្លួន ជាបុគ្គលថោកទាបវិញ ដូច្នេះ ។ ក្នុងព្រះបាលីថា **សិក្ខំ បច្ចក្ខា** មានវាចាប្រកបសេចក្តីថា ឈ្មោះថា មនុស្សដូចអញ គប្បីលាសិក្ខាហើយ ធ្វើកាលកិរិយាបានដូចម្តេច តែនឹងជាអ្នកដល់ព្រមដោយសិក្ខាធ្វើ កាលកិរិយា ព្រោះដូច្នោះ អញនឹងយកសស្ត្រាមក ប្រយោជន៍អ្វី របស់អញ ដោយការរស់នៅ ។

បទថា **តទាហំ** បានដល់ ក្នុងកាលដែលខ្ញុំនឿយណាយក្នុងជីវិត ព្រោះ

មិនអាចបំពេញសមណធម៌បាន ព្រោះត្រូវកិលេសគ្របសង្កត់ ។

បទថា **ខុរំ** បានដល់ កាំបិតកោរដែលសំលៀងហើយ ម្យ៉ាងទៀត បានដល់ សស្រ្តាដែលមានមុខដូចកាំបិតកោរ ។

បទថា **មញ្ចកម្ហិ ឧបាវិសឹ** សេចក្តីថា ព្រោះខ្លាចអ្នកដទៃឃាត់ ទើបខ្ញុំចូលបន្ទប់ ហើយអង្គុយលើគ្រែ ។ បទថា **បរិនីតោ** បានដល់ នាំចូលទៅជិតហើយ អធិប្បាយថា ផ្ទាប់ត្រង់ក ។ ដោយបទថា **ធមនឹ** នេះ អាចារ្យពួកខ្លះហៅសរសៃត្រង់កថា **កណ្ឋធមនិ** បានដល់ បំពង់ក ដូច្នេះក៏មាន ។

បទថា **ឆេត្តុំ** ប្រែថា ដើម្បីអារ ។ បទថា **តតោ មេ មនសីការោ យោនិសោ ឧទបជ្ជថ** សេចក្តីថា ក្នុងកាលណា ដែលខ្ញុំគិតថា នឹងស្លាប់ទើបយកកាំបិតកោរផ្ទាប់ដើម្បីកាត់បំពង់ក បន្ទាប់អំពីនោះ កាលខ្ញុំពិចារណាឃើញថា សីលរបស់អញបរិសុទ្ធ ព្រោះបានឃើញសីលបរិសុទ្ធ មិនដាច់មិនធ្លុះ ទើបបីតិកើតឡើង កាយរបស់បុគ្គលមានចិត្តប្រកបដោយបីតិក៏ស្ងប់ កាលបុគ្គលមានកាយស្ងប់ ដែលសោយសុខ ប្រាសចាកអាមិស យោនិសោមនសិការក៏កើតឡើងដោយអំណាចវិបស្សនា ព្រោះចិត្តតាំងមាំ ។

ម្យ៉ាងទៀត បទថា **តតោ** សេចក្ដីថា ក្រោយអំពីយកកាំបិតអារត្រង់បំពង់ក កាលមានទនូវបបួស ក៏កើតយោនិសោមនសិការ សង្កត់វេទនាដែលកើតឡើង ដោយអំណាចវិបស្សនា ឥឡូវនេះ ដើម្បីសម្ដែងឲ្យដឹងថា មគ្គផល និងបច្ចវេក្ខណញ្ញាណកើតឡើងក្រោយអំពីនោះ ទើបព្រះថេរះពោលថា **អាទីនវោ ចាតុរហុ** ដូច្នេះជាដើម ។ ពាក្យនោះ មានអត្ថដូចពោលហើយខាងដើមនោះឯង ៕ល៚

**អដ្ឋកថា សប្បទាសត្ថេរគាថា ចប់**

# សុត្តន្តបិដក

## កាតិយានត្ថេរគាថា

[ ២១៧ ] ( ព្រះសាស្តាត្រាស់ថា ) ម្នាលកាតិយាន ចូរអ្នកក្រោកអង្គុយឡើង កុំដេកច្រើនពេក ចូរភ្ញាក់រឭកឡើង មច្ចុរាជជាមារ ចូរកុំឈ្នះអ្នកជាបុគ្គលខ្ជិលច្រអូស ដូចជានាយនេសាទ ប្រហារសត្វដោយញញួរ ។ ជាតិ និងជរា តែងប្រព្រឹត្តកន្លងអ្នក ដូចជាកម្លាំងមហាសមុទ្រ អ្នកនោះ ចូរធ្វើនូវទីពឹង ដ៏ល្អដល់ខ្លួន ព្រោះថា គ្រឿងការពារដទៃរបស់អ្នកក្នុងលោកនេះមិនមានទេ ។ ដ្បិតព្រះសាស្តាទ្រង់ចង្អុលប្រាប់អរិយមគ្គនុ៎ះ ថាជាផ្លូវកន្លងចាកគ្រឿងជាប់ ចាកភ័យ គឺជាតិ និងជរា ចូរអ្នកកុំប្រមាទអស់រាត្រីខាងដើម និងខាងចុង ចូរប្រឹងធ្វើព្យាយាមឲ្យមាំមួន ។ ខ្លួនអ្នកជាអ្នកទ្រទ្រង់សង្ឃាដិគោរសក់ដោយកាំបិតកោរ និងបរិភោគកិក្ខាហារ ចូរលះបង់កាមគុណ ដែលជាចំណងក្នុងកាលមុនចេញ ម្នាលកាតិយាន អ្នកកុំប្រកបការត្រេកអរក្នុងល្បែងផង កុំប្រកបការលក់ផង ចូរចម្រើនឈាន ។ ម្នាលកាតិយាន អ្នកចូរដុត ចូរឈ្នះ ( នូវកិលេល ) អ្នកជាមនុស្សឈ្លាសវៃ ក្នុងផ្លូវជាទីក្សេមចាកយោគៈ នឹងដល់នូវព្រះនិព្វាន ដ៏បរិសុទ្ធក្រៃលែង ហើយរលត់ ដូចជាគំនរភ្លើងដែលរលត់ដោយទឹក ។ ម្នាលឥន្ទសគោត្រ កាលបើអ្នកមិនប្រកាន់យ៉ាងនេះ ចូរកម្ចាត់បង់មារឲ្យអស់ចេញ ដូចប្រទីបដែលមានពន្លឺតិច ឬដូច

វល្លិតូចដែលខ្យល់កម្ចាត់បង់បាន ដូច្នោះ ។ អ្នកនោះ ប្រាសចាកគម្រេកក្នុងវេទនាទាំងឡាយ ដែលខ្លួនទទួលហើយ មានសេចក្តីត្រជាក់ ចូររង់ចាំនិព្វានកាល ក្នុងទីនេះចុះ ។

កាតិយានត្ថេរ

# អដ្ឋកថា

## កាតិយានត្ថេរគាថា

[ ២១៧ ] គាថារបស់ព្រះកាតិយានត្ថេរ មានពាក្យផ្តើមថា **ឧដ្ឋេហិ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងពុទ្ធុប្បាទនេះ កើតជាកូនរបស់ព្រាហ្មណ៍កោសិយគោត្តម្នាក់ ក្នុងក្រុងសាវត្ថី ព្រោះទាក់ទងដោយគោត្តខាងមាតា ទើបមានឈ្មោះថា **កាតិយានៈ** ។ លុះចម្រើនវ័យ បានជាសម្លាញ់កាលនៅជាគ្រហស្ថរបស់ព្រះសាមញ្ញកានិត្ថេរ បានឃើញព្រះថេរៈ ក៏បួសធ្វើសមណធម៌ ។ ក្នុងវេលាយប់ ឡើងកាន់ទីចង្រ្កម ដោយបំណងនឹងបន្ទោបង់នូវភាពងោកងុយដែលគ្របសង្កត់ ។ លោកដើរចង្រ្កម ត្រូវសេចក្តីដេកលក់គ្របសង្កត់ ក៏ដួលចុះ ដេកលក់ត្រង់ដីដែលមិន

មានកម្រាល ក្នុងទីចង្ក្រមនោះឯង ។ ព្រះសាស្តាទ្រង់ឃើញការប្រព្រឹត្តទៅរបស់ព្រះថេរៈ ក៏យាងទៅទីនោះ ដោយព្រះអង្គឯង ទ្រង់ឈរក្នុងអាកាស ត្រាស់ហៅឲ្យដឹងខ្លួនដោយព្រះតម្រាស់ថា កាតិយានៈ ។ ព្រះថេរៈបានឃើញព្រះសាស្តា ក៏ក្រោកឡើងថ្វាយបង្គំ កើតនូវសេចក្តីសង្វេគ ទើបឈរ ។ គ្រានោះ ព្រះសាស្តាកាលទ្រង់សម្តែងធម៌ដល់ព្រះថេរៈ ទើបត្រាស់គាថាទាំងនេះថា

ម្នាលកាតិយាន ចូរអ្នកក្រោកអង្គុយឡើង កុំដេកច្រើនពេក ចូរភ្ញាក់រឭកឡើង មច្ចុរាជជាមារ ចូរកុំឈ្នះអ្នកជាបុគ្គលខ្ជិលច្រអូស ដូចជានាយនេសាទ ប្រហារសត្វដោយញញួរ ។ ជាតិ និងជរាតែងប្រព្រឹត្តកន្លងអ្នក ដូចជាកម្លាំងមហាសមុទ្រ អ្នកនោះ ចូរធ្វើនូវទីពឹងដ៏ល្អដល់ខ្លួន ព្រោះថា គ្រឿងការពារដទៃរបស់អ្នកក្នុងលោកនេះមិនមានទេ ។ ដ្បិតព្រះសាស្តា ទ្រង់ចង្អុលប្រាប់អរិយមគ្គនុ៎ះ ថាជាផ្លូវកន្លងចាកគ្រឿងជាប់ ចាកភ័យ គឺជាតិ និងជរា ចូរអ្នកកុំប្រមាទអស់រាត្រីខាងដើម និងខាងចុង ចូរប្រឹងធ្វើព្យាយាមឲ្យមាំមួន ។ ខ្លួនអ្នកជាអ្នកទ្រទ្រង់សង្ឃាដិ កោរសក់ដោយកាំបិតកោរ និងបរិភោគភិក្ខាហារ ចូរលះបង់កាមគុណ ដែលជាចំណង់ក្នុងកាលមុនចេញ ម្នាលកាតិយាន អ្នកកុំប្រកបការត្រេកអរក្នុងល្បែងផង កុំប្រកបការលក់ផង ចូរចម្រើនឈាន ។ ម្នាលកាតិយាន អ្នកចូរដុត ចូរឈ្នះ ( នូវកិលេស ) អ្នកជា

មនុស្សឈ្លាសវៃក្នុងផ្លូវ ជាទីក្សេមចាកយោគៈ នឹងដល់នូវព្រះនិព្វានដ៏បរិសុទ្ធក្រៃលែង ហើយរលត់ ដូចជាគំនរភ្លើងដែលរលត់ដោយទឹក ។ ម្នាលឥន្ទសគោត្រ កាលបើអ្នកមិនប្រកាន់យ៉ាងនេះ ចូរកម្ចាត់បង់មារឲ្យអស់ចេញ ដូចប្រទីបដែលមានពន្លឺតិច ឬដូចវល្លិតូច ដែលខ្យល់កម្ចាត់បង់បាន ដូច្នោះ ។ អ្នកនោះ ប្រាសចាកតម្រេកក្នុងវេទនាទាំងឡាយ ដែលខ្លួនទទួលហើយ មានសេចក្តីត្រជាក់ ចូររង់ចាំនិព្វានកាល ក្នុងទីនេះចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧដ្ឋហិ** សេចក្តីថា ចូរអ្នកក្រោកឡើងអំពីនិទ្រា ហើយធ្វើសេចក្តីព្យាយាមក្នុងការក្រោកឡើង ។ ព្រោះធម្មតាការដេកប្រព្រឹត្តទៅក្នុងចំណែកនៃសេចក្តីខិលច្រអូស ព្រោះដូច្នោះ អ្នកកុំដេកឡើយ ។

បទថា **និសីទ** សេចក្តីថា ចូរអង្គុយពត់ភ្នែន តាំងកាយឲ្យត្រង់ តម្រង់ស្មារតីចំពោះមុខ ។

ព្រះមានព្រះភាគត្រាស់ហៅព្រះថេរៈនោះ ដោយឈ្មោះថា កាតិយាន។ បទថា **មា និទ្ទាពហុលោ អហុ** សេចក្តីថា កុំជាអ្នកច្រើនដោយការដេកលក់ គឺត្រូវសេចក្តីដេកលក់គ្របសង្កត់ឡើយ ។

បទថា **ជាគរស្សុ** សេចក្តីថា ចូរភ្ញាក់ គឺចូរជាអ្នកប្រកបដោយសេចក្តីព្យាយាមក្នុងការភ្ញាក់ ។

បទថា **មា តំ អលសំ** សេចក្តីថា មច្ចុរាជជាគ្នីគ្នានៃបុគ្គលប្រមាទ កុំ

ឈ្មោះ គឺចូរកុំគ្របសង្កត់ កុំជាន់ឈ្លីអ្នកខិលប្រអូស មិនប្រកបនូវព្យាយាមជាគ្រឿងភ្ញាក់រឭក ដោយជរា និងព្យាធិ ដូចនាយនេសាទ ឈ្មោះម្រឹគ និងបក្សី ដោយកលឧបាយ គឺដោយអន្ទាក់ ឬអន្ទាក់ ដូច្នោះ ។

បទថា **សេយ្យថាបិ** កាត់បទជា **សេយ្យថា អបិ** ប្រែថា យ៉ាងណា ។ បទថា **មហាសមុទ្ទវេគោ** បានដល់ កម្លាំងរលកនៃមហាសមុទ្រ ។

បទថា **ឯវំ** ជាដើម សេចក្ដីថា កម្លាំងរលកនៃមហាសមុទ្រ តាំងឡើងត្រួតៗ គ្នា គ្របសង្កត់បុរស ដែលមិនអាចឆ្លងមហាសមុទ្រនោះបាន យ៉ាងណា ជាតិ និងជរា ក៏ដូច្នោះ រមែងគ្របសង្កត់ គឺញាំញីអ្នកដែលត្រូវសេចក្ដីខិលប្រអូសគ្របសង្កត់ ។

បទថា **សោ ករោហិ** សេចក្ដីថា ម្នាលកាតិយាន អ្នកចូរធ្វើនូវកោះដែលជាទីពឹងដ៏ល្អ ពោល គឺអរហត្តផល ដែលឱឃៈទាំង ៤ លិចលង់មិនបានសម្រាប់ខ្លួន គឺចូរឲ្យកើតឡើងក្នុងសន្ដានរបស់ខ្លួន ។

សព្ទថា **ហិ** ក្នុងបទថា **ន ហិ តាណំ តវ វិជ្ជតេជ អញ្ញំ** ជានិបាតប្រើក្នុងអត្ថថា ហេតុ អធិប្បាយថា ព្រោះហេតុដែលអ្នកមិនបានទីពឹងដទៃអំពីអរហត្តផលនោះ ក្នុងលោកនេះ ឬលោកខាងមុខ ដូច្នោះ ចូរអ្នកធ្វើកោះដែលជាទីពឹងដ៏ល្អ គឺអរហត្តផលនោះ ។

បទថា **សត្ថា ហិ វិជេសិ មគ្គមេតំ** សេចក្ដីថា ព្រះសាស្ដាទ្រង់គ្របសង្កត់ទេវបុត្តមារជាដើម ហើយត្រាស់ប្រាប់ គឺទ្រង់ឲ្យសម្រេចនូវអរិយមគ្គដែលពួកតិត្ថិយចំនួនច្រើនឲ្យសម្រេចមិនបាន ដែលជាហេតុនៃទីពឹងនោះ ដែល

ធ្វើឲ្យពួកតិរ្ថិយចាញ់ មិនកន្ទន់ផុតចាកកិលេស ដែលជាគ្រឿងជាប់ជំពាក់ ៥ ប្រការ និងចាកភ័យ មានជាតិជាដើម ។ ព្រោះសម្បត្តិ គឺធម៌របស់ព្រះសាស្តា ដែលសាវកគួរគ្រប់គ្រង មិនគួរលះបង់ ដូច្នោះ ដើម្បីនឹងគ្រប់គ្រងសម្បត្តិនោះ ចូរអ្នកជាបុគ្គលមិនប្រមាទ គឺមានសតិសម្បជញ្ញៈ អស់បឋមយាម និងបច្ឆិមយាម គឺចូរជាអ្នកមានសតិសម្បជញ្ញៈ គឺយាមដំបូង និងយាមចុងក្រោយ ប្រឹងប្រែងប្រកបសេចក្តីព្យាយាម និងការចម្រើនភាវនាឲ្យមាំទាំ ។

បទថា **ហិត្វាន បុព្វេ ពន្ធនានិ** សេចក្តីថា ចូរអ្នកលែង គឺលះបង់នូវគ្រឿងចងរបស់គ្រហស្ថ បានដល់ ចំណង គឺកាមគុណដែលមានក្នុងកាលមុន គឺដែលចងក្នុងកាលជាគ្រហស្ថ អធិប្បាយថា ចូរកុំអាល័យក្នុងចំណង គឺកាមគុណនោះ ។

បទថា **សង្ឃាដិខុរមុណ្ឌភិក្ខុភោជី** បានដល់ ជាអ្នកគ្រងសំពត់សង្ឃាដី មានក្បាលត្រងោលដោយកាំបិតកោរ បរិភោគអាហារដែលបានដោយការសូម ពាក្យទាំង ៣ នេះ ជាពាក្យពោលដល់ហេតុនៃការលោស់នូវចំណងដែលមានក្នុងកាលមុន និងដល់ហេតុនៃការមិនត្រេកអរក្នុងការលេងនិងការដេកលក់ ។ ប្រកបសេចក្តីថា ព្រោះហេតុដែលអ្នកដណ្តប់សំពត់សង្ឃាដី មានក្បាលត្រងោល មានអាហារដែលបានដោយការសូមគេចិញ្ចឹមជីវិត ព្រោះដូច្នោះ ការប្រកបកាមសុខ និងការប្រកបសេចក្តីត្រេកអរ ក្នុងការលេង និងក្នុងការដេកលក់ ទើបមិនគួរដល់អ្នក ដោយហេតុនោះ ចូរអ្នក

លែងនូវចំណង់ ដែលមានក្នុងកាលមុន កុំតាមប្រកបនូវចំណង់ កុំប្រកបសេចក្តីត្រេកអរក្នុងការលេង និងការដេកលក់ឡើយ ។

បទថា **ឈាយ** បានដល់ ចូរសម្លឹង គឺចូរព្យាយាមប្រកបអារម្មណូ-បនិជ្ឈាន ។ ព្រះសាស្តាកាលទ្រង់សម្តែងថា អ្នកកាលចម្រើនឈាននោះ ចូរព្យាយាមចម្រើននូវលក្ខណូបនិជ្ឈាន ដែលជាឈានធ្វើអ្នកសម្លឹងឲ្យឈ្នះនូវកិលេសដោយឥតសល់ ទើបត្រាស់ថា ចូរសម្លឹង ចូរឈ្នះកិលេសចុះ ។

បទថា **យោគក្ខេមបថេសុ កោវិទោសិ** សេចក្តីថា ចូរជាអ្នកឈ្លាស គឺឈ្លាសក្នុងពោធិបក្ខិយធម៌ ដែលជាផ្លូវនៃព្រះនិព្វាន ដែលក្សេមចាកយោគៈទាំង ៤ ព្រោះហេតុនោះ អ្នកកាលបំពេញភាវនា នឹងសម្រេចដល់សេចក្តីបរិសុទ្ធដ៏កំពូល ដែលមិនមានវត្ថុក្រៃលែងជាង គឺព្រះនិព្វាន និងអរហត្តហើយបរិនិព្វាន ។

បទថា **វារិណាវ ជោតិ** សេចក្តីថា នឹងរម្ងត់កិលេស ដោយការបង្អុរចុះនៃភ្លៀង គឺអរិយមគ្គ ដូចគំនរភ្លើងរលត់ដោយការធ្លាក់ចុះនៃភ្លៀងធំដូច្នោះ ។

បទថា **បជ្ជោតករោ** បានដល់ ប្រទីបដែលធ្វើនូវពន្លឺ ។ បទថា **បរិត្តរំសោ** បានដល់ មានអណ្តាតតូច គឺពន្លឺតិច ។ បទថា **វិនម្យតេ** ប្រែថា រមែងរលត់ទៅ គឺប្រាសទៅ ។ បទថា **លតាវ** ប្រែថា ដូចវល្លិ លោកអធិប្បាយដូច្នេះថា ប្រទីបដែលមានពន្លឺតូច គឺមានពន្លឺតិច ព្រោះខ្វះបច្ច័យមានប្រេងជាដើម ឬវល្លិតូចៗ ត្រូវខ្យល់កម្ចាត់ គឺទម្លាយ យ៉ាងណា ម្នាល

អ្នកមានគោត្តស្មើគ្នានឹងព្រះឥន្ទ្រ ព្រោះជាកោសិយគោត្ត សូម្បីអ្នកក៏ដូច្នោះ ឈ្មោះថា ជាអ្នកមិនប្រកាន់មាំ ព្រោះមិនធ្លាក់ក្នុងអំណាចរបស់មារនោះ ព្រោះមិនប្រកាន់មាំ ចូរកម្ចាត់ គឺចូរទម្លាយនូវមារចុះ អ្នកកាលកម្ចាត់បានយ៉ាងនេះ ជាអ្នកប្រាសចាកឆន្ទរាគក្នុងវេទនាទាំងពួង ដែលបានសោយហើយ ឈ្មោះថា ជាអ្នកមានសេចក្តីត្រជាក់ គឺរម្ងត់នូវការក្តៅហើយ ព្រោះមិនមានការក្តៅ គឺសេចក្តីក្រវល់ក្រវាយ ព្រោះកិលេសទាំងពួង ក្នុងអត្តភាពនេះឯង ចូរទន្ទឹង គឺចូររង់ចាំកាលបរិនិព្វានរបស់ខ្លួន ។ កាលព្រះសាស្តាត្រាស់ទេសនាឲ្យដល់អនុបាទិសេសនិព្វាន ដោយប្រការដូច្នេះ ក្នុងកាលចប់ទេសនា ព្រះថេរៈចម្រើនវិបស្សនា សម្រេចអរហត្តហើយ កាលសម្រេចអរហត្តហើយ បានពោលគាថាទាំងនេះ តាមនិយាមដែលព្រះសាស្តាទ្រង់សម្តែងហើយនោះឯង គាថាទាំងនេះឯង ជាការព្យាករណ៍អរហត្តផលរបស់ព្រះថេរៈ ។ល។

**អដ្ឋកថា កាតិយានត្ថេរគាថា ចប់**

# សុត្តន្តបិដក

## មិគជាលត្ថេរគាថា

[ ២១៨ ] មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ដែលព្រះពុទ្ធជាអាទិច្ចពន្ធុមានចក្ខុ ទ្រង់សម្តែងហើយដោយប្រពៃ ជាធម៌កន្ទង់ចាកសំយោជនៈទាំងអស់ ញ៉ាំងវដ្តៈទាំងអស់ឲ្យវិនាស នាំសត្វចេញចាកវដ្តៈ ញ៉ាំងសត្វឲ្យឆ្លងចាកឱឃៈ ញ៉ាំងឫសគល់នៃទុក្ខ គឺតណ្ហាឲ្យរីងស្ងួត ទម្លាយនូវតណ្ហា មានឫសជាពិសជាគ្រឿងបៀតបៀន ញ៉ាំងសត្វឲ្យដល់នូវទីរម្ងាត់ទុក្ខ ជាគ្រឿងកម្ចាត់បង់នូវយន្ត គឺអត្តភាពដែលកើតអំពីកម្ម ព្រោះទម្លាយនូវឫសគល់នៃអវិជ្ជាបាន ជាទីធ្លាក់ចុះនៃញាណដ៏មុតដូចកែវវជិរៈ ក្នុងកិរិយាកំណត់នូវវិញ្ញាណ ញ៉ាំងសត្វឲ្យដឹងនូវវេទនាទាំងឡាយ ដោះសត្វឲ្យរួចចេញចាកឧបាទាន ជាគ្រឿងឃើញភពដូចជារណ្តៅរងើកភ្លើង ដោយបញ្ញាញាណ ជាធម៌មានរសដ៏ប្រសើរ ជាធម៌ជ្រៅ ជាធម៌ហាមឃាត់នូវជរា និងមច្ចុ ជាធម៌រម្ងាប់បង់នូវកងទុក្ខ ជាធម៌ដ៏ក្សេម ជាទីឃើញនូវពន្លឺតាមពិត ព្រោះដឹងនូវកម្ម ថាជាកម្ម នូវផលថាជាផល នៃធម៌ទាំងឡាយ អាស្រ័យបច្ច័យកើតតៗ គ្នា រមែងជាធម៌ដល់នូវទីដ៏ក្សេមប្រសើរ ជាធម៌ស្ងប់ចាកកិលេស ជាធម៌ចម្រើនក្នុងទីបំផុត ។

មិគជាលត្ថេរ

# អដ្ឋកថា

## មិគជាលត្ថេរគាថា

[ ២១៨ ] គាថារបស់ព្រះមិគជាលត្ថេរ មានពាក្យផ្ដើមថា **សុទេសិតោ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ។ ក្នុងពុទ្ធុប្បាទនេះ កើតជាកូនរបស់នាងវិសាខាមហាឧបាសិកា ក្នុងនគរសាវត្ថី មានឈ្មោះថា **មិគជាល** ។

មិគជាលនោះ បានទៅវិហារ ព្រោះបានស្ដាប់ធម៌រឿយៗ ទើបកើតសទ្ធាបួសហើយ ចម្រើនវិបស្សនា បានសម្រេចអរហត្ត កាលព្យាករអរហត្តផល ទើបពោលគាថាទាំងនេះថា

មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ដែលព្រះពុទ្ធជាអាទិច្ចពន្ធុ មានចក្ខុ ទ្រង់សម្ដែងហើយដោយប្រពៃ ជាធម៌កន្លងចាកសំយោជនៈទាំងអស់ ញុំាងវដ្ដៈទាំងអស់ឲ្យវិនាស នាំសត្វចេញចាកវដ្ដៈ ញុំាងសត្វឲ្យឆ្លងចាកឱឃៈ ញុំាងឫសគល់នៃទុក្ខ គឺតណ្ហាឲ្យរីងស្ងួត ទម្លាយនូវតណ្ហា មានឫសជាពិស ជាគ្រឿងបៀតបៀន ញុំាងសត្វឲ្យដល់នូវទីរម្ងត់ទុក្ខ ជាគ្រឿងកម្ចាត់បង់នូវយន្ត គឺអត្តភាពដែលកើតអំពីកម្ម ព្រោះទម្លាយនូវឫសគល់នៃអវិជ្ជាបាន ជាទីធ្លាក់ចុះនៃញាណដ៏មុតដូចកែវវជីរៈ ក្នុងកិរិយាកំណត់នូវវិញ្ញាណ ញុំាងសត្វឲ្យដឹងនូវវេទនាទាំងឡាយ ដោះសត្វ

ឲ្យរួចចេញចាកឧបាទាន ជាគ្រឿងឃើញកពដូចជារណ្ដៅរងើក ភ្លើងដោយបញ្ញាញាណ ជាធម៌មានរសដ៏ប្រសើរ ជាធម៌ជ្រៅ ជាធម៌ហាមឃាត់នូវជរា និងមច្ចុ ជាធម៌រម្ងាប់បង់នូវកងទុក្ខ ជាធម៌ដ៏ក្សេម ជាទីឃើញនូវពន្ធ័តាមពិត ព្រោះដឹងនូវកម្មថាជាកម្ម នូវផលថាជាផល នៃធម៌ទាំងឡាយ អាស្រ័យបច្ច័យកើតតៗ គ្នា រមែងជាធម៌ដល់នូវទីដ៏ក្សេមប្រសើរ ជាធម៌ស្ងប់ចាកកិលេស ជាធម៌ចម្រើនក្នុងទីបំផុត ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សុទេសិតោ** បានដល់ ទ្រង់សម្ដែងដោយល្អហើយ អធិប្បាយថា ទ្រង់សម្ដែងដោយការប្រកាសតាមសេចក្ដីពិត ដល់ប្រយោជន៍បច្ចុប្បន្ន ប្រយោជន៍ក្នុងសម្បរាយភព និងប្រយោជន៍យ៉ាងក្រៃលែង ដែលសមគួរដល់អធ្យាស្រ័យនៃវេនេយ្យសត្វ ។

ម្យ៉ាងទៀត បទថា **សុទេសិតោ** បានដល់ ទ្រង់បានសម្ដែងដោយប្រពៃ អធិប្បាយថា ទ្រង់ភាសិត គឺត្រាស់ល្អហើយ ដោយការប្រកាសបវត្តិ និងនិវត្តិ ( ទុក្ខសច្ច និងនិរោធសច្ច ) និងហេតុនៃសច្ចៈទាំង ២ នោះ ដោយមិនខុស ។

បទថា **ចក្ខុមតា** បានដល់ ទ្រង់មានចក្ខុ ដោយចក្ខុ ៥ ប្រការ គឺ មំសចក្ខុ ទិព្វចក្ខុ បញ្ញាចក្ខុ ពុទ្ធចក្ខុ និងសមន្តចក្ខុ ។

បទថា **ពុទ្ធេន** បានដល់ ព្រះសព្វញ្ញុពុទ្ធ ។

បទថា **អាទិច្ចពន្ធុនា** បានដល់ ជាអាទិត្តគោត្ត ពិតហើយ វង្សរបស់

ក្សត្រក្នុងលោក មាន ២ គឺអាទិច្ចវង្ស ១ សោមវង្ស ( វង្សរបស់ព្រះចន្ទ ) ១ ។ ក្នុង ២ វង្សនោះ គប្បីជ្រាបថា វង្សរបស់ព្រះបាទឱក្កាកករាជ ជា **អាទិច្ចវង្ស** ស្តេចសក្យៈទាំងឡាយ ឈ្មោះថា **អាទិច្ចគោត្ត** ព្រោះមានសញ្ជាតិមកអំពីវង្សរបស់ព្រះបាទឱក្កាកករាជនោះ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ សត្វលោកនាំគ្នាហៅថា **អាទិច្ចពន្ធុ** ព្រោះជាពូជពង្សនៃព្រះអាទិត្យ ។

ម្យ៉ាងទៀត ព្រះមានព្រះភាគ ឈ្មោះថា **អាទិច្ចពន្ធុ** ព្រោះជាផៅពង្សនៃព្រះអាទិត្យដូច្នេះក៏មាន អត្ថនេះ បានពោលហើយខាងដើមនោះឯង ។

ធម៌ ឈ្មោះថា **សព្វសំយោជនាតីតោ** ព្រោះឈានកន្លងនូវសំយោជនៈទាំងពួង មានកាមរាគសំយោជនៈជាដើម ឈ្មោះថា **សព្វវដ្ដវិនាសនោ** ព្រោះធ្វើឲ្យវិនាស គឺកម្ចាត់កិលេសវដ្ដ កម្មវដ្ដ និងវិបាកវដ្ដនោះឯង ឈ្មោះថា **និយ្យានិកោ** ព្រោះនាំចេញទៅអំពីការវិលវល់ក្នុងសង្សារ ឈ្មោះថា **ឧត្តរណោ** ព្រោះអត្ថថា ឆ្លងផុតចាកមហាឱឃៈ គឺសង្សារ ឈ្មោះថា **តណ្ហាមូលវិសោសនោ** ព្រោះធ្វើឫសគល់នៃតណ្ហាទាំងពួង មានកាមតណ្ហាជាដើម ដែលបានដល់អវិជ្ជា និងអយោនិសោមនសិការឲ្យក្រៀមស្វិត គឺឲ្យក្រៀមស្ងួត ទម្លាយបង់ គឺកាត់ជាសមុច្ឆេទនូវកម្ម ឬកិលេសដែលឈ្មោះថា **វិសមូលំ** ព្រោះជាទីកើតឡើងនៃសេចក្ដីវិនាសរបស់ពួកសត្វដោយកម្ចាត់ការដឹងច្បាស់ក្នុងវេទនាទាំង ៣ ហើយឲ្យដល់នូវការរលត់ គឺព្រះនិព្វាន ។

អយោនិសោមនសិការ និងអាសវៈទាំងឡាយ ជាឫសគល់នៃអវិជ្ជា ដូចព្រះសារីបុត្តត្ថេរពោល ( ក្នុងមជ្ឈិមនិកាយ សម្មាទិដ្ឋិសូត្រ ) ថា **អាសវសមុទយា អវិជ្ជាសមុទយោ** សេចក្តីកើតឡើងនៃអវិជ្ជា ព្រោះសេចក្តីកើតឡើងនៃអាសវៈ ដូច្នេះ ដើម្បីទម្លាយ គឺដើម្បីទម្លាយឫសគល់នៃអវិជ្ជានោះដោយញាណ ដែលប្រៀបដូចពេជ្រ ។

ម្យ៉ាងទៀត ភ្ជាប់សេចក្តីថា ឈ្មោះថា មានអវិជ្ជាជាឫសគល់ ព្រោះមានអវិជ្ជាជាឫសគល់ដោយព្រះតម្រាស់ថា **អវិជ្ជាបច្ចយា សង្ខារា** ជាដើម បានដល់ ចក្រនៃភព ព្រះពុទ្ធទ្រង់សម្តែងធម៌ដើម្បីទម្លាយភវចក្រនោះដោយពេជ្រ គឺមគ្គញ្ញាណ ។

បទថា **កម្មយន្តវិឃាដនោ** បានដល់ ជាគ្រឿងកម្ចាត់នូវយន្ត គឺអត្តភាពដែលបន្តដោយកម្ម ។

ក្នុងបទថា **វិញ្ញាណានំ បរិគ្គហោ** នេះ គប្បីបន្ថែមពាក្យចូលមកថា កាលការប្រកាន់នូវវិញ្ញាណប្រាកដឡើងតាមកម្មនៃខ្លួន ក្នុងកាមភពជាដើម ។ ពិតហើយ កាលសត្វបដិសន្ធិក្នុងភពនោះៗ សូម្បីវិញ្ញាណដែលអាស្រ័យភពនោះៗ ក៏រមែងជាបដិសន្ធិផងដែរ ។

បទថា **ញាណវជិរនិបាតនោ** បានដល់ ធ្វើនូវពេជ្រ គឺញាណឲ្យធ្លាក់ចុះ គឺធ្វើញាណវជិរៈឲ្យធ្លាក់ចុះ ហើយទម្លាយនូវបដិសន្ធិវិញ្ញាណទាំងនោះ ។ ពិតហើយ លោកុត្តរធម៌ កាលកើតឡើង រមែងកើតឡើងទម្លាយវិញ្ញាណដែលគួរដល់ការកើតក្នុងភពទី ៧ ជាដើមនោះឯង ។

បទថា **វេទនានំ វិញ្ញាបនោ** សេចក្តីថា ប្រកាសវេទនា ៣ មាន សុខវេទនាជាដើមតាមសេចក្តីពិត ដោយអំណាចជាទុក្ខ ដូចព្រួញ និងមិនទៀងតាមលំដាប់ ។

បទថា **ឧបាទានប្បមោចនោ** សេចក្តីថា ដោះនូវចិត្តសន្តានចាកឧបាទានទាំង ៤ មានកាមុបាទានជាដើម ។

បទថា **ភវំ អង្គារកាសុំវ ញាណេន អនុបស្សនោ** សេចក្តីថា សម្តែងនូវភពទាំង ៩ យ៉ាង មានកាមភពជាដើម ដោយប្រចក្សរឿយៗ ដោយត្រូវភ្លើង ១១ កងនេះទូទៅហើយ ដោយមគ្គញ្ញាណ ឲ្យដូចជារណ្តៅរងើកភ្លើងជម្រៅមួយជួរបុរស ។

ឈ្មោះថា **មហារសោ** ព្រោះអត្ថថា ធ្វើមិនឲ្យឆ្អែតដោយភាពជាធម៌ស្ងប់ និងប្រណីត ។ ម្យ៉ាងទៀត ឈ្មោះថា **មហារសោ** ព្រោះមានកិច្ចច្រើនដោយបរិញ្ញាកិច្ចជាដើម និងព្រោះជាធម៌មានសម្បត្តិច្រើន ដោយសាមញ្ញផល ឈ្មោះថា **សុគម្ភីរោ** ព្រោះបុគ្គលដែលមិនបានសន្សំបុណ្យ ឈមចុះបានដោយកម្រ និងព្រោះពិចារណាមិនដល់ ជាធម៌ហាមឃាត់នូវជរា និងមច្ចុ គឺជាធម៌រារាំងនូវជរា និងមច្ចុ ដោយហាមការកើតក្នុងភពតទៅ ។ ឥឡូវនេះ ព្រះថេរៈកាលនឹងសម្តែងធម៌ ដែលប្រកបដោយគុណវិសេសតាមដែលពោលហើយដោយសង្ខេប ទើបពោលថា មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ដើម្បីចង្អុលបង្ហាញនូវគុណរបស់ព្រះធម៌នោះបន្តិចបន្តួចទៀត ទើបពោលពាក្យថា ជាធម៌រម្ងាប់បង់នូវទុក្ខ ជាធម៌ដ៏ក្សេមជាដើម ។

ពាក្យនោះ មានអធិប្បាយថា ឈ្មោះថា **អរិយោ** ព្រោះអត្ថថា បរិសុទ្ធ ឈ្មោះថា **អដ្ឋង្គិកោ** ព្រោះជាទីប្រជុំនៃធម៌ ៨ ប្រការ មានសម្មាទិដ្ឋិជាដើម ។ ឈ្មោះថា **មគ្គោ** ព្រោះអត្ថថា ស្វែងរកនូវព្រះនិព្វាន ឈ្មោះថា **ទុក្ខូបសមនោ** ព្រោះអត្ថថា ស្ងប់រម្ងាប់នូវវដ្តទុក្ខទាំងពួង ឈ្មោះថា **សិវោ** ព្រោះអត្ថថា ក្សេម ។

ព្រោះដឹងនូវកម្មថាជាកម្ម នូវផលថាជាផល នៃធម៌ទាំងឡាយអាស្រ័យបច្ច័យកើតតៗ គ្នា គឺក្នុងធម៌ដែលអាស្រ័យគ្នាកើតឡើង ដោយមិនឃ្លៀងឃ្លាត ដូចក្នុងលទ្ធិខាងក្រៅចាកសាសនានេះ ដែលឃើញកម្ម និងវិបាករបស់កម្មឃ្លៀងឃ្លាត ព្រោះជាបុគ្គលដែលមិនបានត្រាស់ដឹងដោយប្រពៃ ប្រៀនប្រដៅ គឺព្រោះដឹងដោយញាណ ដែលជាចំណែកខាងដើម ទើបឈ្មោះថាជាទីឃើញនូវពន្លឺតាមពិត គឺជាគ្រឿងឃើញនូវពន្លឺ គឺលោកុត្តរញ្ញាណ ដែលធ្វើនូវការឃើញនោះ ព្រោះកម្ចាត់នូវការប្រកាន់ដោយសស្សតទិដ្ឋិ និងឧច្ឆេទ-ទិដ្ឋិបាន ឈ្មោះថា **មហាខេមង្គមោ** ព្រោះដល់ និងញុំាងសត្វទាំងឡាយឲ្យដល់ព្រះនិព្វាន ដែលឈ្មោះថាក្សេមក្រៃលែង ព្រោះមិនមានបុគ្គលណាប្រទូស្តបុគ្គលណា ក្នុងកាលណាឡើយ ។

មានវាចាប្រកបសេចក្ដីថា ធម៌ ឈ្មោះថា **សន្តោ** ព្រោះស្ងប់រម្ងាប់នូវការក្រវល់ក្រវាយ និងការក្ដៅក្រហាយដែលកើតអំពីកិលេសទាំងពួង ឈ្មោះថា **បរិយោសានភទ្ទកោ** ព្រោះឲ្យដល់នូវចេតោវិមុត្តិដែលមិនកម្រើក និងអនុបាទិសេសនិព្វានធាតុ ដែលព្រះពុទ្ធមានចក្ខុទ្រង់សម្ដែងហើយ ។

ព្រះថេរៈ កាលសរសើរអរិយធម៌ ដោយន័យផ្សេងៗ ដោយប្រការដូច្នេះ ស្មើនឹងប្រកាសថា លោកបានសម្រេចធម៌នោះ ដោយអាងដល់អរហត្តដូច្នេះ ។ល។

**អដ្ឋកថា មិគជាលត្ថេរគាថា ចប់**

# សុត្តន្តបិដក

## ជេន្តបុរោហិតបុត្តត្ថេរគាថា

[ ២១៩ ] ខ្ញុំស្រវឹងដោយសេចក្តីស្រវឹង ព្រោះជាតិផង ដោយភោគៈនិងឥស្សរិយយសផង ដោយសណ្ឋានវណ្ណៈ និងរូប ( ល្អ ) ផង ខ្ញុំជាបុគ្គលប្រព្រឹត្តស្រវឹងជ្រប់ហើយ ។ ខ្ញុំត្រូវអតិមានះកម្ចាត់បង់ហើយ ជាមនុស្សពាលជាអ្នករឹងរូស មានមានះដូចជាទង់ជ័យ ដែលគេលើកឡើងហើយ មិនបានសម្គាល់អ្នកណាមួយ ថាជាបុគ្គលស្មើនឹងខ្លួនផង ថាជាបុគ្គលក្រៃលែងជាងខ្លួនផង ។ ខ្ញុំជាអ្នកមានមានះរឹងរូស មិនអើពើ មិនក្រាបសំពះអ្នកណាមួយទោះជាមាតាក្តី បិតាក្តី ឬអ្នកដទៃដែលសន្មតថាគួរគោរព ។ ខ្ញុំបានឃើញព្រះសាស្តា ជាអ្នកទូន្មានសត្វប្រសើរខ្ពង់ខ្ពស់ ជាងនាយសារថីទាំងឡាយព្រះអង្គរុងរឿងដូចព្រះអាទិត្យ មានភិក្ខុសង្ឃចោមរោម ក៏មានចិត្តជ្រះថ្លាបានលះមានះ និងសេចក្តីស្រវឹងចេញអស់ហើយ ទើបថ្វាយបង្គំព្រះសាស្តាព្រះអង្គខ្ពង់ខ្ពស់ជាងសព្វសត្វដោយត្បូង ។ ខ្ញុំបានលះបង់ គាស់រម្លើងនូវសេចក្តីប្រកាន់ថា វិសេសជាងគេផង នូវសេចក្តីប្រកាន់ថា ថោកទាបជាងគេផង បានផ្តាច់ផ្តិលអស្មិមានះចោលអស់ហើយ ទាំងមានះផ្សេងៗ ទាំងអស់ខ្ញុំក៏បានកម្ចាត់បង់ស្រឡះហើយ ។

*ជេន្តបុរោហិតបុត្តត្ថេរ*

# អដ្ឋកថា

## ជេន្តបុរោហិតបុត្តត្ថេរគាថា

[ ២១៩ ] គាថារបស់ព្រះជេន្តបុរោហិតបុត្តត្ថេរ មានពាក្យផ្ដើមថា **ជាតិមទេន មត្តោហំ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងពុទ្ធុប្បាទនេះ កើតជាកូនប្រុសរបស់បុរោហិតនៃព្រះបាទកោសល ក្នុងនគរសាវត្ថី មានឈ្មោះថា **ជេន្តៈ** លុះកុលបុត្តនោះចម្រើនវ័យ ក៏ស្រវឹងដោយជាតិមទៈ និងក្នុងភោគមទៈ ភាពជាធំ និងរូបសម្បត្តិជាដើម មើលងាយអ្នកដទៃ មិនធ្វើសេចក្ដីកោតក្រែងដល់បុគ្គលដែលតាំងនៅក្នុងឋានៈដែលគួរគោរព មានមានះខ្លាំង ត្រាច់ទៅ ។ ថ្ងៃមួយ កុលបុត្តឈ្មោះជេន្តៈនោះ ឃើញព្រះសាស្ដាដែលមហាបរិស័ទចោមរោមកំពុងសម្ដែងធម៌ កាលនឹងចូលទៅគាល់ ក៏ធ្វើការគិតឲ្យកើតឡើងថា បើព្រះសមណគោតមនេះ ត្រាស់រាក់ទាក់អញមុន អញក៏រាក់ទាក់ដែរ បើមិនត្រាស់រកអញ ក៏អញមិននិយាយ ដូច្នេះហើយទើបចូលទៅគាល់ ហើយឈរ ។ កាលព្រះមានព្រះភាគមិនត្រាស់រាក់ទាក់ខ្លួនឯងក៏មិននិយាយ ព្រោះប្រកាន់ខ្លួន សម្ដែងអាការនឹងដើរចេញទៅ ទើបព្រះមានព្រះភាគត្រាស់ ( ក្នុងសំយុត្តនិកាយ សគាថវគ្គ ) ដោយគាថាថា

ម្នាលព្រាហ្មណ៍ មានះរបស់បុគ្គលណា ក្នុងលោកនេះ មាន
ម្នាលព្រាហ្មណ៍ មានះនោះ មិនប្រពៃទេ បុគ្គលមកហើយដោយ

ប្រយោជន៍ណា បុគ្គលត្រូវចម្រើននូវប្រយោជន៍នោះឯង ដូច្នេះ ។

កុលបុត្តនោះគិតថា ព្រះសមណគោតម ដឹងចិត្តរបស់អញហ្ន៎ ក៏មានសេចក្តីជ្រះថ្លាក្រៃលែង បង្អោនសិរសាទៀបព្រះបាទាទាំងទ្វេរបស់ព្រះមានព្រះភាគ ធ្វើនូវអាការគោរពកោតក្រែងក្រៃលែង ហើយទូលសួរថា

បុគ្គលមិនគួរធ្វើមានះ ក្នុងពួកបុគ្គលណា បុគ្គលគួរប្រកបដោយសេចក្តីគោរព ក្នុងបុគ្គលណា ពួកបុគ្គលណា ដែលបុគ្គលគប្បីលំអុតលំឱន ពួកបុគ្គលណា ដែលបុគ្គលបូជាល្អហើយ ញុំាងប្រយោជន៍ឲ្យសម្រេច ដូច្នេះ ។

ព្រះមានព្រះភាគ កាលទ្រង់ឆ្លើយបញ្ហារបស់កុលបុត្តនោះ ទើបទ្រង់ត្រាស់ថា

បុគ្គលមិនគួរធ្វើមានះចំពោះមាតា បិតា បង និងអាចារ្យ ជាគម្រប់ ៤ គួរប្រកបដោយសេចក្តីគោរពចំពោះបុគ្គលទាំង ៤ នោះ បុគ្គលទាំង ៤ នោះ បុគ្គលគួរលំអុតលំឱន មួយទៀត បុគ្គលទាំង ៤ នោះ ដែលគេបូជាល្អហើយ ញុំាងប្រយោជន៍ឲ្យសម្រេច បុគ្គលគួរកម្ចាត់មានះ មិនគួររឹងត្អឹងដោយអនុស័យ គឺមានះនោះ ចំពោះព្រះអរហន្ត ដែលមានសេចក្តីត្រជាក់ មានសោឡសកិច្ចធ្វើរួចហើយ មិនមានអាសវៈ ជាអ្នកប្រសើរ ដូច្នេះ ។

ហើយទ្រង់សម្តែងធម៌ ( បន្ថែមទៀត ) ដល់កុលបុត្តនោះ ។ កុលបុត្តនោះបានជាសោតាបន្ន ដោយទេសនានោះ បួសហើយ បំពេញវិបស្សនា

សម្រេចអរហត្ត កាលនឹងព្យាករអរហត្តផល ដោយប្រារព្ធបដិបទារបស់ខ្លួន ទើបពោលគាថាទាំងនេះថា

ខ្ញុំស្រវឹងដោយសេចក្ដីស្រវឹង ព្រោះជាតិផង ដោយភោគៈ និង ឥស្សរិយយសផង ដោយសណ្ឋានវណ្ណៈ នឹងរូប ( ល្អ ) ផង ខ្ញុំជាបុគ្គលប្រព្រឹត្តស្រវឹងជ្រប់ហើយ ។ ខ្ញុំត្រូវអតិមានះកម្ចាត់បង់ហើយ ជាមនុស្សពាល ជាអ្នករឹងរូស មានមានះដូចជាទង់ជ័យដែលគេលើកឡើងហើយ មិនបានសម្គាល់អ្នកណាមួយ ថាជាបុគ្គលស្មើនឹងខ្លួនផង ថាជាបុគ្គលក្រៃលែងជាងខ្លួនផង ។ ខ្ញុំជាអ្នកមានមានះរឹងរូស មិនអើពើ មិនក្រាបសំពះអ្នកណាមួយ ទោះជាមាតាក្ដី បិតាក្ដី ឬអ្នកដទៃដែលសន្មតថា គួរគោរព ។ ខ្ញុំបានឃើញព្រះសាស្ដា ជាអ្នកទូន្មានសត្វប្រសើរខ្ពង់ខ្ពស់ ជាងនាយសារថីទាំងឡាយ ព្រះអង្គរុងរឿងដូចព្រះអាទិត្យ មានភិក្ខុសង្ឃចោមរោម ក៏មានចិត្តជ្រះថ្លា បានលះមានះ និងសេចក្ដីស្រវឹងចេញអស់ហើយ ទើបថ្វាយបង្គំព្រះសាស្ដា ព្រះអង្គខ្ពង់ខ្ពស់ជាងសព្វសត្វដោយត្បូង ។ ខ្ញុំបានលះបង់ គាស់រម្លើងនូវសេចក្ដីប្រកាន់ថា វិសេសជាងគេផង នូវសេចក្ដីប្រកាន់ថា ថោកទាបជាងគេផង បានផ្ដាច់ផ្ដិលអស្មិមានះចោលអស់ហើយ ទាំងមានះផ្សេងៗ ទាំងអស់ ខ្ញុំក៏បានកម្ចាត់បង់ស្រឡះហើយដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ជាតិមទេន មត្តោហំ** មានវាចាប្រកប សេចក្តីថា ខ្ញុំកើតក្នុងត្រកូលព្រាហ្មណ៍ឧទិច្ចៈ ទើបស្រវឹងដោយការប្រកាន់ក្នុងត្រកូលថា មិនមានអ្នកដទៃដែលកើតល្អហើយអំពីមាតាបិតា ទាំង ២ ចំណែកដូចអញ ទើបប្រកាន់ខ្លួន ត្រាច់ទៅ ។

បទថា **ភោគឥស្សរិយេន ច** មានពាក្យប្រកបសេចក្តីថា ខ្ញុំជាអ្នកស្រវឹងដោយទ្រព្យសម្បត្តិ និងភាពជាធំ គឺត្រាច់ទៅ ដោយការស្រវឹងដែលកើតឡើង ព្រោះអាស្រ័យភោគសម្បត្តិ និងឥស្សរិយសម្បត្តិជាហេតុ ។

បទថា **សណ្ឋានវណ្ណរូបេន** សេចក្តីថា ទ្រង់ទ្រាយ បានដល់ ការសម្បូរដោយកម្ពស់ និងទំហំ វណ្ណៈ បានដល់ ការសម្បូរដោយពណ៌សម្បុរមានសម្បុរស និងសម្បុរសណ្តែកបាយជាដើម ។ រូប បានដល់ ការល្អនៃអវយវៈតូចធំ ។ ក្នុងបទថា **សណ្ឋានវណ្ណរូបេន** នេះ គប្បីជ្រាបវាចាប្រកបសេចក្តីដោយន័យដូចពោលហើយ ។

បទថា **មទមត្តោ** បានដល់ ជាអ្នកស្រវឹងដោយការស្រវឹងដទៃទៀត ក្រៅអំពីអាការដែលពោលហើយ ។

បទថា **នាត្តនោ សមកំ កញ្ចិ** សេចក្តីថា ខ្ញុំមិនសម្គាល់ គឺមិនទទួលស្គាល់បុគ្គលណាថាស្មើ គឺដូចគ្នានឹងខ្លួន បានដល់ ស្មើ ឬក្រៃលែងជាងខ្លួនដោយជាតិជាដើម អធិប្បាយថា បុគ្គលដែលស្មើនឹងខ្លួន ក៏មិនសម្គាល់ថាមាន តើនឹងសម្គាល់បុគ្គលដែលក្រៃលែងជាងមកអំពីណា ។

បទថា **អតិមានហតោ ពាលោ** សេចក្តីថា ខ្ញុំជាមនុស្សពាល ព្រោះ

ភាពជាបុគ្គលពាលនោះ ទើបជាបុគ្គលត្រូវសេចក្តីមើលងាយអ្នកដទៃ កម្ចាត់មារយាទដែលល្អ ព្រោះហេតុនោះឯង ទើបខ្ញុំមានចិត្តរឹងត្អឹង តម្កើងនូវមានះដូចទង់ គឺជាអ្នករឹងត្អឹងខ្លាំង បានដល់ ជាបុគ្គលរឹងត្អឹង ដោយមិនបន្ទន់បន្ទាបខ្លួន ជាអ្នកលើកនូវទង់ គឺមានះ ព្រោះមិនធ្វើការឱនលំទោនដល់បុគ្គលដែលគួរគោរព ដោយភាពចចេស ។

ដើម្បីធ្វើអត្ថតាមដែលពោលហើយនោះ ឲ្យប្រាកដជាក់ច្បាស់ ទើបពោលពាក្យថា **មាតរំ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **អញ្ញេ**[១] បានដល់ បងប្រុសជាដើម និងសមណព្រាហ្មណ៍ ។

បទថា **គរុសម្មតេ** បានដល់ ដែលសន្មតថាគ្រូ គឺតាំងនៅក្នុងឋានៈជាបុគ្គលគួរគោរព ។

បទថា **អនាទរោ** បានដល់ វៀរចាកនូវការអើពើ ។

បទថា **ទិស្វា វិនាយកំ អគ្គំ** មានវាចាប្រកបសេចក្តីថា ខ្ញុំជាអ្នកមានមានះខ្លាំងយ៉ាងនេះ ត្រាច់ទៅ បានឃើញព្រះសាស្តាឧត្តមជាងសព្វសត្វដែលឈ្មោះថា **វិនាយកំ** ព្រោះដឹកនាំពួកវេនេយ្យសត្វ ដោយទិដ្ឋធម្មិកត្ថប្រយោជន៍ សម្បរាយិកត្ថប្រយោជន៍ និងបរមត្ថប្រយោជន៍ និងព្រោះភាវៈជាអ្នកនាំដោយភាពជាព្រះសយម្ភូ ឈ្មោះថា **អគ្គំ** ព្រោះជាបុគ្គលប្រសើរបំផុតក្នុងលោក ព្រមទាំងទេវលោកដោយគុណ មានសីលជាដើម ឈ្មោះថា

---

១- បិដកខ្មែរ ជាអញ្ញេ ។

**សារថីនំ វរុត្តមំ** គឺឧត្តមក្រៃលែង ព្រោះទូន្មាននូវបុរសដែលគួរទូន្មានបាន ឈ្មោះថា **តបន្តំ** គឺរុងរឿងដោយរស្មី មានរស្មីប្រមាណមួយព្យាមជាដើម ដូចព្រះអាទិត្យ មានភិក្ខុសង្ឃចោមរោម ទ្រង់សម្តែងធម៌ ត្រូវពុទ្ធានុភាពគំរាម ទើបលះ គឺបោះបង់នូវមានៈដែលកើតឡើងថា អញប៉ុណ្ណោះជាបុគ្គលប្រសើរ អ្នកដទៃថោកថយ និងការស្រវឹងដែលមានមកក្នុងភោគៈជាដើម មានចិត្តជ្រះថ្លា អភិវាទដោយសិរសា គឺត្បូង ។ សួរថា ជេន្តកុលបុត្តនេះ ជាអ្នកមានមានៈខ្លាំង ហេតុអ្វី ទើបលះមានៈ ដោយហេតុត្រឹមតែបានឃើញព្រះសាស្តា ឆ្លើយថា សេចក្តីនោះ មិនគប្បីឃើញយ៉ាងនោះ កុលបុត្តនោះ មិនបានលះមានៈ ដោយត្រឹមតែឃើញព្រះសាស្តាទេ តែលះមានៈបានដោយទេសនា មានពាក្យថា ម្នាលព្រាហ្មណ៍ មានៈរបស់បុគ្គលណា ក្នុងលោកនេះ មាន ... ដូច្នេះជាដើម ដែលលោកពោលសំដៅថា ក៏មានចិត្តជ្រះថ្លា បានលះមានៈ និងសេចក្តីស្រវឹងចេញអស់ហើយ ទើបថ្វាយបង្គំព្រះសាស្តា ព្រះអង្គខ្ពង់ខ្ពស់ជាងសព្វសត្វដោយត្បូង ដូច្នេះ ។ ក្នុងបទថា **វិប្បសន្នេន ចេតសា** នេះ គប្បីជ្រាបថា ជាតតិយាវិភត្តិ ប្រើក្នុងអត្ថឥត្ថម្ភូត ប្រែថា មាន ។

អាចារ្យពួកខ្លះពោលថា មានៈដែលកើតឡើងថា អាត្មាអញប៉ុណ្ណោះជាបុគ្គលប្រសើរបំផុត ដូច្នេះ ជាអតិមានៈ មានៈរបស់បុគ្គលដែលប្រកាន់អ្នកដទៃថា ជាបុគ្គលអាក្រក់ ជាការមើលងាយ ។ ម្យ៉ាងទៀត មានៈដែលប្រកាន់ថា ល្អជាងគេ ដែលកើតដល់បុគ្គលដែលប្រកាន់ខ្លួនថា ប្រសើរជាង

អ្នកដទៃថា អាត្មាអញប្រសើរជាង ដូច្នេះ ជាអតិមានះ ។ មានះដែលអាក្រក់ជាងគេ កើតឡើងថា អញជាបុគ្គលអាក្រក់ជាងគេ ដូច្នេះ ជាការមើលងាយ ( ឱមានះ ) ។

បទថា **បហីនា សុសមូហតា** សេចក្តីថា ជាអ្នកលះដោយមគ្គខាងក្រោម ដកឡើងបានជាសមុច្ឆេទដោយអរហត្តមគ្គ ។

បទថា **អស្មិមានោ** បានដល់ មានះដែលកើតឡើងដោយអំណាចការប្រកាន់ថា អញ ក្នុងខន្ធថា នុ៎ះជាអញ ។

បទថា **សព្វេ** សេចក្តីថា មិនមែនអតិមានះ ឱមានះ និងអស្មិមានះតែម្យ៉ាងប៉ុណ្ណោះទេ ដោយពិត ខ្ញុំកម្ចាត់ប្រភេទរបស់មានះ គឺចំណែកនៃមានះទាំងអស់ មានប្រភេទមានះ ៩ យ៉ាង ដូចជា ប្រសើរជាងគេ សម្គាល់ថាអញប្រសើរជាងគេជាដើម និងមានះច្រើនប្រភេទ ដោយប្រភេទដទៃៗ គឺដកបានជាសមុច្ឆេទហើយ ដោយអរហត្តមគ្គ ។ល។

**អដ្ឋកថា ជេន្តបុរោហិតបុត្តត្ថេរគាថា ចប់**

# សុត្តន្តបិដក

## សុមនត្ថេរគាថា

[ ២២០ ] ខ្ញុំមានអាយុ ៧ ឆ្នាំ អំពីកំណើត ទើបនឹងបួសថ្មីៗ បានសង្កត់សង្កិននាគរាជមានឫទ្ធិច្រើន ដោយឫទ្ធិ ហើយដងយកទឹកពីស្រះធំឈ្មោះអនោតត្តៈ មកប្រគេនព្រះឧបជ្ឈាយ៍ក្នុងគ្រាណា គ្រានោះ ព្រះសាស្តាទ្រង់ទតឃើញខ្ញុំហើយ បានត្រាស់ព្រះពុទ្ធដីកានេះថា ម្នាលសារីបុត្ត អ្នកចូរមើលកុមារតូចនេះ កំពុងនាំយកនូវក្អមទឹកមក មានចិត្តតាំងខ្ជាប់ខ្ជួនខាងក្នុងៗ សាមណេររបស់ព្រះអនុរុទ្ធ មានវត្តគួរជ្រះថ្លា មានឥរិយាបថបរិបូណ៌ និងជាអ្នកក្លៀវក្លាដោយឫទ្ធិ ជាបុរសអាជានេយ្យ ដែលព្រះអនុរុទ្ធ ជាបុរសអាជា-នេយ្យ ជាសប្បុរស ឲ្យធ្វើតែអំពើល្អ ណែនាំតែខាងផ្លូវល្អ មានកិច្ចធ្វើរួចហើយ មានសិក្ខាឲ្យសិក្សាហើយ សុមនសាមណេរនោះ បានដល់នូវព្រះនិព្វានជាទីស្ងប់រម្ងាប់ក្រៃលែង បានធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល ជាធម៌មិនកម្រើក ប្រាថ្នាថា សូមកុំឲ្យជនណាមួយស្គាល់អញឡើយ ។

សុមនត្ថេរ

# អដ្ឋកថា

## សុមនត្ថេរគាថា

[ ២២០ ] គាថារបស់ព្រះសុមនត្ថេរ មានពាក្យផ្ដើមថា **យទា នវោ បព្វជិតោ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមសិខី កុលបុត្តនេះ កើតក្នុងត្រកូលអ្នកក្រផ្កា ដល់នូវភាពជាអ្នកដឹងក្ដីហើយ ។ ថ្ងៃមួយ បានឃើញព្រះមានព្រះភាគព្រះនាមសិខី មានចិត្តជ្រះថ្លា បានបូជាផ្កាម្លិះ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងផ្ទះរបស់ឧបាសកម្នាក់ ឧបាសកនោះជាឧបដ្ឋាករបស់ព្រះអនុរុទ្ធត្ថេរ ។ ក្នុងកាលមុនអំពីនោះ ទារករបស់គាត់កើតហើយ ក៏ស្លាប់ទៅ ដូច្នោះហើយ ទើបគាត់កើតគំនិតឡើងថា ឥឡូវនេះ បើអញបានកូនប្រុស នឹងឲ្យបួសក្នុងសម្នាក់លោកម្ចាស់អនុរុទ្ធត្ថេរ ។

ទារកក្នុងគភ៌នោះ លុះកន្លងទៅបាន ១០ ខែ ក៏កើតជាទារក មិនមានជំងឺ ធំធាត់មកដោយលំដាប់ មានអាយុ ៧ ឆ្នាំ ឪពុកបានឲ្យបួសក្នុងសម្នាក់ព្រះថេរៈ ។ កាលបួសហើយ ព្រោះជាអ្នកមានញាណចាស់ក្លា ក៏បំពេញនូវវិបស្សនាកម្មដ្ឋាន មិនយូរប៉ុន្មាន ជាអ្នកមានអភិញ្ញា ៦ កាលនឹងបម្រើព្រះថេរៈ គិតថា អញនឹងដងទឹកផឹក ទើបកាន់យកក្អមទឹកទៅកាន់អនោតត្តស្រះដោយឫទ្ធិ ។

លំដាប់នោះ នាគរាជមួយ ជាសត្វមិច្ឆាទិដ្ឋិ ដើម្បីបិទអនោតត្តស្រះ ទើបក្ដោបរង្វេល ៧ ជុំ បើកមហាពពារ បិទអំពីខាងលើ មិនឲ្យឱកាសដល់សុមនសាមណេរ ។ សុមនសាមណេរកាឡាខ្លួនជាគ្រុឌ ឈ្នះនាគរាជនោះ ហើយដងទឹក ហោះទៅកាន់លំនៅព្រះថេរៈ ។

ព្រះសាស្តា គង់ក្នុងវត្តជេតពន ឃើញសុមនៈនោះទៅដោយប្រការយ៉ាងនោះ ក៏ត្រាស់ហៅព្រះធម្មសេនាបតីមក ហើយត្រាស់គុណរបស់សាមណេរ ៦ គាថាថា ម្នាលសារីបុត្ត ចូរអ្នកមើលកុមារតូចនេះ កំពុងនាំយកនូវក្អមទឹកមក ដូច្នេះជាដើម ។ ក្នុងកាលតមក សុមនត្ថេរបានពោល ៦ គាថា ដោយការព្យាករណ៍អរហត្តផលថា

ខ្ញុំមានអាយុ ៧ ឆ្នាំ អំពីកំណើត ទើបនឹងបួសថ្មីៗ បានសង្កត់សង្កិននាគរាជមានឫទ្ធិច្រើនដោយឫទ្ធិ ហើយដងយកទឹកពីស្រះធំឈ្មោះអនោតត្តៈ មកប្រគេនព្រះឧបជ្ឈាយ៍ក្នុងគ្រាណា គ្រានោះព្រះសាស្តា ទ្រង់ទតឃើញខ្ញុំហើយ បានត្រាស់ព្រះពុទ្ធដីកានេះថា ម្នាលសារីបុត្ត អ្នកចូរមើលកុមារតូចនេះ កំពុងនាំយកនូវក្អមទឹកមក មានចិត្តតាំងខ្ជាប់ខ្ជួនខាងក្នុង ។ សាមណេររបស់ព្រះអនុរុទ្ធមានវត្តគួរជ្រះថ្លា មានឥរិយាបថបរិបូណ៌ និងជាអ្នកក្លៀវក្លាដោយឫទ្ធិ ជាបុរសអាជានេយ្យ ដែលព្រះអនុរុទ្ធជាបុរសអាជា-នេយ្យ ជាសប្បុរស ឲ្យធ្វើតែអំពើល្អ ណែនាំតែខាងផ្លូវល្អ មានកិច្ចធ្វើរួចហើយ មានសិក្ខាឲ្យសិក្សាហើយ សុមនសាមណេរ

នោះ បានដល់នូវព្រះនិព្វានជាទីស្ងប់រម្ងាប់ក្រៃលែង បានធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល ជាធម៌មិនកម្រើក ប្រាថ្នាថា សូមកុំឲ្យជនណាមួយស្គាល់អញឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ ២ គាថាខាងដើម ព្រះសុមនត្ថេរពោលខ្លួនឯង ៤ គាថាទៀត ព្រះសាស្ដាត្រាស់សរសើរព្រះថេរៈ ។ ព្រះសុមនត្ថេរសរុបគាថាទាំងអស់នោះចូលជាមួយគ្នាហើយ បានពោលទាក់ទងដោយការព្យាករណ៍អរហត្តផលក្នុងកាលជាខាងក្រោយ ។

បណ្ដាបទទាំងនោះ បទថា **បន្នគិន្ទំ** បានដល់ ស្ដេចនាគ ។ បទថា **តតោ** បានដល់ ក្នុងកាលនោះ អធិប្បាយថា ក្នុងកាលដែលខ្ញុំបួសថ្មីៗ មានអាយុ ៧ ឆ្នាំពីកំណើត បានឈ្នះស្ដេចនាគមានឫទ្ធិច្រើន ដោយកម្លាំងនៃឫទ្ធិកាន់យកទឹកអំពីអនោតត្តស្រះ មកប្រគេនព្រះឧបជ្ឈាយ៍ ។

ព្រះថេរៈកាលនឹងសម្ដែងនូវព្រះតម្រាស់ ដែលព្រះសាស្ដាត្រាស់ចំពោះខ្ញុំ ទើបពោលពាក្យជាដើមថា ម្នាលសារីបុត្ត ចូរអ្នកមើលកុមារតូចនេះកំពុងនាំយកនូវក្អមទឹកមក ដូច្នេះ ។

បទថា **អជ្ឈត្តំ សុសមាហិតំ** សេចក្ដីថា មានចិត្តតាំងមាំល្អហើយដោយសមាធិ ដែលសម្បយុត្តដោយអរហត្តផលដែលជាអារម្មណ៍ខាងក្នុង ។

បទថា **ចាសាធិកេន វត្តេន** បានដល់ ដោយអាចារវត្ត ដែលនាំនូវការជ្រះថ្លាមកឲ្យដល់អ្នកឃើញ ។ បទថា **ចាសាធិកេន វត្តេន** នេះ ជាតតិយាវិភត្តិ ប្រើក្នុងអត្ថនៃករណៈ ប្រែថា ផង ។

បទថា **កល្យាណឥរិយាបថោ** បានដល់ ជាអ្នកមានឥរិយាបថមិនធ្គង ម្យ៉ាងទៀត បទថា **ចាសាមិកោន វត្តេន** នេះ ជាតតិយាវិភត្តិ ប្រើជាឥត្ថម្ភូត ប្រែថា មាន ។ ភាពជាសមណៈ ឈ្មោះថា **សមណ្ណ** គឺសាមញ្ញ ។ ឈ្មោះថា សាមណេរ បានដល់ សមណុទ្ទេស ព្រោះទៅ គឺទៅដើម្បីសាមញ្ញ ( ភាពជាសមណៈនោះ ) ។

បទថា **ឥទ្ធិយា ច វិសារទោ** បានដល់ ជាអ្នកឈ្លាស គឺឈ្លាសល្អក្នុងឫទ្ធិ ។

បទថា **អាជានីយេន** បានដល់ បុរសអាជានេយ្យ អធិប្បាយថា ជាបុគ្គលដែលព្រះអនុរុទ្ធអ្នកធ្វើកិច្ចស្រេចហើយ ឈ្មោះថា **សាធុនា** ព្រោះធ្វើនូវប្រយោជន៍ខ្លួន និងប្រយោជន៍អ្នកដទៃឲ្យសម្រេច ធ្វើ គឺទូន្មានឲ្យជាបុគ្គលល្អ គឺឲ្យសម្រេចប្រយោជន៍ទាំង ២ ម្យ៉ាងទៀត ធ្វើ គឺទូន្មានឲ្យជាអ្នកដឹងរបៀសដោយល្អ និងទូន្មានហើយដោយវិជ្ជាដ៏ក្រៃលែង ឲ្យសិក្សាហើយដោយការឲ្យសម្រេចភាពជាអសេក្ខៈ ។

សុមនសាមណេរនោះ បានសម្រេចនូវការស្ងប់ក្រៃលែង គឺព្រះនិព្វានសម្រេចហើយដោយការសម្រេចអរហត្តមគ្គ ធ្វើឲ្យជាក់ច្បាស់ គឺធ្វើឲ្យប្រចក្សដល់ខ្លួននូវអរហត្តផលដែលជាធម៌មិនកម្រើក ព្រោះជាអ្នកដល់នូវភាពប្រាថ្នាតិចក្រៃលែង ទើបប្រាថ្នា គឺបំណងថា បុគ្គលណាម្នាក់ កុំគប្បីស្គាល់អញថា បុរសនេះមានអាសវៈអស់ហើយ ឬថា មានអភិញ្ញា ៦ ដូច្នេះឡើយ ។៚

**អដ្ឋកថាសុមនត្ថេរគាថា ចប់**

# សុត្តន្តបិដក

## ឆ្ឋាតកមុនិត្ថេរគាថា

[ ២២១ ] ( ព្រះសាស្ដាត្រាស់សួរថា ) ម្នាលភិក្ខុ អ្នកត្រូវរោគខ្យល់គ្របសង្កត់ហើយ កាលនៅក្នុងព្រៃធំ មានគោចរលះបង់ហើយ ជាព្រៃសៅហ្មង នឹងធ្វើដូចម្ដេចកើត ។

( ព្រះឆ្ឋាតកមុនិត្ថេរទូលថា ) ខ្ញុំព្រះអង្គមានបីតិ និងសុខបរិបូណ៌ផ្សាយទៅកាន់រាងកាយ ហើយអត់សង្កត់នូវអារម្មណ៍ដ៏សៅហ្មង ទាំងនៅក្នុងព្រៃធំ ។ ខ្ញុំព្រះអង្គចម្រើនពោជ្ឈង្គ ៧ ផង ឥន្ទ្រិយផង ពលផង បរិបូណ៌ដោយឈានដ៏សុខុម ជាអ្នកមិនមានអាសវៈ ។ ខ្ញុំព្រះអង្គបានពិចារណាឃើញចិត្តដ៏ស្អាត ផុតស្រឡះចាកកិលេស ជាចិត្តមិនល្អក់រឿយៗ ជាអ្នកមិនមានអាសវៈ ។ អាសវៈទាំងឡាយណា ខាងក្នុងក្ដី ខាងក្រៅក្ដី ចាក់ដោតហើយដល់ខ្ញុំព្រះអង្គ អាសវៈទាំងអស់នោះ ខ្ញុំព្រះអង្គបានផ្ដាច់ផ្ដិលមិនឲ្យសេសសល់ មិនកើតទៅទៀតបានទេ ។ បញ្ចក្ខន្ធ ខ្ញុំព្រះអង្គកំណត់ដឹងហើយ ខ្ញុំព្រះអង្គកាត់ឫសគល់ដាច់ហើយ ខ្ញុំព្រះអង្គបានដល់នូវការអស់ទុក្ខហើយ ឥឡូវនេះ ភពថ្មីមិនមានទៀតទេ ។

ឆ្ឋាតកមុនិត្ថេរ

# អដ្ឋកថា

## ឆ្នាតកមុនិត្ថេរគាថា

[ ២២១ ] គាថារបស់ព្រះឆ្នាតកមុនិត្ថេរ មានពាក្យផ្តើមថា **វាត-រោគាភិនីតោ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងក្រុងរាជគ្រឹះ ចម្រើនវ័យហើយសម្រេចក្នុងវិជ្ជា ( សិល្បសាស្ត្រ ១៨ យ៉ាង ) ជាដើម មហាជនស្គាល់ទូទៅថា **ឆ្នាតកៈ** ព្រោះប្រកបដោយលក្ខណៈរបស់អ្នកឆ្អែតហើយ ( អ្នកអស់កិលេស ) ។

ឆ្នាតកកុលបុត្តនោះ បួសជាតាបស ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយគ្រាប់ស្ពួយ ក្នុងដងព្រៃ ឆ្ងាយអំពីក្រុងរាជគ្រឹះប្រមាណ ៣ យោជន៍ ជាអ្នកបម្រើភ្លើង ។ ព្រះសាស្តាទ្រង់ឃើញឧបនិស្ស័យនៃអរហត្តរបស់កុលបុត្តនេះ ដែលឆេះសន្ធោសន្ធៅខាងក្នុងហទយៈ ដូចប្រទីបឆេះសន្ធោសន្ធៅក្នុងថ្នាំង ទើបយាងទៅកាន់អាស្រមរបស់កុលបុត្តនោះ ។

កុលបុត្តនោះ បានឃើញព្រះមានព្រះភាគហើយ មានចិត្តត្រេកអរ បង្អោនភោជនចូលទៅប្រគេន តាមបែបអាហារដែលខ្លួនបរិភោគ ។ ព្រះមុនីទ្រង់សោយអាហារនោះ ក្នុងថ្ងៃទី ២-៣ ក៏ដូច្នោះ ។ ក្នុងថ្ងៃទី ៤ ក៏ក្រាបទូលថា បពិត្រព្រះមានព្រះភាគ ទ្រង់ជាបុគ្គលសុខុមាលជាតិ ហេតុអ្វី ទើបញ៉ាំង

នូវអត្តភាពឲ្យប្រព្រឹត្តទៅដោយអាហារបែបនេះបាន ។ ព្រះសាស្តា កាល ទ្រង់ប្រកាសគុណអរិយសន្តោសដល់តាបស ទើបទ្រង់សម្តែងធម៌ ។

តាបសបានស្តាប់ធម៌នោះហើយ បានជាព្រះសោតាបន្ន បួសហើយ សម្រេចអរហត្ត ។ ព្រះមានព្រះភាគ កាលធ្វើតាបសនោះ ឲ្យតាំងនៅក្នុង អរហត្តហើយ ក៏យាងចៀសចេញទៅ ។ តាបសនៅអាស្រ័យក្នុងទីនោះឯង ក្នុងកាលក្រោយមក ក៏ត្រូវរោគខ្យល់បៀតបៀន ។ ព្រះសាស្តាបានយាងទៅ ក្នុងទីនោះ ដើម្បីត្រាស់សួរវិហារធម៌របស់ព្រះថេរៈ ដោយបដិសណ្ឋារៈ ទើប ត្រាស់ព្រះគាថានេះថា

ម្នាលភិក្ខុ អ្នកត្រូវរោគខ្យល់ គ្របសង្កត់ហើយ កាលនៅក្នុងព្រៃ ធំ មានគោចរលះបង់ហើយ ជាព្រៃសៅហ្មង នឹងធ្វើដូចម្តេចកើត ដូច្នេះ ។

គ្រានោះ ព្រះថេរៈក៏ប្រកាសវិហារធម៌របស់ខ្លួនដល់ព្រះសាស្តា ដោយ គាថាទាំងនេះថា

ខ្ញុំព្រះអង្គមានបីតិ និងសុខបរិបូណ៌ ផ្សាយទៅកាន់រាងកាយ ហើយអត់សង្កត់នូវអារម្មណ៍ដ៏សៅហ្មង ទាំងនៅក្នុងព្រៃធំ ។ ខ្ញុំ ព្រះអង្គចម្រើនពោជ្ឈង្គ ៧ ផង ឥន្ទ្រិយផង ពលផង បរិបូណ៌ ដោយឈានដ៏សុខុម ជាអ្នកមិនមានអាសវៈ ។ ខ្ញុំព្រះអង្គបាន ពិចារណាឃើញចិត្តដ៏ស្អាត ផុតស្រឡះចាកកិលេស ជាចិត្តមិន ល្អក់រឿយៗ ជាអ្នកមិនមានអាសវៈ ។ អាសវៈទាំងឡាយណា

ខាងក្នុងក្តី ខាងក្រៅក្តី ចាក់ដោតហើយ ដល់ខ្ញុំព្រះអង្គ អាសវៈទាំងអស់នោះ ខ្ញុំព្រះអង្គបានផ្តាច់ផ្តិលមិនឲ្យសេសសល់ មិនកើតទៅទៀតបានទេ ។ បញ្ចក្ខន្ធ ខ្ញុំព្រះអង្គកំណត់ដឹងហើយ ខ្ញុំព្រះអង្គកាត់ឫសគល់ដាច់ហើយ ខ្ញុំព្រះអង្គបានដល់នូវការអស់ទុក្ខហើយ ឥឡូវនេះ ភពថ្មីមិនមានទៀតទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឈានសោខុមសម្បន្នោ** បានដល់ ដែលប្រកបដោយភាវៈដ៏ល្អិតនៃឈាន ។ អរូបជ្ឈាន ឈ្មោះថា ឈានសុខុម ។ ព្រោះដូច្នោះ ទើបលោកអធិប្បាយថា ខ្ញុំជាអ្នកបានសមាបត្តិ ៨ ។ ដោយបទថា **ឈានសោខុម្មសម្បន្នោ** បានដល់ ជាអ្នកប្រកបដោយភាវៈល្អិតល្អន់នៃឈាន ។ អរូបជ្ឈាន ឈ្មោះថា ឈានដ៏សុខុម ព្រោះហេតុនោះ ស្មើគ្នានឹងប្រាប់ថា ខ្ញុំជាអ្នកបានសមាបត្តិ ៨ ។ ដោយបទថា **ឈានសោខុម្ម-សម្បន្នោ** នេះ ព្រះថេរៈសម្តែងថា លោកជាឧភតោភាគវិមុត្តិ ។ ចំណែកអាចារ្យមួយពួកទៀតពោលថា ដោយបទថា **សោខុម្មំ** នេះ លោកបំណងយកអធិប្បញ្ញាសិក្ខា ក្នុងអរហត្តមគ្គ និងអរហត្តផល ។ បន្ទាប់អំពីនោះ លោកប្រកាសដល់ភាពដែលខ្លួនជាឧភតោភាគវិមុត្តិ ដោយ **ឈាន** សព្ទ ។

បទថា **វិប្បមុត្តំ កិលេសេហិ** សេចក្តីថា ឈ្មោះថា រួចផុតចាក កិលេសទាំងពួង ព្រោះបដិបស្សទ្ធិវិមុត្តិ ឈ្មោះថា **សុទ្ធចិត្តំ** ព្រោះរួចចាក ផុតកិលេសទាំងពួងនោះឯង ឈ្មោះថា **អនាវិលំ** ព្រោះភាពជាអ្នកមានសេចក្តី ត្រិះរិះមិនល្អក់ ដោយបទទាំង ៣ លោកពោលដល់ចិត្តដែលសម្បយុត្តដោយ អរហត្តផលនោះឯង ។

ពាក្យដ៏សេស មានន័យដូចពោលហើយ ខាងដើមនោះឯង គាថានេះ បានជាការព្យាករណ៍អរហត្តផលរបស់ព្រះថេរៈ ដោយប្រការដូច្នេះ ។ល។

**អដ្ឋកថា ឆ្ឆាតកមុនិត្ថេរគាថា ចប់**

# សុត្តន្តបិដក

## ព្រហ្មទត្តត្ថេរគាថា

[ ២២២ ] បុគ្គលមិនមានសេចក្តីក្រោធ បានទូន្មានចិត្ត ចិញ្ចឹមជីវិតស្មើ ( ត្រូវ ) មានចិត្តរួចចាកអាសវៈ ព្រោះដឹងដោយប្រពៃ មានចិត្តស្ងប់ចាកកិលេស មិនញាប់ញ័រដោយលោកធម៌ នឹងមានសេចក្តីក្រោធពីណា ។ បុគ្គលណាខឹងតបចំពោះបុគ្គលដែលខឹង បុគ្គលនោះ នឹងមានសេចក្តីអាក្រក់ ព្រោះតែការខឹងតបនោះ បុគ្គលមិនខឹងតបនឹងបុគ្គលដែលខឹង ឈ្មោះថាឈ្នះសង្គ្រាមដែលគេឈ្នះបានដោយក្រ ។ បុគ្គលណាដឹងថា បុគ្គលដទៃខឹងហើយ មានស្មារតីខំអត់សង្កត់ បុគ្គលនោះ ឈ្មោះថា ប្រព្រឹត្តនូវប្រយោជន៍ ដើម្បីជនទាំង ២ គឺដើម្បីខ្លួន ១ ដើម្បីអ្នកដទៃ ១ ។ ពួកជនមិនឈ្លាសក្នុងធម៌ រមែងសម្គាល់ជនទាំង ២ គឺខ្លួន ១ អ្នកដទៃ ១ ដែលជាអ្នកព្យាបាលព្យាធិ គឺក្រោធបាន ថាជាមនុស្សពាល ។ បើសេចក្តីក្រោធកើតឡើងដល់អ្នក ចូរអ្នកពិចារណានូវឱវាទ ដែលឧបមាដោយរណារ បើចំណង់ក្នុងរសកើតឡើងដល់អ្នក ចូរអ្នករឭកនូវឱវាទដែលឧបមាដោយការបរិភោគសាច់កូន ។ បើចិត្តរបស់អ្នកស្ទុះទៅក្នុងកាមទាំងឡាយក្តី ក្នុងភពទាំងឡាយក្តី ចូរអ្នកប្រញាប់សង្កត់សង្កិនចិត្តនោះដោយសតិ ដូចជាបុរសសង្កត់សង្កិនគោកាច ដែលស៊ីសំណាប ។

ព្រហ្មទត្តត្ថេរ

# អដ្ឋកថា

## ព្រហ្មទត្តត្ថេរគាថា

[ ២២២ ] គាថារបស់ព្រះព្រហ្មទត្តត្ថេរ មានពាក្យផ្តើមថា **អក្កោធស្ស** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងពុទ្ធុប្បាទនេះ កើតជាឱរសនៃព្រះបាទកោសល ក្នុងនគរសាវត្ថី មាននាមថា **ព្រហ្មទត្ត** ។ ព្រហ្មទត្តនោះ ចម្រើនវ័យហើយ បានឃើញពុទ្ធានុភាព ក្នុងកាលឆ្លងវត្តជេតពន មាននូវសទ្ធាបួសហើយ ប្រកបវិបស្សនាកម្មដ្ឋាន បានអភិញ្ញា ៦ មួយអន្លើដោយបដិសម្ភិទា ។ ថ្ងៃមួយ ព្រាហ្មណ៍ម្នាក់ជេរព្រះថេរៈ ដែលកំពុងនិមន្តបិណ្ឌបាតក្នុងព្រះនគរ ព្រះថេរៈបានស្តាប់ការជេរនោះក៏នៅស្ងៀម នៅតែត្រាច់បិណ្ឌបាតនោះឯង ព្រាហ្មណ៍ក៏នៅតែជេរហើយជេរទៀត ។ ពួកមនុស្សក៏និយាយនឹងព្រាហ្មណ៍ ដែលកំពុងជេរយ៉ាងនេះថា ព្រះថេរៈនេះមិនពោលនូវពាក្យណាមួយ ។

ព្រះថេរៈបានស្តាប់ដូច្នោះ កាលនឹងសម្តែងធម៌ដល់មនុស្សទាំងនោះ ក៏ពោលគាថាទាំងនេះថា

បុគ្គលមិនមានសេចក្តីក្រោធ បានទូន្មានចិត្ត ចិញ្ចឹមជីវិតស្មើ
( ត្រូវ ) មានចិត្តរួចចាកអាសវៈ ព្រោះដឹងដោយប្រពៃ មាន
ចិត្តស្ងប់ចាកកិលេស មិនញាប់ញ័រដោយលោកធម៌ នឹងមាន
សេចក្តីក្រោធពីណា ។ បុគ្គលណា ខឹងតបចំពោះបុគ្គលដែលខឹង

បុគ្គលនោះ នឹងមានសេចក្តីអាក្រក់ ព្រោះតែការខឹងតបនោះ បុគ្គលមិនខឹងតបនឹងបុគ្គលដែលខឹង ឈ្មោះថាឈ្នះសង្គ្រាមដែលគេឈ្នះបានដោយក្រ ។ បុគ្គលណាដឹងថា បុគ្គលដទៃខឹងហើយ មានស្មារតីទំអត់សង្កត់ បុគ្គលនោះ ឈ្មោះថា ប្រព្រឹត្តនូវប្រយោជន៍ ដើម្បីជនទាំង ២ គឺដើម្បីខ្លួន ១ ដើម្បីអ្នកដទៃ ១ ។ ពួកជនមិនឈ្លាសក្នុងធម៌ រមែងសម្គាល់ជនទាំង ២ គឺខ្លួន ១ អ្នកដទៃ ១ ដែលជាអ្នកព្យាបាលព្យាធិ គឺក្រោធបាន ថាជាមនុស្សពាល ។ បើសេចក្តីក្រោធកើតឡើងដល់អ្នក ចូរអ្នកពិចារណានូវឱវាទ ដែលឧបមាដោយរណារ បើចំណង់ក្នុងរសកើតឡើងដល់អ្នក ចូរអ្នករឭកនូវឱវាទ ដែលឧបមាដោយការបរិភោគសាច់កូន ។ បើចិត្តរបស់អ្នក ស្ទុះទៅក្នុងកាមទាំងឡាយក្តី ក្នុងភពទាំងឡាយក្តី ចូរអ្នកប្រញាប់សង្កត់សង្កិនចិត្តនោះដោយសតិ ដូចជាបុរសសង្កត់សង្កិនគោកាច ដែលស៊ីសំណាបដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អក្កោធស្ស** បានដល់ ប្រាសចាកសេចក្តីក្រោធ គឺកាត់សេចក្តីក្រោធបានជាសមុច្ឆេទហើយដោយមគ្គ ។

បទថា **កុតោ កោធោ** សេចក្តីថា ការក្រោធដែលជាហេតុគប្បីកើតឡើងបានអំពីណា អធិប្បាយថា មិនមានហេតុឲ្យកើតសេចក្តីក្រោធនោះ ។ បទថា **ទន្តស្ស** បានដល់ ទូន្មានខ្លួនហើយ ដោយការទូន្មានដ៏ឧត្តម គឺទូន្មាន

ដោយអរហត្តមគ្គ ។

បទថា **សមជីវិនោ** បានដល់ លះនូវការមិនស្មើផ្លូវកាយជាដើម ដោយប្រការទាំងពួង ចិញ្ចឹមជីវិតស្មើដោយកាយជាដើម គឺប្រព្រឹត្តទៅដោយប្រពៃ ដោយសម្បជញ្ញៈ ដែលជាទីតាំងនៃសេចក្តីស្ងប់ ។

បទថា **សម្មទញ្ញា វិមុត្តស្ស** បានដល់ ជាអ្នករួចផុតចាកអាសវៈទាំងពួង ព្រោះដឹងដោយប្រពៃ គឺព្រោះដឹងនូវធម៌ មានអភិញ្ញេយ្យធម៌ជាដើម ព្រោះហេតុនោះឯង ទើបឈ្មោះថា ជាអ្នកស្ងប់ ព្រោះស្ងប់រម្ងាប់នូវសេចក្តីក្រវល់ក្រវាយ និងការក្តៅក្រហាយ គឺកិលេសទាំងពួង ។

ព្រះថេរៈ កាលប្រាប់នូវភាពដែលខ្លួនមិនក្រោធ និងហេតុនៃការមិនក្រោធនោះ ដោយអាងអរហត្តផលថា ជាអ្នកមិនញាប់ញ័រ ព្រោះដល់នូវលក្ខណៈនៃតាទិបុគ្គលក្នុងឥដ្ឋារម្មណ៍ជាដើម គឺអស់អាសវៈហើយ សេចក្តីក្រោធនឹងកើតឡើងអំពីណា ដូច្នេះហើយ ឥឡូវនេះ កាលនឹងពោលធម៌ដោយសម្តែងទោស និងអានិសង្សក្នុងសេចក្តីក្រោធ និងការមិនក្រោធ ទើបពោលពាក្យជាដើមថា **តស្សេវ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **យោ កុទ្ធំ បដិកុជ្ឈតិ** សេចក្តីថា បុគ្គលដែលក្រោធចំពោះបុគ្គលដែលក្រោធតប គឺអ្នកដែលខឹងក្រោធលើខ្លួននោះឯងអាក្រក់ជាង គឺមិនល្អជាង ដោយត្រូវវិញ្ញូជនតិះដៀលក្នុងលោកនេះ និងដោយទុក្ខក្នុងនរក ក្នុងលោកខាងមុខ ព្រោះមានការក្រោធតប ជេរតប និងប្រហារតបជាដើមនោះ ។ មិនមានពាក្យដែលគួរពោលថា បុគ្គលដែលមិន

ក្រោធ ព្រោះបុគ្គលដែលត្រូវសេចក្តីក្រោធនឹងអាក្រក់ ( មានបាប ) ។ ឯអាចារ្យពួកខ្លះអធិប្បាយថា បុគ្គលណាក្រោធ ព្រោះប្រារព្ធបុគ្គលដែលមិនក្រោធ ឬបុគ្គលដែលក្រោធតប ។

បទថា **កុទ្ធំ អប្បដិកុជ្ឈន្តោ** សេចក្តីថា ឯបុគ្គលណាដឹងថា បុគ្គលនេះក្រោធ ត្រូវសេចក្តីក្រោធគ្របសង្កត់ ហើយមិនក្រោធតបនឹងបុគ្គលដែលក្រោធ អត់ធន់បាន បុគ្គលនោះឈ្មោះថា ឈ្នះសង្គ្រាមកិលេស ដែលឈ្នះបានដោយក្រ ។ ព្រះថេរៈកាលសម្តែងថា បុគ្គលនោះឈ្នះសង្គ្រាម គឺកិលេសតែម្យ៉ាងប៉ុណ្ណោះក៏មិនមែន ដោយពិត ថែមទាំងបានធ្វើប្រយោជន៍ និងសេចក្តីចម្រើនដល់ជនទាំង ២ ទើបពោលថា **ឧភិន្នមត្ថំ ។បេ។ ឧបសម្មតិ** ដូច្នេះ បុគ្គលណាដឹងបុគ្គលដទៃក្រោធថា បុគ្គលនោះ ត្រូវសេចក្តីក្រោធគ្របសង្កត់ ទើបមេត្តាចំពោះបុគ្គលនោះ ឬដាក់ចិត្តជាឧបេក្ខា ជាអ្នកមានសតិសម្បជញ្ញៈ ស្ងប់រម្ងាប់ គឺអត់ធន់បាន មិនក្រោធតប បុគ្គលនោះ ឈ្មោះថា ប្រព្រឹត្តប្រ-យោជន៍ ដែលនាំសេចក្តីសុខក្នុងលោកទាំង ២ មកឲ្យដល់ជនទាំង ២ គឺដល់ខ្លួន និងដល់អ្នកដទៃ ។

បទថា **ឧភិន្នំ តិកិច្ឆន្តំ តំ** សេចក្តីថា ជនទាំងឡាយដែលមិនឈ្លាសក្នុងធម៌ គឺក្នុងអាចារដ៏ប្រសើរ ជាបុគ្គលល្ងង់ខ្លៅ រមែងសម្គាល់បុគ្គលដែលព្យាបាលដោយការព្យាបាលព្យាធិ គឺសេចក្តីក្រោធ អត់ធន់ចំពោះជនទាំង ២ ចំណែក គឺចំពោះខ្លួន និងអ្នកដទៃ បុគ្គលមិនធ្វើអ្វីមួយដល់បុគ្គលអ្នកជេរខ្លួន ប្រហារខ្លួនថា បុគ្គលនេះជាបុគ្គលមិនឈ្លាស អធិប្បាយថា ទុំះជាសេចក្តី

សម្គាល់ ដោយមិនមែនជាឧបាយនៃជនទាំងនោះ ។ អាចារ្យពួកខ្លះពោលថា **តិកិច្ឆនំ** ការរក្សាព្យាបាលដូច្នេះក៏មាន អធិប្បាយថា ជាសភាពនៃការព្យាបាល ។

ព្រាហ្មណ៍ដែលជេរបានស្តាប់ធម៌ ដែលព្រះថេរៈពោលហើយយ៉ាងនោះ ជាអ្នកមានចិត្តសង្វេគ និងមានចិត្តជ្រះថ្លា សូមខមាទោសនឹងព្រះថេរៈហើយ បួសក្នុងសម្នាក់ព្រះថេរៈនោះឯង ។ ព្រះថេរៈកាលឲ្យកម្មដ្ឋានដល់ព្រាហ្មណ៍ ទើបគិតថា ការចម្រើនមេត្តាភាវនា សមគួរដល់ភិក្ខុនេះ ទើបឲ្យមេត្តាកម្មដ្ឋាន កាលនឹងសម្តែងវិធីពិចារណាជាដើម ក្នុងកាលកើតសេចក្តីក្រោធចោមរោមជាដើម ទើបពោលពាក្យថា បើសេចក្តីក្រោធកើតឡើងដល់អ្នក ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **ឧប្បជ្ជេ តេ សចេ** សេចក្តីថា កាលបើអ្នកបំពេញកម្មដ្ឋាន សេចក្តីក្រោធដែលសន្សំមកអស់កាលយូរ ព្រោះបុគ្គលណាគប្បីកើតឡើង ដើម្បីរម្ងាប់សេចក្តីក្រោធនោះ ចូរអ្នករឭកដល់ឱវាទដែលឧបមាដោយរណារ ដែលព្រះសាស្តាត្រាស់ថា

ម្នាលភិក្ខុទាំងឡាយ បើពួកចោរ ដែលប្រព្រឹត្តអាក្រក់ នាំគ្នាអារ

អវយវៈតូចធំរបស់អ្នកទាំងឡាយ ដោយរណារ ដែលមានដង ទាំងសងខាង ភិក្ខុណាមួយ ញុំាងចិត្តឲ្យប្រទូស្តចំពោះចោរទាំងអម្បាលនោះ ភិក្ខុនោះ មិនឈ្មោះថា ជាអ្នកធ្វើតាមសាសនារបស់តថាគត ដោយការមិនអត់សង្កត់នោះឡើយ ដូច្នេះ ។

បទថា **ឧប្បជ្ជេ តេ រសេ តណ្ហា** សេចក្តីថា បើតណ្ហា គឺការត្រេកអរក្នុងរស មានរសផ្អែមជាដើមកើតឡើងដល់អ្នកសោត ដើម្បីរម្ងាប់នូវសេចក្តីត្រេកអរនោះ ចូររឭក គឺរឭកដល់ឱវាទដែលឧបមាដោយសាច់កូន ដែលត្រាស់យ៉ាងនេះថា

ភរិយា និងស្វាមីទំពាស៊ីនូវសាច់កូន ដើម្បីឆ្លងផុតផ្លូវកន្តារប៉ុណ្ណោះ មិនមែនដើម្បីឆ្ងាញ់ យ៉ាងណា សូម្បីកុលបុត្តក៏ដូច្នោះ បួសហើយ បរិភោគនូវបិណ្ឌបាតដើម្បី ។បេ។ ការនៅជាផាសុក ដូច្នេះ ។

បទថា **សចេ ធាវតិ តេ ចិត្តំ** សេចក្តីថា បើចិត្តរបស់អ្នកមនសិការដោយអយោនិសោ រសាត់ទៅ ផ្សាយទៅ ស្ទុះទៅក្នុងកាម គឺកាមគុណ ៥ ដោយអំណាចឆន្ទរាគ និងក្នុងបណ្តាភពទាំងឡាយ មានកាមភពជាដើមដោយអំណាចប្រាថ្នាភព ។

បទថា **ខិប្បំ និគ្គណ្ហ សតិយា កិដ្ឋាទំ វិយ ទុប្បសុំ** សេចក្តីថា កាលមិនឲ្យចិត្តស្ទុះទៅយ៉ាងនោះ ចូរយកសតិ បានដល់ ខ្សែ គឺសតិចងត្រង់បង្គោល គឺសមាធិ សង្កត់សង្កិនដោយរហ័ស ដូចបុរសយកខ្សែចងសត្វដែលកាច គឺគោកាច ដែលចូលចិត្តស៊ីសំណាប គឺស៊ីសម្ទូងត្រង់បង្គោលធ្វើឲ្យនៅក្នុងអំណាចរបស់ខ្លួន ដូច្នោះ គឺចូរទូន្មានដោយការឲ្យចិត្តអស់ព្យសន៍ព្រោះប្រាសចាកកិលេស ឯអាចារ្យពួកខ្លះពោលថា ព្រះថេរៈនៅជាបុថុជ្ជននៅឡើយ អត់ធន់នឹងការជេរបាន កាលប្រកាសនូវគុណដ៏ប្រសើរ ទើបពោលធម៌ដល់អ្នកទាំងនោះ ក្រោយមក ទើបទូន្មានខ្លួន ដោយគាថា ២ ចម្រើនវិបស្សនា សម្រេចអរហត្ត កាលព្យាករអរហត្តផល ទើបពោលគាថាទាំងនេះឯង ។ ៚

## អដ្ឋកថា ព្រហ្មទត្តត្ថេរគាថា ចប់

# សុត្តន្តបិដក

## សិរិមណ្ឌត្ថេរគាថា

[ ២២៣ ] ភ្លៀង គឺអាបត្តិ តែងធ្លាក់ស្រោចនូវបុគ្គល អ្នកបិទបាំងអាបត្តិទុក មិនធ្លាក់ស្រោចនូវបុគ្គល អ្នកបើកអាបត្តិ ព្រោះហេតុនោះ បុគ្គលត្រូវបើកអាបត្តិ ដែលខ្លួនបិទបាំងហើយ កាលបើធ្វើយ៉ាងនេះ ទើបភ្លៀង គឺអាបត្តិ មិនធ្លាក់ស្រោចនូវបុគ្គលនោះ ។ សត្វលោកត្រូវមច្ចុកម្ចាត់បង់ហើយ ត្រូវជរាចោមរោមហើយ ត្រូវសរ គឺតណ្ហាមុតហើយ ត្រូវឥច្ឆាឲ្យក្តៅក្រហាយហើយសព្វកាល ។ សត្វលោក ត្រូវមច្ចុកម្ចាត់បង់ហើយ ត្រូវជរាបិទបាំងហើយ ជាសត្វឥតមានទីពឹង តែងលំបាកជានិច្ច ដូចជាមនុស្សអ្នកធ្វើកំហុសនោះ ដែលមានអាជ្ញាសម្រេចហើយ ។ មច្ចុ ព្យាធិ និងជរាទាំង ៣ នេះ ដូចជាគំនរភ្លើងកំពុងរាលមក កម្លាំងដើម្បីទប់ទល់មិនមាន សន្ទុះសម្រាប់រត់ចេញក៏មិនមាន ។ បុគ្គលគប្បីធ្វើថ្ងៃ កុំឲ្យឥតអំពើ ដោយកិច្ចតិចក្តី ច្រើនក្តី រាត្រីរមែងអស់ទៅយ៉ាងណាៗ ជីវិតរបស់បុគ្គលនោះ រមែងថយទៅយ៉ាងនោះៗដែរ ។ រាត្រីខាងក្រោយ របស់បុគ្គលអ្នកដើរក្តី ឈរក្តី អង្គុយក្តី ដេកក្តី រមែងកន្ទើញចូលមកជិត កាលនេះ មិនមែនជាកាលគួរអ្នកប្រមាទទេ ។

**សិរិមណ្ឌត្ថេរ**

# អដ្ឋកថា

## សិរិមណ្ឌត្ថេរគាថា

[ ២២៣ ] គាថារបស់ព្រះសិរិមណ្ឌត្ថេរ មានពាក្យផ្ដើមថា **ឆន្នមតិ-វស្សតិ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងសុង្សុមារគិរនគរ ។ បានឈ្មោះថា **សិរិមណ្ឌៈ** ចម្រើនវ័យហើយ ក្នុងកាលព្រះមានព្រះភាគគង់នៅក្នុងភេសកឡាវ័ន ទើបចូលទៅគាល់ព្រះសាស្ដា ស្ដាប់ធម៌ បាននូវសទ្ធាហើយបួស បានឧបសម្បទា ធ្វើសមណធម៌ ។ ក្នុងថ្ងៃឧបោសថមួយ អង្គុយក្នុងទីសម្ដែងបាតិមោក្ខ ក្នុងកាលចប់និទានុទ្ទេស ពិចារណាអត្ថនៃបាលីថា ភិក្ខុនោះធ្វើឲ្យជាក់ច្បាស់ ( នូវអាបត្តិ ) ហើយ រមែងមានផាសុក ធ្វើទុកក្នុងចិត្តដល់សេចក្ដីនេះថា ភិក្ខុបិទបាំង មិនធ្វើឲ្យជាក់ច្បាស់នូវអាបត្តិដែលត្រូវហើយ រមែងត្រូវអាបត្តិបន្ថែមទៀត ដោយហេតុនោះ ភិក្ខុនោះរមែងមិនមានផាសុក ចំណែកភិក្ខុដែលធ្វើឲ្យជាក់ច្បាស់ ហើយដោះនូវអាបត្តិតាមធម៌ រមែងមានសេចក្ដីសុខ ដូច្នេះ ទើបជ្រះថ្លាថា គួរអស្ចារ្យ ពាក្យប្រៀនប្រដៅរបស់ព្រះសាស្ដាបរិសុទ្ធពិត សង្កត់នូវបីតិ ដែលកើតឡើងយ៉ាងនោះ ហើយចម្រើនវិបស្សនា បានសម្រេចអរហត្ត ពិចារណាបដិបទារបស់ខ្លួនហើយមានចិត្តជ្រះថ្លា កាលនឹងឲ្យឱវាទដល់ភិក្ខុទាំងឡាយ ទើបពោលគាថាទាំង-ឡាយថា

ភ្លៀង គឺអាបត្តិ តែងធ្លាក់ស្រោចនូវបុគ្គល អ្នកបិទបាំងអាបត្តិទុក មិនធ្លាក់ស្រោចនូវបុគ្គលអ្នកបើកអាបត្តិ ព្រោះហេតុនោះ បុគ្គល ត្រូវបើកអាបត្តិ ដែលខ្លួនបិទបាំងហើយ កាលបើធ្វើយ៉ាងនេះ ទើបភ្លៀង គឺអាបត្តិមិនធ្លាក់ស្រោចនូវបុគ្គលនោះ ។ សត្វលោក ត្រូវមច្ចុកម្ចាត់បង់ហើយ ត្រូវជរាចោមរោមហើយ ត្រូវសរ គឺតណ្ហា មុតហើយ ត្រូវឥច្ឆាឲ្យក្តៅក្រហាយហើយសព្វកាល ។ សត្វ លោកត្រូវមច្ចុកម្ចាត់បង់ហើយ ត្រូវជរាបិទបាំងហើយ ជាសត្វ ឥតមានទីពឹង តែងលំបាកជានិច្ច ដូចជាមនុស្សអ្នកធ្វើកំហុសនោះ ដែលមានអាជ្ញាសម្រេចហើយ ។ មច្ចុ ព្យាធិ និងជរាទាំង ៣ នេះ ដូចជាគំនរភ្លើងកំពុងរាលមក កម្លាំងដើម្បីទប់ទល់មិនមាន សន្ទុះ សម្រាប់រត់ចេញ ក៏មិនមាន ។ បុគ្គលគប្បីធ្វើថ្ងៃ កុំឲ្យឥតអំពើ ដោយកិច្ចតិចក្តី ច្រើនក្តី រាត្រី រមែងអស់ទៅយ៉ាងណាៗ ជីវិត របស់បុគ្គលនោះ រមែងថយទៅយ៉ាងនោះៗ ដែរ ។ រាត្រីខាង ក្រោយរបស់បុគ្គលអ្នកដើរក្តី ឈរក្តី អង្គុយក្តី ដេកក្តី រមែង កន្លើញចូលមកជិត កាលនេះ មិនមែនជាកាលគួរអ្នកប្រមាទទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឆន្នំ** បានដល់ ទុច្ចរិតដែលបិទបាំង គឺមិន បើក មិនប្រកាសតាមសេចក្តីពិត ។

បទថា **អតិវស្សតិ** សេចក្តីថា ភ្លៀង គឺអាបត្តិ និងភ្លៀង គឺកិលេស

រមែងធ្លាក់ចុះរហូតសើមជោកជាំ ។ លោកពោលការបិទ គឺហេតុនៃការលិចស្រោចថា ពិតហើយ ការបិទអាបត្តិ ដូចគ្នានឹងភាពជាបុគ្គលអលជ្ជីជាដើមនោះឯង ព្រោះការបិទអាបត្តិ ទើបត្រូវអាបត្តិដទៃអំពីអាបត្តិនោះមួយទៀត ឬត្រូវអាបត្តិបែបនោះដដែលទៀត ឬត្រូវអាបត្តិដែលធ្ងន់ជាងនោះ ។

បទថា **វិវដំ** បានដល់ បើកផ្ចារ គឺមិនបិទបាំង ។ ពាក្យថា **អតិ** ក្នុងបទថា **ឆាតិវស្សតិ** នេះ ត្រឹមតែជាឧបសគ្គ អធិប្បាយថា រមែងមិនលិចស្រោច ។ ក្នុងទីនេះ គប្បីជ្រាបការមិនលិចស្រោចដោយបរិយាយដែលផ្ទុយគ្នានឹងការលិចស្រោចដែលពោលមកហើយ ព្រោះធ្វើចិត្តសន្តានឲ្យបរិសុទ្ធ ។

បទថា **តស្មា** រមែងសំដៅដល់អត្ថដែលពោលហើយនោះឯង ដោយភាពជាហេតុ អធិប្បាយថា ព្រោះភ្លៀង គឺអាបត្តិជាដើមលិចស្រោចនូវទុច្ចរិតដែលបិទបាំង និងព្រោះមិនលិចស្រោចនូវទុច្ចរិតដែលបើកផ្ចារហើយ ។

បទថា **ឆន្នំ វិវរេថ** សេចក្តីថា កាលមានបំណងនឹងបិទ ព្រោះភាវៈដែលជាបុថុជ្ជន អ្នកក៏កុំប្រព្រឹត្តតាមបំណង គប្បីបើក គឺគប្បីធ្វើឲ្យជាក់ច្បាស់ គប្បីសម្តែងអាបត្តិតាមធម៌ ។

បទថា **ឯវំ** បានដល់ ដោយការបើក គឺដោយកិច្ចបដិបត្តិតាមធម៌ ។ បទថា **តំ** បានដល់ ទុច្ចរិតដែលបិទបាំងនោះ ។

បទថា **ឆាតិវស្សតិ** បានដល់ ភ្លៀង គឺអាបត្តិ និងភ្លៀង គឺកិលេសរមែងមិនលិចស្រោច អធិប្បាយថា រមែងញុំាងបុគ្គលឲ្យតាំងនៅក្នុងសេចក្តីបរិសុទ្ធ ។

ឥឡូវនេះ ព្រះថេរៈកាលសម្តែងវត្ថុជាទីតាំងនៃសេចក្តីសង្វេគដែលជាហេតុនៃការបើទបាំងថា គប្បីធ្វើខ្លួនឲ្យបរិសុទ្ធដោយឥតសេសសល់ ដោយរហ័ស មិនគួរធ្វើសេចក្តីប្រមាទ ទើបពោលពាក្យជាដើមថា សត្វលោកត្រូវមច្ចុកម្ចាត់បង់ហើយ ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **មច្ចុនាព្ភាហតោ លោកោ** សេចក្តីថា សត្វលោកទាំងអស់នេះ ត្រូវមច្ចុ គឺសេចក្តីស្លាប់ ដែលមានប្រក្រតីធ្វើសត្វឲ្យធ្លាក់ចូលក្នុងវដ្តៈទាំងពួងកម្ចាត់ហើយ ដូចចោរត្រូវពេជ្ឈឃាតប្រហារជីវិតដូច្នោះ គឺ រមែងមិនផុតអំពីកណ្តាប់ដៃរបស់មច្ចុនោះ ។

បទថា **ជរាយ បរិវារិតោ** សេចក្តីថា សត្វលោកនេះ ត្រូវជរា ដែលមានកិច្ចនាំចូលទៅរកសេចក្តីស្លាប់តាំងអំពីកើត ចោមរោម គឺគ្របសង្កត់បានដល់ រឹតរុំដោយគំនរនៃជរា ។

បទថា **តណ្ហាសល្លេន ឱតិណ្ណោ** សេចក្តីថា ត្រូវសរ គឺតណ្ហាដែលមានលក្ខណៈប្រកាន់ ទម្លុះ គឺចាក់ទម្លុះហទយៈ ដូចព្រួញលាបថ្នាំពិសមុតចូលក្នុងរាងកាយ ។ ពិតហើយ តណ្ហា លោកហៅថា ព្រួញ ព្រោះកើតនូវការបៀតបៀន ព្រោះចាក់ធ្លុះខាងក្នុង និងព្រោះដកបានលំបាក ។

បទថា **ឥច្ឆាធូបាយិតោ** សេចក្តីថា ត្រូវចំណង់ដែលមានលក្ខណៈប្រាថ្នានូវអារម្មណ៍ផុតពេល ។ ពិតហើយ បុគ្គលប្រាថ្នាអារម្មណ៍នោះ កាលបានអារម្មណ៍តាមដែលប្រាថ្នា ឬមិនបានក្តី រមែងជាអ្នកក្តៅក្រហាយ គឺបានទទួលនូវការក្តៅក្រហាយ ដោយការប្រាថ្នាដែលមានលក្ខណៈតាមផុតពេល

នោះឯង ។

បទថា **សទា** បានដល់ សព្វកាល ។ បទថា **សទា** នេះ គប្បីប្រកបចូលគ្រប់បទ ។

បទថា **បរិក្ខិត្តោ ជរាយ ច** សេចក្តីថា មិនមែនមច្ចុកម្ចាត់តែម្យ៉ាងប៉ុណ្ណោះទេ ដោយពិត ត្រូវជរាចោមរោមផងដែរ អធិប្បាយថា ត្រូវជរាឃុំឃាំង បានដល់ ព័ទ្ធដោយកំពែង គឺជរា មិនកន្លងផុតជរានោះបានឡើយ ។

បទថា **ហញ្ញតិ និច្ចមត្តាណោ** សេចក្តីថា ជាអ្នកមិនមានបុគ្គលណាជ្រកកោន គឺមិនមានអ្នកណាជាទីពឹង ត្រូវបៀតបៀន គឺត្រូវជរា និងមរណៈបៀតបៀនជានិច្ចកាល ដូចអ្វី ដូចចោរត្រូវជាក់អាជ្ញាដូច្នោះ លោកសម្តែងថា ចោរដែលធ្វើនូវអំពើអាក្រក់ ធ្វើនូវកំហុស មិនមានបុគ្គលណាម្នាក់ការពាររមែងក្តៅក្រហាយដោយអាជ្ញា យ៉ាងណា សត្វលោកនេះ រមែងក្តៅក្រហាយដោយជរា និងមរណៈ ក៏ដូច្នោះ ។

បទថា **អាគច្ឆន្តគ្គិក្ខន្ធា** សេចក្តីថា ធម៌ ៣ ប្រការ គឺមច្ចុ ព្យាធិ និងជរា ឈ្មោះថា គំនរភ្លើង ព្រោះអត្ថថា តាមដុត រមែងតាមមកគ្របសង្កត់សត្វលោកនេះ ដូចគំនរភ្លើងធំគ្របសង្កត់ព្រៃធំដូច្នោះ សត្វលោកនេះ មិនមានកម្លាំង គឺឧស្សាហ៍ ដែលជាអ្នកអាចតទល់ គឺគ្របសង្កត់ធម៌ទាំង ៣ នោះបាន មិនមានកម្លាំងដែលនឹងគេចទៅ គឺសត្វលោកនេះ កាលធម៌ មានមច្ចុជាដើមសុះទៅ គ្របសង្កត់ មិនមានកម្លាំងខ្លាំងក្លា ដែលបែរខ្នងរត់ទៅកាន់ទីដែលមច្ចុជាដើមគ្របសង្កត់មិនបាន ។ បើខ្លួនឯងមិនអាចយ៉ាងនោះ កាល

មានបច្ចាមិត្តដែលមានកម្លាំង ៣ ពួក ដែលមិនមានបុគ្គលណាម្នាក់ តតាំង ដោយឧបាយ មានការបញ្ចោតជាដើម បានប្រាកដជានិច្ច សត្វលោកគួរធ្វើដូចម្តេច ឆ្លើយថា បុគ្គលគប្បីធ្វើថ្ងៃ កុំឲ្យឥតអំពើ ដោយកិច្ចតិចក្តី ច្រើនក្តី អធិប្បាយថា គួរធ្វើថ្ងៃ កុំឲ្យទទេឥតប្រយោជន៍ គឺមិនឲ្យទទេ ដោយការដាក់ចិត្តដល់វិបស្សនាតិចខ្លះ គឺប្រព្រឹត្តទៅដោយហោច សូម្បីត្រឹមរយៈកាលពស់ចឹកច្រើនខ្លះ គឺប្រព្រឹត្តទៅអស់ថ្ងៃ និងយប់ ព្រោះរាត្រីរមែងអស់ទៅយ៉ាងណាៗ ជីវិតរបស់បុគ្គលនោះ រមែងថយទៅយ៉ាងនោះៗ ដែរ គឺសត្វលះរាត្រីណាទៅ គឺធ្វើឲ្យវិនាសទៅ ឲ្យអស់ទៅ ជីវិតរបស់សត្វនោះ ក៏អស់ទៅស្មើគ្នានឹងរាត្រីនោះ ដោយហេតុនោះ ទើបលោកសម្តែងថា ឈ្មោះថាការអស់ទៅនៃរាត្រី ជាការអស់ទៅនៃអាយុ ព្រោះរាត្រីនោះ មិនវិលត្រឡប់ ដោយហេតុនោះ ទើបលោកពោល ( ក្នុងអយោឃរជាតក ) ថា

សត្វនៅក្នុងគភ៌ អស់រាត្រីណាមួយជាដំបូង សត្វនោះ ប្រព្រឹត្តទៅ
ដូចជាពពក ដែលតាំងឡើង សត្វនោះ កាលទៅ រមែងមិន
ត្រឡប់វិញទេ ដូច្នេះ ។

មិនមែនដោយអំណាចរាត្រីតែម្យ៉ាងប៉ុណ្ណោះទេ ដោយពិត គួរពិចារណាដល់ការអស់ទៅនៃជីវិត ជាឥរិយាបថផងដែរ ព្រោះហេតុនោះ ទើបលោកពោលថា **ចរតោ** ជាដើម ។

បទថា **ចរតោ** បានដល់ ដើរទៅ ។ បទថា **តិដ្ឋតោ** បានដល់ សម្រេចការឈរ ។ បទថា **អាសីនសយនស្ស វា** កាត់បទជា **អាសីនស្ស**

**សយនស្ស វា** អធិប្បាយថា អង្គុយ ឬដេក ។ អាចារ្យពួកខ្លះពោលថា **អាសីនំ** ដូច្នេះក៏មាន ។ ក្នុងបាលីថា **អាសីនំ** នោះ គប្បីជ្រាបថា ជាទុតិយាវិភត្តិ ប្រើក្នុងអត្ថនៃឆដ្ឋីវិភត្តិ ។

បទថា **ឧបេតិ ចរិមា រត្តិ** សេចក្ដីថា រាត្រីប្រកបដោយចិត្តចុងក្រោយ រមែងចូលដល់ ។ សព្ទថា **រត្តិ** ក្នុងបទនោះ ត្រឹមតែជាមាតិកានៃទេសនា ។ ពេលចុងក្រោយ គឺពេលស្លាប់ រមែងមានដល់បុគ្គលដែលនៅក្នុងឥរិយាបថណាមួយ ក្នុងបណ្ដាឥរិយាបថ មានការដើរជាដើម ដោយហេតុនោះឯង ខណៈនៃឥរិយាបថរបស់បុគ្គលនោះ ទើបធ្វើជីវិតឲ្យអស់ទៅដែរ ។ ព្រោះហេតុនោះ កាលនេះ មិនមែនជាកាលគួរអ្នកប្រមាទទេ គឺពេលនេះ មិនមែនពេលដែលអ្នកគួរប្រមាទ ព្រោះជ្រាបមិនបានថា ការស្លាប់នឹងមិនមាន ក្នុងកាលឈ្មោះនេះ សមដូចព្រះតម្រាស់ ( ក្នុងខុទ្ទកនិកាយ សុត្តនិបាត ) ថា

ជីវិតរបស់សត្វទាំងឡាយ ក្នុងលោកនេះ មិនមានកំណត់ មិនមានអ្នកណាមួយអាចដឹងបាន ជីវិតនោះ ជារបស់ក្រផង តិចផង ប្រកបដោយសេចក្ដីទុក្ខផង ដូច្នេះ ។

អធិប្បាយថា ព្រោះហេតុនោះ បុគ្គលមិនប្រមាទ ទូន្មានខ្លួនយ៉ាងនេះហើយ គប្បីធ្វើសេចក្ដីព្យាយាមរឿយៗ ក្នុងសិក្ខាទាំង ៣ ចុះ ។៚

**អដ្ឋកថា សិរិមណ្ឌត្ថេរគាថា ចប់**

# សុត្តន្តបិដក

## សព្វកាមត្ថេរគាថា

[ ២២៤ ] កាយមានជើង ២ នេះ មិនស្អាត មានក្លិនស្អុយ ពេញដោយសាកសពផ្សេងៗ បង្ហូរ ( នូវវត្ថុមិនស្អាត ) ចេញតាមទ្វារនោះៗ ដែលមនុស្សខំរក្សាថែទាំ ( ជានិច្ច ) ។ រូប សំឡេង ក្លិន រស និងផោដ្ឋព្វៈ ជាទីត្រេកអរនៃចិត្ត តែងបៀតបៀនបុថុជ្ជន ដូចអ្នកនេសាទធ្វើវត្ថុឲ្យកំបាំងហើយ ( ចាប់ ) ម្រឹគដោយគ្រឿងចង ( ចាប់ ) ត្រីដោយសន្ទូច ( ចាប់ ) ស្វាដោយជ័រ កាមគុណទាំង ៥ នេះឯង តែងប្រាកដក្នុងរូបនៃស្រី ។ ពួកបុថុជ្ជនណា មានចិត្តត្រេកអរ ហើយចូលទៅគប់រកស្រីទាំងនុ៎ះ ពួកបុថុជ្ជននោះ ឈ្មោះថា ធ្វើសង្សារវដ្ត ដែលមានទុក្ខដ៏ពន្លឹកឲ្យចម្រើនឡើង ទាំងឈ្មោះថា សន្សំនូវភពថ្មី ។ មួយទៀត បុគ្គលណាវៀរចេញចាកស្រីទាំងនុ៎ះបាន ដូចគេចៀសវាងក្បាលពស់ដោយជើង បុគ្គលនោះ ឈ្មោះថា ជាអ្នកមានស្មារតី ប្រព្រឹត្តកន្លងនូវតណ្ហា ជាគ្រឿងផ្សាយទៅក្នុងលោកនេះបាន ។ ខ្ញុំឃើញទោសក្នុងកាមទាំងឡាយ ឃើញការចេញចាកកាមដោយក្សេមក្សាន្ត រលាស់ចេញចាកកាមទាំងអស់ បានដល់នូវការអស់អាសវៈហើយ ។

សព្វកាមត្ថេរ

### ឧទ្ទាន

និយាយអំពីឧរុវេលកស្សបត្ថេរ ១ តិកិច្ឆកានិត្ថេរ ១ មហានាគត្ថេរ ១ កុល្លត្ថេរ ១ មាលុង្ក្យបុត្តត្ថេរ ១ សប្បទាសត្ថេរ ១ កាតិយានត្ថេរ ១ មិគជាលត្ថេរ ១ ជេន្តបុរោហិតបុត្តត្ថេរ ១ សុមនត្ថេរ ១ ន្ហាតកមុនិត្ថេរ ១ ព្រហ្មទត្តត្ថេរ ១ សិរិមណ្ឌលត្ថេរ ១ សព្វកាមត្ថេរ ១ ក្នុងឆក្កនិបាតនេះ ព្រះថេរៈ ១៤ អង្គ ( បានពោល ) គាថា ៨៤ ។

ឆក្កនិបាត ចប់

# អដ្ឋកថា

## សព្វកាមត្ថេរគាថា

[ ២២៤ ] គាថារបស់ព្រះសព្វកាមិត្ថេរ[១] មានពាក្យផ្ដើមថា **ទ្វិបាទកោ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា ព្រះថេរៈនេះ បានឃើញព្រះថេរៈមួយរូប ជម្រះនូវហេតុនៃការបែកបាក់សាមគ្គី ដែលកើតឡើងក្នុងសាសនារបស់ព្រះមានព្រះភាគបទុមុត្តរៈ ហើយរៀបចំឲ្យជាប្រក្រតីដូចមុន ទើបតាំងសេចក្ដីប្រាថ្នាថា ខ្ញុំគប្បីជាអ្នកអាចជម្រះនូវការបែកសាមគ្គី ក្នុងសាសនារបស់ព្រះពុទ្ធអង្គណាមួយ ក្នុងអនាគតហើយរៀបចំឲ្យដូចប្រក្រតី ដូច្នេះហើយ ធ្វើបុណ្យទាំងឡាយ

១- ក្នុងបាលី ជាសព្វកាមត្ថេរ ។

ដែលសមគួរដល់សេចក្តីប្រាថ្នានោះ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំង-ឡាយ ក្នុងពុទ្ធុប្បាទនេះ កាលព្រះមានព្រះភាគមិនទាន់បរិនិព្វាន កើតក្នុងត្រកូលក្សត្រ ក្នុងនគរវេសាលី បានឈ្មោះថា **សព្វកាម** លុះចម្រើនវ័យហើយ ពួកញាតិរៀបចំឲ្យនៅគ្រប់គ្រងផ្ទះ តែព្រោះមានអធ្យាស្រ័យក្នុងការចេញចាកទុក្ខ ខ្ពើមរអើមនូវការគ្រប់គ្រងផ្ទះ ទើបបួសក្នុងសម្នាក់របស់ព្រះធម្មភណ្ឌាគារិក បំពេញសមណធម៌ បានចូលទៅកាន់នគរវេសាលី មួយអន្លើដោយព្រះឧបជ្ឈាយ៍ ទើបបានទៅកាន់ផ្ទះញាតិ ។ ក្នុងផ្ទះញាតិនោះភរិយាចាស់បានទទួលសេចក្តីទុក្ខ ព្រោះព្រាត់ចាកស្វាមី ជាអ្នកស្គាំងស្គមមានពណ៌សម្បុរសៅហ្មង មិនប្រដាប់តាក់តែងកាយ ស្លៀកសំពត់ចាស់ៗថ្វាយបង្គំព្រះថេរៈហើយ ឈរយំក្នុងចំណែកម្ខាង កាលព្រះថេរៈឃើញដូច្នោះ ក៏កើតសេចក្តីមេត្តា ដែលមាននូវករុណាជាប្រធាន កិលេសក៏កើតឡើងដោយអំណាចអយោនិសោមនសិការ ក្នុងអារម្មណ៍ដែលបានសោយមកហើយ ។

ព្រះថេរៈកើតសេចក្តីសង្វេគ ដូចសេះអាជានេយ្យដែលគេវាយដោយរំពាត់ រំពេចនោះឯង ក៏ចូលទៅកាន់ព្រៃខ្មោច កំណត់អសុភនិមិត្ត ធ្វើឈានដែលបានក្នុងព្រៃខ្មោចនោះឲ្យជាបាទ ចម្រើនវិបស្សនាហើយ បានសម្រេចអរហត្ត ។

លំដាប់នោះ ឪពុកក្មេករបស់ព្រះថេរៈនាំកូនស្រីដែលប្រដាប់តាក់តែងមក បំណងឲ្យព្រះថេរៈសឹក ចូលទៅកាន់វិហារ មួយអន្លើដោយបរិវារច្រើន

បំណងឲ្យព្រះថេរៈសឹក ព្រះថេរៈដឹងបំណងរបស់នាងហើយ កាលប្រាប់ឲ្យដឹងថា លោកមិនត្រេកអរក្នុងកាមទាំងឡាយ និងភាពដែលខ្លួនមិនជាប់ក្នុងអារម្មណ៍ទាំងពួង ទើបពោលគាថាទាំងនេះថា

កាយមានជើង ២ នេះ មិនស្អាត មានក្លិនស្អុយ ពេញដោយសាកសពផ្សេងៗ បង្ហូរ ( នូវវត្ថុមិនស្អាត ) ចេញតាមទ្វារនោះៗ ដែលមនុស្សខំរក្សាថែទាំ ( ជានិច្ច ) ។ រូប សំឡេង ក្លិន រស និងផោដ្ឋព្វៈ ជាទីត្រេកអរនៃចិត្ត តែងបៀតបៀនបុថុជ្ជន ដូចអ្នកនេសាទធ្វើវត្ថុឲ្យកំបាំងហើយ ( ចាប់ ) ម្រឹគដោយគ្រឿងចង ( ចាប់ ) ត្រីដោយសន្ទូច ( ចាប់ ) ស្វាដោយជ័រ កាមគុណទាំង ៥ នេះឯង តែងប្រាកដក្នុងរូបនៃស្រី ។ ពួកបុថុជ្ជនណាមានចិត្តត្រេកអរ ហើយចូលទៅគប់រកស្រីទាំងនុ៎ះ ពួកបុថុជ្ជននោះ ឈ្មោះថា ធ្វើសង្សារវដ្ដ ដែលមានទុក្ខដ៏ពន្លឹកឲ្យចម្រើនឡើង ទាំងឈ្មោះថា សន្សំនូវកពថ្មី ។ មួយទៀត បុគ្គលណាវៀរចេញចាកស្រីទាំងនុ៎ះបាន ដូចគេចៀសវាងក្បាលពស់ដោយជើង បុគ្គលនោះ ឈ្មោះថា ជាអ្នកមានស្មារតី ប្រព្រឹត្តកន្លងនូវតណ្ហា ជាគ្រឿងផ្សាយទៅក្នុងលោកនេះបាន ។ ខ្ញុំឃើញទោសក្នុងកាមទាំងឡាយ ឃើញការចេញចាកកាម ដោយក្សេមក្សាន្ត រលាស់ចេញចាកកាមទាំងអស់ បានដល់នូវការអស់អាសវៈហើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ទ្វិបាទកោ** ក្នុងគាថានេះ មានវិនិច្ឆ័យដូចតទៅ ខ្ទួនរបស់សត្វដែលមិនមានជើងជាដើម មិនស្អាតដូចគ្នាក៏ពិត តែលោកពោលយ៉ាងនេះ ដោយបំណងចំពោះ ឬដោយការកំណត់យ៉ាងខ្ពស់ ។ ម្យ៉ាងទៀត ព្រោះហេតុដែលកាយសត្វដទៃៗ មិនស្អាត ប្រើរបស់ប្រែ និងរបស់ជូរជាដើមមកប្រឡាក់ ក៏ធ្វើជាអាហាររបស់មនុស្សបាន តែកាយរបស់មនុស្សធ្វើជាអាហារមិនបាន ព្រោះដូច្នោះ កាលទឹងសម្ដែងភាវៈដែលមិនស្អាតនៃកាយមនុស្សនោះ ទើបលោកពោលថា **ទ្វិបាទកោ** ដូច្នេះជាដើម ។

បទថា **អយំ** លោកពោលសំដៅយកមនុស្សស្រីដែលប្រាកដក្នុងពេលនោះ ។ បទថា **អសុចិ** ប្រែថា មិនស្អាត អធិប្បាយថា ក្នុងរូបស្រីនេះ មិនមានអ្វីស្អាតឡើយ ។

បទថា **ទុគ្គន្ធោ បរិហីរតិ** សេចក្ដីថា ជាកាយមានក្លិនស្អុយ ម្ចាស់កាយតាក់តែងដោយផ្កា និងគ្រឿងក្រអូបជាដើម ហើយថែរក្សា ។

បទថា **នានាកុណបបរិបូរោ** បានដល់ ពេញដោយសាកសពច្រើនប្រការ មានសក់ជាដើម ។

ក្នុងបទថា **វិស្សវន្តោ តតោ តតោ** នេះ ភ្ជាប់សេចក្ដីថា កាយនេះ សូម្បីជនទាំងឡាយព្យាយាមបិទបាំងនូវរបស់គួរខ្ពើម ដោយផ្កាកម្រង និងគ្រឿងក្រអូបជាដើម សេចក្ដីព្យាយាមនោះក៏ឥតផល ត្រូវបណ្ដោយឲ្យទឹកមាត់ និងទឹកសម្បោរជាដើមហូរចេញតាមទ្វារទាំង ៩ និងបណ្ដោយឲ្យញើសហូរចេញអំពីរន្ធរោមទាំងឡាយ ហើយថែរក្សា ។

កាលសម្ដែងថា កាយនេះ សូម្បីជារបស់គួរខ្ពើមយ៉ាងនេះ ក៏គង់បោក បញ្ឆោតអន្ធបុថុជ្ជនដោយរូបជាដើមរបស់ខ្លួន ដូចព្រានព្រៃបញ្ឆោតម្រឹគជាដើម ដោយគ្រឿងបង្កាត់ មានរណ្ដៅជាដើម ដូច្នោះ ទើបពោលពាក្យជាដើមថា **មិគំ** ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **មិគំ និលីនំ កូដេន** សេចក្ដីថា ដូចព្រាន ម្រឹគពួន គឺពួនដាក់ម្រឹគដោយបង្កាត់ មានអន្ទាក់ជាដើម ។ ពិតហើយ **វា** សព្ទ ដែលកំពុងពោលដល់ ក៏គួរនាំមកប្រកបក្នុងប្រយោគនេះ ។

បទថា **ពឡិសេនេវ អម្ពុជំ** សេចក្ដីថា ដូចព្រានសន្ទូចដាក់សត្វដែល កើតក្នុងទឹក គឺត្រី ដោយសន្ទូចដែលបិទនុយ ដូច្នោះ ។

បទថា **វានរំ វិយ លេបេន** សេចក្ដីថា បញ្ចកាមគុណ រមែងបោក បញ្ឆោតអន្ធបុថុជ្ជនឲ្យលំបាក ដូចព្រានម្រឹគបញ្ឆោតចាប់ស្វា ដោយតាំងដែល លាបជ័រ ដាក់លើដើមឈើ និងថ្មជាដើម ។

ដើម្បីចៀសវាងពាក្យសួរដែលថា អ្នកណាធ្វើឲ្យលំបាក ទើបពោល ពាក្យជាដើមថា រូប សំឡេង ដូច្នេះ ។ ពិតហើយ ចំណែកនៃកាម ៥ មាន រូបជាដើមដោយចំពោះយ៉ាងក្រៃលែង ដែលមានក្នុងវត្ថុដែលផុយគ្នា កាល ធ្វើចិត្តរបស់បុថុជ្ជនល្ងង់ខ្លៅ ដែលត្រូវចោមរោមដោយអយោនិសោមនសិការ ដែលជាទីចូលទៅ អាស្រ័យរបស់វិបល្លាស ឲ្យត្រេកអរ ឈ្មោះថា រមែង ញុំាងអន្ធបុថុជ្ជនទាំងនោះឲ្យលំបាក ព្រោះនាំសេចក្ដីវិនាសមកឲ្យ ដោយភាព ជាទីតាំងនៃកិលេស ដោយហេតុនោះ ទើបលោកពោលថា រូប សំឡេង ។បេ។

នេះឯងតែងប្រាកដក្នុងរូបនៃស្រី ។ សព្ទថា **ឥត្ថី** ក្នុងទីនេះ គប្បីជ្រាបថា លោកធ្វើដោយប្រាថ្នាចំពោះ ដោយហេតុនោះ ទើបលោកពោលថា **យេ ឯតា ឧបសេវន្តិ** ដូច្នេះជាដើម ។

ពាក្យនោះ មានអត្ថថា បុថុជ្ជនណាមានចិត្តតម្រេក គឺមានចិត្តត្រូវរាគៈគ្របសង្កត់ រមែងសេពស្រីទាំងនោះ ដោយកំណត់ថា ជាគ្រឿងឧបភោគប្រើប្រាស់ ។

បទថា **វឌ្ឍេន្តិ កដសឹ ឃោរំ** សេចក្តីថា បុថុជ្ជនទាំងនោះរមែងញ៉ាំងសង្សារដែលប្រកាន់ជាព្រៃស្មសាន ព្រោះជាទីដែលអន្ធពាលពេញចិត្តដែលគួរខ្លាច គឺនាំភ័យមកឲ្យដោយជាតិជាដើម និងដោយនរកជាដើម ឲ្យរីកដុះដាលដោយការកើត និងការស្លាប់រឿយៗ ដោយហេតុនោះ ទើបលោកពោលថា **អាចិនន្តិ បុនព្ភវំ** ដូច្នេះ ។

បទថា **យោ ចេតា** សេចក្តីថា ឯបុគ្គលណាវៀរស្រីទាំងនោះបានដោយការសង្កត់ ព្រោះការកាត់ផ្តាច់ឆន្ទរាគក្នុងស្រីទាំងនោះ ដូចបុគ្គលវៀរក្បាលពស់ដោយជើង បុគ្គលនោះ ជាអ្នកមានសតិកន្លងផុតតណ្ហា ពោលគឺការបន្សាត់ទៅក្នុងលោក ព្រោះលះលោកទាំងពួងបាន ហើយតាំងនៅ ។

បទថា **កាមេស្វាទីនវំ ទិស្វា** សេចក្តីថា ឃើញនូវអាទីនវៈ គឺការវិនាស ដោយប្រការមិនមែនតិច ក្នុងវត្ថុកាម និងកិលេសកាមទាំងឡាយដោយន័យ ( ក្នុងវិនយបិដកមហាវិភង្គ ) ថា កាមទាំងឡាយ មានឧបមាដោយរាងឆ្អឹង មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ដូច្នេះជាដើម ។

បទថា **នេក្ខម្មំ ទដ្ឋុ ខេមតោ** សេចក្ដីថា ជាអ្នកឃើញនេក្ខម្មៈ គឺការចេញបួស និងព្រះនិព្វាន ថាជាការក្សេម មិនមានអន្តរាយ ព្រោះជាភាវៈឲ្យចេញចាកកាម និងភព ទើបរលាស់ចេញ គឺប្រាសចេញចាកកាមទាំងពួងបានដល់ ចាកធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ទាំងអស់នេះ ឈ្មោះថា **កាម** ព្រោះអត្ថថា ជាទីតាំងនៃសេចក្ដីប្រាថ្នា ព្រះថេរៈប្រាសហើយចាកកាមទាំងនោះ ដោយហេតុនោះ ទើបលោកពោលថា **បត្តោ មេ អាសវក្ខយោ** ដូច្នេះ ។

ព្រះថេរៈពោលធម៌ដោយគាថា ៥ គាថាខាងដើមយ៉ាងនេះហើយ បានព្យាករអរហត្តផល ដោយគាថាទី ៦ ។ ឪពុកក្មេកបានស្ដាប់ដូច្នោះ គិតថា បុរសនេះ មិនជាប់ក្នុងវត្ថុទាំងពួង បុគ្គលណាម្នាក់ មិនអាចឲ្យបុរសនេះវិលទៅក្នុងកាមទាំងឡាយបានឡើយ ទើបទៅតាមផ្លូវដែលមកហើយនោះឯង ។ ឯព្រះថេរៈ កាលព្រះមានព្រះភាគបរិនិព្វានហើយបាន ១០០ ឆ្នាំ ឧបសម្បទាបាន ១២០ ជាថេរៈក្នុងផែនដី ជម្រះមន្ទិលនៃសាសនាដែលភិក្ខុវជ្ជីបុត្ត អ្នកវេសាលីឲ្យកើតឡើង សង្គាយនាចងក្រងព្រះធម៌ព្រះវិន័យលើកទី ២ ហើយទើបផ្ដាំផ្ញើតិស្សមហាព្រហ្មថា ចូរអ្នកជម្រះឧបទ្រពចង្រៃដែលកើតឡើង ក្នុងរជ្ជកាលព្រះបាទធម្មាសោកក្នុងអនាគតកាលផង ហើយលោកក៏បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ដូច្នេះ ។៚

**អដ្ឋកថាសព្វកាមិត្ថេរគាថា ចប់**

**ឆក្កនិបាត ចប់**

# សុត្តន្តបិដក
# ថេរគាថា សត្តកនិបាត

## សុន្ទរសមុទ្ទត្ថេរគាថា

[ ២២៥ ] ស្រីផ្កាមាស តាក់តែង ស្លៀកពាក់ល្អ ទ្រទ្រង់កម្រងផ្កា ស្អិតស្អាងហើយ មានជើងស្រឡាបដោយទឹកល័ក្ត ពាក់ស្បែកជើង លុះដោះស្បែកជើងចេញហើយ ក៏ធ្វើអញ្ជលីចំពោះមុខ ស្រីផ្កាមាសនោះ និយាយនូវពាក្យជាប្រធាននៃនិមិត្តនឹងខ្ញុំ ដោយសម្តីដ៏ទន់ពីរោះថា លោកនៅកំលោះហើយបួស លោកចូរឋិតនៅក្នុងពាក្យប្រដៅរបស់ខ្ញុំ លោកចូរបរិភោគកាម ជារបស់មនុស្សចុះ ខ្ញុំនឹងឲ្យសម្បត្តិដ៏ពេញចិត្តដល់លោក ។ ខ្ញុំប្តេជ្ញាពាក្យពិតដល់លោក ឬនឹងនាំភ្លើងដល់លោក ។ កាលណា យើងទាំងពីរនាក់ ជាមនុស្សចាស់ កាន់ឈើច្រត់ហើយ យើងនឹងបួសទាំងពីរនាក់ នឹងកាន់យកនូវជ័យជម្នះក្នុងលោកទាំងពីរ ។ ខ្ញុំបានឃើញស្រីផ្កាមាសនោះមកធ្វើអញ្ជលីតាក់តែង ស្លៀកពាក់ល្អ ដូចជាជាប់អន្ទាក់មច្ចុលំដាប់នោះ ខ្ញុំក៏បានធ្វើទុកក្នុងចិត្តដោយឧបាយនៃបញ្ញា ។បេ។[១]

សុន្ទរសមុទ្ទត្ថេរ

---

១- គប្បីមើលក្នុងចតុក្កនិបាត ។

# អដ្ឋកថា
# ថេរគាថា សត្តកនិបាត

## សុន្ទរសមុទ្ទត្ថេរគាថា

[ ២២៥ ] ក្នុងសត្តកនិបាត មានវិនិច្ឆ័យដូចតទៅនេះ គាថារបស់ព្រះសុន្ទរសមុទ្ទត្ថេរ មានពាក្យផ្ដើមថា **អលង្កតា** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងពុទ្ធុប្បាទនេះ កើតជាកូនរបស់សេដ្ឋី មានទ្រព្យសម្បត្តិច្រើនម្នាក់ ក្នុងនគររាជគ្រឹះ មានឈ្មោះថា **សមុទ្ទ** តែប្រាកដឈ្មោះថា **សុន្ទរសមុទ្ទ** ព្រោះប្រកបដោយរូបសម្បត្តិ ។

លោកតាំងនៅក្នុងបឋមវ័យ បានឃើញពុទ្ធានុភាព ក្នុងគ្រាដែលព្រះមានព្រះភាគ យាងចូលទៅកាន់ក្រុងរាជគ្រឹះ បាននូវសទ្ធា ព្រោះជាអ្នកមាននូវអជ្ឈាស្រ័យក្នុងការរលាស់ចេញចាកទុក្ខ ទើបបួស ឧបសម្បទាហើយ សមាទានធុតង្គ ចេញអំពីនគររាជគ្រឹះ ទៅកាន់នគរសាវត្ថី រៀននូវវិបស្សនា ក្នុងសម្នាក់របស់ភិក្ខុដែលជាកល្យាណមិត្ត បំពេញកម្មដ្ឋាន ។ ក្នុងថ្ងៃមហោស្រព ក្នុងនគររាជគ្រឹះ មាតារបស់ព្រះថេរៈបានឃើញសេដ្ឋីបុត្តដទៃៗ មួយ

អន្ទើនឹងកិរិយានាំគ្នាស្អិតស្អាងរាងកាយលេងមហោស្រព រឭកដល់បុត្ត ទើបទ្រហោយំ ។

ស្រីគណិកាម្នាក់ឃើញដូច្នោះ ក៏សួរដល់ហេតុដែលយំ ទើបមាតាប្រាប់ហេតុនោះដល់ស្រីគណិកានោះ ស្រីគណិកាបានស្តាប់ដូច្នោះ ក៏ពោលថា ខ្ញុំនឹងនាំលោកមក ដំបូងសូមអ្នកម៉ែយល់ថាខ្ញុំជាស្រី ទើបមាតានោះសន្យាថា បើធ្វើបានដូច្នោះ ខ្ញុំនឹងធ្វើនាងឲ្យជាកិរិយារបស់កូនខ្ញុំ ហើយតាំងឲ្យជាម្ចាស់ក្នុងត្រកូលនេះ ប្រគល់ទ្រព្យជាច្រើន ហើយបញ្ជូនទៅ ទើបនាងទៅកាន់នគរសាវត្ថី ដោយបរិវារច្រើន ហើយស្នាក់នៅក្នុងផ្ទះមួយ ជិតទីបិណ្ឌបាតរបស់ព្រះថេរៈ ប្រើឲ្យអ្នកដទៃៗ ប្រគេនបិណ្ឌបាតដល់ព្រះថេរៈដោយសេចក្តីគោរពរាល់ៗ ថ្ងៃ ខ្លួនឯងតាក់តែងកាយ ពាក់គ្រឿងអលង្ការ ពាក់ស្បែកជើងមាស បង្ហាញខ្លួនឲ្យព្រះថេរៈឃើញ ។ ថ្ងៃមួយ នាងឃើញព្រះថេរៈកំពុងទៅតាមផ្លូវ ទើបដោះស្បែកជើងមាស ផ្គងអញ្ជលី ដើរទៅខាងមុខនិមន្តព្រះថេរៈដោយកាម មានប្រការផ្សេងៗ ។ ព្រះថេរៈបានស្តាប់ដូច្នោះ ធម្មតាចិត្តរបស់បុថុជ្ជន រមែងញាប់ញ័រ បើដូច្នោះ អាត្មាអញគប្បីធ្វើឧស្សាហៈធ្វើវត្តដែលគួរធ្វើក្នុងកាលឥឡូវនេះ ឈរក្នុងទីនោះឯង បំពេញការនា បានអភិញ្ញា ៦ ដូចលោកពោលថា

ស្រីផ្កាមាស តាក់តែង ស្លៀកពាក់ល្អ ទ្រទ្រង់កម្រងផ្កា ស្អិតស្អាង
ហើយ មានជើងស្រឡាបដោយទឹកល័ក្ត ពាក់ស្បែកជើង លុះ
ដោះស្បែកជើងចេញហើយ ក៏ធ្វើអញ្ជលីចំពោះមុខ ស្រីផ្កាមាស

នោះ និយាយនូវពាក្យជាប្រធាននៃនិមិត្តនឹងខ្ញុំ ដោយសម្ដីដ៏ទន់ពីរោះថា លោកនៅកំលោះហើយបួស លោកចូរឋិតនៅក្នុងពាក្យប្រដៅរបស់ខ្ញុំ លោកចូរបរិភោគកាម ជារបស់មនុស្សចុះ ខ្ញុំនឹងឲ្យសម្បត្តិដ៏ពេញចិត្តដល់លោក ។ ខ្ញុំប្តេជ្ញាពាក្យពិតដល់លោក ឬនឹងនាំភ្លើងដល់លោក ។ កាលណា យើងទាំងពីរនាក់ជាមនុស្សចាស់ កាន់ឈើច្រត់ហើយ យើងនឹងបួសទាំងពីរនាក់ នឹងកាន់យកនូវជ័យជម្នះក្នុងលោកទាំងពីរ ។ ខ្ញុំបានឃើញស្រីផ្កាមាសនោះ មកធ្វើអញ្ជលី តាក់តែង ស្លៀកពាក់ល្អ ដូចជាជាប់អន្ទាក់មច្ចុ លំដាប់នោះ ខ្ញុំក៏បានធ្វើទុកក្នុងចិត្ត ដោយឧបាយនៃបញ្ញា ។បេ។ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **មាលធារី** បានដល់ ទ្រទ្រង់នូវកម្រងផ្កា គឺប្រដាប់ដោយកម្រងផ្កា ។

បទថា **វិភូសិតា** បានដល់ តាក់តែងកាយដោយផ្កា និងលាបដោយគ្រឿងក្រអូបជាដើម ដោយធ្វើទីដែលខ្វះខាតឲ្យពេញ ។

ដោយបទថា **អលង្កតា** នេះ លោកបំណងយកការប្រដាប់ដោយគ្រឿងអាភរណៈទាំងឡាយ មានខ្សែដៃ និងខ្សែកជាដើម ។

បទថា **អលត្តកកតាបាទា** បានដល់ មានជើងទាំងគូលាបដោយទឹកល័ក្ខ ដែលមានពណ៌ដូចផ្កាជ័យព្រឹក្ស និងផ្កាដកគាំចាស់ ។ ពិតហើយ បទថា **អលត្តកកតាបាទា** នេះ ជាបទសមាស គឺវិធីបង្រួញសព្ទ កាលគួរ

ពោលថា **អលត្តកកតចរណា** តែលោកធ្វើឲ្យជាទីឃៈដើម្បីស្រួលក្នុងការចងគាថា តែក្នុងកាលមិនជាបទសមាស ត្រូវបន្ថែមពាក្យដ៏សេសចូលមកថា **តស្សា** ដូច្នេះ ។

ក្នុងបទថា **ចារុការុឡ្ហ វេសិកា** បានដល់ ស្រីម្នាក់ដែលអាស្រ័យរូបចិញ្ចឹមជីវិត តែងខ្លួនតាមដែលពោលហើយ ពាក់ស្បែកជើងមាស គប្បីបន្ថែមពាក្យដ៏សេស គឺពាក្យថា កំពុងឈរចូលមក ។ បទថា **ចារុកា ឱរុយ្ហិត្វាន** បានដល់ ចុះចាកពីស្បែកជើង អធិប្បាយថា ដោះស្បែកជើងមាស ។

បទថា **បញ្ជលីកតា** សេចក្តីថា នាង គឺស្រីផ្កាមាស ផ្គងអញ្ជលីពោលនឹងខ្ញុំ ។ម្យ៉ាងទៀត នាងពោលឯង គឺដោយខ្លួនឯង មិនមានអ្នកដទៃប្រាប់ ។

បទថា **សណ្ហោន** បានដល់ មូលក្រអៅ ។ បទថា **មុទុនា** បានដល់ ផ្អែមពីរោះ ។ ទោះបីមិនពោលពាក្យថា **វចនេន** ក៏ដូចជាពោល ព្រោះពោលពាក្យថា **អភាសថ**។

ដោយបទថា **យុវាសិ ត្វំ បព្វជិតោ** នេះ លោកសម្តែងសេចក្តីថា លោកម្ចាស់កាលបួស ក៏នៅកំលោះបួស កាលនឹងបួស គួរបួសក្នុងអាយុ ៧០ មិនមែនឬ ។

បទថា **តិដ្ឋាហិ មម សាសនេ** សេចក្តីថា សូមលោកម្ចាស់តាំងនៅក្នុងពាក្យរបស់ខ្ញុំចុះ ។ ដើម្បីចៀសវាងពាក្យសួរថា ពាក្យនោះសំដៅដល់អ្វី ទើបនាងពោលថា ចូរបរិភោគកាមដែលជារបស់មនុស្សចុះ ។ បុគ្គលដែល

បំណងនឹងបរិភោគកាម ត្រូវប្រាថ្នារូបសម្បត្តិ វយសម្បត្តិ បរិវារសម្បត្តិ និងភោគសម្បត្តិ ។ ក្នុងសម្បត្តិទាំងនោះ បើព្រះថេរៈប្រាប់ថា អាត្មានឹងមានភោគសម្បត្តិមកអំពីណា ព្រោះហេតុនោះ ទើបនាងពោលថា ខ្ញុំនឹងឲ្យសម្បត្តិដ៏ពេញចិត្តដល់លោក ។ ព្រះថេរៈសម្គាល់ថា ពាក្យនោះ គប្បីជឿបានដូចម្តេច ព្រោះហេតុនោះ កាលនាងឲ្យព្រះថេរៈជឿ ទើបពោលថា ខ្ញុំប្តេជ្ញាពាក្យពិតដល់លោក ឬនឹងនាំភ្លើងដល់លោក ( យកភ្លើងមកធ្វើសម្បថ ) អធិប្បាយថា ពាក្យណា ដែលខ្ញុំប្តេជ្ញាថា សូមលោកម្ចាស់បរិភោគកាម ដែលជារបស់មនុស្សចុះ ខ្ញុំនឹងឲ្យទ្រព្យជាគ្រឿងត្រេកអរចិត្តដល់លោកម្ចាស់ ពាក្យនោះ ខ្ញុំសូមឲ្យនូវសច្ចៈប្តេជ្ញាយ៉ាងដាច់ខាត បើមិនជឿចិត្តខ្ញុំទេ ខ្ញុំនឹងនាំយកភ្លើងមកស្បថក៏បាន គឺខ្ញុំនាំយកភ្លើងមកហើយ ធ្វើនូវសម្បថចំពោះមុខភ្លើង ។

បទថា **ឧភយត្ថ កដគ្គហោ** សេចក្តីថា ការដែលយើងទាំងពីរបួសក្នុងកាលឯចាស់ ជាការកាន់យកជ័យជម្នះក្នុងលោកទាំង ២ បាន អធិប្បាយថា ការដែលយើងទាំង ២ ប្រើប្រាស់នូវភោគៈ ដរាបដល់កាន់ឈើច្រត់ឈ្មោះថា មិនសាបសូន្យចាកភោគៈក្នុងលោកនេះផង កាលដែលយើងទាំង ២ បួសក្នុងកាលជាខាងក្រោយនោះ ឈ្មោះថា មិនសាបសូន្យចាកភោគៈក្នុងលោកខាងមុខផង ។

*បទថា* **គតោ** *បានដល់ ព្រោះហេតុនៃពាក្យ ដែលស្រីផ្កាមាសនោះ អញ្ជើញដោយកាមទាំងឡាយ ពោលដោយពាក្យជាដើមថា លោកនៅកំលោះហើយបួស និងដោយពាក្យជាដើមថា កាលណា យើងទាំងពីរនាក់ ជាមនុស្សចាស់ ដូច្នេះ ។ ពិតហើយ ព្រះថេរៈធ្វើពាក្យនោះឲ្យដូចជាកង្វេរ បំពេញនូវសមណធម៌ បានធ្វើនូវប្រយោជន៍របស់ខ្លួនឲ្យបរិបូណ៌ហើយ ។ ពាក្យដ៏សេស មានន័យដូចពោលហើយខាងដើមនោះឯង ។*

**អដ្ឋកថាសុន្ទរសមុទ្ទត្ថេរគាថា ចប់**

# សុត្តន្តបិដក

## លកុណ្ឋកភទ្ទិយត្ថេរគាថា

[ ២២៦ ] ព្រះភទ្ទិយត្ថេរ នៅក្នុងអម្ពាដកអារាម ដ៏ប្រសើរ ក្បែរជង់ព្រៃ បានដកតណ្ហា ព្រមទាំងឫស ចោលអស់ហើយ ជាអ្នកប្រសើរ ចម្រើនឈាន ក្នុងអារាមនោះ ។

ជនពួកខ្លះ ត្រេកអរដោយសម្ភោរ ដោយពិណ ដោយស្គរជ័យ ក៏មាន ចំណែកខ្ញុំនៅទៀបគល់ឈើ ត្រេកអរតែក្នុងពុទ្ធសាសនា ។ មួយទៀត ព្រះពុទ្ធទ្រង់ប្រទានពរដល់ខ្ញុំៗ បាននូវពរនោះ ខ្ញុំកាន់យកនូវកាយគតាសតិជានិច្ច ដើម្បីលោកទាំងអស់ ។ ពួកជនណា មើលងាយខ្ញុំ ដោយរូបក្តី ពួកជនណា តាមខ្ញុំទៅដោយសំឡេងក្តី ពួកជនទាំងនោះ សុទ្ធតែលុះអំណាចនៃឆន្ទរាគៈ មិនស្គាល់ខ្ញុំទេ ។ បុគ្គលណា មិនដឹងធម៌ខាងក្នុង ទាំងមិនឃើញធម៌ខាងក្រៅ បុគ្គលនោះឯង ជាមនុស្សពាល មានធម៌ជាគ្រឿងរាំងរាជុំវិញ តែងត្រូវសំឡេងនាំបន្សាត់ទៅ ។ បុគ្គលណា មិនដឹងធម៌ខាងក្នុង ប៉ុន្តែឃើញច្បាស់នូវធម៌ខាងក្រៅ បុគ្គលនោះ ឈ្មោះថាឃើញផលខាងក្រៅ ក៏ត្រូវសំឡេងបន្សាត់ទៅដែរ ។ បុគ្គលណា ដឹងច្បាស់នូវធម៌ខាងក្នុង ទាំងឃើញច្បាស់នូវធម៌ខាងក្រៅ បុគ្គលនោះ ឈ្មោះថា ជាអ្នកឃើញធម៌ដែលគ្មានអ្វីរាំងរា តែងមិនត្រូវសំឡេងបន្សាត់ទៅឡើយ ។

លកុណ្ឋកត្ថេរ

# អដ្ឋកថា

## លកុណ្ឌកភទ្ទិយត្ថេរគាថា

[ ២២៦ ] គាថារបស់ព្រះលកុណ្ឌកភទ្ទិយត្ថេរ មានពាក្យផ្ដើមថា **បរេ អម្ពាដការាមេ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា ក្នុងសាសនានៃព្រះមានព្រះភាគ ព្រះនាមបទុមុត្តរៈ ព្រះថេរៈនេះ កើតក្នុងត្រកូលមានភោគៈច្រើន ក្នុងហង្សវតីនគរ លុះចម្រើនវ័យ អង្គុយស្ដាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្ដា ក្នុងខណៈនោះ បានឃើញព្រះសាស្ដាទ្រង់ស្ថាបនាភិក្ខុមួយរូប ក្នុងតំណែងជាឯតទគ្គៈនៃភិក្ខុអ្នកមានសំឡេងពីរោះ ខ្លួនឯងក៏ប្រាថ្នាឋានន្តរនោះ ទើបថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយបានធ្វើបណិធានថា ខ្ញុំព្រះអង្គគប្បីជាកំពូលនៃភិក្ខុអ្នកមានសំឡេងពីរោះ ក្នុងសាសនារបស់ព្រះពុទ្ធអង្គណាមួយ ក្នុងអនាគត ដូចភិក្ខុរូបនេះ ព្រះមានព្រះភាគទ្រង់ឃើញសេចក្ដីប្រាថ្នានោះមិនមានអន្តរាយ ទើបទ្រង់ព្យាករ ហើយចៀសចេញទៅ ។

កុលបុត្តនោះ ធ្វើបុណ្យក្នុងជាតិនោះដរាបដល់អស់ជីវិត អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ។ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមផុស្សៈ កើតជាសត្វតាវ៉ៅ មានស្លាបល្អវិចិត្រ ពាំផ្លែស្វាយផ្អែម ចេញអំពីព្រះរាជឧទ្យាន ហើរទៅ បានឃើញព្រះសាស្ដា មានចិត្តជ្រះថ្លា ទើបកើតគំនិតថានឹងថ្វាយ ។ ព្រះសាស្ដាទ្រង់ជ្រាបការគិតរបស់សត្វតាវ៉ៅនោះ ទើបទ្រង់កាន់បាត្រប្រថាប់គង់ ។ សត្វតាវ៉ៅបានដាក់ផ្លែស្វាយក្នុងបាត្ររបស់ព្រះ

សាស្តា ។ ព្រះសាស្តាទ្រង់សោយផ្លែស្វាយទុំនោះ ។ សត្វតាវ៉ៅនោះ មានចិត្តជ្រះថ្លា នៅដោយសេចក្តីសុខដែលកើតអំពីបីតិ អស់មួយសប្តាហ៍ និងដោយបុញ្ញកម្មនោះ ទើបជាអ្នកមានសំឡេងពីរោះ ។

ក្នុងសាសនាព្រះកស្សបសម្ពុទ្ធ កាលមហាជនប្រារព្ធសាងព្រះចេតិយពិភាក្សាថា ពួកយើងនឹងធ្វើប៉ុនណា កាលមហាជនពោលថា ៧ យោជន៍ ក៏ពោលថា ទំហំនោះធំពេក កាលអ្នកដទៃពោលថា ៦ យោជន៍ ក៏ពោលថា ទំហំនោះក៏ធំពេក កាលអ្នកដទៃពោលថា ៥ យោជន៍ ៤ យោជន៍ ៣ យោជន៍ ២ យោជន៍ ដូច្នេះ ក៏នៅតែពោលថា ធំពេក ។ ក្នុងកាលនោះ កុលបុត្តនេះជាមេជាង និយាយឡើងថា មកអ្នកដ៏ចម្រើនទាំងឡាយ គួរធ្វើចេតិយឲ្យបដិបត្តិបានស្រួលក្នុងអនាគត ដូច្នេះហើយ ទើបកាន់យកខ្សែព័ទ្ធហើយឈប់ក្នុងទីបំផុតមួយគាវុត ទើបពោលថា មួយទិសៗ មួយគាវុតជុំវិញចេតិយនឹងបានទំហំមួយយោជន៍ កម្ពស់មួយយោជន៍ ជនទាំងនោះក៏ជឿពាក្យរបស់មេជាងនោះ មេជាងបានធ្វើប្រមាណរបស់ព្រះពុទ្ធ ដែលមិនមានប្រមាណ ដោយប្រការដូច្នេះឯង ។ ដោយកម្មនោះ ទើបមេជាងនោះមានរូបរាងទាបជាងមនុស្សដទៃ ក្នុងទីដែលកើតហើយ ។

ក្នុងសាសនានៃព្រះសាស្តារបស់យើងទាំងឡាយ កុលបុត្តនេះកើតក្នុងត្រកូលមានភោគៈច្រើន ក្នុងក្រុងសាវត្ថី បានឈ្មោះថា ភទ្ទិយៈ តែព្រោះជាមនុស្សតឿ ទើបប្រាកដឈ្មោះថា លកុណ្ឌកភទ្ទិយៈ ។ កុលបុត្តនោះ បានស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្តា បានទូវសទ្ធា បួសហើយ ជាពហុស្សូត

ជាធម្មកថិក សម្តែងធម៌ដល់អ្នកដទៃ ដោយសំឡេងដ៏ពីរោះ ។ ក្នុងថ្ងៃមហោ-ស្រពមួយ ស្រីផ្កាមាសម្នាក់ ទៅដោយរថជាមួយព្រាហ្មណ៍ម្នាក់ ឃើញព្រះថេរៈ ក៏អស់សំណើច របូតឃើញធ្មេញ ។ ព្រះថេរៈកាន់យកនិមិត្តក្នុងឆ្អឹងធ្មេញរបស់ស្រីនោះហើយ ធ្វើឈានឲ្យកើតឡើង ធ្វើឈាននោះឲ្យជាបាទចម្រើនវិបស្សនា បានជាព្រះអនាគាមី លោកនៅដោយកាយគតាសតិជានិច្ច ថ្ងៃមួយ កាលព្រះធម្មសេនាបតីទូន្មាន ក៏តាំងនៅក្នុងអរហត្ត សមដូចគាថាព័ន្ធដែលលោកពោលក្នុងអបទានថា

ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង ព្រះអង្គជានាយក ទ្រង់កើតឡើងក្នុងលោក ក្នុងកប្បទីមួយសែនអំពីកប្បនេះ ។ កាលនោះ ខ្ញុំកើតជាសេដ្ឋីបុត្រ ក្នុងនគរហង្សវតី ជាអ្នកមានទ្រព្យច្រើន បានដើរទៅកាន់ទីសម្រាកស្ងួន ក៏ចៀងចូលទៅកាន់អារាមរបស់សង្ឃ ។ គ្រានោះ ព្រះអង្គជាប្រទីបនៃលោកជានាយក កំពុងសម្តែងធម៌ ទ្រង់សរសើរសាវកដ៏ប្រសើរ ដែលមានសំឡេងពីរោះជាងពួកសាវក ដែលមានសំឡេងពីរោះទាំងឡាយ ។ ខ្ញុំឮព្រះពុទ្ធដីកានោះហើយ ក៏ត្រេកអរ បានធ្វើគ្រឿងសក្ការៈចំពោះព្រះមហេសី ហើយថ្វាយបង្គំបាទានៃព្រះសាស្តា រួចប្រាថ្នានូវតំណែងនោះ ។

គ្រានោះ ព្រះពុទ្ធជានាយក ទ្រង់ព្យាករក្នុងកណ្តាលជំនុំសង្ឃថា អ្នកនឹងបាននូវតំណែងនុ៎ះ ដូចចិត្តប៉ុនប៉ង ក្នុងកាល

អនាគត ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ មានមហាបុរស សម្ភពក្នុងត្រកូលស្តេចឱក្កាកៈ នឹងបានជាសាស្តា ព្រះនាមគោតម ត្រាស់ក្នុងលោក ។ សេដ្ឋីបុត្រនេះ នឹងបានជាឱរសដែលព្រះធម៌ និម្មិត ជាអ្នកទទួលមត៌កក្នុងធម៌របស់ព្រះគោតម ជាសាវកនៃព្រះ សាស្តា មាននាមថាកទ្ទិយៈ ។

ដោយអំពើដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ទុកនូវ ចេតនានោះផង លុះខ្ញុំលះបង់រាងកាយរបស់មនុស្សហើយ ក៏បាន ទៅកើតក្នុងឋានតាវត្តិង្ស ។ ព្រះជិនស្រីព្រះនាមផុស្សៈ ជានាយក ដែលគេចូលទៅរកបានដោយកម្រ គេគ្របសង្កត់បានដោយក្រ ព្រះអង្គខ្ពង់ខ្ពស់ជាងលោកទាំងពួង ទ្រង់កើតឡើងក្នុងកប្បទី ៩២ អំពីកប្បនេះ ។ ទ្រង់បរិបូណ៌ដោយចរណៈ ជាបុគ្គលប្រសើរ មានព្រះហឫទ័យត្រង់ មានតេជះ ស្វែងរកប្រយោជន៍ដល់សព្វ សត្វ ទ្រង់ញុំាងសត្វជាច្រើនឲ្យរួចចាកចំណង ។ ខ្ញុំកើតជាសត្វ តាវ៉ៅស នៅលើដើមស្វាយក្បែរគន្ធកុដិ ក្នុងឧទ្យានរបស់ព្រះ សាស្តានោះ ។ គ្រានោះ ខ្ញុំបានឃើញព្រះជិនស្រី ជាទក្ខិណេយ្យ- បុគ្គលដ៏ខ្ពង់ខ្ពស់ ស្តេចកំពុងទៅបិណ្ឌបាត ហើយញុំាងចិត្តឲ្យ ជ្រះថ្លា ក៏ស្រែករំពងដោយសំឡេងដ៏ពីរោះ ។ ខ្ញុំបានហើរទៅកាន់ ឧទ្យានស្តេចហើយ ពាំយកផ្លែស្វាយទុំ មានសម្បុរនៃសម្បកដូច មាស បង្អោនទៅជិតព្រះសម្ពុទ្ធ ។ ព្រះជិនស្រីទ្រង់ប្រកបដោយ

មហាករុណា ជានាយក ទ្រង់ជ្រាបច្បាស់នូវចិត្តរបស់ខ្ញុំហើយ ក៏យកបាត្រអំពីដៃភិក្ខុជាឧបដ្ឋាក ( ហើយបង្អោនបាត្រទៅរកខ្ញុំជាសត្វតាវ៉ៅសនោះ ) ។ ខ្ញុំមានចិត្តរីករាយ បានដាក់ផ្លែស្វាយក្នុងបាត្រ ថ្វាយព្រះមហាមុនី រួចធ្វើអញ្ជលីដោយស្លាបទាំងពីរ ស្រែកដោយសំឡេងដ៏ពីរោះ កាលស្រែកដោយសំឡេងគួរត្រេកអរ គួរស្តាប់ដ៏ទន់ពីរោះ ដើម្បីពុទ្ធបូជាហើយ ក៏ហើរទៅកាន់ទ្រនំ ហើយដេកលក់ ។ គ្រានោះ សត្វខ្លែង ជាសត្វចិត្តអាក្រក់ ហើរមកចាបយកខ្ញុំ ដែលកំពុងមានចិត្តរីករាយ មានអធ្យាស្រ័យស្រឡាញ់ចំពោះព្រះពុទ្ធ ។ ខ្ញុំច្យុតចាកអត្តភាពនោះ ក៏បានទទួលមហាសុខ ក្នុងឋានតុសិត ( លុះច្យុតចាកឋានតុសតិ ) ក៏បានមកកាន់កំណើតមនុស្ស ព្រោះអានិសង្សនៃកុសលកម្មនោះឯង ។ ក្នុងកប្បនេះ ព្រះពុទ្ធព្រះនាមកស្សបៈដោយគោត្រ មានផៅពង្សប្រសើរ មានយសធំ ព្រះអង្គប្រសើរជាងពួកអ្នកប្រាជ្ញ ស្តេចកើតឡើង ។ ព្រះអង្គបំភ្លឺសាសនា គ្របសង្កត់តិរ្ថិយអាក្រក់ ទ្រង់ទូន្មានពួកវេនេយ្យសត្វ រួចហើយព្រះអង្គ ព្រមទាំងពួកសាវ័កបរិនិព្វានទៅ ។ កាលព្រះអង្គជាបុគ្គលប្រសើរជាងសត្វលោកបរិនិព្វានហើយ ពួកជនច្រើនគ្នា កើតសេចក្តីជ្រះថ្លា នាំគ្នាធ្វើព្រះស្តូបដើម្បីជាពុទ្ធបូជាចំពោះព្រះសាស្តា ។ ពួកជនទាំងនោះប្រឹក្សាគ្នាយ៉ាងនេះថា យើងទាំងឡាយនឹងឲ្យពួកជាងធ្វើព្រះស្តូបកម្ពស់

៧ យោជន៍ ស្អិតស្អាងដោយកែវ ៧ ប្រការ ថ្វាយព្រះពុទ្ធជាមហេសី ។ កាលនោះ ខ្ញុំជានាយកនៃសេនារបស់ព្រះបាទកិកិនៃដែនកាសី បានបង្គាប់ឲ្យគេធ្វើចេតិយដែលត្រូវមានទំហំធំ ឲ្យមកជាតូចវិញ ។ គ្រានោះ ពួកជនទាំងនោះក៏នាំគ្នាធ្វើចេតិយតាមពាក្យខ្ញុំ កម្ពស់មួយយោជន៍ សឹងស្អិតស្អាងដោយកែវផ្សេងៗ ថ្វាយព្រះពុទ្ធជាអ្នកប្រាជ្ញ ប្រសើរជាងជន ។ ដោយអំពើដែលខ្ញុំធ្វើដោយល្អនោះផង ដោយការតម្កល់នូវចេតនានោះផង លុះខ្ញុំលះបង់រាងកាយ ជារបស់មនុស្សហើយ បានទៅកើតក្នុងឋានតាវត្តិង្ស ។ ក្នុងបច្ឆិមភព ឥឡូវនេះ ខ្ញុំកើតក្នុងត្រកូលសេដ្ឋីក្រុងសាវត្ថី ជាក្រុងដ៏ប្រសើរ ស្តុកស្តម្ភ ទូលាយ មានទ្រព្យច្រើន ។ ខ្ញុំឃើញព្រះសុគតកំពុងចូលទៅក្នុងបុរី ក៏មានចិត្តស្ញប់ស្ញែង បានចូលទៅបួស មិនយូរប៉ុន្មាន ខ្ញុំក៏បានសម្រេចព្រះអរហត្ត ។ ខ្ញុំបានធ្វើចេតិយឲ្យមានទំហំតូចណា ព្រោះអំពើនោះឯង បានជាខ្ញុំកើតមកមានសរីរៈតឿ គួរដល់ការមើលងាយ ( នៃអ្នកផង ) ។ ខ្ញុំបានដល់នូវភាពជាបុគ្គលប្រសើរ ( ខាងមានសំឡេងពីរោះ ) ជាងពួកភិក្ខុ ដែលមានសំឡេងពីរោះ ព្រោះបានបូជាព្រះពុទ្ធជាឥសីទី ៧ ដោយសំឡេងដ៏ពីរោះ ។ ខ្ញុំបានសម្រេចនូវសាមញ្ញផល ឥតមានអាសវៈ ព្រោះបានថ្វាយផ្ទៃស្វាយដល់ព្រះពុទ្ធ និងការនឹករឭកគុណនៃព្រះពុទ្ធ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។

ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ ។

ក្នុងកាលតមក កាលព្រះថេរៈព្យាករអរហត្តផល ទើបពោល ៣ គាថានេះថា

ព្រះភទ្ទិយត្ថេរ នៅក្នុងអម្ពាដការាម ដ៏ប្រសើរ ក្បែរដងព្រៃ
បានដកតណ្ហា ព្រមទាំងឫសចោលអស់ហើយ ជាអ្នកប្រសើរ
ចម្រើនឈាន ក្នុងអារាមនោះ ។

ជនពួកខ្លះ ត្រេកអរដោយសម្ភោរ ដោយពិណ ដោយស្គរជ័យ
ក៏មាន ចំណែកខ្ញុំនៅទៀបគល់ឈើ ត្រេកអរតែក្នុងពុទ្ធសាសនា ។
មួយទៀត ព្រះពុទ្ធទ្រង់ប្រទានពរដល់ខ្ញុំៗ បាននូវពរនោះ ខ្ញុំកាន់
យកនូវកាយគតាសតិជានិច្ច ដើម្បីលោកទាំងអស់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បរេ** បានដល់ ប្រសើរ គឺក្រៃលែង អធិប្បាយថា វិសេស ។ ពិតហើយ **បរ** សព្ទនេះ ប្រាប់ដល់អត្ថថា ក្រៃលែង ដូចក្នុងប្រយោគជាដើមថា **បរំ វិយ មត្តាយ** ហាក់ដូចជាមានប្រមាណដ៏ក្រៃលែង ដូច្នេះ ។

បទថា **អម្ពាដការាមេ** បានដល់ ក្នុងអារាមដែលមានឈ្មោះយ៉ាងនេះ បានឮថា អារាមនោះ សម្បូរដោយម្លប់ និងទឹក ប្រដាប់ដោយដងព្រៃ ដែលគួរជាទីត្រេកអរ ។ ដោយហេតុនោះ ទើបលោកពោលឲ្យវិសេសដោយសព្ទថា **បរេ** ។ ឯអាចារ្យពួកខ្លះពោលថា ក្នុងអម្ពាដកវនៃ គឺក្នុងព្រៃដែលបានឈ្មោះតាមដើមម្កាក់ ។

បទថា **វនសណ្ឌម្ហិ** បានដល់ ក្នុងដងព្រៃ អធិប្បាយថា ក្នុងព្រៃដែលសម្បូរដោយដើមឈើខ្ពស់ៗ គុម្ពោតឈើ និងវល្លិលាយចម្រុះគ្នាយ៉ាងក្រាស់ ។ បទថា **ភទ្ទិយោ** បានដល់ ដែលមានឈ្មោះយ៉ាងនេះ ។ ព្រះថេរៈពោលដល់ខ្លួនឯង ដូចពោលនឹងអ្នកដទៃ ។

បទថា **សមូលំ តណ្ហាមព្ពុយ្ហ** សេចក្តីថា អវិជ្ជា ឈ្មោះថា ឫសគល់ ឈ្មោះថា ឫសគល់នៃតណ្ហា ព្រោះដូច្នោះ ទើបដកនូវតណ្ហា ព្រមទាំងអវិជ្ជា ដោយអរហត្តមគ្គ ។

បទថា **តត្ថ ភទ្ទោវ ឈាយតិ** សេចក្តីថា ជាអ្នកចម្រើន គឺលូតលាស់ដោយសីលជាដើមដែលជាលោកុត្តរ ព្រោះជាអ្នកធ្វើកិច្ចស្រេចហើយ ទើបសម្លឹងដោយឈាន ដែលសម្បយុត្តដោយអរហត្តផល ដោយធម៌ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន ក្នុងដងព្រៃនោះ ។

ព្រះថេរៈ កាលសម្តែងសេចក្តីត្រេកអរក្នុងវិវេករបស់ខ្លួនថា នៅសម្លំដោយផលសុខ និងឈានសមាបត្តិទាំងឡាយ ដូច្នេះហើយ ទើបសម្តែងនូវសេចក្តីនោះ ដោយបំណងពង្រីកសេចក្តីដោយគាថាថា **រមន្តេកេ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **មុទិង្គេហិ** បានដល់ សម្ភោរជាដើម ។

បទថា **វីណាហិ** បានដល់ ពិណដែលជាគ្រឿងដេញជាដើម ។

បទថា **បណវេហិ** សេចក្តីថា កាមភោគីបុគ្គលមួយពួក រមែងត្រេកអរដោយតន្ត្រី តែការត្រេកអររបស់កាមភោគីបុគ្គលទាំងនោះ មិនប្រសើរ មិន

ប្រកបដោយប្រយោជន៍ ។

បទថា **អហាញ្ញ** សេចក្ដីថា ឯខ្ញុំជាអ្នកត្រេកអរក្នុងពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ គឺរបស់ព្រះមានព្រះភាគ ព្រោះហេតុនោះ ទើបខ្ញុំត្រេកអរ គឺត្រេកអរក្រៃលែងត្រង់គល់ឈើ ។

ព្រះថេរៈប្រារព្ធដល់ការត្រេកអរ ក្នុងវិវេករបស់ខ្លួនយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីសរសើរកាយគតាសតិកម្មដ្ឋាន ដែលចម្រើនហើយ សម្រេចអរហត្ត ទើបពោលគាថាថា **ពុទ្ធោ ចេ មេ** ដូច្នេះជាដើម ។

សេចក្ដីនៃគាថានេះដូច្នេះថា ព្រះថេរៈពោលដើម្បីជ្រើសរើសថា បើព្រះពុទ្ធ គឺព្រះមានព្រះភាគ ដែលខ្ញុំអារាធនាថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមពរមួយនឹងទ្រង់ ព្រះសាស្ដាមិនបដិសេធថា ម្នាលភិក្ខុ ព្រះតថាគតទាំងឡាយកន្លងផុតពរហើយ ហើយគប្បីឲ្យពរដល់ខ្ញុំ តាមដែលទូលសូម ហើយពរនោះ ខ្ញុំបានពេញតាមបំណងរបស់ខ្ញុំ គឺធ្វើមនោរថរបស់ខ្ញុំឲ្យដល់ទីបំផុត ព្រះថេរៈកាលមិនសម្ដែងថា ខ្ញុំទទួលពរ ព្រោះធ្វើការសូមពរថា បពិត្រព្រះអង្គដ៏ចម្រើន សូមសត្វលោកទាំងអស់ ចម្រើននូវកាយគតា-សតិសព្វកាល គឺសត្វលោកទាំងអស់ ចូរចម្រើនកាយគតាសតិជានិច្ច ទើបពោលថា **គណ្ហេហំ សព្វលោកស្ស និច្ចំ កាយគតាសតឹ** ដូច្នេះជាដើម ។ ឥឡូវនេះ ព្រះថេរៈបំណងនឹងតិះដៀលការមិនពិចារណា សរសើរការពិចារណា ទើបពោល ៤ គាថានេះថា

ពួកជនណា មើលងាយខ្ញុំ ដោយរូបក្ដី ពួកជនណា តាមខ្ញុំទៅ

ដោយសំឡេងក្តី ពួកជនទាំងនោះ សុទ្ធតែលុះអំណាចនៃឆន្ទរាគៈ មិនស្គាល់ខ្ញុំទេ ។ បុគ្គលណា មិនដឹងធម៌ខាងក្នុង ទាំងមិនឃើញធម៌ខាងក្រៅ បុគ្គលនោះឯង ជាមនុស្សពាល មានធម៌ជាគ្រឿងរាំងរាជុំវិញ តែងត្រូវសំឡេងនាំបន្សាត់ទៅ ។ បុគ្គលណាមិនដឹងធម៌ខាងក្នុង ប៉ុន្តែឃើញច្បាស់នូវធម៌ខាងក្រៅ បុគ្គលនោះ ឈ្មោះថា ឃើញផលខាងក្រៅ ក៏ត្រូវសំឡេងបន្សាត់ទៅដែរ ។ បុគ្គលណា ដឹងច្បាស់នូវធម៌ខាងក្នុង ទាំងឃើញច្បាស់ នូវធម៌ខាងក្រៅ បុគ្គលនោះ ឈ្មោះថា ជាអ្នកឃើញធម៌ ដែលគ្មានអ្វីរាំងរា តែងមិនត្រូវសំឡេងបន្សាត់ទៅឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យេ មំ រូបេន ចាមឹសុ** សេចក្តីថា ជនពួកណាមិនដឹង ទើបប្រមាណខ្ញុំដែលអន់ថយដោយរូប ដែលមិនគួរជ្រះថ្លា គឺថោកថយ និងដោយសរីរៈ គឺធម៌ថា បញ្ញា ក៏ដូចគ្នានឹងរូប អធិប្បាយថា ចំអកថា បុគ្គលនេះថោកថយ ទើបឈ្មោះថា ដៅស្មានដោយខ្លួនឯង ។

បទថា **យេ ច ឃោសេន អន្វគូ** សេចក្តីថា ចំណែកសត្វពួកណាឲ្យតម្លៃ គឺសរសើរខ្ញុំព្រោះសំឡេងពីរោះ ការធ្វើនោះជាការមិនប្រពៃរបស់សត្វទាំងនោះ ព្រោះបុគ្គលមិនគួរមើលងាយខ្ញុំត្រឹមតែរូប ឬមិនគួរឲ្យតម្លៃត្រឹមតែសំឡេង ព្រោះហេតុនោះ ជនទាំងនោះជាអ្នកជាប់ក្នុងអំណាចឆន្ទរាគៈ លះឆន្ទរាគៈមិនបាន ទើបមិនស្គាល់ខ្ញុំដែលលះឆន្ទរាគៈបានហើយ ដោយប្រការទាំងពួង ។

*ដើម្បីសម្តែងថា មនុស្សដូចខ្ញុំ មិនជាវិស័យរបស់ជនទាំងនោះ ព្រោះជាបុគ្គលមានគុណដែលបុគ្គលណាម្នាក់កំណត់មិនបាន ទាំងខាងក្នុង និងខាងក្រៅ ទើបព្រះថេរៈពោលពាក្យជាដើមថា* **អជ្ឈត្តំ** *ដូច្នេះ ។*

*បទថា* **អជ្ឈត្តំ** *បានដល់ ធម៌ មានខន្ធ និងអាយតនៈជាដើមក្នុងសន្តានរបស់ខ្លួន ។*

*បទថា* **ពហិទ្ធា** *បានដល់ ក្នុងសន្តានរបស់អ្នកដទៃ ។ម្យ៉ាងទៀត បទថា* **អជ្ឈត្តំ** *បានដល់ សីលក្ខន្ធដែលជារបស់អសេក្ខៈជាដើមខាងក្នុងរបស់ខ្ញុំ ។ បទថា* **ពហិទ្ធា** *បានដល់ ការប្រព្រឹត្តទៅនៃរូបធម៌ និងការប្រព្រឹត្តទៅនៃចក្ខុវិញ្ញាណជាដើមខាងក្រៅ ដែលប្រកបដោយកាពសម្បូរនៃមារយាទជាដើមរបស់ខ្ញុំនោះឯង ។*

*បទថា* **សមន្តាវរណោ** *សេចក្តីថា ព្រោះមិនដឹងទាំងខាងក្នុង និងខាងក្រៅយ៉ាងនេះ ទើបជាអ្នកប្រកបដោយកិលេសជាគ្រឿងរាំងដោយប្រពៃ គឺជាអ្នកមានគតិនៃញាណដែលត្រូវរាំងហើយ ។*

*បទថា* **ស វេ ឃោសេន វុយ្ហតិ** *សេចក្តីថា បុគ្គលពាលដែលអ្នកដទៃទូន្មានឲ្យដឹងបាននោះ រមែងបន្សាត់ទៅ គឺត្រូវនាំចេញទៅ បានដល់ ត្រូវអូសទាញមកតាមសំឡេងឃោសនា គឺតាមពាក្យរបស់អ្នកដទៃ ។*

*បទថា* **ពហិទ្ធា ច វិបស្សតិ** *សេចក្តីថា បុគ្គលណារមែងមិនដឹងខាងក្នុង ដោយន័យដូចពោលហើយ តែរមែងឃើញដោយជាក់ច្បាស់ខាងក្រៅ តាមគន្លងដែលបានស្តាប់ហើយ ឬតាមរក្សាមារយាទដែលល្អជាដើម គឺរមែង*

យល់ថា ភិក្ខុនេះ ជាអ្នកប្រកបដោយគុណវិសេស បុគ្គលនោះ ជាអ្នកឃើញតែផលខាងក្រៅ គឺកាន់យកត្រឹមតែផល ដោយការកាន់យកតាមការយល់រមែងរសាត់ទៅតាមសំឡេង ដោយន័យដូចពោលហើយ សូម្បីបុគ្គលនោះក៏រមែងមិនស្គាល់បុគ្គលដូចខ្ញុំ ។

ឯបុគ្គលណាដឹងខាងក្នុង គឺដឹងនូវគុណ មានសីលក្ខន្ធដែលជារបស់អសេក្ខៈជាដើមខាងក្នុងរបស់ព្រះខីណាស្រព និងដឹងខាងក្រៅ គឺការប្រកបដោយគុណវិសេស ដោយជាក់ច្បាស់ ដោយការកំណត់បដិបទារបស់ព្រះខីណាស្រពនោះ ជាអ្នកមានការឃើញមិនត្រូវគ្នា ( ជាមួយបុគ្គលខាងដើមនោះ ) គឺជាបុគ្គលដែលបុគ្គលណាម្នាក់រារាំងមិនបាន អាចដឹង គឺឃើញនូវគុណនៃព្រះអរិយៈទាំងឡាយ បុគ្គលនោះ រមែងមិនអណ្តែតទៅដោយហេតុត្រឹមតែសំឡេង ព្រោះឃើញតាមសេចក្តីពិត ដូច្នេះ ។៙

**អដ្ឋកថា លកុណ្ឌកភទ្ទិយត្ថេរគាថា ចប់**

# សុត្តន្តបិដក

## ភទ្ទត្ថេរគាថា

[ ២២៧ ] ខ្ញុំជាកូនប្រុសតែមួយ ជាទីស្រឡាញ់ របស់មាតា ជាទីស្រឡាញ់ របស់បិតា ដែលមាតាបិតា បានហើយ ដោយការប្រព្រឹត្តវត្តដ៏ច្រើនផង ដោយការបន់ស្រន់ផង ។ ឯមាតា និងបិតាទាំងពីរនោះ ជាអ្នកប្រាថ្នាសេចក្តីចម្រើន ស្វែងរកប្រយោជន៍ ទើបនាំខ្ញុំទៅថ្វាយព្រះពុទ្ធ ព្រោះសេចក្តីអនុគ្រោះ ( ដោយពាក្យថា ) កូននេះធ្លាប់សុខ ចម្រើនដោយសេចក្តីសុខ ខ្ញុំព្រះអង្គបានដោយលំបាក បពិត្រព្រះលោកនាថ យើងខ្ញុំសូមថ្វាយកូននេះ ឲ្យជាអ្នកបម្រើព្រះអង្គ អ្នកទ្រង់ឈ្នះមារ ។ ទើបព្រះសាស្តាទទួលខ្ញុំ ហើយត្រាស់ពាក្យនេះនឹងព្រះអានន្ទថា អ្នកចូរបំបួសកុមារនេះឲ្យឆាប់ កុមារនេះនឹងបានជាបុរសអាជានេយ្យ ។ លុះព្រះសាស្តា អ្នកឈ្នះមារ ទ្រង់ឲ្យបំបួសខ្ញុំរួចហើយ ក៏ស្តេចចូលទៅកាន់វិហារ នាកាលព្រះអាទិត្យមិនទាន់លិច លំដាប់នោះ ចិត្តរបស់ខ្ញុំក៏ផុតចាកអាសវៈ ។ តពីនោះមក ព្រះសាស្តាទ្រង់ចេញចាកទីសម្ងំ លះបង់ហើយត្រាស់នឹងខ្ញុំថា ម្នាលភទ្ទៈ អ្នកចូរមក ព្រះវាចានោះ បានជាឧបសម្បទារបស់ខ្ញុំ ។ ខ្ញុំបានឧបសម្បទា ក្នុងអាយុ ៧ ឆ្នាំ អំពីកំណើត ខ្ញុំបានសម្រេចវិជ្ជា ៣ ហើយ ឱ ! ព្រះធម៌ ល្អណាស់តើ ។

ភទ្ទត្ថេរ

# អដ្ឋកថា

## ភទ្ទត្ថេរគាថា

[ ២២៧ ] គាថារបស់ព្រះភទ្ទត្ថេរ មានពាក្យផ្ដើមថា **ឯកបុត្តោ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះ បូជាព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ និងភិក្ខុសង្ឃប្រមាណមួយសែនអង្គ ដោយបច្ច័យ ៤ មានចីវរជាដើម ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលសេដ្ឋី ក្នុងក្រុងសាវត្ថី មុនកើត មាតាបិតាមិនមានបុត្ត ធ្វើការបន់ស្រន់ចំពោះទេវតាជាដើម ក៏មិនបាន ទើបចូលទៅគាល់ព្រះសាស្ដា ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន បើខ្ញុំព្រះអង្គទាំង ២ បានបុត្តត្រឹមតែម្នាក់សោត នឹងថ្វាយបុត្តនោះ ដល់ព្រះអង្គដើម្បីឲ្យជាទាសៈ ដូច្នេះហើយ ក៏ទៅ ។ គាប់ជួនទេវបុត្តមួយអង្គជិតអស់អាយុ ដឹងបំណងព្រះសាស្ដា ត្រូវសក្កទេវរាជត្រាស់ថា ចូរអ្នកកើតក្នុងត្រកូលឈ្មោះនោះ ទើបកើតក្នុងត្រកូលសេដ្ឋីនោះ ពួកញាតិបានដាក់ឈ្មោះថា **ភទ្ទៈ** ។

កុលបុត្តនោះកើតបានអាយុ ៧ ឆ្នាំ មាតាបិតាបានតែងខ្លួន ហើយនាំទៅគាល់ព្រះមានព្រះភាគ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទារកដែលខ្ញុំព្រះអង្គទាំង ២ សូមទ្រង់ ឥឡូវបានមកហើយ គឺទារកនេះ ខ្ញុំព្រះអង្គទាំង ២ សូមថ្វាយទារកនេះដល់ទ្រង់ ។

ព្រះសាស្តាទ្រង់ត្រាស់នឹងព្រះអានន្ទត្ថេរថា ចូរអ្នកបំបួសទារកនេះ ត្រាត្រាស់ហើយ ទើបយាងចូលព្រះគន្ធកុដិ ។ ព្រះថេរៈឲ្យកុលបុត្តនោះបួសហើយប្រាប់គន្ធវិបស្សនាដោយសង្ខេប ព្រោះជាអ្នកសម្បូរដោយឧបនិស្ស័យ បំពេញវិបស្សនាកម្មដ្ឋាន កាលព្រះអាទិត្យមិនទាន់លិច បំពេញភាវនា ក៏បានអភិញ្ញា ៦ សមដូចគាថាព័ន្ធដែលលោកពោលក្នុងអបទានថា

ប្រជុំជនទាំងពួង បានចូលគាល់ព្រះសម្ពុទ្ធ ព្រះនាមបទុមុត្តរៈ ទ្រង់មានព្រះហឫទ័យប្រកបដោយមេត្តា ជាអ្នកប្រាជ្ញដ៏ប្រសើរ ទ្រង់ដឹកនាំសត្វដ៏វិសេស ក្នុងលោកទាំងមូល ។ ពួកជនទាំងពួង តែងថ្វាយនូវសដូវផង នំឈ្មោះបវាកៈផង អាមិសៈ ទឹកនិងភោជនផង ដល់ព្រះសាស្តា ជាបុញ្ញក្ខេត្តដ៏ប្រសើរ ។ ឯខ្ញុំក៏គិតថា នឹងនិមន្តព្រះពុទ្ធដ៏ប្រសើរផង ព្រះសង្ឃដ៏ប្រសើរផង ហើយនឹងថ្វាយទានដល់ព្រះសម្ពុទ្ធ ជាទេវតាដ៏ក្រៃលែងជាងទេវតា ទ្រង់មិនញាប់ញ័រដោយលោកធម៌ ។ ពួកជនទាំងនុ៎ះ ដែលខ្ញុំបញ្ជូនទៅឲ្យនិមន្ត ក៏បាននិមន្តព្រះតថាគតផង ភិក្ខុសង្ឃទាំងអស់ជាបុញ្ញក្ខេត្តដ៏ប្រសើរផង ។ ខ្ញុំបានក្រាលបល្ល័ង្កមានថ្លៃមួយសែន ជាវិការនៃមាស កម្រាលឈ្មោះគោណកៈ ព្រមដោយកម្រាលញាត់គ កម្រាលធ្វើដោយរោមសត្វ ជាផ្កាចង្កោមផង កម្រាលដែលធ្វើដោយសម្បកឈើ កម្រាលដែលត្បាញដោយអំបោះផង ។ ខ្ញុំក្រាលនូវអាសនៈ មានថ្លៃ

ដ៏ច្រើន គួរដល់ព្រះពុទ្ធ ឯព្រះបទុមុត្តរៈ ទ្រង់ជ្រាបច្បាស់នូវលោក ទ្រង់ជាទេវតាប្រសើរជាងទេវតា ជានរាសភៈ ទ្រង់កុះករដោយភិក្ខុសង្ឃ ស្តេចចូលមកកាន់ទ្វារផ្ទះរបស់ខ្ញុំ ខ្ញុំក្រោកទទួលព្រះសម្ពុទ្ធ ជាលោកនាថ ដ៏ទ្រង់យស ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ ញុំាងភិក្ខុសង្ឃមួយសែនអង្គ ទាំងព្រះពុទ្ធជាលោកនាយក ឲ្យចូលមកកាន់ផ្ទះរបស់ខ្លួន ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ ( ញុំាងព្រះសម្ពុទ្ធ និងភិក្ខុសង្ឃ ) ឲ្យឆ្អែតស្កប់ស្កល់ ដោយចង្ហាន់ដ៏ថ្លៃថ្លា ព្រះបទុមុត្តរៈ ទ្រង់ជ្រាបច្បាស់នូវលោក ទ្រង់គួរទទួលគ្រឿងបូជា ទ្រង់គង់ក្នុងភិក្ខុសង្ឃ ហើយត្រាស់នូវគាថាទាំងនេះថា

កុលបុត្តណា ថ្វាយអាសនៈ ជាវិការនៃមាស ក្រាលដោយកម្រាលគោណកៈនេះ តថាគតនឹងសម្តែងសរសើរនូវកុលបុត្តនោះ អ្នកទាំងឡាយ ចូរស្តាប់តថាគតសម្តែងចុះ ។ កុលបុត្តនោះ នឹងសោយទេវរជ្ជសម្បត្តិ អស់ ៧៤ ដង នឹងសោយទិព្វសម្បត្តិ មានពួកស្រីអប្សរចោមរោម នឹងបានគ្រប់គ្រងផែនដីបានជាស្តេចក្នុងប្រទេស មួយពាន់ដង ។ នឹងកើតជាស្តេចចក្រពត្តិ អស់ចំនួន ៥១ ដង នឹងបានជាអ្នកមានត្រកូលខ្ពស់ក្នុងកំណើតដែលមានក្នុងភពទាំងពួង ។ លុះកាលជាខាងក្រោយ កុលបុត្តនោះ ត្រូវកុសលមូលដាស់តឿន ក៏ចេញបួស

មានទាមថាភទ្ទិយៈ នឹងបានជាសាវ័ករបស់ព្រះសាស្តា ។ ខ្ញុំប្រកបរឿយៗ នូវវិវេក អាស្រ័យនៅក្នុងសេនាសនៈដ៏ស្ងាត់ ផលទាំងអស់ ខ្ញុំបានសម្រេចហើយ ក្នុងថ្ងៃនេះ ខ្ញុំមានកិលេសលះបង់ហើយ ។ ព្រះសព្វញ្ញូជាលោកនាយក ទ្រង់ជ្រាបនូវហេតុសព្វគ្រប់របស់ខ្ញុំ ទើបទ្រង់គង់ក្នុងភិក្ខុសង្ឃ ហើយតាំងខ្ញុំក្នុងទីជាឯតទគ្គៈ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

១- ក្នុងអបទាន ជាភទ្ទិយកាឡិគោធាយបុត្តត្ថេរ ។

ព្រះមានព្រះភាគទ្រង់ជ្រាបថា អភិញ្ញា ៦ កើតដល់សាមណេរហើយ ទើបត្រាស់ថា មកភទ្ទៈ ។ រំពេចនោះឯង ព្រះភទ្ទៈនោះចូលទៅគាល់ព្រះមុនីថ្វាយបង្គំហើយ បានឈរផ្គងអញ្ជលីក្នុងទីជិតព្រះសាស្តា ។ ព្រះវាចាដែលព្រះសាស្តា ត្រាស់ដូច្នោះឯង បានជាឧបសម្បទារបស់ព្រះថេរៈ ។ បានឮថា ឧបសម្បទានោះ ឈ្មោះថា ពុទ្ធឧបសម្បទា ។ ព្រះថេរៈកាលព្យាករនូវអរហត្តផល ដោយបំណងពោលដល់ប្រវត្តិរបស់ខ្លួនតាំងអំពីកើត ទើបពោលគាថាទាំងនេះថា

ខ្ញុំជាកូនប្រុសតែមួយ ជាទីស្រឡាញ់របស់មាតា ជាទីស្រឡាញ់របស់បិតា ដែលមាតាបិតាបានហើយ ដោយការប្រព្រឹត្តវត្តដ៏ច្រើនផង ដោយការបន់ស្រន់ផង ។ ឯមាតា និងបិតាទាំងពីរ

នោះ ជាអ្នកប្រាថ្នាសេចក្ដីចម្រើន ស្វែងរកប្រយោជន៍ ទើបនាំខ្ញុំទៅថ្វាយព្រះពុទ្ធ ព្រោះសេចក្ដីអនុគ្រោះ ( ដោយពាក្យថា ) កូននេះធ្លាប់សុខ ចម្រើនដោយសេចក្ដីសុខ ខ្ញុំព្រះអង្គបានដោយលំបាក បពិត្រព្រះលោកនាថ យើងខ្ញុំសូមថ្វាយកូននេះ ឲ្យជាអ្នកបម្រើព្រះអង្គ អ្នកទ្រង់ឈ្មោះមារ ។ ទើបព្រះសាស្ដាទទួលខ្ញុំហើយត្រាស់ពាក្យនេះ នឹងព្រះអានន្ទថា អ្នកចូរបំបួសកុមារនេះឲ្យឆាប់ កុមារនេះ នឹងបានជាបុរសអាជានេយ្យ ។ លុះព្រះសាស្ដា អ្នកឈ្មោះមារ ទ្រង់ឲ្យបំបួសខ្ញុំរួចហើយ ក៏ស្ដេចចូលទៅកាន់វិហារ នាកាលព្រះអាទិត្យមិនទាន់លិច លំដាប់នោះ ចិត្តរបស់ខ្ញុំក៏ផុតចាកអាសវៈ ។ តពីនោះមក ព្រះសាស្ដាទ្រង់ចេញចាកទីសម្ងំ លះបង់ហើយ ត្រាស់នឹងខ្ញុំថា ម្នាលកុទ្ទៈ អ្នកចូរមកព្រះវាចានោះ បានជាឧបសម្បទារបស់ខ្ញុំ ។ ខ្ញុំបានឧបសម្បទាក្នុងអាយុ ៧ ឆ្នាំ អំពីកំណើត ខ្ញុំបានសម្រេចវិជ្ជា ៣ ហើយ ឱ! ព្រះធម៌ ល្អណាស់តើ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វតចរិយាហិ** សេចក្ដីថា ដោយការបានស្ដាប់ពាក្យរបស់ព្រាហ្មណ៍ទាំងឡាយ ដែលពោលថា អ្នកទាំងឡាយធ្វើយ៉ាងនេះ នឹងបានបុត្ត ហើយក៏ប្រព្រឹត្តវត្ត មានការផឹកទឹកខីរៈ មិនបរិភោគអាហារជាដើម ។

បទថា **អាយាចនាហិ** បានដល់ ដោយសូមចំពោះទេវតា និងសូម

ចំពោះព្រះសាស្តា ។

ពាក្យថា **អាយាចនាហិ** នេះប៉ុណ្ណោះជាហេតុក្នុងការបានបុត្តនេះ ព្រះថេរៈពោលពាក្យដទៃ ដើម្បីសម្តែងកិច្ចបដិបត្តិរបស់មាតាបិតា និងដើម្បីសម្តែងការៈដែលមាតាបិតាបានបុត្តលំបាក ។

បទថា **តេ** សំដៅដល់ មាតាបិតា ។ បទថា **ឧបនាមយុំ** បានដល់ នាំចូលទៅថ្វាយ ។ បទថា **សុខេធិតោ** បានដល់ ចម្រើនដោយសេចក្តីសុខ ។ បទថា **តេ** ស្មើគ្នានឹង **តុយ្ហំ** ប្រែថា របស់ព្រះអង្គ ។ បទថា **បរិចារិកំ** បានដល់ ឲ្យជាអ្នកធ្វើករណីយកិច្ច ។

បទថា **ហោស្សត្យាជានិយោ អយំ** សេចក្តីថា កុមារនោះនឹងជាអ្នកត្រាស់ដឹងរហ័ស ក្នុងសាសនារបស់តថាគត ព្រោះហេតុនោះ ទើបព្រះសាស្តាត្រាស់ពាក្យនោះថា ចូរប្រញាប់ឲ្យបួសក្នុងថ្ងៃនេះឯង ។

បទថា **បព្វាជេត្វាន** បានដល់ ត្រាស់នឹងព្រះអានន្ទត្ថេរឲ្យបំបួស ។ បទថា **វិហារំ** បានដល់ ព្រះគន្ធកុដិ ។ បទថា **អនោគ្គតស្មឹ សុរិយស្មឹ** បានដល់ កាលព្រះអាទិត្យមិនទាន់អស្តង្គត ។ បទថា **តតោ ចិត្តំ វិមុច្ចិ មេ** សេចក្តីថា ខាងមុខអំពីប្រារព្ធវិបស្សនានោះ មិនយូរប៉ុន្មាន ចិត្តរបស់ខ្ញុំ ក៏រួចផុតចាកអាសវៈទាំងពួង គឺខ្ញុំជាអ្នកអស់អាសវៈហើយ ។

បទថា **តតោ** បានដល់ ខាងក្រោយអំពីការអស់អាសវៈរបស់ខ្ញុំ ។

បទថា **និវដ្ដិត្វា** បានដល់ ចូលផលសមាបត្តិដែលព្រះអង្គដល់ព្រមហើយ ហើយទ្រង់ចេញអំពីផលសមាបត្តិនោះ ។

ព្រោះហេតុនោះ ទើបលោកពោលថា **បដិសល្លានវុដ្ឋិតោ** ដូច្នេះ ។ បទថា **សា មេ អាសូបសម្បទា** សេចក្ដីថា ព្រះវាចារបស់ព្រះសាស្ដា ដែលត្រាស់ចំពោះខ្ញុំថា ម្នាលភទ្ទៈ អ្នកចូរមក នុ៎ះឯងជាឧបសម្បទារបស់ខ្ញុំ ។

បទថា **ជាតិយា សត្តវស្សេន លទ្ធា មេ ឧបសម្បទា** នេះ ព្រះថេរៈសម្ដែងដល់ការអនុគ្រោះយ៉ាងល្អ ដែលព្រះសាស្ដាទ្រង់ធ្វើ និងដែលព្រះ-សាសនាជានិយ្យានិកធម៌ នាំសត្វចេញចាកទុក្ខ ដោយប្រការយ៉ាងនេះ ។ ដោយហេតុនោះ ទើបលោកពោលថា **អហោ ធម្មសុធម្មតា** គួរអស្ចារ្យព្រះធម៌ ជាធម៌ល្អ ដូច្នេះ ។

ក្នុងទីនេះ សូម្បីព្រះថេរៈប្រកាសភាពជាព្រះខីណាស្រព ដោយពាក្យថា ចិត្តរបស់ខ្ញុំក៏ផុតចាកអាសវៈ ហើយសម្ដែងចែកលោកិយអភិញ្ញាចេញទៅដោយពាក្យថា **តិស្សោ វិជ្ជា អនុប្បត្តា** ខ្ញុំបានសម្រេចវិជ្ជា ៣ ហើយ ដើម្បីប្រកាសថា លោកសម្រេចអភិញ្ញា ៦ ហើយ ។ ដោយហេតុនោះ ទើបលោកពោលក្នុងអបទានថា អភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ដូច្នេះ ៕

## អដ្ឋកថា ភទ្ទត្ថេរគាថា ចប់

# សុត្តន្តបិដក

## សោបាកត្ថេរគាថា

[ ២២៨ ] ខ្ញុំបានឃើញព្រះសាស្តា ព្រះអង្គឧត្តមជាងជន ដែលកំពុងចង្រ្កម ឰដ៏ម្លប់ប្រាសាទ គឺគន្ធកុដិ ក៏បានចូលទៅគាល់ព្រះសាស្តានោះក្នុងទីនោះ ហើយថ្វាយបង្គំនូវព្រះអង្គ ជាបុរសដ៏ឧត្តម ។ ខ្ញុំធ្វើនូវចីវរ ឆៀងស្មាម្ខាង ហើយផ្គុំដៃ បានដើរចង្រ្កមតាមព្រះពុទ្ធ ព្រះអង្គប្រាសចាកធូលី គឺរាគៈ ឧត្តមជាងសព្វសត្វ ។ លំដាប់នោះ ព្រះសាស្តាព្រះអង្គទ្រង់ឈ្លាសវៃ ជ្រាបនូវប្រស្នា បានសួរប្រស្នាចំពោះខ្ញុំៗ ក៏មិនតក់ស្លុត មិនភិតភ័យ បានឆ្លើយប្រស្នាថ្វាយព្រះសាស្តា ។ កាលដែលខ្ញុំឆ្លើយប្រស្នាចប់ហើយ ព្រះតថាគត ក៏ទ្រង់អនុមោទនា ហើយទ្រង់ទតមើលភិក្ខុសង្ឃ បានត្រាស់សេចក្តីនេះថា ។ សោបាកៈនេះ ប្រើប្រាស់បច្ច័យ គឺចីវរ បិណ្ឌបាត ទីដេក និងទីអង្គុយរបស់ពួកអ្នកដែនអង្គៈ មគធៈណា ពួកជនអ្នកដែនអង្គៈ មគធៈនោះ ហៅពេញជាមានលាភ ។ មួយទៀត ព្រះសាស្តាត្រាស់នូវការក្រោកទទួល និងការប្រព្រឹត្តសមគួរ ថាជាលាភរបស់ពួកជនអ្នកដែនអង្គៈ មគធៈនោះ ។ ( ព្រះសាស្តាត្រាស់ថា ) ម្នាលសោបាកៈ តាំងពីថ្ងៃនេះជាដើមទៅ អ្នកចូរមកជួបនឹងតថាគតចុះ ម្នាលសោបាកៈ ការដោះស្រាយប្រស្នានេះឯង ចូរជាឧបសម្បទារបស់អ្នកចុះ ។ ខ្ញុំមានអាយុ ៧ ឆ្នាំអំពីកំណើត ក៏បានឧបសម្បទាទ្រទ្រង់រាងកាយជាទីបំផុត ឱ ! ព្រះធម៌ ល្អណាស់តើ ។

# អដ្ឋកថា

## សោបាកត្ថេរគាថា

[ ២២៨ ] គាថារបស់ព្រះសោបាកត្ថេរ មានពាក្យផ្តើមថា **ទិស្វា បាសាទឆាយាយំ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងសាសានារបស់ព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈ កើតក្នុងត្រកូលព្រាហ្មណ៍ ដល់នូវភាពជាអ្នកដឹងក្តីហើយ សម្រេចក្នុងវិជ្ជា និងសិប្បៈទាំងឡាយរបស់ពួកព្រាហ្មណ៍ ឃើញទោសក្នុងកាម ទើបលះនូវការគ្រប់គ្រងផ្ទះ បួសជាតាបសត្រង់ភ្នំមួយ ។ ព្រះសាស្តា ទ្រង់ជ្រាបថា តាបសនេះជិតធ្វើកាលកិរិយា ទើបយាងទៅ ។ តាបសឃើញព្រះមានព្រះភាគហើយ មានចិត្តជ្រះថ្លា កាលនឹងប្រកាសភាពដែលបីតិ និងបាមោជ្ជដ៏ក្រៃលែង ទើបរៀបចំអាសនៈផ្កាថ្វាយ ព្រះសាស្តាគង់លើអាសនៈនោះហើយ ត្រាស់ធម្មីកថាដែលសម្បយុត្តដោយអនិច្ចតា កាលតាបសនោះកំពុងឃើញនោះឯង បានយាងទៅតាមអាកាស ។ តាបសលះការប្រកាន់ថា ទៀង ដែលខ្លួនធ្លាប់ប្រកាន់ក្នុងកាលមុន ហើយតាំងអនិច្ចសញ្ញាក្នុងហទយៈ ធ្វើកាលកិរិយាហើយ កើតក្នុងទេវលោក អន្ទោលទៅមកក្នុងទេវតា និងក្នុងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលចុងភៅ ក្នុងនគររាជគ្រឹះ មានឈ្មោះដោយកំណើតថា សោបាកៈ ។ ឯអាចារ្យពួកខ្លះពោលថា លោកកើតក្នុងត្រកូលឈ្នួញ ឯពាក្យថា **សោបាក**

គ្រាន់តែជាឈ្មោះប៉ុណ្ណោះ តែពាក្យនេះ ខុសនឹងបាលីក្នុងអបទាន ព្រោះលោក ពោលថា កាលដល់កពចុងក្រោយ ខ្ញុំកើតក្នុងកំណើតសោបាកៈ ដូច្នេះ ។ កាលកុលបុត្តកើតបាន ៤ ខែ បិតាក៏ស្លាប់ ទើបឪពុកមាចិញ្ចឹម ។ កុលបុត្ត នេះកើតបាន ៧ ឆ្នាំដោយលំដាប់ ថ្ងៃមួយ ឪពុកមាខឹងក្រោធ ព្រោះឈ្មោះ គ្មានឹងកូនរបស់ខ្លួន ទើបនាំទៅកាន់ព្រៃខ្មោច យកខ្សែចងដៃទាំង ២ ភ្ជាប់គ្នា ហើយយកកន្ទុយខ្សែចងយ៉ាងជាប់ជាមួយនឹងសាកសពមនុស្សស្លាប់ ហើយ ចៀសចេញទៅ ដោយគិតថា ចចកចូរស៊ីវា ។ ព្រោះហេតុកុមារនោះ ជា សត្វដែលកើតក្នុងបច្ឆិមភព មិនអាចស្លាប់ឯង ព្រោះផលបុណ្យរបស់ទារក សត្វទាំងឡាយមានចចកជាដើម មិនអាចគ្របសង្កត់បានឡើយ ក្នុងកណ្តាល យប់ ទារកនោះរវើរវាយថា

គតិរបស់ខ្ញុំ ដែលមិនមានគតិដូចម្តេច ផៅពង្សរបស់ខ្ញុំ ដែលមិនមាន ផៅពង្ស ជាអ្នកណា អ្នកណាហ្ន៎ ជួយខ្ញុំដែលជាប់ចំណងក្នុងព្រៃខ្មោច ឲ្យ ផុតភ័យ ។ ក្នុងពេលនោះ ព្រះសាស្តាទ្រង់ប្រមើលមើលវេនេយ្យសត្វ ដែល ជាផៅពង្ស ទ្រង់ឃើញឧបនិស្ស័យនៃអរហត្ត ភ្លឺរន្ទាលប្រាលផ្លោ ក្នុងហទយៈ របស់ទារក ទើបទ្រង់ផ្សាយព្រះឱភាស ធ្វើឲ្យកើតសតិ ហើយត្រាស់យ៉ាង នេះថា

មកចុះ សោបាកៈ អ្នកកុំខ្លាចឡើយ ចូរសម្លឹងមើលតថាគតៗ នឹង ញុំាងអ្នកឲ្យឆ្លងផុត ដូចព្រះចន្ទផុតបាកមាត់រាហូ ដូច្នោះ ។

ទារកផុតចាកចំណងដោយពុទ្ធានុភាព បានជាព្រះសោតាបន្ន ក្នុង

កាលចប់គាថា បានឈរត្រង់មុខព្រះគន្ធកុដិ ។ មាតារបស់ទារកនោះ មិនឃើញបុត្ត ទើបសួរឪពុកមា កាលឪពុកមាមិនប្រាប់ការប្រព្រឹត្តទៅរបស់បុត្តនោះ ទើបទៅរកក្នុងទីផ្សេងៗ បានទៅកាន់សម្នាក់ព្រះសាស្តា ដោយគិតថា បានឮថា ព្រះពុទ្ធទ្រង់ដឹងអតីត អនាគត និងបច្ចុប្បន្ន បើដូច្នោះ អញនឹងចូលទៅគាល់ព្រះមានព្រះភាគ ទូលសួរការប្រព្រឹត្តទៅនៃបុត្តរបស់អញ ។ ព្រះសាស្តាទ្រង់បំបាំងទារកនោះដោយឫទ្ធិ កាលនាងទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនឃើញបុត្តរបស់ខ្ញុំព្រះអង្គ ព្រះមានព្រះភាគ ទ្រង់ជ្រាបការប្រព្រឹត្តទៅរបស់កូនខ្ញុំព្រះអង្គខ្លះដែរឬទេ ព្រះសាស្តាទ្រង់ត្រាស់ ( ធម្មបទ ) ថា

កាលបុគ្គលត្រូវមច្ចុគ្របសង្កត់ហើយ កូនទាំងឡាយ មិនមានដើម្បីជាទីពឹង បិតាក៏មិនមាន ទាំងផៅពង្សក៏មិនមានដើម្បីជាទីពឹងឡើយ សេចក្តីទីពឹងក្នុងញាតិទាំងឡាយក៏មិនមាន ដូច្នេះ ។

ស្ត្រីនោះបានស្តាប់ធម៌នោះហើយ ក៏បានជាព្រះសោតាបន្ន ទារកក៏បានសម្រេចអរហត្ត សមដូចគាថាព័ន្ធដែលលោកពោលក្នុងអបទានថា

កាលខ្ញុំកំពុងតែសម្អាតញកជិតភ្នំដ៏ឧត្តមប្រសើរ ព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថៈ ទ្រង់ស្តេចមកកាន់សម្នាក់ខ្ញុំ ។ លុះខ្ញុំឃើញព្រះសម្ពុទ្ធស្តេចមកដល់ ក៏ក្រាលកម្រាល ហើយបូជាអាសនៈជាវិការនៃផ្កា ចំពោះព្រះសម្ពុទ្ធ ជាលោកជេដ្ឋ ព្រះអង្គមិនញាប់ញ័រ ដោយលោកធម៌ ។ ព្រះលោកនាយក ព្រះនាមសិទ្ធត្ថៈ

គង់លើបុប្ផាសនៈហើយ ជ្រាបគតិរបស់ខ្ញុំ ទើបទ្រង់បន្ទឺឡើងនូវអនិច្ចតាធម៌ថា សង្ខារទាំងឡាយ មិនទៀងទាត់ពិត មានការកើតឡើង និងការសូន្យទៅវិញជាធម្មតា លុះកើតឡើងហើយ រមែងរលត់ទៅវិញ ការរម្ងាប់នូវសង្ខារទាំងឡាយនោះបាន ទើបនាំមកនូវសេចក្តីសុខ ។ ព្រះសព្វញ្ញុពុទ្ធ ព្រះអង្គជាច្បងក្នុងលោក ជានរាសភៈ ជាអ្នកប្រាជ្ញ លុះទ្រង់សំដែងអនិច្ចតាធម៌នេះចប់ហើយ ទើបស្តេចហោះឡើងទៅឰដ៏អាកាស ដូចស្តេចហង្ស កាលហើរទៅឰដ៏អាកាស ។ ខ្ញុំបានលះបង់នូវទិដ្ឋិរបស់ខ្លួន ហើយចម្រើននូវអនិច្ចសញ្ញា ខ្ញុំក៏បានចម្រើនអស់ ១ ថ្ងៃ ហើយធ្វើមរណកាលក្នុងទីនោះ ។ ខ្ញុំសោយសម្បត្តិទាំងពីរ ត្រូវកុសលមូលដាស់តឿនក៏បានដល់នូវបច្ឆិមភព ខ្ញុំចូលទៅកាន់កំណើតប្រកបដោយផល ។ ខ្ញុំមានអាយុ ៧ ឆ្នាំ ខ្ញុំចេញចាកផ្ទះចូលទៅកាន់ផ្នួស បានដល់អរហត្តផល ។ ខ្ញុំមានព្យាយាមតឹងរ៉ឹងណាស់ មានចិត្តបញ្ជូនទៅកាន់សមាធិ មានចិត្តតម្កល់ខ្ជាប់ល្អក្នុងសីល ញុំាងព្រះពុទ្ធ ជាមហានាគ ឲ្យប្រោសប្រាណ ហើយបានឧបសម្បទា ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយផ្កា ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានចម្រើននូវអនិច្ចសញ្ញា ក្នុងកាលនោះ ការអស់អាសវៈក៏បានសម្រេចដល់ខ្ញុំ

ដែលចម្រើនសញ្ញានោះ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦
នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះសម្ពុទ្ធ
ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ ។

លំដាប់នោះ ព្រះមានព្រះភាគទ្រង់រំសាយឫទ្ធិ ។ ឯមាតាបានឃើញបុត្ត មានចិត្តត្រេកអរ បានស្តាប់ថា បុត្តនោះ ជាព្រះខីណាស្រព ទើបអនុញ្ញាតឲ្យបួសហើយក៏ទៅ ។ ព្រះសោបាកៈនោះចូលទៅគាល់ព្រះសាស្តា ដែលកំពុងយាងចង្ក្រមត្រង់ស្រមោលព្រះគន្ធកុដិ ថ្វាយបង្គំហើយ ចង្ក្រមតាមព្រះសាស្តា ព្រះមានព្រះភាគបំណងនឹងប្រទានឧបសម្បទាដល់សាមណេរ ទើបត្រាស់សួរបញ្ហា ១០ មានពាក្យថា **ឯកំ នាម កឹ** អ្វី ឈ្មោះថា មួយ ដូច្នេះជាដើម ។

ឯសោបាកៈនោះ កាន់យកព្រះពុទ្ធបំណងប្រៀបធៀបនឹងសព្វញ្ញុតញ្ញាណ ទូលឆ្លើយបញ្ហានោះ ដោយន័យជាដើមថា **សព្វេ សត្តា អាហារដ្ឋិតិកា** សត្វទាំងឡាយតាំងនៅបានដោយអាហារ ដូច្នេះជាដើម ។ ដោយហេតុនោះ ទើបបញ្ហាទាំងនោះ ឈ្មោះថា កុមារបញ្ហា ។ ព្រះសាស្តា ទ្រង់មានព្រះហឫទ័យអនុគ្រោះ ព្រោះការព្យាករណ៍បញ្ហារបស់លោក ទ្រង់ក៏អនុញ្ញាតឧបសម្បទា ដោយហេតុនោះ ទើបឧបសម្បទានោះ ឈ្មោះថា បញ្ហាព្យាករណឧបសម្បទា គឺឧបសម្បទាដោយការព្យាករណ៍បញ្ហា ។ ព្រះថេរៈកាលប្រកាសប្រវត្តិរបស់ខ្លួន និងព្យាករអរហត្តផល ទើបពោលគាថាទាំងនេះថា

ខ្ញុំបានឃើញព្រះសាស្តា ព្រះអគ្គឧត្តមជាងជន ដែលកំពុងចង្ក្រម

ពួដ៏មួប់ប្រាសាទ គឺគន្ធកុដិ ក៏បានចូលទៅគាល់ព្រះសាស្តានោះ ក្នុងទីនោះ ហើយថ្វាយបង្គំនូវព្រះអង្គ ជាបុរសដ៏ឧត្តម ។ ខ្ញុំធ្វើនូវចីវរឆៀងស្មាម្ខាង ហើយផ្គុំដៃ បានដើរចង្រ្កមតាមព្រះពុទ្ធ ព្រះអង្គប្រាសចាកធូលី គឺរាគៈ ឧត្តមជាងសព្វសត្វ ។ លំដាប់នោះ ព្រះសាស្តាព្រះអង្គទ្រង់ឈ្លាសវៃ ជ្រាបនូវប្រស្នា បានសួរប្រស្នាចំពោះខ្ញុំៗ ក៏មិនតក់ស្លុត មិនភិតភ័យ បានឆ្លើយប្រស្នាថ្វាយព្រះសាស្តា ។ កាលដែលខ្ញុំឆ្លើយប្រស្នាចប់ហើយ ព្រះតថាគត ក៏ទ្រង់អនុមោទនា ហើយទ្រង់ទតមើលភិក្ខុសង្ឃ បានត្រាស់សេចក្តីនេះថា ។ សោបាកៈនេះ ប្រើប្រាស់បច្ច័យ គឺចីវរ បិណ្ឌបាត ទីដេក និងទីអង្គុយរបស់ពួកអ្នកដែនអង្គៈ មគធៈណា ពួកជនអ្នកដែនអង្គៈ មគធៈនោះ ហៅពេញជាមានលាភ ។ មួយទៀត ព្រះសាស្តា ត្រាស់នូវការក្រោកទទួល និងការប្រព្រឹត្តសមគួរ ថាជាលាភរបស់ពួកជនអ្នកដែនអង្គៈ មគធៈនោះ ។ ( ព្រះសាស្តាត្រាស់ថា ) ម្នាលសោបាកៈ តាំងពីថ្ងៃនេះជាដើមទៅ អ្នកចូរមកជួបនឹងតថាគតចុះ ម្នាលសោបាកៈ ការដោះស្រាយប្រស្នានេះឯង ចូរជាឧបសម្បទារបស់អ្នកចុះ ។ ខ្ញុំមានអាយុ ៧ ឆ្នាំ អំពីកំណើត ក៏បានឧបសម្បទាទ្រទ្រង់រាងកាយជាទីបំផុត ឱ ! ព្រះធម៌ ល្អណាស់តើ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ចាសាទឆាយាយំ** បានដល់ ក្នុងស្រមោល

នៃព្រះគន្ធកុដិ ។

បទថា **វន្ទិស្សំ** ប្រែថា ថ្វាយបង្គំ ។

បទថា **សំហរិត្វាន ទាណយោ** បានដល់ ធ្វើដៃទាំង ២ ឲ្យជួបគ្នា ដោយអាការដូចក្រពុំឈូក អធិប្បាយថា ធ្វើអញ្ជលី ។

បទថា **អនុចង្កមិស្សំ** សេចក្តីថា ខ្ញុំដើរចង្រ្កម ដោយការដើរតាមក្រោយ ព្រះសាស្តា ដែលទ្រង់កំពុងចង្ក្រម ។ បទថា **វិរជំ** បានដល់ ប្រាសចាក ធូលី មានរាគៈជាដើម ។ បទថា **បញ្ហោ** បានដល់ កុមារបញ្ហា ។ បទថា **វិទូ** បានដល់ ដឹងវត្ថុដែលគួរដឹង អធិប្បាយថា ដឹងវត្ថុទាំងពួង ។ ឈ្មោះថា **អច្ឆម្ភី ច អភីតោ ច** ព្រោះខ្ញុំលះនូវការតក់ស្លុត និងការភ័យខ្លាចដែល កើតឡើងថា ព្រះសាស្តានឹងត្រាស់សួរអញ ដូច្នេះ ដោយអរហត្តមគ្គ ហើយព្យាករ ។

បទថា **យេសាយំ** ស្មើគ្នានឹង **យេសំ អង្គមគធានំ អយំ សោទាកោ** ប្រែថា សោបាកភិក្ខុនេះបរិភោគចីវរ ។បេ។ របស់អ្នកអង្គៈ និងអ្នកមគធៈ ពួកណា ។

បទថា **បច្ចយំ** បានដល់ គិលានប្បច្ច័យ ។ បទថា **សាមីចឹ** បានដល់ ការធ្វើសាមីចិកម្ម មានការចៀសផ្លូវ និងការបក់ផ្លិតជាដើម ។

ឧ អក្ខរៈក្នុងបទថា **អជ្ជឧគ្គេ** នេះ គ្រាន់តែធ្វើការភ្ជាប់បទ អធិប្បាយ ថា ធ្វើថ្ងៃនេះឲ្យជាដើម គឺចាប់ផ្តើមអំពីថ្ងៃនេះ ។ បាលីថា **អជ្ជតគ្គេ** ដូច្នេះ ក៏មាន អធិប្បាយថា ធ្វើនូវកាល មានថ្ងៃនេះ ឲ្យជាខាងដើមតទៅ ។

*បទថា* **ឧស្សុក្កាយោបសង្កម** *សេចក្តីថា អ្នកកុំគិតថា មានជាតិថោកទាប ឬមានវ័យទន់ក្មេងជាង ចូរអ្នកមករកតថាគតចុះ ។*

*បទថា* **ឯសា មេ** *មានវាចាប្រកបសេចក្តីថា ព្រះសាស្តាបានត្រាស់ថា ការដែលអ្នកប្រៀបធៀបសព្វញ្ញុតញ្ញាណរបស់តថាគត ហើយធ្វើការឆ្លើយបញ្ហានេះ ចូរជាឧបសម្បទារបស់អ្នក ។ បាលីថា* **លទ្ធា មេ ឧបសម្បទា** *ដូច្នេះក៏មាន ។ សម្រាប់អាចារ្យពួកខ្លះ ដែលពោលថា* **លទ្ធាន ឧបសម្បទំ** *នោះ មានពាក្យអធិប្បាយថា មានអាយុ ៧ ឆ្នាំ ចំណែកពាក្យដែលមិនបានពោលក្នុងទីនេះ មានអត្ថងាយយល់ហើយ ដូច្នេះ ។*

**អដ្ឋកថាសោបាកត្ថេរគាថា ចប់**

# សុត្តន្តបិដក

## សរភង្គត្ថេរគាថា

[ ២២៩ ] ខ្ញុំ ( កាលនៅជាតាបស ) បានប្រួតស្បូវដោយដៃឯង ធ្វើកុដិសម្រាប់នៅ ព្រោះហេតុនោះ បានជាឈ្មោះរបស់ខ្ញុំថា សរភង្គ ដោយសម្មតិ ។ ការប្រួតស្បូវដោយដៃ មិនគួរដល់ខ្ញុំ ក្នុងថ្ងៃនេះទេ ព្រោះសិក្ខាបទទាំងឡាយ ព្រះគោតមដ៏មានយស បានបញ្ញត្តហើយដល់យើង ។ ខ្ញុំឈ្មោះសរភង្គ មិនបានឃើញរោគ ដែលពេញពោរទាំងអស់ ក្នុងកាលមុន រោគនោះដែលសរភង្គអ្នកធ្វើតាមឱវាទ នៃព្រះសម្មាសម្ពុទ្ធ ជាទេវតាដ៏ប្រសើរ បានឃើញហើយ ។

ព្រះវិបស្សីទ្រង់យាងទៅហើយ តាមផ្លូវណា ព្រះសិខី
ព្រះវេស្សភូ ព្រះកកុសន្ធៈ ព្រះកោនាគមនៈ និងព្រះ
កស្សបៈ ទ្រង់យាងទៅតាមផ្លូវណា ព្រះគោតមទ្រង់
យាងទៅតាមផ្លូវនោះដែរ ។

ព្រះពុទ្ធទាំងឡាយ ៧ ព្រះអង្គ ប្រាសចាកតណ្ហា មិនមានសេចក្តីប្រកាន់ យាងចុះកាន់ព្រះនិព្វាន ព្រះអង្គមានធម្មកាយកើតហើយ ប្រកបដោយតាទិគុណ ទ្រង់សម្តែងនូវធម៌នេះ គឺអរិយសច្ច ៤ បានដល់ ទុក្ខ សមុទ័យ មគ្គ និរោធ ជាទីអស់ទៅនៃទុក្ខ ដើម្បីអនុគ្រោះដល់ពួកសត្វ ។ ទុក្ខក្នុងសង្សារ មិនមានទីបំផុត ប្រព្រឹត្តទៅក្នុងកាយណា អំពីការបែកធ្លាយនៃកាយនេះក្តី ការអស់ទៅនៃ

ជីវិតក្តី ភពថ្មីដទៃទៀត មិនមាន ខ្ញុំផុតស្រឡះហើយចាកកិលេស ទាំងអស់ ។

សរភង្គត្ថេរ

## ឧទ្ទាន

ព្រះថេរៈ ៥ អង្គ គឺសុន្ទរសមុទ្ទត្ថេរ ១ លកុណ្ឋកភទ្ទិយត្ថេរ ១ ភទ្ទត្ថេរ ១ សោបាកត្ថេរ ១ សរភង្គមហាឥសី ១ ពោលនូវគាថា ៣៥ ក្នុងសត្តកនិបាត ។

សត្តកនិបាត ចប់

# អដ្ឋកថា

## សរភង្គត្ថេរគាថា

[ ២២៩ ] គាថារបស់ព្រះសរភង្គត្ថេរ មានពាក្យផ្តើមថា **សរេ ហត្ថេហិ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងពុទ្ធុប្បាទនេះ កើតជាកូនព្រាហ្មណ៍ម្នាក់ ក្នុងក្រុងរាជគ្រឹះ មានឈ្មោះតាមវង្សត្រកូលថា **អនភិលក្ខិតៈ** កុលបុត្តនោះចម្រើនវ័យហើយ លះកាម បួស

ជាតាបស កាច់ឈើ និងស្មៅដោយខ្លួនឯង យកមកធ្វើបណ្ណសាលា ។ តាំង អំពីនោះ ទើបតាបសមាននាមបញ្ញត្តថា **សរភង្គ** ។

លំដាប់នោះ ព្រះមានព្រះភាគទ្រង់ប្រមើលមើលសត្វលោក ដោយពុទ្ធ-ចក្ខុ បានឃើញឧបនិស្ស័យអរហត្តរបស់តាបសនោះ ទើបយាងទៅក្នុងទីនោះ ទ្រង់សម្តែងធម៌ តាបសបានទូវសទ្ធា បួស ចម្រើនវិបស្សនាកម្មដ្ឋាន មិនយូរ ប៉ុន្មានក៏សម្រេចអរហត្ត ហើយនៅក្នុងទីនោះឯង ។ កាលនោះ សាលាស្លឹក ដែលព្រះថេរៈនោះធ្វើក្នុងកាលជាតាបស បានទ្រុឌទ្រោមបាក់បែក ។ ពួក មនុស្សឃើញដូច្នោះ ក៏និយាយថា បពិត្រលោកម្ចាស់ ហេតុអ្វី ទើបមិន ជួសជុលកុដិនេះ ។ ព្រះថេះកាលប្រកាសកិច្ចទាំងពួងនោះថា ឥឡូវនេះ អាត្មាមិនអាចធ្វើកុដិដូចក្នុងកាលជាតាបស ទើបពោល ២ គាថាថា

ខ្ញុំ ( កាលនៅជាតាបស ) បានច្រូតស្បូវដោយដៃឯង ធ្វើកុដិ សម្រាប់នៅ ព្រោះហេតុនោះ បានជាឈ្មោះរបស់ខ្ញុំថា សរភង្គ ដោយសម្មតិ ។ ការច្រូតស្បូវដោយដៃ មិនគួរដល់ខ្ញុំ ក្នុងថ្ងៃ នេះទេ ព្រោះសិក្ខាបទទាំងឡាយ ព្រះគោតមដ៏មានយស បាន បញ្ញត្តហើយដល់យើង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សរេ ហត្ថេហិ ភញ្ជិត្វា** សេចក្តីថា ក្នុង កាលមុន គឺក្នុងកាលជាតាបស ខ្ញុំយកដៃទាំង ២ កាច់ដើមបបុស និងច្រូត ស្មៅ ធ្វើជាបណ្ណសាលាអាស្រ័យ គឺអង្គុយ និងដេក ។

បទថា **តេន** បានដល់ ដោយការកាច់ដើមបបុសទាំងឡាយមកធ្វើតូប ។

បទថា **សម្មុតិយា** សេចក្តីថា បានឈ្មោះថា សរភង្គ តាមសន្មតដែលអនុលោមតាមហេតុ ។

បទថា **ន មយ្ហំ កប្បតេ អជ្ជ** សេចក្តីថា ថ្ងៃនេះ គឺឥឡូវនេះ ខ្ញុំឧបសម្បទាហើយ មិនសម គឺមិនគួរដាច់ដើមបបុសដោយដៃទាំង ២ ព្រោះហេតុអ្វី ព្រោះព្រះសមណគោតមទ្រង់យស ទ្រង់បញ្ញត្តសិក្ខាបទដល់យើងទាំងឡាយ ដោយពាក្យនោះ ព្រះថេរៈសម្តែងថា សិក្ខាបទដែលព្រះសាស្តាទ្រង់បញ្ញត្តដល់យើងទាំងឡាយនោះ យើងទាំងឡាយមិនកន្លង ព្រោះហេតុនៃជីវិត ។

ព្រះថេរៈកាលសម្តែងហេតុក្នុងការមិនជួសជុលបណ្ណសាលា ដោយប្រការមួយយ៉ាងនេះហើយ ឥឡូវនេះ កាលសម្តែងហេតុនោះ ដោយបរិយាយដទៃទៀត ទើបពោលគាថានេះថា

ខ្ញុំឈ្មោះសរភង្គ មិនបានឃើញរោគ ដែលពេញពោរទាំងអស់ ក្នុង
កាលមុន រោគនោះ ដែលសរភង្គអ្នកធ្វើតាមឱវាទ នៃព្រះសម្មា-
សម្ពុទ្ធ ជាទេវតាដ៏ប្រសើរ បានឃើញហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សកលំ** ប្រែថា ទាំងមូល ។ បទថា **សមត្តំ** ប្រែថា គ្រប់បរិបូណ៌ អធិប្បាយថា មិនមានសេសសល់ចំណែកទាំងពួង ។

ដោយបទថា **រោគំ** ព្រះថេរៈពោលសំដៅយកឧបាទានក្ខន្ធ ៥ ដែលជារោគ ព្រោះអត្ថថា ចាក់ដោត ព្រោះជាតួទុក្ខជាដើម ។

បទថា **ឆាទ្ទសំ បុរេ** សេចក្ដីថា ក្នុងកាលមុន មុននឹងបានទទួលឱវាទរបស់ព្រះសាស្ដា ខ្ញុំមិនធ្លាប់ឃើញឡើយ ។

បទថា **សោយំ រោគោ ឩដ្ឋោ វចនករេនាតិទេវស្ស** សេចក្ដីថា រោគពោល គឺបញ្ចក្ខន្ធនេះ ដែលសាវកជ្ឈអ្នកធ្វើតាមឱវាទរបស់ព្រះសម្មាសម្ពុទ្ធដែលជាធំជាងទេវតា ព្រោះក្រៃលែងជាងទេវតាទាំងឡាយ គឺសម្មតិទេព ឧបបត្តិទេព និងវិសុទ្ធិទេព ដោយសីលគុណជាដើមរបស់អង្គ បានឃើញហើយ គឺកំណត់ដឹងដោយភាពជាបញ្ចក្ខន្ធ ដោយបញ្ញាដែលសម្បយុត្តដោយមគ្គ ដែលប្រកបដោយវិបស្សនាបញ្ញា ។ ដោយបទថា **សោ យំ រោគោ** ជាដើមនេះ ព្រះថេរៈសម្ដែងថា សូម្បីកុដិ គឺអត្តភាពក៏មិនជាប់ជំពាក់យ៉ាងនេះ នឹងពោលថ្វី ដល់ការជួសជុលកុដិស្មៅខាងក្រៅនោះ ។

ឥឡូវនេះ ព្រះថេរៈកាលប្រាប់បដិបទាដើម្បីសម្រេចអរហត្តរបស់ខ្លួនយ៉ាងនេះថា ផ្លូវដែលខ្ញុំបដិបត្តិ ធ្វើឲ្យឃើញរោគ គឺអត្តភាពតាមសេចក្ដីពិតនោះ ជាផ្លូវទូទៅសម្រាប់ព្រះពុទ្ធគ្រប់អង្គ ១ ធម៌ គឺឱវាទនៃព្រះពុទ្ធទាំងឡាយនោះ ដែលដូចជាមាសបាក់ពាក់កណ្ដាល ដែលបុគ្គលណាបដិបត្តិតាមហើយធ្វើឲ្យដល់នូវការអស់ទុក្ខបាន ១ ដូច្នេះ ទើបពោលគាថាទាំងនេះថា

> ព្រះវិបស្សីទ្រង់យាងទៅហើយ តាមផ្លូវណា ព្រះសិខី
> ព្រះវេស្សភូ ព្រះកកុសន្ធៈ ព្រះកោនាគមនៈ និងព្រះ
> កស្សបៈ ទ្រង់យាងទៅតាមផ្លូវណា ព្រះគោតមទ្រង់
> យាងទៅតាមផ្លូវនោះដែរ ។

ព្រះពុទ្ធទាំងឡាយ ៧ ព្រះអង្គ ប្រាសចាកតណ្ហា មិនមានសេចក្តីប្រកាន់ យាងចុះកាន់ព្រះនិព្វាន ព្រះអង្គមានធម្មកាយកើតហើយ ប្រកបដោយតាទិគុណ ទ្រង់សំដែងនូវធម៌នេះ គឺអរិយសច្ច ៤ បានដល់ ទុក្ខ សមុទ័យ មគ្គ និរោធ ជាទីអស់ទៅនៃទុក្ខ ដើម្បីអនុគ្រោះដល់ពួកសត្វ ។ ទុក្ខក្នុងសង្សារ មិនមានទីបំផុត ប្រព្រឹត្តទៅក្នុងកាយណា អំពីការបែកធ្លាយនៃកាយនេះក្តី ការអស់ទៅនៃជីវិតក្តី ភពថ្មីដទៃទៀត មិនមាន ខ្ញុំផុតស្រឡះហើយចាកកិលេសទាំងអស់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យេនេវ មគ្គេន** បានដល់ អរិយមគ្គដែលប្រកបដោយអង្គ ៨ ណា ដែលជាចំណែកដើម ។

បទថា **គតោ** បានដល់ ប្រព្រឹត្តទៅ គឺសម្រេចព្រះនិព្វាន ។ បទថា **វិបស្សី** បានដល់ ព្រះវិបស្សីសម្មាសម្ពុទ្ធ ។ បទថា **កកុសន្ធ** ជានិក្ខេបបទដែលមិនមានវិភត្តិ ។ បាលីថា **កកុសន្ធកោណាគមន** ដូច្នេះក៏មាន ។

បទថា **តេនញ្ជសេន** បានដល់ ផ្លូវ គឺអរិយមគ្គនោះឯង ។ បទថា **អនាទានា** បានដល់ ដែលមិនប្រកាន់មាំ ឬដែលមិនមានបដិសន្ធិ ។ បទថា **១យោគធា** បានដល់ ឈមចុះកាន់ព្រះនិព្វាន គឺមានព្រះនិព្វានជាទីពឹង ។

បទថា **យេហាយំ ទេសិតោ ធម្មោ** សេចក្តីថា សាសនធម៌នេះ ព្រះសម្មាសម្ពុទ្ធ ៧ អង្គឯណា ទ្រង់សំដែងហើយ គឺទ្រង់ប្រកាសហើយ ។

បទថា **ធម្មភូតេហិ** បានដល់ មានធម៌ជាសភាវៈ ព្រោះជាធម្មកាយ

ឬកើតឡើងអំពីលោកុត្តរធម៌ ៩ ឬសម្រេចធម៌ ។

បទថា **តាធិភិ** បានដល់ ជាអ្នកដល់នូវភាពជាបុគ្គលមិនញាប់ញ័រក្នុងឥដ្ឋារម្មណ៍ជាដើម ។

ដោយបទថា **ចត្តារិ អរិយសច្ចានិ** ជាដើម ព្រះថេរៈសម្តែងដល់ធម៌ដែលព្រះពុទ្ធទាំងនោះ ទ្រង់សម្តែង ។

បណ្តាបទទាំងនោះ បទថា **ចត្តារិ** ជាការកំណត់នូវការរាប់ ។

បទថា **សច្ចានិ** ជាគ្រឿងសម្តែងដល់ធម៌ដែលកំណត់ ។ តែដោយអត្ថនៃសព្ទ ឈ្មោះថា **អរិយសច្ច** ព្រោះប្រសើរ និងពិត ព្រោះអត្ថថា ពិត ។ ម្យ៉ាងទៀត ឈ្មោះថា **អរិយសច្ច** ព្រោះជាសច្ចៈ ដែលព្រះមានព្រះភាគដ៏ប្រសើរ ទ្រង់សម្តែង ឬព្រោះជាសច្ចៈដែលធ្វើឲ្យបានជាព្រះអរិយៈ ឈ្មោះថាជា **ទុក្ខំ** ព្រោះជារបស់គួរខ្ពើម និងព្រោះជារបស់ទទេ បានដល់ ឧបាទាក្ខន្ធទាំង ៥ ។ ឈ្មោះថា **សមុទយោ** បានដល់ តណ្ហា ព្រោះជាដែនកើតនៃទុក្ខ ។ ឈ្មោះថា **មគ្គោ** ព្រោះសម្លាប់កិលេសទាំងឡាយ ឬព្រោះអ្នកត្រូវការព្រះនិព្វាន ត្រូវស្វែងរក ។ បានដល់ ធម៌ ៨ ប្រការ មានសម្មាទិដ្ឋិជាដើម ឈ្មោះថា **និរោធោ** ព្រោះក្នុងព្រះនិព្វាននោះ មិនមានត្រើយ ពោលគឺសង្សារដែលជាទីត្រាច់ទៅ ឬថា កាលបុគ្គលសម្រេចព្រះនិព្វាននោះហើយរមែងមិនមានត្រើយ ឬឈ្មោះថា **និរោធោ** ព្រោះជាទីរម្ងត់ទុក្ខ បានដល់ព្រះនិព្វាន ។

ដោយហេតុនោះ ទើបលោកពោលថា **ទុក្ខសង្ខយោ** ក្នុងទីនេះ មាន

*សេចក្តីសង្ខេបប្រមាណប៉ុណ្ណេះ ឯសេចក្តីពិស្តារ គប្បីជ្រាបដោយន័យដូចពោលហើយ ក្នុងវិសុទ្ធិមគ្គនោះឯង ។*

*បទថា* **យស្មឹ** *បានដល់ កាលសម្រេចនិរោធ គឺព្រះនិព្វានណា ។*

*បទថា* **និវត្តតេ** *មានវាចាប្រកបសេចក្តីថា ព្រះសម្មាសម្ពុទ្ធទាំងឡាយ ដែលមានធម្មកាយ ទ្រង់សម្តែងធម៌នេះថា កាលអរិយមគ្គភាវនាមាន ទុក្ខមានជាតិជាដើម ដែលមិនមានទីបំផុត គឺមិនមានទីបំផុត រមែងមិនប្រព្រឹត្តទៅក្នុងសង្សារនេះ គឺរមែងដាច់សូន្យ ភាពដែលទុក្ខដាច់សូន្យនោះ ជានិរោធ ។ ដោយបទថា* **ភេទា** *ព្រះថេរៈសម្តែងដោយសរុបដល់ការសម្រេចអរហត្តរបស់លោក ដោយការកំណត់ដឹងនូវទុក្ខថា* **រោគោ ទិដ្ឋោ** *( រោគនោះដែលខ្ញុំឃើញហើយ ) ។ ចំណែកបាលីថា* **យស្មឹ និវត្តតេ ទុក្ខំ** *ជាដើម មានអធិប្បាយដូចតទៅនេះ ទុក្ខ មានជាតិជាដើម មិនមានទីបំផុតនេះ កើតក្នុងសង្សារ ដែលបញ្ញត្តថា ជាទីបន្តនៃខន្ធជាដើមណា សង្សារនោះ ដទៃចាកការដល់នូវសេចក្តីទុក្ខនេះ ហៅថា ភពថ្មី ព្រោះកើតរឿយៗ ក្រោយអំពីជីវិតិន្ទ្រិយសូន្យទៅ គឺក្រោយអំពីការបែកធ្លាយ ការវិនាសនៃខន្ធ ៥ ពោលគឺកាយហើយ ក៏មិនមាន ( អ្វី ) ព្រោះហេតុនោះ ទើបខ្ញុំរួចផុត គឺប្រាសចាកកិលេសទាំងពួង គឺចាកកិលេស និងភពទាំងពួង ៕*

**អដ្ឋកថា សរភង្គត្ថេរគាថា ចប់**

**សត្តកនិបាត ចប់**

# សុត្តន្តបិដក

# ថេរគាថា អដ្ឋកនិបាត

## មហាកច្ចាយនត្ថេរគាថា

[ ២៣០ ] បព្វជិតមិនគប្បីធ្វើនូវកម្មច្រើនទេ គប្បីលះបង់ជន ( បាបមិត្ត ) មិនគប្បីខ្វល់ខ្វាយ ( ដើម្បីលាភទេ ) ព្រោះបព្វជិតអ្នកខ្វល់ខ្វាយ ជាប់ចិត្តក្នុងរស រមែងលះបង់ប្រយោជន៍ដែលនាំមកនូវសេចក្តីសុខ ។ ការថ្វាយបង្គំ និងការបូជាណាក្នុងត្រកូលទាំងឡាយ ពួកព្រះអរិយៈ ដឹងច្បាស់នូវការថ្វាយបង្គំ និងការបូជានោះ ថាដូចជាភក់ ទាំងដឹងថាជាសរដ៏ល្អិតគេកម្រដកបាន ជាគ្រឿងសក្ការៈ ដែលបុរសអាក្រក់ លះបង់បានដោយកម្រ ។

បុគ្គលមិនគប្បីសេពនូវអំពើអាក្រក់ ដោយខ្លួនឯង ព្រោះបំពេញ ( ទុក្ខ ) ដល់សត្វដទៃ ( ទាំងមិនញុំាងបុគ្គលដទៃឲ្យសេពនូវអំពើអាក្រក់នោះ ) ព្រោះថា សត្វទាំងឡាយ មានកម្មជាផៅពង្ស ។ បុគ្គលជាចោរ ព្រោះពាក្យអ្នកដទៃក៏ទេ បុគ្គលជាអ្នកប្រាជ្ញ ព្រោះពាក្យអ្នកដទៃក៏ទេ បុគ្គលដឹងខ្លួនឯងយ៉ាងណា សូម្បីពួកទេវតាក៏ដឹងបុគ្គលនោះដូច្នោះដែរ ។ ពួកជនផ្សេងផ្តាស រមែងមិនដឹងច្បាស់ថា យើងទាំងឡាយនឹងលំបាក ក្នុងលោកនេះ តែពួកជន

ណា ដឹងច្បាស់ក្នុងដំណើរនោះ ការជម្លោះតែងស្ងប់រម្ងាប់ទៅអំពីសម្នាក់ពួកជននោះ ។ បុគ្គលប្រកបដោយបញ្ញា បើទុកជាអស់សម្បត្តិរលីងធេង ក៏ឈ្មោះថា រស់នៅ ឯបុគ្គលមានសម្បត្តិ ឈ្មោះថា មិនរស់នៅ ព្រោះការមិនបាននូវបញ្ញា ។ បុគ្គលរមែងស្តាប់នូវសំឡេងទាំងអស់បាន ដោយសារត្រចៀក បុគ្គលមានចក្ខុ រមែងឃើញរូបគ្រប់យ៉ាង ចំណែកអ្នកប្រាជ្ញមិនគួរលះចោល ( ឬប្រកាន់ ) នូវអារម្មណ៍ទាំងពួង ដែលខ្លួនឃើញហើយ ឮហើយឡើយ ។ បុគ្គលអ្នកមានភ្នែក គប្បីធ្វើដូចជាខ្វាក់ បុគ្គលអ្នកមានត្រចៀក គប្បីធ្វើដូចជាថ្លង់ បុគ្គលអ្នកមានបញ្ញា គប្បីធ្វើដូចជាគ បុគ្គលអ្នកមានកម្លាំង គប្បីធ្វើដូចជាអ្នកខ្សោយកម្លាំង តែកាលបើហេតុ ( មិនគួរធ្វើ ) កើតឡើងហើយ ត្រូវដេកដូចជាដេកស្លាប់ ។

**មហាកច្ចាយនត្ថេរ**

# អដ្ឋកថា

# ថេរគាថា អដ្ឋកនិបាត

## មហាកច្ចាយនត្ថេរគាថា

[ ២៣០ ] ក្នុងអដ្ឋកនិបាត គាថារបស់ព្រះមហាកច្ចាយនត្ថេរ មានពាក្យផ្តើមថា **កម្មំ ពហុកំ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងសាសនាព្រះមានព្រះភាគ ព្រះនាមបទុមុត្តរៈ កើតក្នុងត្រកូលគហបតីមហាសាល ចម្រើនវ័យហើយ ថ្ងៃមួយ កំពុងស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្តា ជួបភិក្ខុមួយរូប ដែលព្រះសាស្តាទ្រង់ស្ថាបនាក្នុងតំណែងឯតទគ្គៈ ជាងភិក្ខុទាំងឡាយ ខាងចែកអត្ថ ដែលព្រះសាស្តាទ្រង់ត្រាស់ដោយសង្ខេបឲ្យពិស្តារ ខ្លួនឯងក៏ប្រាថ្នាតំណែងនោះ ក្នុងសាសនាព្រះមានព្រះភាគ ព្រះនាមសុមេធ កើតជាវិជ្ជាធរ ហោះទៅតាមអាកាស ឃើញព្រះសាស្តាគង់ក្នុងដងព្រៃមួយក្បែរភ្នំហិមពាន្ត មានចិត្តជ្រះថ្លា ធ្វើនូវការបូជាដោយផ្កាកណិការជាច្រើន ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះ អន្ទោលទៅមកក្នុងសុគតិនោះឯង ក្នុងសាសនានៃព្រះមានព្រះភាគ ព្រះនាមកស្សបៈ កើតក្នុងផ្ទះមានត្រកូលក្នុងក្រុងពារាណសី កាលព្រះមានព្រះភាគបរិនិព្វានហើយ ធ្វើការបូជាក្នុង

ទីសាងចេតិយដោយឥដ្ឋមាស ដែលមានតម្លៃមួយសែន ហើយតាំងសេចក្តីប្រាថ្នាថា បពិត្រព្រះមានព្រះភាគ សូមឲ្យសរីរៈរបស់ខ្ញុំព្រះអង្គ មានពណ៌ដូចមាស ក្នុងទីដែលខ្ញុំព្រះអង្គកើតហើយ ។

បន្ទាប់អំពីនោះមក ក៏បំពេញតែកុសលកម្មដរាបដល់អស់ជីវិត អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ អស់មួយពុទ្ធន្តរ ក្នុងពុទ្ធុប្បាទនេះ កុលបុត្តនោះ កើតក្នុងផ្ទះបុរោហិតរបស់ព្រះបាទចណ្ឌប្បជ្ជោត ក្នុងនគរឧជ្ជេនី ក្នុងថ្ងៃដាក់ឈ្មោះទារកនោះ មាតាគិតថា បុត្តរបស់អញមានកាយដូចមាស នាំយកឈ្មោះរបស់ខ្លួនមកហើយ ដូច្នេះ ទើបដាក់ឈ្មោះថា កញ្ចនមាណព នោះឯង ។ ទារកនោះចម្រើនវ័យហើយ សិក្សាចប់ត្រៃវេទ អំណើះឥតអំពីឪពុកទៅ ក៏បានតំណែងបុរោហិត ប្រាកដឈ្មោះថា កច្ចាយនៈ ដោយអំណាចនៃគោត្ត ។ ព្រះបាទចណ្ឌប្បជ្ជោត ទ្រង់ស្តាប់ថា ព្រះពុទ្ធទ្រង់កើតឡើង ក៏បញ្ជូនបុរោហិតនោះទៅថា សូមលោកអាចារ្យទៅទីនោះ នាំព្រះសាស្តាមកទីនេះចុះ ។

កច្ចាយនបុរោហិតនោះ មានសម្លាញ់ជាគម្រប់ ៨ ចូលទៅគាល់ព្រះសាស្តា។ ទ្រង់សម្តែងធម៌ដល់បុរោហិតនោះ ក្នុងទីបំផុតនៃទេសនាកច្ចាយនមាណព និងជនទាំង ៧ តាំងនៅក្នុងអរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយ សមដូចគាថាព័ន្ធដែលលោកពោលក្នុងអបទានថា

ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ទ្រង់មិនញាប់ញ័រ ឥតមានបុគ្គលផ្ចាញ់បាន ជានាយក ទ្រង់ត្រាស់ឡើងក្នុងកប្បទីមួយសែន អំពី

កទុកប្បនេះ ។ ព្រះវីរសម្ពុទ្ធ ទ្រង់មានត្របកព្រះនេត្រដូចផ្កាឈូក មានព្រះឱស្ឋប្រាសចាកមន្ទិលដូចព្រះចន្ទ មានព្រះតចៈដូចមាស មានរស្មីរុងរឿងដូចព្រះអាទិត្យ ទ្រង់ជាទីត្រូវភ្នែក និងចិត្តរបស់សត្វ ប្រដាប់ដោយលក្ខណៈដ៏ប្រសើរ ទ្រង់កន្លងផុតគន្លងពាក្យទាំងពួង ត្រូវមនុស្ស និងទេវតាធ្វើសក្ការៈហើយ ។ ព្រះសម្ពុទ្ធទ្រង់ញុំាងពួកសត្វឲ្យត្រាស់ដឹង ទ្រង់មានសំឡេងពីរោះ ផ្សាយទៅ ទ្រង់មានសន្តានជាប់ដោយសេចក្តីករុណា ទ្រង់ក្លៀវក្លាក្នុងពួកបរិស័ទ ។ ព្រះសម្ពុទ្ធ ទ្រង់សម្តែងធម៌ពីរោះ ប្រកបដោយសច្ចៈ ៤ ទ្រង់ស្រង់ពួកសត្វដែលលិចចុះក្នុងភក់ គឺមោហៈ ។ ក្នុងកាលនោះ ខ្ញុំកើតជាតាបស មានលំនៅក្នុងព្រៃហិមពាន្ត ត្រាច់ទៅតែម្នាក់ឯង ហោះទៅកាន់មនុស្សលោកតាមអាកាស បានឃើញព្រះជិនស្រី ។ ខ្ញុំចូលទៅកាន់សម្នាក់ព្រះជិនស្រីនោះ បានស្តាប់ធម្មទេសនារបស់ព្រះសម្ពុទ្ធជាអ្នកប្រាជ្ញ ដែលកំពុងពណ៌នានូវគុណដ៏ធំរបស់សាវកថា ភាសិតដែលតថាគតពោលដោយបង្រួញ សាវកនេះ ប្រកាសដោយពិស្តារបាន ញុំាងបរិស័ទ និងតថាគតឲ្យត្រេកអរ ដូចកច្ចាយនភិក្ខុ ។ តថាគតមិនឃើញមានសាវកដទៃណាមួយ ក្នុងសាសនានេះ យ៉ាងនេះឡើយ ព្រោះហេតុនោះ សាវកនេះ ជាអ្នកប្រសើរ ( ឋិតនៅ ) ក្នុងទីជាឯតទគ្គៈ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរចាំទុកយ៉ាងនេះ

ចុះ កាលនោះ ខ្ញុំមានសេចក្ដីស្ញប់ស្ញែង ព្រោះស្ដាប់ពាក្យជាទីគាប់ចិត្តនោះ ទើបទៅកាន់ព្រៃហិមពាន្ត ដើរសេន្សំ បេះផ្កាឈើ ។ ខ្ញុំបូជាចំពោះព្រះសម្ពុទ្ធ ជាទីពឹងនៃលោក ហើយប្រាថ្នានូវតំណែងនោះ ។

កាលនោះ ព្រះសរណាលយសម្ពុទ្ធ ទ្រង់ជ្រាបអធ្យាស្រ័យដ៏ធំរបស់ខ្ញុំ ទ្រង់ព្យាករថា អ្នកទាំងឡាយ ចូរមើលនូវឥសីដ៏ប្រសើរនេះ មានស្បែកដូចមាស មិនមានមន្ទិល មានរោមខ្ពស់ និងសាច់ពេញលេញ ឈរផ្គងអញ្ជលីមិនកម្រើក មានសេចក្ដីរីករាយ មានភ្នែកពេញល្អ មានអធ្យាស្រ័យស្ងប់ ក្នុងការពណ៌នានូវពុទ្ធគុណ ជាអ្នកកើតអំពីធម៌ មានហឫទ័យខ្ពស់ ហាក់ដូចជាស្រោចស្រពដោយទឹកអម្រឹត ។

បពិត្រព្រះមហាមុនី លុះខ្ញុំឈរស្ដាប់នូវគុណរបស់ព្រះកច្ចានភិក្ខុហើយ ក៏ប្រាថ្នានូវតំណែងនោះ ក្នុងសាសនានៃព្រះគោតម ក្នុងកាលជាអនាគត ។ ( ព្រះបទុមុត្តរៈ ទ្រង់ព្យាករថា ) តាបសនេះ នឹងបានជាធម្មទាយាទ ជាឱរសរបស់ព្រះគោតមនោះ ជាធម្មនិម្មិត មាននាមថា កច្ចានភិក្ខុ ជាសាវករបស់ព្រះសាស្ដា ។ កច្ចានភិក្ខុនោះ នឹងបានជាពហុស្សុត មានញាណដ៏ប្រសើរ ជាអ្នកប្រាជ្ញ ដឹងនូវសេចក្ដីអធិប្បាយ នឹងដល់នូវតំណែងនោះ ដូចជាតថាគតព្យាករហើយនេះ ។

ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្មក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ខ្ញុំតែងអន្ទោលទៅក្នុងភពពីរ គឺទេវតា ឬមនុស្ស មិនដែលស្គាល់គតិដទៃឡើយ នេះជាផលនៃពុទ្ធបូជា ។ ខ្ញុំតែងកើតក្នុងត្រកូលពីរ គឺត្រកូលក្សត្រ ឬព្រាហ្មណ៍ មិនដែលកើតក្នុងត្រកូលទាបឡើយ នេះជាផលនៃពុទ្ធបូជា ។ ក្នុងបច្ឆិមភព ខ្ញុំកើតជាប្អូន[1]នៃបុរោហិត របស់ស្តេចព្រះនាមចណ្ឌប្បជ្ជោត ក្នុងបុរីឧជ្ជេនី ជាទីរីករាយ ។ ខ្ញុំជាបុត្តរបស់តិបិតិវច្ឆព្រាហ្មណ៍ ជាអ្នកមានប្រាជ្ញាល្អិត ដល់នូវត្រើយនៃវេទ ឯមាតាខ្ញុំ ឈ្មោះនាងចន្ទនបទុមា ខ្ញុំឈ្មោះកច្ចានៈ មានស្បែកល្អ ខ្ញុំដែលព្រះភូមិបាលបញ្ជូនទៅ ដើម្បីល្បងមើលព្រះសម្ពុទ្ធ ក៏បានឃើញព្រះនាយក ជានាយទ្វារ នៃមោក្ខបុរី ទ្រង់សន្សំនូវគុណ ។ ខ្ញុំស្តាប់ពាក្យមិនមានមន្ទិល ជាពាក្យជម្រះនូវកក់ គឺគតិ ក៏បានដល់នូវអមតធម៌ ជាទីរម្ងាប់ ជាមួយនឹងពួកបុរោហិតដ៏សេស ៧ នាក់ ។ ខ្ញុំជាអ្នកដឹងនូវសេចក្តីអធិប្បាយ ក្នុងបំណងធំនៃព្រះសុគត ព្រះអង្គទ្រង់តាំងខ្ញុំទុកក្នុងទីជាឯតទគ្គៈ ខ្ញុំមានសេចក្តីប្រាថ្នាសម្រេចល្អហើយ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។

---

១- បាលីថា បិរោហិតទុជាតិនោ គួរប្រែថា កូននៃបុរោហិត ទើបត្រូវតាមន័យរបស់អដ្ឋកថា ។

ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ ។

គ្រានោះ ព្រះសាស្តាទ្រង់លាព្រះហស្តត្រាស់ថា អ្នកទាំងឡាយ ចូរជាភិក្ខុចុះ ។ ក្នុងខណៈនោះឯង លោកទាំងនោះ មានសក់ និងពុកមាត់ត្រឹម ២ អង្គុលី ទ្រទ្រង់នូវបាត្រ និងចីវរដែលសម្រេចដោយឫទ្ធិ បានជាអ្នកដូចព្រះថេរៈដែលមានវស្សា ៦០ ព្រះថេរៈធ្វើនូវប្រយោជន៍របស់ខ្លួនឲ្យសម្រេចដោយប្រការដូច្នេះហើយ ទើបទូលដល់ព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះបាទចណ្ឌប្បជ្ជោត ទ្រង់ប្រាថ្នាថ្វាយបង្គំព្រះបាទារបស់ព្រះអង្គ និងដើម្បីស្តាប់ធម៌របស់ព្រះអង្គ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ អ្នកនោះឯង ចូរទៅក្នុងទីនោះ កាលអ្នកទៅហើយ ព្រះរាជានឹងជ្រះថ្លា ។

ព្រះថេរៈមានភិក្ខុដទៃជាគម្រប់ ៨ ទៅក្នុងទីនោះ តាមព្រះតម្រាស់របស់ព្រះសាស្តា ធ្វើឲ្យព្រះរាជាទ្រង់ជ្រះថ្លាហើយ ប្រតិស្ឋានព្រះសាសនាក្នុងអវន្តីជនបទ ហើយត្រឡប់ទៅគាល់ព្រះសាស្តាម្តងទៀត ។ ថ្ងៃមួយ ព្រះថេរៈឃើញភិក្ខុជាច្រើនលះបង់សមណធម៌ មកត្រេកអរក្នុងការងារ ត្រេកអរក្នុងការប្រឡូកប្រឡំ ពេញចិត្តក្នុងរសតណ្ហា និងនៅដោយសេចក្តីប្រមាទ ដើម្បីដាស់តឿនភិក្ខុទាំងនោះ ទើបពោល ២ គាថាថា

បព្វជិតមិនគប្បីធ្វើនូវកម្មច្រើនទេ គប្បីលះបង់ជន ( បាបមិត្ត )
មិនគប្បីខ្វល់ខ្វាយ ( ដើម្បីលាភទេ ) ព្រោះបព្វជិត អ្នក
ខ្វល់ខ្វាយ ជាប់ចិត្តក្នុងរស រមែងលះបង់ប្រយោជន៍ ដែលនាំ
មកនូវសេចក្តីសុខ ។ ការថ្វាយបង្គំ និងការបូជាណា ក្នុង

ត្រកូលទាំងឡាយ ពួកព្រះអរិយៈ ដឹងច្បាស់នូវការថ្វាយ

បង្គំ និងការបូជានោះ ថាដូចជាកក់ ទាំងដឹងថាជាសរដ៏ធ្ងារ

គេកម្រដកបាន ជាគ្រឿងសក្ការៈ ដែលបុរសអាក្រក់លះបង់

បានដោយកម្រ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កម្មំ ពហុកំ ន ការយេ** សេចក្ដីថា ភិក្ខុមិនគប្បីប្រាថ្នានូវនវកម្មដែលធំ មានការសាងសង់លំនៅថ្មីជាដើម ដែលជាបលិពោធចំពោះការបំពេញសមណធម៌ ឯការកសាង គឺជួសជុលរបស់ដែលទ្រុឌទ្រោម ដែលចាប់ផ្ដើមធ្វើបន្តិចបន្តួច ដើម្បីបូជាព្រះតម្រាស់របស់ព្រះសាស្ដា ក៏គួរធ្វើនោះឯង ។

បទថា **បរិវជ្ជេយ្យ ជនំ** សេចក្ដីថា គួរវៀរពួកជនដោយអំណាចការប្រឡូកប្រឡំដោយពួកគណៈ ។ម្យ៉ាងទៀត បទថា **ជនំ** សេចក្ដីថា កាលភិក្ខុសេពគប់ ចូលទៅអង្គុយជិតបុគ្គលណា កុសលធម៌រមែងសាបសូន្យទៅ អកុសលធម៌រមែងចម្រើន ភិក្ខុគួរចៀសវាងពួកជនដែលមិនមែនកល្យាណមិត្តនោះចេញ ។

បទថា **ន ឧយ្យមេ** សេចក្ដីថា ភិក្ខុមិនគប្បីព្យាយាមដោយការសង្គ្រោះត្រកូល ដើម្បីឲ្យបច្ច័យកើតឡើង ។ ព្រោះបទថា **សោ ឧស្សុក្កោ រសានុគិទ្ធោ អត្ថំ រិញ្ចតិ យោ សុខាធិវាហោ** សេចក្ដីថា ភិក្ខុណាជាអ្នកជាប់ក្នុងរសអាហារ គឺជាប់រសអាហារដោយអំណាចតណ្ហា ជាអ្នកខ្វល់ខ្វាយដើម្បីឲ្យបច្ច័យកើតឡើង ភិក្ខុនោះរមែងជាអ្នកខ្វល់ខ្វាយដើម្បីសង្គ្រោះត្រកូល កាល

ត្រកូលមានសេចក្តីសុខ ខ្លួនឯងក៏មានសេចក្តីសុខតាម កាលត្រកូលជួបសេចក្តីទុក្ខ ខ្លួនឯងក៏កើតទុក្ខ កាលកិច្ចរបស់ត្រកូលកើតឡើង ក៏យកខ្លួនទៅប្រឡូកប្រឡំ រមែងលះបង់ គឺវៀរនូវប្រយោជន៍ មានសីលជាដើម ដែលនាំសេចក្តីសុខមកឲ្យ គឺដែលនាំសេចក្តីសុខកើតអំពីសមថៈ វិបស្សនា មគ្គ ផល និងព្រះនិព្វានមកឲ្យ អធិប្បាយថា គេចចេញអំពីប្រយោជន៍នោះ ដោយចំណែកមួយ ។

ព្រះថេរៈទូន្មានថា ចូរអ្នកវៀរចាកនូវការត្រេកអរក្នុងការងារ ត្រេកអរក្នុងការប្រឡូកប្រឡំ និងការជាប់ចិត្តក្នុងបច្ច័យ ដោយគាថាដំបូងយ៉ាងនេះហើយ ឥឡូវនេះ កាលតិះដៀលដល់ការប្រាថ្នាក្នុងសក្ការៈ ទើបពោលគាថាទី ២ ។ អត្ថនៃគាថាទី ២ នោះថា ការថ្វាយបង្គំ និងការបូជានេះ ដែលពួកជនគ្រប់គ្រងផ្ទះ ក្នុងត្រកូលធ្វើដើម្បីលើកតម្កើងនូវគុណរបស់បព្វជិត ដែលចូលទៅដើម្បីភិក្ខា ព្រោះព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាដើម ចង្អុលបង្ហាញ ឬប្រកាសឲ្យដឹងថា ការថ្វាយបង្គំ និងការបូជានោះ ជាភក់ ព្រោះអត្ថថា ញុំាងបុគ្គលដែលមិនបានអប់រំខ្លួនឲ្យលិច និងព្រោះអត្ថថា ធ្វើនូវការសៅហ្មង ( ឲ្យដល់ខ្លួន ) និងព្រោះពោលដល់ការប្រាថ្នាសក្ការៈរបស់អន្ធ-បុថុជ្ជន ដែលមិនដឹងដល់ខ្លួនថា ជាសរដ៏ឆ្មារ គេកម្រដកបាន ព្រោះធ្វើឲ្យកើតការបៀតបៀន ព្រោះសង្កត់សង្កិនខាងក្នុង និងព្រោះដកឡើងបានលំបាក ដោយហេតុជាសភាវៈដែលបុគ្គលដឹងបានដោយលំបាក ដូច្នោះឯង ទើបជាគ្រឿងសក្ការៈដែលបុរសអាក្រក់ លះបង់បានដោយកម្រ គឺលះបានលំបាក

ព្រោះមិនប្រព្រឹត្តទៅតាមបដិបទាជាគ្រឿងលះសក្ការៈនោះ ព្រោះបុគ្គលលះសក្ការៈបាន ព្រោះលះនូវការប្រាថ្នាសក្ការៈ ព្រោះហេតុនោះ ទើបលោកពោលថា ការប្រកបសេចក្តីព្យាយាមដើម្បីការលះសក្ការៈនោះ ជាកិច្ចដែលភិក្ខុគួរធ្វើ ។

ព្រះថេរៈបានពោល ៦ គាថាខាងក្រោមនេះ ដោយបំណងទូន្មានព្រះបាទចណ្ឌប្បជ្ជោតថា

បុគ្គលមិនគប្បីសេពនូវអំពើអាក្រក់ ដោយខ្លួនឯង ព្រោះបំពេញ ( ទុក្ខ ) ដល់សត្វដទៃ ( ទាំងមិនញុំាងបុគ្គលដទៃឲ្យសេពនូវអំពើអាក្រក់នោះ ) ព្រោះថា សត្វទាំងឡាយមានកម្មជាផៅពង្ស ។ បុគ្គលជាចោរ ព្រោះពាក្យអ្នកដទៃក៏ទេ បុគ្គលជាអ្នកប្រាជ្ញ ព្រោះពាក្យអ្នកដទៃក៏ទេ បុគ្គលដឹងខ្លួនឯង យ៉ាងណា សូម្បីពួកទេវតាក៏ដឹងបុគ្គលនោះ ដូច្នោះដែរ ។ ពួកជនផ្សេងៗ រមែងមិនដឹងច្បាស់ថា យើងទាំងឡាយនឹងលំបាក ក្នុងលោកនេះ តែពួកជនណា ដឹងច្បាស់ក្នុងដំណើរនោះ ការជម្លោះតែងស្ងប់រម្ងាប់ទៅ អំពីសម្នាក់ពួកជននោះ ។ បុគ្គលប្រកបដោយបញ្ញា បើទុកជាអស់សម្បត្តិរលីងធេងក៏ឈ្មោះថា រស់នៅ ឯបុគ្គលមានសម្បត្តិ ឈ្មោះថា មិនរស់នៅ ព្រោះការមិនបាននូវបញ្ញា ។ បុគ្គលរមែងស្តាប់នូវសំឡេងទាំងអស់បាន ដោយសារត្រចៀក បុគ្គលមានចក្ខុ រមែងឃើញរូបគ្រប់យ៉ាង ចំណែកអ្នកប្រាជ្ញមិនគួរលះបោល ( ឬប្រកាន់ ) នូវអារម្មណ៍ទាំង

ពួន ដែលខ្លួនឃើញហើយ ឮហើយឡើយ ។ បុគ្គលអ្នកមានភ្នែក គប្បីធ្វើដូចជាខ្វាក់ បុគ្គលអ្នកមានត្រចៀក គប្បីធ្វើដូចជាថ្លង់ បុគ្គលអ្នកមានបញ្ញា គប្បីធ្វើដូចជាគ បុគ្គលអ្នកមានកម្លាំង គប្បីធ្វើដូចជាអ្នកខ្សោយកម្លាំង តែកាលបើហេតុ ( មិនគួរធ្វើ ) កើតឡើងហើយ ត្រូវដេកដូចជាដេកស្លាប់ ដូច្នេះ ។

បានឮថា ព្រះរាជាអង្គនោះ ទ្រង់ជឿពួកព្រាហ្មណ៍ ហើយត្រាស់ឲ្យសម្លាប់សត្វបូជាយញ្ញ ទ្រង់មិនស្រាវជ្រាវការធ្វើឲ្យពិតប្រាកដ ដាក់អាជ្ញាជនទាំងឡាយដែលមិនមែនចោរ ដោយសម្គាល់ថាជាចោរ ឯការកាត់ក្តី ក៏កាត់ធ្វើបុគ្គលមិនមែនម្ចាស់ទ្រព្យឲ្យជាម្ចាស់ទ្រព្យ ទ្រង់ធ្វើបុគ្គលដែលជាម្ចាស់ទ្រព្យមិនឲ្យជាម្ចាស់ ព្រោះហេតុនោះ ដើម្បីបង្ហាញសេចក្តីនោះដល់ព្រះរាជា ទើបពោល ៦ គាថា ដោយន័យជាដើមថា **ន បរស្ស** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **ន បរស្សុបណិធាយ កម្មំ មច្ចស្ស បាបកំ** សេចក្តីថា បុគ្គលមិនគួរសេពនូវកម្មអាក្រក់ មានការសម្លាប់ និងការចងជាដើម ដោយអាងបុគ្គលដទៃជាហេតុ អធិប្បាយថា មិនគួរប្រើអ្នកដទៃឲ្យធ្វើ ។

បទថា **អត្តនា តំ ន សេវេយ្យ** សេចក្តីថា មិនគួរធ្វើកម្មអាក្រក់នោះដោយខ្លួនឯង ព្រោះអ្វី ព្រោះសត្វមានកម្មជាផៅពង្ស អធិប្បាយថា សត្វទាំងនេះ រមែងជាទាយាទនៃកម្ម ព្រោះហេតុនោះ ខ្លួនឯងក៏មិនត្រូវធ្វើកម្មអាក្រក់ណាមួយឡើយផង មិនដឹកនាំឲ្យអ្នកដទៃធ្វើអាក្រក់នោះផង ។

បទថា **ន បរេ វចនា ចោរោ** សេចក្តីថា ខ្លួនឯងមិនបានធ្វើចោរកម្ម និងឈ្មោះថាជាចោរត្រឹមតែពាក្យរបស់អ្នកដទៃនោះក៏មិនមែន បុគ្គលជាអ្នកប្រាជ្ញព្រោះពាក្យអ្នកដទៃក៏ទេ ក៏ដូចគ្នា គឺមុនីជាអ្នកមានកាយសមាចារ វចី-សមាចារ និងមនោសមាចារបរិសុទ្ធដោយល្អ ដោយហេតុត្រឹមតែពាក្យរបស់អ្នកដទៃនោះ ក៏មិនមែន ។

បទថា **បរេ** ក្នុងគាថានេះ ជាពាក្យប្រើដោយមិនលុបវិភត្តិ ។ ឯអាចារ្យពួកខ្លះពោលថា កាលគួរនឹងពោលថា **បរេសំ** តែសម្តែងថា **បរេ** ព្រោះធ្វើនូវការលុប **សំ** អក្ខរៈចេញ ។

បទថា **អត្តា ច នំ យថា វេទិ** សេចក្តីថា ខ្លួន គឺចិត្តស្គាល់ គឺស្គាល់ច្បាស់តាមសេចក្តីពិតថា អាត្មាអញបរិសុទ្ធ ឬមិនបរិសុទ្ធ ។

បទថា **ទេវាបិ នំ តថា វិទូ** សេចក្តីថា វិសុទ្ធិទេព និងឧបបត្តិទេពរមែងដឹងជាក់ច្បាស់បុគ្គលនោះថា ដូច្នោះ ព្រោះហេតុនោះ ខ្លួនឯង និងទេវតាបែបនោះ ទើបជាប្រមាណថាបរិសុទ្ធ ឬមិនបរិសុទ្ធ អធិប្បាយថា ពួកសត្វណាទីមួយ ដែលត្រូវលោភៈ និងទោសៈគ្របសង្កត់ មិនដឹងច្បាស់បានឡើយ ។

បទថា **បរេ** សេចក្តីថា ក្រៅអំពីបណ្ឌិតហើយ បុគ្គលដទៃក្រៅអំពីបណ្ឌិតនោះ គឺជាអ្នកមិនស្គាល់កុសល អកុសល កម្មមានទោស និងមិនមានទោស កម្ម និងផលនៃកម្ម ការមិនស្អាតនៃរាងកាយ និងភាពដែលសង្ខារទាំងឡាយ មិនទៀង ឈ្មោះថា **បរេ** ក្នុងទីនេះ ។ យើងទាំងឡាយ

នឹងលំបាក គឺនឹងនាំគ្នាលះបង់ក្នុងលោកនេះ គឺក្នុងជីវលោកនេះ បានដល់មិនដឹងថា ពួកយើងនឹងនាំគ្នាទៅកាន់ទីជិតមច្ចុរាជរឿយៗ គឺពិតប្រាកដ ។

បទថា **យេ ច តត្ថ វិជានន្តិ** សេចក្តីថា ក្នុងជនទាំងនោះ ជនណា គឺពួកដែលជាបណ្ឌិត រមែងដឹងខ្លួនថា ពួកយើងនឹងទៅកាន់ទីជិតនៃមច្ចុរាជ ។

បទថា **តតោ សម្មន្តិ មេធគា** សេចក្តីថា ជនទាំងនោះដែលស្គាល់ខ្លួនហើយយ៉ាងនោះ រមែងបដិបត្តិដើម្បីស្ងប់រម្ងាប់នូវវិវាទ គឺការបៀតបៀនអ្នកដទៃបាន អធិប្បាយថា ជនពួកដទៃ រមែងមិនទាស់ទែងគ្នា មិនបៀតបៀនគ្នាដោយខ្លួនឯង តែព្រះអង្គ ( ព្រះបាទចណ្ឌប្បជ្ជោត ) ព្រោះរក្សាជីវិត ទើបធ្វើបុគ្គលដែលមិនមែនចោរ ឲ្យជាចោរខ្លះ ដោយការដាក់នូវអាជ្ញា ទាំងធ្វើបុគ្គលជាម្ចាស់ទ្រព្យ មិនឲ្យជាម្ចាស់ទ្រព្យ ដោយការដាក់អាជ្ញាខ្លះ បៀតបៀនធ្វើឲ្យវិនាសទ្រព្យ ព្រោះការខ្វះបញ្ញា ។ បុគ្គលមិនធ្វើតាមនោះ ឈ្មោះថាបុគ្គលប្រកបដោយបញ្ញា បើទុកជាអស់សម្បត្តិរលីងគេង ក៏ឈ្មោះថារស់នៅឯបុគ្គលមានសម្បត្តិ ឈ្មោះថា មិនរស់នៅ ព្រោះការមិនបាននូវបញ្ញា គឺបុគ្គលមានបញ្ញា ទោះបីអស់ទ្រព្យ ក៏សន្តោសត្រេកអរដោយបច្ច័យតាមមាន តាមបាន ចិញ្ចឹមជីវិតដោយការងារដែលប្រាសចាកទោស នេះឈ្មោះថា ជាជីវិតរបស់បុគ្គលដែលមានបញ្ញា ។

ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ ( ក្នុងសំយុត្តនិកាយ សគាថវគ្គ ) ថា អ្នករស់នៅដោយបញ្ញា ឈ្មោះថា ជាអ្នករស់នៅប្រសើរបំផុត ឯបុគ្គលដែលមានបញ្ញាថោកថយ ព្រោះខ្វះនូវបញ្ញា ធ្វើប្រយោជន៍ក្នុង

លោកនេះ និងលោកខាងមុខឲ្យវិនាសទៅ ទោះបីមានទ្រព្យ ក៏រស់នៅមិនបាន មិនឈ្មោះថា រស់នៅ ព្រោះត្រូវពាក្យនិន្ទាជាដើម ឬធ្វើទ្រព្យដែលមានហើយឲ្យវិនាសទៅ សូម្បីជីវិតក៏មិនអាចប្រព្រឹត្តទៅបាន ព្រោះខ្លួនមិនមានឧបាយ ។

បានឮថា ព្រះថេរៈបានពោលគាថាទាំង ៤ នេះ ថ្វាយព្រះរាជាក្នុងព្រះសុបិន ។ ព្រះរាជាទ្រង់សុបិន ទ្រង់តើនឡើងខណៈដែលសុបិនថា កំពុងថ្វាយបង្គំព្រះថេរៈនោះឯង លុះរាត្រីអស់ហើយ ក៏ចូលទៅរកព្រះថេរៈ ទ្រង់ថ្វាយបង្គំហើយ ទ្រង់ពោលដល់ការយល់សប្តិ តាមដែលទ្រង់ឃើញហើយដល់ព្រះថេរៈៗ ស្តាប់រឿងនៃការយល់សប្តិនោះហើយ បានភាសិតចំពោះគាថានោះ ថ្វាយជាឱវាទដល់ព្រះរាជាដោយ ២ គាថាថា **សព្វំ សុណាតិ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ ដោយបទថា **សព្វំ សុណាតិ សោតេន** ក្នុងទីនេះសំដៅសេចក្តីថា បុគ្គលមិនថ្លង់ រមែងបានឮសំឡេង ដែលល្មមបានឮច្បាស់ទាំងអស់ ដែលមកប្រាកដ គឺទាំងដែលជាពាក្យសុភាសិតផង និងពាក្យដែលជាទុព្ភាសិតផង ដោយសោតប្បសាទ ។ បុគ្គលមិនខ្វាក់ ក៏ដូចគ្នារមែងឃើញរូបទាំងអស់ គឺដែលល្អ និងមិនល្អដោយចក្ខុបសាទ នេះចាត់ថាជាសភាវៈនៃឥន្ទ្រិយទាំងឡាយ ។

បណ្តាបទទាំងនោះ បទថា **ន ច ទិដ្ឋំ សុតំ ធីរោ សព្វំ ឧជ្ឈិតុំ** នេះត្រឹមតែជាឧទាហរណ៍ប៉ុណ្ណោះ សេចក្តីថា អ្នកប្រាជ្ញ គឺបុគ្គលមានបញ្ញា មិន

គួរលះបង់ ឬប្រកាន់នូវរូបទាំងអស់ដែលបានឃើញមក ឬសំឡេងទាំងអស់ដែលបានឮមកហើយ ។ អ្នកប្រាជ្ញពិចារណាដល់គុណ និងទោស ក្នុងរូប និងសំឡេងនោះហើយ គួរលះបង់ចំពោះវត្ថុដែលគួរលះបង់ និងគួរប្រកាន់វត្ថុដែលគួរប្រកាន់ ព្រោះដូច្នោះ បុគ្គលមានបញ្ញា ទោះបីមានភ្នែកល្អ ក៏ធ្វើដូចជាបុគ្គលខ្វាក់ គឺទោះបីមានភ្នែកល្អ កាលឃើញវត្ថុដែលគួរលះបង់ ក៏គួរធ្វើដូចមនុស្សខ្វាក់ គឺធ្វើដូចមើលមិនឃើញ ។ កាលបានស្តាប់វត្ថុដែលគួរលះបង់ក៏ដូចគ្នា ទោះបីមានត្រចៀកល្អ ក៏ធ្វើដូចមនុស្សត្រចៀកថ្លង់ គឺធ្វើដូចមិនបានឮ ។

បទថា **បញ្ញវស្ស យថា មូគោ** សេចក្តីថា បុគ្គលមានបញ្ញា សូម្បីឈ្លាសក្នុងពាក្យដែលគប្បីធ្វើដូចមនុស្ស-គ ក្នុងកាលមិនគួរនិយាយ ព្រោះមានបញ្ញាជាគ្រឿងពិចារណា ។ បុគ្គលមានកម្លាំង គឺដល់ព្រមដោយកម្លាំង ក៏គប្បីធ្វើដូចបុគ្គលទុព្វល ក្នុងកាលមិនគួរធ្វើ ។ រ អក្ខរៈ ( ក្នុងពាក្យថា **ទុព្វលោរិវ** ) ធ្វើការភ្ជាប់បទ បានដល់ គប្បីធ្វើដូចបុគ្គលដែលឥតសមត្ថភាព ។

បទថា **អថ អត្ថេ សមុប្បន្នេ សយេថ មតសាយិកំ** សេចក្តីថា

កាលកិច្ចដែលខ្លួនគួរធ្វើកើតឡើង គឺប្រាកដឡើង ទោះដេកក្នុងពេលជិតស្លាប់ បានដល់ សូម្បីនៅក្នុងពេលជិតស្លាប់ ក៏គួរពិចារណាដល់ប្រយោជន៍នោះឯង គឺមិនព្រមឲ្យប្រយោជន៍នោះសាបសូន្យទៅ ។

ម្យ៉ាងទៀត បទថា **អថ អត្ថេ សមុប្បន្នេ** សេចក្តីថា កាលប្រយោជន៍ គឺកិច្ចដែលខ្លួនមិនគួរធ្វើកើតឡើង គឺប្រាកដឡើង ទោះដេកក្នុងពេលជិតស្លាប់ បានដល់ ដេកក្នុងពេលជិតស្លាប់ហើយ មិនព្រមធ្វើវត្ថុដែលមិនគួរធ្វើនោះឡើយ ។ ព្រះរាជាបានទទួលឱវាទអំពីព្រះថេរៈយ៉ាងនេះថា បណ្ឌិតមិនគួរធ្វើវត្ថុដែលមិនគួរធ្វើ ដូច្នេះហើយ ទ្រង់លះវត្ថុដែលមិនគួរធ្វើ ប្រកបចំពោះវត្ថុដែលគួរធ្វើប៉ុណ្ណោះ ៕

**អដ្ឋកថា មហាកច្ចាយនត្ថេរគាថា ចប់**

# សុត្តន្តបិដក

## សិរិមិត្តត្ថេរគាថា

[ ២៣១ ] ភិក្ខុណា គ្មានសេចក្តីក្រោធ មិនចងសេចក្តីក្រោធទុក មិនមានមាយា ប្រាសចាកសេចក្តីញុះញង់ ភិក្ខុមានសភាពដូច្នោះ នោះឯង រមែងមិនសោយសោកក្នុងខាងមុខ ដោយសេចក្តីប្រតិបត្តិយ៉ាងនេះ ។ ភិក្ខុណា គ្មានសេចក្តីក្រោធ មិនចងសេចក្តីក្រោធទុក មិនមានមាយា ប្រាសចាកសេចក្តីញុះញង់ មានទ្វាររក្សាហើយ គ្រប់កាល ភិក្ខុនោះ រមែងមិនសោយសោកក្នុងខាងមុខ ដោយសេចក្តីប្រតិបត្តិយ៉ាងនេះ ។ ភិក្ខុណា គ្មានសេចក្តីក្រោធ មិនចងសេចក្តីក្រោធទុក មិនមានមាយា ប្រាសចាកសេចក្តីញុះញង់ មានសីលល្អ ភិក្ខុនោះ រមែងមិនសោយសោកក្នុងខាងមុខ ដោយសេចក្តីប្រតិបត្តិយ៉ាងនេះ ។ ភិក្ខុណា គ្មានសេចក្តីក្រោធ មិនចងសេចក្តីក្រោធទុក មិនមានមាយា ប្រាសចាកសេចក្តីញុះញង់ មានមិត្តល្អ ភិក្ខុនោះ រមែងមិនសោកសោយ ក្នុងកាលខាងមុខ ដោយសេចក្តីប្រតិបត្តិយ៉ាងនេះ ។ ភិក្ខុណា គ្មានសេចក្តីក្រោធ មិនចងសេចក្តីក្រោធទុក មិនមានមាយា ប្រាសចាកសេចក្តីញុះញង់ មានបញ្ញាល្អ ភិក្ខុនោះ រមែងមិនសោកស្តាយ ក្នុងកាលខាងមុខ ដោយសេចក្តីប្រតិបត្តិយ៉ាងនេះ ។ បុគ្គលណា មានសទ្ធាមិនញាប់ញ័រ បានតម្កល់ស៊ប់ក្នុងព្រះតថាគតផង បុគ្គលណា មានសីលល្អ ជាទីត្រេកអរនៃព្រះអរិយៈ ដែលព្រះអរិយៈសរសើរហើយផង បុគ្គលណា មានសេចក្តី

ជ្រះថ្លា ក្នុងសង្ឃផង បុគ្គលណា មានការយល់ឃើញត្រង់ផង អ្នកប្រាជ្ញទាំងឡាយ ហៅបុគ្គលនោះថាជាអ្នកមិនខ្សត់ ជីវិតរបស់បុគ្គលនោះ មិនមែនជាមោឃៈទេ ។ ព្រោះហេតុនោះ មេធាវីបុគ្គលកាលរឭកនូវពាក្យប្រដៅ របស់ព្រះពុទ្ធទាំងឡាយ គួរប្រកបរឿយៗ នូវសទ្ធាផង សីលផង សេចក្ដីជ្រះថ្លាផង ការយល់ធម៌ផង ។

**សិរិមិត្តត្ថេរ**

# អដ្ឋកថា

## សិរិមិត្តត្ថេរគាថា

[ ២៣១ ] គាថារបស់ព្រះសិរិមិត្តត្ថេរ មានពាក្យផ្ដើមថា **អក្កោធនោ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងពុទ្ធុប្បាទនេះ កើតជាកូនប្រុសរបស់កុដុម្ពិកៈ ដែលមានទ្រព្យច្រើន ក្នុងក្រុងរាជគ្រឹះ មានឈ្មោះថា សិរិមិត្ត បានឮថា មាតារបស់សិរិមិត្តនោះ ជាប្អូនស្រីរបស់សិរិគុត្ត រឿងរបស់សិរិគុត្តនោះ មកហើយក្នុងអដ្ឋកថាធម្មបទនោះឯង ។ សិរិមិត្តជាក្មួយប្រុសនៃសិរិគុត្តនោះ ចម្រើនវ័យហើយ បាននូវសេចក្ដីជ្រះថ្លាចំពោះព្រះសាស្ដា ក្នុងការទូន្មានដំរីធនបាល បួសហើយ បំពេញ

វិបស្សនា មិនយូរប៉ុន្មានក៏សម្រេចអរហត្ត ថ្ងៃមួយ ឡើងកាន់អាសនៈដើម្បីសូធ្យបាតិមោក្ខ ទើបអន្ទុយចាប់ផ្ចិតវីជនីដ៏វិចិត្រ ប្រាប់ធម៌ដល់ភិក្ខុទាំងឡាយ ព្រះថេរៈកាលនឹងប្រាប់ និងកាលបែកសម្តែងគុណដ៏ឧឡារ ទើបពោលគាថាថា

ភិក្ខុណា គ្មានសេចក្តីក្រោធ មិនចងសេចក្តីក្រោធទុក មិនមានមាយា ប្រាសចាកសេចក្តីញុះញង់ ភិក្ខុមានសភាពដូច្នោះនោះឯង រមែងមិនសោយសោកក្នុងខាងមុខ ដោយសេចក្តីប្រតិបត្តិយ៉ាងនេះ ។ ភិក្ខុណា គ្មានសេចក្តីក្រោធ មិនចងសេចក្តីក្រោធទុក មិនមានមាយា ប្រាសចាកសេចក្តីញុះញង់ មានទ្វាររក្សាហើយគ្រប់កាល ភិក្ខុនោះ រមែងមិនសោយសោកក្នុងខាងមុខ ដោយសេចក្តីប្រតិបត្តិយ៉ាងនេះ ។ ភិក្ខុណា គ្មានសេចក្តីក្រោធ មិនចងសេចក្តីក្រោធទុក មិនមានមាយា ប្រាសចាកសេចក្តីញុះញង់ មានសីលល្អ ភិក្ខុនោះ រមែងមិនសោយសោកក្នុងខាងមុខ ដោយសេចក្តីប្រតិបត្តិយ៉ាងនេះ ។ ភិក្ខុណា គ្មានសេចក្តីក្រោធ មិនចងសេចក្តីក្រោធទុក មិនមានមាយា ប្រាសចាកសេចក្តីញុះញង់ មានមិត្តល្អ ភិក្ខុនោះ រមែងមិនសោកសោយ ក្នុងកាលខាងមុខ ដោយសេចក្តីប្រតិបត្តិយ៉ាងនេះ ។ ភិក្ខុណា គ្មានសេចក្តីក្រោធ មិនចងសេចក្តីក្រោធទុក មិនមានមាយា ប្រាសចាកសេចក្តីញុះញង់ មានបញ្ញាល្អ ភិក្ខុនោះ រមែងមិនសោកស្តាយក្នុងកាល

ខាងមុខ ដោយសេចក្ដីប្រតិបត្តិយ៉ាងនេះ ។ បុគ្គលណា មាន សទ្ធាមិនញាប់ញ័រ បានតម្កល់ស៊ប់ ក្នុងព្រះតថាគតផង បុគ្គល ណា មានសីលល្អ ជាទីត្រេកអរនៃព្រះអរិយៈ ដែលព្រះអរិយៈ សរសើរហើយផង បុគ្គលណា មានសេចក្ដីជ្រះថ្លា ក្នុងសង្ឃផង បុគ្គលណា មានការយល់ឃើញត្រង់ផង អ្នកប្រាជ្ញទាំងឡាយ ហៅបុគ្គលនោះថា ជាអ្នកមិនខ្សត់ ជីវិតរបស់បុគ្គលនោះ មិន មែនជាមោឃៈទេ ។ ព្រោះហេតុនោះ មេធាវីបុគ្គល កាលរឭកនូវ ពាក្យប្រដៅ របស់ព្រះពុទ្ធទាំងឡាយ គួរប្រកបរឿយៗ នូវសទ្ធា ផង សីលផង សេចក្ដីជ្រះថ្លាផង ការយល់ធម៌ផង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អក្កោធនោ** បានដល់ មានប្រក្រតីមិន ក្រោធ អធិប្បាយថា កាលមានហេតុដែលនឹងឲ្យកើតសេចក្ដីក្រោធប្រាកដ ឡើង ក៏តាំងនៅក្នុងអធិវាសនខន្តី មិនព្រមឲ្យសេចក្ដីក្រោធកើតឡើងឡើយ ។

បទថា **អនុបនាហី** បានដល់ មិនចងនូវសេចក្ដីក្រោធ អធិប្បាយថា ជាអ្នកមានប្រក្រតី មិនចងសេចក្ដីក្រោធដោយអាងកំហុស ដែលអ្នកដទៃធ្វើ ដោយន័យជាដើមថា បុគ្គលឯណោះបានជេរអញ បានសម្លាប់អញ បានយក ឈ្នះអញ បានលួចទ្រព្យរបស់អញ ដូច្នេះ ។

ឈ្មោះថា **អមាយោ** ព្រោះមិនមានមាយា ដែលមានលក្ខណៈបិទបាំង នូវទោសកំហុសដែលមាន ។

ឈ្មោះថា **រិត្តបេសុណោ** ព្រោះវៀរចាកបិសុណវាចា ។

បទថា **ស វេ តាទិសកោ ភិក្ខុ** បានដល់ ភិក្ខុនោះ គឺជាបុគ្គលបែប នោះ ដែលមានជាតិយ៉ាងនោះ ជាអ្នកប្រកបដោយគុណតាមដែលពោលមក ហើយ អធិប្បាយថា ដោយបដិបទាតាមដែលពោលហើយយ៉ាងនេះ ភិក្ខុនោះ លះលោក ( នេះ ) ទៅហើយ រមែងមិនសោយសោកក្នុងលោកខាងមុខ ព្រោះថា មិនមានហេតុនៃសេចក្ដីសោក ។

ឈ្មោះថា **គុត្តទ្វារោ** ព្រោះមានចក្ខុទ្វារជាដើម និងមានកាយទ្វារ ជាដើម គ្រប់គ្រងរក្សាហើយ ។

បទថា **កល្យាណសីលោ** បានដល់ ជាអ្នកមានសីលល្អ គឺមានសីល ដ៏បរិសុទ្ធល្អ ។

បទថា **កល្យាណមិត្តោ** សេចក្ដីថា ឈ្មោះថា កល្យាណមិត្ត ព្រោះ អត្ថថា មានមិត្តល្អ ដែលមានលក្ខណៈតាមដែលទ្រង់សម្ដែង ( ក្នុងអង្គុត្តរ-និកាយ សត្តកនិបាត ) យ៉ាងនេះថា

ភិក្ខុជាអ្នក ( ធ្វើខ្លួន ) ឲ្យជាទីស្រឡាញ់ផង គួរគោរពផង គួរ សរសើរផង ឧស្សាហ៍ប្រៀនប្រដៅផង អត់ធន់ចំពោះពាក្យផង ជាអ្នកនិយាយពាក្យជ្រៅផង ទាំងមិនដឹកនាំក្នុងហេតុដែលមិនគួរ ផង ដូច្នេះ ។

បទថា **កល្យាណបញ្ញោ** បានដល់ ជាអ្នកមានបញ្ញាល្អ អធិប្បាយថា ធម្មតាបញ្ញាដែលមិនល្អ មិនមានក៏ពិត តែទោះជាយ៉ាងនោះ លោកពោល យ៉ាងនេះ ក៏ដោយអំណាចបញ្ញាដែលជាហេតុនាំចេញចាកសង្សារ ។

ព្រះថេរៈកាលសម្តែងដល់សម្មាបដិបត្តិ ដោយគាថាដែលជាបុគ្គលា-ធិដ្ឋាន ដោយលើកយកការមិនក្រោធជាប្រធានជាដើម ដោយអំណាចការសង្កត់ និងដោយអំណាចការកាត់ផ្តាច់នូវកិលេស មានសេចក្តីក្រោធជាដើម ក្នុងគាថានោះយ៉ាងនេះហើយ ឥឡូវនេះ កាលនឹងលើកយកសទ្ធាដែលជាលោកុត្តរ ដែលខ្លួនបានសម្រេចហើយជាដើម យកមកសម្តែងដល់សម្មាបដិ-បត្តិ ដោយគាថាដែលជាបុគ្គលាធិដ្ឋានសុទ្ធៗ ទើបពោលពាក្យថា **យស្ស សទ្ធា** ដូច្នេះជាដើម ។

អត្ថនៃគាថានោះថា បុគ្គលណាមានសទ្ធា ដែលមកដោយមគ្គ ដែលប្រព្រឹត្តទៅដោយន័យជាដើមថា **ឥតិបិ សោ ភគវា អរហំ** ជាដើម ព្រោះហេតុនោះឯង ទើបមិនញាប់ញ័រ គឺមិនល្អៀងក្នុងព្រះតថាគតសម្មាសម្ពុទ្ធតាំងមាំហើយដោយល្អ បណ្ឌិតគប្បីនាំបទថា **អត្ថិ** មកភ្ជាប់ផងដែរ ។

បទថា **អរិយកន្តំ** បានដល់ ដែលព្រះអរិយៈទាំងឡាយពេញចិត្តប្រាថ្នា ព្រោះមិនលះក្នុងវវាងភព ។

បទថា **បសំសិតំ** មានវាចាប្រកបសេចក្តីថា មានសីលដែលបណ្ឌិតទាំងឡាយ មានព្រះពុទ្ធសរសើរហើយជាដើម លើកតម្កើងហើយ ។ សីលនេះមាន ២ យ៉ាង គឺសីលរបស់គ្រហស្ថ និងសីលរបស់បព្វជិត ។

ក្នុងបណ្តាសីល ២ យ៉ាងនោះ សីល គឺសិក្ខាបទ ៥ ដែលគ្រហស្ថអាចរក្សាបាន ឈ្មោះថា សីលរបស់គ្រហស្ថ ។ ចតុប្បារិសុទ្ធិសីល រួមនឹងសិក្ខាបទ ១០ ឈ្មោះថា សីលរបស់បព្វជិត សីលទាំងនេះ បណ្ឌិតគប្បី

ជ្រាបថា ស្អាត ព្រោះមិនត្រូវវិបត្តិ មានសីលដាច់ពាល់ត្រូវហើយជាដើម ។

បទថា **សទ្ធា បសាទោ យស្សត្ថិ** សេចក្ដីថា បុគ្គលណាមានសេចក្ដីជ្រះថ្លា គឺមានសទ្ធាមិនញាប់ញ័រ តាំងមាំល្អហើយ ក្នុងអរិយសង្ឃ ដោយន័យជាដើមថា **សុបដិបន្នោ ភគវតោ សាវកសង្ឃោ** ដូច្នេះ បណ្ឌិតគប្បីនាំពាក្យថា **អចលោ សុបតិដ្ឋិតោ** មកប្រកបចូលផង ។

បទថា **ឧជុភូតញ្ច ទស្សនំ** មានវាចាប្រកបសេចក្ដីថា បុគ្គលណាមានការឃើញទាំង ២ យ៉ាង គឺការឃើញថា សត្វមានកម្មជារបស់ខ្លួន និងការឃើញថា នាមរូប ជាវត្ថុទាក់ទងដោយបច្ច័យ បច្ច័យជាវត្ថុដែលត្រង់ គឺមិន-ងមិនកោង ព្រោះមិនមានការវៀច គឺទិដ្ឋិ និងព្រោះមិនមានការវៀច គឺកិលេស បុគ្គលនោះ ឈ្មោះថា **អចលោ សុបតិដ្ឋិតោ** ដូច្នេះ ។

បទថា **អទលិទ្ទោតិ តំ អាហុ** សេចក្ដីថា ព្រះអរិយៈទាំងឡាយមានព្រះសម្ពុទ្ធជាដើម ពោលបុគ្គលនោះ គឺបុគ្គលបែបនោះថា ជាអ្នកមិនក្រីក្រ ព្រោះបុគ្គលនោះមានទ្រព្យដ៏បរិសុទ្ធដោយល្អទាំងនេះ ទ្រព្យ គឺសទ្ធា ទ្រព្យ គឺសីល ទ្រព្យ គឺសុតៈ ទ្រព្យ គឺចាគៈ និងទ្រព្យ គឺបញ្ញា ។

បទថា **អមោឃំ តស្ស ជីវិតំ** សេចក្ដីថា បណ្ឌិតទាំងឡាយពោលថា ជីវិតរបស់បុគ្គលនោះ គឺបុគ្គលបែបនោះ មិនឥតប្រយោជន៍ គឺមិនទទេចាក

ការសម្រេចដល់ប្រយោជន៍ មានប្រយោជន៍ដែលជាបច្ចុប្បន្នជាដើម បានដល់ជាជីវិតដែលមានផលពិតប្រាកដ ។

បទថា **តស្មា** បានដល់ ព្រោះបុគ្គលប្រកបដោយគុណ មានសទ្ធាតាមដែលពោលហើយជាដើម បណ្ឌិតហៅថា ជាអ្នកមិនក្រីក្រ មានជីវិតមិនឥតប្រយោជន៍ ដូច្នោះ សូម្បីខ្លួនអាត្មាអញ ក៏គប្បីជាបុគ្គលបែបនោះ ។

បទថា **សទ្ធញ្ច ។បេ។ សាសនំ** សេចក្ដីថា កុលបុត្រកាលរឭកដល់ពាក្យប្រៀនប្រដៅទាំងឡាយដែលត្រាស់ហើយ ដោយន័យជាដើមថា **សព្វបាបស្ស អករណំ** ការមិនធ្វើបាបទាំងពួង ដូច្នេះ គប្បីប្រកប គឺគប្បីចម្រើននូវសទ្ធា សីល មានប្រភេទដូចពោលហើយ និងការជ្រះថ្លា ដែលមានការឃើញធម៌ជាហេតុ ដែលជាការរួចផុត ដោយការចូលក្នុងធម៌ ឲ្យចម្រើនឡើងចុះ ។

កាលព្រះថេរៈប្រកាសគុណដែលមានក្នុងខ្លួន ដោយបំណងសម្ដែងធម៌ដល់ភិក្ខុទាំងឡាយយ៉ាងនេះ ទើបស្មើនឹងបានព្យាករអរហត្តផល ដូច្នេះ ។៚

**អដ្ឋកថា សិរិមិត្តត្ថេរគាថា ចប់**

# សុត្តន្តបិដក

## មហាបន្ថកត្ថេរគាថា

[ ២៣២ ] កាលណា ខ្ញុំឃើញព្រះសាស្តា ព្រះអង្គគ្មានភ័យអំពីទីណាជាដំបូង ក្នុងកាលនោះ សេចក្តីសង្វេគក៏មានដល់ខ្ញុំ ព្រោះឃើញព្រះសាស្តា ជាឧត្តមបុរស ។ អ្នកណា ប្រទានសិរីដែលមក ( រកខ្លួន ) ដោយដៃ ឬជើង អ្នកនោះ ឈ្មោះថា ញុំាងព្រះសាស្តាបែបនេះឲ្យត្រេកអរ ហើយឲ្យប្រាសចាកសេចក្តីត្រេកអរវិញ ។ ក្នុងកាលនោះ ខ្ញុំលះបោលកូន និងប្រពន្ធផង ទ្រព្យ និងស្រូវផង កោរសក់ និងពុកចង្កា ហើយចូលទៅកាន់ផ្នួស ។ ខ្ញុំបរិបូណ៌ដោយសិក្ខា និងសាជីវៈ សង្រួមនូវឥន្ទ្រិយទាំងឡាយ ជាអ្នកមិនចាលចាញ់កិលេស តែងនមស្ការព្រះសម្ពុទ្ធ សម្រាន្តនៅ ។ ខណៈនោះ សេចក្តីតាំងចិត្តខ្ញុំបានតម្កល់ហើយថា កាលបើខ្ញុំមិនទាន់ដកសរ គឺតណ្ហាបានទេ ខ្ញុំមិនអង្គុយសូម្បីមួយរំពេច ។ អ្នកចូរមើលសេចក្តីព្យាយាម និងការប្រឹងប្រែងរបស់ខ្ញុំនោះ យ៉ាងនេះ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ ពុទ្ធសាសនា ខ្ញុំបានធ្វើហើយ ។ ខ្ញុំដឹងនូវបុព្វេនិវាស ទិព្វចក្ខុ ខ្ញុំក៏បានជម្រះហើយ ខ្ញុំជាព្រះអរហន្ត គួរទទួលនូវទក្ខិណាទាន មានចិត្តរួចស្រឡះហើយ មិនមានឧបធិ ។ លំដាប់នោះ ក្នុងកាលរាត្រីអស់ទៅ ព្រះអាទិត្យក៏រះឡើង ខ្ញុំបានធ្វើតណ្ហាទាំងអស់ ឲ្យរីងស្ងួត ហើយអង្គុយដោយភ្នែន ។

មហាបន្ថកត្ថេរ

**ឧទ្ទាន**

ព្រះថេរៈ ៣ អង្គ គឺមហាកច្ចាយនត្ថេរ ១ សិរិមិត្តត្ថេរ ១ មហាបន្ថកត្ថេរ ១ បានសម្ដែងគាថាទាំងឡាយ ២៤ ក្នុងអដ្ឋកនិបាត ។

អដ្ឋកនិបាត ចប់

# អដ្ឋកថា

## មហាបន្ថកត្ថេរគាថា

[ ២៣២ ] គាថារបស់ព្រះមហាបន្ថកត្ថេរ មានពាក្យផ្ដើមថា **យទា បឋមមទ្ទក្ខឹ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា ក្នុងសាសនាព្រះមានព្រះភាគ ព្រះនាមបទុមុត្តរៈ ព្រះមហាបន្ថកៈនេះ ជាកុដុម្ពិកៈ សម្បូរដោយទ្រព្យសម្បត្តិ ក្នុងហង្សវតីនគរ ថ្ងៃមួយកំពុងស្ដាប់ធម៌ក្នុងសម្នាក់ព្រះសាស្ដា ឃើញព្រះសាស្ដាស្ថាបនាភិក្ខុមួយរូបក្នុងតំណែងជាឯតទគ្គៈជាងភិក្ខុទាំងឡាយ ដែលឈ្លាសក្នុងការបើកបញ្ញាសូម្បីខ្លួនឯង ក៏ប្រាថ្នានូវតំណែងនោះ ទើបបំពេញមហាទាន ឲ្យប្រព្រឹត្តទៅអស់ ៧ ថ្ងៃ ដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយតាំងសេចក្ដីប្រាថ្នាថា បពិត្រព្រះអង្គដ៏ចម្រើន កាលពី ៧ ថ្ងៃមុន ទ្រង់តែងតាំងភិក្ខុណាក្នុងតំណែងឯតទគ្គៈថា ភិក្ខុនេះជាកំពូលជាងភិក្ខុទាំងឡាយដែលឈ្លាសក្នុងការបើកបញ្ញា ក្នុងសាសនារបស់តថាគត ដូច្នេះ ដោយកម្លាំងនៃកុសលកម្ម

ដែលសន្សំនេះ ខ្ញុំព្រះអង្គសូមបានជាឯតទគ្គៈ ក្នុងសាសនារបស់ព្រះពុទ្ធអង្គណាមួយ ក្នុងអនាគតកាល ដូចភិក្ខុនោះចុះ ។

ប្អូនប្រុសរបស់កុដុម្ពិកៈនោះ បំពេញកុសលកម្ម សន្សំក្នុងព្រះមានព្រះភាគយ៉ាងនោះដូចគ្នា ហើយតាំងបណិធានដោយន័យដូចពោលហើយនោះឯង គឺដោយអង្គ ២ បានដល់ ការនិម្មិតរាងកាយដែលសម្រេចដោយចិត្ត និងភាពជាអ្នកឈ្លាសក្នុងការបើកចិត្ត ។ ព្រះមានព្រះភាគទ្រង់ឃើញសេចក្តីប្រាថ្នារបស់ជនទាំង ២ សម្រេចដោយមិនមានអន្តរាយ ទើបទ្រង់ព្យាករថា ក្នុងអនាគត ក្នុងទីបំផុតនៃមួយសែនកប្ប ក្នុងសាសនានៃព្រះសម្មាសម្ពុទ្ធព្រះនាមគោតម សេចក្តីប្រាថ្នារបស់ពួកអ្នកនឹងសម្រេច ។

ជនទាំង ២ នោះ បំពេញបុណ្យជាច្រើនក្នុងអត្តភាពនោះ ដរាបដល់អស់ជីវិត ចុតិចាកអត្តភាពនោះ ក៏កើតក្នុងទេវលោក ។ ក្នុងជនទាំង ២ នោះ មហាបន្ថកៈបំពេញសេចក្តីល្អក្នុងវាងភពដូចម្តេច លោកមិនបានពោលដល់ ។

ឯចូឡបន្ថកៈ បួសក្នុងសាសនានៃព្រះមានព្រះភាគ ព្រះនាមកស្សបៈ ចម្រើនឱទាតកសិណអស់ពីរម៉ឺនឆ្នាំ ហើយកើតក្នុងទេវបុរី ។ ចំណែកក្នុងអបទានលោកពោលថា ក្នុងកាលនៃព្រះមានព្រះភាគ ព្រះនាមបទុមុត្តរៈ ចូឡបន្ថកតាបស នៅក្នុងហិមវន្តប្បទេស ជួបព្រះមានព្រះភាគក្នុងទីនោះ ហើយ បានធ្វើការបូជាដោយឆត្រផ្កា ។ កាលជនទាំង ២ នោះ អន្ទោលក្នុងទេវតា និងមនុស្សនោះឯង ពេលវេលាកន្លងទៅមួយសែនកប្ប ។ តមកព្រះសាស្តានៃយើងសម្រេចអភិសម្មាសម្ពោធិញ្ញាណហើយ ទ្រង់ញុំាងធម្មចក្ក

ដ៏បវរឲ្យប្រព្រឹត្តទៅ ទ្រង់អាស្រ័យក្រុងរាជគ្រឹះ គង់នៅក្នុងវេឡុវនមហាវិហារ ។

សម័យនោះ កូនស្រីរបស់ធនសេដ្ឋី ក្នុងក្រុងរាជគ្រឹះ លបលួចស្រឡាញ់ទាសៈរបស់ខ្លួន ខ្លាចពួកញាតិ ទើបកាន់យកទ្រព្យដែលជាសារៈគេចទៅជាមួយទាសៈនោះ ទៅរស់នៅក្នុងទីដទៃ អាស្រ័យការនៅរួមគ្នានោះ ក៏តាំងគភ៌ លុះគភ៌ចាស់ខែ គិតថា អញនឹងទៅប្រសូតកូនក្នុងផ្ទះរបស់ញាតិ ខណៈធ្វើដំណើរទៅ បានប្រសូតបុត្តក្នុងចន្លោះផ្លូវនោះឯង ត្រូវប្តីតាមឲ្យត្រឡប់ហើយ ក៏នៅក្នុងទីដែលខ្លួននៅក្នុងកាលមុន បានដាក់ឈ្មោះកូននោះថា **បន្ថកៈ** ព្រោះកើតតាមផ្លូវ ។ ក្នុងកាលបន្ទកៈរត់ទៅរត់មកបាន ព្រោះការនៅរួមជាមួយស្វាមីនោះទៀត នាងក៏តាំងគភ៌ជាលើកទី ២ លុះគភ៌ចាស់ហើយក៏ប្រសូតបុត្ត ក្នុងរវាងផ្លូវដោយន័យដូចពោលហើយខាងដើមដូចគ្នា ត្រូវប្តីតាមឲ្យត្រឡប់ ទើបដាក់ឈ្មោះកូនប្រុសច្បងថា **មហាបន្ថកៈ** កូនប្អូនថា **ចូឡបន្ថកៈ** នៅក្នុងទីដែលធ្លាប់រស់នៅនោះឯង ។ កាលទារកទាំង ២ ចម្រើនវ័យដោយលំដាប់ ត្រូវទារកទាំង ២ រំអុកថា អ្នកម៉ែ សូមប្រាប់ត្រកូលតា យាយ ដល់ពួកខ្ញុំផងចុះ ទើបបញ្ជូនទារកទាំង ២ ទៅរកមាតាបិតា ។ ចាប់តាំងពីកាលនោះមក កុមារទាំង ២ ចម្រើនវ័យក្នុងផ្ទះរបស់ធនសេដ្ឋី ។

ក្នុងទារកទាំងនោះ ចូឡបន្ថកៈនៅតូច ឯមហាបន្ថកៈទៅកាន់សម្នាក់នៃព្រះមានព្រះភាគជាមួយជីតា ហើយឃើញព្រះសាស្តា ដំណាលគ្នានឹងការឃើញ ក៏កើតសទ្ធា ស្តាប់ធម៌ហើយ ព្រោះភាពដែលខ្លួនសម្បូរដោយឧប-

និស្ស័យ ជាអ្នកមានបំណងបព្វជ្ជា ទើបប្រាប់ដល់ជីតា ។ ជីតាទូលសេចក្តីនោះដល់ព្រះសាស្តា ហើយក៏អនុញ្ញាតឲ្យមហាបន្ថកៈបួស មហាបន្ថកៈបព្វជ្ជាហើយ រៀនព្រះពុទ្ធវចនៈជាច្រើន លុះមានអាយុគ្រប់ ២០ ឧបសម្បទាហើយ ធ្វើមនសិការដោយឧបាយ ជាអ្នកបាននូវអរូបជ្ឈាន ៤ ដោយពិសេស ចេញអំពីអរូបជ្ឈាន ៤ ហើយ ព្យាយាមលើកចិត្តឡើងកាន់វិបស្សនា ហើយសម្រេចអរហត្ត ។ ព្រោះហេតុនោះ ទើបព្រះថេរៈជាកំពូលជាងភិក្ខុទាំងឡាយដែលឈ្លាសក្នុងការបើកបញ្ញា ។ ព្រះថេរៈនៅសម្រាំដោយសេចក្តីសុខដែលកើតអំពីឈាន និងសេចក្តីសុខកើតអំពីផល ។ ថ្ងៃមួយ ពិចារណាដល់បដិបទារបស់ខ្លួន អាស្រ័យបដិបទាដែលខ្លួនសម្រេចហើយ កើតនូវសោមនស្ស កាលបន្លឺសីហនាទ ទើបពោលគាថាទាំងនេះថា

កាលណា ខ្ញុំឃើញព្រះសាស្តា ព្រះអង្គគ្មានភ័យអំពីទីណាជាដំបូង ក្នុងកាលនោះ សេចក្តីសង្វេគក៏មានដល់ខ្ញុំ ព្រោះឃើញព្រះសាស្តាជាឧត្តមបុរស ។ អ្នកណា ប្រានសិរីដែលមក ( រកខ្លួន ) ដោយដៃ ឬជើង អ្នកនោះ ឈ្មោះថា ញុំាងព្រះសាស្តាបែបនេះឲ្យត្រេកអរ ហើយឲ្យប្រាសចាកសេចក្តីត្រេកអរវិញ ។ ក្នុងកាលនោះ ខ្ញុំលះបោលកូន និងប្រពន្ធផង ទ្រព្យ និងស្រូវផង កោរសក់ និងពុកចង្កា ហើយចូលទៅកាន់ផ្នួស ។ ខ្ញុំបរិបូណ៌ដោយសិក្ខា និងសាជីវៈ សង្រួមនូវឥន្ទ្រិយទាំងឡាយ ជាអ្នកមិនចាលចាញ់កិលេស តែងនមស្ការព្រះសម្ពុទ្ធ សម្រាន្តនៅ ។ ខណៈនោះ

សេចក្ដីតាំងចិត្ត ខ្ញុំបានតម្កល់ហើយថា កាលបើខ្ញុំមិនទាន់ដកសរ គឺតណ្ហាបានទេ ខ្ញុំមិនអង្គុយ សូម្បីមួយរំពេច ។ អ្នកចូរមើល សេចក្ដីព្យាយាម និងការប្រឹងប្រែងរបស់ខ្ញុំនោះយ៉ាងនេះ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ ពុទ្ធសាសនា ខ្ញុំបានធ្វើហើយ ។ ខ្ញុំដឹងនូវបុព្វេនិវាស ទិព្វចក្ខុ ខ្ញុំក៏បានជម្រះហើយ ខ្ញុំជាព្រះអរហន្ត គួរទទួលនូវទក្ខិណាទាន មានចិត្តរួចស្រឡះហើយ មិនមានឧបធិ ។ លំដាប់នោះ ក្នុងកាលរាត្រីអស់ទៅ ព្រះអាទិត្យក៏រះឡើង ខ្ញុំបានធ្វើតណ្ហាទាំងអស់ ឲ្យរីងស្ងួត ហើយអង្គុយដោយភ្នែន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យទា** ប្រែថា ក្នុងកាលណា ។ បទថា **បឋមំ** បានដល់ តាំងពីដំបូង ។ បទថា **អទ្ទក្ខឹ** ប្រែថា បានឃើញហើយ ។ បទថា **សត្ថារំ** បានដល់ ព្រះមានព្រះភាគ ។

បទថា **អកុតោភយំ** បានដល់ មិនមានភ័យ ។ អត្ថក្នុងសេចក្ដីនោះ មានដូចតទៅនេះ ក្នុងពេលដែលខ្ញុំទៅព្រមជាមួយជីតារបស់ខ្ញុំ បានឃើញព្រះសម្មាសម្ពុទ្ធគ្រាដំបូង ព្រះអង្គឈ្មោះថា **សត្ថា** ព្រោះទ្រង់ប្រៀនប្រដៅវេនេយ្យសត្វដោយទិដ្ឋធម្មិកត្ថប្រយោជន៍ សម្បរាយិកត្ថប្រយោជន៍ និងបរ-មត្ថប្រយោជន៍តាមសមគួរ ឈ្មោះថា **អកុតោភយំ** គឺជាអ្នកមិនមានភ័យ ព្រោះមិនមានភ័យអំពីទីណាមួយ ព្រោះហេតុនៃភ័យទាំងអស់ ទ្រង់លះបានហើយត្រង់មណ្ឌលពោធិព្រឹក្សនោះឯង ជាអ្នកមានសេចក្ដីក្លៀវក្លាដោយចតុ-វេសារជ្ជញ្ញាណ ព្រោះបានឃើញព្រះសាស្ដានោះ ដែលជាឧត្តមបុរស គឺជា

បុគ្គលដ៏កំពូលក្នុងលោក ព្រមទាំងទេវលោក ព្រោះហេតុនៃការឃើញនោះ គឺខាងក្រោយអំពីការឃើញនោះ ទើបការសង្វេគកើតមានដល់ខ្ញុំថា អស់កាលមានប្រមាណប៉ុណ្ណេះ អាត្មាអញមិនបានឱកាសឃើញព្រះសាស្តា និងបានស្តាប់ធម៌ឡើយ គឺមានញាណ ព្រមដោយឱត្តប្បៈកើតឡើងហើយ ។ ព្រោះខ្ញុំមានសេចក្តីសង្វេគកើតឡើងហើយ ទើបគិតយ៉ាងនេះ ព្រោះហេតុនោះ ទើបព្រះថេរៈសម្តែងដោយគាថាថា **សិរឹ ហត្ថេហិ** ដូច្នេះជាដើម ។

អត្ថនៃបាទគាថានោះ មានដូច្នេះ បុគ្គលណា គឺបុរសដែលត្រូវការដោយសម្បត្តិ គិតថា អញនឹងជាឧបដ្ឋាកក្នុងសម្នាក់លោកអ្នកមានសិរី ដូច្នេះហើយ ទើបច្របាច់ និងជាន់ បុគ្គលអ្នកមានសិរីសព្វរាងកាយលើដំណេកដោយដៃ និងជើង និងរង់ចាំបម្រើ បុរសអកព្វនោះ គឺបែបនោះ គប្បីញ៉ាំងព្រះសាស្តាដ៏ជាព្រះសម្មាសម្ពុទ្ធដែលមានសិរីនោះ ឲ្យទ្រង់ត្រេកអរ ហើយបាននូវសេចក្តីសង្វេគ ក្នុងខណៈទី ៩ នេះ ព្រោះបុគ្គលនោះ មិនធ្វើតាមឱវាទ អធិប្បាយថា ចំណែកខ្ញុំមិនធ្វើយ៉ាងនោះឡើយ ដោយហេតុនោះ ទើបព្រះថេរៈពោលថា **តថាហំ ។បេ។ អឆការិយំ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **ឆឌ្ឌយឹ** បានដល់ ខ្ញុំលះហើយ ។ បាលីថា **ឆឌ្ឌិយំ** ដូច្នេះក៏មាន ។ សួរថា ព្រះថេរៈមិនធ្លាប់មានកិរិយា មកបួសតាំងពីក្មេងមិនមែនឬ ព្រោះហេតុអ្វី ទើបពោលថា ខ្ញុំលះបុត្ត និងកិរិយា ឆ្លើយថា ប្រៀបដូចបុរសកាត់ដើមឈើដែលមិនទាន់មានផ្លែ កាលកាប់ហើយ តែងឈ្មោះថា វិនាសចាកផ្លែដែលបានហើយអំពីដើមឈើនោះ យ៉ាងណា ឧបមា

ដូចគ្រឿងឧបមេយ្យឲ្យដល់ព្រមនេះ បណ្ឌិតគប្បីជ្រាបដូច្នោះ ។

បទថា **សិក្ខាសាជីវសមាបន្នោ** សេចក្តីថា ប្រកបដោយអធិសីល សិក្ខា និងដោយសាជីវៈ គឺសិក្ខាបទ ដែលព្រះមានព្រះភាគទ្រង់បានបញ្ញត្តិ ដែលជាទីធ្វើឲ្យភិក្ខុទាំងឡាយ នៅរួមគ្នា មានជីវិតតែមួយដូចគ្នា មានការប្រព្រឹត្តស្មើគ្នា ធ្វើសិក្ខាឲ្យបរិបូណ៌ និងមិនកន្លងសាជីវៈ ឈ្មោះថា ជាអ្នកធ្វើសិក្ខា និងសាជីវៈទាំងពួងនោះឲ្យដល់ព្រម ។ ដោយហេតុនោះ ទើបព្រះថេរៈសម្តែងឲ្យជ្រាបថា លោកតាំងមាំក្នុងសីល គឺបាតិមោក្ខ ដែលបរិសុទ្ធដោយល្អ ។

បទថា **ឥន្ទ្រិយេសុ សុសំវុតោ** សេចក្តីថា ជាអ្នកសង្រួមហើយដោយល្អក្នុងឥន្ទ្រិយទាំងឡាយ ដែលមានចិត្តជាគម្រប់ ៦ គឺមានចក្ខុទ្វារជាដើម ដែលបិទល្អហើយ ដោយសន្ទុះទ្វារ គឺសតិ ដោយអំណាចការហាមការប្រព្រឹត្តទៅនៃកិលេស មានអភិជ្ឈាជាដើម ដែលកើតក្នុងអារម្មណ៍ មានរូបារម្មណ៍ជាដើម ។

ដោយអាការយ៉ាងនេះ កាលពោលដោយអត្ថ សីលដែលក្រៅអំពីនេះ ក៏ឈ្មោះថា ព្រះថេរៈបានសម្តែងហើយនោះឯង ដោយការសម្តែងនូវការដល់ព្រមនៃសីល គឺបាតិមោក្ខសំវរៈ និងឥន្ទ្រិយសំវរៈ ព្រោះហេតុនោះ ព្រះថេរៈ កាលសម្តែងនូវការដល់ព្រមនៃចតុប្បារិសុទ្ធិសីលរបស់ខ្លួនហើយ ទើបពោលដល់ការប្រកបភាវនាក្នុងពុទ្ធានុស្សតិ និងដោយពាក្យជាដើមថា **ឆមស្សមានោ សត្ថុនំ** នេះ ។

បទថា **វិហាសឹ អបរាជិតោ** សេចក្ដីថា ខ្ញុំជាអ្នកមិនចាញ់ចំពោះមារ មានកិលេសមារជាដើម ហើយតាំងនៅ គឺមិនត្រូវមារ មានកិលេសមារជាដើម នោះគ្របសង្កត់បាន រហូតបានសម្រេចដល់អរហត្ត បានដល់ ដោយពិត ខ្ញុំគ្របសង្កត់កិលេសមារទាំងនោះឯងជាដើម ។

បទថា **តតោ** សេចក្ដីថា ព្រោះជាអ្នកមានសីលបរិសុទ្ធដោយល្អ ជ្រះថ្លាក្រៃលែងក្នុងព្រះសាស្ដា តាំងនៅក្នុងបដិបទា ដើម្បីគ្របសង្កត់កិលេស ។

បទថា **បណិធី** បានដល់ បណិធាន គឺការតាំងចិត្តមាំ ឬអភិនីហារនៃចិត្ត ( ដែលកើត ) អំពីបណិធាននោះ ។

បទថា **អាសិ** គឺ **អហោសិ** ប្រែថា មានហើយ ។

បទថា **ចេតសោ អភិបត្ថិតោ** បានដល់ ដែលចិត្តរបស់ខ្ញុំប្រាថ្នា ។ ដើម្បីចៀសវាងនូវពាក្យសួរថា ការប្រាថ្នានេះដូចម្ដេច ទើបលោកពោលថា កាលបើខ្ញុំមិនទាន់ដកសរ គឺតណ្ហាបានទេ ខ្ញុំមិនអង្គុយសូម្បីមួយរំពេច អធិប្បាយថា ការប្រាថ្នាដែលតាំងចិត្តពិតមានដល់ខ្ញុំយ៉ាងនេះថា ខ្ញុំមិនអង្គុយ គឺមិនសម្រេចការអង្គុយទទេ សូម្បីត្រឹមមួយខណៈ ក្នុងកាលមិនទាន់ដកនូវព្រួញ គឺតណ្ហាបានអំពីហទយៈរបស់ខ្ញុំ ដោយសណ្ឋាស គឺអរហត្តមគ្គ ។

កាលអធិដ្ឋានចិត្តយ៉ាងនេះហើយ ចម្រើនវិបស្សនា ឲ្យរាត្រីកន្លងទៅ ដោយការឈរ និងការចង្ក្រមប៉ុណ្ណោះ ចេញអំពីរូបសមាបត្តិហើយ ផ្ដើមចម្រើនវិបស្សនា ដោយមានអង្គឈានជាប្រធាន ធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ។

ដោយហេតុនោះ ទើបលោកពោលថា **តស្ស មេ** ដូច្នេះជាដើម ។ បទថា **និរុបធិ** បានដល់ មិនមានឧបធិ ព្រោះមិនមានឧបក្កិលេសជាដើម ។

បទថា **រត្យា វិវសានេ** បានដល់ ក្នុងចំណែកនៃរាត្រីអស់ទៅហើយ គឺក្នុងកាលរាត្រីអស់ទៅហើយ ។

បទថា **សុរិយុគ្គមនំ បតិ** បានដល់ កំណត់យកព្រះអាទិត្យជាគោល ។

បទថា **សព្វំ តណ្ហំ** បានដល់ ធ្វើក្រសែនៃតណ្ហាទាំងអស់ ដូចជាកាមតណ្ហាជាដើមឲ្យក្រៀមស្វិត គឺឲ្យហួតហែងទៅដោយអរហត្តមគ្គបាន ដើម្បីដោះខ្លួនអំពីពាក្យប្រេជ្ញាថា ខ្ញុំមិនបានអង្គុយទេ កាលមិនទាន់ដកព្រួញគឺតណ្ហាបាន ។

បទថា **បល្លង្កេន ឧបាវិសឹ** សេចក្តីថា ខ្ញុំអង្គុយពត់ភ្នែន ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ៕

**អដ្ឋកថាមហាបន្ថកត្ថេរគាថា ចប់**

**ថេរគាថា អដ្ឋកនិបាត ចប់**

# សុត្តន្តបិដក

# ថេរគាថា នវកនិបាត

## ភូតត្ថេរគាថា

[ ២៣៣ ] ពួកបុថុជ្ជន មិនដឹងថា ជរាមរណៈជាទុក្ខ ហើយជាប់ចំពាក់ក្នុងឧបាទានក្ខន្ធណា អ្នកប្រាជ្ញមានស្មារតី បានកំណត់ដឹង ( នូវឧបាទានក្ខន្ធនោះ ) ថាជាទុក្ខ ហើយចម្រើនឈានក្នុងកាលណា កាលនោះ រមែងមិនបាននូវសេចក្តីត្រេកអរលើសលុប ជាងឈាននោះឡើយ ។ បណ្ឌិតលុះលះបង់នូវតណ្ហា ដែលនាំមកនូវសេចក្តីទុក្ខ ជាធម្មជាតផ្សាយទៅក្នុងអារម្មណ៍ផ្សេងៗ នាំមកនូវកិលេសជាគ្រឿងនាំសត្វឲ្យយឺតយូរ និងសេចក្តីទុក្ខដូចជាឃ្នាប មានស្មារតីចម្រើនឈាន ក្នុងកាលណា កាលនោះ រមែងមិនបាននូវសេចក្តីត្រេកអរដ៏លើសលុបជាងឈាននោះឡើយ ។ បុគ្គលពាល់ត្រូវមគ្គដ៏ឧត្តមប្រកបដោយអង្គ ៨ ពីរជងដ៏ក្សេម ជាគ្រឿងជម្រះនូវកិលេសទាំងអស់ ដោយបញ្ញា ជាអ្នកមានស្មារតី ចម្រើនឈាន ក្នុងកាលណា កាលនោះ រមែងមិនបាននូវសេចក្តីត្រេកអរ ដ៏ក្រៃលែងជាងឈាននោះឡើយ ។ បុគ្គលចម្រើននូវសន្តិបទ ដែលឥតមានសោកប្រាសចាកធូលី គឺកិលេស ឥតមានបច្ច័យតាក់តែង ជាគ្រឿងជម្រះ

នូវកិលេសទាំងអស់ ផ្តាច់នូវចំណង គឺសញ្ញោជនៈ ក្នុងកាលណា កាលនោះ រមែងមិនបាននូវសេចក្តីត្រេកអរ ដ៏ក្រៃលែង ជាងការចម្រើននូវសន្តិបទនោះឡើយ ។ ផ្គរលាន់ក្នុងអាកាស ទឹកភ្លៀងពាសពេញ ដោយជុំវិញ ពួដ៏អាកាសក្នុងកាលណា កាលនោះ ភិក្ខុចូលទៅនៅក្នុងញកភ្នំ ចម្រើនឈាន រមែងមិនបាននូវសេចក្តីត្រេកអរជាងឈាននោះឡើយ ។ ភិក្ខុអង្គុយក្បែរឆ្នេរស្ទឹងទាំងឡាយ ដ៏ដេរដាសដោយផ្កា មានផ្កាឈើក្នុងព្រៃដ៏វិចិត្រជាគ្រឿងប្រដាប់ មានចិត្តល្អ ចម្រើនឈាន ក្នុងកាលណា កាលនោះ រមែងមិនបាននូវសេចក្តីត្រេកអរ ដ៏លើសលុប ជាងឈាននោះឡើយ ។ កាលបើភ្លៀងធ្លាក់ចុះ ក្នុងព្រៃស្ងាត់ ពេលយប់ ពួកសត្វមានចង្កូមបន្លឺឡើង ចំណែកភិក្ខុចូលទៅកាន់ញកភ្នំ ហើយចម្រើនឈាន ក្នុងកាលណា កាលនោះ រមែងមិនបាននូវសេចក្តីត្រេកអរ ដ៏លើសលុប ជាងឈាននោះឡើយ ។ ភិក្ខុអាស្រ័យនូវចន្លោះភ្នំ ក្នុងកណ្តាលនៃភ្នំ បិទនូវវិតក្កទាំងឡាយរបស់ខ្លួន ប្រាសចាកសេចក្តីខ្វល់ ប្រាសចាកសេចក្តីរឹងត្អឹងនៃចិត្ត ហើយចម្រើនឈាន ក្នុងកាលណា កាលនោះ រមែងមិនបាននូវសេចក្តីត្រេកអរ ដ៏លើសលុប ជាងឈាននោះឡើយ ។ ( ភិក្ខុ ) ជាអ្នកមានសេចក្តីសុខ ជាអ្នកធ្វើសេចក្តីរឹងត្អឹងជាមន្ទិល និងសេចក្តីសោកឲ្យវិនាស ជាអ្នកគ្មានសន្ទះទ្វារ គឺអវិជ្ជា គ្មានតណ្ហា ប្រាសចាកសរ

គឺរាគាទិក្កិលេស ធ្វើនូវអាសវៈទាំងអស់ ឲ្យវិនាស ចម្រើនឈាន ក្នុងកាលណា កាលនោះ រមែងមិនបាននូវសេចក្តីត្រេកអរ ដ៏លើសលុប ជាងឈាននោះឡើយ ។

**ភូតត្ថេរ**

---

**ឧទ្ទាន**

ព្រះភូតត្ថេរ តែមួយអង្គឯង ដូចជាកុយរមាស ជាអ្នកឃើញពិត បានសម្តែង ៩ គាថា ដែលមក ក្នុងនវកនិបាត ។

**នវកនិបាត ចប់**

---

# អដ្ឋកថា
# ថេរគាថា នវកនិបាត

## ភូតត្ថេរគាថា

[ ២៣៣ ] ក្នុងនវកនិបាត គាថារបស់ព្រះភូតត្ថេរ មានពាក្យផ្ដើមថា **យទា ទុក្ខំ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងសាសនានៃព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថ កើតក្នុងត្រកូលព្រាហ្មណ៍ បានឈ្មោះថា **សេនកៈ** ជាអ្នកដឹងក្ដីហើយ ថ្ងៃមួយ ជួបព្រះសាស្ដា មានចិត្តជ្រះថ្លា ទើបសរសើរ ៤ គាថា មានន័យជាដើមថា **ឧសភំ បវរំ** ដូច្នេះ ។

ដោយបុញ្ញកម្មនោះ ទើបកុលបុត្តអន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតជាកូនប្រុសរបស់សេដ្ឋីដែលមានទ្រព្យសម្បត្តិច្រើន ក្បែរទ្វារនគរសាកេត បានឮថា សេដ្ឋីនោះមានទារកកើតហើយច្រើននាក់ តែត្រូវយក្ខមួយរូបចាប់ទំពាស៊ី ព្រោះការចងពៀរ តែសម្រាប់កុមារនេះ ពួកភូតនាំគ្នាការពារ ព្រោះកុមារនេះជាអ្នកកើតក្នុងភពចុងក្រោយ ។

ឯយក្ខទៅកាន់ទីបម្រើស្ដេចវេស្សវ័ណហើយ មិនបានមកវិញឡើយ ក្នុងថ្ងៃដាក់ឈ្មោះ ពួកញាតិទាំងឡាយបាននាំគ្នាដាក់ឈ្មោះទារកនេះថា **ភូត** ព្រោះ

គិតថា កាលដាក់ឈ្មោះយ៉ាងនេះហើយ ពួកអមនុស្សនឹងអនុគ្រោះបរិហារគ្រប់គ្រង ។ ដោយផលបុណ្យរបស់ខ្លួនឯង ទើបទារកនោះមិនមានអន្តរាយចម្រើនវ័យហើយ ។ ពាក្យថា ប្រាសាទ ៣ ខ្នង មានហើយដល់កុលបុត្តនោះ ដូចគ្នានឹងសម្បត្តិរបស់យសកុលបុត្តដែលពោលហើយ ។

ទារកនោះដឹងក្តីហើយ កាលព្រះសាស្តាគង់នៅក្នុងនគរសាកេត ចូលទៅកាន់វិហារ មួយអន្លើដោយឧបាសកទាំងឡាយ ស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្តា បាននូវសទ្ធា បួសហើយក្នុងគុហា ជិតស្ទឹងឈ្មោះអជករណី ចម្រើនវិបស្សនា មិនយូរក៏សម្រេចអរហត្ត សមដូចគាថាព័ន្ធដែលលោកពោលក្នុងអបទានថា

បុគ្គលណា ឃើញព្រះសម្ពុទ្ធ មានសម្បុរដូចមាស ជាឧសភបុរស ជាវីរបុរសប្រសើរ ទ្រង់ស្វែងរកនូវគុណធម៌ដ៏ធំ មានជ័យជម្នះហើយ នឹងខានជ្រះថ្លាម្តេចបាន ។ ភ្នំហិមពាន្តមានប្រមាណមិនបាន និងសមុទ្រសាគរ គេឆ្លងបានដោយក្រ យ៉ាងណាមិញ ឈានរបស់ព្រះពុទ្ធ ក៏យ៉ាងនោះដែរ បុគ្គលឃើញហើយ នឹងខានជ្រះថ្លាម្តេចបាន ។ ផែនដីមានប្រមាណមិនបាន របៀបផ្កាឈើក្នុងព្រៃដ៏ត្រកាល យ៉ាងណាមិញ សីលរបស់ព្រះពុទ្ធ ក៏យ៉ាងនោះដែរ បុគ្គលណាឃើញហើយ នឹងខានជ្រះថ្លាម្តេចបាន ។ អាកាសមិនញាប់ញ័រដោយផ្លូវខ្យល់ បុគ្គលរាប់មិនបាន យ៉ាងណាមិញ

ញាណរបស់ព្រះពុទ្ធ ក៏យ៉ាងនោះដែរ បុគ្គលណាឃើញ
ហើយ នឹងខានជ្រះថ្លាម្ដេចបាន ។ ព្រាហ្មណ៍ឈ្មោះសោនៈ
សរសើរ នូវព្រះសិទ្ធត្ថៈ ជាព្រះពុទ្ធប្រសើរ ព្រះអង្គឈ្នះ
កិលេសមារ ដោយគាថាទាំង ៤ នេះហើយ មិនទៅកាន់
ទុគ្គតិអស់ ៩៤ កប្ប ។

ខ្ញុំបានទទួលសម្បត្តិដ៏ល្អ ក្នុងសុគតិទាំងឡាយ មិនមែន
តិចឡើយ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ខ្ញុំសរសើរព្រះ
សម្ពុទ្ធ ជានាយកនៃសត្វលោក ហើយមិនស្គាល់នូវទុគ្គតិ
នេះជាផលនៃការសរសើរព្រះពុទ្ធ ។ ក្នុងកប្បទី ១៤ ខ្ញុំបាន
ជាស្ដេចចក្រពត្តិ ៤ ជង ព្រះនាមឧគ្គតៈដូចគ្នា ទ្រង់បរិបូរ
ដោយរតនៈ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤
វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ
ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ(១) ។

ព្រះថេរៈកាលសម្រេចអរហត្តហើយ សម័យតមក កាលធ្វើអនុគ្រោះ
ពួកញាតិ ទើបទៅកាន់នគរសាកេត បានទទួលការទំនុកបម្រុងអំពីពួកញាតិ
២-៣ ថ្ងៃ ក៏ទៅកាន់ព្រៃអញ្ជន មានបំណងទៅកាន់ទីដែលខ្លួនធ្លាប់នៅហើយ
នោះឯងវិញ ទើបសម្ដែងអាការនឹងទៅ ។ ពួកញាតិក៏នាំគ្នាអង្វរព្រះថេរៈថា
សូមនិមន្តនៅក្នុងទីនេះឯង លោកម្ចាស់នឹងមិនលំបាក ពួកខ្ញុំនឹងបានបម្រើន

១- ក្នុងអបទានជា បរប្បសាទកត្ថេរ ។

ដោយបុណ្យ ។

ព្រះថេរៈកាលប្រកាសការត្រេកអរក្រៃលែងក្នុងការស្ងាត់ និងភាពជាផាសុកក្នុងព្រៃនោះរបស់ខ្លួន ទើបពោលគាថាទាំងឡាយថា

ពួកបុថុជ្ជន មិនដឹងថា ជរាមរណៈជាទុក្ខ ហើយជាប់ចំពាក់ ក្នុងឧបាទានក្ខន្ធណា អ្នកប្រាជ្ញមានស្មារតី បានកំណត់ដឹង ( នូវឧបាទានក្ខន្ធនោះ ) ថាជាទុក្ខ ហើយចម្រើនឈាន ក្នុងកាលណា កាលនោះ រមែងមិនបាននូវសេចក្តីត្រេកអរលើសលុប ជាងឈាននោះឡើយ ។ បណ្ឌិតលុះលះបង់នូវតណ្ហា ដែលនាំមកនូវសេចក្តីទុក្ខ ជាធម្មជាតផ្សាយទៅក្នុងអារម្មណ៍ផ្សេងៗ នាំមកនូវកិលេសជាគ្រឿងនាំសត្វឲ្យយឺតយូរ និងសេចក្តីទុក្ខ ដូចជាឃ្នាប មានស្មារតី ចម្រើនឈាន ក្នុងកាលណា កាលនោះ រមែងមិនបាននូវសេចក្តីត្រេកអរ ដ៏លើសលុបជាងឈាននោះឡើយ ។ បុគ្គលពាល់ត្រូវមគ្គដ៏ឧត្តមប្រកបដោយអង្គ ៨ ពីរជងដ៏ក្សេម ជាគ្រឿងជម្រះនូវកិលេសទាំងអស់ដោយបញ្ញា ជាអ្នកមានស្មារតី ចម្រើនឈានក្នុងកាលណា កាលនោះ រមែងមិនបាននូវសេចក្តីត្រេកអរដ៏ក្រៃលែងជាងឈាននោះឡើយ ។ បុគ្គលចម្រើននូវសន្តិបទដែលឥតមានសោក ប្រាសចាកធូលី គឺកិលេស ឥតមានបច្ច័យតាក់តែង ជាគ្រឿងជម្រះនូវកិលេសទាំងអស់ ផ្តាច់នូវចំណង គឺសញ្ញោជនៈ ក្នុងកាលណា កាលនោះ រមែងមិនបាននូវសេចក្តី

ត្រេកអរដ៏ក្រៃលែង ជាងការចម្រើននូវសន្តិបទនោះឡើយ ។ ផ្គរលាន់ក្នុងអាកាស ទទឹកភ្លៀង ពាសពេញ ដោយជុំវិញ ពួដ៏អាកាស ក្នុងកាលណា កាលនោះ ភិក្ខុចូលទៅនៅក្នុងញកភ្នំចម្រើនឈាន រមែងមិនបាននូវសេចក្តីត្រេកអរ ជាងឈាននោះឡើយ ។ ភិក្ខុអង្គុយក្បែរឆ្នេរស្ទឹងទាំងឡាយ ដ៏ដេរដាសដោយផ្កាមានផ្កាឈើក្នុងព្រៃដ៏វិចិត្រជាគ្រឿងប្រដាប់ មានចិត្តល្អ ចម្រើនឈាន ក្នុងកាលណា កាលនោះ រមែងមិនបាននូវសេចក្តីត្រេកអរដ៏លើសលុបជាងឈាននោះឡើយ ។ កាលបើភ្លៀងធ្លាក់ចុះក្នុងព្រៃស្ងាត់ ពេលយប់ ពួកសត្វមានចង្កូមបន្លឺឡើង ចំណែកភិក្ខុចូលទៅកាន់ញកភ្នំ ហើយចម្រើនឈាន ក្នុងកាលណា កាលនោះ រមែងមិនបាននូវសេចក្តីត្រេកអរ ដ៏លើសលុបជាងឈាននោះឡើយ ។ ភិក្ខុអាស្រ័យនូវចន្លោះភ្នំ ក្នុងកណ្តាលនៃភ្នំ បិទនូវវិតក្កទាំងឡាយរបស់ខ្លួន ប្រាសចាកសេចក្តីខ្វល់ ប្រាសចាកសេចក្តីរឹងត្អឹងនៃចិត្ត ហើយចម្រើនឈាន ក្នុងកាលណា កាលនោះ រមែងមិនបាននូវសេចក្តីត្រេកអរ ដ៏លើសលុប ជាងឈាននោះឡើយ ។ ( ភិក្ខុ ) ជាអ្នកមានសេចក្តីសុខ ជាអ្នកធ្វើសេចក្តីរឹងត្អឹងជាមន្ទិល និងសេចក្តីសោកឲ្យវិនាស ជាអ្នកគ្មានសន្ទះទ្វារគឺអវិជ្ជា គ្មានតណ្ហា ប្រាសចាកសរ គឺរាគាទិក្កិលេស ធ្វើនូវអាសវៈទាំងអស់ ឲ្យវិនាស ចម្រើនឈាន ក្នុងកាលណា កាល

នោះ រមែងមិនបាននូវសេចក្តីត្រេកអរ ដ៏លើសលុប ជាងឈាន
នោះឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បណ្ឌិតគប្បីជ្រាបពាក្យអធិប្បាយរបស់គាថាដំបូង ដោយការអធិប្បាយសព្វដូចតទៅ ការចាស់ដោយជុំវិញនៃខន្ធទាំងឡាយ ឈ្មោះថា **ជរា** ។ ការបែកធ្លាយនៃខន្ធទាំងឡាយ ឈ្មោះថា **មរណៈ** ។ ក្នុងទីនេះ វត្ថុទាំងពួងដែលមានការចាស់ និងការស្លាប់ លោកសង្គ្រោះចូលក្នុងមាតិកាថា **ជរា** និង **មរណៈ** ។

បុថុជ្ជនទាំងឡាយដែលមិនដឹងច្បាស់ មិនដឹងតាមសេចក្តីពិតថា ការចាស់ និងកាស្លាប់នេះ ជាទុក្ខ ដូច្នេះហើយ លិចចុះ គឺពាក់ព័ន្ធ ចាក់ស្រេះក្នុងជរា និងមរណៈណា គឺក្នុងឧបាទានក្ខន្ធ ៥ ណា ភិក្ខុមានសតិ មានសម្បជញ្ញៈ ជាបណ្ឌិតក្នុងសាសនានេះ កំណត់ដឹងទុក្ខនោះ ដោយមគ្គប្បញ្ញាដែលសម្បយុត្តដោយវិបស្សនាបញ្ញាថា វត្ថុនេះជាទុក្ខ ទុក្ខមានប្រមាណប៉ុណ្ណេះ មិនមានទុក្ខដទៃក្រៅលែងជាងនេះ ដូច្នេះហើយ សម្លឹងពិនិត្យដោយលក្ខណូ-បនិជ្ឈាន កាលណា គឺក្នុងកាលណា ក្នុងកាលនោះ រមែងមិនជួប គឺមិនបាននូវការត្រេកអរក្រៅលែងជាង គឺឧត្តមជាងការត្រេកអរក្នុងវិបស្សនា និងការត្រេកអរក្នុងមគ្គ និងផលនោះ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ ( ក្នុងធម្មបទ ) ថា

ភិក្ខុពិចារណាការកើតឡើង និងការវិនាសខន្ធទាំងឡាយ ក្នុង
កាលណា ក្នុងកាលនោះ ភិក្ខុនោះ រមែងបាននូវបីតិ និងបាមោជ្ជ

បីតិ និងបាមោជ្ជនោះ ឈ្មោះថា ជាអតមធម៌របស់បណ្ឌិតអ្នកដឹង
នូវធម៌ទាំងឡាយ ដូច្នេះ ។

សោតាបត្តិផល ជាគុណជាតដ៏ប្រសើរ ជាងភាពនៃឯករាជ្យលើ
ផែនដីផង ជាងដំណើរទៅកាន់ឋានសួគ៌ផង ជាងភាពជាធំក្នុង
លោកទាំងមូលផង ដូច្នេះ ។

ព្រះថេរៈកាលសម្តែងដល់ការត្រេកអរក្នុងទីស្ងាត់ ដោយបំណងពោល
ដល់ការត្រាស់ដឹងដោយបរិញ្ញាកិច្ចយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីសម្តែង
ដល់សេចក្តីនោះ ដោយបំណងពោលដល់ការត្រាស់ដឹងដោយបហានកិច្ច
ជាដើម ទើបពោល ៣ គាថា បន្ថែមបន្ទាប់អំពីគាថាទី ២ ។

បណ្តាបទទាំងនោះ បទថា **ទុក្ខស្សាវហានិ** បានដល់ ប្រព្រឹត្តទៅដើម្បី
សេចក្តីទុក្ខខាងមុខ អធិប្បាយថា ឲ្យផលជាទុក្ខ ។

បទថា **វិសត្តិកំ** គឺតណ្ហា ។ តណ្ហានោះ លោកហៅថា **វិសត្តិកា**
ព្រោះអត្ថថា ផ្សាយទៅ ព្រោះអត្ថថា ទូលំទូលាយ ព្រោះអត្ថថា ហូរទូទៅ
ព្រោះអត្ថថា មិនអាចហាម ព្រោះអត្ថថា នាំទៅកាន់វត្ថុមានពិស ព្រោះអត្ថ
ថា បោកបញ្ឆោត ព្រោះអត្ថថា មានឫសគល់ជាពិស ព្រោះអត្ថថា មានផ្លែ
ជាពិស ព្រោះអត្ថថា មានការបរិភោគជាពិស ។ម្យ៉ាងទៀត តណ្ហានោះ
ដែលធំទូលាយ លោកហៅថា **វិសត្តិកា** ព្រោះអត្ថថា ផ្សាយទៅក្នុងរូប
សំឡេង ក្លិន រស ផោដ្ឋព្វៈ ធម្មារម្មណ៍ ត្រកូល និងពួកគណៈ ។

បទថា **បបញ្ចសង្ឃាតទុខាធិវាហានិ** សេចក្តីថា ឈ្មោះថា **បបញ្ច**

ព្រោះអត្ថថា ធ្វើនូវការបន្តនៃសត្វក្នុងសង្សារឲ្យយូរ គឺឲ្យវែងឆ្ងាយ បានដល់ រាគៈជាដើម និងបានដល់មានៈជាដើម ។ បបញ្ចធម៌ទាំងឡាយនោះ ឈ្មោះថា **សង្ឃាត** ព្រោះអត្ថថា រួបរួមទុក្ខដែលកើតឡើង និងឈ្មោះថា **បបញ្ច-សង្ឃាតទុក្ខ** ព្រោះជាទុក្ខមានសភាវៈក្រវល់ក្រវាយ និងក្តៅក្រហាយ ទើបឈ្មោះថា **បបញ្ចសង្ឃាតទុខាធិវាហិនី** ព្រោះនាំមកចំពោះ គឺព្រោះកើតសេចក្តីទុក្ខ ដែលរួបរួមនូវធម៌ជាគ្រឿងយឺតយូរនោះ ។ បទថា **តណ្ហំ បហន្ត្វាន** បានដល់ កាត់បានជាសមុច្ឆេទនូវតណ្ហានោះដោយអរិយមគ្គ ។

បទថា **សិវំ** បានដល់ ផ្សេង អធិប្បាយថា ដោយការកាត់ផ្តាច់នូវកិលេសទាំងឡាយ ដែលធ្វើនូវការមិនទូលាយឲ្យបណ្ឌិតទាំងនោះ ទើបមិនក្តៅក្រហាយ ។

ផ្លូវប្រកបដោយអង្គ ៨ ដោយអំណាចនៃសម្មាទិដ្ឋិជាដើម ឈ្មោះថា **ទេ្វចតុរង្គគាមិនំ** ព្រោះអត្ថថា ឲ្យព្រះអរិយៈទាំងឡាយដល់នូវព្រះនិព្វាន ក្នុងគាថានេះ គប្បីឃើញថា លោកមិនធ្វើការលុបវិភត្តិ ក៏ដើម្បីងាយស្រួលដល់ការចងគាថា ។

ឈ្មោះថា **មគ្គុត្តមំ** ព្រោះជាផ្លូវឧត្តម ក្នុងបណ្តាផ្លូវទាំងអស់ មានផ្លូវដែលធ្វើឲ្យកើតរូបជាដើម ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា មគ្គមានអង្គ ៨ ប្រសើរជាងផ្លូវទាំងឡាយជាដើម ។ ឈ្មោះថា **សព្វ-កិលេសសោធនំ** ព្រោះជម្រះសត្វទាំងឡាយឲ្យស្អាតចាកមន្ទិល គឺកិលេសទាំងពួង ។

បទថា **បញ្ញាយ បស្សិត្វា** បានដល់ ចូលដល់ហើយ ដោយអំណាចការដឹងចំពោះភាវនា ដោយបដិវេធប្បញ្ញា ។

ឈ្មោះថា **អសោកំ** ព្រោះសេចក្ដីសោកក្នុងទីនេះមិនមាន ព្រោះមិនមានហេតុនៃសេចក្ដីសោក និងព្រោះមិនមានហេតុដែលធ្វើឲ្យបុគ្គលសោយសោក ។

ឈ្មោះថា **វិរជំ** ព្រោះធូលី មានរាគៈជាដើមទៅប្រាសហើយ ។ ឈ្មោះថា **អសង្ខតំ** ព្រោះបច្ច័យណាមួយតាក់តែងមិនបាន ។

ឈ្មោះថា **សន្តំ បទំ** ព្រោះស្ងប់រម្ងាប់កិលេសទាំងពួង និងទុក្ខទាំងពួងបាន និងព្រោះវៀរផុតចាកការបៀតបៀនក្នុងសង្សារទុក្ខ ។

ឈ្មោះថា **សព្វកិលេសោធនំ** ព្រោះមានការជម្រះសន្តានរបស់សត្វឲ្យស្អាតចាកមន្ទិល គឺកិលេសទាំងពួង ។

បទថា **ភាវេតិ** សេចក្ដីថា រមែងសម្រេចដោយអំណាចសច្ឆិកិរិយាភិសម័យ ( ការត្រាស់ដឹងដោយការធ្វើឲ្យជាក់ច្បាស់ ) ។ ពិតហើយ ព្រះថេរៈពោលយ៉ាងនេះ ដោយលើកឡើងនូវអារម្មណ៍ ដែលគប្បីទាញយកមកឲ្យ ជាគុណវិសេសដែលបាននៃព្រះយោគាវចរប្រាថ្នានូវព្រះនិព្វានច្រើនដង ញ៉ាំងការត្រាស់ដឹងដោយការធ្វើឲ្យជាក់ច្បាស់ ឲ្យប្រព្រឹត្តទៅ ។ ឈ្មោះថា **សញ្ញោជនពន្ធនច្ឆិទំ** ព្រោះកាត់នូវគ្រឿងចងទាំងឡាយ គឺសំយោជនៈបាន ។

ក្នុងគាថានេះ និមិត្ត លោកប្រើដោយភាពជាអ្នកធ្វើ ដូចពាក្យថា អរិយសច្ច គឺសច្ចៈដែលធ្វើឲ្យ ( បាន ) ជាព្រះអរិយៈ ។ ក្នុងគាថានេះថា ក្នុងកាល

*ណា កាលនោះ រមែងមិនបាននូវសេចក្តីត្រេកអរ ដ៏ក្រៃលែងជាងការចម្រើននូវសន្និបទនោះឡើយ មានវាចាប្រកបសេចក្តី ដូចក្នុងគាថាមុនៗ ថា ក្នុងកាលណា កាលនោះ ភិក្ខុចូលទៅនៅក្នុងញកភ្នំ ចម្រើនឈាន រមែងមិនបាននូវសេចក្តីត្រេកអរ ជាងឈាននោះឡើយ ដូច្នោះ ។*

*ព្រះថេរៈ កាលព្យាករអរហត្តដោយមិនទាក់ទងដល់ខ្លួនឯង គាថា ៤ យ៉ាងនេះហើយ ប្រារព្ធដល់ការត្រាស់ដឹងនូវសច្ចៈ ៤ ប្រការ ឥឡូវនេះ កាលសម្តែងដល់ផាសុកនៃទីលំនៅដែលខ្លួននៅហើយថា មានការស្ងប់ស្ងាត់ ទើបពោលគាថាទាំងឡាយ មានគាថាថា* **យទា** លភេ *ដូច្នេះជាដើម ។*

*បណ្តាបទទាំងនោះ បទថា* **នភេ** *បានដល់ ក្នុងអាកាស ។ ស្គរ គឺ មេឃ ឈ្មោះថា* **មេឃទុន្ទុភិ** *ព្រោះមានសំឡេងក្រាងក្រអៅ លាន់រំពង ។*

*ឈ្មោះថា* **ធារាកុលា** *ព្រោះដេរដាសដោយធ្លារទឹកដែលហូរគ្រប់ទិស មានវាចាប្រកបសេចក្តីថា ក្នុងនភាកាសដែលឈ្មោះថា ជាផ្លូវទៅនៃហ្វូងបក្សី ព្រោះជាផ្លូវទៅនៃហ្វូងបក្សាបក្សី ។ បទថា* **តតោ** *បានដល់ ជាងការត្រេកអរក្នុងឈាន ។ បទថា* **កុសុមាកុលានំ** *បានដល់ ដេរដាសដោយផ្កាកុសុម ដែលរុះរោយហើយចាកដើម ។*

*បទថា* **វិចិត្តវានេយ្យវដំសកានំ** *សេចក្តីថា ឈ្មោះថា ផ្កាឈើក្នុងព្រៃ ព្រោះកើតក្នុងព្រៃ ឈ្មោះថា ដ៏វិចិត្រ ព្រោះមានសំណុំផ្កាដ៏វិចិត្រ អធិប្បាយថា ស្ទឹងមានសំណុំផ្កាព្រៃច្រើនប្រភេទ ឈ្មោះថា មានចិត្តល្អ ចម្រើនឈាន ព្រោះមានចិត្តស្អាត ដោយអំណាចឧត្តរិមនុស្សធម្ម ។*

បទថា **និសីថេ** ប្រែថា ក្នុងពេលរាត្រី ។ បទថា **រហិតម្ហិ** បានដល់ ក្នុងទីស្ងប់ស្ងាត់ ប្រាសចាកការរំខាននៃពួកជន ។

បទថា **ទេវេ** បានដល់ ភ្លៀង ។ បទថា **គឡន្តម្ហិ** បានដល់ មានផ្គរ ទឹកភ្លៀងដែលស្រក់ចុះ ។

បទថា **ទាឋិនោ** បានដល់ ហ្វូងសត្វដែលជាសត្រូវ មានរាជសីហ៍ និងខ្លាធំជាដើម ។ ពិតហើយ សត្វទាំងនោះ មានចង្កូមជាអាវុធ ទើបលោក ហៅថា **ទាឋិនោ** ។ ពាក្យថា **ចរន្តិ ទាឋិនោ** នេះ លោកនាំមកពោល ក៏ដើម្បីសម្តែងដល់ការស្ងាត់ចាកពួកជននោះឯង ។

បទថា **វិតក្កេ ឧបរុន្ធិយត្តនោ** សេចក្តីថា កម្ចាត់មិច្ឆាវិតក្កទាំងឡាយ មានកាមវិតក្កជាដើម ត្រង់ឈ្មោះរបស់ខ្លួន ព្រោះមានក្នុងសន្តានខ្លួន ដោយ កម្លាំងធម៌ដែលផ្ទុយគ្នា ។ ម្យ៉ាងទៀត បទថា **អត្តនោ** នេះ គប្បីប្រកប ចូលដោយបទថា **វិន្ទតិ** នេះថា កាលនោះ រមែងមិនបានជួបដោយខ្លួនឯង នូវការត្រេកអរក្រៃលែង ជាងការពិចារណាធម៌នោះ ។

បទថា **នគន្តរេ** ប្រែថា ខាងក្នុងភ្នំ ។ បទថា **នគវិវរំ** បានដល់ គុហា ខាងក្នុងភ្នំ ឬញកភ្នំ ។ បទថា **សមស្សិតោ** បានដល់ ចូលទៅដោយការ អាស្រ័យនៅ ។ បទថា **វីតទ្ទរោ** បានដល់ ប្រាសចាកកិលេសដែលជាហេតុ ឲ្យក្រវល់ក្រវាយ ។

បទថា **វីតខិលោ** បានដល់ លះកិលេសដូចជាសសរគោលចេញបាន បទថា **សុខី** បានដល់ មានសេចក្តីសុខ ដោយសុខដែលកើតអំពីឈានជា

ដើម ។ បទថា **មលខិលសោកនាសនោ** បានដល់ លះមន្ទិល មានរាគៈជាដើម លះកិលេសដូចសសរគោល ៥ ប្រការ និងលះសេចក្ដីសោក មានការព្រាត់ប្រាសចាកញាតិជាដើមជាហេតុបាន ។

បទថា **និរគ្គឡោ** អវិជ្ជា លោកហៅថា រនុកទ្វារ ព្រោះរាំងការចូលទៅជិតព្រះនិព្វាន ហៅថា **និរគ្គឡោ** ព្រោះមិនមានរនុកទ្វារ គឺអវិជ្ជានោះ ។

បទថា **និព្វនថោ** បានដល់ មិនមានតណ្ហា ។ បទថា **វិសល្លោ** បានដល់ ប្រាសចាកព្រួញ គឺកិលេស មានរាគៈជាដើម ។

បទថា **សព្វាសវេ** បានដល់ ធ្វើអាសវៈទាំងអស់ មានកាមាសវៈជាដើមឲ្យអស់ទៅ ។ បទថា **ព្យន្តិករោ** មានវាចាប្រកបសេចក្ដីថា កាលណាភិក្ខុធ្វើអាសវៈឲ្យអស់ទៅ គឺធ្វើកិលេសឲ្យប្រាសទៅដោយអរិយមគ្គ តាំងនៅសម្លឹងពិនិត្យដើម្បីការនៅជាសុខក្នុងទិដ្ឋធម៌ កាលនោះ រមែងមិនជួបនូវការត្រេកអរដទៃ ក្រៃលែងជាងការត្រេកអរក្នុងការសម្លឹងពិចារណាធម៌នោះ ។ ព្រះថេរៈកាលពោលយ៉ាងនេះហើយ ក៏បែរមុខឆ្ពោះទៅកាន់ឆ្នេរស្ទឹងអជករណីនោះឯង ។ល។

**អដ្ឋកថា ភូតត្ថេរគាថា ចប់**

**ថេរគាថា នវកនិបាត ចប់**

# សុត្តន្តបិដក

# ថេរគាថា ទសកនិបាត

## កាឡុទាយិត្ថេរគាថា

[ ២៣៤ ] បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ពួកឈើមានពណ៌ដូចរងើកភ្លើង ជិតផ្លែហើយ ជម្រុះស្លឹកចាស់ចោល ឈើទាំងនោះរុងរឿង ដូចជាអណ្តាតភ្លើង បពិត្រព្រះអង្គមានព្យាយាមធំ កាលនេះ ជាកាលគួរបានចំណែកធម្មរសហើយ ។ ឈើទាំងឡាយ ជាទីរីករាយនៃចិត្ត មានផ្លែ ផ្សាយក្លិនសព្វទិស ដោយជុំវិញ ជម្រុះស្លឹកចាស់ចោល ប្រុងនឹងចេញផ្លែថ្មីទៀត បពិត្រព្រះអង្គមានព្យាយាម កាលនេះ ជាកាលគួរដើម្បីចេញទៅអំពីទីនេះ ។ បពិត្រព្រះអង្គដ៏ចម្រើន រដូវដែលមិនត្រជាក់ពេក មិនក្តៅពេក ជាសុខស្រួល គួរដើរទៅកាន់ផ្លូវឆ្ងាយបាន ពួកសក្យៈ និងពួកកោលិយៈ សូមជួបព្រះអង្គ ដែលមានព្រះភក្ត្រ បែរត្រឡប់មកខាងក្រោយ កំពុងឆ្លងស្ទឹងរោហិណី ។

អ្នកស្រែភ្ជួរស្រែ ដោយសេចក្ដីប្រាថ្នា ព្រោះពូជ ដោយសេចក្ដីប្រាថ្នា ពួកឈ្មួញ អ្នករកទ្រព្យឆ្លងសមុទ្រ ដោយសេចក្ដីប្រាថ្នា ។ ខ្ញុំព្រះអង្គ ឋិតនៅដោយសេចក្ដីប្រាថ្នាណា សេចក្ដីប្រាថ្នារបស់ខ្ញុំព្រះអង្គនោះ សូមឲ្យសម្រេច ។

អ្នកស្រែទាំងឡាយ ព្រោះពូជរឿយៗ ទេវរាជ បង្អុរភ្លៀងក៏រឿយៗ ពួកអ្នកស្រែ ភ្ជួរស្រែរឿយៗ ពួកអ្នកស្រែនោះនាំស្រូវចូលទៅកាន់ដែនក៏រឿយៗ ។ ពួកស្មូមត្រាច់សូមរឿយៗ អ្នកម្ចាស់ទាន តែងឲ្យក៏រឿយៗ ពួកម្ចាស់ទានលុះឲ្យរឿយៗ ហើយ តែងទៅកាន់ឋានសួគ៌ក៏រឿយៗ ដែរ ។ អ្នកប្រាជ្ញមានបញ្ញាដូចផែនដី កើតក្នុងត្រកូលណា រមែងញ៉ាំងគូនៃបុរស ៧ ជួរ ក្នុងត្រកូលនោះឲ្យស្អាត ខ្ញុំព្រះអង្គសម្គាល់ថា ( ព្រះមានព្រះភាគ ) ជាទេវតាប្រសើរជាងទេវតា អាច ( ធ្វើសត្វដទៃឲ្យស្អាតបាន ) ព្រោះអ្នកប្រាជ្ញមានព្រះនាមដ៏ពិត កើតហើយអំពីព្រះអង្គ ។ ព្រះបាទសុទ្ធោទនៈ ជាបិតារបស់ព្រះពុទ្ធព្រះអង្គស្វែងរកនូវគុណដ៏ធំ ឯព្រះមហេសី ព្រះនាមមាយា ជាពុទ្ធមាតា ដែលរក្សាព្រះពោធិសត្វ ដោយផ្ទៃ លុះរំលាយខន្ធ

ទៅ កើតក្នុងតុសិតទេវលោក ។ ព្រះនាងទេវីនោះ ជាគោតមគោត្រ លុះទិវង្គតច្យុតចាកលោកនេះទៅ បានស្កប់ស្កល់ដោយកាមជាទិព្វទាំងឡាយ ព្រះនាងទ្រង់រីករាយ ដោយកាមគុណទាំង ៥ មានពពួកទេវតាទាំងនោះចោមរោមហើយ ។ ខ្ញុំព្រះអង្គជាបុត្រនៃព្រះពុទ្ធ ព្រះអង្គមិនមានបុគ្គលដទៃគ្របសង្កត់បាន ព្រះនាមអង្គីរសៈ មិនមានបុគ្គលដទៃប្រៀបបាន ប្រកបដោយតាទិគុណ បពិត្រព្រះអង្គជាសក្យៈ ព្រះអង្គជាបិតានៃបិតារបស់ខ្ញុំព្រះអង្គ បពិត្រព្រះគោតម ព្រះអង្គជាជីតារបស់ខ្ញុំព្រះអង្គ ដោយធម៌ ។

កាឡុទាយិត្ថេរ

# អដ្ឋកថា

# ថេរគាថា ទសកនិបាត

## កាឡុទាយិត្ថេរគាថា

[ ២៣៤ ] ក្នុងទសកនិបាត គាថារបស់ព្រះកាឡុទាយិត្ថេរ មានពាក្យផ្ដើមថា **អង្គារិនោ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈ មានអត្ថុប្បត្តិ-ហេតុដូចម្ដេច ។

បានឮថា ក្នុងសាសនាព្រះមានព្រះភាគ ព្រះនាមបទុមុត្តរៈ កុលបុត្តនេះកើតក្នុងផ្ទះនៃត្រកូល ក្នុងហង្សវតី កាលស្ដាប់ធម្មទេសនារបស់ព្រះសាស្ដា ឃើញព្រះសាស្ដាទ្រង់តាំងភិក្ខុមួយរូប ក្នុងតំណែងជាអ្នកធ្វើត្រកូលឲ្យជ្រះថ្លា ទើបធ្វើកុសលកម្ម ប្រាថ្នាតំណែងនោះ ។

កុលបុត្តនោះធ្វើកុសលកម្មដរាបអស់ជីវិតហើយ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ បដិសន្ធិក្នុងផ្ទះអមាត្យ ក្នុងនគរកបិលពស្តុនោះឯង ជំណាលគ្នានឹងបដិសន្ធិរបស់ព្រះពោធិសត្វនៃយើង ក្នុងគភ៌ព្រះមាតា កើតក៏កើតក្នុងថ្ងៃតែមួយជាមួយព្រះពោធិសត្វដូចគ្នា ដូច្នោះ ក្នុងថ្ងៃនោះឯង ពួកញាតិក៏ឲ្យទារកនោះដេកលើកែប ដែលធ្វើដោយសំពត់សាច់ល្អ នាំទៅកាន់ទីបម្រើរបស់ព្រះពោធិសត្វ ។

ពិតហើយ សហជាត ៧ គឺដើមពោធិព្រឹក្ស ១ រាហុលមាតា ១ កំណប់

ទ្រព្យទាំងបួន ១ ដំរី[១] ១ សេះកណ្ឋកៈ ១ នាយឆន្ន ១ កាឡុទាយី ១ បាន កើតព្រមមួយអន្លើដោយព្រះពោធិសត្វ ព្រោះកើតក្នុងថ្ងៃជាមួយគ្នានោះឯង ។ ក្នុងថ្ងៃដាក់ឈ្មោះ ពួកញាតិនាំគ្នាដាក់ឈ្មោះថា **ឧទាយី** ព្រោះកើតក្នុងថ្ងៃដែលអ្នកនគរទាំងអស់ មានចិត្តត្រេកអរ តែព្រោះមានសម្បុរខ្មៅបន្តិច ទើបប្រាកដឈ្មោះថា **កាឡុទាយី** ។ កាឡុទាយីនោះ ជាសម្លាញ់លេងដីជាមួយនឹងព្រះពោធិសត្វ រហូតដល់ធំចម្រើនវ័យ ។

ក្នុងកាលក្រោយមក កាលព្រះលោកនាថ ចេញមហាភិនេស្រ្កមណ៍ សម្រេចសព្វញ្ញុតញ្ញាណតាមលំដាប់ ទ្រង់ប្រកាសធម្មចក្រដ៏បវរ ឲ្យប្រព្រឹត្តទៅហើយ ទ្រង់អាស្រ័យក្រុងរាជគ្រឹះ គង់នៅក្នុងវត្តវេឡុវនមហាវិហារ ព្រះបាទសុទ្ធោទនមហារាជ ទ្រង់ស្តាប់ការប្រព្រឹត្តទៅនោះហើយ ទ្រង់បញ្ជូនអមាត្យម្នាក់ មានបុរស ១០០០ ជាបរិវារទៅ ដោយត្រាស់ថា ចូរនាំកូនយើងមកក្នុងទីនេះ ។ អមាត្យនោះ ធ្វើដំណើរទៅគាល់ព្រះសាស្តា ក្នុងកាលដែលទ្រង់សម្តែងធម៌ ទើបឈរស្តាប់ធម៌ខាងក្រោយបរិស័ទ ក៏សម្រេចអរហត្ត មួយអន្លើដោយបរិស័ទ ។

លំដាប់នោះ ព្រះសាស្តា ទ្រង់ក៏លាព្រះហស្តត្រាស់នឹងបុគ្គលទាំងនោះថា ចូរពួកអ្នកជាភិក្ខុចុះ ក្នុងខណៈនោះឯង មនុស្សទាំងអស់ក៏ទ្រទ្រង់បាត្រនិងចីវរដែលសម្រេចដោយឫទ្ធិ ដូចព្រះថេរៈមានវស្សា ៦០ ។ ចាប់តាំងអំពីសម្រេចអរហត្តហើយ ព្រះអរិយៈទាំងឡាយក៏ជាអ្នកមានអារម្មណ៍ជាកណ្តាល

(១) ក្នុងទីខ្លះរាប់ព្រះអានន្ទចូលមក ។

ព្រោះដូច្នោះ ទើបមិនបានក្រាបទូលដល់ព្រះទសពលឲ្យទ្រង់ជ្រាបដល់សាសន៍ ដែលព្រះរាជាបញ្ជូនទៅ ។ ព្រះរាជាទ្រង់ព្រះតម្រិះថា ពួកមនុស្សដែលបញ្ជូន ទៅហើយ ក៏មិនត្រឡប់មក ដំណឹងសូម្បីតែមួង ក៏មិនបានឮសោះ ទើបទ្រង់ បញ្ជូនអមាត្យម្នាក់ទៀត មួយអន្លើដោយបុរស ១០០០ ឲ្យធ្វើដំណើរទៅ កាលអមាត្យនោះបដិបត្តិតាមគ្នាយ៉ាងនោះ ព្រះរាជាក៏បញ្ជូនអមាត្យម្នាក់ទៅ ទៀត ដោយប្រការដូច្នេះ សរុបបុរស ៩០០០ នាក់ មួយអន្លើនឹងអមាត្យ ៩ នាក់ មនុស្សទាំងអស់ សម្រេចអរហត្តហើយ នាំគ្នាអង្គុយស្ងៀម ។

គ្រានោះ ព្រះរាជាទ្រង់ព្រះតម្រិះថា មនុស្សមានប្រមាណប៉ុណ្ណោះ ប្រហែលជាមិនមានសេចក្តីស្រឡាញ់ចំពោះអញសោះឡើយ មិនមកប្រាប់ ពាក្យណាមួយដល់ព្រះទសពល ដើម្បីយាងមកក្នុងទីនេះ តែឧទាយីនេះ ជា អ្នកមានវ័យជំណាលគ្នានឹងព្រះទសពល ធ្លាប់លេងដីជាមួយគ្នា និងមាន សេចក្តីស្រឡាញ់ក្នុងអញ អញនឹងបញ្ជូនអមាត្យនេះទៅ ដូច្នេះ ទើបទ្រង់ ត្រាស់ឲ្យហៅឧទាយីនោះមក ហើយត្រាស់ថា នែបា ចូរបានាំបុរសជាបរិវារ ១០០០ ទៅកាន់ក្រុងរាជគ្រឹះ ហើយនាំព្រះទសពលមក ដូច្នេះហើយ ទ្រង់ ក៏បញ្ជូនទៅ ។ ឯកាឡុទាយីអមាត្យនោះ កាលនឹងទៅក្រាបទូលព្រះរាជា ទើប ក្រាបទូលថា បើទ្រង់ឲ្យទូលបង្គំបួសសោត ទើបទូលបង្គំនាំព្រះមានព្រះភាគ មកក្នុងទីនេះ ព្រះរាជាក៏មានព្រះតម្រាស់តបថា អ្នកធ្វើអ្វីក៏ធ្វើចុះ ឲ្យតែបង្ហាញ បុត្តដល់យើង ដូច្នេះហើយ ក៏ទៅកាន់ក្រុងរាជគ្រឹះ ក្នុងកាលព្រះសាស្តាទ្រង់ សម្តែងធម៌ ទើបឈរស្តាប់ខាងចុងបរិស័ទ មួយអន្លើដោយបរិវារ សម្រេច

អរហត្ត តាំងនៅក្នុងភាពជាឯហិភិក្ខុ សមដូចគាថាព័ន្ធដែលលោកពោលក្នុងអបទានថា

ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ទ្រង់មានបញ្ញាចក្ខុ ក្នុងធម៌ទាំងពួង ព្រះអង្គជានាយកកើតឡើងក្នុងកប្បទីមួយសែន អំពីកទូកប្បនេះ ។ ព្រះសាស្ដាទ្រង់ប្រសើរជាងពួកអ្នកទូន្មាន ទ្រង់ជ្រាបនូវគុណ និងទោស ព្រះអង្គឈ្មោះមារ ជាកតញ្ញូកតវេទីបុគ្គល ទ្រង់ញុំាងពួកសត្វឲ្យប្រកបក្នុងកំពង់ គឺធម្មវិន័យ ។ ព្រះអង្គជាសព្វញ្ញូ មានសេចក្ដីអាណិតសត្វជាទីអាស្រ័យ ទ្រង់សន្សំនូវគុណរកទីបំផុតគ្មាន ទ្រង់ថ្លឹងមើលដោយញាណនោះហើយ សម្ដែងនូវធម៌ដ៏ប្រសើរ ។ ក្នុងកាលណាៗ ក៏ដោយ ព្រះសាស្ដាមានព្យាយាមមាំមួន មានការបរិសុទ្ធស្អាត ជាងប្រជុំជនជាអនន្ត ទ្រង់សម្ដែងធម៌ដ៏ពីរោះ ប្រកបដោយសច្ចៈ ៤ ។ ពួកសត្វចំនួនមួយសែនបានត្រាស់ដឹងមគ្គផល ព្រោះបានស្ដាប់នូវធម៌ដ៏ប្រសើរ មានលម្អខាងដើម កណ្ដាល និងខាងចុង ។ ក្នុងកាលនោះ ផែនដីក៏លាន់ឮ មេឃក៏គ្រហឹម ពួកទេវតា ព្រហ្ម មនុស្ស អសុរ ក៏ញុំាងសាធុការឲ្យប្រព្រឹត្តទៅថា ឱ ! ព្រះសាស្ដា ទ្រង់ប្រកបដោយករុណា ឱ ! ព្រះសទ្ធម្មទេសនា ឱ ! ព្រះជិនស្រី ទ្រង់ស្រង់ទេវតា មនុស្សសត្វ ដែលមុជចុះក្នុងសមុទ្រ គឺភពឡើងបាន ។ ( កាលបើសត្វទាំងឡាយ ) ព្រមទាំងមនុស្ស ទេវតា ព្រហ្ម កើត

សេចក្ដីសង្វេគយ៉ាងនេះហើយ ព្រះជិនស្រីទ្រង់សរសើរនូវសាវ័ក ដែលប្រសើរជាង បុគ្គលជ្រះថ្លាក្នុងត្រកូលទាំងឡាយ ។ កាល នោះ ខ្ញុំកើតក្នុងត្រកូលអាមាត្យ ក្នុងហង្សវតីនគរ ជាបុគ្គល ប្រកបដោយសេចក្ដីជ្រះថ្លា គួរឲ្យរមិលមើល មានទ្រព្យ និង ស្រូវច្រើន ។ ខ្ញុំចូលទៅក្នុងហង្សារាម ថ្វាយបង្គំព្រះតថាគតនោះ ស្ដាប់នូវធម៌ដ៏ពីរោះ ហើយធ្វើនូវគ្រឿងសក្ការៈដល់ព្រះតថាគត ជាតាទិបុគ្គល ។ ខ្ញុំក្រាបទៀបព្រះបាទា ពោលពាក្យនេះថា បពិត្រ ព្រះមុនី បុគ្គលណាប្រសើជាង បុគ្គលអ្នកជ្រះថ្លាក្នុងត្រកូល ក្នុង សាសនានៃព្រះអង្គ ។ បពិត្រព្រះអង្គ មានព្យាយាមធំ ខ្ញុំព្រះអង្គ សូមឲ្យបានជាបុគ្គលប្រាកដដូចបុគ្គលនោះ ក្នុងសាសនានៃ ព្រះពុទ្ធដ៏ប្រសើរ ។

កាលនោះ ព្រះពុទ្ធទ្រង់ប្រកបដោយមហាករុណា ក៏ស្រោច ខ្ញុំដោយអម្រឹតធម៌ ។ ព្រះពុទ្ធទ្រង់ត្រាស់នឹងខ្ញុំថា ម្នាលបុត្រ ចូរ អ្នកក្រោកឡើង អ្នកនឹងបាននូវតំណែងសមដូចបំណងនុ៎ះ បុគ្គល ធ្វើនូវការបូជាចំពោះព្រះជិនស្រី នឹងប្រាសចាកផលដូចម្ដេចកើត ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រះសាស្ដាទ្រង់ព្រះនាមគោតម ព្រះអង្គសម្ភពក្នុងឱក្កាកត្រកូល នឹងត្រាស់ឡើងក្នុងលោក ។ បុរស នេះនឹងបានជាទាយាទ ក្នុងធម៌ទាំងឡាយ របស់ព្រះសាស្ដានោះ ជាឱរសដែលធម៌និម្មិតហើយ ឈ្មោះឧទាយី ជាសាវ័ករបស់ព្រះ

សាស្តានោះ ។ កាលនោះ ខ្ញុំបានស្តាប់នូវព្រះពុទ្ធដីកានោះហើយ ក៏មានចិត្តរីករាយ មានចិត្តប្រកបដោយមេត្តា បានបម្រើនូវព្រះជិនស្រីព្រះអង្គជាអ្នកដឹកនាំសត្វ ដោយការបរិច្ចាគបច្ច័យទាំងឡាយ រហូតដល់អស់ជីវិត ។ ដោយវិបាកនៃកុសលកម្មនោះផង ដោយការតម្កល់នូវចេតនានោះផង លុះខ្ញុំលះបង់នូវរាងកាយជារបស់មនុស្ស ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។ ឥឡូវនេះ ដល់មកបច្ឆិមភព ខ្ញុំបានកើតក្នុងត្រកូលអាមាត្យជាធំ ក្នុងកបិលវត្ថុបុរីជាទីរីករាយ មានព្រះបាទសុទ្ធោទនៈជាម្ចាស់ផែនដី ។ កាលនោះ ព្រះសិទ្ធត្ថកុមារ ជាអ្នកអង់អាចជាងនរជន បានកើតឡើងក្នុងព្រៃលុម្ពិនីជាទីរីករាយ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់សព្វសត្វលោក ។ ខ្ញុំកើតក្នុងថ្ងៃនោះដែរ មានវ័យចម្រើនឡើងជាមួយនឹងព្រះសិទ្ធត្ថកុមារនោះ ជាសម្លាញ់ ជាទីស្រឡាញ់ប្រកបដោយសេចក្តីអាណិត ជាអ្នកស្និទ្ធស្នាល ឈ្លាសវៃក្នុងនីតិសាស្ត្រ ។ ព្រះសិទ្ធត្ថកុមារនោះ មានវ័យ ២៩ ឆ្នាំ ក៏ចេញទៅបួស ញុំាងកាលឲ្យកន្លងទៅអស់ ៦ វស្សា បានត្រាស់ជាព្រះពុទ្ធ ដឹកនាំ ( សត្វលោក ) ព្រះអង្គឈ្នះមារ ព្រមទាំងសេនា ហើយញុំាងអាសវៈឲ្យអស់ ទ្រង់ឆ្លងអន្លង់ គឺភព បានជាព្រះពុទ្ធក្នុងមនុស្សលោក និងទេវលោក ។ ទ្រង់ស្តេចទៅកាន់ព្រៃឈ្មោះឥសិបតនៈ ទូន្មានបញ្ចវគ្គិយភិក្ខុ តពីនោះមក ព្រះមានព្រះភាគក៏ស្តេចទៅក្នុង

ទីនោះៗ ហើយទូន្មាន ( សត្វ ) ។ ព្រះមានព្រះភាគនោះ កាល ទូន្មានពួកសត្វដែលគួរទូន្មាន សង្គ្រោះនូវមនុស្ស និងទេវតា រួចស្តេចចូលទៅឯភ្នំក្នុងដែនមគធៈ កាលនោះ ព្រះជិនស្រី ទ្រង់គង់ ( លើភ្នំនោះ ) ។ ពេលនោះ ខ្ញុំត្រូវព្រះបាទសុទ្ធោទនៈ ជាភូមិ-បាលបញ្ជូនទៅហើយខ្ញុំក៏ទៅ លុះខ្ញុំបានឃើញព្រះទសពលហើយ ក៏បួសបានជាអរហន្ត ។ ខ្ញុំបានអារាធនាព្រះពុទ្ធ ព្រះអង្គស្វែងរកនូវគុណដ៏ធំ ឲ្យចូលទៅកាន់ក្រុងកបិលពស្តុ លំដាប់នោះ ខ្ញុំទៅម្តងទៀត បានញុំាងមហាត្រកូលឲ្យជ្រះថ្លា ។ ព្រះជិនស្រីត្រេកអរក្នុងគុណនោះ ព្រះអង្គជាបុរសប្រសើរ ជានាយកដ៏វិសេស បានតាំងខ្ញុំថា ជាអ្នកប្រសើរជាងសាវ័ក អ្នកញុំាងត្រកូលឲ្យជ្រះថ្លា ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ ។

ឯព្រះកាឡុទាយី កាលសម្រេចអរហត្តហើយ គិតថា អាត្មាអញ បង្អង់ក្នុងកាលនេះ មិនសមគួរ ដើម្បីការយាងទៅកាន់ព្រះនគរ ដែលជាមាតុភូមិព្រះទសពល តែកាលដល់រដូវភ្លៀងហើយ ដងព្រៃនឹងមានផ្ការីកស្គុសស្គាយ ទើបជាកាលសមគួរ ដើម្បីការយាងទៅលើភូមិភាគ ដែលដេរដាសដោយតិណជាតិខៀវខ្ចី ដូច្នេះហើយ ទើបរង់ចាំកាល លុះដល់រដូវវស្សាហើយ កាលពណ៌នាសរសើរផ្លូវដើម្បីការយាងទៅកាន់ព្រះនគរ ដែលជាមាតុភូមិរបស់ព្រះសាស្តា ទើបពោលគាថាទាំងនេះថា

បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ពួកឈើមានពណ៌ដូចរងើកភ្លើង ជិតផ្លែហើយ ជម្រុះស្លឹកចាស់ចោល ឈើទាំងនោះ រុងរឿង ដូចជាអណ្តាតភ្លើង បពិត្រព្រះអង្គមានព្យាយាមធំ កាលនេះ ជាកាលគួរបានចំណែកធម្មរសហើយ ។ ឈើទាំងឡាយ ជាទីរីករាយនៃចិត្ត មានផ្លែ ផ្សាយក្លិនសព្វទិស ដោយជុំវិញ ជម្រុះស្លឹកចាស់ចោល ប្រុងនឹងចេញផ្លែថ្មីទៀត បពិត្រព្រះអង្គមានព្យាយាម កាលនេះ ជាកាលគួរដើម្បីចេញទៅអំពីទីនេះ ។ បពិត្រព្រះអង្គដ៏ចម្រើន រដូវដែលមិនត្រជាក់ពេក មិនក្តៅពេក ជាសុខស្រួល គួរដើរទៅកាន់ផ្លូវឆ្ងាយបាន ពួកសក្យៈ និងពួកកោលិយៈ សូមជួបព្រះអង្គដែលមានព្រះភក្ត្រ បែរត្រឡប់មកខាងក្រោយ កំពុងឆ្លងស្ទឹងរោហិណី ។

អ្នកស្រែភ្ជួរស្រែ ដោយសេចក្តីប្រាថ្នា ព្រោះពូជ ដោយសេចក្តីប្រាថ្នា ពួកឈ្មួញ អ្នករកទ្រព្យឆ្លងសមុទ្រ ដោយសេចក្តីប្រាថ្នា ។ ខ្ញុំព្រះអង្គ ឋិតនៅ ដោយសេចក្តីប្រាថ្នាណា សេចក្តីប្រាថ្នារបស់ខ្ញុំព្រះអង្គនោះ សូមឲ្យសម្រេច ។

អ្នកស្រែទាំងឡាយ ព្រោះពូជរឿយៗ ទេវរាជ បង្អុរភ្លៀងក៏រឿយៗ ពួកអ្នកស្រែ ភ្ជួរស្រែរឿយៗ ពួកអ្នកស្រែនោះនាំស្រូវចូលទៅកាន់ដែនក៏រឿយៗ ។ ពួកស្មូមត្រាច់សូមរឿយៗ អ្នកម្ចាស់ទានតែងឲ្យក៏រឿយៗ ពួកម្ចាស់ទាន លុះឲ្យរឿយៗ ហើយ តែងទៅកាន់

ឋានសួគ៌ ក៏រឿយៗ ដែរ ។ អ្នកប្រាជ្ញមានបញ្ញាដូចផែនដី កើត ក្នុងត្រកូលណា រមែងញ៉ាំងគូនៃបុរស ៧ ជួរ ក្នុងត្រកូលនោះឲ្យ ស្អាត ខ្ញុំព្រះអង្គសម្គាល់ថា ( ព្រះមានព្រះភាគ ) ជាទេវតាប្រសើរ ជាងទេវតា អាច ( ធ្វើសត្វដទៃឲ្យស្អាតបាន ) ព្រោះអ្នកប្រាជ្ញ មានព្រះនាមដ៏ពិត កើតហើយអំពីព្រះអង្គ ។ ព្រះបាទសុទ្ធោទនៈ ជាបិតារបស់ព្រះពុទ្ធ ព្រះអង្គស្វែងរកនូវគុណដ៏ធំ ឯព្រះមហេសី ព្រះនាមមាយា ជាពុទ្ធមាតា ដែលរក្សាព្រះពោធិសត្វ ដោយផ្ទៃ លុះរំលាយខន្ធទៅ ត្រេកអរក្នុងតុសិតទេវលោក ។ ព្រះនាងទេវី នោះ ជាគោតមគោត្រ លុះទិវង្គតច្យុតចាកលោកនេះទៅ បាន ស្កប់ស្កល់ដោយកាមជាទិព្វទាំងឡាយ ព្រះនាងទ្រង់រីករាយដោយ កាមគុណទាំង ៥ មានពពួកទេវតាទាំងនោះ ចោមរោមហើយ ។ ( កាឡុទាយិត្ថេរថ្វាយព្រះពរព្រះបាទសុទ្ធោទនមហារាជថា ) ខ្ញុំ ព្រះអង្គជាបុត្រនៃព្រះពុទ្ធ ព្រះអង្គមិនមានបុគ្គលដទៃគ្របសង្កត់ បាន ព្រះនាមអង្គីរសៈ មិនមានបុគ្គលដទៃប្រៀបបាន ប្រកប ដោយតាទិគុណ បពិត្រព្រះអង្គជាសក្យៈ ព្រះអង្គជាបិតានៃបិតា របស់ខ្ញុំព្រះអង្គ បពិត្រព្រះគោតម ព្រះអង្គជាជីតារបស់ខ្ញុំព្រះអង្គ ដោយធម៌ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អង្គារិនោ** ប្រែថា ដូចរងើកភ្លើង ។ ឈ្មោះ ថា **អង្គារិនោ** ព្រោះអត្ថថា ពួកឈើទាំងឡាយនោះ មានផ្កា និងស្លឹក មាន

ពណ៌ដូចកែវប្រពាលក្រហម អធិប្បាយថា ដូចភ្លៀងរងើកភ្លើង ដេរដាស ដោយគុម្ពផ្កាកុសុមពណ៌ក្រហមចាស់ ដូចរងើកភ្លើង ។

បទថា **ឥទានិ** ប្រែថា ក្នុងកាលឥឡូវនេះ ។ បទថា **ទុមា** ប្រែថា ដើមឈើទាំងឡាយ ។ បទថា **ភទន្តេ** បានដល់ ព្រះថេរៈពោលថា បពិត្រ ព្រះមានព្រះភាគដ៏ចម្រើន ដោយលុប **ទ** អក្ខរៈមួយតួចេញ ។ ព្រះសាស្តា ទ្រង់ប្រកបដោយគុណវិសេស និងជាបុគ្គលក្រៃលែងជាងបុគ្គលប្រកបដោយ គុណវិសេសទាំងឡាយ ព្រោះដូច្នោះ បទថា **ភទន្តេ** ទើបជាពាក្យហៅព្រះ សាស្តា ។ បទថា **ភទន្តេ** នេះ ជាបឋមាវិភត្តិ ផ្លាស់អក្សរខាងចុងជា **ឯ** បាន ដូចក្នុងប្រយោគថា **សុកតេ បដិកម្មេ សុខេ ទុក្ខេ ជីវេ** ជាដើម ។ តែក្នុងទីនេះ បណ្ឌិតគប្បីឃើញថា **ភទន្តេ** ចុះក្នុងអត្ថនៃការត្រាស់ដឹង ។ ដោយហេតុនោះ ទើបលោកពោលថា **ភទន្តេ** ជាអាលបនៈ ។ អាចារ្យ ពួកខ្លះពោលថា **ភទន្ត** សព្ទ ដែលមានត្រង់កណ្តាលបទ មានអត្ថស្មើគ្នានឹង **ភទ្ទ** សព្ទ ។

ឈ្មោះថា **ផលេសិនោ** ព្រោះអត្ថថា រមែងត្រូវការឲ្យផល ពិតហើយ ក្នុងវត្ថុដែលមិនមានចេតនា លោកក៏ដាក់ពាក្យកិរិយារបស់វត្ថុដែលមានចេតនា ចូលទៅក៏បាន ដូចពាក្យថា ត្រកូលដែលប្រាថ្នាឲ្យធ្លាក់ទៅ ដូច្នោះ ទើបមាន អត្ថថា ដើមឈើផ្តើមចេញនូវផ្លែ គឺពេលដែលដើមឈើចេញផ្លែ ។

បទថា **ឆទនំ វិប្បហាយ** បានដល់ ជ្រុះស្លឹកឈើចាស់ៗ គឺស្លឹកឈើ ទុំទូទៅ ។ បទថា **តេ** សំដៅដល់ **ទុមា** ប្រែថា ពួកឈើទាំងនោះ ។

បទថា **អច្ចិមន្តោ វ បភាសយន្តិ** សេចក្តីថា រមែងភ្លឺសព្វទិស ដូចអណ្តាតភ្លើង ឬដូចគំនរភ្លើងដែលឆេះសន្ធោសន្ធៅ ។

បទថា **សមយោ** ស្មើគ្នានឹង **កាលោ** គប្បីបន្ថែមពាក្យពិសេស ( គឺពាក្យថា ) **អនុគ្គហាយ** ( ដើម្បីអនុគ្រោះ ) ចូលមក ។ បទថា **មហាវីរ** បានដល់ បពិត្រព្រះអង្គដ៏ចម្រើន ទ្រង់មានសេចក្តីក្លាហានធំ ។ បទថា **ភាគី រសានំ** បានដល់ ជាអ្នកមានចំណែកនៃអត្ថរសជាដើម សមដូចពាក្យដែលព្រះធម្មសេនាបតីពោល ( ខុទ្ទកនិកាយ ចូឡនិទ្ទេស ) ថា ព្រះមានព្រះភាគព្រោះព្រះមានបុណ្យ ទ្រង់មានភាគនៃអត្ថរស ធម្មរស ដូច្នេះជាដើម ។ ពាក្យថា **មហាវីរ ភាគី** នេះ បណ្ឌិតគប្បីជ្រាបថា ជាពាក្យប្រើជាមួយព្រះសម្ពុទ្ធ ពោលសំដៅដល់ការត្រាស់ដឹង ។ ចំណែកក្នុងបាឋៈថា **ភាគីរថានំ** ព្រះរាជាអង្គដំបូង ទ្រង់ព្រះនាមថា **ភាគីរថ** អធិប្បាយថា ពួកស្តេចសក្យៈ បានឈ្មោះថា **ភាគីរថ** ព្រោះកើតរួមវង្សជាមួយព្រះបាទ **ភាគីរថ** នោះ ។ ដើម្បីឧបការៈស្តេចសក្យៈទាំងនោះ ។

បទថា **ទុមានិ** លោកពោលដោយភាពជាលិង្គវិបល្លាស បានដល់ **ទុមា** ប្រែថា ដើមឈើទាំងឡាយ ។

បទថា **សមន្ততោ សព្វទិសា បវន្តិ** សេចក្តីថា ពួកឈើទាំងឡាយមានផ្ការីកហើយ ក្នុងទិសទាំងពួងដោយជុំវិញ គឺដោយសព្វផែនដី ព្រោះរីកហើយយ៉ាងនោះ ទើបផ្សាយក្លិន គឺបង្ហើរក្លិនក្រអូបទៅសព្វទិស ។

បទថា **អាសមានា** បានដល់ សង្ឃឹម គឺត្រូវការចេញផ្លែ ។ ព្រះ

ថេរៈកាលសម្តែងថា ផ្លូវដែលទៅគួរត្រេកអរ ព្រោះស្អាតដោយឈើទាំង-ឡាយយ៉ាងនេះហើយ ឥឡូវនេះ ទើបសម្តែងការសម្បូរនៃឧតុ ដោយពាក្យថា **នេវាតិសីតំ** ដូច្នេះជាដើម ។

បទថា **សុខា** បានដល់ ឧតុដែលសប្បាយ គឺគួរប្រាថ្នា ព្រោះជាឧតុមិនត្រជាក់ពេក មិនក្តៅពេក ។

បទថា **ឧតុ អទ្ធនិយា** បានដល់ រដូវដែលសមដល់ការដើរផ្លូវឆ្ងាយ ។

បទថា **បស្សន្តុ តំ សាកិយា កោលិយា ច បច្ឆាមុខំ រោហិណិយំ តរន្តំ** សេចក្តីថា ស្ទឹងឈ្មោះថា រោហិណី ហូរអំពីទិសខាងជើងមកកាន់ទិសខាងត្បូង កាត់ត្រង់ពាក់កណ្តាលសាកិយជនបទ និងកោលិយជនបទ ឯក្រុងរាជគ្រឹះនៅត្រង់ទិសអាគ្នេយ៍នៃស្ទឹងនោះ ព្រោះហេតុនោះ ទើបបុគ្គលចេញអំពីនគររាជគ្រឹះទៅកាន់នគរកបិលពស្តុ ត្រូវបែរមុខទៅកាន់ទិសខាងលិចហើយឆ្លងទៅ ព្រោះហេតុនោះ ទើបព្រះថេរៈពោលថា **បស្សន្តុ តំ ។បេ។ តរន្តំ** ដូច្នេះជាដើម ។

ព្រះថេរៈព្យាយាមអារាធនាព្រះមានព្រះភាគ ដើម្បីយាងទៅកាន់ក្រុងកបិលពស្តុថា អ្នកសាកិយៈ និងកោលិយជនបទ នឹងបានឃើញទ្រង់ ក្នុងកាលឆ្លងស្ទឹងរោហិណី ដោយបែរព្រះភក្ត្រទៅទិសខាងលិចចុះ ។

ឥឡូវនេះ ព្រះថេរៈកាលប្រកាសសេចក្តីប្រាថ្នារបស់ខ្លួន ដោយឧបមា ទើបពោលគាថាថា **អាសាយ កសតេ** ដូច្នេះជាដើម ។

បទថា **អាសាយ កសតេ ខេត្តំ** សេចក្តីថា អ្នកស្រែ កាលភ្ជួរស្រែ

ក៏ភ្ជួរដោយសង្ឃឹមផល ។

បទថា **ពីជំ អាសាយ វប្បតិ** សេចក្តីថា កាលភ្ជួរហើយ កាលនឹងព្រោះពូជ ក៏ព្រោះ គឺព្រោះពូជដោយសង្ឃឹមផល ។

បទថា **អាសាយ វាណិជា យន្តិ** សេចក្តីថា ពួកឈ្មួញដែលស្វែងរកទ្រព្យ រមែងបន្សាត់សំពៅទៅកាន់មហាសមុទ្រ ដើម្បីឆ្លងមហាសមុទ្រ គឺដើម្បីចូលទៅកាន់ប្រទេសមួយ ដោយសង្ឃឹមបានទ្រព្យ ។ បទថា **យាយ អាសាយ តិដ្ឋាមិ** សេចក្តីថា ព្រះថេរៈទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គនៅក្នុងទីនេះ ដោយសង្ឃឹម គឺការប្រាថ្នាផលឯណា គឺដោយត្រូវការឲ្យទ្រង់យាងទៅកបិលពស្តុ ។ ការសង្ឃឹមនោះរបស់ខ្ញុំព្រះអង្គ សូមសម្រេចចុះ ទ្រង់គួរយាងទៅកាន់ក្រុងកបិលពស្តុបានហើយ ដូច្នេះ ។ ក្នុងសេចក្តីនេះ ព្រះថេរៈពោលដល់ការពេញចិត្ត គឺការប្រាថ្នាដើម្បីនឹងធ្វើថា **អាសា** ព្រោះដូចគ្នានឹងការសង្ឃឹម ។

ព្រះថេរៈ កាលសម្តែងហេតុនៃការអារាធនាច្រើនដង ដោយមានការពណ៌នាដោយផ្លូវដែលយាងទៅជាដើម ទើបពោលពាក្យថា **បុនប្បុនំ** ដូច្នេះជាដើម ។

អត្ថនៃបាទគាថានោះ ដូច្នេះថា កាលពូជមិនឲ្យផល ដោយការសាបព្រោះម្តង ពួកអ្នកស្រែ ក៏សាបព្រោះពូជរឿយៗ គឺសាបព្រោះជាគម្រប់ ២ ដង ជាគម្រប់ ៣ ដង ទេវតានៃភ្លៀងឈ្មោះថា បជ្ជុនៈ មិនបានឲ្យភ្លៀងធ្លាក់ត្រឹមតែម្តង តែបង្អុររឿយៗ គឺធ្លាក់តាមរដូវកាល ទោះបីពួកអ្នកស្រែ ក៏មិន

ភ្ជួរស្រែត្រឹមតែម្ដងប៉ុណ្ណោះ តែភ្ជួរស្រែរឿយៗ ដើម្បីធ្វើដីឲ្យហ្មត់ ឬធ្វើកក់ឲ្យបែក ដើម្បីឲ្យស្រូវបរិបូណ៌ ។ ធញ្ញាហារ មានស្រូវសាលីជាដើម ដែលមនុស្សប្រមូលផលម្ដងហើយ មិនទាន់ពេញចិត្តថា ប៉ុណ្ណេះល្មមហើយ ជញ្ជូនមកទុកក្នុងជង្រុកជាដើម រមែងចូលដល់ គឺចូលរដ្ឋរឿយៗ ។

សូម្បីពួកយាចកត្រាច់ទៅសូម គឺចូលកាន់ត្រកូលទាំងឡាយរឿយៗ មិនមែនសូមតែម្ដងប៉ុណ្ណោះទេ ឯពួកទានបតី ដែលត្រូវពួកយាចកទាំងនោះសូមហើយ ក៏ឲ្យរឿយៗ មិនមែនឲ្យតែម្ដងនោះទេ ។

ពួកទានបតី កាលឲ្យទេយ្យធម៌រឿយៗ យ៉ាងនោះហើយ គឺសន្សំបុណ្យដែលសម្រេចដោយទានហើយ រមែងចូលដល់ស្ថានសួគ៌រឿយៗ គឺទៅមកៗបានដល់ រមែងចូលដល់ទេវលោក ដោយអំណាចបដិសន្ធិ អធិប្បាយថា ព្រោះដូច្នោះ ខ្ញុំព្រះអង្គក៏អារាធនារឿយៗ បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ញ៉ាំងមនោរថរបស់ខ្ញុំព្រះអង្គ ឲ្យដល់ទីបំផុតចុះ ។

ឥឡូវនេះ ព្រះថេរៈអារាធនាព្រះសាស្ដា ឲ្យយាងទៅកាន់ក្រុងកបិលពស្តុដើម្បីជាប្រយោជន៍ណា ដើម្បីសម្ដែងដល់ប្រយោជន៍នោះ ទើបពោលពាក្យជាគាថាថា **វីរោ ហវេ** ដូច្នេះជាដើម ។

សេចក្ដីនៃបាទគាថានោះថា វាចារបស់សត្វលោក ដែលថា បុរសអ្នកមានព្យាយាម មានវីរិយៈ មានការអាចហ៊ាន មានបញ្ញាទូលាយ គឺមានបញ្ញាច្រើនរមែងកើត គឺកើតក្នុងត្រកូលណា រមែងញ៉ាំងមនុស្សក្នុងត្រកូលនោះ អស់ ៧ តំណ គឺរាប់ដល់តាទួតជាជួរទី ៧ ឲ្យបរិសុទ្ធស្អាត គឺឲ្យផ្លូវផង់

ដោយសម្មាបដិបត្តិ ដោយពិត គឺដោយចំណែកមួយ នេះជាពាក្យសរសើរ ដែលប្រើក្នុងមនុស្សដទៃផងដែរ ។

ខ្ញុំព្រះអង្គយល់ថា ព្រះមានព្រះភាគ ជាទេវតាប្រសើរជាងទេវតា ព្រោះទ្រង់ជាទេវតាក្រៃលែងជាងទេវតាទាំងពួង ទ្រង់អាចធ្វើត្រកូលដែលក្រៃលែងទាំងនោះឲ្យបរិសុទ្ធ ដោយការហាមចាកអំពើអាក្រក់ និងដោយការឲ្យតាំងនៅក្នុងអំពើល្អ ព្រោះហេតុអ្វី ព្រោះទ្រង់កើតហើយដោយអរិយជាតិ បាននាមតាមសេចក្តីពិតថា ជាអ្នកប្រាជ្ញ អធិប្បាយថា ព្រោះភាវៈដែលព្រះអង្គជាព្រះសាស្តា កើតហើយដោយអរិយជាតិ ជាអ្នកប្រាជ្ញ ទ្រង់ជាអ្នកដឹង ទើបបានព្រះនាមតាមសេចក្តីពិតថា **មុនិ** ព្រោះអត្ថថា ដឹងនូវប្រយោជន៍ផ្ទាល់ព្រះអង្គ និងប្រយោជន៍អ្នកដទៃ និងព្រោះអត្ថថា ដឹងច្បាស់នូវលោកនេះ និងលោកខាងមុខ ។ ម្យ៉ាងទៀត បុគ្គលមានការដឹង ឈ្មោះថា **មុនិ** ទ្រង់មានព្រះនាមតាមសេចក្តីពិតថា **សមណៈ បព្វជិត ឥសី** ដូច្នេះ បពិត្រព្រះមានព្រះភាគ ព្រោះហេតុនៃការបានចំពោះនូវប្រយោជន៍ដោយចំណែកមួយដល់ពួកសត្វ ទើបខ្ញុំព្រះអង្គទូលអារាធនាព្រះអង្គ ដើម្បីយាងទៅក្នុងក្រុងកបិលពស្តុនោះ ។

ឥឡូវនេះ កាលព្រះថេរៈពោលថា **សត្តមយុគំ** ដូច្នេះហើយ កាលនឹងសម្តែងយុគនៃបិតា ទើបពោលពាក្យថា **សុទ្ធោទនោ នាម** ដូច្នេះជាដើម ។ ឈ្មោះថា **សុទ្ធោទនោ** ព្រោះអត្ថថា ជាអ្នករស់នៅដោយបាយដ៏បរិសុទ្ធ ។ ពិតហើយ ពុទ្ធបិតា ជាអ្នកមានកាយសមាចារ វចីសមាចារ និងមនោសមាចារ

ដែលបរិសុទ្ធវិសេសដោយចំណែកមួយ ទើបជាអ្នកមានអាជីវៈបរិសុទ្ធ ព្រោះទ្រង់ដល់ព្រមដោយអភិនីហារយ៉ាងនោះ ។

បទថា **មាយនាមា** បានដល់ មានឈ្មោះថា **មាយា** ព្រោះព្រះនាងមានព្រះគុណដែលពួកញាតិ និងមិត្រជាដើមគប្បីពោលថា កុំទៅឡើយ ដូច្នេះ ព្រោះសម្បូរដោយគុណ មានត្រកូល រូបរាង សីល មារយាទជាដើម ។

បទថា **បរិហរិយ** បានដល់ ផ្គង ។ បទថា **កាយស្ស ភេទា** បានដល់ ខាងមុខអំពីកាយរបស់ខ្លួន ដែលដូចជាចេតិយរបស់សត្វលោក ព្រមទាំងទេវលោកវិនាសទៅ ។

បទថា **តិទិវម្ហិ** បានដល់ ក្នុងតុសិតទេវលោក ។ បទថា **សា** សំដៅដល់ **មាយាទេវី** ប្រែថា ព្រះនាងមហាមាយាទេវីនោះ ។ បទថា **គោតមី** សេចក្ដីថា ព្រះថេរៈប្រារព្ធដល់ព្រះនាងដោយព្រះគោត្ត ។

បទថា **ទិព្វេហិ កាមេហិ** បានដល់ ដោយវត្ថុកាមដែលជាទិព្វ ដែលមានក្នុងភពជាន់តុសិត ។

បទថា **សមង្គិភូតា** បានដល់ ប្រកបព្រមហើយ ។

បទថា **កាមគុណេហិ** បានដល់ ដោយចំណែកនៃកាមគុណទាំងឡាយ ព្រះថេរៈកាលពោលថា **កាមេហិ** ដូច្នេះហើយ ក៏នៅសម្ដែងថា បានទទួលការបម្រើដោយវត្ថុកាម ដែលមានចំណែកច្រើន ដោយពាក្យថា **កាម-គុណេហិ** ដូច្នេះទៀត ។

បទថា **តេហិ** សេចក្ដីថា កើតហើយក្នុងពួកទេវតាជាន់ណា ដែលពួក

ទេវតាជាន់តុសិតទាំងនោះចោមរោម ឬត្រេកអរដោយកាមគុណទាំងនោះ ។ ពាក្យថា **សមង្គិភូតា បរិវារិតា** នេះ លោកប្រើជាឥត្ថីលិង្គ ព្រោះសំដៅដល់ភាវៈជាស្រី ឬភាវៈជាទេវតា ដែលកើតហើយក្នុងអត្តភាពមុន ឯការកើតក្នុងពួកទេវតា កើតដោយភេទប្រុសប៉ុណ្ណោះ[១] ។

ព្រះសាស្តាត្រូវព្រះថេរៈអារាធនាយ៉ាងនោះ ទ្រង់ឃើញថា មហាជនជាច្រើននឹងបានសម្រេចគុណវិសេស ព្រោះការយាងទៅនគរកបិលពស្តុនោះ ទើបមានព្រះទីណាស្រេចពីរម៉ឺនរូបចោមរោម ហើយយាងអំពីនគររាជគ្រឹះដោយមាគ៌ាទៅកាន់នគរកបិលពស្តុ ដោយបែបចារិកមិនប្រញាប់ប្រញាល់ ។ ព្រះថេរៈចូលទៅកាន់នគរកបិលពស្តុដោយឫទ្ធិ ឈរក្នុងអាកាសក្នុងទីចំពោះព្រះភក្ត្រព្រះរាជា ។ ទ្រង់ឃើញភេទដែលមិនធ្លាប់ឃើញមកអំពីមុន ទើបត្រាស់សួរថា លោកជានរណា កាលសម្តែងថា បើទ្រង់ចាំអាត្មាភាពដែលជាបុត្រអមាត្យ ដែលទ្រង់បញ្ជូនទៅគាល់ព្រះមានព្រះភាគមិនបានសោត សូមទ្រង់ដឹងយ៉ាងនេះចុះ ដូច្នេះ ទើបពោលគាថាចុងក្រោយថា

ខ្ញុំព្រះអង្គជាបុត្រនៃព្រះពុទ្ធ ព្រះអង្គមិនមានបុគ្គលដទៃ គ្របសង្កត់បាន ព្រះនាមអង្គីរសៈ មិនមានបុគ្គលដទៃប្រៀបបាន ប្រកបដោយតាទិគុណ បពិត្រព្រះអង្គជាសក្យៈ ព្រះអង្គជាបិតានៃបិតារបស់ខ្ញុំព្រះអង្គ បពិត្រព្រះគោតម ព្រះអង្គជាជីតារបស់ខ្ញុំព្រះអង្គ

---

១- ព្រះនាងសិរិមហាមាយា ដែលជាពុទ្ធមាតា កាលកើតតុសិតទេវលោក មានភេទជាបុរស មិនមែនជាស្ត្រីឡើយ ។

ដោយធម៌ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ពុទ្ធស្ស បុត្តោម្ហិ** អាត្មាជាឱរសរបស់ព្រះសព្វញ្ញុពុទ្ធ ព្រោះកើតអំពីទ្រង់ ។

បទថា **អសយ្ហសាហិនោ** សេចក្ដីថា ឈ្មោះថា **អសយ្ហសាហិនោ** ព្រោះនាំទៅ គឺនាំចេញនូវពោធិសម្ភារ និងមហាករុណាធិគុណ[១] ទាំងពួង ដែលឈ្មោះថា **អសយ្ហសាហិនោ** ព្រោះមិនមានបុគ្គលដទៃអាចនាំទៅ គឺនាំចេញនូវព្រះមហាពោធិសត្វចេញចាកការត្រាស់ដឹង មុននឹងបានត្រាស់ដឹងក្រោយអំពីនោះ ព្រោះញាំញី គឺគ្របសង្កត់នូវមារ ៥ ដែលឈ្មោះថា **អសយ្ហសាហិនោ** ព្រោះបុគ្គលដទៃមិនអាចញាំញី គឺគ្របសង្កត់បាន និងព្រោះទ្រង់អត់ធន់ចំពោះពុទ្ធកិច្ច ដែលអ្នកដទៃអត់ធន់បានដោយក្រ ដែលបានដល់ការទូន្មានវេនេយ្យសត្វ ដោយទិដ្ឋធម្មិកត្ថប្រយោជន៍ សម្បរាយិកត្ថប្រយោជន៍ និងបរមត្ថប្រយោជន៍តាមសមគួរ ដោយការឈមចុះដល់ការផ្សេងគ្នារបស់សត្វ តាមអាសយាអនុសយ ចរិត និងអធិមុត្តិជាដើម ម្យ៉ាងទៀត ឈ្មោះថា **អសយ្ហសាហិនោ** ក្នុងទីនេះ ព្រោះទ្រង់ធ្វើល្អ ។

បទថា **អង្គីរសស្ស** បានដល់ ជាអ្នកសម្បូរដោយព្រះគុណ មានសីល ដែលទ្រង់បំពេញមកហើយជាដើម ។ អាចារ្យពួកដទៃពោលថា មានរស្មី ផ្សាយចេញអំពីអវយវៈតូចធំ ដូច្នេះក៏មាន ។ ឯអាចារ្យពួកខ្លះពោលថា ឈ្មោះថា ព្រះនាម ២ គឺព្រះអង្គីរសៈ និងព្រះសិទ្ធត្ថនេះ ពុទ្ធបិតាទ្រង់ថ្វាយ ។

---

១- ប្រែមកអំពីបាលីថា មហាការុណិកាធិការស្ស ។

បទថា **អប្បដិមស្ស** បានដល់ មិនមានបុគ្គលប្រៀបស្មើ ។ ឈ្មោះថា **តាទិនោ** ព្រោះសម្បូរដោយលក្ខណៈនៃបុគ្គលមិនញាប់ញ័រ ក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ ។

បទថា **បិតុបិតា មយ្ហំ តុវំសិ** សេចក្តីថា ដោយលោកវោហារ ទ្រង់ជាបិតារបស់ព្រះសម្មាសម្ពុទ្ធដែលជាបិតារបស់អាត្មា ដោយអរិយជាតិ ។

ព្រះថេរៈហៅព្រះរាជាដោយជាតិថា **សក្កៈ** ។

បទថា **ធម្មេន** បានដល់ ដោយសភាវៈ គឺដោយរួមយកជាតិពីរ គឺ អរិយជាតិ និងលោកិយជាតិចូលជាមួយគ្នា ។ ព្រះថេរៈហៅព្រះរាជាដោយគោត្តថា **គោតម** ។

បទថា **អយ្យកោសិ** សេចក្តីថា ទ្រង់ជាជីតា ។ ក្នុងគាថានេះ ព្រះថេរៈកាលពោលពាក្យផ្តើមថា **ពុទ្ធស្ស បុត្តោម្ហិ** ដូច្នេះ ក៏ស្មើគ្នានឹងបានព្យាករអរហត្តដូចគ្នា ។

ព្រះថេរៈកាលសម្តែងខ្លួនឲ្យព្រះរាជាទ្រង់ដឹងយ៉ាងនោះហើយ កាលព្រះរាជាទ្រង់ត្រេកអរក្នុងព្រះរាជហឫទ័យ និមន្តឲ្យគង់លើបល្ល័ង្ក ដែលមានតម្លៃច្រើន ទ្រង់ដាក់ភោជនមានរសដ៏ប្រសើរផ្សេងៗ ដែលរៀបចំដើម្បីព្រះអង្គក្នុងបាត្រហើយប្រគេន បានសម្តែងអាការទើងទៅ ។

កាលព្រះរាជាត្រាស់សួរថា ព្រោះហេតុអ្វី ទើបបំណងទឹងទៅ សូមនិមន្តឆាន់ចុះ ព្រះថេរៈក៏តបថា អាត្មាទៅគាល់ព្រះសាស្តាហើយ ទើបឆាន់ ។ ព្រះរាជាត្រាស់សួរថា ព្រះសាស្តាគង់នៅក្នុងទីណា ព្រះថេរៈតបថា ព្រះ

សាស្តាមានភិក្ខុប្រមាណពីរម៉ឺនរូបជាបរិវារកំពុងយាងមកតាមផ្លូវ ដើម្បីគាល់ទ្រង់ ។ ព្រះរាជាត្រាស់ថា និមន្តលោកម្ចាស់ឆាន់បិណ្ឌបាតនេះសិន សូមនាំបិណ្ឌបាតទៅអំពីទីនេះ ទម្រាំបុត្ររបស់ខ្ញុំមកដល់នគរនេះ ។

ព្រះថេរៈធ្វើភត្តកិច្ចស្រេចហើយ សម្តែងធម៌ដល់ព្រះរាជា និងបរិស័ទមុនព្រះសាស្តាយាងមកដល់ លោកបានធ្វើឲ្យមនុស្សក្នុងរាជនិវេសន៍នោះជ្រះថ្លាក្នុងព្រះរតនត្រ័យ កាលមនុស្សទាំងអស់កំពុងឃើញនោះឯង ក៏បោះបាត្រដែលពេញដោយភត្ត ដែលខ្លួននាំមកដើម្បីថ្វាយព្រះសាស្តា ទៅក្នុងអាកាស ខ្លួនឯងក៏ហោះឡើងទៅកាន់អាកាស បង្អោនបិណ្ឌបាតក្នុងព្រះហស្តរបស់ព្រះសាស្តា ។ ព្រះសាស្តាទ្រង់សោយបិណ្ឌបាតនោះ ។ ព្រះថេរៈបាននាំភត្តអំពីព្រះរាជវាំងមកថ្វាយព្រះសាស្តាដែលទ្រង់យាងទៅ មួយថ្ងៃ មួយយោជន៍ អស់ចម្ងាយផ្លូវ ៦០ យោជន៍ ដោយប្រការយ៉ាងនេះ ។

គ្រានោះ ព្រះមានព្រះភាគ ទ្រង់ព្រះតម្រិះថា ឧទាយីធ្វើមនុស្សក្នុងព្រះរាជវាំងទាំងអស់ របស់ព្រះរាជាដែលជាបិតា របស់តថាគតជ្រះថ្លា ទើបទ្រង់ស្ថាបនាព្រះថេរៈក្នុងតំណែងឯតទគ្គៈ ជាងភិក្ខុសាវ័កទាំងឡាយ ដែលធ្វើត្រកូលឲ្យជ្រះថ្លា ដូច្នេះ ។l៚

## អដ្ឋកថា កាឡុទាយិត្ថេរគាថា ចប់

# សុត្តន្តបិដក

## ឯកវិហារិយត្ថេរគាថា

[ ២៣៥ ] បើបុគ្គលដទៃ មិនមានអំពីមុខក្តី ក្រោយក្តី សេចក្តីសប្បាយក្រៃពេក រមែងមានដល់បុគ្គលម្នាក់ឯងនៅក្នុងព្រៃ ។ បើដូច្នោះ អាត្មាអញតែម្នាក់ឯង នឹងទៅកាន់ព្រៃ ដែលព្រះពុទ្ធទ្រង់សរសើរហើយ ជាទីសប្បាយរបស់ភិក្ខុអ្នកមានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ជាអ្នកនៅតែម្នាក់ឯង ។ អាត្មាអញតែម្នាក់ឯង ជាអ្នកស្ទាត់ក្នុងប្រយោជន៍ នឹងចូលយ៉ាងឆាប់ទៅកាន់ព្រៃ ជាទីធ្វើឲ្យកើតបីតិដល់យោគាវចរ ជាទីរីករាយ ដែលដំរីចុះប្រេង សេពគប់ហើយ ។ អាត្មាអញម្នាក់ឯង នឹងស្រោចស្រពខ្លួន ហើយចង្ក្រមក្នុងព្រៃ ត្រជាក់ មានផ្ការីកស្គុសស្គាយ ក្បែរជ្រោះភ្នំដ៏ត្រជាក់ ។ អង្កាល់ណា អាត្មាអញនឹងទៅជាបុគ្គលម្នាក់ឯង មិនមានបុគ្គលជាគម្រប់ពីរ មានសោឡសកិច្ចធ្វើហើយ ជាអ្នកមិនមានអាសវៈនៅក្នុងព្រៃធំ ដែលគួររីករាយ ។ សូមសេចក្តីប៉ុនប៉ងរបស់អាត្មាអញ ដែលប្រាថ្នាដើម្បីធ្វើសេចក្តីព្យាយាមយ៉ាងនេះ បានសម្រេច អាត្មាអញនឹងធ្វើឲ្យសម្រេច ( ព្រោះថា ) អ្នកដទៃ ធ្វើជួសអ្នកដទៃពុំបានទេ ។ ឥឡូវនេះ អាត្មាអញនោះ នឹងចងក្រោះ គឺព្យាយាម ហើយចូលទៅកាន់ព្រៃ បើអាត្មាអញ មិនទាន់សម្រេចនូវធម៌ជាគ្រឿងអស់អាសវៈទេ នឹងមិនចេញពីព្រៃនោះឡើយ ។ កាលបើខ្យល់ត្រជាក់ មានក្លិនក្រអូបបក់ផ្សាយទៅ អាត្មាអញនឹងអង្គុយលើ

កំពូលភ្នំ ហើយទម្លាយអវិជ្ជាឲ្យបាន ។ អាត្មាអញទទួលសេចក្តីសុខ ដោយវិមុត្តិសុខក្នុងព្រៃ មានផ្កាដេរដាស ក្បែរញកភ្នំដ៏ត្រជាក់រួចហើយ នឹងត្រេកអរក្នុងក្រុងរាជគ្រឹះ មានភ្នំព័ទ្ធជុំវិញដូចក្រោលគោ ។ អាត្មាអញនោះ មានតម្រិះគ្រប់គ្រាន់ ដូចព្រះចន្ទ្រក្នុងថ្ងៃ ១៥ កើត អស់អាសវៈទាំងពួងហើយ ឥឡូវនេះ ភពថ្មីមិនមានទេ ។

ឯកវិហារិយត្ថេរ

# អដ្ឋកថា

## ឯកវិហារិយត្ថេរគាថា

[ ២៣៥ ] គាថារបស់ព្រះឯកវិហារិយត្ថេរ មានពាក្យផ្តើមថា **បុរតោ បច្ឆតោ វាបិ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងសាសនាព្រះមានព្រះភាគ ព្រះនាមកស្សបៈ កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្តីហើយ ស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្តា មានសេចក្តីជ្រះថ្លា បួសហើយ ចូលកាន់ព្រៃ ដោយស្ងប់ស្ងាត់ ។

ដោយបុញ្ញកម្មនោះ ទើបលោកអន្ទោលទៅក្នុងទេវតា និងមនុស្សទាំង

ឡាយ អស់មួយពុទ្ធន្តរ ក្នុងពុទ្ធុប្បាទនេះ កាលព្រះមានព្រះភាគបរិនិព្វាន ហើយ កើតជាប្អូនប្រុសរបស់ព្រះបាទធម្មាសោក ។

បានឮថា ក្នុងឆ្នាំទី ២១៨ រាប់អំពីព្រះសាស្តាបរិនិព្វានមក ព្រះបាទអសោកមហារាជ ទ្រង់បានទទួលការអភិសេកជាឯករាជ្យក្នុងជម្ពូទ្វីបទាំងមូល ហើយ ទ្រង់ស្ថាបនាតិស្សកុមារដែលជាប្អូនប្រុសរបស់ព្រះអង្គ ក្នុងតំណែងឧបរាជ ទ្រង់ប្រើឧបាយណាមួយ ធ្វើប្អូនប្រុសនោះឲ្យជ្រះថ្លាក្នុងព្រះសាសនា ។ ថ្ងៃមួយ តិស្សកុមារនោះ ទៅបាញ់សត្វ ឃើញព្រះយោនកមហាធម្មរក្ខិតត្ថេរក្នុងព្រៃ ដែលដំរីដ៏ប្រសើរកំពុងចាប់មែកសាលព្រឹក្សបក់ប្រគេន ទើបកើតសេចក្តីជ្រះថ្លា គិតថា ឱហ្ន៎ ! អញបួសហើយ គប្បីនៅព្រៃដូចព្រះមហាថេរៈនេះ ។

ព្រះថេរៈ ជ្រាបដល់ការប្រព្រឹត្តទៅនៃចិត្តរបស់កុលបុត្តនោះ កាលកុលបុត្តនោះកំពុងឃើញនោះឯង ក៏ហោះទៅកាន់អាកាស មកឈរលើទឹកនៃស្រះបោក្ខរណី ក្នុងអសោការាម មិនធ្វើទឹកឲ្យបែក ព្យួរចីវរ និងស្បង់ក្នុងអាកាស ហើយស្រង់ទឹក ។

ព្រះកុមារ ឃើញអានុភាពរបស់ព្រះថេរៈហើយ មានសេចក្តីជ្រះថ្លាក្រៃលែង ត្រឡប់អំពីព្រៃហើយ ចូលទៅកាន់ព្រះរាជវាំង ហើយក្រាបទូលដល់ព្រះរាជាថា ខ្ញុំនឹងបួស ដូច្នេះ ។ ព្រះរាជាទ្រង់អង្វរព្រះកុមារនោះ ដោយប្រការផ្សេងៗ មិនអាចឲ្យកុមារលះបំណងបាន ។ ព្រះរាជកុមារនោះ ជាឧបាសក ប្រាថ្នាដល់សេចក្តីសុខក្នុងការបួស ទើបពោល ៦ គាថាថា

បើបុគ្គលដទៃ មិនមានអំពីមុខក្តី ក្រោយក្តី សេចក្តីសប្បាយ ក្រៃពេក រមែងមានដល់បុគ្គលម្នាក់ឯងនៅក្នុងព្រៃ ។ បើដូច្នោះ អាត្មាអញតែម្នាក់ឯង នឹងទៅកាន់ព្រៃ ដែលព្រះពុទ្ធទ្រង់សរសើរ ហើយ ជាទីសប្បាយរបស់ភិក្ខុ អ្នកមានចិត្តបញ្ជូនទៅកាន់ព្រះ និព្វាន ជាអ្នកនៅតែម្នាក់ឯង ។ អាត្មាអញតែម្នាក់ឯង ជាអ្នក ស្ទាត់ក្នុងប្រយោជន៍ នឹងចូលយ៉ាងឆាប់ទៅកាន់ព្រៃ ជាទីធ្វើឲ្យ កើតបីតិ ដល់យោគាវចរ ជាទីរីករាយ ដែលដំរីចុះប្រេងសេពគប់ ហើយ ។ អាត្មាអញម្នាក់ឯង នឹងស្រោចស្រពខ្លួន ហើយចង្ក្រម ក្នុងព្រៃត្រជាក់ មានផ្ការីកស្គុសស្គាយ ក្បែរជ្រោះភ្នំដ៏ត្រជាក់ ។ អង្កាល់ណា អាត្មាអញនឹងទៅជាបុគ្គលម្នាក់ឯង មិនមានបុគ្គលជា គម្រប់ពីរ មានសោឡសកិច្ចធ្វើហើយ ជាអ្នកមិនមានអាសវៈ នៅ ក្នុងព្រៃធំដែលគួររីករាយ ។ សូមសេចក្តីប៉ុនប៉ងរបស់អាត្មាអញ ដែលប្រាថ្នាដើម្បីធ្វើសេចក្តីព្យាយាមយ៉ាងនេះ បានសម្រេច អាត្មា អញនឹងធ្វើឲ្យសម្រេច ( ព្រោះថា ) អ្នកដទៃ ធ្វើជួសអ្នកដទៃពុំ បានទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បុរតោ បច្ឆតោ វា** បានដល់ បើអ្នកដទៃ មិនមានខាងមុខ ឬខាងក្រោយខ្លួន ព្រោះ **វា** សព្ទ ប្រើក្នុងអត្ថជ្រើសរើស ទើបសំដៅដល់ ផ្នែកខាងទទឹងផងដែរ ។ បើមិនមានបុគ្គលដទៃ គឺបុគ្គល ដទៃ គង់មានសេចក្តីសប្បាយ គឺសេចក្តីសុខបរិបូណ៌ក្រៃលែងដល់ខ្ញុំ ដែល

ជាបុគ្គលតែឯងមិនមានសម្លាញ់ ព្រោះជាបុគ្គលម្នាក់ឯង ។

ឧបាសកនោះមានចិត្តដែលអធ្យាស្រ័យបង្អោនទៅក្នុងវិវេក ដែលសន្សំមកអស់កាលយូរជាស់តៀន កាលមហាជនចោមរោម ទាំងពេលយប់ទាំងពេលថ្ងៃ ទើបកើតនូវការនឿយណាយក្នុងការនៅច្រឡូកច្រឡំ ដោយគណៈ និងឲ្យសម្គាល់ក្នុងសេចក្តីសុខដែលកើតអំពីវិវេកដ៏ច្រើន ។

សព្ទថា **ហន្ទ** ជានិបាត ចុះក្នុងអត្ថថា ដាក់ចិត្ត ។ ដោយនិបាតនោះទើបកុលបុត្តនោះ ពោលដល់ការសម្រេចចិត្តដែលត្រូវទៅព្រៃ ( ធ្វើសមណធម៌ ) ក្នុងឥឡូវនេះ ។

បទថា **ឯកោ គមិស្សាមិ** សេចក្តីថា ខ្ញុំម្នាក់ឯង មិនមានសម្លាញ់នឹងទៅ គឺនឹងចូលទៅ ដោយបំណងនឹងនៅព្រៃ ដែលព្រះពុទ្ធទាំងឡាយសរសើរដោយព្រះតម្រាស់ដែលត្រាស់ ( ក្នុងវិនយបិដក ចុល្លវគ្គ ) ថា ម្នាលគហបតីព្រះតថាគតទាំងឡាយ រមែងត្រេកអរចំពោះក្នុងលំនៅដ៏ស្ងាត់តែម្យ៉ាងជាដើម ព្រោះផាសុកក្នុងការនៅព្រៃ រមែងមានដល់ភិក្ខុដែលនៅតែម្នាក់ឯង គឺនៅម្នាក់ឯង ព្រោះមិនមានសម្លាញ់ក្នុងការឈរជាដើម ឈ្មោះថា **បហិតត្តស្ស** ព្រោះខ្លួនមានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន បានដល់ ដែលសិក្សាសិក្ខា ៣ មានអធិសីលសិក្ខាជាដើម អធិប្បាយថា នាំសេចក្តីសុខដែលគួរប្រាថ្នាមកឲ្យ ។

បទថា **យោគីបីតិករំ** បានដល់ ឈ្មោះថា ធ្វើឲ្យកើតបីតិដល់ព្រះយោគាវចរ ព្រោះនាំមកនូវបីតិដែលកើតអំពីឈាន និងវិបស្សនាជាដើមដល់ព្រះយោគាវចរទាំងឡាយ ដែលប្រកបព្យាយាមក្នុងភាវនា ដោយការមាន

សទ្ធាជាដើម ។ ឈ្មោះថា **រម្មំ** ព្រោះជាទីសមគួរដល់ការសម្ងំ ដោយមិនមានវិសភាគារម្មណ៍ដែលជាសត្រូវ ។

បទថា **មត្តកុញ្ជរសេវិតំ** បានដល់ ជាអ្នកត្រាច់ទៅរបស់ពួកដំរីចុះប្រេង ដោយបទនេះ កុលបុត្តនោះសម្តែងដល់លំនៅដែលស្ងាត់ចាកពួកជនប៉ុណ្ណោះ ព្រោះជាព្រៃធំ ។

កុលបុត្តនោះបំណងយកសមណធម៌ថា ប្រយោជន៍ក្នុងបទថា **អត្ថវសី** នេះ បានដល់ ធ្លាក់ក្នុងអំណាចនៃប្រយោជន៍នោះថា ធ្វើដូចម្តេចហ្ន៎ សមណធម៌នោះ គប្បីមានដល់អញ ដូច្នេះ ។

បទថា **សុបុប្ផិតេ** បានដល់ មានផ្ការីកដោយល្អ ។ បទថា **សីតវនេ** បានដល់ ក្នុងព្រៃដែលត្រជាក់ ព្រោះបរិបូរដោយម្លប់ និងទឹក ។ ដោយបទទាំង ២ កុលបុត្តនោះ សម្តែងដល់ទីឋាននោះថា គួរជាទីត្រេកអរនោះឯង ។

បទថា **គិរិកន្ទរេ** បានដល់ ក្នុងញកនៃភ្នំ ។ ពិតហើយ ទឹក លោកហៅថា **កំ** ទីរណ្តៅដែលទឹកទម្លុះហើយ ឈ្មោះថា **កន្ទរ** ។ កុលបុត្តនោះសម្តែងថា មិនជាប់ក្នុងទីណាមួយថា អាត្មាអញជាបុគ្គលតែឯង បន្ទាបន់នូវកំដៅក្នុងរដូវប្រាំង លាបស្រឡាបទឹកហើយ ចង្ក្រមត្រង់ញកភ្នំ ដ៏ត្រជាក់តែម្នាក់ឯង ។

បទថា **ឯកាកិយោ** បានដល់ តែម្នាក់ឯងមិនមានសម្លាញ់ ។

បទថា **អទុតិយោ** បានដល់ មិនមានសម្លាញ់ ព្រោះមិនមានសម្លាញ់ពោល គឺតណ្ហា ។ ពិតហើយ តណ្ហា ឈ្មោះថា ជាសម្លាញ់របស់បុរស

ព្រោះអត្ថថា មិនលះបង់ក្នុងកាលទាំងពួង ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ ( ខុទ្ទកនិកាយ ឥតិវុត្តក ) ថា បុរសមានតណ្ហាជាគម្រប់ពីរ កាលអន្ទោលទៅកាន់សង្សារអស់កាលដ៏វែង ដូច្នោះ ។

បទថា **ឯវំ មេ កត្តុកាមស្ស** សេចក្តីថា សូមបំណងរបស់ខ្ញុំដែលប្រាថ្នានឹងទៅព្រៃ ធ្វើការប្រកបសេចក្តីព្យាយាម ចម្រើនភាវនា ដោយវិធីដែលពោលហើយជាដើមថា បើដូច្នោះ អាត្មាអញតែម្នាក់ឯងនឹងទៅកាន់ព្រៃ ដូច្នេះ ។

បទថា **អធិប្បាយោ សមិជ្ឈតុ** សេចក្តីថា សូមមនោរថដែលប្រព្រឹត្តទៅហើយយ៉ាងនេះថា អង្កាល់ណា អាត្មាអញនឹងទៅជាបុគ្គលម្នាក់ឯង មិនមានបុគ្គលជាគម្រប់ពីរ មានសោឡសកិច្ចធ្វើហើយ ជាអ្នកមិនមានអាសវៈនៅក្នុងព្រៃធំដែលគួររីករាយ ដូច្នេះ ចូរសម្រេច គឺចូរដល់នូវការសម្រេចចុះ ។ ព្រោះការសម្រេចអរហត្ត នឹងសម្រេចត្រឹមតែការបន់ស្រន់ក៏មិនមែន ទាំងអ្នកដទៃ ក៏គប្បីឲ្យសម្រេចក៏មិនមែន ដូច្នោះ ទើបលោកពោលថា សូមសេចក្តីប៉ុនប៉ងរបស់អាត្មាអញ ដែលប្រាថ្នាដើម្បីធ្វើសេចក្តីព្យាយាមយ៉ាងនេះបានសម្រេច អាត្មាអញនឹងធ្វើឲ្យសម្រេច ( ព្រោះថា ) អ្នកដទៃ ធ្វើជួសអ្នកដទៃពុំបានទេ ដូច្នេះជាដើម ។

ព្រះរាជាទ្រង់ជ្រាបថា ឧបរាជមានប្រាថ្នាមាំទាំ ក្នុងការបួសយ៉ាងនេះ ទើបទ្រង់ត្រាស់ឲ្យមនុស្ស ប្រដាប់តាក់តែងផ្លូវទៅកាន់អសោការាម ហើយទ្រង់នាំកុមារដែលប្រដាប់ដោយអលង្ការទាំងពួង ទៅកាន់វិហារ ដោយរាជា-

នុភាពធំ មួយអន្ទើដោយសេនាធំ ។ ព្រះរាជកុមារទៅកាន់ផ្ទះសម្រាប់ព្យាយាមបួសក្នុងសម្នាក់ព្រះមហាជម្មរក្ខិតត្ថេរ ពួកមនុស្សប្រាប់រយនាក់ នាំគ្នាបួសតាមព្រះរាជកុមារនោះហើយ ។ សូម្បីអគ្គិព្រហ្មដែលជាក្មួយ និងជាស្វាមីរបស់ព្រះនាងសង្ឃមិត្តា ក៏ចេញបួសតាមព្រះរាជកុមារនោះដូចគ្នា ។ លុះព្រះរាជកុមារបួសហើយ មានចិត្តត្រេកអរ កាលប្រកាសដល់កិច្ចដែលខ្លួនគួរធ្វើ ទើបពោល ៣ គាថាថា

ឥឡូវនេះ អាត្មាអញនោះនឹងចងក្រោះ គឺព្យាយាម ហើយ
ចូលទៅកាន់ព្រៃ បើអាត្មាអញមិនទាន់សម្រេចនូវធម៌ ជាគ្រឿង
អស់អាសវៈទេ នឹងមិនចេញពីព្រៃនោះឡើយ ។ កាលបើខ្យល់
ត្រជាក់ មានក្លិនក្រអូបបក់ផ្សាយទៅ អាត្មាអញនឹងអង្គុយលើ
កំពូលភ្នំ ហើយទម្លាយអវិជ្ជាឲ្យបាន ។ អាត្មាអញទទួលសេចក្ដី
សុខ ដោយវិមុត្តិសុខក្នុងព្រៃ មានផ្កាដេរដាស ក្បែរញកភ្នំដ៏
ត្រជាក់ រួចហើយ នឹងត្រេកអរក្នុងក្រុងរាជគ្រឹះ មានភ្នំព័ទ្ធជុំវិញ
ដូចក្រោលគោ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឯស ពន្ធាមិ សន្នាហំ** សេចក្ដីថា ខ្ញុំនឹងចងក្រោះ គឺសេចក្ដីព្យាយាម បានដល់ ខ្ញុំមិនអាឡោះអាល័យក្នុងរាងកាយនិងជីវិត នឹងចងដោយក្រោះ គឺសេចក្ដីព្យាយាម ។ មានពាក្យអធិប្បាយថាប្រៀបដូចបុរសក្លាហាន មានបំណងនឹងយកឈ្នះពួកសត្រូវដែលបះបោរ ក៏លះបង់កិច្ចដទៃ ហើយសៀតគ្រឿងចម្បាំងដោយជុំវិញ មានអាវក្រោះជាដើម

ទៅកាន់យុទ្ធភូមិ ហើយបើមិនទាន់ឈ្នះសត្រូវ ក៏មិនត្រឡប់មកអំពីទីនោះ យ៉ាងណា សូម្បីខ្ញុំក៏ដូច្នោះដូចគ្នា បំណងយកឈ្នះពួកសត្រូវ គឺកិលេស មិនអាឡោះអាល័យដល់ក្បាល និងសំពត់ ទោះបីត្រូវភ្លើងឆេះដោយជុំវិញក៏ដោយ ក៏នៅតែចងក្រោះ គឺសេចក្តីព្យាយាម ដែលបានដល់សម្មប្បធាន ៤ បើមិនទាន់ឈ្នះកិលេស មិនព្រមលះបង់ទីស្ងាត់ យកឈ្នះតែកិលេសតែម្យ៉ាង ដោយហេតុនោះ ទើបលោកពោលថា ឥឡូវនេះ អាត្មាអញនោះនឹងចងក្រោះ គឺព្យាយាម ហើយចូលទៅកាន់ព្រៃ បើអាត្មាអញមិនទាន់សម្រេចនូវធម៌ ជាគ្រឿងអស់អាសវៈទេ នឹងមិនចេញពីព្រៃនោះឡើយ ដូច្នេះជាដើម ។

ដោយបទថា **មាលុតេ ឧបវាយន្តេ** ដូច្នេះជាដើម លោកពោលដល់ស្ថានទីដែលជាលំនៅក្នុងព្រៃថា សមគួរដល់ការបំពេញកម្មដ្ឋាន ប្រកបសេចក្តីថា ខ្ញុំនឹងគេ្រកអរក្នុងគុហានៃញកភ្នំពិតប្រាកដ អធិប្បាយថា លោកពោលចង្អុលដល់អនាគតកាលថា ខ្ញុំនឹងត្រេកអរត្រង់ជើងភ្នំ ។ ពាក្យដ៏សេសយល់បានងាយហើយនោះឯង ។

ព្រះថេរៈពោលយ៉ាងនោះហើយ ចូលទៅកាន់ព្រៃ បំពេញសមណធម៌ហើយ ទៅកាន់ដែនកលិង្គៈ មួយអន្លើដោយឧបជ្ឈាយ៍ ។ ក្នុងដែននោះ ព្រះថេរៈកើតរោគពងបែកត្រង់ជើង ។ គ្រូពេទ្យម្នាក់ឃើញហើយពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់រកសប្បិមកចុះ ខ្ញុំនឹងរក្សាព្យាបាលឲ្យលោកម្ចាស់ ។ ព្រះថេរៈមិនព្រមស្វែងរកសប្បិ គិតតែបំពេញវិបស្សនាតែម្យ៉ាង

រោគរើឡើង គ្រូពេទ្យឃើញថា ព្រះថេរៈមានសេចក្តីខ្វល់ខ្វាយតិចក្នុងរឿងនេះ ហើយខ្លួនឯងក៏ស្វែងរកសប្បិ ធ្វើព្រះថេរៈឲ្យជាសះស្បើយអំពីរោគ ។ ព្រះថេរៈនោះមិនមានរោគ ក្នុងកាលមិនយូរ ក៏សម្រេចអរហត្ត ។ សមដូចគាថាព័ន្ធដែលលោកពោលក្នុងអបទានថា

ព្រះសម្ពុទ្ធ ព្រះនាមកស្សបៈដោយគោត្រ ព្រះអង្គមានផៅពង្សប្រសើរ ទ្រង់មានយសប្រសើរជាងអ្នកប្រាជ្ញទាំងឡាយ ទ្រង់ត្រាស់ហើយក្នុងកទ្ទកប្បនេះ ។ ព្រះអង្គមិនមានធម៌នាំឲ្យយឺតយូរ មិនជាប់អារម្មណ៍ ទ្រង់មានព្រះហឫទ័យស្មើអាកាស ព្រះអង្គច្រើនទៅដោយធម៌ដ៏សូន្យចាកកិលេស ព្រះអង្គមិនញាប់ញ័រដោយលោកធម៌ ទ្រង់ត្រេកអរក្នុងអនិមិត្ត គង់នៅហើយ ។ ព្រះអង្គមានព្រះហឫទ័យមិនជាប់ចំពាក់ មិនមានកិលេសជាគ្រឿងលាបមិនប្រឡូកប្រឡំក្នុងត្រកូល និងពួកគណៈ ព្រះអង្គជាអ្នកប្រាជ្ញប្រកបដោយករុណាដ៏ធំ ទ្រង់ឈ្លាសវៃក្នុងឧបាយ ជាគ្រឿងណែនាំ ។ ព្រះអង្គប្រកបក្នុងកិច្ចរបស់បុគ្គលដទៃ ទ្រង់ទូន្មានពួកមនុស្ស ព្រមទាំងទេវតា ឲ្យទៅកាន់ផ្លូវជាទីទៅកាន់ព្រះនិព្វាន ជាគ្រឿងញ៉ាំងកក់ គឺគតិ ឲ្យរីងស្ងួត ។ ព្រះអង្គជាអ្នកចម្លងសត្វលោក ទ្រង់គង់នៅក្នុងកណ្តាលនៃបរិស័ទធំ ( ទ្រង់សម្តែង ) នូវអមតៈ គឺព្រះនិព្វាន ដែលជាគ្រឿងត្រេកអរយ៉ាងក្រៃលែងជាគ្រឿងរាំងរានូវជរា និងមរណៈបាន ។ ព្រះតថាគត ទ្រង់ជា

ទីពឹងនៃសត្វលោក ព្រះអង្គមានសំឡេងដូចសត្វករវិក មានសំឡេងគឹកកង ដូចជាសំឡេងនៃព្រហ្ម ទ្រង់ស្រោចស្រង់ពពួកសត្វ ដែលដល់ហើយនូវសេចក្ដីវិនាស មិនមានអ្នកដឹកនាំព្រះអង្គឲ្យរួចចាកទុក្ខធំ ។ ព្រះអង្គជានាយកនៃសត្វលោក ទ្រង់សម្ដែងធម៌ដ៏ប្រាសចាកធូលី ខ្ញុំបានឃើញហើយ ទាំងបានស្ដាប់ធម៌របស់ព្រះអង្គ ហើយចូលទៅកាន់ផ្នួស ។ លុះខ្ញុំបួសស្រេចហើយ ក៏ប្រឹងយកចិត្តទុកដាក់ នឹងសាសនានៃព្រះជិនស្រី ត្រូវសេចក្ដីជាប់ចំពាក់បៀតបៀន ក៏នៅក្នុងព្រៃជាទីរីករាយតែម្នាក់ឯង ។ ការចេញចាកពួកដោយកាយរបស់ខ្លួននៃខ្ញុំ ជាហេតុនៃការចេញចាកពួកដោយចិត្តនៃខ្ញុំ ដែលជាអ្នកឃើញភ័យក្នុងការជាប់ចំពាក់ក៏មានមកដល់ខ្ញុំ ។ កិលេសទាំងឡាយ ខ្ញុំដុតចោលហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ ។

កាលព្រះថេរៈសម្រេចអរហត្តហើយ នៅក្នុងដែនកលិង្គៈនោះ ព្រះរាជាទ្រង់បរិច្ចាគទ្រព្យមួយកោដិ ឲ្យសាងវិហារឈ្មោះ **ភោជកគិរិវិហារ** រួចទ្រង់និមន្តព្រះថេរៈឲ្យនៅក្នុងវិហារនោះ ។

ព្រះថេរៈនោះ នៅក្នុងវិហារនោះ ក្នុងកាលជិតបរិនិព្វាន បានពោល

គាថាចុងក្រោយថា

អាត្មាអញនោះ មានតម្រិះគ្រប់គ្រាន់ ដូចព្រះចន្ទក្នុងថ្ងៃ ១៥ កើត

អស់អាសវៈទាំងពួងហើយ ឥឡូវនេះ ភពថ្មីមិនមានទេ ដូច្នេះ ។

គាថានោះ មានអត្ថងាយយល់ហើយ គាថានោះ បានជាការព្យាករ

អរហត្តរបស់ព្រះថេរៈនោះឯង ។ល។

**អដ្ឋកថា ឯកវិហារិយត្ថេរគាថា ចប់**

# សុត្តន្តបិដក

## មហាកប្បិនត្ថេរគាថា

[ ២៣៦ ] បុគ្គលណា ពិចារណាឃើញនូវកិច្ចជាប្រយោជន៍ និង មិនជាប្រយោជន៍ទាំងពីរនោះ ដែលមិនទាន់មកដល់ទុកជាមុន ជនទាំងឡាយ ជាសត្រូវក្តី ជាអ្នកស្វែងរកប្រយោជន៍ក្តី កាលគយគន់មើល រមែងមិនឃើញនូវទោសនៃបុគ្គលនោះឡើយ ។ អានាបានស្សតិ ដែលព្រះយោគាវចរណា បានចម្រើនល្អគ្រប់គ្រាន់ហើយ បានសន្សំហើយ តាមលំដាប់ ដូចព្រះពុទ្ធទ្រង់សម្តែងមក ព្រះយោគាវចរនោះ រមែងញុំាងលោកនេះ ឲ្យភ្លឺច្បាស់ ដូចព្រះចន្ទ្រផុតចាកពពក ។ ឱ ចិត្តរបស់អញស រកប្រមាណមិនបាន អាត្មាអញ បានអប់រំល្អហើយផង បានផ្គងជានិច្ចផង ញុំាងទិសទាំងពួងឲ្យភ្លឺផង ។ បុគ្គលប្រកបដោយប្រាជ្ញា បើទុកជាឲ្យអស់ទ្រព្យរលីង ក៏ឈ្មោះថារស់នៅ ឯបុគ្គលអ្នកមានទ្រព្យ មិនឈ្មោះថារស់នៅ ព្រោះកិរិយាមិនបាននូវប្រាជ្ញា ។ ប្រាជ្ញាជាគ្រឿងវិនិច្ឆ័យនូវសុតៈ ប្រាជ្ញាជាគ្រឿងញុំាងកិត្តិសព្ទ និងសេចក្តីសរសើរឲ្យចម្រើន នរជនប្រកបដោយប្រាជ្ញា រមែងបាននូវសេចក្តីសុខ សូម្បីក្នុងសភាវៈដែលជាទុក្ខ ។ ធម៌នេះមិនមែនជាធម៌ទើបនឹងមាន ក្នុងថ្ងៃនេះទេ ជាធម៌មិនអស្ចារ្យ មិនមែនជាធម៌ចម្លែកទេ សត្វកើតស្លាប់ ក្នុងលោកណា ហេតុតិចតួច ក៏មិនចម្លែក ក្នុងលោកនោះ ។ សេចក្តីពិតថា បន្ទាប់អំពីការកើតមក មានសេចក្តីស្លាប់ចាកជីវិត ជាធម្មជាតទៀងទាត់

សត្វទាំងឡាយ ដែលកើតហើយៗ រមែងស្លាប់ ក្នុងលោកនេះ ព្រោះថា សត្វទាំងឡាយ មានសភាពយ៉ាងនេះឯង ។ សេចក្តីសោកស្តាយណា របស់បុរសបុគ្គលទាំងឡាយដទៃ ដើម្បីជីវិត សេចក្តីសោកស្តាយនុ៎ះ មិនមែនដើម្បីប្រយោជន៍ដល់សត្វ ដែលស្លាប់ទៅហើយទេ ការយំចំពោះសត្វដែលស្លាប់ហើយ មិនមែនជាយស មិនមែនជាការល្អទេ សមណព្រាហ្មណ៍ទាំងឡាយ មិនសរសើរការយំឡើយ ។ ការយំ រមែងបៀតបៀននូវចក្ខុ និងសរីរៈ ( របស់បុគ្គលអ្នកយំ ) ពណ៌សម្បុរក្តី កម្លាំងក្តី ប្រាជ្ញាក្តី នៃអ្នកយំ រមែងសាបសូន្យ ពួកសត្រូវរបស់បុគ្គលអ្នកយំនោះ ក៏មានសេចក្តីត្រេកអរ ពួកបុគ្គលអ្នកស្វែងរកប្រយោជន៍ ឲ្យបុគ្គលអ្នកយំនោះបាននូវសេចក្តីទុក្ខ ។ ព្រោះហេតុនោះ ពួកជន ឆ្លងនូវកិច្ច ( របស់ខ្លួន ) ដោយកម្លាំងប្រាជ្ញា របស់អ្នកប្រាជ្ញទាំងឡាយណា ដូចពួកជនឆ្លងនូវទន្លេ មានទឹកពេញដោយទូក បុគ្គលគប្បីប្រាថ្នានូវពួកអ្នកប្រាជ្ញជាពហុស្សូតនោះ ឲ្យនៅក្នុងត្រកូល ( របស់ខ្លួន ) ។

**មហាកប្បិនត្ថេរ**

# អដ្ឋកថា

## មហាកប្បិនត្ថេរគាថា

[ ២៣៦ ] គាថារបស់ព្រះមហាកប្បិនត្ថេរ មានពាក្យផ្ដើមថា **អនាគតំ យោ បដិកច្ច បស្សតិ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា ក្នុងសាសនាព្រះមានព្រះភាគ ព្រះនាមបទុមុត្តរៈ ព្រះមហាកប្បិនត្ថេរនេះ កើតក្នុងផ្ទះមានត្រកូល ក្នុងនគរហង្សវតី ដល់នូវភាពជាអ្នកដឹងក្ដីហើយ ស្ដាប់ធម៌ក្នុងសម្នាក់ព្រះសាស្ដា ឃើញព្រះសាស្ដាទ្រង់តាំងភិក្ខុមួយរូប ក្នុងតំណែងឯតទគ្គៈថា ជាកំពូលជាងភិក្ខុទាំងឡាយ ខាងឲ្យឱវាទដល់ភិក្ខុ ទើបធ្វើបុញ្ញាធិការដែលជាហេតុបានតំណែងនោះ ហើយប្រាថ្នាតំណែងនោះ ។

កុលបុត្តនោះបំពេញកុសលក្នុងភពនោះ ដរាបដល់អស់ជីវិត អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងសាសនាព្រះសម្ពុទ្ធព្រះនាមកស្សបៈ កើតក្នុងផ្ទះមានត្រកូល ក្នុងក្រុងពារាណសី ដល់នូវភាពជាអ្នកដឹងក្ដីហើយ បានជាប្រធានបុរស ១០០០ នាក់ រួមគ្នាសាងមហាបរិវេណ ដែលប្រកបដោយបន្ទប់ ១០០០ ជនទាំងអស់នោះ ធ្វើកុសលដរាបដល់អស់ជីវិត មួយអន្ទើដោយបុត្ត និងភរិយា មានឧបាសកនោះជាប្រធាន ទៅកើតក្នុងទេវលោក អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ អស់មួយពុទ្ធន្តរ ។

ក្នុងមនុស្សទាំងនោះ មុនព្រះសាស្ដានៃយើង ទ្រង់កើតឡើងនោះឯង បុរសជាប្រធាន កើតឡើងក្នុងព្រះរាជវាំង ក្នុងនគរឈ្មោះកុក្កុដៈ ក្នុងបច្ចន្ត-

ប្បទេស មានឈ្មោះថា **កប្បិន** ។

ពួកបុរសដ៏សេស កើតក្នុងត្រកូលអមាត្យ ក្នុងនគរនោះឯង លុះព្រះរាជបិតាសោយទិវង្គតទៅ កប្បិនកុមារទ្រង់បានទទួលស្វេតច្ឆត្រ ជាព្រះបាទមហាកប្បិន ។ ព្រះបាទមហាកប្បិននោះ ទ្រង់ដាក់ព្រះហឫទ័យក្នុងការសិក្សា ទើបទ្រង់បញ្ជូនទូតទៅតាមទ្វារទាំង ៤ ដោយបួសរាន់អំពីព្រលឹមថា ពួកអ្នកឃើញអ្នកចេះដឹងក្នុងទីណា ចូរត្រឡប់អំពីទីនោះ មកប្រាប់យើង ។

សម័យនោះ ព្រះសាស្តានៃយើងទ្រង់កើតក្នុងលោកហើយ ទ្រង់អាស្រ័យក្រុងសាវត្ថីគង់នៅ ។ ក្នុងកាលនោះ ពួកឈ្មួញអ្នកក្រុងសាវត្ថី នាំទំនិញដែលធ្វើក្នុងក្រុងសាវត្ថី ទៅកាន់កុក្កុដនគរលក់នូវទំនិញហើយ គិតថា ពួកយើងនឹងចូលគាល់ព្រះរាជា ហើយនាំគ្នាកាន់បណ្ណាការទៅ ក្រាបទូលដល់ព្រះរាជា ។ ព្រះរាជាទ្រង់ឲ្យហៅជនទាំងនោះមកហើយ កាលពួកជនទាំងនោះថ្វាយបណ្ណាការហើយ ឈរគាល់ ទើបត្រាស់សួរថា ពួកអ្នកមកអំពីណា ឈ្មួញទាំងនោះក្រាបទូលថា ទូលបង្គំមកអំពីក្រុងសាវត្ថី ។ ព្រះរាជាត្រាស់សួរថា ឯដែនរបស់អ្នកមានកិក្ខារកបានងាយឬ ព្រះរាជាតាំងនៅក្នុងធម៌ឬ ពួកឈ្មួញក្រាបទូលថា ករុណាថ្លៃវិសេស ។ ព្រះរាជាត្រាស់សួរថា ក្នុងប្រទេសរបស់ពួកអ្នក មានធម៌ដូចម្តេចដែលកំពុងប្រព្រឹត្តទៅក្នុងឥឡូវនេះ ។ ពួកឈ្មួញក្រាបទូលថា បពិត្រព្រះសម្មតិទេព សេចក្តីនោះ ពួកខ្ញុំព្រះអង្គមិនអាចក្រាបទូលទាំងមាត់សៅហ្មងបានឡើយ ។ ព្រះរាជាក៏ប្រទានទឹកដោយព្រះសុវណ្ណកិង្គា ។ ពួកឈ្មួញទាំងនោះខ្ពុរមាត់ហើយ បែរមុខទៅរក

ទិសដែលព្រះទសពលគង់នៅ ផ្គងអញ្ជលីហើយ ក្រាបទូលថា បពិត្រព្រះសម្មតិទេព ពុទ្ធរតនៈកើតឡើងហើយ ក្នុងប្រទេសរបស់ពួកទូលបង្គំ ។

ត្រឹមតែបានស្តាប់ពាក្យថា **ពុទ្ធោ** ប៉ុណ្ណោះ បីតិក៏កើតឡើងផ្សាយទូទៅពេញព្រះសរីរៈទាំងមូលរបស់ព្រះរាជា ។ បន្ទាប់អំពីនោះ ព្រះរាជាក៏ត្រាស់ថា បាទាំងឡាយ ចូរពោលពាក្យថា **ពុទ្ធោ** ទៀតចុះ ពួកឈ្មួញក្រាបទូលថា បពិត្រព្រះសម្មតិទេព ពួកខ្ញុំព្រះអង្គសូមពោលជដែលទៀតថា **ពុទ្ធោ** ។ ព្រះរាជាត្រាស់ឲ្យពួកឈ្មួញពោលយ៉ាងនោះអស់វារៈ ៣ ដង ទ្រង់ជ្រះថ្លាក្នុងបទនោះឯងថា បទថា **ពុទ្ធោ** ជាបទដែលមានគុណប្រមាណមិនបាន ដូច្នេះហើយព្រះរាជទានទ្រព្យមួយសែន ត្រាស់សួរថា នែបាទាំងឡាយ ចូរបានាំគ្នាពោលបទដទៃទៀតចុះ ពួកឈ្មួញក្រាបទូលថា បពិត្រព្រះសម្មតិទេព ព្រះធម្មរតនៈកើតឡើងហើយក្នុងលោក ព្រះរាជាស្តាប់បទនោះហើយ ព្រះរាជ-ទានទ្រព្យមួយសែនដូចគ្នា ហើយត្រាស់សួរថា នែបា ចូរពោលបទដទៃទៀតចុះ ពួកឈ្មួញក្រាបទូលថា បពិត្រព្រះសម្មតិទេព ព្រះសង្ឃរតនៈកើតឡើងហើយ ព្រះរាជាទ្រង់ស្តាប់បទនោះហើយ ព្រះរាជទានទ្រព្យមួយសែន ហើយយាងចេញអំពីទីនោះដោយតាំងព្រះហឫទ័យថា អញនឹងបួសក្នុងសម្នាក់របស់ព្រះពុទ្ធ ។

ពួកអមាត្យក៏ចេញទៅហើយយ៉ាងនោះដូចគ្នា ។ ព្រះរាជា មួយអន្លើដោយអមាត្យ ១០០០ យាងដល់ឆ្នេរស្ទឹងហើយ ទ្រង់ធ្វើសច្ចាធិដ្ឋានថា បើព្រះសាស្តាទ្រង់ជាព្រះសម្មាសម្ពុទ្ធសោត សូមទឹកកុំសើមត្រឹមក្រចកជើងសេះ

ទាំងនេះឡើយ ហើយទ្រង់ធ្វូងស៊ីងដែលពេញប្រៀប ដោយសេះនោះឯង ព្រះរាជាធ្វូងស៊ីងដទៃទៀត ដែលមានទទឹងកន្លះយោជន៍ក៏ទ្រង់ធ្វើយ៉ាងនោះដូចគ្នា ទ្រង់ដល់ស៊ីងទី ៣ ឈ្មោះចន្ទភាគា ហើយធ្វូងស៊ីងនោះ ដោយធ្វើសច្ចាធិដ្ឋានដូចគ្នា ។

ក្នុងកាលទៀបភ្លឺថ្ងៃនោះឯង ព្រះសាស្តាទ្រង់ចេញអំពីព្រះមហាករុណាសមាបត្តិហើយ ទ្រង់ប្រមើលមើលលោក ទ្រង់ឃើញថា ថ្ងៃនេះ ព្រះបាទមហាកប្បិនទ្រង់លះរាជសម្បត្តិ និងអាណាចក្រដែលមានទំហំ ៣០០ យោជន៍មួយអន្លើដោយអមាត្យជាបរិវារ ១០០០ នាក់ ហើយធ្វើដំណើរមកដើម្បីបួសក្នុងសម្នាក់របស់តថាគត ហើយទ្រង់ត្រិះរិះថា តថាគតគួរទទួលជនទាំងនោះ ទើបទ្រង់ជម្រះសរីរៈអំពីព្រលឹម មានភិក្ខុសង្ឃចោមរោមហើយយាងទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី ត្រឡប់អំពីបិណ្ឌបាត ខាងក្រោយភត្តយាងទៅតាមអាកាស មួយព្រះអង្គឯងប៉ុណ្ណោះ គង់ពត់ភ្នែនត្រង់គល់មហានិគ្រោធ ក្បែរឆ្នេរស្ទឹងចន្ទភាគា ទ្រង់បញ្ចេញព្រះពុទ្ធរស្មី មានពណ៌ ៦ ឆ្ពោះទៅត្រង់ទីឡើងច្រាំងរបស់ជនទាំងនោះ ។

ខណៈធ្វូងស៊ីង ព្រះរាជា និងអមាត្យទាំងនោះ ឃើញព្រះពុទ្ធរស្មីផ្សាយទៅក្នុងទិសផ្សេងៗ ព្រះរាជាឃើញព្រះមានព្រះភាគ ទ្រង់ក៏សន្និដ្ឋានដោយការឃើញប៉ុណ្ណោះថា ពួកយើងមកឧទ្ទិសព្រះសាស្តាអង្គណា បុរសនេះ គឺព្រះសាស្តាអង្គនោះពិត ដូច្នេះហើយ តាំងអំពីកាលដែលឃើញហើយ ក៏បន្អោនកាយ ធ្វើសេចក្តីគោរពក្រៃលែង ចូលទៅគាល់ព្រះមានព្រះភាគ ទ្រង់

ចាប់កព្រះបាទរបស់ព្រះមានព្រះភាគហើយ ថ្វាយបង្គំព្រះសាស្តា ប្រថាប់គង់មួយអន្លើដោយអមាត្យ ១០០០ នាក់ ក្នុងទីសមគួរនាចំណែកម្ខាង ។ ព្រះសាស្តាទ្រង់សម្តែងធម៌ដល់ជនទាំងនោះហើយ ក្នុងកាលចប់ព្រះធម្មទេសនា ព្រះរាជា មួយអន្លើដោយបរិស័ទ តាំងនៅក្នុងអរហត្តផល សមដូចគាថាព័ន្ធដែលលោកពោល ក្នុងអបទានថា

ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ទ្រង់ដល់នូវត្រើយ នៃធម៌ទាំងពួង ទ្រង់រុងរឿងដូចព្រះអាទិត្យ រះឡើងពួដ៏អជជាកាស ក្នុងសរទ-កាល ។ ព្រះអង្គទ្រង់ញុាំងផ្កាឈូក គឺពួកវិនេយ្យសត្វ ឲ្យរីកដោយពន្លឺ គឺព្រះពុទ្ធដីកា ព្រះនាយកទ្រង់ញុាំងភក់ គឺកិលេសឲ្យរីងស្ងួតដោយរស្មី គឺប្រាជ្ញា ។ ព្រះនាយកទ្រង់សម្លាប់យសរបស់ពួកតិរ្ថិយដោយប្រាជ្ញា ដូចកែវរជីរ ព្រះអង្គប្រកាសធម៌ក្នុងទីទាំងពួង ដូចព្រះអាទិត្យញុាំងយប់ និងថ្ងៃឲ្យភ្លឺសព្វ ។ ព្រះអង្គជាទីកើតនៃគុណទាំងឡាយ ដូចជាសាគរជាទីកើតនៃរតនៈទាំង-ឡាយ ទ្រង់តែងបង្អុរភ្លៀង គឺធម៌ឲ្យដល់ពួកសត្វ ដូចមេឃបង្អុរភ្លៀង ។ កាលនោះ ខ្ញុំជាចៅក្រម ( អ្នកកាត់ក្តី ) ក្នុងនគរឈ្មោះហង្សវតី បានចូលទៅស្តាប់ធម៌របស់ព្រះមុនី ព្រះនាមបទុមុត្តរៈដែលកំពុងប្រទានឱវាទដល់ពួកភិក្ខុ កំពុងប្រកាសនូវគុណនៃសាវ័ក អ្នកមានសតិ ទ្រង់ញុាំងចិត្តរបស់ខ្ញុំឲ្យរីករាយ ។ ខ្ញុំបាន

ស្តាប់ហើយ ក៏មានបីតិ មានចិត្តរីករាយ និមន្តព្រះតថាគត ព្រម ទាំងភិក្ខុជាសិស្សឲ្យឆាន់ ហើយប្រាថ្នានូវតំណែងនោះ ។ កាល នោះ ព្រះនាយកទ្រង់មានចំណែកប្រៀបស្មើដោយសត្វហង្ស ទ្រង់ បញ្ចេញព្រះវាចាដូចជាស្គរ មានសំឡេងដូចសត្វហង្ស ដូច្នេះថា

អ្នកទាំងឡាយ ចូរមើលមហាមាត្យនុ៎ះ ជាអ្នកក្លៀវក្លាក្នុងការ កាត់ក្តី ជាអ្នកមានរោមរៀវ មានចុងង មានភ្នែក និងមុខស្រស់ បស់ល្អ រុងរឿងដូចសម្បុរកែវជួមុត្ត កំពុងក្រាបទៀបបាទមូលនៃ តថាគត ជាអ្នកមានយសធំ ដោយបរិវារច្រើន ដែលស្តេចទ្រង់ ប្រទានឲ្យ ឯមហាមាត្យនុ៎ះ ប្រាថ្នានូវតំណែងរបស់ភិក្ខុដែលជា អ្នកឈ្លាសក្នុងពាក្យ ដោយចិត្តរីករាយ មហាមាត្យនុ៎ះនឹងមិនទៅ កាន់ទុគ្គតិអស់មួយសែនកប្ប ដោយចង្ហាន់បិណ្ឌបាតនេះផង ដោយ ការបរិច្ចាគនេះផង ដោយការតាំងសេចក្តីប្រាថ្នានេះផង ។ មហា-មាត្យនុ៎ះនឹងទទួលនូវសួស្តីរបស់ទេវតា ក្នុងទេវលោក នូវភាពជា ធំក្នុងមនុស្ស នឹងបានដល់នូវព្រះនិព្វានដោយសេសសល់នៃផល ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រះសាស្តាព្រះនាមគោតម ទ្រង់កើតក្នុងត្រកូលក្សត្រឱក្កាកៈ នឹងត្រាស់ឡើងក្នុងលោក ។ ឯ មហាមាត្យនេះ នឹងបានជាធម្មទាយាទរបស់ព្រះគោតមនោះ ជា ឱរស ជាធម្មនិម្មិត មាននាមថាកប្បិនៈ ជាសាវ័ករបស់ព្រះ សាស្តានោះ ។

លំដាប់នោះ ខ្ញុំធ្វើសក្ការៈដ៏ល្អក្នុងសាសនារបស់ព្រះជិនស្រី លុះខ្ញុំលះរាងកាយជារបស់មនុស្សហើយ ទៅកើតក្នុងឋានតុសិត ។ ខ្ញុំបានគ្រប់គ្រងនូវទេវរាជសម្បត្តិ និងមនុស្សរាជសម្បត្តិដោយស្កប់ស្កល់ហើយ ទើបខ្ញុំមកកើតក្នុងកំណើតគេហបតិយៈ ជិតក្រុងពារាណសី ។ ខ្ញុំមានបរិវារមួយសែន មានភរិយា បានចូលទៅបម្រើព្រះបច្ចេកពុទ្ធ ៥០០ អង្គ ។ យើងខ្ញុំទាំងអស់គ្នា ញុំាងព្រះបច្ចេកពុទ្ធឲ្យឆាន់ផង ឲ្យស្លៀកពាក់ត្រៃចីវរផងអស់ ៣ ខែ ទើបច្យុតចាកអត្តភាពនោះ ទៅកើតក្នុងឋានតាវត្តិង្ស ។ យើងទាំងអស់ច្យុតចាកទេវតានោះ មកកាន់អត្តភាពរបស់មនុស្ស កើតក្នុងកុក្កុដបុរី ជិតព្រៃហិមពាន្ត ។ ខ្ញុំជារាជបុត្រមាននាមថា កប្បិនៈ មានយសធំ ឯទេវតាដ៏សេស មកកើតក្នុងត្រកូលអាមាត្យហែហមខ្ញុំ ខ្ញុំដល់នូវសេចក្ដីសុខ ដោយរាជសម្បត្តិដ៏ធំ សម្រេចសេចក្ដីប្រាថ្នាទាំងពួង ខ្ញុំបានឮនូវការកើតឡើងនៃព្រះពុទ្ធ ដោយពួកពាណិជប្រាប់ថា ព្រះពុទ្ធត្រាស់ឡើងហើយក្នុងលោក ទ្រង់ជាបុគ្គលឯក ឥតមានបុគ្គលស្មើ ព្រះអង្គនោះទ្រង់ប្រកាសនូវព្រះសទ្ធម្ម គឺអមតៈ ជាសុខដ៏ឧត្តម ។ ឯពួកសិស្សរបស់ព្រះសម្ពុទ្ធអង្គនោះ ប្រកបព្យាយាមល្អ រួចស្រឡះចាកកិលេស ជាអ្នកមិនមានអាសវៈ លុះខ្ញុំស្ដាប់ពាក្យរបស់ពាណិជទាំងនោះហើយ ក៏ធ្វើសក្ការៈចំពោះពួកពាណិជនោះ ។ ខ្ញុំ ព្រមទាំងអាមាត្យជាអ្នករាប់

អានព្រះពុទ្ធ ស៊ូលះរាជ្យ ចេញដើរទៅ បានឃើញស្ទឹងមហាចន្ទា មានទឹកពេញប្រៀប ។ ជាស្ទឹងមិនមានកំពង់ មិនមានឈើស្ពួ ( ស្ពាន ) គេឆ្លងបានដោយក្រ ជាស្ទឹងមានខ្សែទឹករហ័ស ខ្ញុំរឭកគុណព្រះសម្ពុទ្ធហើយ ក៏ឆ្លងបានដោយសួស្តី ដោយគិតថា ប្រសិនបើព្រះសម្ពុទ្ធទ្រង់ឆ្លងនូវខ្សែទឹក គឺភពរួចហើយ ដល់នូវព្រះនិព្វានជាទីបំផុតនៃលោក ទ្រង់ជ្រាបច្បាស់ ( ត្រាស់ឡើងពិតមែន ) ដំណើររបស់ខ្ញុំ សូមឲ្យសម្រេចដោយពាក្យសច្ចៈនេះ ។ ប្រសិនបើមគ្គ ជាដំណើរទៅកាន់ទីស្ងប់រម្ងាប់ ជាទីឲ្យនូវការរួចស្រឡះកិលេស ជាទីស្ងប់រម្ងាប់ ជាទីសុខ ( មានពិតមែន ) ដំណើររបស់ខ្ញុំ សូមឲ្យសម្រេចដោយពាក្យសច្ចៈនេះ ។ ប្រសិនបើព្រះសង្ឃជាអ្នកឆ្លងផុតផ្លូវលំបាករួចហើយ ជាបុញ្ញក្ខេត្តដ៏ប្រសើរ ( មានពិតមែន ) ដំណើររបស់ខ្ញុំ សូមឲ្យសម្រេចដោយពាក្យសច្ចៈនេះ ។ លុះខ្ញុំធ្វើសច្ចៈដ៏ប្រសើររួចហើយ ទឹកស្ទឹងក៏រីងខះអស់អំពីផ្លូវ លំដាប់នោះ ខ្ញុំឆ្លងឡើងលើត្រើយស្ទឹងជាទីមនោរម្យដោយសុវត្ថិភាព ។ ខ្ញុំបានឃើញព្រះពុទ្ធទ្រង់គង់នៅ មានរស្មីដូចព្រះអាទិត្យដែលរះឡើង ទ្រង់រុងរឿងដូចភ្នំមាស មានពន្លឺដូចដើមឈើប្រចាំទ្វីប ។ មានពួកសាវកចោមរោម ដូចព្រះចន្ទដែលប្រកបដោយពួកផ្កាយ ឬដូចជាទឹកហូរ ដែលទេវតាបង្អុរចុះមកទ្រង់ជាទីរីករាយរបស់ពួកជន ។ ខ្ញុំ ព្រមទាំងអាមាត្យ លុះថ្វាយ

បន្តំហើយ ចូលទៅកាន់ទីសមគួរ លំដាប់នោះ ព្រះសម្ពុទ្ធទ្រង់ជ្រាបអធ្យាស្រ័យហើយ បានសំដែងធម៌ ។ លុះយើងខ្ញុំស្តាប់ធម៌ស្អាត មិនមានមន្ទិល ទើបក្រាបទូលព្រះជិនស្រីថា បពិត្រព្រះអង្គដ៏ទ្រង់ព្យាយាមធំ សូមព្រះអង្គបំបួសយើងខ្ញុំ នឹងធ្ងន់កពទាំងឡាយ ។ ព្រះសម្ពុទ្ធជាព្រះមុនីទី ៧ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ធម៌ដែលតថាគតពោលល្អហើយ ដល់អ្នកទាំងឡាយ ជាធម៌ប្រព្រឹត្តទៅដើម្បីធ្វើនូវព្រះនិព្វាន ជាទីបំផុតនៃកងទុក្ខ អ្នកទាំងឡាយ ចូរប្រព្រឹត្តព្រហ្មចរិយៈចុះ ។ ពួកយើងខ្ញុំទាំងអស់ ទ្រទ្រង់ភេទជាភិក្ខុ ដំណាលនឹងព្រះពុទ្ធដីកា លុះបានឧបសម្បទាហើយ ក៏បានជាសោតាបន្នបុគ្គលក្នុងសាសនា ។ លំដាប់នោះ ព្រះនាយកទ្រង់ស្តេចទៅកាន់វត្តជេតពន ទ្រង់ប្រៀនប្រដៅខ្ញុំ ឯខ្ញុំដែលព្រះជិនស្រីទ្រង់ប្រៀនប្រដៅហើយ ក៏បានដល់នូវព្រះអរហត្ត ។ លំដាប់នោះ ខ្ញុំប្រដៅពួកភិក្ខុមួយពាន់រូប ពួកភិក្ខុទាំងមួយពាន់នោះ ធ្វើតាមពាក្យប្រៀនប្រដៅរបស់ខ្ញុំ ក៏ទៅជាអ្នកមិនមានអាសវៈ ក្នុងកាលនោះ ។ ព្រះជិនស្រីទ្រង់ត្រេកអរក្នុងគុណនោះ ទ្រង់តាំងខ្ញុំក្នុងទីជាឯតទគ្គៈក្នុងកណ្តាលមហាជនថា កប្បិនភិក្ខុ ជាកំពូលនៃពួកសាវ័កអ្នកឲ្យឱវាទភិក្ខុ ។ ព្រះជិនស្រីទ្រង់សំដែងផលកម្ម ដែលខ្ញុំធ្វើហើយ ក្នុងកប្បទីមួយសែន ក្នុងសាសនានេះ ខ្ញុំមានចិត្តរួចស្រឡះហើយ ដូចជាសន្ទុះនៃកូនសរ

ខ្ញុំដុតកិលេសទាំងឡាយរបស់ខ្ញុំហើយ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ ។

ជនទាំងនោះ កាលសម្រេចអរហត្តហើយ ទើបនាំគ្នាសូមបួសជាមួយព្រះសាស្តា ព្រះសាស្តាត្រាស់នឹងជនទាំងនោះថា ចូរពួកអ្នកជាភិក្ខុចុះ បព្វជ្ជានិងឧបសម្បទានោះឯង មានហើយដល់ជនទាំងនោះ ដោយព្រះតម្រាស់នេះ ។ ព្រះសាស្តាទ្រង់នាំភិក្ខុ ១០០០ អង្គនោះ ទៅកាន់វត្តជេតពន តាមអាកាស ។

សម័យថ្ងៃមួយ ព្រះមានព្រះភាគ ត្រាស់សួរភិក្ខុដែលជាអន្តេវាសិកនៃព្រះមហាកប្បិននោះថា ម្នាលភិក្ខុទាំងឡាយ កប្បិនសម្តែងធម៌ដល់ភិក្ខុទាំងឡាយខ្លះដែរឬទេ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះថេរៈមិនសម្តែង លោកជាអ្នកខ្វល់ខ្វាយតិច ប្រកបព្យាយាមដោយសេចក្តីសុខក្នុងទិដ្ឋធម៌ មិនព្រមឲ្យឱវាទត្រឹមតែម្តង ដូច្នេះ ។ ព្រះសាស្តាទ្រង់ឲ្យហៅព្រះថេរៈមកហើយ ត្រាស់សួរថា ម្នាលកប្បិន បានឮថា អ្នកមិនព្រមឲ្យសូម្បីត្រឹមតែឱវាទដល់ពួកអន្តេវាសិក ពិតមែនឬទេ ព្រះថេរៈក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពិតមែន ។ ព្រះសាស្តាត្រាស់ថា ម្នាលព្រាហ្មណ៍ អ្នកកុំធ្វើយ៉ាងនោះឡើយ តាំងអំពីថ្ងៃនេះទៅ ចូរអ្នកសម្តែងធម៌ដល់ពួកភិក្ខុដែលចូលទៅរក ។ ព្រះថេរៈទទួលព្រះតម្រាស់ព្រះសាស្តា ដោយសិរសាគឺត្បូងថា សាធុ ព្រះអង្គ ហើយឲ្យសមណៈ ១០០០ តាំងនៅក្នុងអរហត្ត

ដោយឱវាទត្រឹមតែមួយប៉ុណ្ណោះ ។ ដោយហេតុនោះ ទើបព្រះសាស្តាតាំងព្រះថេរៈដែលជាសាវករបស់ព្រះអង្គតាមលំដាប់ ទើបទ្រង់តាំងព្រះថេរៈក្នុងតំណែងឯតទគ្គៈថា ជាកំពូលជាងភិក្ខុទាំងឡាយអ្នកឲ្យឱវាទភិក្ខុ ។ ថ្ងៃមួយព្រះថេរៈកាលទូន្មានភិក្ខុនីទាំងឡាយ ទើបពោលគាថាទាំងនេះថា

បុគ្គលណា ពិចារណាឃើញនូវកិច្ចជាប្រយោជន៍ និងមិនជាប្រយោជន៍ទាំងពីរនោះ ដែលមិនទាន់មកដល់ទុកជាមុន ជនទាំងឡាយ ជាសត្រូវក្តី ជាអ្នកស្វែងរកប្រយោជន៍ក្តី កាលគយគន់មើល រមែងមិនឃើញ នូវទោសនៃបុគ្គលនោះឡើយ ។ អានាបានស្សតិ ដែលព្រះយោគាវចរណា បានចម្រើនល្អគ្រប់គ្រាន់ហើយ បានសន្សំហើយ តាមលំដាប់ ដូចព្រះពុទ្ធទ្រង់សម្តែងមក ព្រះយោគាវចរនោះ រមែងញុំាងលោកនេះ ឲ្យភ្លឺច្បាស់ ដូចព្រះចន្ទផុតចាកពពក ។ ឱ ចិត្តរបស់អញ សរកប្រមាណមិនបាន អាត្មាអញ បានអប់រំល្អហើយផង បានផ្គងជានិច្ចផង ញុំាងទិសទាំងពួងឲ្យភ្លឺផង ។ បុគ្គលប្រកបដោយប្រាជ្ញា បើទុកជាឲ្យអស់ទ្រព្យរលីង ក៏ឈ្មោះថា រស់នៅ ឯបុគ្គលអ្នកមានទ្រព្យ មិនឈ្មោះថារស់នៅ ព្រោះកិរិយាមិនបាននូវប្រាជ្ញា ។ ប្រាជ្ញាជាគ្រឿងវិនិច្ឆ័យនូវសុតៈ ប្រាជ្ញាជាគ្រឿងញុំាងកិត្តិសព្ទ និងសេចក្តីសរសើរឲ្យចម្រើន នរជនប្រកបដោយប្រាជ្ញា រមែងបាននូវសេចក្តីសុខ សូម្បីក្នុងសភាវៈដែលជាទុក្ខ ។ ធម៌នេះមិនមែនជាធម៌ទើបនឹងមាន ក្នុងថ្ងៃនេះទេ ជាធម៌មិន

អស្ចារ្យ មិនមែនជាធម៌ចម្លែកទេ សត្វកើតស្លាប់ ក្នុងលោកណា ហេតុតិចតួច ក៏មិនចម្លែក ក្នុងលោកនោះ ។ សេចក្តីពិតថា បន្ទាប់អំពីការកើតមក មានសេចក្តីស្លាប់ចាកជីវិត ជាធម្មជាតទៀងទាត់ សត្វទាំងឡាយ ដែលកើតហើយៗ រមែងស្លាប់ ក្នុងលោកនេះ ព្រោះថា សត្វទាំងឡាយ មានសភាពយ៉ាងនេះឯង ។ សេចក្តីសោកស្តាយណា របស់បុរសបុគ្គលទាំងឡាយដទៃ ដើម្បីជីវិត សេចក្តីសោកស្តាយនុ៎ះ មិនមែនដើម្បីប្រយោជន៍ដល់សត្វ ដែលស្លាប់ទៅហើយទេ ការយំចំពោះសត្វ ដែលស្លាប់ហើយ មិនមែនជាយស មិនមែនជាការល្អទេ សមណព្រាហ្មណ៍ទាំងឡាយ មិនសរសើរការយំឡើយ ។ ការយំ រមែងបៀតបៀននូវចក្ខុ និងសរីរៈ ( របស់បុគ្គលអ្នកយំ ) ពណ៌សម្បុរក្តី កម្លាំងក្តី ប្រាជ្ញាក្តី នៃអ្នកយំ រមែងសាបសូន្យ ពួកសត្រូវរបស់បុគ្គលអ្នកយំនោះ ក៏មានសេចក្តីត្រេកអរ ពួកបុគ្គលអ្នកស្វែងរកប្រយោជន៍ ឲ្យបុគ្គលអ្នកយំនោះបាននូវសេចក្តីទុក្ខ ។ ព្រោះហេតុនោះ ពួកជនឆ្លងនូវកិច្ច ( របស់ខ្លួន ) ដោយកម្លាំងប្រាជ្ញា របស់អ្នកប្រាជ្ញទាំងឡាយណា ដូចពួកជនឆ្លងនូវទន្លេមានទឹកពេញដោយទូក បុគ្គលគប្បីប្រាថ្នានូវពួកអ្នកប្រាជ្ញជាពហុស្សូតនោះ ឲ្យនៅក្នុងត្រកូល ( របស់ខ្លួន ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អនាគតំ** សេចក្តីថា មិនទាន់មកដល់ គឺមិនទាន់ជួប ។ បទថា **បដិកច្ច** ប្រែថា មុនអំពីនោះ ។ បទថា **បស្សតិ**

ប្រែថា រមែងឃើញ ។ បទថា **អត្ថំ** បានដល់ កិច្ច ។ បទថា **តំ ទ្វយំ** បានដល់ វត្ថុដែលជាប្រយោជន៍ និងមិនមែនជាប្រយោជន៍ ។ បទថា **វិទ្ទេសិនោ** បានដល់ មិនមែនជាមិត្ត ។ បទថា **ហិតេសិនោ** បានដល់ មិត្ត ។ បទថា **រន្ធំ** បានដល់ ឱកាស ឬចន្លោះ ។

បទថា **សមេក្ខមានា** បានដល់ ជាអ្នកស្វែងរក ។ មានពាក្យដែលលោកពោលអធិប្បាយថា បុគ្គលណាឃើញ គឺពិចារណា បានដល់ ពិចារណាបានមុនដោយភ្នែក គឺបញ្ញា នូវប្រយោជន៍ គឺកិច្ចទាំងដែលជាប្រយោជន៍ ទាំងមិនជាប្រយោជន៍ដល់ខ្លួន និងទាំង ២ យ៉ាង ដែលមិនទាន់មកដល់ គឺមិនទាន់សម្រេច ដូចដែលខ្ញុំឃើញ ។ បុគ្គលមិនមែនមិត្តរបស់បុគ្គលនោះ រកឱកាសដោយអធ្យាស្រ័យដែលមិននាំប្រយោជន៍មកក្តី ដែលជាមិត្ត ស្វែងរកឱកាសដោយអធ្យាស្រ័យ ដែលប្រាថ្នាប្រយោជន៍ក្តី រមែងមិនជួបបុគ្គលអ្នកមានបញ្ញាបែបនេះ រាប់ថា ជាអ្នកប្រព្រឹត្តមិនខុសឆ្គង ព្រោះហេតុនោះ អ្នកទាំងឡាយ គប្បីជាបុគ្គលបែបនោះ ។

ឥឡូវនេះ ព្រះថេរៈកាលសម្តែងគុណក្នុងការចម្រើនអានាបានស្សតិ ទើបពោលគាថាទី ២ ថា **អានាបានស្សតិ យស្ស** ដូច្នេះជាដើម ដើម្បីប្រកបនូវប្រយោជន៍ទាំងនោះក្នុងគាថានោះ ។

បណ្តាបទទាំងនោះ បទថា **អាន** បានដល់ ខ្យល់ដង្ហើមចូល ។ បទថា **អបាន** បានដល់ ខ្យល់ដង្ហើមចេញ ។ សតិមានការកំណត់ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញជាគ្រឿងសម្គាល់ ឈ្មោះថា **អានាបានស្សតិ**។

ក្នុងទីនេះ កាលពោលដល់មាតិកានៃសតិ លោកបំណងយកការចម្រើនសមាធិ ដែលសម្បយុត្តដោយអានាបានស្សតិនោះ ។

បទថា **យស្ស** បានដល់ ព្រះយោគាវចររូបណា ។ បទថា **បរិបុណ្ណា សុភាវិតា** សេចក្តីថា ឲ្យពេញហើយដោយប្រការទាំងពួង ដើម្បីបរិបូណ៌នៃសតិប្បដ្ឋាន ៤ និងនៃអាការ ១៦ អប់រំ គឺឲ្យចម្រើនដោយល្អ ដើម្បីការបរិបូណ៌នៃពោជ្ឈង្គ ៧ វិជ្ជា និងវិមុត្តិ ។

បទថា **អនុបុព្វំ បរិចិតា យថា ពុទ្ធេន ទេសិតា** សេចក្តីថា សន្សំហើយ គឺសេពរឿយៗ បានដល់ ចម្រើនតាមលំដាប់ ដោយប្រការដែលព្រះមានព្រះភាគទ្រង់សម្តែងដោយន័យជាដើមថា ភិក្ខុនោះមានស្មារតីដកដង្ហើមចូល ដូច្នេះ ។

បទថា **សោមំ លោកំ បភាសេតិ អព្ភា មុត្តោវ ចន្ទិមា** សេចក្តីថា ព្រះយោគាវចរនោះផុតចាកឧបក្កិលេស មានអវិជ្ជាជាដើមហើយ រមែងញុំាងសង្ខារលោក ដែលកប់ក្នុងសន្តានរបស់ខ្លួន និងដែលកប់ក្នុងសន្តាននៃបុគ្គលដទៃឲ្យភ្លឺច្បាស់ដោយពន្លឺនៃញាណ ប្រៀបដូចព្រះចន្ទផុតហើយចាកពពកមានពពកដែលសៅហ្មងជាដើម រមែងញុំាងឱកាសលោកនេះឲ្យភ្លឺ ដោយពន្លឺនៃព្រះចន្ទ ដូច្នោះ ។ អធិប្បាយថា ព្រោះដូច្នោះ ពួកអ្នកគប្បីនាំគ្នាចម្រើនអានាបានស្សតិភាវនាចុះ ។ ឥឡូវនេះ ព្រះថេរៈកាលធ្វើខ្លួនឲ្យជាឧទាហរណ៍ហើយ កាលនឹងសម្តែងការប្រកបព្យាយាមក្នុងភាវនាថា មានផល ទើបពោលគាថាទី ៣ ថា **ឱទាតំ វត មេ ចិត្តំ** ដូច្នេះជាដើម ។

អត្ថនៃបាទគាថានោះថា ចិត្តរបស់ខ្ញុំផូរផង់ បរិសុទ្ធហើយហ្ន៎ ព្រោះប្រាសចាកមន្ទិល គឺនីវរណធម៌ ឈ្មោះថា **អប្បមាណំ សុភាវិតំ** ព្រោះអំណាចដែលខ្ញុំអប់រំហើយ ដោយប្រការដែលរាគៈជាដើមដែលជាធម៌ ធ្វើប្រមាណ និងដោយវិធីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ដែលមិនមានប្រមាណ ។ បន្ទាប់អំពីនោះ ចាក់ធ្លុះនូវសច្ចៈ ៤ ប្រការ ជាអ្នកមានចិត្តដែលលើកឲ្យផុតចាកធម៌ ដែលជាចំណែកសៅហ្មងទាំងពួង រមែងញុំាងទិស គឺទុក្ខជាដើម និងចំណែកអតីតជាដើមឲ្យភ្លឺស្វាង ព្រោះឆ្លងផុតសេចក្តីសង្ស័យក្នុងធម៌នោះបាន និងព្រោះប្រាសចាកមោហៈក្នុងធម៌ទាំងពួង ព្រោះហេតុនោះ ទើបព្រះថេរៈសម្តែងថា សូម្បីពួកលោក ក៏គប្បីអប់រំចិត្តយ៉ាងនោះចុះ ។

ព្រះថេរៈកាលសម្តែងថា បញ្ញាក្រៅអំពីនេះ ក៏ដូចបញ្ញាដែលសម្រេចដោយភាវនា ដែលមានឧបការៈច្រើនដល់បុគ្គល ដោយគ្រឿងជម្រះមន្ទិលនៃចិត្តឲ្យស្អាតជាដើមបាន ទើបពោលគាថាទី ៤ ថា **ជីវតេ វាបិ សប្បញ្ញោ** ដូច្នេះជាដើម ។

សេចក្តីនៃបាទគាថានោះថា បុគ្គលមានបញ្ញា ទោះអស់ទ្រព្យ សន្តោសដោយបច្ច័យតាមមាន តាមបាន ក៏គង់រស់នៅបាន ដោយការចិញ្ចឹមជីវិតដោយប្រាសចាកទោស ។ ព្រោះថា ការរស់នៅរបស់បុគ្គលមានបញ្ញានោះ ទើបឈ្មោះថា ការរស់នៅបាន ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ ( ក្នុងសំយុត្តនិកាយ សគាថវគ្គ ) ថា បណ្ឌិតទាំងឡាយពោលថា អ្នករស់នៅដោយបញ្ញា ឈ្មោះថា ជាអ្នករស់នៅប្រសើរបំផុត ដូច្នេះ ។

ឯអ្នកមានបញ្ញាថោកថយ ព្រោះខ្វះបញ្ញា រមែងធ្វើប្រយោជន៍ ដែលប្រព្រឹត្តទៅក្នុងទិដ្ឋធម្ម និងប្រយោជន៍ដែលប្រព្រឹត្តទៅក្នុងសម្បរាយិកកពឲ្យវិនាសទៅ សូម្បីមានទ្រព្យសម្បត្តិ ក៏រស់នៅមិនបាន ព្រោះបានទទួលការតិះដៀលជាដើម ឈ្មោះថា ការរស់នៅរមែងមិនមានដល់បុគ្គលនោះ ម្យ៉ាងទៀត ព្រោះខ្លួនមិនស្គាល់ឧបាយទ្រព្យដែលសន្សំ រមែងវិនាសទៅ សូម្បីជីវិតក៏មិនអាចរក្សាបាន ព្រោះដូច្នោះ ទើបមានអធិប្បាយថា ពួកអ្នកគប្បីធ្វើបញ្ញាជាគ្រឿងបរិហារឲ្យដល់ព្រម ដោយការមិនប្រមាទចុះ ។

ឥឡូវនេះ ដើម្បីសម្តែងអានិសង្សនៃបញ្ញា ព្រះថេរៈពោលគាថាទី ៥ ថា **បញ្ញា សុតវិនិច្ឆិនី** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **បញ្ញា សុតវិនិច្ឆិនី** សេចក្តីថា ធម្មតាបញ្ញានេះជាគ្រឿងកាត់សម្រេចនូវវត្ថុដែលខ្លួនស្តាប់មកហើយ គឺជាគ្រឿងឲ្យកើតនូវការកាត់ផ្តាច់ក្នុងប្រយោជន៍ដែលខ្លួនស្តាប់មកហើយ ដែលមកប្រាកដក្នុងសោតប្បសាទ ដោយអត្ថជាដើមថា នេះមិនល្អ នេះល្អ នេះមានទោស នេះមិនមានទោស ។

បទថា **កិត្តិសិលោកវឌ្ឍនី** សេចក្តីថា ជាគ្រឿងធ្វើឲ្យកេរ្តិ៍ឈ្មោះការសរសើរចំពោះមុខ និងយសដែលផ្សាយទៅចម្រើន ពិតហើយ កិត្តិគុណជាដើម រមែងមានដល់បុគ្គលអ្នកមានបញ្ញាប៉ុណ្ណោះ ព្រោះវិញ្ញូជនទាំងឡាយសរសើរ ។

បទថា **បញ្ញាសហិតោ** សេចក្តីថា ជាអ្នកប្រកបដោយបរិហារិ-

យប្បញ្ញា និងវិបស្សនាបញ្ញា ។

បទថា **អតិ ទុក្ខេសុ សុខានិ វិន្ទតិ** សេចក្ដីថា រមែងបានចំពោះនូវសេចក្ដីសុខ ដែលមិនមានអាមិស ព្រោះឃើញច្បាស់តាមសេចក្ដីពិត ដោយសម្មាបដិបត្តិក្នុងខន្ធ និងអាយតនៈជាដើម ដែលមានសេចក្ដីទុក្ខជាសភាវៈដោយចំណែកមួយ ។

ឥឡូវនេះ ព្រះថេរៈកាលទូន្មានធម៌ដែលសម្បយុត្តដោយអនិច្ចតា ដែលនាំមកនូវភាពជាអ្នកប្រាជ្ញដល់ភិក្ខុនីទាំងនោះ ទើបពោលគាថាដ៏សេស ដោយអត្ថជាដើមថា **ឆាយំ អជ្ជតនោ ធម្មោ** ដូច្នេះ ។

ក្នុងបាទគាថានោះ មានសេចក្ដីសង្ខេបដូចតទៅនេះថា ធម៌ គឺការដែលសត្វមានការកើត និងការស្លាប់ជាធម្មតានោះ មិនមែនមានតែក្នុងកាលឥឡូវនេះទេ គឺមិនមែនមានមកមិនយូរ មិនគួរអស្ចារ្យ ព្រោះប្រព្រឹត្តទៅរឿយៗផង មិនមែនមិនធ្លាប់មានមកហើយផង ព្រោះការមិនធ្លាប់មានមកហើយក្នុងកាលមុនក៏មិនមែន ព្រោះហេតុនោះ ក្នុងលោកដែលសត្វកើតស្លាប់ គឺសត្វគប្បីកើតក្នុងលោកណា សត្វនោះ គប្បីស្លាប់ដោយចំណែកមួយ ក្នុងលោកនោះ នឹងមិនមានការស្លាប់បានដូចម្ដេច ព្រោះមានការស្លាប់ជាសភាវៈប្រចាំ ។ ពិតហើយ ខណិកមរណៈមិនមានហេតុតិចតួចឡើយ ។

ព្រោះសេចក្ដីពិតថា បន្ទាប់អំពីការកើតមក មានសេចក្ដីស្លាប់ចាកជីវិតជាធម្មជាតទៀងទាត់ គឺកាលសត្វកើតមកហើយ បន្ទាប់អំពីការកើត ក៏មានសេចក្ដីស្លាប់ជាទីបំផុតតែម្យ៉ាង ព្រោះខន្ធទាំងឡាយ ដែលកើតឡើងហើយ

មានការបែកធ្លាយទៅជាធម្មតា ដោយចំណែកមួយ ។ ក្នុងពាក្យនេះ លោក-ពោលហេតុដែលថា មានជីវិតរស់នៅ មានទីបំផុតជាអនេក ព្រោះទាក់ទងដោយបច្ច័យច្រើននៃឧបាទាននោះ ព្រោះសេចក្តីនោះបែបនេះ ព្រោះហេតុនោះ ទើបព្រះថេរៈពោលថា សត្វទាំងឡាយដែលកើតហើយៗ រមែងស្លាប់ក្នុងលោកនេះ ព្រោះថា សត្វទាំងឡាយ មានសភាពយ៉ាងនេះឯង អធិប្បាយថា ជាប្រក្រតីរបស់សត្វទាំងឡាយ គឺការស្លាប់ រមែងមានដល់សត្វទាំងឡាយដែលកើតមកហើយ ព្រោះហេតុនោះ ទើបពោលថា ការស្លាប់ជាប់មកអំពីការកើត ។

ឥឡូវនេះ ព្រោះដើម្បីធ្វើការកម្ចាត់សេចក្តីសោករបស់ភិក្ខុនី សូម្បីអ្នកមានចិត្តត្រូវសេចក្តីសោករឹតរុំហើយ ដូច្នោះ ទើបព្រះថេរៈពោលពាក្យជាដើមថា **ន ហេតទត្ថាយ** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ន ហេតទត្ថាយ មតស្ស ហោតិ** សេចក្តីថា ការយំរបស់បុរសដទៃ គឺអ្នកដទៃដើម្បីឲ្យអ្នកស្លាប់ត្រឡប់បាននូវជីវិត គឺជាហេតុឲ្យមានជីវិតរបស់សត្វដែលស្លាប់ហើយនោះ ចូរវៀរបង់ព្រោះការយំនោះ មិនមានប្រយោជន៍ដល់សត្វណាម្នាក់ឡើយ ព្រោះសត្វពួកណាយំការយំរបស់សត្វទាំងនោះ ដល់បុគ្គលដែលស្លាប់ គឺមានអ្នកស្លាប់ជាហេតុ មិនមែនជាយស មិនមែនជាការល្អទេ គឺរមែងមិននាំមកនូវកិត្តិយស និងសេចក្តីបរិសុទ្ធមកឲ្យឡើយ ។

បទថា **ន វណ្ណិតំ សមណព្រាហ្មណេហិ** បានដល់ វិញ្ញូជនដែល

សរសើរក៏មិនមាន ដោយពិត វិញ្ញូជនតិះដៀលតែម្យ៉ាង ។

ព្រះថេរៈកាលនឹងសម្តែងថា ទោសរបស់បុគ្គលដែលយំ មិនមែនមានត្រឹមតែម្យ៉ាងប៉ុណ្ណោះទេ ដោយពិត សូម្បីក្រៅអំពីនេះ ក៏នៅមាន ដូច្នេះទើបពោលថា **ចក្ខុំ សរីរំ ឧបហន្តិ** ដូច្នេះជាដើម ក្រៃលែងជាងនោះ កាលទូន្មានភិក្ខុនីទាំងនោះ ឲ្យបួលទៅរកកល្យាណមិត្ត ដើម្បីការពារនូវវត្ថុដែលមិនជាប្រយោជន៍ មានសេចក្តីសោកជាដើម ទើបពោលគាថាចុងក្រោយដោយអត្ថជាដើមថា **តស្មា** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តស្មា** សេចក្តីថា ព្រោះការយំ រមែងប៉ះពាល់ គឺបៀតបៀនចក្ខុ និងសរីរៈនៃបុគ្គលដែលយំ ព្រោះការយំនោះ ទើបធ្វើឲ្យពណ៌សម្បុរ កម្លាំង និងគំនិតសាបសូន្យទៅ គឺវិនាសទៅ ។ ថោរ គឺបុគ្គលដែលជាសត្រូវនៃបុគ្គលដែលយំ រមែងមានចិត្តត្រេកអរ គឺមាននូវបាមោជ្ជ បីតិ ឯមិត្តអ្នកប្រាថ្នាប្រយោជន៍ ក៏មានទុក្ខលំបាកចិត្តទៅជាមួយដែរ ដូច្នោះ បុគ្គលគប្បីប្រាថ្នា គឺគប្បីទន្ទឹងចំពោះបុគ្គលដែលជាអ្នកប្រាជ្ញ ព្រោះប្រកបដោយបញ្ញាដែលកើតអំពីធម៌ បុគ្គលឈ្មោះថា ជាពហុស្សូត ព្រោះដល់ព្រមដោយពាហុសច្ចៈ ដែលអាស្រ័យប្រយោជន៍ មានទិដ្ឋធម្មិកត្ថ-ប្រយោជន៍ជាដើម ឲ្យនៅក្នុងត្រកូលរបស់ខ្លួន គឺគប្បីធ្វើឲ្យជាអ្នកចូលដល់ត្រកូល ។

បទថា **យេសំ** មានវាចាប្រកបសេចក្តីថា កុលបុត្តទាំងឡាយឆ្ងងផុត កិច្ចរបស់ខ្លួន គឺដល់នូវត្រើយបាន ក៏ដោយកម្លាំងបញ្ញា ព្រោះបញ្ញាជាសម្បត្តិ របស់បុគ្គលដែលជាអ្នកប្រាជ្ញ ជាពហុស្សុត ជាបណ្ឌិត ដូចបុគ្គលឆ្លងស្ទឹង ដែលពេញដោយជំនន់ទឹកធំដោយទូក ដូច្នោះ បុគ្គលគប្បីប្រាថ្នាអ្នកប្រាជ្ញ ជាដើមនោះ ឲ្យនៅក្នុងត្រកូលចុះ ។

ព្រះថេរៈ កាលទូន្មានធម៌ដល់ភិក្ខុនីទាំងនោះយ៉ាងនេះហើយ ទើបឲ្យត្រឡប់ទៅ ភិក្ខុនីទាំងនោះតាំងនៅក្នុងឱវាទរបស់ព្រះថេរៈ បន្ទោបង់សេចក្តីសោកហើយ បដិបត្តិដោយឧបាយ ធ្វើប្រយោជន៍របស់ខ្លួនឲ្យបរិបូណ៌បាន ហើយនោះឯង ។

**អដ្ឋកថា មហាកប្បិនត្ថេរគាថា ចប់**

# សុត្តន្តបិដក

## ចូឡបន្ថកត្ថេរគាថា

[ ២៣៧ ] ញាណគតិ របស់អាត្មាអញទន់ខ្សោយ ក្នុងកាលមុន អាត្មាអញ ក្មេចក្មាំងស្មារតី ថែមទាំងបងប្រុស ក៏បណ្តេញអាត្មាអញថា ឥឡូវនេះ អ្នកចូរទៅផ្ទះចុះ ។ អាត្មាអញនោះ ត្រូវបងបណ្តេញហើយក៏តូចចិត្ត តែនៅមានអាឡោះអាល័យ ក្នុងសាសនា ក៏ឈរនៅជិតខ្លោងទ្វារ នៃអារាម របស់សង្ឃនោះ ។ ព្រះមានព្រះភាគ ទ្រង់យាងមកក្នុងទីនោះ បានស្ទាបអង្អែលក្បាល របស់អាត្មាអញ ហើយក៏ចាប់អាត្មាអញត្រង់ដើមដៃ ឲ្យចូលទៅកាន់អារាមនៃសង្ឃ ។ ព្រះសាស្តាទ្រង់ប្រទាននូវសំពត់សម្រាប់ជូតជើង ដោយសេចក្តីអនុគ្រោះដល់អាត្មាអញថា អ្នកចូរអធិដ្ឋាននូវសំពត់ស្អាតនេះ ធ្វើឲ្យជាសំពត់ដែលខ្លួនអធិដ្ឋានល្អហើយ ក្នុងទីដ៏សមគួរចុះ ។ លុះអាត្មាអញបានស្តាប់ព្រះបន្ទូល របស់ព្រះមានព្រះភាគនោះហើយ ក៏ត្រេកអរក្នុងសាសនា បានញ៉ាំងសមាធិឲ្យសម្រេច ដើម្បីបាននូវប្រយោជន៍ដ៏ឧត្តម អាត្មាអញដឹងនូវបុព្វេនិវាស ទិព្វចក្ខុអាត្មាអញបានជម្រះហើយ ត្រៃវិជ្ជា អាត្មាអញបានដល់ ដោយលំដាប់ហើយ ព្រះពុទ្ធសាសនា អាត្មាអញបានធ្វើហើយ ។ បន្ថកភិក្ខុនិម្មិតខ្លួនជាមួយពាន់ ហើយអង្គុយក្នុងអម្ពវ័នជាទីរីករាយ ដរាបដល់ការប្រាប់នូវកត្តកាល ។ លំដាប់នោះ ព្រះសាស្តាទ្រង់ប្រើទូតឲ្យទៅប្រាប់កត្តកាលដល់អាត្មាអញ កាលទូតមកប្រាប់កត្តកាល អាត្មាអញក៏មក

តាមអាកាស ។ អាត្មាអញថ្វាយបង្គំព្រះបាទានៃព្រះសាស្តារួចហើយ អង្គុយក្នុងទីសមគួរ គ្រានោះ ព្រះសាស្តាទ្រង់ជ្រាបថា អាត្មាអញ អង្គុយហើយ ទើបបានទ្រង់ទទួល ( ទក្ខិណោទក ) ។ ព្រះអង្គជាទីបូជារបស់សត្វលោក ជាបដិគ្គាហកៈរបស់បុគ្គលអ្នកបូជាទាំងឡាយ ជាបុញ្ញក្ខេត្ត របស់មនុស្សទាំងឡាយ ទ្រង់ទទួលនូវទក្ខិណាទាន ។

ចូឡបន្ថកត្ថេរ

# អដ្ឋកថា

## ចូឡបន្ថកត្ថេរគាថា

[ ២៣៧ ] គាថារបស់ព្រះចូឡបន្ថកត្ថេរ មានពាក្យផ្តើមថា **ទន្ធា មយ្ហំ គតិ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

ពាក្យដែលគួរពោលទាក់ទងដោយការកើត បានពោលហើយក្នុងរឿងមហាបន្ថកៈ ក្នុងអដ្ឋកនិបាត ឯការប្លែកគ្នាមានដូចតទៅនេះ

ព្រះមហាបន្ថកត្ថេរសម្រេចអរហត្តហើយ នៅសម្រាំដោយសេចក្តីសុខដែលកើតអំពីអរហត្តផល គិតថា ធ្វើដូចម្តេចហ្ន៎ អាត្មាអញអាចឲ្យចូឡបន្ថកៈ តាំងនៅក្នុងសេចក្តីសុខយ៉ាងនេះ ។

ព្រះមហាបន្ថកត្ថេរនោះ ចូលទៅរកធនសេដ្ឋីដែលជាជីតារបស់ខ្លួន រួច

ពោលថា បពិត្រលោកសេដ្ឋី បើលោកអនុញ្ញាតសោត អាត្មានឹងឲ្យចូឡ-បន្ថកៈបួសដែរ ។ ជីតាពិតថា សូមលោកម្ចាស់ឲ្យគេបួសចុះ ព្រះថេរៈក៏ឲ្យចូឡបន្ថកៈនោះបួសហើយ ។ ចូឡបន្ថកៈនោះតាំងនៅមាំក្នុងសីល ១០ ប្រការហើយ រៀននូវគាថា ( ក្នុងសំយុត្តនិកាយ សគាថវគ្គ ) ក្នុងសម្នាក់របស់បងប្រុសថា

ផ្កាឈូក ( ក្រហមប្រាល ) រីកក្នុងវេលាព្រឹក មានក្លិនក្រអូប
មិនប្រាសចាកក្លិន យ៉ាងណា អ្នកចូរមើលនូវព្រះសម្មាសម្ពុទ្ធ
មានរស្មីផ្សាយចេញអំពីព្រះអង្គ កំពុងរុងរឿង ដូចព្រះអាទិត្យ
ដែលរុងរឿង ក្នុងអាកាសយ៉ាងនោះឯង ដូច្នេះ ។

ដោយ ៤ ខែកន្លងទៅ ក៏ចាំមិនបាន បទដែលរៀនហើយ ទន្ទេញហើយ មិនជាប់នៅក្នុងហទយៈរបស់លោកឡើយ ។ តមក ព្រះមហាបន្ថកៈក៏ពោលដល់ព្រះថេរៈថា នែបន្ថកៈ លោកជាអភព្វបុគ្គលក្នុងសាសនានេះ ៤ ខែកន្លងទៅហើយ លោកមិនអាចចាំបានសូម្បីតែមួយគាថា លោកនឹងធ្វើកិច្ចនៃបព្វជិតឲ្យដល់ទីបំផុតបានដូចម្ដេច ចូរលោកចេញអំពីទីនេះ ចូឡបន្ថកៈនោះត្រូវព្រះថេរៈបណ្ដេញ ក៏ទៅឈរយំត្រង់ខ្លោងទ្វារ ។

ដោយសម័យនោះ ព្រះសាស្ដាគង់ត្រង់អម្ពវនារាមរបស់ពេទ្យជីវកលំដាប់នោះ ពេទ្យជីវកបញ្ជូនបុរសទៅថា ចូរអ្នកនិមន្តព្រះសាស្ដា មួយអន្លើដោយភិក្ខុ ៥០០ រូបមក ។ សម័យនោះ ព្រះមហាបន្ថកៈជាភត្តុទ្ទេសក៍ ។ ព្រះមហាបន្ថកៈនោះដែលទាយកនិមន្តថា សូមលោកម្ចាស់ទទួលភិក្ខាដើម្បី

ភិក្ខុ ៥០០ រូបចុះ ដូច្នេះក៏ពោលថា អាត្មានឹងទទួលភិក្ខាដើម្បីភិក្ខុទាំងឡាយ ដ៏សេស វៀរតែចូឡបន្ថកៈ ។ ព្រះចូឡបន្ថកៈបានស្តាប់ដូច្នោះ មានសេចក្តីទោមនស្សក្រៃលែងឡើង ។

ព្រះសាស្តាទ្រង់ជ្រាបថា ចូឡបន្ថកៈទោមនស្សហើយ ទើបទ្រង់ត្រិះរិះថា ចូឡបន្ថកៈនឹងត្រាស់ដឹងដោយឧបាយ ដែលតថាគតសាងឡើង ដូច្នេះហើយ ទើបទ្រង់បង្ហាញព្រះកាយក្នុងទីមិនឆ្ងាយអំពីចូឡបន្ថកៈនោះ ត្រាស់សួរថា ម្នាលបន្ថកៈ ហេតុអ្វី ទើបអ្នកយំ ចូឡបន្ថកៈទូលថា បងប្រុសបណ្តេញខ្ញុំព្រះអង្គ ។ ព្រះសាស្តាត្រាស់ថា ម្នាលបន្ថកៈ កុំគិតបរិ្វឡើយ អ្នកបួសហើយក្នុងសាសនារបស់តថាគត មក ចូរទទួលរបស់នេះ ហើយធ្វើនូវបរិកម្មក្នុងចិត្តថា **រជោ ហរណំ រជោ ហរណំ** ដូច្នេះ ទើបទ្រង់និម្មិតកំណាត់សំពត់ដែលស្អាតបរិសុទ្ធ ហើយទ្រង់ប្រទាន ។ ព្រះចូឡបន្ថកៈនោះ អង្គុយយកដៃអង្អែលកំណាត់សំពត់ដែលព្រះសាស្តាប្រទាន បរិកម្មថា **រជោ ហរណំ រជោ ហរណំ** ដូច្នេះ ។

កាលព្រះថេរៈបរិកម្ម អង្អែលកំណាត់សំពត់ ការសៅហ្មងកើតឡើង កាលអង្អែលទៀត សំពត់នោះក៏ហាក់ដូចជាសំពត់ជូតឆ្នាំងបាយ ព្រោះព្រះ-ថេរៈមានញាណចាស់ក្លាជុំវិញហើយ ទើបគិតថា កំណាត់សំពត់នេះ ពីមុនជារបស់ស្អាត ក្លាយទៅជាដទៃ សៅហ្មងទៅ ព្រោះអាស្រ័យឧបាទិន្នកសរីរៈនេះ ព្រោះហេតុនោះ កំណាត់សំពត់នេះ ជាអនិច្ចំ យ៉ាងណា ចិត្តក៏ជាអនិច្ចំដូច្នោះ ដូច្នេះហើយ ទើបផ្តើមតាំងនូវការអស់ទៅ សូន្យទៅ ធ្វើឈានឲ្យកើត

ឡើង ព្រោះនិមិត្តនោះឯង ផ្តើមវិបស្សនា មានឈានជាបាទ សម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយ ។ សមដូចគាថាព័ន្ធដែលលោកពោលក្នុងអបទានថា

កាលនោះ ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ទ្រង់គួរទទួលគ្រឿងបូជា គេចចេញចាកគណៈ ទៅគង់ក្នុងព្រៃហិមពាន្ត ។ គ្រានោះ ខ្ញុំនៅក្នុងអាស្រម នាព្រៃហិមពាន្ត បានចូលទៅគាល់ព្រះលោកនាយក ព្រះអង្គមានព្យាយាមធំ ដែលទ្រង់ទើបស្តេចមកដល់ថ្មីៗ ។ ខ្ញុំកាន់ឆត្រជាវិការនៃផ្កាហើយ ចូលទៅគាល់ព្រះនរាសភៈ ដែលកំពុងចូលសមាធិហើយ បានធ្វើឲ្យខូចសមាធិព្រះអង្គ ។ ខ្ញុំផ្គងដៃទាំងពីរហើយថ្វាយឆត្រផ្កា ព្រះមានព្រះភាគជាមហាមុនី ព្រះនាមបទុមុត្តរៈ ទ្រង់បានទទួល ។ ពួកទេវតាទាំងអស់ មានចិត្តរីករាយ ចូលទៅកាន់ព្រៃហិមពាន្ត ពួកទេវតាទាំងនោះ បានញុំាងសាធុការឲ្យប្រព្រឹត្តទៅ ( ហើយពោលថា ) ព្រះពុទ្ធមានបញ្ញាចក្ខុ នឹងធ្វើអនុមោទនា ។ ទេវតាទាំងនោះលុះពោលពាក្យនេះហើយ ក៏ចូលទៅគាល់ព្រះសម្ពុទ្ធដ៏ប្រសើរជាងនរៈ ដែលកំពុងបាំងឆត្រផ្កាឈូកដ៏ឧត្តមរបស់ខ្ញុំ ក្នុងអាកាស ។

( ព្រះបទុមុត្តរៈត្រាស់ថា ) តាបសបានលើកឆត្រប្រដាប់ដោយស្រទាប់ ៧ ថ្វាយតថាគត តថាគតនឹងសម្តែងសរសើរ

តាបសនោះ អ្នកទាំងឡាយ ចូរស្តាប់គថាគតសម្តែងចុះ ។ តាបសនេះ នឹងសោយទេវរាជ្យ អស់ ២៥ កប្ប មួយទៀត នឹងបានជាស្តេចចក្រពត្តិ អស់ ៣៤ ដង ។ តាបសនេះ បើអន្ទោលទៅកាន់កំណើតណាៗ ទោះជាទេវតា ឬជាមនុស្ស ផ្កាឈូកនឹងបាំងតាបសនោះ ដែលកំពុងឋិតនៅក្នុងទីវាល ។ កន្លងទៅមួយសែនកប្ប ព្រះបរមសាស្ដាព្រះនាមគោតម ទ្រង់កើតក្នុងឱក្កាកត្រកូល នឹងត្រាស់ដឹងក្នុងលោក ។ លុះដល់សាសនា ដែលព្រះពុទ្ធព្រះនាមគោតម ទ្រង់ប្រកាសហើយ តាបសនោះ នឹងបាននូវអត្តភាពជាមនុស្ស ជាអ្នកប្រសើរ ក្នុងកាយដ៏សម្រេចដោយចិត្ត ។ មានបងប្អូនពីរនាក់ ឈ្មោះបន្ថកៈ ដូចគ្នា ទាំងពីរនាក់ នឹងបានទទួលនូវប្រយោជន៍ដ៏ឧត្តម ហើយធ្វើពុទ្ធសាសនាឲ្យរុងរឿង ។

ខ្ញុំមានអាយុ ១៨ ឆ្នាំ បានចូលទៅកាន់ផ្នួស តែខ្ញុំមិនសម្រេចគុណវិសេស ក្នុងសាសនាព្រះពុទ្ធ ជាសក្យបុត្តទេ ។ គតិរបស់ខ្ញុំយឺត ( ព្រោះ ) ខ្ញុំបានមើលងាយគេ ក្នុងកាលមុន ឯភិក្ខុជាបង ក៏បណ្តេញខ្ញុំថា លោកចូរទៅកាន់ផ្ទះ របស់ខ្លួនឥឡូវនេះចុះ ។ ខ្ញុំនោះ ដែលត្រូវបងបណ្តេញចេញហើយ ក៏តូចចិត្ត បានទៅឈរអែបត្រង់ខ្លោងទ្វារនៃអារាម របស់សង្ឃនោះ ឥតមានសេចក្តីអាឡោះអាល័យ ក្នុងសមណភេទឡើយ ។ គ្រានោះ ព្រះ

សាស្តាស្តេចមកដល់ទីនោះហើយ អង្អែលសីសៈរបស់ខ្ញុំ ចាប់ខ្ញុំត្រង់ដើមដៃ ហើយនាំចូលទៅកាន់អារាម នៃសង្ឃវិញ ។ ព្រះសាស្តាបានប្រទានសំពត់ជូតជើងដល់ខ្ញុំ ហើយទ្រង់ត្រាស់ដោយសេចក្តីអនុគ្រោះថា អ្នកចូរអធិដ្ឋានសំពត់ដ៏ស្អាតយ៉ាងនេះចុះ សំពត់នេះ តថាគតអធិដ្ឋានហើយ ក្នុងទីដ៏សមគួរ ។ ខ្ញុំក៏បានទទួលយកសំពត់នោះ ដោយដៃទាំងពីរ ហើយនឹកនូវកម្មដ្ឋានមានផ្កាឈូកក្រហមជាអារម្មណ៍ ចិត្តរបស់ខ្ញុំក៏រួចស្រឡះ ( ចាកកិលេស ) ក្នុងទីនោះ ខ្ញុំបានដល់អរហត្តផលហើយ ។ ខ្ញុំបានដល់នូវបារមីញាណក្នុងទីទាំងពួង ក្នុងកាយដ៏សម្រេចដោយចិត្ត ហើយកំណត់ដឹងអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ ។

ព្រះត្រៃបិដក និងអភិញ្ញា ៥ មានដល់ព្រះចូឡបន្ថកៈនោះ មួយអន្លើដោយអរហត្តមគ្គនោះឯង ។ ព្រះសាស្តាយាងទៅ មួយអន្លើដោយភិក្ខុ ៤៩៩ រូប ហើយគង់លើអាសនៈដែលគេបានរៀបចំក្នុងផ្ទះរបស់ពេទ្យជីវក ឯព្រះចូឡបន្ថកៈមិនបានទៅ ព្រោះបងប្រុសមិនបានទទួលនិមន្តដើម្បីភិក្ខាសម្រាប់លោក ពេទ្យជីវកផ្តើមថ្វាយយាគូ ព្រះសាស្តាទ្រង់យកព្រះហស្តបិទបាត្រ ។ កាលពេទ្យជីវកក្រាបទូលថា ព្រោះហេតុអ្វី ទើបទ្រង់មិនទទួល ដូច្នេះ ទើបត្រាស់ថា ក្នុងវិហារនៅមានភិក្ខុមួយរូបទៀត ។

ទេព្យជីវកនោះបញ្ជូនអ្នកបម្រើទៅថា នែអ្នក ចូរអ្នកទៅនាំលោកម្ចាស់ ដែលអង្គុយក្នុងវិហារមក ។ ព្រះចូឡបន្ថកត្រេនិម្មិតភិក្ខុ ១០០០ រូប ឲ្យមានរូបរាងមិនដូចគ្នា ភិក្ខុមួយរូបៗ ធ្វើការងារខុសៗ គ្នា ។ អ្នកបម្រើនោះឃើញថា ភិក្ខុក្នុងវិហារមានច្រើន ទើបទៅប្រាប់ពេទ្យជីវកថា ក្នុងវិហារមានភិក្ខុសង្ឃច្រើន ខ្ញុំមិនស្គាល់លោកម្ចាស់ដែលឲ្យទៅនិមន្តមកនោះទេ ។ ពេទ្យជីវកទូលសួរព្រះសាស្ដាម្ដងទៀតថា ភិក្ខុដែលអង្គុយក្នុងវិហារឈ្មោះអ្វី ព្រះសាស្ដាត្រាស់ថា ឈ្មោះចូឡបន្ថកៈ ។ ពេទ្យជីវកប្រើអ្នកបម្រើទៀតថា នែអ្នក ចូរទៅ ហើយសួរថា លោកម្ចាស់អង្គណាឈ្មោះចូឡបន្ថកៈ ហើយចូរនិមន្តព្រះថេរៈរូបនោះមក ។

អ្នកបម្រើនោះទៅកាន់វិហារ ហើយសួរថា ភិក្ខុរូបណាឈ្មោះចូឡបន្ថកៈ ភិក្ខុទាំង ១០០០ រូប ក៏ឆ្លើយដំណាលគ្នាថា អាត្មាឈ្មោះចូឡបន្ថកៈ ។ អ្នកបម្រើនោះត្រឡប់មកប្រាប់ការប្រព្រឹត្តទៅដល់ពេទ្យជីវក ។ ព្រោះភាពដែលខ្លួនបាក់ចុះសច្ចៈហើយ ទើបពេទ្យជីវកដឹងដោយន័យថា លោកម្ចាស់អង្គនេះមានឫទ្ធិច្រើន ហើយពោលថា នែអ្នក ចូរអ្នកទៅពោលនឹងលោកម្ចាស់ដោយការនិយាយតែម្ដងថា ព្រះសាស្ដាត្រាស់ឲ្យនិមន្តលោកម្ចាស់ រួចចូរចាប់ជាយចីវរចុះ ។ អ្នកបម្រើនោះទៅវិហារហើយ បានធ្វើតាមនោះ ក្នុងខណៈនោះឯង ភិក្ខុដែលនិម្មិតហើយ ក៏វិនាសទៅ អ្នកបម្រើនោះបាននាំព្រះថេរៈទៅហើយ ។

ក្នុងខណៈនោះ ព្រះសាស្ដាទ្រង់ទទួលបបរ និងអាហារច្រើនប្រភេទ

មានខាទនីយាហារជាដើម ។ កាលព្រះទសពលទ្រង់ធ្វើកត្តកិច្ចស្រេចហើយ ក៏យាងត្រឡប់ទៅកាន់វិហារ ការសន្ទនាក៏កើតឡើងក្នុងរោងធម្មសភាថា ឱ ! អានុភាពរបស់ព្រះពុទ្ធ ដែលបានធ្វើឲ្យចូឡបន្ថកៈមិនអាចរៀនមួយគាថា ក្នុង ៤ ខែបាន ធ្វើឲ្យជាអ្នកមានឫទ្ធិច្រើនយ៉ាងនេះ ដោយរយៈពេលបន្តិចបន្តួច ។ ព្រះសាស្តាទ្រង់ស្តាប់ពាក្យសន្ទនារបស់ភិក្ខុទាំងនោះ ទើបយាងមកគង់លើពុទ្ធាសនៈ ហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកកំពុងនិយាយដល់រឿងអ្វី កាលភិក្ខុទាំងឡាយទូលថា រឿងឈ្មោះនេះព្រះអង្គ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ចូឡបន្ថកៈតាំងនៅក្នុងឱវាទរបស់តថាគត បានលោកុត្តរសម្បត្តិ ឯក្នុងជាតិមុន បានលោកិយសម្បត្តិ ដូច្នេះ ត្រូវភិក្ខុទាំងនោះទូលអារាធនាហើយ ទើបត្រាស់ចូឡសេដ្ឋីជាតក ។

ក្នុងកាលតមក ព្រះសាស្តា ដែលពួកព្រះអរិយៈចោមរោមហើយ គង់លើធម្មាសនៈ តាំងចូឡបន្ថកៈនោះក្នុងតំណែងឯតទគ្គៈថា ម្នាលភិក្ខុទាំង-ឡាយ បណ្តាពួកភិក្ខុអ្នកនិមិត្តកាយសម្រេចតាមចិត្តបាន ដែលជាសាវ័ករបស់តថាគត ស្រេចនឹងចូឡបន្ថកៈប្រសើរជាងគេ ។ ពួកភិក្ខុអ្នកឈ្លាសក្នុងការបើកចិត្ត ស្រេចនឹងចូឡបន្ថកៈ ។ សម័យក្រោយមក ព្រះចូឡបន្ថកៈនោះ ត្រូវភិក្ខុទាំងឡាយសួរថា លោកល្វង់ដល់ម៉្លេះ លោកត្រាស់ដឹងសច្ចៈបានដូចម្តេច កាលប្រកាសដល់បដិបទារបស់ខ្លួន តាំងពីត្រូវបងប្រុសបណ្តេញ ទើបពោលគាថាទាំងនេះថា

ញាណគតិ របស់អាត្មាអញទន់ខ្សោយ ក្នុងកាលមុន អាត្មាអញ

ក្មេចក្លាំងស្មារតី ថែមទាំងបងប្រុស ក៏បណ្តេញអាត្មាអញថា ឥឡូវនេះ អ្នកចូរទៅផ្ទះចុះ ។ អាត្មាអញនោះ ត្រូវបងបណ្តេញហើយ ក៏តូចចិត្ត តែនៅមានអាឡោះអាល័យក្នុងសាសនា ក៏ឈរនៅជិតខ្លោងទ្វារ នៃអារាមរបស់សង្ឃនោះ ។ ព្រះមានព្រះភាគទ្រង់យាងមកក្នុងទីនោះ បានស្ទាបអង្អែលក្បាលរបស់អាត្មាអញហើយក៏ចាប់អាត្មាអញត្រង់ដើមដៃ ឲ្យចូលទៅកាន់អារាមនៃសង្ឃ ។ ព្រះសាស្តាទ្រង់ប្រទាននូវសំពត់សម្រាប់ជូតជើង ដោយសេចក្តីអនុគ្រោះដល់អាត្មាអញថា អ្នកចូរអធិដ្ឋាននូវសំពត់ស្អាតនេះធ្វើឲ្យជាសំពត់ដែលខ្លួនអធិដ្ឋានល្អហើយ ក្នុងទីដ៏សមគួរចុះ ។ លុះអាត្មាអញបានស្តាប់ព្រះបន្ទូល របស់ព្រះមានព្រះភាគនោះហើយ ក៏ត្រេកអរក្នុងសាសនា បានញុំាងសមាធិឲ្យសម្រេច ដើម្បីបាននូវប្រយោជន៍ដ៏ឧត្តម អាត្មាអញដឹងនូវបុព្វេនិវាស ទិព្វចក្ខុ អាត្មាអញបានជម្រះហើយ ត្រៃវិជ្ជា អាត្មាអញបានដល់ ដោយលំដាប់ហើយ ព្រះពុទ្ធសាសនា អាត្មាអញបានធ្វើហើយ ។ បន្ថកភិក្ខុនិម្មិតខ្លួនជាមួយពាន់ ហើយអង្គុយក្នុងអម្ពវ័នជាទីរីករាយ ដរាបដល់ការប្រាប់នូវកត្តកាល ។ លំដាប់នោះ ព្រះសាស្តាទ្រង់ប្រើទូតឲ្យទៅប្រាប់កត្តកាលដល់អាត្មាអញ កាលទូតមកប្រាប់កត្តកាល អាត្មាអញក៏មកតាមអាកាស ។ អាត្មាអញថ្វាយបង្គំព្រះបាទានៃព្រះសាស្តារួចហើយ អង្គុយក្នុងទីសមគួរ គ្រានោះ ព្រះសាស្តាទ្រង់ជ្រាបថា អាត្មាអញ

អគ្គិយហើយ ទើបបានទ្រង់ទទួល ( ទក្ខិណោទក ) ។ ព្រះអង្គជាទីបូជារបស់សត្វលោក ជាបដិគ្គាហករបស់បុគ្គលអ្នកបូជាទាំងឡាយ ជាបុញ្ញក្ខេត្ត របស់មនុស្សទាំងឡាយ ទ្រង់ទទួលនូវទក្ខិណាទាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧត្វា** បានដល់ ល្ងង់ខ្លៅ គឺខ្សោយកម្លាំង ព្រោះមិនអាចប្រើពេល ៤ ខែ រៀនគាថា ដែលប្រកបដោយបាទទាំង ៤ បាន ។

បទថា **គតី** បានដល់ ញាណគតិ ។ បទថា **អាសិ** ស្មើគ្នានឹង **អហោសិ** ប្រែថា កើត ។ បទថា **បរិភូតោ** បានដល់ ត្រូវមើលងាយអំពីបងប្រុសនោះឯងថា ជាមនុស្សវង្វេង មិនមានការដឹង ដូច្នេះ ។

បទថា **បុរេ** បានដល់ ក្នុងកាលមុន គឺក្នុងកាលជាបុថុជ្ជន ។ **ច** សព្ទក្នុងបទថា **ភាតា ច** នេះ ជាសមុច្ចយត្ថៈ សេចក្តីថា មិនមែនខ្ញុំត្រូវមើលងាយតែម្យ៉ាងប៉ុណ្ណោះទេ ដោយពិត សូម្បីបងប្រុសក៏បណ្តេញខ្ញុំ គឺអូសទាញខ្ញុំចេញទៅថា បន្ថកៈ លោកជាបុគ្គលល្ងង់ខ្លៅ ប្រហែលជាមិនមានហេតុក្នុងការត្រាស់ដឹង ព្រោះដូច្នោះ ទើបមិនអាចធ្វើកិច្ចនៃបព្វជិតឲ្យដល់ទីបំផុតបាន លោកមិនសមគួរក្នុងសាសនានេះ ឥឡូវនេះ ចូរលោកទៅកាន់ផ្ទះជីតាលោកចុះ ។ បទថា **ភាតា** បានដល់ បងប្រុស ។

បទថា **កោដ្ឋកេ** បានដល់ ក្បែរខ្លោងទ្វារ ។ បទថា **ទុម្មនោ** បានដល់ ដល់នូវទោមនស្ស ។ បទថា **សាសនស្មឹ អបេក្ខវា** បានដល់ នៅ

មានសេចក្តីអាល័យក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធ គឺមិនចង់សឹក ។

បទថា **ភគវា តត្ថ អាគច្ឆិ** សេចក្តីថា ព្រះមានព្រះភាគមានព្រះហឫទ័យ ត្រូវព្រះមហាករុណាជាស់តឿនហើយ កាលទ្រង់អនុគ្រោះខ្ញុំ ទើបយាងមកក្នុងទីដែលខ្ញុំឈរ ។ កាលទ្រង់យាងមកហើយ ទ្រង់លួងលោមថា ម្នាលបន្តកៈ តថាគតជាសាស្តារបស់អ្នក មិនមែនមហាបន្តកៈទេ ការបួសរបស់អ្នក ក៏ឧទ្ទិសចំពោះតថាគត ដូច្នេះ ទ្រង់អង្អែលក្បាលខ្ញុំ គឺកាលនឹងសម្តែងថា អ្នកជាកូនរបស់តថាគតក្នុងឥឡូវនេះឯង ដូច្នេះ ទើបទ្រង់អង្អែលក្បាលខ្ញុំ ដោយបាតព្រះហស្ត ដែលមានរូបកងចក្រជាគ្រឿងសម្គាល់ ដែលប្រទាក់ដូចក្រឡាសំណាញ់ មានសម្ផស្សទន់ ឯម្រាមព្រះហស្តផ្សាយចេញស្មើគ្នាល្អ មានព្រះសិរីល្អដូចផ្កាបទុមដែលរីកហើយ ។

បទថា **ពាហាយ មំ គហេត្វាន** សេចក្តីថា ព្រះសាស្តាត្រាស់សួរខ្ញុំថា ហេតុអ្វី ទើបអ្នកមកឈរក្នុងទីនេះ ដូច្នេះហើយ យកព្រះហស្តរបស់ទ្រង់ចាប់ខ្ញុំត្រង់ដើមដៃ នាំទៅកាន់ខាងក្នុងសង្ឃារាម ដែលមានកុដិនក្រអូបដោយខ្លឹមចន្ទន៍ ។

បទថា **ចាទាសិ ចាទបុញ្ឆនឹ** សេចក្តីថា ទ្រង់ប្រទានសំពត់ ដែលធ្វើសំពត់ជូតជើង គឺព្រះរាជទានឲ្យដោយត្រាស់ថា ចូរអ្នកធ្វើទុកក្នុងចិត្តថា **រជោហរណំ** ប្រែថា សំពត់សម្រាប់ជូតធូលី ដូច្នេះ ។ បាលីថា **អទាសិ** និង **ចាទបុញ្ឆនឹ** ដូច្នេះក៏មាន ។ ចំណែកអាចារ្យពួកខ្លះពោលថា បទថា **ចាទ-បុញ្ឆនឹ** បានដល់ ប្រទានកំណាត់សំពត់សម្រាប់ជូតជើង ដូច្នេះក៏មាន ។

ពាក្យនោះ មិនសមគួរ ព្រោះកំណាត់សំពត់នោះ ទ្រង់និម្មិតឡើងដោយឫទ្ធិប្រទានឲ្យ ។

បទថា **ឯតំ សុទ្ធំ អធិដ្ឋេហិ ឯកមន្តំ សុវិធិដ្ឋិតំ** សេចក្តីថា ចូរអ្នកអង្គុយក្នុងទីសមគួរ នាចំណែកម្ខាងត្រង់ខាងមុខព្រះគន្ធកុដិដែលស្អាត់ ចូរអធិដ្ឋានកំណាត់សំពត់សស្អាតនេះ ធ្វើឲ្យខ្ជាប់ខ្ជួន ដោយមនសិការថា **រជោ ហរណំ រជោ ហរណំ** គឺធ្វើរហូតទាល់តែចិត្តជាសមាធិប្រព្រឹត្តទៅ ។

បទថា **តស្សាហំ វចនំ សុត្វា** សេចក្តីថា ខ្ញុំស្តាប់ព្រះតម្រាស់ដែលជាឱវាទរបស់ព្រះមានព្រះភាគអង្គនោះហើយ ត្រេកអរក្នុងពាក្យប្រៀនប្រដៅ គឺក្នុងឱវាទនោះហើយ ជាអ្នកបដិបត្តិពាក្យប្រៀនប្រដៅ ។ បានញុំាងសមាធិឲ្យសម្រេច ដើម្បីបាននូវប្រយោជន៍ដ៏ឧត្តម សេចក្តីថា ខ្ញុំធ្វើរបជ្ញានឲ្យកើតឡើងហើយ ដោយអំណាចការបរិកម្មកសិណដើម្បីសម្រេចអរហត្តដែលជាប្រយោជន៍ដ៏ឧត្តម ផ្តើមចម្រើនវិបស្សនា មានឈានជាបាទ ធ្វើអរហត្ត-មគ្គសមាធិឲ្យដល់ព្រមតាមលំដាប់នៃមគ្គ ។

បទថា **សមាធឹ** ក្នុងទីនេះ លោកសំដៅដល់សមាធិទូទៅ តាំងអំពីឧបចារសមាធិ រហូតដល់អរហត្តមគ្គសមាធិ ។ ឯអរហត្តផលសមាធិ លោកសំដៅដល់សព្ទថា **ឧត្តមត្ថស្ស** តែព្រះចូឡបន្ថកៈនេះ ឈ្លាសក្នុងសមាធិយ៉ាងល្អ ព្រោះហេតុនោះ ទើបលោកពោលថា **សមាធឹ បដិបាទេសឹ** ដូច្នេះជាដើម ។

ពិតហើយ ព្រះចូឡបន្ថកៈអង្គនេះ ជាអ្នកឈ្លាសក្នុងសមាធិ ទើបក្លាយ

ជាអ្នកឈ្លាសក្នុងការបើកចិត្ត ចំណែកព្រះមហាបន្ថកត្ថេរ ព្រោះលោកជាអ្នកឈ្លាសក្នុងវិបស្សនា ទើបជាអ្នកឈ្លាសក្នុងការបើកបញ្ញា ។ លោកពណ៌នាថា ក្នុងព្រះថេរៈ ២ រូបនោះ មួយរូបជាអ្នកឈ្លាសក្នុងលក្ខណៈនៃសមាធិ មួយរូបជាអ្នកឈ្លាសក្នុងលក្ខណៈនៃវិបស្សនា មួយរូបឈមចុះក្នុងសមាធិ មួយរូបឈមចុះក្នុងវិបស្សនា មួយរូបជាអ្នកឈ្លាសក្នុងការសង្ខេបអវយវៈ ( ធ្វើកាយឲ្យតូច ) មួយរូបជាអ្នកឈ្លាសក្នុងការសង្ខេបអារម្មណ៍ ( ធ្វើអារម្មណ៍ឲ្យតូច ) មួយរូប ជាអ្នកឈ្លាសក្នុងការកំណត់កាយ មួយរូបជាអ្នកឈ្លាសក្នុងការកំណត់អារម្មណ៍ ។

ម្យ៉ាងទៀត លោកពោលថា ព្រះចូឡបន្ថកត្ថេរជាអ្នកឈ្លាសក្នុងការបើកចិត្ត ព្រោះលោកបាននូវរូបាវចរជ្ឈាន ៤ យ៉ាងល្អក្រៃលែង ។ ព្រះមហាបន្ថកត្ថេរជាអ្នកឈ្លាសក្នុងការបើកបញ្ញា ព្រោះលោកបានអរូបាវចរជ្ឈាន ៤ ដ៏ល្អក្រៃលែង ។ ម្យ៉ាងទៀត ព្រះថេរៈទី ១ ជាអ្នកឈ្លាសក្នុងការបើកចិត្តថា អញជាអ្នកបានរូបាវចរជ្ឈាន ចេញអំពីអង្គឈានទាំងឡាយហើយ សម្រេចអរហត្ត ព្រះថេរៈមួយអង្គទៀត ជាអ្នកឈ្លាសក្នុងការបើកបញ្ញា ព្រោះបានអរូបាវចរជ្ឈាន ចេញអំពីអង្គឈានទាំងឡាយហើយសម្រេចអរហត្ត ។

ភិក្ខុដទៃកាលនិម្មិតកាយដែលសម្រេចដោយចិត្ត ក៏និម្មិតបាន ៣ នាក់ ខ្លះ ៤ អ្នកខ្លះ និម្មិតច្រើននាក់មិនបាន និម្មិតបានដូចរូបដើមតែម្យ៉ាង ហើយធ្វើការងារប្រភេទតែមួយប៉ុណ្ណោះ ឯព្រះថេរៈនេះ និម្មិតសមណៈ ១០០០

ដោយអាវជ្ជនៈតែមួយ មនុស្ស ២ នាក់ មានកាយមិនដូចគ្នា មិនធ្វើការតែមួយដូចគ្នា ព្រោះហេតុនោះ ទើបលោកជាកំពូលជាងភិក្ខុទាំងឡាយខាងបើកចិត្ត ( និម្មិតកាយដែលសម្រេចដោយចិត្ត ) ។

ឥឡូវនេះ ដើម្បីសម្តែងដល់គុណវិសេស ដែលខ្លួនសម្រេចហើយ ទើបលោកពោលពាក្យជាដើមថា **បុព្វេនិវាសំ ជានាមិ** ដូច្នេះ ។ ព្រះថេរៈជាអ្នកបានអភិញ្ញា ៦ ក៏ពិត តែដើម្បីសម្តែងអភិញ្ញាដែលមានឧបការៈច្រើនដល់ការសម្រេចអាសវក្ខយញ្ញាណ ទើបពោលពាក្យថា អាត្មាអញដឹងនូវបុព្វេ-និវាស ទិព្វចក្ខុ អាត្មាអញបានជម្រះហើយ ដូច្នេះហើយ ពោលបន្តថា ត្រៃវិជ្ជា អាត្មាអញបានដល់ដោយលំដាប់ហើយជាដើម ។ ពិតហើយ បុព្វេ-និវាសញ្ញាណ យថាកម្មូបគញ្ញាណ និងអនាគតំសញ្ញាណ មានឧបការៈច្រើន ដល់ការបំពេញវិបស្សនាញាណក្រៅអំពីនេះ មិនមានឧបការៈយ៉ាងនោះឡើយ ។

បទថា **សហស្សក្ខត្តុំ** ប្រែថា ១០០០ អាចារ្យពួកខ្លះពោលថា ១០០០ ដង ដូច្នេះក៏មាន ។ ព្រះថេរៈនិម្មិតកាយដែលសម្រេចដោយចិត្តជា ១០០០ ដោយអាវជ្ជនៈតែមួយ មិនមែនប្រើអាវជ្ជនៈម្តងមួយនាក់ ។ ឯរាងកាយដែលនិម្មិតហើយនោះឯង ធ្វើការងារដូចគ្នាក៏បាន ផ្សេងគ្នាក៏បាន ។ សួរថា ការនិម្មិតដោយឫទ្ធិបែបនេះ រមែងមានដល់សាវកទាំងឡាយឬ ឆ្លើយថា មិនមានដល់សាវកទាំងពួងឡើយ ព្រះថេរៈអង្គនេះប៉ុណ្ណោះ ធ្វើបានយ៉ាងនេះ ព្រោះដល់ព្រមនៃអភិនីហារ ពិតហើយ ដោយហេតុនេះ ទើបព្រះថេរៈបាន

ទទួលឯតទគ្គៈយ៉ាងនោះ ។

បទថា **បណ្ឌុកោ និសីទិ** សេចក្តីថា ព្រះថេរៈពោលនឹងខ្លួនឯងដូចជាអ្នកដទៃ ។ បទថា **អម្ពវនេ** បានដល់ ក្នុងអម្ពវ័នដែលជាវិហារ ដែលពេទ្យជីវកសាងឧទ្ទិស ( ព្រះមានព្រះភាគ ) ។

បទថា **វេហាសា** ក្នុងបទថា **វេហាសាឧបសង្កមី** នេះ ជាបញ្ចមីវិភត្តិ ចុះក្នុងអត្ថតតិយាវិភត្តិ សេចក្តីថា ក្នុងអាកាស ។ **ឧ** អក្ខរៈ គ្រាន់តែធ្វើការភ្ជាប់បទ ។

បទថា **អជ** បានដល់ ខាងក្រោយអំពីការអន្តុយរបស់ខ្ញុំ ។ បទថា **បដិគ្គហិ** បានដល់ ទ្រង់ទទួលទក្ខិណោទក ។ បទថា **អាយាគោ សព្វ-លោកស្ស** សេចក្តីថា ជាអ្នកតាំងនៅក្នុងឋានៈដែលសត្វលោកទាំងពួង ព្រមទាំងទេវលោក គប្បីនាំទេយ្យធម៌មកបូជា ព្រោះអង្គជាអគ្គទក្ខិណេយ្យ-បុគ្គល ។

បទថា **អាហុតីនំ បដិគ្គហោ** សេចក្តីថា ជាអ្នកគួរទទួលទក្ខិណាដែលគេនាំមកបូជា ដោយធ្វើឲ្យមានផលច្រើន ។

បទថា **បដិគ្គណ្ហិត្ថ ទក្ខិណំ** បានដល់ ទទួលទក្ខិណា មានបបរ និងរបស់គួរទំពាជាដើមដែលពេទ្យជីវកបង្អោននាំមកថ្វាយ ។

លំដាប់នោះឯង ព្រះមានព្រះភាគទ្រង់ធ្វើកត្តកិច្ចស្រេចហើយ ទ្រង់ត្រាស់នឹងចូឡបន្ថកៈថា ចូរអ្នកធ្វើអនុមោទនា ។ ព្រះថេរៈនោះ ព្រោះភាពដែលលោកសម្រេចបដិសម្ភិទា កាលធ្វើពុទ្ធវចនៈ គឺព្រះត្រៃបិដកឲ្យខ្វះខ្វារ

ហាក់ដូចអញ្ជាស្រ័យរបស់ព្រះសាស្តា ធ្វើអនុមោទនាហាក់បីដូចជាចាប់នូវភ្នំសិនេរុ យកមកគរមហាសមុទ្រ ដូច្នោះ ។ ពិតហើយ ព្រះថេរៈរូបនេះ ដល់ព្រមដោយឧបនិស្ស័យយ៉ាងនេះ ក៏ត្រូវកម្មចាស់ដែលសេសសល់ មានសភាពបែបនោះបៀតបៀនបាន គឺមិនអាចប្រើពេល ៤ ខែ រៀនគាថា ៤ បាទបាន ព្រះមុនីទ្រង់ឃើញឧបនិស្ស័យសម្បត្តិរបស់ព្រះថេរៈហើយ ទ្រង់ទូន្មានឲ្យប្រើយោនិសោមនសិការ ដែលសមគួរដល់ការប្រព្រឹត្ត ដែលធ្លាប់មានមកក្នុងកាលមុន ។ ពិតហើយ ព្រះមានព្រះភាគ គង់ក្នុងនិវេសន៍របស់ពេទ្យជីវក ក្នុងកាលនោះ យ៉ាងនោះឯង ទ្រង់ជ្រាបថា ចិត្តរបស់ព្រះចូឡ-បន្ថកៈជាសមាធិហើយ បដិបត្តិត្រូវផ្លូវនៃវិបស្សនាហើយ ដូច្នេះ ទ្រង់សម្តែងព្រះកាយឲ្យប្រាកដ ទាំងដែលប្រថាប់គង់នោះឯង កាលនឹងសម្តែងថា ម្នាលបន្ថកៈ សូម្បីកំណាត់សំពត់នេះ ជារបស់សៅហ្មង ប្រឡាក់ដោយធូលី តែធម៌ដទៃក្រៅអំពីសំពត់នេះដែលសៅហ្មង នឹងមានធូលីក្នុងអរិយវិន័យ ទើបត្រាស់គាថា ( ក្នុងខុទ្ទកនិកាយ មហានិទ្ទេស ) ៣ គាថានេះថា

ធូលី គឺរាគៈ មិនមែនសំដៅយកលម្អងទេ ពាក្យថា ធូលីនុ៎ះ ជាឈ្មោះនៃរាគៈ បណ្ឌិតទាំងនោះ រមែងលះបង់នូវធូលីនុ៎ះ ហើយ

សម្រាកសម្រាន្តនៅក្នុងសាសនានៃព្រះពុទ្ធ ដែលប្រាសចាកធូលី ។ ធូលី គឺទោសៈ មិនមែនសំដៅយកលម្អងទេ ពាក្យថា ធូលីនុ៎ះ ជាឈ្មោះនៃទោសៈ បណ្ឌិតទាំងនោះ រមែងលះបង់នូវធូលីនុ៎ះ ហើយសម្រាកសម្រាន្តនៅក្នុងសាសនានៃព្រះពុទ្ធ ដែលប្រាសចាក ធូលី ។ ធូលី គឺមោហៈ មិនមែនសំដៅយកលម្អងទេ ពាក្យថា ធូលីនុ៎ះ ជាឈ្មោះនៃមោហៈ បណ្ឌិតទាំងនោះ រមែងលះបង់នូវ ធូលីនុ៎ះ ហើយសម្រាកសម្រាន្តនៅក្នុងសាសនានៃព្រះពុទ្ធ ដែល ប្រាសចាកធូលី ដូច្នេះ ។

ក្នុងកាលចប់គាថា ព្រះចូឡបន្ថកៈសម្រេចអរហត្ត ដែលមានអភិញ្ញា និងបដិសម្ភិទាជាបរិវារ ។l៚

**អដ្ឋកថា ចូឡបន្ថកត្ថេរគាថា ចប់**

# សុត្តន្តបិដក

## កបេ្បាត្ថេរគាថា

[ ២៣៨ ] កាយដ៏ពេញដោយមន្ទិល មានចំណែកផ្សេងៗ កើតក្នុងរណ្តៅលាមកធំ គឺផ្ទៃមាតា ដូចជ្រាំចាស់ដែលអាប់អួយូរ ឬដូចបូសធំ ដំបៅធំ ជាកាយដ៏ពេញដោយខ្ទុះ និងឈាម ពេញព្រៀបក្នុងរណ្តៅលាមក ជាទីហូរចេញនៃទឹក រមែងហូរចេញនូវវត្ថុមិនស្អាតសព្វៗ កាល ។ កាយ ដែលចងភ្ជាប់ដោយសរសៃធំ ៦០ លាបដោយគ្រឿងលាប គឺសាច់ ប្រដាប់ដោយអាវ គឺស្បែក ជាកាយស្អុយរកប្រយោជន៍គ្មាន តភ្ជាប់គ្នាដោយរាងឆ្អឹង ចងស្រាក់ដោយចេស គឺសរសៃ សម្រេចឥរិយាបថបាន ព្រោះប្រជុំនៃអាការមិនតែមួយ ។ កាយមានដំណើរទៅរកសេចក្តីស្លាប់ ដ៏ទៀងទាត់ ( ឋិតនៅ ) ក្នុងសម្នាក់នៃមច្ចុរាជ ឯនរជនតែងទម្លាក់ចោលនូវកាយ ក្នុងលោកនេះហើយទៅតាមយថាកម្ម ។ កាយត្រូវអវិជ្ជា ដោតក្រងហើយ ត្រូវគ្រឿងចាក់ស្រែះ ៤ យ៉ាងចាក់ស្រែះហើយ កាយក៏លិចចុះក្នុងឱឃៈត្រូវបណ្តាញនៃអនុសយៈ គ្របសង្កត់ហើយ ប្រកបក្នុងនីវរណៈ ៥ ពេញដោយមិច្ឆាវិតក្ក ជាប់ដោយមូលនៃភព គឺតណ្ហា ត្រូវជំបូលគឺមោហៈបិទបាំងហើយ កាយនេះ រមែងប្រព្រឹត្តទៅដូចពោលមកនេះ អន្ទោលទៅតាមយន្ត គឺកម្ម ។ ធម្មតាសម្បត្តិ តែងមានវិបត្តិជាទីបំផុត ការកើតផ្សេងៗ រមែងវិនាសទៅវិញ ។ ពួកជនណា ជាអន្ធពាលបុថុជ្ជន រាប់អានកាយនេះ ពួកជននោះ រមែងញុំាងសង្សារ

ដ៏ពន្លឹកឲ្យចម្រើន តែងកាន់យកនូវភពថ្មីទៀត ។ ពួកជនណា វៀរ បង់នូវកាយនេះ ដូចបុគ្គលវៀរបង់ នូវអាសិរពិស ដែលប្រឡាក់ ដោយលាមក ពួកជននោះ រមែងខ្ជាក់ចោលនូវអវិជ្ជា និងតណ្ហា ដែលជាមូលនៃភព ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។

កប្បត្ថេរ

# អដ្ឋកថា

## កប្បត្ថេរគាថា

[ ២៣៨ ] គាថារបស់ព្រះកប្បត្ថេរ មានពាក្យផ្ដើមថា **នានាកុលមលសម្បុណ្ណោ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើហើយ ក្នុងព្រះសម្ពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈ កើតក្នុងត្រកូលដែលសម្បូរ ដោយទ្រព្យសម្បត្តិច្រើន អំណឹះអត់អំពីបិតាទៅ ដល់នូវភាពជាអ្នកដឹងក្ដី ហើយ សម្បូរដោយកប្បព្រឹក្ស ដោយសំពត់ដែលវិចិត្រដោយពណ៌ច្រើន ពណ៌ ដោយអាភរណៈច្រើនប្រភេទ ដោយកែវមណីច្រើនប្រភេទ និងដោយ កម្រងផ្កាច្រើនប្រភេទជាដើម ហើយបូជាស្តូបរបស់ព្រះសាស្ដា ដោយ

ដើមកប្បព្រឹក្ស ។

ដោយបុញ្ញកម្មនោះ កុលបុត្រនោះអន្ទោលទៅក្នុងទេវតា និងមនុស្ស ទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងរាជត្រកូលដែលដល់ព្រមដោយគ្រឿង ប្រដាប់ក្នុងមគធរដ្ឋ លុះព្រះបិតាសោយទិវង្គតហើយ ទ្រង់តាំងនៅក្នុង រាជសម្បត្តិ ហើយទ្រង់ជាអ្នកត្រេកអរច្រើនក្នុងកាមទាំងឡាយពន់ប្រមាណ ។

ព្រះសាស្តា ទ្រង់ចេញអំពីមហាករុណាសមាបត្តិ ទ្រង់ប្រមើលមើល សត្វលោក ឃើញកុលបុត្តនោះមកប្រាកដក្នុងសំណាញ់ញាណហើយ ទ្រង់ ពិចារណាថា តើនឹងមានអ្វីហ្ន៎ ដូច្នេះ ទ្រង់ជ្រាបថា ព្រះរាជាអង្គនេះ បាន ស្តាប់អសុភកថាក្នុងសម្នាក់របស់តថាគតហើយ នឹងជាអ្នកមានចិត្តប្រាសចាក តម្រេកក្នុងកាមទាំងឡាយ ទ្រង់បួសហើយ នឹងបានសម្រេចអរហត្ត ដូច្នេះ ហើយ ទ្រង់យាងទៅក្នុងទីនោះតាមអាកាស ហើយត្រាស់អសុភកថាដល់ព្រះ រាជាអង្គនោះ ដោយគាថាទាំងនេះថា

កាយដ៏ពេញដោយមន្ទិល មានចំណែកផ្សេងៗ កើតក្នុងរណ្តៅ
លាមកធំ គឺផ្ទៃមាតា ដូចជ្រាំចាស់ដែលអាប់អួយួរ ឬដូចបូសធំ
ដំបៅធំ ជាកាយដ៏ពេញដោយខ្ទុះ និងឈាម ពេញព្រៀបក្នុង
រណ្តៅលាមក ជាទីហូរចេញនៃទឹក រមែងហូរចេញនូវវត្ថុមិនស្អាត
សព្វៗ កាល ។ កាយ ដែលចងភ្ជាប់ដោយសរសៃធំ ៦០ លាប
ដោយគ្រឿងលាប គឺសាច់ ប្រដាប់ដោយអាវ គឺស្បែក ជាកាយ
ស្អុយ រកប្រយោជន៍គ្មាន តភ្ជាប់គ្នាដោយរាងឆ្អឹង ចងស្រោក់ដោយ

ចេស គឺសរសៃ សម្រេចឥរិយាបថបាន ព្រោះប្រជុំនៃអាការ មិនតែមួយ ៗ កាយ មានដំណើរទៅរកសេចក្ដីស្លាប់ ដ៏ទៀងទាត់ ( បិតនៅ ) ក្នុងសម្នាក់នៃមច្ចុរាជ ឯនរជនតែងទម្លាក់ចោលនូវកាយ ក្នុងលោកនេះ ហើយទៅតាមយថាកម្ម ៗ កាយត្រូវអវិជ្ជាជោត ក្រងហើយ ត្រូវគ្រឿងចាក់ស្រែះ ៤ យ៉ាងចាក់ស្រែះហើយ កាយ ក៏លិចចុះក្នុងឱឃៈ ត្រូវបណ្ដាញនៃអនុសយៈ គ្របសង្កត់ហើយ ប្រកបក្នុងនីវរណៈ ៥ ពេញដោយមិច្ឆាវិតក្ក ជាប់ដោយមូលនៃ ភព គឺតណ្ហា ត្រូវជំបូល គឺមោហៈបិទបាំងហើយ កាយនេះ រមែងប្រព្រឹត្តទៅដូចពោលមកនេះ អន្ទោលទៅតាមយន្ត គឺកម្ម ៗ ធម្មតាសម្បត្តិ តែងមានវិបត្តិជាទីបំផុត ការកើតផ្សេងៗ រមែង វិនាសទៅវិញ ៗ ពួកជនណា ជាអន្ធពាលបុថុជ្ជន រាប់អានកាយ នេះ ពួកជននោះ រមែងញុំាងសង្សារដ៏ពន្លឹកឲ្យចម្រើន តែងកាន់ យកនូវភពថ្មីទៀត ៗ ពួកជនណា វៀរចេញនូវកាយនេះ ដូចបុគ្គល វៀរចេញនូវអាសិរពិស ដែលប្រឡាក់ដោយលាមក ពួកជននោះ រមែងខ្ជាក់ចោលនូវអវិជ្ជា និងតណ្ហា ដែលជាមូលនៃភព ជាអ្នក មិនមានអាសវៈ នឹងបរិនិព្វាន ដូច្នេះ ៗ

ព្រះរាជាអង្គនោះទ្រង់ស្ដាប់អសុភកថា ដែលសម្ដែងសភាវៈនៃរាងកាយ តាមសេចក្ដីពិត មានទោសច្រើនបែបច្រើនយ៉ាង ក្នុងទីចំពោះព្រះភក្ត្រព្រះ សាស្ដា ទ្រង់នឿយណាយ ខ្ពើមរអើម រង្កៀស មានព្រះហឫទ័យសង្វេគ

ចំពោះរាងកាយរបស់ព្រះអង្គ ថ្វាយបង្គំព្រះសាស្តាហើយ ទូលសូមបព្វជ្ជាថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គគប្បីបានបព្វជ្ជាក្នុងសម្នាក់ព្រះមានព្រះភាគ ។ ព្រះសាស្តាទ្រង់ត្រាស់នឹងភិក្ខុមួយរូបដែលឈរក្បែរ ដោយព្រះតម្រាស់ថា ម្នាលភិក្ខុ ចូរអ្នកទៅ ចូរឲ្យព្រះរាជានេះបាននូវបព្វជ្ជាឧបសម្បទាហើយ សឹមមក ។

ភិក្ខុរូបនោះ ឲ្យតចបញ្ចកកម្មដ្ឋានហើយ ឲ្យព្រះរាជាអង្គនោះបព្វជ្ជា ព្រះរាជាអង្គនោះ ក្នុងខណៈដាក់កាំបិតកោរដល់សីសៈប៉ុណ្ណោះ ក៏សម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយ សមដូចគាថាព័ន្ធដែលលោកពោលក្នុងអបទានថា

ខ្ញុំបានដាំនូវដើមកប្បព្រឹក្សមួយដើម ព្រមទាំងព្យួរនូវសំពត់ដ៏វិចិត្រទាំងឡាយ នៅខាងមុខនៃព្រះស្តូបដ៏ប្រសើរ របស់ព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈ ។ ខ្ញុំទៅចាប់កំណើតណាៗ ទោះជាទេវតា ឬជាមនុស្ស សឹងមានដើមកប្បព្រឹក្សដ៏ល្អ ប្រតិស្ឋានទៀបមាត់ទ្វារផ្ទះនៃខ្ញុំ ។ យើងទាំងឡាយ គឺខ្ញុំផង បរិស័ទផង ពួកជនណានីមួយ ដែលមានធ្នាំស្មើគ្នានឹងខ្ញុំផង តែងកាន់យកសំពត់អំពីដើមកប្បព្រឹក្សនោះ មកស្លៀកដណ្តប់ ក្នុងកាលនោះ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំដាំដើមឈើ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃដើមកប្បព្រឹក្ស ។ ក្នុងកប្បទី ៧ អំពីកប្បនេះ ខ្ញុំបានជាក្សត្រិយ៍ចក្រពត្តិ ៨ ដង ព្រះនាមសុចេលៈ

ដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ ទាំងមានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ ។

ព្រះថេរៈបានសម្រេចអរហត្តហើយ បានឧបសម្បទាហើយ ចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំ អង្គុយក្នុងទីសមគួរ នាចំណែកម្ខាង កាលនឹងព្យាករអរហត្ត ទើបពោលមួយគាថាទៀត ដោយហេតុនោះ ទើបគាថាទាំងនោះ ចាត់ជាថេរគាថា ។

បណ្តាបទទាំងនោះ បទថា **នានាកុលមលសម្បុណ្ណា** សេចក្តីថា ដែលពេញទៅដោយរបស់គួរខ្ពើមទាំងពួង និងរបស់ដែលជាមន្ទិល មានចំណែកផ្សេងៗ គឺពេញទៅដោយចំណែកដែលមិនស្អាតច្រើនប្រភេទ មានសក់ និងរោមជាដើម ។

រណ្តៅលាមក លោកហៅថា **ឧក្ការ** ក្នុងបទថា **មហាឧក្ការសម្ភវោ** នេះ ។ គភ៌របស់មាតា លោកបំណងថា រណ្តៅលាមកធំ ព្រោះសព្វកាលក្នុងគភ៌មាតា ដូចគ្នានឹងរណ្តៅលាមក ដែលនំដោយក្លិនមិនស្អាត គភ៌នេះជាដែនកើត គឺជាទីកើតឡើងនៃសត្វនោះ ហេតុនោះ ទើបឈ្មោះថា **មហា-ឧក្ការសម្ភវោ** ប្រែថា កើតក្នុងរណ្តៅលាមកធំ ។

បទថា **ចន្ទនិកាំវ** សេចក្តីថា កន្លែងដែលជាទីសម្រាប់ចាក់ទឹកមិនស្អាត និងមន្ទិលគភ៌ជាដើម ដែលពេញទៅដោយរបស់មិនស្អាតត្រឹមក្បាលជង្គង់ ទី

បែបនោះ ឈ្មោះថា រណ្តៅជ្រាំ ។

បទថា **បរិបក្កំ** បានដល់ ចាស់ ដែលមានមកយូរ ដោយហេតុនោះ ទើបលោកសម្តែងថា ប្រៀបដូចក្តៀងមានគ្រាប់ធំ ធ្លាក់ចុះក្នុងរដូវក្តៅ ជិតទ្វារស្រុកចណ្ឌាល របស់បដិកូលដែលពេញដោយសាកសពផ្សេងៗ មានបស្សាវៈ ឧច្ចារៈ ធ្អឹង ស្បែក សរសៃ ទឹកមាត់ ទឹកសម្បោរជាដើម ផ្សំចូលជាមួយទឹក ក៏ល្អក់ទៅដោយភក់ លុះកន្លងទៅ ២-៣ ថ្ងៃ ក៏កើតជាពួកដង្កូវ មានទឹកក្តៅបែកជាពពុះ ព្រោះត្រូវពន្លឺព្រះអាទិត្យ ខាងលើមានពពុះទឹក និងក្រពេញទឹកផុសឡើង មានពណ៌ខៀវ មានក្លិនស្អុយក្រៃលែង គួរខ្ពើសជាអណ្តូងជ្រាំ មិនគួរចូលទៅជិតផង មិនគួរសម្លឹងមើលផង ត្រូវឈរអំពីចម្ងាយ រាងកាយនេះក៏ដូច្នោះ ឈ្មោះថា **មហាគណ្ឌោ** ព្រោះប្រៀបដូចបូសធំ ព្រោះមានការប៉ោងឡើង ចាស់ដោយជុំវិញ និងបែកធ្លាយទៅជាសភាវៈ ដោយការកើតឡើង ចាស់ និងស្លាប់ទៅ ព្រោះប្រកបដោយមូលគឺសេចក្តីទុក្ខ និងព្រោះហូរចេញនូវវត្ថុមិនស្អាត ។

ឈ្មោះថា **មហាវណោ** ព្រោះប្រៀបដូចដំបៅធំ ព្រោះត្រូវអត់ធន់ចំពោះរបួស ព្រោះមានទុក្ខវេទនាជាប់តាម និងព្រោះជាទីហូរចេញនូវរបស់មិនស្អាត ។

បទថា **គូថភស្តាបេឧ គាឍ្ឍិតោ** បានដល់ ពេញដោយរណ្តៅលាមក ឬពេញដោយលាមក ។ បាលីថា **គូថភស្តាបមិគាឍ្ឍិតោ** ដូច្នេះក៏មាន អធិប្បាយថា ហូរចេញអំពីរណ្តៅលាមក ។

បទថា **អាទោបគ្ឃរណី កាយោ សទា សន្ទតិ បូតិកំ** សេចក្តីថា រាងកាយនេះ មានអាបោធាតុហូរចេញជាប្រក្រតីសព្វកាល សរីរៈនោះឯង មានតែរបស់ស្អុយ មិនស្អាត ដូចជាប្រមាត់ ស្លេស្ម ញើស និងមូត្រជាដើម ហូរចេញ មិនមានកាលណា ដែលមានវត្ថុស្អាតហូរចេញឡើយ ។

បទថា **សដ្ឋិកណ្ឌរសម្ពន្ធោ** សេចក្តីថា ឈ្មោះថា ចងដោយសរសៃធំ ៦០ ព្រោះមានសរសៃធំ ៦០ ត្រូវព័ទ្ធព័ន្ធគ្រប់កន្លែង គឺសរសៃដែលចងសរីរៈ តាំងអំពីចំណែកខាងលើនៃ-ក ត្រង់ខាងមុខ ខាងក្រោយ ខាងទទឹង និងខាងឆ្វេងនៃសរីរៈ មួយកន្លែង ៥ សរសៃ រួមជា ២០ សរសៃ ចងត្រង់ដៃ និងជើង ខាងមុខដៃ និងខាងក្រោយដៃ ត្រង់បាតជើង និងខ្នងជើង មួយកន្លែង ៥ សរសៃ រួមជា ៤០ សរសៃ ។

បទថា **មំសលេបនលេបិតោ** បានដល់ បូកលាបដោយគ្រឿងលាប គឺសាច់ អធិប្បាយថា បូកលាបដោយចម្រៀកសាច់ ៩០០ ដុំ ។

បទថា **ចម្មកញ្ចុកសន្នទ្ធោ** បានដល់ វេចខ្ចប់ និងបិទបាំងក្នុងទីទាំងពួង ដោយថង់ គឺស្បែក ។

បទថា **បូតិកាយោ** បានដល់ រាងកាយដែលមានក្លិនស្អុយទាំងមូល ។ បទថា **និរត្ថកោ** បានដល់ មិនមានប្រយោជន៍ អធិប្បាយថា ពិតហើយ រាងកាយរបស់ពួកសត្វដទៃ អាចមានប្រយោជន៍ ដោយប្រើជាគ្រឿងចង ដូចជាស្បែកជាដើម តែរាងកាយរបស់មនុស្សមិនមានប្រយោជន៍យ៉ាងនេះឡើយ ។

បទថា **អដ្ឋិសង្ឃាតឃដិតោ** បានដល់ ជារបស់ជាប់គ្នា ដោយការបន្តដោយគ្រោងឆ្អឹង ៣០០ កំណាត់ ។

បទថា **ន្ហារុសុត្តនិពន្ធនោ** បានដល់ ចងរឹតហើយដោយសរសៃ ៩០០ ដែលដូចគ្នានឹងសរសៃអំបោះ ។

បទថា **នេកេសំ សង្គតីភាវា** សេចក្តីថា សម្រេចឥរិយាបថ មានឈរជាដើម ដោយការទាក់ទង ដោយមហាភូតរូប ៤ ជីវិតិន្ទ្រិយ ខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញ និងវិញ្ញាណជាដើម ដូចគ្នានឹងយន្ត ដែលសម្រេចដោយការប្រជុំនៃសរសៃ និងខ្សែ ។

បទថា **ធុវប្បយាតោ មរណាស្ស** សេចក្តីថា ជាបុគ្គលដើរទៅរកសេចក្តីស្លាប់ដោយចំណែកមួយ គឺចាប់តាំងអំពីកើតមក ការស្លាប់ក៏នឹងធ្លាក់មកដល់ បន្ទាប់អំពីនោះ ក៏នៅក្នុងទីជិតមច្ចុរាជ គឺសេចក្តីស្លាប់នោះឯង ។

បទថា **ឥធេវ ឆឌ្ឌយិត្វាន** សេចក្តីថា សត្វនេះលះបង់រាងកាយក្នុងលោកនេះឯង ហើយក៏ទៅកាន់ទីដែលខ្លួនពេញចិត្ត ព្រោះដូច្នោះ ទើបលោកសម្តែងថា បុគ្គលមិនគប្បីធ្វើនូវការជាប់ជំពាក់យ៉ាងនេះ ព្រោះសត្វត្រូវលះបង់រាងកាយនេះទៅ ។

បទថា **អវិជ្ជាយ និវុតោ** បានដល់ រាងកាយនេះ ត្រូវគ្រឿងរាំង គឺអវិជ្ជាចោមរោមហើយ គឺមានទោស ដែលបិទបាំង អធិប្បាយថា បុគ្គលណាមួយ នឹងដឹងនូវការពាក់ព័ន្ធដទៃ ក្នុងកាយនេះបាន ។

បទថា **ចតុគ្គន្ថេន** បានដល់ ចងដោយគន្ថៈ ដែលជាគ្រឿងចង ៤

យ៉ាង មានគ្រឿងចង គឺអភិជ្ឈាកាយគន្ថៈជាដើម គឺរួបរឹតដោយភាពជាគ្រឿងចង ។

បទថា **ឱឃសំសីទនោ** បានដល់ ជាអ្នកលិចចុះក្នុងឱឃៈ ៤ មានកាមោឃៈជាដើម ព្រោះជាសភាពធ្វើឲ្យលិចចុះ ។ អនុស័យ មានកាមរាគៈជាដើម ឈ្មោះថា អនុសយក្កិលេស ព្រោះអត្ថថា ដេកត្រាំក្នុងសន្តានដោយភាពដែលមិនទាន់លះបាន ។

ឈ្មោះថា **អនុសយជាលមោត្ថតោ** ព្រោះគ្របដណ្តប់ គឺគ្របសង្កត់សត្វទាំងនោះដោយសំណាញ់ ។ **ម** អក្ខរៈ ត្រឹមតែធ្វើការភ្ជាប់បទ លោកពោលជាទីឃៈ ដើម្បីងាយស្រួលដល់ការចងគាថា ។ ឈ្មោះថា **បញ្ច-នីវរណោ** ព្រោះប្រកប គឺបង្អោនទៅក្នុងនីវរណធម៌ ៥ យ៉ាង មានកាមច្ឆន្ទៈជាដើម ។ បទថា **បញ្ចនីវរណោ** នេះ ជាសត្តមីវិភត្តិ ចុះក្នុងអត្ថនៃតតិយាវិភត្តិ ។

ឈ្មោះថា **វិតក្កេន សមប្បិតោ** ព្រោះដល់ព្រមហើយ គឺសម្បូរហើយដោយមិច្ឆាវិតក្ក មានកាមវិតក្កជាដើម ។ បទថា **តណ្ហាមូលេនា-នុគតោ** បានដល់ ត្រូវឫសគល់នៃភព គឺតណ្ហាចង ។

បទថា **មោហច្ឆាទនឆាទិតោ** បានដល់ គ្របដណ្តប់ដោយគ្រឿងបិទបាំង គឺសម្មោហៈ ។ ពាក្យទាំងអស់នោះ សំដៅដល់ ករជកាយដែលមានវិញ្ញាណ ។ ពិតហើយ អត្តភាពដែលមានវិញ្ញាណគ្រប់គ្រង លោកហៅថា **កាយ** ដូចប្រយោគ ( ទីឃនិកាយ ព្រហ្មជាលសូត្រ ) ជាដើមថា ម្នាលភិក្ខុ

ទាំងឡាយ កាយរបស់ព្រះតថាគត មានតណ្ហាដែលនាំទៅកាន់ភពថ្មីទៀតដាច់អស់ហើយ ( តែកាយនេះ ) ឋិតនៅ ដូច្នេះ និងដូចពុទ្ធដីកា ( សំយុត្តនិកាយ និទានវគ្គ ) មួយទៀតថា កាយនេះផង នាមរូបខាងក្រៅផង ដូច្នេះជាដើម ។

បទថា **ឋាយំ វត្តតី កាយោ** សេចក្តីថា កាយនេះ រមែងវិលទៅដោយប្រការដែលពោលហើយជាដើមថា កាយនេះពេញទៅដោយរបស់មិនស្អាត និងមន្ទិលផ្សេងៗ ត្រូវអវិជ្ជារឹតរុំហើយ ដូច្នេះ កាលវិលទៅ ក៏វិលជាប់តគ្នាទៅដោយគ្រឿងយន្ត គឺកម្ម ដែលខ្ជួនធ្វើល្អ និងធ្វើអាក្រក់ វិលទៅដោយមិនអាចដល់ដែនកន្សែមបាន គឺអន្ទោលទៅក្នុងសុគតិ និងទុគ្គតិ ។ បទថា **សម្បត្តិ ច វិបត្យន្តា** បានដល់ សម្បត្តិដែលមានក្នុងរាងកាយនេះ រមែងមានវិបត្តិក្នុងទីបំផុត ។ ពិតហើយ ភាពជាកំលោះ និងក្រមុំ ទាំងអស់ មានការចាស់ជាទីបំផុត ការមិនមានរោគទាំងអស់ មានការឈឺជាទីបំផុត ជីវិតទាំងអស់ មានការស្លាប់ជាទីបំផុត ការប្រជុំនៃសង្ខារទាំងអស់ មានការបែកចាកគ្នាជាទីបំផុត ដោយហេតុនោះ ទើបលោកពោលថា **ឆាឆាភាវោ វិបជ្ជតិ** ដូច្នេះជាដើម ។

បទថា **ឆាឆាភាវេា** បានដល់ ការវៀរ គឺការព្រាត់ប្រាសចាកគ្នា អធិប្បាយថា ការព្រាត់ប្រាសចាកគ្នានោះ រមែងដល់ គឺប្រព្រឹត្តទៅច្រើនយ៉ាង គឺជួនកាលដោយអំណាចនៃមនុស្សដែលព្រាត់ប្រាសទៅ ជួនកាលដោយអំណាចនៃទ្រព្យដែលបាត់បង់ទៅ ។

បទថា **យេមំ កាយំ មមាយន្តិ** សេចក្តីថា អន្ធពាលបុថុជ្ជនទាំងឡាយណា ប្រកាន់រាងកាយនេះ ដែលមិនស្អាត មិនទៀង មិនស្ថិតស្ថេរ ជាទុក្ខ មិនមានសារៈថា សរីរៈនេះជារបស់អញ ដូច្នេះ ញ៉ាំងធនូរាគៈឲ្យកើតឡើង បុគ្គលទាំងនោះ រមែងធ្វើសង្គ្រាវឲ្យវែងឆ្ងាយ គឺចម្រើននូវព្រៃស្មសាន ព្រោះ ( កាយនេះ ) បុគ្គលដែលមិនមែនបណ្ឌិតគប្បីត្រេកអរ ជារបស់មានភ័យគួរខ្លាច ដោយជាតិ និងដោយនរកជាដើម ឲ្យទូលំទូលាយដោយការកើត និងការស្លាប់រឿយៗ ជាដើម ដោយហេតុនោះ ទើបលោកពោលថា ពួកជនណា ជាអន្ធពាលបុថុជ្ជន រាប់អានកាយនេះ ពួកជននោះរមែងញ៉ាំងសង្គ្រាវដ៏ពន្លឹកឲ្យចម្រើន តែងកាន់យកនូវភពថ្មីទៀត ដូច្នេះជាដើម ។

បទថា **យេមំ កាយំ វិវជ្ជេន្តិ គូថលិត្តំវ បន្នគំ** សេចក្តីថា ប្រៀបដូចបុរសដែលប្រាថ្នាសេចក្តីសុខ ចង់មានជីវិត ឃើញលាមក ឬឃើញអាសិរពិស ហើយគេចទៅ គឺមិនប៉ះពាល់ ព្រោះជារបស់ដែលគួរស្អប់ស្អែង មានភ័យចំពោះមុខ យ៉ាងណា កុលបុត្រជាបណ្ឌិត ក៏យ៉ាងនោះដូចគ្នា ចៀសវាងសរីរៈនេះ ដែលគួរវៀស ព្រោះជារបស់មិនស្អាត មានភ័យចំពោះមុខ ព្រោះជាសភាពមិនទៀងជាដើម គឺលះដោយការកម្ចាត់ឆន្ទរាគៈ កុលបុត្តទាំងនោះ លះបង់អវិជ្ជា ដែលជាឫសគល់នៃភព និងតណ្ហាក្នុងភព ការលះបានជាសមុច្ឆេទហើយ បន្ទាប់អំពីនោះ ក៏ជាអ្នកមិនមានអាសវៈ ដោយប្រការទាំងពួង នឹងបរិនិព្វាន ដោយសឧបាទិសេសនិព្វានធាតុ និងអនុបាទិសេសនិព្វានធាតុ ដោយប្រការដូច្នេះ ។

**អដ្ឋកថា កប្បត្ថេរគាថា ចប់**

# សុត្តន្តបិដក

## ឧបសេនវង្គន្តបុត្តត្ថេរគាថា

[ ២៣៩ ] ភិក្ខុគប្បីសេពនូវសេនាសនៈស្ងាត់ ដែលមានសំឡេងតិចតិច ដែលម្រឹគសាហាវ អាស្រ័យនៅហើយ ព្រោះហេតុនៃការពួនសម្ងំ ។ ភិក្ខុគប្បីនាំមក ( នូវកំណាត់សំពត់ ) អំពីគំនរនៃសំរាម ឬព្រៃស្មសាន ឬចន្លោះនៃថ្នល់ ធ្វើជាសង្ឃាដី ដោយកំណាត់សំពត់ដែលខ្លួននាំមកនោះ ហើយទ្រទ្រង់នូវចីវរដ៏សៅហ្មង ។ ភិក្ខុគប្បីធ្វើចិត្តឲ្យទាប គ្រប់គ្រងនូវទ្វារ សង្រួមដោយប្រពៃ ហើយត្រាច់ទៅកាន់ផ្ទះជាលំដាប់ គឺចេញអំពីត្រកូល ១ ទៅកាន់ត្រកូល ១ ដើម្បីបិណ្ឌបាត ។ មួយទៀត ភិក្ខុត្រូវសន្តោស ដោយវត្ថុសៅហ្មង មិនគប្បីប្រាថ្នានូវរសឯទៀតឲ្យច្រើនទេ ចិត្តរបស់ភិក្ខុអ្នកជាប់ញ៉ាមក្នុងរសទាំងឡាយ រមែងមិនត្រេកអរក្នុងឈាន ។ មុនីគប្បីជាអ្នកមានសេចក្តីប្រាថ្នាតិច ជាអ្នកសន្តោស ជាអ្នកស្ងប់ស្ងាត់ នៅមិនច្រឡូកច្រឡំ ដោយបុគ្គលពីរពួក គឺគ្រហស្ថ និងបព្វជិត ។ មនុស្សល្ងង់ល្ងើនិងមនុស្សគ យ៉ាងណា បណ្ឌិតគប្បីសម្តែងខ្លួនយ៉ាងនោះ មិនគប្បីពោលឲ្យហួសប្រមាណ ក្នុងកណ្តាលសង្ឃ ។ បណ្ឌិតនោះ មិនគប្បីតិះដៀលបុគ្គលណាមួយ គប្បីវៀរបង់នូវការបៀតបៀនផង សង្រួមក្នុងបាតិមោក្ខផង ដឹងប្រមាណក្នុងភោជនផង ។ បណ្ឌិតគប្បីជាអ្នកឈ្លាសវៃ ក្នុងការកើតឡើងនៃចិត្ត ដែលមាននិមិត្តកំណត់ល្អហើយ គប្បីប្រកបរឿយៗ នូវសមថៈ និងវិបស្សនាតាមកាលគួរ គប្បីជា

អ្នកបរិបូណ៌ដោយព្យាយាម ប្រព្រឹត្តទៅរឿយៗ ប្រកបក្នុងធម៌ដ៏គួរ សព្វៗ កាល បើមិនទាន់ដល់នូវព្រះនិព្វានជាទីបំផុតនៃទុក្ខក្នុងវដ្តៈ ទេ កុំអាលដល់នូវសេចក្ដីទុកចិត្តឡើយ ។ កាលភិក្ខុប្រាថ្នានូវសេចក្ដីបរិសុទ្ធ សម្រាន្តនៅយ៉ាងនេះ អាសវៈទាំងពួង រមែងអស់ទៅ ភិក្ខុនោះ រមែងដល់នូវការរលត់ទុក្ខ ។

ឧបសេនវង្គន្តបុត្តត្ថេរ

# អដ្ឋកថា

## ឧបសេនវង្គន្តបុត្តត្ថេរគាថា

[ ២៣៩ ] គាថារបស់ព្រះឧបសេនវង្គន្តបុត្តត្ថេរ មានពាក្យផ្ដើមថា **វិវិត្តំ អប្បនិគ្ឃោសំ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កុលបុត្តនេះ កើតក្នុងផ្ទះមានត្រកូល ក្នុងហង្សវតីនគរ លុះចម្រើនវ័យហើយ ទៅស្ដាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្ដា ឃើញព្រះសាស្ដាទ្រង់តាំងភិក្ខុមួយរូបក្នុងតំណែងឯតទគ្គៈ នៃភិក្ខុទាំងឡាយ ដែលនាំសេចក្ដីជ្រះថ្លាមកឲ្យបុគ្គលជុំវិញ ទើបធ្វើបុញ្ញាធិការក្នុងសម្នាក់ព្រះសាស្ដា ហើយប្រាថ្នាតំណែងនោះ បំពេញតែកុសលដរាបដល់អស់ជីវិត អន្ទោលទៅក្នុងទេវតា និងមនុស្សទាំង

ឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងផ្ទៃព្រាហ្មណីឈ្មោះរូបសារី ក្នុងនាលកគ្រាម មានឈ្មោះថា **ឧបសេន** ។

ឧបសេនចម្រើនវ័យហើយ រៀនត្រៃវេទចប់ហើយ ស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្តា បានទូវសទ្ធាហើយចេញបួស មានវស្សា ១ បានឲ្យកុលបុត្តម្នាក់ឧបសម្បទាក្នុងសម្នាក់របស់ខ្លួន ដោយគិតថា អញនឹងញ៉ាំងបន្ទប់នៃព្រះអរិយៈឲ្យចម្រើន ដូច្នេះហើយ ទៅកាន់សម្នាក់របស់ព្រះសាស្តាមួយអន្លើដោយកុលបុត្តនោះ ព្រះសាស្តាទ្រង់ជ្រាបថា ភិក្ខុដែលមិនទាន់មានវស្សានោះ ជាសទ្ធិវិហារិករបស់ព្រះថេរៈ ទើបទ្រង់តិះដៀលថា ម្នាលមោឃបុរស អ្នកវិលមកដើម្បីការមានបរិស័ទច្រើនឆាប់ពេកណាស់ ទើបគិតថា ឥឡូវនេះ អាត្មាអញត្រូវព្រះសាស្តាតិះដៀលព្រោះបរិស័ទ ណ្ហើយចុះ អញនឹងអាស្រ័យបរិស័ទនោះឯង ឲ្យព្រះសាស្តាទ្រង់សរសើរ ដូច្នេះហើយ ទើបបំពេញវិបស្សនា មិនយូរប៉ុន្មានក៏សម្រេចអរហត្ត សមដូចគាថាព័ន្ធដែលលោកពោលក្នុងអបទានថា

ខ្ញុំចូលទៅគាល់ព្រះមានព្រះភាគ ព្រះនាមបទុមុត្តរៈ ព្រះអង្គជាធ្មេមក្នុងលោក អង់អាចជាងនរៈ ប្រសើរជាងនរៈ ដែលទ្រង់គង់នៅក្នុងញកភ្នំ ។ គ្រានោះ ខ្ញុំបានឃើញផ្កាកណិការរីក ក៏កាច់ផ្កានោះត្រង់ទង យកមកធ្វើប្រដាប់លើឆត្រហើយ បង្អោនចូលទៅថ្វាយព្រះសម្ពុទ្ធ ។ ទាំងបានថ្វាយចង្ហាន់បិណ្ឌបាត ជាភោជនដ៏ល្អឧត្តម ញ៉ាំងសមណៈ ៨ អង្គ គម្រប់ ៩ នឹងព្រះសម្ពុទ្ធ

ឲ្យចាន់ស្កប់ស្កល់ក្នុងទីនោះ ។ ព្រះសយម្ភូ មានព្យាយាមធំ ព្រះអង្គប្រសើរ ទ្រង់អនុមោទនាចំពោះការថ្វាយឆត្រ និងការថ្វាយចង្អាន់ដ៏ប្រសើរនេះថា

ដោយចិត្តជ្រះថ្លានោះ បុគ្គលនេះ នឹងបានទទួលសម្បត្តិ គឺនឹងបានគ្រប់គ្រងទេវរាជ្យ ជាធំជាងទេវតាអស់ ៣០ ដង ។ នឹងបានជាស្តេចចក្រពត្តិអស់ ២១ ដង នឹងបានគ្រប់គ្រងប្រទេសរាជ្យដ៏ធំទូលាយ រាប់បានមួយអសំខេយ្យកប្ប ។ ព្រះសម្ពុទ្ធទាំងឡាយ ទ្រង់ត្រាស់ហៅបណ្ឌិតណា ជាអ្នកមានប្រាជ្ញាដូចផែនដី មានប្រាជ្ញាល្អ ថាជាអ្នកមានប្រាជ្ញាល្អ បណ្ឌិតនុ៎ះ នឹងកើតក្នុងឧក្កាកត្រកូល ក្នុងកប្បទីមួយសែន អំពីកប្បនេះ ។ បណ្ឌិតនុ៎ះ នឹងបានជាព្រះពុទ្ធព្រះនាមគោតម កាលបើសាសនានៃព្រះគោតមរុងរឿង បុគ្គល ( អ្នកថ្វាយផ្កា ) នោះ នឹងទៅកាន់អត្តភាពជាមនុស្ស ឈ្មោះឧបសេនៈ នឹងបានជាសាវ័ករបស់ព្រះសាស្តាព្រះនាមគោតមនោះ ។

គុណវិសេស ជាទីបំផុតរបស់ខ្ញុំ កំពុងប្រព្រឹត្តទៅ ភពទាំងអស់ខ្ញុំបានដកចោលហើយ ខ្ញុំបានឈ្នះមារ ព្រមទាំងសេនារបស់មារហើយទ្រទ្រង់នូវរាងកាយជាទីបំផុត ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ ។

កាលសម្រេចអរហត្តហើយ ខ្លួនឯងសមាទានធុតង្គធម៌ទាំងអស់ផង បបួលឲ្យភិក្ខុដទៃសមាទានផង ដើម្បីប្រយោជន៍ដល់ធុតង្គធម៌នោះ ដោយហេតុនោះ ទើបព្រះមានព្រះភាគទ្រង់តាំងព្រះថេរៈនោះ ក្នុងតំណែងឯតទគ្គៈនៃភិក្ខុទាំងឡាយ ដែលនាំសេចក្ដីជ្រះថ្លាមកឲ្យបុគ្គលដោយជុំវិញ ។ សម័យតមក កាលភិក្ខុក្នុងក្រុងកោសម្ពី មានជម្លោះនឹងគ្នា ភិក្ខុសង្ឃបែកគ្នាជា ២ ពួក ព្រះថេរៈត្រូវភិក្ខុមួយរូបបំណងនឹងចៀសវាងនូវជម្លោះនេះ សួរថា ឥឡូវនេះ ជម្លោះកើតឡើងហើយ សង្ឃបែកគ្នាជា ២ ពួក ខ្ញុំគប្បីបដិបត្តិដូចម្ដេចហ្ន៎ ដូច្នេះ ការពោលបដិបទាដល់ភិក្ខុរូបនោះ តាំងអំពីការនៅយ៉ាងស្ងប់ទើបពោលគាថាទាំងនេះថា

*ភិក្ខុគប្បីសេពនូវសេនាសនៈស្ងាត់ ដែលមានសំឡេងតិកកងតិច ដែលម្រឹគសាហាវ អាស្រ័យនៅហើយ ព្រោះហេតុនៃការពួនសម្ងំ ។ ភិក្ខុគប្បីនាំមក ( នូវកំណាត់សំពត់ ) អំពីគំនរនៃសំរាម ឬព្រៃស្មសាន ឬចន្លោះនៃថ្នល់ ធ្វើជាសង្ឃាដី ដោយកំណាត់សំពត់ ដែលខ្លួននាំមកនោះ ហើយទ្រទ្រង់នូវចីវរដ៏សៅហ្មង ។ ភិក្ខុគប្បីធ្វើចិត្តឲ្យទាប គ្រប់គ្រងនូវទ្វារ សង្រួមដោយប្រពៃ ហើយត្រាច់ទៅកាន់ផ្ទះជាលំដាប់ គឺចេញអំពីត្រកូល ១ ទៅកាន់ត្រកូល ១ ដើម្បីបិណ្ឌបាត ។ មួយវិញទៀត ភិក្ខុត្រូវសន្ដោសដោយវត្ថុសៅហ្មង មិនគប្បីប្រាថ្នានូវរសឯទៀតឲ្យច្រើនទេ ចិត្តរបស់ភិក្ខុអ្នកជាប់ញ៉ាំមក្នុងរសទាំងឡាយ រមែងមិនត្រេកអរក្នុង*

ឈាន ។ មុនីគប្បីជាអ្នកមានសេចក្តីប្រាថ្នាតិច ជាអ្នកសន្តោស ជាអ្នកស្ងប់ស្ងាត់ នៅមិនច្រឡូកច្រឡំ ដោយបុគ្គលពីរពួក គឺ គ្រហស្ថ និងបព្វជិត ។ មនុស្សល្ងេល្ងើ និងមនុស្សគ យ៉ាងណា បណ្ឌិតគប្បីសម្តែងខ្លួន យ៉ាងនោះ មិនគប្បីពោលឲ្យហួសប្រមាណ ក្នុងកណ្តាលសង្ឃ ។ បណ្ឌិតនោះ មិនគប្បីតិះដៀលបុគ្គលណា មួយ គប្បីវៀរបង់នូវការបៀតបៀនផង សង្រួមក្នុងបាតិមោក្ខផង ដឹងប្រមាណក្នុងភោជនផង ។ បណ្ឌិតគប្បីជាអ្នកឈ្លាសវៃក្នុងការ កើតឡើងនៃចិត្ត ដែលមាននិមិត្តកំណត់ល្អហើយ គប្បីប្រកប រឿយៗ នូវសមថៈ និងវិបស្សនាតាមកាលគួរ គប្បីជាអ្នកបរិបូណ៌ ដោយព្យាយាម ប្រព្រឹត្តទៅរឿយៗ ប្រកបក្នុងធម៌ដ៏គួរ សព្វៗ កាល បើមិនទាន់ដល់នូវព្រះនិព្វានជាទីបំផុតនៃទុក្ខក្នុងវដ្តៈទេ កុំ អាលដល់នូវសេចក្តីទុកចិត្តឡើយ ។ កាលភិក្ខុប្រាថ្នានូវសេចក្តី បរិសុទ្ធ សម្រាន្តនៅយ៉ាងនេះ អាសវៈទាំងពួងរមែងអស់ទៅ ភិក្ខុនោះ រមែងដល់នូវការរលត់ទុក្ខ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វិវិត្តំ** បានដល់ សេនាសនៈ មានព្រៃ ជាដើម ជាសេនាសនៈទទេ ដែលស្ងាត់ចាកពួកជន ។

បទថា **អប្បនិគ្ឃោសំ** បានដល់ ស្ងាត់ចាកសំឡេង គឺវៀរចាក សំឡេងបៀតបៀន ។

បទថា **វាឡមិគនិសេវិតំ** បានដល់ ដែលមានរាជសីហ៍ ខ្លាធំ និងខ្លា

ដំបង និងសត្វសាហាវនៅអាស្រ័យ ដោយបទនេះ លោកសម្តែងដល់ទីដ៏ស្ងាត់ចាកពួកមនុស្សនោះឯង ព្រោះសម្តែងថា ជាសេនាសនៈស្ងាត់ ។

ទីលំនៅព្រោះជាទីសមគួរ សម្រាប់ដេក និងអង្គុយ លោកបំណងយកថា សេនាសនៈ ក្នុងពាក្យថា **សេនាសនំ** នេះ ។

បទថា **បដិសល្លានការណា** បានដល់ មានការពួនសម្ងំជាហេតុ គឺដើម្បីទប់ចិត្តឲ្យត្រឡប់ចាកអារម្មណ៍ផ្សេងៗ ហើយឲ្យចិត្តចុះស៊ប់ក្នុងកម្មដ្ឋានដោយប្រពៃ ។

ព្រះថេរៈ កាលចង្អុលបង្ហាញដល់សេនាសនៈ ដែលសមគួរដល់ការចម្រើនភាវនា សម្តែងសេចក្តីសន្តោសក្នុងសេនាសនៈយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីសម្តែងសេចក្តីសន្តោសនោះក្នុងបច្ច័យ ៤ មានចីវរជាដើម ទើបពោលពាក្យថា **សង្ការបុញ្ជា** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **សង្ការបុញ្ជា** គំនរនៃសំរាមទាំងឡាយឈ្មោះថា **សង្ការបុញ្ជា** ។ អំពីគំនរសំរាមនោះ ។

បទថា **អាហាត្វា** ប្រែថា នាំមកហើយ ។

បទថា **តតោ** បានដល់ អំពីគំនរសេសសំពត់ ដែលនាំមកហើយបែបនោះ ។ ពិតហើយ ពាក្យនេះ ជាបញ្ចមីវិភត្តិ ប្រើក្នុងអត្ថតតិយាវិភត្តិ ។

បទថា **លូខំ** បានដល់ សៅហ្មង ដោយការសៅហ្មងព្រោះការកាត់ និងដោយការសៅហ្មងព្រោះការជ្រលក់ជាដើម គឺមានពណ៌មិនស្អាត ។

បទថា **ធារេយ្យ** សេចក្តីថា គប្បីប្រើប្រាស់ដោយការស្លៀកជាដើម

ដោយពាក្យនេះ ព្រះថេរៈពោលដល់ការសន្តោសក្នុងចីវរ ។

បទថា **ឆិចំ មធំ ករិត្វាន** សេចក្ដីថា វេញកដល់ឱវាទរបស់ព្រះសុគត ( ក្នុងសំយុត្តនិកាយ ខន្ធវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ ការត្រាច់ទៅរកដុំបាយ ដើម្បីចិញ្ចឹមជីវិតនេះ ដូច្នេះជាដើម ហើយធ្វើចិត្តឲ្យមានមានះនិងការរឹងត្អឹងដែលកម្ចាត់ហើយ ។

បទថា **សបទានំ** បានដល់ វៀរចាកការរំលងក្នុងផ្ទះទាំងឡាយ អធិប្បាយថា តាមលំដាប់ផ្ទះ ។ ដោយហេតុនោះ ទើបលោកពោលថា **កុលា កុលំ** ដូច្នេះជាដើម ។

បទថា **កុលា កុលំ** បានដល់ អំពីត្រកូលកាន់ត្រកូល អធិប្បាយថា តាមលំដាប់ត្រកូល គឺតាមលំដាប់ផ្ទះ ។

បទថា **បិណ្ឌិកាយ** បានដល់ ភិក្ខាដែលលាយឡំគ្នា ព្រះថេរៈពោលដល់ការសន្តោសក្នុងបិណ្ឌបាតដោយពាក្យនេះ ។

បទថា **គុត្តទ្វារោ** បានដល់ គ្រប់គ្រងចក្ខុទ្វារជាដើមល្អហើយ ។

បទថា **សុសំវុតោ** បានដល់ សង្រួមហើយដោយល្អ ព្រោះមិនមានការក្ដាំក្ដងដៃជាដើម ។

**អបិ** សព្ទ ក្នុងពាក្យថា **លូខេនបិ វា** នេះ ជាសមុច្ចយត្ថៈ ( មានអត្ថថា ប្រមូលមក ) ។ **វា** សព្ទ ជាវិកប្បត្ថៈ ( មានអត្ថថា ជ្រើសរើស ) សេចក្ដីថា គប្បីសន្តោស គឺគប្បីត្រេកអរជានិច្ចដោយប្រពៃ ដោយបច្ច័យទាំងពីរ គឺដែលសៅហ្មង ដែលជារបស់តិចឯណានីមួយ ដែលបានមកដោយ

ងាយ គឺតាមមាន តាមបាន ដោយហេតុនោះ ទើបលោកពោលថា **ឆាញ្ចំ បត្តេ រសំ ពហុំ** ដូច្នេះ ។

បទថា **ឆាញ្ចំ បត្តេ រសំ ពហុំ** សេចក្តីថា មិនគប្បីប្រាថ្នា គឺមិនគប្បីប្រាថ្នាបិណ្ឌបាតដែលច្រើន និងប្រណីត មានរសឆ្ងាញ់ជាដើម អំពីដែលខ្លួនបានហើយ ។ ដោយបទនេះ ព្រះថេរៈសម្តែងដល់ការសន្តោសក្នុងគិលានប្បច្ច័យផងដែរ ។

ព្រះថេរៈ កាលពោលដល់ហេតុដើម្បីឃាត់នូវការជាប់ចិត្តក្នុងរសទាំងឡាយ ទើបពោលថា ចិត្តរបស់ភិក្ខុអ្នកជាប់ញ៉ាមក្នុងរសទាំងឡាយ រមែងមិនត្រេកអរក្នុងឈាន ដូច្នេះជាដើម អធិប្បាយថា បុគ្គលដែលមិនធ្វើឥន្ទ្រិយសំវរៈឲ្យបរិបូណ៌ នឹងធ្វើចិត្តឲ្យស្ងប់ចាកការរាយមាយបានអំពីណា ។

ព្រះថេរៈកាលសម្តែងដល់បដិបទាក្នុងការជុសខាត់ ក្នុងបច្ច័យទាំង ៤ យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីសម្តែងដល់កថាវត្ថុដ៏សេសទាំងឡាយ ទើបពោលពាក្យជាដើមថា **អប្បិច្ឆោ ចេវ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **អប្បិច្ឆោ** បានដល់ មិនមានសេចក្តីប្រាថ្នា គឺវៀរចាកការប្រាថ្នាក្នុងបច្ច័យ ៤ ។ ដោយហេតុនោះ ទើបលោកពោលដល់ការសង្កត់តណ្ហាដែលកើតឡើងក្នុងបច្ច័យទាំង ៤ យ៉ាង ។ បទថា **សន្តុដ្ឋោ** បានដល់ សេចក្តីសន្តោស ដោយការត្រេកអរក្នុងបច្ច័យ ៤ តាមដែលបានមក ។

បុគ្គលណា មិនសោកស្តាយដល់រឿងដែលកន្លងមកហើយ មិនសង្ឃឹម

រឿងដែលមិនទាន់មកដល់ គប្បីញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយហេតុក្នុងបច្ចុប្បន្ន បុគ្គលនោះ លោកហៅថា ជាអ្នកសន្តោស ដូច្នេះ ។

បទថា **បវិវិត្តោ** បានដល់ លះនូវការប្រឡូកប្រឡំដោយពួកគណៈ ហើយរំលៀកកាយចូលទៅរកសេចក្តីស្ងប់ ។ ពិតហើយ ក្នុងរឿងការស្ងាត់ផ្លូវចិត្តជាដើម ខ្ញុំនឹងពោលខាងមុខ ។

បទថា **វសេ** គប្បីប្រកបចូលគ្រប់បទ ។ ឈ្មោះថា **មុនិ** ព្រោះប្រកបដោយមោនេយ្យធម៌ ។

បទថា **អសំសដ្ឋោ** បានដល់ មិនប្រឡូកប្រឡំ ព្រោះមិនមានការប្រឡូកប្រឡំដោយកាយ ដោយការឃើញ ដោយការស្តាប់ ដោយការចរចា ដោយការបរិភោគរួម គឺវៀរចាកសំសគ្គតាមដែលពោលហើយ ។

បទថា **ឧភយំ** បានដល់ មិនប្រឡូកប្រឡំដោយជនទាំង ២ ពួក គឺដោយគ្រហស្ថ និងដោយបព្វជិត ។ ពិតហើយ ពាក្យនេះ ជាបឋមាវិភត្តិចុះក្នុងអត្ថតតិយាវិភត្តិ ។

បទថា **អត្តានំ ឧស្សយេ តថា** សេចក្តីថា ទោះបីមិនមែនធ្លូត មិនមែនខ្វ-គ តែគប្បីធ្វើខ្លួនដូចមនុស្សធ្លូត ឬមនុស្ស-គ ។ ដោយបទនោះ ព្រះថេរៈពោលដល់ការលះនូវការអួតអាង ។

បទថា **ជឡោ វ មូគោ វ** នេះ ព្រះថេរៈធ្វើជារស្សៈដើម្បីងាយស្រួលក្នុងការបងគាថា **វា** សព្ទនេះ ជាសមុច្ចយត្ថៈ ។

បទថា **នាតិវេលំ សម្ភាសេយ្យ** សេចក្តីថា មិនគួរពោលហួសកាល

គឺពោលលើសប្រមាណ បានដល់ គប្បីជាអ្នកពោលតែល្មមប្រមាណ ។

បទថា **សង្ឃមជ្ឈម្ហិ** បានដល់ ក្នុងពួកភិក្ខុសង្ឃ ឬក្នុងប្រជុំជន ។ បទថា **ន សោ ឧបវទេ កញ្ចិ** សេចក្តីថា ភិក្ខុអ្នកបដិបត្តិតាមដែលពោលហើយនោះ មិនគួរពោលទ្រគោះបុគ្គលណាម្នាក់ ទោះជាបុគ្គលថោកទាប កណ្តាល ឬឧត្តមដោយវាចា ។

បទថា **ឧបឃាតំ វិវជ្ជយេ** សេចក្តីថា គួរវៀរការចូលទៅបៀតបៀន គឺការបៀតបៀនផ្លូវកាយចេញ ។

បទថា **សំវុតោ បាតិមោក្ខស្មឹ** សេចក្តីថា គប្បីជាអ្នកសង្រួមក្នុងបាតិមោក្ខ គឺក្នុងបាតិមោក្ខសំវរសីល បានដល់ គប្បីជាអ្នកសង្រួមកាយវាចាដោយសង្រួមក្នុងបាតិមោក្ខ ។

បទថា **មត្តញ្ញូ ចស្ស ភោជនេ** សេចក្តីថា គប្បីជាអ្នកស្គាល់ប្រមាណក្នុងភោជន ក្នុងការស្វែងរកការទទួល ការបរិភោគ និងការលះបង់ ។

បទថា **សុគ្គហីតនិមិត្តស្ស** សេចក្តីថា កាលកំណត់អាការរបស់ចិត្តនោះថា កាលខ្ញុំធ្វើទុកក្នុងចិត្តយ៉ាងនេះ ចិត្តបានជាសមាធិតាំងមាំហើយ ដូច្នេះ គប្បីជាអ្នកកាន់យកសមាធិនិមិត្តដោយល្អ បាលីថា **សុគ្គហីតនិមិត្តោ សោ** ដូច្នេះក៏មាន ។ បទថា **សោ** នោះ សំដៅដល់ **យោគី** ប្រែថា ( ព្រះយោគីនោះ ) ។

បទថា **ចិត្តស្សុប្បាទកោវិទោ** សេចក្តីថា គប្បីជាអ្នកឈ្លាសក្នុងហេតុដែលធ្វើចិត្តរួញរា និងរាយមាយថា កាលចម្រើនភាវនាយ៉ាងនេះ ចិត្តមានការ

រួញរា កាលចម្រើនការនោយ៉ាងនេះ ចិត្តមានការរាយមាយ ។ ព្រោះកាលចិត្តរួញរា គប្បីចម្រើនធម្មវិចយសម្ពោជ្ឈង្គ វិរិយសម្ពោជ្ឈង្គ និងបីតិ-សម្ពោជ្ឈង្គ កាលចិត្តរាយមាយ គប្បីចម្រើនបស្សទ្ធិសម្ពោជ្ឈង្គ សមាធិ-សម្ពោជ្ឈង្គ និងឧបេក្ខាសម្ពោជ្ឈង្គ ចំណែកសតិសម្ពោជ្ឈង្គ ចម្រើនបានគ្រប់កាល ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ បើចិត្តរួញរាក្នុងសម័យណា សម័យនោះ ជាកាលគួរនឹងចម្រើនធម្មវិចយសម្ពោជ្ឈង្គ ដូច្នេះជាដើម ។

បទថា **សមថំ អនុយុញ្ជេយ្យ** សេចក្តីថា គប្បីចម្រើនសមថការនា គឺគប្បីធ្វើសមាធិដែលមិនទាន់កើត ឲ្យកើតឡើង គឺគប្បីចម្រើននូវសមាធិដែលកើតឡើងហើយ រហូតដល់នូវភាពជាអ្នកជំនាញ ។

បទថា **កាលេន ច វិបស្សនំ** សេចក្តីថា គប្បីប្រកបរឿយៗ នូវវិបស្សនាតាមវេលាដែលគួរ ដោយមិនធ្វើសមាធិ តាមដែលបានហើយ ឲ្យមានចំណែកនៃសេចក្តីវិនាស ឬចំណែកនៃសេចក្តីតាំងនៅ ដោយការពេញចិត្ត ឬដោយការមិនធ្វើឲ្យដល់ទីបំផុត ហើយធ្វើឲ្យមានចំណែកនៃការត្រាស់ដឹង ។

ម្យ៉ាងទៀត បទថា **កាលេន ច វិបស្សនំ** សេចក្តីថា កាលប្រកបនូវសមថៈ មិនគួរផ្អាកក្នុងវេលាដែលមានសមាធិមាំទាំ តែគប្បីប្រកបវិបស្សនារឿយៗ ដើម្បីសម្រេចអរិយមគ្គជាដើម សមដូចព្រះមានព្រះភាគត្រាស់ ( ក្នុងខុទ្ទកនិកាយ ធម្មបទ ) ថា

អថ វា សមាធិលាភេន វិវិត្តសយនេន វា
ភិក្ខុ វិស្សាសមាបាទិ អប្បត្តោ អាសវក្ខយំ ។

ម្នាលភិក្ខុ បើភិក្ខុមិនទាន់ដល់នូវការអស់អាសវៈទេ កុំអាល
ទុកចិត្ត ដោយការបានសមាធិ ឬក៏ដោយការដេកក្នុងទីស្ងាត់
ដូច្នេះឡើយ[១] ។

១- ក្នុងគាថាធម្មបទ គាថានេះ លោកពោល ៤ បាទ តែព្រះអដ្ឋកថាចារ្យ លោក
ស្រង់យកតែបាទទី៣ បាទទី ៤ បាទទី ៧ និងបាទទី ៨ មកប៉ុណ្ណោះ ។

ដោយហេតុនោះ ទើបលោកពោលពាក្យជាដើមថា **វិរិយសាតច្ច-
សម្បន្នោ** ដូច្នេះជាដើម ។ អធិប្បាយថា ការប្រព្រឹត្តទៅជាប់តគ្នា ឈ្មោះថា
**សាតច្ច** បានដល់ ការប្រព្រឹត្តទៅជាប់តគ្នានៃសេចក្តីព្យាយាម ជាអ្នកដល់
ព្រមហើយ ប្រកបព្រមហើយ ដោយសេចក្តីព្យាយាមដែលប្រព្រឹត្តទៅជាប់ត
គ្នានោះ គឺជាអ្នកមានសេចក្តីព្យាយាមដែលប្រព្រឹត្តទៅជាប់តគ្នា បានដល់
មានសេចក្តីព្យាយាមដែលផ្គងចិត្តជានិច្ច ។

បទថា **យុត្តយោគោ សទា សិយា** សេចក្តីថា ជាបុគ្គលប្រកបភាវនា
សព្វកាល ។

បទថា **ឧក្កដ្ឋំ** សេចក្តីថា មិនទាន់ដល់ទីបំផុតនៃវដ្តទុក្ខ គឺនិរោធ
និព្វាន ដែលជាទីបំផុតហើយ មិនគប្បីដល់ គឺមិនគប្បីដល់នូវការទុកចិត្ត គឺ
មិនគប្បីដាក់ចិត្តថា ខ្ញុំជាបុគ្គលដែលមានសីលបរិសុទ្ធ បានឈាន បាន
អភិញ្ញា ធ្វើវិបស្សនាឲ្យដល់ទីបំផុត ហើយតាំងនៅ ។

*បទថា* **ឯវំ វិហារមានស្ស** *សេចក្តីថា តាំងនៅដោយអាការយ៉ាងនេះ គឺដោយវិធីដែលមានការប្រើប្រាស់សេនាសនៈស្ងាត់ជាខាងដើម មានការប្រកបវិបស្សនាជាទីបំផុត ។*

*បទថា* **សុទ្ធិកាមស្ស** *បានដល់ របស់ភិក្ខុអ្នកប្រាថ្នាសេចក្តីបរិសុទ្ធនៃញាណទស្សនៈ សេចក្តីបរិសុទ្ធដ៏ក្រៃលែង ព្រះនិព្វាន និងអរហត្ត អធិប្បាយថា អាសវៈទាំងអស់ មានកាមាសវៈជាដើមរបស់ភិក្ខុដែលឃើញភ័យក្នុងសង្សារ រមែងអស់ទៅ គឺរមែងដល់នូវការអស់ទៅ តាំងនៅមិនបាន រមែងដល់ គឺរមែងសម្រេចព្រះនិព្វានទាំង ២ យ៉ាង គឺសឧបាទិសេសនិព្វាន និងអនុបាទិសេសនិព្វាន ដោយការដល់នូវការអស់ទៅនៃអាសវៈទាំងនោះឯង ។*

*ព្រះថេរៈកាលសម្តែងថា ខ្លួនមានបដិបទាយ៉ាងនោះ ដោយការសម្តែងនូវការឲ្យឱវាទដល់ភិក្ខុនោះយ៉ាងនេះ ទើបស្មើគ្នានឹងបានព្យាករភាពជាអរហត្ត ។*

**អដ្ឋកថា ឧបសេនវង្គន្តបុត្តត្ថេរគាថា ចប់**

# សុត្តន្តបិដក

## គោតមត្ថេរគាថា

[ ២៤០ ] បុរសគប្បីដឹងច្បាស់នូវប្រយោជន៍របស់ខ្លួន គប្បីរមិលមើលនូវពាក្យជាប្រធាន គឺសាសនា មួយទៀត អំពើណា របស់កុលបុត្រអ្នកចូលកាន់ផ្នួសជាសមណភាព ជាអំពើមានសភាពដ៏សមគួរ ក្នុងសាសនានេះ ( បុគ្គលគប្បីរមិលមើលនូវអំពើនោះផង ) ។ ក្នុងសាសនានេះ ( ការសេពគប់ ) នូវកល្យាណមិត្រ ១ ការសមាទាននូវសិក្ខាបទដ៏ធំទូលាយ ១ ការប្រុងស្តាប់ ( នូវឱវាទ ) នៃគ្រូទាំងឡាយ ១ ទាំង ៣ យ៉ាងនេះ ជាអំពើសមគួរដល់សមណៈ ។ សេចក្តីគោរពក្នុងព្រះពុទ្ធទាំងឡាយ ១ ការកោតក្រែងក្នុងព្រះធម៌គួរតាមពិត ១ ការកោតក្រែងក្នុងព្រះសង្ឃ ១ ទាំង ៣ យ៉ាងនេះ ជាអំពើសមគួរដល់សមណៈ ។ កិច្ចប្រកបក្នុងអាចារ និងគោចរ ១ មានអាជីវៈដ៏បរិសុទ្ធ ដែលអ្នកប្រាជ្ញមិនគប្បីតិះដៀលបាន ១ ការតម្កល់ចិត្តទុកដោយប្រពៃ ១ ទាំង ៣ យ៉ាងនេះ ជាអំពើសមគួរដល់សមណៈ ។ ចារិត្តសីល ឬវារិត្តសីល ១ សម្បជញ្ញៈដែលអាស្រ័យនឹងឥរិយាបថ ជាទីនាំមកនូវសេចក្តីប្រាថ្នា ១ ការប្រកបរឿយៗ ក្នុងអធិចិត្ត ១ ទាំង ៣ យ៉ាងនេះ ជាអំពើសមគួរដល់សមណៈ ។ សេនាសនៈតាំងនៅក្នុងព្រៃស្ងាត់ មានសំឡេងតិចដែលអ្នកប្រាជ្ញគប្បីគប់រក នេះជាទីសមគួរដល់សមណៈ ។ សីល ១ ភាពជាពហុស្សូត ១ ការពិចារណានូវធម៌ទាំងឡាយ គួរតាមពិត ១ ការ

ត្រាស់ដឹងនូវសច្ចៈទាំងឡាយ ១ ទាំង ៤ យ៉ាងនេះ ជាអំពើសមគួរដល់សមណៈ ។ ភិក្ខុគប្បីចម្រើននូវអនិច្ចសញ្ញាផង អនត្តសញ្ញាផង អសុភសញ្ញាផង អនភិរតិសញ្ញា ក្នុងលោកនេះផង ទាំង ៤ យ៉ាងនេះ ជាអំពើសមគួរដល់សមណៈ ។ ភិក្ខុគប្បីចម្រើន នូវពោជ្ឈង្គទាំងឡាយផង ឥទ្ធិបាទទាំងឡាយផង ឥន្ទ្រិយ និងពលទាំងឡាយផង អរិយមគ្គមានអង្គ ៨ ផង ទាំង ៥ យ៉ាងនេះ ជាអំពើសមគួរដល់សមណៈ ។ មុនីគប្បីលះបង់នូវតណ្ហា គប្បីទម្លុះទម្លាយ នូវអាសវៈទាំងឡាយ ព្រមទាំងឫសគល់ គប្បីជាអ្នករួចស្រឡះ ( ចាកកិលេសទាំងពួង ) ហើយសម្រេចសម្រាន្តនៅ នេះជាអំពើដ៏សមគួរដល់សមណៈ ។

**គោតមត្ថេរ**

## ឧទ្ទាន

ព្រះថេរៈទាំងឡាយ ៧ អង្គនេះ គឺកាឡុទាយិត្ថេរ ១ ឯកវិហារិត្ថេរ ១ មហាកប្បិនត្ថេរ ១ ចូឡបន្ថកត្ថេរ ១ កប្បត្ថេរ ១ ឧបសេនវង្គន្តបុត្តត្ថេរ ១ គោតមត្ថេរ ១ ( បានពោល ) នូវគាថាទាំងឡាយ ៧០ ក្នុងទសកនិបាតនេះ ។

**ទសកនិបាត ចប់**

# អដ្ឋកថា

## គោតមត្ថេរគាថា

[ ២៤០ ] គាថារបស់ព្រះគោតមត្ថេរ មានពាក្យផ្ដើមថា **វិជានេយ្យ សកំ អត្ថំ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើហើយ ក្នុងព្រះសម្ពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ មុនការកើតឡើងនៃព្រះមានព្រះភាគនៃយើងទាំងឡាយ កើតក្នុងត្រកូលឧទិច្ចព្រាហ្មណ៍ ក្នុងនគរសាវត្ថី ចម្រើនវ័យហើយ ជាអ្នកចប់ត្រៃវេទ រៀននូវវិធីក្នុងការនិយាយ កាលមិនមានអ្នកដទៃដែលមានវាទៈក្រៃលែងជាងវាទៈរបស់ខ្លួន ក៏ត្រាច់ធ្វើនូវការលើកវាទៈ ប្រកួតប្រជែងពាក្យសម្ដី ជាមួយមនុស្សនោះៗ រឿយៗ ទៅ ។

លំដាប់នោះ ព្រះមានព្រះភាគនៃយើង ទ្រង់កើតឡើងហើយក្នុងលោក ទ្រង់សម្ដែងធម្មចក្រដ៏បវរឲ្យប្រព្រឹត្តទៅហើយ ទ្រង់ទូន្មានវេនេយ្យសត្វទាំងឡាយ មានយសកុលបុត្តជាដើមដោយលំដាប់ ហើយបានយាងទៅកាន់នគរសាវត្ថី តាមពាក្យរបស់អនាថបិណ្ឌិកសេដ្ឋី ក្នុងកាលដែលវេរវត្តជេតពនថ្វាយដល់ព្រះសាស្ដា កុលបុត្តនោះបាននូវសទ្ធា ចូលទៅគាល់ព្រះសាស្ដា ស្ដាប់ធម៌ ហើយទូលសូមបព្វជ្ជា ។

ព្រះសាស្ដា ទ្រង់ត្រាស់ឲ្យភិក្ខុសមាទានបិណ្ឌបាតជាវត្តមួយរូប ដោយព្រះតម្រាស់ថា ម្នាលភិក្ខុ ចូរអ្នកឲ្យកុលបុត្តនេះបួសចុះ ។ កុលបុត្តនោះ កាលភិក្ខុនោះឲ្យបព្វជ្ជា គ្រាន់តែកាំបិតកោរដល់សីសៈប៉ុណ្ណោះ ក៏សម្រេច

អរហត្ត ទៅកាន់កោសលជនបទ នៅត្រង់កោសលជនបទនោះអស់កាលយូរ ហើយត្រឡប់មកកាន់ក្រុងសាវត្ថីវិញ ។ ពួកញាតិជាព្រាហ្មណមហាសាល ជាច្រើន ចូលទៅរកព្រះគោតមត្ថេរនោះហើយ ហើយសួរថា ពួកសមណ-ព្រាហ្មណ៍ជាច្រើន ក្នុងលោកនេះ មានវាទៈបរិសុទ្ធក្នុងសង្សារ ក្នុងវាទៈទាំងនោះ វាទៈរបស់បុគ្គលពួកណា ជាវាទៈនាំចេញ ( ចាកសង្សារ ) បដិបត្តិដូចម្តេច ទើបបរិសុទ្ធចាកសង្សារបាន ។

ព្រះថេរៈកាលប្រកាសសេចក្តីនោះដល់ញាតិទាំងនោះ ទើបពោលគាថាទាំងនេះថា

បុរសគប្បីដឹងច្បាស់នូវប្រយោជន៍របស់ខ្លួន គប្បីរមិលមើលនូវពាក្យជាប្រធាន គឺសាសនា មួយទៀត អំពើណា របស់កុល-បុត្រអ្នកចូលកាន់ផ្នួសជាសមណភាព ជាអំពើមានសភាពដ៏សមគួរក្នុងសាសនានេះ ( បុគ្គលគប្បីរមិលមើលនូវអំពើនោះផង ) ។ ក្នុងសាសនានេះ ( ការសេពគប់ ) នូវកល្យាណមិត្រ ១ ការសមាទាននូវសិក្ខាបទដ៏ធំទូលាយ ១ ការប្រុងស្តាប់ ( នូវឱវាទ ) នៃគ្រូទាំងឡាយ ១ ទាំង ៣ យ៉ាងនេះ ជាអំពើសមគួរដល់សមណៈ ។ សេចក្តីគោរពក្នុងព្រះពុទ្ធទាំងឡាយ ១ ការកោតក្រែងក្នុងព្រះធម៌ គួរតាមពិត ១ ការកោតក្រែងក្នុងព្រះសង្ឃ ១ ទាំង ៣ យ៉ាងនេះ ជាអំពើសមគួរដល់សមណៈ ។ ភិក្ខុប្រកបក្នុងអាចារ និងគោចរ ១ មានអាជីវៈដ៏បរិសុទ្ធ ដែលអ្នកប្រាជ្ញមិន

គប្បីតិះដៀលបាន ១ ការតម្កល់ចិត្តទុកដោយប្រពៃ ១ ទាំង ៣ យ៉ាងនេះ ជាអំពើសមគួរដល់សមណៈ ។ ចារិតសីល ឬវារិត-សីល ១ សម្បជញ្ញៈដែលអាស្រ័យនឹងឥរិយាបថ ជាទីនាំមកនូវសេចក្តីប្រាថ្នា ១ ការប្រកបរឿយៗ ក្នុងអធិចិត្ត ១ ទាំង ៣ យ៉ាងនេះ ជាអំពើសមគួរដល់សមណៈ ។ សេនាសនៈតាំងនៅក្នុងព្រៃស្ងាត់ មានសំឡេងតិច ដែលអ្នកប្រាជ្ញគប្បីគប់រក នេះជាទីសមគួរដល់សមណៈ ។ សីល ១ ភាពជាពហុស្សូត ១ ការពិចារណានូវធម៌ទាំងឡាយ គួរតាមពិត ១ ការត្រាស់ដឹងនូវសច្ចៈទាំងឡាយ ១ ទាំង ៤ យ៉ាងនេះ ជាអំពើសមគួរដល់សមណៈ ។ ភិក្ខុគប្បីចម្រើននូវអនិច្ចសញ្ញាផង អនត្តសញ្ញាផង អសុភសញ្ញាផង អនភិរតិសញ្ញា ក្នុងលោកនេះផង ទាំង ៤ យ៉ាងនេះ ជាអំពើសមគួរដល់សមណៈ ។ ភិក្ខុគប្បីចម្រើននូវពោជ្ឈង្គទាំង-ឡាយផង ឥទ្ធិបាទទាំងឡាយផង ឥន្ទ្រិយ និងពលទាំងឡាយផង អរិយមគ្គមានអង្គ ៨ ផង ទាំង ៥ យ៉ាងនេះ ជាអំពើសមគួរដល់សមណៈ ។ មុនីគប្បីលះបង់នូវតណ្ហា គប្បីទម្លុះទម្លាយនូវអាសវៈទាំងឡាយ ព្រមទាំងឫសគល់ គប្បីជាអ្នករួច ស្រឡះ ( ចាកកិលេសទាំងពួង ) ហើយសម្រេចសម្រាន្តនៅ នេះជាអំពើដ៏សមគួរដល់សមណៈ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វិជានេយ្យ សកំ អត្ថំ** សេចក្តីថា បុរស

មានជាតិជាអ្នកប្រាជ្ញ គប្បីសម្លឹងពិនិត្យប្រយោជន៍របស់ខ្លួនឲ្យដឹងតាមសេចក្តីពិត កាលសម្លឹងពិនិត្យ គប្បីពិចារណានូវពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា បានដល់ ពាក្យប្រៀនប្រដៅដែលសមណព្រាហ្មណ៍ជាបុថុជ្ជនទាំងឡាយ និងដែលព្រះសម្មាសម្ពុទ្ធត្រាស់ក្នុងលោកនេះ បានដល់ លទ្ធិ គឺគប្បីពិចារណាពាក្យប្រៀនប្រដៅ ដែលគប្បីនាំចេញចាកសង្សារ ដោយបញ្ញាចក្ខុ ។

ពិតហើយ សមណព្រាហ្មណ៍ដែលជាតិរ្ថិយទាំងនោះ ជាអ្នកប្រកាន់ខុសនូវវត្ថុទាំងឡាយ ដែលមិនទៀង ថាទៀង វត្ថុដែលមិនមែនត្លួន ថាជាត្លួន និងផ្លូវដែលមិនបរិសុទ្ធ ថាជាផ្លូវបរិសុទ្ធ និងភាពជាបុគ្គលមានវាទៈជំទាស់នូវគ្នានិងគ្នា ព្រោះហេតុនោះ វាទៈនៃសមណព្រាហ្មណ៍ទាំងនោះ ទើបជាវាទៈដែលមិននាំចេញចាកសង្សារ ឯព្រះសម្មាសម្ពុទ្ធ ទ្រង់ជាសព្វញ្ញូ ដោយការដឹងក្រៃលែងតាមសេចក្តីពិត ដោយព្រះសយម្ភូញាណថា សង្ខារទាំងពួងមិនទៀង ធម៌ទាំងពួងជាអនត្តា ព្រះនិព្វានជាធម៌ស្ងប់ ព្រោះហេតុនោះ វាទៈរបស់ព្រះសម្មាសម្ពុទ្ធអង្គនោះ ទើបជាវាទៈដែលនាំចេញចាកសង្សារ អធិប្បាយថា គប្បីពិចារណាមើលពាក្យប្រៀនប្រដៅដ៏ក្រៃលែងរបស់ព្រះសាស្តា ។

បទថា **យញ្ចេត្ថ អស្ស បដិរូបំ សាមញ្ញំ អជ្ឈុបគតស្ស** សេចក្តីថា គប្បីជាអ្នកសម្លឹងពិនិត្យវត្ថុដែលសមគួរ គឺវត្ថុដែលសមគួរដល់កុលបុត្តដែលចូលដល់នូវភាពជាសមណៈ គឺសមណភាវៈ បានដល់ ការបួសក្នុងព្រះសាសនានេះ ឬក្នុងភាពជាបព្វជិត ។

ដើម្បីចៀសវាងនូវពាក្យសួរថា សេចក្តីនោះដូចម្តេច ព្រះគោមតត្ថេរក៏

ពោលពាក្យថា **មិត្តំ ឥធេវ កល្យាណំ** ជាដើម ។ មានវាចាប្រកបសេចក្ដីថា ការគប់រកកល្យាណមិត្តក្នុងព្រះសាសនានេះ រាប់ជាការសមគួរដល់សមណៈក្នុងបទក្រៅអំពីនេះក៏មានន័យដូចគ្នា ។ ព្រោះកុលបុត្តលះអកុសល ចម្រើនកុសល បរិហារខ្លួនឲ្យបរិសុទ្ធស្អាតបាន ព្រោះអាស្រ័យកល្យាណមិត្ត ។

បទថា **សិក្ខា វិបុលំ សមាទានំ** បានដល់ ការសមាទានសិក្ខាឲ្យបរិបូណ៌ អធិប្បាយថា បដិបត្តិក្នុងសិក្ខា មានអធិសីលសិក្ខាជាដើម ដែលនាំមកនូវគុណធំ គឺព្រះនិព្វាន ។

បទថា **សុស្សូសា ច គរូនំ** សេចក្ដីថា ការស្ដាប់ និងការប្រព្រឹត្តតាមឱវាទរបស់គ្រូទាំងឡាយ គឺរបស់កល្យាណមិត្តទាំងឡាយ មានអាចារ្យ និងឧបជ្ឈាយ៍ជាដើម ។

បទថា **ឯតំ** បានដល់ ការគប់រកកល្យាណមិត្តជាដើម ។ បទថា **ពុទ្ធេសុ សគារវតា** សេចក្ដីថា ប្រកបនូវសេចក្ដីគោរព ធ្វើនូវការកោតក្រែងក្នុងព្រះសព្វញ្ញុពុទ្ធថា ព្រះមានព្រះភាគជាសម្មាសម្ពុទ្ធ ដូច្នេះ ។

បទថា **ធម្មេ អបចិតិ យថាភូតំ** បានដល់ ឱនលំទោន គឺបូជាដោយអើពើក្នុងអរិយធម៌តាមសេចក្ដីពិត ។

បទថា **សង្ឃេ** បានដល់ ក្នុងអរិយសង្ឃ ។ បទថា **ចិត្តីការោ** បានដល់ ការគោរព គឺការរាប់អាន ។ បទថា **ឯតំ** បានដល់ ធ្វើនូវការគោរពក្នុងព្រះរតនត្រ័យ ។ បទថា **អាចារគោចរេ យុត្តោ** សេចក្ដីថា លះនូវអនាចារ គឺការឈានកន្លងតាមកាយ តាមវាចា និងការលះទីអគោចរ មានទី

ស្រីពេស្យាជាដើម ដែលជាទីមិនសមគួរចូលទៅបិណ្ឌបាតជាដើម ហើយប្រកប គឺដល់ព្រមដោយអាចារ គឺការមិនកន្ទង់តាមកាយ និងតាមវាចា និងដោយគោចរក្នុងទីដែលសមគួរចូលទៅបិណ្ឌបាតជាដើម ឈ្មោះថា ជាអ្នកបរិបូណ៌ដោយអាចារ និងគោចរ ។

បទថា **អាជីវោ សោធិតោ** សេចក្តីថា កាលកិក្ខុលះអនេសនាកម្មមានការឲ្យឫស្សីជាដើម ដែលព្រះពុទ្ធទ្រង់រង្កៀសហើយ សេពតែបច្ច័យដែលកើតឡើង មិនមានទោស ឈ្មោះថា ជាអ្នកមានអាជីវៈបរិសុទ្ធ គឺបរិសុទ្ធដោយល្អ ព្រោះភាពជាអ្នកមានអាជីវៈបរិសុទ្ធនោះឯង ទើបវិញ្ញូជនទាំងឡាយមិនតិះដៀល ។

បទថា **ចិត្តស្ស ច សណ្ឋបនំ** សេចក្តីថា ការតាំងចិត្តប្រពៃ ដោយអំណាចរូបដែលឃើញហើយ និងអារម្មណ៍ដែលដឹងហើយជាដើម ដោយមិនឲ្យកិលេស មានអភិជ្ឈាជាដើម ប្រព្រឹត្តទៅក្នុងអារម្មណ៍ មានរូបជាដើមតាមទ្វារ មានចក្ខុទ្វារជាដើម ។

បទថា **ឯតំ** សំដៅដល់ គុណធម៌ ៣ យ៉ាង គឺការដល់ព្រមដោយអាចារគោចរ ១ អាជីវៈដែលបរិសុទ្ធ ១ មានទ្វារគ្រប់គ្រងហើយក្នុងឥន្ទ្រិយទាំងឡាយ ១ ដូច្នេះ ។

បទថា **ចារិត្តំ** បានដល់ សីលដែលគប្បីប្រព្រឹត្តឲ្យបរិបូណ៌ ។ បទថា **វារិត្តំ** បានដល់ សីលដែលគប្បីឲ្យបរិបូណ៌ ដោយវិរតិចេតនា ។ បទថា **ឥរិយាបថិយំ បសាទនីយំ** សេចក្តីថា មានសម្បជញ្ញៈទាក់ទងក្នុងឥរិយាបថ

ដែលមានអាកប្បកិរិយាជាគ្រឿងចង្អុលបង្ហាញ ដែលនាំមកនូវសេចក្ដីជ្រះថ្លាដល់ជនដទៃ ។

បទថា **អធិចិត្តេ ច អាយោគោ** បានដល់ ការប្រកបរឿយៗ គឺការចម្រើនក្នុងសមថៈ និងវិបស្សនា ។

បទថា **អារញ្ញកានិ** បានដល់ សេនាសនៈដែលទាក់ទងហើយ ដែលនៅក្នុងព្រៃ ។ បទថា **បន្តានិ** ប្រែថា ដែលស្ងាត់ ។ បទថា **សីលំ** បានដល់ចតុប្បារិសុទ្ធិសីល ពិតហើយ ខាងដើមពោលដល់សីល ដោយការចែកក្នុងទីនេះ លោកពោលដល់សីលដោយមិនចែក ។

បទថា **ពាហុសច្ចំ** បានដល់ ភាពជាអ្នកស្ដាប់ច្រើន ។ ពិតហើយពាហុសច្ចៈនោះ រមែងមានឧបការៈច្រើន ដល់បុគ្គលអ្នកប្រកបរឿយៗ ក្នុងភាវនា ។ ការប្រកបរឿយៗ ក្នុងសមថវិបស្សនា រមែងសម្រេចដល់បុគ្គលដែលច្រើនទៅដោយការពិចារណាដោយប្រពៃ ក្នុងភាពជាអ្នកឈ្លាសក្នុងពោជ្ឈង្គ និងក្នុងភាពជាអ្នកប្រកបរឿយៗ ក្នុងអធិចិត្ត ដែលមានភាវៈត្រជាក់ដ៏ក្រៃលែងជាដើម ។

បទថា **ធម្មានំ បវិចយោ យថាភូតំ** សេចក្ដីថា ការពិចារណាដោយលក្ខណៈដែលមិនជំទាស់គ្នា និងដោយលក្ខណៈដែលស្មើគ្នានៃរូបធម៌ និងអរូបធម៌ ។ លោកពោលដល់ធម៌ គឺអធិប្បញ្ញា និងវិបស្សនាដល់បទនេះ ។

បទថា **សច្ចានំ អភិសមយោ** បានដល់ ការចាក់ធ្លុះដោយអំណាចការត្រាស់ដឹង ដោយការឈមចុះដល់អរិយសច្ច មានទុក្ខជាដើម ។

ដើម្បីសម្តែងវិធីដែលត្រាស់ដឹងអរិយសច្ច ទើបព្រះថេរៈពោលពាក្យថា **ភាវេយ្យ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **ភាវេយ្យ ច អនិច្ចំ** សេចក្តីថា បុគ្គលគប្បីធ្វើឲ្យមាន ឲ្យកើតឡើង និងឲ្យចម្រើនឡើងនូវអនិច្ចសញ្ញាក្នុងសង្ខារទាំងពួងដោយការមិនចែកថា សង្ខារទាំងពួងមិនទៀង ដូច្នេះជាដើម ។ ឬដោយការចែកថា រូបណាមួយដែលជាអតីត អនាគត និងបច្ចុប្បន្ន ដូច្នេះជាដើម ។

បទថា **អនត្តសញ្ញំ** មានវាចាប្រកបសេចក្តីថា គប្បីចម្រើនអនត្តសញ្ញាឲ្យប្រព្រឹត្តទៅថា ធម៌ទាំងពួងជាអនត្តា ដូច្នេះ សូម្បីក្នុងបទដ៏សេស ក៏មានន័យយ៉ាងនេះ ។

បទថា **អសុភសញ្ញំ** បានដល់ សញ្ញាដែលប្រព្រឹត្តទៅថា មិនស្អាតក្នុងករជកាយ ឬក្នុងសង្ខារដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ព្រោះមិនស្អាត គឺកិលេសហូរចេញ ។ ពិតហើយ គប្បីជ្រាបថា អសុភសញ្ញានេះ មានទុក្ខសញ្ញាចូលរួមផងដែរ សូម្បីទុក្ខសញ្ញា ក៏លោកកាន់យកហើយ ដោយបទអសុភសញ្ញានេះឯង ។

បទថា **លោកម្ហិ ច អនភិរតឹ** បានដល់ សញ្ញាក្នុងការមិនត្រេកអរក្រៃលែងក្នុងសង្ខារទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ក្នុងលោកទាំងពួង ដោយបទនេះ លោកពោលសំដៅដល់អាទីនវានុបស្សនា និងនិព្វិទានុបស្សនាផងដែរ ។

ព្រះថេរៈប្រកបនូវការចម្រើនវិបស្សនាយ៉ាងនោះហើយ កាលនឹងឲ្យពួក

ញាតិកើតនូវសេចក្តីខ្វល់ខ្វាយ កាលនឹងសម្តែងថា គប្បីចម្រើនធម៌ទាំងនេះ ដូច្នេះ ទើបពោលគាថាថា **ភាវេយ្យ ច ពោជ្ឈង្គេ** ដូច្នេះជាដើម ។

អត្ថនៃបាទគាថានេះថា ធម៌ទាំងឡាយ មានសតិជាដើម ឈ្មោះថា **ពោជ្ឈង្គ** ព្រោះជាអង្គនៃការដល់ព្រមនៃធម៌ ៧ មានសតិជាដើម ដើម្បីការត្រាស់ដឹង ឬជាអង្គនៃបុគ្គលដែលដល់ព្រមដោយធម៌ ៧ ប្រការនោះ ដើម្បីការត្រាស់ដឹង ។ ធម៌ទាំងនោះ បានដល់ ពោជ្ឈង្គ ៧ ប្រការ មានសតិជាដើម ឥទ្ធិបាទ ៤ មានឆន្ទៈជាដើម ឥន្ទ្រិយ ៥ មានសទ្ធាជាដើម ពល ៥ មានសទ្ធាជាដើមដូចគ្នា និងអរិយមគ្គមានអង្គ ៨ មានសម្មាទិដ្ឋិជាដើម ។ ដោយ ច សព្ទ លោកសង្គ្រោះយកសតិប្បដ្ឋាន និងសម្មប្បធានចូលផង ព្រោះហេតុនោះ គប្បីអប់រំធ្វើឲ្យកើត និងគប្បីចម្រើនពោធិបក្ខិយធម៌ទាំង ៣៧ ប្រភេទ ។ ក្នុងសេចក្តីនោះ ការធ្វើនូវពោធិបក្ខិយធម៌ ៣៧ ប្រការនោះ ឲ្យកើតឡើងក្នុងខណៈនៃសោតាបត្តិមគ្គ និងការចម្រើនក្នុងខណៈនៃអរហត្តមគ្គ សេចក្តីនោះ ជាការសមគួរដល់សមណៈ គឺភិក្ខុ ។

ព្រះថេរៈ កាលអប់រំញាតិក្នុងពោធិបក្ខិយធម៌យ៉ាងនោះហើយ កាលសម្តែងថា បុគ្គលត្រាស់ដឹងមគ្គសច្ច ដោយអំណាចការត្រាស់ដឹង ដោយការនាយ៉ាងណា បុគ្គលត្រាស់ដឹងសមុទយសច្ច ក៏ដោយអំណាចការត្រាស់ដឹងដោយការលះ និងដោយត្រាស់ដឹងនិរោធសច្ច ដោយការត្រាស់ដឹង ដោយការធ្វើឲ្យជាក់ច្បាស់ ដូច្នោះ ទើបពោលគាថាចុងក្រោយថា **តណ្ហំ បជហេយ្យ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **តណ្ហំ បជហេយ្យ** សេចក្តីថា គប្បីកាត់តណ្ហាទាំងអស់ មានកាមតណ្ហាជាដើម ដោយមិនឲ្យសេសសល់ ដោយអរិយមគ្គ **ញាណ** លោកហៅថា **មោន** ឈ្មោះថា **មុនី** ព្រោះប្រកបព្រមដោយញាណនោះ ។

បទថា **សមូលកេ អាសវេ បទាលេយ្យ** សេចក្តីថា គប្បីទម្លាយ គឺគប្បីដកនូវអាសវៈទាំងអស់ មានកាមាសវៈជាដើម មួយអន្លើដោយឫសគល់ មានកាមរាគានុស័យជាដើម ។

បទថា **វិហរេយ្យ វិប្បមុត្តោ** សេចក្តីថា ព្រោះលះសង្កិលេសទាំងឡាយ ដោយប្រការទាំងពួងយ៉ាងនេះ ទើបជាអ្នករួចផុតក្នុងទីទាំងពួង ធ្វើឲ្យជាក់ច្បាស់នូវនិរោធ គឺនិព្វានដែលលះនូវឧបធិជាសមុច្ឆេទទាំងអស់បាន ។

បទថា **ឯតំ** សេចក្តីថា ការនៅយ៉ាងនោះ រាប់ថា ជាការសមគួរដល់សមណៈ គឺភិក្ខុដែលរម្ងាប់នូវបាបបានហើយ ។

ព្រះថេរៈចង្អុលបង្ហាញថា សាសនាជានិយ្យានិក ដោយប្រារព្ធដល់បដិបទាដែលសមគួរដល់សមណៈ និងចង្អុលបង្ហាញថា លទ្ធិខាងក្រៅ មិនជាអនិយ្យានិកធម៌ និងព្រោះផ្ទុយក្នុងព្រះសាសនានេះ ។

ព្រាហ្មណមហាសាលទាំងនោះ មានសេចក្តីជ្រះថ្លាក្រៃលែង ក្នុងព្រះសាសនា នាំគ្នាតាំងនៅក្នុងសរណៈជាដើមហើយ ។៚

**អដ្ឋកថាគោតមត្ថេរគាថា ចប់**

**ថេរគាថា ទសកនិបាត ចប់**

# សុត្តន្តបិដក

# ថេរគាថា ឯកាទសកនិបាត

## សង្កិច្ចត្ថេរគាថា

[ ២៨១ ] ម្នាលសាមណេរ ប្រយោជន៍អ្វីដល់អ្នក ( ដែលនៅ ) ក្នុងព្រៃភ្នំឈ្មោះឧជ្ជុហានៈ ( មិនជាទីសប្បាយ ) ក្នុងរដូវភ្លៀង ខ្យល់ឈ្មោះវេរម្ភៈ ( ខ្យល់ព្យុះ ) ជាទីរីករាយដល់អ្នកឬ ព្រោះថា សេចក្តីស្ងប់ស្ងាត់ រមែងមានដល់បុគ្គលទាំងឡាយអ្នកមានឈាន ។ ខ្យល់ឈ្មោះវេរម្ភៈ រមែងបក់ផាត់នូវពពកទាំងឡាយ ក្នុងរដូវភ្លៀង យ៉ាងណា សញ្ញារបស់ខ្ញុំ ដែលប្រកបដោយវិវេក ក៏រមែងរាយមាយយ៉ាងនោះដែរ ។ សត្វដែលកើតអំពីពង មានសម្បុរខ្មៅ ( ក្អែក ) ត្រាច់ទៅកាន់លំនៅក្នុងទីស្មសាន ក៏ញុំាងសតិនៃខ្ញុំដែលអាស្រ័យនូវការប្រាសចាកតម្រេកក្នុងរាងកាយ ឲ្យកើតឡើង ។ ជនទាំងឡាយដទៃ មិនរក្សានូវភិក្ខុណា ភិក្ខុណាមិនរក្សានូវជនទាំងឡាយដទៃ ភិក្ខុនោះ ជាអ្នកមិនមានសេចក្តីអាឡោះអាល័យក្នុងកាមទាំងឡាយ រមែងដេកជាសុខ ។ ភ្នំថ្មទាំងឡាយនោះ មានទឹកថ្លា មានថ្មក្រាស់ ប្រកបដោយសត្វមានកន្ទុយដូចគោ មានទឹកដេរដាសដោយសារាយ រមែងញុំាងអាត្មាឲ្យរីករាយ ។ អាត្មាក៏ធ្លាប់នៅក្នុងព្រៃទាំងឡាយផង ក្នុងប្រកភ្នំទាំងឡាយផង ក្នុងគុហាទាំងឡាយផង ក្នុងសេនាសនៈ

ទាំងឡាយដ៏ស្ងាត់ផង ក្នុងព្រៃដែលសត្វម្រឹគសាហាវ អាស្រ័យនៅផង ។ អាត្មាមិនធ្លាប់ដឹងនូវសេចក្តីត្រិះរិះ មិនប្រសើរ ប្រកបដោយទោស យ៉ាងនេះថា ពួកសត្វទាំងនេះ ចូរលំបាក ចូរស្លាប់ ចូរដល់នូវសេចក្តីទុក្ខ ( ដូច្នេះឡើយ ) ។ ព្រះសាស្តា អាត្មាបានបម្រើហើយ ព្រះពុទ្ធសាសនា អាត្មាបានធ្វើហើយ ភារៈដ៏ធ្ងន់ គឺខន្ធ អាត្មាបានដាក់ចុះហើយ តណ្ហាជាគ្រឿងនាំទៅកាន់ភព អាត្មាក៏បានដកចោលហើយ ។ បព្វជិតចេញចាកផ្ទះ ចូលកាន់ផ្នួស ដើម្បីប្រយោជន៍ណា ប្រយោជន៍ជាគ្រឿងអស់ទៅនៃសំយោជនៈទាំងពួងនោះ អាត្មាក៏បានដល់ហើយ ។ អាត្មាមិនត្រេកអរនឹងសេចក្តីស្លាប់ មិនត្រេកអរនឹងការរស់នៅ អាត្មារង់ចាំតែកាលនឹងបរិនិព្វាន ដូចជាអ្នកស៊ីឈ្នួលទន្ទឹងតែអស់ថ្ងៃ ។ អាត្មាមិនត្រេកអរនឹងសេចក្តីស្លាប់ មិនត្រេកអរនឹងការរស់នៅ អាត្មាជាអ្នកដឹងខ្លួន មានស្មារតីតាំងមាំ រង់ចាំតែកាលនឹងបរិនិព្វាន ។

### សង្កិច្ចត្ថេរ

## ឧទ្ទាន

អំពីសង្កិច្ចត្ថេរ តែមួយអង្គឯង លោកមានកិច្ចធ្វើស្រេចហើយ មិនមានអាសវៈ ពោលនូវគាថា ១១ នោះ ក្នុងឯកាទសកនិបាត ។

**ឯកាទសកនិបាត ចប់**

# អដ្ឋកថា
# ថេរគាថា ឯកាទសកនិបាត

## សំកិច្ចត្ថេរគាថា

[ ២៤១ ] ក្នុងឯកាទសកនិបាត គាថារបស់ព្រះសង្កិច្ចត្ថេរ មានពាក្យផ្ដើមថា **កឹ វតត្ថោ វនេ តាត** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងពុទ្ធុប្បាទនេះ បដិសន្ធិនៅក្នុងត្រកូលព្រាហ្មណមហាសាល ក្នុងក្រុងសាវត្ថី កាលលោកនៅក្នុងផ្ទៃនោះឯង មាតាមានជំងឺ ធ្វើកាលកិរិយា កាលមាតាត្រូវនាំទៅកាន់ឈាបនដ្ឋាន កន្សោមស្បូនមិនឆេះ ពួកមនុស្សយកឈើស្ទួលចាក់ចំត្រង់ចុងចិញ្ចើមរបស់ទារក ។ មនុស្សទាំងនោះចាក់ហើយ យករងើកភ្លើងកប់ ហើយចៀសចេញទៅ ។ ចំណែកនៃផ្ទៃត្រូវភ្លើងឆេះ ឯទារកដូចគ្នានឹងរូបបដិមាមាស ដេកលើរងើកភ្លើង ដូចដេកក្នុងត្របកឈូក ដូច្នោះ ។ ពិតហើយ ធម្មតាសត្វដែលជាបច្ឆិមភវិកសត្វ ( សត្វដែលមានភពចុងក្រោយ ) ទោះបីត្រូវភ្នំសិនេរុសង្កត់ បើមិនទាន់សម្រេចអរហត្ត ជីវិតក៏មិនអស់ ។

ស្អែកឡើង ពួកមនុស្សទៅកាន់ព្រៃខ្មោច ឃើញទារកដេកយ៉ាងនោះ កើតអស្ចារ្យមិនធ្លាប់មាន នាំទារកទៅកាន់ផ្ទះ សួរពួកហោរាអ្នកទាយនិមិត្ត ពួកអ្នកទាយនិមិត្តពោលថា បើទារកនេះនៅគ្រប់គ្រងផ្ទះសោត មនុស្សក្នុងត្រកូល ៧ តំណ នឹងបានទទួលសេចក្តីទុក្ខលំបាក បើបួសសោត នឹងចោមរោមដោយសមណៈ ៥០០ ត្រាច់ទៅ ពួកញាតិពោលថា ណ្ហើយចុះ ពេលទារកចម្រើនវ័យ ពួកយើងនឹងឲ្យបួសក្នុងសម្នាក់របស់លោកម្ចាស់សារីបុត្ត ហើយនាំគ្នាហៅឈ្មោះថា សង្កិច្ច ព្រោះត្រូវឈើស្ងួលចាក់ត្រង់ចុងចិញ្ចើម ទើបប្រាកដឈ្មោះថា **សង្កិច្ច** ។

លុះអាយុបាន ៧ ឆ្នាំ ស្តាប់រឿងដែលនៅក្នុងគភ៌ និងការស្លាប់របស់មាតា កើតនូវសេចក្តីសង្វេគ ទើបពោលថា ខ្ញុំនឹងបួស ។ ពួកញាតិពោលថា សាធុ ដូច្នេះហើយ នាំទៅកាន់សម្នាក់របស់ព្រះធម្មសេនាបតី បានប្រគល់ឲ្យដោយពាក្យថា បពិត្រលោកម្ចាស់ សូមឲ្យកុមារនេះបួសចុះ ។ ព្រះថេរៈបានឲ្យតចបញ្ចកកម្មដ្ឋាន ហើយឲ្យបួស ។ កុលបុត្តសម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទាក្នុងខណៈកោរសក់នោះឯង នៅក្នុងព្រៃជាមួយភិក្ខុ ៣០ រូប ជួយភិក្ខុទាំងនោះឲ្យរួចផុតអំពីកណ្តាប់ដៃចោរ សូម្បីខ្លួនឯង ក៏ទូន្មានចោរទាំងនោះឲ្យបួស ហើយនៅជាមួយភិក្ខុជាច្រើន ក្នុងវិហារមួយកន្លែង ឃើញភិក្ខុទាំងនោះរវល់តែឈ្លោះគ្នា ទើបប្រាប់ភិក្ខុទាំងនោះដោយពាក្យថា ខ្ញុំនឹងទៅក្នុងទីដទៃ ក្នុងរឿងនេះ មានសេចក្តីសង្ខេបប្រមាណប៉ុណ្ណេះ ។ ឯសេចក្តីពិស្តារ គប្បីជ្រាបដោយន័យមកហើយ ក្នុងរឿងនៃធម្មបទនោះឯង ។

លំដាប់នោះ ឧបាសកម្នាក់បំណងនឹងឧបដ្ឋាកព្រះថេរៈ ទើបអង្វរព្រះថេរៈឲ្យនៅក្នុងទីជិតៗ ទើបពោលគាថាទី ១ ថា

ម្នាលសាមណេរ ប្រយោជន៍អ្វីដល់អ្នក ( ដែលនៅ ) ក្នុងព្រៃភ្នំឈ្មោះឧជ្ជុហានៈ ( មិនជាទីសប្បាយ ) ក្នុងរដូវភ្លៀង ខ្យល់ឈ្មោះវេរម្ភៈ ( ខ្យល់ព្យុះ ) ជាទីរីករាយដល់អ្នកឬ ព្រោះថាសេចក្តីស្ងប់ស្ងាត់ រមែងមានដល់បុគ្គលទាំងឡាយ អ្នកមានឈាន ដូច្នេះ ។

សង្កិច្ចសាមណេរបានស្តាប់ដូច្នោះ ទើបពោលគាថាទាំងនេះថា

ខ្យល់ឈ្មោះវេរម្ភៈ រមែងបក់ផាត់នូវពពកទាំងឡាយ ក្នុងរដូវភ្លៀង យ៉ាងណា សញ្ញារបស់ខ្ញុំ ដែលប្រកបដោយវិវេក ក៏រមែងរាយមាយ យ៉ាងនោះដែរ ។ សត្វដែលកើតអំពីពង មានសម្បុរខ្មៅ ( ក្អែក ) ត្រាច់ទៅកាន់លំនៅក្នុងទីស្មសាន ក៏ញ៉ាំងសតិនៃខ្ញុំដែលអាស្រ័យនូវការប្រាសចាកតម្រេក ក្នុងរាងកាយឲ្យកើតឡើង ។ ជនទាំងឡាយដទៃ មិនរក្សានូវភិក្ខុណា ភិក្ខុណាមិនរក្សានូវជនទាំងឡាយដទៃ ភិក្ខុនោះ ជាអ្នកមិនមានសេចក្តីអាឡោះអាល័យក្នុងកាមទាំងឡាយ រមែងដេកជាសុខ ។ ភ្នំថ្មទាំងឡាយនោះ មានទឹកថ្លា មានថ្មក្រាស់ ប្រកបដោយសត្វមានកន្ទុយដូចគោ មានទឹកដេរដាសដោយសារាយ រមែងញ៉ាំងអាត្មាឲ្យរីករាយ ។ អាត្មាក៏ធ្លាប់នៅក្នុងព្រៃទាំងឡាយផង ក្នុងប្រកភ្នំ

ទាំងឡាយផង ក្នុងគុហាទាំងឡាយផង ក្នុងសេនាសនៈទាំង-ឡាយដ៏ស្ងាត់ផង ក្នុងព្រៃដែលសត្វម្រឹគសាហាវ អាស្រ័យនៅផង ។ អាត្មាមិនធ្លាប់ដឹងនូវសេចក្ដីត្រិះរិះមិនប្រសើរ ប្រកបដោយទោស យ៉ាងនេះថា ពួកសត្វទាំងនេះ ចូរលំបាក ចូរស្លាប់ ចូរដល់នូវសេចក្ដីទុក្ខ ( ដូច្នេះឡើយ ) ។ ព្រះសាស្ដា អាត្មាបានបម្រើហើយ ព្រះពុទ្ធសាសនា អាត្មាបានធ្វើហើយ ភារៈដ៏ធ្ងន់ គឺខន្ធ អាត្មាបានដាក់ចុះហើយ តណ្ហាជាគ្រឿងនាំទៅកាន់ភព អាត្មាក៏បានដកចោលហើយ ។ បព្វជិតចេញចាកផ្ទះ ចូលកាន់ផ្នួសដើម្បីប្រយោជន៍ណា ប្រយោជន៍ជាគ្រឿងអស់ទៅនៃសំយោជនៈទាំងពួងនោះ អាត្មាក៏បានដល់ហើយ ។ អាត្មាមិនត្រេកអរនឹងសេចក្ដីស្លាប់ មិនត្រេកអរនឹងការរស់នៅ អាត្មារង់ចាំតែកាលនឹងបរិនិព្វាន ដូចជាអ្នកស៊ីឈ្នួល ទន្ទឹងតែអស់ថ្ងៃ ។ អាត្មាមិនត្រេកអរនឹងសេចក្ដីស្លាប់ មិនត្រេកអរនឹងការរស់នៅ អាត្មាជាអ្នកដឹងខ្លួន មានស្មារតីតាំងមាំ រង់ចាំតែកាលនឹងបរិនិព្វាន ដូច្នេះ ។

សព្ទថា **កឹ** ក្នុងបទថា **កឹ វនេ្ត វនេ** នេះ ក្នុងគាថានេះ លោកពោលជាលិង្គវិបល្លាស អធិប្បាយថា ប្រយោជន៍អ្វីដោយការនៅព្រៃ គឺបានប្រយោជន៍អ្វី ។

ឧបាសកកាប់អានសាមណេរនោះ ដូចជាកូនរបស់ខ្លួន ទើបហៅថា **តាត** ព្រោះសាមណេរនៅក្មេង ។ បទថា **ឧជ្ជុហានោវ ចាតុសេ** សេចក្ដីថា

ភ្នំមួយឈ្មោះឧជ្ជុហានៈ ត្រង់ភ្នំនោះ ដេរដាសទៅដោយព្រៃក្រាស់ មានជ្រោះត្រង់ញកភ្នំច្រើន មានទឹកហូរ ក្នុងទីផ្សេងៗ មិនជាទីសប្បាយ ក្នុងរដូវភ្លៀង ព្រោះដូច្នោះ ភ្នំឈ្មោះថា ឧជ្ជុហានៈ នឹងមានប្រយោជន៍អ្វីសម្រាប់លោកម្ចាស់ក្នុងរដូវភ្លៀងនាពោលនេះ ។ តែក្នុងទីនេះ អាចារ្យពួកខ្លះពោលថា បក្សីមួយប្រភេទឈ្មោះឧជ្ជុហានៈ អត់ធន់ក្នុងភាពរងាមិនបាន ក្នុងរដូវភ្លៀង ទើបពួនក្នុងគុម្ពោតព្រៃ តាមមតិរបស់អាចារ្យពួកខ្លះនោះ ព្រៃមិនមានប្រយោជន៍សម្រាប់លោក ដូចព្រៃមិនមានប្រយោជន៍សម្រាប់បក្សី ឈ្មោះឧជ្ជុហានៈនោះឯង ។

បទថា **វេភារា រមណីយា តេ** មានវាចាប្រកបសេចក្ដីថា ខ្យល់កំបុតត្បូងបក់មក លោកម្ចាស់មានការពេញចិត្តឬ ។ អាចារ្យពួកខ្លះពោលថា វេភារាជាគុហាត្រង់ភ្នំ ឬជាឈ្មោះរបស់ភ្នំមួយ ទីនោះទៅមកមិនងាយស្រួល មិនមានមនុស្សច្រើន ដល់ព្រមដោយម្លប់ និងទឹក ព្រោះដូច្នោះ ទើបគុហាវេភារា ជាទីត្រេកអរនៃចិត្ត សមគួរដើម្បីការនៅក្នុងព្រៃ ។ ព្រោះហេតុអ្វី ព្រោះជាទីស្ងាត់សម្រាប់អ្នកចូលឈាន ព្រោះបុគ្គលចូលឈានបែបនោះត្រូវការភាពស្ងាត់ក្នុងទីណាមួយ ដូច្នោះ ទើបឧបាសកពោលថា សូមលោកម្ចាស់កុំទៅកាន់ព្រៃដែលឆ្ងាយ សូមនៅក្នុងគុហាវេភារាចុះ ។

ក្នុងសេចក្ដីនេះ មានអធិប្បាយថា ព្រោះកាលបុគ្គលចូលឈាន បាននូវសេនាសនៈដែលជាផាសុកដល់ការនៅ ជាទីស្ងប់ស្ងាត់នោះឯង ឈានជាដើមរមែងសម្រេច កាលមិនបាន ក៏មិនសម្រេចឡើយ ដូច្នោះ ក្នុងរដូវរងា

បែបនេះ លោកម្ចាស់មិនគួរនៅក្នុងព្រៃណាមួយ តែអាចនៅត្រង់គុហា និង ញកភ្នំជាដើមបាន ។

កាលឧបាសកពោលយ៉ាងនោះ ព្រះថេរៈកាលសម្តែងថា ព្រៃជាដើម ប៉ុណ្ណោះ រមែងញ៉ាំងអាត្មាឲ្យត្រេកអរ ទើបពោលពាក្យជាដើមថា **យថា អព្ភានិ** ដូច្នេះ ។

ពាក្យនោះ មានអធិប្បាយដូច្នេះថា ក្នុងរដូវភ្លៀង ខ្យល់កំបុតត្បូង រមែងបក់បន្សាត់នូវពពក និងភ្លៀងឲ្យធ្លាក់ចុះ យ៉ាងណា សញ្ញាដែលប្រកប ដោយវិវេក រមែងបន្សាត់ចិត្តរបស់ខ្ញុំ ឲ្យមកកាន់ទីស្ងាត់ ដូច្នោះ ។

សេចក្តីនេះ ដូចអ្វី ដូចក្អែកមានពណ៌មិនសជាសត្វកើតអំពីស៊ុត ត្រាច់ អាស្រ័យ គឺត្រាច់ធ្វើព្រៃខ្មោចនោះឲ្យជាទីនៅអាស្រ័យ ដូច្នោះ ។

បទថា **ឧប្បាទយតេវ មេ សតឹ សន្ទេហស្មឹ វិរាគនិស្សិតំ** សេចក្តីថា កាយគតាសតិកម្មដ្ឋាន ដែលប្រកបដោយការប្រាសចាកតម្រេកក្នុងកាយនេះ រមែងកើតឡើង ដល់អាត្មាមួយរំពេច ។ បានឮថា ថ្ងៃមួយ ព្រះថេរៈឃើញ សាកសពមនុស្សដែលក្អែកចឹកស៊ី បាននូវអសុភសញ្ញា ព្រះថេរៈពោល យ៉ាងនោះ សំដៅដល់កាយគតាសតិកម្មដ្ឋាននោះឯង ដោយហេតុនោះ ទើប លោកសម្តែងថា អាត្មាប្រាថ្នានៅក្នុងព្រៃប៉ុណ្ណោះ ព្រោះឆន្ទរាគៈក្នុងកាយមិន មាន ដោយប្រការទាំងពួង ។

សព្ទ ច ក្នុងបទថា **យញ្ច** ជាពាក្យប្រើក្នុងអត្ថថា ប្រមូលមក ដោយ ច សព្ទនោះ លោកសម្តែងថា ចូរអ្នកស្តាប់ហេតុនៃការនៅព្រៃរបស់ខ្ញុំ ដទៃ

ទៀត ។ ជនដទៃ មានសេវកៈជាដើម មិនចាំបាច់រក្សាបព្វជិតណា ព្រោះមិនមានការចាំបាច់ត្រូវរក្សា ព្រោះជាបុគ្គលនៅដោយមេត្តា និងព្រោះមិនមានគ្រឿងបរិក្ខារដែលគួរត្រូវការ ។ ម្យ៉ាងទៀត បព្វជិតណា មិនរក្សាជនដទៃដែលជាកិលេសគ្រឿងកន្លល់ដោយហេតុណាមួយ ព្រោះមិនមានបុគ្គលបែបនោះឯង ។

បទថា **ស វេ ភិក្ខុ សុខំ សេតិ** សេចក្តីថា ភិក្ខុនោះមិនមានសេចក្តីអាល័យ គឺវៀរចាកសេចក្តីជាប់ជំពាក់ក្នុងវត្ថុកាម ដោយប្រការទាំងពួង ព្រោះកាត់កិលេសកាមបានជាសមុច្ឆេទ រមែងនៅជាសុខក្នុងទីគ្រប់ទីកន្លែង អធិប្បាយថា ដូចជាក្នុងព្រៃក្បែរស្រុក ព្រោះបុគ្គលនោះ មិនមានសេចក្តីរង្កៀស ។

ឥឡូវនេះ ដើម្បីសម្តែងភ្នំ និងព្រៃជាដើមថាជាទីគួរត្រេកអរ និងថាជាទីដែលធ្លាប់នៅអាស្រ័យ ទើបលោកពោលថា **អច្ឆោធិកា** ជាដើម ។

បណ្តាបទទាំងនោះ បទថា **វសិតំ មេ** បានដល់ ទីដែលខ្ញុំធ្លាប់នៅ ។ បទថា **វាឡមិគនិសេវិតេ** បានដល់ ក្នុងព្រៃដែលមានសត្វសាហាវ មានរាជសីហ៍ និងខ្លាជាដើមចូលទៅអាស្រ័យនៅ ។

ដោយបទថា **សព្ពប្បំ ឆាភិជាឆាមិ** លោកសម្តែងដល់កាពជាអ្នកនៅដោយកម្មដ្ឋាន មានមេត្តាជាអារម្មណ៍ថា អាត្មាមិនមានការគិតអាក្រក់ ដូចជាព្យាបាទវិតក្ក និងវិហិង្សាវិតក្កជាដើម ដែលមិនប្រសើរ ដែលកើតឡើងហើយចាកចិត្តដែលប្រកបដោយទោស និងប្រកបដោយបដិឃៈនោះឯង យ៉ាងនេះថា សូមសត្វដែលមានជីវិតពួកណាមួយ ចូរត្រូវសម្លាប់ ចូរត្រូវបៀតបៀនដោយព្រួញ និងស្នជាដើម ចូរត្រូវសម្លាប់ ចូរត្រូវបៀតបៀន ដោយបាតដៃជាដើម ឬចូរដល់នូវសេចក្តីទុក្ខដោយអាការឯណានីមួយ ដូច្នេះ ការត្រិះរិះខុស មិនធ្លាប់កើតឡើងដល់អាត្មាឡើយ ។

ឥឡូវនេះ លោកសម្តែងថា លោកបានធ្វើកិច្ចស្រេចហើយ ដោយបទថា **បរិចិណ្ណោ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **បរិចិណ្ណោ** បានដល់ ឲ្យពេញព្រះហឫទ័យ ហើយដោយការធ្វើតាមឱវាទានុសាសនី ។

បទថា **ឱហិតោ** ប្រែថា ដាក់ចុះហើយ ។ បទថា **គរុកោ ភារោ** បានដល់ ខន្ធភារៈដែលធ្ងន់ក្រៃលែង ។ បទថា **ឆាភិឆន្ទាមិ មរណំ** សេចក្តីថា ខ្ញុំមិនប្រាថ្នាសេចក្តីស្លាប់ថា ធ្វើម្តេច ទើបអាត្មាអញស្លាប់ហ្ន៎ ។

បទថា **នាភិនន្ទាមិ ជីវិតំ** សេចក្តីថា ខ្ញុំមិនប្រាថ្នាសូម្បីជីវិតថា ធ្វើម្តេចហ្ន៎ អាត្មាអញគប្បីមានជីវិតរស់នៅបានយូរ ។ ដោយពាក្យនេះ លោកសម្តែងឲ្យឃើញថា មានការគិតដូចគ្នា ទាំងក្នុងការស្លាប់ និងក្នុងការមានជីវិត ។

បទថា **កាលញ្ច បដិកង្ខាមិ** សេចក្តីថា ខ្ញុំរង់ចាំបរិនិព្វានប៉ុណ្ណោះ ។ បទថា **និព្វិសំ** បានដល់ ស៊ីឈ្នួល គឺធ្វើការងារដើម្បីថ្លៃឈ្នួល ។

បទថា **ភតកោ យថា** សេចក្តីថា កូនឈ្នួលធ្វើនូវការងារដើម្បីអ្នកដទៃ សូម្បីមិនពេញចិត្តធ្វើ ក៏ធ្វើរឿយៗ ទៅ ឲ្យអស់ថ្ងៃ យ៉ាងណា អាត្មាក៏ដូច្នោះ មិនចង់រស់នៅ ក៏ត្រូវព្យាបាលអត្តភាព ទោះបីមិនចង់ស្លាប់ ក៏ត្រូវរង់ចាំកាលចុងក្រោយ ។ បទដ៏សេស មានន័យដូចពោលហើយ ( ក្នុងថ្ងៃគាថា ) នោះឯង ៕

**អដ្ឋកថា សំកិច្ចត្ថេរគាថា ចប់**

**ថេរគាថា ឯកាទសកនិបាត ចប់**

# សុត្តន្តបិដក

# ថេរគាថា ត្តិំសនិបាត

## សីលវត្ថេរគាថា

[ ២៤២ ] បុគ្គលគប្បីសិក្សានូវសីល ឲ្យជាសីលដែលខ្លួនសិក្សាល្អ ហើយ ក្នុងលោកនេះ ព្រោះថា សីលដែលបុគ្គលសេពហើយ រមែង បង្អោនមកនូវសម្បត្តិទាំងពួង ។ ជនអ្នកមានប្រាជ្ញា កាលចង់បាននូវ សេចក្តីសុខ ៣ យ៉ាង គឺសេចក្តីសរសើរ ១ ការបាននូវសេចក្តី ត្រេកអរ ១ ការលះលោកនេះទៅហើយ រីករាយក្នុងឋានសួគ៌ ១ គប្បីរក្សានូវសីល ។ ពិតណាស់ បុគ្គលអ្នកមានសីល រមែងបាន នូវមិត្តទាំងឡាយច្រើន ដោយការសង្រួម ចំណែកបុគ្គលទ្រុស្តសីល កាលប្រព្រឹត្តអាក្រក់ រមែងឃ្លាតចាកមិត្តទាំងឡាយ ។ ជនទ្រុស្ត-សីល រមែងបាននូវទោសផង នូវតំណិះដំណៀលផង ឯជនអ្នកមាន សីល រមែងបាននូវគុណផង នូវកិត្តិសព្ទផង នូវសេចក្តីសរសើរ ផង សព្វៗ កាល ។ សីលជាខាងដើម ជាទីតាំង ជាមេនៃកល្យាណ-ធម៌ និងជាប្រធាននៃធម៌ទាំងពួង ព្រោះហេតុនោះ បុគ្គលគប្បីជម្រះ សីល ។ សីលជាប្រាំង ជាទំនប់ ជាគ្រឿងញុំាងចិត្តឲ្យរីករាយ ទាំង ជាកំពង់របស់ព្រះពុទ្ធគ្រប់ព្រះអង្គ ព្រោះហេតុនោះ បុគ្គលគប្បីជម្រះ នូវសីល ។ សីលជាកម្លាំងរកអ្វីប្រៀបផ្ទឹមមិនបាន សីលជាអាវុធដ៏

ឧត្តម សីលជាគ្រឿងអាភរណៈដ៏ប្រសើរ សីលជាគ្រឿងក្រោះយ៉ាងអស្ចារ្យ ។ សីល ជាស្ពានមានសក្តិធំ សីលជាគ្រឿងក្រអូបដ៏ប្រសើរ សីលជាគ្រឿងលាបដ៏ប្រសើរ តែងបក់ទៅ សព្វៗ ទិស ។ សីល ជាកញ្ចប់បាយដ៏ប្រសើរ សីលជាស្បៀងដ៏ឧត្តម សីលជាវាហនៈដ៏ប្រសើរ សម្រាប់ទៅកាន់ទិសទាំងពួង ។ បុគ្គលពាលមានចិត្តអាក្រក់ក្នុងទីទាំងពួង មិនតាំងមាំក្នុងសីលទាំងឡាយ រមែងបាននូវសេចក្តីនិន្ទាក្នុងលោកនេះផង លុះលះលោកនេះទៅហើយ រមែងមានចិត្តជាទុក្ខ ក្នុងអបាយផង ។ អ្នកប្រាជ្ញ មានចិត្តល្អ ក្នុងទីទាំងពួង តាំងមាំក្នុងសីលទាំងឡាយ រមែងបាននូវកិត្តិសព្ទ ក្នុងលោកនេះផង លុះលះលោកនេះទៅ រមែងមានចិត្តរីករាយក្នុងឋានសួគ៌ផង ។ សីលជាកំពូលក្នុងលោកនេះ ចំណែកបុគ្គលអ្នកមានប្រាជ្ញាក៏ឧត្តមដែរ ជ័យជម្នះក្នុងមនុស្សលោក និងទេវលោក ព្រោះសីល និងបញ្ញា ។

**សីលវត្ថេរ**

# អដ្ឋកថា

# ថេរគាថា ទ្វាទសកនិបាត

## សីលវត្ថេរគាថា

[ ២៨២ ] ក្នុងទ្វាទសកនិបាត គាថារបស់ព្រះសីលវត្ថេរ មានពាក្យផ្តើមថា **សីលមេវ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងពុទ្ធុប្បាទនេះ កើតជាឱរសនៃព្រះបាទពិម្ពិសារ ក្នុងក្រុងរាជគ្រឹះ មានមនាមថា **សីលវៈ** ។ កាលលោកចម្រើនវ័យហើយ ព្រះបាទអជាតសត្តុបំណងនឹងសម្លាប់ លើកឡើងដាក់លើដំរីចុះប្រេង ព្យាយាមដោយឧបាយផ្សេងៗ ក៏មិនអាចនឹងឲ្យស្លាប់បាន ព្រោះជាបច្ឆិមភវិកសត្វ មិនមានអន្តរាយចំពោះជីវិតក្នុងរវាងដែលមិនទាន់បានសម្រេចអរហត្ត ។ ព្រះមានព្រះភាគទ្រង់ជ្រាបការប្រព្រឹត្តទៅរបស់កុលបុត្តនោះ ត្រាស់នឹងព្រះមហាមោគ្គល្លានត្ថេរថា ចូរអ្នកនាំសីលវកុមារមក ព្រះថេរៈបាននាំសីលវៈមក មួយអន្លើដោយដំរីដោយកម្លាំងនៃឫទ្ធិ ។

កុមារចុះអំពីដំរី ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរនាចំណែកម្ខាង ។ ព្រះមានព្រះភាគទ្រង់សម្តែងធម៌ ដែលសមគួរដល់អធ្យា-

ស្រ័យនៃកុលបុត្តនោះ ។ កុលបុត្តនោះស្តាប់ធម៌ហើយ បាននូវសទ្ធា បួស បំពេញវិបស្សនាកម្មដ្ឋាន មិនយូរប៉ុន្មានក៏សម្រេចអរហត្ត ក្នុងកោសលរដ្ឋ ។ លំដាប់នោះ ព្រះបាទអជាតសត្តុទ្រង់ត្រាស់នឹងបុរសទាំងឡាយថា ពួកអ្នកចូរសម្លាប់ ។ រាជបុរសទាំងនោះទៅកាន់សម្នាក់របស់ព្រះថេរៈ ហើយឈរស្តាប់ធម្មកថាដែលព្រះថេរៈសម្តែង កើតនូវសេចក្តីសង្វេគ មានចិត្តជ្រះថ្លាបួសហើយ ។ ព្រះថេរៈបានសម្តែងធម៌ដល់ភិក្ខុទាំងនោះ ដោយគាថាទាំងនេះថា

បុគ្គលគប្បីសិក្សានូវសីល ឲ្យជាសីលដែលខ្លួនសិក្សាល្អហើយក្នុងលោកនេះ ព្រោះថា សីលដែលបុគ្គលសេពហើយ រមែងបង្អោនមកនូវសម្បត្តិទាំងពួង ។ ជនអ្នកមានប្រាជ្ញា កាលចង់បាននូវសេចក្តីសុខ ៣ យ៉ាង គឺសេចក្តីសរសើរ ១ ការបាននូវសេចក្តីត្រេកអរ ១ ការលះលោកនេះទៅហើយ រីករាយក្នុងឋានសួគ៌ ១ គប្បីរក្សានូវសីល ។ ពិតណាស់ បុគ្គលអ្នកមានសីល រមែងបាននូវមិត្តទាំងឡាយច្រើន ដោយការសង្រួម ចំណែកបុគ្គលទ្រុស្តសីលកាលប្រព្រឹត្តអាក្រក់ រមែងឃ្លាតចាកមិត្តទាំងឡាយ ។ ជនទ្រុស្ត-សីល រមែងបាននូវទោសផង នូវតំណិះដំណៀលផង ឯជនអ្នកមានសីល រមែងបាននូវគុណផង នូវកិត្តិសព្ទផង នូវសេចក្តីសរសើរផង សព្វៗ កាល ។ សីលជាខាងដើម ជាទីតាំង ជាមេនៃកល្យាណ-ធម៌ និងជាប្រធាននៃធម៌ទាំងពួង ព្រោះហេតុនោះ បុគ្គលគប្បីជម្រះ

សីល ។ សីលជាប្រាំង ជាទំនប់ ជាគ្រឿងញុំាងចិត្តឲ្យរីករាយ ទាំងជាកំពង់របស់ព្រះពុទ្ធគ្រប់ព្រះអង្គ ព្រោះហេតុនោះ បុគ្គលគប្បីជម្រះនូវសីល ។ សីលជាកម្លាំងរកអ្វីប្រៀបផ្ទឹមមិនបាន សីលជាអាវុធដ៏ឧត្តម សីលជាគ្រឿងអាភរណៈដ៏ប្រសើរ សីលជាគ្រឿងក្រោះយ៉ាងអស្ចារ្យ ។ សីល ជាស្ពានមានសក្តិធំ សីលជាគ្រឿងក្រអូបដ៏ប្រសើរ សីលជាគ្រឿងលាបដ៏ប្រសើរ តែងបក់ទៅ សព្វៗ ទិស ។ សីលជាកញ្ចប់បាយដ៏ប្រសើរ សីលជាស្បៀងដ៏ឧត្តម សីលជាវាហនៈដ៏ប្រសើរ សម្រាប់ទៅកាន់ទិសទាំងពួង ។ បុគ្គលពាលមានចិត្តអាក្រក់ក្នុងទីទាំងពួង មិនតាំងមាំក្នុងសីលទាំងឡាយ រមែងបាននូវសេចក្តីនិន្ទាក្នុងលោកនេះផង លុះលះលោកនេះទៅហើយ រមែងមានចិត្តជាទុក្ខ ក្នុងអបាយផង ។ អ្នកប្រាជ្ញ មានចិត្តល្អ ក្នុងទីទាំងពួងតាំងមាំក្នុងសីលទាំងឡាយ រមែងបាននូវកិត្តិសព្ទ ក្នុងលោកនេះផង លុះលះលោកនេះទៅ រមែងមានចិត្តរីករាយក្នុងឋានសួគ៌ផង ។ សីលជាកំពូលក្នុងលោកនេះ ចំណែកបុគ្គលអ្នកមានប្រាជ្ញាក៏ឧត្តមដែរ ជ័យជម្នះក្នុងមនុស្សលោក និងទេវលោក ព្រោះសីល និងបញ្ញាដូច្នេះ ។

បទថា **៩៨** ក្នុងបទថា **សីលមេវិធ សិក្ខេថ អស្មឹ លោកេ** នេះ ក្នុងគាថានោះ ត្រឹមតែជានិបាត ។ កុលបុត្តប្រាថ្នាចំពោះប្រយោជន៍ ក្នុងសត្វលោកនេះ គប្បីសិក្សាសីលតាំងអំពីដើម មានចារិតសីល និងវារិតសីល

ជាដើម កាលសិក្សាសីលនោះគប្បីសិក្សាសីលនោះឲ្យល្អ គឺយ៉ាងល្អ បាន ដល់ ធ្វើឲ្យបរិសុទ្ធបរិបូណ៌ដោយល្អ ដោយឲ្យដល់ភាវៈដែលសីលមិនដាច់ ជាដើម ។

បទថា **អស្មឹ លោកេ** សេចក្តីថា ម្យ៉ាងទៀត គប្បីសិក្សាសីលក្នុង ធម៌ដែលគួរសិក្សា ក្នុងសង្ខារលោកនេះតាំងអំពីខាងដើម ។

លោកពោលថា **សីលំ ហិ** ជាដើម ព្រោះសីលជាទីតាំងមាំ នៃទិដ្ឋិសម្បត្តិផងដែរ ។

សព្ទថា **ហិ** ក្នុងគាថានោះ ជាពាក្យប្រាប់ហេតុ ប្រែថា ព្រោះ ឬដ្បិត ។ ព្រោះសីលដែលបុគ្គលសេពហើយ អប់រំហើយ រក្សាហើយ រមែងបង្អោនទាំ មកនូវសម្បត្តិទាំងពួង គឺមនុស្សសម្បត្តិ ទិព្វសម្បត្តិ និព្វានសម្បត្តិ ដល់ សត្វដែលប្រកបព្រមដោយសីលនោះ ។

កាលសម្តែងអត្ថដែលលោកពោលដោយន័យសង្ខេបថា សីលដែល បុគ្គលសេពហើយ រមែងបង្អោនមកនូវសម្បត្តិទាំងពួង ឲ្យពិស្តារ ទើបពោល ពាក្យថា ជនអ្នកមានប្រាជ្ញា កាលចង់បាននូវសេចក្តីសុខ ... ជាដើម ។

បណ្តាបទទាំងនោះ បទថា **រក្ខេយ្យ** ប្រែថា គប្បីរក្សា ។ ព្រោះ បុគ្គលកាលវៀរចាកបាណាតិបាតជាដើម និងបំពេញវត្ត បដិបត្តិឲ្យបរិបូណ៌ ឈ្មោះថា រមែងរក្សាខ្លួននោះ ឲ្យផុតចាកការញាំញីរបស់សត្រូវ ។

បទថា **មេធាវី** បានដល់ អ្នកមានប្រាជ្ញា ។ បទនេះ ជាបទសម្តែង ឧបាយ ជាគ្រឿងរក្សាសីលនោះ ពិតហើយ ការសមាទានសីលនោះ និងការ

ដែលសីលនោះមិនកម្រើក រមែងមានដោយកម្លាំងនៃញាណ ។

បទថា **បត្តយានោ** បានដល់ កាលត្រូវការ ។ បទថា **តយោ សុខេ** បានដល់ សុខ ៣ យ៉ាង ។ ម្យ៉ាងទៀត ហេតុនៃសេចក្តីសុខ លោកបំណង យកថា ជាសុខ ។

បទថា **បសំសំ** បានដល់ កិត្តិយស ឬពាក្យសរសើររបស់វិញ្ញូជន ។ បទថា **វិត្តិលាភំ** បានដល់ បាននូវការត្រេកអរ ។ តែអាចារ្យពួកខ្លះពោលថា **វិត្តលាភំ** ដូច្នេះក៏មាន អធិប្បាយថា បានទ្រព្យ ។ ពិតហើយ បុគ្គលមានសីល រមែងជួបនូវគំនរភោគៈធំ ព្រោះជាអ្នកមិនប្រមាទ ។

បទថា **បេច្ច** បានដល់ ធ្វើកាលកិរិយាហើយ ។ បទថា **សគ្គេ បមោទនំ** ភ្ជាប់សេចក្តីថា ប្រាថ្នានូវការត្រេកអរដោយកាមគុណដែលគួរពេញចិត្តក្នុងទេវលោក ។ មានវាចាប្រកបសេចក្តីថា កាលប្រាថ្នានូវសេចក្តីសរសើរ គឺចង់បាននូវការត្រេកអរក្នុងលោកនេះ និងការត្រេកអរដោយទិព្វសម្បត្តិក្នុងលោកខាងមុខ គប្បីរក្សាសីល ។

បទថា **សញ្ញមេន** បានដល់ ធ្វើនូវការសង្រួមកាយជាដើម ។ ពិតហើយ កាលសង្រួម មិនបៀតបៀនបុគ្គលណាម្នាក់ដោយកាយទុច្ចរិតជាដើម ឲ្យនូវអភយទាន ឈ្មោះថា រមែងចងមិត្តបាន ព្រោះជាទីស្រឡាញ់ និងជាទីពេញចិត្ត ។

បទថា **ធំសតេ** បានដល់ រមែងធ្វើឲ្យឃ្លាតចាក ។ បទថា **ចាបមាចរំ** បានដល់ ធ្វើនូវបាបកម្ម មានបាណាតិបាតជាដើម ។ ពិតហើយ សត្វទាំង-

ឡាយ ប្រាថ្នាចំពោះប្រយោជន៍ រមែងមិនគប់រកបុគ្គលដែលទ្រុស្តសីល ដោយពិត រមែងវៀរ ។

បទថា **អវណ្ណំ** បានដល់ នូវទោសដែលមិនមែនគុណ ឬការនិន្ទា ចំពោះមុខ ។

បទថា **អកិត្តឹ** បានដល់ ទោសមិនមែនយស គឺមិនមានកេរ្តិ៍ឈ្មោះ ។ បទថា **វណ្ណំ** បានដល់ គុណ ។

បទថា **កិត្តឹ** បានដល់ ការសរសើរ គឺមានយសដែលគួរប្រាថ្នា ។ បទថា **បសំសំ** បានដល់ ការសរសើរចំពោះមុខ ។ បទថា **អាទិ** បានដល់ ជាមូល ។ ពិតហើយ សីលជាខាងដើមនៃកុសលធម៌ ដូចព្រះតម្រាស់ ( ក្នុង សំយុត្តនិកាយ មហាវារវគ្គ ) ថា ម្នាលភិក្ខុ បើដូច្នោះ ចូរអ្នកជម្រះក្នុង កុសលធម៌ទាំងឡាយ ជាខាងដើមបន្តិសសិនចុះ ។ ចុះអ្វីជាខាងដើមនៃ កុសលធម៌ទាំងឡាយ គឺសីលដ៏បរិសុទ្ធ ១ ទិដ្ឋិត្រង់ ១ ដូច្នេះ ។

បទថា **បតិដ្ឋា** បានដល់ តាំងមាំ ពិតហើយ សីលជាទីតាំងនៃឧត្តរិ-មនុស្សធម៌ទាំងអស់ ។ ព្រោះហេតុនោះ ទើបលោកពោលថា តាំងនៅក្នុង សីលជាដើម ។

បទថា **កល្យាណានញ្ច មាតុកំ** សេចក្តីថា ជាប្រភពកើត គឺឲ្យ កំណើតកល្យាណធម៌ មានសមថៈ និងវិបស្សនាជាដើម ។

បទថា **បមុខំ សព្វធម្មានំ** បានដល់ ជាប្រមុខ គឺជាប្រធាន អធិប្បាយ ថា ជាទ្វារនៃការប្រព្រឹត្តទៅនៃធម៌ដែលមិនមានទោសទាំងអស់ មានបាមោជ្ជ

ជាដើម ។

បទថា **តស្មា** បានដល់ ព្រោះភាពជាចំណែកខាងដើម ។

បទថា **វិសោធយេ** បានដល់ គប្បីឲ្យសម្រេច ដោយភាពជាសីលមិនដាច់ជាដើម ។

បទថា **វេលា** បានដល់ ជាដែន អធិប្បាយថា ជាខេត្ត ព្រោះអត្ថថា ទុច្ចរិតទាំងឡាយឈានកន្លងមិនបាន ឬឈ្មោះថា **វេលា** ព្រោះកន្លង គឺធ្វើភាពជាបុគ្គលទ្រុស្តសីលឲ្យកន្លងទៅ កម្ចាត់ភាពជាអ្នកទ្រុស្តសីល ឈ្មោះថា **សំវរំ** ព្រោះបិទនូវទ្វារនៃការកើតឡើងនៃកាយទុច្ចរិតជាដើម ។

បទថា **អភិហាសនំ** សេចក្តីថា ឈ្មោះថា ត្រេកអរ ព្រោះធ្វើចិត្តឲ្យត្រេកអរក្រៃលែង ដោយភាពជាហេតុមិនក្តៅក្រហាយ ។

បទថា **តិត្ថញ្ច សព្វពុទ្ធានំ** សេចក្តីថា ដូចជាកំពង់ក្នុងការបន្សាត់មន្ទិល គឺកិលេស និងក្នុងការឈមចុះកាន់មហាសមុទ្រ គឺព្រះនិព្វាននៃអ្នកប្រាជ្ញទាំងពួង គឺសាវកពុទ្ធ បច្ចេកពុទ្ធ ព្រះសម្មាសម្ពុទ្ធ ។

បទថា **សីលំ ពលំ អប្បដិមំ** បានដល់ ជាកម្លាំង និងជាថាមពលនៃកងទ័ពដែលមិនមានបុគ្គលស្មើ ក្នុងការញាំញីមារ និងសេនា ។

បទថា **អាវុធមុត្តមំ** បានដល់ ជាគ្រឿងប្រហារដ៏ឧត្តមក្នុងការកាត់នូវសង្កិលេសធម៌ ឈ្មោះថា **អាភរណំ** ព្រោះអត្ថថា ធ្វើរាងកាយឲ្យល្អ ។

បទថា **សេដ្ឋំ** សេចក្តីថា ប្រសើរ និងសមគួរសព្វកាល ។ ឈ្មោះថា **កវចមព្ភុតំ** ( ក្រោះ ) ព្រោះការពារសត្វមានជីវិត ។ អាចារ្យពួកខ្លះពោល

ថា **អត្ថុធំ** ក៏មាន សេចក្តីថា ទម្លាយមិនបាន ។ ឈ្មោះថា **សេតុ** ( ស្ពាន ) ព្រោះអត្ថថា មិនលិចចុះដោយកិលេស ព្រោះឈានកន្លងនូវអន្លង់ទឹកធំ គឺ អបាយ និងព្រោះឈានកន្លងអន្លង់ទឹកធំ គឺសង្សារ ។

បទថា **មហេសក្ខោ** បានដល់ មានកម្លាំងច្រើន ។ បទថា **គន្ធោ អនុត្តរោ** សេចក្តីថា ឈ្មោះថា **គន្ធោ អនុត្តរោ** ព្រោះផ្សាយទៅនូវក្លិន សព្វទិស ។ ជាហេតុត្រេកអរនៃចិត្តរបស់ជនទាំងពួង ដោយហេតុនោះ ទើប លោកពោលថា **យេន វាតិ ទិសោ ទិសំ** អធិប្បាយថា បុគ្គលដល់ព្រម ដោយក្លិន គឺសីលនោះ រមែងផ្សាយទៅសព្វទិសតូចទិសធំ គឺសព្វទិស ទាំងពួង បាលីថា **ទិសោទិសា** ដូច្នេះក៏មាន អធិប្បាយថា ទៅកាន់ទិស ១០ ។

បទថា **សម្ពលមេវគ្គំ** បានដល់ កញ្ចប់បាយ ឈ្មោះថា **បុដភត្ត** បុរស កាន់យកបុដកត្តដើរទៅ រមែងមិនលំបាកដោយសេចក្តីទុក្ខ ព្រោះការឃ្លាន ក្នុងរវាងផ្លូវ យ៉ាងណា បុរសដែលសម្បូរដោយសីលក៏ដូច្នោះ កាន់យក បុដកត្ត គឺសីលដែលបរិសុទ្ធ ដើរទៅកាន់ផ្លូវកន្តារ គឺសង្សារ រមែងមិនលំបាក ក្នុងទីដែលទៅហើយ ព្រោះហេតុនោះ ទើបសីល ឈ្មោះថា កញ្ចប់បាយដ៏ ប្រសើរ ។ ម្យ៉ាងទៀត **សីល** ឈ្មោះថា **ចាជយ្យមុត្តមំ** ព្រោះមិនទូទៅ ដល់ចោរជាដើម និងព្រោះឲ្យសម្រេចនូវសម្បត្តិដែលប្រាថ្នាក្នុងទីនោះៗ យាន ចាត់ជាពាហនៈ ព្រោះកាលដើរទៅ ធ្វើឲ្យឆ្លងទៅ គឺឲ្យដល់ទីនោះៗ ឬទីដែល ប្រាថ្នា ។ សីលជាធម្មជាតដែលបុគ្គលណាម្នាក់ប្រទូស្តមិនបាន ជាគុណជាត

ដ៏ប្រសើរ ជាពាហនៈដ៏ប្រសើរ ព្រោះធ្វើឲ្យដល់ឋានៈដែលប្រាថ្នាបាន ។

បទថា **យេន** បានដល់ រមែងទៅពាហនៈដ៏ប្រសើរក្រៃលែងណា ។ បទថា **ទិសោទិសំ** សេចក្តីថា រមែងទៅកាន់ទិសនោះៗ ដោយងាយស្រួល ទាំងពេលមក និងពេលទៅ ។

បទថា **ឥធេវ និន្ទំ លភតិ** សេចក្តីថា ក្នុងលោកនេះ បុគ្គលពាល ជាអ្នកសោកស្តាយ ជាអ្នកមានចិត្តដែលកិលេស មានរាគៈជាដើម ប្រទូស្ត ហើយ រមែងបានទទួលនូវការនិន្ទាថា បុគ្គលនេះជាអ្នកទ្រុស្តសីល ជាអ្នក មានធម៌ដ៏លាមក ។ លះលោកនេះទៅហើយ ក្នុងបរលោក រមែងបានទទួល សេចក្តីនិន្ទាអំពីបុរសនៃយមរាជជាដើមក្នុងអបាយ ដោយន័យជាដើមថា ជា បុគ្គលមានបាបក្នុងខ្លួនជាអវជាត ដូច្នេះ ។ រមែងបានទទួលតែការនិន្ទាតែម្យ៉ាង ប៉ុណ្ណោះក៏មិនមែន ដោយពិត បុគ្គលនោះ ឈ្មោះថា ជាបុគ្គលពាល មាន ចិត្តអាក្រក់ក្នុងទីគ្រប់ស្ថាន គឺជាអ្នកមានចិត្តដែលការប្រព្រឹត្តអាក្រក់ក្នុងលោក នេះប្រទូស្តហើយ ព្រោះឲ្យកើតទុក្ខ ដោយអំណាចហេតុនៃកម្មជាដើមក្នុង បរលោក ព្រោះហេតុនោះ ទើបបុគ្គលពាល ជាអ្នកមាននូវទោមនស្សក្នុង ទីគ្រប់ស្ថាន ។

សួរថា សេចក្តីនេះព្រោះអ្វី ឆ្លើយថា ព្រោះបុគ្គលនោះជាអ្នកមានចិត្ត មិនតាំងមាំនៅក្នុងសីលទាំងឡាយ គឺមានចិត្តមិនតាំងនៅ មិនប្រតិស្ឋានក្នុង សីលទាំងឡាយដោយជុំវិញ ។

បទថា **ឥធេវ កិត្តឹ លភតិ** សេចក្តីថា ជាអ្នកមានចិត្តត្រេកអរក្នុង

លោកនេះ មនុស្សល្អរមែងជាអ្នករីករាយ រមែងបានទទួលកិត្តិយសថា ជាសប្បុរស មានសីល មានកល្យាណធម៌ បុគ្គលនោះលះលោកនេះទៅហើយ រមែងបានទទួលកិត្តិយសក្នុងបរលោក មានស្ថានសួគ៌ជាដើមថា បុគ្គលនេះជាសប្បុរស មានសីល មានកល្យាណធម៌ផង ដល់នូវភាពជាសម្លាញ់នៃទេវតាទាំងឡាយផង រមែងបានទទួលកិត្តិយសតែម្យ៉ាងក៏មិនមែន ថែមទាំងបានឈ្មោះថា ជាអ្នកប្រាជ្ញ ដល់ព្រមដោយបញ្ញា មានចិត្តតាំងមាំដោយល្អ ប្រតិស្ឋានដោយល្អ ក្នុងសីលទាំងឡាយ ជាអ្នកមានចិត្តផ្អែត មានចិត្តតាំងមាំ ឈ្មោះថា ជាអ្នកមានចិត្តរីករាយ គឺមានសោមនស្សក្នុងទីគ្រប់ស្ថាន គឺក្នុងលោកនេះ ព្រោះការប្រព្រឹត្តសុចរិត ក្នុងលោកខាងមុខ ព្រោះបានទទួលសម្បត្តិ ។

ក្នុងបទថា **សីលមេវ ឥធ អគ្គំ** នេះ សីលមាន ២ យ៉ាង គឺលោកិយសីល ១ លោកុត្តរសីល ១ ក្នុងសីល ២ យ៉ាងនោះ លោកិយសីល ជាលំដាប់ដំបូង រមែងនាំមកនូវគុណវិសេស ដូចជាធ្វើឲ្យកើតជាខត្តិយមហាសាលជាដើម ក្នុងកាមលោក និងនូវគុណវិសេស គឺធ្វើឲ្យកើតក្នុងទេវលោក និងក្នុងព្រហ្មលោក និងជាហេតុឲ្យបុគ្គលមានលាភជាដើម ។ ចំណែកលោកុត្តរសីល រមែងឲ្យឈានកន្លងវដ្តទុក្ខទាំងមូលបាន ព្រោះហេតុនោះ ទើបឈ្មោះថាជាកំពូលដោយពិត សមដូចព្រះបច្ចេកពុទ្ធពោល ( ខុទ្ទកនិកាយ ជាតក ) ថា

បុគ្គលចូលទៅកើតក្នុងពួកក្សត្រិយ៍ ដោយព្រហ្មចរិយធម៌ដ៏ថោក
ទាប បុគ្គលចូលទៅកាន់ភាពជាទេវតា ដោយព្រហ្មចរិយធម៌

យ៉ាងកណ្ដាល បុគ្គលបរិសុទ្ធដោយព្រហ្មចរិយធម៌ដ៏ឧត្តម ដូច្នេះ ។

និងពុទ្ធដីកា ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) មួយកន្លែងទៀតថា ម្នាលភិក្ខុទាំងឡាយ បើភិក្ខុប្រាថ្នាថា អាត្មាអញគប្បីបានចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យភេសជ្ជបរិក្ខារ ដូច្នេះ គួរធ្វើសីលឲ្យបរិបូរណ៍ ដូច្នេះ និងពុទ្ធដីកា ( ក្នុងអង្គុត្តរនិកាយ អដ្ឋកនិបាត ) មួយកន្លែងទៀតថា ម្នាលភិក្ខុទាំងឡាយ សេចក្ដីប្រាថ្នាដោយចិត្តរបស់បុគ្គលមានសីល រមែងសម្រេច ព្រោះចិត្តបរិសុទ្ធ ដូច្នេះ ។

មិនចាំបាច់ពោលដល់ភាពជាកំពូលនៃលោកុត្តរសីល ដែលធ្វើឲ្យលះធម៌ ដែលជាសត្រូវបាន ដោយប្រការទាំងពួង ដែលធ្វើឲ្យកន្លងសង្សារទុក្ខបាន តាំងអំពីភពទី ៧ ឡើយ ។

បទថា **បញ្ញវា បន ឧត្តមោ** លោកពោលថា បញ្ញានោះឯង ប្រសើរបំផុត ដោយបុគ្គលាធិដ្ឋានថា បុគ្គលអ្នកមានបញ្ញា រមែងជាបុគ្គលដ៏ឧត្តម គឺប្រសើរក្រៃលែង ។

ឥឡូវនេះ កាលនឹងសម្ដែងភាវៈដែលសីល និងបញ្ញាប្រសើរតាមកិច្ច ទើបលោកពោលថា ជ័យជម្នះក្នុងមនុស្សលោក និងទេវលោក ព្រោះសីល និងបញ្ញា ។

បទថា **ជយំ** នេះ គប្បីឃើញថា ជាលិង្គវិបល្លាស ម្យ៉ាងទៀត គប្បីនាំពាក្យដែលសល់ គឺពាក្យថា **អហុ** មកភ្ជាប់ចូលផង ។

ក្នុងសីល និងបញ្ញានោះ ឈ្មោះថា **បញ្ញា** ព្រោះអត្ថថា ដឹងទូទៅឯការឈ្នះសត្រូវ ព្រោះសីល និងបញ្ញា ។

ព្រោះមិនមានសីល បញ្ញា ក៏កើតមិនបាន បើមិនមានបញ្ញា សីលក៏ធ្វើកិច្ចឯងមិនបាន ធម៌ទាំង ២ នោះ រមែងឧបការៈដល់គ្នានិងគ្នា សមដូចពាក្យដែលលោកពោល ( ក្នុងទីឃនិកាយ សីលក្ខន្ធវគ្គ ) ថា ដ្បិតប្រាជ្ញា រមែងជម្រះសីលឲ្យបរិសុទ្ធ សីលសោត ក៏រមែងជម្រះប្រាជ្ញាឲ្យបរិសុទ្ធដែរ ដូច្នេះ ។

បទថា **មនុស្សេសុ ច ទេវេសុ** នេះ ជាបទសម្តែងឋានៈដែលផ្សេងគ្នារបស់សីល និងបញ្ញានោះ ។ សេចក្តីពិត ក្នុងសេចក្តីនោះ សីល និងបញ្ញាទាំងនោះ មានសេចក្តីផ្សេងគ្នា ។ ក្នុងសេចក្តីនេះ សមាធិជាគ្រឿងពិចារណាសីល ឬជាគ្រឿងពិចារណាបញ្ញា ព្រោះជាទីតាំងនៃបញ្ញា ព្រោះជាធម៌ដែលគួរចម្រើន និងព្រោះមានសីលជាទីតាំង ។

ព្រះថេរៈកាលសម្តែងធម៌ដោយលើកសីលឡើងជាប្រធាន ដល់ភិក្ខុទាំងនោះ ដោយប្រការដូច្នេះ ស្មើគ្នានឹងព្យាករអរហត្តផល ដោយសម្តែងថា លោកជាអ្នកមានគុណធម៌ មានសីលបរិសុទ្ធដោយល្អជាដើម ។៙

**អដ្ឋកថា សីលវត្ថេរគាថា ចប់**

# សុត្តន្តបិដក

## សុធីតត្ថេរគាថា

[ ២៤៣ ] ខ្ញុំកើតក្នុងត្រកូលទាប ជាអ្នកក្រីក្រ មានភោជនតិច ការងាររបស់ខ្ញុំ ក៏ថោកទាប ខ្ញុំជាអ្នកចាក់ចោលនូវផ្កា គឺលាមក ។ មនុស្សទាំងឡាយស្អប់ខ្ពើម មើលងាយ បន្តុះបង្អាប់ខ្ញុំៗ បានធ្វើចិត្តឲ្យទាប សំពះនូវជនជាច្រើន ។ គ្រានោះ ខ្ញុំបានឃើញនូវព្រះសម្ពុទ្ធ មានភិក្ខុសង្ឃហែហមហើយ ព្រះអង្គមានព្យាយាមធំ កំពុងយាងចូលទៅកាន់បុរីដ៏ឧត្តម របស់ជនអ្នកមគធៈ ។ ខ្ញុំក៏ដាក់នូវអម្រែក ចូលទៅដើម្បីថ្វាយបង្គំព្រះសម្ពុទ្ធ ជាបុរសដ៏ខ្ពង់ខ្ពស់ ទ្រង់ឋិតនៅដើម្បីអនុគ្រោះខ្ញុំ ។ ខ្ញុំថ្វាយបង្គំព្រះបាទទាំងគូរបស់ព្រះសាស្ដាហើយ ឋិតនៅក្នុងទីសមគួរ គ្រានោះ ខ្ញុំសូមបព្វជ្ជានឹងព្រះសម្ពុទ្ធ ព្រះអង្គឧត្តមជាងសព្វសត្វទាំងឡាយ ។ លំដាប់នោះ ព្រះសាស្ដាព្រះអង្គប្រកបដោយសេចក្ដីករុណា ទ្រង់អនុគ្រោះដល់លោកទាំងមូល ត្រាស់ហៅខ្ញុំថា ចូរអ្នកមកជាភិក្ខុចុះ ដូច្នេះ ព្រះវាចានោះជាឧបសម្បទារបស់ខ្ញុំ ។ ព្រះជិនស្រី ទ្រង់ទូន្មានខ្ញុំយ៉ាងណា ខ្ញុំនោះជាបុគ្គលម្នាក់ឯង នៅក្នុងព្រៃ មិនខ្ជិលច្រអូស ក៏បានធ្វើតាមព្រះពុទ្ធដីកា នៃព្រះសាស្ដាយ៉ាងនោះ ។ ខ្ញុំរឭកឃើញនូវបុព្វជាតិ ក្នុងបឋមយាមនៃរាត្រី ជម្រះនូវទិព្វចក្ខុ ក្នុងមជ្ឈិមយាមនៃរាត្រី បានទម្លាយនូវគំនរនៃងងឹត គឺអវិជ្ជា ក្នុងបច្ឆិមយាមនៃរាត្រី ។ លំដាប់នោះ កាលដែលរាត្រីអស់ទៅ ព្រះអាទិត្យជិតរះឡើង ព្រះឥន្ទ្រ និងព្រះព្រហ្ម មកផ្គងអញ្ជលី

នមស្ការចំពោះខ្ញុំថា បពិត្រលោកជាបុរសអាជានេយ្យ ខ្ញុំសូមថ្វាយបង្គំចំពោះលោក បពិត្រលោកជាបុរសដ៏ខ្ពង់ខ្ពស់ ខ្ញុំសូមថ្វាយបង្គំចំពោះលោក បពិត្រលោកនិទ្ទុក្ខ អាសវៈទាំងឡាយរបស់លោកណាអស់ហើយ លោកនោះ ជាទក្ខិណេយ្យបុគ្គល ។ លំដាប់នោះព្រះសាស្តាទ្រង់ទតឃើញខ្ញុំ ដែលមានពួកទេវតាហែហម ទ្រង់ក៏ធ្វើនូវការញញឹមឲ្យប្រាកដ ហើយទ្រង់ត្រាស់សេចក្តីនេះថា បុគ្គលឈ្មោះថា ព្រាហ្មណ៍ ព្រោះធម៌ ៤ ប្រការនេះ គឺតបៈ ១ ព្រហ្មចរិយៈ ១ សញ្ញមៈ ១ ទមៈ ១ នេះជាព្រាហ្មណវត្តដ៏ឧត្តម ។

**សុនីតត្ថេរ**

## ឧទ្ទាន

ព្រះថេរៈទាំងឡាយពីរអង្គនេះ គឺសីលវត្ថេរ ១ សុនីតត្ថេរ ១ សុទ្ធតែមានឫទ្ធិច្រើន បានពោលនូវគាថា ២៤ ក្នុងទ្វាទសកនិបាត ។

**ទ្វាទសកនិបាត ចប់**

# អដ្ឋកថា

## សុនីតត្ថេរគាថា

[ ២៤៣ ] គាថារបស់ព្រះសុនីតត្ថេរ មានពាក្យផ្តើមថា **នីចេ កុលម្ហិ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងចន្លោះកាលនៃព្រះពុទ្ធ កើតក្នុងផ្ទះមានត្រកូល ចម្រើនវ័យហើយ ខ្វល់ខ្វាយក្នុងការលេង ជាមួយបុគ្គលពាលទាំងឡាយ ត្រាច់ទៅ ឃើញព្រះបច្ចេកពុទ្ធមួយអង្គ កំពុងត្រាច់បិណ្ឌបាតក្នុងស្រុក ទើបជេរថា ការដែលលោកបិទបាំងកាយ ដូចមានដំបៅពេញខ្លួនហើយត្រាច់ភិក្ខាចារមានប្រយោជន៍អ្វី លោកគួររកស៊ីចិញ្ចឹមជីវិតដោយកសិកម្មនិងពាណិជ្ជកម្មជាដើម មិនមែនឬ បើលោកធ្វើការងារទាំងនោះមិនបាន ក៏ចូរចិញ្ចឹមជីវិត ដោយការជញ្ជូនបស្សាវៈ និងឧច្ចារៈជាដើមគ្រប់ៗ ផ្ទះចេញទៅខាងក្រោយសីមមកបោសដី ។

ព្រោះកម្មនោះ ទើបកុលបុត្តនោះឆេះក្នុងនរក ដោយវិបាកនៃកម្មនោះសូម្បីមកកើតក្នុងមនុស្សលោក ក៏កើតក្នុងត្រកូលអ្នកចាក់សំរាម ចិញ្ចឹមជីវិតដោយការចាក់សំរាមច្រើនរយជាតិ ។ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលនៃអ្នកចាក់សំរាមទៀត ធ្វើការងារចិញ្ចឹមជីវិត ដោយការលាងឧច្ចារៈ មិនបានសូម្បីតែអាហារនិងសំពត់ស្លៀក ។

*ក្នុងកាលតមក ព្រះមានព្រះភាគ ទ្រង់ចូលមហាករុណាសមាបត្តិដែលព្រះពុទ្ធទ្រង់ធ្លាប់ប្រព្រឹត្តមក ចេញអំពីសមាបត្តិនោះហើយ ទ្រង់ប្រមើលមើលសត្វលោកដោយពុទ្ធចក្ខុ ទ្រង់ឃើញធម៌ដែលជាឧបនិស្ស័យនៃអរហត្តដែលរុងរឿងខាងក្នុងហទយៈរបស់សុនីតៈ ដូចប្រទីបឆេះសន្ធោសន្ធៅក្នុងថ្នាំងដូច្នោះ ។ កាលរាត្រីអស់ហើយ ត្រង់ស្បៀកស្បង់អំពីព្រលឹម កាន់បាត្រនិងចីវរ ចោមរោមដោយភិក្ខុសង្ឃ ត្រាច់បិណ្ឌបាតក្នុងក្រុងរាជគ្រឹះ យាងទៅតាមវិថីដែលសុនីតៈធ្វើកម្ម គឺលាងជម្រះឧច្ចារៈ ។*

*ឯសុនីតៈ ធ្វើឧច្ចារៈ និងសំរាម និងកាកសំណល់អាហារជាដើមក្នុងទីនោះៗ ឲ្យជាគំនរ ហើយដាក់ក្នុងល្អីរែកចេញទៅ ឃើញព្រះសាស្តាចោមរោមដោយភិក្ខុសង្ឃកំពុងយាងមក មានចិត្តត្រេកអរ និងប្របូកប្របល់ កាលមិនមានផ្លូវគេចចេញ ទើបដាក់អម្រែកក្បែរជញ្ជាំងផ្ទះ ឈរក្បែរជញ្ជាំង ផ្គងអញ្ជលីបញ្ចេញខ្លួនត្រឹមពាក់កណ្តាល ។ អាចារ្យពួកខ្លះពោលថា សុនីតៈបំណងនឹងចៀសចេញទៅតាមប្រហោងជញ្ជាំងក៏មាន ។*

*ព្រះសាស្តាយាងទៅក្បែរ ទ្រង់ព្រះតម្រិះថា សុនីតៈនេះ សរសើរតថាគត ជាបុគ្គលត្រូវកុសលមូលជាស់តឿន ក្នុងទីចំពោះមុខ ក៏នៅខ្មាសព្រោះមានជាតិ និងកម្មអាក្រក់ ណ្ហើយចុះ តថាគតនឹងឲ្យកុលបុត្តនេះកើតនូវសេចក្តីអាចហ៊ាន ដូច្នេះ ទើបត្រាស់ហៅថា សុនីតៈ ដោយព្រះសូរសៀងដូចសំឡេងព្រហ្ម គឺកកងពេញព្រះនគរ ពីរោះដូចសំឡេងបក្សីករវិក ហើយត្រាស់ថា ការរស់នៅលំបាកយ៉ាងនេះ ហេតុអ្វី ទើបអ្នកមិនបួស សុនីតៈ*

ត្រូវព្រះតម្រាស់របស់ព្រះសាស្តាលិចស្រោច ដូចស្រោចដោយទឹកអម្រឹត ទើបសោយបីតិ និងសោមនស្សដ៏ក្រៃលែង ក្រាបទូលថា បពិត្រព្រះមានព្រះភាគ បើបុគ្គលទាំងឡាយដូចខ្ញុំព្រះអង្គ បានបួសក្នុងទីនេះសោត រឿងអ្វីដែលថា ខ្ញុំព្រះអង្គមិនបួស បពិត្រព្រះមានព្រះភាគ សូមទ្រង់ឲ្យខ្ញុំព្រះអង្គបួសផងចុះ ។

ព្រះសាស្តាត្រាស់ថា ចូរអ្នកមកជាភិក្ខុចុះ ក្នុងខណៈនោះឯង កុលបុត្តនោះបានបព្វជ្ជា និងឧបសម្បទាដោយឯហិភិក្ខុ ទ្រទ្រង់នូវបាត្រ និងចីវរដែលសម្រេចដោយឫទ្ធិ ហាក់បីដូចជាព្រះថេរៈមានវស្សា ៦០ ឈរក្នុងសម្នាក់ព្រះសាស្តា ។ ព្រះមានព្រះភាគទ្រង់នាំទៅកាន់វិហារ ត្រាស់ប្រាប់នូវកម្មដ្ឋាន ព្រះថេរៈញុំាងសមាបត្តិ ៨ និងអភិញ្ញា ៥ ឲ្យកើតមុន ហើយចម្រើនវិបស្សនា ជាអ្នកបានអភិញ្ញា ៦ ទេវតាមានសក្កទេវរាជជាដើម និងព្រហ្ម ចូលទៅមនស្ការព្រះថេរៈ ដោយហេតុនោះ ទើបលោកពោលថា

ទេវតា ៧០០ និងព្រហ្មជាច្រើន មួយអន្លើដោយព្រះឥន្ទ្រ មានចិត្តជ្រះថ្លា ចូលទៅនមស្ការព្រះសុនីតៈ ដូចសេះអាជានេយ្យ គ្របសង្កត់ជាតិ និងជរាបានហើយ ដូច្នេះជាដើម ។

ព្រះមានព្រះភាគ ទ្រង់ឃើញព្រះថេរៈចោមរោមដោយពួកទេវតា ទ្រង់ធ្វើការញញឹម ហើយទ្រង់សរសើរ ទ្រង់សម្តែងធម៌ដោយគាថាថា **តបេន ព្រហ្មចរិយេន** ជាដើម ។ លំដាប់នោះ ភិក្ខុជាច្រើនបំណងនឹងឲ្យព្រះថេរៈបន្លឺសីហនាទ ទើបសួរថា អាវុសោសុនីតៈ ព្រោះហេតុអ្វី ទើបលោកចេញ

ចាកត្រកូលបួស លោកបួសបានដូចម្តេច លោកចាក់ធ្លុះសច្ចៈបានដូចម្តេច ព្រះថេរៈកាលនឹងប្រកាសរឿងនោះ ទើបបន្លឺសីហនាទ ដោយគាថាទាំងនោះថា

ខ្ញុំកើតក្នុងត្រកូលទាប ជាអ្នកក្រីក្រ មានភោជនតិច ការងាររបស់ខ្ញុំ ក៏ថោកទាប ខ្ញុំជាអ្នកចាក់ចោលនូវផ្កា គឺលាមក ។ មនុស្សទាំងឡាយស្អប់ខ្ពើម មើលងាយ បន្តុះបង្អាប់ខ្ញុំៗ បានធ្វើចិត្តឲ្យទាប សំពះនូវជនជាច្រើន ។ គ្រានោះ ខ្ញុំបានឃើញនូវព្រះសម្ពុទ្ធ មានភិក្ខុសង្ឃហែហមហើយ ព្រះអង្គមានព្យាយាមធំ កំពុងយាងចូលទៅកាន់បុរីដ៏ឧត្តម របស់ជនអ្នកមគធៈ ។ ខ្ញុំក៏ដាក់នូវអម្រែក ចូលទៅដើម្បីថ្វាយបង្គំព្រះសម្ពុទ្ធ ជាបុរសដ៏ខ្ពង់ខ្ពស់ ទ្រង់ឋិតនៅ ដើម្បីអនុគ្រោះខ្ញុំ ។ ខ្ញុំថ្វាយបង្គំព្រះបាទទាំងគូរបស់ព្រះសាស្តាហើយ ឋិតនៅក្នុងទីសមគួរ គ្រានោះ ខ្ញុំសូមបព្វជ្ជានឹងព្រះសម្ពុទ្ធ ព្រះអង្គឧត្តមជាងសព្វសត្វទាំងឡាយ ។ លំដាប់នោះ ព្រះសាស្តា ព្រះអង្គប្រកបដោយសេចក្តីករុណា ទ្រង់អនុគ្រោះដល់លោកទាំងមូល ត្រាស់ហៅខ្ញុំថា អ្នកចូរចូលមកជាភិក្ខុចុះ ដូច្នេះ ព្រះវាចានោះជាឧបសម្បទារបស់ខ្ញុំ ។ ព្រះជិនស្រីទ្រង់ទូន្មានខ្ញុំយ៉ាងណា ខ្ញុំនោះជាបុគ្គលម្នាក់ឯង នៅក្នុងព្រៃ មិនខ្ជិលច្រអូស ក៏បានធ្វើតាមព្រះពុទ្ធដីកានៃព្រះសាស្តាយ៉ាងនោះ ។ ខ្ញុំរឭកឃើញនូវបុព្វជាតិ ក្នុងបឋមយាមនៃរាត្រី ជម្រះនូវទិព្វចក្ខុ

ក្នុងមជ្ឈិមយាមនៃរាត្រី បានទម្លាយនូវគំនរនៃងងឹត គឺអវិជ្ជា ក្នុងបច្ឆិមយាមនៃរាត្រី ។ លំដាប់នោះ កាលដែលរាត្រីអស់ទៅ ព្រះអាទិត្យជិតរះឡើង ព្រះឥន្ទ្រ និងព្រះព្រហ្ម មកផ្គងអញ្ជលី នមស្ការចំពោះខ្ញុំថា បពិត្រលោកជាបុរសអាជានេយ្យ ខ្ញុំសូមថ្វាយបង្គំចំពោះលោក បពិត្រលោកជាបុរសដ៏ខ្ពង់ខ្ពស់ ខ្ញុំសូមថ្វាយបង្គំចំពោះលោក បពិត្រលោកនិទ្ទុក្ខ អាសវៈទាំងឡាយរបស់លោកណាអស់ហើយ លោកនោះជាទក្ខិណេយ្យបុគ្គល ។ លំដាប់នោះ ព្រះសាស្តាទ្រង់ទតឃើញខ្ញុំ ដែលមានពួកទេវតាហែហម ទ្រង់ក៏ធ្វើនូវការញញឹមឲ្យប្រាកដ ហើយទ្រង់ត្រាស់សេចក្តីនេះថា បុគ្គលឈ្មោះថា ព្រាហ្មណ៍ ព្រោះធម៌ ៤ ប្រការនេះ គឺតបៈ ១ ព្រហ្មចរិយៈ ១ សញ្ញមៈ ១ ទមៈ ១ នេះជាព្រាហ្មណវត្តដ៏ឧត្តម ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **នីចេ** បានដល់ លាមក គឺអាក្រក់ជាងត្រកូលទាំងពួង ។ ពិតហើយ ការខ្ពស់ និងការទាបកើតឡើង ព្រោះប្រៀបធៀបនឹងសត្វទាំងឡាយ ។ ព្រះថេរៈនេះកាលសម្តែងថា លោកកើតក្នុងត្រកូលចាក់សំរាម ដែលអាក្រក់ជាងត្រកូលទាំងឡាយ ទើបពោលថា ខ្ញុំកើតក្នុងត្រកូលទាប ។ ដោយហេតុនោះ ទើបលោកពោលថា **នីចេ** ដែលប្រែថា លាមក គឺអាក្រក់ជាងត្រកូលទាំងពួង ។

បទថា **ទលិទ្ទោ** ប្រែថា ជាអ្នកក្រីក្រ ពិតហើយ អ្នកក្រីក្រពួកខ្លះ បាន

អាហារ និងសំពត់ស្លៀកម្តងម្កាល មិនរស់ដោយការខ្វះខាត ចំណែកខ្ញុំ ឈ្មោះថា ជាមនុស្សអាក្រក់ ព្រោះមានការរស់នៅខ្វះខាត សព្វកាល ។ ព្រះថេរៈកាលសម្តែងថា ខ្ញុំដូចបុគ្គលលើកឆ្នាំងបាយឡើងអំពីជើងក្រាន ឃើញតែដំណក់ទឹកដែលល្មមមើលឃើញ ទើបពោលថា មានភោជនតិច ដូច្នេះ ។

កាលនឹងសម្តែងថា បុគ្គលខ្លះកើតក្នុងត្រកូលទាបផង ជាអ្នកក្រីក្រផង តែការងារ និងអាជីពមិនថោកថយ ឯខ្ញុំមិនដូច្នោះឡើយ ទើបពោលថា ការងាររបស់ខ្ញុំក៏ថោកទាប ដូច្នេះ ។ បើសួរថា ដូចអ្វី ឆ្លើយថា ខ្ញុំជាអ្នកចាក់ចោលនូវផ្កា គឺលាមក អធិប្បាយថា ឈ្មោះដែលហៅលោកថា **អហោសឹ បុប្ផឆឌ្ឌកោ** ( ជាអ្នកចាក់ចោលនូវផ្កា ) នេះ ជាពាក្យហៅបែបប្រៀបធៀប ដូចហៅមនុស្សមិនមានដៃថា អ្នកមានដៃ ដូច្នោះ ម្យ៉ាងទៀត ពាក្យបែបនេះប្រើហៅទីដែលប្រឡាក់ឧច្ចារៈ ព្រោះមានពណ៌ដូចក្តាម ដែលសង្កត់ដោយផ្កាស្លួត ។

បទថា **ជិគុច្ឆិតោ** ត្រូវអ្នកដទៃមើលងាយដោយជាតិ និងការងារ ។ បទថា **មនុស្សានំ** ប្រែថា ដែលពួកមនុស្ស ។ បទថា **បរិភូតោ** ប្រែថា មើលងាយ ។ បទថា **វម្ភិតោ** បានដល់ ដែលគេសម្មតកំហែង ។

បទថា **នីចំ មនំ ករិត្វាន** សេចក្តីថា លើកមនុស្សដទៃឡើង ដូចលើកឡើងកាន់ក្នុំសិនេរុ ធ្វើខ្លួនឲ្យទាបជាងធូលីដែលជាប់នឹងជើងរបស់មនុស្សទាំងនោះ គឺគិតថា ខ្លួនជាមនុស្សថោកទាប ។

បទថា **វន្ទិស្សំ ពហុកំ ជនំ** សេចក្តីថា ខ្ញុំថ្វាយបង្គំ គឺផ្គងអញ្ជលីដាក់

លើសិរសា គឺត្បូង ក្នុងកាលដែលឃើញមហាជនច្រើន ។

សព្ទថា **អថ** ជានិបាត ប្រើក្នុងការសម្ដែងលំដាប់រឿងរ៉ាវ ។ បទថា **អទ្ទសាសឹ** ប្រែថា បានឃើញហើយ ។ បទថា **មគធានំ** សេចក្ដីថា លំនៅរបស់ព្រះរាជកុមារក្នុងមគធជនបទ សូម្បីជនបទមួយ ក៏ហៅជាពហុវចនៈថា **មាគធានំ** ព្រោះជាពាក្យមានសំឡេងរណ្ដំទៅ អធិប្បាយថា នៃមគធ-ជនបទ ។

បទថា **បុរុត្តមំ** បានដល់ បុរី ( នគរ ) ដ៏ឧត្ដម ។ បទថា **ព្យាភង្គឹ** ប្រែថា រែក ។ បទថា **បព្វជ្ជំ អហាមាយាចឹ** សេចក្ដីថា កាលព្រះសាស្ដាទ្រង់ធ្វើឱកាសថា សុនីតៈ អ្នកបួសឬទេ ទើបខ្ញុំបានសូមបព្វជ្ជា ។

បទថា **អាស្វូបសម្បទា** បានដល់ ជាឧបសម្បទាដោយហេតុត្រឹមព្រះតម្រាស់របស់ព្រះសាស្ដាថា ចូរអ្នកជាភិក្ខុចុះ ។

បទថា **យថា មំ ឱវទិ** សេចក្ដីថា ព្រះសាស្ដាទ្រង់បានទូន្មានខ្ញុំថា ចូរចម្រើនវិបស្សនា ដែលមានសមថៈជាខាងដើមយ៉ាងនេះ យ៉ាងណា ខ្ញុំធ្វើគឺបដិបត្តិតាមព្រះតម្រាស់របស់ព្រះសាស្ដាយ៉ាងនោះ ។

បទថា **រត្តិយា** ជាដើម ជាបទសម្ដែងកិច្ចនៃបដិបទានោះ ។ ក្នុងគាថានោះ បទថា **យាមំ** ជាទុតិយាវិភត្តិ ចុះក្នុងអត្ថអច្ចន្តសំយោគ ( ប្រែថា រហូត ) ថា **បឋមំ យាមំ មជ្ឈិមំ យាមំ** រហូតបឋមយាម រហូតមជ្ឈិម-យាម ដូច្នេះ ព្រោះបុព្វេនិវាសញ្ញាណ និងអនាគតំសញ្ញាណ មានកិច្ចច្រើន ។ អាសវក្ខយញ្ញាណមិនមែនដូច្នោះឡើយ ព្រោះប្រព្រឹត្តទៅ ដោយអំណាចការ

ត្រាស់ដឹងក្នុងខណៈតែមួយ ព្រោះហេតុនោះ បទថា **បច្ឆិមេ យាមេ** គប្បីជ្រាបថា លោកប្រើជាសត្តមីវិភត្តិ ( ប្រែថា ក្នុង ) ។ បទថា **វណ្ណោ** បានដល់ សក្កទេវរាជ ។

បទថា **ព្រហ្មា** បានដល់ មហាព្រហ្ម ។ ដោយសព្ទថា **វណ្ណព្រហ្មា** គប្បីជ្រាបថា លោកពោលដល់ការមកនៃទេវតាក្នុងកាមភព និងព្រហ្មដទៃនោះឯង ។ ពិតហើយ សព្ទថា **វណ្ណព្រហ្មា** នោះ ជាពាក្យសម្តែងយ៉ាងឧក្រិដ្ឋ ដូចពោលថា រាជាយាងមកហើយ ( រមែងរួមយកមនុស្សដែលតូចជាងព្រះរាជាថា មកដែរ ) ។

បទថា **នមស្សិំសុ** បានដល់ ធ្វើនមស្ការដោយកាយ និងដោយវាចា ។ ក្នុងពាក្យនោះ ព្រះថេរៈកាលសម្តែងការឱនលំទោនដែលធ្វើដោយកាយ ទើបពោលពាក្យជាដើមថា **បញ្ជលី** ដើម្បីសម្តែងដល់ការថ្វាយបង្គំដែលធ្វើដោយវាចា ទើបពោលថា **នមោ តេ** ជាដើម ។

បទថា **ទេវសង្ឃបុរក្ខតំ** សេចក្តីថា ពួកព្រហ្ម លោកកាន់យកដោយ **ទេវ** សព្ទ ព្រោះជាឧបបត្តិទេពដែរ ។

បទថា **សិតំ បាតុករិត្វាន** សេចក្តីថា ព្រោះឱវាទរបស់ព្រះអង្គ មានផលច្រើន និងព្រោះទេវតា និងព្រហ្ម មកដោយគុណរបស់ព្រះសាស្តា ទើបទ្រង់ធ្វើញញឹមឲ្យប្រាកដ ។ កាលទ្រង់ធ្វើឲ្យប្រាកដ ទ្រង់មិនបានបង្ហាញព្រះទន្តឲ្យឃើញដូចពួកមនុស្សដទៃ តែទ្រង់ញញឹមបន្តិច ដោយត្រឹមតែធ្វើការញញឹមនោះ ពន្លឺដ៏ភ្លឺផ្លេកកើតអំពីព្រះចន្ទមកែវ គ្របសង្កត់ពន្លឺកែវផលិក

កែវមុក្តាដែលជាទិព្វ គឺជាពន្លឺដែលភ្លឺជាងពន្លឺផ្កាយ និងព្រះចន្ទ រិលប្រទក្សិណព្រះកក្ត្ររបស់ព្រះសាស្តា ៣ ជុំ មនុស្សដែលដើរខាងក្រោយ ឃើញពន្លឺនោះហើយ ក៏ដឹងថា ព្រះសាស្តាទ្រង់ញញឹម ។

បទថា **តបេន** បានដល់ ដោយការសង្រួមឥន្ទ្រិយ អាចារ្យពួកខ្លះពោលថា ដោយការសមាទានធុតង្គធម៌ ។

បទថា **សញ្ញមេន** បានដល់ ដោយសីល ។ បទថា **ទមេន** បានដល់ ដោយបញ្ញា ។ បទថា **ព្រហ្មចរិយេន** បានដល់ ដោយការប្រព្រឹត្តដ៏ប្រសើរដែលមិនទាន់ដល់ទីបំផុត ។

បទថា **ឯតេន** បានដល់ ដោយតបៈតាមដែលពោលហើយជាដើម ។ ឈ្មោះថា **ព្រាហ្មណោ** ព្រោះជាអ្នកមានបាបបន្សាត់ហើយ ។ បទថា **ឯតំ** បានដល់ តបៈតាមដែលពោលហើយជាដើម ។ បទថា **ព្រាហ្មណមុត្តមំ** បានដល់ ព្រាហ្មណ៍ដ៏ឧត្តម ឬក្នុងបណ្តាព្រាហ្មណ៍ទាំងឡាយ លោកជាបុរសឧត្តម គឺប្រសើរជាងទានទាំងអស់ បាលីដ៏សេសថា **អហុ** ក៏គប្បីនាំចូលមកភ្ជាប់ ។

ម្យ៉ាងទៀត លោកពោលដល់ភាពជាព្រហ្មដោយពាក្យថា **ព្រាហ្មណោ** អធិប្បាយថា ជាព្រហ្មដ៏ឧត្តមដោយគុណធម៌យ៉ាងនេះ មិនមែនដោយជាតិជាដើមទេ ។

ពិតហើយ ជាតិ ត្រកូល ប្រទេស គោត្ត និងសម្បត្តិជាដើម មិនជាហេតុឲ្យនូវភាពជាអរិយៈឡើយ តែអធិសីលសិក្ខាជាដើមប៉ុណ្ណោះជាហេតុ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ ( ខុទ្ទកនិកាយ ធម្មបទ ) ថា

ផ្កាឈូក ទុកជាកើតក្នុងគំនរសំរាម ដែលគេចាក់ចោលក្បែរផ្លូវ
ធំនោះ ក៏គង់មានក្លិនក្រអូប ជាទីរីករាយនៃចិត្តបាន ដូចម្តេចមិញ
បណ្តាជនដែលដូចជាគំនរសំរាម សាវករបស់ព្រះសម្មាសម្ពុទ្ធ
រមែងរុងរឿង កន្លងផុតបុថុជ្ជនទាំងឡាយ ដែលល្ងិតល្ងង់ដោយ
ប្រាជ្ញា ( របស់ខ្លួន ) ដូច្នោះឯង ដូច្នេះ ។

ព្រះថេរៈកាលភិក្ខុទាំងនោះសួរហើយយ៉ាងនេះ កាលនឹងឆ្លើយសេចក្តីនោះដោយគាថាទាំងនេះ ស្មើគ្នានឹងបានបន្លឺសីហនាទហើយនោះឯង ។ល។

**អដ្ឋកថាសុណីតត្ថេរគាថា ចប់**

**ថេរគាថា ទ្វាទសកនិបាត ចប់**

# សុត្តន្តបិដក
## ថេរគាថា តេរសកនិបាត

### សោណកោឡិវិសត្ថេរគាថា

[ ២៨៤ ] ព្រះសោណៈណា ជាអ្នកប្រសើរ ល្បីក្នុងដែនអង្គៈ ព្រះសោណៈនោះ ជាអ្នកប្រសើរ ក្នុងធម៌ទាំងឡាយ បានដល់នូវត្រើយនៃទុក្ខ ក្នុងថ្ងៃនេះ ។ ភិក្ខុកាត់នូវសំយោជនៈ ( ខាងក្រោម ) ៥ ផង លះបង់នូវសំយោជនៈ ( ខាងលើ ) ៥ ផង ចម្រើននូវឥន្ទ្រិយ ៥ តទៅទៀតផង ជាអ្នកកន្លងនូវធម៌ជាគ្រឿងជាប់ចំពាក់ ៥ យ៉ាងផង ទើបហៅថា អ្នកឆ្លងនូវអន្លង់បាន ។ សីល សមាធិ និងបញ្ញា នៃភិក្ខុអ្នកមានមានះដូចបបុស ជាអ្នកប្រមាទ មានសេចក្ដីប្រាថ្នាខាងក្រៅ រមែងមិនដល់នូវការពេញលេញឡើយ ។ ព្រោះថា អំពើណាដែលត្រូវធ្វើ អំពើនោះ ពួកភិក្ខុណាបោះបង់ចោល តែឡប់ធ្វើអំពើដែលមិនត្រូវធ្វើវិញ អាសវៈទាំងឡាយ នៃពួកភិក្ខុទាំងនោះ ដែលជាអ្នកមានមានះដូចបបុស ជាអ្នកប្រមាទ រមែងចម្រើនឡើង ។ លុះតែ

កាយគតាសតិ ភិក្ខុទាំងឡាយណា ប្រារព្ធល្អជានិច្ច ភិក្ខុទាំងឡាយនោះ ជាអ្នកមានកិរិយាធ្វើរឿយៗ ក្នុងអំពើដែលត្រូវធ្វើ មិនសេពនូវអំពើដែលមិនត្រូវធ្វើ អាសវៈទាំងឡាយ នៃភិក្ខុទាំងឡាយមានស្មារតី ជាអ្នកដឹងខ្លួន រមែងដល់នូវសេចក្ដីវិនាសទៅ ។ ផ្លូវត្រង់ព្រះសាស្ដាបានប្រាប់ហើយ អ្នកទាំងឡាយចូរដើរទៅចុះ កុំត្រឡប់វិញឡើយ កុលបុត្រគប្បីដាស់តឿនខ្លួនដោយខ្លួនឯង គប្បី ( នាំខ្លួន ) ទៅកាន់ព្រះនិព្វាន ។ កាលខ្ញុំប្រារព្ធសេចក្ដីព្យាយាម យ៉ាងតឹងរឹងព្រះសាស្ដា ជាបុគ្គលប្រសើរក្នុងលោក ព្រះអង្គមានចក្ខុ ទ្រង់បានសម្ដែងធម៌ ធ្វើនូវសេចក្ដីឧបមាដោយពិណ ។ ខ្ញុំបានស្ដាប់ព្រះពុទ្ធដីកានៃព្រះមានព្រះភាគនោះ ក៏ត្រេកអរក្នុងព្រះពុទ្ធសាសនា បានញុំាងសមថៈឲ្យសម្រេច ដើម្បីបាននូវប្រយោជន៍ដ៏ឧត្តម វិជ្ជាទាំង ៣ ខ្ញុំបានដល់ហើយ ដោយលំដាប់ ព្រះពុទ្ធសាសនា ខ្ញុំបានធ្វើហើយ ។ ព្រោះឃើញនូវសេចក្ដីស្ងាត់របស់ចិត្ត ដែលបង្អោនទៅក្នុងការចេញចាកកាមផង នូវការមិនវង្វេងព្រម របស់ចិត្ត ដែលបង្អោនទៅ ក្នុងការមិនព្យាបាទ ទាំងបង្អោនទៅ ក្នុងការអស់ទៅនៃ

តណ្ហា ព្រោះការអស់ទៅនៃឧបាទានផង នូវការកើតឡើងនៃអាយតនៈផង ចិត្តក៏រួចស្រឡះដោយប្រពៃ ។ កាលភិក្ខុនោះ មានចិត្តរួចដោយប្រពៃ មានចិត្តស្ងប់រម្ងាប់ហើយ ការសន្សំកុសល ឬអកុសលដែលធ្វើរួចហើយ មិនមានទេ កិច្ចដែលត្រូវធ្វើ ក៏មិនមាន ។ ភ្នំថ្មតាន់មួយដុំ មិនរំកើបដោយខ្យល់ យ៉ាងណា រូប រស សំឡេង ក្លិន សម្ផស្ស ទាំងអស់នេះ ទាំងពួកធម្មារម្មណ៍ ដែលគួរប្រាថ្នា និងមិនគួរប្រាថ្នា ក៏ញុំាងចិត្តភិក្ខុ ជាតាទិបុគ្គល ឲ្យញាប់ញ័រមិនបាន យ៉ាងនោះដែរ ចិត្តដែលតាំងនៅនឹង ទាំងប្រាសចាកសំយោជនៈ រមែងឃើញច្បាស់នូវការសូន្យទៅនៃអារម្មណ៍នោះ ។

### សោណកោឡិវិសត្ថេរ

## ឧទ្ទាន

ព្រះសោណកោឡិវិសត្ថេរ តែម្នាក់ឯង ជាអ្នកមានឫទ្ធិច្រើន ពោលនូវគាថា ១៣ ដែលមកក្នុងតេរសកនិបាតនេះ ។

**តេរសកនិបាត ចប់**

# អដ្ឋកថា
# ថេរគាថា តេរសកនិបាត

## សោណកោឡិវិសត្ថេរគាថា

[ ២៨៤ ] ក្នុងតេរសកនិបាត គាថារបស់ព្រះសោណកោឡិវិសត្ថេរ មានពាក្យផ្ដើមថា **យាហុ រដ្ឋេ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងសាសនានៃព្រះមានព្រះភាគ ព្រះនាមអនោមទស្សី កុលបុត្តនេះ ជាសេដ្ឋីមានសម្បត្តិច្រើន ទៅកាន់វិហារជាមួយឧបាសកទាំងឡាយ ស្ដាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្ដា មានចិត្តជ្រះថ្លា ធ្វើបរិកម្មដោយបាយ-អ ក្នុងទីចង្ក្រមរបស់ព្រះសាស្ដា ក្រាលដោយផ្កា មានពណ៌ផ្សេងៗ ឲ្យចងពិតានដោយសំពត់ ជ្រលក់ដោយពណ៌ផ្សេងៗ អំពីខាងលើ ម្យ៉ាងទៀត បានសាងសាលាវែងថ្វាយដល់ព្រះសាស្ដា និងភិក្ខុសង្ឃ ។

ដោយបុញ្ញកម្មនោះ កុលបុត្តនោះអន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងកាលនៃព្រះមានព្រះភាគ ព្រះនាមបទុមុត្តរៈ កើតក្នុងត្រកូលសេដ្ឋី ក្នុងហង្សវតីនគរ មានឈ្មោះថា **សិរិវឌ្ឍ** ។ កុលបុត្តនោះ ចម្រើនវ័យហើយ ទៅកាន់វិហារ កំពុងស្ដាប់ធម៌ក្នុងសម្នាក់ព្រះសាស្ដា ឃើញព្រះសាស្ដា

ទ្រង់ស្ថាបនាភិក្ខុមួយរូប ក្នុងតំណែងឯតទគ្គៈ នៃភិក្ខុដែលប្រារព្ធព្យាយាម សូម្បីខ្លួនឯងក៏ប្រាថ្នាតំណែងនោះ ទើបបំពេញមហាទានឲ្យប្រព្រឹត្តទៅអស់ ៧ ថ្ងៃ ហើយតាំងសេចក្តីប្រាថ្នា ។ ព្រះសាស្តាទ្រង់ឃើញថា សេចក្តីប្រាថ្នារបស់កុលបុត្តនោះសម្រេច ទើបទ្រង់ព្យាករហើយយាងទៅ ។

កុលបុត្តនោះ បំពេញកុសលដរាបដល់អស់ជីវិត អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ កាលព្រះទសពលព្រះនាមកស្សបៈ បរិនិព្វានហើយ កាលព្រះមានព្រះភាគនៃយើង មិនទាន់កើតឡើង កើតក្នុងផ្ទះមានត្រកូល ក្នុងក្រុងពារាណសី ដល់នូវភាពជាអ្នកដឹងក្តីហើយ សាងបណ្ណសាលាក្បែរច្នេរស្ទឹងគង្គា ឧបដ្ឋាកព្រះបច្ចេកពុទ្ធមួយអង្គដោយគោរព ដោយបច្ច័យ ៤ អស់កាល ៣ ខែ ។

ព្រះបច្ចេកពុទ្ធចេញវស្សាហើយ មានបរិក្ខារគ្រប់គ្រាន់ ទៅកាន់ភ្នំគន្ធមាទន៍ ។ កុលបុត្តនោះ បំពេញបុណ្យក្នុងទីនោះ ដរាបដល់អស់ជីវិត ចុតិអំពីអត្តភាពនោះហើយ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងសាសនាព្រះមានព្រះភាគនៃយើងទាំងឡាយ បដិសន្ធិក្នុងផ្ទះនៃឧសភសេដ្ឋីក្នុងចម្ប៉ានគរ ចាប់តាំងពីកាលដែលកុលបុត្តនោះបដិសន្ធិ គំនរនៃភោគៈជាច្រើន ចម្រើនឡើងដល់សេដ្ឋី ។ ក្នុងថ្ងៃដែលកុលបុត្តនេះកើត កុលបុត្តនេះជាអ្នកដល់ព្រមទៅដោយមហាសក្ការៈ ក្នុងនគរទាំងមូល ព្រោះលោកបរិច្ចាគសំពត់កម្ពលក្រហមមានតម្លៃមួយសែនដល់ព្រះបច្ចេកពុទ្ធក្នុងកាលមុន ទើបមានអត្តភាពពណ៌ដូចមាស និងសុខុមក្រៃលែង ដោយហេតុនោះ ទើបជន

ទាំងឡាយឲ្យឈ្មោះថា **សោណៈ** ។ កុលបុត្តនោះមានបរិវារច្រើន បាតដៃបាតជើងនៃកុលបុត្តនេះមានពណ៌ដូចផ្កាចប្បា មានសម្ផស្សទន់ដូចសំឡីដែលជ្រួចហើយ ១០០ ដង មានរោមពណ៌ក្រហម ដូចកុណ្ឌល កើតឡើងត្រង់ផ្ទៃបាតជើងទាំងពីរ កាលកុលបុត្តនោះចម្រើនវ័យហើយ ពួកញាតិបានសាងប្រាសាទ ៣ ដែលសមគួរដល់រដូវ ឲ្យបម្រើដោយអ្នករបាំ ។ កុលបុត្តនោះសោយមហាសម្បត្តិក្នុងទីនោះ ដូចទេវកុមារ ។

កាលព្រះសាស្តានៃយើងទាំងឡាយ សម្រេចសព្វញ្ញុតញ្ញាណហើយ ទ្រង់ប្រកាសធម្មចក្រដ៏បវរ ចូលទៅអាស្រ័យក្រុងរាជគ្រឹះ ត្រូវព្រះបាទពិម្ពិសារត្រាស់ឲ្យចូលគាល់ ទើបមកកាន់នគររាជគ្រឹះ មួយអន្លើដោយអ្នកស្រុក ៨ ម៉ឺននាក់ ទៅកាន់សម្នាក់ព្រះសាស្តា ស្តាប់ធម៌ហើយ បានទូវសទ្ធា ឲ្យមាតាបិតាអនុញ្ញាតហើយ បានបព្វជ្ជាឧបសម្បទាក្នុងសាសនា រៀនទូវកម្មដ្ឋានក្នុងសម្នាក់ព្រះសាស្តា ស្នាក់នៅក្នុងសីតវៃន ចៀសចេញពីការច្រឡូកច្រឡំដោយពួកគណៈ គិតថា រាងកាយរបស់អញសុខុមពេក អញមិនអាចសម្រេចសេចក្តីសុខបានដោយងាយឡើយ អញគួរធ្វើរាងកាយឲ្យលំបាក បំពេញសមណធម៌ ទើបអធិដ្ឋានក្នុងការចង្ក្រមប៉ុណ្ណោះ ប្រកបព្យាយាម សូម្បីបាតជើងពុះពង មិនគិតដល់ទុក្ខវេទនា ធ្វើទូវសេចក្តីព្យាយាម តែមិនអាចធ្វើគុណវិសេស ឲ្យកើតឡើងបាន ព្រោះប្រារព្ធសេចក្តីព្យាយាមខ្លាំងពេក ទើបគិតថា អញសូម្បីព្យាយាមយ៉ាងនេះ ក៏មិនអាចឲ្យមគ្គ ឬផលកើតឡើងបានឡើយ ប្រយោជន៍អ្វីដោយការបួសរបស់អញ អញនឹងសឹកបរិភោគភោគៈ

ហើយបំពេញបុណ្យ ។

ព្រះសាស្តា ទ្រង់ជ្រាបវារចិត្តរបស់ព្រះថេរៈ ទើបយាងទៅក្នុងទីនោះ ទ្រង់ទូន្មានដោយឱវាទដែលប្រៀបដោយពិណ កាលទ្រង់សម្តែងវិធីប្រកបសេចក្តីព្យាយាមឲ្យស្មើ ទើបឲ្យជម្រះកម្មដ្ឋាន ហើយទ្រង់យាងទៅកាន់ភ្នំគិជ្ឈកូដ ។ ឯព្រះសោណត្ថេរ បានទទួលឱវាទក្នុងទីចំពោះព្រះភក្ត្រព្រះសាស្តា ហើយ ប្រកបព្យាយាមឲ្យស្មើ បំពេញវិបស្សនា បានតាំងនៅក្នុងអរហត្តសមដូចគាថាព័ន្ធដែលលោកពោលក្នុងអបទានថា

ខ្ញុំឲ្យគេធ្វើទីចង្ក្រម ធ្វើនូវការលាបដោយកំបោរ ថ្វាយព្រះមុនី ព្រះនាមអនោមទស្សី ទ្រង់ជាច្បងក្នុងលោក ទ្រង់មិនញាប់ញ័រដោយលោកធម៌ ។ ខ្ញុំក្រាលទីចង្ក្រមដោយផ្កាមានពណ៌ផ្សេងៗ ធ្វើនូវពិតានព្ធដ៏អាកាស និមន្តព្រះពុទ្ធដ៏ប្រសើរ ឲ្យឆាន់កត្ត ។ គ្រានោះ ខ្ញុំផ្គងអញ្ជលី ថ្វាយបង្គំព្រះសម្ពុទ្ធ ទ្រង់មានវត្តដ៏ល្អ ហើយថ្វាយទីឃសាលាចំពោះព្រះមានព្រះភាគ ។ ព្រះសាស្តា ទ្រង់ប្រសើរផុតក្នុងលោក ទ្រង់ជ្រាបនូវបំណងរបស់ខ្ញុំ ព្រះមានព្រះភាគមានចក្ខុ ទ្រង់បានទទួល ( សាលានោះ ) ដោយអនុគ្រោះ ។ ព្រះសម្ពុទ្ធ ជាទក្ខិណេយ្យបុគ្គល ក្នុងលោក ព្រមទាំងទេវលោក លុះទទួលរួចហើយ ទ្រង់គង់ក្នុងភិក្ខុសង្ឃហើយ សម្តែងនូវគាថាទាំងឡាយនេះថា

កុលបុត្តណា មានចិត្តរីករាយ បានថ្វាយទីយសាលា ចំពោះតថាគត តថាគតនឹងសម្តែងសរសើរ នូវកុលបុត្តនោះ អ្នកទាំងឡាយ ចូរស្តាប់តថាគត សម្តែងចុះ ។ កុលបុត្ត ដែលបរិបូណ៌ដោយបុញ្ញកម្មនេះ នឹងមានរថទឹមដោយសេះ មួយពាន់ កើតឡើងប្រាកដ ក្នុងមរណកាល ។ បុរសនេះ នឹងទៅកាន់ទេវលោក ដោយយាននោះ ពួកទេវតារីករាយ ក្នុងភពជាកុសលដែលសម្រេចដល់បុរសនោះ ។ ទេវបុត្ត នោះ នឹងនៅគ្រប់គ្រងវិមាន ដ៏ប្រសើរ ដែលមានថ្លៃច្រើន លាបលនដោយដីកែវ ជាវិមានប្រកបដោយកំពូលដ៏ ប្រសើរ ។ ទេវបុត្តនោះ នឹងរីករាយក្នុងទេវលោក អស់ ៣០០០០ កប្ប នឹងបានជាទេវរាជ អស់ ២៥ កប្បទៀត ។ នឹងបានជាស្តេចចក្រពត្តិ អស់ ៧៧ ដង ស្តេចចក្រពត្តិ ទាំងអស់នោះ មាននាមតែមួយ គឺនាមថាយសោធរៈ ។ លុះកុលបុត្តនោះ សោយសម្បត្តិទាំងពីររួចហើយ សន្សំ នូវបុណ្យ នឹងបានជាស្តេចចក្រពត្តិ ក្នុងកប្បទី ២៨ ។ ស្តេចចក្រពត្តិនោះ នឹងនៅគ្រប់គ្រងប្រាសាទដ៏ប្រសើរ ដែលវិស្សុកម្មនិម្មិតថ្វាយ ក្នុងទីនោះ ជាបុរី មិនស្ងាត់ចាក សំឡេង ១០ ប្រការ ។ ក្នុងកប្បច្រើន ប្រមាណមិនបាន អំពីកប្បនេះ កុលបុត្តនោះ នឹងបានជាស្តេចក្នុងដែន គ្រប់

គ្រងផែនដី មានឫទ្ធិធំ មាននាមថាឱក្កាកៈ ។ អភិជាតខត្តិយានី ( របស់ស្តេចនោះ ) ដ៏ប្រសើរលើសជាងស្រីស្នំ ១៦ ពាន់ទាំងអស់ ព្រះនាងនឹងប្រសូតនូវព្រះរាជបុត្រ ៩ ព្រះអង្គ ។

នាងខត្តិយានី លុះប្រសូតបុត្រ ៩ ព្រះអង្គហើយ ក៏នឹងធ្វើកាលកិរិយាទៅ នឹងមាននាងកញ្ញា ( ដទៃទៀត ) ជាស្ត្រីក្មេង ជាទីគាប់ព្រះហឫទ័យ នឹងបានមកជាមហេសី ។ នាងកញ្ញា ធ្វើក្សត្រឱក្កាកៈ ឲ្យត្រេកអរហើយ នឹងបាននូវពរ លុះនាងកញ្ញានោះ បានទទួលពរហើយ ក៏ញុំាងព្រះរាជាឲ្យបំបរបង់ព្រះរាជបុត្រដើមទាំងឡាយចោល ។ ព្រះរាជបុត្តទាំងអស់នោះ លុះព្រះបិតាបំបរបង់ហើយ ក៏នាំគ្នាទៅកាន់ភ្នំហិមពាន្ត ព្រះរាជបុត្រទាំងអស់ ខ្លាចបែកធ្លាយជាតិ ក៏នៅរួមសង្វាសនឹងប្អូនស្រីទាំងឡាយរបស់ខ្លួន ។ ឯនាងកញ្ញាម្នាក់ នឹងកើតព្យាធិ៍ពេញខ្លួន ក្សត្រទាំងឡាយនឹងដឹក ( រណ្តាំឲ្យនៅ ដោយបំណងថា ) ជាតិរបស់យើងកុំធ្លាយឡើយ ។ មានក្សត្រ ( រង្សដទៃ ) មួយអង្គ នាំនាងកញ្ញានោះ យកទៅនៅរួមសង្វាសជាមួយ ក្នុងការកើតត្រកូលក្សត្រឱក្កាកៈ នឹងបែកធ្លាយក្នុងកាលនោះ ។ ព្រះរាជឱរសទាំងឡាយ របស់ក្សត្រទាំងពីរអង្គនោះ នឹង

បានឈ្មោះថា កោលិយៈ ( ក្សត្រទាំងពីរអង្គនោះ ) នឹងសោយភោគៈ ជារបស់មនុស្ស ប្រមាណមិនបាន ក្នុងទីនោះ ។ លុះកុលបុត្តនោះ ច្យុតចាកកាយនោះ នឹងទៅកើតក្នុងទេវលោក នឹងបានទូវប្រាសាទដ៏ប្រសើរ ដែលជាទីគាប់ចិត្តក្នុងទេវលោកនោះ ។ លុះច្យុតចាកទេវលោកត្រូវកុសលមូលដាស់តឿន ទើបមកកាន់អត្តភាពជាមនុស្សមាននាមថាសោណៈ ។ សោណមាណព ប្រារព្ធព្យាយាម មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន តាំងនៅក្នុងសាសនារបស់ព្រះសាស្ដា កំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។ ព្រះអនន្តទស្សី មានព្រះភាគ ព្រះនាមគោតម ជាសក្យៈប្រសើរ ទ្រង់ជ្រាបវិសេស មានព្យាយាមធំ នឹងតាំង ( សោណៈនោះ ) ក្នុងឋានៈដ៏ប្រសើរ ។

កាលភ្លៀងធ្លាក់ លិចស្មៅអស់ ៤ ធ្នាប់ នៅសល់មួយធ្នាប់ ត្រូវខ្យល់បក់ទៀត ( នៅតែប្រឹងដុះ )
វៀរលែងតែតាទិបុគ្គល អ្នកមានព្យាយាម មិនមានអ្វីប្រឹងលើស ជាងស្មៅនោះទៀតទេ ។

ខ្ញុំមានខ្លួនទូន្មានហើយ ក្នុងការទូន្មានដ៏ឧត្តម ចិត្តរបស់ខ្ញុំតម្កល់ស៊ប់ហើយ ភារៈទាំងអស់ ខ្ញុំដាក់ចុះហើយ ខ្ញុំជា

អ្នកមិនមានអាសវៈ មានទុក្ខរលត់ហើយ ។ ព្រះមហានាគ ជាអង្គីរស មានជាតិដ៏ប្រសើរ ដូចជាកេសររាជសីហ៍ គង់ក្នុងភិក្ខុសង្ឃ ហើយតាំងខ្ញុំក្នុងទីជាឯតទគ្គៈ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ(១) ដូច្នេះ ។

១- ក្នុងអបទានជា សោណកោដិយវេស្សត្ថេរ ។

កាលសម្រេចអរហត្តហើយ ពិចារណាកិច្ចបដិបត្តិរបស់ខ្លួន ទើបពោលគាថាទាំងនេះ ដោយអំណាចឧទាន និងដោយអំណាចការព្យាករណ៍អរហត្តផលថា

ព្រះសោណៈណា ជាអ្នកប្រសើរ ល្បីក្នុងដែនអង្គៈ ព្រះសោណៈនោះ ជាអ្នកប្រសើរ ក្នុងធម៌ទាំងឡាយ បានដល់នូវត្រើយនៃទុក្ខក្នុងថ្ងៃនេះ ។ ភិក្ខុកាត់នូវសំយោជនៈ ( ខាងក្រោម ) ៥ ផង លះបង់នូវសំយោជនៈ ( ខាងលើ ) ៥ ផង ចម្រើននូវឥន្ទ្រិយ ៥ តទៅទៀតផង ជាអ្នកកន្លងនូវធម៌ជាគ្រឿងជាប់ចំពាក់ ៥ យ៉ាងផង ទើបហៅថា អ្នកឆ្លងនូវអន្លង់បាន ។ សីល សមាធិ និងបញ្ញា នៃភិក្ខុអ្នកមានមានះដូចបបុស ជាអ្នកប្រមាទ មានសេចក្តីប្រាថ្នាខាងក្រៅ រមែងមិនដល់នូវការពេញលេញឡើយ ។ ព្រោះថា អំពើណាដែលត្រូវធ្វើ អំពើនោះ ពួកភិក្ខុណាបោះបង់

បោល ត្រឡប់ធ្វើអំពើដែល មិនត្រូវធ្វើវិញ អាសវៈទាំងឡាយ នៃពួកភិក្ខុទាំងនោះ ដែលជាអ្នកមានមានះដូចបបុស ជាអ្នកប្រមាទ រមែងចម្រើនឡើង ។ លុះតែកាយគតាសតិ ភិក្ខុទាំងឡាយណា ប្រារព្ធល្អជានិច្ច ភិក្ខុទាំងឡាយនោះ ជាអ្នកមានកិរិយាធ្វើរឿយៗ ក្នុងអំពើដែលត្រូវធ្វើ មិនសេពនូវអំពើដែលមិនត្រូវធ្វើ អាសវៈ ទាំងឡាយ នៃភិក្ខុទាំងឡាយមាន ស្មារតីជាអ្នកដឹងខ្លួន រមែងដល់ នូវសេចក្ដីវិនាសទៅ ។ ផ្លូវត្រង់ ព្រះសាស្ដាបានប្រាប់ហើយ អ្នក ទាំងឡាយចូរដើរទៅចុះ កុំត្រឡប់វិញឡើយ កុលបុត្រគប្បីដាស់ តឿនខ្លួន ដោយខ្លួនឯង គប្បី ( នាំខ្លួន ) ទៅកាន់ព្រះនិព្វាន ។ កាលខ្ញុំប្រារព្ធសេចក្ដីព្យាយាមយ៉ាងតឹងរ៉ឹង ព្រះសាស្ដា ជាបុគ្គល ប្រសើរក្នុងលោក ព្រះអង្គមានចក្ខុ ទ្រង់បានសម្ដែងធម៌ ធ្វើនូវ សេចក្ដីឧបមាដោយពិណ ។ ខ្ញុំបានស្ដាប់ព្រះពុទ្ធដីកា នៃព្រះមាន ព្រះភាគនោះ ក៏ត្រេកអរក្នុងព្រះពុទ្ធសាសនា បានញុំាងសមថៈ ឲ្យសម្រេច ដើម្បីបាននូវប្រយោជន៍ដ៏ឧត្តម វិជ្ជាទាំង ៣ ខ្ញុំបាន ដល់ហើយ ដោយលំដាប់ ព្រះពុទ្ធសាសនា ខ្ញុំបានធ្វើហើយ ។ ព្រោះឃើញនូវសេចក្ដីស្ងាត់របស់ចិត្ត ដែលបង្អោនទៅក្នុងការ ចេញចាកកាមផង នូវការមិនវង្វេងព្រមរបស់ចិត្ត ដែលបង្អោន ទៅក្នុងការមិនព្យាបាទ ទាំងបង្អោនទៅក្នុងការអស់ទៅនៃតណ្ហា ព្រោះការអស់ទៅនៃឧបាទានផង នូវការកើតឡើងនៃអាយតនៈផង

ចិត្តក៏រួចស្រឡះដោយប្រពៃ ។ កាលភិក្ខុនោះ មានចិត្តរួចដោយប្រពៃ មានចិត្តស្ងប់រម្ងាប់ហើយ ការសន្សំកុសល ឬអកុសលដែលធ្វើរួចហើយ មិនមានទេ កិច្ចដែលត្រូវធ្វើ ក៏មិនមាន ។ ភ្នំថ្មតាន់មួយដុំ មិនរំកើបដោយខ្យល់ យ៉ាងណា រូប រស សំឡេង ក្លិន សម្ផស្ស ទាំងអស់នេះ ទាំងពួកធម្មារម្មណ៍ ដែលគួរប្រាថ្នានិងមិនគួរប្រាថ្នា ក៏ញ៉ាំងចិត្តភិក្ខុជាតាទិបុគ្គល ឲ្យញាប់ញ័រមិនបានយ៉ាងនោះដែរ ចិត្តដែលតាំងនៅនឹង ទាំងប្រាសចាកសំយោជនៈរមែងឃើញច្បាស់ នូវការសូន្យទៅនៃអារម្មណ៍នោះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យាហុ រដ្ឋេ សមុក្កដ្ឋោ** សេចក្ដីថា បុគ្គលណា ជាបុគ្គលឧត្ដម គឺប្រសើរដោយប្រពៃ គឺក្រៃលែងដោយភោគសម្បត្តិនិងដោយឥស្សរិយសម្បត្តិ មួយអន្លើដោយអ្នកស្រុក ៨ ម៉ឺននាក់ ក្នុងអង្គរដ្ឋ ។

បទថា **រញ្ញោ អង្គស្ស បទ្ធគូ** ប្រកបសេចក្ដីថា ជាបរិវារនៃព្រះបាទពិម្ពិសារ ដែលជាអធិបតីនៃដែនអង្គរដ្ឋ ដែលឈ្មោះថា ជាព្រះរាជា ព្រោះអត្ថថា ធ្វើឲ្យបរិស័ទត្រេកអរដោយសង្គហវត្ថុ ៤ ជាគហបតីដ៏សំខាន់ ជាកុដុម្ពិកៈក្នុងរដ្ឋរបស់ព្រះបាទពិម្ពិសារនោះ ។ បទថា **ស្វាជ្ជ ធម្មេសុ ឧក្កដ្ឋោ** សេចក្ដីថា ព្រះសោណៈនោះ ជាបុគ្គលឧត្ដម ក្នុងលោកុត្តរធម៌ ក្នុងថ្ងៃនេះគឺក្នុងឥឡូវនេះ ក្នុងកាលជាគ្រហស្ថ លោកក៏ជាបុគ្គលឧត្ដមជាងជនទាំងពួងឥឡូវនេះ សូម្បីក្នុងពេលជាបព្វជិត លោកក៏ជាបុគ្គលឧត្ដមដូចគ្នា ព្រោះដូច្នោះ ទើបលោកសម្ដែងខ្លួនឲ្យដូចអ្នកដទៃ ។

*បទថា* **ទុក្ខស្ស ចារគូ** *សេចក្តីថា លោកដល់ត្រើយ គឺដល់នូវទីបំផុតនៃទុក្ខក្នុងវដ្តៈទាំងមូល ដោយពាក្យនោះ ព្រះថេរៈបន្ថែមនូវគុណដ៏ខ្ពង់ខ្ពស់ ដែលលោកពោលដោយមិនផ្សេងគ្នាថា* **ធម្មេសុ ឧក្កដ្ឋោ** *ព្រោះសម្តែងដល់ការសម្រេចអរហត្ត ។*

*ឥឡូវនេះ ព្រះថេរៈជាអ្នកដល់នូវត្រើយនៃទុក្ខដោយបដិបទាណា កាលនឹងសម្តែងបដិបទានោះ ដោយអាងដល់អរហត្តផល ទើបពោលពាក្យជាដើមថា* **បញ្ច ឆិន្ទេ** *ប្រែថា ភិក្ខុកាត់នូវសំយោជនៈខាងក្រោម ៥ ផង ដូច្នេះ ។*

*គាថានោះ មានអធិប្បាយថា បុរសគប្បីកាត់នូវសំយោជនៈ ដែលជាចំណែកខាងក្រោម ៥ ដែលឲ្យដល់អបាយ និងកាមសុគតិ ដោយមគ្គ ៣ ខាងក្រោម ដូចកាត់នូវខ្សែដែលចងត្រង់ជើងដោយសស្ត្រា ដូច្នោះ បុរសគប្បីលះ គឺគប្បីកាត់សំយោជនៈដែលជាចំណែកខាងលើ ៥ ដែលឲ្យចូលដល់រូបភព និងអរូបភព ដោយអរហត្តមគ្គ ដូចកាត់នូវខ្សែដែលចងត្រង់ក ដូច្នោះ លុះលះសំយោជនៈដែលជាចំណែកខាងលើទាំងនោះបានហើយ គប្បីចម្រើន គឺគប្បីធ្វើឥន្ទ្រិយ ៥ មានសទ្ធិន្ទ្រិយជាដើមឲ្យចម្រើនក្រៃលែងឡើង ភិក្ខុបែបនេះ ឈ្មោះថា ជាអ្នកឈានកន្លងនូវធម៌ជាគ្រឿងចង ៥ ព្រោះឈានកន្លងនូវធម៌ជាគ្រឿងជាប់ជំពាក់ ៥ គឺរាគៈ ទោសៈ មោហៈ មានៈ និងទិដ្ឋិ ទើបលោកហៅថា ជាអ្នកឆ្លងនូវឱឃៈបានហើយ ព្រោះឆ្លងនូវឱឃៈ ៤ គឺកាមោឃៈ ភវោឃៈ ទិដ្ឋោឃៈ និងអវិជ្ជោឃៈ ។*

*កាលសម្តែងថា បដិបទានេះ ឈ្មោះថា ជាការបរិបូណ៌នៃសីលដែល*

ជាបដិបទាជាគ្រឿងធ្វងឱ្យៈជាដើមនោះឯង ឯសីលជាដើម រមែងដល់នូវសេចក្តីបរិបូណ៌ ព្រោះលះនូវមានះជាដើម មិនមែនដោយប្រការដទៃ ទើបលោកពោលគាថាថា **ឧន្នឡស្ស** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **ឧន្នឡស្ស** បានដល់ មានមានះ គឺភាពទទេ លើកឡើង ។

ពិតហើយ មានះ លោកហៅថា **នឡ** ព្រោះដូចដើមបបុស ដោយភាពជារបស់ទទេ ព្រោះសម្តែងអាការនៃចិត្តដែលប៉ោងឡើង ។

បទថា **បមត្តស្ស** បានដល់ ដល់នូវសេចក្តីប្រមាទ ព្រោះបណ្តោយនូវសតិ ។

បទថា **ពាហិរាសស្ស** សេចក្តីថា ដែលមានការសង្ឃឹមក្នុងអាយតនៈខាងក្រៅ អធិប្បាយថា ដែលមិនប្រាសចាករាគៈក្នុងកាមទាំងឡាយ ។

បទថា **សីលំ សមាធិ បញ្ញា ច បារិបូរឹ ន គច្ឆតិ** សេចក្តីថា សម្រាប់ភិក្ខុនោះ ដែលសេពនូវធម៌ដែលជាសត្រូវចំពោះសីលជាដើម លំដាប់ដំបូង គុណ មានសីលជាដើម ដែលជាលោកិយ រមែងដល់នូវការបរិបូរនឹងពោលថ្វីដល់លោកុត្តរធម៌នោះ ។

ក្នុងសេចក្តីនេះ លោកពោលហេតុដោយពាក្យថា **យញ្ហិ កិច្ចំ** ដូច្នេះជាដើម ។ ពិតហើយ កិច្ចដូចជាការគ្រប់គ្រងសីលក្ខន្ធ ដែលមិនមានប្រមាណចាប់តាំងអំពីកាលដែលភិក្ខុបួសហើយ ការនៅព្រៃ ការរក្សាធុតង្គ ការត្រេកអរក្នុងភាវនាជាដើម ឈ្មោះថា កិច្ចដែលគួរធ្វើ ។ កិច្ចតាមដែលពោលមកហើយ

នេះ ដែលភិក្ខុបដិសេធហើយ គឺលះបង់ហើយដោយមិនធ្វើ ។

ឈ្មោះថា **អកិច្ចំ** សេចក្តីថា ការតាក់តែងបរិក្ខារ ដូចជាការតាក់តែងបាត្រ តាក់តែងចីវរ តាក់តែងវត្តពន្ធបង្កេះ សំពត់អង្សៈ ឆត្រ ស្បែកជើងផ្ចិតស្លឹកត្នោត និងធម្មក្រកជាដើម ។ ឯការងារ ដូចជាការខ្នះខ្នែង ស្វែងរកបច្ច័យ ឈ្មោះថា កិច្ចដែលមិនគួររបស់ភិក្ខុ ភិក្ខុពួកណាធ្វើកិច្ចនោះ អាសវៈទាំង ៤ រមែងចម្រើនដល់ភិក្ខុទាំងនោះ បុគ្គលឈ្មោះថា **ឧន្នឡានំ** ព្រោះលើកនូវមានះដែលដូចដើមបបុសរឿយៗទៅ ឈ្មោះថា **បមត្តានំ** ព្រោះបណ្តោយនូវស្មារតី ។

ឯគុណ មានបញ្ញាជាដើម ចម្រើនដល់ភិក្ខុពួកណា ដើម្បីសម្តែងភិក្ខុទាំងនោះ ទើបលោកពោលថា **យេសំ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **សុសមារទ្ធា** សេចក្តីថា ផ្គងនូវសេចក្តីព្យាយាមល្អហើយ ។

បទថា **កាយគតាសតិ** បានដល់ កាយានុបស្សនាភាវនា ។ បទថា **អកិច្ចំ តេ** បានដល់ ភិក្ខុទាំងនោះ មិនធ្វើកិច្ចដែលមិនគួរធ្វើ មានការរចនាបាត្រជាដើម ។

បទថា **ន សេវន្តិ** ប្រែថា មិនធ្វើ ។ បទថា **កិច្ចេ** បានដល់ កិច្ចមានការគ្រប់គ្រងគំនរនៃសីលដែលមិនមានប្រមាណ ដែលភិក្ខុគប្បីធ្វើ ចាប់តាំងពីកាលដែលខ្លួនបួសហើយ ។

បទថា **សាតច្ចការិនោ** អធិប្បាយថា អាសវៈទាំង ៤ រមែងដល់នូវ

ការតាំងនៅមិនបាន គឺដល់នូវការអស់ទៅ ដល់នូវការមិនមានដល់សត្វទាំងនោះ ដែលមានការធ្វើជាប់តគ្នា បុគ្គលឈ្មោះថា **សតានំ** ព្រោះមិនទៅប្រាសចាកសតិ បុគ្គលឈ្មោះថា **សម្បជានានំ** ( ព្រោះទៅ ) ដោយសម្បជញ្ញៈ ៤ គឺសាត្ថកសម្បជញ្ញៈ ១ សប្បាយសម្បជញ្ញៈ ១ គោចរ-សម្បជញ្ញៈ ១ អសម្មោហសម្បជញ្ញៈ ១ ។

ឥឡូវនេះ កាលនឹងឲ្យឱវាទដល់ភិក្ខុដែលនៅក្នុងសម្នាក់របស់ខ្លួន ទើបព្រះថេរៈពោលថា **ឧជុមគ្គម្ហិ** ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **ឧជុមគ្គម្ហិ អក្ខាតេ** សេចក្ដីថា កាលព្រះសាស្ដាត្រាស់អរិយមគ្គដែលជាមជ្ឈិមប្បដិបទា ដែលឈ្មោះថា **ឧជុ** ព្រោះវៀរទីបំផុត ( អន្តធម៌ ) ពីរចំណែក និងព្រោះលះនូវការវៀចផ្លូវកាយជាដើម ។

បទថា **គច្ឆថ** ប្រែថា ចូរដើរទៅ ។ បទថា **មា និវត្តថ** បានដល់ ចូរកុំឈប់ក្នុងចន្លោះ ។

បទថា **អត្តនា ចោទយត្តានំ** សេចក្ដីថា កុលបុត្តអ្នកប្រាថ្នាប្រយោជន៍ក្នុងសាសនានេះ កាលដាស់តឿនខ្លួនដោយខ្លួនឯង ដូចជាពិចារណាភ័យក្នុងអបាយជាដើម ។

បទថា **និព្វានមភិហារយេ** សេចក្ដីថា គប្បីនាំខ្លួនទៅកាន់ព្រះនិព្វាន គឺគប្បីចូលទៅជិតព្រះនិព្វាន អធិប្បាយថា គប្បីបដិបត្តិដោយប្រការដែលធ្វើព្រះនិព្វាននោះឲ្យជាក់ច្បាស់ ។

ឥឡូវនេះ ដើម្បីនឹងសម្ដែងកិច្ចបដិបត្តិរបស់ខ្លួនថា ខ្ញុំបដិបត្តិយ៉ាងនេះ

ឯង ទើបលោកពោលថា **អច្ចារទ្ធម្ហិ** ដូច្នេះជាដើម ។

បទថា **អច្ចារទ្ធម្ហិ វីរិយម្ហិ** សេចក្តីថា កាលខ្ញុំចម្រើនវិបស្សនា មិនធ្វើសេចក្តីព្យាយាមជាមួយសមាធិឲ្យស្មើគ្នា ផ្គងសេចក្តីព្យាយាមខ្លាំងពេក ភាពដែលលោកប្រារព្ធព្យាយាមខ្លាំងពេក បានពោលហើយ ។

បទថា **វីណោបមំ ករិត្វា មេ** សេចក្តីថា កាលព្រះសោណៈកើតគំនិតឡើងថា សាវ័ករបស់ព្រះមានព្រះភាគអង្គណាមួយ ប្រារព្ធសេចក្តីព្យាយាម ខ្ញុំជាបុគ្គលម្នាក់ ក្នុងសាវ័កទាំងនោះ បើចិត្តរបស់ខ្ញុំរួចផុតចាកអាសវៈទាំងឡាយ ដោយការមិនប្រកាន់មាំមិនបាន ខ្ញុំនឹងសឹក ។ ព្រះសាស្តា ទ្រង់បានសម្តែងព្រះកាយក្នុងទីចំពោះមុខរបស់ព្រះសោណៈនោះដោយឫទ្ធិ ត្រាស់សួរថា ម្នាលសោណៈ ព្រោះហេតុអ្វី ទើបអ្នកកើតគំនិតថា នឹងសឹក កាលមុនអ្នកជាអ្នកគ្រប់គ្រងផ្ទះ ជាអ្នកឈ្លាសក្នុងសំឡេងនៃខ្សែពិណ មិនមែនឬ កាលលោកទូលថា ករុណាព្រះអង្គ ទើបទ្រង់សម្តែងធម៌ដល់ខ្ញុំ ដោយឱវាទឧបមាដោយខ្សែពិណ ដែលប្រព្រឹត្តទៅ ដោយការធ្វើពិណឲ្យជាឧបមា ( ក្នុងវិនយបិដក មហាវគ្គ ) យ៉ាងនេះថា នែសោណៈ អ្នកឯងសម្គាល់ហេតុនោះដូចម្តេច កាលណាខ្សែពិណរបស់អ្នកតឹងពេកទៅ តើពិណរបស់អ្នកឯងមានសំឡេងពីរោះឬ គួរដល់ការងារក្នុងកាលនោះដែរឬ ។ ព្រះសោណៈក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ការនុ៎ះមិនដូច្នោះទេ ។ ព្រះមានព្រះភាគទ្រង់សួរថា នែសោណៈ អ្នកឯងសម្គាល់ហេតុនោះដូចម្តេច កាលណាបើខ្សែពិណរបស់អ្នកធូរពេក តើពិណរបស់អ្នកឯងមានសំឡេងពីរោះឬ គួរដល់

ការងារក្នុងកាលនោះដែរឬ ។ ព្រះសោណៈក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ការនោះមិនដូច្នោះទេ ។ ព្រះមានព្រះភាគទ្រង់សួរថា នែសោណៈ អ្នកសម្គាល់ហេតុនោះដូចម្ដេច កាលណាបើខ្សែពិណរបស់អ្នក មិនតឹងពេក មិនធូរពេក តាំងនៅក្នុងគុណដ៏ល្មម តើពិណរបស់អ្នកឯង មានសំឡេងពីរោះឬ គួរដល់ការងារក្នុងកាលនោះដែរឬ ។ ព្រះសោណៈនោះក្រាបទូលថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា នែសោណៈ សេចក្ដីព្យាយាមដែលតឹងពេក នាំឲ្យកើតសេចក្ដីរាយមាយ សេចក្ដីព្យាយាមដែលធូរពេក នាំឲ្យកើតសេចក្ដីខ្ជិលច្រអូស ដូចខ្សែពិណយ៉ាងនោះឯង ព្រោះហេតុនោះ នែសោណៈ ក្នុងវេលានេះ ចូរអ្នកតាំងសេចក្ដីព្យាយាមឲ្យស្មើក្នុងធម្មវិន័យនេះ ត្រូវប្រើឥន្ទ្រិយទាំងឡាយឲ្យស្មើគ្នាផង ត្រូវកាន់យកនូវនិមិត្តក្នុងសមថៈនោះផង ដូច្នេះ ។

បទថា **តស្សាហំ វចនំ សុត្វា** សេចក្ដីថា ខ្ញុំបានស្ដាប់វីណោបមសូត្រដែលជាព្រះតម្រាស់របស់ព្រះមានព្រះភាគនោះហើយ ទើបលះនូវការគិតចង់សឹក ដែលកើតឡើងក្នុងចន្លោះនោះចេញ ត្រេកអរហើយ គឺត្រេកអរក្រៃលែងហើយ ក្នុងសាសនារបស់ព្រះសាស្ដា ។

កាលខ្ញុំញុំាងសមថៈឲ្យសម្រេច គឺប្រកបសេចក្ដីព្យាយាមឲ្យល្មមប្រមាណ គឺឲ្យសមាធិ និងវីរិយៈធ្វើកិច្ចស្មើគ្នា ឲ្យសទ្ធា និងបញ្ញាធ្វើកិច្ចស្មើគ្នា ញុំាងសមាធិដើម្បីវិបស្សនា មានឈានជាបាទឲ្យដល់ព្រមហើយ បំពេញវិបស្សនា ។ ព្រះថេរៈពោលដល់ប្រយោជន៍ក្នុងសេចក្ដីនោះថា **ឧត្តមត្ថស្ស**

**បត្តិយា** ដូច្នេះ ។

បទថា **ឧត្តមត្ថស្ស បត្តិយា** សេចក្តីថា ដើម្បីសម្រេចអរហត្ត ។

ឥឡូវនេះ កាលសម្តែងប្រការដែលសមថៈ និងវិបស្សនាសម្រេចដល់អ្នកបដិបត្តិ ដោយអាងដល់អរហត្តផល ទើបពោលពាក្យថា **នេក្ខម្មេ** ដូច្នេះជាដើម ។

បណ្តាបទទាំងនេះ បទថា **នេក្ខម្មេ** បានដល់ ក្នុងការលោសចេញចាកកាម មានការចេញបួសជាដើម ។

បទថា **អធិមុត្តស្ស** សេចក្តីថា ដែលប្រកបខ្វល់ខ្វាយ ដោយបង្អោនទៅ ឱនទៅ ទោរទន់ទៅក្នុងនេក្ខម្មៈនោះ អធិប្បាយថា ជាអ្នកបែរចំពោះបព្វជ្ជា ហើយលះកាមទាំងឡាយ កាលបួសហើយ ប្រកបការខ្វល់ខ្វាយក្នុងធម៌ដែលមិនមានទោស ដូចជាការជម្រះសីលឲ្យបរិសុទ្ធ ការនៅព្រៃ ការរក្សាធុតង្គ និងការប្រកបក្នុងភាវនាជាដើម ។

បទថា **បវិវេកញ្ច ចេតសោ** សេចក្តីថា មានសតិបង្អោនទៅកាន់ទីស្ងាត់ និងបង្អោនទៅក្នុងនេក្ខម្មៈយ៉ាងនេះ គឺប្រកបខ្វល់ខ្វាយក្នុងវិវេក ដោយញ៉ាំងឈានពួក ៤ និងឈានពួក ៥ ឲ្យកើតឡើង ។

បទថា **អព្យាពជ្ឈាធិមុត្តស្ស** សេចក្តីថា បង្អោនចិត្តទៅក្នុងការមិនបៀតបៀន ព្រោះប្រាសចាកទុក្ខ គឺញ៉ាំងឈានសមាបត្តិឲ្យកើតហើយខ្វល់ខ្វាយក្នុងសេចក្តីសុខ ដែលកើតអំពីសមថៈ ។

បទថា **ឧបាទានក្ខយស្ស ច** សេចក្តីថា បង្អោនទៅក្នុងការអស់ទៅ

នៃឧបាទានក្ខន្ធ ៤ គឺក្នុងអរហត្ត ពិតណាស់ បទថា **ឧបាទានក្ខយស្ស** នេះ ជាឆដ្ឋីវិភត្តិ ប្រើក្នុងអត្ថសត្តមីវិភត្តិ អធិប្បាយថា ធ្វើឈានតាមដែលខ្លួនសម្រេចហើយនោះឲ្យជាបាទ ហើយខ្វល់ខ្វាយក្នុងវិបស្សនា ដើម្បីសម្រេចអរហត្ត ។

បទថា **តណ្ហាក្ខយាធិមុត្តស្ស** សេចក្តីថា ឈ្មោះថា **តណ្ហាក្ខយ** ព្រោះជាទីអស់ទៅនៃតណ្ហា បានដល់ ព្រះនិព្វាន បង្អោនទៅក្នុងព្រះនិព្វាននោះ គឺបង្អោនទៅ ឱនទៅ ឈមទៅក្នុងនិរោធ ដោយឃើញឧបាទានដោយភាពជាភ័យ និងឃើញការមិនមានឧបាទានថា ជាដែនក្សេម ។

បទថា **អសម្មោហញ្ច ចេតសោ** សេចក្តីថា បង្អោនចិត្តទៅកាន់ត្រើយនៃសេចក្តីមិនវង្វេង ដោយអំណាចអសម្មោហសម្បជញ្ញៈ ឬបង្អោនចិត្តទៅកាន់អរិយមគ្គដែលជាការមិនវង្វេង ដោយការដកសេចក្តីវង្វេងបានជាសមុច្ឆេទ ។

បទថា **ទិស្វា អាយតនុប្បាទំ** សេចក្តីថា ព្រោះឃើញ គឺព្រោះហេតុដែលបានឃើញការកើតឡើងនៃអាយតនៈទាំងឡាយ មានចក្ខុជាដើមគ្រប់ៗ ខណៈ ដោយបច្ច័យរបស់ខ្លួន និងឃើញការរលត់ ដោយជាសត្រូវចំពោះការកើតនោះ ដោយមគ្គប្បញ្ញា ដែលប្រកបដោយវិបស្សនាបញ្ញា ។

បទថា **សម្មា ចិត្តំ វិមុច្ចតិ** សេចក្តីថា ចិត្តរមែងរួចផុតចាកអាសវៈទាំងពួងដោយប្រពៃ គឺដោយហេតុ ដោយញាណ គឺដោយលំដាប់នៃមគ្គ ។

ក្នុងពាក្យថា **តស្ស សម្មា វិមុត្តស្ស** ជាដើម មានសេចក្តីសង្ខេបដូច

តទៅនេះថា

កាលចិត្តនោះរួចផុតហើយ ចាកកិលេសទាំងឡាយ ដោយន័យដែលពោលហើយ គឺដោយប្រពៃពិត ព្រោះហេតុនោះឯង ទើបភិក្ខុខីណាស្រពមានចិត្តស្ងប់ ព្រោះស្ងប់ដោយចំណែកមួយ មិនមានការសន្សំកុសល ឬអកុសល ព្រោះដកឡើងដោយមគ្គនោះហើយ កិច្ចដែលគួរធ្វើដោយបរិញ្ញាកិច្ចជាដើម មិនមាន ព្រោះធ្វើកិច្ចស្រេចហើយ ។ ភ្នំដែលសម្រេចដោយថ្មតាន់ រមែងមិនរង្គើ មិនញាប់ញ័រ ដោយខ្យល់តាមប្រក្រតី យ៉ាងណា ធម៌គឺអារម្មណ៍ មានរូបដែលគួរប្រាថ្នាជាដើម និងមិនគួរប្រាថ្នា រមែងមិនញាប់ញ័រ មិនធ្វើចិត្តឲ្យកម្រើក មិនទោរទន់ ជាចិត្តប្រាសចាកកិលេសគ្រឿងប្រកប ព្រោះភាពជាអ្នកលះសេចក្ដីសោកទាំងអស់បាន របស់បុគ្គលមានសភាពបែបនោះ គឺតាទិបុគ្គល បានដល់ បុគ្គលនឹងធឹងក៏យ៉ាងនោះ លោករមែងចូលផលសមាបត្តិ ពិចារណានូវធម៌ គឺអារម្មណ៍នោះម្ដងម្កាល រមែងពិចារណាឃើញនូវការវិនាស គឺការរលត់ បានដល់ ការបែកធ្លាយទៅគ្រប់ខណៈ ព្រះថេរៈព្យាករអរហត្តផល ដោយសេចក្ដីដូចពោលមកនេះ ។៙

**អដ្ឋកថា សោណកោឡិវិសត្ថេរគាថា ចប់**

**ថេរគាថា តេរសកនិបាត ចប់**

# សុត្តន្តបិដក
# ថេរគាថា ចុទ្ទសកនិបាត

## រេវតត្ថេរគាថា

[ ២៨៥ ] ខ្ញុំចេញចាកផ្ទះចូលកាន់ផ្នួស ក្នុងកាលណា កាលណោះ ខ្ញុំមិនដែលនឹកនូវសេចក្តីត្រិះរិះមិនប្រសើរ ដែលប្រកបដោយទោសទេ ។ ក្នុងចន្លោះកាលដ៏វែងនេះ ខ្ញុំមិនដែលនឹកនូវសេចក្តីត្រិះរិះថា ពួកសត្វទាំងនេះចូរលំបាកចុះ ចូរស្លាប់ចុះ ចូរដល់នូវសេចក្តីទុក្ខចុះ ដូច្នេះទេ ។ ប៉ុន្តែខ្ញុំធ្លាប់នឹកនូវមេត្តា រកប្រមាណមិនបាន ដែលបានចម្រើនល្អហើយ បានសន្សំហើយ តាមលំដាប់ ដូចព្រះពុទ្ធទ្រង់សម្តែងហើយ ។ ខ្ញុំមានសត្វទាំងពួងជាមិត្រ មានសត្វទាំងពួងជាសម្លាញ់ ជាអ្នកអនុគ្រោះដល់សត្វទាំងពួង បានចម្រើននូវមេត្តាចិត្ត ត្រេកអរក្នុងការមិនបៀតបៀនសព្វកាល ។ ខ្ញុំត្រេកអរចំពោះចិត្ត ដែលមិនងឹកងាក មិនកម្រើក ខ្ញុំចម្រើនព្រហ្មវិហារធម៌ ដែលព្រះអរិយៈជាបុរសមិនថោកទាបគប់រកហើយ ។ សាវ័ករបស់ព្រះសម្មាសម្ពុទ្ធ ដល់នូវឈានមិនមានវិតក្ក រមែងជាអ្នកប្រកបដោយតុណ្ហីភាពដ៏ប្រសើរ ក្នុងខណៈនោះ ។ ភ្នំថ្មមិនកម្រើក តាំងនៅស៊ប់ យ៉ាងណាមិញ ភិក្ខុរមែងមិនញាប់ញ័រដូចជាភ្នំ ព្រោះអស់ទៅនៃមោហៈ ក៏យ៉ាងនោះដែរ ។ សប្បុរសមិនមានទីទួល គឺកិលេស

អ្នកស្វែងរកនូវសេចក្ដីស្អាតជានិច្ច ទុកជាមានបាបបន្តិចបន្តួច ប៉ុន ចុងរោមកន្ទុយសត្វ ក៏ប្រាកដដូចជាប៉ុនមេឃ ។ នគរជាទីបំផុតនៃ ដែន ដែលគេគ្រប់គ្រងហើយ ទាំងខាងក្នុង ខាងក្រៅ យ៉ាងណា មិញ អ្នកទាំងឡាយ ចូរគ្រប់គ្រងខ្លួនយ៉ាងនោះ ខណៈកុំកន្លងនូវ អ្នកទាំងឡាយឡើយ ។ ខ្ញុំមិនត្រេកអរនឹងសេចក្ដីស្លាប់ ខ្ញុំមិន ត្រេកអរនឹងការរស់នៅទេ ខ្ញុំរង់ចាំតែកាល ( បរិនិព្វាន ) ប៉ុណ្ណោះ ដូចអ្នកស៊ីឈ្នួល ទន្ទឹងតែអស់ថ្ងៃ ។ ខ្ញុំមិនត្រេកអរនឹងសេចក្ដី ស្លាប់ ខ្ញុំមិនត្រេកអរនឹងការរស់នៅ ខ្ញុំជាអ្នកដឹងខ្លួន មានស្មារតី តាំងមាំ រង់ចាំតែកាល ( បរិនិព្វាន ) ប៉ុណ្ណោះ ។ ព្រះសាស្ដាខ្ញុំបាន បម្រើហើយ ព្រះពុទ្ធសាសនា ខ្ញុំបានធ្វើហើយ ភារៈធ្ងន់ ខ្ញុំបាន ដាក់ចុះហើយ តណ្ហាគ្រឿងនាំសត្វទៅកាន់ភព ខ្ញុំបានដកចោល ហើយ ។ ខ្ញុំចេញចាកផ្ទះ ចូលកាន់ផ្នួស ដើម្បីប្រយោជន៍ណា ប្រយោជន៍ គឺការអស់ទៅនៃសំយោជនៈទាំងពួងនោះ ខ្ញុំបានដល់ ហើយ ។ អ្នកទាំងឡាយ ចូរឲ្យដល់ព្រម ដោយសេចក្ដីមិនប្រមាទ ចុះ នេះជាពាក្យប្រៀនប្រដៅរបស់ខ្ញុំ ណ្ហើយចុះ ខ្ញុំនឹងបរិនិព្វាន ខ្ញុំ ជាអ្នកមានចិត្តរួចស្រឡះហើយចាកកិលេសទាំងពួង ។

រេវតត្ថេរ

# អដ្ឋកថា
# ថេរគាថា ចុទ្ទសកនិបាត

## ១ខិរវនិយ រេវតត្ថេរគាថា

[ ២៤៥ ] ក្នុងចុទ្ទសកនិបាត គាថារបស់ព្រះរេវតត្ថេរ មានពាក្យផ្ដើមថា **យទា អហំ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្ដេច ។

គាថារបស់ព្រះថេរៈអង្គនេះ មានមកហើយក្នុងឯកនិបាតខាងដើមក៏ពិតតែក្នុងឯកនិបាត លោកសម្ដែងត្រឹមតែជាស់តឿនស្មារតីដល់ក្មួយៗ របស់លោកព្រោះដូច្នោះ ទើបគាថានោះ លោកសង្គ្រោះក្នុងឯកនិបាត តែគាថាទាំងនេះលោកប្រកាសដល់បដិបទា ចាប់តាំងពីព្រះថេរៈបួសហើយ រហូតដល់បរិនិព្វាន ទើបលើកមកក្នុងចុទ្ទសកនិបាតនេះ ។

ក្នុងសេចក្ដីនោះ អត្ថុប្បត្តិហេតុបានពោលក្នុងឯកនិបាតនោះហើយ ។ តែការប្លែកគ្នាមានដូចតទៅ បានឮថា ព្រះថេរៈសម្រេចអរហត្តហើយ ទៅកាន់ទីឧបដ្ឋាកព្រះសាស្ដា និងរបស់ព្រះមហាថេរៈមានព្រះធម្មសេនាបតីជាដើម មួងម្កាល នៅក្នុងទីនោះ ពីរបីថ្ងៃ ហើយត្រឡប់មក នៅក្នុងព្រៃគគីរនោះឯង សម្រាំនៅដោយសេចក្ដីសុខ ដែលកើតអំពីផលសមាបត្តិ និងដោយព្រហ្មវិហារធម៌ ។

កាលវេលាកន្លងទៅដោយអាការយ៉ាងនេះ ព្រះថេរៈក៏ចាស់ទៅតាមលំដាប់ ថ្ងៃមួយ ទៅកាន់ទីបម្រើព្រះពុទ្ធក្នុងរវាងផ្លូវ បានសម្រាកក្នុងព្រៃមិនឆ្ងាយអំពីក្រុងសាវត្ថី ។ ដោយសម័យនោះ ពួកចោរធ្វើនូវការប្លន់ក្នុងនគរ ត្រូវមនុស្សអ្នករក្សានគរដេញតាម នាំគ្នាគេចទៅ បោះបង្វិចទ្រព្យដែលលួចមកក្បែរព្រះថេរៈ ។ ពួកមនុស្សដេញតាម ឃើញភណ្ឌៈក្នុងទីជិតព្រះថេរៈ ទើបចងព្រះថេរៈហើយនាំទៅ ដោយគិតថាជាចោរ ទើបបង្ហាញដល់ព្រះរាជាថា បពិត្រព្រះអង្គ បុរសនេះជាចោរ ។ ព្រះរាជាត្រាស់ឲ្យលែងព្រះថេរៈ ហើយត្រាស់សួរថា បពិត្រលោកម្ចាស់ លោកម្ចាស់ធ្វើចោរកម្មឬ ទោះបីមិនបានធ្វើកម្មនោះ តាំងអំពីកើតមក ដើម្បីសម្ដែងថា លោកមិនបានធ្វើកម្មនោះ តាំងអំពីបួសមក ព្រោះមិនគួរធ្វើកម្មបែបនោះ ព្រោះដកនូវកិលេសបានជាសមុច្ឆេទហើយ ព្រះថេរៈកាលសម្ដែងធម៌ដល់ភិក្ខុ ដែលនៅក្នុងទីជិតនឹងដល់ព្រះរាជា ទើបពោលគាថាទាំងឡាយថា

ខ្ញុំចេញចាកផ្ទះចូលកាន់ផ្នួស ក្នុងកាលណា កាលណោះ ខ្ញុំមិនដែលនឹកនូវសេចក្ដីត្រិះរិះមិនប្រសើរ ដែលប្រកបដោយទោសទេ ។ ក្នុងចន្លោះកាលដ៏វែងនេះ ខ្ញុំមិនដែលនឹកនូវសេចក្ដីត្រិះរិះថា ពួកសត្វទាំងនេះ ចូរលំបាកចុះ ចូរស្លាប់ចុះ ចូរដល់នូវសេចក្ដីទុក្ខចុះ ដូច្នេះទេ ។ ប៉ុន្តែ ខ្ញុំធ្លាប់នឹកនូវមេត្តា រកប្រមាណមិនបាន ដែលបានចម្រើនល្អហើយ បានសន្សំហើយ តាមលំដាប់ ដូចព្រះពុទ្ធទ្រង់សម្ដែងហើយ ។ ខ្ញុំមានសត្វទាំងពួងជាមិត្រ មានសត្វទាំងពួង

ជាសម្លាញ់ ជាអ្នកអនុគ្រោះដល់សត្វទាំងពួង បានចម្រើននូវមេត្តាចិត្ត ត្រេកអរក្នុងការមិនបៀតបៀន សព្វកាល ។ ខ្ញុំត្រេកអរចំពោះចិត្ត ដែលមិនងឹកងាក មិនកម្រើក ខ្ញុំចម្រើនព្រហ្មវិហារធម៌ ដែលព្រះអរិយៈជាបុរសមិនថោកទាបគប់រកហើយ ។ សាវ័ករបស់ព្រះសម្មាសម្ពុទ្ធ ដល់នូវឈានមិនមានវិតក្ក រមែងជាអ្នកប្រកបដោយតុណ្ហីភាពដ៏ប្រសើរ ក្នុងខណៈនោះ ។ ភ្នំថ្មមិនកម្រើក តាំងនៅស៊ប់ យ៉ាងណាមិញ ភិក្ខុរមែងមិនញាប់ញ័រដូចជាភ្នំ ព្រោះអស់ទៅនៃមោហៈ ក៏យ៉ាងនោះដែរ ។ សប្បុរសមិនមានទីទួល គឺកិលេស អ្នកស្វែងរកនូវសេចក្តីស្អាតជានិច្ច ទុកជាមានបាបបន្តិចបន្តួច ប៉ុនចុងរោមកន្ទុយសត្វ ក៏ប្រាកដដូចជាប៉ុនមេឃ ។ នគរជាទីបំផុតនៃដែន ដែលគេគ្រប់គ្រងហើយ ទាំងខាងក្នុង ខាងក្រៅ យ៉ាងណាមិញ អ្នកទាំងឡាយ ចូរគ្រប់គ្រងខ្លួនយ៉ាងនោះ ខណៈកុំកន្លងនូវអ្នកទាំងឡាយឡើយ ។ ខ្ញុំមិនត្រេកអរនឹងសេចក្តីស្លាប់ ខ្ញុំមិនត្រេកអរនឹងការរស់នៅទេ ខ្ញុំរង់ចាំតែកាល ( បរិនិព្វាន ) ប៉ុណ្ណោះ ដូចអ្នកស៊ីឈ្នួល ទន្ទឹងតែអស់ថ្ងៃ ។ ខ្ញុំមិនត្រេកអរនឹងសេចក្តីស្លាប់ ខ្ញុំមិនត្រេកអរនឹងការរស់នៅ ខ្ញុំជាអ្នកដឹងខ្លួន មានស្មារតីតាំងមាំ រង់ចាំតែកាល ( បរិនិព្វាន ) ប៉ុណ្ណោះ ។ ព្រះសាស្តា ខ្ញុំបានបម្រើហើយ ព្រះពុទ្ធសាសនា ខ្ញុំបានធ្វើហើយ ភារៈធ្ងន់ ខ្ញុំបានដាក់ចុះហើយ តណ្ហាគ្រឿងនាំសត្វទៅកាន់ភព ខ្ញុំបានដកចោល

ហើយ ។ ខ្ញុំចេញចាកផ្ទះ ចូលកាន់ផ្នួស ដើម្បីប្រយោជន៍ណា ប្រយោជន៍ គឺការអស់ទៅនៃសំយោជនៈទាំងពួងនោះ ខ្ញុំបានដល់ហើយ ។ អ្នកទាំងឡាយ ចូរឲ្យដល់ព្រមដោយសេចក្តីមិនប្រមាទចុះ នេះជាពាក្យប្រៀនប្រដៅរបស់ខ្ញុំ ណ្ហើយចុះ ខ្ញុំនឹងបរិនិព្វាន ខ្ញុំជាអ្នកមានចិត្តរួចស្រឡះហើយចាកកិលេសទាំងពួង ដូច្នេះ ។

ក្នុងគាថានោះ មានពណ៌នាតាមលំដាប់បទដូចតទៅនេះ បទថា **នាភិជានាមិ ឥមស្មិំ ទីឃមន្តរេ** ប្រកបសេចក្តីថា តាំងអំពីពេលដែលខ្ញុំបួសមក រហូតដល់ពេលចុងក្រោយនេះ ក្នុងរយៈកាលដ៏វែងឆ្ងាយបែបនេះ ខ្ញុំមិនធ្លាប់ត្រិះរិះដល់វត្ថុដែលមានទោស ដែលមិនប្រសើរ ដោយអំណាចការសម្លឹងថា សូមវត្ថុនេះជារបស់អញ ឬដោយអំណាចព្យាបាទថា សូមសត្វទាំងនេះត្រូវសម្លាប់ជាដើម ។

បទថា **មេត្តញ្ច អភិជានាមិ** សេចក្តីថា ឈ្មោះថា **មេត្តា** ព្រោះជាហេតុឲ្យជាប់ជំពាក់ គឺឲ្យមានសេចក្តីស្នេហា បានដល់ ការមិនព្យាបាទ ។ ឈ្មោះថា **មេត្តា** បានដល់ មេត្តាភាវនា និងព្រហ្មវិហារធម៌ ។ នូវមេត្តានោះ លោកសង្គ្រោះព្រហ្មវិហារក្រៅអំពីនេះ គឺ **ករុណា មុទិតា** និង **ឧបេក្ខា** ដោយ ច សព្ទ ។

បទថា **អភិជានាមិ** សេចក្តីថា ខ្ញុំដឹងដោយចំពោះមុខ ។ ព្រោះឈានដែលសម្រេចហើយ រមែងបែរមុខចំពោះបច្ចវេក្ខណញ្ញាណសម្រាប់អ្នកពិចារណា ។ កាលឆ្លើយនូវពាក្យសួរថា បែបណា ទើបពោលថា **អប្បមាណំ**

ជាដើម ។ ឈានទោះឈ្មោះថា **អប្បមាណា** ព្រោះមាន សត្វប្រមាណមិនបានជាអារម្មណ៍ ដោយអំណាចការផ្សាយទៅមិនចំពោះ តាមដែលព្រះមានព្រះភាគទ្រង់សម្តែងហើយ ។

ប្រកបសេចក្តីថា ខ្ញុំដឹងចំពោះឈាននេះ ដែលឈ្មោះថា **សុភាវិតំ** ព្រោះចម្រើនដោយល្អ ដោយការឲ្យដល់នូវភាពជាញាណ មានកម្លាំងស្ទាត់ជំនាញ ដែលឈ្មោះថា **បរិចិតំ** គឺស្និទ្ធស្នាលធ្វើឲ្យច្រើនហើយ ដោយលំដាប់ គឺតាមលំដាប់យ៉ាងនេះ គឺលំដាប់ដំបូង បានដល់ មេត្តា បន្ទាប់អំពីនោះករុណា បន្ទាប់អំពីនោះមុទិតា ចុងក្រោយជាឧបេក្ខា ។ ឈ្មោះថា **សព្វមិត្តោ** ព្រោះជាមិត្តរបស់សត្វទាំងពួង ឬមនុស្សទាំងពួងជាមិត្ររបស់យើង ព្រោះបុគ្គលចម្រើនមេត្តា រមែងជាទីស្រឡាញ់របស់សត្វទាំងឡាយ ។

ក្នុងបទថា **សព្វសខោ** នេះ ក៏មានន័យដូចគ្នា ។ បទថា **សព្វភូតានុកម្បកោ** បានដល់ ដែលអនុគ្រោះសត្វទាំងពួង ។ បទថា **មេត្តាចិត្តញ្ច ភាវេមិ** សេចក្តីថា ខ្ញុំញុំាងចិត្តដែលប្រកប គឺដែលសម្បយុត្តដោយមេត្តាឲ្យកើត គឺឲ្យចម្រើនដោយពិសេស ឬប្រាប់ឲ្យដឹងដោយមិនបាច់និយាយ ព្រោះចិត្តដល់នូវភាពឧត្តមក្នុងភាវនាហើយ ។ម្យ៉ាងទៀត បាឋៈថា **មេត្តំ ចិត្តញ្ច ភាវេមិ** ដូច្នេះក៏មាន អត្ថនៃពាក្យនោះ មានន័យដូចពោលហើយខាងដើមនោះឯង ។ បទថា **អព្យាបជ្ឈរតោ** សេចក្តីថា ត្រេកអរក្រៃលែងក្នុងការមិនបៀតបៀន គឺក្នុងការនាំប្រយោជន៍ចូលទៅឲ្យដល់សត្វទាំងឡាយ ។

បទថា **សទា** បានដល់ សព្វៗ កាល ដោយពាក្យនោះ លោក

សម្តែងដល់ការធ្វើប្រព្រឹត្តទៅជាប់តក្នុងការចម្រើនមេត្តានោះ ។

បទថា **អសំហិរំ** បានដល់ មិនងឹកងាក គឺមិនត្រូវរាគៈដែលជាសត្រូវជិតអូសទាញមក ។

បទថា **អសំកុប្បំ** បានដល់ មិនកម្រើក គឺមិនកម្រើកដោយព្យាបាទដែលជាសត្រូវឆ្ងាយ កាលធ្វើយ៉ាងនេះ ខ្ញុំរមែងត្រេកអរ គឺត្រេកអរក្រៃលែងនូវមេត្តាចិត្តរបស់ខ្ញុំ បានដល់ ចម្រើនព្រហ្មវិហារ ។

បទថា **អកាបុរិសសេវិតំ** សេចក្តីថា ខ្ញុំធ្វើឲ្យកើត គឺចម្រើននូវវិហារធម៌មានមេត្តាជាដើមដ៏ប្រសើរក្រៃលែង មិនមានទោស ដែលបុរសថោកទាប គឺបុគ្គលថោកថយមិនសេព ឬបុគ្គលមិនថោកថយ គឺព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាដើមសេពហើយ ។

កាលសម្តែងបដិបទារបស់ខ្លួន ៥ គាថា ដោយលើកខ្លួនឡើងសម្តែងយ៉ាងនេះ ឥឡូវនេះ កាលសម្តែងបដិបទានោះដោយអាងដល់អរហត្តផលទើបពោល ៤ គាថា ដោយន័យជាដើមថា **អវិតក្កំ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **អវិតក្កំ សមាបន្នោ** សេចក្តីថា ចូលដល់ហើយនូវឈាន មានទុតិយជ្ឈានជាដើម ដែលមិនមានវិតក្ក ដោយពាក្យនោះព្រះថេរៈពោលដល់ការដែលខ្លួនលោកជាអ្នកសម្រេចឈាន មានទុតិយជ្ឈានជាដើម ដោយអាងដល់អរហត្តផល ដោយព្រហ្មវិហារភាវនា ព្រោះព្រះថេរៈធ្វើឈាននោះឲ្យជាបាទហើយ ចម្រើនវិបស្សនា កាន់យកព្រះអរហត្ត ដោយអាសនៈមួយនោះឯង ដូច្នោះ កាលសម្តែងសេចក្តីនោះ ដោយអាងដល់

អរហត្តផល ទើបពោលថា **អវិតក្កំ សមាបន្នោ** ដូច្នេះហើយ ពោលថា សាវករបស់ព្រះសម្មាសម្ពុទ្ធ ដល់នូវឈាន មិនមានវិតក្ក រមែងជាអ្នកប្រកបដោយតុណ្ហីភាពដ៏ប្រសើរ ក្នុងខណៈនោះ ដូច្នេះ ។

ក្នុងសេចក្តីនោះ សមាបត្តិដែលមិនមានវិតក្ក មិនមានវិចារៈ ព្រោះមិនមានវចីសង្ខារ ព្រះពុទ្ធទាំងឡាយត្រាស់ថា ជាការនៅស្ងៀមបែបព្រះអរិយៈ សមាបត្តិឯណានីមួយ ឈ្មោះថា ជាការស្ងៀមបែបព្រះអរិយៈ ព្រោះព្រះបាលី ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយប្រជុំគ្នាហើយ ត្រូវធ្វើកិច្ច ២ យ៉ាង គឺពាក្យប្រកបដោយធម៌ ១ ភាពជាអ្នកស្ងប់ស្ងៀមដ៏ប្រសើរ ១ ដូច្នេះ ។ តែក្នុងទីនេះ លោកបំណងយកសមាបត្តិដែលសម្បយុត្តដោយអរហត្តផល ដែលប្រកបដោយឈានទី ៤ ។

ឥឡូវនេះ កាលប្រកាសភាពដែលខ្លួនមិនញាប់ញ័រ ដោយលោកធម៌ ដោយឧបមា ព្រោះភាពដែលខ្លួនសម្រេចអរហត្តផលនោះហើយ ទើបពោលគាថាថា **យថាបិ បព្វតោ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **យថាបិ បព្វតោ សេលោ** សេចក្តីថា ភ្នំដែលសម្រេចហើយអំពីថ្មសុទ្ធ ជាថ្មក្រាស់ យ៉ាងណា អធិប្បាយថា មិនមែនភ្នំដី មិនមែនភ្នំក្រួសរវាន ។

បទថា **អចលោ សុប្បតិដ្ឋិតោ** សេចក្តីថា ជាភ្នំដែលមានឫសតាំងនៅហើយដោយល្អ មិនកម្រើកដោយខ្យល់តាមប្រក្រតី ព្រោះដូច្នោះ ព្រះអរហន្តទីផងនិព្វាន ឈ្មោះថា ជាគ្រឿងលះមោហៈបានជាសមុច្ឆេទ ក្នុងបទថា

យ៉ាងណាមិញ ភិក្ខុរមែងមិនញាប់ញ័រដូចជាភ្នំ ព្រោះអស់ទៅនៃមោហៈ ក៏យ៉ាងនោះដែរ ។ ភិក្ខុលះអកុសលទាំងពួងបានហើយ ព្រោះអកុសលទាំងពួងមានមោហៈជាមូល រមែងមិនញាប់ញ័រ មិនកម្រើកដោយលោកធម៌ទាំងឡាយដូចភ្នំនោះ រមែងមិនកម្រើកដោយខ្យល់តាមប្រក្រតី ដូច្នោះ ម្យ៉ាងទៀតអធិប្បាយថា ព្រោះអរហត្ត និងព្រះនិព្វាន មានឈ្មោះហៅថា **មោហក្ខយ** ដូច្នោះ ពាក្យថា **មោហក្ខយា** បានដល់ ព្រោះអស់មោហៈ ភិក្ខុតាំងនៅដោយល្អ ក្នុងអរិយសច្ច ៤ ទោះក្នុងវេលាមិនចូលសមាបត្តិ ក៏មិនញាប់ញ័រដូចភ្នំ ព្រោះលោកសម្រេចនិព្វាន និងអរហត្តហើយ មិនចាំបាច់ពោលដល់ក្នុងវេលាចូលសមាបត្តិឡើយ ។

ឥឡូវនេះ កាលនឹងសម្តែងថា ឈ្មោះថា បាបនេះ អ្នកមានប្រក្រតីមិនស្អាតប៉ុណ្ណោះ រមែងប្រព្រឹត្ត ឯអ្នកមានប្រក្រតីស្អាត មិនប្រព្រឹត្តឡើយ ព្រោះបាបមានប្រមាណបន្តិចបន្តួចនោះ សម្រាប់បុគ្គលអ្នកមានប្រក្រតីស្អាតក៏ប្រាកដជារបស់ធ្ងន់ ទើបព្រះថេរៈពោលថា **អនង្គណស្ស** ដូច្នេះជាដើម ។

ពាក្យនៃគាថានោះ មានអធិប្បាយដូច្នេះថា សេចក្តីអាក្រក់មានប្រមាណប៉ុនចុងរោមទ្រាយ ប្រមាណប៉ុនចុងសក់ សូម្បីត្រឹមតែស្រមោលនៃអំពើអាក្រក់ ក៏ប្រាកដមានទំហំប៉ុនមេឃ ផ្សាយទៅពេញសកលលោកធាតុដល់សប្បុរស ដែលឈ្មោះថាមិនមានទីទួល គឺកិលេស ព្រោះមិនមានកិលេសជាគ្រឿងក្តៅក្រហាយ មានរាគៈជាដើម ដែលស្វែងរកធម៌ដ៏ស្អាត ជាធម៌មិនមានទោសសព្វកាលទាំងពួង ព្រោះដូច្នោះ ទើបមានអធិប្បាយថា កុំសង្ស័ម

ថា បុគ្គលដូចខ្ញុំធ្វើនូវកម្មបែបនេះ ។

កាលឲ្យឱវាទថា ព្រោះក្នុងបុគ្គលមិនមានកិលេស បុគ្គលអន្ធពាល គង់ដាក់ចិត្តបែបនោះបាន ដូច្នោះ បុគ្គលប្រាថ្នាប្រយោជន៍ គប្បីរក្សាខ្លួនឲ្យល្អ ទើបព្រះថេរៈពោលថា **នគរំ យថា** ដូច្នេះជាដើម ។

គាថានោះមានអធិប្បាយថា ដូចបច្ចន្តនគរ ដែលមនុស្សអ្នកបច្ចន្តនគរ ធ្វើនូវទ្វារកំពែងឲ្យមាំទាំជាដើម ឈ្មោះថា ធ្វើឲ្យមាំទាំខាងក្នុង ធ្វើប៉ម និងគូទឹកឲ្យមាំទាំជាដើម ឈ្មោះថា ធ្វើឲ្យមាំទាំខាងក្រៅ ព្រោះដូច្នោះ ទើបឈ្មោះថា ធ្វើនូវការគ្រប់គ្រងទាំងខាងក្នុង និងខាងក្រៅ យ៉ាងណា ពួកអ្នកទាំងឡាយក៏ដូច្នោះ ចូរកុំបណ្តោយសតិ ដែលអ្នកចូលទៅតាំងទុក បិទនូវទ្វារទាំង ៦ ដែលប្រព្រឹត្តទៅខាងក្នុងហើយ រក្សានូវទ្វារ ហើយធ្វើទ្វារទាំងនោះឲ្យមាំទាំ ដោយការមិនប្រកាន់ ដោយប្រការដែលអាយតនៈខាងក្រៅ ៦ ដែលបុគ្គលប្រកាន់ និងចូលទៅទម្លាយអាយតនៈខាងក្នុងបាន មិនលះបង់សតិដែលរក្សាទ្វារ ដោយមិនឲ្យអាយតនៈខាងក្រៅទាំងនោះចូលដល់ ត្រាច់ទៅ ឈ្មោះថា គ្រប់គ្រងខ្លួន ។ ព្រោះហេតុអ្វី ព្រោះខណៈកុំកន្លងនូវអ្នកទាំងឡាយឡើយ ។

ពិតហើយ ខណៈទាំងអស់នេះ គឺខណៈជាទីកើតឡើងនៃព្រះពុទ្ធ ខណៈដែលបានអត្តភាពជាមនុស្ស ខណៈកើតក្នុងមជ្ឈិមប្រទេស ខណៈបាននូវសម្មាទិដ្ឋិ ខណៈមិនខ្វះខាតនូវអាយតនៈ ៦ រមែងកន្លងបុគ្គលដែលមិនគ្រប់គ្រងខ្លួន ដោយអាការយ៉ាងនេះ ។ ខណៈនោះ កុំកន្លងអ្នកទាំងឡាយទៅឡើយ ។

ព្រះថេរៈកាលទូន្មានបរិស័ទ មួយអន្លើដោយរាជបរិវារដោយគាថានេះដោយអាការយ៉ាងនេះហើយ កាលប្រកាសភាពដែលខ្លួនមានចិត្តស្មើក្នុងមរណៈ និងជីវិត និងកិច្ចដែលខ្លួនធ្វើស្រេចហើយទៀត ទើបពោលពាក្យថា **ណាភិ-ណន្ទាមិ មរណំ** ដូច្នេះជាដើម ។ ពាក្យនោះ មានអត្ថដូចពោលហើយ ខាងដើមនោះឯង ។

កាលពោលយ៉ាងនេះហើយ ឃើញកាលបរិនិព្វាននៃខ្លួនប្រាកដ ទើបឲ្យឱវាទដល់ពួកជនទាំងនោះដោយសង្ខេបនោះឯង កាលប្រកាសព្រះនិព្វាន ក៏ពោលគាថាចុងក្រោយ ។

បណ្ដាបទទាំងនោះ បទថា **សម្បាទេថប្បមាទេន** សេចក្ដីថា អ្នកទាំង-ឡាយ ចូរធ្វើទាន និងសីលជាដើម ដែលគួរឲ្យដល់ព្រម ឲ្យដល់ព្រមដោយការមិនប្រមាទចុះ ចូរជាអ្នកមិនប្រមាទក្នុងការតាមរក្សានូវសីល សម្រាប់គ្រហស្ថ ដែលចែកជាសីល ដែលឲ្យនូវប្រយោជន៍ មានប្រយោជន៍បច្ចុប្បន្ន និងប្រយោជន៍ខាងមុខ ក្នុងការប្រកបសមថៈ និងវិបស្សនាភាវនា ។

បទថា **ឯសា មេ អនុសាសនី** សេចក្ដីថា ការប្រៀនប្រដៅថា អ្នកទាំងឡាយ ចូរកុំប្រមាទក្នុងទាន និងសីលជាដើម នេះជាពាក្យប្រៀនប្រដៅគឺជាឱវាទរបស់ខ្ញុំ ។

កាលសម្ដែងបដិបទាដែលជាប្រយោជន៍ ដល់អ្នកដទៃយ៉ាងនេះហើយ កាលនឹងកាន់យកទីបំផុតនៃបដិបទា ដែលជាប្រយោជន៍ខ្លួន ទើបពោលថា ណ្ហើយចុះ ខ្ញុំនឹងបរិនិព្វាន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វិប្បមុត្តោម្ហិ សព្វធិ** សេចក្ដីថា ខ្ញុំជាបុគ្គលរួចផុតហើយចាកកិលេស និងភពទាំងឡាយ ដោយប្រការទាំងពួង ព្រោះហេតុនោះ ខ្ញុំនឹងបរិនិព្វានដោយចំណែកមួយ ។

កាលពោលយ៉ាងនេះហើយ ព្រះថេរៈអង្គុយពត់ភ្នែនចូលឈាន មានតេជោធាតុជាអារម្មណ៍ កាលភ្លើងឆេះ ក៏បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ។

**អដ្ឋកថា ខទិរវនិយរេវតត្ថេរគាថា ចប់**

# សុត្តន្តបិដក

## គោឧត្តត្ថេរគាថា

[ ២៨៦ ] គោអាជានេយ្យដ៏ចម្រើន ដែលបុគ្គលទឹមហើយក្នុងនឹម ជាសត្វនាំទៅនូវធុរៈ ទុកជាម្ចាស់ញាំញីដោយការៈ ដ៏លើសលុបក៏ដោយ ក៏មិនរលាស់ចោល នូវនឹមដែលម្ចាស់ទឹមឡើយ យ៉ាងណាមិញ បុគ្គលទាំងឡាយណា ឆ្អែតហើយដោយប្រាជ្ញា ដូចជាសមុទ្រដែលឆ្អែតហើយដោយទឹក បុគ្គលទាំងឡាយនោះ រមែងមិនមើលងាយនូវពួកជនដទៃ ដូចជាបុគ្គលមានធម៌ដ៏ប្រសើរ មិនមើលងាយនូវសត្វទាំងឡាយ ក៏យ៉ាងនោះដែរ ។ មាណពទាំងឡាយ អ្នកលុះនូវអំណាចនៃកាល ( លោកធម៌ មានលាភជាដើម ) ក្នុងកាល ( ដែលបរិបូណ៌ដោយលោកធម៌ មានលាភជាដើម ) លុះអំណាចនៃសេចក្តីចម្រើន និងសេចក្តីវិនាស រមែងដល់នូវសេចក្តីទុក្ខ មាណពទាំងឡាយនោះ រមែងសោកសៅ ។ បុគ្គលពាលទាំងឡាយ ជាអ្នកមិនឃើញតាមពិត ប៉ោងឡើង ដោយហេតុនៃសេចក្តីសុខ ទ្រោមចុះដោយហេតុនៃសេចក្តីទុក្ខ រមែងលំបាក ដោយហេតុទាំងពីរ ។ ចំណែកបុគ្គលទាំងឡាយណា បានកន្លងនូវតណ្ហាជាគ្រឿងចាក់ស្រេះ ព្រោះសុខទុក្ខ និងឧបេក្ខា បុគ្គលទាំងឡាយនោះឈ្មោះថា តាំងនៅនឹង ដូចជាសសរខឿន មិនប៉ោងឡើង ទាំងមិនទ្រោមចុះ ។ អ្នកប្រាជ្ញទាំងឡាយ មិនបានជាប់ចំពាក់ក្នុងលាភ មិនជាប់ចំពាក់ក្នុងអលាភ មិនជាប់ចំពាក់ក្នុងអយស មិនជាប់ចំពាក់ក្នុងកិត្តិយស

មិនជាប់ចំពាក់ក្នុងនិន្ទា និងសេចក្តីសរសើរ មិនជាប់ចំពាក់ក្នុងទុក្ខ និងសុខ អ្នកប្រាជ្ញទាំងឡាយនោះ មិនជាប់ចំពាក់ក្នុងទីទាំងពួង ដូចជាតំណក់នៃទឹក ដែលមិនជាប់នឹងស្លឹកឈូក បានសេចក្តីសុខក្នុងទីទាំងពួង មិនចាលចាញ់ក្នុងទីទាំងពួង ។ ការមិនមានលាភ ( ប្រកប ) ដោយធម៌ណា ហើយនឹងលាភមិនប្រកបដោយធម៌ណា ការមិនមានលាភដែលប្រកបដោយធម៌នោះប្រសើរ ឯលាភមិនប្រកបដោយធម៌ពុំប្រសើរឡើយ ។ យសរបស់បុគ្គលមិនមានប្រាជ្ញាទាំងឡាយណា និងការមិនមានយស របស់អ្នកប្រាជ្ញទាំងឡាយណា ការមិនមានយស របស់អ្នកប្រាជ្ញទាំងឡាយនោះប្រសើរ ឯយសរបស់អ្នកមិនមានប្រាជ្ញាទាំងឡាយ ពុំប្រសើរឡើយ ។ ការសរសើរ អំពីបុគ្គលមិនមានបញ្ញាទាំងឡាយណា និងសេចក្តីតិះដៀល អំពីបុគ្គលមានបញ្ញាទាំងឡាយណា សេចក្តីតិះដៀល អំពីបុគ្គលមានបញ្ញាទាំង-ឡាយនោះ ប្រសើរ ឯការសរសើរ របស់បុគ្គលពាល ពុំប្រសើរឡើយ ។ សេចក្តីសុខកើតឡើង ព្រោះអាស្រ័យកាម និងសេចក្តីទុក្ខកើតឡើង អំពីសេចក្តីស្ងប់ស្ងាត់ សេចក្តីទុក្ខដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ប្រសើរ ឯសេចក្តីសុខ ដែលកើតអំពីកាម ពុំប្រសើរឡើយ ។ ការរស់នៅមិន ( ប្រកប ) ដោយធម៌ណា និងសេចក្តីស្លាប់ ប្រកបដោយធម៌ណា សេចក្តីស្លាប់ ប្រកបដោយធម៌នោះប្រសើរ ឯបុគ្គលរស់នៅមិនប្រកបដោយធម៌ ពុំប្រសើរសោះឡើយ ។

បុគ្គលទាំងឡាយណា មានកាម និងសេចក្តីក្រោធ លះបង់ហើយ មានចិត្តស្ងប់រម្ងាប់ហើយ រមែងត្រាច់ទៅក្នុងភពតូច និងភពធំ មិនអាស្រ័យនឹងលោក ( មានខន្ធលោកជាដើម ) សេចក្តីស្រឡាញ់ ឬមិនស្រឡាញ់ របស់ជនទាំងឡាយនោះ មិនមានសោះឡើយ ។ បុគ្គលទាំងឡាយ បានចម្រើនពោជ្ឈង្គទាំងឡាយផង ឥន្ទ្រិយទាំងឡាយផង ពលទាំងឡាយផង រមែងដល់នូវសេចក្តីស្ងប់ យ៉ាងក្រៃលែង ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។

គោទត្តត្ថេរ

## ឧទ្ទាន

ព្រះថេរៈពីរអង្គនេះ គឺរេវតៈ ១ គោទត្ត ១ ជាអ្នកមានឫទ្ធិច្រើន បានពោលនូវគាថា ២៨ ដែលមកក្នុងចុទ្ទសកនិបាត ។

ចុទ្ទសកនិបាត ចប់

# អដ្ឋកថា

## គោធត្តត្ថេរគាថា

[ ២៤៦ ] គាថារបស់ព្រះគោទត្តត្ថេរ មានពាក្យផ្ដើមថា **យថាបិ ភទ្ទោ អាជញ្ញោ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលឈ្មួញរទេះ ក្នុងក្រុងសាវត្ថី មានឈ្មោះថា **គោធត្ត** ។ ចម្រើនវ័យហើយ កាលបិតាស្លាប់ហើយ ប្រមូលទ្រព្យ យករទេះ ៥០០ ដាក់ទំនិញត្រាច់ទៅមកៗ ចិញ្ចឹមជីវិត ដោយការលក់ដូរ ធ្វើបុណ្យតាមកម្លាំងសម្បត្តិ ។

ថ្ងៃមួយ កាលគោដែលទឹមត្រង់នឹមមិនអាចអូសរទេះទៅ បានលុតជង្គង់ក្នុងរវាងផ្លូវ កាលពួកមនុស្ស មិនអាចឲ្យគោនោះក្រោកឡើងបាន ទើបគាត់ទៅឯង ចាក់គោនោះត្រង់កន្ទុយដ៏ខ្លាំងក្លា គោក្រោធថា បុរសនេះ ជាអសប្បុរស មិនដឹងអញមានកម្លាំង ឬមិនមានកម្លាំង ទើបចាក់អញយ៉ាងខ្លាំង ទើបជេរដោយភាសាមនុស្ស តាមចំណង់ថា នៃគោទត្តដ៏ចម្រើន អញមិនសំចៃកម្លាំងរបស់ខ្លួន អស់កាលមានប្រមាណប៉ុណ្ណេះ នាំភារៈរបស់ឯងទៅ តែថ្ងៃនេះ ឯងបៀតបៀនអញដែលកំពុងដួលចុះ ព្រោះមិនមានកម្លាំងណ្ហើយចុះ អញងាប់អំពីអត្តភាពនេះហើយ សូមជាសត្រូវ អាចបៀតបៀនឯងក្នុងទីដែលអញកើតហើយចុះ ។

គោទត្តបានស្តាប់ដូច្នោះ គិតថា ប្រយោជន៍អ្វី ដោយការបៀតបៀនសត្វទាំងឡាយ ហើយចិញ្ចឹមជីវិតនេះ កើតនូវសេចក្តីសង្វេគ លះនូវសម្បត្តិទាំងអស់ បួសក្នុងសម្នាក់របស់ព្រះមហាថេរៈមួយរូប បំពេញវិបស្សនា មិនយូរប៉ុន្មានក៏សម្រេចអរហត្ត នៅដោយសេចក្តីសុខ ដែលកើតអំពីសមាបត្តិ ។ ថ្ងៃមួយ កាលសម្តែងធម៌ដល់ពួកព្រះអរិយៈ ដែលជាគ្រហស្ថផង បព្វជិតផង ដែលចូលទៅរកលោក ទាក់ទងដោយលោកធម៌ ទើបពោលគាថាទាំងនេះថា

គោអាជានេយ្យដ៏ចម្រើន ដែលបុគ្គលទឹមហើយក្នុងនឹម ជាសត្វនាំទៅនូវធុរៈ ទុកជាម្ចាស់ញាំញីដោយភារៈ ដ៏លើសលុបក៏ដោយ ក៏មិនរលាស់ចោល នូវនឹមដែលម្ចាស់ទឹមឡើយ យ៉ាងណាមិញ បុគ្គលទាំងឡាយណា ឆ្អែតហើយដោយប្រាជ្ញា ដូចជាសមុទ្រដែលឆ្អែតហើយដោយទឹក បុគ្គលទាំងឡាយនោះ រមែងមិនមើលងាយនូវពួកជនដទៃ ដូចជាបុគ្គលមានធម៌ដ៏ប្រសើរ មិនមើលងាយនូវសត្វទាំងឡាយ ក៏យ៉ាងនោះដែរ ។ មាណពទាំងឡាយអ្នកលុះនូវអំណាចនៃកាល ( លោកធម៌ មានលាភជាដើម ) ក្នុងកាល ( ដែលបរិបូណ៌ដោយលោកធម៌ មានលាភជាដើម ) លុះអំណាចនៃសេចក្តីចម្រើន និងសេចក្តីវិនាស រមែងដល់នូវសេចក្តីទុក្ខ មាណពទាំងឡាយនោះ រមែងសោកសៅ ។ បុគ្គលពាលទាំងឡាយ ជាអ្នកមិនឃើញតាមពិត ប៉ោងឡើង ដោយហេតុនៃ

សេចក្តីសុខ ទ្រោមចុះ ដោយហេតុនៃសេចក្តីទុក្ខ រមែងលំបាក ដោយហេតុទាំងពីរ ។ ចំណែកបុគ្គលទាំងឡាយណា បានកន្ទងនូវតណ្ហាជាគ្រឿងចាក់ស្រែះ ព្រោះសុខទុក្ខ និងឧបេក្ខា បុគ្គលទាំង-ឡាយនោះ ឈ្មោះថា តាំងនៅនឹង ដូចជាសសរខឿន មិនប៉ោងឡើង ទាំងមិនទ្រោមចុះ ។ អ្នកប្រាជ្ញទាំងឡាយ មិនបានជាប់ចំពាក់ក្នុងលាភ មិនជាប់ចំពាក់ក្នុងអលាភ មិនជាប់ចំពាក់ក្នុងអយស មិនជាប់ចំពាក់ក្នុងកិត្តិយស មិនជាប់ចំពាក់ក្នុងនិន្ទា និងសេចក្តីសរសើរ មិនជាប់ចំពាក់ក្នុងទុក្ខ និងសុខ អ្នកប្រាជ្ញទាំង-ឡាយនោះ មិនជាប់ចំពាក់ក្នុងទីទាំងពួង ដូចជាតំណក់នៃទឹកដែលមិនជាប់នឹងស្លឹកឈូក បានសេចក្តីសុខក្នុងទីទាំងពួង មិនចាលចាញ់ក្នុងទីទាំងពួង ។ ការមិនមានលាភ ( ប្រកប ) ដោយធម៌ណា ហើយនឹងលាភមិនប្រកបដោយធម៌ណា ការមិនមានលាភដែលប្រកបដោយធម៌នោះប្រសើរ ឯលាភមិនប្រកបដោយធម៌ពុំប្រសើរឡើយ ។ យសរបស់បុគ្គលមិនមានប្រាជ្ញាទាំងឡាយណា និងការមិនមានយសរបស់អ្នកប្រាជ្ញទាំងឡាយណា ការមិនមានយសរបស់អ្នកប្រាជ្ញទាំងឡាយនោះប្រសើរ ឯយសរបស់អ្នកមិនមានប្រាជ្ញាទាំងឡាយ ពុំប្រសើរឡើយ ។ ការសរសើរអំពីបុគ្គលមិនមានបញ្ញាទាំងឡាយណា និងសេចក្តីតិះដៀលអំពីបុគ្គលមានបញ្ញាទាំងឡាយណា សេចក្តីតិះដៀលអំពីបុគ្គលមានបញ្ញាទាំង-

ឡាយនោះ ប្រសើរ ឯការសរសើររបស់បុគ្គលពាល ពុំប្រសើរឡើយ ។ សេចក្តីសុខកើតឡើង ព្រោះអាស្រ័យកាម និងសេចក្តីទុក្ខកើតឡើង អំពីសេចក្តីស្ងប់ស្ងាត់ សេចក្តីទុក្ខដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ប្រសើរ ឯសេចក្តីសុខដែលកើតអំពីកាម ពុំប្រសើរឡើយ ។ ការរស់នៅមិន ( ប្រកប ) ដោយធម៌ណា និងសេចក្តីស្លាប់ ប្រកបដោយធម៌ណា សេចក្តីស្លាប់ប្រកបដោយធម៌នោះប្រសើរ ឯបុគ្គលរស់នៅមិនប្រកបដោយធម៌ ពុំប្រសើរសោះឡើយ ។ បុគ្គលទាំងឡាយណា មានកាម និងសេចក្តីក្រោធលះបង់ហើយ មានចិត្តស្ងប់រម្ងាប់ហើយ រមែងត្រាច់ទៅក្នុងភពតូច និងភពធំ មិនអាស្រ័យនឹងលោក ( មានខន្ធលោកជាដើម ) សេចក្តីស្រឡាញ់ ឬមិនស្រឡាញ់ របស់ជនទាំងឡាយនោះ មិនមានសោះឡើយ ។ បុគ្គលទាំងឡាយ បានចម្រើនពោជ្ឈង្គទាំង-ឡាយផង ឥន្ទ្រិយទាំងឡាយផង ពលទាំងឡាយផង រមែងដល់នូវសេចក្តីស្ងប់យ៉ាងក្រៃលែង ជាអ្នកមិនមានអាសវៈ នឹងបរិ-និព្វាន ។

បណ្តាបទទាំងនោះ បទថា **អាជញ្ញោ** បានដល់ គោឧសភៈ ដែលជាអាជានេយ្យ ។

បទថា **ធុរេ យុត្តោ** បានដល់ ទឹមក្នុងនឹមរទេះ ។

បទថា **ធុរស្សហោ** បានដល់ ដែលនាំនឹមទៅ ក្នុងទីនេះ ដើម្បីងាយស្រួល

ក្នុងការចងគាថា លោកធ្វើនិទ្ទេសដោយត្រួត **ស** អក្ខរៈពីរតួ អធិប្បាយថា អាចនាំរទេះធ្ងន់ទៅ ។

បទថា **មថិតោ អតិភារេន** សេចក្ដីថា ត្រូវបៀតបៀនដោយភារៈដ៏ក្រៃលែង គឺដោយភារៈធ្ងន់ ។

បាលីថា **មទ្ទិតោ** ដូច្នេះក៏មាន សេចក្ដីក៏យ៉ាងនោះ ។

បទថា **សំយុត្តំ** បានដល់ មិនទម្លាក់នឹម គឺមិនរលាស់នឹមដែលគេទឹមត្រង់ករបស់ខ្លួន បានដល់ លីនឹម ដោយមិនរលាស់នឹម ឈរស្ងៀមយ៉ាងត្រឹមត្រូវ ។ បទថា **ឃរំ** សេចក្ដីថា គោនោះ នាំនឹមទៅ មិនដាក់ធុរៈ គឺមិនលះបង់ភារៈរបស់ខ្លួន ព្រោះខ្លួនជាគោអាជានេយ្យដ៏ចម្រើន និងព្រោះជាអ្នកឈ្លាសនិងមានសេចក្ដីព្យាយាម យ៉ាងណា ជនពួកណា ពេញ ទ្រទ្រង់ បរិបូណ៌ដោយបញ្ញាជាលោកិយផង លោកុត្តរផង ដូចមហាសមុទ្រ បរិបូណ៌ដោយទឹក ជនទាំងនោះ រមែងមិនមើលងាយ គឺរមែងមិនសង្កត់សង្កិនអ្នកមានបញ្ញាថោកថយ លោកពោលហេតុនោះថា **អរិយធម្មោវ ចាណិនំ** អធិប្បាយថា ធម៌របស់ព្រះអរិយៈទាំងឡាយនេះរបស់សត្វទាំងឡាយ គឺក្នុងសត្វទាំង-ឡាយ គឺការមិនមើលងាយអ្នកដទៃ ដោយការមិនមានលាភជាដើម ដូចការលើកខ្លួនសង្កត់សង្កិនអ្នកដទៃ ដោយលាភជាដើម ព្រោះភាពដែលព្រះអរិយៈទាំងឡាយនោះ ដល់នូវការបរិបូណ៌ដោយបញ្ញា ។

ដើម្បីសម្ដែងការនៅជាសុខរបស់ព្រះអរិយៈទាំងឡាយ ដោយសេចក្ដីបរិបូណ៌ដោយបញ្ញាយ៉ាងនេះ ទើបសម្ដែងការនៅជាទុក្ខរបស់បុគ្គលដែលមិន

មែនជាអរិយៈទាំងឡាយ ព្រោះការមិនបរិបូណ៌ដោយបញ្ញានោះ ទើបព្រះថេរៈពោលថា **កាលេ**។

បណ្ដាបទទាំងនោះ បទថា **កាលេ** សេចក្ដីថា ដោយកាល មានការដល់ព្រមដោយការមានលាភ និងការវិនាសលាភជាដើម ។

បទថា **កាលវសំ បត្តា** សេចក្ដីថា នៅក្នុងអំណាចនៃកាល មានលាភជាដើម អធិប្បាយថា កើតនូវសោមនស្ស ព្រោះលាភជាដើម និងកើតនូវទោមនស្ស ដោយការមិនមានលាភជាដើម ។

បទថា **ភវាភវវសំ គតា** សេចក្ដីថា មនុស្សទាំងនោះ ចូលដល់អំណាចនៃសេចក្ដីចម្រើន និងសេចក្ដីវិនាស គឺប្រព្រឹត្តទៅតាមសេចក្ដីចម្រើន និងសេចក្ដីវិនាស ។

បទថា **នរា ទុក្ខំ និគច្ឆន្តិ តេធ សោចន្តិ មាណវា** សេចក្ដីថា អ្នកទាំងនោះ គឺសត្វដែលបានឈ្មោះថា **មាណវា:** ដល់នូវការត្រេកអរ និងការមិនត្រេកអរដោយអំណាចមានលាភ និងមិនមានលាភ គឺដោយអំណាចសេចក្ដីចម្រើន និងសេចក្ដីវិនាស រមែងសោយសោកក្នុងលោកនេះ និងរមែងដល់ គឺរមែងជួបនូវទុក្ខ ដូចជាទុក្ខក្នុងនរកជាដើមក្នុងលោកខាងមុខ ។

ដោយបទថា **ឧន្នតា** ជាដើម ព្រះថេរៈសម្ដែងដល់ការសម្រេចវត្ថុដែលឥតប្រយោជន៍របស់សត្វទាំងឡាយ ដោយអំណាចលោកធម៌នោះឯង ។

បណ្ដាបទទាំងនោះ បទថា **ឧន្នតា សុខធម្មេន** សេចក្ដីថា ដល់នូវការប៉ោងឡើង ដោយហេតុសេចក្ដីសុខ គឺព្រោះមានសុខជាបច្ច័យ បានដល់

ដោយភោគសម្បត្តិជាដើម អធិប្បាយថា ជាអ្នកស្រើង ដោយការស្រើងក្នុងភោគៈជាដើម ។

បទថា **ឧក្កូជម្មេន បោណតា** សេចក្តីថា ដល់នូវភាពជាអ្នកវិនាស ដោយការសាបសូន្យភោគៈជាដើម ព្រោះហេតុនៃទុក្ខ គឺព្រោះមានទុក្ខជាបច្ច័យ គឺដល់នូវភាពជាបុគ្គលគួរដែលគេស្គាល់ថា ជាមនុស្សអាក្រក់ ដោយភាពជាមនុស្សក្រីក្រជាដើម ។

បទថា **ទ្វយេន** សេចក្តីថា ពាលបុថុជ្ជនទាំងឡាយ រមែងក្តៅក្រហាយព្រោះការប៉ោងឡើង និងការស្រុតចុះទាំង ២ យ៉ាង គឺដោយហេតុ ២ យ៉ាង មានលាភ និងមិនមានលាភជាដើម គឺត្រូវបៀតបៀន និងត្រូវបៀតបៀន ដោយអំណាចសេចក្តីត្រេកអរ និងមិនត្រេកអរ ។

ព្រោះហេតុអ្វី ព្រោះបុគ្គលពាលទាំងឡាយ ជាអ្នកមិនឃើញតាមពិត អធិប្បាយថា ព្រោះបុគ្គលពាលទាំងនោះ មិនដឹងក្រៃលែង នូវសភាវៈនៃធម៌តាមសេចក្តីពិត និងជាអ្នកមិនកំណត់ដឹងខន្ធ និងមិនទាន់លះកិលេសបាន ។ អាចារ្យពួកខ្លះសូធ្យថា **យថាភូតំ អទស្សនា** ដូច្នេះក៏មាន អធិប្បាយថា ព្រោះការមិនដឹងជាហេតុ ។

បទថា **យេ ច ទុក្ខេ សុខស្មិញ្ច មជ្ឈេ សិព្វិនិមច្ចគូ** សេចក្តីថា ព្រះអរិយៈទាំងឡាយណាសម្រេច គឺឈានកន្លងតណ្ហា ជាគ្រឿងរួបរឹត ដែលជាចន្លួភាគៈ ដែលទាក់ទងដោយទុក្ខវេទនា សុខវេទនា និងឧបេក្ខាវេទនានោះ ដោយការសម្រេចអរហត្តមគ្គ ព្រះអរិយៈទាំងនោះ តាំងនៅ មិនញាប់ញ័រ

ដោយលោកធម៌ ដូចសសរខឿនមិនញាប់ញ័រដោយខ្យល់ ដូច្នោះ ជាបុគ្គលមិនឈ្មោះថា ប៉ោងឡើង ឬទ្រោមចុះ គឺមិនប៉ោងឡើង ឬទ្រោមចុះ ក្នុងកាលណាឡើយ ព្រោះមិនមានការត្រេកអរ និងការមិនត្រេកអរ ដោយប្រការទាំងពួង ។

កាលសម្ដែងទីតាំងនៃវេទនា ដែលប្រឡាក់ព្រះអរហត្តមិនបានយ៉ាងនេះហើយ ឥឡូវនេះ កាលចែកលោកធម៌ ហើយសម្ដែងថា ( លោកធម៌ ) ចូលទៅប្រឡាក់ព្រះអរហត្តមិនបាន ដោយប្រការទាំងពួង ទើបព្រះគោទត្តពោលពាក្យថា **ន ហោវ** ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **លាភេ** សេចក្ដីថា ក្នុងការបានបច្ច័យមានចីវរជាដើម ។

បទថា **អលាភេ** សេចក្ដីថា ក្នុងការមិនបានទទួល គឺមិនបាននូវបច្ច័យ មានចីវរជាដើមនោះឯង ។

បទថា **ន យសេ** បានដល់ វិនាសចាកបរិវារ និងវិនាសកិត្តិយស ។ បទថា **កិត្តិយា** សេចក្ដីថា ក្នុងការសរសើរ គឺក្នុងការមានយស ដែលផ្សាយចេញទៅ ។

បទថា **និន្ទាយ** បានដល់ ក្នុងការនិន្ទាចំពោះមុខ ។ បទថា **បសំសាយំ** បានដល់ ក្នុងការសរសើរគុណចំពោះមុខ ។ បទថា **ទុក្ខេ** បានដល់ ក្នុងទុក្ខកើតឡើង ។ សូម្បីក្នុងបទថា **សុខេ** នេះ ក៏ន័យនេះដូចគ្នា ។

បទថា **សព្វត្ថ** សេចក្ដីថា ព្រះខីណាស្រពទាំងនោះ រមែងមិនជាប់នៅ

ក្នុងលោកធម៌ ៨ ប្រការ ដូចពោលហើយ ឬក្នុងអារម្មណ៍ទាំងពួង មានរូបជាដើម ព្រោះលះកិលេសបាន ដោយប្រការទាំងពួង ។ សេចក្តីនេះ ដូចអ្វី ដូចតំណក់នៃទឹកដែលមិនជាប់នឹងស្លឹកឈូក សេចក្តីថា តំណក់ទឹកលើស្លឹកឈូក សូម្បីដក់ ក៏មិនសើមជាប់ត្រង់ស្លឹកឈូកនោះ ហើយស្លឹកឈូក ក៏ជាប់ដោយតំណក់ទឹក ឃ្លាតចាកគ្នាទៅ យ៉ាងណា ព្រះវីណាស្រេពទាំងនោះ ក៏ដូច្នោះ ជាអ្នកលែងចោលនូវលាភជាដើម ដែលកើតឡើង និងលែងនូវអារម្មណ៍ មានរូបជាដើម ដែលមកប្រាកដដូចគ្នានោះឯង ។

ព្រោះហេតុនោះឯង អ្នកប្រាជ្ញ គឺបណ្ឌិត ឈ្មោះថា បានសេចក្តីសុខក្នុងទីគ្រប់ស្ថាន ព្រោះមិនមានសេចក្តីសោកជាដើម ដែលមានវត្ថុជាទីស្រឡាញ់ជាហេតុ ដោយដឹងទាន់ក្នុងលាភជាដើម និងមិនចាលចាញ់ក្នុងទីទាំងពួង ព្រោះមិនត្រូវលាភគ្របសង្កត់ជាដើម ។

ឥឡូវនេះ កាលនឹងសម្តែងឲ្យឃើញនូវភាពប្រសើរជាងគ្នាក្នុងលាភ និងការមិនមានលាភជាដើម ចែកជាផ្នែកៗ ទើបព្រះថេរៈពោលពាក្យថា **ធម្មេន** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **ធម្មេន ច អលាភោ យោ** សេចក្តីថា ការមិនបានលាភ គឺការមិនមានលាភ បានដល់ ការសាបសូន្យចាកលាភឯណា ដែលមានការរក្សាធម៌នោះជាហេតុ និងការបានលាភឯណា ដែលមិនប្រកបដោយធម៌ កើតឡើងដោយធម៌ ដោយមិនប្រពៃ ដោយវិធីដែលព្រះពុទ្ធទ្រង់តិះដៀល ក្នុង ២ យ៉ាងនោះ ការមិនបានលាភដែលជាធម៌ គឺបានមកដោយ

ធម៌ប្រសើរជាង កាលបុគ្គលវៀរចាកលាភ អកុសលធម៌ រមែងវិនាស កុសលធម៌រមែងចម្រើន ការមិនបានលាភបែបនេះ គួរសរសើរជាង នាំមកនូវប្រយោជន៍ ។

បទថា **យញ្ចេ លាភោ អធម្មិកោ** អធិប្បាយថា លាភណាកើតឡើងដោយអធម៌ លាភនោះមិនប្រសើរឡើយ ។

បទថា **យសោ ច អប្បពុទ្ធីនំ វិញ្ញូនំ អយសោ ច យោ** សេចក្ដីថា យសដែលបុគ្គលបានមក ដោយអំណាចរបស់បុគ្គលទាំងឡាយ ដែលមានការចេះដឹងតិច គឺមិនមានការចេះដឹងក្ដី ការមិនមានយស គឺការវិនាសយសដែលបុគ្គលបានមក ដោយអំណាចបុគ្គលទាំងឡាយ ដែលមានការចេះដឹង គឺបណ្ឌិតក្ដី ក្នុង ២ យ៉ាងនោះ ការមិនមានយស ចាកពួកបុគ្គលដែលមានការចេះដឹងប្រសើរជាង ព្រោះថា បុគ្គលដែលមានការចេះដឹងទាំងនោះ រមែងប្រាថ្នានូវការសាបសូន្យយសដល់បុគ្គលនោះ ដោយប្រការដែលអកុសលធម៌វិនាស កុសលធម៌ចម្រើន ។ ម្យ៉ាងទៀត បុគ្គលដែលមានជាតិបរិបូណ៌ ក៏លះបង់វត្ថុមិនល្អនោះ ហើយតាំងនៅក្នុងសេចក្ដីល្អយ៉ាងនោះ ។

បទថា **ឆយសោ អប្បពុទ្ធីនំ** សេចក្ដីថា យសដែលបានដោយអំណាចនៃពួកបុគ្គលដែលមិនមានការចេះដឹង រមែងមិនប្រសើរ ព្រោះថា បុគ្គលដែលមិនមានការចេះដឹងនោះ អាចញុំាងយសនោះឲ្យកើតឡើង ដោយអំណាចការខ្វល់ខ្វាយបានមក ដោយគុណដែលមិនមានតាមសេចក្ដីពិត យសនោះ រមែងនាំមកនូវសេចក្ដីវិនាសដល់បុគ្គលនោះ ក្នុងលោកនេះ ដោយការ

ត្រូវវិញ្ញូជនតិះដៀលជាដើម និងក្នុងលោកខាងមុខ ដោយសេចក្តីលំបាក ដែលកើតអំពីទុក្ខជាដើម ក្នុងទុគ្គតិ ។ ដោយហេតុនោះ ព្រះមានព្រះភាគ ត្រាស់ ( ក្នុងខុទ្ទកនិកាយ សុត្តនិបាត ) ថា លាភ សេចក្តីសរសើរ សក្ការៈ និងយស ដែលបានដោយអំពើខុស ... ដូច្នេះ ។ និងត្រាស់ ( ក្នុងវិនយបិដក ចូឡវគ្គ ) ថា សក្ការៈ តែងសម្លាប់បុរសអាក្រក់ ... ដូច្នេះ ។

បទថា **ទុម្មេធេហិ** បានដល់ ចាកបុគ្គលមិនមានបញ្ញា ។

បទថា **យញ្ច ពាលប្បសំសនា** សេចក្តីថា ការសរសើរអំពីបុគ្គល ពាល គឺបុគ្គលមិនចេះដឹង ឈ្មោះថា មានប្រយោជន៍អ្វី ។

បទថា **កាមមយិកំ** បានដល់ ដែលសម្រេចមកអំពីវត្ថុកាម គឺ អាស្រ័យកាមគុណកើតឡើង ។

បទថា **ទុក្ខញ្ច បារិវេកិយំ** សេចក្តីថា សេចក្តីទុក្ខតាមកាយ ដែល កើតអំពីការស្ងាត់ គឺដែលប្រព្រឹត្តទៅ ដោយអំណាចសេចក្តីលំបាកកាយ ដែលធ្វើឲ្យក្តៅក្រហាយ ព្រោះអន្ទុយក្នុងទីមិនស្មើជាហេតុជាដើម តែទុក្ខនោះ ជាការសរសើររបស់វិញ្ញូជន ព្រោះជាឧបនិស្ស័យដល់ព្រះនិព្វាន ដែលប្រាស ចាកអាមិស ដោយហេតុនោះ ទើបព្រះថេរៈពោលថា **បាវេកទុក្ខំ សេយ្យោ** ដូច្នេះ ។

បទថា **ជីវិតញ្ច អធម្មេន** សេចក្តីថា ការចិញ្ចឹមជីវិតដោយមិនប្រពៃ តាមធម៌ គឺមិនប្រព្រឹត្តធម៌ ព្រោះហេតុនៃជីវិតជាដើម ។ ឈ្មោះថា ការស្លាប់ ដោយធម៌ បានដល់ កាលបុគ្គលណាម្នាក់ពោលថា ខ្ញុំនឹងស្លាប់ បុគ្គលនោះ

ដែលមិនធ្វើបាបឈ្មោះនេះឲ្យស្លាប់ សូម្បីបុគ្គលនោះស្លាប់ទៅ ក៏មិនព្រមធ្វើបាប មិនញុំាងធម៌ឲ្យកម្រើក ការស្លាប់ដើម្បីធម៌ជាការស្លាប់ប្រកបដោយធម៌ប្រសើរជាង ព្រោះដូច្នោះ ការស្លាប់បែបនោះ ឈ្មោះថា ប្រកបដោយធម៌ ព្រោះមិនប្រាសចាកធម៌ ដែលវិញ្ញូជនសរសើរជាង ព្រោះឲ្យដល់នូវស្ថានសួគ៌ និងព្រោះជាឧបនិស្ស័យនៃព្រះនិព្វាន សមដូចព្រះតម្រាស់ដែលត្រាស់ ( ក្នុងខុទ្ទកនិកាយ ជាតក ) ថា

*ជនគប្បីលះបង់នូវទ្រព្យ ព្រោះហេតុនៃអវយវៈដ៏ប្រសើរ កាលបើរក្សានូវជីវិត ក៏គប្បីលះបង់នូវអវយវៈ កាលបើរឭកឃើញនូវធម៌ គប្បីលះបង់ទាំងអវយវៈ ទ្រព្យ និងជីវិតទាំងអស់ ។*

បទថា **យញ្ចេ ជីវេ អធម្មិកំ** អធិប្បាយថា ការដែលបុគ្គលរស់នៅដោយប្រាសចាកធម៌ ឈ្មោះថា មិនប្រសើរ ព្រោះត្រូវវិញ្ញូជនតិះដៀល និងឲ្យដល់អបាយ ។

ឥឡូវនេះ កាលសម្តែងការមិនចូលទៅប្រឡាក់របស់ព្រះវីណាស្រេពតាមដែលពោលហើយដោយហេតុ ទើបព្រះថេរៈពោលគាថាជាដើមថា **កាមកោបប្បហីនា** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កាមកោបប្បហីនា** សេចក្តីថា លះនូវការត្រេកអរ និងមិនត្រេកអរបានជាសមុច្ឆេទ ដោយអរិយមគ្គ ។

បទថា **សន្តចិត្តា ភវាភវេ** សេចក្តីថា ឈ្មោះថា មានចិត្តចូលទៅស្ងប់ ព្រោះលះកិលេសជាគ្រឿងក្តៅបាន ដោយឥតសេសសល់ មួយអន្ទើ

ដោយកពតូច និងកពធំ ។

បទថា **លោកេ** បានដល់ ក្នុងខន្ធលោកជាដើម ។ បទថា **អសិតា** បានដល់ ជាបុគ្គលដែលតណ្ហាមិនអាស្រ័យហើយ ដោយអំណាចតណ្ហា និងទិដ្ឋិ ។

បទថា **ឆត្តិ តេសំ បិយាបិយំ** សេចក្តីថា អារម្មណ៍ដែលជាទីស្រឡាញ់ ឬមិនជាទីស្រឡាញ់ក្នុងទីណាមួយ គឺក្នុងលាភជាដើម និងក្នុងរូបារម្មណ៍ជាដើម រមែងមិនមានដល់ព្រះទីណាស្រពទាំងឡាយនោះ ។ ព្រោះលោកកាត់នូវកិលេស ដែលជាដើមហេតុនៃការស្រឡាញ់ និងការស្អប់នោះ បានជាសមុច្ឆេទ ដោយប្រការទាំងពួង ។

ឥឡូវនេះ កាលសម្តែងប្រការដែលធម៌នោះ គឺបែបនោះ ដែលកើតដោយការនាហើយ កាលកាន់យកកំពូលនៃទេសនា ដោយអនុបាទិសេស-និព្វានធាតុ ទើបព្រះថេរៈពោលគាថាចុងក្រោយថា **ការយិត្វាន** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **បប្បុយ្យ** ប្រែថា ដល់ហើយ ។ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង គាថាទាំងនេះឯង បានជាការព្យាករណ៍អរហត្តផលរបស់ព្រះថេរៈ ។ល។

**អដ្ឋកថា គោឧត្តត្ថេរគាថា ចប់**

**ថេរគាថា ចុទ្ទសកនិបាត ចប់**

# សុត្តន្តបិដក
# ថេរគាថា សោឡសកនិបាត

## អញ្ញាកោណ្ឌញ្ញត្ថេរគាថា

[ ២៤៧ ] ខ្ញុំនេះបានស្តាប់ធម៌មានរសច្រើន ជ្រះថ្លាក្រៃលែង វិរាគធម៌ ដែលលោកសម្តែងហើយ មិនកាន់យក ( ធម៌ណាមួយ ) ដោយប្រការទាំងពួង ។ អារម្មណ៍ទាំងឡាយច្រើន ដ៏វិចិត្រក្នុងលោក លើមណ្ឌលនៃផែនដីនេះ ទំនងជាញាំញីនូវសេចក្តីត្រិះរិះថា ល្អ ដែលប្រកបដោយរាគៈ ។ អរិយសាវក ពិចារណាឃើញ ដោយប្រាជ្ញា ក្នុងកាលណា សេចក្តីត្រិះរិះទាំងឡាយ ក៏ស្ងប់រម្ងាប់ក្នុងកាលណោះ ដូចជាភ្លៀងរម្ងាប់នូវធូលី ដែលហុយឡើងដោយខ្យល់ ។ អរិយសាវក ពិចារណាឃើញដោយប្រាជ្ញាថា សង្ខារទាំងពួង មិនទៀង ក្នុងកាលណា រមែងនឿយណាយក្នុងសេចក្តីទុក្ខ ក្នុងកាលណោះ នេះជាផ្លូវនៃសេចក្តីបរិសុទ្ធិ ។ អរិយសាវក ពិចារណាឃើញដោយប្រាជ្ញាថា សង្ខារទាំងពួង ជាទុក្ខ ក្នុងកាលណា រមែងនឿយណាយក្នុងទុក្ខ ក្នុងកាលណោះ នេះជាផ្លូវនៃសេចក្តីបរិសុទ្ធិ ។ អរិយសាវក ពិចារណាឃើញ ដោយប្រាជ្ញាថា ធម៌ទាំងពួង មិនមែនជារបស់ខ្លួន ក្នុងកាលណា រមែងនឿយណាយក្នុងទុក្ខ ក្នុងកាលណោះ នេះជាផ្លូវនៃសេចក្តីបរិសុទ្ធិ ។ ព្រះថេរៈឈ្មោះកោណ្ឌញ្ញ ត្រាស់ដឹងតាម

ព្រះពុទ្ធ ដែលមានសេចក្តីព្យាយាមដ៏ក្លៀវក្លា មានជាតិ និងមរណៈ លះបង់ហើយ បរិបូណ៌ដោយព្រហ្មចរិយធម៌ ។ អន្ទាក់ គឺឱឃៈក្តី ចិត្តរឹងរូសដ៏មាំក្តី មោហៈដូចភ្នំ ដែលទម្លាយបានដោយកម្រក្តី ព្រះអញ្ញាកោណ្ឌញ្ញនោះ បានកាត់នូវចិត្តដ៏រឹងរូសផង នូវអន្ទាក់ គឺឱឃៈផង នូវភ្នំ គឺមោហៈដែលបុគ្គលបំបែកបានដោយកម្រផង បានឆ្លងទៅដល់ត្រើយ ជាអ្នកមានឈាន រួចចាកចំណងនៃមារ ។ ភិក្ខុអ្នកមានចិត្តរាយមាយ ឃ្លេងឃ្លោង អាស្រ័យនឹងពួកបាបមិត្រ រមែងត្រូវលោក គឺឧបាយនៃសេចក្តីក្រោធជ្រមុជ ហើយលិចចុះក្នុងអន្លង់ធំ ។ ឯភិក្ខុមានប្រាជ្ញា មានចិត្តមិនរាយមាយ មិនឃ្លេងឃ្លោង មានប្រាជ្ញាល្អិត សង្រួមឥន្ទ្រិយល្អ មានកល្យាណមិត្រ តែងធ្វើនូវទីបំផុតនៃទុក្ខបាន ។ ជនអ្នកមានអវយវៈប្រាកដស្មើដោយថ្នាំងវល្លិ ស្គមរីមរាមដោយសរសៃ ជាអ្នកដឹងប្រមាណក្នុងបាយ និងទឹក មានចិត្តមិនរួញរា ត្រូវរបោម និងមូសទាំងឡាយខាំហើយ ក្នុងព្រៃតូច និងព្រៃធំ ជាអ្នកមានស្មារតី គង់អត់ទ្រាំនៅក្នុងព្រៃនោះបាន ដូចដំរីដ៏ប្រសើរ ( អត់ទ្រាំ ) ក្នុងប្រធាននៃសង្គ្រាម ។ ខ្ញុំមិនត្រេកអរ

នឹងសេចក្តីស្លាប់ មិនត្រេកអរនឹងការរស់នៅ ខ្ញុំរង់ចាំតែកាល ( បរិនិព្វាន ) ដូចអ្នកធ្វើការឈ្នួល ទន្ទឹងតែអស់ថ្ងៃ ។ ខ្ញុំមិនត្រេកអរនឹងសេចក្តីស្លាប់ មិនត្រេកអរនឹងការរស់នៅ ខ្ញុំជាអ្នកដឹងខ្លួន មានស្មារតី រង់ចាំតែបរិនិព្វានកាល ។ ព្រះសាស្តា ខ្ញុំបានបម្រើហើយ ព្រះពុទ្ធសាសនា ខ្ញុំក៏បានធ្វើហើយ ភារៈដ៏ធ្ងន់ ខ្ញុំបានដាក់ចុះហើយ តណ្ហាជាគ្រឿងនាំទៅកាន់ភព ខ្ញុំដកចោលហើយ ។ កុលបុត្រអ្នកចេញចាកផ្ទះ ចូលកាន់ផ្នួស ដើម្បីប្រយោជន៍ណា ប្រយោជន៍នោះ ខ្ញុំបានដល់ហើយ ខ្ញុំមានប្រយោជន៍អ្វី ដោយសទ្ធិវិហារិក ។

## អញ្ញាកោណ្ឌញ្ញត្ថេរ

# អដ្ឋកថា
# ថេរគាថា សោឡសកនិបាត

## អញ្ញាកោណ្ឌញ្ញត្ថេរគាថា

ក្នុងសោឡសកនិបាត គាថារបស់ព្រះអញ្ញាកោណ្ឌញ្ញត្ថេរ មានពាក្យផ្តើមថា **ឯស ភិយ្យោ បសីទាមិ** ដូច្នេះ ។ រឿងរ៉ាវរបស់ព្រះថេរៈ មានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ក្នុងសាសនាព្រះមានព្រះភាគ ព្រះនាមបទុមុត្តរៈ កុលបុត្តនេះកើតក្នុងត្រកូលគហបតីមហាសាល ក្នុងហង្សវតីនគរ ដល់នូវភាពជាអ្នកដឹងក្តីហើយ ថ្ងៃមួយ ស្តាប់ធម៌ក្នុងសម្នាក់ព្រះសាស្តា ឃើញព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុមួយរូប ក្នុងតំណែងឯតទគ្គៈ នៃភិក្ខុដែលជារត្តញ្ញូ ក្នុងធម៌ដែលខ្លួនបានជាដំបូងក្នុងព្រះសាសនា ខ្លួនឯងក៏ប្រាថ្នាតំណែងនោះ ទើបបំពេញមហាទាន ឲ្យប្រព្រឹត្តទៅអស់ ៧ ថ្ងៃ ដល់ព្រះសាស្តា ដែលមានភិក្ខុមួយសែនរូបជាបរិវារ ហើយតាំងសេចក្តីប្រាថ្នា ។ ឯព្រះសាស្តា ទ្រង់ឃើញភាពដែលកុលបុត្តនោះមិនមានអន្តរាយ ទើបព្យាករសម្បត្តិដែលកើតឡើង ។ កុលបុត្តនោះ បំពេញនូវបុណ្យជរាបដល់អស់ជីវិត កាលព្រះសាស្តាបរិនិព្វានហើយ កាលមហាជនកំពុងសាងចេតិយ កុលបុត្តនោះ សាងផ្ទះកែវខាងក្នុងចេតិយ និងឲ្យសាងគោមភ្លើងកែវ មានតម្លៃ ១ ពាន់កហាបណៈព័ទ្ធជុំវិញចេតិយ ។

កុលបុត្តនោះ ធ្វើបុណ្យយ៉ាងនេះហើយ ចុតិអំពីអត្តភាពនោះ អន្ទោល

ទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងសាសនាព្រះមានព្រះភាគ ព្រះនាម វិបស្សី កើតជាកុដុម្ពិកៈ មានឈ្មោះថា មហាកាល ចាត់ចែងបាយាសអំពីទឹកដោះ មិនប្រើទឹក ដោយអង្ករនៃស្រូវសាលី ដែលខ្លួនបែកជង្រើមស្រូវក្នុងស្រែប្រមាណ ៨ ករីស ទើបដាក់ទឹកឃ្មុំ សប្បិ ស្ករក្រាមជាដើមក្នុងបាយាសនោះ ហើយបានថ្វាយសង្ឃ មានព្រះពុទ្ធជាប្រធាន ។ ទីដែលកុលបុត្តនោះបែកជង្រើមស្រូវហើយ ក៏ពេញដូចដើម ក្នុងកាលដែលស្រូវត្រូវធ្វើអំបុក បានថ្វាយកត្តដ៏ប្រសើរ គឺអំបុក ក្នុងកាលដែលច្រូត បានថ្វាយកត្តដ៏ប្រសើរ ក្នុងកាលដែលច្រូត ក្នុងកាលធ្វើចំណង បានថ្វាយកត្តដ៏ប្រសើរ ក្នុងកាលធ្វើចំណង ក្នុងកាលរាប់កណ្តាប់ បានថ្វាយកត្តដ៏ប្រសើរ ក្នុងកាលដែលរាប់កណ្តាប់ ក្នុងកាលធ្វើលាន បានថ្វាយកត្តដ៏ប្រសើរ ក្នុងកាលធ្វើលាន បានថ្វាយកត្តដ៏ប្រសើរ ក្នុងកាលដែលពូកជាពំនូក បានថ្វាយកត្តដ៏ប្រសើរ ក្នុងកាលដែលរាប់ចំនួន បានថ្វាយកត្តដ៏ប្រសើរ ក្នុងកាលដែលជញ្ជូនដាក់ជង្រុក សេចក្តីថា កុលបុត្តនោះ បានថ្វាយកត្តដ៏ប្រសើរ ៩ ដង ក្នុងរដូវធ្វើស្រែ ស្រូវនោះក៏បរិបូរក្រៃលែងឡើង ។

កុលបុត្តនោះ បំពេញបុណ្យជរាបដល់អស់ជីវិត ដោយការធ្វើយ៉ាងនេះ ចុតិចាកអត្តភាពនោះហើយ កើតក្នុងទេវលោក អន្ទោលទៅមកក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលព្រាហ្មណមហាសាលក្នុងស្រុកព្រាហ្មណ៍ឈ្មោះទោណវត្ថុ មិនឆ្ងាយអំពីក្រុងកបិលពស្តុ មុនកាលព្រះមានព្រះភាគនៃយើងទ្រង់កើតឡើងនោះឯង កុលបុត្តនោះ មាននាម

តាមគោត្រថា **កោណ្ឌញ្ញៈ** លោកចម្រើនវ័យហើយ រៀននូវវេទ ៣ បាន ដល់នូវត្រើយក្នុងមន្តសម្រាប់ទាយលក្ខណៈ ។ សម័យនោះ ព្រះពោធិសត្វ នៃយើងច្យុតិអំពីតុសិតបុរី កើតក្នុងព្រះដំណាក់របស់ព្រះបាទសុទ្ធោទនមហារាជ ក្នុងនគរកបិលពស្តុ ក្នុងថ្ងៃថ្វាយព្រះនាម កាលព្រាហ្មណ៍ ១០៨ ត្រូវហៅ ចូលគាល់ កុលបុត្រនេះ ក្មេងជាងព្រាហ្មណ៍ទាំងអស់ ក្នុងបណ្តាព្រាហ្មណ៍ ៨ នាក់ ដែលនាំមកកាន់មហាល្វែងដ៏ប្រសើរសម្រាប់កំណត់លក្ខណៈ ឃើញ ការដល់ព្រមដោយលក្ខណៈរបស់ព្រះមហាបុរស ទើបប្បាស់ក្នុងចិត្តថា បុរស នេះ នឹងបានជាព្រះពុទ្ធដោយចំណែកមួយ ទើបរង់ចាំការចេញមហាភិនេ-ស្រ្កមណ៍របស់ព្រះមហាសត្វ ។

ឯព្រះមហាសត្វចម្រើនដោយបរិវារច្រើន ដល់នូវសេចក្តីចម្រើនដោយ លំដាប់ ដល់នូវការចាស់ក្លានៃញាណ ក្នុងឆ្នាំទី ២៩ យាងចេញមហាភិ-នេស្រ្កមណ៍ បួសត្រង់ច្នេរស្ទឹងអនោមានទី យាងទៅឧរុវេលាបទេសដោយ លំដាប់ ហើយផ្តើមតាំងសេចក្តីព្យាយាម ។ ក្នុងកាលនោះ កោណ្ឌញ្ញមាណព ដឹងថា ព្រះមហាសត្វបួសហើយ មួយអន្លើដោយវប្បមាណពជាដើម ដែល ជាបុត្ររបស់ព្រាហ្មណ៍អ្នកទាយលក្ខណៈ មានខ្លួនជាគម្រប់ ៥ បួសហើយ ចូលទៅកាន់សម្នាក់ព្រះពោធិសត្វដោយលំដាប់ ឧបដ្ឋាកព្រះអង្គ ៦ វស្សា នឿយណាយព្រោះការដែលព្រះអង្គបរិភោគអាហារគ្រោតគ្រាត ទើបគេចទៅ កាន់ព្រៃឥសិបតនមិគទាយវ័ន ។ កាលនោះឯង ព្រះពោធិសត្វមានកម្លាំង កាយ ព្រោះបរិភោគអាហារគ្រោតគ្រាត គង់ប្រថាប់លើអបរាជិតបល្ល័ង្ក នា

មណ្ឌលនៃពោធិព្រឹក្ស ក្នុងថ្ងៃវិសាខបុណ្ណមី ទ្រង់ញាំញីនូវមារ ៣ ជាអ្នកត្រាស់ដឹងក្រៃលែងឯង ឲ្យកាលវេលា ៧ សប្តាហ៍កន្លងទៅ ត្រង់ម្តុំពោធិមណ្ឌលនោះឯង ទ្រង់ជ្រាបការចាស់ក្លានៃញាណរបស់បញ្ចវគ្គិយ ទើបយាងទៅកាន់ព្រៃឥសិបតនមិគទាយវ័ន ក្នុងថ្ងៃអាសាឡ្ហបុណ្ណមី ហើយទ្រង់សម្តែងធម្មចក្កប្បវត្តនសូត្រ ដល់បញ្ចវគ្គិយភិក្ខុទាំងនោះ ។ ក្នុងកាលចប់ព្រះធម្មទេសនា ព្រះកោណ្ឌញ្ញត្ថេរ តាំងនៅក្នុងសោតាបត្តិផល មួយអន្លើដោយព្រហ្ម ១៨ កោដិ ។ តមក ព្រះអញ្ញាកោណ្ឌញ្ញត្ថេរ ក៏បានធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល ដោយអនត្តលក្ខណសូត្រ ក្នុងតិថីទី ៥ នៃបក្ខ ដោយហេតុនេះ ទើបលោកពោលក្នុងអបទានថា

ខ្ញុំបានឃើញជាដំបូង នូវព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈ ព្រះអង្គជាច្បងក្នុងលោក ជាអ្នកដឹកនាំសត្វលោក ទ្រង់ដល់នូវពុទ្ធភូមិ ។ ពួកយក្ខទាំងអស់មកជួបជុំគ្នា ចោមរោមធ្វើអញ្ជលី ថ្វាយបង្គំព្រះសម្ពុទ្ធ ទៀបគល់នៃពោធិព្រឹក្ស ។ ពួកទេវតាទាំងអស់នោះមានចិត្តត្រេកអរ សញ្ចរទៅឰដ៏អាកាស ( ពោលថា ) ព្រះពុទ្ធអង្គនេះ ទ្រង់បានដល់ដោយលំដាប់ ទ្រង់កម្ចាត់បង់ងងឹតដែលជាធម៌ធ្វើឲ្យខ្វាក់ ។ ពួកទេវតាទាំងអស់នោះ មានសេចក្តីរីករាយប្រព្រឹត្តទៅខាងមុខ សំឡេងកងរំពងដ៏ខ្លាំង ប្រព្រឹត្តទៅថា យើងទាំងឡាយ នឹងដុតបំផ្លាញនូវពួកកិលេស ក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធ ។ លុះខ្ញុំដឹងពាក្យរបស់ទេវតា

ទាំងឡាយ ដែលពោលដោយវាចាហើយ ក៏ត្រេកអរ បាន ថ្វាយចង្ហាន់ជាដំបូង ដោយចិត្តដែលត្រេកអរ ។ ព្រះសាស្តា ព្រះអង្គប្រសើរក្នុងលោក ទ្រង់ជ្រាបបំណងរបស់ខ្ញុំ ទ្រង់គង់ ក្នុងកណ្តាលនៃពួកទេវបរិស័ទ ហើយត្រាស់គាថាទាំងនេះថា តថាគតចេញទៅទ្រង់ព្រះផ្នួស អស់ ៧ ថ្ងៃ ក៏បានដល់នូវ ពោធិញ្ញាណ ភត្តជាដំបូងរបស់តថាគតនេះ ញ៉ាំងព្រហ្មចារី-បុគ្គល ឲ្យប្រព្រឹត្តទៅបាន ។ បុគ្គលណា ចុះចាកឋានតុសិត មកកើតក្នុងមនុស្សលោកនេះ ហើយថ្វាយចង្ហាន់ដល់តថាគត តថាគតនឹងសម្តែងសរសើរបុគ្គលនោះ អ្នកទាំងឡាយចូរស្តាប់ តថាគតសម្តែងចុះ ។ បុគ្គលនេះ នឹងបានសោយរាជ្យ ជាស្តេច នៃទេវតា អស់ ៣០ ពាន់កប្ប នឹងគ្របសង្កត់ទេវតាទាំងអស់ ហើយនៅគ្រប់គ្រងទេវលោក ។ លុះច្យុតចាកទេវលោក មក កាន់អត្តភាពជាមនុស្ស នឹងបានជាស្តេចចក្រពត្តិ សោយរាជ្យ ក្នុងមនុស្សលោកនោះ អស់មួយពាន់ដង ។ កន្លងទៅមួយ សែនកប្ប ព្រះសាស្តាព្រះនាមគោតម កើតក្នុងឧក្កាកត្រកូល នឹងបានត្រាស់ដឹងក្នុងលោក ។ កុលបុត្រនោះ ច្យុតចាកទេវ-លោក មកកាន់អត្តភាពជាមនុស្ស នឹងចេញចាកផ្ទះទៅបួស នៅអស់ ៦ វស្សា ។ លំដាប់អំពីនោះមក ព្រះពុទ្ធនឹងទ្រង់ សម្តែងនូវអរិយសច្ច ក្នុងវស្សាជាគម្រប់ ៧ កុលបុត្រមាន

ឈ្មោះថា កោណ្ឌញ្ញៈ នឹងបានធ្វើឲ្យជាក់ច្បាស់នូវធម៌ជាដំបូង ។ ខ្ញុំបួសតាមព្រះពោធិសត្វ ដែលចេញទៅទ្រង់ព្រះផ្នួស ហើយបានធ្វើសេចក្តីព្យាយាមដោយប្រពៃ ខ្ញុំចូលទៅកាន់ផ្នួស ដើម្បីប្រយោជន៍ដុតបំផ្លាញនូវកិលេសទាំងឡាយ ។ ព្រះសព្វញ្ញុពុទ្ធលុះបានត្រាស់ដឹងក្នុងលោក ព្រមទាំងទេវលោកហើយ ទ្រង់យកសច្ចៈនេះទូងស្គរ គឺអមតនិព្វាន ក្នុងព្រៃជំដល់ខ្ញុំ ។ ឥឡូវនេះ ខ្ញុំនោះបានដល់នូវអមតនិព្វាន ជាសន្តិបទដ៏ប្រសើរ ជាអ្នកមិនមានអាសវៈ ព្រោះកំណត់ដឹងនូវអាសវៈទាំងពួង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

ក្នុងកាលតមក ព្រះសាស្តាទ្រង់ប្រថាប់គង់លើបវរពុទ្ធាសនៈ ដែលគេរៀបចំទុកក្នុងកណ្តាលភិក្ខុសង្ឃ ក្នុងជេតពនមហាវិហារ កាលទ្រង់សម្តែងថា ព្រះថេរៈបានត្រាស់ដឹងធម៌មុនគេ ទើបទ្រង់ស្ថាបនាក្នុងឯតទគ្គៈថា ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកដឹងរាត្រី ដែលជាសាវ័ករបស់តថាគតស្រេចនឹងអញ្ញាកោណ្ឌញ្ញៈ ប្រសើរជាងគេ ។ ព្រះថេរៈបំណងមិនឲ្យអគ្គសាវ័កទាំង ២ ធ្វើសេចក្តីគោរពចំពោះខ្លួន និងការនៅប្រឡូកប្រឡំ ក្នុងសេនាសនៈស្រុក និងបំណងនៅដោយការត្រេកអរក្រៃលែងក្នុងវិវេក ឃើញថា ការធ្វើបដិសណ្ឋារៈចំពោះបព្វជិត និងគ្រហស្ថ ដែលមកកាន់សម្នាក់ខ្លួន

ជាការរីករាយ ទើបទូលលាព្រះសាស្តា ចូលទៅកាន់ព្រៃហិមពាន្តដែលមានដីរ ឈ្មោះឆទ្ទន្តជាឧបដ្ឋាក ហើយនៅត្រង់ឆ្នេរស្រះឆទ្ទន្តអស់ ១២ ឆ្នាំ ។ កាល ព្រះថេរៈនៅដោយអាការយ៉ាងនោះ ថ្ងៃមួយ សក្កទេវរាជយាងទៅរកក្នុង ទីនោះ ទ្រង់ថ្វាយបង្គំហើយ ឈរប្រថាប់ ត្រាស់យ៉ាងនេះថា បពិត្រលោក ម្ចាស់ សូមលោកម្ចាស់សម្តែងធម៌ដល់ខ្ញុំ ។ ព្រះថេរៈសម្តែងធម៌ដោយ ពុទ្ធលីលា ឈមចុះកាន់សច្ចៈ ៤ ទាក់ទងដោយលក្ខណៈ ៣ ប្រកបដោយ សុញ្ញតា វិចិត្រដោយន័យផ្សេងៗ ឈមចុះក្នុងអមតធម៌ ។

សក្កទេវរាជទ្រង់ស្តាប់ដូច្នោះហើយ កាលទ្រង់ប្រកាសសេចក្តីជ្រះថ្លានៃ ខ្លួន ទើបត្រាស់គាថាទី ១ ថា

> ខ្ញុំនេះ បានស្តាប់ធម៌មានរសច្រើន ជ្រះថ្លាក្រៃលែង វិរាគធម៌
> ដែលលោកសម្តែងហើយ មិនកាន់យក ( ធម៌ណាមួយ )
> ដោយប្រការទាំងពួង ។

បណ្តាបទទាំងនោះ បទថា **ឯស ភិយ្យោ បសីទាមិ សុត្វា ធម្មំ មហារសំ** សេចក្តីថា ខ្ញុំស្តាប់ធម៌ក្នុងសម្នាក់ព្រះសាស្តាច្រើនដង ហើយ ជ្រះថ្លាក្រៃលែងក្នុងធម៌នោះ ឥឡូវនេះ ខ្ញុំស្តាប់ធម៌ដែលលោកម្ចាស់សម្តែង ហើយ មានរសច្រើន ព្រោះវិចិត្រដោយន័យផ្សេងៗ និងព្រោះមានការ ត្រេកអរក្រៃលែង ទើបជ្រះថ្លាក្រៃលែងជាងនោះ ។

បទថា **វិរាគោ ទេសិតោ ធម្មោ អនុបាទាយ សព្វសោ** សេចក្តីថា ឈ្មោះថា **វិរាគោ** ព្រោះប្រាសចាកសង្កិលេសទាំងពួង និងសង្ខារទាំងពួង

បានដល់ ព្រោះញុំាងវិរាគធម៌ឲ្យកើត ឈ្មោះថា **ធេសិតោ ធម្មោ អនុ-ចាទាយ សព្វសោ** ព្រោះមិនប្រកាន់មាំ គឺមិនកាន់យកនូវធម៌ណាមួយ ក្នុងបណ្ដាធម៌ មានរូបជាដើម ព្រោះវិរាគធម៌នោះឯង ហើយជាអ្នកទៅ ដោយអំណាចញុំាងវិមុត្តិឲ្យសម្រេច ។

សក្កទេវរាជ ទ្រង់សរសើរទេសនារបស់ព្រះថេរៈយ៉ាងនេះហើយ ទ្រង់អភិវាទព្រះថេរៈ ហើយយាងទៅកាន់ទីគង់របស់ព្រះសាស្ដា ។

ថ្ងៃមួយ ព្រះថេរៈឃើញវារៈនៃចិត្តរបស់បុថុជ្ជនពួកខ្លះ ដែលត្រូវមិច្ឆា-វិតក្កគ្របសង្កត់ ឮកដល់លំដាប់របស់ចិត្តនោះ ដែលជាបដិបក្ខចំពោះមិច្ឆា-វិតក្កនោះ និងនឹកដល់ភាពដែលខ្លួនមានចិត្តរួចផុតចាកមិច្ឆាវិតក្កនោះ ដោយប្រការទាំងពួង ទើបសម្ដែងសេចក្ដីនោះ ហើយពោល ២ គាថាថា

អារម្មណ៍ទាំងឡាយច្រើន ដ៏វិចិត្រក្នុងលោក លើមណ្ឌលនៃផែនដី
នេះ ទំនងជាញុំាញីនូវសេចក្ដីត្រិះរិះថា ល្អ ដែលប្រកបដោយរាគៈ ។
អរិយសាវកពិចារណាឃើញដោយប្រាជ្ញា ក្នុងកាលណា សេចក្ដី
ត្រិះរិះទាំងឡាយ ក៏ស្ងប់រម្ងាប់ក្នុងកាលណោះ ដូចជាភ្លៀងរម្ងាប់
នូវធូលី ដែលហុយឡើងដោយខ្យល់ ។

បណ្ដាបទទាំងនោះ បទថា **ពហូនិ លោកេ ចិត្រានិ** សេចក្ដីថា ធម្មជាត គឺអារម្មណ៍ដែលវិចិត្រមានក្នុងលោកជាច្រើន ដោយអំណាចនៃរូបជាដើម ដូចជាពណ៌ខៀវ ពណ៌លឿងជាដើម ក្នុងរូបនោះ និងដោយអំណាចនៃស្ត្រី និងបុរសជាដើម ។ ដោយបទថា **អស្មឹ បថវិមណ្ឌលេ** នេះ លោក

ពោលសំដៅយកមនុស្សលោកដែលប្រាកដច្បាស់ ។ បទថា **មវេន្តិ មញ្ញា សង្កប្បំ** សេចក្តីថា ប្រហែលធ្វើឲ្យរីករវរ គឺតាំងនៅ ដូចធ្វើឲ្យការត្រិះរិះខុស ដែលកើតអំពីអយោនិសោមនសិការរីករវរ ដូចធ្វើឲ្យភ្លើងដែលកើតអំពីសេចក្តីព្យាយាមរបស់បុរស និងឈើក្ងួតភ្លើង ដូច្នោះ ដូចអ្វី ដូចអារម្មណ៍ថា ល្អ ដែលប្រកបដោយរាគៈ បានដល់ កាមវិតក្ក ។ កាមវិតក្កនោះ លោកហៅថា ល្អ ព្រោះកាន់យកអាការថា ស្អាត ។

សព្ទថា **ច** ក្នុងបទថា **រជមុហតញ្ច វាតេន** នេះ ត្រឹមតែជានិបាត ។ មហាមេឃធ្លាក់ចុះ គប្បីរម្ងាប់ គឺគប្បីរម្ងាប់ធូលីដែលខ្យល់បក់ទៅ គឺឲ្យតាំងឡើងក្នុងខែចុងក្រោយនៃគិម្ហរដូវ យ៉ាងណា អរិយសាវកពិចារណាឃើញដោយប្រាជ្ញា ក្នុងកាលណា សេចក្តីត្រិះរិះទាំងឡាយ ក៏ស្ងប់រម្ងាប់ក្នុងកាលណោះ ដូច្នោះ ។ អធិប្បាយថា កាលណា ព្រះអរិយសាវក រមែងពិចារណាឃើញដោយបញ្ញា តាមសេចក្តីពិតនូវអារម្មណ៍ទាំងនោះ ដែលវិចិត្រក្នុងលោក ដោយភាពជាហេតុកើតនៃទុក្ខ ដោយមិនទ្រេកអរ ដោយជាទោស និងដោយការរលាស់ចេញ កាលនោះ មិច្ឆាសង្កប្បទាំងអស់ រមែងរម្ងាប់ទៅដោយបញ្ញា ដូចភ្លៀងរម្ងាប់ធូលី ដែលខ្យល់បក់ទៅ ដូច្នោះ ព្រោះកាលសម្មាទិដ្ឋិកើតឡើងហើយ មិច្ឆាសង្កប្បទាំងឡាយ ក៏មិនបាននូវទីពឹង ព្រះថេរៈកាលសម្តែងថា លោកឃើញដោយបញ្ញា ទើបពោល ៣ គាថាថា

អរិយសាវក ពិចារណាឃើញដោយប្រាជ្ញាថា សង្ខារទាំងពួង មិនទៀង ក្នុងកាលណា រមែងនឿយណាយក្នុងសេចក្តីទុក្ខ ក្នុងកាល

ណោះ នេះជាផ្លូវនៃសេចក្ដីបរិសុទ្ធ ។ អរិយសាវក ពិចារណាឃើញដោយប្រាជ្ញាថា សង្ខារទាំងពួងជាទុក្ខ ក្នុងកាលណា រមែងនឿយណាយក្នុងទុក្ខ ក្នុងកាលណោះ នេះជាផ្លូវនៃសេចក្ដីបរិសុទ្ធ ។ អរិយសាវក ពិចារណាឃើញដោយប្រាជ្ញាថា ធម៌ទាំងពួង មិនមែនជារបស់ខ្លួន ក្នុងកាលណា រមែងនឿយណាយក្នុងទុក្ខ ក្នុងកាលណោះ នេះជាផ្លូវនៃសេចក្ដីបរិសុទ្ធ ។

បណ្ដាបទទាំងនោះ បទថា **សព្វេ សង្ខារា** បានដល់ ខន្ធ ៥ ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ទាំងអស់ ដែលសង្គ្រោះដោយអារម្មណ៍ ៦ ។ បទថា **អនិច្ចា** សេចក្ដីថា កាលណា ព្រះអរិយសាវកពិចារណាឃើញដោយបញ្ញាថា សង្ខារទាំងឡាយ ឈ្មោះថា មិនទៀង ព្រោះមានខាងដើម កណ្ដាល និងទីបំផុត ព្រោះមានការមិនទៀងជាទីបំផុត ព្រោះប្រព្រឹត្តទៅមួយជួរខណៈ ព្រោះបែកទៅក្នុងទីនោះៗ ។ បទថា **អថ និព្វិន្ទតិ ទុក្ខេ** សេចក្ដីថា កាលនោះ ព្រះអរិយសាវកនោះ រមែងនឿយណាយក្នុងវដ្តទុក្ខ កាលនឿយណាយតែងចាក់ធ្លុះនូវសច្ចៈ ដោយការកំណត់ដឹងទុក្ខជាដើម ។ បទថា **ឯស មគ្គោ វិសុទ្ធិយា** សេចក្ដីថា វិបស្សនាវិធីដែលពោលហើយនោះ រមែងជាផ្លូវ គឺជាឧបាយគ្រឿងសម្រេចញាណទស្សនវិសុទ្ធិ និងអច្ចន្តវិសុទ្ធិ ( សេចក្ដីបរិសុទ្ធដោយចំណែកមួយ ) ។

បទថា **ទុក្ខា** សេចក្ដីថា ឈ្មោះថា ជាទុក្ខ ព្រោះប្រព្រឹត្តទៅដោយភ័យដែលកើតឡើងចំពោះមុខ ព្រោះត្រូវការកើតឡើង និងការរលត់ទៅគ្របសង្កត់

ជានិច្ច ព្រោះអត់ធន់បានលំបាក និងព្រោះជាបដិបក្ខចំពោះសុខ ។ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ។

បទថា **សព្វេ ធម្មា អនត្តា** សេចក្តីថា ធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ទាំងអស់ ជាអនត្តា តែក្នុងទីនេះ គួរកាន់យកចំពោះធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។ ពិតហើយ ធម៌ទាំងនោះ គប្បីឃើញថា ជាអនត្តា ព្រោះមិនប្រព្រឹត្តទៅក្នុងអំណាច ព្រោះមិនមានខ្លឹមសារ ព្រោះទទេ ព្រោះបដិសេធអត្តា ។ ពាក្យដ៏សេស ដូចគ្នានឹងពាក្យដែលមានក្នុងកាលមុននោះឯង ។

កាលសម្តែងវិបស្សនាវិធីយ៉ាងនេះហើយ កាលសម្តែងកិច្ចដែលខ្លួនធ្វើហើយដោយវិធីនោះ ធ្វើខ្លួនឲ្យដូចអ្នកដទៃ ទើបពោល ២ គាថាថា

> ព្រះថេរៈ ឈ្មោះកោណ្ឌញ្ញៈ ត្រាស់ដឹងតាមព្រះពុទ្ធ ដែលមានសេចក្តីព្យាយាមដ៏ក្លៀវក្លា មានជាតិ និងមរណៈ លះបង់ហើយ បរិបូណ៌ដោយព្រហ្មចរិយធម៌ ។ អន្ទាក់ គឺឱឃៈក្តី ចិត្តរឹងរូសដ៏មាំក្តី មោហៈដូចភ្នំ ដែលទម្លាយបានដោយកម្រក្តី ព្រះអញ្ញាកោណ្ឌញ្ញៈនោះ បានកាត់នូវចិត្តដ៏រឹងរូសផង នូវអន្ទាក់ គឺឱឃៈផង នូវភ្នំ គឺមោហៈដែលបុគ្គលបំបែកបានដោយកម្រផង បានឆ្លងទៅដល់ត្រើយ ជាអ្នកមានឈាន រួចចាកចំណងនៃមារ ។

បណ្តាបទទាំងនោះ បទថា **ពុទ្ធានុពុទ្ធោ** បានដល់ ដែលត្រាស់ដឹងតាមព្រះពុទ្ធទាំងឡាយ អធិប្បាយថា ត្រាស់ដឹងនូវសច្ចៈ ៤ ដែលព្រះសម្មាសម្ពុទ្ធត្រាស់ដឹងហើយ តាមក្រសែទេសនានៃព្រះពុទ្ធទាំងនោះ ឈ្មោះថា

**ថេរោ** ព្រោះប្រកបដោយសារៈ មានសីលសារៈមាំទាំជាដើម ដែលជាអសេក្ខៈ ។ បទថា **កោណ្ឌញ្ញោ** បានដល់ ជាពាក្យហៅតាមគោត្ត ។ បទថា **តិព្វនិក្កមោ** បានដល់ ដែលមានសេចក្ដីព្យាយាមមាំទាំ គឺមានការប្រឹងប្រែងមាំទាំ ។ ឈ្មោះថា **បហីនជាតិមរណោ** ព្រោះហេតុដែលលះជាតិ និងមរណៈបានហើយ ។ បទថា **ព្រហ្មចរិយស្ស កេវលី** សេចក្ដីថា មគ្គព្រហ្មចរិយៈមិនមានចំណែកសេសសល់ ឬមគ្គប្រហ្មចរិយៈ បរិបូណ៌ដោយមិនមានចំណែកសល់ ម្យ៉ាងទៀត មគ្គញ្ញាណ និងផលញ្ញាណ ឈ្មោះថា **កេវលី** ព្រោះមិនលាយឡំដោយកិលេស មគ្គញ្ញាណ និងផលញ្ញាណនោះ មានក្នុងមគ្គព្រហ្មចរិយៈនេះ ព្រោះដូច្នោះ ទើបឈ្មោះថា **កេវលី** ព្រោះមគ្គញ្ញាណ និងផលញ្ញាណទាំងនោះ រមែងមានក្នុងមគ្គព្រហ្មចរិយៈនេះ ព្រោះហេតុនោះ ទើបមគ្គព្រហ្មចរិយៈ ឈ្មោះថា **កេវលី** ។ ព្រោះមគ្គញ្ញាណ និងផលញ្ញាណទាំង ២ នោះ រមែងមានដោយអំណាចនៃមគ្គព្រហ្មចរិយៈ មិនមែនមានដោយប្រការដទៃឡើយ ព្រោះហេតុនោះ ទើបលោកពោលថា **ព្រហ្មចរិយស្ស កេវលី** ដូច្នេះ ។

ឱឃៈ ៤ ដែលលោកពោលយ៉ាងនេះថា កាមោឃៈ ភវោឃៈ ទិដ្ឋោឃៈ អវិជ្ជោឃៈ និងអន្ទាក់ គឺរាគៈដែលលោកពោល ( ក្នុងសំយុត្តនិកាយ សគាថវគ្គ ) យ៉ាងនេះថា អន្ទាក់ គឺរាគៈណា ដែលត្រាច់ទៅលើអាកាស តែងតែប្រព្រឹត្តទៅក្នុងចិត្ត ។ បទថា **ខិលា** បានដល់ ចម្រឹងដោតចិត្ត ៥ យ៉ាងដ៏មាំទាំ ដែលត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនា

នេះ សង្ស័យមិនដាច់ស្រេច មិនជឿស៊ប់ មិនជ្រះថ្លាក្នុងព្រះសាស្តា ... មិនជ្រះថ្លាក្នុងធម៌ ... មិនជ្រះថ្លាក្នុងសង្ឃ ... មិនជ្រះថ្លាក្នុងសិក្ខា ... មានចិត្តរឹងរូសក្នុងពួកសព្រហ្មចារី[១] ដូច្នេះ ។ ឈ្មោះថា **ទុប្បទាលយោ** ព្រោះជនច្រើន មិនអាចទម្លាយបាន ព្រោះហេតុនោះឯង ទើបហៅថា **បញ្ចោ** ព្រោះដូចក្នុំ និងជាការមិនដឹង ដែលលោកពោលដោយន័យជាដើមថា មិនដឹងក្នុងទុក្ខ ដូច្នេះ ។

បុគ្គលណាប្រើដាវ គឺអរិយមគ្គញ្ញាណ កាត់នូវចម្រឹងដោតចិត្ត និងអន្ទាក់ក្នុងធម៌ គឺសង្កិលេស ៤ យ៉ាងនេះ ដែលលោកពោលថា **ចេតោខិលញ្ច ទាសញ្ច** ទាំងអស់នេះជាដើម ដោយប្រការដូច្នេះ ។

បទថា **សេលំ ភេត្វាន ឱត្តិណំ** សេចក្តីថា ប្រើញាណដែលប្រៀបដូចពេជ្រកាត់នូវក្នុំ ដែលសម្រេចហើយអំពីថ្ម គឺការមិនដឹង ដែលបុគ្គលណាម្នាក់ មិនអាចកាត់បានដោយញាណណាមួយ ហើយឆ្លងឱឃៈទាំង ៤ ឈ្មោះថា បានឆ្លងដល់ត្រើយ ព្រោះតាំងនៅក្នុងព្រះនិព្វាន ដែលជាត្រើយអាយនៃឱឃៈទាំង ៤ នោះ ឈ្មោះថា ជាអ្នកមានឈាន ដោយឈានទាំង ២ គឺអារម្មណូបនិជ្ឈាន ១ លក្ខណូបនិជ្ឈាន ១ ។ បទថា **មុត្តោ សោ មារពន្ធនា** សេចក្តីថា ព្រះថេរៈសំដៅយកខ្លួននោះឯងថា ព្រះខីណាស្រពនោះ គឺបែបនោះ ផុតហើយ ផុតស្រឡះហើយ ប្រាសហើយចាកគ្រឿងចង គឺកិលេសមារទាំងអស់ ។

---

១-សេចក្តីពិស្តារ សូមរកកាន់យក ក្នុងបិ.២០ ឃ្នាប ២២៨ ឯណោះចុះ ។

ថ្ងៃមួយ ព្រះថេរៈឃើញភិក្ខុមួយរូប ដែលជាសទ្ធិវិហារិករបស់ខ្លួន ជាមនុស្សខ្ជិលច្រអូស មានព្យាយាមធូរថយ មានចិត្តរាយមាយ មានចិត្តដូចដើមបបុសលើកឡើង ដោយការនៅច្រឡូកច្រឡំ ដោយបុគ្គលដែលមិនជាកល្យាណមិត្ត ទើបទៅក្នុងទីនោះដោយឫទ្ធិ ហើយទូន្មានភិក្ខុនោះថា នៃអាវុសោ លោកកុំធ្វើយ៉ាងនេះឡើយ ចូរលះបង់បុគ្គល ដែលមិនមែនជាកល្យាណមិត្ត គប់រកបុគ្គលដែលជាកល្យាណមិត្តទាំងឡាយ បំពេញសមណធម៌ចុះ ។ ភិក្ខុនោះ មិនអើពើនឹងពាក្យរបស់ព្រះថេរៈៗ ដល់នូវសេចក្ដីសង្វេគ ដោយការមិនអើពើរបស់ភិក្ខុនោះ ទើបតិះដៀលកិច្ចបដិបត្តិខុស ដោយពាក្យជាបុគ្គលាធិដ្ឋាន កាលសរសើរកិច្ចបដិបត្តិប្រពៃ និងការនៅដោយសេចក្ដីស្ងាត់ ទើបពោលគាថាទាំងនេះថា

ភិក្ខុអ្នកមានចិត្តរាយមាយ ឃ្លេងឃ្លោង អាស្រ័យនឹងពួកបាបមិត្រ រមែងត្រូវលេក គឺឧបាយនៃសេចក្ដីក្រោធជ្រមុជ ហើយលិចចុះក្នុងអន្លង់ធំ ។ ឯភិក្ខុមានប្រាជ្ញា មានចិត្តមិនរាយមាយ មិនឃ្លេងឃ្លោង មានប្រាជ្ញាល្អិត សង្រួមឥន្ទ្រិយល្អ មានកល្យាណមិត្រ តែងធ្វើនូវទីបំផុតនៃទុក្ខបាន ។ ជនអ្នកមានអវយវៈប្រាកដស្មើដោយថ្នាំងវល្លិ ស្គមរវីមរវាមដោយសរសៃ ជាអ្នកដឹងប្រមាណក្នុងបាយនិងទឹក មានចិត្តមិនរួញរា ត្រូវរបោម និងមូសទាំងឡាយខាំហើយ ក្នុងព្រៃតូច និងព្រៃធំ ជាអ្នកមានស្មារតី គង់អត់ទ្រាំនៅក្នុងព្រៃនោះបាន ដូចដំរីដ៏ប្រសើរ ( អត់ទ្រាំ ) ក្នុងប្រធាននៃសង្គ្រាម ។ ខ្ញុំ

មិនត្រេកអរនឹងសេចក្តីស្លាប់ មិនត្រេកអរនឹងការរស់នៅ ខ្ញុំរង់ចាំតែកាល (បរិនិព្វាន) ដូចអ្នកធ្វើការឈ្នួល ទន្ទឹងតែអស់ថ្ងៃ ។ ខ្ញុំមិនត្រេកអរនឹងសេចក្តីស្លាប់ មិនត្រេកអរនឹងការរស់នៅ ខ្ញុំជាអ្នកដឹងខ្លួន មានស្មារតី រង់ចាំតែបរិនិព្វានកាល ។ ព្រះសាស្តា ខ្ញុំបានបម្រើហើយ ព្រះពុទ្ធសាសនា ខ្ញុំក៏បានធ្វើហើយ ភារៈដ៏ធ្ងន់ ខ្ញុំបានដាក់ចុះហើយ តណ្ហាជាគ្រឿងនាំទៅកាន់ភព ខ្ញុំដកចោលហើយ ។ កុលបុត្រអ្នកចេញចាកផ្ទះ ចូលកាន់ផ្នួស ដើម្បីប្រយោជន៍ណា ប្រយោជន៍នោះ ខ្ញុំបានដល់ហើយ ខ្ញុំមានប្រយោជន៍អ្វី ដោយសទ្ធិវិហារិក ។

បណ្តាបទទាំងនោះ បទថា **ឧន្នឡោ** សេចក្តីថា ប្រកបដោយការរាយមាយ គឺមានចិត្តមិនតាំងមាំ មានចិត្តរំជើបរំជួល ។

បទថា **ចបលោ** សេចក្តីថា ប្រកបដោយការឃ្លេងឃ្លោង ដោយការតាក់តែងបាត្រ និងចីវរជាដើម គឺជាអ្នកមានចិត្តឡេះឡោះជាប្រក្រតី ។

បទថា **មិត្តេ អាគម្ម បាបកេ** សេចក្តីថា មិនពេញសមណធម៌ ព្រោះមិនជាកល្យាណមិត្ត ។ បទថា **សំសីទតិ មហោឃស្មឹ មិយាបដិ-**

**កុជ្ជិតោ** សេចក្តីថា បុរសធ្លាក់ទៅក្នុងមហាសមុទ្រ ដែលរលកក្នុងមហាសមុទ្រគ្របសង្កត់ កាលមិនអាចងើបក្បាលឡើងបាន លិចចុះក្នុងមហាសមុទ្រនោះឯង យ៉ាងណា បុគ្គលវិលវល់ក្នុងឱឃៈធំ គឺសង្សារ ក៏ដូច្នោះ ត្រូវរលក គឺកោធៈ និងឧបាយាសគ្របសង្កត់ គឺលិចលង់ កាលមិនអាចងើបក្បាល គឺបញ្ញាឡើង ដោយអំណាចវិបស្សនា ទើបលិចចុះក្នុងឱឃៈធំ គឺសង្សារនោះឯង ។

បទថា **និបកោ** បានដល់ ជាអ្នកល្អិតល្អន់ គឺជាអ្នកឈ្លាសក្នុងប្រយោជន៍ខ្លួន និងប្រយោជន៍អ្នកដទៃ ។ បទថា **សំវុតិន្ទ្រិយោ** សេចក្តីថា ជាអ្នកមានឥន្ទ្រិយដែលបិទហើយ ដោយការសង្រួមឥន្ទ្រិយ មានចិត្តជាគម្រប់ ៦ ។ បទថា **កល្យាណមិត្តោ** បានដល់ ជាអ្នកមានកល្យាណមិត្ត ។

បទថា **មេធាវី** បានដល់ ប្រកបដោយបញ្ញា មានឱជៈដែលកើតអំពីធម៌ ។ បទថា **ទុក្ខស្សន្តករោ សិយា** សេចក្តីថា បុគ្គលបែបនោះ គប្បីធ្វើនូវទីបំផុតនៃវដ្ដទុក្ខទាំងពួងបាន ។

បទថា **កាលបព្វង្គសង្កាសោ** ជាដើម ជាពាក្យសម្ដែងដល់ការត្រេកអរក្នុងវិវេក ។ ឯបទថា **នាភិនន្ទាមិ** ជាដើម ជាបទសម្ដែងថា លោកបានធ្វើ

កិច្ចស្រេចហើយ ។ ពាក្យទាំងអស់ មានអត្ថដូចពោលហើយខាងដើមនោះឯង ។ ក្នុងគាថាចុងក្រោយថា **កឹ មេ សទ្ធិវិហារិនា** ព្រះថេរៈសំដៅយកសទ្ធិវិហារិករបស់លោក ។ ព្រោះហេតុនោះ នឹងមានប្រយោជន៍អ្វីសម្រាប់ខ្ញុំ ដោយសទ្ធិវិហារិកដែលប្រដៅក្រ ដែលមិនអើពើ ដូច្នោះ អធិប្បាយថា ខ្ញុំពេញចិត្តការនៅម្នាក់ឯងប៉ុណ្ណោះ ។

ព្រះថេរៈកាលពោលយ៉ាងនេះហើយ បានទៅកាន់ស្រះឆទ្ទន្តនោះឯង ។ លោកនៅក្នុងទីនោះ អស់ ១២ ឆ្នាំ កាលទៀបបរិនិព្វាន ទើបចូលទៅគាល់ព្រះមានព្រះភាគ ឲ្យព្រះមានព្រះភាគទ្រង់អនុញ្ញាតហើយ ទើបទៅបរិនិព្វានក្នុងទីនោះឯង ។៚

**អដ្ឋកថា អញ្ញាកោណ្ឌញ្ញត្ថេរគាថា ចប់**

# សុត្តន្តបិដក

## ឧទាយិត្ថេរគាថា

[ ២៤៨ ] មនុស្សទាំងឡាយ តែងនមស្ការ នូវព្រះសម្ពុទ្ធ ដែលទ្រង់មានព្រះជាតិជាមនុស្ស ទ្រង់បានបង្ហឹកព្រះអង្គត្រឹមត្រូវឥតមានធ្គង មានព្រះហឫទ័យខ្ជាប់ខ្ជួន ទ្រង់ប្រព្រឹត្តក្នុងគន្លងដ៏ប្រសើរ ទ្រង់ពេញព្រះហឫទ័យ ចំពោះឈានជាគ្រឿងស្ងប់ចិត្ត ព្រះអង្គបានដល់នូវត្រើយ នៃធម៌ទាំងពួង ទ្រង់ឆ្លងរំលងនូវសំយោជនៈទាំងពួងហើយ ទ្រង់ ( ចេញផុត ) ចាកព្រៃ គឺកិលេស ស្តេចមកដល់ព្រះនិព្វានហើយ ទ្រង់ពេញព្រះហឫទ័យក្នុងការចេញចាកកាមទាំងឡាយ ដូចមាសចេញផុតចាកជាតុថ្មហើយ ទោះបីពួកទេវតាក៏នមស្ការព្រះអង្គដែរ ពាក្យដូច្នេះនេះ ខ្ញុំព្រះអង្គបានស្តាប់ ( ក្នុងសម្នាក់ ) នៃព្រះអរហន្ត ឯព្រះសម្ពុទ្ធទ្រង់ព្រះនាមថា នាគនោះឯងព្រះអង្គរុងរឿងក្រៃពេក ដូចភ្នំហិមពាន្តដែលរុងរឿង កន្លងនូវពួកភ្នំឯទៀត ព្រះអង្គមានព្រះនាមពិតប្រាកដ ប្រសើរបំផុត ជាងជនទាំងពួង ដែលមាននាមថានាគដែរ ខ្ញុំនឹងថ្លែងនូវពុទ្ធនាគ ដល់អ្នកទាំងឡាយ ព្រះពុទ្ធនាគនោះ មិនធ្វើនូវអំពើអាក្រក់ឡើយ ។ សោរច្ចៈនិងអវិហឹសា ទាំងពីរនោះ ជាបាទា ( ខាងមុខ ) របស់ព្រះពុទ្ធនាគ ។ សតិ និងសម្បជញ្ញៈ ទាំងពីរនោះ ជាបាទាខាងក្រោយ របស់ព្រះពុទ្ធនាគ ។ ព្រះសម្ពុទ្ធជាមហានាគ ទ្រង់មានសទ្ធាជាប្រមោយ មានឧបេក្ខាជាភ្លុកស ។ ព្រះពុទ្ធនាគនោះ មានសតិជាក បញ្ញាជាសិរ

ប្រទេស គំនិតសម្រាប់គិតគូរធម៌ជាចុងប្រមោយ ធម៌ជាផ្ទៃសម្រាប់ដាក់នូវគ្រឿងចម្អែត វិវេកជាកន្ទុយ ។ ព្រះពុទ្ធនាគនោះ មានឈានទ្រង់រីករាយចំពោះខ្យល់ដកដង្ហើម គឺព្រះនិព្វាន មានព្រះហឫទ័យតាំងមាំខាងក្នុង ព្រះពុទ្ធនាគ កាលបើទ្រង់ស្តេចយាត្រា ក៏មានព្រះហឫទ័យខ្ជាប់ខ្ជួន ព្រះពុទ្ធនាគ ទ្រង់ឋិត ក៏មានព្រះហឫទ័យខ្ជាប់ខ្ជួន ព្រះពុទ្ធនាគ ទ្រង់ផ្ទំ ក៏មានព្រះហឫទ័យខ្ជាប់ខ្ជួន ទ្រង់គង់ ក៏មានព្រះហឫទ័យខ្ជាប់ខ្ជួន ព្រះពុទ្ធនាគ ទ្រង់សង្រួម រក្សាទ្វារទាំងអស់ នេះជាសម្បទារបស់ព្រះពុទ្ធនាគ ។ ព្រះពុទ្ធនាគ ទ្រង់សោយតែភោជនដែលឥតទោស មិនសោយនូវភោជន ដែលប្រកបដោយទោស ( កាលបើ ) ទ្រង់បាននូវចង្ហាន់ និងគ្រឿងស្លៀកដណ្តប់ ទ្រង់វៀរនូវការសន្សំទុក ទ្រង់កាត់នូវសំយោជនៈ ដែលជាចំណងតូចធំទាំងអស់ ហើយទ្រង់យាងទៅណាៗ ក៏ស្តេចទៅដោយឥតមានព្រះហឫទ័យអាឡោះអាល័យ ។ ឈូកស ដុះចម្រើនឡើងក្នុងទឹក មិនជាប់ប្រឡាក់ដោយទឹក មានក្លិនក្រអូប ជាទីរីករាយចិត្តយ៉ាងណាមិញ ព្រះពុទ្ធ ទ្រង់កើតក្នុងលោក គង់នៅក្នុងលោក មិនប្រឡាក់ដោយលោក ដូចជាឈូក មិនជាប់ប្រឡាក់ដោយទឹកដូច្នោះឯង ។ គំនរភ្លើងធំ ដែលឆេះសន្ធោ មិនមានចំណី រមែងរលត់ បើទុកជារងើកទាំងឡាយមាននៅ ក៏គេនិយាយថា ភ្លើងរលត់ហើយ ។ ពាក្យឧបមានេះ ជាគ្រឿងបញ្ជាក់នូវសេចក្តី ដែលពួកវិញ្ញូជនបាន

សម្តែងហើយ មហានាគ គឺព្រះខីណាស្រពទាំងឡាយ គង់ដឹងច្បាស់នូវព្រះពុទ្ធនាគ ដែលខ្ញុំជានាគសម្តែងរួចមកហើយនេះថា ព្រះពុទ្ធនាគ ទ្រង់ប្រាសចាករាគៈ ទោសៈ មោហៈហើយ អស់អាសវៈហើយ លះបង់សរីរៈ មិនមានអាសវៈ នឹងបរិនិព្វាន ។

## ឧទាយិត្ថេរ

ឧទ្ទាន មានក្នុងសោឡសកនិបាតនោះ

ព្រះថេរៈពីរអង្គ អ្នកមានឫទ្ធិច្រើននោះ គឺព្រះកោណ្ឌញ្ញៈ ១ ព្រះឧទាយី ១ ពោលនូវគាថា ៣២ ក្នុងសោឡសកនិបាត ។

សោឡសកនិបាត ចប់

# អដ្ឋកថា

## ឧទាយិត្ថេរគាថា

[ ២៤៨ ] គាថារបស់ព្រះឧទាយិត្ថេរ មានពាក្យផ្តើមថា **មនុស្សភូតំ សម្ពុទ្ធំ** ដូច្នេះជាដើម ។ រឿងរ៉ាវរបស់ព្រះថេរៈមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កុលបុត្តនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងក្រុងកបិលពស្តុ មានឈ្មោះថា **ឧទាយី** ចម្រើនវ័យហើយ ឃើញពុទ្ធានុភាពក្នុងសមាគមព្រះញាតិរបស់ព្រះសាស្តា បាននូវសទ្ធា បួសហើយ បំពេញវិបស្សនា មិនយូរប៉ុន្មានក៏សម្រេចអរហត្ត ។ ព្រះឧទាយិត្ថេរមាន ៣ អង្គ គឺកាឡុទាយី កូនអមាត្យដែលពោលមកហើយ ក្នុងកាលមុន ១ លោឡុទាយីកូនរបស់កោរិយព្រាហ្មណ៍ ១ ឧទាយីក្នុងទីនេះឈ្មោះមហាឧទាយីជាកូនព្រាហ្មណ៍ ១ ថ្ងៃមួយ ព្រះឧទាយិត្ថេរនេះ កាលព្រះសាស្តាទ្រង់សម្តែងនាគោបមសូត្រ ធ្វើនូវដំរីស ប្រដាប់ដោយគ្រឿងអលង្ការទាំងពួង ដែលមហាជននាំគ្នាសរសើរ ឲ្យជាអត្ថុប្បត្តិហេតុ ក្នុងកាលចប់ទេសនា នឹកដល់គុណរបស់ព្រះសាស្តា តាមសមគួរដល់កម្លាំងញាណរបស់ខ្លួន ជាអ្នកមានចិត្តដែលបីតិ មានព្រះពុទ្ធជាអារម្មណ៍ជាស់តឿន ទើបគិតថា មហាជននេះសរសើរនាគ ដែលជាសត្វតិរច្ឆាន មិនសរសើរមហានាគ គឺព្រះពុទ្ធ ណ្ហើយចុះ អញនឹងធ្វើគុណដ៏រមហាគន្ធៈ គឺព្រះពុទ្ធឲ្យប្រាកដ ដូច្នេះហើយ កាលសរសើរព្រះសាស្តា ទើបពោលគាថាទាំងនេះថា

មនុស្សទាំងឡាយ តែងនមស្ការនូវព្រះសម្ពុទ្ធ ដែលទ្រង់មាន ព្រះជាតិជាមនុស្ស ទ្រង់បានបង្វឹកព្រះអង្គត្រឹមត្រូវ ឥតមានធ្លង មានព្រះហឫទ័យខ្ជាប់ខ្ជួន ទ្រង់ប្រព្រឹត្តក្នុងគន្លងដ៏ប្រសើរ ទ្រង់ពេញព្រះហឫទ័យ ចំពោះឈានជាគ្រឿងស្ងប់ចិត្ត ព្រះអង្គបានដល់នូវត្រើយ នៃធម៌ទាំងពួង ទ្រង់ឆ្លងរំលង នូវសំយោជនៈទាំងពួងហើយ ទ្រង់ ( ចេញផុត ) ចាកព្រៃគឺកិលេស ស្តេចមកដល់ព្រះនិព្វានហើយ ទ្រង់ពេញព្រះហឫទ័យក្នុងការចេញចាកកាមទាំងឡាយ ដូចមាសចេញផុតចាកជាតុថ្មហើយ ទោះបីពួកទេវតាក៏នមស្ការព្រះអង្គដែរ ពាក្យដូច្នេះនេះ ខ្ញុំព្រះអង្គបានស្តាប់ ( ក្នុងសម្នាក់ ) នៃព្រះអរហន្ត ឯព្រះសម្ពុទ្ធទ្រង់ព្រះនាមថានាគនោះឯង ព្រះអង្គរុងរឿងក្រៃពេក ដូចភ្នំហិមពាន្តដែលរុងរឿងកន្លងនូវពួកភ្នំឯទៀត ព្រះអង្គមានព្រះនាមពិតប្រាកដ ប្រសើរបំផុត ជាងជនទាំងពួង ដែលមាននាមថានាគដែរ ខ្ញុំនឹងថ្លែងនូវពុទ្ធនាគ ដល់អ្នកទាំងឡាយ ព្រះពុទ្ធនាគនោះ មិនធ្វើនូវអំពើអាក្រក់ឡើយ ។ សោរច្ចៈ និងអវិហឹសា ទាំងពីរនោះ ជាបាទា ( ខាងមុខ ) របស់ព្រះពុទ្ធនាគ ។ សតិ និងសម្បជញ្ញៈទាំងពីរនោះ ជាបាទាខាងក្រោយ របស់ព្រះពុទ្ធនាគ ។ ព្រះសម្ពុទ្ធជាមហានាគ ទ្រង់មានសទ្ធាជាប្រមោយ មានឧបេក្ខាជាភ្លុកស ។ ព្រះពុទ្ធនាគនោះ មានសតិជាក បញ្ញាជាសិរប្រទេស គំនិតសម្រាប់

គិតគូរធម៌ជាចុងប្រមោយ ធម៌ជាផ្ទៃសម្រាប់ដាក់នូវគ្រឿងចម្អែត វិវេកជាកន្ទុយ ។ ព្រះពុទ្ធនាគនោះមានឈាន ទ្រង់រីករាយចំពោះខ្យល់ដកដង្ហើម គឺព្រះនិញ្វន មានព្រះហឫទ័យតាំងមាំខាងក្នុងព្រះពុទ្ធនាគ កាលបើទ្រង់ស្តេចយាត្រា ក៏មានព្រះហឫទ័យខ្ជាប់ខ្ជួនព្រះពុទ្ធនាគ ទ្រង់ឋិត ក៏មានព្រះហឫទ័យខ្ជាប់ខ្ជួន ព្រះពុទ្ធនាគទ្រង់ផ្ទំ ក៏មានព្រះហឫទ័យខ្ជាប់ខ្ជួន ទ្រង់គង់ ក៏មានព្រះហឫទ័យខ្ជាប់ខ្ជួន ព្រះពុទ្ធនាគ ទ្រង់សង្រួម រក្សាទ្វារទាំងអស់ នេះជាសម្បទារបស់ព្រះពុទ្ធនាគ ។ ព្រះពុទ្ធនាគ ទ្រង់សោយតែភោជនដែលឥតទោស មិនសោយនូវភោជន ដែលប្រកបដោយទោស ( កាលបើ ) ទ្រង់បាននូវចង្ហាន់ និងគ្រឿងស្លៀកដណ្តប់ ទ្រង់វៀរនូវការសន្សំទុក ទ្រង់កាត់នូវសំយោជនៈ ដែលជាចំណងតូចធំទាំងអស់ហើយ ទ្រង់យាងទៅណាៗ ក៏ស្តេចទៅដោយឥតមានព្រះហឫទ័យអាឡោះអាល័យ ។ ឈូកស ដុះចម្រើនឡើងក្នុងទឹក មិនជាប់ប្រឡាក់ដោយទឹក មានក្លិនក្រអូប ជាទីរីករាយចិត្ត យ៉ាងណាមិញ ព្រះពុទ្ធ ទ្រង់កើតក្នុងលោក គង់នៅក្នុងលោក មិនប្រឡាក់ដោយលោក ដូចជាឈូក មិនជាប់ប្រឡាក់ដោយទឹក ដូច្នោះឯង ។ គំនរភ្លើងធំ ដែលឆេះសន្ធោ មិនមានចំណី រមែងរលត់ បើទុកជារងើកទាំងឡាយ មាននៅ ក៏គេនិយាយថា ភ្លើងរលត់ហើយ ។ ពាក្យឧបមានេះ ជាគ្រឿងបញ្ជាក់នូវសេចក្តី ដែល

ពួកវិញ្ញូជនបានសម្តែងហើយ មហានាគ គឺព្រះខីណាស្រពទាំង-ឡាយ គន់ដឹងច្បាស់នូវព្រះពុទ្ធនាគ ដែលខ្ញុំជានាគសម្តែងរួចមក ហើយនេះថា ព្រះពុទ្ធនាគ ទ្រង់ប្រាសចាករាគៈ ទោសៈ មោហៈ ហើយ អស់អាសវៈហើយ លះបង់សរីរៈ មិនមានអាសវៈ នឹង បរិនិព្វាន ។

បណ្តាបទទាំងនោះ បទថា **មនុស្សភូតំ** សេចក្តីថា ជាអ្នកកើតក្នុង មនុស្ស ឬបាននូវអត្តភាពជាមនុស្ស ។ ពិតហើយ ព្រះសាស្តាសូម្បីទ្រង់ផុត ចាកគតិទាំងពួង ព្រោះទ្រង់សម្រេចអាសវក្ខយញ្ញាណ ដោយអំណាចដែល ទ្រង់បដិសន្ធិក្នុងអត្តភាពចុងក្រោយ ក៏ហៅថាមនុស្សដូចគ្នា តែដោយអំណាច នៃគុណ ទ្រង់ជាទេវតាក្រៃលែងជាងទេវតា ជាព្រហ្មក្រៃលែងជាងព្រហ្ម ។ បទថា **សម្ពុទ្ធំ** បានដល់ ព្រោះត្រាស់ដឹងធម៌ដោយព្រះអង្គឯង ។

បទថា **អត្តទន្តំ** បានដល់ ជាមានខ្លួនទូន្មានហើយដោយខ្លួនឯង ។ ពិតហើយ ព្រះមានព្រះភាគ ទ្រង់ទូន្មានព្រះអង្គដោយការទូន្មានយ៉ាងឧត្តម តាមផ្លូវចក្ខុទ្វារ ។បេ។ តាមផ្លូវចិត្តទ្វារ ដោយអរិយមគ្គដែលទ្រង់ឲ្យកើតឡើង ដោយព្រះអង្គឯង ។ បទថា **សមាហិតំ** បានដល់ តាំងមាំហើយដោយ សមាធិ ៨ យ៉ាង និងដោយសមាធិដែលកើតអំពីមគ្គ និងផល ។

បទថា **ឥរិយាមានំ ព្រហ្មបថេ** សេចក្តីថា ប្រព្រឹត្តទៅក្នុងផ្លូវ គឺ ព្រហ្មវិហារធម៌ទាំង ៤ ឬក្នុងផ្លូវ គឺផលសមាបត្តិដ៏ប្រសើរ គឺឧត្តមដោយ អំណាចការចូលសមាបត្តិ ។ ព្រះមានព្រះភាគ មិនយាងទៅក្នុងគន្លងដ៏ប្រសើរ

តាមដែលពោលហើយ អស់កាលទាំងមូលក៏ពិត តែទោះជាយ៉ាងនោះ ព្រះឧទាយិត្ថេរក៏ពោលថា **ឥរិយាមានំ** ព្រោះអាស្រ័យការអាចប្រព្រឹត្តទៅ និងការបង្អោនទៅក្នុងផ្លូវដ៏ប្រសើរនោះ ។

បទថា **ចិត្តស្សូបសមេ រតំ** សេចក្ដីថា ត្រេកអរក្រៃលែងក្នុងការស្ងប់សង្ខារទាំងពួង គឺក្នុងព្រះនិព្វានដែលជាហេតុស្ងប់នៃចិត្ត ។

បទថា **យំ មនុស្សា នមស្សន្តិ សព្វធម្មាន បារគុំ** សេចក្ដីថា មនុស្សទាំងឡាយ មានក្សត្រ និងបណ្ឌិតជាដើម រមែងនមស្ការនូវព្រះសម្មាសម្ពុទ្ធអង្គណា ដែលជាអ្នកដល់ត្រើយ គឺសម្រេចនូវធម៌ដ៏ឧត្តម ៦ យ៉ាង គឺដល់ត្រើយនៃអភិញ្ញា ១ ដល់នូវត្រើយនៃបរិញ្ញា ១ ដល់នូវត្រើយនៃបហានៈ ១ ដល់នូវត្រើយនៃភាវនា ១ ដល់នូវត្រើយនៃសច្ឆិកិរិយា ១ ដល់នូវត្រើយនៃសមាបត្តិ ១ នៃធម៌មានខន្ធ និងអាយតនៈជាដើម កាលបូជាដោយកិច្ចបដិបត្តិធម៌ សមគួរដល់ធម៌ រមែងជាអ្នកបង្អោនទៅ ឱនទៅ ទោរទន់ទៅក្នុងព្រះសម្មាសម្ពុទ្ធនោះ ដោយកាយ វាចា និងចិត្ត ។

បទថា **ទេវាបិ តំ នមស្សន្តិ** សេចក្ដីថា មិនមែនពួកមនុស្សតែម្យ៉ាងនោះទេ ដោយពិត សូម្បីទេវតាទាំងឡាយក្នុងលោកធាតុ មិនមានប្រមាណក៏នមស្ការព្រះពុទ្ធអង្គនោះ ។

ដោយបទថា **ឥតិ មេ អរហតោ សុតំ** នេះ លោកសម្ដែងថា ពាក្យយ៉ាងនេះ គឺពាក្យដែលខ្ញុំស្ដាប់មកហើយយ៉ាងនេះ ក្នុងសម្នាក់របស់ព្រះមានព្រះភាគដែលជាអរហន្តជាដើម ដោយហេតុមាន **អរហំ** ជាដើម និងក្នុង

សម្នាក់របស់ព្រះធម្មសេនាបតី ដែលពោលពាក្យថា **សត្ថា ទេវមនុស្សានំ** ជាដើម ។

បទថា **សព្វសំយោជនាតីតំ** សេចក្ដីថា ជាអ្នកឈានកន្លងនូវសំយោជនៈទាំង ១០ ព្រមទាំងវាសនា ដោយមគ្គ ៤ តាមសមគួរ ។

បទថា **វនា និព្វនមាគតំ** បានដល់ ចេញអំពីព្រៃ គឺកិលេស ចូលដល់ការមិនមានព្រៃ ដែលវៀរចាកកិលេសនោះ ។

បទថា **កាមេហិ នេក្ខម្មរតំ** បានដល់ ចេញអំពីកាមដោយប្រការទាំងពួង ហើយត្រេកអរក្នុងនេក្ខម្មៈ ដូចជាបព្វជ្ជា ឈាន និងវិបស្សនា ជាដើម ។

បទថា **មុត្តំ សេលាវ កញ្ចនំ** សេចក្ដីថា ដូចមាសដែលផុតហើយចាកថ្ម ព្រោះមានសភាវៈជាមាសពិត ដែលកម្ចាត់វត្ថុមិនមែនមាសចេញហើយ ។ មានពាក្យអធិប្បាយប្រកបសេចក្ដីថា សូម្បីទេវតាទាំងឡាយក៏នមស្ការព្រះសម្មាសម្ពុទ្ធអង្គនោះ ។

បទថា **ស វេ អច្ចរុចិ នាគោ** សេចក្ដីថា ទ្រង់មិនធ្វើបាបដោយចំណែកមួយ មិនទៅកាន់កពប្ថី ជាអ្នកមានកម្លាំងដូចដំរី ព្រោះហេតុនោះ ទើបព្រះសម្មាសម្ពុទ្ធទ្រង់បាននាមថា **នាគ**។

បទថា **អច្ចរុចិ** សេចក្ដីថា ទ្រង់រុងរឿងផុតលោកនេះ ព្រមទាំងទេវលោក ដោយសេចក្ដីរុងរឿងនៃព្រះកាយ និងព្រះញាណរបស់ព្រះអង្គ ។ សេចក្ដីនេះដូចអ្វី ដូចភ្នំហិមពាន្តដែលរុងរឿងកន្លងនូវពួកភ្នំឯទៀត អធិប្បាយ

ថា ទ្រង់រុងរឿងក្រៃលែង ដូចស្តេចភ្នំហិមពាន្ត រុងរឿងកន្ទង់ភ្នំដទៃដោយគុណ ដូចជាការមាំទាំ ធ្ងន់ និងមានថ្មច្រើនជាដើម ។

បទថា **សព្វេសំ នាគនាមានំ** បានដល់ នាគ គឺពស់ នាគ គឺដំរី នាគ គឺបុរស ។ ម្យ៉ាងទៀត បានដល់ សេក្ខនាគ នាគ គឺព្រះសេក្ខៈ អសេក្ខនាគ នាគ គឺព្រះអសេក្ខៈ បច្ចេកពុទ្ធនាគ នាគ គឺព្រះបច្ចេកពុទ្ធ ។

បទថា **សច្ចនាមោ** បានដល់ ឈ្មោះថា នាគតាមសេចក្តីពិត ។ ម្យ៉ាងទៀត ព្រះឧទាយិត្ថេរ រមែងពោលនូវភាពជានាគតាមសេចក្តីពិត ដោយខ្លួនឯងនោះឯង ដោយពាក្យថា **ន ហិ អាគុំ ករោតិ** ដូច្នេះជាដើម ។

ឥឡូវនេះ កាលសម្តែងដល់ព្រះពុទ្ធនាគដោយអវយវៈ និងដើម្បីសម្តែងដល់ឈ្មោះមុន ទើបព្រះថេរៈពោលថា **ន ហិ អាគុំ ករោតិ សោ** អធិប្បាយថា ឈ្មោះថា នាគ ព្រោះមិនធ្វើបាប ដោយប្រការទាំងពួង ។

បទថា **សោរច្ចំ** បានដល់ សីល ។ បទថា **អវិហឹសា** បានដល់ករុណា ។ ការស្ងប់ស្ងៀម និងការមិនមានបៀតបៀន សមជាជើងមុខរបស់ព្រះពុទ្ធនាគ ព្រោះការធ្វើវិគ្គហៈថា **សោរច្ច** និង **អវិហឹសា** ទាំង ២ នោះ ជាប្រធាននៃគំនរគុណទាំងពួង ព្រោះហេតុនោះ ទើបព្រះថេរៈពោលថា សោរច្ច និងអវិហឹសា ទាំងពីរនោះ ជាបាទា ( ខាងមុខ ) របស់ព្រះពុទ្ធនាគ ។

កាលពោលដល់ធម៌ ដែលដូចជាជើងក្រោយ ទើបព្រះថេរៈពោលថា សតិ និងសម្បជញ្ញៈ ទាំងពីរនោះ ជាបាទាខាងក្រោយ ។ បាលីថា **ត្យាបរេ** ដូច្នេះក៏មាន ។ ចែកបទថា **តេ អបរេ** ដូច្នេះ ។ សទ្ធាក្នុងការជឿធម៌

ដែលមិនមានទោស ឈ្មោះថា **សទ្ធា ហត្ថោ** ព្រោះសទ្ធាក្នុងការទាញយកធម៌ ដែលមិនមានទោស ដូចជាប្រមោយរបស់ដំរីនោះ ឈ្មោះថា **ឧបេក្ខា-សេតទន្តវា** ព្រោះឧបេក្ខាដែលជាប្រភេទរបស់ញាណ ដែលជាវេទនាបរិសុទ្ធល្អ ជាភ្លុកសរបស់ដំរីនោះ មានបញ្ញាជាសិរប្រសើរ មានសតិជាក ព្រោះហេតុនោះ ទើបព្រះថេរៈពោលថា មានសតិជាក បញ្ញាជាសិរប្រសើរ ។

បទថា **វីមំសា ធម្មចិន្តនា** សេចក្តីថា ការស្ទាប និងការហិត ហិតក្លិនវត្ថុ នូវរបស់ដែលគួរបរិភោគ និងមិនគួរបរិភោគដោយប្រមោយ ជាបញ្ញាគ្រឿងពិចារណារបស់ហត្ថិនាគ យ៉ាងណា ការគិតនូវធម៌ មានកុសលជាដើម ឈ្មោះថា ជាបញ្ញាគ្រឿងពិចារណារបស់ព្រះពុទ្ធនាគ ក៏យ៉ាងនោះ ។ ឈ្មោះថា **សមាវាសោ** ព្រោះដែលនៅស្មើគ្នា បានដល់ ទីសម្រាប់ទ្រទ្រង់ គឺផ្ទៃដែលជាទីទទួល ។ ធម៌ ពោល គឺសមថៈ និងវិបស្សនា ជាផ្ទៃសម្រាប់ទទួលរបស់ព្រះពុទ្ធនាគនោះ ព្រោះជាទីទទួលនូវអភិញ្ញា និងសមថៈ ព្រោះហេតុនោះ ទើបព្រះពុទ្ធនាគ ឈ្មោះថា **ធម្មកុច្ឆិ សមាវាសោ** ។

បទថា **វិវេកោ** បានដល់ ឧបធិវិវេក ។ បទថា **តស្ស** បានដល់ របស់ព្រះពុទ្ធនាគ ។ ឈ្មោះថា **វាលធិ** ព្រោះជាអវយវៈដែលនៅខាងក្រោយ ។

បទថា **ឈាយី** បានដល់ មានប្រក្រតីសម្លឹងឈាន ព្រោះសម្លឹងដោយអារម្មណូបនិជ្ឈាន ។ បទថា **អស្សាសរតោ** សេចក្តីថា ត្រេកអរហើយ ក្នុងនិព្វានដែលជាទីស្រឡះ ដូចជាខ្យល់ដង្ហើមដ៏ក្រៃលែង ។

បទថា **អជ្ឈត្តំ សុសមាហិតោ** សេចក្តីថា មានចិត្តតាំងមាំដោយល្អ

ក្នុងផលសមាបត្តិដែលជាអារម្មណ៍ខាងក្នុង ដើម្បីសម្តែងថា ការតាំងមាំនេះប្រព្រឹត្តទៅបានសព្វកាលដោយល្អ ទើបព្រះថេរៈពោលថា កាលបើទ្រង់យាត្រា ក៏មានព្រះហឫទ័យខ្ជាប់ខ្ជួន ដូច្នេះ ។

ពិតហើយ ព្រះមានព្រះភាគ ទ្រង់មានព្រះហឫទ័យតាំងមាំដោយល្អជានិច្ច ព្រោះមិនមានការរាយមាយ ព្រោះលះឧទ្ធច្ចៈបាន ព្រោះហេតុនោះ ទោះទ្រង់សម្រេចឥរិយាបថណាមួយ ក៏មានព្រះហឫទ័យតាំងមាំ សម្រេចឥរិយាបថនោះៗ ។

បទថា **សព្វត្ថ** បានដល់ ក្នុងអារម្មណ៍ទាំងពួង និងរាំងការប្រព្រឹត្តទៅក្នុងទ្វារទាំងពួង ដោយអាការទាំងពួង ដោយហេតុនោះ ទើបលោកពោលថា កាយកម្មទាំងពួង មានញាណប្រធាន ប្រព្រឹត្តទៅតាមញាណ ។

បទថា **ឯសា នាគស្ស សម្បទា** សេចក្តីថា នេះជាគុណសម្បត្តិ គឺជាភាពបរិបូណ៌ដោយគុណនៃដំរីត្រកូលគន្ធៈ គឺព្រះសម្ពុទ្ធ តាមដែលពោលហើយ និងកំពុងពោល ដោយន័យជាដើមថា **ន ហិ អាគុំ ករោតិ សោ** ឬដោយន័យជាដើមថា **សម្ពុទ្ធំ** ដូច្នេះ ។

បទថា **ភុញ្ជតិ អនវជ្ជានិ** មានពាក្យអធិប្បាយប្រកបថា បរិភោគវត្ថុដែលមិនត្រូវតិះដៀល ព្រោះដល់ព្រមដោយសម្មាអាជីវៈ ដែលជាបុណ្យសន្សំមកយ៉ាងខ្ពស់ និងមិនបរិភោគវត្ថុដែលមានទោស គឺវត្ថុដែលត្រូវតិះដៀល ព្រោះលះនូវមិច្ឆាអាជីវៈ និងអាសវៈ ព្រមទាំងវាសនា ដោយប្រការទាំងពួង ។ម្យ៉ាងទៀត កាលបរិភោគវត្ថុដែលមិនមានទោស រមែង

បរិភោគវៀរនូវការសន្សំ ។

បទថា **សំយោជនំ** បានដល់ សំយោជនៈទាំង ១០ ដែលអាចឲ្យសត្វលិចចុះក្នុងវដ្តៈ ព្រោះប្រកបសត្វក្នុងវដ្តទុក្ខ ។

បទថា **អណុំ ថូលំ** បានដល់ តូច និងធំ ។ បទថា **សព្វំ ឆេត្វាន ពន្ធនំ** សេចក្ដីថា កាត់នូវចំណង គឺកិលេសបានជាសមុច្ឆេទ ដោយមគ្គញាណ ។

បទថា **យេន** បានដល់ ដោយទិសាភាគណាមួយ មានយោជនាថា ដូចផ្កាឈូកកើតក្នុងទឹក រមែងដុះក្នុងទឹក តែមិនជាប់ដោយទឹក ព្រោះមានសភាវៈមិនជាប់ដោយទឹក យ៉ាងណា ព្រះពុទ្ធក៏ដូច្នោះដូចគ្នា កើតក្នុងលោក នៅក្នុងលោក តែមិនជាប់ដោយលោក ព្រោះមិនមានគ្រឿងបូកលាប គឺតណ្ហា ទិដ្ឋិ និងមានះ ។

បទថា **គិនិ** ប្រែថា ភ្លើង ។ បទថា **អនាហារោ** បានដល់ មិនមានកំពួម ។

បទថា **អត្ថស្សាយំ វិញ្ញាបនី** សេចក្ដីថា ធ្វើឲ្យអ្នកដទៃដឹង គឺការប្រកាសអត្ថនៃឧបមេយ្យ ពោល គឺគុណរបស់ព្រះសាស្ដា នេះឈ្មោះថា ជាឧបមានៃនាគ គឺដីរដ៏ប្រសើរ ។

បទថា **វិញ្ញូហិ** បានដល់ ដែលកំណត់ដឹងសច្ចធម៌ ដែលព្រះសាស្ដាទ្រង់ត្រាស់ដឹងហើយ ដោយពាក្យនេះ ព្រះឧទាយិត្ថេរពោលសំដៅដល់ខ្លួនឯង ។

*បទថា* **វិញ្ញិស្សន្តិ** *ជាដើម ជាពាក្យពោលដល់ហេតុ អធិប្បាយថា ព្រោះហេតុដែលមហានាគ គឺព្រះវិញ្ញាណស្រេចតាំងនៅក្នុងវិស័យរបស់ខ្លួន និងដឹងច្បាស់នូវនាគ គឺដំរីដែលមានក្លិនក្រអូប គឺព្រះតថាគតដែលខ្ញុំជានាគសម្តែងមកហើយ ដូច្នោះ ដើម្បីឲ្យបុថុជ្ជនដទៃយល់ ទើបខ្ញុំពោលឧបមានេះ ។*

*បទថា* **សរីរំ វិជហំ នាគោ បរិនិព្វិស្សត្យនាសវោ** *សេចក្តីថា ដំរី គឺព្រះសម្មាសម្ពុទ្ធ ឈ្មោះថា ជាអ្នកមិនមានអាសវៈ ដោយសឧបាទិសេស-បរិនិព្វាន ត្រង់មណ្ឌលពោធិព្រឹក្ស ឥឡូវនេះ កាលទ្រង់លះរាងកាយ គឺអត្តភាព នឹងបរិនិព្វានដោយខន្ធបរិនិព្វាន ។*

*ព្រះថេរៈកាលស្តាប់ដោយឧបមា ១៤ យ៉ាងនេះហើយ បានពណ៌នាព្រះគុណរបស់ព្រះសាស្តាដោយ ១៦ គាថា មាន ៦៤ បាទ ហើយឲ្យទេសនាចប់ ដោយអនុបាទិសេសនិព្វានធាតុ ៕*

**អដ្ឋកថា ឧទាយិត្ថេរគាថា ចប់**

**ថេរគាថា សោឡសកនិបាត ចប់**

# ក្បាលទី ៤២

# សុត្តន្តបិដក ចាលីប្រែ -៥៦

## សន្ទឹកចង្អុលប្រាប់មាតិកា


| មាតិកា | | លេខទំព័រ |
|---|---|---|
| អគ្គណិកភារទ្វាជត្ថេរគាថា | ...... ...... ...... ...... | ២ |
| អដ្ឋកថាអគ្គណិកភារទ្វាជត្ថេរគាថា | ...... ...... ...... ...... | ៣ |
| បច្ចយត្ថេរគាថា | ...... ...... ...... ...... | ៩ |
| អដ្ឋកថា បច្ចយត្ថេរគាថា | ...... ...... ...... ...... | ៩ |
| ពាកុលត្ថេរគាថា | ...... ...... ...... ...... | ១៤ |
| អដ្ឋកថា ពាកុលត្ថេរគាថា | ...... ...... ...... ...... | ១៤ |
| ធនិយត្ថេរគាថា | ...... ...... ...... ...... | ២៤ |
| អដ្ឋកថា ធនិយត្ថេរគាថា | ...... ...... ...... ...... | ២៤ |
| មាតង្គបុត្តត្ថេរគាថា | ...... ...... ...... ...... | ២៩ |
| អដ្ឋកថា មាតង្គបុត្តត្ថេរគាថា | ...... ...... ...... ...... | ២៩ |
| ខុជ្ជសោភិតត្ថេរគាថា | ...... ...... ...... ...... | ៣៥ |
| អដ្ឋកថា ខុជ្ជសោភិតត្ថេរគាថា | ...... ...... ...... ...... | ៣៦ |
| វារណត្ថេរគាថា | ...... ...... ...... ...... | ៤២ |
| អដ្ឋកថា វារណត្ថេរគាថា | ...... ...... ...... ...... | ៤២ |
| បស្សិកត្ថេរគាថា | ...... ...... ...... ...... | ៤៩ |
| អដ្ឋកថា បស្សិកត្ថេរគាថា | ...... ...... ...... ...... | ៥០ |
| យសោជត្ថេរគាថា | ...... ...... ...... ...... | ៥៤ |
| អដ្ឋកថា យសោជត្ថេរគាថា | ...... ...... ...... ...... | ៥៥ |
| សាដិមត្តិយត្ថេរគាថា | ...... ...... ...... ...... | ៦២ |

អដ្ឋកថា សាធិមត្តិយត្ថេរគាថា ...... ...... ...... ...... ៦៣
ឧបាលិត្ថេរគាថា ...... ...... ...... ...... ៦៨
អដ្ឋកថា ឧបាលិត្ថេរគាថា ...... ...... ...... ...... ៦៨
ឧត្តរបាលត្ថេរគាថា ...... ...... ...... ...... ៩៣
អដ្ឋកថា ឧត្តរបាលត្ថេរគាថា ...... ...... ...... ...... ៩៣
អភិភូតត្ថេរគាថា ...... ...... ...... ...... ៩៨
អដ្ឋកថា អភិភូតត្ថេរគាថា ...... ...... ...... ...... ៩៨
គោតមត្ថេរគាថា ...... ...... ...... ...... ១០៤
អដ្ឋកថា គោមត្ថេរគាថា ...... ...... ...... ...... ១០៥
ហារិតត្ថេរគាថា ...... ...... ...... ...... ១១២
អដ្ឋកថា ហារិតត្ថេរគាថា ...... ...... ...... ...... ១១២
វិមលត្ថេរគាថា ...... ...... ...... ...... ១១៦
អដ្ឋកថា វិមលត្ថេរគាថា ...... ...... ...... ...... ១១៧

## ចតុក្កនិបាត

នាគសមាលត្ថេរគាថា ...... ...... ...... ...... ១២១
អដ្ឋកថា នាគសមាលត្ថេរគាថា ...... ...... ...... ...... ១២២
ភគុត្ថេរគាថា ...... ...... ...... ...... ១២៨
អដ្ឋកថា ភគុត្ថេរគាថា ...... ...... ...... ...... ១២៩
សភិយត្ថេរគាថា ...... ...... ...... ...... ១៣៣
អដ្ឋកថា សភិយត្ថេរគាថា ...... ...... ...... ...... ១៣៤
នន្ទកត្ថេរគាថា ...... ...... ...... ...... ១៤២
អដ្ឋកថា នន្ទកត្ថេរគាថា ...... ...... ...... ...... ១៤៣
ជម្ពុកត្ថេរគាថា ...... ...... ...... ...... ១៤៩
អដ្ឋកថា ជម្ពុកត្ថេរគាថា ...... ...... ...... ...... ១៤៩

សេនកត្ថេរគាថា ...... ...... ...... ...... ១៥៦
អដ្ឋកថាសេនកត្ថេរគាថា ...... ...... ...... ...... ១៥៦
សម្ភូតត្ថេរគាថា ...... ...... ...... ...... ១៦៣
អដ្ឋកថាសម្ភូតត្ថេរគាថា ...... ...... ...... ...... ១៦៤
រាហុលត្ថេរគាថា ...... ...... ...... ...... ១៦៩
អដ្ឋកថារាហុលត្ថេរគាថា ...... ...... ...... ...... ១៧០
ចន្ទនត្ថេរគាថា ...... ...... ...... ...... ១៧៧
អដ្ឋកថាចន្ទនត្ថេរគាថា ...... ...... ...... ...... ១៧៧
ធម្មិកត្ថេរគាថា ...... ...... ...... ...... ១៨១
អដ្ឋកថាធម្មិកត្ថេរគាថា ...... ...... ...... ...... ១៨២
សប្បកត្ថេរគាថា ...... ...... ...... ...... ១៨៩
អដ្ឋកថាសប្បកត្ថេរគាថា ...... ...... ...... ...... ១៩០
មុទិតត្ថេរគាថា ...... ...... ...... ...... ១៩៥
អដ្ឋកថាមុទិតត្ថេរគាថា ...... ...... ...... ...... ១៩៦

## ថេរគាថា បញ្ចកនិបាត

រាជទត្តត្ថេរគាថ ...... ...... ...... ...... ២០០
អដ្ឋកថារាជទត្តត្ថេរគាថា ...... ...... ...... ...... ២០១
សុភូតត្ថេរគាថា ...... ...... ...... ...... ២០៧
អដ្ឋកថាសុភូតត្ថេរគាថា ...... ...... ...... ...... ២០៨
គិរិមានន្ទត្ថេរគាថា ...... ...... ...... ...... ២១៧
អដ្ឋកថាគិរិមានន្ទត្ថេរគាថា ...... ...... ...... ...... ២១៨
សុមនត្ថេរគាថា ...... ...... ...... ...... ២២៥
អដ្ឋកថាសុមនត្ថេរគាថា ...... ...... ...... ...... ២២៦
វឌ្ឍត្ថេរគាថា ...... ...... ...... ...... ២៣១

អដ្ឋកថាវឌ្ឍត្ថេរគាថា ...... ...... ...... ...... ២៣២
នទីកស្សបត្ថេរគាថា ...... ...... ...... ...... ២៣៦
អដ្ឋកថានទីកស្សបត្ថេរគាថា ...... ...... ...... ...... ២៣៧
គយាកស្សបត្ថេរគាថា ...... ...... ...... ...... ២៤៣
អដ្ឋកថាគយាកស្សបត្ថេរគាថា ...... ...... ...... ...... ២៤៤
វក្កលិត្ថេរគាថា ...... ...... ...... ...... ២៥០
អដ្ឋកថាវក្កលិត្ថេរគាថា ...... ...... ...... ...... ២៥១
វិជិតសេនត្ថេរគាថា ...... ...... ...... ...... ២៦៤
អដ្ឋកថាវិជិតសេនត្ថេរគាថា ...... ...... ...... ...... ២៦៥
យសទត្តត្ថេរគាថា ...... ...... ...... ...... ២៧២
អដ្ឋកថាយសទត្តត្ថេរគាថា ...... ...... ...... ...... ២៧៣
សោណកុដិកណ្ណត្ថេរគាថា ...... ...... ...... ...... ២៧៨
អដ្ឋកថាសោណកុដិកណ្ណត្ថេរគាថ ...... ...... ...... ...... ២៧៩
កោសិយត្ថេរគាថា ...... ...... ...... ...... ២៨៦
អដ្ឋកថាកោសិយត្ថេរគាថា ...... ...... ...... ...... ២៨៧

## ថេរគាថា ឆក្កនិបាត

ឧរុវេលកស្សបត្ថេរគាថា ...... ...... ...... ...... ២៩៥
អដ្ឋកថាឧរុវេលកស្សបត្ថេរគាថា ...... ...... ...... ...... ២៩៦
តេកិច្ឆកានិត្ថេរគាថា ...... ...... ...... ...... ៣១០
អដ្ឋកថាតេកិច្ឆការិត្ថេរគាថា ...... ...... ...... ...... ៣១១
មហានាគត្ថេរគាថា ...... ...... ...... ...... ៣១៩
អដ្ឋកថាមហានាគត្ថេរគាថា ...... ...... ...... ...... ៣២០
កុល្លត្ថេរគាថា ...... ...... ...... ...... ៣២៤
អដ្ឋកថាកុល្លត្ថេរគាថា ...... ...... ...... ...... ៣២៥

មាលុង្ក្យបុត្តត្ថេរគាថា ...... ...... ...... ...... ៣៣២

អដ្ឋកថា មាលុង្ក្យបុត្តត្ថេរគាថា ...... ...... ...... ...... ៣៣៣

សប្បទាសត្ថេរគាថា ...... ...... ...... ...... ៣៤០

អដ្ឋកថា សប្បទាសត្ថេរគាថា ...... ...... ...... ...... ៣៤១

កាតិយានត្ថេរគាថា ...... ...... ...... ...... ៣៤៦

អដ្ឋកថា កាតិយានត្ថេរគាថា ...... ...... ...... ...... ៣៤៧

មិគជាលត្ថេរគាថា ...... ...... ...... ...... ៣៥៤

អដ្ឋកថា មិគជាលត្ថេរគាថា ...... ...... ...... ...... ៣៥៥

ជេន្តបុរោហិតបុត្តត្ថេរគាថា ...... ...... ...... ...... ៣៦២

អដ្ឋកថា ជេន្តបុរោហិតបុត្តត្ថេរគាថា ...... ...... ...... ...... ៣៦៣

សុមនត្ថេរគាថា ...... ...... ...... ...... ៣៧០

អដ្ឋកថាសុមនត្ថេរគាថា ...... ...... ...... ...... ៣៧១

ន្ហាតកមុនិត្ថេរគាថា ...... ...... ...... ...... ៣៧៥

អដ្ឋកថាន្ហាតកមុនិត្ថេរគាថា ...... ...... ...... ...... ៣៧៦

ព្រហ្មទត្តត្ថេរគាថា ...... ...... ...... ...... ៣៨០

អដ្ឋកថា ព្រហ្មទត្តត្ថេរគាថា ...... ...... ...... ...... ៣៨១

សិរិមណ្ឌត្ថេរគាថា ...... ...... ...... ...... ៣៨៨

អដ្ឋកថា សិរិមណ្ឌត្ថេរគាថា ...... ...... ...... ...... ៣៨៩

សព្វកាមត្ថេរគាថា ...... ...... ...... ...... ៣៩៦

អដ្ឋកថា សព្វកាមត្ថេរគាថា ...... ...... ...... ...... ៣៩៧


## សុត្តន្តបិដក បាលីប្រែ -៥៧


សុន្ទរសមុទ្ទត្ថេរគាថា ...... ...... ...... ...... ៤០៤

អដ្ឋកថា សុន្ទរសមុទ្ទត្ថេរគាថា ...... ...... ...... ...... ៤០៥

លកុណ្ឌកត្ថេរគាថា ...... ...... ...... ...... ៤១១
អដ្ឋកថា លកុណ្ឌកភទ្ទិយត្ថេរគាថា ...... ...... ...... ...... ៤១២
ភទ្ទត្ថេរគាថា ...... ...... ...... ...... ៤២៤
អដ្ឋកថា ភទ្ទត្ថេរគាថា ...... ...... ...... ...... ៤២៥
សោបាកត្ថេរគាថា ...... ...... ...... ...... ៤៣២
អដ្ឋកថា សោបាកត្ថេរគាថា ...... ...... ...... ...... ៤៣៣
សរភង្គត្ថេរគាថា ...... ...... ...... ...... ៤៤១
អដ្ឋកថា សរភង្គត្ថេរគាថា ...... ...... ...... ...... ៤៤២

## អដ្ឋកនិបាត

មហាកច្ចាយនត្ថេរគាថា ...... ...... ...... ...... ៤៤៩
អដ្ឋកថា មហាកច្ចាយនត្ថេរគាថា ...... ...... ...... ...... ៤៥១
សិរិមិត្តត្ថេរគាថា ...... ...... ...... ...... ៤៦៦
អដ្ឋកថា សិរិមិត្តត្ថេរគាថា ...... ...... ...... ...... ៤៦៧
មហាបន្ថកត្ថេរគាថា ...... ...... ...... ...... ៤៧៤
អដ្ឋកថា មហាបន្ថកត្ថេរគាថា ...... ...... ...... ...... ៤៧៥

## នវកនិបាត

ភូតត្ថេរគាថា ...... ...... ...... ...... ៤៨៤
អដ្ឋកថា ភូតត្ថេរគាថា ...... ...... ...... ...... ៤៨៧

## ទសកនិបាត

កាឡុទាយិត្ថេរគាថា ...... ...... ...... ...... ៤៩៩
អដ្ឋកថា កាឡុទាយិត្ថេរគាថា ...... ...... ...... ...... ៥០២
ឯកវិហារិយត្ថេរគាថា ...... ...... ...... ...... ៥២២

អដ្ឋកថា ឯកវិហារិយត្ថេរគាថា ...... ...... ...... ...... ៥២៣
មហាកប្បិនត្ថេរគាថា ...... ...... ...... ...... ៥៣៤
អដ្ឋកថា មហាកប្បិនត្ថេរគាថា ...... ...... ...... ...... ៥៣៦
ចូឡបន្ថកត្ថេរគាថា ...... ...... ...... ...... ៥៥៦
អដ្ឋកថា ចូឡបន្ថកត្ថេរគាថា ...... ...... ...... ...... ៥៥៧
កប្បត្ថេរគាថា ...... ...... ...... ...... ៥៧៤
អដ្ឋកថា កប្បត្ថេរគាថា ...... ...... ...... ...... ៥៧៥
ឧបសេនវង្គន្តបុត្តត្ថេរគាថា ...... ...... ...... ...... ៥៨៧
អដ្ឋកថា ឧបសេនវង្គន្តបុត្តត្ថេរគាថា ...... ...... ...... ...... ៥៨៨
គោតមត្ថេរគាថា ...... ...... ...... ...... ៦០១
អដ្ឋកថា គោតមត្ថេរគាថា ...... ...... ...... ...... ៦០៣

## ឯកាទសកនិបាត

សង្កិច្ចត្ថេរគាថា ...... ...... ...... ...... ៦១៣
អដ្ឋកថាសង្កិច្ចត្ថេរគាថា ...... ...... ...... ...... ៦១៥

## ទ្វាទសកនិបាត

សីលវត្ថេរគាថា ...... ...... ...... ...... ៦២៤
អដ្ឋកថាសីលវត្ថេរគាថា ...... ...... ...... ...... ៦២៦
សុនីតត្ថេរគាថា ...... ...... ...... ...... ៦៣៨
អដ្ឋកថាសុនីតត្ថេរគាថា ...... ...... ...... ...... ៦៤០

## តេរសកនិបាត

សោណកោឡិវិសត្ថេរគាថា ...... ...... ...... ...... ៦៥០
អដ្ឋកថាសោណកោឡិវិសត្ថេរគាថា ...... ...... ...... ...... ៦៥៣

## ចុទ្ទសកនិបាត

រេវតត្ថេរគាថា ...... ...... ...... ...... ៦៧២
អដ្ឋកថា ខទិរវនិយរេវតត្ថេរគាថា ...... ...... ...... ...... ៦៧៤
គោទត្តត្ថេរគាថា ...... ...... ...... ...... ៦៨៥
អដ្ឋកថា គោទត្តត្ថេរគាថា ...... ...... ...... ...... ៦៨៨

## សោឡសកនិបាត

អញ្ញាកោណ្ឌញ្ញត្ថេរគាថា ...... ...... ...... ...... ៧០១
អដ្ឋកថា អញ្ញាកោណ្ឌញ្ញត្ថេរគាថា ...... ...... ...... ...... ៧០៤
ឧទាយិត្ថេរគាថា ...... ...... ...... ...... ៧២១
អដ្ឋកថា ឧទាយិត្ថេរគាថា ...... ...... ...... ...... ៧២៤